បរមត្ថទីបនី

អដ្ឋកថា - គម្ពីរឧទាន

រចនាដោយព្រះធម្មបាលត្ថេរ

ពុទ្ធសករាជ ២៥៥៦

បរមត្ថទីបនី

អដ្ឋកថា គម្ពីរខ្ទានន

សុត្តន្តបិដក ខុទ្ទកនិកាយ

លេខ ៥២

សេចក្ដីជាភាសាខ្មែរ

ចោះពុម្ពលើកទី ១

ចំនួន ២.០០០ ច្បាប់

ការផ្សាយរបស់ព្រះសង្ឆវត្តបាការនិវេសន៍ កំផែង

ព.ស ២៥៥៦

PARAMATTHATIPANI

(Commentary)

SUTTA-PITAKA

Khuddaka~nikāya

Udāna

Translated from Pali to Khmer

1st Edition 2.000 Copies

A publication

Of

Wat PÀKÀRAKNIVESANÀRÀM KAMPHENG'S MONK

B.E 2556

អារម្ភកថា
របស់ក្រុមប្រែ និងរៀបរៀង

ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វे អគមិត្ថ ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេ-កល្យាណំ បរិយោសានកល្យាណំ សាត្ថं សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធं ព្រហ្មចរិយं បកាសេថ ។ *ប្រែជាខេមរភាសាថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ អ្នកទាំងឡាយ ចូរកុំទៅពីរូបតាមផ្លូវតែ ១ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសម្តែងធម៌ ឱ្យមានលម្អបទដើម បទកណ្តាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់[1] ។ ព្រះពុទ្ធបំណង និងបញ្ជាក់ត្រង់ចំណុចនេះ គឺព្រះដ៏មានព្រះភាគចង់ឱ្យសាវ័ករបស់ព្រះអង្គគ្រប់រូប មានកាតព្វកិច្ចក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា ពោលសំដៅដល់ព្រះធម៌ ជាព្រះពុទ្ធវចនៈ អាចនាំមកនូវសេចក្តីសុខ សេចក្តីចម្រើនសម្រាប់សត្វទាំងឡាយ ។ បើយោងតាមព្រះពុទ្ធបំណងខាងលើនេះ ព្រះធម៌ដែលសម្តែងចេញទៅហើយនោះ នឹងនាំមកនូវសេចក្តីសុខ សេចក្តីចម្រើន លុះត្រាតែអ្នកសម្តែងទាំងឡាយ (ធម្មបកាសនបុគ្គល) ត្រូវសម្តែងឱ្យមានលម្អបទដើម លម្អបទកណ្តាល និងបទចុង ព្រមទាំងប្រកបដោយអត្ថ និងព្យញ្ជនៈបរិបូណ៌ ។ តើអ្វីជាលម្អបទដើម បទ*

១-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ៥៧ ។

កណ្ដាល បទចុង និងប្រកបដោយអត្ថ ព្រមទាំងព្យញ្ជន:? ដើម្បីជ្រាបសេចក្ដីនេះ សូមមិត្តអ្នកសិក្សាទាំងឡាយ ពិចារណាតាមន័យនៃព្រះអដ្ឋកថាចារ្យ និងព្រះដីកាចារ្យ ដែលខ្ញុំនឹងនាំមកពោលដូចតទៅនេះ

អដ្ឋកថាសារត្ថប្បកាសិនី នៃគម្ពីរសំយុត្តនិកាយ ត្រង់ទុតិយមារបាសសូត្រ និងសារត្ថទីបនីដីកា ព្រះវិន័យបានពន្យល់ន័យខ្លះៗរបស់ពុទ្ធបញ្ញាខាងលើនេះ ថា ពាក្យថា ***លម្អខាងដើម*** *សេចក្ដីថា ភាពល្អ ស្អាត ចម្រើន ជាចំណែកខាងដើម ។ ចំណែកកណ្ដាល និងខាងចុងក៏ដូចគ្នា ។ មែនពិត ឈ្មោះថា លម្អបទដើម បទកណ្ដាល និងបទចុង មានពីរប្រការ គឺលម្អដោយសាសន: និងទេសនា ។ បណ្ដាសាសន: និងទេសនានោះ សីលជាខាងដើមនៃសាសនា មគ្គ គឺសមថ: និងវិបស្សនា ជាកណ្ដាលនៃសាសនា ផល និងព្រះនិព្វាន ជាខាងចុងនៃសាសនា ។ ម្យ៉ាងទៀត សីល សមាធិ និងវិបស្សនាជាខាងដើមនៃសាសនា មគ្គជាចំណែកកណ្ដាលនៃសាសនា ផល និងព្រះនិព្វានជាលម្អខាងចុងនៃសាសនា ។ ចំណែកខាងទេសនា បាទទី១ នៃគាថាប្រកបដោយបាទ ៤ ជាលម្អខាងដើមនៃទេសនា បាទទី ២ និងបាទទី ៣ ជាលម្អកណ្ដាលនៃទេសនា បាទទី ៤ ជាលម្អខាងចុងនៃទេសនា ។ ម្យ៉ាងទៀត បាទទី ១ នៃគាថា ប្រកបដោយបាទ ៥ និងបាទ ៦ ជាលម្អខាងដើម បាទទីបំផុតជាលម្អខាងចុង ហើយបាទដ៏សេស ជាលម្អបទកណ្ដាលនៃទេសនា ។ និទានៃព្រះសូត្រដែលមានអនុសន្ធិតែមួយ ជាលម្អខាងដើម ពាក្យថា "**ឥទមវោច** ពាក្យនេះតថាគតបានសម្ដែងហើយ" ជាលម្អខាងចុង បទដ៏សេសជាលម្អបទកណ្ដាល ។ អនុសន្ធិដ៏ច្រើន ត្រង់កណ្ដាលនៃព្រះសូត្រ ដែលមានអនុសន្ធិដ៏អនេក ជាលម្អបទកណ្ដាល និទានជាលម្អបទ*

ដើម ពាក្យថា "**ឥមភេច** ពាក្យនេះតថាគតបានសម្តែងហើយ" ជាលម្អខាងចុង ។ ពាក្យថា ប្រកបដោយអត្ថ បានសេចក្តីថា អ្នកទាំងឡាយ ចូរសម្តែងធម៌ដោយការពន្យល់សេចក្តី ។ ពាក្យថា ព្រមដោយព្យញ្ជនៈ សេចក្តីថា អ្នកទាំងឡាយចូរសម្តែងធម៌ ដោយការធ្វើព្យញ្ជនៈ និងបទឱ្យបរិបូណ៌ ។ ពាក្យថា **បរិសុទ្ធ** គឺប្រាសចាកកិលេស ។ ពាក្យថា **ព្រហ្មចរិយៈ** បានដល់ សាសនព្រហ្មចរិយៈ គឺត្រៃសិក្ខា ។ ពាក្យថា ចូរប្រកាសធម៌ គឺពោលព្រះធម៌ឱ្យមានភាពជាក់ស្តែង ។

ការសិក្សាព្រះពុទ្ធសាសនា ឱ្យបានស៊ីជម្រៅ ត្រូវមានជំហាន និងដំណើរច្បាស់លាស់ ។ ការសិក្សានេះ មានការសិក្សាគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា យោជនា អនុដីកា គណ្ឋីបទ បករណ៍ពិសេស ។ល។ ម្យ៉ាងទៀត អត្ថបទទាំងឡាយជាព្រះពុទ្ធវចនៈ និងសេចក្តីពន្យល់ទាំងឡាយជារបស់ព្រះដ៏មានព្រះភាគក្តី របស់ព្រះសាវកទាំងឡាយ អ្នកយល់ពុទ្ធបំណងក្តី បានត្រូវសរសេរទុកហើយ ដោយភាសាមគធៈ ឬភាសាបាលី ។ ភាសា **បាលី** ជាភាសាមួយដែលមានលក្ខណៈសកល អាចបត់បែនទៅតាមភាសាគ្រប់ភាសាទាំងអស់ក្នុងលោក ។ ភាសាបាលី ឬបាឡី យើងអាចហៅម្យ៉ាងទៀតថា **តន្តិភាសា** ដូច្នេះ ក៏មាន ។ ក៏ព្រោះតែភាសាបាលី ជាភាសាដែលមានក្ជួនច្បាប់ វេយ្យាករណ៍ត្រឹមត្រូវ និងប្រាកដប្រជា ដូច្នេះ ទើបលោកហៅថា **តន្តិភាសា** ។ ដើម្បីឱ្យការសិក្សាព្រះពុទ្ធ-ដីកាបានផលល្អ សិក្ខាកាមជនទាំងឡាយត្រូវតែសិក្សាវេយ្យាករណ៍បាលី ជាថ្នាក់ដំបូង ។ ការមិនសិក្សាវេយ្យាករណ៍បាលី ឱ្យបានប្រាកដច្បាស់លាស់ ជាចំណុចខ្វះខាត់នៃការសិក្សា ព្រះពុទ្ធវចនៈដែលអាចធ្វើឱ្យការសិក្សាមិនអាចយល់ច្បាស់បានល្អ និងមានការសង្ស័យ ។ សមដូចពាក្យដែលព្រះអកយាវាមសាមី

*អ្នករចនាគម្ពីរ**មោគ្គល្លានបញ្ចិកា ដីកា ឈ្មោះ សារត្ថវិលាសិនី** បានពោលថា*

យោ និរុត្តឺ ន សិក្ខេយ្យ សិក្ខ្ជេ្ជ ២ិដកត្តយំ

២េ ២េ ២ិកង្ខ្ជេ្ជ ២ ២ ២ អ ២ ២ ២ យ ២ ។

បុគ្គលណា ការសិក្សាបិដកទាំងបី មិនបានសិក្សានូវនិរុត្តិ គឺបាលីវេយ្យាករណ៍ បុគ្គលនោះ គប្បីមានសេចក្តីសង្ស័យក្នុងបទនោះ១ ដូចដំរីខ្វាក់ដែលធ្វើដំណើរក្នុងព្រៃដូច្នោះដែរ ។

ការនាំយកចំណុចនេះ មកបរិយាយក្នុងអារម្ភកថានេះ គឺគ្រាន់តែមានបំណងឱ្យ មានការលើកកម្ពស់ និងឱ្យតម្លៃក្នុងការសិក្សាភាសាបាលី ឬពុទ្ធភាសាឱ្យមានលក្ខណៈ ទូលំទូលាយ និងការសិក្សាព្រះពុទ្ធវចនៈ ដោយផ្តោតទៅលើគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា អនុដីកា ។ល។ សូមប្រគេន និងចម្រើនពរផងដែរថា ប្រទេសកម្ពុជាយើងធ្លាប់មាន កិត្តិយសក្នុងការបកប្រែគម្ពីរព្រះត្រៃបិដកពីភាសាបាលី មកជាភាសាជាតិ ដោយអ្នក ប្រាជ្ញព្រះពុទ្ធសាសនា ជាបព្វជិត និងគ្រហស្ថ ជាបាលីភាសាវិទូ ធម្មកោវិទូ ។ ការណ៍នេះ ជាមោទនភាពជាតិមួយ ក្នុងឋានៈជាប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា ដោយបានកសាងសមិទ្ធិ-ផលដ៏អស្ចារ្យនេះសម្រាប់មនុស្សជាតិ ។

*គម្ពីរអដ្ឋកថាឈ្មោះ បរមត្ថទីបនី ជាគម្ពីរដែលពន្យល់ន័យព្រះពុទ្ធដីកាក្នុងគម្ពីរ **សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២** ដែលស្ថិតក្នុងព្រះហស្តរបស់ព្រះថេរានុត្តេរគ្រប់អង្គ និងដៃនៃអ្នកសប្បុរសទាំងឡាយ គឺជាវណ្ណកម្មដ៏ល្អឧត្តមប្រពៃរបស់ ព្រះធម្មបាលត្ថេរ ជាអដ្ឋកថាចារ្យ ដីកាចារ្យ អនុដីកាចារ្យដ៏ជំនាញគង់នៅពទរតិត្ថវិហារ ក្នុងទមិឡរដ្ឋ នាប្រទេសឥណ្ឌា ភាគខាងត្បូង*

ប្រហែលក្នុងពុទ្ធសកវាជ ៤៥០-១០០០ ឆ្នាំ[១] ។ ធម្មក្ខន្ធនៃគម្ពីរឧទាននេះ ពោលដោយវគ្គមាន ៨ វគ្គ គឺ**ពោធិវគ្គ មុចលិន្ទវគ្គ នន្ទវគ្គ មេឃិយវគ្គ សោណត្ថេរវគ្គ ជច្ចន្ធវគ្គ ចូឡវគ្គ បាដលិគាមិយវគ្គ** បើពោលដោយសូត្រមាន ៨០ សូត្រ ពោលដោយសង្គហគាថា ជាឧទានគាថា មាន ៤៥ គាថា គឺព្រះធម្ម-បាលត្ថេរបានយកមកអធិប្បាយហើយក្នុងគម្ពីរឈ្មោះ **បរមត្ថទីបនី** នេះ ដោយ សេចក្ដីពិស្តារ[២] ។

គោលបំណងនៃការបកប្រែ និងរៀបចំបោះពុម្ពផ្សាយនូវគម្ពីរនេះគឺ

១- ដើម្បីផ្សព្វផ្សាយព្រះពុទ្ធាវាទឱ្យទូលំទូលាយ ។

២- ផ្ដល់ជាឯកសារសម្រាប់អាន និងសិក្សាស្រាវជ្រាវឱ្យកាន់តែច្រើន ។

៣- ដើម្បីពន្យល់ព្រះពុទ្ធវចនៈតាមវាទៈរបស់ព្រះអរហន្តទាំងឡាយ ជាពុទ្ធមតញ្ញូ

សម្រាប់យកទៅបកស្រាយឱ្យបានត្រឹមត្រូវតាមពុទ្ធអធ្យាស្ស័យ ។

៤- ចូលរួមលើកកម្ពស់អក្សរសាស្ត្រជាតិ តាមរយៈសាសនារបស់ជាតិ ។

៥- ចូលរួមលើកកម្ពស់សីលធម៌ តាមរយៈអត្ថបទសាសនា ។

៦- ផ្ដល់ជាមាគ៌ា សម្រាប់ប្រតិបត្តិធម្មព្រះពុទ្ធសាសនា ។

ដំណើរនៃការបកប្រែ និងរៀបរៀងបោះពុម្ព

- ធ្វើការបកប្រែគម្ពីរបរមត្ថទីបនី មកជាភាសាខ្មែរ ដោយសរសេរជាសំណៅដៃលើ ក្រដាសសៀវភៅព្រៀង ។

- ចម្ងងចូលកុំព្យូទ័រ

- ត្រួតពិនិត្យសារជាថ្មី លើអត្ថបទដើមមាន អត្ថន័យ បទ បាលី អក្ខរៈ

១-សូមនិមន្ត និងអញ្ជើញអានក្នុងទំព័រប្រវត្តិព្រះធម្មបាលត្ថេរ បន្ថែម ។

២-ទិដ្ឋភាពទូទៅនៃគម្ពីរនេះសូមនិមន្ត និងអញ្ជើញអានក្នុងគន្ថារម្ភកថា និងនិគមនកថារបស់ព្រះធម្មបាលត្ថេរ ។

ញ្ញាន: អក្ខរាវិរុទ្ធ និងសម្រួលសេចក្ដីជាភាសាខ្មែរឱ្យងាយយល់ ។

- ផ្ទៀងផ្ទាត់ឡើងវិញដោយប្រើអដ្ឋកថាបរមត្ថទីបនី ភាសាបាលីរបស់ច្បាប់ធម្ម្ដសង្គ្ដាយនា (ភូមា) និងគម្ពីរបរមត្ថទីបនី ភាសាបាលីរបស់មហាមកុដ-រាជវិទ្យាល័យសង្ឆ (ថៃ) ដោយប្រើប្រាស់ព្រះត្រៃបិដកជាភាសាខ្មែរជាគោល និងប្រើប្រាស់វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឆរាជ **ជោតញ្ញាណោ ជួន ណាត** ក្នុងការសរសេរអក្សរ ។ ក្រុមការងារធម្មទាន ក៏បានប្រើប្រាស់ឯកសារដទៃទៀតជាជំនួយក្នុងការបកប្រែ និងរៀបរៀងគម្ពីរនេះ ដូចមានក្នុងឯកសារយោងស្រាប់ ។

ទោះបីការបកប្រែ និងរៀបរៀងព្រមទាំងការកែសម្រួល ដោយហ្មត់ចត់ជាទីបំផុត យ៉ាងណាក៏ដោយ ក៏មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ កំហុសទាំងនោះ អាចកើតឡើងដោយអចេតនាក៏មាន ដោយសមត្ថភាពអ្នកធ្វើមិនទាន់គ្រប់គ្រាន់ក៏មាន ។ ទោះបីជាមានកំហុសខ្លះក៏ដោយ ក៏ក្រុមប្រែ និងរៀបរៀង យល់ឃើញថា ការមានប្រសើរ ជាជាងការមិនមានអ្វីសោះ ។

ព្រោះហេតុនេះ ក្រុមប្រែ និងរៀបរៀងសូមផ្ញើនូវគម្ពីរបរមត្ថទីបនីនេះដល់អ្នក សិក្សា និងអត្ថកោវិទូ បណ្ឌិត កវី ដើម្បីជួយកែសម្រួលកន្ទែងដែលមានកំហុស ហើយក្រុមប្រែ និងរៀបរៀងនឹងយកមកកែលម្អជាថ្មី ក្នុងការបោះពុម្ពលើកក្រោយទៀត ។ ក្រុមប្រែ និងរៀបរៀងសង្ឆឹមយ៉ាងមុតមាំថា អ្នកសប្បុរសទាំងឡាយ នឹងជួយកែសម្រួល ដោយក្ដីអនុគ្រោះជាមិនខាន ។

បាត់ដំបង ថ្ងៃ ១៥ កើត ខែ មាឃ ព.ស២៥៥៦

តំណាងក្រុមប្រែ និងរៀបរៀង

សចូកល្យាណោ មឿន សាមុត

ប្រវត្តិសង្ខេប
ព្រះធម្មបាលត្ថេរ

បណ្តាព្រះអដ្ឋកថាចារ្យទាំងឡាយ ដែលបានរចនាគម្ពីរអដ្ឋកថា ដីកា អនុ-ដីកា..ដើម្បីពន្យល់ព្រះបាលីដែលជាពុទ្ធវចនៈ ជាឧត្តមប្រយោជន៍ដល់វេនេយ្យជនទាំងឡាយ ព្រះធម្មបាលត្ថេរក៏ជាព្រះអាចារ្យមួយអង្គដ៏ឆ្នើម ដែលមានគុណសម្បត្តិ រចនាគម្ពីរ និងបានបន្សល់ទុកនូវវណ្ណកម្មជាច្រើនគួរឱ្យសរសើរ និងគោរពដឹងគុណ ។

ក្រៅពីព្រះសាវ័កល្បីៗ នៃព្រះដ៏មានព្រះភាគ គឺព្រះសារីបុត្ត ព្រះមោគ្គល្លាន ព្រះមហាកស្សបៈ...ដែលមានប្រាកដក្នុងសម័យពុទ្ធកាល ហើយក្រោយពីការបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធជាច្រើនរយឆ្នាំកន្ទងមក ក៏មានសាវ័កល្បីៗជាច្រើនមានឧបការៈក្នុងការទ្រទ្រង់នូវព្រះបរិយត្តិធម៌ និងបន្តការផ្សព្វផ្សាយព្រះពុទ្ធ-សាសនា មានព្រះមហិន្ទត្ថេរ ព្រះពុទ្ធឃោសាចារ្យ ព្រះពុទ្ធទត្តត្ថេរជាដើម ព្រះកិត្តិ-នាមរបស់ព្រះថេរៈត្រូវបានលោកអ្នកប្រាជ្ញទាំងឡាយ យកមកបរិយាយយ៉ាងក្បោះ-ក្បាយ ប៉ុន្តែព្រះកិត្តិនាមរបស់ព្រះធម្មបាលត្ថេរ កម្រនឹងមានឮសម្តែងណាស់ ។ ទោះបីជាព្រះធម្មបាលត្ថេរ បានបន្សល់វណ្ណកម្មដ៏ច្រើនក៏ដោយ ជីវប្រវត្តិរបស់លោកមិនសូវបានឃើញមានអធិប្បាយ និងលើកយកមកសរសេរឡើយ ។

*ដូច្នេះ មុននឹងមិត្តអ្នកសិក្សាព្រះពុទ្ធវចនៈទាំងឡាយ សិក្សាអត្ថបទធម៌ក្នុងគម្ពីរនេះ (**ឋានត្ថទីបនី** គម្ពីរ ឧទាន) សូមគោរពនិមន្ត និងអញ្ជើញអាន និងចងចាំនៅប្រវត្តិរបស់ព្រះគន្ថរចនាចារ្យអង្គនេះ ។ ព្រះធម្មបាលត្ថេរ ប្រសូតនៅពទរតិត្ថៈ ក្នុងទមិឡរដ្ឋ នាប្រទេសឥណ្ឌា ភាគខាងត្បូង ប្រហែលក្នុងពុទ្ធសករាជ ៩៥០-១០០០ ឆ្នាំ ។ ក្នុងវចនានុក្រម* Dictionary of Pali Proper Names *បានប្រាប់យើងថា "ព្រះថេរៈជាជនជាតិ កាញ្ចិបុរៈ និងបានសិក្សាក្នុងមហាវិហារ ដោយសារមានប្រាកដក្នុងសេចក្តីផ្តើម*

នៃអដ្ឋកថាបេត្តវត្ថុ" ។ នៅក្នុងនិគមនកថារបស់គម្ពីរនេត្តិប្បករណ-អដ្ឋកថា បានពណ៌នា ថា ព្រះថេរៈគង់នៅវិហារមួយជិតនាគាបដ្ឋនៈ ដែលកសាងដោយព្រះបាទអសោក-មហារាជ ។ ក្នុងគម្ពីរសាសនវង្សរបស់ព្រះបញ្ញាសាមិត្ថេរ បានពោលថា "ព្រះធម្មបាល- ត្ថេរ គង់នៅពទរតិត្ថៈ ក្នុងទមិឡរដ្ឋ ជិតសីហឡទ្វីប (កោះស្រីលង្កា) ។ ក្នុងគម្ពីរសត្ថុ- សាសនកថា ទំព័រ ៧០ បាននិយាយថា **ឧក្ខិណ្ណាឥន្ទ្រិយរដ្ឋេ កាញ្ចិបុរជាតិកោ ពទរតិត្ថវិហារវាសិនា អាចរិយធម្មបាលត្ថេរេន បរមត្ថទីបនី នាម ឧទានស្ស អដ្ឋកថំ កេនចិបិ អនាយាចិតោ អត្តនោ ឥច្ឆាវសេនេវ អកាសិ** *ប្រែថា គម្ពីរ អដ្ឋកថា* **ឧទាន** *ឈ្មោះ* ***បរមត្ថទីបនី*** *ដែលព្រះអាចារ្យនាម ធម្មបាលត្ថេរ កើតក្នុងកាញ្ចិបុរី ក្នុងទក្ខិណឥន្ទ្រិយរដ្ឋ មានប្រក្រតីគង់នៅពទរតិត្ថវិហារ បានរចនាឡើងតាមសេចក្តីប្រាថ្នា របស់ខ្លួន ដោយមិនមានអ្នកណាអាវាធនាទេ ។ តាមមតិរបស់លោកបណ្ឌិតសាស្ត្រាចារ្យ រីដស៍ ដេវីដស៍ ស្ថាបនិកនៃសមាគមអត្ថបទភាសាបាលី មានប្រសាសន៍ថា ព្រះធម្មបាលត្ថេរ អាចសិក្សាក្នុងសំណាក់នៃព្រះពុទ្ធទត្តត្ថេរ ព្រោះអត្ថបទមានសេចក្តី អធិប្បាយក្នុងសៀវភៅរបស់ព្រះថេរៈទាំងពីរអង្គស្រដៀងគ្នាច្រើន ។*

ស្នាព្រះហស្តរបស់ព្រះធម្មបាលត្ថេរមានដូចខាងក្រោមនេះ

១-នេត្តិបករណ-អដ្ឋកថា[១] តាមការអាវាធរបស់ព្រះធម្មរក្ខិតត្ថេរ

១-មូលបាលីនៃគម្ពីរនេះឈ្មោះថា គម្ពីរនេត្តិ ឬនេត្តិបករណ៍ គឺជាប្រភេទគម្ពីរព្រះពុទ្ធសាសនាដ៏ចំណាស់ មួយផងដែរ ហើយក្នុងសម័យកាលខ្លះ គម្ពីរនេះត្រូវបានគេរាប់បញ្ចូលក្នុងខុទ្ទកនិកាយ សុត្តន្តបិដក ពិសេសក្នុងកាលធ្វើសង្គាយនាលើកទីប្រាំនៅប្រទេសកូមា ។ នៅប្រទេសកូមា គម្ពីរឈ្មោះ នេត្តិបករណៈ ត្រូវបានគេចាត់ទុកថា ជាអត្ថបទព្រះត្រៃបិដក ដោយអ្នកដឹកនាំសង្ឆជាង ២.០០០ ឆ្នាំមកហើយ នឹងត្រូវយកមកសង្គាយនាចំនួនពីរដង ក្នុងប្រទេសកូមា គឺសង្គាយនាលើកទី ៥ និងលើកទី ៦ ។ ក្នុងចាប់ឆដ្ឋសង្គាយនា គម្ពីរនេត្តិ ឬនេត្តិបករណៈ បានបរិយាយថា គម្ពីរនេះ បាន

---

*បែងចែកជាមូលបាលី មានឈ្មោះថា គម្ពីរនេត្តិបករណៈ អដ្ឋកថាមានឈ្មោះ នេត្តិបករណដ្ឋកថា រចនាដោយព្រះធម្មបាលត្ថេរ ដីកាមានពីរ គឺនេត្តិប្បករណដីកា រចនាដោយព្រះធម្មបាលត្ថេរ និង នេត្តិវិភាវិនី រចនាដោយព្រះថេរៈដែលទទួលរាជទិន្ននាមថា សទ្ធម្មបាលសិរិមហាធម្មរាជគុរु សញ្ជាតិ ភូមា និងដីកាមួយទៀត ឈ្មោះថា នេត្តិអកិនវដីកា ដែលរចនាដោយព្រះថេរៈព្រះនាម ញាណាកិរ៉ៃ ធម្មសេនាបតិ សញ្ជាតិភូមា ។ នៅក្នុងគម្ពីរចុល្លគន្ធវង្ស បានពោលថា គម្ពីរនេត្តិនេះ មានគណ្ឌីបទ មួយ ឈ្មោះថា នេត្តិបករណគណ្ឌិ តែក្នុងគម្ពីរដដែលនោះ មិនបានប្រាប់ថា រចនាឡើង ដោយព្រះថេ រៈអង្គណាឡើយ ។ បើយោងតាមសៀវភៅ ឈ្មោះថា THE GUIDE ជាសេចក្ដីប្រៃ របស់គម្ពីរនេត្តិបករ ណៈជាភាសាអង់គ្លេស ដែលបកប្រែដោយព្រះកិក្ខុ ញាណមោលី និងបោះពុម្ពផ្សាយដោយសមាគម អត្ថបទភាសាបាលី (Pali Text Society) នៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស បោះពុម្ពក្នុងឆ្នាំ ១៩៧៧ បានបរិយាយក្នុងសេចក្ដីផ្ដើមរបស់លោកថា គម្ពីរនេះមានបួនប្រភេទ គឺមួយច្បាប់បោះពុម្ពជាអត្ថបទ រ៉ូមាំង មួយច្បាប់ទៀត ជាអត្ថបទសីហឬ:របស់ភោះលង្ការ និងពីរ ច្បាប់ទៀតជាអត្ថបទភូមា ។ តាម ដំណើរតគ្នាមកថា គម្ពីរនេត្តិបករណៈនេះ ជាសមិទ្ធិផល នៃបឋមសង្គាយនា ក្នុងឆ្នាំ ៤៨៣ មុន គ.ស នេះបើតាមការសិក្សាវិភាគរបស់អ្នកប្រាជ្ញបច្ចិមប្រទេស និងប្រហែលជា ៦០ ឆ្នាំមុនកាលបរិច្ឆេទនោះ នេះបើតាមការគណនារបស់អ្នក ប្រាជ្ញសីហឬ: ។ ប៉ុន្តែ ក៏មានអ្នកប្រាជ្ញអ៊ីរ៉ុបបច្ចុប្បន្នមួយចំនួន មិន យល់ស្របតាមការស្រាវជ្រាវនេះផងដែរ ។ តាមការសន្និដ្ឋានទូទៅគម្ពីរនេះ ត្រូវបានគេរចនាឡើង មុនសតវត្សរ៍ទី ៥ នៃគ.ស ។ ចំណែកព្រះថេរៈ អ្នក រចនាគម្ពីរមានឈ្មោះប្រាកដថា **ព្រះមហាកច្ចាយនៈ** ព្រោះមានបាលីជាគោលអាងក្នុងគម្ពីរនេត្តិបករណ៍នេះថា **នេត្តិ យា អាយស្មតា មហាកច្ចាយ នេន ភាសិតា ភគវតា អនុមោទិតា មូលសង្ខ្លីតិយំ សង្ខ្លីតាតិ** ប្រែថា គម្ពីរឈ្មោះនេត្តិនេះ គឺព្រះ មហាកច្ចាយនៈដ៏មានអាយុ បានពោលហើយ ដែលព្រះមានព្រះភាគ ព្រះអង្គបានពោលអនុមោទនា និងឡើងកាន់មូលសង្គាយនា(មហាបឋមសង្គាយនា) ។ មានពត៌មានមួយទៀតបានពណ៌នាថា គម្ពីរ នេត្តិប្បករណ៍នេះ រចនាដោយព្រះមហាកច្ចាយនៈ ដែលត្រូវបានព្រះសម្មាសម្ពុទ្ធ តែងតាំងក្នុង ដំណែងជាឯតទគ្គ: ។ នៅក្នុងគម្ពីរចុល្លគន្ធវង្ស រចនាដោយព្រះនន្ទប្បញ្ញាត្ថេរ មានសេចក្ដីម្យ៉ាងទៀត ពោលថា ** កតមេ តិវិធ ជាមាចរិយា មហាកច្ចាយនោ តិវិធជាមំ ។ កតមេ ឥមេ មហាក-ច្ចាយនេន ភាសិតា? ភគ្ចាយនកន្ដោ មហានិរុត្ដិកន្ដោ ចុល្ដនិរុត្ដិកន្ដោ យមកកន្ដោ នេត្ដិ**

២-ឥត្តិវុត្តក អដ្ឋកថា ឈ្មោះ បរមត្ថទីបនី
៣-ឧទាន អដ្ឋកថា ឈ្មោះ បរមត្ថទីបនី
៤-ចរិយាបិដក អដ្ឋកថា ឈ្មោះ បរមត្ថទីបនី
៥-ថេរគាថា អដ្ឋកថា ឈ្មោះ បរមត្ថទីបនី
៦-ថេរីគាថា អដ្ឋកថា ឈ្មោះ បរមត្ថទីបនី
៧-វិមានវត្ថុ អដ្ឋកថា ឈ្មោះ បរមត្ថទីបនី
៨-បេតវត្ថុ អដ្ឋកថា ឈ្មោះ បរមត្ថទីបនី
៩-បរមត្ថមញ្ជូសាមហាដីការិសុទ្ធិមគ្គ តាមការអាវាធរបស់ព្រះទាឋត្ថេរ
១០-ទីឃនិកាយ ដីកា ឈ្មោះ លីនត្ថប្បកាសនី
១១-មជ្ឈិមនិកាយ ដីកា ឈ្មោះ លីនត្ថប្បកាសនី
១២-សំយុត្តនិកាយ ដីកា ឈ្មោះ លីនត្ថប្បកាសនី
១៣-អនុដីកានៃគម្ពីរអភិធម្មដ្ឋកថា

ឌ្ឍោ បេដកោបទេសកឌ្ឍោតិ ឥមេ ឆ ឥមា មហាកច្ចាយនេន ឥតា ។ ប្រែថា ព្រះអាចារ្យអង្គណា មាននាមបីយ៉ាង គឺព្រះមហាកច្ចាយនៈ មានព្រះនាមបីយ៉ាង (គឺបោរាណាចារ្យ ១ អដ្ឋកថាចារ្យ ១ គន្ថការកាចារ្យ១) ។ តើ ព្រះមហាកច្ចាយនៈ បានរចនាគម្ពីរប៉ុន្មាន? ព្រះមហាកច្ចាយនៈ បានកសាងគម្ពីរប្រាំមួយប្រភេទ គឺកច្ចាយនៈ ១ មហានិរុត្តិ ១ ចុល្លនិរុត្តិ ១ យមកៈ១ នេត្តិ ឬនេត្តិប្បករណ៍ ១ បេដកោបទេស ១ ។ បើយោងតាមសេចក្តីកន្ទែងនេះ ព្រះមហាកច្ចាយនៈ ដែលបានរចនាគម្ពីរនេត្តិប្បករណ៍នេះ មិនមែនជា ព្រះមហាកច្ចាយនៈ ដែលព្រះមានព្រះភាគតែងតាំងក្នុងដំណែងជាឯតទគ្គបុគ្គលក្នុងសម័យពុទ្ធកាលឡើយ ។ ប្រហែលជាព្រះថេរៈខាងក្រោមមកទេ តែមានព្រះនាមដូចគ្នានឹងព្រះមហាកច្ចាយនៈជាន់ដើម ។ ចំណែកសម្តេចព្រះសង្ឆរាជ **ដោតញ្ញាណោ ជួន ណាត** បានព្រះរាជចំណារទុកក្នុងវចនានុក្រម ខ្មែរថា **កច្ចាយនៈ** នាមព្រះមហាថេរៈមួយអង្គ ជាអ្នកតែងក្បួនវេយ្យាករណ៍បាលីសម័យជាន់ដើម ។

១៤-ដីកានៃនេត្តិបករណដ្ឋកថា

១៥-ដីកានៃគម្ពីរពុទ្ធវំសដ្ឋកថា

១៦-ដីកានៃគម្ពីរជាតកដ្ឋកថា

ក្នុងគម្ពីរចូឡគន្ថវង្សបានសម្តែងថា ធម្មចាលាចរិយោ នេត្តិប្បការណដ្ឋ-កថា, ឥតិវុត្តកដ្ឋកថា, ឧទានដ្ឋកថា, ចរិយាបិដកដ្ឋកថា, ថេរគាថដ្ឋកថា, ថេរីគាថដ្ឋកថា, វិមានវត្ថុស្ស វិមលវិលាសិនិ ជាម អដ្ឋកថា, បេតវត្ថុស្ស វិមលវិលាសិនិ ជាម អដ្ឋកថា, វិសុទ្ធិមក្គស្ស បរមត្ថមញ្ជូសា ជាម ដីកា, ឌីឃនិកាយស្ស អដ្ឋកថាឌីនំ ចតុន្នំ អដ្ឋកថានំ លីនត្ថប្បកាសនិ ជាម ដីកា, ជាតកដ្ឋកថាយ លីនត្ថប្បកាសនិ ជាម ដីកា, នេត្តិបករណដ្ឋ-កថាយ ដីកា, ពុទ្ធវំសដ្ឋកថាយ បរមត្ថឌីបនី ជាម ដីកា, អភិធម្មដ្ឋកថាយដីកា លីនត្ថវណ្ណនា ជាម អនុដីកាតិ ឥមេ ចុទ្ទស មត្តេ ឥន្ទ អកាសិ ។ *ប្រែថា ព្រះធម្ម-បាលាចារ្យ បានរចនាគម្ពីរ ត្រឹមតែ ១៤ មុខប៉ុណ្ណោះ គឺ អដ្ឋកថា នេត្តិប្បករណ, អដ្ឋកថា ឥតិវុត្តក, អដ្ឋកថា ឧទាន, អដ្ឋកថា ចរិយាបិដក, អដ្ឋកថា ថេរគាថា, អដ្ឋកថា ថេរីគាថា, អដ្ឋកថា វិមានវត្ថុ ឈ្មោះ វិមលវិលាសិនី, អដ្ឋកថា បេតវត្ថុ ឈ្មោះ វិមលវិលាសិនី, បរមត្ថ-មញ្ជូសា មហាដីកាវិសុទ្ធិមគ្គ, លីនត្ថប្បកាសិនី ដីកានៃ អដ្ឋកថាទាំងបួន មានអដ្ឋកថា ទីឃនិកាយជាដើម, លីនត្ថប្បកាសីនី ដីកានៃអដ្ឋកថារបស់ គម្ពីរជាតក, ដីកានៃនេត្តិបករ-ណដ្ឋកថា, បរមត្ថទីបនី ដីកានៃអដ្ឋកថារបស់គម្ពីរពុទ្ធវង្ស, លីនត្ថវណ្ណនា អនុដីកា នៃ ដីការបស់អដ្ឋកថាគម្ពីរអភិធម្ម ។ ប៉ុន្តែក្នុងគម្ពីរសាសនវង្ស បានសម្តែងថា* ឥតិវុត្តោ-ជាតចរិយាបិដកថេរគាថេរីវិមានវត្ថុបេតវត្ថុនេត្តិ-អដ្ឋកថាយោ អាចរិយធម្ម-លត្ថេ អកាសិ ។ សោ ច អាចរិយធម្មចាលត្ថេ សីហឬឌីបស្ស សមីបេ ឧមិលរដ្ឋេ ពនតិត្ថម្ហិ និវាសិតត្តា សីហឬឌីបេ យេវ សង្ខ្យេ ហេត្វា វត្ត ។

វិសុទ្ធិមគ្គស្ស មហាដីកំ ទីឃនិកាយដ្ឋកថាយ ដីកំ មជ្ឈិមនិកាយ-ដ្ឋកថាយ ដីកំ សំយុត្តនិកាយដ្ឋកថាយ ដីកញ្ចាតិ ឥមាយោ អាចរិយធម្ម-ចាលត្ថេរោ អកាសិ ។ សារត្ថទីបនី នាម វិនយដីកំ អង្គុត្តរនិកាយដីកញ្ច បរ-ក្កមពាហុរញ្ញោ យាចិតោ សារិបុត្តត្ថេរោ អកាសិ ។ អនុដីកំ បន អាចរិយ-ធម្មចាលត្ថេរោ ។ សា ច មូលដីកាយ អនុត្តាន-ត្ថានិ ឧត្តានានិ សំវណ្ណិតត្តា អនុដីកាតិ វុច្ចតិ ។ *ប្រែថា ព្រះអាចារ្យ ធម្មបាលត្ថេរ បានរចនាអដ្ឋកថាគម្ពីរឥតិវុត្តក, ឧទាន, ចរិយាបិដក, ថេរគាថា, ថេរីគាថា, វិមានវត្ថុ, បេតវត្ថុ, និងនេត្តិករណដ្ឋកថា ។ ព្រះអាចារ្យធម្មបាលអង្គនេះ លោកបានពោលថា គង់ក្នុងសីហឡទ្វីប ព្រោះលោកអាស្រ័យនៅពទរតិត្ថវិហារ ទមិឡរដ្ឋ ក្បែរ សីហឡទ្វីប ។ ព្រះ ធម្មបាលត្ថេរ បានរចនាដីកាទាំងឡាយនេះ គឺមហាដីកា វិសុទ្ធិមគ្គ, ដីកានៃអដ្ឋកថាទីឃនិកាយ, ដីកានៃអដ្ឋកថាមជ្ឈិមនិកាយ, ដីកានៃអដ្ឋកថា សំយុត្តនិកាយ ។ ម្យ៉ាងទៀត ព្រះសារីបុត្តត្ថេរ ដែលព្រះរាជា ព្រះនាម បរក្កមពាហុ អារាធនា បានរចនាដីកាព្រះវិន័យ ឈ្មោះសារត្ថទី-បនី និងដីកានៃអដ្ឋកថា អង្គុត្តរនិកាយ (សារត្ថមញ្ជូសា) ។ ប៉ុន្តែថា ព្រះធម្មបាលត្ថេរ បានរចនាអនុដីកាមួយ ។ គម្ពីរនោះ ត្រូវបានគេហៅថា អនុដីកា ព្រោះព្រះធម្មបាលត្ថេរ បានពណ៌នាដើម្បីពន្យល់ គម្ពីរមូលដីកា ឱ្យមានន័យរាក់ ងាយស្តាប់ ស្រួលយល់ ។*

<u>សូមបញ្ជាក់ថា</u> *ដីកាសារត្ថមញ្ជូសា ដីកានៃគម្ពីរអង្គុត្តរដ្ឋកថា បានរចនាដោយ ព្រះសារីបុត្តត្ថេរ ក្នុងពុទ្ធសតវត្ស ទី ១២ ។*

បាត់ដំបង, ថ្ងៃ ១៥ កើត ខែ មាឃ ព.ស ២៥៥៦

ធម្មរក្ខិតភិក្ខុ ឡុង កុសល

បត្តិទានវចនៈ

ដោយអំណាចនៃការខិតខំប្រឹងប្រែងបកប្រែ និងរៀបរៀងគម្ពីរ ***បរមត្ថទីបនី អដ្ឋកថា ឧទាន*** *នៃគម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយ លេខ ៥២ ដោយវីរិយភាពនៃធម្មៈ ក្នុងការដ៏ឧត្តមធម្មទានដ៏ឧត្តមនេះ*

-សូមបូជាចំពោះគុណព្រះរតនត្រៃ ដែលជាកែវដ៏ប្រសើរដោយសេចក្ដីគោរព ។

-សូមបូជាចំពោះព្រះធម្មសង្គាហាចារ្យ ព្រះអដ្ឋកថាចារ្យ ព្រះដីកាចារ្យ ព្រះអនុដីកាចារ្យ ព្រះគន្ថរចនាចារ្យ ព្រះគណ្ឋីបទាចារ្យ ព្រះបុរាណាចារ្យ ព្រះវេយ្យាករណាចារ្យទាំងឡាយ ដែលមានឧបការៈក្នុងការថែរក្សាទុកនូវពុទ្ធវចនៈមកដល់សព្វថ្ងៃ ។

-សូមឧទ្ទិសនូវព្រះរាជកុសលនេះ ថ្វាយចំពោះសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឆរាជគណៈមហានិកាយ **ជោតញ្ញាណោ ជួន ណាត** *ជាព្រះបិតាខាងអក្សរសាស្ត្រខ្មែរ ។*

-សូមឧទ្ទិសថ្វាយព្រះអតីតសម្ដេច និងសម្ដេចព្រះសង្ឆរាជគ្រប់ព្រះអង្គ ។

-សូមឧទ្ទិសថ្វាយ ប្រគេន ជួន ព្រះរាជកុសល និងកុសលដ៏មហាប្រសើរនេះ ចំពោះសង្ខ្ដីតិកាចារ្យជាតិគ្រប់ព្រះអង្គ និងរូប ដែលមានគុណូបការៈក្នុងការបកប្រែរៀបចំបោះពុម្ព ព្រះត្រៃបិដកជាភាសាខ្មែរ ។

-សូមឧទ្ទិសថ្វាយព្រះរាជកុសល ចំពោះព្រះករុណា ព្រះបាទសម្ដេច **ព្រះនរោត្តម សីហនុ** *ព្រះមហាវីរក្សត្រ* ***ព្រះបរមរតនកោដ្ឋ*** *។*

-សូមឧទ្ទិសថ្វាយព្រះរាជកុសល ចំពោះអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ៗ ព្រះអង្គ ។

-សូមថ្វាយព្រះរាជកុសល ចំពោះសម្ដេចព្រះសង្ឆរាជទាំងពីរគណៈ

-សូមថ្វាយ និងប្រគេន ព្រះរាជកុសល និងកុសលចំពោះសម្ដេចព្រះសង្ឆនាយក ព្រះសង្ឆនាយករង និងព្រះថេរានុត្ថេរៈគ្រប់ៗ ព្រះអង្គ ។

-សូមប្រគេនកុសលចំពោះព្រះវិសុទ្ធិវង្ស **អ៊ុក មុត** *រាជគណៈថ្នាក់កិត្តិយស និងជាព្រះមេគណខេត្តបាត់ដំបង ត្រូវជាព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណាទាំងឡាយ*

-សូមថ្វាយព្រះរាជកុសល ចំពោះព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា*

-សូមថ្វាយព្រះរាជកុសល សម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** *ព្រះវររាជមាតា ជាតិខ្មែរ ក្នុងសេរីភាព សេចក្តី ថ្លៃថ្នូ និងសុភមង្គល ព្រមទាំងព្រះរាជវង្សានុវង្ស ។*

-សូមជូនចំពោះ ប្រមុខរាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់

-សូមឧទ្ទិសជូនចំពោះមាតាបិតា និងគ្រូឧបជ្ឈាយាចារ្យនៃយើងខ្ញុំទាំងអស់

-សូមជូនលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស**

-សូមជូនលោកគ្រូធម្មបណ្ឌិត **រស់ សុផាត**

-សូមជូនលោកគ្រូវិនយាចារ្យ **គាំ អ៊ីវ**

-សូមជូនលោកគ្រូធម្មាចារ្យ (ឧក្ខុប្បញ្ញោ) **អ៊ឿ សៅ**

-សូមជូនចំពោះពុទ្ធបរិស័ទទាំងក្នុងប្រទេស និងក្រៅប្រទេស

-និងជូនដល់សព្វសត្វក្នុងត្រៃភពទាំងអស់.....។

សូមទ្រង់ត្រេកអរ និងត្រេកអរអនុមោទនា យកនូវចំណែកធម្មទាន ដែលផុសឡើងពីសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រៃ និងវីរិយភាពក្នុងការងារធម្មទាននេះ ឱ្យបានគ្រប់ៗ ព្រះអង្គ គ្រប់ៗ រូប គ្រប់ៗ គ្នា កុំបីអាក់ខានឡើយ ។

ចិរំ តិដ្ឋតុ សទ្ធម្មោ កាលេ វស្សំ ចិរំ បជំ
តប្ប៑ តុ ទេវោ ជម្ម៑ ជ ជា រក្ខ តុ មេ ជ ជ ជ ជ

សូមព្រះសទ្ធម្ម ស្ថិតនៅអស់កាលយូរ
សូមទេវតាបង្អុរភ្លៀងដល់សត្វ តាមសមគួរដល់កាល អស់កាលយូរ
សូមព្រះរាជាគ្រប់គ្រងផែនដីប្រកបដោយធម៌ ។

សូមអនុមោទនានូវធម្មទាន....

ក្រុមប្រែ និងរៀបរៀង

១-ព្រះមហាសង្ឆកល្យាណោ **មឿន សាមុត** សមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង

២- ធម្មរក្ខិតភិក្ខុ **ឡុង កុសល**

៣-ភិក្ខុរតនឃោសកោ **យឹន យ៉ាឆ** វត្តបាការនិវេសន៍ ហៅវត្តកំផែង

៤-ភិក្ខុរក្ខិតមនោ **ឈុន សុវណ្ណ:** សមណសិស្សនៃពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង ខេត្ត បាត់ដំបង

៦-ព្រះមហាចន្ទសេនោ **សុ៊ិម សុឈុំ** សមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះ សីហនុរាជ ភ្នំពេញ

៧-ព្រះមហាគម្ភីរវិជ្ជោ **ណៃប ស៊ីណា** សមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង

៨-ឧបាសក **ញ៉ូយ សារ៉ាត់** និស្សិតនៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង

អ្នកពិនិត្យអក្ខរាវិរុទ្ធ

១-ព្រះមហាសង្ឆកល្យាណោ **មឿន សាមុត**

២-ព្រះភិក្ខុសមថានុរត្តោ **ពេជ្ជ សៀក** ជាធម្មាចារ្យ និងជាសមណសិស្សនៃ ពុទ្ធិក វិទ្យាល័យ អ៊ឹង ធួង ខេត្តបាត់ដំបង

៣-ធម្មរក្ខិតភិក្ខុ **ឡុង កុសល**

៤-ភិក្ខុរតនឃោសកោ **យឹន យ៉ាឆ**

៥-ភិក្ខុរក្ខិតមនោ **ឈុន សុវណ្ណ:**

៦-ព្រះមហាចន្ទសេនោ **សុ៊ិម សុឈុំ**

៧-ព្រះមហាគម្ភីរវិជ្ជោ **ណៃប ស៊ីណា**

៨-លោក **ស្ងួន ប៊ុនឿន** ជាសាស្ត្រាចារ្យភាសាបាលី នៃពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង និងជាប្រធានមន្ទីរធម្មការ និងសាសនា ខេត្តបាត់ដំបង ។

៩-លោកគ្រូធម្មាចារ្យ **ហាយ ចំរើន** បាត់ដំបង

១០-ឧបាសក **ញ៉ូយ សារ៉ាត់**

អ្នកជួយកិច្ចការធម្មទាន

១-ព្រះតេជគុណ **ញាណសរណោ ឃឿប ឫទ** និងពុទ្ធបរិស័ទ វត្តធម្មសាមគ្គី ប្រទេសអូស្ត្រាលី

២-ព្រះតេជគុណ **នេតុបណ្ឌិតោ គឿន ឫទ** ចៅអធិការ វត្តបាការនិវេសន៍ កំផែង

៣-ព្រះតេជគុណ **សមថានុរក្ខោ ពេជ្រ សៀក**

៤-ព្រះតេជគុណ **ចន្ទជោតោ លឿម សុភាព** គ្រូធម្មាចារ្យ វត្តភ្នំជញ្ជាំង

៥-លោកគ្រូធម្មាចារ្យ **ទក្ខប្បញ្ញោ អឿ សៅ** និងពុទ្ធបរិស័ទ វត្តសន្សំកុសល មានឧបាសិកា **លីម៉ូលីន ស៊ីមម៉ូ** ជាដើម (U.S.A)

៦-លោកគ្រូធម្មាចារ្យ **ហាយ ចំរើន** ក្រុងបាត់ដំបង

៧-ឧបាសិកា **ម៉ាង ស៊ុន** និងបុត្រ ក្រុងបាត់ដំបង

៨-ឧបាសិកា **តាំង ប៉ោជឹង** ហៅ**ឧបាសិកា ទន់** និងបុត្រ ក្រុងបាត់ដំបង

៩-លោក **គឹម សោភ័ណ** និងភរិយា ព្រមទាំងបុត្រ ក្រុងកំពត

១០-ឧបាសក **ធី រ៉ាន់** និងឧបាសក **គឹង សំបូរ** ខេត្តបាត់ដំបង

១១-ឧបាសិកា **យឹម ជូរ** និងបុត្រ ខេត្តបន្ទាយមានជ័យ

១២-ទាយិកា **សឹម សុខឡី** ខេត្តបន្ទាយមានជ័យ

១៣-ឧបាសក **ចេត ចេង** ឧបាសិកា **ឆក ភ្ជូឡាប** និងពុទ្ធបរិស័ទ ប្រទេសបារាំង

១៤-ឧបាសក **ឡុង សយ** ឧបាសិកា **ឯក ប៊ុនណា** និងពុទ្ធបរិស័ទ(U.S.A)

១៥-ឧបាសិកា **ភៅ គឹមលន់** និងពុទ្ធបរិស័ទ(U.S.A)

១៦-បងស្រី **ឈុំ សារ៉ែម** និងពុទ្ធបរិស័ទ ប្រទេសកាណាដា

អ្នករចនាក្រុម

១-ភិក្ខុសច្ចលក្ខាណោ **ម្ងឿន សាមុត**

២-ភិក្ខុរតនឃោសកោ **យ៉ីន យ៉ាឥ**

៣-ឧបាសក **ម៉ុន ភិរម្យ**

មាតិកាធម៌

មាតិកា	**ទំព័រ**
គន្ថារម្ភកថា	១
១-ពោធិវគ្គោ ពោធិវគ្គទី ១	**១១**
អដ្ឋកថា បឋមពោធិសូត្រទី ១	១១
អដ្ឋកថា ទុតិយពោធិសូត្រទី ២	៨៧
អដ្ឋកថា តតិយពោធិសូត្រទី ៣	១០១
អដ្ឋកថា អជបាលនិគ្រោធសូត្រទី ៤	១០៧
អដ្ឋកថា ជេរសូត្រទី ៥	១១៥
អដ្ឋកថា មហាកស្សបសូត្រទី ៦	១២៣
អដ្ឋកថា ជ្ជាវាសូត្រទី ៧	១៣៣
អដ្ឋកថា សង្ខ្លាមជិសូត្រទី ៨	១៤៥
អដ្ឋកថា ជដិលសូត្រទី ៩	១៥៣
អដ្ឋកថា ពាហិយសូត្រទី ១០	១៥៩
២-មុចូលិន្ទវគ្គោ មុចូលិន្ទវគ្គទី ២	**១៩៩**
អដ្ឋកថា មុចូលិន្ទសូត្រទី ១	១៩៩
អដ្ឋកថា រាជសូត្រទី ២	២០៥
អដ្ឋកថា ទណ្ឌសូត្រទី ៣	២២១
អដ្ឋកថា សក្ការសូត្រទី ៤	២២៤
អដ្ឋកថា ឧបាសកសូត្រទី ៥	២៣១
អដ្ឋកថា គព្ភិនីសូត្រទី ៦	២៣៥
អដ្ឋកថា ឯកបុត្តសូត្រទី ៧	២៣៩
អដ្ឋកថា សុប្បវាសាសូត្រទី ៨	២៤៥
អដ្ឋកថា វិសាខាសូត្រទី ៩	៣១៥
អដ្ឋកថា ភទ្ទិយសូត្រទី ១០	៣២១

៣-ជន្ធវក្តោ ឆន្ទវគ្គទី ៣ ..... ៣៣១

អដ្ឋកថា កម្មវិបាកជសូត្រទី ១ ..... ៣៣១

អដ្ឋកថា ឆន្ទសូត្រទី ២ ..... ៣៣៧

អដ្ឋកថា យសោជសូត្រទី ៣ ..... ៣៥៩

អដ្ឋកថា សារីបុត្តសូត្រទី ៤ ..... ៣៧៩

អដ្ឋកថា កោលិតសូត្រទី ៥ ..... ៣៨៣

អដ្ឋកថា បិលិន្ទវច្ឆសូត្រទី ៦ ..... ៣៨៩

អដ្ឋកថា មហាកស្សបសូត្រទី ៧ ..... ៣៩៥

អដ្ឋកថា បិណ្ឌបាតសូត្រទី ៨ ..... ៤០៨

អដ្ឋកថា សិប្បសូត្រទី ៩..... ៤១៣

អដ្ឋកថា លោកសូត្រទី ១០ ..... ៤១៩

៤-មេឃិយវក្តោ មេឃិយវគ្គទី ៥ ..... ៤៣៩

អដ្ឋកថា មេឃិយសូត្រទី ១ ..... ៤៣៩

អដ្ឋកថា ឧទ្ទតសូត្រទី ២ ..... ៤៧៩

អដ្ឋកថា គោបាលសូត្រទី ៣ ..... ៤៨៥

អដ្ឋកថា យក្ខបហារសូត្រទី ៤ ..... ៤៩៣

អដ្ឋកថា នាគសូត្រទី ៥ ..... ៥០១

អដ្ឋកថា បិណ្ឌោលសូត្រទី ៦ ..... ៥០៩

អដ្ឋកថា សារីបុត្តសូត្រទី ៧ ..... ៥១៥

អដ្ឋកថា សុន្ទរីសូត្រទី ៨ ..... ៥១៧

អដ្ឋកថា ឧបសេនសូត្រទី ៩ ..... ៥៣៥

អដ្ឋកថា សារីបុត្តឧបសមសូត្រទី ១០ ..... ៥៤៣

៥-សោណត្ថេរវគ្គោ សោណត្ថេរវគ្គនី ៥ ..... ៥៤៧

អដ្ឋកថា បិយតរសូត្រទី ១ ..... ៥៤៧

អដ្ឋកថា អប្ផាយុកសូត្រទី ២ ..... ៥៥៣

អដ្ឋកថា សុប្ផពុទ្ធកុដ្ឋិសូត្រទី ៣ ..... ៥៦១

អដ្ឋកថា កុមារកសូត្រទី ៤ ..... ៥៨៣

អដ្ឋកថា ឧបោសថសូត្រទី ៥ ..... ៥៨៧

អដ្ឋកថា សោណសូត្រទី ៦ ..... ៦១៧

អដ្ឋកថា កង្ខារេវតសូត្រទី ៧ ..... ៦៣៣

អដ្ឋកថា អានន្ទសូត្រទី ៨ ..... ៦៣៧

អដ្ឋកថា សធាយមានសូត្រទី ៩ ..... ៦៤១

អដ្ឋកថា ចូឡបន្ថកសូត្រទី ១០ ..... ៦៤៣

៦-ឆចក្ក្ធវគ្គោ ឆចក្ក្ធវគ្គនី ៦ ..... ៦៤៩

អដ្ឋកថា អាយុសមឱ្យជ្ជនសូត្រទី ១ ..... ៦៤៩

អដ្ឋកថា បដិសល្លានសូត្រទី ២ ..... ៦៦៥

អដ្ឋកថា អាហុសូត្រទី ៣ ..... ៦៧៣

អដ្ឋកថា បឋមនានាតិត្ថិយសូត្រទី៤ ..... ៦៧៩

អដ្ឋកថា ទុតិយនានាតិត្ថិយសូត្រទី ៥ ..... ៦៩១

អដ្ឋកថា តិតយនានាតិត្ថិយសូត្រទី ៦ ..... ៦៩៥

អដ្ឋកថា សុភូតិសូត្រទី ៧ ..... ៦៩៩

អដ្ឋកថា គណិកាសូត្រ ទី ៨ ..... ៧០៣

អដ្ឋកថា ឧបាតិធាវន្តសូត្រទី ៩ ..... ៧១១

អដ្ឋកថា ឧបជ្ជន្ទិសូត្រទី ១០ ..... ៧១៧

៧-ចូឡវគ្គោ ចុល្លវគ្គនី ៧ ..... ៧២៣
អដ្ឋកថា បឋមលកុណ្ឌកកទ្ទិយសូត្រទី ១ ..... ៧២៣
អដ្ឋកថា ទុតិយលកុណ្ឌកកទ្ទិយសូត្រទី ២ ..... ៧២៩
អដ្ឋកថា បឋមកាមសូត្រទី ៣ ..... ៧៣៣
អដ្ឋកថា ទុតិយកាមសូត្រទី ៤ ..... ៧៣៧
អដ្ឋកថា អបរលកុណ្ឌកកទ្ទិយសូត្រទី ៥ ..... ៧៤១
អដ្ឋកថា តណ្ហក្ខយសូត្រទី ៦ ..... ៧៤៧
អដ្ឋកថា បញ្ចខយសូត្រទី ៧ ..... ៧៥១
អដ្ឋកថា មហាកច្ចាយនសូត្រទី ៨ ..... ៧៥៥
អដ្ឋកថា ឧទបានសូត្រទី ៩ ..... ៧៦១
អដ្ឋកថា ឧទេនសូត្រទី ១០ ..... ៧៧៣
៨-ចាជលិកាមិយវគ្គោ ចាជលិកាមិយវគ្គនី ៨ ..... ៧៨៣
អដ្ឋកថា បឋមនិព្វានបដិសំយុត្តសូត្រទី ១ ..... ៧៨៣
អដ្ឋកថា ទុតិយនិព្វានបដិសំយុត្តសូត្រទី ២ ..... ៧៩៣
អដ្ឋកថា តតិយនិព្វានបដិសំយុត្តសូត្រទី ៣ ..... ៧៩៧
អដ្ឋកថា ចតុត្ថនិព្វានសំយុត្តសូត្រទី ៤ ..... ៨០៣
អដ្ឋកថា ចុន្ទសូត្រទី ៥ ..... ៨០៧
អដ្ឋកថា ចាជលិកាមិយសូត្រទី ៦ ..... ៨២៣
អដ្ឋកថា ទ្វិធាបថសូត្រទី ៧ ..... ៨៥៥
អដ្ឋកថា វិសាខាសូត្រទី ៨ ..... ៨៦១
អដ្ឋកថា បឋមទព្វសូត្រទី ៩ ..... ៨៦៧
អដ្ឋកថា ទុតិយទព្វសូត្រទី ១០ ..... ៨៧៥
និគមនកថា ៨៧៩
ឯកសារយោង ៨៨៣
នាមពុទ្ធបរិស័ទចូលរួមគម្ពីរ ៨៨៥

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

បរមត្ថទីបនី

អដ្ឋកថា

ខុទ្ទកនិកាយ ១ឆាន

ឧទានវណ្ណនា

គន្ថារម្ភកថា

ខ្ញុំព្រះករុណាសូមនមស្សការព្រះលោកនាថ ព្រះអង្គប្រកប ដោយព្រះមហាករុណា ព្រះអង្គដល់ត្រើយសាគរ គឺញេយ្យ-ធម៌ ទ្រង់សម្តែងធម៌ដ៏ល្អិតល្អន់ ជ្រាលជ្រៅមានន័យដ៏ វិចិត្រ ។

ខ្ញុំព្រះករុណា សូមនមស្សការព្រះធម៌ដ៏ល្អបំផុត ដែល ព្រះសម្មាសម្ពុទ្ធ ទ្រង់បូជាហើយ ព្រោះជាហេតុនាំសត្ត្ว អ្នកដល់ព្រមដោយវិជ្ជា និងចរណៈ ចេញចាកលោក ។

ខ្ញុំព្រះករុណា សូមនមស្សការព្រះអរិយសង្ឆ អ្នកដល់ព្រម ដោយសីលគុណជាដើម អ្នកតាំងនៅក្នុងមគ្គ និងផល អ្នកជាបុញ្ញខេត្តដ៏កំពូល ។

បុណ្យណា ដែលកើតអំពីការថ្វាយបង្គំចំពោះព្រះរតនៈត្រៃ ដូចពោលមកនេះ សូមឱ្យខ្ញុំជាអ្នកមានអន្តរាយ ត្រូវតេជៈ នៃបុណ្យ កម្ចាត់បង់ហើយក្នុងទីទាំងពួង ។

ព្រះមហេសី[1] ព្រះអង្គអ្នកស្វែងរកប្រយោជន៍ ទ្រង់សម្តែង ***ឧទាន*** *ដោយអបទានដ៏បរិសុទ្ធណា ដោយនិទានៈ ។*

១-**មហេសិនោតិ មហន្តេ សីលសមាធិបញ្ញាក្ខន្ធេ ឯសិ គវេសីតិ មហេសី ។** *ពាក្យថា* ***មហេសី*** *សេចក្តីថា បុគ្គលណាស្វែងរក គឺថា ស្វែងរកដោយចំពោះនូវគំនរសីល សមាធិ និងបញ្ញា ដ៏ធំ បុគ្គលនោះ ឈ្មោះថា* ***មហេសី*** *។ (គម្ពីរមធុរត្ថវិលាសិនី អដ្ឋកថា ពុទ្ធវង្ស)*

ព្រះធម្មសង្គាហាចារ្យ កាលនឹងលើកឧទានទាំងអស់នោះ
រួមទុកជាពួកតែមួយ ហើយចង់ក្រង ដោយឈ្មោះថា **ឧទាន** ។
ឧទាន ដែលជាគ្រឿងសម្តែងសេចក្តីសង្វេគ និងបាមោជ្ជ:
ក្នុងធម៌របស់ព្រះជិនស្រី ដែលប្រដាប់ដោយគាថា មាន
សោមនស្សញ្ញាណ ជាសមុដ្ឋាន ។
ការពណ៌នាអត្ថនៃឧទាននោះ គឺខ្ញុំធ្វើបានដោយលំបាក
ព្រោះនឹងត្រូវប្រើញាណដ៏ជ្រាលជ្រៅ ដោយសភាពដែល
គួរធ្លាក់ចុះ ក៏ពិតយ៉ាងនោះ ។
ក៏ប៉ុន្តែថា សត្ថុសាសន៍ព្រមទាំងសំវណ្ណនានៅមាំមួន ការ
វិនិច្ឆ័យរបស់បុព្វាចារ្យអ្នកសីហឬ: ក៏នៅមាំមួនដូចគ្នា ។
ព្រោះដូច្នោះ ខ្ញុំទើបកាន់យកសត្ថុសាសន៍នោះ ធ្លាក់ចុះ
ក្នុងនិកាយទាំង ៥ អាស្រ័យន័យនៃអដ្ឋកថាបូរាណ ។
ន័យអដ្ឋកថាបូរាណ ដ៏បរិសុទ្ធល្អ មិនលាយគ្នា មានការ
វិនិច្ឆ័យអត្ថដ៏សុខុម ប្រកាន់យកលទ្ធិរបស់ព្រះមហាថេរ:
អ្នកនៅក្នុងមហាវិហារ រឿងអត្ថដែលមកដដែលៗ នឹងធ្វើ
នូវអដ្ឋកថាឧទាន តាមកម្ចាំងឱ្យល្អ ។ ព្រោះដូច្នោះ កាល
ខ្ញុំប្រាថ្នាសេចក្តីមាំមួននៃព្រះសទ្ធម្ម ចែកអត្ថនៃឧទាន សូម
សាធុជនទាំងឡាយ ទទួលយកដោយល្អចុះ ។

បណ្តាបទទាំងនោះ បទថា **ឧ**ទានំ សេចក្តីថា ដែលឈ្មោះថា **ឧទាន**
ដោយអត្ថថា យ៉ាងណា? ឈ្មោះថា **ឧទាន** ដោយអត្ថថា សម្តែងចេញ ។

ឈ្មោះថា **ឧទាន** នេះជាអ្វី? គឺជាការសម្តែង ដែលតាំងឡើងដោយកម្លាំងរបស់បីតិ ។ ឧទាហរណ៍ថា វត្ថុគួរដល់ការកំណត់ មានប្រេងជាដើម មិនអាចនឹងរាប់យកប្រមាណបាន រមែងហូរទៅយ៉ាងណា វត្ថុនោះ ហៅថា **អវសេក:** ។ ម្យ៉ាងទៀត ខ្សែទឹកណា មិនអាចឃាំងជាប់ជោរជន់ឡើយ ខ្សែទឹកនោះ ហៅថា **ឱឃ:** ។ មានឧបមាយ៉ាងណា អន្ទង់ទឹកណា វត្ថុណាតាំងឡើងដោយកម្លាំងបីតិ ផ្សាយជ្រួតជ្រាបទៅដោយកម្លាំងវិតក្ក: មិនអាចតាំងនៅខាងក្នុងហ្ឫទ័យបានក៏ដូច្នោះ ការសម្តែងចេញដោយពិសេសនោះ ជាវត្ថុដ៏ក្រៃលែង មិនតាំងនៅខាងក្នុង ចេញទៅខាងក្រៅតាមរបើទ្វារ មិនដល់ការទទួលយក ហៅថា **ឧទាន** ។ អាការយ៉ាងនេះរមែងបាន សូម្បីដោយអំណាចនៃធម្មសង្វេគ ។

ឧទាននេះនោះ កន្លែងខ្លះប្រព្រឹត្តទៅដោយអំណាចគាថាជាប្រព័ន្ធ កន្លែងខ្លះប្រព្រឹត្តទៅដោយអំណាចពាក្យនិយាយ (វាក្យស័ព្ទ) ។ ក៏លក្ខណៈនៃឧទានឯណា ដែលលោកពោលទុកក្នុងអដ្ឋកថាថា **សោមនស្សញ្ញាណមយិ-ककाथापटिसंयुत्ता** ជាប់ដោយគាថាដែលសម្រេចមកពីសោមនស្សញ្ញាណ" លក្ខណៈយ៉ាងនោះ លោកពោលដោយអំណាចច្រើនយ៉ាង ។ ក៏ដោយភាពច្រើន ឧទានលោកពោលដោយអំណាចគាថាព័ន្ធ និងតាំងឡើងដោយអំណាចបីតិ និងសោមនស្ស ។ តែឧទាន សូម្បីផ្សេងពីនេះ រមែងមានក្នុងប្រយោគជាអាទិ៍ថា **អត្ថि ภิกฺขเว ตถาคเตน อรหตา สมฺมาสมฺพุทฺเธน** ម្នាលភិក្ខុទាំងឡាយ

អាយតនៈនោះ រមែងមានពិត ដ៏មិនមាន ទឹកមិនមាន[១]និងបានក្នុងប្រយោគ ជាអាទ៍ថា **សុខកាមានិ ភូតានិ យោ ឧណ្ហេន វិហឹសតិ** ជនណា ស្វែងរកសេចក្តីសុខ (ដើម្បីខ្លួន) តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា[២] និងក្នុងប្រយោគមានជាអាទ៍ថា **សចេ ការយ ឧក្ខ្ស្ស សចេ ហ ឧក្ខ្ស្ស មប្ប្ យំ** បើអ្នកទាំងឡាយខ្ជាចសេចក្តីទុក្ខ បើសេចក្តីទុក្ខមិនជាទីស្រឡាញ់របស់អ្នកទាំងឡាយទេ[៣] ។

ឧទាននេះនោះ ដូចពោលមក មាន ៣ យ៉ាង គឺសព្វញ្ញុពុទ្ធភាសិត ១ បច្ចេកពុទ្ធភាសិត ១ សាវកភាសិត ១ ។ បណ្ណាភាសិត ៣ យ៉ាងនោះ បច្ចេក-ពុទ្ធភាសិត មកក្នុងខគ្គវិសាណសូត្រ ដោយន័យមានជាអាទ៍ថា **សព្ពេសុ ភូតេសុ និធាយ ឧណ្ហ អវិហេឋយ[៤] អញ្ញតរម្ប្ តេ** បុគ្គលណា ដាក់អាជ្ញាចោលចេញចំពោះសត្វទាំងអស់ មិនបានបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ[៥]។ សូម្បីសាវកភាសិតទាំងឡាយ មានមកហើយក្នុងថេរ-គាថាមានជាអាទ៍ថា **សព្ពោ ភ្ជោ ឧហ្ជោ ម សព្ពោ ឧ្ជោ ឧ្ជោ សមូ្ហ ជ** ។

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ៣២០ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៤៩ ។

៣-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ២៣៤ ។

៤-ក្នុងបរមត្ថទីបនី ទំព័រ ៣ របស់មហាមកុដរាជវិទ្យាល័យថា **អហេឋយ** ។

៥-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១៣ ។

សព្វោ មេ វិតតោ[1] **មោហោ សីតិភូតោស្មិ និព្ពុតោ** *រាគៈទាំងពួង ខ្ញុំលះចោលហើយ ទោសៈទាំងពួង ខ្ញុំក៏ដកចោលហើយ មោហៈទាំងពួងរបស់ខ្ញុំក៏ប្រាសចេញហើយ ខ្ញុំជាបុគ្គលត្រជាក់រលត់ទុក្ខហើយ*[2] *និងគាថាមានមកក្នុងថេរីគាថាមានជាអាទិ៍ថា* **កាយេន សំវុតា អាសឺ វាចាយ ឧត ចេតសា សមូលំ តណ្ហំ អព្ពុយ្ហ សីតិភូតម្ហិ និព្ពុតា**[3] *ខ្ញុំជាអ្នកសង្រួមដោយកាយ ដោយវាចា ដោយចិត្ត បានដកតណ្ហា ព្រមទាំងឫស (ឬព្រមទាំងអវិជ្ជា) ជាអ្នកមានចិត្តត្រជាក់ សម្រេចអនុបាទិសេសនិព្វានធាតុ*[4] *។ ក៏ឧទានទាំងនោះ មិនត្រឹមតែជាឧទានរបស់ព្រះថេរៈ និងព្រះថេរីទាំងនោះតែប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជាឧទានមានប្រភេទជាសីហនាទ (ការបន្ទឺដូចរាជសីហ៍) ទៀតផង ។ ឧទានដែលទេវតាទាំងឡាយ មានស្តេចសក្កៈជាដើមពោលទុកមានជាអាទិ៍ថា* **អហោ ទានំ បរមទានំ កស្សបេ សុប្ពតិដ្ឋិតំ** *ឱហ្ន ទានដែលអាត្មាអញ*

១-ឆដ្ឋសង្គាយនា និងបរមត្ថទីបនី របស់មហាមកុដរាជវិទ្យាល័យថា **វិហតោ** *។*

២-សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា លេខ ៥៦ ទំព័រ ១៦១ ។

៣- **សីតិភូតម្ហិ និព្ពុតាតិ** **សព្វសោ កិលេសបរិឡាហាភាវេន** **សីតិភាវប្ផត្តា** **អនុបាទិសេសាយ** **និព្វានធាតុយា** **និព្ពុតា** **អម្ហិ** *។ ពីរបទថា* **សីតិភូតម្ហិ** **និព្ពុតា** *សេចក្ដីថា (ខ្ញុំម្ចាស់) ជាអ្នកដល់នូវភាពត្រជាក់ ព្រោះលះបង់នូវកិលេសដ៏ពោលពាលទាំងពួង ជាអ្នករលត់ហើយដោយអនុបាទិសេសនិព្វានធាតុ ។ (បរមត្ថទីបនី អដ្ឋកថា ថេរីគាថា)*

៤-សុត្តន្តបិដក ខុទ្ទកនិកាយ ថេរីគាថា លេខ ៥៧ ទំព័រ ១៤៧ ។

បានតម្កល់ទុកល្អហើយក្នុងព្រះមហាកស្សប ហៅពេញជាទានដ៏ឧត្តម[១] និងឧទានដែលមនុស្សទាំងឡាយ មានអាវាមទណ្ឌព្រាហ្មណ៍ជាដើម ពោលទុកមានជាអាទិ៍ថា **ជមោ តស្ស ភគវតោ** សូមក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគអង្គនោះ[២] ឧទានទាំងឡាយ ដែលឡើងកាន់សង្ខ្តីតិទាំង ៣ ដង មិនបំណងយកក្នុងទីនេះទេ ។ ក៏ភាសិតណា ជាពាក្យរបស់ព្រះជិនស្រី ដែលព្រះដ៏មានព្រះភាគទ្រង់សំដៅយក កាលទ្រង់ចែកបរិយត្តិធម៌ជា ៩ យ៉ាង ត្រាស់ថា ឧទាន ភាសិតនោះឯង ព្រះធម្មសង្គាហាចារ្យទាំងឡាយ ចង់ក្រងទុកថា **ឧទាន** ។ ឧទាននោះឯង ក្នុងទីនេះ គឺលោកកាន់យកហើយ ដោយភាពជាវត្ថុគប្បីពណ៌នា ។

ចំណែកគាថាណា ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែង ដោយគាថាមានជាអាទិ៍ថា **អនេកជាតិ សំសារំ** ដែលប្រព្រឹត្តទៅដោយអំណាចឧទានទៀបគល់ពោធិព្រឹក្ស និងឧទានគាថាដែលព្រះសម្មាសម្ពុទ្ធច្រើនសែនព្រះអង្គ ទ្រង់មិនលះបង់ តែក្នុងគ្រាក្រោយមក គាថាទាំងនោះ ព្រះធម្មសង្គាហាចារ្យទាំងឡាយ មិនបានសង្គាយនាទុកក្នុងឧទានបាលី តែសង្គាយនាទុកក្នុងធម្មបទ ព្រោះព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដល់ភិក្ខុអ្នកជាធម្មកណ្ណាគារិក ។ ក៏ពាក្យឧទានថា **អញ្ញាសិ វត ភោ ភោណ្ហញ្ញោ អញ្ញាសិ វត ភោ ភោណ្ហញ្ញោ** *អើហ្ន ភោណ្ហញ្ញ: បានត្រាស់ដឹងពិតហើយ អើហ្ន ភោណ្ហញ្ញ: បានត្រាស់ដឹង*

១-សុត្តន្តដ្ឋកថា ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ១៨១ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ២០ ទំព័រ ១២៩ ។

ពិតហើយ[១]ដូច្នេះ គឺព្រះដ៏មានព្រះភាគត្រាស់ឱ្យមានសំឡេងគឹកកងផ្សាយទៅ អាចប្រកាសដល់ទេវតា និងមនុស្សទាំងឡាយ ក្នុងមុឺនលោកធាតុ សូម្បីឧទាន នោះ ជាហេតុនាំឱ្យមានការពិចារណាដល់សេចក្តីលំបាករបស់ព្រះអង្គ ព្រម ដោយផល ព្រោះការៈនៃព្រះអរិយមគ្គ ដែលទ្រង់សម្តែងជាចំណែកមួយនៃធម៌ ដែលធ្វើព្រះអង្គឱ្យសម្រេច ត្រូវព្រះថេរៈសម្រេចមុនជាងសាវ័កទាំងពួង បណ្តា សាវ័កទាំងឡាយ ក្នុងកាលជាទីបញ្ចប់ទេសនាឈ្មោះព្រះធម្មចក្កប្បវត្តនសូត្រ និងជាហេតុធ្វើឱ្យមានការពិចារណាសម្ថាបដិបត្តិរបស់ភិក្ខុទាំងពួង ក្នុងបឋមពោធិ-កាល ត្រឹមតែជាឧទានដែលកើតអំពីបីតិ និងសោមនស្ស ដូចពាក្យមានជាអាទិ៍ ថា **អាវ១យឺសុ វត មំ ភិក្ខូ ឯកំ សមយំ** ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ ទាំងឡាយ បានញ៉ាំងចិត្តតថាគតឱ្យត្រេកអរក្នុងសម័យហើយ[២] ឧទានដែល មិនមែនជាពាក្យប្រកាសរបស់ការប្រព្រឹត្តទៅ រ៉ាលត្រឡប់មក ដូចពាក្យមានជា អាទិ៍ថា **យ១ា ហ១ វ១ាតុ១ន្តិ ១ម្ម១ា** កាលណាហ្ន៎ ធម៌ទាំងឡាយរមែងប្រាកដ (ដល់ព្រាហ្មណ៍)[៣] ព្រោះដូច្នោះ មិនគប្បីជ្រាបថា ព្រះធម្មសង្គាហកាចារ្យ ចង ក្រងទុកក្នុងឧទានបាលី ។

បណ្តាបិដក ៣ គឺ**វិនៃ្ជយបិដក សុត្តន្តបិដក អភិ១ម្មបិដក** ឧទាននេះនោះ លោកវាប់បញ្ចូលក្នុង**សុត្តន្តបិដក** បណ្តានិកាយ៥ គឺ**ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អ១ុ១ុ១ត្ត១ិ១ាយ** និង**ខុទ្ទ១ិ១ាយ** ឧទាននេះលោកវាប់បញ្ចូលក្នុង

១-វិនៃ្ជយបិដក មហាវគ្គ លេខ ៦ ទំព័រ ៣៦ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក: លេខ ២១ ទំព័រ ៦ ។

៣-សុត្តន្តបិដក ខុទ្ទ១ិ១ាយ ឧទាន លេខ ៥២ ទំព័រ ១១៤ ។

ខុទ្ទកនិកាយ បណ្តាសត្ថុសាសន៍មានអង្គ ៩ គឺសុត្ត: គេយ្យ: វេយ្យាករណ: គាថា ឧទាន ឥតិវុត្តក ជាតក អព្ភូតធម៌ និងវេទល្ល: លោកសង្គ្រោះចូលក្នុងឧទាន ។

បណ្តាធម្មក្ខន្ធ ៨៤.០០០ ធម្មក្ខន្ធ លោកសង្គ្រោះចូលក្នុងធម្មក្ខន្ធបន្ទិច-បន្ទូច ដែលព្រះធម្មកណ្ណាគារិកភិក្ខុកំណត់ទុកយ៉ាងនេះថា

ទ្វាសីតិ ពុទ្ធតោ ១ កណ្ហ ១ ទ្វេ សហស្សានិ ភិក្ខុតោ
ចតុរាសីតិ សហស្សានិ យេ មេ ធម្ម បវត្តិនោ

សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅ (ក្នុងហឫទ័យ) របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មាន ៨ ហ្មឺន ២ ពាន់ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ហ្មឺន ២ ពាន់ធម្មក្ខន្ធ អំពីពួកភិក្ខុ ២ ពាន់ធម្មក្ខន្ធ[១] ។ ធម្មក្ខន្ធ(ឧទាន) ពោលដោយវគ្គមាន ៨ វគ្គ គឺ**ពោធិវគ្គ មុចលិន្ទវគ្គ នន្ទវគ្គ មេឃិយវគ្គ សោណវគ្គ ជច្ចន្ធវគ្គ ចូឡវគ្គ បាដលិគាមិយវគ្គ** ពោលដោយសូត្រ មាន ៨០ សូត្រ ពោលដោយគាថាសង្គ្រោះជាឧទានគាថា មាន ៩៥ គាថា ។ ពោលដោយភាណវារ: មានប្រមាណ ៩ កន្ទ:ភាណវារ: ។ ពោលដោយអនុសន្ធិ មាន ១ អនុសន្ធិ ដោយអំណាចបុច្ឆានុសន្ធិ ក្នុងពោធិសូត្រទាំងឡាយ ។ ក្នុងសុប្បវាសសូត្រ មាន ២ អនុសន្ធិ ដោយអំណាចបុច្ឆានុសន្ធិ និងយថានុសន្ធិ ។ ក្នុងសូត្រដែលនៅសល់ មានអនុសន្ធិតែមួយ ដោយអំណាចយថានុសន្ធិ តែអជ្ឌាសយានុសន្ធិ មិនមានក្នុងទីនេះ ។ ការសង្គ្រោះអនុសន្ធិ ៨១ ដោយប្រការទាំងពួង ដោយ

១-សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា លេខ ៥៧ ទំព័រ ៩៤ ។

ប្រការដូច្នេះ ។ ពោលដោយបទមាន ២១.១០០ បទ ពោលដោយបាទនៃគាថា មាន ៨.២២៣ បាទ ពោលដោយអក្ខរៈមាន ៦៧.៣៨២ អក្ខរៈ ។

ព្រោះហេតុនោះ លោកទើបពោលពាក្យនេះទុកថា

ឧទានពោលដោយសង្ខេប លោកប្រកាសទុកថា មាន ៨០ សូត្រ ៨ វគ្គ ៩៥ គាថា ។ ចំណែកកាណវារៈ ពោលដោយប្រមាណ មានប្រមាណ ៩ កន្ទ:ៈ កាណវារៈ មានអនុសន្ធិ ៨១ អនុសន្ធិ ។ អ្នកមានបញ្ញាឃើញប្រចក្សសម្តែងបទ ឧទានទាំងនេះ ពាក្យនវណ:បាន ២១.១០០ បទ ។

បើពោលដោយបទនៃគាថា លោកសម្តែងទុក មាន ៨.២២៣ បាទគាថា ពោលដោយអក្ខរទុក: មាន ៦៧.៣៨២ អក្ខរ: ដូច្នេះ ។

បណ្តាវគ្គទាំង ៨ របស់ឧទាននោះ ពោធិវគ្គ ជាវគ្គខាងដើម ។ បណ្តាសូត្រទាំងឡាយ ពោធិសូត្រ ជាសូត្រទី ១ ហើយពោធិសូត្រសូម្បីនោះ មាននិទាន ដែលព្រះអានន្ទពោលទុកក្នុងមហាសង្គីតិគ្រាដំបូងមានជាអាទ៍ថា **ឯវម្មេ សុតំ** ដូច្នេះ ជាខាងដើម ។ ក៏មហាសង្គីតិគ្រាដំបូងនេះនោះ លើកឡើងកាន់ តន្ត្រិកាសា ក្នុងវិនិយបិដកនុ:ឯង ។ ក៏ក្នុងទីនេះ កថាមគ្គដែលគួរពោលដើម្បីសេចក្តីធ្វាតក្នុងនិទានសូម្បីនោះ លោកបានពោលទុកក្នុងអដ្ឋកថាទីឃនិកាយ ឈ្មោះ**សុមង្គលវិលាសិនី**នោះឯង ព្រោះដូច្នោះ គប្បីជ្រាបដោយន័យដូចបានពោលទុកក្នុងអដ្ឋកថា ឈ្មោះថា **សុមង្គលវិលាសិនី** នោះចុះ ។

ចប់គន្ថារម្ភកថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

១. ពោធិវគ្គោ

ពោធិវគ្គទី ១

១. បឋមពោធិសុត្តវណ្ណនា

អដ្ឋកថាបឋមពោធិសូត្រ

ក៏ក្នុងពោធិសូត្រនេះ ពាក្យថា **ឯវម្មេ សុតំ** *ជាដើម ជានិទាន ។ បណ្តាបទទាំងនោះ ស័ព្ទថា* **ឯវំ** *ជានិបាតស័ព្ទ ។ បទថា* **មេ** *ជាដើម ជាបទនាម ។ បទថា* **វិ** *ក្នុងបទថា* **ឧរុវេលាយំ វិហរតិ** *នេះ ជាបទឧបសគ្គ ។ បទថា* **ហរតិ** *ជាអាខ្យាតបទ ។ បទវិភាគគប្បីជ្រាបដោយន័យនេះ ជាការរលត់ដំបូងនុ៎ះឯង ។*

តែកាលពោលដោយអត្ថ ជាលំដាប់ដំបូង **ឯវំ**-*ស័ព្ទ មានអត្ថច្រើនប្រភេទ មានជាអាទិ៍ថា* ***ឧបមា ឧបទេសៈ សម្បហំសនៈ គរហណៈ វចនសម្បដិគ្គហៈ អាការៈ និទស្សនៈ អវធារណៈ បុច្ឆា ឥទមត្ថៈ បរិមាណៈ*** *។ ពិតយ៉ាងនោះ* **ឯវំ** *ស័ព្ទនោះ មកក្នុង**ឧបមា** មានក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា* **ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ** *កុសលដែលសត្វកើតមកហើយ គួរធ្វើឱ្យច្រើនយ៉ាងនោះ*[1] *។ មានក្នុង**ឧបទេសៈ*** *(ប្រការណែនាំ) ដូចក្នុងប្រយោគមានជាអាទិ៍ថា* **ឯវន្តេ អភិក្កមិតព្វំ ឯវន្តេ បដិក្កមិតព្វំ** *អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ*[2] *។ មកក្នុង**សម្បហំសនៈ*** *(សេចក្ដីរីករាយ) ដូច*

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៣២ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ២២ ទំព័រ ៣១០ ។

ក្នុងប្រយោគមានជាអាទិ៍ថា **ឯវមេតំ ភគវា ឯវមេតំ សុគត** *បពិត្រព្រះដ៏មាន-ព្រះភាគ ហេតុនុ៎ះយ៉ាងនេះឯង បពិត្រព្រះសុគត ហេតុនុ៎ះយ៉ាងនេះឯង*[១] ។ *មកក្នុង* ***គរហណៈ***(*ការតិះដៀល*) *ដូចក្នុងប្រយោគមានជាអាទិ៍ថា* **ឯវមេវំ បនាយំ វសលី យស្មឹ វា តស្មឹ វា តស្ស មុណ្ឌកស្ស សមណកស្ស វណ្ណំ ភាសតិ** *មេចង្រៃនេះ ធ្លាប់តែអឺចឹង ហ៊ានពោលសរសើរសមណៈត្រងោល ក្នុងទីផ្តេសផ្តាស*[២] ។ *មកក្នុង* ***វចនសម្បដិគ្គហៈ*** (*ការទទួលពាក្យ*) *ក្នុងប្រយោគមានជាអាទិ៍ថា* **ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** *ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ*[៣] ។ *មកក្នុង* ***អាការៈ*** *ក្នុងប្រយោគមានជាអាទិ៍ថា* **ឯវំ ព្យា ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ** *ម្នាលអាវុសោទាំងឡាយ ខ្ញុំក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយយ៉ាងនោះឯង*[៤]។ *មកក្នុង* ***និទស្សនៈ*** (*ការចង្អុលបង្ហាញ*) *ក្នុងប្រយោគមានជាអាទិ៍ថា* **ឯហិ ត្វំ មាណវក យេន សមណោ អានន្ទោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន សមណំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ សុភោ មាណវោ**

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ២២៧ ។

២-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ៣០ ទំព័រ ៨៤ ។

៣-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២០ ទំព័រ ១ ។

៤-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ១៥១ ។

តោទេយ្យបុត្តោ ភវន្តំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ សាធុ កិរ ភវំ អានន្ទោ យេន សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយ *ម្នាលមាណព ឯងចូរមកនេះ ឯងចូរទៅរកព្រះសមណៈ ឈ្មោះ អានន្ទ លុះចូលទៅដល់ហើយចូរសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន មានកម្លាំង នៅជាសុខសប្បាយ នឹងព្រះសមណៈ ឈ្មោះអានន្ទ តាមពាក្យរបស់អញថា សុភមាណពជាកូនរបស់តោទេយ្យព្រាហ្មណ៍ផ្តាំឱ្យសួរនូវអាការមានអាពាធតិច រោគតិច ក្រោកទៅមកបានរហ័សរហួននឹងកម្លាំង និងអាការនៅជាសុខសប្បាយ ចំពោះព្រះអានន្ទដ៏ចម្រើន រួចហើយឯងចូរនិមន្តថា សូមព្រះអានន្ទជាម្ចាស់អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តមកកាន់ទីលំនៅរបស់សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឱ្យទាន*[១] ។ *មកក្នុង* ***អវធារណៈ*** (*ហាមសេចក្តីដទៃ*) *មានយ៉ាងនេះជាអាទិ៍ថា* តំ កឹ មញ្ញថ កាលាមា ឥមេ ធម្មា កុសលា វា អកុសលា វាតិ ។ អកុសលា ភន្តេ ។ សាវជ្ជា វា អនវជ្ជា វាតិ ។ សាវជ្ជា ភន្តេ ។ វិញ្ញុគរហិតា វា វិញ្ញុប្បសត្ថា វាតិ ។ វិញ្ញុគរហិតា ភន្តេ ។ សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សមត្តា ភន្តេ សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ ឯវំ នោ ឯត្ថ ហោតីតិ *ម្នាលកាលាមក្សត្រអ្នកសម្គាល់ហេតុនោះដូចម្តេច ធម៌នេះជាកុសល ឬជាអកុសល ។ ជាអកុសល*

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៥ ទំព័រ ១៦០ ដល់ ១៦១ ។

ព្រះអង្គ ។ ជាធម៌ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ ជាធម៌ប្រកបដោយទោស ព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ព្រះអង្គ ។ ធម៌ទាំងនេះដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនោះ ដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ យើងខ្ញុំក៏យល់ក្នុងដំណើរនោះដូច្នេះដែរ[១] ។ មកក្នុងពាក្យសួរ ក្នុងប្រយោគមានជាអាទិ៍ថា **ឯវមេតេ សុជ-ហាតា សុវិលិត្តា កញ្ចិតកេសមស្ស្ហ អាមុត្តមាលាករណា** ឥសីទាំងនោះ បានងូតទឹកដ៏ស្អាត លាបស្រលាបដោយគ្រឿងក្រអូបសាយល្អ មានសក់និងពុកមាត់កាត់ស្រេចហើយ ពាក់កម្រងផ្កា និងគ្រឿងប្រដាប់ ។ល។ យ៉ាងនេះដែរឬ[២] ។ មកក្នុង**ឥទមត្ថ** (អត្ថនៃ **ឥទំ**-ស័ព្ទ) ក្នុងប្រយោគមានជាអាទិ៍ថា **ឯវំកតានិ បុថុសិប្ប្យាយតនានិ ឯវ្ភិ ណោ ឯវមាការោ** ពុំនោះសោត សិប្ប: សម្រាប់បង្កើតផលមានប្រមាណច្រើន អាការនេះ មានប្រការយ៉ាងនេះ[៣] ។ មែនពិត **កត**-ស័ព្ទ មានការហៅថា ប្រការ ។ ស័ព្ទថា **វិធាការ:** ក៏ដូចគ្នា ។ ពិតយ៉ាង

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៦១ ទំព័រ ២២០ ដល់ ២២១ ។

២-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ២៥១ ។

៣-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ១៤៧ ។

នោះ លោកពោល **កត**-*ស័ព្ទ ដែលប្រកបនឹង* **វិ**-*ស័ព្ទ ក្នុងអត្ថថា ប្រការ ។ មក ក្នុង*__**ឋានៈ**__ *ក្នុងប្រយោគមានជាអាទិ៍ថា* **ឯកំ លហុបរិវត្តំ ឯវមាយុបរិយន្តោ** *(សូម្បីតែសការៈមួយ) ដែលកើតឡើងនិងរលត់ទៅរហ័ស (ដូចចិត្តនេះ) មានការអស់ទៅជាទីបំផុតនៃអាយុជាប្រមាណ[1] ។*

ក៏ដោយ **ឯកំ**-*ស័ព្ទ ក្នុងពាក្យថា* **ឯកំ ឋិតក្ខិតំ ជោ តុម្ហេហិ ឯវមាយុបរ-យន្តោ ឯកំ** *ស័ព្ទដែលឈ្មោះថា មានអាការជាអត្ថប៉ុណ្ណោះ ព្រោះពោលអាការ សួរ និងអាការប្រមាណ មិនដូច្នោះឬ ។ មិនមែនយ៉ាងនោះទេ ព្រោះមានសេចក្តីពិសេស ។ ក៏* **ឯកំ**-*ស័ព្ទ ក្នុងទីនេះប្រាប់ត្រឹមតែអាការដែលលោកប្រាថ្នាយកថា មានអាការជាអត្ថ ។ តែ* **ឯកំ**-*ស័ព្ទ ក្នុងពាក្យមានជាអាទិ៍ថា* **ឯកំ ញ្យ ខោ** *ជាការប្រាប់សេចក្តីប្លែកគ្នានៃអាការ ។ ក៏* **ឯកំ**-*ស័ព្ទទាំងនេះ ដែលឈ្មោះថា ប្រាប់សេចក្តីប្លែកគ្នានៃអាការ ព្រោះប្រាប់អាការនៃពាក្យសួរ និងអាការនៃប្រមាណ ។ ក៏ព្រោះអធិប្បាយយ៉ាងនេះ ឧទាហរណ៍ និងឧបមាមានជាអាទិ៍ថា សត្វកើតមកក៏ដូច្នោះទើបត្រឹមត្រូវ ។ ក៏ក្នុងសេចក្តីនោះមានអធិប្បាយដូច្នេះ សត្វឈ្មោះថា* **មច្ចៈ** *ព្រោះមានទីនឹងគប្បីស្ងាប់ជាសការៈ ចាំបាច់ត្រូវបំពេញបុណ្យជាច្រើន ដែលដូចជាក្រុមផ្លាឈើ ព្រោះគួរដល់ឋានៈជាគំនរផ្លាឈើ ក្នុងគាថានេះថា*

យថាបិ បុប្ផរាសិម្ហា ឯកយ៉ា មាលាកុឡ[2] ពហូ
ឯវំ ជាតេន មច្ចេន ឯកត្តំ ឯកុសលំ ពហុំ

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុក្ក-ត្តិកនិបាត លេខ ២០ ទំព័រ ១៨ ។

២-ក្នុងបរមត្ថទីបនីច្បាប់ឆដ្ឋសង្គាយនា និងច្បាប់របស់មហាមកុដរាជវិទ្យាល័យថា **មហាកុណ្ណ** *ចំណែកព្រះត្រៃបិដកខ្មែរថា* **មាលាកុឡ** *។*

នាយមាលាការ ចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា (ផ្សេងៗគ្នា) ឱ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឱ្យច្រើនយ៉ាងនោះ[១] ព្រោះតាំងឡើងអំពីហេតុនៃការបំពេញបុណ្យ មានទានជាដើម មានការកើតក្នុងមនុស្ស ការគប់រកសប្បុរស ការស្តាប់ព្រះសទ្ធម្ម ការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង និងភាពសម្បូរដោយភោគៈជាដើម ព្រោះប្រកបដោយគុណវិសេស មានសេចក្តីល្អ និងមានកូនក្រអូបជាដើម ព្រោះដូច្នោះ ការពោលអំពីភាពមិនប្លែកគ្នា ទើបមានកម្រងផ្កាឈើ និងក្រុមផ្កាឈើជាគ្រឿងមកប្រៀបធ្នឹម ។ អាការប្រៀបធៀបក្រុមផ្កាឈើទាំងនោះ លោកពោលទុកដោយការកំណត់មិនពិតប្រាកដដោយ**យថា**-សព្ទ លោកពោលអំពីការកំណត់ពិតប្រាកដដោយ **ឯវํ**-សព្ទ ទៀត ។ ក៏អាការប្រៀបធៀបនោះកាលកំណត់ចុះទៅ ដោយសេចក្តីត្រឹមតែជាការឧបមាប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលោកពោលថា **ឧបមាយํ អាកតោ** មកក្នុងឧបមាដូច្នេះ ។

ម្យ៉ាងវិញទៀត **អាការ** គឺការណែនាំក្នុងសេចក្តីដល់ព្រមដោយមារយាទដែលសមគួរដល់សមណៈ ដែលលោកណែនាំទុកដោយន័យមានជាអាទិ៍ថា គប្បីឈានទៅដោយអាការយ៉ាងនេះ គឺដោយអាការនេះនោះ ពោលអំពីអត្ថ ក៏គឺឧបទេសនោះឯង ព្រោះហេតុនោះ លោកទើបពោលថា **ឯវํ**-សព្ទ មកក្នុងឧបទេស ក្នុងប្រយោគមានអាទិ៍ថា លោកគប្បីឈានទៅយ៉ាងនេះ គប្បីថយក្រោយយ៉ាងនេះ ។

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៣២ ។

ក្នុងពាក្យថា **ឯវមេតំ ភគវា ឯវមេតំ សុគត** *នេះ គប្បីជ្រាបដោយន័យដែលលោកពោលទុកថា ការសើច គឺការធ្វើសេចក្តីប៉ោងចិត្ត បានដល់ សេចក្តីរីករាយដោយប្រការនៃគុណ ដែលមាននៅក្នុងទីអ្នកដឹងអត្ថតាមដែលព្រះដ៏មានព្រះភាគត្រាស់ហើយធ្វើមិនឱ្យឃ្ងៀងឃ្ងាត ។ ក្នុងសេចក្តីថា* **ឯវមេវ បជាយំ** *នេះ គប្បីជ្រាបដោយន័យដែលពោលហើយថា ជាអាការនៃការតិះដៀល ។ ក៏អាការ គឺការតិះដៀលនោះ រមែងដឹងបានថា លោកប្រកាសទុកដោយ**ឯវํ**-*ស័ព្ទ* ក្នុងទីនេះ ដោយប្រៀបផ្ទឹមនឹង **ខុំសនៈ**-*ស័ព្ទ* គំរាមថា ស្រីថោកទាបជាដើម ។ គប្បីជ្រាបថា សូម្បីអាការ គឺការប្រៀបធៀប លោកពោលទុកដោយប្រៀបផ្ទឹមស័ព្ទមាន **ឧបមាសិ**-*ស័ព្ទជាដើម ដែលលោកពោលទុកដោយឧបមាជាដើម ដូចក្នុងអាការតិះដៀលនេះ ។*

សូម្បីក្នុងបទថា **ឯវํ ណោ** *នេះ ព្រោះកាលតាំងពាក្យសួរថា មិនជាយ៉ាងនោះ ឬថា ក្នុងសេចក្តីនោះជាយ៉ាងណា ដោយអំណាចការកាន់យកតាមអនុមតិ ដើម្បីនឹងឱ្យដឹងការធ្លាក់ចុះ ដោយការ:ដែលធ្វើតាមដែលពោលហើយនោះ នាំវត្ថុដែលមិនជាប្រយោជន៍ និងទុក្ខមកឱ្យ ទើបធ្វើយថា ក្នុងសេចក្តីនោះ មិនជាយ៉ាងនោះ ការសន្និដ្ឋានអាការដូច្នោះ រមែងដឹងបានថា លោកធ្វើឱ្យជាក់ច្បាស់ ហើយដោយ* **ឯវํ**-*ស័ព្ទ ។ ក៏អាការដែលប្រព្រឹត្តទៅដើម្បីមិនមែនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខនៃធម៌ទាំងនោះ កាលកំណត់ពិតប្រាកដ មានអវធារណៈជាអត្ត ព្រោះដូច្នោះ ទើបលោកពោលថា* **ឯវํ**-*ស័ព្ទ* *មកក្នុងអវធារណ: ក្នុងប្រយោគមានជាអាទិ៍ថា* **ឯវํ ណោ ឯត្ត ហោតិ** *ក្នុងសេចក្តីនេះ សម្រាប់ព្រះអង្គជាយ៉ាងនេះ ។*

ដោយពាក្យថា **ឯវញ្ហ វេហិ** *នេះ លោកពោលថា អាការ គឺការពោល*

ដែលនឹងគប្បីពោលក្នុងឥឡូវនេះថា ពោលអាការយ៉ាងណា លោកចូរពោលនឹងសមណៈអានន្ទដោយអាការយ៉ាងនោះ លោកសម្តែងខ្ញុំដោយ**ឯ**ំ-ស័ព្ទ ព្រោះដូច្នោះ **ឯ**ំ-ស័ព្ទនោះ ទើបមាននិទស្សនៈជាអត្ត ។

លោកពោលដល់ **ឯ**ំ-ស័ព្ទទាំងនោះដល់សេចក្តីប្លែកគ្នានៃអាការយ៉ាងនោះថា មានអត្តឧបមាជាដើម ព្រោះមានការពោលទៅដោយអត្តពិសេស មានឧបមាជាដើម ។ ក៏ **ឯ**ំ-ស័ព្ទ ក្នុងពាក្យថា **ឯវម្ភន្តេ** នោះ មានការទទួលពាក្យជាអត្ត ព្រោះកិក្ខុទាំងឡាយអ្នកប្រកបក្នុងការដាក់ចិត្តដោយល្អ ដែលការស្តាប់ធម៌ពោលទុកដោយអំណាចការដឹងចំពោះសការៈ ដែលខ្ជួនតាំងនៅក្នុងធម៌នោះ ។ ព្រោះហេតុនោះ លោកទើបអធិប្បាយទុកថា បទថា **ឯវម្ភន្តេ** បានដល់ **សាធុ ភន្តេ សុដ្ឋុ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ប្រពៃហើយ បពិត្រព្រះអង្គដ៏ចម្រើន ល្អហើយ ដូច្នេះ ។ ក្នុងទីនេះ **ឯ**ំ-ស័ព្ទនេះនោះ គប្បីឃើញថា ចុះក្នុងអត្ថថា អាការនិទស្សនៈ និងអវធារណៈ ។

បណ្តាអត្ត ៣ យ៉ាងនោះ ដោយ **ឯ**ំ-ស័ព្ទ មានអាការជាអត្ត ព្រះថេរៈសម្តែងអត្តនេះថា អ្នកណាអាចនឹងដឹងនូវព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគនោះ ដោយប្រការទាំងពួង ដែលមានន័យផ្សេងៗ ដ៏ល្អិតល្អន់កើតអំពីអធ្យាស្រ័យជាអនេក បរិបូណ៌ដោយអត្ត និងព្យញ្ជនៈ មានបាដិហារ្យផ្សេងៗគ្នា មានជម្រៅដោយធម៌ អត្ត ទេសនា និងបដិវេធ ដែលប្រាកដតាមសោតទ្វារវិញ្ញាណ ដោយសមរម្យដល់ភាសារបស់ខ្ជួននៃសត្វសត្ត ។ ក៏សូម្បីធ្វើសេចក្តីប្រាថ្នា ដើម្បី

នឹងឱ្យការស្តាប់កើតឡើងដោយប្រការទាំងពួង ក៏បានស្តាប់មកហើយយ៉ាងនេះ គឺក៏បានស្តាប់មកហើយដោយអាការម្យ៉ាង ។

ក៏ក្នុងទីនេះ នយមានប្រភេទផ្សេងៗគ្នា ដោយប្រភេទនៃអារម្មណ៍ជាដើម ពោលគឺ ឯកត្តនយ នានត្តនយ អញ្ញាបារនយ ឯវំធម្មតានយ និងពោលគឺ នន្ទិយាវត្តនយ តិបុក្ខលនយ សីហវិក្កីឡិតនយ ទិសាលោចននយ និងអង្កុស-នយ ឈ្មោះថា នានានយ ។ ម្យ៉ាងទៀត នយទាំងឡាយ មានបាលីជាគតិ និងនយទាំងនោះ ឈ្មោះថា នានានយ ព្រោះមានប្រការផ្សេងៗ ដោយអំណាចបញ្ញត្តិ និងអនុប្បញ្ញត្តិជាដើម ដោយអំណាចជាចំណែកនៃសង្ខ្លិលេសជាដើម ដោយអំណាចជាលោកិយ:ជាដើម និងនយដែលលាយគ្នាទាំងពីរនោះជាដើម ដោយអំណាចកុសលជាដើម ដោយអំណាចខន្ធជាដើម ដោយអំណាចសង្គហ:ជាដើម ដោយអំណាចសមយវិមុត្តិជាដើម ដោយអំណាចឋបន:ជាដើម ដោយអំណាចកុសលមូលជាដើម និងដោយអំណាចតិកបដ្ឋានជាដើម ។ ឈ្មោះថា មានន័យដ៏ល្អិតល្អន់ និងផ្សេងៗ ព្រោះល្អិតល្អន់ ល្អិតសុខុម ដោយនយទាំងនោះ ។

អាសយ:នោះឯង ឈ្មោះថា អធ្យាស្ស័យ ។ ក៏អធ្យាស្ស័យនោះ មានច្រើនយ៉ាង ដោយសេចក្តីផ្សេងនៃការ: មានភាពជារបស់ទៀងជាដើម និងដោយសេចក្តីផ្សេងនៃសភាពដែលសត្វមានកិលេស ដូចធូលីក្នុងភ្នែកតិចជាដើម ឬក៏មានន័យជាអនេកមានជាអាទិ៍ថា អធ្យាស្ស័យរបស់ខ្លួនជាដើម ឈ្មោះថា អនេក-ជ្ឌាសយ: ។ អនេកធ្យាស្ស័យនោះ ឈ្មោះថា អនេកជ្ឌាសយសមុដ្ឋាន ព្រោះសមុដ្ឋានជាហេតុកើតឡើង ។

ឈ្មោះថា បរិបូណ៌ដោយអត្ត និងព្យញ្ជនៈ ព្រោះប្រកបដោយអត្តបទ ៦ យ៉ាង ដោយអំណាចនៃ**សង្ការសនៈ** (ស្រដៀងគ្នា) **បកាសនៈ** (ប្រកាស) **វិវរណៈ** (បើកបង្ហាញ) **វិភជនៈ** (បែងចែក) **ឧត្តានិករណៈ** (ធ្វើឱ្យក្បាក់ផ្ដើល) និង**បញ្ញត្តិ** (ឈ្មោះ) និងប្រកបដោយព្យញ្ជនបទ ៦ យ៉ាង ដោយអំណាចនៃអក្ខរៈ បទ ព្យញ្ជនៈ អាការ និរុត្តិ និងនិទ្ទេសនៃសម្បត្តិរបស់អត្តនៃសីលជាដើម និងសម្បត្តិនៃព្យញ្ជនៈ ដែលធ្វើសេចក្ដីឱ្យជាក់ច្បាស់នៃអត្ត មានសីលជាដើមនោះ ។

ឈ្មោះថា មានបាដិហារ្យផ្សេងៗ ព្រោះមានបាដិហារ្យផ្សេងៗ ឬច្រើនដោយសេចក្ដីផ្សេងនៃឥទ្ធិបាដិហារ្យ អាទេសនាបាដិហារ្យ និងអនុសាសនីបាដិហារ្យ និងដោយសេចក្ដីផ្សេងនៃអារម្មណ៍ជាដើមរបស់បាដិហារ្យមួយៗ ក្នុងចំណោមបាដិហារ្យទាំងនោះ ។ ក្នុងសេចក្ដីនោះ នាកាលអត្ថថា ឈ្មោះថា **បាដិហារ្យ** ព្រោះកម្ចាត់ធម៌ដែលជាសត្រូវ គឺព្រោះកម្ចាត់កិលេសមានរាគៈជាដើម កិលេសមានរាគៈជាដើម ដែលជាសត្រូវនឹងគប្បីកម្ចាត់ មិនមានដល់ព្រះដ៏មានព្រះភាគ ។ កាលចិត្តប្រាសចាកឧបក្កិលេស ប្រកបដោយគុណ ៨ ប្រការ កម្ចាត់ធម៌ដែលជាសត្រូវបានហើយ ឥទ្ធិបាដិហារ្យសម្ដែងឫទ្ធិបាន សូម្បីសម្រាប់បុថុជ្ជនក៏ប្រព្រឹត្តទៅបាន ព្រោះដូច្នោះ កាលពោលអំពីវោហារដែលប្រព្រឹត្តទៅក្នុងការសម្ដែងឫទ្ធិនោះ ទើបមិនអាចនឹងពោលបានថា បាដិហារ្យក្នុងទីនេះ ។ ក៏ប្រសិនបើព្រះដ៏មានព្រះភាគ ព្រះអង្គប្រកបដោយព្រះមហាករុណា មានកិលេសដែលជារបស់វេនេយ្យសត្ត្ជាសត្រូវបានកម្ចាត់ហើយ ភាពមានកិលេសដែលជាសត្រូវនោះ បាននាំចេញ

ហើយ ទើបហៅថា **បាដិហារ្យ**យ៉ាងនោះ *ប្រការនោះ ទើបត្រឹមត្រូវ ។ ម្យ៉ាងទៀត ពួកតិរ្ថិយជាសត្រូវនឹងព្រះដ៏មានព្រះភាគផង និងព្រះសាសនាផង ព្រោះកម្ចាត់ពួកតិរ្ថិយទាំងនោះបាន ទើបហៅថា* **បាដិហារ្យ** *។ មែនពិត តិរ្ថិយទាំងនោះ ត្រូវព្រះមានព្រះភាគទ្រង់កម្ចាត់ចេញ គឺបណ្តេញចេញដោយឥទ្ធិបាដិហារ្យ អាទេសនាបាដិហារ្យ និងអនុសាសនីបាដិហារ្យ ដោយអំណាចនៃការកម្ចាត់ទិដ្ឋិ និងដោយការមិនមានសេចក្តីអាចក្នុងការប្រកាសទិដ្ឋិ ។ ម្យ៉ាងទៀត សព្ទថា* **បដិ** *នេះ រមែងឱ្យដឹងអត្ថរបស់សព្ទថា* **បច្ឆា** *នេះ ដូច* **បដិ**-*សព្ទ ក្នុងប្រយោគមានជាអាទិ៍ថា* **តស្មឹ បដិបវិដ្ឋម្ហិ អញ្ញោ អាកញ្ចិ ព្រាហ្មណো** *កាលគាត់ (ពារ៉ាព្រាហ្មណ៍) ត្រឡប់ចូលមកហើយ ព្រាហ្មណ៍ដទៃបានមកដល់ដែរ[១]។ ព្រោះហេតុនោះ កាលចិត្តតាំងមាំ ប្រាសចាកឧបក្លិសេស បុគ្គលដែលធ្វើកិច្ចហើយ គប្បីនាំទៅ គឺឱ្យប្រព្រឹត្តទៅក្នុងខាងក្រោយ ហេតុនោះ ទើបឈ្មោះថា* **បាដិហារ្យ** *។ ម្យ៉ាងទៀត កាលឧបក្លិសេសរបស់ខ្លួន ត្រូវមគ្គដែលសម្បយុត្តដោយឈានទី ៤ កម្ចាត់ចោលហើយ ការកម្ចាត់ខាងក្រោយ ឈ្មោះថា* **បាដិហារ្យ** *។ ម្យ៉ាងទៀត ឥទ្ធិបាដិហារ្យ អាទេសនាបាដិហារ្យ និងអនុសាសនីបាដិហារ្យ ដែលអ្នកប្រាស-ចាកឧបក្លិសេសសម្រេចកិច្ចហើយ គប្បីឱ្យប្រព្រឹត្តទៅទៀត ដើម្បីប្រយោជន៍ដល់សត្ត ឬក៏កាលឧបក្លិសេសរបស់ខ្លួនត្រូវកម្ចាត់ហើយ ការកម្ចាត់ឧបក្លិសេសក្នុងសន្តានរបស់សត្តដទៃក៏រមែងមាន ព្រោះដូច្នោះ ទើបឈ្មោះថា* **បាដិហារ្យ** *។*

១-សុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស លេខ ៦៧ ទំព័រ ១ ។

បាដិហារ្យនុ៎ះឯង ឈ្មោះថា បាដិហារ្យ ។ ម្យ៉ាងទៀត ការពោលអំពីបាដិហារ្យ បាដិហារ្យតែម្យ៉ាង មានក្នុងពួកឥទ្ធិបាដិហារ្យ អាទេសនាបាដិហារ្យ និងអនុសាសនី-បាដិហារ្យ លោកហៅថា **បាដិហារ្យ** ។ ម្យ៉ាងទៀត ឈានទី ៤ និងមគ្គ ឈ្មោះថា **បាដិហារ្យ** ព្រោះកម្ចាត់ធម៌ដែលជាសត្រូវ ។ គប្បីជ្រាបអត្ថថា **បាដិហារ្យ** ព្រោះកើតក្នុងឈានទី ៤ និងមគ្គនោះ ឬជានិមិត្តក្នុងឈានទី ៤ និងមគ្គនោះ ឬមកពីឈានទី ៤ និងមគ្គនោះ ដូច្នេះ ។

ក៏ព្រោះហេតុតែសេចក្តីជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ ពោលគឺ បែបផែន អត្ថ ទេសនា និងការត្រាស់ដឹង ឈ្មោះរបស់បែបផែនជាដើមនោះ ឬ ពោលគឺ ហេតុ និងផល ដែលបញ្ចេញមកពីហេតុ ទាំងហេតុទាំងផល បញ្ញត្តិ និងបដិវេធ ដែលជាការៈ គឺសត្វអ្នកមិនបានសន្សំកុសលសម្ភារទុក រកទីពឹងមិនបាន និងយល់ដឹងបានដោយលំបាក ដូចមហាសមុទ្រដែលសត្វទាំងឡាយ មានទន្សាយជាដើម មិនអាចសង្ងំជម្រៅបាន ព្រោះដូច្នោះ ព្រះតម្រាស់របស់ព្រះដ៏-មានព្រះភាគ ឈ្មោះថា មានជម្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ ព្រោះ ប្រកបដោយការៈនៃជម្រៅ ៤ ប្រការនោះ ។

ក៏ការប្រកាសព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគ តែម្យ៉ាងប៉ុណ្ណោះ ប្រព្រឹត្តទៅក្នុងខណៈតែមួយ រមែងគួរនឹងកាន់យកបានមិនមុនមិនក្រោយ ដោយ ភាសារបស់ខ្លួនៗ នៃសត្វទាំងឡាយ អ្នកមានភាសាផ្សេងៗគ្នា ។ មែនពិត ពុទ្ធ-នុភាពរបស់ព្រះពុទ្ធទាំងឡាយជាអចិន្ត្យ ព្រោះហេតុនោះ គប្បីជ្រាបថា រមែង

ប្រាកដតាមសោតប្បសាទរបស់សព្វសត្ត តាមសមគួរដល់ភាសារបស់ខ្លួន ។ ។

ដោយ **ឯវํ**-*ស័ព្ទ មានន័យ:ជាអត្ត ព្រះអានន្ទ កាលនឹងដោះខ្លួនថា យើងមិនមែនព្រះសយម្ភូ ព្រះសូត្រនេះយើងមិនបានធ្វើឱ្យជាក់ច្បាស់ឯងៗទេ ទើបសម្តែងនៃព្រះសូត្រទាំងអស់ ដែលនឹងគប្បីពោលក្នុងឥឡូវនេះថា* **ឯវម្មេ សុតํ** *ខ្ញុំបានស្តាប់មកយ៉ាងនេះ គឺសូម្បីយើងក៏បានស្តាប់មកហើយយ៉ាងនេះ ។*

ដោយ **ឯវํ**-*ស័ព្ទ ដែលមានអវធារណ:ជាអត្ត ព្រះអានន្ទកាលនឹងសម្តែងកម្ទាំងនៃការទ្រទ្រង់របស់ខ្លួន ដោយសមគួរដល់ការ:ដែលព្រះដ៏មានព្រះភាគទ្រង់សរសើរទុកយ៉ាងនេះថា* **ឯតទគ្គํ ភិក្ខវេ មម សាវកានํ ភិក្ខូនํ ពហុ-ស្សុតានํ យទិទํ អានន្ទោ តតិមត្តានํ សតិមត្តានํ ធិតិមត្តានํ ឧបដ្ឋាកា-នํ យទិទํ អានន្ទោ** *ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកចេះដឹងច្រើន ដែលជាសាវ័ករបស់តថាគតស្រេចនឹងអានន្ទ ពួកភិក្ខុអ្នកមានស្មារតី ពួកភិក្ខុអ្នកមានគតិ ពួកភិក្ខុអ្នកមានប្រាជ្ញា ពួកភិក្ខុជាឧបដ្ឋាក ស្រេចនឹងអានន្ទដែរ*[១]

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ២០ ទំព័រ ៥៥ ។ ក្នុងអដ្ឋកថា មនោរថបូរណី បានពន្យល់ព្រះបាលីនេះថា ពហុស្សុតានន្តិ អាឡិសុ អញ្ញេបិ ថេរា ពហុស្សុតា សតិមន្តា តតិមន្តា ធិតិមន្តា ឧបដ្ឋាកា ច អត្ថិ ។ អយំ បនាយស្មា ពុទ្ធវចនំ ឧគ្គណ្ហាត្តេ ឧសពលស្ស សាសនេ ភណ្ឌាគារិកបរិយត្តិយំ ឋត្វា ភណ្ឌិ ។ តស្មា ពហុស្សុតានំ អគ្គោ ជាម ជាតោ ។ ឥមស្សេវ ច ថេរស្ស ពុទ្ធវចនំ ភហេត្វា ជារណាភសតិ អញ្ញេហិ ថេរេហិ ពលវតរា អហោសិ តស្មា សតិមន្តានំ អគ្គោ ជាម ជាតោ ។ អយមេវ ចាយស្មា ឯកបនេ ឋត្វា សដ្ឋិ ឋនសហស្សានិ ភណ្ឌាត្តេ សត្ថារា ភាសិតនិយាមេនេវ សព្វបជានិ ជាជាតិ តស្មា ភតិមន្តានំ អគ្គោ ជាម ជាតោ ។ តស្សេវ ចាយស្មតោ ពុទ្ធវចនំ ឧគ្គណ្ហនវីរិយំ សជ្ឈាយ-នវីរិយញ្ច ជារណាវីរិយញ្ច សត្ថ ឧបដ្ឋានវីរិយញ្ច អញ្ញេហិ អសទិសំ អហោសិ តស្មា

ជិតិមត្តានំ អត្តោ ជាម ជាតោ ។ តថាគតំ ឧបដ្ឋហន្តោ ចេស ន អញ្ញេសំ ឧបដ្ឋាក-ភិក្ខូនំ ឧបដ្ឋានការេន ឧបដ្ឋហិ អញ្ញេ ហិ តថាគតំ ឧបដ្ឋហន្តា ន ចិរំ ឧបដ្ឋហឺសុ ន ច ពុទ្ធានំ មនំ កហេត្វា ឧបដ្ឋហឺសុ ។ អយំ ថេរោ បន ឧបដ្ឋាកដ្ឋានំ លទ្ធនិវសតោ បដ្ឋាយ អារទ្ធវីរិយោ ហុត្វា តថាគតស្ស មនំ កហេត្វា ឧបដ្ឋហិ។ តស្មា ឧបដ្ឋាការានំ អត្តោ ជាម ជាតោ ។ *ព្រះថេរៈទាំងឡាយ ដទៃជាពហុស្សុតក៏មាន ជាអ្នកមានសតិក៏មាន ជាអ្នកមានគតិក៏មាន ជាអ្នកមានធិតិក៏មាន ជាឧបដ្ឋាកក៏មាន ក្នុងបទទាំងឡាយមានជាអាទិ៍ថា* **ពហុស្សុតានំ** *។ ក៏ព្រះថេរៈដ៏មានអាយុអង្គនេះ កាលរៀនយកនូវព្រះពុទ្ធវចនៈ រមែងរៀនយកដោយតាំងនៅក្នុងភាពជាអ្នករក្សាកណ្ឌៈ គឺព្រះបរិយត្តិក្នុងសាសនាព្រះទសពល ។ ព្រោះដូច្នោះ ព្រះថេរៈទើបមាននាមថា* ***ពហុស្សុត*** *ជាអ្នកប្រសើរជាងពហុស្សុតទាំងឡាយ ។ ម្យ៉ាងទៀត ព្រះថេរៈ កាលរៀនយកនូវព្រះពុទ្ធវចនៈ រមែងជាអ្នកមានសតិជាគ្រឿងទ្រទ្រង់ទុកដ៏មានកម្ទាំងលើសជាងព្រះថេរៈទាំងឡាយដទៃ ព្រោះដូច្នោះ ព្រះថេរៈទើបមាននាមថា* ***ជាអ្នកមានសតិ*** *ប្រសើរលើសជាងអ្នកមានសតិទាំងឡាយ ។ មួយវិញទៀត ព្រះថេរៈដ៏មានអាយុអង្គនេះ កាលតាំងនៅក្នុងបទតែមួយ ហើយកាន់យកនូវបទហុកសិបពាន់ ដឹងនូវបទទាំងពួង តាមនិយាមនៃការសម្តែងរបស់ព្រះសាស្តា ព្រោះដូច្នោះ ព្រះថេរៈទើបមាននាមថា* ***ជាអ្នកមានគតិ*** *ប្រសើរជាងភិក្ខុអ្នកមានគតិទាំងឡាយ ។ ដទៃទៀត ការព្យាយាមរៀននូវព្រះពុទ្ធវចនៈក្តី ការព្យាយាមស្វាធ្យាយក្តី ការព្យាយាមទ្រទ្រង់ទុកក្តី ការព្យាយាមបម្រើក្តីរបស់ព្រះថេរៈអង្គនេះ គឺមិនមានព្រះថេរៈអង្គណាដទៃស្មើឡើយ ព្រោះដូច្នោះ ព្រះថេរៈ ទើបមាននាមថា* ***ជាអ្នកមានធិតិ*** *ប្រសើរលើសជាងភិក្ខុអ្នកមានធិតិទាំងឡាយ ។ ក៏ព្រះថេរៈអង្គនេះ កាលបម្រើព្រះតថាគត មិនបម្រើដោយអាការដែលភិក្ខុជាឧបដ្ឋាកទាំងឡាយដទៃបម្រើទេ មែនពិត ព្រះថេរៈទាំងឡាយដទៃ បម្រើព្រះតថាគត មិនបានបម្រើអស់កាលយូរផង មិនបម្រើដោយកាន់យកនូវព្រះទ័យរបស់ព្រះពុទ្ធទាំងឡាយផង ។ ប៉ុន្តែ ព្រះថេរៈអង្គនេះ ចាប់តាំងពីថ្ងៃទទួលបានឋានៈជាឧបដ្ឋាកមក ជាអ្នកប្រារព្ធព្យាយាម ជាអ្នកបម្រើដោយកាន់យកព្រះទ័យព្រះតថាគត ។ ព្រោះដូច្នោះ ព្រះថេរៈ ទើបមាននាមថា* ***ជាឧបដ្ឋាក*** *ប្រសើរជាងឧបដ្ឋាកទាំងឡាយ ។*

សម្រាប់ជាធម្មទាន

និងពាក្យដែលព្រះធម្មសេនាបតីសារីបុត្រ សរសើរទុកយ៉ាងនេះថា **អាយស្មា អានន្ទោ អត្ថកុសលោ ធម្មកុសលោ ព្យញ្ជនកុសលោ និរុត្តិកុសលោ បុព្វាបរកុសលោ**[1] *អានន្ទដ៏មានអាយុ ជាអ្នកឈ្លាសក្នុងអត្ថ ១ ឈ្លាសក្នុងធម៌ ១ ឈ្លាសក្នុងអក្ខរប្បភេទ ១ ឈ្លាសក្នុងភាសា ១ ឈ្លាសទាំងខាងដើម ទាំងខាងចុង ១*[2] *ទើបឱ្យពួកសត្វកើតសេចក្ដីប្រាថ្នានឹងស្ដាប់ថា យើងបានស្ដាប់មកហើយយ៉ាងនេះ និងព្រះសូត្រនោះឯងពោលអំពីអត្ថ ព្យញ្ជនៈ មិនខ្វះ មិនលើសជាងគ្នា កាលបើដូច្នេះ ទើបមិនគប្បីឃើញដោយប្រការដទៃ ។ បទថា* **អញ្ញថា** *គឺដោយប្រការដទៃពីអាការដែលបានស្ដាប់មកហើយ ចំពោះព្រះកត្ត្រៃរបស់ព្រះដ៏-មានព្រះភាគ តែមិនមែនដោយប្រការដទៃពីអាការដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងហើយ ។ មែនពិត ទេសនារបស់ព្រះដ៏មានព្រះភាគ មានអានុភាពជាអចិន្ដ្រៃយ៍ ។ ទេសនានោះ អ្នកណាៗ មិនអាចដឹងបានដោយអាការ ទាំងពួងព្រោះដូច្នោះ លោកទើបពោលសេចក្ដីនេះទុកដូច្នោះឯង ។ មែនពិត កម្ទាំងនៃការទ្រទ្រង់ ក៏គឺការដែលមិនខុសឃ្លាតពីអាការដែលបានស្ដាប់មកហើយឡើយ ។*

មេ-ស័ព្ទ*ប្រាកដនៅក្នុងសេចក្ដី ៣ យ៉ាង ។ ពិតដូច្នោះ* **មេ-**ស័ព្ទ *មាន*

---

*១-*បុព្វាបរកុសលោតិ អត្ថបុព្វាបរំ ធម្មបុព្វាបរំ អក្ខរបុព្វាបរំ ព្យញ្ជនបុព្វាបរំ អនុសន្ធិបុព្វាបរន្តិ ឥមស្មឹ បញ្ចវិធេ បុព្វាបរេ ឆេកោ ។ *ឈ្មោះថា ឈ្លាសត្រង់ខាងដើមនិងខាងចុង គឺជាអ្នកឈ្លាសក្នុងខាងដើមនិងខាងចុង ៥ យ៉ាងគឺ ឈ្លាសទាំងអដ្ឋកថាខាងដើម និងអដ្ឋកថាខាងចុង ១ ឈ្លាសទាំងបាលីខាងដើម និងបាលីខាងចុង ១ ឈ្លាសទាំងបទខាងដើម និងបទខាងចុង ១ ឈ្លាសទាំងអក្ខរប្បភេទខាងដើម និងអក្ខរប្បភេទខាងចុង ១ ឈ្លាសទាំងអនុសន្ធិខាងដើម និងអនុសន្ធិខាងចុង ១ ។ (មនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ)*

២-សុត្តន្ដបិដក អង្គុត្តរនិកាយ បញ្ចកនិបាត លេខ ៤៥ ទំព័រ ១៤៦

សេចក្តីថា **មយា** *គឺខ្ញុំ ដូចក្នុងប្រយោគមានជាអាទិ៍ថា* **គាថាភិគីតម្មេ អភោជនេយ្យំ** *ភោជន គឺតថាគតពោលហើយដោយគាថា ជាវត្ថុមិនគួរដល់ការបរិភោគទេ*[១]។ *មានសេចក្តីថា* **មយ្ហំ** *ដល់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា* **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះមានព្រះភាគសម្តែងធម៌ដោយសង្ខេប ប្រោស (ដល់) ខ្ញុំព្រះអង្គផងចុះ*[២] ។ *មានសេចក្តីថា* **មម** *របស់ខ្ញុំ ដូចក្នុងប្រយោគមានជាអាទិ៍ថា* **ធម្មទាយាទា មេ ភិក្ខវេ ភវថ** *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមរតក*[៣]។ *តែក្នុងទីនេះ* **មេ**-*ស័ព្ទ រមែងត្រឹមត្រូវក្នុងសេចក្តីទាំង ២ គឺ* **មេ សុតំ** *គឺខ្ញុំស្តាប់មក* **មម សុតំ** *ការស្តាប់របស់ខ្ញុំ ។*

តែក្នុងទីនេះ **មេ**-*ស័ព្ទ សូម្បីទាំង ៣ យ៉ាង រមែងប្រាកដក្នុងអត្ថតែមួយប៉ុណ្ណោះ ព្រោះប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួន ពោលគឺកើតចំពោះខ្លួន ដែលគប្បីពោលយ៉ាងនេះថា សភាវៈណាមិនជាដទៃ សភាវៈនោះគឺ អត្តា ក៏ពិតមែនហើយ ក៏ប៉ុន្តែថា ការដឹងបានភ្លាមថាសេចក្តីផ្សេងនៃអត្ថនេះ ពោលគឺ សេចក្តីពិសេសនៃករណៈ និងសម្បទានៈជាដើម ព្រោះដូច្នោះ គប្បីឃើញថា* **មេ**-*ស័ព្ទលោកពោលថា ប្រាកដក្នុងអត្ថ ៣ យ៉ាង ។*

សុត-*ស័ព្ទក្នុងបទថា* **សុតំ** *នេះ មានទាំងឧបសគ្គ និងមិនមានឧបសគ្គ មានប្រភេទនៃអត្ថជាច្រើន ដូចគមនៈ វិស្សុតៈ កិលិន្នៈ ឧបចិត្តៈ អនុយោគៈ*

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ២៩ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ សឡាយតនវគ្គ លេខ ៣៥ ទំព័រ ១៤០ ។

៣-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២០ ទំព័រ ៣៩ ។

សោតវិញ្ញេយ្យ: សោតទ្វារនុសារវិញ្ញាត:ជាដើម ។ មែនពិត ឧបសគ្គ រមែងធ្វើកិរិយាឱ្យពិសេសឡើងក៏មែនពិតហើយ ក៏ប៉ុន្តែថា សូម្បីកាលមានឧបសគ្គ **សុត**-*ស័ព្ទនុ៎ះឯង ក៏បញ្ចេញដល់អត្ថនោះ ព្រោះបំភ្ជឹដល់អត្ថ ព្រោះដូច្នោះ ក្នុងការពង្រីកសេចក្តីរបស់* **សុត**-*ស័ព្ទ ដែលមិនមានឧបសគ្គ នឹងកាន់យកសុត:មានឧបសគ្គក៏មិនខុសគ្នា ។*

ក្នុងពាក្យថា **សុតំ** *នោះ* **សុត**-*ស័ព្ទនោះ សេចក្តីថា* **ទៅ** *ដូចក្នុងប្រយោគមានជាអាទិ៍ថា* **សេនាយ បសុតោ** *បញ្ជូនទ័ពទៅ ។ សេចក្តីថា* **ច្បាស់** *ដូចក្នុងប្រយោគមានជាអាទិ៍ថា* **សុតធម្មស្ស បស្សតោ** (*វិវេក*) *របស់បុគ្គលអ្នកមានធម៌ស្តាប់ហើយ បានឃើញច្បាស់ហើយ(ញាណចក្ខុ)*[១] *។ សេចក្តីថា* **តម្រេក** *ដូចក្នុងប្រយោគជាអាទិ៍ថា* **អវស្សុតា អវស្សុតស្ស** *ភិក្ខុនីមានតម្រេកត្រេកអរការដែលបុរសមានតម្រេកមកស្ទាបអង្អែលកាយ*[២] *។ សេចក្តីថា* **សន្ធ្យ** *ដូចក្នុងប្រយោគមានជាអាទិ៍ថា* **តុម្ហេហិ បុញ្ញ បសុតំ អនប្ផកំ** *បុណ្យឈ្មោះថា បានសន្ធ្យុំទុក មិនមែនតិចឡើយផង*[៣] *។ សេចក្តីថា ខ្ជល់ខ្ជាយ ដូចក្នុងប្រយោគមានជាអាទិ៍ថា* **យេ ឈានប្ផសុតា ធីរា** *អ្នកប្រាជ្ញទាំងឡាយណាជាអ្នកខ្ជល់ខ្ជាយក្នុងឈាន*[៤]*។ សេចក្តីថា* **សំឡេងដែលដឹងបានតាមសោត:** *ដូចក្នុងប្រយោគមានជាអាទិ៍ថា* **ឌិដ្ឋំ សុតំ មុតំ** *រូបបានឃើញ សំឡេងបានឮ អារម្មណ៍បានដឹង*[៥] *។ សេចក្តីថា* **ដឹងបានតាមសោតទ្វារ** *ដូចក្នុងប្រយោគមាន*

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ១៣៤ ។

២-វិនយបិដក ភិក្ខុនីវិភង្គ លេខ ៥ ទំព័រ ៨ ។

៣-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១៥ ។

៤-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៦១ ។

៥-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ៥៤ ។

ជាអាទ៍ថា **សុតឌបោ សុតសន្ធិច្ចយោ** ទ្រទ្រង់នូវពុទ្ធវចន: នូវពុទ្ធវចន:នេះ[1] ។ តែក្នុងទីនេះ ស័ព្ទថា **សុត:** សេចក្តីថា ចូលទៅទ្រទ្រង់ទុក ឬការចងចាំដោយវិញ្ញាណ ដែលមានសោតវិញ្ញាណ ។ ក្នុងពាក្យនោះ កាលណា **មេ**-ស័ព្ទ មានសេចក្តីថា **មយា** គឺខ្ញុំ កាលនោះការប្រកបសេចក្តី គឺខ្ញុំស្តាប់មកហើយ គឺចងចាំបានដោយវិញ្ញាណ ដែលមានសោតវិញ្ញាណយ៉ាងនេះ ។ កាលណា **មេ**-ស័ព្ទ មានសេចក្តីថា **មម** របស់ខ្ញុំ កាលនោះ ការប្រកបសេចក្តីថា ការស្តាប់របស់ខ្ញុំ គឺការចងចាំបានដោយសោតទ្វារ ។

បណ្តាបទទាំង ៣ តាមដែលពោលមកនោះ ព្រោះហេតុដែល **ឯ**ំ-ស័ព្ទ ប្រើប្រកបនឹង**សុត**-ស័ព្ទ គប្បីបំភ្ជឹដល់កិរិយាស្តាប់ ដូច្នោះ បទថា **ឯ**ំ ជាពាក្យសម្តែងខ្ចៃដល់កិច្ចនៃវិញ្ញាណដែលប្រព្រឹត្តទៅតាមសោតទ្វារ មានសោតវិញ្ញាណ និងសម្បដិច្ឆន្ន:ជាដើម និងវិញ្ញាណដែលប្រព្រឹត្តទៅតាមមនោទ្វារវិញ្ញាណ មានសោតទ្វារនោះនាំមក ។ បទថា **មេ** ជាបទសម្តែងខ្ចៃដល់បុគ្គលដែលដល់ព្រមដោយវិញ្ញាណដូចពោលហើយ ។ មែនពិត វាក្ય: គឺពាក្យនិយាយដែលជាប្រយោគ គ្រប់ពាក្យប្រកបដោយអត្ថនៃ **ឯ**ំ-អក្សរនុ៎ះឯង ព្រោះពាក្យទាំងនោះ មានអវធារណ:ជាផល ។ បទថា **សុតំ** ជាបទសម្តែងខ្ចៃដល់ការកាន់យកមិនលើស មិនខ្វះ និងមិនវិបរិត ច្រាសចាកការបដិសេធ ការមិនបានស្តាប់ ។ ពិតយ៉ាងនោះ ការស្តាប់គួរនឹងពោលថា **សុតមេវ** យ៉ាងណា ការស្តាប់នោះ ក៏ដូច្នោះ ជាការស្តាប់ត្រឹមត្រូវ គឺជាការកាន់យកមិនខ្វះ មិនលើស និងមិនវិបរិត ។ ម្យ៉ាងទៀត សំឡេងដែលសម្តែងនូវអត្ត ដោយអំណាចនៃការបំភ្ជឹដល់អត្តតាម

---

[1]-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក: លេខ ២២ ទំព័រ ២១ ។

*លំដាប់នៃសំឡេង ព្រោះហេតុដូច្នោះ ក្នុងចំណែកនេះ ព្រោះហេតុដែល**សុត**-ស័ព្ទនេះ មានអត្ថដែលលោកពោលទុកដូច្នេះថា* **អសុតំ ន ហោតិ** *ការមិនបានឮ រមែងមិនមាន ព្រោះហេតុនោះ បទថា* **សុតំ** *ទើបជាបទសម្តែងខ្ចៃដល់ការកាន់យក មិនខ្ទុះ មិនលើស និងមិនវិបរិត ដោយបដិសេធការៈដែលមិនបានស្តាប់ ។ ព្រះថេរៈពោលអធិប្បាយពាក្យនេះទុកដូច្នេះ យើងបានស្តាប់មក ហើយយ៉ាងនេះ យើងមិនបានឃើញ យើងមិនធ្វើឱ្យច្បាស់ដោយសយម្ភូញាណ ឬយើងមិនបាន មកដោយប្រការដទៃទេ ។ ម្យ៉ាងទៀត យើងបានស្តាប់មក ហើយតែម្តង និងការស្តាប់នោះឯងជាការស្តាប់ដោយប្រពៃពិត ។ ម្យ៉ាងទៀត ក្នុង* **ឯ**ំ*-ស័ព្ទ ដែលមានអវធារណៈជាអត្ថ ក៏មានអត្ថយោជនា ការប្រកបសេចក្តីដូចពោលមកនេះ ។* **សុត***-ស័ព្ទ ដែលសម្ងឹងដល់* **ឯ**ំ*-ស័ព្ទនោះ មានអត្ថប្រាកដ ព្រោះដូច្នោះ* **សុត***-ស័ព្ទ ដែលបញ្ជេញដល់* **ឯ**ំ*-ស័ព្ទនោះ គប្បីជ្រាបថា បដិសេធការៈដែលមិន បានឮ និងពោលជាការសម្តែងពន្យល់ដល់ការកាន់យកមិនខ្ទុះ មិនលើស និងមិនវិបរិតដូច្នោះ គប្បីជ្រាបថា លោកធ្វើអត្ថយោជនានៃស័ព្ទទាំង ៣ សូម្បីដោយអំណាចនៃការស្តាប់ ហេតុនៃការស្តាប់ និងសេចក្តីប្លែកគ្នានៃការស្តាប់ ។*

ម្យ៉ាងទៀត បទថា **ឯ**ំ *ជាការប្រកាសការៈនៃវិញ្ញាណវិថី ដែលប្រព្រឹត្តទៅតាមក្រសៃនៃសោតវិញ្ញាណនោះ ប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយប្រការផ្សេងៗ ព្រោះការកាន់យកអត្ថ និងព្យញ្ជនៈផ្សេងៗ ហើយធ្វើការអធិប្បាយថា* **ឯ**ំ*-ស័ព្ទមានអាការជាអត្ថ ។ បទថា* **មេ** *ជាបទប្រកាសអត្ថ ។ បទថា* **សុតំ** *ជាបទប្រកាសធម៌ ព្រោះការៈនៃវិញ្ញាណវិថី ដែលពោលហើយមានបរិយត្តិធម៌*

ជាអារម្មណ៍ ។ មែនពិត ក្នុងសេចក្ដីនេះ មានសេចក្ដីសង្ខេបដូចតទៅនេះ កិច្ចដទៃ ដែលអញមិនធ្វើហើយ ព្រោះការៈនៃការធ្វើដោយវិញ្ញាណវិថី ដែលប្រព្រឹត្តទៅ ក្នុងអារម្មណ៍ដោយប្រការផ្សេងៗ ដែលជាតួហេតុ ប៉ុន្តែកិច្ចនេះ អញបានធ្វើហើយ គឺធម៌នេះ អញបានស្គាប់ហើយ ។

ម្យ៉ាងទៀត បទថា **ឯ** ជាការប្រកាសអត្តដែលគប្បីសម្ដែងខ្ចៃ ព្រោះ អធិប្បាយថា **ឯ**-ស័ព្ទ មានន័ទស្សនៈជាអត្ត ព្រោះនឹងត្រូវសម្ដែងខ្ចៃអត្តដែល គួរសម្ដែងខ្ចៃ ។ ព្រោះដូច្នោះ ព្រះសូត្រសូម្បីទាំងអស់គប្បីជ្រាបថា គឺលោក កាន់យកហើយដោយ **ឯ**-ស័ព្ទ ។ បទថា **មេ** ជាការប្រកាសបុគ្គល ។ បទថា **សុតំ** ជាការប្រកាសកិច្ចរបស់បុគ្គល ។ មែនពិត កិរិយាស្គាប់ កាលបានដោយ **សុត**-ស័ព្ទ រមែងជាប់ដោយសោតវិញ្ញាណចិត្ត និងក្នុងសេចក្ដីនោះ រមែងមាន ការបញ្ញត្តិដល់បុគ្គល តែក្នុងវត្ថុដែលជាប់នឹងធម៌ ដែលវៀរចាកបញ្ញត្តិដល់ បុគ្គល រមែងមិនបានកិរិយាស្គាប់ ។ **សុត**-ស័ព្ទនោះ មានសេចក្ដីដោយសង្ខេប ដូច្នេះថា អញនឹងសម្ដែងព្រះសូត្រណា ព្រះសូត្រនោះ គឺអញបានស្គាប់មក ហើយយ៉ាងនេះ ។

ម្យ៉ាងទៀត បទថា **ឯ** ជាបទសម្ដែងអាការផ្សេងៗ របស់ចិត្តសន្ធាន ឯណា ដែលតោងយកអត្ត និងព្យញ្ជនៈផ្សេងៗ ដោយការប្រព្រឹត្តទៅក្នុង អារម្មណ៍ផ្សេងៗ ព្រោះអធិប្បាយថា **ឯ**-ស័ព្ទមានអាការជាអត្តនោះឯង ។ មែន-ពិត អាការប្ញញ្ញត្តិថា **ឯ** នេះ ព្រោះអាស្រ័យអាការនៃការប្រព្រឹត្តទៅនោះ ។

របស់ធម៌ទាំងឡាយហើយទើបបញ្ញត្តិឡើងជាសការៈ ។ បទថា **មេ** *ជាការសម្តែងដល់បុគ្គលអ្នកធ្វើ ។ បទថា* **សុតំ** *ជាការសម្តែងដល់អារម្មណ៍ ។ មែនពិត ធម៌ដែលគួរស្តាប់ ជាទីតាំងនៃការប្រព្រឹត្តទៅ ដោយអំណាចនៃកិរិយាស្តាប់របស់បុគ្គលដែលធ្វើនូវការស្តាប់ ។ ដោយហេតុត្រឹមតែប៉ុណ្ណោះ ជាការសម្តែងសេចក្តីសន្និដ្ឋានៃការទទួលអារម្មណ៍របស់អ្នកធ្វើ ដែលដល់ព្រមដោយកិរិយាស្តាប់នោះ ដោយសន្តានចិត្តដែលប្រព្រឹត្តទៅដោយប្រការផ្សេងៗ ។*

ម្យ៉ាងវិញទៀត បទថា **ឯវं** *សម្តែងកិច្ចរបស់បុគ្គល ។ មែនពិត ដោយ* **ឯវं**-*ស័ព្ទ មានការប្រកាសនិទស្សនៈ ឬអវធារណៈ ដែលមានអាការកាន់យកធម៌ដែលបានស្តាប់ហើយជាសការៈ ជាការសម្តែងខៃដល់កិច្ចរបស់បុគ្គល ដោយការៈនៃការប្រកាន់បញ្ញត្តិថា បុគ្គល និងការខ្ជល់ខ្ជាយក្នុងធម៌របស់ការទ្រទ្រង់អាការនោះឯងជាដើម ។ បទថា* **សុតំ** *សម្តែងខៃកិច្ចរបស់វិញ្ញាណ ។ មែនពិត កិរិយាស្តាប់សូម្បីរបស់អ្នកមានវាទៈថា បុគ្គលមិនប្រាជ្ញាដល់វិញ្ញាណ ក៏មិនមែន ។ បទថា* **មេ** *ជាការសម្តែងដល់បុគ្គលដែលប្រកបកិច្ចទាំងពីរ ។ មែនពិត ការប្រព្រឹត្តទៅនៃស័ព្ទថា* **មេ** *ជាអារម្មណ៍ពិសេសនៃសត្ត ដោយចំណែកតែមួយប៉ុណ្ណោះ និងកិច្ចរបស់វិញ្ញាណក៏គប្បីប្រជុំចុះក្នុងទីនោះឯង ។ ចំណែកសេចក្តីសង្ខេបក្នុងសេចក្តីនេះមានដូច្នេះ គឺខ្ញុំបានស្តាប់មកហើយ ដោយវោហារនៃសវនកិច្ច គឺបុគ្គលអ្នកដល់ព្រមដោយសោតវិញ្ញាណកិច្ច ហើយដោយអំណាចវិញ្ញាណ ។*

ម្យ៉ាងទៀត បទថា **ឯវं** *និង* **មេ** *ឈ្មោះថា អវិជ្ជមានបញ្ញត្តិ ដោយអំណាចសច្ចិកដ្ឋបរមត្ត ។ ក៏ព្រោះប្រយោជន៍ទាំងពួង ដែលនឹងគប្បីសម្រេច*

ដោយសទ្ធា ចាំបាច់ត្រូវបដិបត្តិ ដោយប្រធានៃបញ្ញត្តិប៉ុណ្ណោះ ឈ្មោះថា ជាសេចក្តីភ្ញាំងភ្ញាត់នៃបញ្ញត្តិទាំងពួង និងក្នុងបញ្ញត្តិ ៦ មាន វិជ្ជមានបញ្ញត្តិជាដើម ព្រោះដូច្នោះ អត្តដែលមិនពិតយ៉ាងណា ដូចកលល្បិច មានមាយា និងថ្ងៃបណ្តើរកូនជាដើម និងអត្តមិនមែនឧត្តមដូចនឹងគប្បីកាន់យកដោយអាការដែលស្តាប់តាមគ្នាមកជាដើម មិនមានទេ អត្តនោះមានសភាវៈជាបរមត្ត មានរូបារម្មណ៍ សទ្ទារម្មណ៍ និងរសារម្មណ៍ជាដើម និងមានការរលាយ ការសោយអារម្មណ៍ជាដើម រមែងមានដោយអំណាចសច្ចិកដ្ឋបរមត្ត ។ ក៏អត្ត គឺអាការជាដើមដែលពោលថា **ឯវํ** និង **មេ** មានសភាវៈមិនមែនបរមត្ត កាលមិនចូលនឹងសច្ចិកដ្ឋបរមត្ត ឈ្មោះថា អវិជ្ជមានបញ្ញត្តិ ។ ព្រោះដូច្នោះ វត្ថុដែលលោកទាំង-ឡាយបានសម្តែងថា **ឯវํ** ឬ **មេ** នឹងមាននៅដោយបរមត្តបានយ៉ាងណា ។ បទថា **សុតํ** បានដល់វិជ្ជមានបញ្ញត្តិ បញ្ញត្តិវត្ថុដែលមាននៅ មែនពិត វត្ថុមួយណាដែលបានដោយសោតវិញ្ញាណនោះ ដោយបរមត្ត ឈ្មោះថា វិជ្ជមាន-បញ្ញត្តិនោះឯង ។

ម្យ៉ាងទៀត បទថា **ឯវํ** ឈ្មោះថា ឧបាទាយបញ្ញត្តិ ដោយអាស្រ័យធម៌ដែលមកប្រាកដតាមសោតទ្វារហើយកាន់យកអាការ គឺការទ្រទ្រង់ធម៌ទាំងនោះជាដើម ។ បទថា **មេ** ឈ្មោះថា ឧបាទាយបញ្ញត្តិ[១] ព្រោះត្រូវពោលអាស្រ័យនូវខន្ធ ដែលរាប់បញ្ចូលក្នុងសន្ត្តតិដ៏ពិសេស ដោយសេចក្តីប្លែកគ្នានៃការធ្វើជាដើម ។ បទថា **សុតํ** ឈ្មោះថា ឧបនិធាបញ្ញត្តិ ព្រោះចូលទៅប្រកាន់យកទិដ្ឋិជាដើម ។

១-ក្នុងបរមត្ថទីបនី អដ្ឋកថា ឧទាន ច្បាប់របស់ធម្មសង្គាយនាថា ឧបាទាបញ្ញត្តិ ។

ហៅថា **សុតៃ** សូម្បីប្រព្រឹត្តទៅក្នុងសទ្ទាយតនៃ ដែលរៀរចាកសការៃ មានរូបដែលឃើញហើយជាដើម ក៏ពោលដល់ការកាន់យករូបដែលឃើញជាដើម ព្រោះមិនសម្ងឹងរូបដែលឃើញហើយ អារម្មណ៍ដែលជ្រាបហើយ និងធម៌ដែលដឹងច្បាស់ហើយ ក៏ដឹងច្បាស់ថា វត្ថុនោះយើង ស្តាប់ហើយដូចហៅថា ទី ២ និងទី ៣ ជាដើម ក៏ពោលដល់ការកាន់យកទី ១ ជាដើម ។ ក៏បទថា **សុតំ** ក្នុងពាក្យថា **អសុតំ ន ហោតិ** នេះ មានអត្ថដែលលោកពោលទុកត្រឹមតែប៉ុណ្ណោះឯង ។

ក៏ក្នុងពាក្យទាំងនោះ ដោយពាក្យថា **ឯវំ** ព្រះថេរៈសម្តែងដល់សេចក្តីមិនវង្វេងក្ងេច ។ មែនពិត សេចក្តីប្លែកគ្នាដោយប្រការនៃព្រះសូត្រ ដែលខ្ជួនដឹងច្បាស់ហើយ ព្រះអានន្ទប្រកាន់យកក្នុងពាក្យថា **ឯវំ** នេះ រមែងជាការបំភ្ជ ដែលព្រះអានន្ទសម្តែងដល់សេចក្តីមិនវង្វេងដោយ **ឯវំ**-ស័ព្ទនោះ ។ មែនពិត លោកអ្នកវង្វេងរមែងមិនអាចដើម្បីនឹងដឹងច្បាស់ដោយប្រការផ្សេងៗ ។ លោកសម្តែងប្រការផ្សេងៗ និងប្រការដែលដឹងបានលំបាកដោយអំណាចបច្ចយាការថា ព្រះសូត្រ ។ ដោយពាក្យថា **សុតំ** លោកសម្តែងដល់សេចក្តីមិនវង្វេង ក្ងេចរឿងដែលបានស្តាប់មកហើយ ព្រោះអាការនៃរឿងដែលបានស្តាប់មកហើយ លោកសម្តែងទុកតាមសេចក្តីពិត ។ ក៏ព្រះសូត្រដែលអ្នកណាស្តាប់ហើយក្ងេចភ្ជាំងអ្នកនោះរមែងមិនប្តេជ្ញាថា យើងបានស្តាប់មកហើយក្នុងអន្តរកាល ។ ព្រោះដូច្នោះ សេចក្តីសម្រេចនៃបញ្ញាក្នុងកាលក្រៃលែងជាងនោះ រមែងមានដោយសេចក្តីមិនវង្វេងក្ងេចរបស់ព្រះថេរៈ គឺមិនមានសេចក្តីវង្វេងក្ងេច ឬដោយបញ្ញានោះឯងដែលកើតអំពីការស្តាប់ សេចក្តីសម្រេចនៃសតិរមែងមានដោយសេចក្តីមិនវង្វេងក្ងេចដូចគ្នា ។ គប្បីជ្រាបអធិប្បាយក្នុងសេចក្តីនោះថា សតិដែលមានបញ្ញាជា

ប្រធាន អាចហាមសេចក្ដីដទៃដោយញាណ: ។ មែនពិត អាការរបស់ញាណ: ដែលនឹងគប្បីដឹងច្បាស់រហូតដល់អស់អាការមិនជ្រៅ អ្នកទ្រទ្រង់ចាំសុត:តាមដែលបានស្ដាប់មក ទើបជាករណីយកិច្ចក្នុងសេចក្ដីនោះ ព្រោះដូច្នោះ សតិទើបមានសេចក្ដីខ្ជល់ខ្ជាយក្រៃលែងជាង ចំណែកបញ្ញាជាតួគុណ ក្នុងសេចក្ដីព្យាយាមរបស់សតិនោះ ព្រោះអធិប្បាយថា ជាអង្គខាងដើមរបស់បញ្ញា ។ គប្បីជ្រាបសេចក្ដីដែលបញ្ញា មានសតិជាប្រធាន ព្រោះអាចចាក់ធ្ងុះអត្ថបាន ។ មែនពិត អាការដែលនឹងគប្បីចាក់ធ្ងុះអត្ថបាន ជាអាការជ្រាលជ្រៅ ព្រោះដូច្នោះ បញ្ញាទើបមានសេចក្ដីព្យាយាមក្រៃលែង ចំណែកសតិជាគុណក្នុងសេចក្ដីព្យាយាមរបស់បញ្ញានោះ ព្រោះអធិប្បាយថា ជាប្រធាននៃសតិ ។ គប្បីជ្រាប ការសម្រេចនៃភាពជាធម្មកណ្ឌាគារិក ដោយភាពជាអ្នក អាចតាមរក្សាធម៌ ដែលបរិបូណ៌ដោយអត្ថ និងញាណ: ព្រោះប្រកបដោយសេចក្ដីអាចក្នុងសតិ និងបញ្ញាទាំងពីរនោះ ។

ន័យម្យ៉ាងទៀត លោកសម្ដែងយោនិសោមនសិការដោយពាក្យថា **ឯវํ** ក៏សេចក្ដីសម្រេចដែលមិនវិបរិតនៃអត្ថរបស់អាការ និទស្សន: និងអវធារណ: ដែលពោលដោយបទថា **ឯវํ** នោះ បំភ្ជឹដល់ការចាក់ធ្ងុះបការ:ផ្សេងៗ ដែលនឹងពោលខាងមុខ ព្រោះមានធម៌ជាអារម្មណ៍ ។ សេចក្ដីពិតថា ការចាក់ធ្ងុះបការ:ផ្សេងៗ ដោយអយោនិសោមនសិការមែងមិនមាន លោកសម្ដែងដល់សេចក្ដីមិនរវើរវាយដោយពាក្យថា **សុតํ** ។ ការស្ដាប់ព្រះសូត្រដែលពោលជាចំណែកនៃបករណ៍ដោយអំណាចពាក្យសួរមានជាអាទិ៍ថា បឋមពោធិសូត្រ លោកពោលទុកក្នុងទីណា រឿរចាកសេចក្ដីតាំងមាំចេញហើយ រមែងមិនមាន ព្រោះចិត្តរវើ-

រវាយ ។ ពិតដូច្នោះ បុគ្គលដែលមានចិត្តរវើរវាយ សូម្បីគេនឹងពោលអំពីសម្បត្តិគ្រប់យ៉ាង ក៏និយាយថា យើងមិនបានឮ លោកចូរនិយាយម្តងទៀត ។ ក៏បុគ្គលអ្នកឈ្វាសវៃក្នុងសេចក្តីនេះ រមែងញ៉ាំងអត្តសម្មាបណិធិ និងបុព្វេកតបុញ្ញតាឱ្យសម្រេច អ្នកដែលមិនបានតាំងខ្លួនទុកដោយប្រពៃ និងមិនបានធ្វើបុណ្យទុកក្នុងកាលមុន រមែងមិនមានយោនិសោមនសិការនោះ ។ ព្រោះសេចក្តីរវើរវាយ រមែងមិនឱ្យសម្រេចការស្តាប់ព្រះសទ្ធម្ម និងការគប់រកសប្បុរស អ្នកដែលមិនបានស្តាប់ និងមិនគប់រកសប្បុរស មិនមានយោនិសោមនសិការនោះ ។ ព្រោះថា អ្នកមានចិត្តរវើរវាយ មិនអាចស្តាប់បាន និងអ្នកដែលមិនគប់រកសប្បុរសក៏រមែងមិនមានការបានស្តាប់ដែរ ។

ន័យម្យ៉ាងទៀត លោកពោលថា (នោះ) ជាការសម្តែងខៃចិត្តសន្ធានដែលកាន់យកអត្ត និងព្យញ្ជនៈផ្សេងៗ ដោយការប្រព្រឹត្តទៅដោយប្រការផ្សេងៗ ។ ក៏ព្រោះហេតុដែលចិត្តសន្ធាននោះ គឺអាការដែលចម្រើនយ៉ាងនេះ ជាគ្រឿងធ្វើប្រយោជន៍របស់អ្នកដទៃឱ្យបរិបូណ៌គ្រប់យ៉ាង ដោយការធ្វាក់ចុះកាន់សាសនសម្បត្តិទាំងអស់ ដោយការកំណត់ប្រភេទអត្ត និងព្យញ្ជនៈ នៃព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ រមែងមិនមានដល់បុគ្គលដែលមិនតាំងខ្លួនទុកដោយប្រពៃ ឬអ្នកមិនបានធ្វើបុណ្យទុកក្នុងកាលមុនដូច្នោះ ដោយអាការដែលចម្រើនថា **ឯវํ** *នេះ ព្រះថេរៈសម្តែងចក្ខុសម្បត្តិ ២ ប្រការ របស់ខ្លួនជាខាងក្រោយ ដោយការប្រកបការស្តាប់ថា* **សុតํ** *ព្រះថេរៈសម្តែងចក្ខុសម្បត្តិ ២ ប្រការជាខាងដើម ។ សេចក្តីពិត អ្នកនៅក្នុងប្រទេសដែលមិនសមគួរ ឬអ្នកវៀរចាកការសេពគប់សប្បុរសរមែងមិនមានការស្តាប់ ។ ព្រោះដូច្នោះ សេចក្តីបរិសុទ្ធនៃ*

អធ្យាស្ស័យរបស់ព្រះថេរៈមែងសម្រេចដោយសម្រេចនៃចក្រ ២ ប្រការ ជាខាងក្រោយ ។ អ្នកដែលតាំងខ្លួនទុកដោយប្រពៃ និងអ្នកបានបំពេញបុណ្យទុកក្នុងកាលមុន រមែងជាអ្នកមានអធ្យាស្ស័យបរិសុទ្ធ ព្រោះកិលេសដែលជាហេតុមិនបរិសុទ្ធនោះនៅឃ្លាតឆ្ងាយ ។ ពិតយ៉ាងនោះ លោកទើបពោលទុកថា **សម្ម្ាបណិហិតំ ចិត្តំ សេយ្យសោ ឦ តតោ ករេ** ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះឱ្យប្រសើរជាងហេតុនោះបាន[១] និងថា **ករតបុញ្ញោសិ តំ អានន្ទ បជានមនុយុញ្ជ ទិប្ប៎ ហោហិបិ អនាសវោ** ម្ាលអានន្ទ ខ្លួនអ្នកជាបុគ្គលបានធ្វើបុណ្យហើយ ចូរប្រកបព្យាយាមឱ្យរឿយៗចុះ នឹងបានជាបុគ្គលមិនមានអាសវៈដោយឆាប់[២] ។ សេចក្ដីសម្រេចនៃការប្រកបព្រោះសេចក្ដីសម្រេចនៃចក្ក ២ ប្រការជាខាងដើម ។ ក៏ការប្រកបដ៏បរិសុទ្ធ រមែងមានដោយការដើរតាមទិដ្ឋានុគតិរបស់សាធុជន ដោយការនៅក្នុងប្រទេសដ៏សមគួរ និងដោយការគប់រកសប្ប៉ុរស ។ ក៏ការសម្រេចដោយភាពជាអ្នកស្ទាត់ជំនាញក្នុងអធិគមៈ រមែងមានបានដោយសេចក្ដីបរិសុទ្ធនៃអធ្យាស្ស័យនោះ ព្រោះខ្លួនបានជម្រះសង្កិលេស គឺតណ្ហា និងទិដ្ឋិ ក្នុងកាលមុនរៀបរយហើយ ការសម្រេចដោយការស្ទាត់ជំនាញក្នុងអាគមៈ រមែងមានដោយសេចក្ដីបរិសុទ្ធនៃការប្រកប ។ មែនពិត បុគ្គលដែលមានកាយប្រយោគ និងវចីប្រយោគដ៏បរិសុទ្ធល្អហើយ ឈ្មោះថា មានចិត្តមិនរវើរវាយ ព្រោះមិនមានសេចក្ដីក្តៅក្រហាយ រមែង

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៣០

២-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ៣០២ ។

ជាអ្នកធ្លាតក្នុងបរិយត្តិ ។ ព្រោះដូច្នោះ ពាក្យរបស់អ្នកបរិសុទ្ធដោយការប្រកប និងអធ្យាស្ស័យអ្នកបូរិបូរដោយអាគម: និងអធិគម ទើបគួរជាខាងដើម នៃ ព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ដូចអរុណរះជាខាងដើមនៃព្រះអាទិត្យ និង ដូចយោនិសោមនសិការ: ជាខាងដើមនៃកុសលកម្ម ព្រោះដូច្នោះ ព្រះអានន្ទ កាលនឹងតាំងនិទាន (ពាក្យចាប់ផ្តើម) ក្នុងឋាន:ដែលគួរទើបពោលពាក្យមាន ជាអាទិ៍ថា **ឯវម្មេ សុតំ** *។*

ន័យម្យ៉ាងទៀត ព្រះអានន្ទសម្តែងការ:នៃសម្បត្តិ គឺអត្តប្បដិសម្ភិទានិង បដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសម្តែងដល់សេចក្តីដឹងច្បាស់ ដោយប្រការផ្សេងៗ ដោយន័យដូចពោលហើយក្នុងកាលមុន ដោយពាក្យថា **ឯវํ** *នេះ ។ សម្តែងសការ: គឺសម្បត្តិនៃធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិសម្ភិទា ដោយការប្រៀបធៀប* **ឯวํ**-*ស័ព្ទ ឬដោយពាក្យដែលសម្តែងដល់ការចាក់ធ្ងុ ដោយបការ:ផ្សេងៗ ដែលគួរស្តាប់ដោយការសម្ងឹងពាក្យដែលនឹងពោលដល់ ដោយពាក្យថា* **សុតํ** *នេះ ។ ក៏ព្រះថេរ:កាលនឹងពោលដល់ពាក្យដែលសម្តែង យោនិសោមនសិការថា* **ឯวํ** *នេះ ដោយន័យដូចពោលហើយ ទើបសម្តែងថា ធម៌ទាំងនេះ យើងសម្ងឹងដោយចិត្ត ចាក់ធ្ងុះដ៏ល្អដោយទិដ្ឋិ ។ មែនពិត បរិយត្តិ-ធម៌ យើងសម្ងឹងដោយចិត្តដោយន័យមានជាអាទិ៍ថា សីល ត្រាស់ទុកក្នុងទីនេះ សមាធិ ត្រាស់ទុកក្នុងទីនេះ បញ្ញា ត្រាស់ទុកក្នុងទីនេះ អនុសន្ធិក្នុងទីនេះ មាន ប្រមាណប៉ុណ្ណោះ កំណត់ចាក់ធ្ងុះរហូតដល់អស់ដោយល្អ ដែលរូបធម៌ និង អរូបធម៌ ដែលត្រាស់ទុកក្នុងទីនោះៗ ដោយន័យមានជាអាទិ៍ថា រូបមានដូច្នេះ*

រូបមានប្រមាណប៉ុណ្ណោះ ដោយទិដ្ឋិដែលប្រកបដោយការត្រិះរិះ តាមអាការដែលបានស្គាប់តគ្នាមក ដែលជាការអត់ធន់ចំពោះការសម្ងឹងធម៌ ឬពោលគឺញាតបរិញ្ញា រមែងនាំប្រយោជន៍សុខដល់ខ្លួន និងអ្នកដទៃ ។ ព្រះថេរៈ កាលនឹងពោលពាក្យដែលសម្តែងដល់ការប្រកបក្នុងការស្គាប់ថា **សុតំ** *នេះ ទើបសម្តែងថា ធម៌ជាច្រើនយើងបានស្គាប់ហើយ ទ្រទ្រង់ចាំទុកហើយ រត់មាត់ហើយ ។ មែនពិត ការស្គាប់ ការទ្រទ្រង់ និងការសន្សំព្រះបរិយត្តិធម៌ ជាប់ដោយការផ្ទៀងសោតៈស្គាប់ ។ សូម្បីដោយបទទាំងពីរនោះ ព្រះថេរៈកាលសម្តែងសេចក្តីបរិបូណ៌នៃអត្ត និងញ្ញាណៈ ដោយភាពជាធម៌ដែលព្រះអង្គត្រាស់ល្អហើយឈ្មោះ ថា ឱ្យកើតសេចក្តីអើពើក្នុងការស្គាប់ ។ មែនពិត អ្នកដែលមិនបានស្គាប់ធម៌ដែលបូរិបូរដោយអត្ត និងញ្ញាណៈ ដោយអើពើរមែងជាអ្នកឃើញធ្លាយចាកប្រយោជន៍ដ៏ធំក្រៃលែង ព្រោះដូច្នោះ គប្បីឱ្យកើតសេចក្តីអើពើមុនហើយ ទើបស្គាប់ធម៌ដោយគោរព ។*

ក៏ដោយពាក្យទាំងអស់ថា **ឯវម្មេ សុតំ** *នេះ ព្រះអានន្ទ កាលលោកមិនចាំធម្មវិន័យដែលព្រះតថាគតប្រកាសហើយសម្រាប់ខ្លួន រមែងឈានទៅកាន់ភូមិអសប្បុរស កាលលោកប្តេជ្ញាខ្លួនថា ជាសាវ័ក ឈ្មោះថា ឈានចុះកាន់ភូមិសប្បុរស ។ ម្យ៉ាងទៀត ឈ្មោះថា រមែងធ្វើចិត្តឱ្យចេញចាកអសទ្ធម្ម និងធ្វើចិត្តឱ្យតាំងនៅក្នុងព្រះសទ្ធម្ម ។ ព្រះថេរៈកាលនឹងសម្តែងថា យើងស្គាប់នូវព្រះសូត្រទាំងអស់ផង និងព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគព្រះអង្គនោះឯងផង*

ឈ្មោះថា រមែងដោះលែងខ្លួន អាងដល់ព្រះសាស្តាប្រកាន់មាំនូវព្រះតម្រាស់
របស់ព្រះជិនស្រីធ្វើញ្ចាំងបែបផែននូវធម៌ប្រតិស្ថានទៅ ។

ម្យ៉ាងទៀត ព្រះថេរៈ កាលមិនប្តេជ្ញានូវភាពនៃខ្លួនឱ្យកើតឡើងឯង
ដោយពាក្យថា **ឯវម្មេ សុតំ** *កាលនឹងបើកផ្សាយពាក្យដែលស្តាប់មកមុន ទើប*
គិតថា ពាក្យនេះ យើងបានទទួលមកក្នុងទីចំពោះព្រះកត្ត្រៃរបស់ព្រះដ៏មាន-
ព្រះភាគអង្គនោះ ព្រះអង្គកៀវក្ងាក្នុងចតុវេសារជ្ជញ្ញាណ (ប្រាជ្ញាដ៏ក្ងៀវក្ងាបួន
យ៉ាង)[១] ព្រះអង្គទ្រទ្រង់នូវទសពលញ្ញាណ[២] ព្រះអង្គតាំងនៅក្នុងឋានៈ ជាអ្នក
អង់អាច ព្រះអង្គបន្ទឹសីហនាទ ព្រះអង្គខ្ពង់ខ្ពស់ជាងសព្វសត្ត ព្រះអង្គជា

១-សេចក្ដីពិស្តារ សូមពិនិត្យមើលក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៤២ ទំព័រ ១៩ ដល់ ២២ និងអភិធម្មបិដក វិភង្គ លេខ ៨២ ទំព័រ ១១៨ ដល់ ១២២ ។

*២-**ទសពលញ្ញាណ** "ញាណមានកម្ទាំងរបស់ព្រះសម្ពុទ្ធ" ១០ យ៉ាង*

១-ឋាន ឋានញ្ញាណ = *ដឹងហេតុនឹងមិនមែនហេតុ*

២-វិចាកញ្ញាណ = *ដឹងផលរបស់កម្ម*

៣-សព្វត្តគាមិមគ្គញ្ញាណ = *ដឹងផ្លូវជាទីទៅក្នុងទីទាំងពួង*

៤-នានាធាតុញ្ញាណ = *ដឹងនូវលោកដែលមានធាតុផ្សេងៗ គ្នា*

៥-នានាធិមុត្តិញ្ញាណ = *ដឹងនូវអធិមុត្តិ គឺអធ្យាស្ស័យនៃសត្ត្ផ្សេងៗគ្នា*

៦-ឥន្ទ្រិយបរោបរិយត្តញ្ញាណ = *ដឹងឥន្ទ្រិយរបស់សត្ត្ទន់ និងរឹង*

៧-ឈានាទិញ្ញាណ = *ដឹងសេចក្ដីសៅហ្មង សេចក្ដីហ្មត់ចត់និងកិរិយាចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិទាំងឡាយ*

៨-បុព្វេនិវាសញ្ញាណ = *ដឹងនូវបុព្វេនិវាស*

៩-ចុតូបចាតញ្ញាណ = *ដឹងនូវចុតិ និងបដិសន្ធិនៃសត្ត*

១០-អាសវក្ខយញ្ញាណ = *ដឹងធម៌ជាគ្រឿងអស់ទៅនៃអាសវៈ។*

ធម្មិស្សរ: ព្រះអង្គជាធម្មរាជ ព្រះអង្គជាអធិបតីក្នុងធម៌ ព្រះអង្គជាប្រទីបនៃធម៌ ព្រះអង្គជាធម្មសរណ: ព្រះអង្គជាចក្រពត្តិនៃព្រះសទ្ធម្មដ៏ប្រសើរ ព្រះអង្គត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯង ក្នុងសេចក្តីនេះ យើងមិនគួរធ្វើសេចក្តីសង្ស័យ ឬសេចក្តីជឿងឆ្ងល់ក្នុងអត្ត ធម៌ បទ ព្យញ្ជន:ឡើយ ព្រោះថា ព្រះអានន្ទ ញ៉ាំងការមិនជឿរបស់ទេវតា និងមនុស្សក្នុងធម៌នេះឱ្យវិនាស ញ៉ាំងសទ្ធាសម្បទាឱ្យកើតឡើង ព្រោះហេតុនោះ លោកទើបពោលពាក្យនេះទុកថា

វិនាសយតិ អសទ្ធិយំ សទ្ធំ វឌ្ឍតិ សាសនេ
ឯវម្ម សុតមិច្ចេវំ វ០ គោតមសាវកោ ។

(ព្រះអានន្ទ) ជាសាវ័ករបស់ព្រះគោតមបរមសម្ពុទ្ធ កាលពោលពាក្យថា **ឯវម្ម សុតំ** ឈ្មោះថា ទម្លាយអសទ្ធិយ (ការមិនជឿ) ញ៉ាំងសទ្ធា (ការជឿ) ឱ្យចម្រើនឡើងក្នុងព្រះសាសនា ។

បទថា **ឯកំ** ជានិទ្ទេសនៃការកំណត់នូវការរាប់ ។ មែនពិត **ឯក**-ស័ព្ទនេះ ប្រាកដក្នុងអត្ថថា ***អញ្ញ: សេដ្ឋ: អសហាយ:*** និង***ឝ្ឝ***:ជាដើម ។ ពិតយ៉ាងនោះ **ឯក**-ស័ព្ទនេះប្រាកដក្នុងអត្ថថា ***អញ្ញ:*** (ខ្ញុ:) ដូចក្នុងប្រយោគមានជាអាទ៍ថា **សស្សតោ អត្តា ច លោកោ ច ឥ០ មេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវ០ន្តិ** គឺសមណព្រាហ្មណ៍ពួកខ្ញុ: និយាយយ៉ាងនេះថា អត្តាក្តី លោកក្តី ជាសភាវ:ទៀង ការយល់ឃើញដទៃជាមោឃ:[1]។ ប្រាកដក្នុងអត្ថថា ***សេដ្ឋ:*** (ប្រសើរបំផុត) ដូចក្នុងប្រយោគមានជាអាទ៍ថា **ចេតសោ ឯកោ០ភាវំ** មាន

១-សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក: លេខ ២៦ ទំព័រ ៦៥ ។

តែចិត្តប៉ុណ្ណោះ ជាការប្រសើរ[១] ។ ប្រាកដក្នុងអត្ថថា ***អសហាយៈ*** *(មិនមានសម្ងាញ់) ដូចក្នុងប្រយោគមានជាអាទិ៍ថា* **ឯកោ រូបកង្ខោ** *អ្នកតែមួយជៀសចេញហើយ ។ ប្រាកដក្នុងអត្ថថា* ***សង្ខ្យៈ*** *(រាប់) ដូចក្នុងប្រយោគមានជាអាទិ៍ថា* **ឯកោវ ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** *ម្នាលភិក្ខុទាំងឡាយ ខណៈនិងសម័យនៃការនៅប្រព្រឹត្តព្រហ្មចរិយៈមានតែមួយ[២]។ សូម្បីក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងការរាប់ផ្ទុះឯង ។ ព្រោះហេតុនោះ លោកទើបពោលថា បទថា* **ឯកំ** *ជាការសម្តែងកំណត់ការរាប់ ។*

បទថា **សមយំ** *ជាបទសម្តែងខែ វេលាដែលកំណត់ទុក ។ បទថា* **ឯកំ សមយំ** *ជាការសម្តែងវេលាដែលមិនកំណត់ពិតប្រាកដ ។*

តត្ត សមយសទ្ទោ--

សមវាយេ ខណេ កាលេ សមូហេ ហេតុទិដ្ឋិសុ
បដិលាភេបហានេ ច បដិវេធេ ច ទិស្សតិ។

ក្នុងពាក្យថា **ឯកំ សមយំ** *នោះ* ***សមយ****-សព្ទ ប្រាកដក្នុងអត្ថ ៩ យ៉ាង គឺសមវាយៈ ១ ខណៈ ១ កាល ១ សមុហៈ ១ ហេតុ ១ ទិដ្ឋិ ១ បដិលាភៈ ១ បហានៈ ១ បដិវេធៈ ១ ។*

ពិតយ៉ាងនោះ ***សមយ****-សព្ទនោះ មាន* ***សមវាយៈ*** *(ព្រមព្រៀង) ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា* **អប្ប្យេ ជាម ស្ទេ្ববិ ឧបសង្ក-មេយ្យាម កាលញ្ច សមយញ្ច ឧបជាយ** *បើដូច្នោះ ចាំយើងពិចារណាទ្ធ*

១-វិនយបិដក មហាវិភង្គ លេខ ១ ទំព័រ ១១ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត លេខ ៤៨ ទំព័រ ១២១ ។

កាល និងការព្រមព្រៀងសិនហើយសឹមទៅក្នុងថ្ងៃស្អែក[១] អធិប្បាយថា បានកាលគួរ និងសេចក្តីព្រមព្រៀងនៃបច្ច័យ ព្រោះដូច្នោះ គប្បីជ្រាបបច្ចយសមវាយ: (សេចក្តីព្រមព្រៀងនៃបច្ច័យ) ។ មានខណ:ជាអត្ថក្នុងប្រយោគមានអាទិ៍ថា **ឯកោវ ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** *ម្នាលភិក្ខុទាំងឡាយ ខណ: និងសម័យនៃការនៅប្រព្រឹត្តព្រហ្មចរិយ:មានតែមួយ[២] អធិប្បាយថា ឱកាស ។ មែនពិត ឱកាសរបស់មគ្គព្រហ្មចរិយ: មានការឧប្បត្តិឡើងនៃព្រះតថាគតជាដើម ព្រោះជាហេតុឱ្យបានមគ្គព្រហ្មចរិយ: នោះជាបច្ច័យ។ អធិប្បាយថា ក៏សម័យ គឺខណ: ដែលលោកហៅថា ខណ: និងសម័យនោះតែម្យ៉ាងនុ៎ះឯង ។ មាន* **កាល** *(វេលា) ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា* **ឧណ្ហាសមយោ បរិឬហាសមយោ** *សម័យក្តៅ សម័យស្អុះស្អាប់[៣] ។ មាន* **សមុហ:** *(ប្រជុំ) ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា* **មហាសមយោ បវនស្មឿ** *ជាថ្ងៃប្រជុំធំ ក្នុងដងព្រៃ[៤]។ មែនពិត បទថា* **មហាសមយោ** *មានសេចក្តីអធិប្បាយថា ជាមហាសន្និបាតនៃភិក្ខុ និងទេវតាទាំងឡាយ ។ មាន* **ហេតុ** *ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា* **សមយោបិ ខោ តេ ភគ្គាលិ អប្បដិវិទ្ធោ អហោសិ ភគវា ខោ សាវត្ថិយំ វិហរតិ ភគវាបិ មំ ជានិស្សតិ ភគ្គាលិ ជាម ភិក្ខុ សត្ថុ សាសនេ សិក្ខាយ អបរិបូណ៌ការីតិ អយម្ឫ ខោ តេ ភគ្គាលិ សមយោ អប្បដិវិទ្ធោ អហោសិ** *ម្នាលភគ្គាលិ អ្នក*

---

១ -សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៥ ទំព័រ ១៦២ ។

២ -សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត លេខ ៨៨ ទំព័រ ១២១ ។

៣ -វិនយបិដក មហាវិភង្គ លេខ ៤ ទំព័រ ២៣០ ។

៤ -សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៧ ទំព័រ ១៧០ ។

មិនបានដឹង ហេតុថាព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី តែព្រះមាន-ព្រះភាគគង់ដឹង **អាត្មាអញថា** *ភិក្ខុឈ្មោះកទ្ទាលិ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ ម្នាលកទ្ទាលិ នេះឯងជាហេតុ ដែលអ្នកមិនបានដឹង[១] ។ មែនពិត ហេតុនៃសិក្ខាបទលោកបំណងយកថា* **សមយ:** *ក្នុងទីនេះ ។ មាន* **លទ្ធិ** *ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា* **តេន ខោ បន សមយេន ឧក្តាហមានោ បរិព្ជាជកោ សមណមុណ្ឌិកាបុត្តោ សមយ-ប្បវាទកេ តិណ្ហាកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ** *សម័យនោះឯង បរិព្ជាជកឈ្មោះឧគ្គាហមាន: ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងអារាម របស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានជួរដើមទន្ទាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវលទ្ធិ[២]។ មែនពិត តិរ្ថិយទាំងឡាយ ដែលអង្គុយក្នុងអារាម មានសាលាមួយខ្នងនោះ ប្រាប់សម័យ ពោលគឺ លទ្ធិរបស់ខ្លួនៗ ព្រោះដូច្នោះ អារាមរបស់បរិពជកនោះ លោកទើបហៅថា ជាទីពោលនូវលទ្ធិ ។ មាន* **បដិលាភ:** *(ការបានចំពោះ) ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា*

ឧភេ ឧម្មេ ច យោ អត្ថោ យោ ចត្ថោ សម្ឆាយិកោ
អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។

(បណ្ឌិតមិនប្រមាថហើយ) រមែងបានប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ អ្នកមានប្រាជ្ញា ព្រោះបានប្រយោជន៍ទាំង ២ ទើបហៅថា ជាបណ្ឌិត[៣]។ មែនពិត បទថា **អត្ថាភិសមយា**

១-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក: លេខ ២៣ ទំព័រ ២៨០ ដល់ ២៨១ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក: លេខ ២៦ ទំព័រ ១៨៨ ។

៣-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ២៣ ។

សេចក្ដីថា បានចំពោះប្រយោជន៍ ។ មាន **ឋហានៃ** (ការលះបង់) ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា **សម្ម។ មាជាកិសមយា អន្ដមកាសិ ឧក្ខ្ស** ធ្វើនូវទីបំផុតកងទុក្ខ ព្រោះដែលហេតុបានលះបង់នូវមាន៖ ចេលដោយប្រពៃ[១] ។ អកិសម័យ ឈ្មោះថា **ឋហានៃ** ក្នុងពាក្យថា **អធិការណៃ** (ការធ្វើឱ្យក្រៃលែង) **សមយៃ** (ការលះ) **រ្ជ្ជ**ាសមៃ (ការចូលទៅស្ងប់) **អ**ាគមៃ (ការទៅប្រាសចាក) ។ មាន **ឋ**ានៃ (ការចាក់ធ្ងុ) ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា **ឧ**ក្ខ្ស **ប**ីឍ្ឌ**ន**ង្ហោ **ស**ន្ធ**ិ**ត**ង**ោ **ស**ន្ដ**ាប**ង**ោ **វ**ិ**ប**ិ**ណ**ាម**ង**ោ **អ**ិ**ស**ម**យ**ង**ោ** ប្រែថា ទុក្ខ មានអត្ថថា ហៀតហៀន មានអត្ថថា បច្ច័យប្រជុំតាក់តែង មានអត្ថថា ក្ដៅក្រហាយ មានអត្ថថា ប្រែប្រួល មានអត្ថថា ចាក់ធ្ងុ៖ចំពោ៖[២] ។ មែនពិត ការចាក់ធ្ងុ៖ ឈ្មោ៖ថា អកិសមយ: ព្រោ៖ចាក់ធ្ងុ៖ ។ អត្ថ គឺអកិសមយ: ឈ្មោ៖ថា អកិសមយត្ត: ព្រោ៖ហេតុនោ៖ ទុក្ខមានការហៀត ហៀនជាដើម លោកពោលរួមតែម្យ៉ាង ព្រោ៖ត្រូវដឹងច្បាស់ ។ ម្យ៉ាងទៀត អត្ថដែលជាអារម្មណ៍នៃអកិសមយ: គឺការចាក់ធ្ងុ៖ ឈ្មោ៖ថា អកិសមយត្ត: អត្ថគឺការចាក់ធ្ងុ៖ ព្រោ៖ហេតុនោ៖ ការហៀតហៀនជាដើមនោ៖ឯង លោកទើបពោលទុកយ៉ាងនោ៖ ដោយសេចក្ដីតែម្យ៉ាង ។ ក្នុងអត្ថទាំងនោ៖ ទុក្ខសច្ច: ហៀតហៀន អ្នកដល់ព្រមព្រៀងដោយទុក្ខសច្ច:នោ៖ គឺធ្វើឱ្យចម្រើនមិនបាន ឈ្មោ៖ថា ហៀតហៀន ។ សេចក្ដីដុតពោល គឺសេចក្ដីក្ដៅផ្សា ដោយអំណាចទុក្ខ និងសេចក្ដីជាទុក្ខជាដើម ឈ្មោ៖ថា សេចក្ដីក្ដៅផ្សា ។

១-សុត្តន្ដបិដក មជ្ឈិមនិកាយ មូលបណ្ណាសក: លេខ ២០ ទំព័រ ៣៨ ។

២-សុត្តន្ដបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧១ ទំព័រ ៦៩ ។

ក៏ក្នុងសេចក្តីនេះ សម័យ ឈ្មោះថា ***សមាយៈ*** *ព្រោះសេចក្តីសម្រេច ព្រោះមានហេតុដែលមានការធ្វើរួមគ្នា រមែងព្រមគ្នា គឺព្រមព្រៀងគ្នា ។ សម័យ ឈ្មោះថា ខណៈ ព្រោះជាទីព្រមគ្នា គឺមកព្រមគ្នានឹងមគ្គព្រហ្មចរិយៈ ដោយបុគ្គលអ្នកទ្រទ្រង់ទុកនូវមគ្គព្រហ្មចរិយៈនោះ ។ សម័យ ឈ្មោះថា កាល ព្រោះជាទីទៅព្រមគ្នា ឬជាហេតុទៅរួមគ្នានៃសត្ត្ব ឬនៃសភាវធម៌ ដោយខណៈ មានឧបាទខណៈជាដើម ឬដោយសម្បយុត្តធម៌ មានសហជាតធម៌ជាដើម ។ ពិតមែន បើពោលដោយអត្ត កាល សូម្បីនឹងមិនមានពិតដោយភាវៈត្រឹមតែជាការប្រព្រឹត្តទៅតាមធម៌ លោកហៅដោយសេចក្តីសមគួរ ដែលសម្រេចមកត្រឹមតែការត្រិះរិះនៃការប្រព្រឹត្តទៅរបស់ធម៌ ដូចអធិករណៈ និងករណសាធនៈ ដូច្នេះឯង ។ សម័យ ឈ្មោះថា* ***សមុហៈ*** *ព្រោះទៅ គឺប្រព្រឹត្តទៅព្រមសេចក្តីតាំងនៅនៃអវយវៈទាំងឡាយស្មើគ្នា ឬព្រមគ្នា ដូចជាការប្រជុំខ្លួនឯង ។ មែនពិតការតាំងចុះព្រមគ្នានៃអវយវៈនោះឯងឈ្មោះថា* ***សមុហៈ*** *(ការប្រជុំ) ។ សម័យ ឈ្មោះថា ហេតុ ព្រោះជាដែនទៅ គឺកើតឡើងប្រព្រឹត្តទៅនៃផល ក្នុងកាលមានការប្រជុំនៃបច្ច័យទាំងអស់ ដូចសមុទយៈកើតឡើងឯង ។ សម័យ ឈ្មោះថា ទិដ្ឋិ ព្រោះទៅព្រមគ្នា គឺជាប់គ្នា និងគ្នាទៅដោយភាវៈជាសញ្ញោជនៈ ប្រព្រឹត្តទៅក្នុងអារម្មណ៍របស់ខ្លួន ។ ម្យ៉ាងទៀត ព្រោះជាគ្រឿងប្រកបដោយការប្រកាន់មាំ គឺប្រព្រឹត្តទៅតាមដែលប្រកាន់មាំរបស់សត្ត្ব ទាំងឡាយ ។ មែនពិត សត្ត្ব ទាំងឡាយត្រូវទិដ្ឋិសញ្ញោជនៈចងរឹតទុកយ៉ាងក្រៃលែង ។ សម័យ ឈ្មោះថា បដិលាភៈ ព្រោះការប្រជុំ ការជួបប្រសព្ធការរួមចុះ ។ សម័យ ឈ្មោះថា បហានៈ ព្រោះបាត់ទៅ សាបសូន្យទៅ ប្រាសចាកទៅ ។ ម្យ៉ាងទៀត សម័យ ឈ្មោះថា អកិស-*

*មយ: ព្រោះជាសម័យក្រៃលែងដោយលះបានដាច់ខាត ដូចអកិធម្ម ។ ឈ្មោះ ថា អកិសមយ: ព្រោះគប្បីប្រកាន់ គឺគប្បីសម្រេចដោយ ញាណចំពោះមុខ បានដល់ យល់ដឹងដល់សភាវ:នៃធម៌ដែលមិនប្រែប្រួល ។ ឈ្មោះថា អកិសមយ: ព្រោះទៅ គឺសម្រេចត្រាស់ដឹងដោយភាវ:ចំពោះមុខ គឺដោយប្រពៃ បានដល់ សេចក្ដីយល់ដឹងសភាវ:តាមសេចក្ដីពិតនៃធម៌ ។ គប្បីជ្រាបការប្រព្រឹត្តទៅនៃ **សមយ**-ស័ព្ទ ក្នុងអត្ថនោះ។ ដោយអាការយ៉ាងនេះ ។*

*គប្បីជ្រាប ហេតុក្នុងការពង្រីកអត្ថនៃ**សមយ**-ស័ព្ទ បន្ថែម **អកិសមយ**-ស័ព្ទ ចូលដោយន័យដូចពោលហើយនោះឯង ។ តែក្នុងទីនេះ **សមយ**-ស័ព្ទ ឈ្មោះ ថាមានកាល ជាអត្ថ ព្រោះអត្ថទាំង ៥ មានសមវាយ:ជាដើមមិនមាន ។ គប្បីជ្រាប**សមយ**-ស័ព្ទនោះ ថាជាកាលក្នុងភាវ:នៃពាក្យចាប់ផ្ដើមរបស់ទេសនា ដូច ស្ថានទីអ្នកសម្ដែង និងបរិស័ទឯង ។ ក៏ព្រោះហេតុដែលលោកប្រាថ្នាយក **កាល** ថា សម័យក្នុងទីនេះ ដូច្នោះព្រះថេរ:ទើបសម្ដែងថា សម័យមួយ បណ្ដា សម័យ ដែលជាប្រភេទនៃកាល ដូចឆ្នាំ រដូវ ខែ កន្ទុះខែ ពេលយប់ ពេលថ្ងៃ វេលាព្រឹក ថ្ងៃត្រង់ ល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងមួយស្រេចក់ ជាដើម ។*

បើមានពាក្យសួរមកថា ព្រោះហេតុអ្វី បានជាក្នុងទីនេះ លោកទើប សម្ដែងខ្ចីដល់កាល ដោយមិនកំណត់ពិតប្រាកដតែម្ដង ហើយកំណត់សម្ដែង ខ្ចី ដោយរដូវ និងឆ្នាំជាដើម ក៏មិនមែន ។ ឆ្លើយថា បណ្ដាសម័យ មានឆ្នាំ ជាដើមទាំងនោះ សូត្រណាៗ ដែលលោកពោលទុកក្នុងឆ្នាំ រដូវ ខែ បក្ខ

ចំណែកពាត្រី ឬចំណែកថ្ងៃណាៗទាំងអស់នោះ ព្រះថេរៈដឹងច្បាស់ហើយ គឺប្រើ
បញ្ញា កំណត់ដោយល្អហើយ ។ ក៏ព្រោះហេតុ ដែលលោកពោលហើយយ៉ាង
នេះថា យើងបានស្តាប់ហើយយ៉ាងនេះ ក្នុងឆ្នាំឯណោះ រដូវឯណោះ ខែ-
ឯណោះ បក្ខឯណោះ ចំណែកពាត្រី ឬចំណែកថ្ងៃឯណោះ មិនមាននរណាៗ
មិនអាចចងចាំនិងសម្តែងខ្លួនឯង ឬឱ្យអ្នកដទៃសម្តែងបានដោយងាយទេទាំង
នឹងត្រូវពោលច្រើនដងដូច្នោះ លោកទើបប្រជុំអត្ថ នោះដោយបទតែមួយ
ប៉ុណ្ណោះ ហើយពោលថា **ឯកំ សមយំ** *ដូច្នេះ ។*

ម្យ៉ាងទៀត សម័យទាំងឡាយនេះ មានច្រើនប្រភេទណាស់ ដែលជា
ការប្រកាសយ៉ាងក្រៃលែង ចំពោះទេវតា និងមនុស្សទាំងឡាយ របស់ព្រះដ-
មានព្រះភាគមានជាអាទិ៍យ៉ាងនេះថា សម័យទ្រង់ចុះកាន់ព្រះគភ៌ សម័យទ្រង់
ប្រសូត សម័យទ្រង់សង្វេគ សម័យទ្រង់ចេញសាងអភិនេស្ក្រម សម័យទ្រង់ធ្វើ
ទុក្ករកិរិយា សម័យទ្រង់ឈ្នះមារ សម័យទ្រង់ត្រាស់ដឹងអភិសម្ពោធិញ្ញាណ
សម័យទ្រង់ប្រថាប់នៅជាសុខក្នុងបច្ចុប្បន្ន សម័យទ្រង់សម្តែងធម៌ និងសម័យ
ទ្រង់បរិនិព្វាន បណ្តាសម័យទាំងអស់នេះ ព្រះថេរៈសម្តែងថា សម័យមួយ
ពោលគឺ សម័យសម្តែងធម៌ ។ ម្យ៉ាងទៀត ព្រះថេរៈពោលថា សម័យមួយ
សំដៅយកសម័យយ៉ាងណាមួយ បណ្តាសម័យទាំងនេះ គឺក្នុងសម័យបំពេញ
គឺកិច្ចនៃព្រះបញ្ញាគុណ និងព្រះករុណាគុណ សម័យបំពេញកិច្ចនៃព្រះករុ-
ណាគុណ ក្នុងសម័យបំពេញប្រយោជន៍ដើម្បីព្រះអង្គ និងប្រយោជន៍ដើម្បី
អ្នកដទៃ គឺសម័យបំពេញប្រយោជន៍ដើម្បីអ្នកដទៃ ក្នុងសម័យព្រះករណីយ-
កិច្ចទាំងពីរ សម្រាប់អ្នកប្រជុំគ្នា គឺសម័យសម្តែងធម្មកថា ក្នុងសម័យសម្តែងធម៌
និងបដិបត្តិធម៌ គឺសម័យសម្តែងធម៌ ។

សួរថា ក៏ព្រោះហេតុណា ក្នុងសុត្តន្តបិដកនេះ លោកធ្វើនិទ្ទេសដោយ ទុតិយាវិភត្តិ ក្នុងអត្ថនៃអច្ចន្តសំយោគថា **ឯកំ សមយំ** *មិនធ្វើដូចយ៉ាងដែល លោកធ្វើនិទ្ទេសដោយសត្តមីវិភត្តិ ក្នុងអកិធម្មថា* **យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ** *ដូច្នេះ និងក្នុងសុត្តបទដទៃពីអកិធម្មនេះថា* **យស្មឹ សមយេ កិញ្ចាបិ កិញ្ចុ រ៉ាបិ ចេ្ចវ កាមេហិ រ៉ាបិ ចេ្ច អកុសលេហិ ធម្មេហិ** *ដូច្នេះ និងក្នុងព្រះវិន័យ លោកធ្វើនិទ្ទេសដោយតតិយាវិភត្តិថា* **តេន សមយេ-ន ពុទ្ធោ ភគវា** *ដូច្នេះ ? ធ្វើយ៉ាង ព្រោះក្នុងព្រះអកិធម្ម និងព្រះវិន័យនោះ មានអត្ថជាយ៉ាងនោះ តែក្នុងព្រះសូត្រនេះដែលមានអត្ថជាយ៉ាងដទៃ ។ មែនពិត បណ្ណាបិដកទាំង ៣ នោះ អត្ថនៃអធិករណសាធនៈពោលគឺ អាធារៈ និងវិសយៈ ក្នុងអកិធម្មបិដក និងក្នុងសុត្តន្តបិដក ក្រៅពីអកិធម្មបិដកនេះ និងអត្ថនៃលក្ខណៈ នៃការៈដោយការៈ ពោលគឺ លក្ខណៈនៃកិរិយាដទៃដោយកិរិយារមែងមាន ។ មែនពិត សម័យដែលមានកាលជាអត្ថ និងមានសមុហៈជាអត្ថ ចាត់ជាអធិករណៈ ។ ម្យ៉ាងទៀត កាលនៃធម៌មានផស្សៈជាដើម តាមដែលពោលហើយក្នុងអត្ថទាំងពីរនោះ សូម្បីមិនមាននៅដោយបរមត្ថ ព្រោះត្រឹមតែជាការប្រព្រឹត្តទៅរបស់សភាវធម៌ ក៏ប្រាកដដោយការៈនៃអាធារៈ ព្រោះធម៌ដែលប្រព្រឹត្តទៅក្នុងខណៈនោះ មិនមានក្នុងកាលមុន និងដទៃពីនោះ ដូចប្រយោគមានជាអាទិ៍ថា* **បុព្វណ្ហេ ជាតោ** (*កើតវេលាព្រឹក*) **សាយណ្ហេ ជាតោ** (*កើតវេលាល្ងាច*) ។ *អត្ថថា សមុហៈ ផុតពីចំណែកប្រកបនៃអវយវៈ សូម្បីមិនមាននៅក្នុងបរមត្ថ ក៏រមែងប្រាកដដោយការៈនៃអាធារៈរបស់ការ*

ប្រកបទាំងឡាយដោយរូប សម្រេចត្រឹមតែជាការត្រិះរិះ ដូចក្នុងប្រយោគមានជាអាទិ៍ថា **រុក្ខេ សាខា យថេ យវាសិម្ហិ សមុដ្ឋិតោ** *មែកតាំងឡើងត្រង់ដើមឈើ ស្រូវតាំងឡើងត្រង់គំនរស្រូវ ។ កុសលចិត្ត ចំណែកកាមាវចរ រមែងកើតក្នុងកាលណា និងក្រុមធម៌ណា សូម្បីសម្បយុត្តធម៌ មានផស្ស:ជាដើម រមែងមានក្នុងកាលនោះ ជាមួយនឹងក្រុមធម៌នោះឯង ។ ក្នុងសេចក្តីនោះមានអធិប្បាយត្រឹមតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ការធម៌ មានផស្ស:ជាដើម ដែលពោលទុកក្នុងអភិធម្មនោះ លោកកំណត់ដោយការ:នៃ**សមយ**-ស័ព្ទ ពោលគឺ ខណ: សមវាយ: និងហេតុ ។ ឧបមាថា លោកកំណត់ក្រិយាទៅ ដោយការធ្វើការច្របាច់ទឹកដោះគោ ក្នុងពាក្យថា កាលមេគោត្រូវច្របាច់ទឹកដោះហើយ នាយគោបាលក៏ទៅ កាលមេគោមានទឹកដោះ នាយគោបាលក៏មកយ៉ាងណា សូម្បីក្នុងព្រះអភិធម្មនេះក៏ដូច្នោះ កាលពោលថា **យស្មិ សមយេ** ជាការចូលសេចក្តីដូច្នេះថា សម្រាប់បរមត្ត និងរៀរសត្វក៏មិនបាន និងមិនមានសត្វក៏មិនបាន ព្រោះដូច្នោះ **សមយ**-ស័ព្ទ លោកកំណត់ក្រិយា គឺឧបាទខណ:នៃចិត្ត និងក្រិយា គឺការសោយសការធម៌ មានផស្ស:ជាដើម ដោយមិនមែនក្រិយានៃសត្វ ។ ម្យ៉ាងទៀត សម័យណា កាលខណ:ទី ៩ ណា កាលហេតុ មានយោនិ-សោមនសិការ:ជាដើមណា ឬកាលសេចក្តីព្រមព្រៀងនៃបច្ច័យណា មានកាមា-វចរកុសលចិត្តរមែងកើតឡើង សូម្បីសការធម៌ មានផស្ស:ជាដើម ក៏មានក្នុងសម័យនោះក្នុងខណ:នោះ ក្នុងហេតុនោះ និងក្នុងសេចក្តីព្រមព្រៀងនៃបច្ច័យនោះឯង ព្រោះដូច្នោះ ទើបធ្វើនិទ្ទេសដោយសត្តមីវិកត្តិ ដើម្បីបំភ្លឺអត្ថនោះ ។*

ចំណែកក្នុងព្រះវិន័យ **សមយ**-សព្ទ មានហេតុជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា **អន្ធេន រសតិ អជ្ឌេនេន រសតិ** បុគ្គលរមែងនៅព្រោះហេតុនៃបាយ ព្រោះហេតុនៃការគោរពអញ្ជើញ និងមានករណៈជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា **ករសេនា ធិន្ធតិ ការុណ្ណេន ខណ្ណតិ** បុគ្គលរមែងកាត់ដោយពូថៅ រមែងជីកដោយចប ។ មែនពិត សម័យក្នុងការបញ្ញត្តិសិក្ខាបទយ៉ាងណា សូម្បីព្រះធម្មសេនាបតីជាដើម ក៏យល់លំបាក ដោយសម័យនោះ ដែលជាករណៈ និងជាហេតុ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបការកន្ទ្ធ ណ្ដើសទើបឱ្យប្រជុំភិក្ខុសង្ឆសាកសួរ និងតិះដៀលបុគ្គលដែលជាដើមហេតុ កាលនឹងទ្រង់បញ្ញត្តិសិក្ខាបទដោយមិនកន្ទ្ធ ហួសវេលា ពោលគឺ សម័យដែល-ក កើតរឿងនោះ។ និងមិនសម្ងឹងដល់ហេតុនៃការបញ្ញត្តិសិក្ខាបទ ដូចបញ្ញត្តិតតិយ- បារាជិកជាដើម ហើយប្រថាប់នៅក្នុងទីនោះ។ ព្រោះដូច្នោះ ទើបធ្វើនិទ្ទេសដោយតតិយាវិភត្តិទុកក្នុងព្រះវិន័យដើម្បីបំភ្លឺអត្ថនោះ ។ តែ **សមយ**-សព្ទដែលមានអច្ចន្តសំយោគជាអត្ថ រមែងមានក្នុងទីនេះ និងក្នុងទីដទៃដែលមានកំណើតយ៉ាងនេះ ។ មែនពិត ក្នុងសម័យណា ឧទាននេះកើតព្រមដោយហេតុ ដែលជាសមុដ្ឋាន ព្រះដ៏មានព្រះភាគប្រថាប់នៅដោយការពិចារណាធម៌ ដែលមានអរិយវិហារធម៌ជាប្រធាន រហូតដល់អស់សម័យនោះ ដោយចំណែកតែមួយ ព្រោះដូច្នោះ ទើបធ្វើនិទ្ទេសដោយទុតិយាវិភត្តិ ក្នុងព្រះសូត្រនេះ ដើម្បីបំភ្លឺអត្ថនៃឧបយោគ: ដូចក្នុងប្រយោគមានជាអាទិ៍ថា **មាសំ អជ្ឌេតិ** (រមែងស្វាធ្យាយ រហូតដល់អស់ខែ) ។

ព្រោះហេតុនោះ លោកទើបពោលពាក្យនេះទុកថា

តំ តំ អត្តមវេក្ខិត្វា ភុម្មេន ការណេន ច

អញ្ញត្ត សមយោ វុត្តោ ឧបយោគេន សោ ឥធ ។

*ព្រះអានន្ទពិចារណាដល់អត្តនោះ។ ហើយពោល**សមយ**-ស័ព្ទ ទុកក្នុងសុត្តន្តបិដក និង**អ**ភិធម្មបិដក ដោយសត្តមីវិភត្តិ និងតតិយាវិភត្តិ **សមយ**-ស័ព្ទនោះ ព្រះឧបាលិពោលទុកក្នុងវិនយបិដកនេះ ដោយទុតិយាវិភត្តិ ។*

ចំណែកព្រះបូរាណាចារ្យទាំងឡាយពណ៌នាទុកថា និទ្ទេសនោះជាសេចក្តីផ្សេងគ្នាត្រឹមតែវោហារថា **យស្មឿ សមយេ** *ថា* **តេន សមយេន** *ឬថា* **ឯកំ សមយំ** *មានអត្ថជាសត្តមីវិភត្តិគ្រប់ៗ បទ ។ ព្រោះដូច្នោះ សូម្បីកាលលោកពោល* **ឯកំ សមយំ** *ក៏គប្បីជ្រាបសេចក្តីថា* **ឯកស្មឿ សមយេ** *ដូច្នេះ ។*

បទថា **ភគវា** *ប្រែថា គ្រូ ។ មែនពិត លោកហៅគ្រូថា* **ភគវា** *។ ក៏ព្រះដ៏មានព្រះភាគអង្គនេះ ជាគ្រូរបស់សព្វសត្ត្ব ព្រោះជាអ្នកវិសេសដោយគុណទាំងពួង ព្រោះដូច្នោះ បណ្ឌិតទើបថ្វាយព្រះនាមព្រះអង្គថា* **ភគវា** *សូម្បីព្រះបូរាណាចារ្យទាំងឡាយក៏ពោលទុកថា*

ភគវាតិ វចនំ សេដ្ឋំ ភគវាតិ វចនមុត្តមំ

គរុការយុត្តោ សោ ភគវា តេន វុច្ចតិ ។

ពាក្យថា **ភគវា** *ជាពាក្យប្រសើរបំផុត ពាក្យថា* **ភគវា** *ជាពាក្យខ្ពង់ខ្ពស់បំផុត ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គគួរដល់សេចក្តីគោរពដោយហានៈជាគ្រូ ព្រោះដូច្នោះ ព្រះអង្គ បណ្ឌិតទើបថ្វាយព្រះនាមព្រះអង្គថា* **ភគវា** *ដូច្នេះ ។*

បណ្តាពាក្យទាំងនោះ ពាក្យពោលថា ប្រសើរបំផុត លោកពោលថា សេដ្ឋៈ ព្រោះប្រព្រឹត្តទៅដោយព្រះគុណដ៏ប្រសើរ ។ ម្យ៉ាងទៀត អត្ត ឈ្មោះថា វចនៈ ព្រោះដែលគេពោល ។ បទថា **ភគវាតិ វចនំ សេដ្ឋំ** សេចក្តីថា អត្តដែលគួរពោលអំពីពាក្យថា **ភគវា** នេះជាអត្តប្រសើរ ។ សូម្បីក្នុងពាក្យថា **ភគវាតិ វចនមុត្តមំ** នេះ គប្បីជ្រាបអត្តដោយន័យដូចពោលហើយនុ៎ះឯង ។ បទថា **ការវយុត្តោ** បានដល់ ឈ្មោះថា ប្រកបដោយភាពជាគ្រូ ព្រោះប្រកបដោយគុណហានៈជាគ្រូ ឬឈ្មោះថា ប្រកបដោយសេចក្តីគោរព ព្រោះមានការធ្វើហានៈគ្រូដោយពិសេស ។ **ភគវា** នេះ គប្បីជ្រាបថា ជាឈ្មោះរបស់អ្នកវិសេសដោយគុណអ្នកខ្ពង់ខ្ពស់បំផុតជាងសត្ត និងអ្នកគួរគោរពដោយហានៈជាគ្រូ ។ ម្យ៉ាងទៀត គប្បីជ្រាបអត្តនៃបទថា **ភគវា** ដោយក្នុងដែលមកហើយក្នុងនិទ្ទេសថា

ភគី ភជី ភាគី វិភត្តវា ឥតិ
អការិ ភត្តន្តិ ករតិ ភាត្យវា
ពហូហិ ញាយេហិ សុការិតត្តនោ
ភវន្តោ សោ ភគវាតិ វុច្ចតិ

ព្រះដ៏មានព្រះភាគនោះ បណ្ឌិតថ្វាយព្រះនាមថា **ភគវា** ព្រោះព្រះអង្គជាអ្នកមានជោគ ជាអ្នកសេពទីស្ងាត់ ជាអ្នកមានចំណែកគួរទទួលបច្ច័យ ជាអ្នកចែក ជាអ្នកកាច់បំបាក់ភត្តធម៌[1] ជាគ្រូ ជាអ្នកមានបុណ្យបារមី ជាអ្នកទូន្មានព្រះអង្គដោយព្រះអង្គឯង យ៉ាងល្អដោយញ្ញាយធម៌ដ៏ច្រើន និងជាអ្នកដល់នូវទីបំផុតនៃភព ។

១-**អការិ ភត្តន្តិ ១ភាគិ១ចាបជ១ម្ម ១ភ១ត្ត ១ អការីតិ ១ភ១ត្ត ១ អ១ត្ត ១** ។ *បទថា* **អការិ ភត្តន្តិ** *(បំបាក់នូវភត្តធម៌) មានអធិប្បាយថា ឈ្មោះថា* **ភគវា** *ព្រោះព្រះអង្គបំបាក់នូវភត្តធម៌ ជាធម៌ដ៏អាក្រក់ មានរាគៈជាដើម ។ (ស្រង់ចាកគម្ពីរសារត្ថទីបនី ដីកា ព្រះវិន័យ ភាគ ១)*

និងដោយអំណាចនៃគាថានេះថា

ភាគ្យវា ភត្តវា យុត្តោ ភត្តេហិ ច វិភត្តវា
ភត្តវា វន្តគមនោ ភវេសុ ភគវា គតោ

ព្រះដ៏មានព្រះភាគ បណ្ឌិតថ្វាយព្រះនាមព្រះអង្គថា **ភគវា** *ព្រោះជាអ្នកមានភាគ្យ: ជាអ្នកកាច់បំបាក់កិលេស ជាអ្នកប្រកបដោយភគ្គធម៌ ជាអ្នកចែក ជាអ្នកសេពគប់ និងជាអ្នកខ្ជាក់ចោលការទៅក្នុងភពចេញបាន ។*

ក៏អត្ថនៃបទថា **ភគវា** *នោះ។ លោកពោលទុកក្នុងវិសុទ្ធិមគ្គដោយអាការទាំងពួង ព្រោះដូច្នោះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ។*

ម្យ៉ាងទៀត ឈ្មោះថា **ភគវា** *ព្រោះសេពគប់ភាគធម៌ ឬខ្ជាក់ចេញ ភគ្គធម៌ ។ មែនពិត ព្រះតថាគត រមែងសេពគប់ គប់រក សេពហើយ ធ្វើឱ្យច្រើន ដល់បារមីធម៌ មានទាន និងសីលជាដើម និងឧត្តរិមនុស្សធម៌មានឈាន និងវិមោក្ខជាដើម ព្រោះដូច្នោះ ទើបឈ្មោះថា* **ភគវា** *ម្យ៉ាងទៀត ឈ្មោះថា* **ភគវា** *ព្រោះសេពគប់ គឺប្រាថ្នាយ៉ាងក្រៃលែងនូវធម៌ទាំងនោះឯងថា យ៉ាងណាហ្ន៎ ធម៌ទាំងនេះ នឹងគប្បីកើតឡើងក្នុងសន្ធានរបស់វេនេយ្យសត្ត ។ ម្យ៉ាងទៀត ឈ្មោះថា* **ភគវា** *ព្រោះខ្ជាក់ចេញ គឺបន្ទោបង់ចេញនូវភាពជាធំ និងយស ពោលគឺភគ្គធម៌មិនអាល័យខ្ជាក់ចោលចេញ ដូចបុគ្គលខ្ជាក់ចោលនូវទឹកមាត់ដូច្នោះ ពិតយ៉ាងនោះ ព្រះតថាគតសម្គាល់សិរីរាជសម្បត្តិនៃចក្រពត្តិ ដែលនៅក្នុងព្រះហស្ត ភាពជាធំក្នុងទ្វីបទាំង ៤ ដូចនឹងភាពជាធំក្នុងទេវលោក និងយសដែលរុងរឿងដោយរតន:ទាំង ៧ យ៉ាង ជាទីអាស្រ័យនៃចក្កពត្តិសម្បត្តិថា ដូចត្រូវក្ងើងនេះ ទ្រង់មិនអាល័យ ស្តេចចេញអកិនេស្ត្រម ត្រាស់ដឹងដោយប្រពៃ*

ដោយព្រះអង្គឯង នូវសម្មាសម្ពោធិញ្ញាណ ព្រោះដូច្នោះ បណ្ឌិតទើបថ្វាយព្រះនាមព្រះអង្គថា **ភគវា** ព្រោះខ្ជាក់ចេញនូវភគ្គធម៌មានសិរីជាដើមនោះ ។ ឈ្មោះថា **ភគា** ព្រោះទៅ គឺប្រព្រឹត្តទៅព្រមជាមួយក្សត្រ ឈ្មោះថា **ភា** ទាំងនោះ គឺជាសេចក្តីល្អដែលអាស្រ័យលោកដែលជាទីទ្រនូវដូចភ្នំសិនេរុ ភ្នំយុគន្ធរ ឧត្តរកុរុទ្វីប និងព្រៃហិមពាន្តជាដើម ព្រោះជាទីតាំងនៅរហូតអស់កប្ប ។ ព្រះដ៏មានព្រះភាគទ្រង់ខ្ជាក់ចេញ គឺលះភគធម៌សូម្បីទាំងនោះ ដោយការលះឆន្ទរាគៈដែលជាប់នឹងភគធម៌នោះ ព្រោះឈានកន្លងការនៅរបស់សត្វអ្នកអាស្រ័យនៅក្នុងលោកនោះឯង ។ កាលបើយ៉ាងនោះ ក៏គប្បីជ្រាបអត្ថរបស់បទថា **ភគវា** ដោយន័យមានជាអាទិ៍យ៉ាងនេះថា ឈ្មោះថា **ភគវា** ព្រោះខ្ជាក់ចេញនូវភគ្គធម៌ ។

ក៏ដោយហេតុត្រឹមនេះ បណ្តាពាក្យទាំងនោះ ដោយបទថា **ឯវម្មេ សុតំ** ព្រះថេរៈកាលនឹងពោលធម៌តាមដែលស្តាប់មក ទើបធ្វើធម្មសរីរៈរបស់ព្រះដ៏-មានព្រះភាគឱ្យប្រចក្ស ។ ព្រោះដូច្នោះ ព្រះថេរៈទើបលួងលោម ជនអ្នកនឿយណាយដោយការមិនបានគាល់ព្រះសាស្តាឱ្យស្រោលចិត្តថា នេះមិនមែនបាវចនៈ គឺធម្មវិន័យដែលព្រះសាស្តាកន្លងទៅហើយ នេះជាសាស្តារបស់ពួកអ្នក ។ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា **យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ។** ម្នាលអានន្ទ ធម៌ណាក្តីនិងវិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តិហើយដល់អ្នកទាំងឡាយ លុះអំណើះតតអំពីតថាគតទៅ ធម៌ និងវិន័យនោះ នឹងជាព្រះសាស្តារបស់អ្នកទាំងឡាយ[១] ។

១-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ៣២១ ។

ដោយពាក្យថា **ឯកំ សមយំ ភគវា** *នេះ ព្រះថេរៈកាលសម្តែងថា ក្នុងសម័យនោះព្រះដ៏មានព្រះភាគ ទ្រង់មិនមានព្រះជន្មនៅ ទើបសម្តែងអាងដល់ការបរិនិព្វានដោយរូបកាយ ។ ព្រោះហេតុនោះ ព្រះថេរៈឱ្យជនអ្នកស្រវឹងព្រោះស្រវឹងក្នុងជីវិតឱ្យតក់ស្ងុត និងឱ្យកើតសេចក្តីឧស្សាហ៍ក្នុងសទ្ធម្មថា ព្រះដ៏មានព្រះភាគ សូម្បីព្រះអង្គនោះ ទ្រង់សម្តែងធម៌មានច្រើនយ៉ាងដូច្នេះ ទ្រទ្រង់ទុកនូវទសពលញ្ញាណ មានព្រះកាយស្មើដោយការបូកលាបដោយពេជ្រ ព្រះអង្គបរិនិព្វានហើយ អ្នកណាដទៃនឹងគប្បីឱ្យកើតសេចក្តីប្រាថ្នាក្នុងជីវិត ។*

ម្យ៉ាងទៀត កាលពោលថា **ឯវํ** *ទើបសម្តែងការកាន់យកទេសនាសម្បត្តិ ព្រោះព្រះសូត្រទាំងអស់ដែលសម្តែងហើយ សំដៅយកពាក្យថា* **ឯវํ** *ដូច្នេះ ។ ដោយបទថា* **មេ សុតํ** *នេះ ព្រះថេរៈសម្តែងដល់សាវកសម្បត្តិ និងសវនសម្បត្តិ ព្រោះសម្តែងដល់ការៈនៃអ្នកសម្រេចបដិសម្ភិទា ជាធម្មកណ្ឌាគារិកដែលព្រះដ៏មានព្រះភាគ ទ្រង់ស្ថាបនាទុកក្នុងឯតទគ្គៈ ក្នុងឋានៈទាំង ៥ យ៉ាង ដូចបានស្តាប់មកហើយយ៉ាងនេះថា និងព្រោះសម្តែងសេចក្តីនេះថា ក៏ព្រះសូត្រនោះឯង គឺខ្ញុំបានស្តាប់មកហើយ មិនមែនមិនបានស្តាប់ និងមិនមែននាំមកបន្តៗគ្នាទេ ។ ដោយបទថា* **ឯកំ សមយំ** *នេះ ព្រះថេរៈសម្តែងដល់កាលសម្បត្តិ ព្រោះសម្តែងដល់ការៈដែលប្រជាប់ដោយពុទ្ធុប្បាទ ជាសម័យដែលព្រះដ៏មានព្រះភាគ ប្រថាប់នៅតំបន់ឧរុវេលា ។ ក៏កាលសម្បទា មានពុទ្ធុប្បាទកាលដ៏ក្រៃលែង ។ ដោយបទថា* **ភគវា** *នេះ ព្រះថេរៈសម្តែងដល់ទេសកសម្បត្តិ ព្រោះសម្តែងដល់ការៈដែលព្រះអង្គជាអ្នកវិសេសដោយគុណ ជាអ្នកខ្ពង់ខ្ពស់បំផុតជាងសត្ត និងជាគ្រូ ។*

បទថា **ឧរុវេលាយំ** បានដល់ ជិតគំនរខ្សាច់ដ៏ធំ អធិប្បាយថា ដែលគំនរខ្សាច់ដ៏ធំ ។ ម្យ៉ាងទៀត ខ្សាច់លោកហៅថា **ឧរុ** ។ ព្រំប្រទល់ លោកហៅថា **វេលា** ។ គប្បីជ្រាបសេចក្តីក្នុងពាក្យនេះយ៉ាងនេះថា ខ្សាច់ដែលគេនាំមក ព្រោះកន្ទ្ធងខេត្តដែន ឈ្មោះថា **ឧរុវេលា** ។ ដំណាលមកថា ក្នុងអតីតកាលកាលព្រះពុទ្ធព្រះអង្គមិនទាន់ទ្រង់ឧប្បត្តិឡើង តាបស ១០.០០០ រូប នៅក្នុងប្រទេសនោះធ្វើកតិការ:ត្តថា កាយកម្ម និងវចីកម្ម រមែងប្រាកដសូម្បីដល់ជនពួកដទៃ ចំណែកមនោកម្មមិនប្រាកដឡើយ ព្រោះដូច្នោះ អ្នកណាត្រិះរិះដល់មិច្ឆាវិតក្ក: អ្នកនោះ ឈ្មោះថា ចូរចោទខ្លួនដោយខ្លួនឯង ចូរប្រើស្ទឹកឈើកើបខ្សាច់មកចាក់ពោយចុះក្នុងទីនេះ នេះជាទណ្ឌកម្មរបស់អ្នកនោះ ។ តអំពីនោះ អ្នកណាត្រិះរិះដល់វិតក្ក:ដូច្នោះ អ្នកនោះនឹងនាំខ្សាច់មកដោយខ្ជាប់ ដែលធ្វើដោយស្ទឹកឈើ ហើយចាក់ពោយចុះក្នុងទីនោះ ។ កាលបើដូច្នោះ ទើបទីនោះកើតជាគំនរខ្សាច់ដ៏ធំ ដោយលំដាប់ក្នុងទីនោះ ។ បន្ទាប់ពីនោះមក ជនជំនាន់ក្រោយ ពួនគំនរខ្សាច់ដ៏ធំនោះធ្វើជាចេតិយ ។ លោកសំដៅយកស្ថានទីនោះ ទើបបានពោលដូច្នេះថា បទថា **ឧរុវេលាយំ** បានដល់ ក្បែរគំនរខ្សាច់ដ៏ធំ គប្បីជ្រាបសេចក្តីថា ក្បែរគំនរខ្សាច់ដ៏ធំ ។

បទថា **វិហរតិ** ជាបទសម្តែងសេចក្តីប្រព្រឹត្តទៅដោយវិហារធម៌ណាមួយ បណ្តាវិហារធម៌ទាំងឡាយ មានឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារដោយមិនប្លែកគ្នា ។ តែក្នុងទីនេះ បទថា **វិហរតិ** គប្បីជ្រាបថាជាបទសម្តែងដល់ការប្រកបឥរិយាបថ ពោលគឺ ការអង្គុយ បណ្តាឥរិយាបថ

ដូចការឈរ ការអង្គុយ ការដើរ និងការដេក ។ ម្យ៉ាងទៀត បទថា **វិហរតិ** *នោះ គប្បីជ្រាបថា ជាការសម្តែងការប្រព្រឹត្តទៅនៃអរិយវិហារ ។ បណ្តា ឥរិយាបថ ទាំងនោះ ព្រោះហេតុដែលបុគ្គលកាត់សេចក្តីលំបាកឥរិយាបថមួយ ដោយ ឥរិយាបថមួយ ហើយនាំអត្តភាពទៅ គឺឱ្យប្រព្រឹត្តទៅដោយមិនឱ្យទ្រុឌទ្រោម ព្រោះដូច្នោះ ក្នុងទីនេះ គប្បីជ្រាបនៃអត្ថបទថា* **វិហរតិ** *ដោយឥរិយាបថវិហារ ។ ក៏ព្រោះហេតុដែលព្រះដ៏មានព្រះភាគទ្រង់នាំទៅ ទ្រង់នាំចូលទៅ ទ្រង់នាំចូល ទៅជិត បានដល់ ឱ្យកើតហិតប្រយោជន៍ច្រើនប្រការដល់សត្វទាំងឡាយ ដោយ ទិព្វវិហារជាដើម ព្រោះដូច្នោះ កាលពោលអំពីទិព្វវិហារជាដើម គប្បីជ្រាបអត្ត យ៉ាងនេះថា នាំទៅផ្សេងៗ ។*

បទថា **ឧជ្ជា** *សេចក្តីថា ឈ្មោះថា* **នទី** *ព្រោះហូរ គឺហូរទៅ ។ ការហូរ ទៅរបស់ទន្ទេនោះ អធិប្បាយថា មេទឹកដែលហូរទៅ ។ បទថា* **នេរញ្ជរាយ** *សេចក្តីថា ទឹករបស់ទន្ទេនោះមិនមានទោស ព្រោះដូច្នោះ កាលគួរនឹងពោលថា* **ឧលញ្ជលាយ** *ពោលចេញថា* **នេរញ្ជរាយ** *ព្រោះផ្ទាស់ ល អក្សរឱ្យជា រ អក្សរ ។ អធិប្បាយថា ទឹកវៀរចាកទោស មានកក់ សាវ៉ាយ និងចកជាដើម ។ អាចារ្យពួកខ្លះពោលថា កាលគួរនិយាយថា* **ឧីលជលាយ** *ពោលចេញថា* **នេរញ្ជរាយ** *ម្យ៉ាងទៀត ឈ្មោះនោះឯងគប្បីជ្រាបថា ជាឈ្មោះទន្ទេនោះ ។ ដើម្បីសម្តែង ស្ថានទីដែលព្រះដ៏មានព្រះភាគប្រថាប់នៅជិតច្រាំងទន្ទេនោះ លោកទើប ពោលថា* **ពោធិរុក្ខមូលេ** *ដូច្នេះ ។ ក្នុងបទថា* **ពោធិរុក្ខមូលេ** *នោះ មគ្គញ្ញាណហៅថា* **ពោធិ** *ក្នុងប្រយោគនេះថា* **ពោធិ រុច្ចតិ ចតូសុ**

មត្តេសុ ញាណំ ញាណក្នុងមគ្គទាំង ៤ ហៅថា **ពោធិ**[១] ដូច្នេះ ។ សព្វញ្ញុត-ញ្ញាណ ហៅថា **ពោធិ** ក្នុងប្រយោគនេះថា **បជ្ជោតិ ពោធឺ រវ្ភូរិមេធសោ** អ្នកមានប្រាជ្ញាដ៏ប្រសើរ ប្រៀបដោយផែនដីនឹងបានពោធិញ្ញាណ[២] ។ ព្រះដ៏-មានព្រះភាគទ្រង់សម្រេចពោធិ សូម្បីទាំងពីរយ៉ាងនេះត្រង់ដើមឈើនោះ ព្រោះហេតុនោះ សូម្បីដើមឈើនោះ រមែងបាននាមថា **ពោធិព្រឹក្ស** ។ ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **ពោធិ** ព្រោះត្រាស់ដឹងពោជ្ឈង្គ ៧ ។ សូម្បីដើមឈើនោះ ក៏បាននាមថា **ពោធិព្រឹក្ស** ព្រោះព្រះអង្គកាលត្រាស់ដឹងត្រូវអាស្រ័យដើមឈើនោះ ។ នៃពោធិព្រឹក្សនោះ ។ បទថា **មូលេ** ប្រែថា ទីជិត ។ មែនពិត សព្ទថា **មូល** នេះ ប្រាកដក្នុងមូល គឺឫសដែលកើតពីដើមក្នុងប្រយោគមានអាទិ៍ថា គប្បីដកឫស ដោយហោចទៅសូម្បីត្រឹមតែជាងស្ស្ងរសណ្ដាស់ ។ ប្រាកដក្នុងហេតុដែលមិនទូទៅ ក្នុងប្រយោគមានជាអាទិ៍ថា លោភចេតសិក ជាអកុសលមូល ។ ប្រាកដក្នុងទីជិត ក្នុងប្រយោគមានជាអាទិ៍ថា វេលាថ្ងៃត្រង់ស្រមោលផ្សាយទៅ វេលាសូរ្យខ្យល់ ស្ងឹកឈើក៏ជ្រុះមានកំណត់ត្រឹមណា ជិតដើមឈើ មានកំណត់ត្រឹមនោះ ។ **មូល**-សព្ទសូម្បីក្នុងទីនេះ លោកបំណងយកក្នុងទីជិត ព្រោះដូច្នោះ គប្បីជ្រាបសេចក្ដីក្នុងសេចក្ដីនេះយ៉ាងនេះថា ត្រង់គល់នៃពោធិព្រឹក្ស គឺទីជិត ។

១-សុត្តន្តបិដក ខុទ្ទកនិកយ ចូឬនិទ្ទេស លេខ ៦៨ ទំព័រ ១៩៧ ។

២-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ៣០ ។

បទថា **បឋមាភិសម្ពុទ្ធោ** *បានដល់ ជាអ្នកត្រាស់ដឹងក្រៃលែងជាគ្រាដំបូង អធិប្បាយថា មុនគេបង្អស់ ។ ដោយលំដាប់ពាក្យត្រឹមតែប៉ុណ្ណោះ ព្រះថេរៈជាធម្មកណ្ឌគារិក កាលផ្តើមតាំងពាក្យចាប់ផ្តើមនៃឧទានទេសនា ទើបជាការប្រកាស សម្តែងអាងដល់កាល ប្រទេស និងអ្នកសម្តែងដល់កាល និងប្រទេសព្រមដោយគុណពិសេស ។*

ក្នុងសេចក្តីនេះ មានអ្នកជំទាស់ពោលថា ក៏ព្រោះហេតុអ្វី កាលសង្គាយនាព្រះធម៌វិន័យ ទើបព្រះថេរៈពោលដល់ពាក្យចាប់ផ្តើម គួរធ្វើការរួបរួមចំពោះព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ហើយមិនមែនឬ? ធ្វើយថាដើម្បីឱ្យព្រះធម្មទេសនាដល់ព្រមដោយការតាំងមាំ មិនកន្ត្រក្ដ និងជាទីតាំងនៃសទ្ធា ។ មែនពិត ទេសនាដែលជាប់ជាបន្តបន្ទាប់ដោយកាល ប្រទេស អ្នកសម្តែង និងវត្ថុជាដើម រមែងជាទេសនាតាំងនៅយូរ មិនមានការកន្ត្រក្ដ និងជាទីតាំងឡើងនៃសទ្ធា ដូចការវិនិច្ឆ័យនូវការបញ្ញត្តិដែលជាប់ដោយប្រទេស កាល អ្នកធ្វើហេតុ និងនិមិត្ត ។ ក៏ព្រោះហេតុនោះឯង កាលព្រះមហាកស្សបៈដ៏មានអាយុ សួរក្នុងប្រទេសជាដើម ដោយន័យមានជាអាទិ៍ថា ម្នាលអានន្ទដ៏មានអាយុ ព្រះដ៏មានព្រះភាគត្រាស់ ឧទាន គ្រាដំបូងទុកទីណា? ព្រះអានន្ទជាធម្មកណ្ឌាគារិកៈ កាលនឹងវិសជ្ជនាបញ្ហាទាំងនោះ ទើបលោកពោលពាក្យចាប់ផ្តើមនៃឧទានដោយន័យមានជាអាទិ៍ថា **ឯវម្មេ សុតំ** *ដូច្នេះឯង ។*

ម្យ៉ាងទៀត លោកពោលដល់ពាក្យចាប់ផ្តើមជាការប្រកាសសត្ថុសម្បត្តិ ។ ការសម្រេចជាព្រះពុទ្ធរមែងមាន ព្រោះព្រះដ៏មានព្រះភាគ ជាព្រះតថាគតមិនមានការរចនាទុកមុនការពិចារណា ការរៀនសូត្រនិកាយ និងការប៉ាន់ស្មាន ។

ព្រោះថា ព្រះសម្មាសម្ពុទ្ធ មិនមានសេចក្តីត្រូវការ ដោយការរចនាទុកមុនជាដើម ព្រោះព្រះអង្គមានប្រមាណជាឯកក្នុងញ្ញេយ្យធម៌ ហេតុដែលព្រះអង្គបានទ្រង់បំពេញព្រះញាណ ដែលមិនមានបច្ច័យ អ្វីៗជំទាស់ក្នុងទីទាំងពួង ។ សេចក្តីសម្រេចជាព្រះខីណាស្រព រមែងមានព្រោះមិនមានសេចក្តីជាប់នៅក្នុងអាចរិ-យមុដ្ឋិ[១] (បិទបាំង) ធម្មមច្ចរិយៈ[២] (កំណត់ធម៌) ពាក្យទូន្មាន និងសាវក ។

១-**អាចរិយមុដ្ឋីតិ អាចរិយស្ស មុដ្ឋិកតឌម្មោ ។** *ធម៌ជាធ្វើកណ្តាប់ដៃរបស់អាចារ្យ ឈ្មោះថា* **អាចរិយមុដ្ឋិ ។** *(លីនត្ថប្បកាសនី ដីកានៃសារត្ថប្បកាសិនី អដ្ឋកថា សំយុត្តនិកាយ)*

អាចរិយមុដ្ឋីតិ យថា ពាហិរកានំ អាចរិយមុដ្ឋि ជាម ហោតិ ឧហរកាលេ ឧស្ស្ចិ អកថេត្វា មច្ចិមកាលេ មរណមញ្ចេ ឌិបន្ថ្ន ឧិយមជាបស្ស អន្តេវាសិកស្ស ឧថេត្ថ្ចិ ឯវំ តថាកតស្ស ឥជ្ជ មហាលូកកាលេ មច្ចិមដ្ឋានេ ឧថេស្ស្ចមីតិ មុដ្ឋី ឧត្វា បរិហរិស្ស្ចមីតិ ឧបិតំ ឧិញ្ចិ ជត្ថ្ចីតិ ឧស្ស្ចតិ ។ *បទថា* **អាចរិយមុដ្ឋि** *ព្រះសម្ពុទ្ធសម្តែងថា ឈ្មោះថា កណ្តាប់ដៃរបស់អាចារ្យ រមែងមានដល់គ្រូខាងក្រៅព្រះពុទ្ធសាសនា (ពួកគ្រូទាំងនោះ) មិនពោលពាក្យណាមួយដល់អ្នកណាម្នាក់ឡើយ ក្នុងកាលខ្លួននៅកំលោះ តែពេលដែលខ្លួនដេកលើគ្រែជាទីស្ងាប់ក្នុងបច្ចិមកាល បានប្រាប់ដល់អន្តេវាសិកជាទីស្រឡាញ់របស់ខ្លួនដោយវិធីយ៉ាងណា ចំណែកកិច្ចឯណាមួយ ដែលតថាគតបានបរិហារតាំងទុកដោយធ្វើទុកជាកណ្តាប់ដៃថា តថាគតនឹងពោលពាក្យនេះ ក្នុងវេលាបច្ចិមវ័យ រមែងមិនមានដល់តថាគត ដោយវិធីយ៉ាងនោះឡើយ ។** *(សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ មហាបរិនិព្វានសុត្តវណ្ណនា)*

២-**បរិយត្តិឌម្ម មច្ចរិយំ ឌម្ម្ចមច្ចរិយំ ។ តេន សមន្ថ្ចតោ ភិក្ខុ ឥមំ ឌម្ម្ចំ បរិយាបុណិត្ថ្ចា ឯសោ មំ អកិកវិស្ស្ចតីតិ អញ្ញស្ស ន ឧេតិ ។ យោ ឧន ឌម្ម្ចានុក្ខហោន ភ្ជ បុគ្ខលានុក្ខហោន ភ្ជ ន ឧេតិ ន តំ មច្ចិយំ ។** *ការកំណាញ់ក្នុងបរិយត្តិធម៌ ឈ្មោះថា ធម្មមច្ចរិយ ។ ភិក្ខុអ្នកដល់ព្រមដោយធម្មមច្ចរិយនោះ តែងមិនឱ្យធម៌ដល់អ្នកដទៃ ដោយគំនិតថា ភិក្ខុអង្គនោះ កាលរៀនយកនូវព្រះធម៌នេះ រមែងគ្របសង្កត់នូវអញ ។ ក៏ប៉ុន្តែថា បុគ្គលឯណា មិនឱ្យនូវធម៌ ព្រោះអាស្រ័យ*

ព្រោះថា អ្នកអស់អាសវៈដោយប្រការទាំងពួង សូម្បីក្នុងទីណាៗ ក៏មិនមានអាចរិយមុដ្ឋិជាដើម ព្រោះដូច្នោះ លោកជាអ្នកបរិសុទ្ធល្អ ទើបអនុគ្រោះពួកសត្ត ។ ដូច្នោះ ការសម្រេចវេសារជ្ជញ្ញាណ ២ ប្រការខាងដើម រមែងមានដោយសេចក្តីបរិសុទ្ធនិងហ្មត់ចត់ល្អ ដែលបំភ្លឺដល់សេចក្តីមិនមានអវិជ្ជា និងតណ្ហា ដែលប្រទូសរ៉ាយទិដ្ឋិសម្បត្តិ និងសីលសម្បត្តិជាទោសក្នុងការសម្តែង និងប្រាកដច្បាស់ដោយញាណសម្បទា និងបហានសម្បទា ម្យ៉ាងទៀត ការសម្រេចវេសារជ្ជញ្ញាណ ២ ប្រការខាងចុង រមែងមានព្រោះសម្រេចដោយការមិនមានអវិជ្ជាក្នុងអន្តរាយិកធម៌ និងនិយ្យានិកធម៌នោះឯង ។ សេចក្តីប្រកបដោយវេសារជ្ជ-ញ្ញាណ ២ របស់ព្រះដ៏មានព្រះភាគ និងការបំពេញប្រយោជន៍របស់ព្រះអង្គ

នូវសេចក្តីអនុគ្រោះនូវធម៌ ឬបុគ្គល ។ ការគិតយ៉ាងនោះ របស់ភិក្ខុនេះ មិនឈ្មោះថា កំណាញ់ធម៌ឡើយ ។(សង្គ្ហិតិសុត្តវណ្ណនា សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ)

ក្នុងលីនត្ថប្បកាសនីដីកា នៃអដ្ឋកថា សុមង្គលវិលាសិនី បានពន្យល់ថា **អយំ ឥមំ ធម្មំ ឧក្ខហេ-ត្វា អញ្ញថា អត្ថំ វិបរិវត្តេត្វា ឧស្សេស្សតីតិ ធម្មានុក្ខហេន ន ទេតិ ។ អយំ ឥមំ ធម្មំ ឧក្ខ-ហេត្វា ឧទ្ធតោ ឧន្ធច្ចោ អវូបសន្តចិត្តោ អបុញ្ញ បសវិស្សតីតិ បុក្ខលានុក្ខហេន ន ទេតិ ។ ន តំ អជានំ មច្ឆរិយំ មច្ឆរិយលក្ខណាស្ស អភាវតោ ។** *ភិក្ខុនេះ រៀនយកនូវធម៌នេះ រមែងធ្វើនូវអត្ថឱ្យប្រែប្រួលវិនាសទៅជាបការៈដទៃ ព្រោះហេតុនោះ ទើបលោកមិនឱ្យធម៌ដោយអាស្រ័យសេចក្តីអនុគ្រោះនូវធម៌ ។ ភិក្ខុនោះ រៀនយកនូវធម៌នោះ ជាអ្នកមានមានៈដូចជាបបុស លើកឡើងហើយមានចិត្តមិនសូប់ខ្ពស់ឡើង រមែងញុំងអកុសលធម៌ឱ្យកើតឡើង ព្រោះហេតុនោះ ទើបលោកមិនឱ្យធម៌ ព្រោះអាស្រ័យសេចក្តីអនុគ្រោះនូវបុគ្គលនោះ ។ ធម្មមច្ឆរិយៈនោះ ដែលបុគ្គលឱ្យហើយ ព្រោះភាវៈនៃធម្មមច្ឆរិយៈនោះ មិនមែនជាលក្ខណៈនៃមច្ឆរិយៈឡើយ ។*

និងប្រយោជន៍របស់អ្នកដទៃ ជាការប្រកាសហើយដោយពាក្យចាប់ផ្តើមព្រោះ សម្តែងដល់ព្រះធម្មទេសនា ដោយបដិភាណដែលកើតឡើង តាមឋានៈដោយ សមគួរដល់អធ្យាស្ស័យរបស់បរិស័ទអ្នកប្រជុំគ្នាក្នុងទីនោះៗ ។ តែក្នុងទីនេះគប្បី ជ្រាបសេចក្តីថា ដោយការប្រកាសការសោយវិមុត្តិសុខ និងមនសិការដល់បដិច្ច-សមុប្បាទ ។ ព្រោះដូច្នោះ ទើបព្រះអានន្ទពោលថា ពោលពាក្យចាប់ផ្តើម ដើម្បី ប្រកាសសត្ថុសម្បត្តិ ។

ម្យ៉ាងទៀត ពោលពាក្យចាប់ផ្តើម ដើម្បីប្រកាសសាសនសម្បត្តិ ។ មែនពិត ព្រះដ៏មានព្រះភាគ ព្រះអង្គបំពេញកិច្ចទាំងពួង ដែលកំណត់ដោយព្រះបញ្ញា-គុណ និងព្រះករុណាគុណ មិនមានការបដិបត្តិដែលគ្មានប្រយោជន៍ ឬ (ប្រាជ្ញ) ប្រយោជន៍របស់ព្រះអង្គ ។ ព្រោះដូច្នោះ កាយកម្ម វចីកម្ម និងមនោកម្ម សូម្បី ទាំងអស់របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបំពេញប្រយោជន៍ទាំងពួង ដែលប្រព្រឹត្ត ទៅដើម្បីប្រយោជន៍ដល់អ្នកដទៃតែម្យ៉ាង ដែលត្រាស់ទៅតាមសមគួរដល់ការ ប្រព្រឹត្តទៅ ឈ្មោះថា **សាសនា** ព្រោះតាមទូន្មានសត្វទាំងឡាយតាមសមគួរ ដោយធម្មិកត្តប្រយោជន៍ សម្ប្រាយិកត្តប្រយោជន៍ និងបរមត្តប្រយោជន៍ មិន មែនជាការរចនារបស់ឥសីទេ ។ ព្រះពុទ្ធចរិយានេះនោះ លោកប្រកាសទុក តាម សមគួរ ដោយពាក្យចាប់ផ្តើមក្នុងទីនោះៗ ព្រមនឹងកាលៈ ទេសៈ អ្នកសម្តែង និងប្រទេស ។ តែក្នុងទីនេះគប្បីប្រកបថា ដោយការសោយវិមុត្តិសុខក្នុងការត្រាស់ ដឹងក្រៃលែង និងដោយមនសិការបដិច្ចសមុប្បាទ ។ ព្រោះហេតុនោះ លោក ទើបពាលថា ពោលពាក្យចាប់ផ្តើមដើម្បីប្រកាសសាសនសម្បត្តិ ។ ម្យ៉ាងទៀត

ការពោលពាក្យចាប់ផ្តើម ដើម្បីសម្តែងដល់ការ:ដែលព្រះសាសនាជាប្រមាណ ដោយការប្រកាសការ:ដែលសាស្តាជាប្រមាណ ។ និងការសម្តែងការ:ដែលព្រះសាសនាជាប្រមាណនោះ គប្បីជ្រាបតាមក្រសៃនៃន័យដែលពោលហើយក្នុងកាលមុន ។ មែនពិត ដោយពាក្យថា **ភគវា** *នេះ ជាការប្រកាសសេចក្តីនេះ ដោយប្រការទាំងពួង ដោយការសម្តែងដល់ការលះមន្ទិល គឺកិលេសទាំងពួងមានរាគ: ទោស: មោហ:ជាដើម និងការលះទោស មានទុច្ចរិតជាដើម ដោយការសម្តែងសេចក្តីដែលព្រះតថាគតជាអ្នកខ្ពង់ខ្ពស់បំផុតជាងសព្វសត្ត្ব និងដោយការសម្តែងដល់ការប្រកបដោយគុណវិសេស មានព្រះបញ្ញាគុណ និងព្រះករុណា-គុណជាដើម ដែលមិនទូទៅដល់អ្នកដទៃ ព្រោះដូច្នោះ ពាក្យនេះ ទើបជាពាក្យសម្តែងត្រឹមតែជាប្រធាននៃការប្រកបពាក្យចាប់ផ្តើមក្នុងសេចក្តីនេះ ។*

ក៏គប្បីជ្រាបពាក្យដែលលោកចាប់ផ្តើមថា **ឯវម្ម សុតំ** *ដរាបដល់ពាក្យថា* **ឥមំ ឧទានំ ឧទានេសិ** *នេះជាពាក្យចាប់ផ្តើមរបស់ឧទាននេះ ។ ពិតយ៉ាងនោះ ពាក្យនោះ ជាពាក្យដែលព្រះសង្គីតិកាចារ្យពោលទុកក្នុងកាលសង្គាយនាដើម្បីប្រកាសការបដិបត្តិតាមផ្លូវកាយ និងផ្លូវចិត្តរបស់ព្រះដ៏មានព្រះភាគនោះ ចាប់ផ្តើមតាំងពីដើម តាមដែលព្រះអង្គទ្រង់បដិបត្តិមកដរាបដល់បន្ទឹព្រះឧទាននេះ ។*

សួរថា ក៏បទថា **ឥមស្មឺ សតិ ឥទំ ហោតិ** *ជាដើម គួរជាពាក្យរបស់ព្រះដ៏មានព្រះភាគប៉ុណ្ណោះ ព្រោះអ្នកដទៃក្រៅអំពីព្រះសាស្តាហើយ មិនអាចនឹងសម្តែងបដិច្ចសមុប្បាទបានមិនមែនឬ? ឆ្លើយថា ប្រការនេះ ពិតមែនសមដូចជាព្រះដ៏មានព្រះភាគទ្រង់ធ្វើបដិច្ចសមុប្បាទទុកក្នុងព្រះទ័យ ដោយការពិចារណាសការធម៌ទៀបគល់ពោធិព្រឹក្សយ៉ាងណា ព្រះធម្មសង្គាហកមហាថេរ:*

ទាំងឡាយ សង្ខ្យាយនាពាក្យចាប់ផ្តើមនៃឧទាននេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងទុកក្នុងបដិច្ចសមុប្បាទ និងសីហនាទសូត្រជាដើម ដើម្បីដាស់ពួកសត្ត្ব អ្នកជាផៅពង្សនៃសត្ត្ব អ្នកគួរនឹងត្រាស់ដឹងបដិច្ចសមុប្បាទនោះ និងសម្តែងមនសិការៈដល់បដិច្ចសមុប្បាទឱ្យជាអត្ថុប្បត្តិហេតុ ដោយអំណាចនៃការធ្វើតាមអាការនៃព្រះតម្រាស់ដែលទ្រង់សម្តែងទុកក៏យ៉ាងនោះ ព្រោះហេតុនោះ គប្បីកាន់យកក្នុងសេចក្តីនេះថា ពាក្យតាមដែលពោលទុកជាពាក្យរបស់ព្រះសង្ខ្តីតិ-កាចារ្យនុ៎ះឯង ។ សូម្បីក្នុងសូត្រដទៃក្រៅពីនេះក៏មានន័យនេះដូចគ្នាដែរ ។

ក៏ក្នុងសេចក្តីនេះ គប្បីជ្រាបសុត្តនិក្ខេបបទ (ការតាំងឡើងនូវព្រះសូត្រ) ៤ ប្រការ គឺកើតដោយអធ្យាស្ស័យរបស់ខ្លួន ១ កើតដោយអធ្យាស្ស័យរបស់អ្នកដទៃ ១ កើតដោយអំណាចពាក្យសួរ ១ កើតដោយការកើតរឿងឡើង ១ ។ ពិតយ៉ាងនោះ ព្រះសូត្រផ្សេងសូម្បីច្រើនរយ ច្រើនពាន់សូត្រ ក៏មិនកន្ទងហួសការៈ ១៦ យ៉ាង ដោយបដ្ឋានន័យ មានសង្ខ្ជិលេសភាគិយន័យជាដើម យ៉ាងណា ព្រះសូត្រសូម្បីទាំងអស់នោះក៏ដូច្នោះ មិនកន្ទងហួសការៈ ៤ ប្រការ ដោយសុត្តនិក្ខេបន័យមានអត្ថជ្ឌាសយន័យ (អធ្យាស្ស័យរបស់ខ្លួន) ជាដើម ។ ក៏ក្នុងសេចក្តីនេះ ការតាំងឡើងព្រះសូត្រដែលកើតដោយអធ្យាស្ស័យរបស់ខ្លួន និងកើតដោយការកើតរឿងឡើង រមែងមានប្រភេទរបស់ការជាប់ទាក់ទងនឹងអធ្យា-ស្ស័យរបស់អ្នកដទៃ និងកើតដោយអំណាចពាក្យសួរ ព្រោះកើតដោយអនុសន្ធិនៃអធ្យាស្ស័យ និងអនុសន្ធិនៃពាក្យសួរក៏ពិត ការតាំងឡើងនៃព្រះសូត្រដែលកើតពីអធ្យាស្ស័យរបស់ខ្លួន និងកើតដោយការកើតរឿងឡើងទើបមិនមានសេចក្តី

ជាប់ទាក់ទងគ្នានិងគ្នា ព្រោះដូច្នោះ បដ្ឋានន័យទើបមិនមានចំណែកនៅសល់ឡើយ ។ ម្យ៉ាងទៀត លោកពោលថា សុត្តនិក្ខេប ៤ ដោយអំណាចមូលនិក្ខេបនៃនិក្ខេបដែលនៅសល់ដែលមាន ព្រោះធ្លាក់ចុះក្នុងខាងក្នុងនៃបដ្ឋានន័យនោះ ។

ក្នុងសេចក្ដីនោះ មានវចនត្ថដូចតទៅនេះ

ការតាំងចុះ ឈ្មោះនិក្ខេប និក្ខេបនៃព្រះសូត្រ ឈ្មោះថា សុត្តនិក្ខេប អធិប្បាយថា សុត្តទេសនា ម្យ៉ាងទៀត ឈ្មោះថា និក្ខេប ព្រោះគេតាំងទុក និក្ខេប គឺសូត្រ ឈ្មោះថា សុត្តនិក្ខេប ។ អធ្យាស្ស័យរបស់ខ្លួនឈ្មោះថា អត្តជ្ឌាសយ: សុត្តនិក្ខេបនោះ ឈ្មោះថា អត្តជ្ឌាសយ: ព្រោះមានអធ្យាស្ស័យនៃខ្លួនជាហេតុ ។ ម្យ៉ាងទៀត ឈ្មោះថា អត្តជ្ឌាសយ: ព្រោះមានខ្លួនជាអធ្យាស្ស័យ ។ សូម្បីក្នុងអធ្យាស្ស័យរបស់អ្នកដទៃក៏ន័យនេះដូចគ្នា ។ អំណាចនៃពាក្យសួរឈ្មោះថា បុច្ឆាវស: សុត្តនិក្ខេបនោះ ឈ្មោះថា បុច្ឆាវសិក: ព្រោះមានអំណាចនៃពាក្យសួរ ។ ការកើតឡើងនៃសេចក្ដីដែលជារឿងនៃសុត្តទេសនានោះ ឈ្មោះថា អត្ថុប្បត្តិ ។ ម្យ៉ាងទៀត អត្ថុប្បត្តិនោះឯង ឈ្មោះថា អដ្ឋុប្បត្តិក: ។ សុត្តនិក្ខេប ឈ្មោះថា អដ្ឋុប្បត្តិក: ព្រោះមានការកើតរឿងឡើង ។ ម្យ៉ាងទៀត ឈ្មោះថា និក្ខេប ព្រោះជាហេតុតាំងព្រះសូត្រ គឺអធ្យាស្ស័យរបស់ខ្លួនជាដើម ។ ចំណែកក្នុងការកំណត់អត្ថនេះ គប្បីជ្រាបអត្ថក្នុងសេចក្ដីនេះយ៉ាងនេះថា អធ្យាស្ស័យរបស់ខ្លួនឈ្មោះថា អត្តជ្ឌាសយ: ។ អធ្យាស្ស័យរបស់អ្នកដទៃ ឈ្មោះថា បរជ្ឌាសយ: ។ ឈ្មោះថា បុច្ឆា ព្រោះគេសួរ គឺរឿងដែលនិងត្រូវសួរ ។ ពាក្យរបស់អ្នកទទួលធម៌ដែលប្រព្រឹត្តទៅដោយពាក្យសួរ ឈ្មោះថា បុច្ឆាវស: បុច្ឆាវស:

ន្ទុ:ឯង លោកពោលជាបុំលិង្គថា **ឧច្ឆាវសិ**ោ ដោយប្រាជ្ញាដល់ស័ព្ទថា និក្ខេប ។ ម្យ៉ាងទៀត អត្ថុប្បត្តិន្ទុ:ឯង ឈ្មោះថា អដ្ឋុប្បត្តិក: ។

ក៏ក្នុងសេចក្តីនេះមានពាក្យសាកសួរមកថា ព្រោះមិនប្រាជ្ញាដល់ហេតុ មានសេចក្តីចាស់ក្ងាវនៃឥន្ទ្រិយជាដើមរបស់អ្នកដទៃ ទើបគួរមានការ:នៃសុត្តនិក្ខេប ផ្នែកមួយរបស់អត្ថជ្ឈាសយ: ព្រោះប្រកាសទេសនា ដើម្បីតាំងបែបផែននៃធម៌ តាមអធ្យាស្ស័យរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ក៏សុត្តនិក្ខេបដែលកើតដោយអធ្យា-ស្ស័យរបស់អ្នកដទៃ និងដែលកើតដោយពាក្យសួរ ប្រព្រឹត្តទៅក្នុងការកើតឡើង នៃអធ្យាស្ស័យ និងពាក្យសួររបស់អ្នកដទៃ ដែលជាហេតុឱ្យប្រកាសធម្មទេសនា យ៉ាងណាទើបមិនខុសក្នុងការកើតរឿងឡើង ឬថា កាលសុត្តនិក្ខេបដែលកើត ដោយអំណាចពាក្យសួរ និងដែលកើតដោយការកើតរឿងឡើង ប្រព្រឹត្តទៅ ដោយបណ្តោយតាមអធ្យាស្ស័យរបស់អ្នកដទៃយ៉ាងណា ទើបមិនខុសក្នុង អធ្យាស្ស័យរបស់អ្នកដទៃ ? ប្រការនោះមិនគប្បីធ្ងល់ឡើយ ។ ក៏ព្រោះលោក កាន់យកការកើតឡើងដែលជាហេតុសម្តែងព្រះសូត្រ ដែលរួចផុតចាកអកិនិហារ និងការសាកសួរជាដើម និងការវិនិច្ឆ័យជាដើមរបស់អ្នកដទៃដោយជាអត្ថុប្បត្តិ ទើបកាន់យកសុត្តនិក្ខេប ដែលកើតដោយអធ្យាស្ស័យរបស់អ្នកដទៃ និងដែល កើតដោយអំណាចពាក្យសួរទុកត្រង់កន្ទ្ធងផ្សេងទៀត ។ ពិតយ៉ាងនោះ ហេតុ ក្នុងការសម្តែងគុណនិងទោស និងការកើតឡើងនៃអាមិស នៃព្រហ្មជាលសូត្រ និងធម្មទាយាទសូត្រជាដើម លោកហៅថា អត្ថុប្បត្តិ ។ រឿរពាក្យសួររបស់អ្នក ដទៃចេញអត្ត ដែលលោកសម្តែងចំពោះអធ្យាស្ស័យឱ្យជានិមិត្តនេះ ប្រាកដថា

បរជ្ឌាសយ: (កើតអំពីអធ្យាស្ស័យរបស់អ្នកដទៃ) ។ សេចក្ដីដែលលោកសម្ដែងដោយអំណាចពាក្យសួរនេះប្រាកដថា បុច្ឆាវសិក: កើតដោយអំណាចពាក្យសួរ ។

បណ្ដានិក្ខេប ៤ យ៉ាងនោះ ឧទានទាំងនេះ គឺពោធិសូត្រ ៣ ខាងជាដើម មុចលិន្ទសូត្រ អាយុសង្ខារោសជ្ជនសូត្រ បច្ចវេក្ខណសូត្រ និងបបញ្ចសញ្ញាសូត្រ ចាត់ជាអត្តជ្ឌាសយនិក្ខេប ។ ឧទានទាំងនេះ គឺហុហុង្គសូត្រ ព្រាហ្មណជាតិ-កសូត្រ ពាហិយសូត្រ ចាត់ជាបុច្ឆាវសិកនិក្ខេប ។ ឧទានទាំងនេះ គឺរាជសូត្រ សក្ការសូត្រ ឧច្ឆាទនសូត្រ បិណ្ឌបាតិកសូត្រ សិប្បសូត្រ គោបាលកសូត្រ សុន្ទរិកាសូត្រ មាតុសូត្រ សង្ឆកេទសូត្រ ឧទបានសូត្រ តថាគតុប្បាទសូត្រ មោនេយ្យសូត្រ បាដលិគាមិយសូត្រ និងទព្ធសូត្រ ២ សូត្រ ចាត់ជាអដ្ឋុប្បត្តិក-និក្ខេប ។ ឧទានទាំងនេះ គឺបាលិលេយ្យសូត្រ បិយសូត្រ នាគសមាលសូត្រ និងវិសាខាសូត្រ មានទាំងអត្តជ្ឌាសយនិក្ខេប និងបរជ្ឌាសយនិក្ខេប ។ សូត្រដែលនៅសល់ ៥១ សូត្រទៀត ចាត់ជាបរជ្ឌាសយនិក្ខេប ។ គប្បីជ្រាបសេចក្ដីប្ដែកគ្នានៃនិក្ខេបរបស់ឧទានទាំងនោះ ដោយអំណាចអត្តជ្ឌាសយនិក្ខេបជាដើម ដោយប្រការដូច្នេះ ។

ក៏ក្នុងទីនេះ ឧទានពួកណា ព្រះដ៏មានព្រះភាគត្រាស់ចំពោះមុខភិក្ខុទាំងឡាយ ឧទានទាំងនោះជាព្រះសូត្រតាមដែលត្រាស់ទុក គឺភិក្ខុទាំងនោះទន្ទេញឱ្យរត់មាត់ពិចារណាបានដោយចិត្ត ត្រាស់ទុកដល់ព្រះធម្មកណ្ឌាគារិក ។ ចំណែកឧទានពួកណា ព្រះដ៏មានព្រះភាគ មិនបានត្រាស់ចំពោះមុខភិក្ខុទាំង-ឡាយ សូម្បីឧទានទាំងនោះខាងក្រោយ ព្រះដ៏មានព្រះភាគបានត្រាស់ដល់ធម្មកណ្ឌាគារិកទៀត ។ គប្បីជ្រាបថា ឧទានទាំងនោះសូម្បីទាំងអស់ដូចពោល

មកនេះ ព្រះអានន្ទអ្នកដ៏មានអាយុ ទ្រទ្រង់ចាំទុកបានទាំងអស់ ហើយប្រាប់ដល់ភិក្ខុទាំងឡាយខាងក្រោយ មកបានលើកឡើងកាន់សង្គាយនាថា ឧទាន នុ៎ះឯង ក្នុងគ្រាធ្វើបឋមមហាសង្គាយនាគ្រាដំបូង ។

ក៏បទថា **តេន សមយេន** ក្នុងបទមានជាអាទិ៍ថា **តេន ខោ បន សមយេន** ជាតតិយាវិភត្តិប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។ បទថា **ខោ បន** ជានិបាតអធិប្បាយថា **តស្មឿ សមយេ** ក្នុងសម័យនោះ ។ ក៏ក្នុងសម័យណា? គឺក្នុងសម័យដែលព្រះដ៏មានព្រះភាគត្រាស់ដឹងគ្រាដំបូង ប្រថាប់នៅត្រង់គល់ពោធិ៍ជិតច្រាំងទន្ទេនេរញ្ជរ ក្នុងតំបន់ឧរុវេលារហូតដល់អស់សម័យណា ក្នុងសម័យនោះ ។ បទថា **សត្តាហំ** ប្រែថា ៧ ថ្ងៃ គឺមួយសប្តាហ៍ ។ បទថា **សត្តាហំ** នេះ ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃអច្ចន្តសំយោគ: ប្រែថា រហូតដល់អស់ ។ ព្រះដ៏-មានព្រះភាគទ្រង់ប្រថាប់នៅដោយផលសមាបត្តិជាសុខ អស់ចំណែកតែមួយ ដោយមិនដាច់រយ:រហូតដល់អស់សប្តាហ៍នោះ យ៉ាងណា លោកទើបពោលដោយទុតិយាវិភត្តិ ដោយអំណាចអច្ចន្តសំយោគ:ថា **សត្តាហំ** ប្រែថា រហូតដល់អស់សប្តាហ៍ ក៏យ៉ាងនោះដែរ ។ បទថា **ឯកបល្លង្ខេន** សេចក្តីថា ដោយគង់ប្រថាប់ចម្រើនសមាធិតែម្យ៉ាងប៉ុណ្ណោះ ទ្រង់មិនក្រោកឡើងត្រឹមតែម្តងតាំងពីវេលាដែលប្រថាប់គង់លើវជិរាសន: ដែលជាអបរាជិតបល្ល័ង្ក ដ៏ប្រសើរ ក្នុងវេលាព្រះអាទិត្យមិនទាន់អស្តង្គត ក្នុងថ្ងៃវិសាខបុណ្ណមី ។

បទថា **វិមុត្តិសុខំ បដិសំវេឡី** សេចក្តីថា ព្រះអង្គប្រថាប់គង់សោយវិមុត្តិ-

សុខ គឺសុខកើតអំពីផលសមាបត្តិ ។ បណ្តាបទទាំងនោះ បទថា **វិមុត្តិ** *បានដល់* **វិមុត្តិ ៥** *គឺ* **តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិ** *។ បណ្តាវិមុត្តិទាំង ៥ នោះ ការរួចផុតដោយរួចផុតពីធម៌ ដែលជាសត្រូវនោះ។ ដោយអង្គនៃគុណនោះ។ មានការបរិច្ចាគទេយ្យធម៌ជាដើម និងដោយអង្គនៃ វិបស្សនា មានការកំណត់នាមរូបជាដើម ដរាបដល់អង្គនោះ។ ប្រព្រឹត្តទៅដោយ មិនមានការសាបសូន្យចាត់ជាបហាន: ។ តើការលះមានអ្វីខ្លះ? គឺការលះ មច្ឆរិយ: និងលោភ:ជាដើម ដោយការឱ្យទាន លះបាណាតិបាតជាដើម ដោយ ការរក្សាសីល លះសក្កាយទិដ្ឋិដោយការកំណត់នាមរូប លះទិដ្ឋិដែលមិនមាន ហេតុ និងមានហេតុមិនស្មើគ្នា ដោយការកំណត់បច្ច័យ និងធម៌ដែលមិនមែន បច្ច័យ លះភាពជាអ្នកសង្ស័យដោយការ ធ្វង់ផុតសេចក្តីសង្ស័យ ដែលជាចំណែក ដទៃរបស់នាមរូបនោះឯង លះការប្រកាន់ថាយើង ថារបស់យើង ដោយការ ពិចារណាដល់រូបកលាប: (រូបជាក្រុម ជាដុំ) លះសេចក្តីសម្គាល់ក្នុងធម៌ដែលមិន មែនមគ្គថាជាមគ្គ ដោយការកំណត់ថា មគ្គ និងមិនមែនមគ្គ លះឧច្ឆេទទិដ្ឋិ ដោយការឃើញការកើតនៃនាមរូប លះសស្សតទិដ្ឋិ ដោយការឃើញការរលត់ នាមរូប លះសេចក្តីសម្គាល់ក្នុងវត្ថុដែលមានភ័យថាមិនជាភ័យ ដោយការឃើញ ថាជាភ័យ លះសេចក្តីសម្គាល់ថា គួរត្រេកអរដោយ ការឃើញថាជាទោសពី សេចក្តីសម្គាល់រូបថា គួរក្ងើតក្ងើនដោយការឃើញរូបថា គួរនឿយណាយ លះ ការមិនប្រាថ្នាដើម្បីនឹង ឱ្យរួចផុតដោយញាណ គឺការចម្រើនប្រាថ្នាដើម្បីប្រាថ្នា នឹងរួចផុត លះការមិនប្រដើរដោយឧបេក្ខាញាណ លះភាវ:ដែលជាបដិលោម (គឺជំទាស់) ក្នុងធម្មឋិតិ និងព្រះនិព្វានដោយអនុលោមញាណ និងផុតពីភាវ:*

មានសង្ខារជានិមិត្ត ដោយគោត្រកូញ្ញាណ នេះឈ្មោះថា **តទង្គវិមុត្តិ** ។

ម្យ៉ាងទៀត សេចក្តីរួចផុតដែលសំដៅដល់ការមិនកើតឡើងនៃនីវរណៈ: មានកាមឆន្ទនីវរណៈជាដើម និងបច្ចនិកធម៌ (ធម៌ដែលជាសត្រូវ) មានវិតក្ក: ជាដើម ដោយសមាធិដែលផ្សេងដោយឧបចារសមាធិ និងអប្បនាសមាធិ ដរាបដល់សមាធិនោះប្រព្រឹត្តទៅដោយការមិនសាបសូន្យ នេះឈ្មោះថា **វិក្ខម្ភនវិមុត្តិ** ។

សេចក្តីរួចផុតដោយអំណាចសមុច្ឆេទបហាន ដោយការមិនកើតឡើងម្តងទៀត នៃក្រុមកិលេសជាចំណែកសមុទយ: ដែលពោលទុកដោយន័យមានជាអាទិ៍ថា **ឧិដ្ឋិកតានំ បហានាយ** ព្រោះលះទិដ្ឋិ តាមសមគួរក្នុងសន្ធានៃព្រះអរិយអ្នកតាំងនៅក្នុងមគ្គនោះ។ ព្រោះលោកធ្វើអរិយមគ្គ ៤ ឱ្យកើត នេះឈ្មោះថា **សមុច្ឆេទវិមុត្តិ** ។ ក៏ការ:នៃកិលេស ដែលសូប់រម្ងាប់ទៅក្នុងខណ:នៃផលចិត្ត នេះឈ្មោះថា **បដិបស្សទ្ធិវិមុត្តិ** ។ ចិត្តដែលរួចផុតពីសង្ខារទាំងពួងឈ្មោះថា ព្រះនិព្វាន ព្រោះរលាស់សង្ខតធម៌ទាំងពួង នេះឈ្មោះថា **និស្សរណ-វិមុត្តិ** ។ តែក្នុងទីនេះ លោកប្រាថ្នាយកការរួចផុតដោយអំណាចនៃផលចិត្ត របស់ព្រះដ៏មានព្រះភាគ ដែលមានព្រះនិព្វានជាអារម្មណ៍ ។ ព្រោះហេតុនោះ លោកទើបពោលថា បទថា **វិមុត្តិសុខំ បដិសំវេទី** សេចក្តីថា ព្រះអង្គគង់ប្រថាប់សោយវិមុត្តិសុខ គឺសុខកើតដែលអំពីផលសមាបត្តិ ។ ក៏បទថា **វិមុត្តំ** បានដល់ ការ:ដែលចិត្តរួចផុតដោយអំណាចការសូប់រម្ងាប់ឧបកិលេស ។ ម្យ៉ាងទៀត គប្បីជ្រាបចិត្តនុ៎ះឯងថា រួចផុតហើយយ៉ាងនោះ ។ សុខដែលកើតឬសម្បយុត្តដោយវិមុត្តិនោះ ឈ្មោះថា វិមុត្តិសុខ ។ ក៏ក្នុងទីនេះ សូម្បីឧបេក្ខា

ក៏គប្បីជ្រាបថាសុខដូចគ្នា ព្រោះព្រះបាលីថា **យាយំ ភន្តេ ឧបេក្ខា សន្តេ សុខេ វុត្តា ភគវតា** *បពិត្រលោកដ៏ចម្រើន ឧបេក្ខានេះណា ព្រះដ៏មានព្រះភាគ ទ្រង់ សម្តែងថា សុខដ៏ឧត្តម[1] ។ សមដូចពាក្យដែលលោកពោលទុកក្នុងអដ្ឋកថា សម្មោហវិនោទនីថា* **ឧបេក្ខា បន សន្តត្តា សុខមិច្ចេវ ភាសិតា** *ក៏ឧបេក្ខា លោកពោលថាសុខដូចគ្នា ព្រោះមានសេចក្តីស្ងប់ ។ មែនពិត ព្រះដ៏មានព្រះភាគ ទ្រង់ចូលអរហត្តសមាបត្តិ ដែលប្រកបដោយឈានទី ៤ មិនមែនចូលសមាបត្តិ ដទៃទេ ។ ម្យ៉ាងទៀត ការចូលទៅស្ងប់សង្ខារទុក្ខ លោកហៅថា* **សុខ** *ដូចក្នុង ប្រយោគមានជាអាទិ៍ថា* **តេសំ រូបសមោ សុខោ** *ការចូលទៅស្ងប់សង្ខារជា សុខយ៉ាងណា ចំពោះបដិប្បស្សទ្ធិវិមុត្តិដែលបានក្នុងផលដ៏ប្រសើរ (អរហត្តផល) ព្រោះជាការស្ងប់ចាកកិលេសនិងទុក្ខទាំងអស់ គប្បីជ្រាបថា សុខក្នុងទីនេះដូច្នេះ ។ វិមុត្តិសុខនេះ នោះមាន ២ យ៉ាង ដោយការចែកការប្រព្រឹត្តទៅរបស់ផលចិត្ត គឺក្នុងមគ្គវិថី ១ ក្នុងកាលដទៃ ១ ។ ផលចិត្ត ៣ ឬ ២ (ខណៈ) ដែលមានព្រះនិព្វាន ជាអារម្មណ៍ដែលជាផលរបស់វិមុត្តិសុខនោះ។ រមែងកើតឡើងក្នុងលំដាប់អរិយមគ្ត តែម្យ៉ាង ព្រោះលោកុត្តរកុសល មានវិបាកក្នុងលំដាប់ ។ ក្នុងគ្រាដែលអនុលោម-ចិត្ត ២ ដួង កើតក្នុងជវនវារៈ ដែលអរិយមគ្តកើតឡើង ចិត្តដួងទី ៣ ចាត់ជា គោត្រភូចិត្ត ដួងទី ៤ ចាត់ជាមគ្គចិត្ត តអំពីនោះទៅជាផលចិត្ត ៣ ដួង ។ តែក្នុង គ្រាដែលអនុលោមចិត្តកើតឡើង ៣ ដួង ចិត្តដួងទី ៤ ជាគោត្រភូចិត្តដួងទី ៥ ជាមគ្គចិត្ត បន្ទាប់ពីនោះទៅ ជាផលចិត្ត ២ ដួង ។ ចិត្តដួងទី ៤ ទី ៥ រមែង*

១-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក: លេខ ២៣ ទំព័រ ១៦២ ។

ប្រព្រឹត្តទៅដោយអំណាចអប្បនា ដោយប្រការដូច្នេះ តអំពីនោះប្រព្រឹត្តទៅមិនបានព្រោះជិតចំពោះកវង្គ្គចិត្ត ។ តែអាចារ្យពួកខ្លះពោលថា សូម្បីចិត្ត ដួងទី ៦ ក៏ជាអប្បនា ។ ពាក្យនោះលោកជំទាស់ទុកក្នុងអដ្ឋកថាហើយ ។ គប្បីជ្រាបផល-ចិត្តក្នុងមគ្គវិថី ដោយប្រការដូច្នេះ ។ តែផលចិត្តក្នុងកាលដទៃវមែងប្រព្រឹត្តទៅដោយផលសមាបត្តិ និងកើតឡើងដល់បុគ្គលអ្នកចេញចាកនិរោធសមាបត្តិ លោកសង្ក្រោះយកផលសមាបត្តិនោះឯង ។ ក៏ផលសមាបត្តិនេះ នោះពោលអំពីអត្ថជាវិបាកនៃលោកុត្តរកុសលចិត្ត ដែលមានព្រះនិព្វានជាអារម្មណ៍ គប្បីជ្រាបថា ជាអប្បនា ។

សួរថា ផលសមាបត្តិនោះ តើបុគ្គលណាចូលបាន បុគ្គលពួកណា ចូលមិនបាន? ឆ្លើយថា បុថុជ្ជនទាំងអស់ចូលមិនបាន ព្រោះមិនទាន់បានសម្រេច ។ ម្យ៉ាងទៀត ព្រះអរិយ:ថ្នាក់ក្រោមក៏ដូចគ្នា ចូលផលសមាបត្តិថ្នាក់ខ្ពស់មិនបាន សូម្បីព្រះអរិយ:ថ្នាក់ខ្ពស់ ក៏មិនចូលផលសមាបត្តិថ្នាក់ក្រោមដូចគ្នា ព្រោះលោកស្ងប់រម្ងាប់ដោយការចូលដល់ភាពជាបុគ្គលដទៃ ។ ព្រះអរិយ:នោះៗ រមែងចូលផលសមាបត្តិរបស់ខ្លួនៗប៉ុណ្ណោះ ។ តែអាចារ្យពួកខ្លះពោលថា ព្រះសោតាបន្ន-បុគ្គល និងព្រះសកទាគামីបុគ្គល រមែងមិនចូលផលសមាបត្តិ ព្រះអរិយបុគ្គលថ្នាក់ខ្ពស់ ២ ពួកប៉ុណ្ណោះ រមែងចូលបាន ព្រោះលោកធ្វើឱ្យបរិបូណ៌ក្នុងសមាធិ ។ ប្រការនោះមិនមែនជាហេតុ សូម្បីបុថុជ្ជនក៏ចូល លោកិយសមាធិដែលខ្លួនបានហើយ ។ ម្យ៉ាងទៀត នឹងចាំបាច់ពោលទៅថ្ងៃ ដោយការគិតដល់ហេតុក្នុងសេចក្ដីនេះ ។ សមដូចដែលលោកពោលទុកក្នុងបដិសម្ភិទាមគ្គថា **ककथा**

ឧស សង្ខារុបេក្ខា *វិបស្សនាវសេន* **ឧប្បជ្ជន្តិ** *សង្ខារុបេក្ខា ១០ កើតឡើងដោយអំណាចវិបស្សនាតើដូចម្តេច*[1] ? **កតមេ ឧស គោត្រភុឧម្មា** *វិបស្ស-* **នាវសេន ឧប្បជ្ជន្តិ** *គោត្រភូធម៌ ១០ ដូចម្តេចខ្លះ កើតឡើងដោយអំណាចវិបស្សនា*[2] *។ ក្នុងការដោះស្រាយបញ្ហាដូចពោលមកនេះ លោកពោលដល់ការចូលផលសមាបត្តិរបស់ព្រះអរិយៈទាំងនោះថា ដើម្បីប្រយោជន៍ដល់សោតាបត្តិផលសមាបត្តិ ដើម្បីប្រយោជន៍ដល់សកទាគামិផលសមាបត្តិ ។ ព្រោះដូច្នោះ ទើបព្រមព្រៀងគ្នាក្នុងសេចក្តីនេះថា ព្រះអរិយៈសូម្បីទាំងពួង រមែងចូលផលសមាបត្តិតាមដែលជារបស់ខ្លួន ។*

សួរថា ក៏ព្រោះហេតុអ្វី ព្រះអរិយៈទាំងនោះទើបចូលសមាបត្តិ? ឆ្លើយថា ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។ តួយ៉ាងដូចជាព្រះរាជាទាំងឡាយ សោយសុខក្នុងរាជសម្បត្តិ ទេវតាទាំងឡាយសោយសុខជាទិព្វយ៉ាងណា ព្រះអរិយៈទាំងឡាយក៏ដូច្នោះ រមែងកំណត់កាលថា នឹងសោយលោកុត្តរសុខ ទើបចូលផលសមាបត្តិក្នុងខណៈដែលត្រូវការ ។

សួរថា ក៏ផលសមាបត្តិនោះ ចូលយ៉ាងណា តាំងនៅយ៉ាងណា ចាកចេញយ៉ាងណា? ឆ្លើយថា មុនការចូលផលសមាបត្តិមានអាការ ២ យ៉ាង គឺការមិនធ្វើទុកក្នុងចិត្តនូវអារម្មណ៍ដទៃពីព្រះនិព្វាន ១ និងធ្វើទុកក្នុងចិត្តនូវព្រះនិព្វាន ១ ។ សមដូចដែលព្រះសារីបុត្តពោលនិងព្រះមហាកោដ្ឋិកៈថា **ទ្វេ ខោ អាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា សមាបត្តិយា សព្ព-**

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ១៦៥ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ១៥៣ ។

និមិត្តានញ្ច អមនសិការោ អនិមិត្តាយ ច ធាតុយា មនសិការោ ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិសមាបត្តិមានបច្ច័យ ២ គឺការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលប្រាសចាកអារម្មណ៍ ១[1] ។

ក៏ក្នុងទីនេះ មានលំដាប់ការចូលផលសមាបត្តិដូចតទៅនេះ ព្រះអរិយសាវកអ្នកត្រូវការផលសមាបត្តិទៅក្នុងទីកំបាំង ពួនសម្ងំនៅ គប្បីពិចារណាសង្ខារដោយឧទយព្វយញ្ញាណជាដើម ។ កាលលោកមាន វិបស្សនាញ្ញាណដោយលំដាប់ដែលប្រព្រឹត្តទៅយ៉ាងនេះ ចិត្តរមែងជាអប្បនាក្នុងនិរោធដោយអំណាចផលសមាបត្តិជាលំដាប់គោត្រភូញ្ញាណ មានសង្ខារជាអារម្មណ៍ ។ ក៏ផលចិត្តប៉ុណ្ណោះកើតដល់សេក្ខបុគ្គល មគ្គចិត្តមិនកើតសម្បីដល់ព្រះសេក្ខបុគ្គលទេ ព្រោះលោកបង្ហោនទៅក្នុងផលសមាបត្តិ ។ ចំណែកអាចារ្យពួកខ្លះពោលថា ព្រះសោតាបន្នគិតថា នឹងចូលផលសមាបត្តិរបស់ខ្លួនហើយចម្រើនវិបស្សនាជាព្រះសកទាគামី និងព្រះសកទាគামីគិតថា នឹងចូលផលសមាបត្តិរបស់ខ្លួនហើយចម្រើនវិបស្សនាបានជាអនាគামី ដូច្នេះ អាចារ្យទាំងនោះគប្បីពោលថា កាលបើសការៈដូច្នោះមាន ព្រះអនាគামីក៏នឹងជាព្រះអរហន្ត ព្រះអរហន្តក៏នឹងជាព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធក៏នឹងជាព្រះសម្ពុទ្ធដូច្នេះ ព្រោះដូច្នោះ វិបស្សនាទើបឱ្យសម្រេចប្រយោជន៍តាមសេចក្ដីត្រេកអរក្នុងចិត្តសន្ដាន តាម

១-សុត្តន្ដបិដក មជ្ឈិមនិកាយ មូលបណ្ណាសក: លេខ ២២ ទំព័រ ២៨០ ។

អធ្យាស្ស័យ ព្រោះហេតុនោះ សម្រាប់ព្រះសេក្ខបុគ្គលក៏កើតតែផលចិត្តប៉ុណ្ណោះ មគ្គចិត្តមិនកើតឡើងទេ ។ ប្រសិនបើលោកសម្រេចមគ្គចិត្ត ដែលសម្បយុត្ត ដោយបឋមឈាន សូម្បីផលចិត្តដែលសម្បយុត្តដោយបឋមឈានប៉ុណ្ណោះ ក៏កើតដល់លោក ប្រសិនបើលោកសម្រេចមគ្គចិត្ត ដែលសម្បយុត្តដោយឈានយ៉ាងណាមួយ បណ្តាឈានទាំងឡាយ មានទុតិយឈានជាដើម ផលចិត្តដែលសម្បយុត្តដោយឈានយ៉ាងណាមួយ បណ្តាឈានទាំងឡាយ មានទុតិយឈានជាដើមក៏រមែងកើត ។

សួរថា ព្រោះហេតុអ្វី ក្នុងទីនេះ គោត្រភូញាណទើបមិនមាននិព្វានជាអារម្មណ៍ ដូចញាណដែលជាបុរេចារិករបស់មគ្គញ្ញាណ? ឆ្លើយថា ព្រោះផលញាណមិនជានិយ្យានិកធម៌ ។ សេចក្តីពិត ធម៌ គឺអរិយមគ្គប៉ុណ្ណោះ ជានិយ្យានិកធម៌ ។ សមដូចពាក្យដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងទុកថា **កតមេ ធម្មា និយ្យានិកា ចត្តារោ មគ្គា អបរិយាបន្នា** *ពួកធម៌ ជានិយ្យានិក: (ធម៌នាំសត្វឱ្យរួចចាកវដ្ត:) តើដូចម្តេច[1] ? ព្រោះដូច្នោះ ញាណដែលជាអនន្តរប្បច្ច័យនៃសភាវធម៌ ដែលជានិយ្យានិក:ដោយចំណែកតែមួយ ដែលប្រព្រឹត្តទៅដោយការចេញចាកទាំងពីរចំណែក គប្បីចេញពីនិមិត្តបាន ព្រោះដូច្នោះ គោត្រភូញាណនោះ មានព្រះនិព្វានជាអារម្មណ៍ទើបត្រឹមត្រូវ ប៉ុន្តែថា ញាណដែលជាបុរេចារិករបស់ផលញ្ញាណ ដែលមានសភាវ:មិនចេញទៅ ព្រោះមិនជានិយ្យានិកធម៌ ជាហេតុដែលមិនកាត់ផ្តាច់កិលេស ដែលកំពុងប្រព្រឹត្តទៅ*

១-អភិធម្មបិដក ធម្មសង្គណី លេខ ៧៩ ទំព័រ ២២០ ។

ដោយវិបាករបស់អរិយមគ្គនោះ ព្រោះបានចម្រើនអរិយមគ្គទុក សូម្បីពេលខ្លះ និងមានព្រះនិព្វានជាអារម្មណ៍ ក៏មិនគួរ ព្រោះអនុលោមញ្ញាណ ក្នុងទាំង ២ ចំណែកមានអាការមិនស្មើគ្នាទេ ។ មែនពិត អនុលោមញ្ញាណក្នុងអរិយមគ្គវិថី ដែលដល់ការបរិបូណ៌យ៉ាងឧត្រិដ្ឋដោយលោកិយញ្ញាណ ដែលជាគ្រឿងទម្ងាយ គំនរលោក:ជាដើមដ៏សន្ធឹកសន្ធាប់ ដែលមិនធ្លាប់ចាក់ធ្ងុះពីមុនរហូតអនុលោម-មគ្គញ្ញាណកើតឡើង ចំណែកផលសមាបត្តិវិថី អនុលោមញ្ញាណនោះ។ មិនមានសេចក្ដីខ្ជល់ខ្ជាយក្នុងអរិយមគ្គវិថីនោះ ព្រោះកាត់កិលេសនោះ។ បានជាសមុច្ឆេទ កើតត្រឹមតែជាបរិកម្មនៃការព្រមព្រៀងដោយសុខ ដែលកើតពីផល-សមាបត្តិរបស់ព្រះអរិយ:ទាំងឡាយតែម្យ៉ាង ព្រោះដូច្នោះ អនុលោមញ្ញាណទាំងនោះ ទើបមិនមានការចេញចាកបច្ច័យណាមួយ ព្រោះញាណក្នុងទីបំផុតនៃអនុលោមញ្ញាណទាំងនោះ ដែលមានសង្ខារជានិមិត្ត គប្បីមានព្រះនិព្វានជាអារម្មណ៍អំពីការចេញចាកសមាបត្តិ ។ ក៏ព្រោះធ្វើពាក្យអធិប្បាយដូច្នេះថា កាលព្រះសេក្ខបុគ្គលពិចារណាសង្ខារទាំងឡាយ ដោយឧទយព្វយញ្ញាណជាដើម ដើម្បីនឹងប្រើផលសមាបត្តិរបស់ខ្លួន ផលចិត្តប៉ុណ្ណោះទើបកើតឡើង ក្នុងលំដាប់វិបស្សនាញ្ញាណមគ្គមិនកើត ។ ព្រោះដូច្នោះ សេចក្ដីដូចពោលមកនេះ ឯង ទើបជាការគ្រប់គ្រាន់ហើយ ។ គប្បីជ្រាប ការចូលផលសមាបត្តិ ដូចពោលមកយ៉ាងនេះមុន ។

ក៏ផលសមាបត្តិនោះ មានការតាំងនៅដោយអាការ ៣ យ៉ាង ព្រោះព្រះបាលីថា ម្នាលអាវុសោ បច្ច័យដែលឱ្យអនិមិត្តាចេតោវិមុត្តតាំងនៅបានយូរ

មាន ៣ ប្រការ គឺមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្ត ដាក់ចំពោះនិព្វានធាតុដែលប្រាសចាកអារម្មណ៍ ១ ការបានតាក់តែងទុកពីខាងដើម ១[1] ។ បណ្តាបច្ច័យ ៣ យ៉ាងនោះ បទថា **បុព្ពេ ច អកិសង្ខ្លោ** *បានដល់ ការកំណត់វេលាក្នុងកាលមុនចូលសមាបត្តិ ។ ក៏ផលសមាបត្តិនោះ មិនមានការចេញដរាបដែលនៅមិនដល់វេលានោះ ព្រោះលោកកំណត់ទុកថា នឹងចេញក្នុងវេលាឯណោះ ។*

ម្យ៉ាងទៀត ផលសមាបត្តិនោះ រមែងមានការចេញចាកដោយអាការ ២ យ៉ាង ព្រោះព្រះបាលីថា ម្នាលអាវុសោ បច្ច័យនៃការចេញអនិមិត្តាចេតោវិមុត្តិ មាន ២ ប្រការ គឺការយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការបានតាក់តែងទុកពីខាងដើម ១[2] ។ បណ្តាបច្ច័យ ២ យ៉ាងនោះ បទថា **សព្ពនិមិត្តានំ** *បានដល់ រូបនិមិត្ត វេទនានិមិត្ត សញ្ញានិមិត្ត សង្ខារនិមិត្ត និងវិញ្ញាណនិមិត្ត ។ ព្រះយោគាវចរ មិនធ្វើទុកក្នុងចិត្តរួមគ្នានូវនិមិត្តទាំងនោះ ក៏ពិតមែនហើយ ក៏ប៉ុន្តែថា លោកពោលទុកយ៉ាងនោះដោយការរួមនិមិត្តទាំងពួង ។ ព្រោះដូច្នោះ អារម្មណ៍របស់ភវង្គចិត្តយ៉ាងណា ការចេញអំពីផលសមាបត្តិ រមែងមានដោយមនសិការដល់អារម្មណ៍នោះ គប្បីជ្រាបការចេញអំពីផលសមាបត្តិនោះ ដោយប្រការយ៉ាងនេះ ។ ដូចព្រះធម្មសង្គាហាចារ្យពោលថា* **វិមុត្តិសុខំ បដិសំវេទី** *ដូច្នេះ សំដៅយកការចូល ការតាំងនៅ និងការចេញចាកផលសមាបត្តិ ដូច*

១-២-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក: លេខ ២២ ទំព័រ ២៨១ ។

ពោលមកនេះ នោះចាត់ជាអរហត្តផល ដែលសូប់រម្ងាប់សេចក្តីខ្ជល់ខ្ជាយ មានអមត:ជាអារម្មណ៍ ជាវន្តលោកាមិសសុខ[1] សូប់ជាសាមញ្ញផលដល់ខ្ពង់ខ្ពស់បំផុត ។ ព្រោះហេតុនោះ លោកទើបពោលថា បទថា **វិមុត្តិសុខំ បដិសំវេទី** បានដល់ គង់ប្រថាប់សោយវិមុត្តិសុខ គឺសុខដែលកើតអំពីផលសមាបត្តិ ។

ស័ព្ទថា **អថ** ជានិបាតចុះក្នុងអត្ថនៃអធិការ ។ ស័ព្ទថា **ខោ** ជានិបាតចុះក្នុងអត្ថនៃបទបូរណៈ (ធ្វើបទឱ្យពេញ) ។ ក្នុងស័ព្ទថា **អថ ខោ** នោះដោយស័ព្ទថា **អថ** ដែលមានអធិការជាអត្ថនេះ លោកសម្តែងដល់អធិការ (គឺការកិច្ច) យ៉ាងដទៃពីការសោយវិមុត្តិសុខ ។ សួរថា ការអធិការដទៃនោះ គឺអ្វី? ឆ្លើយថា គឺការយកចិត្តទុកដាក់ក្នុងបដិច្ចសមុប្បាទ ។ ម្យ៉ាងទៀត ស័ព្ទថា **អថ** ជានិបាតចុះក្នុងអត្ថនេះថា បច្ឆា (ខាងក្រោយ) ។ ព្រោះហេតុនោះ ស័ព្ទថា **អថ** នោះ ទើបបំភ្ជឹអត្ថដែលកំពុងពោលដោយន័យថា ការកន្ធងទៅ ៧ ថ្ងៃនោះ ។ បទថា **តស្ស សត្តាហស្ស** បានដល់ គង់ប្រថាប់អស់ ៧ ថ្ងៃ ។ បទថា **អច្ចយេន** ប្រែថា ប្រាសចាកទៅ ។ បទថា **តម្ហា សមាធិម្ហា** បានដល់ ពីសមាធិដែលសម្បយុត្តដោយអរហត្តផល ។ តែក្នុងទីនេះ អាចារ្យពួកខ្លះពោលឱ្យពិស្តារនូវសប្តាហ៍ទាំងនោះទៅទៀតថា គប្បីសម្តែង ៧ សប្តាហ៍រៀងទៅដោយលំដាប់ ។

១-**តណ្ហាសङ्खातं លោកាមិសं វដ្ដं ឆឌ្ឌិតं ឯតេនាតិ វន្តលោកាមិសं** *សេចក្តីសុខដែលទាត់ចោល គឺកាត់ចោលនូវលោកាមិស ពោលគឺ តណ្ហាដោយសការៈនោះ ព្រោះដូច្នោះ សេចក្តីសុខនោះ ឈ្មោះថា វន្តលោកាមិសសុខ ។ (បរមត្ថមញ្ជូសា មហាដីការ៉ាសុទ្ធិមគ្គ)*

ក៏យើងទាំងឡាយ នឹងពណ៌នាសង្ខាហ៍ទាំងនោះខាងមុខ ដោយវិធីសម្តែងដែលមិនខុសភ្ជាត់ ក្នុងឧទានបាលីនេះ ដោយខន្ធកបាឋ: ។ បទថា **រត្តិយា** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថដែលសម្ព័ន្ធនឹងចំណែកផ្សេងៗ (របស់រាត្រី) ។ បទថា **បឋមំ** ជាទុតិយាវិភត្តិចុះក្នុងអត្ថថា **អច្ចន្តសំយោគ:** ប្រែថា រហូតដល់អស់ ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់ ប្រកបដោយការធ្វើទុកក្នុងចិត្តនោះឯង រហូតដល់អស់បឋមយាមសូម្បីទាំងអស់របស់រាត្រីនោះ ។

បទថា **បដិច្ចសមុប្បាទំ** បានដល់ បច្ចយធម៌ ។ មែនពិត បច្ចយធម៌ មានអវិជ្ជាជាដើម ឈ្មោះថា បដិច្ចសមុប្បាទ ។ បើមានពាក្យសួរថា ប្រការនេះ នឹងគប្បីដឹងបានយ៉ាងណា? ឆ្លើយថា ដឹងបានព្រោះព្រះតម្រាស់របស់ព្រះដ៏-មានព្រះភាគ ។ មែនពិត ព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ជាតិនេះទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃជរាមរណៈ ។ ល ។ អវិជ្ជានេះឯង ជាហេតុជានិទាន ជាសមុទ័យ ជាបច្ច័យនៃសង្ខារទាំងឡាយ[1] គឺអវិជ្ជា រួមសេចក្តីថា បច្ចយធម៌ មានអវិជ្ជាជាដើម ជាតួហេតុ ដូចយ៉ាងដែលលោកពោលទុកថា បច្ច័យ ១២ គឺបដិច្ចសមុប្បាទ ១២ ។

ក្នុងសេចក្តីនោះ មានវចនត្ថ:ដូចតទៅនេះ ឈ្មោះថា **បដិច្ចសមុប្បាទ** ព្រោះអាស្រ័យ គឺប្រាជ្ញាដោយមុខចំពោះគ្នានិងគ្នា មិនបដិសេធសេចក្តីព្រម-ព្រៀងគ្នារបស់ហេតុ ឱ្យបច្ច័យដែលជួយសង្គ្រោះគ្នាកើតឡើង ។ ម្យ៉ាងទៀត ការអាស្រ័យបច្ច័យដែលជាបច្ច័យដែលត្រូវអាស្រ័យគ្នា ប្រព្រឹត្តទៅកើតការ

១-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ១២១ ។

សម្ព័ន្ធគ្នា ដោយមិនរៀរបច្ច័យនោះ ឈ្មោះថា បដិច្ចសមុប្បាទ ។ ក៏ក្នុងពាក្យថា បដិច្ចសមុប្បាទនេះ បានដល់ ហេតុដែលប្រកបដោយសេចក្តីអាចក្នុងការឱ្យកើតផល ដែលនឹងដឹងបានដោយពាក្យ ដែលមានការកើតឡើងព្រមជាហេតុជិត មិនគប្បីជ្រាបត្រឹមតែអាស្រ័យគ្នាកើតឡើង ។

ម្យ៉ាងទៀត បច្ច័យ ឈ្មោះថា **បដិច្ចៈ** នឹងព្រោះជាទីអាស្រ័យចំពោះរបស់បណ្ឌិត ។ ឈ្មោះថា **សមុប្បាទ** ព្រោះឱ្យកើតឡើងដោយប្រពៃដោយខ្លួនឯង ។ បដិច្ចៈ និងសមុប្បាទនោះ ជាបដិច្ចសមុប្បាទ គប្បីជ្រាបសេចក្តីក្នុងបដិច្ចសមុប្បាទនេះ ដោយប្រការដូចពោលមកនេះ ។

បទថា **អនុលោមំ** បានដល់ បច្ចយាការមានអវិជ្ជាជាដើម ដែលលោកពោលទុកដោយន័យមានជាអាទិ៍ថា **អវិជ្ជាបច្ចយា សង្ខារា** ព្រោះអវិជ្ជាជាបច្ច័យ ទើបកើតមានសង្ខារ លោកហៅថា អនុលោម ព្រោះធ្វើកិច្ចដែលខ្លួនគួរធ្វើ ។ ម្យ៉ាងទៀត ឈ្មោះថា អនុលោម ព្រោះលោកពោលតាំងពីដើមដរាបដល់ទីបំផុត ឬព្រោះអនុលោមតាមការប្រព្រឹត្តទៅនូវអនុលោមនោះ ។ បទថា **សាធុកំ មនសាការិ** បានដល់ ធ្វើទុកក្នុងចិត្តដោយគោរព ។ អធិប្បាយថា បច្ចយធម៌ណាៗ ជាបច្ច័យដល់បច្ចយុប្បន្នធម៌ណាៗ ដោយសេចក្តីជាបច្ច័យមានហេតុប្បច្ច័យជាដើម ដោយប្រការណាៗ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម៌ទាំងអស់នោះៗ ទុកក្នុងព្រះទ័យមិនឱ្យវិបរិត មិនឱ្យថយចុះដោយទ្រង់ពិចារណា មិនឱ្យនៅសល់ ។ ក៏ដើម្បីនឹងសម្តែងប្រការដែលព្រះដ៏មានព្រះភាគទ្រង់ធ្វើទុក

ក្នុងព្រះទ័យនូវបដិច្ចសមុប្បាទ ជាអនុលោមដោយសង្ខេបមុន ទើបពោលពាក្យ ជាអាទ៍ថា **ឥតិ ឥមស្មឺ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ឥតិ** *ស្មើនឹង* **ឯវํ** *អធិប្បាយថា ដោយប្រការនេះ ។ បទថា* **ឥមស្មឺ សតិ ឥទំ ហោតិ** *សេចក្តីថា កាលបច្ច័យមានអវិជ្ជាជាដើមនេះមានផល មានសង្ខារជាដើមនេះក៏មាន ។ បទថា* **ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** *សេចក្តីថា ព្រោះបច្ច័យមានអវិជ្ជាជាដើមនេះក៏រមែងកើត ផលមានសង្ខារជាដើមនេះ រមែងកើត ។ បទថា* **ឥមស្មឺ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** *សេចក្តីថា ព្រោះត្រាស់សេចក្តីមិនមានសង្ខារជាដើមក្នុងកាលអវិជ្ជាជាដើមមិនមាន ទុកក្នុងសូត្រទី ២ និងត្រាស់សេចក្តីរលត់សង្ខារជាដើម ក្នុងកាលអវិជ្ជាជាដើមរលត់ ទុកក្នុងសូត្រទី ៣ ឈ្មោះថា ជាការសម្តែងការកំណត់លក្ខណៈនៃបច្ច័យខាងដើមនេះ ។ កាលបច្ច័យ មានអវិជ្ជាជាដើមនេះមាននៅ គឺមិនមែនមិនមានទេ ។ ព្រោះអវិជ្ជាជាដើមនេះកើតមាន គឺមិនមែនមិនកើតទេ ។ ព្រោះរលត់ទ្ចុះឯង មិនមែនមិនរលត់ទេ ។ ព្រោះហេតុដូច្នេះ គប្បីឃើញថា លក្ខណៈនោះជាការកំណត់ ដែលធ្លាក់ចុះក្នុងខាង គឺព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងទីនេះ សម្រាប់បដិច្ចសមុប្បាទ ។ ម្យ៉ាងទៀត បទថា* **និរោធោ** *បានដល់ ការមិនកើតឡើង គឺការមិនប្រព្រឹត្តទៅតទៅទៀត ព្រោះសម្រេចសេចក្តីប្រាសចាកបច្ច័យមានអវិជ្ជាជាដើម ។ សមដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកមានជាអាទ៍ថា* **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** *ការរលត់ទៅនៃសង្ខារ ព្រោះរលត់អវិជ្ជាឥតមានសេសសល់ ។*

ដោយពាក្យថា **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** នោះ លោកសម្តែងសេចក្តីនេះទុកថា ការមិនរលត់ ឈ្មោះថា ការកើត និងការកើតនោះ ក្នុងទីនេះ លោកហៅថា **អត្ថិភាវោ** (សេចក្តីមាន) ដូច្នេះក៏មាន ។ មែនពិត លក្ខណៈថា **ឥមស្មឹ សតិ ឥទំ ហោតិ** នេះឯង កាលពោលអំពីបរិយាយដទៃ បទដំបូងជាការបែកចាកពីរបទចុង ដែលពោលថា **ឥមស្ស ឧប្ប៉ាទា ឥទំ ឧប្ជ្ជតិ** ។ ព្រោះដូច្នោះ ពាក្យដែលលោកពោលថា **ឥមស្មឹ សតិ** សំដៅដល់ការៈដែលទ្រង់មិនគង់នៅប៉ុណ្ណោះ ។ បើតាមពិតទៅ ព្រះអង្គទ្រង់ជ្រាបនូវការមិនរលត់ដោយមគ្គ ។ ក៏ព្រោះហេតុដែលលោកពោលដល់និទ្ទេសនៃលក្ខណៈដែលលើកឡើងសម្តែងជា ២ យ៉ាង គឺ **ឥមស្មឹ អសតិ ឥទំ ន ហោតិ** (និង) **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** ដូច្នេះ ទើបពោលចំពោះសេចក្តីរលត់ដោយន័យមានជាអាទិ៍ថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** ព្រោះហេតុនោះ ទើបលោកសម្តែងថា សូម្បីការមិនមាន ក៏គឺការរលត់នោះឯង ការដែលខុសចាកពីការមិនមាន ក៏គឺការមិនរលត់ ។ ព្រោះហេតុនោះ លោកទើបសម្តែងការកើតឱ្យបែកដោយភាពមានពោលគឺ ការមិនរលត់ ។ ព្រោះហេតុនោះ ក្នុងទីនេះលោកទើបមិនប្រាថ្នាយកថា ការកើតឡើងត្រឹមតែភាពមានប៉ុណ្ណោះទេ បើតាមពិត លោកធ្វើឱ្យច្បាស់ដល់អត្ថនេះថា ការមានគឺការមិនរលត់ ។ កាលបើដូច្នោះ ការពោលដល់លក្ខណៈទាំង ២ នោះ គប្បីជ្រាបថា មានប្រយោជន៍ ព្រោះជាលក្ខណៈដែលនឹងគប្បីឱ្យបែក ដោយសេចក្តីបែកនៃគ្នានិងគ្នា ។

សួរថា ក៏ឈ្មោះថា អនិរោធ: ដែលហៅថា អត្ថិការ: និងថា ឧប្បាទ: នេះ គឺអ្វី? ឆ្លើយថា គឺការ:ដែលនៅមិនលះ ១ ការ:ដែលគួរឱ្យកើតផល ដោយមិនលះការ:ដែលគួរដល់ផលដែលមិនទាន់កើត ១ ការ:ដែលអកុសលធម៌ដែលនឹងគប្បីលះនោះ គឺអរិយមគ្គមិនទាន់បានដកចេញ ១ ការ:នៃកុសលធម៌ និងអព្យាកតធម៌ ដែលមិនត្រូវលះសំយោជន:របស់អ្នកមានអាសវ:មិនទាន់អស់ទៅ ទូវមិនឱ្យអស់ទៅ ១ ។ មែនពិត ការប្រព្រឹត្តទៅនៃខន្ធព្រមដោយសំយោជន:ទាំងអស់ ឈ្មោះថា បដិច្ចសមុប្បាទ ព្រោះការ:មានអនុស័យ មិនទាន់ដកចេញ ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកមានជាអាទិ៍ថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលដែលអវិជ្ជាណាបិទបាំងទុកផង ដែលតណ្ហាណាប្រកបទុកផង ទើបកាយនេះកើតឡើង បុគ្គលពាលមិនបានលះបង់អវិជ្ជានោះមិនទាន់អស់តណ្ហានោះផង ដំណើរនោះតើព្រោះហេតុដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលពាលមិនប្រព្រឹត្តមគ្គព្រហ្មចរិយ: ដើម្បីការអស់នៃទុក្ខដោយប្រពៃទេ ព្រោះហេតុនោះ បុគ្គលពាល លុះបែកធ្លាយរាងកាយទៅហើយ ក៏ចូលទៅចាប់បដិសន្ធិកាយ (ផ្សេងទៀត) កាលបុគ្គលនោះ ចូលទៅចាប់បដិសន្ធិកាយ (ផ្សេងទៀត) រមែងមិនរួចស្រឡះចាកជាតិ ជរា មរណ:[1] ។

ក៏ព្រោះអវិជ្ជារបស់បុគ្គលអ្នកអស់សំយោជន: សង្ខារ ទើបមិនមានតណ្ហានិងឧបាទានក៏មិនមាន ឧបាទាននិងកពក៏មិនមានដែរ ព្រោះហេតុនោះ ការកាត់ផ្តាច់នូវវដ្ត:នឹងប្រាកដ ។ ព្រោះហេតុនោះនុ៎ះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ពាក្យមានជាអាទិ៍ថា

១-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣១ ទំព័រ ៥២ ។

ម្នាលផគ្គុន ឯការរលត់នៃផស្ស: ព្រោះការរលត់ឥតមានសេសសល់នៃ ផស្សាយតន:ទាំង ៦ ការរលត់នៃវេទនា ព្រោះការរលត់នៃផស្ស:[១] ។

មែនពិត តាំងពីសម្រេចព្រះអរហត្តមគ្គដរាបដល់បរិនិព្វាន អាយតន: ៦ ជាដើម តែងប្រព្រឹត្តទៅ ។ បើតាមពិត លោកពោលដល់និរោធ ព្រោះការ: ដែលមិនមានការ:ដែលគួរពោលស័ព្ទនិរោធ ការអស់ទៅនៃសំយោជន: ។ ម្យ៉ាងទៀត កម្មសូម្បីបុគ្គលធ្វើទុកយូរហើយចាត់ថា រមែងជាកម្មដែលគួរឱ្យផល ព្រោះផលមិនទាន់កើត និងព្រោះមិនទាន់លះអាហារ គឺមិនមែនផលដែល កើតហើយ ទាំងមានអាហារមិនទាន់លះផង ។ ការ:ជាបច្ច័យឱ្យកើតផល មាន អវិជ្ជានិងសង្ខារជាដើម ជាបច្ច័យគួរដល់ផលដោយន័យដូចពោលហើយនុ៎ះឯង គប្បីជ្រាបថា **អនិរោធ** (មិនរលត់) ។ មែនពិត ក៏ព្រោះបច្ច័យដែលឱ្យកើតផល យ៉ាងនោះមិនទាន់រលត់ រៀរហេតុណាចេញ ផលមិនកើត ហេតុនោះ មាន អតីតហេតុជាដើម ដែលលោកពោលដោយពាក្យថា **ឥមស្មឹ សតិ** នេះ ។ ក៏ ព្រោះហេតុនោះឯង ការកើតឡើងនៃបច្ច័យ ដែលដល់ការមិនប្រព្រឹត្តទៅរបស់ អ្នកមិនទាន់នៅក្នុងព្រហ្មចរិយ: លោកពោលថា **ឥមស្ស ឧប្ប៉ាឌា** ដោយការ មិនត្រឡប់មកដោយមិនប៉ះពាល់ដល់ប្រភេទរបស់កាល ។ ម្យ៉ាងទៀត ក្នុងសេចក្តី ដល់ព្រមរបស់បច្ច័យ ដែលនៅសល់ការ:ដែលបច្ច័យសូម្បី នឹងមិនមានក៏ដូច មាន នឹងពោលទៅថ្មីដល់ហេតុរបស់បច្ច័យ ដែលមានឱ្យកើតផលនោះ លោក

១-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣១ ទំព័រ ៣០ ។

ហៅថា **ឥមស្ស ឧប្ផាឌា** ។ *ពិតយ៉ាងនោះ ផលរមែងកើតអំពីហេតុនោះ ព្រោះហេតុនោះ ទើបឈ្មោះថា* ***ឥទវត្ត*** *បានដល់ ហេតុសូម្បីមិនមាននៅ ក៏ឈ្មោះ ថា* ***ឥទវត្ត*** *ព្រោះដូច្នោះ ការៈដែលជា* ***ឥទវត្ត*** *គប្បីជ្រាបថា* ***ឧប្ផាទៈ*** ។

បណ្តាបទទាំងនោះ ដោយបទថា **សតិ** *នេះ ព្រះថេរៈកាលនឹងពោល ដល់ការៈដែលជាបច្ច័យដោយត្រឹមតែការដែលមាននៅ ទើបសម្តែងដល់ភាព នៃបដិច្ចសមុប្ផាទមិនខ្វល់ខ្វាយ ។ ដោយបទថា* **ឧប្ផាឌា** *នេះ ព្រះថេរៈ កាល នឹងសម្តែងការកើតឡើងជាធម្មតា និងការៈដែលមិនប្រព្រឹត្តទៅគ្រប់កាល និង ការៈដែលជ្រាជ្ញាចំពោះការកើតផល ទើបសម្តែងដល់ការៈនៃបដិច្ចសមុប្ផាទ ជា* **អនិច្ចតា** ។ *ក៏ព្រះថេរៈសម្តែងដល់បដិច្ចសមុប្ផាទ មានហេតុ មានសមុទយៈ មានជាតិ និងមានដែនកើត ដែលសម្រេចដោយសត្តមីវិភត្តិ និងបញ្ចមីវិភត្តិដែល ប្រើក្នុងអត្ថរបស់ហេតុដោយពាក្យថា* **សតិ ន អសតិ ឧប្ផាឌា ន និរោធា** ។ *លោកកំណត់ការៈនៃផល ដែលមានដោយមិនវៀរចាកក្នុងហេតុ ព្រោះការៈ នៃសត្តមីវិភត្តិចុះក្នុងអត្ថនៃហេតុ គប្បីជ្រាបការប្រព្រឹត្តទៅក្នុងហេតុនោះ ដូច ពាក្យថា កាលបើព្រះមហាក្សត្រ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់អ្នក ក្សត់ទ្រព្យដូច្នេះ សេចក្តីទ័លក្រក៏មានច្រើនឡើង[1] និងពាក្យថា កាលបើស្រូវ សម្ផូរ កិក្ខារកបានដោយស្រួល ។ សូម្បីបញ្ចមីវិភត្តិក៏ចុះក្នុងអត្ថនៃហេតុ ឈ្មោះ ថា ប្រព្រឹត្តទៅបានក្នុងដែនកើត និងក្នុងសេចក្តីប្រក្រតីរបស់ផល ដូចពាក្យថា កលលរូបមក កើតជាអម្ពុទរូប តពីអម្ពុទរូបមក កើតជាបេសិរូប និងពាក្យថា*

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៨ ទំព័រ ១៣៧ ។

ទន្ទេគង្គាកើតពីភ្នំហេមពាន្ត ស្រះកើតពីទន្ទេសរកូ ។ ក៏ក្នុងភាវៈមាននៃវិជ្ជាជាដើមមាន លោកទើបកំណត់ភាវៈនៃផល មានសង្ខារជាដើម ព្រោះភាវៈដែលមិនរៀរចាកអវិជ្ជាជាដើមនោះ និងផល មានសង្ខារជាដើមកើតពីបច្ច័យ មានអវិជ្ជាជាដើម និងដែលបច្ច័យមានអវិជ្ជាជាដើមក៏កើតឡើង ព្រោះដូច្នោះ បច្ច័យមានអវិជ្ជាជាដើមនោះទើបជាដែនកើត និងជាប្រក្រតីរបស់ផល មានសង្ខារជាដើមនោះ ព្រោះដូច្នោះ ដើម្បីនឹងសម្តែងអត្ថនោះ លោកទើបធ្វើនិទ្ទេសសត្តមីវិភត្តិ និងបញ្ចមីវិភត្តិ ក្នុងអត្ថនៃហេតុថា **ឥមស្មឹ សតិ ឥមស្ស ឧប្បាទា** ព្រោះវត្ថុនេះ មាន ព្រោះវត្ថុនេះកើត ។

ក៏ព្រោះក្នុងសេចក្តីនេះ បដិច្ចសមុប្បាទដែលលើកឡើងសម្តែងដោយសង្ខេបថា **ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** មាននិទ្ទេសជាដើមថា **អវិជ្ជាបច្ចយា សង្ខារា** ដូច្នោះ ភាវៈដែលមាននៅនិង ការកើតឡើងតាមដែលពោលហើយ រមែងឱ្យដឹងបានថា ជាបច្ច័យនៃបច្ចុប្បន្ន-ធម៌នោះៗ ។ មែនពិត ភាវៈដែលជាបច្ច័យយ៉ាងដទៃ រមែងមិនមាន ព្រោះចុះ អត្ថិភាវៈ និងឧប្បាទៈពោលគឺ សេចក្តីមិនរលត់ សេចក្តីមិនវិលត្រឡប់ជាសភាព ឬសេចក្តីតាំងនៅរបស់សមុទយៈ (ការកើត) ដែលលោកពោលទុកដោយពាក្យដែលកំណត់ពិតប្រាកដនៅខាងក្នុងថា **សតិឯវ ជាសតិ ឧប្បជ្ជា ឯវ ន និរោជ្ជា** ដូច្នេះ ព្រោះដូច្នោះ គប្បីជ្រាបថា ភាវៈដែលមាននៅនិងឧប្បាទៈ ការកើតឡើងដូចពោលហើយ ជាតួបច្ច័យ ។ សូម្បីបច្ច័យ ២៤ មានហេតុប្បច្ច័យជាដើមដែលមកក្នុងបដ្ឋានបករណ៍នោះ គប្បីជ្រាបថា បច្ច័យពិសេសនៃបច្ច័យនោះនុ៎ះឯង ។

ព្រោះហេតុដូច្នោះ ដើម្បីនឹងសម្តែងប្រការដែលព្រះអង្គទ្រង់មនសិការដល់អនុលោមបដិច្ចសមុប្បាទដោយពិស្តារ ទើបត្រាស់ពាក្យមាន ជាអាទ៍ថា **យនិ្ចំ អវិជ្ជាបច្ចយា សង្ខារា** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យនិ្ចំ** *ជានិបាត បទថា* **យនិ្ចំ** *នោះមានអត្ថថា* **យោ អយំ** *។ ក្នុងបទថា* **អវិជ្ជាបច្ចយា** *ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា* ***អវិជ្ជា*** *ព្រោះប្រសព្វវត្ថុដែលមិនគួរប្រសព្វ មានកាយទុច្ចរិតជាដើម ។ ឈ្មោះថា* ***អវិជ្ជា*** *ព្រោះមិនប្រសព្វវត្ថុដែលគួរប្រសព្វ មានកាយសុចរិតជាដើម ។ ឈ្មោះថា* ***អវិជ្ជា*** *ព្រោះញ៉ាំងសភាវៈនៃធម៌ដែលមិនវិបរិត មិនឱ្យដឹងច្បាស់ ឈ្មោះថា* ***អវិជ្ជា*** *ព្រោះញ៉ាំងសត្វឱ្យត្រាច់ទៅក្នុងភពជាដើម ក្នុងសង្សារដែលវៀរចាកទីបំផុត ។ ឈ្មោះថា* ***អវិជ្ជា*** *ព្រោះត្រាច់ទៅក្នុងវត្ថុដែលមិនមាន មិនត្រាច់ទៅក្នុងវត្ថុដែលមាន ។ ម្យ៉ាងទៀត ឈ្មោះថា* ***អវិជ្ជា*** *ព្រោះជាបដិបក្ខចំពោះវិជ្ជា ។ អវិជ្ជានោះគប្បីជ្រាបថា មាន ៤ យ៉ាង ដោយន័យមានជាអាទ៍ថា* **ទុក្ខេ អញ្ញាណំ** *សេចក្តីមិនដឹងទុក្ខ ។ ឈ្មោះថា* ***បច្ចយ*** *ព្រោះអាស្រ័យទៅ គឺកើតឡើងនិងប្រព្រឹត្តទៅមិនវៀរផល ។ ម្យ៉ាងទៀត ធម៌ដែលមានការគាំទ្រជាអត្ត ឈ្មោះថា* ***បច្ចយ*** *។ អវិជ្ជាផង បច្ចយផង ជាអវិជ្ជានិងបច្ចយ ព្រោះហេតុនោះ ទើបឈ្មោះថា មានអវិជ្ជាជាបច្ចយ ។ ឈ្មោះថា* ***សង្ខារ*** *ព្រោះតាក់តែង ។ បានដល់ កុសលចេតនានិងអកុសលចេតនាជាលោកិយ: កុសលចេតនា និងអកុសលចេតនានោះ គប្បីជ្រាបថាមាន ៣ យ៉ាង គឺ* ***បុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អានេញ្ជាភិសង្ខារ ១*** *។ ឈ្មោះថា វិញ្ញាណ ព្រោះដឹងច្បាស់ ។ វិញ្ញាណនោះមាន ៣២ (គឺអហេតុកវិបាក ១៥ មហាវិបាកចិត្ត ៨ មហគ្គតវិបាក ៩) ដោយអំណាច*

វិបាកវិញ្ញាណចំណែកលោកិយ: ។

*ឈ្មោះថា **នាម** ព្រោះបង្ហោនទៅ បានដល់ នាមខន្ធ ៣ មានវេទនា ជាដើម ។ ឈ្មោះថា **រូប** ព្រោះអត្ថថា រលាយទៅ បានដល់ ភូតរូប ៤ និងឧបាទាយរូប ២៤ មានចក្ខុបសាទរូបជាដើម ។ ឈ្មោះថា **អាយតន:** ព្រោះជាទី-ត និងនាំសត្វទៅកាន់សង្សារទុក្ខ ។ ឈ្មោះថា **ផស្ស:** ព្រោះពាល់ត្រូវ ។ ឈ្មោះថា **វេទនា** ព្រោះសោយ (អារម្មណ៍) ។ សូម្បីទាំងពីរនោះ ពោលអំពីទ្វារមាន ៦ ពោលអំពីវិបាកមាន ៣៦ ។ ឈ្មោះថា **តណ្ហា** ព្រោះតក់ស្ទុត ។ តណ្ហានោះ ដោយសង្ខេប មាន ៣ មានកាមតណ្ហាជាដើម និងដោយពិស្តារមាន ១០៨ ។ ឈ្មោះថា **ឧបាទាន** ព្រោះប្រកាន់មាំ ឧបាទានៈ មាន ៤ យ៉ាង មានកាមុបាទានជាដើម ។ ឈ្មោះថា **ភព** ព្រោះជាទីកើត ឬញ្ជាំងសត្វឱ្យកើត ។ ភពនោះ មាន ២ គឺកម្មភព និងឧបត្ដិ-ភព ។ ការកើត ឈ្មោះថា **ជាតិ** ។ ការចាស់គ្រាំគ្រា ឈ្មោះថា **ជរា** ។ ឈ្មោះថា **មរណ:** ព្រោះជាហេតុស្ងាប់នៃសត្ត ។ សេចក្ដីសោកសៅ ឈ្មោះថា **សោក:** ។ សេចក្ដីខ្សឹកខ្ជួល ឈ្មោះថា **បរិទេវ:** ។ ឈ្មោះថា **ទុក្ខ** ព្រោះទ្រាំបានដោយលំបាក ម្យ៉ាងទៀត ឈ្មោះថា ទុក្ខ ព្រោះមាន ២ ខណ: គឺទុក្ខក្នុងខណ:កើត និងទុក្ខក្នុងខណ:តាំងនៅ ។ ភាវ:នៃសេចក្ដីខូចចិត្ត ឈ្មោះថា **ទោមនស្ស** ។ សេចក្ដីចង្អៀតចង្អ ល់ចិត្ដក៏ក្រៃលែង ឈ្មោះថា **ឧបាយាស:** ។ បទថា **សម្ភវន្ដि** ប្រែថា រមែងកើត ។ សេចក្ដីពិត មិនមែនប្រកបដោយបទ មានសោក:ជាដើមតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិតគប្បីប្រកបបទថា **សម្ភវន្ដि** គ្រប់ៗបទ ។ ក៏កាលបើដូច្នេះ រមែងជាការសម្ដែងការកំណត់បច្ចយធម៌ និងបច្ចុប្បន្នធម៌ ដោយពាក្យថា **អវិជ្ជាបច្ចយា សង្ខារា សម្ភវន្ដि** ។ ក្នុងបទទាំងពួង ក៏ន័យនេះ ។*

បណ្តាធម៌ទាំងនោះ ***អវិជ្ជា*** *មានសេចក្តីមិនដឹងជាលក្ខណៈ មានសេចក្តីវង្វេងជាកិច្ច មានការបិទបាំងជាអាការប្រាកដ មានអាសវៈជាហេតុជិត ។ សង្ខារមានការតាក់តែងជាលក្ខណៈ មានការប្រមូលមកជាកិច្ច មានការចាត់-ចែងជាអាការប្រាកដ មានអវិជ្ជាជាហេតុជិត ។* ***វិញ្ញាណ*** *មានការដឹងច្បាស់ជាលក្ខណៈ មានភាពជាប្រធានជាកិច្ច មានបដិសន្ធិជាអាការប្រាកដ មានសង្ខារជាហេតុជិតឬមានវត្ថុនិងអារម្មណ៍ជាហេតុជិត ។* ***នាម*** *មានការបង្ហាញទៅជាលក្ខណៈ មានសម្បយោគជាកិច្ច មានការមិនបែកពីគ្នាជាអាការ ប្រាកដមានវិញ្ញាណជាហេតុជិត ។* ***រូប*** *មានការរលាយទៅជាលក្ខណៈ មានការមិនដឹងអារម្មណ៍ជាកិច្ច មានការៈជាសម្បយោគជាអាការប្រាកដ មានវិញ្ញាណជាហេតុជិត ។* ***សឡាយតនៈ*** *មានការចំពោះជាលក្ខណៈ មានការឃើញជាដើមជាកិច្ច មានការៈជាវត្ថុនិងទ្វារជាអាការប្រាកដ មាននាមរូបជាហេតុជិត ។* ***ផស្សៈ*** *មានការពាល់ត្រូវជាលក្ខណៈ មានការប៉ះខ្ទប់ជាកិច្ច មានការជួបប្រសព្វជាអាការប្រាកដ មានសឡាយតនៈជាហេតុជិត ។* ***វេទនា*** *មានការសោយអារម្មណ៍ជាលក្ខណៈ មានការបរិភោគរសនៃអារម្មណ៍ជាកិច្ច មានសុខ និងទុក្ខជាអាការប្រាកដ មានផស្សៈជាហេតុជិត ។* ***តណ្ហា*** *មានសេចក្តីជាតួហេតុ ជាលក្ខណៈ មានសេចក្តីក្ងៀតក្ងៀនជាកិច្ច មានសេចក្តីមិនឆ្អែតជាអាការប្រាកដ មានវេទនាជាហេតុជិត ។* ***ឧបាទាន*** *មានការប្រកាន់មាំជាលក្ខណៈ មានការមិនបញ្ចេញជាក់ជាកិច្ច មានទិដ្ឋិ គឺសេចក្តីប្រកាន់មាំដោយអំណាចតណ្ហា ជាអាការប្រាកដ មានតណ្ហាជាហេតុជិត ។* ***ភព*** *មានកម្ម និងផលនៃកម្មជាលក្ខណៈ:មានការកើត និងការឱ្យកើតជាកិច្ច មានកុសល អកុសល និងអព្យាក្រិតជាអាការប្រាកដ មានឧបាទានជាហេតុជិត ។* ***ជាតិ*** *មានការកើត មុនក្នុងភពនោះៗជាលក្ខណៈ:*

មានការពង្រីកចេញទៅជាកិច្ច មានការកើត ក្នុងភពនេះ ពីអតីតភពជាអាការ ប្រាកដ ឬក៏មានភាពវិចិត្រនៃទុក្ខជាអាការប្រាកដ ។ **ជរា** មានសេចក្តីជោរនៃ ខន្ធជាលក្ខណៈ មានការនាំទៅរកសេចក្តីស្វាប់ជាកិច្ច មានការធ្វើភាពជាកំណ្ងោះ ក្រមុំឱ្យវិនាសជាអាការប្រាកដ ។ **មរណៈ** មានចុតិជាលក្ខណៈ មានការរបូត ប្រាសចាកជាកិច្ច មានការនៅប្រាសចាកគតិជាអាការប្រាកដ ។ **សោកៈ** មាន សេចក្តីឆេះក្នុងខាងក្នុងជាលក្ខណៈ មានសេចក្តីទុក្ខក្នុងចិត្តជាកិច្ច មានសេចក្តី សោកសៅដល់ជាអាការប្រាកដ ។ **បរិទេវៈ** មានសេចក្តីរអ៊ូរទាំជាលក្ខណៈ មាន ការនិយាយដល់គុណ និងទោសជាកិច្ច មានសេចក្តីតក់ស្ទុតជាអាការប្រាកដ ។ **ទុក្ខ** មានការបៀតបៀនកាយជាលក្ខណៈ មានការធ្វើឱ្យខូចចិត្តដល់បុគ្គលអ្នក មានបញ្ញាខ្សោយជាកិច្ច មានអាពាធផ្ទូវកាយជាអាការប្រាកដ ។ **ទោមនស្ស** មាន ការបៀតបៀនចិត្តជាលក្ខណៈ មានសេចក្តីចង្អៀតចង្អល់ចិត្តជាកិច្ច មានព្យាធិ ផ្ទូវចិត្តជាអាការប្រាកដ ។ **ឧបាយាសៈ** មានសេចក្តីទុក្ខព្រួយក្នុងចិត្តជាលក្ខណៈ មានការរួញរាដកចិត្តចេញជាកិច្ច មានការប្រាសចាកសេចក្តីរីករាយជាអាការ ប្រាកដ ។ បច្ចយធម៌ មានអវិជ្ជាជាដើមទាំងនោះ គប្បីជ្រាប សូម្បីដោយលក្ខណៈ ជាដើមដោយប្រការយ៉ាងនេះឯង ។ ក្នុងទីនេះ មានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណោះ ចំណែកសេចក្តីពិស្តារ អ្នកប្រាជ្ញវិនិច្ឆ័យដែលសម្ជរដោយប្រការទាំងពួង គប្បី មើលក្នុងអដ្ឋកថា រ៉ាកង្គ ឈ្មោះ **សម្មោហវិនោទនី** ។

បទថា **ឯវํ** ជាបទសម្តែងខ្ចៃដល់ន័យដែលបានសម្តែងមកហើយ ។ ដោយ បទថា **ឯវํ** នោះ លោកសម្តែងអំពីហេតុ មានអវិជ្ជាជាដើមនោះឯង មិនមែន

សម្តែងដោយហេតុមាននិមិត្តរបស់តស្សរជនជាដើម ។ បទថា **ឯតស្ស** បានដល់តាមដែលពោលហើយ ។ បទថា **កេវលស្ស** បានដល់ មិនច្រឡូកច្របល់ គឺទាំងអស់ ។ បទថា **ទុក្ខក្ខន្ធស្ស** បានដល់ ប្រជុំទុក្ខ មិនមែនសត្វ មិនមែនជីវៈ ទាំងមិនមែនជាស្រស់ស្អាត និងសុខជាដើមទេ ។ បទថា **សមុទយោ ហោតិ** បានដល់ កើត គឺកើតព្រម ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ការដឹងច្បាស់នូវសេចក្តីនោះដែលពោលទុកថា កងទុក្ខមានសង្ខារជាដើម រមែងកើតដោយអវិជ្ជាជាដើម ដោយអាការទាំងពួង ។ បទថា **តាយំ វេលាយំ** បានដល់ ក្នុងវេលាដែលដឹងច្បាស់នូវអត្ថនោះ ។ បទថា **ឥមំ ឧទានំ ឧទានេសិ** សេចក្តីថា បន្លឺនូវឧទាននេះ ដែលសម្តែងអានុភាពនៃការដឹងហេតុ និងធម៌ ដែលកើតពីហេតុក្នុងកាលស្គាល់ផលនោះ ដែលជាសមុដ្ឋាននៃញាណ ដែលសម្បយុត្តដោយសោមនស្សមានជាអាទិ៍ថា **យទា ហវេ ចាតុភវន្តិ** អធិប្បាយថា បន្លឺនូវព្រះវាចាជាទីគាប់ព្រះទ័យ ។

ឧទាននោះមានអធិប្បាយដូច្នេះ បទថា **យទា** ប្រែថា ក្នុងកាលណា ។ ស័ព្ទថា **ហវេ** ជានិបាត ចុះក្នុងអត្ថនេះថា **ព្យត្តំ** ជាក់ច្បាស់ ។ តែអាចារ្យពួកខ្លះពោលអធិប្បាយថា ស័ព្ទថា **ហវេ** ប្រែថា ក្នុងសង្គ្រាម គឺការប្រយុទ្ធ ។ ក៏លោកអាចារ្យទាំងនោះមានសេចក្តីដែលលោកសំដៅដល់យកថា ក្នុងសម័យច្បាំងនឹងកិលេសមារ ដោយព្រះបាលីថា **យោធេថ មារំ បញ្ញាវុធេន** បុគ្គលគប្បីច្បាំង

នូវមារដោយអាវុធ គឺបញ្ញា[១] ។ បទថា **ចាតុកវណ្ណិ** ប្រែថា កើតឡើង ។ បទថា **ធម្មា** បានដល់ ពោធិបក្ខិយធម៌ ដែលឱ្យសម្រេចការចាក់ធ្លុះបច្ចយាការដោយអនុលោម ។ ម្យ៉ាងទៀត បទថា **ចាតុកវណ្ណិ** បានដល់ ប្រកាស គឺធ្វើឱ្យជាក់ច្បាស់ គឺប្រាកដដោយការត្រាស់ដឹង ។ បទថា **ធម្មា** បានដល់ ធម៌ គឺអរិយសច្ច: ៤ ។ បទថា **អាតាប** ហៅថា សេចក្តីព្យាយាម ព្រោះអត្ថថា ដុតកម្តៅនូវកិលេស ។ បទថា **អាតាបិនោ** បានដល់ មានសេចក្តីព្យាយាម គឺសម្មប្បធាន ។ បទថា **ឈាយតោ** បានដល់ សម្ងឹងដោយអារម្មណូបនិជ្ឌានៈ និងលក្ខណូបនិជ្ឌាន ។ បទថា **ព្រាហ្មណស្ស** បានដល់ ព្រះខីណាស្រពអ្នកមានបាបបន្សាត់ហើយ ។ បទថា **អថស្ស ភិន្នា រជយន្តិ សព្វា** សេចក្តីថា គ្រាដែលព្រាហ្មណ៍នោះមានធម៌ប្រាកដយ៉ាងនេះហើយ សេចក្តីសង្ស័យក្នុងបច្ចយាការ ដែលត្រាស់ទុកដោយន័យមានជាអាទិ៍ថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងពាល់ត្រូវព្រះដ៏មានព្រះភាគត្រាស់ថា ប្រស្នានេះមិនត្រឹមត្រូវទេ[២] ដោយន័យមានអាទិ៍ថា បពិត្រព្រះអង្គដ៏ចម្រើន ជាជរានិងមរណៈ:តើដូចម្តេចហ្ន៎ មួយទៀត ជរានិងមរណៈ:នេះឯងជារបស់នរណា ។ ព្រះដ៏មានព្រះភាគត្រាស់ថា ប្រស្នានេះមិនត្រឹមត្រូវទេ[៣] ។ និងសេចក្តី សង្ស័យ ១៦ ប្រការ ដែលមកដោយន័យមានជាអាទិ៍ថា **អហោសឺ ជុ ខ្វាហំ អតីតមទ្ធានំ** អាត្មាអញបានកើតហើយក្នុង អតីត-

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ២៩ ។

២-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣១ ទំព័រ ២៧ ។

៣-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣១ ទំព័រ ១៣៣ ។

កាលដែលឬហ្ន៎[1] ក្នុងអតីតកាល យើងបានមានហើយឬហ្ន៎ ព្រោះមិនទាន់ចាក់ធ្លុះបច្ចយាការនុ៎ះឯង ។ សេចក្តីសង្ស័យទាំងអស់នោះ រមែងបាត់ទៅ ប្រាសចាកទៅ រលត់ទៅ ។ ព្រោះហេតុណា ព្រោះដឹងទូទៅនូវធម៌ព្រមទាំងហេតុ អធិប្បាយថា ដឹងច្បាស់ ដឹងទូទៅ គឺចាក់ធ្លុះនូវធម៌ គឺកងទុក្ខទាំងអស់ មានសង្ខារជាដើមនេះ ដែលដល់ព្រមដោយហេតុ មានអវិជ្ជាជាដើម ។

ក៏ពោធិបក្ខិយធម៌ ឬចតុសច្ចធម៌ប្រាកដកើតឡើង គឺជាក់ច្បាស់ដល់ព្រាហ្មណ៍នោះ ។ ក្នុងកាលណា ក្នុងកាលវិបស្សនាញាណនិងមគ្គញ្ញាណកើតឡើង ។ បណ្តាញាណ ២ យ៉ាងនោះ គប្បីជ្រាបថា វិបស្សនាញាណកើតមុន ។ ធម៌ទាំងឡាយមានសតិជាដើម ដែលសម្បយុត្តដោយវិបស្សនាញាណ និងវិបស្សនាញាណ កាលលះសុភសញ្ញាជាដើម ដោយអំណាចតទង្គបហានក្នុងអារម្មណ៍របស់ខ្លួន ទើបកើតឡើងជាចំណែកៗ ដោយអនុបស្សនាមានកាយានុ-បស្សនាជាដើម ។ ក៏ក្នុងខណៈមគ្គកើតឡើង ធម៌ទាំងនោះ កាលប្រទាញយកព្រះនិព្វាន និងធម៌ដែលជាបដិបក្ខដោយសមុច្ឆេទបហាន កើតឡើងតែម្តងប៉ុណ្ណោះ ដោយអំណាចនៃការចាក់ធ្លុះមិនវង្វេងក្នុងអរិយសច្ចទាំង ៤ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបថា ពោធិបក្ខិយធម៌ប្រាកដ ដោយអត្ថថា កើតឡើងដោយប្រការដូច្នេះមុន ។

ក៏គប្បីជ្រាបថា អរិយសច្ចធម៌ជាចំណែកនៃលោកិយៈប្រាកដដោយការធ្វើវិបស្សនាឱ្យជាអារម្មណ៍ ក្នុងខណៈវិបស្សនា គប្បីជ្រាបថា អរិយសច្ចធម៌ជាចំណែកនៃលោកុត្តរៈប្រាកដ ដោយការៈដែលបង្ហោនទៅក្នុងលោកុត្តរធម៌នោះ គប្បីជ្រាបថា និរោធសច្ចៈ ប្រាកដដោយការត្រាស់ដឹងអារម្មណ៍ក្នុងខណៈមគ្គ

១-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣១ ទំព័រ ៥៧ ។

និងគប្បីជ្រាបថា ទាំងអស់ ប្រាកដដោយអត្ថថា ជាក់ច្បាស់ ប្រាកដច្បាស់ ដោយអំណាចនៃការត្រាស់ដឹងកិច្ច ។

សូម្បីកាលធម៌ទាំងអស់ ប្រាកដដល់ព្រះញាណរបស់ព្រះអង្គដោយអាការទាំងពួង ព្រះដ៏មានព្រះភាគទ្រង់ពិចារណាបច្ចយាការនោះ ព្រោះបច្ចយាការជាសភាពល្អិតជ្រាលជ្រៅ និងឃើញបានដោយលំបាក ជាហេតុទ្រង់ធ្វើសេចក្តីតាំងចិត្តមាំក្នុងវិបស្សនាដោយបដិច្ចសមុប្បាទជាប្រមុខ ទ្រង់កើតសោមនស្សយ៉ាងខ្លាំងក្លា ទើបទ្រង់បន្លឺនូវឧទានក្នុងសេចក្តីនេះ ដែលសម្តែងដល់អានុភាពនៃការត្រាស់ដឹងបច្ចយាការនោះរបស់ព្រះអង្គ ព្រមដោយជាបច្ច័យកាត់បដិបក្ខធម៌បានដាច់ខាត ។

ព្រះបាលីថា **អយម្បិ ឧជានោ វុត្តោ ភគវតា ឥតិ មេ សុតំ** នេះ ប្រាកដក្នុងគម្ពីរត្រង់កន្លែងខ្លះ ។ បណ្តាបទទាំងនោះ **បិ**-ស័ព្ទ ក្នុងបទថា **អយម្បិ** ជាសម្បិណ្ឌនត្ថៈ ដូចក្នុងប្រយោគថា **ឥទម្បិ ពុទ្ធេ រតនំ បណីតំ អយម្បិ ចារជិកោ ហោតិ** សូម្បីនេះជារតនៈដែលប្រណីតក្នុងព្រះពុទ្ធ ភិក្ខុសូម្បីនេះ ជាបារាជិក ។ ព្រោះហេតុនោះ **បិ**-ស័ព្ទនោះ រមែងប្រមូលពាក្យមុនៗ មក ។ ***វុត្តៈ*** ស័ព្ទនេះក្នុងបទថា **វុត្តោ** ប្រាកដក្នុងពាក្យមានជាអាទិ៍ថា ***កេសោហារណៈ វបនៈ វាបសមីករណៈ ជីវិតវុត្តិ បមុត្តភាវៈ បាវចនភាវេនបវត្តនៈ អជ្ឈេសនៈ*** និង***កថនៈ*** ។ ពិតយ៉ាងនោះ ***វុត្តៈ*** ស័ព្ទនោះ មកក្នុង ***កេសោហារណៈ*** (ការកោរសក់) ក្នុងប្រយោគមានជាអាទិ៍ថា

មានមាណពកំលោះម្នាក់ឈ្មោះកាបដិកៈមានក្បាលកោរ[១] ។ មកក្នុង ***វបនៈ*** (ការព្រោះពូជ) ក្នុងប្រយោគមានជាអាទិ៍ថា

កាហេ តស្ស បជាយន្តិ ខេត្តេ វុត្តំ វិរូហតិ

១-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ លេខ ២៥ ទំព័រ ២២៦ ។

វុត្ថានំ ផលមស្នាតិ យោ មិត្តានំ ន ទុព្ភតិ ។

បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ គោទាំងឡាយរបស់បុគ្គលនោះ សម្រាលកូនដោយស្រួល ពូជដែលបុគ្គលនោះសាបព្រោះក្នុងស្រែរមែងដុះដាល បុគ្គលនោះ រមែងបរិភោគផ្លែនៃពូជទាំងឡាយដែលខ្លួនសាបព្រោះហើយ[១] ។

មកក្នុង ***រាបសមីករណៈ*** *(ការធ្វើពូជដែលព្រោះឱ្យស្មើគ្នា) ដោយប្រើរនាស់ជាដើម ក្នុងប្រយោគមានជាអាទិ៍ថា* **ឆោ ច ខោ បដិវុត្តំ** *ស្រែគេមិនទាន់ព្រោះទេ[២] ។ មកក្នុង* ***ជីវិតវុត្តិ*** *(ការចិញ្ចឹមជីវិត) ក្នុងប្រយោគមានជាអាទិ៍ថា* **បន្ន-លោមោ បរេ ជុត្តោ មិតភូតេន ចេតសា វិហាមិ** *ខ្ញុំជាមនុស្សសម្ងួបបុសតតព្រឹតព្ជួចរោម ចិញ្ចឹមជីវិតដោយបច្ច័យដែលអ្នកដទៃឱ្យ នៅដោយមានចិត្តដូចជាពួកម្រឹគ[៣] ។ មកក្នុង* ***បមុត្តការៈ*** *(សេចក្ដីរបួតចាកពីទង) ក្នុងប្រយោគមានជាអាទិ៍ថា* **បណ្ណុបលាសោ ពន្ធនា បវុត្តោ អកញ្ចោ ហរិតត្ថាយ** *ធម្មតាស្លឹកឈើទុំដែលជ្រុះចាកទងហើយ មិនអាចទៅត្រឡប់ជាមានពណ៌ខៀវវិញបានទេ[៤] ។ មកក្នុង ជាវចនការេនបវត្តនៈ (សេចក្ដីប្រព្រឹត្តទៅដោយជ្រាប់ពោលគ្នាមក) ក្នុងប្រយោគមានជាអាទិ៍ថា* **តីតំ បវុត្តំ សមិហិតំ** *(លំអានៃមន្ត បុរាណនេះ) ដែលពួកឥសីណាបានច្រៀង (ស្វាធ្យាយ) មកហើយ បានសូត្រមកហើយ បានសន្សំមកច្រើនហើយ[៥]។ មកក្នុង* ***អជ្ឌេសនៈ*** *(សេចក្ដីគោរពអញ្ជើញ) ក្នុងប្រយោគមានជាអាទិ៍ថា* **វុត្តោ ករណ្ដោ វុត្តោ ចាវយនោ** *សេចក្ដីគោរព*

១-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៦២ ទំព័រ ៤ ។

២-វិនយបិដក មហាវិភង្គ លេខ ២ ទំព័រ ១០២ ។

៣-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ១៥៧ និងវិនយបិដក ចុល្លវគ្គ លេខ ១១ ទំព័រ ១៣ ។

៤-វិនយបិដក មហាវិភង្គ លេខ ១ ទំព័រ ១៥៤ ។

៥-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ២៥០ ។

អញ្ជើញចាកគុណ សេចក្តីគោរពអញ្ជើញចាកសេចក្តីសាបសូន្យ ។ មកក្នុង **កថនៃ** *(ការពោល) ក្នុងប្រយោគមានជាអាទិ៍ថា នេះជាព្រះពុទ្ធដីកា ដែលព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកធម៌ តថាគតជាមរតក កុំយកអាមិសជាមរតកឡើយ[1] ។ សូម្បីក្នុងទីនេះ គប្បីជ្រាបថា* **រ៉ុត្ត**-*ស័ព្ទប្រើក្នុងការពោលប៉ុណ្ណោះ ។ អធិប្បាយថា សូម្បីឧទានជាកាសិត គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយព្រះតម្រាស់នេះ ។* **ឥតិ**-*ស័ព្ទនេះ ស្មើនិង* **ឯវំ** *។ សេចក្តីរបស់បទទាំងពីរថា* **មេ សុតំ** *បានពោលទុកក្នុងអដ្ឋកថា* **និទាន** *ដោយអាការទាំងពួងនោះឯង ។ មែនពិត ក្នុងកាលមុនសេចក្តីរបស់បទទាំងពីរថា* **ឯវម្មេ សុតំ** *បានពោលទុកដោយអំណាចពាក្យចាប់ផ្តើម ក្នុងទីនេះ ពោលទៀតថា* **ឥតិ មេ សុតំ** *ដោយអំណាចនៃនិគមន: ពាក្យចុងមិនមែនការពោលដដែលដល់អត្ថដែលពោលហើយនោះឯង ឈ្មោះថា* **និគមន:** *។ ការលើកសេចក្តីនៃ***ឥតិ**-*ស័ព្ទដូចក្នុងពាក្យថា* **ឯវម្មេ សុតំ** *នេះ ព្រោះ* **ឥតិ**-*ស័ព្ទ មានអត្ថស្មើនិង***ឯវ**-*ស័ព្ទ និងការប្រកបសេចក្តីរបស់***ឥតិ**-*ស័ព្ទ ប្រកាសទុកហើយក្នុងអដ្ឋកថា ឥត្ថិវុត្តក:នោះឯង ព្រោះហេតុនោះ គប្បីជ្រាបដោយន័យតាមដែលពោលហើយក្នុងអដ្ឋកថានោះ ដូច្នេះឯង ។*

បរមត្ថទីបនិយា ខុទ្ទកនិកាយដ្ឋកថាយ
ឧទានសំវណ្ណនាបឋមពោធិសុត្តវណ្ណនា និដ្ឋិតា។

ចប់ អដ្ឋកថាបឋមពោធិសូត្រ នៃឧទានសំវណ្ណនា

ក្នុងអដ្ឋកថា ខុទ្ទកនិកាយ ឈ្មោះថា បរមត្ថទីបនី ។

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក: លេខ ២០ ទំព័រ ២៤ ។

២. ទុតិយពោធិសុត្តវណ្ណនា

អដ្ឋកថាទុតិយពោធិសូត្រ

ទុតិយពោធិសូត្រទី ២ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **បដិលោមំ** *សេចក្តីថា បច្ចយាការ[1]មានអវិជ្ជាជាដើម ដែលលោកពោលទុកដោយន័យមានជាអាទិ៍ថា ព្រោះអវិជ្ជារលត់ សង្ខារទើបរលត់ ដូច្នេះ កាលរលត់ដែលមិនត្រឡប់កើត លោកហៅថា* ***បដិលោម*** *ព្រោះមិនធ្វើកិច្ចដែលខ្ជិនគួរធ្វើ ។ ម្យ៉ាងទៀត ឈ្មោះថា* ***បដិលោម*** *ព្រោះបញ្ញាសការប្រព្រឹត្តទៅ ក៏ព្រោះមិនបានពោលដល់តាំងពីទីបំផុត ឬពាក់កណ្តាលដរាបដល់ខាងដើម ក្នុងទីនេះ សេចក្តីដែលបច្ចយាការជាបដិលោម ដោយសេចក្តីដទៃពីនេះ ទើបមិនត្រូវ ។ ម្យ៉ាងទៀត បទថា* **បដិលោម** *ជាការសម្តែងការៈនបុំសកលិង្គ ដូចក្នុងប្រយោគថា* **វិសមំ ចន្ទិមសុរិយា បរិវត្តំ** *ព្រះចន្ទ និងព្រះអាទិត្យវិលទៅមិនស្មើ ។ បទថា* **ឥមស្មឹ អសតិ ឥទំ ន ហោតិ** *សេចក្តីថា កាលបច្ច័យមានអវិជ្ជាជាដើមនេះមិនមាន គឺត្រូវមគ្គលះចេញហើយ ផលមានសង្ខារជាដើមនេះក៏មិនមាន គឺមិនប្រព្រឹត្តទៅ ។ បទថា* **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** *សេចក្តីថា ព្រោះបច្ច័យមានអវិជ្ជាជាដើមនេះរលត់ គឺព្រោះមគ្គឱ្យដល់ភាពជាធម្មជាតិមិនកើតឡើង ផលមានសង្ខារជាដើមនេះទើបរលត់ គឺមិនប្រព្រឹត្តទៅ ។ សូម្បីក្នុងសេចក្តីនេះគប្បីជ្រាបថា លោកសម្តែងលក្ខណៈដែលកំណត់ចុះក្នុងខាងក្នុងមានជាអាទិ៍ថា កាលបច្ច័យមានអវិជ្ជាជាដើមនេះមិនមាន គឺមិនកើតឡើងព្រោះបច្ច័យ*

---

*១-*បច្ចយាការន្តិ អវិជ្ជាទិបច្ចយានំ ឧប្បាទការំ *អាការដែលកើតឡើងនូវបច្ច័យទាំងឡាយមានអវិជ្ជាជាដើម ឈ្មោះថា បច្ចយាការ ។ (យោជនា)*

មានអវិជ្ជានេះរលត់ គឺមិនកើត ដូចលោកសម្តែងលក្ខណៈដែលកំណត់ចុះក្នុងខាងក្នុងមានជាអាទិ៍ថា កាលបច្ច័យមានអវិជ្ជាជាដើមនេះមាន គឺមិនមែនមិនមានទេ ព្រោះបច្ច័យមានអវិជ្ជាជាដើមនេះនៅកើតឡើង គឺមិនរលត់ដូចក្នុងពាក្យនេះថា កាលបច្ច័យមានអវិជ្ជាជាដើមនេះមាន ផលមានសង្ខារជាដើមនេះក៏មាន ព្រោះបច្ច័យមានអវិជ្ជាជាដើមនេះកើត ផលមានសង្ខារជាដើមនេះក៏កើត ។ ក្នុងទីនេះ ពាក្យដែលនៅសល់ដែលនឹងគប្បីពោល គប្បីជ្រាបតាមន័យដែលពោលក្នុងអដ្ឋកថាបឋមពោធិសូត្រ ។

ព្រះដ៏មានព្រះភាគ ត្រាស្ទង់សម្តែងប្រការ ដែលព្រះអង្គទ្រង់ធ្វើបដិច្ចសមុប្បាទ ដោយបដិលោមទុកក្នុងព្រះទ័យដូចពណ៌នាមកដូច្នេះ ដោយសង្ខេបហើយ ឥឡូវនេះដើម្បីនឹងសម្តែងដោយពិស្តារ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **អវិជ្ជានិរោធា សង្ខារនិរោធោ** ព្រោះអវិជ្ជារលត់ សង្ខារទើបរលត់ ។ បណ្តាបទទាំងនោះ បទថា **អវិជ្ជានិរោធា** សេចក្តីថា ព្រោះអវិជ្ជារលត់ដាច់ខាត ដោយអរិយមគ្គ អធិប្បាយថា ព្រោះអវិជ្ជាត្រូវអរហត្តមគ្គដកឡើង បានដាច់ខាត ដោយអំណាចការប្រហារអនុស័យ ។ សូម្បីបើអវិជ្ជាកាលត្រូវមគ្គខាងក្រោមលះបាន រមែងលះបានចំពោះដោយអំណាចដកឡើងបាន ដោយចំណែកតែមួយ ក៏ពិតមែន ទោះជាយ៉ាងនោះក៏ដោយ អវិជ្ជានូវតែលះមិនឱ្យអស់ ។ ម្យ៉ាងទៀត អវិជ្ជាដែលនាំសត្វទៅកាន់អបាយត្រូវបឋមមគ្គលះបានហើយ ។ អវិជ្ជាដែលជាបច្ច័យឱ្យកើតក្នុងលោកនេះម្តងទៀត និងក្នុងភូមិដែលមិនមែនជាភូមិរបស់ព្រះអរិយៈ

ទាំងអស់ រមែងលះដោយមគ្គទី ២ និងមគ្គទី ៣ រមែងលះបានតាមលំដាប់ មិនមែនលះកិលេសក្រៅនេះបានទេ ។ មែនពិត អវិជ្ជានោះ អរហត្តមគ្គប៉ុណ្ណោះ លះបានដោយមិនឱ្យសេសសល់ ។ បទថា **សङ्खारनिरोधो** សេចក្តីថា រមែងរលត់ដោយសង្ខារមិនកើតឡើង ។ ដើម្បីសម្តែងថា ក៏ព្រោះសង្ខាររលត់ទៅយ៉ាងនេះ វិញ្ញាណទើបរលត់ និងព្រោះវិញ្ញាណជាដើមរលត់ នាមរូបជាដើមក៏រលត់ដូចគ្នា លោកទើបពោលពាក្យមានជាអាទិ៍ថា ព្រោះសង្ខាររលត់វិញ្ញាណទើបរលត់ ហើយពោលថា កងទុក្ខទាំងមូលនេះ រមែងរលត់ទៅដោយប្រការដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យដែលគួរពោលមានន័យដូចពោលហើយក្នុងកាលមុននោះឯង ។

ម្យ៉ាងទៀត ក្នុងទីនេះ ព្រោះអវិជ្ជារលត់ សង្ខារទើបរលត់ ព្រោះសង្ខាររលត់ វិញ្ញាណទើបរលត់ ព្រោះដូច្នោះ ទើបជាការពោលកងទុក្ខទាំងមូលរលត់ទៅដោយមិនឱ្យសេសសល់ សូម្បីដោយហេតុត្រឹមតែប៉ុណ្ណោះ ក៏ពិតមែនហើយ ក៏ប៉ុន្តែថា ដើម្បីសម្តែងសេចក្តីនេះក្នុងអនុលោមថា បច្ចុប្បន្នធម៌ណាៗ មិនទាន់រលត់ទៅ គឺនៅប្រព្រឹត្តទៅ ព្រោះបច្ច័យធម៌ណាៗ មានលោកទើបពោលថា **អវិជ្ជាបច្ចយា សङ्खारा ។បេ។ សមុទយো ហোতি** ដូច្នេះ យ៉ាងណា ដើម្បីសម្តែងថា បច្ចុប្បន្នធម៌នោះៗ រមែងរលត់ គឺមិនប្រព្រឹត្តទៅ ព្រោះបច្ចយធម៌នោះៗ មិនមាន ព្រោះជាបដិបក្ខចំពោះបច្ចុប្បន្នធម៌នោះ លោកទើបពោលទុកក្នុងទីនេះថា **អវិជ្ជានិរោធা សङ्खारনিরোধো សङ্খারনিরোধা វিঞ্ঞাণনিরোধো វিঞ্ঞাণনিরোধা នামরূপনিরোধো ។បេ។ ទុক্খক্খন্ধস্স নিরোধো হোতি** ដូច្នេះ ។ តែមិនបានពោលដើម្បីសម្តែងការរលត់កងទុក្ខ ពាក់បញ្ចូល

ក្នុងកាល ៣ ដូចក្នុងអនុលោមទេ ។ គប្បីជ្រាបសេចក្តីប្លែកគ្នា សូម្បីយ៉ាងនេះ ថា មែនពិត កាលមិនមានអរិយមគ្គភាវនា នៃកងទុក្ខដែលជាអនាគត លោកប្រាថ្នាយកការរលត់កងទុក្ខដែលគួរនឹងកើតដោយអរិយមគ្គភាវនា ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ដឹងអត្ថនេះដែលលោកពោលថា កងទុក្ខ មានសង្ខារជាដើម រមែងរលត់ដោយអំណាចអវិជ្ជារលត់ជាដើម ដោយអាការទាំងពួង ។ បទថា **ឥមំ ឧទានំ ឧទានេសិ** សេចក្តីថា ទ្រង់បន្ទឺនូវឧទាននេះ ដែលសម្តែងអានុភាពនៃការយល់ដឹងនូវការអស់ទៅនៃបច្ច័យ មានអវិជ្ជាជាដើម ដែលប្រកាសទុកយ៉ាងនេះថា ព្រោះអវិជ្ជារលត់ សង្ខារទើបរលត់ក្នុងកាលដឹងច្បាស់អត្ថនោះ ។

ក្នុងសេចក្តីនោះ មានសេចក្តីសង្ខេបដូច្នេះ ព្រោះហេតុដែលព្រះអង្គទ្រង់ដឹង ដឹងទូទៅដល់ គឺការចាក់ធ្លុះនូវការអស់ទៅ ពោលគឺសេចក្តីរលត់ មិនកើតឡើងនៃបច្ច័យធម៌មានអវិជ្ជាជាដើមដូច្នោះ ពោធិបក្ខិយធម៌ ឬចតុសច្ចធម៌ មានប្រការដូចពោលហើយ ប្រាកដកើត កើតឡើង ឬជាក់ច្បាស់ដល់ព្រាហ្មណ៍នោះ អ្នកមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស អ្នកមានឈាន ដោយន័យដូចដែលពោលហើយ ក៏យ៉ាងនោះដែរ ។ ត្រានោះ សេចក្តីសង្ស័យមានប្រភេទដូចពោលហើយក្នុងកាលមុនគប្បីកើតឡើង ព្រោះមិនដឹងច្បាស់សេចក្តីរលត់បច្ច័យដោយប្រពៃ ធម៌ទាំងអស់នោះរមែងបាត់ទៅ គឺរលត់ទៅ ។ ពាក្យដែលនៅសល់មានន័យដូចពោលហើយក្នុងកាលមុនទុំ:ឯង ។

ឧតិយសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ២

សម្រាប់ជាធម្មទាន

៣. តតិយពោធិសុត្តវណ្ណនា

អដ្ឋកថាតតិយពោធិសូត្រ

តតិយពោធិសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **អនុលោមបដិលោមំ** *បានដល់ អនុលោម និងបដិលោម អធិប្បាយថា ដោយអំណាចអនុលោមតាមដែលពោលហើយ និងដោយអំណាចបដិលោម ។ មានពាក្យសួរថា ក៏លោកពោលការប្រព្រឹត្តទៅរបស់មនសិការក្នុងបដិច្ចសមុប្បាទ ទុកក្នុងសូត្រទាំងពីរដោយអំណាចអនុលោម និងបដិលោម សម្បីក្នុងកាលមុនមិនមែនឬ ព្រោះហេតុអ្វី ក្នុងទីនេះលោក ទើបពោលការប្រព្រឹត្តទៅរបស់មនសិការ ដោយអំណាចនៃសូត្រទាំងពីរនោះ ទៀត ឆ្វើយថា ព្រោះប្រកាសមនសិការទុកក្នុងបដិច្ចសមុប្បាទដល់ភ្លេចទី ៣ ដោយអំណាចសូត្រទាំងពីរនោះ ។ សួរថា ក៏លោកប្រកាសមនសិការទុកដោយ សូត្រទាំងពីរយ៉ាងណា ព្រោះអ្នកណាៗ មិនអាចប្រកាសមនសិការបដិច្ចសមុប្បាទទាំងអនុលោម និងបដិលោម មិនមុន មិនក្រោយ ឆ្វើយថា ប្រការនោះមិនគប្បីឃើញយ៉ាងនោះថា ព្រះដ៏មានព្រះភាគទ្រង់មនសិការដល់អនុលោម និងបដិលោមទាំងពីរនោះរួមគ្នា ដោយពិត ព្រះដ៏មានព្រះភាគទ្រង់មនសិការជាភ្លេច ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់មនសិការដល់បដិច្ចសមុប្បាទ ដោយអនុលោមមុន ហើយទ្រង់បន្ទឹនូវឧទានលើកដំបូងដ៏សមគួរដល់មនសិការនោះ ។ សម្បីលើកទីពីរ ព្រះដ៏មានព្រះភាគទ្រង់ធ្វើមនសិការដល់បដិច្ចសមុប្បាទនោះ ដោយបដិ-លោម ហើយទ្រង់បន្ទឹនូវឧទានដ៏សមគួរដល់មនសិការនោះដូចគ្នា ។ ចំណែកលើកទីបី ព្រះដ៏មានព្រះភាគទ្រង់ធ្វើមនសិការដល់អនុលោមបដិលោម ដោយ*

អំណាចមនសិការជាអនុលោមដោយកាល ជាបដិលោមដោយកាល ។ ព្រោះ-ហេតុនោះ លោកទើបពោលថា បទថា **អនុលោមបដិលោមំ** បានដល់ អនុលោម និងបដិលោម ដោយអំណាចអនុលោម និងបដិលោមតាមដែលពោលហើយ ។ ដោយពាក្យនេះ ជាការប្រកាសសេចក្តីដែលមនសិការរហ័ស-រហួនមានកម្លាំង និងមានភាពជំនាញ ។ តែក្នុងទីនេះ គប្បីជ្រាបការវិភាគនៃអនុលោម និងបដិលោមទាំងនោះ ដោយអំណាចចំណែកខាងដើមដែលប្រព្រឹត្ត ទៅយ៉ាងនេះថា តថាគតធ្វើមនសិការដល់អនុលោមមនសិការ ដល់បដិលោមមនសិការដល់អនុលោមបដិលោម ។

បណ្តាគាថាទាំងនោះ បទថា **អវិជ្ជាយត្វេវ** កាត់បទថា **អវិជ្ជាយ តុ ឯវ** ។ បទថា **អសេសវិរាគនិរោធា** បានដល់ ព្រោះរលត់ដោយមិនសេសសល់ ដោយមគ្គ ពោលគឺ វិរាគធម៌ អធិប្បាយថា ជាការលះមិនឱ្យកើតឡើងមិនឱ្យសេសសល់ដោយអរហត្តមគ្គ ។ បទថា **សङ्खารនិរោធោ** បានដល់ រលត់សង្ខារទាំងពួង ដោយមិនឱ្យកើតឡើងមិនឱ្យសេសសល់ ។ មែនពិត សង្ខារពួកខ្លះ រលត់ដោយមគ្គ ៣ ខាងក្រោម សង្ខារពួកខ្លះទៀតមិនទាន់រលត់ ព្រោះអវិជ្ជារលត់មិនទាន់អស់ ។ តែសង្ខារពួកខ្លះនឹងមិនរលត់ក៏មិនមែន ព្រោះអរហត្តមគ្គ រលត់អវិជ្ជាមិនឱ្យសេសសល់ ។

បទថា **ឯតមត្ថं វិនិត្វា** សេចក្តីថា ដឹងច្បាស់អត្ថនេះដោយអាការៈទាំង-ពួង ដែលលោកពោលទុកដោយអំណាចអវិជ្ជាជាដើមថា កងទុក្ខមានសង្ខារជាដើមកើត ព្រោះអវិជ្ជាជាដើមកើត កងទុក្ខមានសង្ខារជាដើមរលត់ ព្រោះអវិជ្ជា

ជាដើមរលត់ ។ បទថា **ឥមំ ឧទានំ ឧទានេសិ** សេចក្តីថា ព្រះដ៏មានព្រះភាគ ទ្រង់បន្ទឺនូវឧទាននេះ មានប្រការដូចពោលហើយដែលសម្តែងអានុភាពអរិយ-មគ្គនោះ ដែលជាហេតុឱ្យដឹងច្បាស់ដល់អត្ត ពោលគឺ ការកើត និងការរលត់ កងទុក្ខ ដោយអំណាចកិច្ច និងការធ្វើឱ្យជាអារម្មណ៍ ។

ក្នុងសេចក្តីនោះ មានសេចក្តីសង្ខេបដូចតទៅនេះ

កាលណា ធម៌ទាំងឡាយប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស អ្នកមានឈាន កាលនោះ ព្រាហ្មណ៍នោះ រមែងកម្ចាត់មារ និងសេនាមារចេញបាន ដោយពោធិបក្ខិយធម៌ដែលកើតឡើងទាំងនោះ ឬដោយអរិយមគ្គដែលជាហេតុប្រាកដនៃចតុសច្ចធម៌ ។ បទថា **វិធូបយំ តិដ្ឋតិ មារសេនំ** សេចក្តីថា កម្ចាត់ រំលាយ ធ្វើឱ្យបាត់បង់នូវមារ និងសេនាមារ មានប្រការដូចពោលហើយដោយន័យមានជាអាទិ៍ថា **កាមា តេ បឋមា សេនា** កាមជាសេនាទី ១ របស់អ្នក (មារ)[1] ។ សួរថា យ៉ាងណា ? ឆ្លើយថា ដូចព្រះអាទិត្យ ធ្វើអាកាសឱ្យស្វាងស្រៃ អធិប្បាយថា ព្រះអាទិត្យគោចរឡើងទៅ ធ្វើអាកាសឱ្យស្វាងស្រៃដោយរស្មីខ្លួន ហើយកម្ចាត់សេចក្តីងងឹតអណ្តែត យ៉ាងណា ព្រាហ្មណ៍ជាខីណាស្រពសូម្បីនោះក៏ដូច្នោះ ចាក់ធ្ទុះនូវសច្ចៈទាំងឡាយដោយធម៌ទាំងនោះ

១-សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស លេខ ៦៤ ទំព័រ ១៨០ ។

ឬដោយអរិយមគ្គនោះ ឈ្មោះថា រមែងកម្ចាត់មារ និងសេនាមារចេញបានហើយ តាំងនៅ ។

ក្នុងយាមទាំង ៣ ព្រះដ៏មានព្រះភាគត្រាស់ឧទានទាំង ៣ នេះ ដែលប្រកាសនូវអានុភាពនៃការដឹងច្បាស់បច្ចយាការក្នុងយាមទី ១ ការសម្រេចនូវការអស់នៃបច្ច័យក្នុងយាមទី ២ និងការសម្រេចអរិយមគ្គក្នុងយាមទី ៣ ដោយប្រការដូច្នេះ ។ ក្នុងរាត្រីទីប៉ុន្មាន ក្នុងរាត្រីទី ៧ បន្ទាប់ពីការត្រាស់ដឹងអភិសម្ពោ-ធិញ្ញាណ ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់រឭកបុព្វេនិវាសញ្ញាណក្នុងបឋម-យាម ទ្រង់ជម្រះទិព្វចក្ខុញ្ញាណក្នុងមជ្ឈិមយាម ទ្រង់ជម្រះញាណចុះក្នុងបដិច្ចសមុប្បាទក្នុងបច្ឆិមយាមនៃរាត្រីវិសាខបុណ្ណមី ទ្រង់ពិចារណាសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយន័យផ្សេងៗ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ អរុណនឹងរះឡើង ក៏បានសម្រេចព្រះសម្មាសម្ពោធិញ្ញាណ តែក្នុងលំដាប់ដែលកើតព្រះសព្វញ្ញុតញ្ញាណ អរុណក៏រះឡើង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ប្រថាប់នៅអស់ ១ សប្តាហ៍ទៀបគល់ពោធិព្រឹក្សដោយបល្ល័ង្ក្ខនោះឯង លុះដល់រាត្រីថ្ងៃបាដិបទ (ថ្ងៃ ១ រនោច) ព្រះដ៏មានព្រះភាគទ្រង់ធ្វើមនសិការដល់បដិច្ចសមុប្បាទ ដោយន័យដែលពោលហើយក្នុងយាមទាំង ៣ ហើយ ព្រះដ៏-មានព្រះភាគទ្រង់បន្ទឹនូវឧទានេះតាមលំដាប់ ។ តែព្រោះមកក្នុងខន្ធក:ទាំង ៣ វារ:ថា ព្រះដ៏មានព្រះភាគទ្រង់ធ្វើមនសិការដល់បដិច្ចសមុប្បាទ ជាអនុលោមបដិលោម[1] លោកទើបពោលទុកក្នុងអដ្ឋកថាខន្ធក:ថា ព្រះដ៏មាន-

---

១-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ១ ។

ព្រះភាគទ្រង់ធ្វើមនសិការយ៉ាងនេះក្នុងយាមទាំង ៣ ហើយទ្រង់បន្ទឹនូវឧទានទាំងនេះយ៉ាងនេះ គឺឧទានទី ១ ដោយអំណាចពិចារណាបច្ចយាការ ឧទានទី ២ ដោយអំណាចពិចារណាព្រះនិព្វាន ឧទានទី ៣ ដោយអំណាចពិចារណាមគ្គ ។ សូម្បីពាក្យនោះក៏មិនខុស ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់ពិចារណាធម៌ក្នុងចន្ទោះខាងក្នុងសប្តាហ៍ទាំង ៦ ដែលនៅសល់ រៀងសប្តាហ៍ដែលប្រថាប់ក្នុងរតនឃរចេតិយដោយច្រើន ទ្រង់សោយវិមុត្តិសុខហើយប្រថាប់នៅ ។ តែក្នុងសប្តាហ៍ដែលប្រថាប់ក្នុងរតនឃរចេតិយ ទ្រង់ប្រថាប់នៅដោយការពិចារណាព្រះអភិធម្មប៉ុណ្ណោះឯង ។

តតិយសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាពោធិសូត្រទី ៣

៤. អជបាលនិគ្រោធសុត្តវណ្ណនា[1]

អដ្ឋកថាអជបាលនិគ្រោធសូត្រ

អជបាលនិគ្រោធសូត្រទី ៤ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **អជបាលនិគ្រោធេ** *សេចក្តីថា បានឮថា អ្នកគង្វាលពពែទាំងឡាយ បានទៅអង្គុយក្នុងម្ទប់ដើមនិគ្រោធ (ដើមជ្រៃ) នោះ ព្រោះដូច្នោះ ដើមនិគ្រោធនោះ ទើបឈ្មោះថា* ***អជបាលនិគ្រោធ*** *នោះឯង ។ តែអាចារ្យពួកខ្លះពោលថា ព្រោះហេតុដែលពួកព្រាហ្មណ៍ចាស់ៗ មិនអាចនឹងទន្ទេញវេទទាំងឡាយក្នុងទីនោះបាន ទើបធ្វើទីនៅអាស្រ័យដោយការលោមព័ទ្ធនូវរបង ហើយនៅ ព្រោះដូច្នោះ ដើមឈើនោះ ទើបកើតឈ្មោះថា* ***អជបាលនិគ្រោធ*** *។ ក្នុងសេចក្តីនោះ មានវចនត្ថៈដូចតទៅនេះ*

ឈ្មោះថា ***អជបា*** *ព្រោះរាយមន្តមិនបាន អធិប្បាយថា បុគ្គលអ្នកស្វាធ្យាយមន្តមិនបាន ឈ្មោះថា* ***អជបាលៈ*** *ព្រោះបុគ្គលនោះតែងទៅកាន់ គឺអាស្រ័យនៅក្រោមដើមឈើនោះ ព្រោះដូច្នោះ ជននោះឈ្មោះថា* ***អជបាលៈ*** *។ អាចារ្យមួយពួកទៀតពោលថា ព្រោះហេតុដែលដើមឈើនោះបិទបាំងរក្សាពួកពពែដែលចូលទៅនៅខាងក្នុងវេលាថ្ងៃត្រង់ ដោយស្រមោលរបស់ខ្លួនដូច្នោះ ដើមឈើនោះទើបកើតឈ្មោះថា* ***អជបាលៈ*** *(រក្សាពពែ) ។ នោះជាឈ្មោះរបស់ដើមឈើនោះ សូម្បីគ្រប់ឈ្មោះ ។ ទីជិតដើមឈើនោះ ។ ពិតមែនបទថា* **អជ-បាលនិគ្រោធេ** *នេះ ជាសត្តមីវិភត្តិចុះក្នុងអត្ថថា ជិត ។*

បទថា **វិមុត្តិសុខំ បដិសំវេទី** *សេចក្តីថា កាលព្រះដ៏មានព្រះភាគទ្រង់*

១-ក្នុងអដ្ឋកថាច្បាប់ឆដ្ឋសង្គាយនា ព្រះសូត្រនេះមានឈ្មោះថា **ហ៊ុំហ៊ុង្ខ** សុត្តវណ្ណនា *។*

ពិចារណាធម៌ សូម្បីក្រោមដើមអជបាលនិគ្រោធនោះ ប្រថាប់គង់សោយវិមុត្តិ-សុខ ។ ដើមឈើនោះ មាននៅក្នុងចំណែកខាងបុរត្ថិមទិស (ទិសខាងកើត) អំពីដើមពោធិព្រឹក្ស ។ ក៏បទថា **សត្តាហំ** នេះ មិនមែនជាសប្តាហៈជាប់តនឹងសប្តាហៈ ដែលទ្រង់គង់ចម្រើនសមាធិ ។ សេចក្តីពិត ព្រះដ៏មានព្រះភាគទ្រង់ប្រថាប់គង់ទីជិតពោធិព្រឹក្សនុ៎ះឯង រហូតដល់អស់ ៣ សប្តាហៈ ក្រៅពីសប្តាហៈដែលទ្រង់គង់ចម្រើនសមាធិ ។ ក្នុងសេចក្តីនោះមានអនុបុព្វិកថាដូចតទៅនេះ

បានឮថា ព្រះដ៏មានព្រះភាគទ្រង់សម្រេចសម្មាសម្ពោធិញាណ ហើយប្រថាប់គង់ចម្រើនសមាធិរហូតដល់អស់ ១ សប្តាហ៍ ទេវតាពួកខ្ទុះកើតសេចក្តីសង្ស័យឡើងថា ព្រះដ៏មានព្រះភាគមិនស្តេចយាងចេញ ធម៌ដែលធ្វើភាពជាព្រះពុទ្ធសូម្បីយ៉ាងដទៃនៅមានដែរឬហ្ន៎ ។ ក្នុងថ្ងៃទី ៨ ព្រះដ៏មានព្រះភាគស្តេចចេញពីសមាបត្តិ ទ្រង់ជ្រាបសេចក្តីសង្ស័យរបស់ពួកទេវតា ទើបហោះឡើងទៅលើអាកាស ដើម្បីកម្ចាត់សេចក្តីសង្ស័យរបស់ទេវតាទាំងនោះ ហើយសម្តែងយមកបាដិហារ្យ បន្ទោបង់នូវសេចក្តីសង្ស័យរបស់ទេវតានោះ ប្រថាប់ឈរខាងទិសឧត្តរដែលធ្វៀងទៅទិសបស្ចិម (ទិសខាងជើងធ្វៀងខាងលិច) នឹងបល្ល័ង្ក ព្រះដ៏មានព្រះភាគទ្រង់សម្ងឹងដោយមិនធ្មេចព្រះនេត្រនូវបល្ល័ង្កផង និងពោធិ-ព្រឹក្សផង ដែលជាស្ថានទីសម្រេចផលនៃបារមី ដែលទ្រង់សន្សំមករហូតដល់អស់ ៤ អសង្ខ្យេយ្យ និង ១ សែនមហាកប្ប ទ្រង់ឈប់សម្រាកនៅ ១ សប្តាហ៍ ស្ថានទីនោះ ទើបកើតឈ្មោះថា **អនិមិសចេតិយ** ។ លំដាប់នោះ ព្រះដ៏មានព្រះភាគចង្ក្រមក្នុងទីរតនចង្ក្រមដ៏វែង ពីបុរត្ថិមទិសទៅបច្ឆិមទិស

(ពីកើតទៅលិច) ចន្ទោះបល្ល័ង្ក និងទីដែលប្រថាប់ឈរ ទ្រង់ឈប់សម្រាកអស់ ១ សប្តាហ៍ ។ ស្ថានទីនោះ ទើបឈ្មោះថា **រតនចង្ក្រមចេតិយ** ។ ក្នុងបច្ចិមទិស អំពីរតនចង្ក្រមចេតិយនោះ ទេវតានិម្មិតផ្ទះកែវ ទ្រង់ប្រថាប់គង់សមាធិក្នុងផ្ទះកែវនោះ ទ្រង់ពិចារណាអភិធម្មបិដកដែលជាសមន្តបដ្ឋាន អនន្តន័យដោយពិសេស ទ្រង់ឈប់សម្រាកអស់ ១ សប្តាហ៍ ស្ថានទីនោះ ទើបឈ្មោះថា **រតនឃរ-ចេតិយ** ។ ទ្រង់ឈប់សម្រាកអស់ ៨ សប្តាហ៍ក្នុងទីជិតពោធិព្រឹក្សដោយអាការយ៉ាងនេះ ក្នុងសប្តាហ៍ទី ៥ ស្តេចយាងចេញពីពោធិព្រឹក្ស ចូលទៅកាន់ដើមអជបាលនិគ្រោធ ទ្រង់ប្រថាប់គង់សមាធិត្រង់គល់ដើមអជបាលនិគ្រោធនោះ ។

បទថា **តម្ហា សមាធិម្ហា វុដ្ឋាសិ** សេចក្តីថា ចេញចាកសមាធិ គឺផលសមាបត្តិនោះ តាមវេលាដែលកំណត់ទុក ក៏ត្រាដែលព្រះដ៏មានព្រះភាគ ស្តេចចេញពីសមាបត្តិហើយប្រថាប់គង់ក្នុងទីនោះយ៉ាងនេះ ព្រាហ្មណ៍ម្នាក់ មកកន្លងព្រះអង្គទូលសួរបញ្ហា ។ ព្រោះហេតុនោះ លោកទើបពោលពាក្យ មានជាអាទិ៍ថា **អថ ខោ អញ្ញតរោ** ។ បណ្តាបទទាំងនោះ បទថា **អញ្ញតរោ** បានដល់ ព្រាហ្មណ៍ម្នាក់មានឈ្មោះ និងគោត្រមិនប្រាកដ ។ បទថា **ហុំ ហុ ङ្ក-ជាតិកោ** សេចក្តីថា បានឮថា ព្រាហ្មណ៍នោះជាទិដ្ឋិមង្គលិក: មានមានះចាត់ ឃើញវត្ថុគ្រប់យ៉ាងមានកំណើតថោកទាប ទើបស្ពប់ ត្រាប់ធ្វើសំឡេង ហុំ ហុំ ដោយអំណាចមានុះ និងសេចក្តីក្រោធ ។ ព្រោះដូច្នោះ គេទើបហៅ (ព្រាហ្មណ៍ នោះ) ថា **ហុហុङ្ករជាតិក:** បាលីថា **ហុហុङ្ករជាតិកោ** ដូច្នេះក៏មាន ។ បទថា **ព្រាហ្មណោ** បានដល់ ជាព្រាហ្មណ៍ដោយកំណើត ។

បទថា **យេន ភគវា** សេចក្តីថា ព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងទិសណា ។

ក៏ពាក្យថា **យេន** នេះ ជាតតិយាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ។ ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគដែលទេវតា និងមនុស្សគប្បីចូលទៅគាល់ក្នុងទិសណា ព្រាហ្មណ៍ក៏ចូលទៅគាល់ក្នុងទិសនោះ ។ ម្យ៉ាងទៀត បទថា **យេន** ជាតតិយា-វិភត្តិប្រើក្នុងអត្ថនៃហេតុ អធិប្បាយថា ព្រះដ៏មានព្រះភាគដែលទេវតា និងមនុស្ស គប្បីចូលទៅគាល់ព្រោះហេតុណា ព្រាហ្មណ៍ក៏ចូលទៅគាល់ ព្រោះហេតុនោះ ។ ក៏ព្រោះហេតុអ្វី ទើបត្រូវចូលទៅគាល់ព្រះដ៏មានព្រះភាគ ព្រោះទេវតា និងមនុស្សទាំងឡាយអ្នកមានចិត្តរសាប់រសល់ ព្រោះត្រូវព្យាធិ គឺកិលេសផ្សេងៗ បៀតបៀនទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ ដោយហេតុមានការស្តាប់ធម៌ និងសួរបញ្ហាជាដើម ដើម្បីព្យាបាលព្យាធិ គឺកិលេស ដូចពេទ្យអ្នកមានអានុភាពច្រើន ដែលមហាជនអ្នកមានកាយរសាប់រសល់ ព្រោះត្រូវរោគ និងទុក្ខមានប្រការផ្សេងៗ បៀតបៀនទើបចូលទៅរកដើម្បីព្យាបាលរោគ ។ ព្រោះហេតុនោះ ព្រាហ្មណ៍សូម្បីនេះ ប្រាថ្នានឹងកាត់សេចក្តីសង្ស័យរបស់ខ្លួនទើបចូលទៅគាល់ ។

បទថា **ឧបសङ्कមិត្វា** ជាបទសម្តែងដល់ទីបំផុតរបស់ការទៅគាល់ ។ ម្យ៉ាងទៀត សេចក្តីថា ចូលទៅកាន់ស្ថានទីដែលជិតកៀកព្រះដ៏មានព្រះភាគ ពីទីដែលគេចូលទៅគាល់ ។ បទថា **សម្មោទិ** បានដល់ រីករាយនៅស្មើ ឬដោយប្រពៃ ។ ក៏ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងព្រាហ្មណ៍ឱ្យរីករាយដោយធ្វើបដិសណ្ឋារៈមានជាអាទិ៍ថា នែ៎ព្រាហ្មណ៍អ្នកលួមអត់ទ្រាំបានឬ លួមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបានឬទេ ។ បទថា **សម្មោទនីយំ** បានដល់ គួរដល់

សេចក្តីរីករាយ គឺសមគួរដល់ការឱ្យកើតសេចក្តីរីករាយ ។ បទថា **ករណ** *បានដល់ការចរចាប្រាស្រ័យ ។ បទថា* **សារណីយ** *បានដល់ គួររឭក គឺដែលអ្នកល្អ គប្បីឱ្យប្រព្រឹត្តទៅ ឬគប្បីគិតក្នុងវេលាដទៃ ។ បទថា* **រីតិសារេត្វា** *ប្រែថា ឱ្យសម្រេច ។ បទថា* **ឯកមន្ត** *ជាបទសម្តែងការ:នបុំសកលិង្ត ។ អធិប្បាយថា ក្នុងទីមួយកន្លែង គឺចំណែកមួយ រៀរគោសរបស់ការអង្គុយ ៦ យ៉ាង មានការអង្គុយត្រង់មុខពេកជាដើម ។ បទថា* **ឯតទវោច** *សេចក្តីថា ព្រះដ៏មានព្រះភាគ ត្រាស់ពាក្យនេះ គឺពាក្យដែលនឹងគប្បីត្រាស់ក្នុងឥឡូវនេះមានជាអាទិ៍ថា* **កិត្តាវតា ឧ ខោ** *ដោយហេតុត្រឹមតែប៉ុនណាហ្ន៎ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **កិត្តាវតា** *ប្រែថា ដោយប្រមាណប៉ុនណា ។ បទថា* **ឧ** *ជានិបាត ប្រើក្នុងអត្ថថា សង្ស័យ ។ បទថា* **ខោ** *ជានិបាតប្រើក្នុងអត្ថថា ធ្វើបទឱ្យពេញ ។ បទថា* **ភោ** *ជាអាលបន: ស្រែកហៅជាតិរបស់ព្រាហ្មណ៍ ។ សមដូចពាក្យដែលព្រះដ៏មានព្រះភាគសម្តែងទុកថា បុគ្គលនោះគ្រាន់តែបាន នាមថា* **ភោវាទី** *(អ្នកពោលថា ចម្រើន) ព្រោះបុគ្គលនោះឯងជាអ្នកមានកិលេស ជាគ្រឿងកង្ខ្ល់នៅឡើយ[1] ។ ព្រាហ្មណ៍ស្រែកហៅព្រះដ៏មានព្រះភាគដោយ គោត្រថា* **គោតម:** *។ សួរថាយ៉ាងណា ព្រាហ្មណ៍នេះ មកដល់ឥឡូវនេះ ទើប បានជ្រាបគោត្ររបស់ព្រះដ៏មានព្រះភាគ ឆ្វើយថា ព្រាហ្មណ៍នេះមិនមែនជ្រាប ក្នុងកាលឥឡូវនេះ ។ ព្រះដ៏មានព្រះភាគព្រះអង្គត្រាច់ទៅជាមួយនឹងបញ្ចវគ្គិយ អ្នកឧបដ្ឋាក ក្នុងគ្រាបំពេញទុក្ករកិរិយាអស់ ៦ វស្សាក្តី ខាងក្រោយមក ទើប*

១-សុត្តន្តបិដក ខុទ្ទកនិកាយ គាថាធម្មបទ លេខ ៥២ ទំព័រ ១០៥ ។

ទ្រង់លះចោលវត្តនោះ ព្រះអង្គត្រាច់ទៅបិណ្ឌបាត តែមួយព្រះអង្គ មិនមានសម្ងាញ់ជាគម្រប់ពីរ ក្នុងតំបន់ឧរុវេលាសេនានិគមក្តី ព្រាហ្មណ៍នោះធ្លាប់ឃើញ និងធ្លាប់ចរចា ។ ព្រោះហេតុនោះ ព្រាហ្មណ៍នោះ ទើបរត្ងកដល់គោត្ររបស់ព្រះដ៏មានព្រះភាគ ដែលបញ្ចវគ្គិយទទួលរាប់អានក្នុងកាលមុន ទើបបានស្រែកហៅព្រះដ៏មានព្រះភាគដោយគោត្រថា **ភោ គោតម** (នែ៎គោតមដ៏ចម្រើន) ។ ម្យ៉ាងទៀត ចាប់ផ្តើមអំពីព្រះដ៏មានព្រះភាគស្តេចយាងចេញសាងមហាភិនេស្ក្រមត្រង់ច្រាំងស្ទឹងអនោមា ព្រះអង្គជាអ្នកប្រាកដដូចព្រះចន្ទ និងព្រះអាទិត្យដែលស្គាល់ជាទូទៅថា ព្រះសមណគោតម មិនចាំត្រូវស្វែងរកហេតុក្នុងការដឹងគោត្ររបស់ព្រះដ៏មានព្រះភាគនោះទេ ។

បទថា **ព្រាហ្មណ្យការណា** សេចក្តីថា ឈ្មោះថា **ព្រាហ្មណ្យការណា** ព្រោះធ្វើភាពជាព្រាហ្មណ៍ អធិប្បាយថា ធ្វើការ:ថាជាព្រាហ្មណ៍ ។ ក៏ក្នុងពាក្យនោះ ដោយពាក្យថា **កិត្តាវតា** នេះ ព្រាហ្មណ៍ទូលសួរដល់ប្រមាណនៃធម៌ដែលជាហេតុឱ្យជាព្រាហ្មណ៍ ។ ក៏ដោយពាក្យថា **កតមេ ច បន** នេះ ទូលសួរដល់សេចក្តីសរុបធម៌ទាំងនោះ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះអង្គទ្រង់ដឹងច្បាស់សេចក្តីនេះ ដែលជាកំពូលនៃបញ្ហាដែលព្រាហ្មណ៍នោះទូលសួរ ទើបព្រះដ៏មានព្រះភាគទ្រង់បន្ទឺនូវឧទានេះ ក្នុងវេលានោះ ។ តែព្រះអង្គទ្រង់មិនបានសម្តែងធម៌ដល់ព្រាហ្មណ៍នោះទេ ។ ព្រោះហេតុអ្វី ព្រោះព្រាហ្មណ៍មិនទាន់ជាទីទ្រទ្ទទួលព្រះធម្មទេសនា ។ ពិតយ៉ាងនោះ ព្រាហ្មណ៍នោះបានស្តាប់គាថានេះហើយ

ក៏មិនបានត្រាស់ដឹងនូវសច្ចៈទេ ត្រឹមតែប្រកាសនូវពុទ្ធគុណដល់ព្រាហ្មណ៍នោះ ដូចជាប្រកាសនូវពុទ្ធគុណដល់ឧបកាជីវកដូច្នោះដែរ ។ មែនពិត ព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងចំណែកខាងដើម មុនការប្រកាសធម្ម-ចក្រ ចំពោះជាចំណែកនៃវាសនាដល់ពួកដទៃអ្នកបានស្តាប់ ដូចឱ្យសរណៈ ដល់តបុស្សៈនិងកលិកៈ (ពាណិជ្ជ ២ នាក់បងប្អូន) មិនមែនជាចំណែកនៃ ព្រះសេក្ខៈ និងមិនមែនជាចំណែកនៃការត្រាស់ដឹង ។ សេចក្តីពិត ប្រការធម៌ នោះជាធម្មតា ។

បណ្តាបទទាំងនោះ បទថា **យោ ព្រាហ្មណោ** សេចក្តីថា បុគ្គលណា ឈ្មោះថា ជាព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបន្សាត់បង់ហើយ ជាអ្នកមិនប្រកប ដោយបាបធម៌ មានការគំរាមថា ហុំ ហុំ ដូចទឹកអម្ចត់ជាដើម ព្រោះជាទិដ្ឋិមង្គ-លិកៈ នូវប្តេជ្ញាខ្លួនថាជាព្រាហ្មណ៍ដោយត្រឹមតែជាតិតែប៉ុណ្ណោះក៏ទេ បុគ្គល នោះឈ្មោះថាជាព្រាហ្មណ៍ ព្រោះមានបាបបន្សាត់បង់បានហើយ ឈ្មោះថា ប្រាសចាកកិលេស ដែលគម្រាមអ្នកដទៃថា ហុំ ហុំ ព្រោះលះកិលេសដែល គំរាមអ្នកដទៃថា ហុំ ហុំ បាន ឈ្មោះថា មិនមានកិលេសដូចទឹកអម្ចត់ ព្រោះមិន មានកិលេសដូចទឹកអម្ចត់ មានរាគៈជាដើម ឈ្មោះថា មានសេចក្តីព្យាយាមជា សការៈ ព្រោះមានចិត្តប្រកបដោយការនានុយោគ ឬឈ្មោះថាសង្រ្ទួមខ្លួនហើយ ព្រោះមានចិត្តសង្រ្ទួមហើយដោយសីលសំវរៈ ឈ្មោះថា អ្នកដល់នូវទីបំផុតនៃ វេទ ព្រោះដល់ទីបំផុត គឺព្រះនិព្វានជាទីបំផុតនៃសង្ខារ ឬទីបំផុតនៃវេទ ដោយ វេទទាំងឡាយពោល គឺមគ្គញ្ញាណ ៤ ។ ឈ្មោះថា នៅចប់ព្រហ្មចរិយៈហើយ ព្រោះនៅចប់មគ្គព្រហ្មចរិយៈ ។ បុគ្គលដែលពោលវាទៈថាជាព្រាហ្មណ៍ដោយ

ធម៌ គឺពោលវាទ:នេះថា អញជាព្រាហ្មណ៍ដោយធម៌ដ៏ប្រពៃមិនមានកិលេស ជាគ្រឿងប៉ោងឡើងទាំងនេះ បានដល់ កិលេសដែគ្រឿងប៉ោងឡើង គឺរាគ: ទោស: មោហ: មាន: និងទិដ្ឋិក្នុងទីណាៗ គឺសូម្បីក្នុងអារម្មណ៍តែមួយក្នុង លោកសន្និវាសទាំងអស់ អធិប្បាយថា លះបានដោយមិនឱ្យសេសសល់ ។

ចតុត្ថសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៤

៤. ថេរសុត្តវណ្ណនា[1]

អដ្ឋកថាថេរសូត្រ

ថេរសូត្រទី ៥ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **សាវត្ថិយំ** *គឺជិតនគរឈ្មោះយ៉ាងនេះ ។ មែនពិត នគរនោះ លោកហៅថា* **សាវត្ថី** *ព្រោះសាងក្នុងទីនៅអាស្រ័យរបស់ឥសីឈ្មោះ* **សាវត្ថ:** *ដូចក្រុងកាកន្ទិ ហៅថា* **មាកន្ទី** *។ អ្នកប្រាជ្ញអក្សរសាស្ត្រគប្បីជ្រាបយ៉ាងនេះជាដំបូង ។ ចំណែកព្រះអដ្ឋកថាទាំងឡាយពោលថា ឈ្មោះថា* **សាវត្ថី** *ព្រោះជាទីមានគ្រឿងឧបភោគ និងបរិភោគគ្រប់យ៉ាងសម្រាប់មនុស្ស ។ កាលត្រូវសួរថា ក្នុងទីនេះមានវត្ថុអ្វី ក្នុងការប្រកបជាពួក ទើបហៅថា* **សាវត្ថី** *ធ្វើយថា ព្រោះអាស្រ័យ ពាក្យថា* **សព្វមត្ថិ** *វត្ថុទាំងអស់មាននៅដូច្នេះ ។*

> *គ្រឿងឧបករណ៍ទាំងអស់មានច្រើនយ៉ាង ដោយប្រការទាំងពួង ប្រមូលមកក្នុងក្រុងសាវត្ថី ព្រោះអាស្រ័យសេចក្តីព្រមមូលទាំង-ពួង ទើបហៅថា* **សាវត្ថី** *ដូច្នេះ ។*

ជិតក្រុងសាវត្ថីនោះ ។ ក៏បទថា **សាវត្ថិយំ** *នេះ ជាសត្តមីវិភត្តិប្រើក្នុងអត្ថថា ជិត ។*

បទថា **ជេតវនេ** *សេចក្តីថា ឈ្មោះថា* **ជេត** *ព្រោះឈ្នះសត្រូវរបស់ខ្លួន ។ ម្យ៉ាងទៀត ឈ្មោះថា* **ជេត** *ព្រោះប្រសូត ក្នុងកាលព្រះរាជាឈ្នះពួកជន អ្នកជាសត្រូវ ។ ម្យ៉ាងទៀត ឈ្មោះថា* **ជេត** *ព្រោះតាំងឈ្មោះលោកយ៉ាងនោះ ព្រោះត្រូវការឱ្យជាមង្គល ។ ឈ្មោះថា* **វន:** *ព្រោះគប់រក អធិប្បាយថា ធ្វើសេចក្តី*

១-ក្នុងអដ្ឋកថាច្បាប់ធម្មសង្គាយនា ព្រះសូត្រនេះមានឈ្មោះថា ព្រាហ្មណសុត្តវណ្ណនា *។*

រីករាយក្នុងខ្លួនឱ្យកើតដល់សត្វទាំងឡាយ ដោយគុណសម្បត្តិរបស់ខ្លួន ។ ម្យ៉ាងទៀត ឈ្មោះថា **វនៃ** ព្រោះស្រែកសូម អធិប្បាយថា ដូចស្រែកសូមពួកសត្វថា ពួកលោកចូរប្រើប្រាស់យើង ដោយការធ្វើយសំឡេងស្រែករបស់បក្សីដូចសត្វតារ៉ៅថាជាដើម ដោយសេចក្តីស្រវឹងក្នុងភាពក្ងើតក្ងើន ដោយផ្លាឈើ និងរបស់ក្រអូបប្រភេទផ្សេងៗ និងដោយដៃ គឺស្ទឹកឈើខ្ចីរបស់មែកឈើដែលត្រូវខ្យល់បក់តិចៗ ។ សួនរបស់ព្រះរាជកុមារជេត: ឈ្មោះថា **ជេតវន** ។ មែនពិតសួននោះព្រះរាជកុមារព្រះនាមថា ជេត ទ្រង់ដាំសាងឱ្យចម្រើន និងរក្សាទុក ។ ព្រះរាជកុមារជេតនុ៎ះឯងជាម្ចាស់របស់សួននោះ ព្រោះដូច្នោះ សួននោះ ទើបហៅថា **ជេតវន** ។ ក្នុងសួនឈ្មោះថា **ជេតវន**នោះ ។

បទថា **អនាថបិណ្ឌិកស្ស អារាមេ** សេចក្តីថា មហាសេដ្ឋីនោះ នាមថា **សុទត្ត:** ដែលមាតាបិតាតាំងឈ្មោះឱ្យ ក៏លោកសេដ្ឋីនោះឱ្យដុំបាយដល់ជនអនាថាជានិច្ចជាកាល ព្រោះមានសេចក្តីសម្រេចក្នុងវត្ថុដែលប្រាថ្នាគ្រប់ប្រការ ព្រោះប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ និងដល់ព្រមដោយគុណមានករុណាជាដើម ព្រោះដូច្នោះ ទើបហៅថា **អនាថបិណ្ឌិក:** ។ ឈ្មោះថាអារាមព្រោះជាទីត្រេកអររបស់សត្វ គឺអ្នកបួសដោយពិសេស អធិប្បាយថា អ្នកមកពីទីនោះៗ រមែងត្រេកអរ ក្ងើតក្ងើនមិននឿយណាយដោយសេចក្តីល្អរបស់ផ្លាឈើ និងផ្ទៃឈើជាដើម និងដោយសេចក្តីសម្បូរនៃអង្គរបស់សេនាសន: ៩ ប្រការ មានមិនធ្វាយពេក មិនជិតណាស់ជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **អារាម** ព្រោះនាំអ្នកសូម្បីទៅក្នុងទីនោះៗ មកត្រេកអរចំពោះក្នុងខាងក្នុងខ្លួន

ដោយសម្បត្តិមានប្រការដូចពោលហើយ ។ មែនពិត អារាមនោះ អនាថ-
បិណ្ឌិកគហបតី ចំណាញ្ជ្រាក់ ១៨ កោដិទិញពីព្រះហស្តរបស់ព្រះរាជកុមារ
ព្រះនាមថា **ជេត** ដោយការយកមាសមកក្រាល ចំណាញ្ជ្រាក់ ១៨ កោដិ
សាងសេនាសនៈ ចំណាញ្ជ្រាក់ ១៨ កោដិ ដើម្បីធ្វើបុណ្យធ្វើវិហារ ហើយវេ
ច្ចាយចំពោះព្រះសង្ឆ មានព្រះពុទ្ធជាប្រធាន ដោយចំណាញ្ជ្រាក់ ៥៤ កោដិ
ដោយប្រការយ៉ាងនេះ ព្រោះដូច្នោះ ទើបហៅថា **អារាមរបស់អនាថបិណ្ឌិក-
គហបតី** ។ ក្នុងអារាមរបស់អនាថបិណ្ឌិកគហបតីនោះ ។

ក៏បណ្តាពាក្យទាំងនោះ ពាក្យថា **ជេតវនេ** ជាពាក្យបញ្ជាក់ដល់ម្ចាស់
ខាងដើម ។ ពាក្យថា **អនាថបិណ្ឌិកស្ស អារាមេ** ជាពាក្យបញ្ជាក់ដល់ម្ចាស់
របស់អ្នកខាងក្រោយ ។ សម្បីពាក្យទាំងពីរក៏មានសេចក្តីសំដៅយកឱ្យកាន់ជា
តួយ៉ាងតទៅ របស់អ្នកត្រូវការបុណ្យ ដោយការសម្តែងការបរិច្ចាគជាពិសេស
របស់លោកទាំងពីរ ។ មែនពិត ការពោលអំពីការសាងស៊ុមទ្វារ និងប្រាសាទ
ត្រង់វត្តជេតពននោះ ព្រះរាជកុមារជេតទ្រង់បរិច្ចាគប្រាក់ ១៨ កោដិ ដែលបាន
មកពីការលក់ឈើដែលមានតម្លៃច្រើនកោដិ និងលោកអនាថបិណ្ឌិកគហបតី
បរិច្ចាគ ៥៤ កោដិ ។ ព្រោះដូច្នោះ ព្រះអានន្ទអ្នកជាធម្មកណ្ឌាគារិក កាលនឹង
សម្តែងថា អ្នកត្រូវការបុណ្យ រមែងធ្វើបុណ្យយ៉ាងនេះ ដោយការបញ្ជាក់ដល់
ការបរិច្ចាគទ្រព្យរបស់លោកទាំងពីរនោះ ទើបបបួលអ្នកត្រូវការបុណ្យសម្បី
ពួកដទៃ ដោយការដើរតាមគំរូរបស់លោកទាំងពីរនោះឯង ។

ក្នុងសេចក្តីនោះ គប្បីមានពាក្យសួរថា ប្រសិនបើព្រះដ៏មានព្រះភាគ
ប្រថាប់នៅក្នុងក្រុងសាវត្ថី មិនគួរពោលថា ក្នុងវត្តជេតពន បើប្រថាប់នៅក្នុង

វត្តជេតពន ក៏មិនគួរពោលថា ក្នុងក្រុងសាវត្ថីដែរ ព្រោះអ្នកណាៗ មិនអាចនឹងនៅក្នុងកន្ទែង ២ រៀលតែមួយទេ ធ្វើយថា ក៏ប្រការនោះមិនគួរឃើញយ៉ាងនោះទេ ព្រោះខ្ញុំបានពោលទុកហើយយ៉ាងនេះថា បទថា **សាវត្ថិយំ** *នេះ ជាសត្តមីវិភត្តិប្រើក្នុងអត្ថថា ជិត មិនដូច្នោះឬ ។ ព្រោះដូច្នោះ កាលព្រះអង្គប្រថាប់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី លោកទើបពោលថា* **សាវត្ថិយំ វិហរតិ ជេតវនេ** *ប្រថាប់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ។ មែនពិត ពាក្យថា* **សាវត្ថី** *ជាពាក្យសម្តែងដល់គោចរគ្រាមរបស់ព្រះដ៏មានព្រះភាគនោះ ជាអត្ត ។ ពាក្យដ៏សេសសល់ ជាពាក្យសម្តែងទីនៅដ៏សមរម្យរបស់បព្វជិត ។*

ពាក្យថា **អាយស្មា** *ក្នុងពាក្យមានជាអាទិ៍ថា* **អាយស្មា ច សារីបុត្តោ** *ជាពាក្យសម្តែងដល់សេចក្តីស្រឡាញ់ ។* **ច**-*ស័ព្ទ ជាសមុច្ចយត្ថ: ។ ឈ្មោះថា សារីបុត្រ ព្រោះជាបុត្ររបស់ព្រាហ្មណី ឈ្មោះ រូបសារី ។ ពាក្យថា* **មហាមោគ្គ-ល្លានោ** *ជាពាក្យសម្តែងដល់ការបូជា ។ សេចក្តីពិត ឈ្មោះ មហាមោគ្គល្លាន ព្រោះព្រះមោគ្គល្លានជាអ្នកធំដោយគុណវិសេស ។ បទថា* **រេវតោ** *បានដល់ ព្រះខទិរវនិករេវត: មិនមែនព្រះកង្ខារេវត:ទេ ។ មែនពិត ថ្ងៃមួយ ព្រះដ៏មាន-ព្រះភាគហែហមដោយកិក្ខុដ៏ច្រើន ដូចព្រះចន្ទអណ្តែតធ្វោពាក់កណ្តាលផ្ទៃអាកាស ទ្រង់ប្រថាប់គង់សម្តែងធម៌កណ្តាលបរិស័ទទាំង ៤ ដូចប្រាសាទមាសដែលព័ន្ធព័ទ្ធដោយរាំងនន១ពណ៌ក្រហម ដូចភ្នំមាសព័ន្ធព័ទ្ធដោយជលធារ១ពណ៌ទឹកប្រាក់ ដូចស្តេចហង្សធតរដ្ឋហែហមដោយហង្ស ៤ ម៉ឺន ដូចស្តេចចក្រពត្តិហែហមដោយចតុរង្គិនីសេនាដែលរុងរោចន៍ដោយរតន: ៧ ។ សម័យនោះ អគ្ត-*

សាវក និងមហាសាវកទាំងនេះបានចូលទៅគាល់ ដើម្បីថ្វាយបង្គំព្រះយុគល-
បាទរបស់ព្រះដ៏មានព្រះភាគ ។

បទថា **ភិក្ខូ អាមន្តេសិ** *សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹង*
សាវកទាំងនោះ អ្នកកំពុងមក ត្រាស់ចំពោះភិក្ខុអ្នកអង្គុយហែហមព្រះអង្គ ។
មែនពិត ព្រះដ៏មានព្រះភាគ ទ្រង់ឃើញលោកដ៏មានអាយុទាំងនោះ អ្នកបរិបូរ
ដោយគុណមានសីល សមាធិ និងបញ្ញាជាដើម អ្នកប្រកបដោយសេចក្តីស្ងប់
យ៉ាងក្រៃលែង ប្រកបដោយសម្បត្តិ គឺមារយាទយ៉ាងក្រៃលែង កំពុងចូលមក
គាល់ ទ្រង់មានព្រះទ័យជ្រះថ្លា ដើម្បីនឹងបញ្ជាក់នូវគុណវិសេសរបស់សាវក
ទាំងនោះ ទើបត្រាស់ចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍
ទាំងនោះកំពុងមក ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ទាំងនោះកំពុងតែមក ។
ពាក្យនោះ ព្រះអង្គត្រាស់ដោយសេចក្តីជ្រះថ្លា នឹងត្រាស់ដោយសេចក្តីសរសើរ
ដូច្នេះក៏ត្រូវ ។ បទថា **ឯវំ វុត្តេ** *សេចក្តីថា កាលព្រះដ៏មានព្រះភាគត្រាស់ថា*
ព្រាហ្មណ៍ សំដៅយកលោកដ៏មានអាយុទាំងនោះ ដោយប្រការដូច្នេះ ។ បទថា
អញ្ញតរោ *បានដល់ ភិក្ខុមួយរូបអ្នកមិនប្រាកដឈ្មោះ និងគោត្រអង្គុយនៅក្នុង*
ចំណោមបរិស័ទទាំងនោះ ។ បទថា **ព្រាហ្មណជាតិកោ** *ប្រែថា អ្នកកើតក្នុង*
ត្រកូលព្រាហ្មណ៍ ។ មែនពិត ភិក្ខុនោះបួសដោយចេញពីត្រកូលព្រាហ្មណ៍មហា-
សាលអ្នកមានភោគៈច្រើន ។ បានឮថា ភិក្ខុនោះបានគិតយ៉ាងនេះថា លោក
ទាំងនេះនិយាយគ្នាថា បុគ្គលនេះជាព្រាហ្មណ៍ដោយឧកតោសុជាតិ និងសម្រេច
ការសិក្សាមកពីលទ្ធិព្រាហ្មណ៍ មិនមែនជាព្រាហ្មណ៍ដោយប្រការដទៃទេ តែ
ព្រះដ៏មានព្រះភាគត្រាស់ហៅលោកដ៏មានអាយុទាំងនោះថា ជាព្រាហ្មណ៍ បើ

អ៊ីចឹង យើងនឹងទូលសួរនូវលក្ខណៈជាព្រាហ្មណ៍ចំពោះព្រះដ៏មានព្រះភាគ ។ មែនពិត ក្នុងគ្រានោះ ព្រះដ៏មានព្រះភាគបានត្រាស់ដល់ព្រះថេរៈទាំងនោះថា ជាព្រាហ្មណ៍សំដៅយកសេចក្តីនោះឯង មែនពិត រូបវិគ្រោះនៃជាតិព្រាហ្មណ៍ថា ឈ្មោះថា ព្រាហ្មណ៍ ព្រោះស្វាធ្យាយមន្ត ។ ចំណែកព្រះអរិយៈ ឈ្មោះថា ព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបន្សាត់បង់ហើយ ។ សមដូចពាក្យដែលព្រះដ៏-មានព្រះភាគត្រាស់ទុកថា **ពាហិតចាចោ ហិ ព្រាហ្មណោ សមចរិយា ព្រាហ្មណោតិ វុច្ចតិ** អ្នកដែលបាបបន្សាត់ហើយ ឈ្មោះថា **ព្រាហ្មណ៍** អ្នកដែលតថាគតហៅថា **សមណៈ** ព្រោះការប្រព្រឹត្តរំងាប់[1] ។

បទថា **ឯតមត្ថំ វិទិត្វា** បានដល់ ជ្រាបសេចក្តីនៃព្រាហ្មណសព្ទនេះ ដែលដល់ភាពជាកំពូលដោយបរមត្ថ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ព្រះដ៏-មានព្រះភាគទ្រង់បន្ទឹនូវឧទាននេះ ដែលសម្តែងភាពជាព្រាហ្មណ៍ដោយបរមត្ថ ។

បណ្តាបទទាំងនោះ បទថា **ពាហិត្វា** បានដល់ ធ្វើទុកខាងក្រៅ គឺនាំចេញពីសន្តានរបស់ខ្លួន អធិប្បាយថា លះដោយសមុច្ឆេទបហាន ។ បទថា **ចាបកេ ឌម្ភេ** ប្រែថា ធម៌ដ៏លាមក អធិប្បាយថា ដោយទុច្ចរិត បានដល់ ទុច្ចរិត ៣ ។ ពោលអំពីចិត្តុប្បាទ បានដល់ អកុសលចិត្តុប្បាទ ១២ ។ ពោលអំពីកម្មបថ បានដល់ អកុសលកម្មបថ ១០ ពោលអំពីប្រភេទនៃប្រវត្តិ បានដល់ អកុសលធម៌ទាំងអស់ចែកជាច្រើនប្រភេទ ។ បទថា **យេ ចរន្តិ សតា សតា** សេចក្តីថា ជនពួកណា មានសតិ គឺជាអ្នកមានសតិ ដោយធម៌ជាគ្រឿងនៅ

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ១០៣ ។

*គឺសតិ ៦ ក្នុងអារម្មណ៍ ៦ មានរូបជាដើមគ្រប់កាលទាំងពួង ព្រោះជាអ្នកចាស់ក្ងាបរិបូរដោយសតិ រមែងត្រាច់ទៅដោយឥរិយាបថទាំង ៤ ។ ក៏ក្នុងទីនេះ សូម្បីសម្បជញ្ញៈគប្បីជ្រាបថា លោកក៏កាន់យកដោយ**សតិ**-ស័ព្ទនុ៎ះដែរ ។ បទថា* **ទ្វីណាសំយោជនា** *បានដល់ ឈ្មោះថា អស់សំយោជនៈ ទាំងពួង ព្រោះកាត់សញ្ញោជនៈ ១០ ប្រការ បានដោយអរិយមគ្គទាំង ៤ ។ បទថា* **ពុទ្ធា** *គឺឈ្មោះថា* **ពុទ្ធ**ៈ *ព្រោះត្រាស់ដឹងសច្ចៈ ៤ ។ ក៏ឯពុទ្ធទាំងនោះមាន ៣ ប្រភេទ គឺសាវកពុទ្ធ បច្ចេកពុទ្ធ និងសម្មាសម្ពុទ្ធ ។ ក៏បណ្ដាពុទ្ធៈ ៣ នោះ ក្នុងទីនេះ ប្រាថ្នាយកសាវកពុទ្ធ ។ បទថា* **តេ ច លោកស្មិ ព្រាហ្មណា** *សេចក្ដីថា ពុទ្ធទាំងនោះកើតដោយអរិយជាតិក្នុងធម៌ ពោលគឺព្រាហ្មណ៍ ព្រោះអត្ថថា ជាអ្នកប្រសើរ ឬជាបុត្រ គឺឱរសរបស់ព្រះដ៏មានព្រះភាគ ព្រះអង្គជាព្រាហ្មណ៍ ព្រោះដូច្នោះ កាលពោលអំពីបរមត្ថ ក៏ឈ្មោះថា ព្រាហ្មណ៍ក្នុងសត្វលោកនេះ អធិប្បាយថា មិនមែនជាព្រាហ្មណ៍ដោយហេតុត្រឹមតែជាតិ និងគោត្រ ឬមិន មែនជាព្រាហ្មណ៍ដោយហេតុត្រឹមតែទ្រទ្រង់ជដាជាដើមទេ ។ ក្នុងសូត្រទាំងពីរនេះ ធម៌ដែលធ្វើភាពជាព្រាហ្មណ៍ ព្រះអង្គត្រាស់ដល់ព្រះអរហត្តដោយប្រការដូច្នេះ តែគប្បីជ្រាបសេចក្ដីផ្សេងគ្នានៃទេសនា ដោយការត្រាស់ផ្សេងៗគ្នា ដោយទេសនាវិលាស ព្រោះពួកសត្វមានអធ្យាស្ស័យផ្សេងគ្នា ។*

បញ្ចមសុត្តវណ្ណនា និដ្ឋិតា។

ចប់ អដ្ឋកថាសូត្រទី ៥

៦. មហាកស្សបសុត្តវណ្ណនា

អដ្ឋកថាមហាកស្សបសូត្រ

មហាកស្សបសូត្រទី ៦ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **រាជគហេ** *បានដល់ ជិតនគរដែលមានឈ្មោះយ៉ាងនេះ ។ មែនពិត នគរនោះហៅថា* ***រាជគ្រឹះ*** *ព្រោះព្រះបាទមហាមន្ធាតុ និងព្រះបាទ-មហាគោវិន្ទ:ជាដើមគ្រប់គ្រង ។ អាចារ្យពួកខ្លះពណ៌នាក្នុងសេចក្តីនេះដោយប្រការដទៃមានជាអាទិ៍ថា ឈ្មោះថា* ***រាជគ្រឹះ*** *ព្រោះជារាំងរបស់ព្រះរាជាដែលមានព្រះរាជាជាសត្រូវណាមួយ គ្របសង្កត់បានលំបាក ។ ពាក្យអាចារ្យទាំងនោះ និងមានប្រយោជន៍អ្វី ។ ពាក្យថា រាជគ្រឹះនោះ ជាឈ្មោះរបស់នគរនោះ ។ ក៏នគររាជគ្រឹះនេះ នោះជាក្រុងនៅក្នុងសម័យពុទ្ធកាល និងសម័យស្តេចចក្រពត្តិ ប៉ុណ្ណោះ ក្នុងកាលដទៃជាក្រុងទទេ ពួកយក្ខគ្រប់គ្រងក្ងាយជាទីនៅរបស់ពួកយក្ខទាំងនោះ ។ ពាក្យថា* **វេឡុវនំ** *ក្នុងពាក្យថា* **វេឡុវនេ កលន្ទកនិវាបេ** *ជាឈ្មោះរបស់វិហារនោះ ។ បានឮថា វត្តវេឡុវ័ននោះលោមព័ទ្ធដោយកំពែងកម្ពស់ ១៨ ហត្ថ ប្រដាប់ដោយគន្ធកុដិធំ សមគួរជាទីប្រថាប់នៅរបស់ព្រះពុទ្ធជាព្រះដ៏មានព្រះភាគ និងដោយវត្ថុដទៃ មានប្រាសាទ កុដិ លេណដ្ឋាន មណ្ឌបទីចង្ក្រម និងស៊ុមទ្វារជាដើម ខាងក្រៅព័ទ្ធព័ទ្ធដោយឫស្សីមានពណ៌ខៀវ គួររីក-រាយ ព្រោះដូច្នោះ ទើបហៅថា* ***វេឡុវ័ន*** *។ ហៅថា* ***កលន្ទកនិវាបៈ*** *ព្រោះជាទីឱ្យចំណីដល់ពួកកង្កែន ។ បានឮថា សម័យមុន ព្រះរាជាមួយព្រះអង្គ ស្តេចប្រពាតព្រះរាជឧទ្យានៃ ទ្រង់ស្រវឹង ទឹកចណ្ឌ (សុរា) ទើបផ្ទំក្នុងវេលាថ្ងៃ ចំណែកបរិវារបស់ព្រះរាជានោះ គិតថា ព្រះរាជាផ្ទំលក់ហើយ ត្រូវលួងលោមដោយផ្ការ៉ាយ និងផ្លែឈើ ទើបជៀសទៅអំពីទីនោះ ។ ។ ត្រានោះ ពស់ដែកលួនចេញ*

អំពីប្រហោងឈើមួយដើមដោយក្ងិនសុភ ហើយលូនទៅត្រង់ព្រះកន្ត្រៃរបស់ព្រះរាជា ។ រុក្ខទេវតាឃើញដូច្នោះ ទើបគិតថា យើងនឹងជួយជីវិតព្រះរាជា ទើបប្ដូរកេទជាកង្កែនទៅស្រែកឡើងក្បែរព្រះកណ្ណៈ (ត្រចៀក) របស់ព្រះរាជា ។ ព្រះរាជាទ្រង់តើនពីផ្ទំ ពស់ដែកក៏លូនត្រឡប់ទៅវិញ ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ទើបទ្រង់ព្រះតម្រិះថា កង្កែននេះឱ្យជីវិតយើង ទើបទ្រង់ព្រះរាជទាន ចំណីដល់ពួកកង្កែនក្នុងទីនោះ និងទ្រង់ឱ្យប្រកាសប្រទានអភ័យ ព្រោះដូច្នោះ តាំងពីនោះមក ទីនោះទើបហៅថា **កលន្ទកនិវាបៈ** ក៏ពាក្យថា **កលន្ទកៈ** ជាឈ្មោះរបស់ពួកកង្កែន ។ ក្នុងវត្តវេឡុវ័ន កលន្ទកនិវាបៈ នោះ ។

បទថា **មហាកស្សបោ** សេចក្ដីថា ឈ្មោះថា **មហាកស្សបៈ** ព្រោះជាព្រះកស្សបៈជាធំ ប្រកបដោយគុណដ៏ធំមានសីលក្ខន្ធជាដើម ។ ម្យ៉ាងទៀត ព្រះមហាថេរៈអង្គនេះហៅថា មហាកស្សបៈ ព្រោះប្រៀបធៀបនឹងព្រះកុមារ-កស្សបត្ថេរ ។ បទថា **បិប្ផលិគុហាយំ** សេចក្ដីថា បានឮថា ដែលជិតទ្វារ ល្អាងនោះមានដើមដ៏ប្ញី[1]មួយដើម ព្រោះដូច្នោះ ល្អាងនោះ ទើបប្រាកដថា **បិប្ផលិ-គុហា** ។ ទីល្អាងបិប្ផលិគុហានោះ ។ បទថា **អាពាធិកោ** សេចក្ដីថា ឈ្មោះថា **អាពាធិកៈ** ព្រោះមានអាពាធ អធិប្បាយថា ព្រោះមានជំងឺ ។ បទថា **ឧក្ខិតោ**

១-ឈ្មោះវល្លិឡើងជន្ទង់មួយប្រភេទ (ពួកម្រេច) ផ្លែមូលទ្រវែង មានរសជាតិហឹរ សម្រាប់ប្រើជាថ្នាំក្ដៅ ឬជាគ្រឿងសម្ង, ច្រើនដាំឱ្យវារតោងឡើងឈើស្រស់ ទំព័រ ៣០៧ ។ (វចនានុក្រមសម្ដេច-ព្រះសង្ឆរាជ **ជោតញ្ញាណោ ជួន ណាត**)។

សេចក្ដីថា ឈ្មោះថា មានទុក្ខព្រោះកើតទុក្ខ ដែលពឹងអាស្រ័យនឹងកាយ អធិប្បាយថា ប្រសប់ទុក្ខ ។ បទថា **ពាឬ្ហគិលានោ** *បានដល់ អ្នកមានអាពាធ ឈឺធ្ងន់ ។ តែព្រះមហាកស្សប: មានសតិសម្បជញ្ញ: អត់ធ្មត់នឹងជំងឺនោះបាន ។ កាលព្រះដ៏មានព្រះភាគទ្រង់ជ្រាបហេតុនោះរបស់ព្រះថេរ: ទើបស្ដេចយាងទៅក្នុងទីនោះ ត្រាស់ពោជ្ឈង្គបរិត្ត ។ ដោយពោជ្ឈង្គបរិត្តនោះឯង ព្រះថេរ:ទើបជាសះស្បើយអំពីអាពាធនោះ ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងពោជ្ឈង្គសំយុត្តថា*

សម័យនោះឯង ព្រះមហាកស្សប:ដ៏មានអាយុគង់នៅក្នុងបិប្ផលិគុហា លោកមានអាពាធ ដល់ទូវសេចក្ដីទុក្ខ មានជំងឺជាទម្ងន់ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហ-សម័យ ទ្រង់ចូលទៅរកព្រះមហាកស្សប:ដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសន:ដែលគេក្រាលទុក ។ លុះព្រះដ៏មានព្រះភាគគង់ហើយ ទ្រង់មានព្រះពុទ្ធដីកានឹងព្រះមហាកស្សប:ដ៏មានអាយុដូច្នេះថា ម្នាលកស្សប: សរីរយន្ដរបស់អ្នក ល្មមអត់ធន់បានខ្លះដែរឬ ល្មមឱ្យប្រព្រឹត្ដទៅបានដែរឬ ទុក្ខវេទនាធូរថយ មិនចម្រើនឡើង មានតែស្រាកស្រាន្ដទៅ មិនរឹតឡើងទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន សរីរយន្ដរបស់ខ្ញុំព្រះអង្គ មិនល្មមអត់ធន់បានទេ ឱ្យប្រព្រឹត្ដទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គក្ងៀវក្ងាខ្ចាំងណាស់ មិនធូរថយទេ មានតែរឹតឡើង មិនស្រាកស្រាន្ដទេ ។

ម្នាលកស្សប: ពោជ្ឈង្គទាំង ៧ នេះ ដែលតថាគតសម្ដែងប្រពៃហើយ បានចម្រើនហើយ ធ្វើឱ្យរឿយ ៗ ហើយ តែងប្រព្រឹត្ដទៅដើម្បីដឹងចំពោះ ដើម្បី

ត្រាស់ដឹង ដើម្បីនិព្វាន ។ ពោជ្ឌង្គ្គទាំង ៧ តើអ្វីខ្លះ ។

ម្នាលកស្សប: សតិសម្ពោជ្ឌង្គ្គដែលតថាគតបានសម្តែងប្រាប់ប្រពៃហើយ ចម្រើនហើយ ធ្វើឱ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ល ។ ម្នាលកស្សប: ឧបេក្ខាសម្ពោជ្ឌង្គ្គដែលតថាគតសម្តែងប្រាប់ប្រពៃហើយ ចម្រើនហើយ ធ្វើឱ្យរឿយ ។ ហើយ តែងប្រព្រឹត្តដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលកស្សប: ពោជ្ឌង្គ្គទាំង ៧ នេះឯងដែលតថាគតសម្តែងប្រាប់ប្រពៃហើយ ចម្រើនហើយ ធ្វើឱ្យរឿយ ។ ហើយ តែងប្រព្រឹត្តដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។

បពិត្រព្រះដ៏មានព្រះភាគ ពិតមែនហើយ ពោជ្ឌង្គ្គទាំងឡាយ បពិត្រព្រះសុគត ពិតមែនហើយ ពោជ្ឌង្គ្គទាំងឡាយ ។ លុះព្រះដ៏មានព្រះភាគត្រាស់ធម៌នេះចប់ហើយ ។ ព្រះមហាកស្សប:ដ៏មានអាយុ ក៏ត្រេកអរចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ។ ឯព្រះមហាកស្សប:ដ៏មានអាយុ ក៏បានសះស្បើយចាកអាពាធនោះ មួយទៀត អាពាធនោះ ក៏ព្រះមហាកស្សប:ដ៏មានអាយុបានលះ បង់យ៉ាងនោះហើយ[1] ។

ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ អាយស្មា មហាកស្សបោ អបរេន សមយេន តម្ហា អាពាធា វុដ្ឋាសិ** លុះក្នុងសម័យខាងក្រោយមក ព្រះមហាកស្សប:ដ៏មានអាយុសះស្បើយចាកអាពាធនោះ ។

បទថា **ឯតទហោសិ** សេចក្តីថា ព្រះមហាកស្សប:ធាន់បិណ្ឌបាតដែល

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៧ ទំព័រ ២០៥ ដល់ ២០៧ ។

សទ្ធិវិហារិកនាំចូលទៅប្រគេនក្នុងថ្ងៃជាពីជំងឺក្នុងកាលមុន ក៏បាននៅក្នុងវិហារ នោះឯង ។ កាលដែលព្រះថេរៈជាសះស្បើយពីអាពាធនោះហើយ មានសេចក្តី បរិវិតក្កៈនេះថា អាត្មាអញគប្បីត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះដូចម្តេចហ្ន៎ ។ បទថា **បញ្ចមត្តានិ ទេវតាសតានិ** *បានដល់ នាងអប្សរអ្នកមានជើងដែលមាន ពណ៌ដូចជាពណ៌នៃជើងសត្វព្រាប ចំនួន ៥០០ នាក់ ជាអ្នកបម្រើស្តេចសក្ក-ទេវរាជ ។ បទថា* **ឧស្សុក្កំ អាបន្នានិ ហោន្តិ** *សេចក្តីថា នាងអប្សរទាំងនោះ គិតនឹងប្រគេនបិណ្ឌបាតដល់ព្រះថេរៈ ទើបត្រៀមបិណ្ឌបាត ៥០០ ភាជន៍ ដែល ដាក់ភាជនៈមាសយកទៅឈរចន្ទោះផ្លូវ ពោលបណ្តើរថា បពិត្រលោកម្ចាស់ដ៏ ចម្រើន សូមលោកម្ចាស់ទទួលបិណ្ឌបាតនេះ សូមសង្គ្រោះពួកខ្ញុំម្ចាស់ ហើយក៏ ខ្ជិលខ្ជាយក្នុងការប្រគេនបិណ្ឌបាត ។ ព្រោះហេតុនោះ លោកទើបពោលថា* **អាយស្មតោ មហាកស្សបស្ស បិណ្ឌាចាតបដិលាភាយ** *បម្រុងឱ្យព្រះមហា-កស្សបៈដ៏មានអាយុបានបិណ្ឌបាត ។*

បានឮថា ស្តេចសក្កទេវរាជជ្រាបការប្រព្រឹត្តទៅនៃចិត្តរបស់ព្រះថេរៈ ទើបបញ្ជូននាងអប្សរទាំងនោះទៅដោយព្រះតម្រាស់ថា នាងទាំងឡាយចូរទៅ ប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្តេរជាម្ចាស់នៃយើង ហើយចូរធ្វើសេចក្តី ប្រាថ្នារបស់ខ្លួនចុះ ។ មែនពិត ស្តេចសក្កទេវរាជមានព្រះតម្រិះយ៉ាងនេះថា បណ្តា នាងអប្សរទាំងអស់នេះដែលទៅដល់ ពេលខ្ជះព្រះថេរៈគប្បីទទួលបិណ្ឌបាតអំពី ដៃរបស់នាងអប្សរសូម្បីត្រឹមតែមួយនាក់ ប្រការនោះនឹងជាប្រយោជន៍និងសេចក្តី សុខដល់នាងរហូតដល់អស់កាលយូរ ។ ព្រះថេរៈហាមនាងអប្សរអ្នកកំពុងនិយាយ ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទទួលបិណ្ឌបាតរបស់ខ្ញុំម្ចាស់

សូមលោកម្ចាស់ទទួលបិណ្ឌបាតរបស់ខ្ញុំម្ចាស់ ហើយព្រះថេរៈពោលថា នាងទាំង-ឡាយបានធ្វើបុណ្យទុកហើយ មានកោគៈច្រើន ចូរជៀសចេញទៅ អាត្មានឹងសង្គ្រោះដល់អ្នកក្រខ្សត់ ហើយទើបហាមឃាត់ពួកនាងអប្សរម្តងទៀត ដែលកំពុងពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំធ្វើពួកខ្ញុំម្ចាស់ឱ្យវិនាសឡើយ សូមសង្គ្រោះពួកខ្ញុំម្ចាស់ផង ទើបពោលចំពោះនាងអប្សរដែលមិនជៀសចេញទៅ នៅតែនិយាយដដែល ៗ ថា នាងទាំងឡាយមិនស្គាល់ប្រមាណរបស់ខ្លួនសោះ នាងទាំងឡាយចូរជៀសចេញទៅ ។ នាងអប្សរទាំងនោះបានឮសំឡេងដេញរបស់ព្រះថេរៈ កាលមិនអាចនឹងតាំងនៅបាន ទើបគេចជៀសទៅកាន់ទេវ-លោកដូចដើម ។ ព្រោះហេតុនោះ លោកទើបពោលថា **បញ្ចមត្តានិ ទេវតា-សតានិ បដិក្ខិបិត្វា** *សេចក្ដីថា ហាមទេវតាចំនួន ៥០០ រូប ។*

បទថា **បុព្ពណ្ហសមយំ** *បានដល់ សម័យមួយ គឺវេលាមួយក្នុងពេលព្រឹក ។ បទថា* **និវាសេត្វា** *សេចក្ដីថា ស្ងៀកដណ្ដប់យ៉ាងរឹងមាំ ដោយការផ្ចាស់គ្រឿងស្ងៀកដណ្ដប់ក្នុងព្រះវិហារ ។ បទថា* **បត្តចីវរមាទាយ** *សេចក្ដីថា ដណ្ដប់ចីវរហើយកាន់បាត្រ ។ បទថា* **បិណ្ឌាយ ចាវិសិ** *បានដល់ ចូលទៅបិណ្ឌបាត ។ បទថា* **ឧលិទ្ធវិសិកា** *បានដល់ អាវាសជាទីនៅរបស់អ្នកក្រខ្សត់ ។ បទថា* **ឆបណវិសិកា** *បានដល់ ទីនៅរបស់អ្នកក្រលំបាក ព្រោះដល់ទូវកាពសាបសូន្យអស់កោគៈ ។ បទថា* **បេសការវិសិកា** *បានដល់ ទីនៅរបស់ជាងតម្បាញ ។ បទថា* **អទ្ធសា ខោ ភគវា** *សេចក្ដីថា ព្រះដ៏មាន-ព្រះភាគទ្រង់ឃើញនូវអ្វី ព្រះដ៏មានព្រះភាគទ្រង់រំពឹងថា កស្សបៈបុត្ររបស់*

តថាគត ជាសះស្បើយពីអាពាធហើយ កំពុងធ្វើអ្វីហ្ន៎ ទាំងដែលប្រថាប់គង់ក្នុងវត្តវេឡុវ័ននុ៎ះឯង ទ្រង់បានឃើញដោយទិព្វចក្ខុ ។

បទថា **ឯតមត្ថं វិទិត្វា** *សេចក្តីថា ព្រះដ៏មានព្រះភាពទ្រង់ជ្រាបសេចក្តីដែលព្រះមហាកស្សប:ហាមបិណ្ឌបាតទិព្វ មានសូប: (សម្ប) និងព្យញ្ជន: (ម្ហូបក្រៀម) យ៉ាងច្រើន ដែលនាងអប្សរ ៥០០ រូប នាំយកទៅប្រគេន ហើយសម្តែងដល់ការប្រតិបត្តិក្នុងការអនុគ្រោះមនុស្សទុគ្គត ។ បទថា* **ឥមं ឧជ្ជាលं** *បានដល់ ព្រះដ៏មានព្រះភាគទ្រង់បន្ទឹនូវឧទាននេះ ដែលសម្តែងអានុភាពនៃសេចក្តីរឹងមាំរបស់ព្រះខីណាស្រព ដោយសម្តែងភាពជាអ្នកប្រាជ្ញាតិចជាប្រធាន ។*

បណ្តាបទទាំងនោះ បទថា **អនញ្ញចោសី** *សេចក្តីថា ឈ្មោះថា* ***អញ្ញចោសី*** *ព្រោះចិញ្ចឹមអ្នកដទៃ អ្នកមិនចិញ្ចឹមអ្នកដទៃ ឈ្មោះថា* ***អនញ្ញចោ-សី*** *អធិប្បាយថា ឈ្មោះថា មិនមានសម្ងាញ់ជាគម្រប់ពីរ គឺជាអ្នកតែម្នាក់ឯង ព្រោះមិនមានអ្នកដទៃដែលខ្ជូននឹងត្រូវចិញ្ចឹម ។ ដោយពាក្យនោះ លោកសម្តែងដល់ព្រះថេរ:ជាអ្នកចិញ្ចឹមងាយ ។ មែនពិត ព្រះថេរ:ចិញ្ចឹមខ្ជូនឯង ដោយចីវរជាគ្រឿងរក្សាកាយ និងដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ឈ្មោះថា ជាអ្នកប្រាជ្ញាតិចយ៉ាងក្រៃលែង ។ មិនចិញ្ចឹមនរណាម្នាក់ មានញាតិមិត្តជាដើម ព្រោះជាអ្នកមិនជាប់ក្នុងអារម្មណ៍ណានិមួយ ។ ម្យ៉ាងទៀត ឈ្មោះថា* **អនញ្ញចោសី** *ព្រោះមិនមានការ:ដែលខ្ជូន និងអ្នកដទៃអ្នកណាមួយនឹងគប្បីចិញ្ចឹម ។ សេចក្តីពិត អ្នកដែលមានបច្ច័យ ៤ ជាប់ក្នុងទាយកអ្នកឱ្យបច្ច័យសូម្បីតែម្នាក់ប៉ុណ្ណោះ មិនឈ្មោះថា* **អនញ្ញចោសី** *ទេ ព្រោះមានការប្រព្រឹត្តជាប់នឹងបុគ្គលម្នាក់ ។ ចំណែកព្រះថេរ:អាស្រ័យកម្ទាំងស្មងជើង ហើយត្រាច់បិណ្ឌបាត ដោយន័យ*

ដូចពោលក្នុងគាថាមានជាអាទិ៍ថា **យថាបិ ភមរោ បុប្ផំ** ដូចជាភមរជាតិ មិនធ្វើផ្ការណ្ណៃដែលមានពណ៌ និងក្លិនឱ្យវិនាសទេ[១] ។ ជាអ្នកថ្មីក្នុងត្រកូលទាំងឡាយជានិច្ច ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយអាហារដែលលាយ ។ ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគទ្រង់សរសើរអ្នកនោះដោយបដិបទា ដែលប្រៀបផ្ទឹមដោយព្រះចន្ទ ។ បទថា **អញ្ញាតំ** ប្រែថា មានកេរ្តិ៍ឈ្មោះប្រាកដ គឺមានកិត្តិយសផ្សាយទៅដោយគុណតាមសេចក្តីពិត ។ ម្យ៉ាងទៀត ឈ្មោះថា មានកេរ្តិ៍ឈ្មោះប្រាកដ ព្រោះជាអ្នកប្រាថ្នាតិច សន្តោសដោយការៈដែលមិនត្រូវចិញ្ចឹមអ្នកដទៃនោះនុ៎ះឯង ។ ម្យ៉ាងទៀត បទថា **អញ្ញាតំ** ឈ្មោះថា ដែលអ្នកដទៃមិនស្គាល់ ដោយឱ្យអ្នកដទៃស្គាល់ខ្លួន ព្រោះមិនប្រាថ្នាលាភ សក្ការៈ និងកេរ្តិ៍ឈ្មោះ ព្រោះលះតណ្ហាបានហើយដោយប្រការទាំងពួង ។ មែនពិត អ្នកមានតណ្ហា នៅមិនទាន់លះ មានសេចក្តីប្រាថ្នាលាមក រមែងឱ្យអ្នកដទៃស្គាល់ខ្លួន ដោយប្រាថ្នាការលើកតម្កើងដោយការបញ្ជោតបន្ទំ ។ បទថា **ឧត្តំ** សេចក្តីថា ទូន្មានខ្លួនហើយ ព្រោះអត្ថថា ទូន្មានខ្លួនយ៉ាងខ្ពស់បំផុត ក្នុងឥន្ទ្រិយទាំងឡាយ ដោយអំណាចឆឡង្គុបេក្ខា (ឧបេក្ខាមានអង្គ ៦) ។ បទថា **សាវេ បតិដ្ឋិតំ** បានដល់ តាំងចុះក្នុងវិមុត្តិសារៈ ឬតាំងនៅក្នុងសីលសារៈជាដើម មានសីលខន្ធ ដែលជារបស់ព្រះអសេក្ខៈជាដើម ។ បទថា **ខីណាសវំ វន្តទោសំ** សេចក្តីថា ឈ្មោះថា ***ខីណាសវៈ*** ព្រោះលះអាសវៈ ៤ មានកាមាសវៈជាដើម បានដោយមិនឱ្យសេសសល់ ក្រៅពីនោះឯង ឈ្មោះថា ***វន្តទោសៈ*** ព្រោះខ្ជាក់ទោសមានរាគៈជា

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៣១ ។

ដើមបានដោយប្រការទាំងពួង ។ បទថា **តម្ហំ ព្រូមិ ព្រាហ្មណំ** *សេចក្ដីថា យើងពោលបុគ្គលនោះ គឺបុគ្គលដែលជាព្រាហ្មណ៍ដោយបរមត្ថ ដែលមានគុណតាមដែលពោលហើយថា ជាព្រាហ្មណ៍ ។ សូម្បីក្នុងទីនេះ គប្បីជ្រាប សេចក្ដីផ្សេងគ្នានៃទេសនា ដោយន័យដូចពោលហើយ ក្នុងកាលមុននោះឯង ។*

ឆដ្ឋសុត្តវណ្ណនា និដ្ឋិតា ។

ចប់អដ្ឋកថាសូត្រទី ៦ ។

៧. ចាវាសុត្តវណ្ណនា[1]

អដ្ឋកថាឆាវាសូត្រ

ចាវាសូត្រទី ៧ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ចាវាយំ** *បានដល់ ជិតក្រុងរបស់ស្តេចមល្ល: ដែលមានឈ្មោះ យ៉ាងនោះ ។ បទថា* **អជកលាបកេ ចេតិយេ** *បានដល់ ក្នុងទីដែលពួក មនុស្សកោតក្រែង ដែលបាននាមថា* ***អជកលាបក:*** *ព្រោះយក្ខឈ្មោះថា* ***អជក-លាបក:*** *គ្រប់គ្រង ។ បានឮថា យក្ខនោះទទួលពលីកម្មដោយកោដ្ឋាសនៃពពែ ដោយការចងពពែឱ្យជាក្រុមៗ មិនមែនទទួលដោយប្រការដទៃទេ ព្រោះដូច្នោះ ទើបប្រាកដឈ្មោះថា អជកលាបកយក្ខ ។ តែអាចារ្យពួកខ្លះពោលថា ឈ្មោះថា អជកលាបកយក្ខ ព្រោះញ៉ាំងពួកសត្វឱ្យស្រែកដូចពពែ បានឮថា ក្នុងវេលា ដែលពួកមនុស្សនាំពលីកម្មទៅឱ្យដល់អជកលាបកយក្ខ ស្រែកសំឡេងខ្លាំងដូច ពពែ ហើយនាំពលីកម្មចូលទៅ យក្ខនោះក៏ត្រេកអរ ព្រោះដូច្នោះ ទើបគេហៅថា* ***អជកលាបកយក្ខ*** *។ ក៏យក្ខសម្ផ្ទុរដោយអានុភាព ជាអ្នករឹងរុះ មានពាក្យអាក្រក់ និងស្ថិតនៅទីនោះ ព្រោះដូច្នោះ ពួកមនុស្សទើបធ្វើទីនោះឱ្យជាទីគោរពកោត-ក្រែង បង្ហោនៗនាំពលីកម្មចូលទៅរហូតដល់អស់កាលតាមកាល ។ ព្រោះហេតុ នោះ លោកទើបពោលថា* **អជកលាបកេ ចេតិយេ** *។ បទថា* **អជកលាប-កស្ស យក្ខស្ស ភវនេ** *បានដល់ វិមានរបស់យក្ខនោះ ។*

បានឮថា ក្នុងគ្រានោះ ព្រះសាស្តាប្រាថ្នានឹងទូន្មានយក្ខនោះ ក្នុងវេលា ល្ងាច ព្រះអង្គតែមួយអង្គឯងមិនមានបុគ្គលជាគម្រប់ពីរ ទ្រង់កាន់បាត្រ និងចីវរ ហើយស្តេចយាងទៅកាន់ទ្វារនៃវិមានរបស់អជកលាបកយក្ខ ទើបអង្វរនាយទ្វារ

១-ក្នុងអដ្ឋកថាច្បាប់ឆដ្ឋសង្គាយនា ព្រះសូត្រនេះមានឈ្មោះថា **អជកលាបកសុត្តវណ្ណនា** *។*

របស់យក្ខនោះ ដើម្បីស្តេចយាងចូលទៅកាន់ទីនៅ ។ នាយទ្វារនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន អជកលាបកយក្ខជាយក្ខរឹងរុះ មិនធ្វើសេចក្តីគោរពថាជាសមណៈ ឬព្រាហ្មណ៍ទេ ព្រោះដូច្នោះ សូមព្រះអង្គនិមន្តជ្រាបចុះ តែខ្ញុំព្រះអង្គ មិនប្រាប់ដល់យក្ខនោះមិនសមគួរទេ ហើយទើបប្រញាប់ទៅកាន់ទីនៅរបស់អជកលាបកយក្ខអ្នកទៅសមាគមយក្ខក្នុងខណៈនោះឯង ។ ព្រះសាស្តាស្តេចយាងចូលទៅខាងក្នុងទីនៅរបស់យក្ខនោះ ហើយប្រថាប់គង់លើបញ្ញត្តាសនៈ ក្នុងមណ្ឌប ដែលជាទីអង្គុយរបស់អជកលាបកយក្ខ ។ ពួកស្ទ្រីរបស់យក្ខចូលទៅគាល់ព្រះសាស្តាថ្វាយបង្គំ ហើយបានឈរក្នុងចំណែកម្ខាង ។ ព្រះសាស្តាបានសម្តែងធម្មីកថាដែលគួរដល់វេលាដល់ស្ទ្រីទាំងនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ប្រថាប់នៅត្រង់អជកលាបកចេតិយដែលជាទីនៅរបស់អជកលាបកយក្ខ ជិតក្រុងបាវា ។

សម័យនោះ សាតាគិរិយក្ខ និងហេមវតយក្ខ ទៅកាន់សមាគមយក្ខ ដោយហោះកាត់ដំបូលវិមានរបស់អជកលាបកយក្ខ កាលខ្ជួនទៅមិនបាន ទើបរំពឹងថា នឹងមានហេតុអ្វីហ្ន៎ ក៏ឃើញព្រះដ៏មានព្រះភាគកំពុងប្រថាប់គង់នៅក្នុងវិមានរបស់អជកលាបកយក្ខ ទើបចូលទៅថ្វាយបង្គំព្រះដ៏មានព្រះភាគក្នុងទីនោះ ទើបទូលលាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ នឹងទៅកាន់សមាគមរបស់យក្ខ ធ្វើប្រទក្សិណជៀសចេញទៅ ឃើញអជកលាបកយក្ខក្នុងទីសន្និបាតយក្ខ ទើបសម្តែងសេចក្តីត្រេកអរថា នែ៎អជកលាបកៈដ៏ចម្រើន ពិតជាលាភរបស់អ្នកឯងមែន ព្រះដ៏មានព្រះភាគជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ប្រថាប់គង់

ក្នុងទីលំនៅរបស់អ្នក អ្នកចូរចូលទៅគាល់អង្គុយជិតព្រះដ៏មានព្រះភាគនិងស្តាប់ធម៌ចុះ ។ អជកលាបកយក្ខនោះ បានស្តាប់ពាក្យរបស់សាតាគិរិយក្ខ និងមេហ-រតយក្ខនោះ ហើយគិតថា ពួកយក្ខទាំងនេះបានប្រាប់ថា សមណៈត្រដោលអង្គុយក្នុងទីនៅរបស់យើង ទើបត្រូវសេចក្តីក្រោធគ្របសង្កត់ គិតថា ថ្ងៃនេះ យើងនឹងធ្វើសង្គ្រាមនឹងសមណៈនោះ ទើបក្រោកឡើងចាកសន្ទិបាតយក្ខ លើកជើងស្តាំជាន់កំពូលភ្នំប្រមាណ ៦០ យោជន៍ កំពូលភ្នំនោះបានចែកចេញជា ២ ភាគ ។ ក៏ពាក្យដែលគួរនឹងពោលក្នុងទីនោះ គប្បីជ្រាបដោយន័យដែលមកក្នុងអដ្ឋកថាអាឡវកសូត្រនុ៎ះឯង ។

មែនពិត សមាគមរបស់អជកលាបកយក្ខ ដូចជាសមាគមរបស់អាឡវ-កយក្ខនុ៎ះដែរ តែរៀរការសួរបញ្ហា ការដោះស្រាយបញ្ហា និងការបណ្តេញចេញចាកទីនៅនិងការចូលទៅ ៣ ដង ។ ក៏ឈ្មួមអជកលាបកយក្ខមកដល់ប៉ុណ្ណោះ ក៏គិតថា យើងនឹងដេញសមណៈនោះដោយក្ងៀងទាំងនេះ ទើបធ្វើក្ងៀង ៩ ប្រភេទ មានមណ្ឌលខ្យល់ជាដើមឱ្យតាំងឡើង កាលមិនអាចធ្វើសូម្បីត្រឹមតែឱ្យព្រះដ៏មានព្រះភាគកម្រើកដោយក្ងៀងទាំងនោះបាន ទើបនិម្មិតពួកកូតមានរូបគួរភ័យខ្លាចយ៉ាងក្រៃលែង កាន់គ្រឿងប្រហារមានប្រភេទផ្សេងៗ ចូលទៅរកព្រះដ៏មានព្រះភាគព្រមនឹងកូតទាំងនោះត្រាច់ទៅជុំវិញៗ សូម្បីធ្វើអាការប្ងៃកៗមានប្រការផ្សេងៗ រហូតដល់អស់មួយយប់ទល់ភ្លឺ ក៏មិនអាចនឹងធ្វើព្រះដ៏មានព្រះភាគឱ្យឃ្លាតចាកទីដែលប្រថាប់គង់ សូម្បីត្រឹមតែប៉ុនសរសៃសក់ ។ អជក-លាបកយក្ខក៏ក្តៅឡើងដោយអំណាចសេចក្តីក្រោធតែម្យ៉ាងថា សមណៈនេះមិនប្រាប់ដល់យើងឡើយ ហើយចូលទៅអង្គុយក្នុងវិមានរបស់យើង ។ លំដាប់

នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបការប្រព្រឹត្តទៅនៃចិត្តរបស់យក្ខនោះ ទើបទ្រង់មានព្រះតម្រិះថា បុគ្គលវាយត្រង់ច្រមុះឆ្កែកាច កាលបើយ៉ាងនេះ ឆ្កែនោះគប្បីជាសត្វកាចលើសប្រមាណក្រៃលែងឡើង សូម្បីយ៉ាងណា យក្ខនេះក៏ដូច្នោះដែរ កាលយើងអង្គុយក្នុងទីនេះក៏ក្រេវក្រោធ ដូចម្តេចហ្ន៏ យើងគប្បីចេញទៅខាងក្រៅ ហើយព្រះអង្គតែមួយអង្គឯង ក៏ស្តេចយាងចេញអំពីវិមាន ប្រថាប់ឋដ៏អាកាស ។ ព្រោះហេតុនោះ លោកទើបពោលថា សម័យនោះ ព្រះដ៏មាន-ព្រះភាគទ្រង់ក្នុងទីវាលនៅវាត្រីងងឹតអ័ព្ទ ។

បណ្តាបទទាំងនោះ បទថា **រត្តន្ធការតិមិសាយំ** ប្រែថា ក្នុងវេលាងងឹតអ័ព្ទក្នុងរាត្រី អធិប្បាយថា ក្នុងសេចក្តីងងឹតស្ទុង រៀរការកើតចក្ខុវិញ្ញាណ ។ បានឮថា គ្រានោះ សេចក្តីងងឹតប្រកបដោយអង្គ ៤ កើតឡើង ។ បទថា **ឧដេ** បានដល់ មេឃញ្ចាំងតំណក់ទឹកភ្ងៀងជាគ្រាប់ៗ ឱ្យធ្លាក់ចុះ ។ លំដាប់នោះ យក្ខគិតថា យើងនឹងឱ្យសមណៈនេះកន្ត្រាក់ព្រឺព្រួចដោយសំឡេងនេះ ហើយជៀសចេញទៅ ទើបទៅកាន់ទីជិតព្រះដ៏មានព្រះភាគ ហើយធ្វើសំឡេងដែលគួរខ្ជាប ដោយន័យមានជាអាទិ៍ថា អក្ខុលៈ ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា **អថ ខោ អជកលាបកោ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភយំ** បានដល់ សេចក្តីតក់ស្ទុតនៃចិត្ត ។ បទថា **ឆម្ភិតត្តំ** បានដល់ ភាវៈដែលសរីរៈកន្ត្រាក់ព្រឺព្រួច មានអាការរឹង ។ បទថា **លោមហំសំ** បានដល់ ភាវៈដែលរោមបះឡើង ។ ដោយបទទាំង ៣ លោកសម្តែងចំពោះការកើតនូវភ័យ ។ បទថា **ឧបសង្ក្រមិ** សួរថា ព្រោះហេតុអ្វី

យក្ខនេះមានសេចក្តីប្រាថ្នាយ៉ាងនេះចូលទៅរក បានធ្វើអាការបែក ដែលខ្លួនធ្វើទុកក្នុងកាលមុនពិតមែនឬ? ធ្វើយថា បានធ្វើពិត តែយក្ខនោះសម្គាល់ថា យើងមិនអាចធ្វើអ្វីៗ ដល់សមណៈអ្នកប្រថាប់នៅក្នុងខាងក្នុងទីនៅ ជាទីរួចផុតកំយ ជាផ្ទៃដីដ៏រឹងមាំ ឥឡូវនេះ យើងអាចឱ្យសមណៈអ្នកនៅខាងក្រៅកំយព្រឺ-ព្ជួចយ៉ាងនេះហើយគេចជៀសទៅ ទើបចូលទៅរកព្រះដ៏មានព្រះភាគនោះ ។ មែនពិត យក្ខនេះសម្គាល់ទីនៅរបស់ខ្លួនថា រឹងមាំ និងសម្គាល់ថា សមណៈនេះមិនខ្ជាច ព្រោះនៅក្នុងទីនៅរបស់ខ្លួននោះ ។

បទថា **តិក្ខត្តុं អ្ក្ករ្ណោ បក្ខ្ជិលោតិ អ្ក្ករ្ណលបក្ករ្ណលិកំ អ្ករ្ណសិ** *សេចក្តីថា យក្ខបានធ្វើសំឡេងបែបនេះថា* **អ្ក្ករ្ណោ បក្ករ្ណោ** *៣ ដង ដើម្បីប្រាថ្នាឱ្យព្រះអង្គកំយព្រឺព្ជួច ។ សេចក្តីពិត នេះជាសំឡេងធ្វើតាម ។ ព្រោះថា គ្រានោះយក្ខនោះ ដូចជាអ្នកវិសេសលើកភ្នំសិនេរុ និងដូចជាការត្រឡប់ផែនដីធំ ដូចជាសន្ធឹកជើងសេះរាប់រយរត់មកដោយសេចក្តីព្យាយាមយ៉ាងធំ ដូចសំឡេងពោទ៍របស់ដំរីប្រចាំទិស ដែលរួមគ្នាជាហ្វូងក្នុងទីតែមួយគ្នា ហើយថ្ងៃងចេញ ដូចបន្ទឹសីហនាទរបស់រាជសីហ៍ ដូចសំឡេងច្រណែនរបស់ពួកយក្ខ ដូចសំឡេងសើចរបស់ពួកកូត ដូចសំឡេងទះដៃរបស់ពួកអសុរ ដូចសំឡេងគឹកកង នៃវជិរាវុធដែលស្ដេចទេវរាជវាយចុះមក ដូចសំឡេងគឹកកងរបស់ព្យុះធំដែលតាំងនៅរហូតអស់កប្ប ដូចជានឹងសង្កត់សង្ខិន និងគ្របសង្កត់សំឡេងដទៃៗ ព្រោះជាសំឡេងជ្រៅធំទូលាយ និងធ្វើសេចក្តីគួរខ្ជាចឱ្យដល់ខ្លួន និងដូចសំឡេងគឹកកងដែលជាកំយចំពោះមុខដ៏ធំ ដូចពុះដួងហទ័យរបស់ពួកបុថុជ្ជន ។ ព្រោះសំឡេងដែលថ្ងៃងចេញ យក្ខគិតថា យើងនឹងឱ្យសមណៈនេះកំយព្រឺព្ជួចដោយ*

សំឡេងនេះ ហើយជៀសចេញទៅ ភ្ជុំក៏បែកជាកំទេច ឫក៏ធ្លាក់ចុះមក ស្លឹកឈើ ផ្ទៃឈើ និងផ្កាឈើក៏លេចបាត់ក្នុងគុម្ពវល្លិ និងគុម្ពោព្រៃទាំងអស់ដែលអាស្រ័យ នៅតាមដើមឈើជាម្ចាស់នៃព្រៃ ក៏ស្រអាប់ចុះ ភ្ជុំហេមពន្តមានកម្រាស់ ៣.០០០ យោជន៍ ក៏ញាប់ញ័រយ៉ាងខ្លាំង សូម្បីពួកទេវតា តាំងពីតកុម្មទេវតា មានសេចក្តីខ្លាច ភ័យព្រឺព្រួច និងបះពោមឡើង នឹងចាំបាច់ពោលទៅថ្វីដល់ពួកមនុស្ស និងសត្វដទៃៗ ដែលមិនមានជើង មានជើង ២ និងមានជើង ៤ សេចក្តីភ័យ ព្រឺព្រួចច្រើន ដូចជាគ្រាផែនដីធំស្រុតចុះ ឫក៏កោលាហលយ៉ាងធំបានកើតឡើង លើផ្ទៃនៃជម្ពូទ្វីបទាំងអស់ ។ ចំណែកព្រះដ៏មានព្រះភាគ មិនបានទ្រង់សម្គាល់សំឡេងនោះថាជាអ្វី ទ្រង់ប្រថាប់គង់ស្ងៀម ទ្រង់អធិដ្ឋានថា ព្រោះហេតុនេះ អន្តរាយកុំមានដល់អ្នកណាៗ ឡើយ ។

ក៏ព្រោះហេតុដែលសំឡេងនោះ មកប្រាកដតាមសោតទ្វាររបស់សត្វទាំងឡាយ ដោយអាការយ៉ាងនេះថា **អ**ក្ខ**ុ**ល: ព**ក**ុ**ល**: ដូច្នោះ លោកអាចារ្យទើបលើកកាន់ការសង្ត្រោះថា យក្ខបានបន្ទឹសំឡេងថា **អ**ក្ខ**ុ**ល: ព**ក**ុ**ল**: ដោយអធិប្បាយថា ឈ្មោះថា **អ**ក្ខ**ុ**ল: ព**ক**ুল: ព្រោះធ្វើតាមសំឡេងនោះ និងថា ការថ្វៃងសំឡេងថា **অ**ক্ষুল: ব**ক**ুল: មាននៅក្នុងការដែលយក្ខបន្ទឹសំឡេងយ៉ាងគឺកកងនោះ ។ តែអាចារ្យពួកខ្លះពោលថា យក្ខបន្ទឹសំឡេងតាមភាសានេះ **অ**ক্ষুল: ব**ক**ুল: ដោយអំណាចនៃឈ្មោះនូវបទទាំងពីរបទថា **অ**কল: ব্যাকুল: ដូចពាក្យថា **ঐ**ক: **ঐ**কক: ។ ព្រោះហេតុដែល **অ** អក្សរ ដែលកើតក្នុងពេលតែមួយ មានអត្ថជាអាទ៍ថា **অ**কুল: ព្រោះកើតបានដោយការកើតគ្រាដំបូងនោះឯង

និងធ្វើ **អា** អក្សរនោះឱ្យមានសំឡេងខ្លីដោយចុះ **ក** អាគមនោះឯង ។ តែដែលកើត ២ វារៈជា **ពក្ខុលៈ** ។ ក៏**ក្ខុ**ល-ស័ព្ទក្នុងទីនេះជាបរិយាយរបស់ជាតិ ដូចក្នុងប្រយោគថា **កោលំកោលៈ** ជាដើម និងការប្រកបស័ព្ទជាការធ្វើត្រាប់សេចក្ដីប្រាថ្នាដែលលោកពោលហេតុនេះ បទទី ១ លោកពោលដល់ជលាពុជៈកំណើត មានសីហៈ និងព្យគ្ឃៈ (ខ្លាធំ) ជាដើម ។ បទទី ២ ពោលដល់អណ្ឌជៈកំណើត មានពស់ និងពស់វែកជាដើម ។ ព្រោះដូច្នោះ អាចារ្យពួកដទៃពោលថា យក្ខសម្ដែងសេចក្ដីនេះដោយពីរបទថា **អហន្តេ ជីវិតហារកោ** យើងនាំជីវិតរបស់លោកទៅ ដូចសីហៈជាដើម និងពស់ជាដើម ។ តែអាចារ្យមួយពួកទៀតពោលបាលីថា **អក្ខុលៈ ភក្ខុលៈ** ហើយពោលសេចក្ដីរបស់ពីរបទ នោះថា ដែលឈ្មោះថា **អក្ខុលៈ** ព្រោះទៅ គឺប្រព្រឹត្តទៅដើម្បីទម្ងាយ គឺឱ្យអស់ទៅ គឺឱ្យវិនាសទៅ ដែលឈ្មោះថា **ភក្ខុលៈ** ព្រោះទៅដើម្បីនឹងស៊ី គឺទំពាស៊ី ។ ក៏អត្ថនោះគឺអ្វី? គឺអ្នកណាៗ មានយក្ខ អារក្សទឹក បីសាច សីហៈ និងព្យគ្ឃៈជាដើម បុគ្គលណាមួយ ជាអ្នកនាំសេចក្ដីវិនាសមកឱ្យដល់ពួកមនុស្ស ។ សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបអធិប្បាយសេចក្ដីដោយន័យដូចពោលហើយក្នុងកាលមុននោះឯង ។

បទថា **ឯសោ តេ សមណ បិសាចោ** សេចក្ដីថា យក្ខនិម្មិតរូបយ៉ាងធំគួរខ្លាច ឈរត្រង់ព្រះកន្ត្រៃព្រះដ៏មានព្រះភាគ ពោលសំដៅដល់ខ្លួនថា នែ៎សមណៈដ៏ចម្រើន បីសាចអ្នកប្រាថ្នាស៊ីសាច់ប្រាកដដល់លោកហើយ ។

បទថា **ឯតមត្ថं វិទិត្វា** សេចក្ដីថា ដឹងប្រការប្ញែកនេះដែលយក្ខនោះ ឱ្យប្រព្រឹត្តទៅតាមកាយ និងវាចា នឹងដឹងសេចក្ដីដែលខ្លួនអស់ឧបក្លិសក្នុងលោកធម៌ ជាហេតុនៃអាការដែលយក្ខនោះគ្របសង្កត់គំរាមមិនបាន ដោយអាការ

ទាំងពួង ។ បទថា **តាយំ វេលាយំ** បានដល់ វេលាដែលធ្វើអាការប្លែកនោះ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា មិននឹកនូវអាការប្លែកនោះ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទឹនូវឧទាននេះដែលសម្តែងធម្មានុភាព មានការមិននឹកនូវអាការប្លែកនោះជាហេតុ ។

បណ្តាបទទាំងនោះ បទថា **យានិ សកេសុ ធម្មេសុ** បានដល់ ធម៌ គឺ ឧបាទានខន្ធ ៥ ពោលគឺ អត្តភាពរបស់ខ្លួនក្នុងកាលណា ។ បទថា **ចារកូ** សេចក្តីថា អ្នកដល់ត្រើយដោយអំណាចនៃការបរិបូរនូវបរិញ្ញាកិសម័យ តអំពីនោះឯង អ្នកដល់ត្រើយដោយអំណាចនៃការបរិបូរនូវបហានាកិសម័យ សច្ឆិ-កិរិយាកិសម័យ និងភាវនាកិសម័យក្នុងសមុទយ:ជាហេតុនៃឧបាទានខន្ធទាំងនោះ ក្នុងនិរោធដែលមានលក្ខណ:មិនប្រព្រឹត្តទៅតាមសមុទយ:នោះ និងក្នុងនិរោធគាមិនីបដិបទា ។ បទថា **ហោតិ ព្រាហ្មណោ** សេចក្តីថា ឈ្មោះថាជាព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបន្សាត់បង់ហើយដោយប្រការទាំងពួងដូច្នេះ ។ មែនពិត ការត្រាស់ដឹងសច្ច: ៤ រមែងមានសូម្បីដោយការយល់ដឹងអត្តភាពរបស់អ្នកដោយប្រការទាំងពួង ។ សមដូចពាក្យដែលលោកពោលទុកមានជាអាទិ៍ថា ព្រះតថាគតតែងបញ្ញត្តិ (នូវលោក គឺទុក្ខផង) ក្នុងអត្តភាពប្រមាណមួយព្យាមនេះឯង ដែលប្រកបដោយសញ្ញាផង ប្រកបដោយចិត្តផង[1] ។ ម្យ៉ាងទៀត បទ-ថា **សកេសុ ធម្មេសុ** បានដល់ ក្នុងធម៌របស់ខ្លួន ឈ្មោះថា ធម៌របស់ខ្លួន បានដល់ ធម៌ មានសីលជាដើមរបស់បុគ្គលដែលស្រឡាញ់ខ្លួន ។ មែនពិត

១-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៦២ ទំព័រ ១១៧ ។

ពោទានធម៌ មានសីល សមាធិ បញ្ញា និងវិមុត្តិជាដើមឈ្មោះថា ធម៌របស់អ្នក គឺ
របស់ខ្លួន ព្រោះញ៉ាំងហិតសុខឱ្យសម្ជូរដោយចំណែកតែមួយ មិនជាធម៌របស់
អ្នកដទៃ ដូចសង្ខ្លិលេសធម៌ដែលនាំសេចក្ដីវិនាសមកឱ្យ ។ បទថា **ចារកូ** បាន
ដល់ ដល់ត្រើយ គឺទីបំផុតរបស់សេចក្ដីបរិបូរនៃធម៌ មានសីលជាដើមនោះ ។

បណ្ដាធម៌ទាំងនោះ លំដាប់ដំបូង ឈ្មោះថា សីល មាន ២ យ៉ាង គឺ
លោកិយសីល ១ លោកុត្តរសីល ១ ។ បណ្ដាសីលទាំង ២ យ៉ាងនោះ លោកិយ-
សីល ជាសីលខាងដើម ។ សីលខាងដើមនោះពោលដោយសង្ខេបរមែងមាន ៤
យ៉ាង មានបាតិមោក្ខសំវរសីលជាដើម តែពោលដោយពិស្ដារមានច្រើនប្រភេទ ។
លោកុត្តរសីលមាន ២ យ៉ាង គឺមគ្គសីល ១ ផលសីល ១ តែពោលអំពីអត្ត
បានដល់ សម្មាវាចា សម្មាកម្មន្ត: និងសម្មាអាជីវ: ។ ក៏សមាធិ និងបញ្ញាមាន ២
យ៉ាង គឺជាលោកិយ: ១ ជាលោកុត្ត: ១ ដូចសីលដែរ ។ បណ្ដាសមាធិ ២ យ៉ាង
នោះ លោកិយសមាធិ បានដល់ សមាបត្តិ ៨ ព្រមដោយឧបចារ: លោកុត្តរ-
សមាធិ បានដល់ សមាធិដែលរាប់ជាប់ក្នុងមគ្គ ។ ចំណែកបញ្ញាដែលជាលោ-
កិយ: បានដល់ សុតមយបញ្ញា ចិន្តាមយបញ្ញា និងភាវនាមយបញ្ញា ដែលនៅ
មានអាសវ: ចំណែកលោកុត្តរបញ្ញា បានដល់ បញ្ញាដែលសម្បយុត្តដោយមគ្គ
និងផល ។ ឈ្មោះថា វិមុត្តិ បានដល់ ផលវិមុត្តិ និងនិព្វាន ព្រោះដូច្នោះ វិមុត្តិ
នោះ ទើបជាលោកុត្តរ:តែម្យ៉ាង ។ វិមុត្តិញាណទស្សន:ជាលោកិយ:តែម្យ៉ាង
វិមុត្តិញាណទស្សន:នោះមាន ១៩ យ៉ាង ព្រោះជាបច្ចវេក្ខណញាណ ។ ឈ្មោះថា
អ្នកដល់ត្រើយ គឺទីបំផុត ព្រោះសេចក្ដីបរិបូរនៃ ធម៌មានសីលជាដើមទាំងនេះ
ដែលកើតឡើងដោយមិនឱ្យសេសសល់ ព្រោះសម្រេចព្រះអរហត្តក្នុងសន្ធាន

របស់ខ្លួន ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបឈ្មោះថា ដល់ត្រើយក្នុងធម៌របស់ខ្លួន ។

ម្យ៉ាងទៀត ឈ្មោះថា ដល់ត្រើយក្នុងសីល ព្រោះសម្រេចសោតាបត្តិផល ។ មែនពិត ព្រះសោតាបន្ននោះ លោកហៅថា ធ្វើឱ្យបរិបូរក្នុងសីលទាំងឡាយ ។ ក៏ក្នុងទីនេះ សូម្បីព្រះសកទាគামី ក៏ជាការលោកកាន់យកដោយសោតាបន្ន-ស័ព្ទដូចគ្នា ។ ឈ្មោះថា អ្នកដល់ត្រើយក្នុងសមាធិ ព្រោះសម្រេចអនាគាមិផល ។ មែនពិត ព្រះអនាគាមីនោះ លោកហៅថា អ្នកធ្វើឱ្យបរិបូរក្នុងសមាធិ ។ ឈ្មោះថា អ្នកដល់ត្រើយក្នុងធម៌ ៣ ក្រៅនេះ ព្រោះសម្រេចព្រះអរហត្តផល ។ មែនពិត ព្រះអរហន្ត ឈ្មោះថាជាអ្នកដល់ត្រើយក្នុងបញ្ញាវិមុត្តិ និងវិមុត្តិញាណ-ទស្សនៈ ព្រោះសម្រេចចេតោវិមុត្តិដែលជាអកុប្បធម៌ដ៏ប្រសើរ ដោយការដល់សេចក្តីបរិបូរដោយបញ្ញា និងព្រោះដល់ទីបំផុតនៃបច្ចវេក្ខណញាណ ។ ឈ្មោះថាជាអ្នកដល់ត្រើយក្នុងធម៌របស់ខ្លួនក្នុងកាលនោះ។ តាមដែលពោលហើយ ព្រោះសម្រេចកិច្ច ១៦ យ៉ាង មានបរិញ្ញាកិច្ចជាដើម ដោយមគ្គ ៤ ក្នុងអរិយ-សច្ចៈ ៤ សូម្បីដោយប្រការទាំងពួងដូច្នេះ ។

បទថា **ហោតិ ព្រាហ្មណោ** សេចក្តីថា ក្នុងកាលនោះ បុគ្គលនោះ ឈ្មោះថាជាព្រាហ្មណ៍ដោយបរមត្ថ ព្រោះជាអ្នកមានបាបបន្សាត់បង់ហើយ ។ បទថា **អថ ឯវំ បិសាចញ្ច បញ្ញាលញ្ចាតិ វត្តតិ** សេចក្តីថា ម្នាលអជកលាបកៈ: បន្ទាប់អំពីការដល់ត្រើយ តាមដែលបានពោលហើយនោះ បុគ្គលប្រព្រឹត្តទៅកន្ទ្ធ គឺឈានកន្ទ្ធ គឺគ្របសង្កត់ មិនខ្វាចបីសាចដែលមកស៊ីសាច់ដែល

លោកសម្តែងហើយនោះ និងសំឡេងអកុល: ពកុល: ជាទីតាំងឡើងញ្ចាំងជនដទៃឱ្យខ្ជាច ។ គាថាសូម្បីនេះ លោកពោលលើកតម្កើងចំពោះព្រះអរហត្ត ។ គ្រានោះ អជកលាបកយក្ខ ឃើញភាពតាំងមាំនោះរបស់ព្រះដ៏មានព្រះភាគទ្រង់មិនញាប់ញ័រ សូម្បីដោយសេចក្តីគួរខ្ជាច ដែលមានភ័យកើតចំពោះមុខបែបនោះ ដែលខ្លួនធ្វើហើយក៏មានចិត្តជ្រះថ្លាថា ព្រះសមណ:នេះជាមនុស្សអស្ចារ្យហ្ន៎ កាលនឹងប្រកាសដល់សទ្ធាដែលជារបស់បុថុជ្ជនតាំងមាំក្នុងខ្លួន ទើបប្រកាសភាពជាឧបាសកចំពោះព្រះភ័ក្ត្រនៃព្រះសាស្តា ។

សត្តមសុត្តវណ្ណនា និដ្ឋិតា។

ចប់ អដ្ឋកថាសូត្រទី ៧

៨. សង្ហាមជិសុត្តវណ្ណនា

អដ្ឋកថាសង្ហាមជិសូត្រ

សង្ហាមជិសូត្រទី ៨ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **សង្ហាមជិ** *បានដល់ មានឈ្មោះយ៉ាងនេះ ។ មែនពិត អ្នកដ៏មានអាយុនេះ ជាបុត្ររបស់សេដ្ឋីមានសម្បត្តិច្រើនម្នាក់ក្នុងក្រុងសាវត្ថី លោចម្រើនវ័យ មាតាបិតាឱ្យមានការិយាដោយសមគួរ ប្រគល់ទ្រព្យសម្បត្តិឱ្យនៅគ្រប់គ្រងផ្ទះ ។ ថ្ងៃមួយ កុលបុត្រនោះឃើញឧបាសកអ្នកក្រុងសាវត្ថី កំពុងថ្វាយទានសមាទានសីលក្នុងវេលាព្រឹក ស្បៃកដណ្តប់សំពត់ស កាន់របស់ក្រអូបនិងផ្ការណើជាដើម មានមុខឆ្ពោះទៅកាន់វត្តជេតពនដើម្បីស្តាប់ធម៌ក្នុងវេលាល្ងាច ទើបសួរថា អ្នកទាំងឡាយទៅណាហ្ន៎ កាលជនទាំងឡាយនៅ្ងយថា ទៅសម្នាក់ព្រះសាស្តាក្នុងវត្តជេតពន ដើម្បីស្តាប់ធម៌ ទើបពោលថា បើដូច្នោះ សូម្បីខ្ញុំក៏នឹងទៅដែរ ទើបបានទៅកាន់វត្តជេតពនជាមួយជនទាំងឡាយនោះ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគប្រថាប់អង្គុយលើពុទ្ធាសនៈដ៏ប្រសើរ ដែលគេក្រាលទុកក្នុងមណ្ឌបសម្រាប់ស្តាប់ព្រះសទ្ធម្ម សម្តែងធម៌នៅត្រង់កណ្តាលបរិស័ទទាំង ៤ ដូចស្តេចរាជសីហ៍បន្ទឹសីហនាទក្នុងណ្ហាងមាស ។*

គ្រានោះឯង ឧបាសកទាំងនោះថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ចំណែកសង្ហាមជិកុលបុត្រ អង្គុយស្តាប់ធម៌នៅចុងបរិស័ទ

នោះ ។ ព្រះដ៏មានព្រះភាគត្រាស់អនុបុព្វីកថា ប្រកាសសច្ច:៤ ក្នុងវេលាចប់សច្ច: សត្វច្រើនពាន់បានត្រាស់ដឹងធម៌ ។ ចំណែកសង្គ្រាមជិកុលបុត្រ ក៏សម្រេចសោតាបត្តិផល កាលបរិស័ទចេញទៅហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគថ្វាយបង្គំហើយទូលសូមបព្វជ្ជាថា បពិត្រព្រះដ៏មានព្រះភាគ សូមព្រះដ៏មានព្រះភាគបំបួសខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ក៏មាតាបិតាអនុញ្ញាតឱ្យអ្នកបព្វជ្ជាហើយឬ ។ សង្គ្រាមជិក្រាបបង្គំទូលថា មិនទាន់បានទទួលអនុញ្ញាតទេ ព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសង្គ្រាមជិ ព្រះតថាគតទាំងឡាយមិនដែលបំបួសកុលបុត្រដែលមាតាបិតាមិនបានអនុញ្ញាតនោះទេ ។ សង្គ្រាមជិទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ នឹងធ្វើគ្រប់យ៉ាងឱ្យតែមាតាបិតាអនុញ្ញាតឱ្យខ្ញុំព្រះអង្គបួស ដូច្នេះហើយថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណហើយចូលទៅរកមាតាបិតាពោលថា បពិត្រមាតាបិតា សូមលោកទាំងពីរអនុញ្ញាតឱ្យខ្ញុំបួសចុះ ។ អំពីនោះគប្បីជ្រាបតាមន័យដែលពោលមកហើយក្នុងរដ្ឋបាលសូត្រ ។

លំដាប់នោះ សង្គ្រាមជិប្តេជ្ញាថា កាលបើខ្ញុំបួសហើយ ខ្ញុំនឹងបង្ហាញខ្លួនឱ្យមាតាបិតាបានឃើញ កាលមាតាបិតាអនុញ្ញាតហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយទូលសូមបព្វជ្ជា ក៏សង្គ្រាមជិបានបព្វជ្ជាឧបសម្បទាក្នុងសម្ងាក់

របស់ព្រះដ៏មានព្រះភាគ លំដាប់នោះ សង្គ្រាមជិឧបសម្បទាបាន ហើយព្យាយាមប្រឹងប្រែងដើម្បីមគ្គខាងលើៗ នៅចាំវស្សាក្នុងអរញ្ញវាសមួយ បានអភិញ្ញា ៦ មានវស្សានៅរួចហើយ ទៅក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគផង ដើម្បីដោះពាក្យប្តេជ្ញានឹងមាតាបិតាផង ។ ព្រោះហេតុដូច្នោះ លោកទើបពោលថា **តេន ខោ បន សមយេន អាយស្មា សង្ហ្គាមជិ សាវត្ថឺ អនុប្ផត្តោ ហោតិ** *សម័យនោះឯង ព្រះសង្គ្រាមជិដ៏មានអាយុ បានទៅនគរសាវត្ថីដើម្បីជួបព្រះដ៏-មានព្រះភាគ ។*

ក៏សង្គ្រាមជិដ៏មានអាយុនោះ ត្រាច់បិណ្ឌបាតក្នុងធុរគ្រាម ត្រឡប់មកអំពីបិណ្ឌបាតខាងក្រោយភត្ត ចូលទៅកាន់វត្តជេតពនគាល់ព្រះដ៏មានព្រះភាគ ព្រះអង្គក៏បានធ្វើបដិសណ្ឋារៈហើយបានព្យាករណ៍អរហត្តផល ព្រះសង្គ្រាមជិ-ដ៏មានអាយុថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណចេញទៅគង់សម្រាកវេលាថ្ងៃទៀបគល់ឈើមួយដើម ។ លំដាប់នោះ មាតាបិតា និងញាតិមិត្តរបស់ព្រះថេរៈជ្រាបថា ព្រះថេរៈនិមន្តមកហើយ ក៏មានចិត្តរីករាយត្រេកអរដោយគំនិតថា បានឮមកថា ព្រះសង្គ្រាមជិដ៏មានអាយុនិមន្តមកក្នុងទីនេះ ទើបប្រញាប់ទៅកាន់វិហារ ស្វែងរកព្រះសង្គ្រាមជិដ៏មានអាយុដែលកំពុងគង់ក្នុងទីនោះ ចូលទៅរកធ្វើបដិសណ្ឋារៈ ហើយអង្វរថា ព្រះរាជាទាំងឡាយ តែងរឹបអូសទ្រព្យសម្បត្តិរបស់បុគ្គលអ្នកគ្មានបុត្រ ម្យ៉ាងទៀត ទាយាទមិនជាទីស្រឡាញ់ទាំងឡាយ

គប្បីកាន់យកនូវទ្រព្យសម្បត្តិរបស់បុគ្គលអ្នកគ្មានបុត្រ ល្មមហើយដោយការបព្វជ្ជា នែ៎កូនសម្ងាញ់ កូនចូរមក ចូរសឹកចុះ ។ ព្រះថេរៈស្តាប់ដូច្នោះហើយ គិតថា អ្នកទាំងនេះមិនដឹងថា យើងមិនត្រូវការដោយកាមទាំងឡាយ ប្រាថ្នានឹងឱ្យជាប់នៅក្នុងកាមប៉ុណ្ណោះ ដូចអ្នកវែកលាមកត្រូវការដុំលាមកដូច្នោះ អ្នកណាៗ មិនអាចនឹងឱ្យអ្នកទាំងនេះយល់ធម្មីកថាបាន ទើបអង្គុយធ្វើដូចជាមិនបានឮ ។ អ្នកទាំងនោះអង្វរដោយប្រការផ្សេងៗ ឃើញព្រះថេរៈមិនជឿពាក្យរបស់ខ្លួន ទើបចូលទៅផ្ទះបង្គាប់ភរិយារបស់ព្រះថេរៈ ព្រមដោយបុត្រនិងបរិវារបណ្តើរ ពោលថា ពួកយើងនឹងអង្វរព្រះថេរៈដោយប្រការផ្សេងៗ ក៏លួងលោមមិនបានទើបនាំគ្នាមក នែ៎កូនស្រី នាងចូរទៅអង្វរកស្តារបស់អ្នកឯងឱ្យព្រម ដោយបង្ហាញនូវបុត្រ ។ បានឮថា កាលនាងតាំងគភ៌ ព្រះសង្ហាមជិ-ដ៏មានអាយុនេះទៅបួស ។ នាងទទួលនូវពាក្យនោះថា ប្រពៃហើយ ទើបនាំទារកព្រមដោយបរិវារជាច្រើនទៅកាន់វត្តជេតពន ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា **អសេ្ឍ្ឍ សិ ខោ អាយស្មតោ សង្ហ្គ្ គ្ គ្ ជ្ ជ ិ ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧ្ ាណ ុ ិ ** សេចក្តីថា កាលមុន គឺក្នុងវេលាជាគ្រហស្ថ នាងបានជាភរិយាចាស់ដោយអំណាចនៃការបម្រើដើង

អធិប្បាយថា ជាភរិយា ។ ដោយពាក្យថា **អយ្យោ** *កាលនឹងនិយាយថា ព្រះអយ្យបុត្ត តែនិយាយដោយវោហារដែលសមគួរដល់បព្វជិត ។ ស័ព្ទថា* **ភិរ** *ជានិបាត ប្រើក្នុងអនុស្សវនត្ថៈ បានឮមក ។ គប្បីជ្រាបសម្ព័ន្ធថា បានឮថា កាលលោកមកដល់ ។ បទថា* **ខុទ្ធបុត្តំ ហិ សមណាចោស មំ** *សេចក្ដីថា នាងពោលថា លោកបោះបង់នូវខ្ញុំដែលកំពុងតាំងគភ៌ហើយទៅបួស ឥឡូវនេះ ខ្ញុំនោះជាស្ត្រីមានកូនតូច ការដែលលោកបោះបង់ ខ្ញុំជាស្ត្រីមានសភាពយ៉ាងនោះ ហើយធ្វើសមណធម៌ជាការមិនសមគួរទេ បពិត្រសមណៈ ព្រោះដូច្នោះ លោកចូរចិញ្ចឹមខ្ញុំជាស្ត្រីមានកូនជាគម្រប់ពីរ ដោយអាហារ និងគ្រឿងស្ងៀកដណ្ដប់ជាដើមផងចុះ ។ ចំណែកឯព្រះសង្គ្រាមជិដ៏មានអាយុសង្រ្ដួមឥន្ទ្រិយមិនសម្ងឹងមើល ទាំងមិនចរចាជាមួយនាង ។ ព្រោះហេតុនោះ លោកទើបពោលថា* **ឯវំ វុត្តេ អាយស្មា សង្គ្រាមជិ តុណ្ហី អហោសិ** *និមិត្តតែបុរាណទុតិយិកានោះ ពោលយ៉ាងនេះហើយ ព្រះសង្គ្រាមជិដ៏មានអាយុនៅស្ងៀម ។ នាងពោលដូច្នោះ អស់វារៈ ៣ ដង ឃើញព្រះសង្គ្រាមជិដ៏មានអាយុនៅស្ងៀមតែម្យ៉ាង ទើបសម្គាល់ថា ឈ្មោះថា បុរសទាំងឡាយមិនអាល័យក្នុងភរិយា តែនៅមានអាល័យក្នុងបុត្ត សេចក្ដីស្នេហាក្នុងបុត្រតាំងនៅក្នុងខួរក្នុងឆ្អឹងរបស់បិតា ព្រោះដូច្នោះ លោកនឹងលុះនៅក្នុងអំណាចរបស់ខ្ញុំដោយសេចក្ដីស្នេហាក្នុងបុត្រ ទើបដាក់បុត្រលើភ្ជៅរបស់ព្រះថេរៈហើយដៀសចេញទៅ ដោយពោលថា បពិត្រសមណៈ នេះបុត្ត*

របស់លោក លោកចូរចិញ្ចឹមគេចុះ ហើយចេញដោយសន្សឹមៗ ។ បានឮថា នាងមិនអាចឈរចំពោះមុខរបស់ព្រះថេរៈដោយតេជសមណៈ ។ សូម្បីក្មេង ព្រះថេរៈក៏មិនសម្ងឹងមើលទាំងមិននិយាយរកផងទេ ។ ពេលនោះ នាងសូម្បីជាស្ត្រីឈរក្នុងទីមិនឆ្ងាយ ក្រឡេកទៅមុខសម្ងឹងមើលដឹងអាការព្រះថេរៈ ត្រឡប់មកបីក្មេងដោយគំនិតថា សមណៈនេះមិនត្រូវការបុត្រ ហើយក៏ជៀសចេញទៅ ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា **អថ ខោ អាយស្មតោ សង្ហ-មជ្ជិស្ស បុរាណទុតិយិកា** លំដាប់នោះ បុរាណទុតិយិការបស់ព្រះសង្ហាមជ-ដ៏មានអាយុ ។

បណ្តាបទទាំងនោះ បទថា **បុត្តេនបិ** សេចក្តីថា សមណៈនេះមិនត្រូវការបុត្រ សូម្បីដែលកើតអំពីទ្រូងរបស់ខ្លួន អធិប្បាយថា នឹងចាំបាច់ពោលទៅថ្ងៃដល់អ្នកដទៃហ្ន៎ ។ ឈ្មោះថា **ទិព្ព** ក្នុងបទថា **ឌិព្ពេន** នេះ ព្រោះដូចជាទិព្ព ។ មែនពិត ទេវតាទាំងឡាយមានចក្ខុបសាទជាទិព្ព ដែលកើតអំពីកម្មណ្ឌ មិនប្រឡាក់ដោយទឹកប្រមាត់ ស្លេស្ម និងឈាមជាដើម អាចទទួលអារម្មណ៍បានសូម្បីក្នុងទីឆ្ងាយ ។ សូម្បីអភិញ្ញាចក្ខុនេះកើតអំពីចតុត្ថជ្ឈាន សមាធិក៏ដូច្នោះ ហេតុនោះ ទើបឈ្មោះថា **ទិព្ព** ព្រោះដូចជារបស់ទិព្ព ។ ម្យ៉ាងទៀត ឈ្មោះថា **ទិព្ព** ព្រោះមានសេចក្តីរុងរឿងច្រើន ឬមានគតិជំដោយទិព្ពនោះ ។ បទថា **វិសុ-**

ខ្ជេន *បានដល់ ឈ្មោះថា បរិសុទ្ធដោយល្អ ព្រោះប្រាសចាកសង្កិលេស មាននីវរណៈជាដើម ។ បទថា* **អតិក្ក្ជ្ជមានុសកេន** *បានដល់ កន្ធវិស័យរបស់មនុស្ស ។ បទថា* **ឥមំ ឯវរូបំ វិប្ឍការំ** *សេចក្ដីថា មានសេចក្ដីប្ដែកនេះ គឺយ៉ាងនេះ បានដល់ កិរិយាដែលខុសរូបពោលគឺ ដាក់បុត្ត្រលើភ្លៅដែលមិនសមគួរក្នុងបព្ជជិតតាមដែលពោលហើយ ។*

បទថា **ឯតមត្ថំ** *សេចក្ដីថា ដឹងអត្ថនេះ ពោលគឺ សេចក្ដីដែលព្រះសង្ឆាមជិដ៏មានអាយុអស់សេចក្ដីអាល័យក្នុងសត្ត្ជគ្រប់ពួក មានបុត្ត្រ និងកិរិយាជាដើម ដោយអាការទាំងពួង ។ បទថា* **ឥមំ ឧ្ជានំ** *សេចក្ដីថា ព្រះដ៏មានព្រះភាគទ្រង់បន្ទ្ជីនូវឧ្ជានេះ គឺដែលសម្ដែងអានុភាពរបស់ព្រះសង្ឆាមជិ-ដ៏មានអាយុនោះ ជាអ្នកវ៉ាងមាំក្នុងឥដ្ឋារម្ម ណ៍ និងអនិដ្ឋារម្ម ណ៍ជាដើម ។*

បទថា **អាយន្ត្ជ** *អធិប្ប ាយថា ភ្ជ ិយាចាស់អ្ន ក ។ បទថា* **ជ ាកិ-ជ ន្ជ ត ិ** *សេចក្ដីថា មិនភ្ជ ីតភ្ជ ីន គឺមិនត្ជ ក អ ជ ោ ជ ោ យ គ ំ ន ិ ត ថ ា ន ា ង ន ឹ ង ម ក ម ើ ល យ ើ ង ។ ប ទ ថ ា* **ប ក ្ក ម ន ្ត ី** *សេ ច ក ្ដ ី ថ ា អ ្ន ក ឃ ើ ញ ហ ើ យ ទ ៅ ដ ោ យ ค ิ ต ថ ា អ ្ន ក ន េ ះ មិ ន អ ា ล ័ យ យ ើ ង ហ ើ យ ទ ៅ ។ ប ទ ថ ា* **ន ្ជ ោ ช ต ิ** *ប ា ន ដ ល ់ ម ិ ន ដ ល ់ ส ช ค ្ค ี ก ្ค ា (ก ร ห า ย ช ิ ต) ។ ต ែ ដ ើ ម ្ប ី ส ម ្ដ ែ ง ห េ ต ុ ដ ែ ล ព ្រ ះ ช ว ะ : ม ิ น ต ្រ ก អ ร ม ิ น ส ោ ก ส ៅ យ ៉ ា ง ន េ ះ ទ ើ ป ព ោ ล ព ា ก ្យ ม ា ន ជ ា អ ា ទ ិ (ว ิ ต ก) ว ่ า* **ส ง ฺ ค ฺ ค ส ง ฺ ฉ ามชิ ม ุ ต ฺ ต ํ** *ด ู จ ช ว ก ิ ก ฺ ข ุ (ช ว ก) ช ื่ อ ส ง ฺ ฉ ามชิ ด ู ล ว จ ส ร ส ฺ ส ะ ห ั ย ต ก ค ร ื ง ช ั บ ค ื ก ิ ล ส ។*

បណ្តាបទទាំងនោះ បទថា **សង្ហ** *សេចក្តីថា ភិក្ខុអ្នកឈ្នះសង្គ្រាមដ៏អ្នកផុតពីធម៌ជាគ្រឿងជាប់ជំពាក់ ៥ យ៉ាង គឺគ្រឿងជាប់ជំពាក់ គឺរាគៈ ទោសៈ មោហៈ មានៈ និងទិដ្ឋិ ដោយសមុច្ឆេទវិមុត្តិ និងបដិបស្សទ្ធិវិមុត្តិ ។ បទថា* **តម្ហ ព្រូមិ ព្រាហ្មណំ** *សេចក្តីថា តថាគតហៅបុគ្គលនោះជាអ្នកដល់ភាពមាំមួនជាអ្នកមានអាសវៈអស់ហើយថាជាព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបន្សាត់បង់ហើយ ដោយប្រការទាំងពួង ។*

អដ្ឋមសុត្តវណ្ណនា និដ្ឋិតា ។

ចប់ អដ្ឋកថាសូត្រទី ៨

៩. ជដិលសុត្តវណ្ណនា

អដ្ឋកថាជដិលសូត្រ

ជដិលសូត្រទី ៩ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **កយា** *ក្នុងពាក្យថា* **កយាយំ** *នេះ គេហៅថា ស្រុកខ្ទះ កំពង់ខ្ទះ ។ មែនពិត ព្រះដ៏មានព្រះភាគ កាលប្រថាប់នៅក្នុងទីមិនឆ្ងាយពីគយាគ្រាម គេហៅថា ប្រថាប់នៅជិតស្រុកគយា ។ កាលប្រថាប់នៅក្នុងទីមិនឆ្ងាយកំពង់គយា គេក៏ហៅថា ប្រថាប់នៅជិតកំពង់គយាដូចគ្នា ។ មែនពិត ក្នុងពាក្យថា* **កយាតិត្ថំ** *ស្រះក្តី ទន្ទេក្តីមាននៅក្នុងទីមិនឆ្ងាយស្រុក ឈ្មោះថា* ***គយា*** *។ ទាំងពីរយ៉ាងនោះ លោកិយមហាជនហៅថា កំពង់ជាទីបណ្តែតបាប ។ បទថា* **កយាសីសេ** *សេចក្តីថា ក្នុងទីនោះមានកូនភ្នំមួយឈ្មោះ* ***គយាសីសៈ*** *មានកំពូលប្រាកដស្មើដូចក្បាលដំរី មានថ្ពាក្រាលដូចពោងដំរី ជាឱកាសល្មមកិក្ខុមួយពាន់រូបនៅបាន ។ ព្រះដ៏មានព្រះភាគក៏ប្រថាប់នៅក្នុងទីនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា* **កយាយំ វិហរតិ កយាសីសេ** *។*

បទថា **ជដិលា** *បានដល់ តាបស ។ មែនពិត តាបសទាំងនោះ គេហៅថា* ***ជដិល*** *ក្នុងទីនេះ ព្រោះជាអ្នកទ្រទ្រង់ជដា ។ បទថា* **អន្តរដ្ឋកេ ហិមចាតសមយេ** *សេចក្តីថា ក្នុងវេលាទឹកកកធ្លាក់មានប្រមាណដល់ ៨ ថ្ងៃ គឺក្នុងទីបំផុតរបស់ខែមាឃដែលជាខាងក្នុងហេមន្តរដូវ ៤ ថ្ងៃ ក្នុងថ្ងៃដើមរបស់ខែផន្ទុណ ៤ ថ្ងៃ ។ បទថា* **កយាយំ ឧម្មុជ្ជន្តិ** *សេចក្តីថា ជដិលពួកខ្លះមុជចុះទាំងខ្លួនអាក្រាតដំបូងក្នុងទឹកដែលសន្ធតិគ្នាថា កំពង់ទឹកនោះ បន្ទាប់ពីនោះ ក៏ផុសឡើងថា អណ្តែតទៅ ។ បទថា* **និម្មុជ្ជន្តិ** *សេចក្តីថា មុជចុះក្នុងទឹកទាំងក្បាល ។*

បទថា **ឧម្មុជ្ជនិម្មុជ្ជម្បិ ករោន្តិ** សេចក្តីថា មុជចុះងើបឡើងរឿយៗ ។

មែនពិត ក្នុងការធ្វើនោះ ជដិលពួកខ្លះមានការយល់ឃើញយ៉ាងនេះថា ដោយការត្រឹមតែងើបឡើងម្តងប៉ុណ្ណោះជាការបរិសុទ្ធពីបាប ជដិលទាំងនោះ ងើបឡើងហើយក៏ជៀសចេញទៅ ។ តែការផុសឡើងមិនមានក្នុងចន្លោះការមុជចុះ ព្រោះដូច្នោះ ជដិលទាំងនោះទើបធ្វើត្រឹមតែការមុជចុះដោយមិនរៀ។ ចំណែកជដិលពួកណា មានទិដ្ឋិយ៉ាងនេះថា ដោយការមុជចុះត្រឹមតែម្តងប៉ុណ្ណោះ ទើបជាការបរិសុទ្ធពីបាប ជដិលពួកនោះក៏មុជត្រឹមតែម្តង ធ្វើត្រឹមតែការផុសឡើងដោយមិនរៀតាមន័យដែលពោលហើយនុ៎ះឯង ហើយក៏ជៀសចេញទៅ ។ ចំណែកជដិលទាំងឡាយណាមានទិដ្ឋិយ៉ាងនេះថា ដោយការមុជចុះត្រង់កំពង់នោះឯង ជាការបរិសុទ្ធពីបាប ជដិលពួកនោះទើបមុជចុះត្រង់កំពង់នោះ ក៏ជាប់ខ្សល់ស្ទាប់ចុះក្នុងទីនោះឯង ដូចប្រៀបដូចលិចចុះក្នុងអន្ទង់ខ្សាច់ ។ ជដិលពួកដទៃទៀតមានទិដ្ឋិយ៉ាងនេះថា ក្នុងការធ្វើការផុសឡើងមុជចុះញយៗ ហើយទើបងូត ជាការបរិសុទ្ធពីបាប ជនទាំងនោះទើបធ្វើការផុសឡើង និងមុជចុះរហូតដល់អស់រយៈ ។ លោកសំដៅយកជដិលនោះទាំងអស់ ទើបពោលថា ផុសឡើងខ្លះ មុជចុះខ្លះ ទាំងងើបឡើង ទាំងមុជចុះខ្លះ ។ ក៏ក្នុងសេចក្តីនេះ ការផុសឡើងត្រូវមានការមុជចុះមុនក៏ពិតមែនហើយ ក៏ប៉ុន្តែថា ជដិលអ្នកធ្វើការមុជចុះ មានប្រមាណតិច ជដិលអ្នកធ្វើការផុសឡើង និងការមុជចុះផុសឡើងទាំងពីរមានច្រើន ព្រោះដូច្នោះ ដើម្បីនឹងសម្តែងការៈដែលជដិលទាំងនោះ ជាចំណែកខាងច្រើន ទើបពោលការផុសឡើងមុន ។ ម្យ៉ាងទៀត បទថា **ជដិលា**

ក៏សមដូចដែលលោកពោលទុក ក៏ព្រោះពួកជដិលជាចំណែកខាងច្រើន ម្យ៉ាង-ទៀត ពួកព្រាហ្មណ៍សូម្បីទាំងក្បាលត្រដោលនិងបួងសក់ជាកញ្ចុំ អ្នកត្រូវការភាពបរិសុទ្ធដោយទឹក រមែងធ្វើយ៉ាងនោះត្រង់កំពង់ទឹកនោះ ក្នុងកាលនោះ ។

បទថា **ឱសិញ្ចន្តិ** សេចក្ដីថា ជដិលពួកខ្លះយកដៃដងទឹកក្នុងស្រះ ហើយស្រោចទឹកលើក្បាលនិងខ្លួន ជដិលមួយពួកទៀតយកឆ្នាំងដងទឹក ឈរត្រង់មាត់ច្រាំងហើយ ធ្វើដូចយ៉ាងនោះ ។ បទថា **អគ្គឺ ជុហន្តិ** សេចក្ដីថា ជដិលពួកខ្លះចាត់ចែងដំណាក់ ត្រង់មាត់ច្រាំងស្ទឹងគយា ហើយនាំគ្រឿងឧបករណ៍ជាគ្រឿងបូជាមានឱស និងស្ជូវជាដើម ចូលទៅបូជាភ្លើង គឹបម្រើភ្លើង ។ បទថា **ឥមិនា សុទ្ធិ** សេចក្ដីថា ជដិលពួកខ្លះជាអ្នកមានទិដ្ឋិយ៉ាងនេះថា សេចក្ដីបរិសុទ្ធពីមន្ទិល គឺបាប បានដល់ ការបណ្ដែតបាប ឬសេចក្ដីបរិសុទ្ធពីសង្សារ រមែងមានដោយការមុជចុះជាដើមក្នុងស្ទឹងគយា និងដោយការបម្រើភ្លើងនេះ ។ ក៏ក្នុងទីនេះ ការមុជចុះជាដើម គប្បីឃើញថា លោកពោលទុកត្រឹមតែជាឧទាហរណ៍ ។ ក៏បណ្ដាអ្នកទាំងនោះ ពួកខ្លះនៅក្នុងទឹក ពួកខ្លះធ្វើអញ្ជលីទឹក ពួកខ្លះឈរក្នុងទឹកហើយបែរតាមព្រះចន្ទ ព្រះអាទិត្យ ពួកខ្លះការនាធនុ: មានសាវិត្ដិធនុ:ជាដើម ច្រើនពាន់ដង ពួកខ្លះក៏រាយវិជ្ជាដោយន័យមានជាអាទិ៍ថា **ឥន្ទ អាគច្ឆ** ចូរមកចុះព្រះឥន្ទ ពួកខ្លះធ្វើពិធីបម្រើមហាព្រហ្ម ។ ក៏កាលធ្វើយ៉ាងនេះ ពួកខ្លះចុះ ពួកខ្លះឡើង ពួកខ្លះឡើងមកហើយក៏ជម្រះលាមកឱ្យស្អាត ពួកខ្លះឈរក្នុងទឹក ត្រូវសេចក្ដីត្រជាក់ចៀតចៀន ទើបសម្ដែងកិរិយាមានប្រការផ្សេងៗ មានជាអាទិ៍យ៉ាងនេះថា ដូចលេងពិណដែលធ្វើដោយកុកដំរីជាដើម ។ ម្យ៉ាងទៀត ព្រោះហេតុដែលពួកទាំងនោះ កាលធ្វើកិរិយាដែលប្ដែកបែបនេះ

ក៏ធ្វើចំពោះការមុជចុះ និងផុសឡើងជាខាងដើមក្នុងទឹកនោះប៉ុណ្ណោះ ដូច្នោះ លោកធ្វើហេតុទាំងអស់នោះ ឱ្យនៅខាងក្នុងការមុជចុះ និងផុសឡើងប៉ុណ្ណោះ ទើបពោលពាក្យមានជាអាទិ៍ថា **ឧម្មុជ្ជន្តិ** ។ កាលសំឡេងអាកុលពាកុល: ដូចលាន់រំពងនៅក្នុងទីនោះយ៉ាងនេះ ព្រះដ៏មានព្រះភាគប្រថាប់ឈរលើកំពូលភ្នំ ទ្រង់ស្តាប់សំឡេងកោលាហលនោះរបស់អ្នកទាំងនោះ ទើបទ្រង់ត្រួតមើលថា នេះហេតុអ្វីហ្ន៎ បានទ្រង់ឃើញកិរិយាដែលប្លែកនោះ លោកសំដៅយកប្រការនោះ ទើបបានពោលដូច្នេះថា **អជ្ជសា ភោ ភគវា ។ប។ ឥមិនា សុទ្ធិ** ។ ពាក្យនោះមានសេចក្តីដូចពោលហើយនុ៎ះឯង ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ដឹងច្បាស់សេចក្តីនោះ គឺការដែលអ្នកទាំងនោះប្រកាន់មាំផ្លូវដែលមិនបរិសុទ្ធ មានការចុះទឹកជាដើមថា ជាផ្លូវបរិសុទ្ធ និងការដែលព្រះអង្គយល់ដឹងក្នុងផ្លូវដែលបរិសុទ្ធមានសច្ច:ជាដើមថា មិនខុស ដោយអាការទាំងពួង ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់បន្ទឺនូវឧទាននេះ គឺសម្តែងសេចក្តីមិនជាផ្លូវបរិសុទ្ធ ដោយសេចក្តីបរិសុទ្ធ ព្រោះទឹក និងសម្តែងដល់ធម៌មានសច្ច:ជាដើមជាផ្លូវបរិសុទ្ធតាមសេចក្តីពិត ។

បណ្តាបទទាំងនោះ បទថា **ឧទកេន** ក្នុងបទថា **ន ឧទកេន សុចិ ហោតិ** នេះ បានដល់ ដោយការផុសឡើងពីទឹកជាដើម ។ ក៏ក្នុងទីនេះ ការផុសឡើងពីទឹកលោកពោលថា **ឧទកំ** (ទឹក) ព្រោះលុបបទចុងដូចឧទាហរណ៍ថា **រូបកវេ រូបំ** រូប គឺរូបកព ។ ម្យ៉ាងទៀត បទថា **ឧទកេន** សេចក្តីថា សេចក្តីស្អាតដោយទឹកដែលជាតួ ធ្វើកិរិយាមានការផុសឡើងជាដើម មិនឈ្មោះថា ជាសេចក្តីបរិសុទ្ធរបស់សត្វទេ គឺមិនមាន ។ ម្យ៉ាងទៀត បទថា

សុចិ សេចក្តីថា សេចក្តីបរិសុទ្ធដោយទឹកតាមដែលពោលហើយនោះ មិនមែនជាសត្វ ឈ្មោះថា អ្នកបរិសុទ្ធពីមន្ទិល គឺបាប ។ ព្រោះហេតុអ្វី ព្រោះជនជាច្រើនងូតទឹកនេះ ។ ប្រសិនបើឈ្មោះថា សេចក្តីបរិសុទ្ធពីបាបមាន ព្រោះការចុះទឹកជាដើម តាមដែលពោលហើយនោះ ប្រហែលជាជនជាច្រើន ក៏នឹងនាំគ្នាងូតទឹកនេះ គឺអ្នកធ្វើកម្មអាក្រក់ មានមាតុឃាត (សម្លាប់មាតា) ជាដើម និងសត្វជទៃមានគោ ក្របីជាដើម ដោយហោចទៅសូម្បីត្រី និងអណ្តើក ក៏នឹងនាំគ្នាងូតទឹកនេះ មនុស្សនិងសត្វទាំងអស់នោះ ក៏នឹងបរិសុទ្ធពីបាបទៅដោយប្រការទាំងពួង ការងូតទឹកជាដើមនោះឱ្យបរិសុទ្ធមិនមានទេ ។ ព្រោះហេតុអ្វី ព្រោះការងូតទឹកមិនជាបដិបក្ខចំពោះហេតុនៃបាប ។ ក៏វត្ថុណាធ្វើវត្ថុណាឱ្យវិនាសទៅបាន វត្ថុនោះក៏ជាបដិបក្ខចំពោះវត្ថុនោះ ដូចភ្លឺស្វាងជាបដិបក្ខចំពោះភាពងងឹត និងវិជ្ជាជាបដិបក្ខចំពោះអវិជ្ជា ការងូតទឹកមិនជាបដិបក្ខចំពោះបាបដូច្នោះឡើយ ។ ព្រោះដូច្នោះ គប្បីកាន់យកក្នុងសេចក្តីនេះថា សេចក្តីស្អាតរមែងមិនមានព្រោះទឹក ។

ក៏ដើម្បីនឹងសម្តែងធម៌ដែលជាហេតុធ្វើឱ្យស្អាត ទើបពោលពាក្យមានជាអាទិ៍ថា **យម្ហិ សច្ចញ្ច** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **យម្ហិ** បានដល់ក្នុងបុគ្គលណា ។ បទថា **សច្ចំ** បានដល់ វចីសច្ចៈ និងវិរតិសច្ចៈ។ ម្យ៉ាងទៀត បទថា **សច្ចំ** បានដល់ ញាណសច្ចៈ និងបរមត្ថសច្ចៈ ។ បទថា **ធម្មោ** បានដល់ ធម៌ គឺអរិយមគ្គ និងធម៌ គឺផលចិត្ត ។ ធម៌ទាំងអស់នោះ រមែងមានក្នុងបុគ្គលណា ។ បទថា **សោ សុចី សោ ច ព្រាហ្មណោ** សេចក្តីថា បុគ្គលនោះ គឺព្រះអរិយបុគ្គលដ៏ពិសេស បានដល់ ព្រះខីណាស្រព ឈ្មោះថា ជាអ្នកស្អាត និងឈ្មោះថាជាព្រាហ្មណ៍ព្រោះជាអ្នកបរិសុទ្ធដ៏ក្រៃលែង ។ ក៏ព្រោះហេតុអ្វី

ក្នុងសេចក្តីនេះ សច្ចៈលោកធ្វើឱ្យផ្សេងគ្នាពីធម៌ហើយកាន់យក ព្រោះសច្ចៈមានឧបការៈច្រើន ។ ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគបានទ្រង់ប្រកាសគុណរបស់សច្ចៈទុកក្នុងសុត្តបទជាច្រើន ដោយន័យមានជាអាទិ៍ថា **សច្ចំ វេ អមតា វាចា** វាចាពិត ជាវាចាមិនស្លាប់[១] ។ **សច្ចំ ហវេ សាធុតរំ រសានំ** ពាក្យសត្យៈ មានរសធ្ងាញ់ពិសាជាងរសទាំងឡាយ[២] ។ **សច្ចេ អត្តេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា** ពួកសប្បុរសបានតាំងនៅក្នុងអត្តផង ក្នុងធម៌ផង ព្រោះសច្ចៈ[៣] ។ **សច្ចេ ឋិតា សមណាព្រាហ្មណា ច** ពួកសមណៈ និងព្រាហ្មណ៍ដែលតាំងនៅក្នុងសច្ចៈ[៤] ។ ប្រកាសទោសរបស់ធម៌ ដែលផ្ទុយគ្នានឹងសច្ចៈដោយន័យមានជាអាទិ៍ថា **ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ** បុគ្គលប្រព្រឹត្តកន្ទ (ពាក្យសច្ចៈ) ដែលជាធម៌ឯក[៥] និងថា **អភូតវាទី និរយំ ឧបេតិ** អ្នកពោលពាក្យមិនពិតរមែងទៅកាន់នរក[៦] ។

ជរមសុត្តវណ្ណនា និដ្ឋិតា។

ចប់ អដ្ឋកថាសូត្រទី ៩

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១២២ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ៦២ ។

៣-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១២២ ។

៤-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៦១ ទំព័រ ១៩៩ ។

៥-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៥៩ ។

៦-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៨៥ ។

១០. ពាហិយសុត្តវណ្ណនា

អដ្ឋកថាពាហិយសូត្រ

ពាហិយសូត្រទី ១០ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ពាហិយោ** *ជាឈ្មោះរបស់លោក ។ បទថា* **ទារុចីរិយោ** *បានដល់សំពត់ដែលក្រងដោយសម្បកឈើ ។ បទថា* **សុប្ផារកេ** *បានដល់ នៅត្រង់កំពង់ឈ្មោះយ៉ាងនោះ ។ ក៏ពាហិយ:នេះ គឺអ្នកណា និងព្រោះហេតុអ្វី ទើបជាអ្នកទ្រទ្រង់សំពត់ដែលក្រងដោយសម្បកឈើ ហេតុអ្វីទើបនៅអាស្រ័យត្រង់កំពង់ឈ្មោះ* ***សុប្ផារក:*** ?

ក្នុងសេចក្ដីនោះ មានអនុបុព្វីកថាដូចតទៅនេះ

បានឮថា ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមថា ***បទុមុត្តរ:*** *ក្នុងទីបំផុតសែនកប្បអំពីកទ្រកប្បនេះទៅ មានកុលបុត្រម្នាក់កំពុងស្ដាប់ព្រះធម៌ទេសនារបស់ព្រះទសពល ក្នុងហង្សវតីនគរ ឃើញព្រះសាស្ដាទ្រង់ស្ថាបនាកិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គ:នៃកិក្ខុជាខិប្ផាភិញ្ញា កុលបុត្រនោះគិតថា ដូចម្ដេចហ្ន៎ ក្នុងអនាគត អាត្មាអញនឹងបួសក្នុងព្រះសាសនារបស់ព្រះសម្មាសម្ពុទ្ធបែបនេះ ហើយគប្បីជាអ្នកដែលព្រះសាស្ដាស្ថាបនាទុកក្នុងតំណែងឯតទគ្គ:ដូច្នេះ ដូចកិក្ខុរូបនេះបានប្រាថ្នាតំណែងយ៉ាងនោះហើយ ទើបបំពេញបុញ្ញាធិការដែលសមគួរដល់តំណែងនោះ បំពេញបុណ្យរហូតដល់អស់ជីវិត មានសួគ៌ជាទីទៅក្នុងខាងមុខ អន្ទោលទៅក្នុងទេវតានិងមនុស្ស បួសក្នុងព្រះសាសនារបស់ព្រះកស្សប-ទសពលជាអ្នកមានសីលបរិបូរ បំពេញសមណធម៌ដល់អស់ជីវិត ហើយទៅកើតក្នុងទេវលោក ។ ពាហិយ:នោះស្ថិតនៅក្នុងទេវលោកអស់មួយពុទ្ធន្ដរ ក្នុង*

ពុទ្ធុប្បាទនេះ ចុះចាប់បដិសន្ធិ ក្នុងផ្ទៃនៃត្រកូលក្នុងពាហិយរដ្ឋ ជនទាំងឡាយ សម្គាល់បានថា **ពាហិយ:** ព្រោះកើតក្នុងពាហិយរដ្ឋ ។ ពាហិយ:ចម្រើនវ័យ ហើយនៅគ្រប់គ្រងផ្ទះ ជាអ្នកនាំទំនិញដ៏ច្រើនតាមទូកទៅមកក្នុងសមុទ្របាន ៧ ដង ទើបត្រឡប់មកនគររបស់ខ្លួនមួយអន្ទើជាមួយបរិវារវិញ ។ តែលើកទី ៨ ពាហិយ:គិតថា អញនិងទៅសុវណ្ណភូមិ ទើបលើកទំនិញដាក់ទូកហើយទៅ ។ នាវាចូលទៅកាន់មហាសមុទ្រមិនទាន់ដល់កន្លែងដែលប្រាថ្នា ក៏បែកធ្វាយកណ្តាលមហាសមុទ្រ ។ មហាជនបានជាចំណីរបស់ត្រី និងអណ្តើក ចំណែកពាហិយ: គោងផែនក្តារមួយបន្ទះ កំពុងធ្វងទៅត្រូវរលកបក់ម្តងបន្តិចៗ ក៏ដល់កំពង់ឈ្មោះ សុប្បារក: ដេកត្រង់ឆ្នេរសមុទ្រដោយកាយអាក្រាតដូចពេលកើត ព្រោះសំពត់របូតធ្លាក់ទៅក្នុងសមុទ្រ ។ ពាហិយ:នោះបន្ទោបង់សេចក្តីខ្ជល់ខ្ជាយ មានត្រឹមតែខ្យល់ដកដង្ហើមចេញចូល ក្រោកឡើងដើរទៅកាន់គុម្ពឈើដោយសេចក្តីអៀនខ្មាស មិនឃើញអ្វីៗ ជាគ្រឿងស្លៀកពាក់ ទើបកាត់ដើមម្រ័ក្សណ៍[1] ក្រងដោយក្រចៅ យកសម្បករុំ (កាយ) ធ្វើជាគ្រឿងបិទបាំងកាយ ហើយស្លៀកពាក់ ។ តែអាចារ្ય

១-**ម្រ័ក្សណ៍** ម្រាក់ សំ.; បា. (ន.) (ម្រក្សណ; មកួន "ដំរឬប្រេងសម្រាប់លាបលន; ការលាប លន; ដំណើរលុបបំបិទគុណគេ") ឈ្មោះដំរកើតអំពីដើមគ្រើលមានសម្បុរខ្មៅក្ងិនហាងធ្ងួ សម្រាប់ប្រើការលាបលន លាបម្រ័ក្សណ៍ ។ ម្រ័ក្សណ៍បាវ៉ាង ម្រ័ក្សណ៍ដែលនាំមកពីប្រទេសបាវ៉ាង ។ ម្រ័ក្សណ៍ពោល ចំហាយម្រ័ក្សណ៍ដែលពោលស្បែកមនុស្សឱ្យឡើងផេរកន្ទឹសស្ងៀបខ្ចាំងបណ្តាលឱ្យចង់ដៃតែអេះ (សរសេរក្ងាយជាម្រាក់ យូរអង្វែងណាស់មកហើយ, ត្រូវសរសេរ **ម្រ័ក្សណ៍** វិញ ទើបត្រឹមត្រូវតាមប្រភពនៃពាក្យ) ។

(វចនានុក្រមសម្តេចព្រះសង្ឆរាជ **ជោតញ្ញាណោ ជួន ណាត** ទំព័រ ៥៧៥)

ពួកខ្ញុះពោលថា ពាហិយៈនោះចោះផែន ក្តារក្រងដោយក្រចៅធ្វើជាគ្រឿងស្ងៀកដណ្តប់បិទបាំងកាយ ។ លោកក៏ប្រាកដឈ្មោះថា **ទារុចីរិយៈ** ព្រោះទ្រទ្រង់សំពត់ក្រងធ្វើដោយឈើ និងថា ពាហិយៈតាមឈ្មោះពីដើម សូម្បីដោយប្រការទាំងពួងដូច្នេះ ។

ពាហិយៈនោះកាន់អំបែងមួយ ត្រាច់សូមដុំបាយត្រង់កំពង់សុប្ផារកៈ ដោយទំនងដូចពោលហើយ មនុស្សទាំងឡាយបានជួបទើបគិតថា ប្រសិនបើឈ្មោះថា ព្រះអរហន្តក្នុងលោកនេះមាន លោកនេះគប្បីជាយ៉ាងនេះដែរ លោកម្ចាស់អង្គនេះ នឹងកាន់យកសំពត់ដែលគេឱ្យ ឬក៏មិនកាន់យកព្រោះសេចក្តីប្រាថ្នាតិចដូច្នេះ កាលនឹងសាកល្បង ទើបនាំសំពត់មកពីទិសផ្សេងៗ ចូលទៅរក ។ ពាហិយៈគិតថា ប្រសិនបើអញមិនមកដោយទំនងយ៉ាងនេះទេ កាលបើដូច្នោះជនទាំងឡាយក៏មិនជ្រះថ្លានឹងអញដែរ កាលបើយ៉ាងដូចម្តេចហ្ន៎ អញនឹងហាមសំពត់ទាំងនេះចេញ នៅដោយទំនងនេះឯង កាលបើដូច្នេះ លាភសក្តារៈក៏នឹងកើតឡើងដល់អញ ។ ពាហិយៈនោះគិតយ៉ាងនេះហើយ ទើបតាំងនៅក្នុងឋានៈជាអ្នកបញ្ជោតបន្ទំមិនទទួលសំពត់ ។ មនុស្សទាំងឡាយគិតថា អស្ចារ្យណាស់ហ្ន៎ លោកម្ចាស់នេះប្រាថ្នាតិចពិត ទើបមានចិត្តជ្រះថ្លាដោយប្រមាណដ៏ក្រៃលែងធ្វើសក្តារៈនិងការរាប់អានជាច្រើន ។

ចំណែក ពាហិយៈធ្វើកត្តកិច្ចហើយ បានទៅកាន់ខ្ទមអ្នកតាមួយកន្លែងក្នុងទីមិនឆ្ងាយ ។ មហាជនក៏ទៅជាមួយនឹងលោកដូចគ្នា បានជុសជុលខ្ទមអ្នកតានោះហើយប្រគល់ឱ្យ ។ ពាហិយៈគិតថា ជនទាំងនេះជ្រះថ្លាក្នុងឋានៈត្រឹមតែដែលយើងទ្រទ្រង់សំពត់ក្រង ទើបនាំគ្នាធ្វើសក្តារៈ និងការរាប់អានយ៉ាងនេះ យើងគួរ

និងមានការប្រព្រឹត្តយ៉ាងឧក្រិដ្ឋសម្រាប់អ្នកទាំងនេះ ទើបជាអ្នកមានបរិក្ខារស្រាលៗ ជាអ្នកប្រាជ្ញាតិច ។ ចំណែកពាហិយៈនោះ លោកកាលត្រូវអ្នកទាំងនោះលើកតម្កើងថាជាព្រះអរហន្ត ក៏សម្គាល់ខ្លួនថាជាព្រះអរហន្ត ម្យ៉ាងទៀត ការធ្វើសក្ការៈ និងធ្វើសេចក្តីគោរពក៏ចម្រើនក្រៃលែងៗ ឡើង និងពាហិយៈក៏មានបច្ច័យច្រើន ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា សម័យនោះឯង ពាហិយ-ទារុចីរិយៈបុរស (អ្នកស្ងៀកដណ្តប់សំពត់សំបកឈើ ឈ្មោះ ពាហិយៈ) អាស្រ័យនៅទៀបឆ្នេរសមុទ្រឈ្មោះ សុប្បារកៈជាអ្នកដែលធ្វើសក្ការៈគោរពរាប់អានជាដើម។

បណ្តាបទទាំងនោះ បទថា **សក្ក្ឥតោ** សេចក្តីថា ជាអ្នកដែលមហាជនសក្ការៈ ដោយអំណាចនៃការទំនុកបម្រុងដោយសេចក្តីគោរព គឺអើពើ ។ បទថា **ឥសុ្ការ** តោ សេចក្តីថា អ្នកដែលមហាជនធ្វើឱ្យធ្ងន់ ដោយអំណាចនៃការធ្វើឱ្យធ្ងន់ដូចធ្ងន់ត្ម ព្រោះអធិប្បាយថា ជាអ្នកប្រកបដោយគុណវិសេស ។ បទថា **មានិ**តោ សេចក្តីថា អ្នកដែលមហាជនរាប់អានដោយអំណាចនៃការសរសើរដោយចិត្ត ។ បទថា **ឬ**ជ្ជិ**តោ** សេចក្តីថា អ្នកដែលមហាជនបូជាហើយដោយការបូជា ដោយសក្ការៈ មានផ្ការ ឈើ និងរបស់ក្រអូបជាដើម ។ បទថា **អ**ចិ**តោ** បានដល់ អ្នកដែលមហាជនកោតក្រែងហើយដោយការឱ្យផ្ទ្ យ និងការនាំអាសនៈមកជាដើម ដោយចិត្តជ្រះថ្លាយ៉ាងក្រៃលែង ។ បទថា **ឥ**ជ្ជ-**ចីវ**-**ប**ិ**ណ្ឌ**ាចាតសេ**ជ**ាសនកិ**ណ**ានប្ប**ច**ូ**ឃ**ាកេ**ស**ជ្ជ**ំ**ប**ិ**ក្ខ**ារ**ានំ សេចក្តីថា ជាអ្នកមានលាភដោយអំណាចនៃការបានបច្ច័យ ៤ មានចីវរជាដើម ដ៏ប្រណីតៗ ដែលមហាជននាំចូលទៅបូជា ។

ន័យម្យ៉ាងទៀត បទថា **សក្ការោ** *បានដល់ បានទទួលសក្ការៈ។ បទថា* **ករុ**ក**ោ** *បានដល់ បានទទួលសេចក្តីគោរព ។ បទថា* **ម**ានិ**ោ** *បានដល់ ដែលមហាជនពាប់អានច្រើន និងមានចិត្តស្រឡាញ់ច្រើនដោយចិត្ត ។ បទថា* **ឬ**ជ**ិ**ោ *បានដល់ ដែលមហាជនបូជា ហើយដោយការបូជាយ៉ាងក្រៃលែង ដោយបច្ច័យ ៤ ។ បទថា* **អ**ប**ិ**ោ *បានដល់ បានទទួលការឱ្យនលំទោន ។ មែនពិតជនទាំងឡាយ រមែងធ្វើសក្ការៈដោយបច្ច័យ ៤ តាក់តែងយ៉ាងល្អ ធ្វើឱ្យ ប្រណីតៗ ប្រគល់ឱ្យបុគ្គលណា បុគ្គលនោះឈ្មោះថា ដែលគេធ្វើសក្ការៈ។ អ្នកទាំងឡាយធ្វើសេចក្តីគោរព ឱ្យប្រាកដហើយប្រគល់ឱ្យក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថា ជាទីគោរពរបស់ជនទាំងឡាយ ជនទាំងឡាយស្រឡាញ់ និងពាប់អានច្រើនដោយចិត្តនូវបុគ្គលណា បុគ្គលនោះឈ្មោះថា ជាទីពាប់អានរបស់ ជនទាំងឡាយ ជនទាំងឡាយធ្វើការបូជាទាំងពួងដោយអំណាចនៃការបូជាចំពោះ បុគ្គលណា បុគ្គលនោះ ឈ្មោះថា អ្នក គឺជាទីបូជា ជនទាំងឡាយកោតក្រែងក្រៃលែងដោយអំណាចនៃការអភិវាទ ការទទួល និងអញ្ជលីកម្មជាដើមដល់បុគ្គលណា បុគ្គលនោះឈ្មោះថា អ្នកគឺគេកោតក្រែង ។ ក៏អ្នកទាំងនោះ បានធ្វើវត្ត នោះគ្រប់យ៉ាងដល់ពាហិយៈ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមាន ជាអាទិ៍ថា ពាហិយទារុចីរិយៈ ដែលគេធ្វើសក្ការៈហើយ អាស្រ័យនៅត្រង់កំពង់សុប្បារកៈ។ ក៏ក្នុងទីនេះ ពាហិយទារុចីរិយៈ សូម្បីកាលមិនទទួលចីវរ គេក៏ពោលថា ជាអ្នកបានសូម្បីចីវរដូចគ្នា ដោយការបង្ហោនចូលទៅថា បពិត្រលោកដ៏ចម្រើន សូមលោកមកចុះ សូមទទួលយកនូវសំពត់នេះ។

បទថា **រហោគតស្ស** *បានដល់ អ្នកទៅកាន់ទីស្ងាត់ ។ បទថា* **បដិសល្លី-ឌស្ស** *បានដល់ ជាអ្នកនៅឯកោ ។ កាលត្រូវមនុស្សជាច្រើនពោលថា លោកជាព្រះអរហន្ត លោកក៏កើតសេចក្តីបរិវិតក្ក:នៃចិត្ត គឺកើតសេចក្តីត្រិះរិះខុសនៃចិត្តដោយអាការដែលពោលក្នុងឥឡូវនេះ ។ តើពាហិយ:បុរសនោះកើតបរិវិតក្ក:ខុសយ៉ាងណា? គាត់មានបរិវិតក្ក:ខុសយ៉ាងនេះថា បុគ្គលណាមួយក្នុងលោកនេះជាព្រះអរហន្តក្តី ឬថាអ្នកដល់នូវព្រះអរហន្ត ខ្ញុំនេះក៏ជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលទាំងនោះ ។ សេចក្តីនោះមានអធិប្បាយដូច្នេះ ជនពួកណាឈ្មោះថាជា ព្រះអរហន្ត ព្រោះកម្ចាត់សត្រូវ គឺកិលេសក្នុងសត្វលោកនេះ និងព្រោះជាអ្នកគួរដល់បូជា និងសក្ការ:ជាដើម ឬបុគ្គលពួកណា ឈ្មោះថាសម្រេចអរហត្តមគ្គ ព្រោះសម្ងាប់សត្រូវ គឺកិលេសទាំងនោះ បណ្តាអ្នកទាំងនោះ យើងម្នាក់ដែរ ។*

បទថា **បុរាណសាលោហិតា** *បានដល់ ទេវតាអ្នកបំពេញសមណ-ធម៌រួមគ្នា ប្រាកដស្មើដូចអ្នករួមលោហិតក្នុងកពមុន ។ តែអាចារ្យពួកខ្លះពោលថា បទថា* **បុរាណសាលោហិតា** *បានដល់ ទេវតាអង្គមួយអ្នកមានមាតារួមសាលោហិតក្នុងកាលមុន គឺក្នុងកពដទៃ ។ ក្នុងអដ្ឋកថាលោកបដិសេធពាក្យនោះ កាន់យកនូវសេចក្តីដំបូងតែម្យ៉ាង ។*

បានឮថា កាលមុន នាកាលសាសនារបស់ព្រះកស្សបទសពលនឹងសាប-សូន្យ ភិក្ខុ ៧ រូបឃើញប្រការប្លែក ៗ របស់សហធម្មិក: មានសាមណេរជាដើម កើតសេចក្តីតក់ស្លុត គិតថា សាសនាមិនទាន់អន្តរធានដរាបណា យើងនឹងធ្វើ

ទីពីងរបស់ខ្លួនដរាបនោះ ទើបថ្វាយបង្គំសុវណ្ណចេតិយហើយចូលព្រៃ ឃើញកន្ទុំ
មួយ ទើបពោលថា លោកម្ចាស់អង្គណាមានសេចក្តីអាល័យក្នុងជីវិតចូរត្រឡប់
ទៅលោកម្ចាស់អង្គណាមិនមានសេចក្តីអាល័យក្នុងជីវិត សូមឡើងកន្ទុំនេះហើយ
នាំគ្នាចងជណ្តើរឡើងកន្ទុំនោះ ទាំងអស់ហើយទម្លាក់ជណ្តើរចុះ ធ្វើសមណធម៌ ។
បណ្តាភិក្ខុទាំងនោះ ព្រះសង្ឆត្ថេរ សម្រេចព្រះអរហត្តដោយការកន្ទ្ងទៅនៃរាត្រី
ត្រឹមតែមួយប៉ុណ្ណោះ ។ ព្រះសង្ឆត្ថេរអង្គនោះ នាំបិណ្ឌបាតមកពីឧត្តរកុរុទ្វីប
ហើយពោលនឹងភិក្ខុទាំងនោះថា លោកអ្នកមានអាយុទាំងឡាយ សូមនិមន្តធាន់
បិណ្ឌបាតអំពីទីនោះចុះ ។ ភិក្ខុទាំងនោះពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន
លោកម្ចាស់បានធ្វើយ៉ាងនេះដោយអានុភាពរបស់ខ្លួន ប្រសិនបើខ្ញុំព្រះករុណា នឹង
ញ៉ាំងគុណវិសេសឱ្យកើតឡើងដូចលោកម្ចាស់ ខ្ញុំព្រះករុណានឹងនាំបិណ្ឌបាត
ដោយខ្លួនឯងហើយធាន់ ទើបមិនប្រាថ្នានឹងធាន់ ។ តាំងពីថ្ងៃទីពីរបន្ទាប់ពីថ្ងៃ
នោះព្រះថេរៈទី២ ក៏សម្រេចអនាគាមិផល ។ សូម្បីព្រះថេរៈអង្គនោះក៏កាន់
យកបិណ្ឌបាតដោយប្រការដូចគ្នាទៅកាន់ទីនោះ ហើយនិមន្តភិក្ខុក្រៅនេះឱ្យធាន់ ។
ចំណែកភិក្ខុទាំងនោះ ក៏បានបដិសេធដូចយ៉ាងនោះឯង ។ បណ្តាភិក្ខុ ទាំងនោះ
ភិក្ខុអ្នកសម្រេចព្រះអរហត្តក៏បរិនិព្វានទៅ ។ ព្រះអនាគាមីក៏ទៅកើតក្នុងជាន់
សុទ្ធាវាស ។ ចំណែកជន (ភិក្ខុ) ៥ រូបក្រៅនេះ សូម្បីព្យាយាមប្រឹងប្រែងនៅ
ក៏មិនអាចធ្វើគុណវិសេសឱ្យកើតឡើងបាន ។ ភិក្ខុទាំងនោះកាលមិន អាចញ៉ាំង
គុណវិសេសឱ្យកើតឡើងបាន ក៏ស្តមស្តាំងស្ងាប់ក្នុងទីនោះឯងហើយកើតក្នុង
ទេវលោក ។ ជនទាំងឡាយនោះអន្ទោលទៅក្នុងទេវលោកនុ៎ះឯង អស់មួយ
ពុទ្ធន្តរក្នុងពុទ្ធុប្បាទនេះ បានចុតិចាកពីទេវលោក កើតក្នុងផ្ទះមានត្រកូលនោះ។ ។

ក៏បណ្ដាអ្នកទាំង ៥ នាក់នោះ ម្នាក់បានជាព្រះរាជាព្រះនាមថា បុក្កុស:[1] ម្នាក់បានជាកុមារកស្សប: ម្នាក់បានជាទព្ធមល្ល បុត្រ ម្នាក់បានជាសកិយបរិព្វាជក ម្នាក់បានជាពាហិយទារុចីរិយ: ។ បណ្ដាជនទាំងឡាយនោះ ព្រះអនាគាមីអ្នកដែលកើតក្នុងព្រហ្មលោក លោកសំដៅយកពោលពាក្យនេះទុកថា **បុរាណ-សាលោហិតា ទេវតា** ទេវតាអ្នករួមសាលោហិតពីបុរាណដូច្នេះ ។ មែនពិតសូម្បីទេវបុត្រក៏ហៅថា ទេវតា ព្រោះអធិប្បាយថា ទេវតា ក៏គឺទេវដូច ទេពធីតាដូចក្នុងប្រយោគមានជាអាទិ៍ថា **អថ ខោ អញ្ញតរា ទេវតា** គ្រានោះឯងទេវតាអង្គមួយ ។ តែក្នុងទីនេះ ព្រហ្មលោកប្រាថ្នាយកថា ទេវតា ក្នុងស័ព្ទនេះ ។

ក៏កាលព្រហ្មនោះ ត្រួតមើលព្រហ្មសម្បត្តិ ហើយនឹកដល់ស្ថានទីរបស់ខ្លួនមកក្នុងលំដាប់ដែលកើតក្នុងព្រហ្មលោកនោះតែម្តង ការដែលពួកជនទាំង ៣ នាក់ ឡើងភ្នំធ្វើសមណធម៌ក្តី ភាពនៃព្រះអរហន្តមួយអង្គដែលបរិនិព្វានក្នុងទីនោះក្តី ភាពនៃខ្លួនសម្រេចអនាគាមិផល ហើយកើតក្នុង ព្រហ្មលោកក្តីប្រាកដហើយ ។ ព្រហ្មនោះរំពឹងថា ចំណែកជនទាំង ៥ កើតក្នុងទីណាហ្ន៎ ដឹងថា ជនទាំងនោះកើតក្នុងទេវលោកជាកាមាវចរ គ្រាតមកតាមវេលាដែលសមគួរបាន ត្រួតមើលប្រវត្តិរបស់ជនទាំងនោះថា ធ្វើយ៉ាងណាហ្ន៎ ។ តែក្នុងកាលនេះព្រហ្មនោះកាលរំពឹងថា ពួកជនទាំងនោះនៅទីណាហ្ន៎ ទើបបានឃើញពាហិយ: អាស្រ័យកំពង់សុប្បារក: ស្ងៀកសំពត់ក្រងដោយសំបកឈើ ចិញ្ចឹមជីវិតដោយការបញ្ឆោតអ្នកដទៃ ព្រហ្មនោះគិតថា កាលមុនជននេះជាមួយនឹងយើងចង

១-ក្នុងច្បាប់ឆដ្ឋសង្គាយនាថា បក្ខុស: ។

ជណ្តើរឡើងភ្នំធ្វើសមណធម៌មិនអាល័យក្នុងជីវិត ព្រោះប្រព្រឹត្តយ៉ាង ក្រៃលែងសូម្បីព្រះអរហន្ត នឹងនាំបិណ្ឌបាតមកឱ្យក៏មិនធាន់ឥឡូវនេះ ប្រាថ្នាតែនឹងឱ្យគេលើក តម្កើងទាំងមិនមែនជាព្រះអរហន្តឡើយ ក៏នៅតែប្តេជ្ញាខ្លួនថាជា ព្រះអរហន្តមានសេចក្តីប្រាថ្នាលាភសក្តារ: និងកេរ្តិ៍ឈ្មោះទាំងមិនដឹងថា ព្រះទស-ពលឧប្បត្តិឡើងហើយ ណ្លើយចុះយើងនឹងញ៉ាំងពាហិយ:ឱ្យតក់ស្ទុតហើយ ឱ្យដឹងថា ព្រះពុទ្ធឧប្បត្តិឡើងហើយ ភ្លាមនោះឯងទើបចុះពីព្រហ្មលោកប្រាកដត្រង់មុខទារុចីរិយ: ត្រង់កំពង់សុប្បារក:ក្នុងវេលាយប់ ។ ពាហិយ:ឃើញពន្ធឺក្ងីស្វាងរុងរឿងក្នុងទីនៅរបស់ខ្លួនក៏គិតថា នេះហេតុអ្វីហ្ន៎ ហើយបានចេញទៅខាងក្រៅ ក្រឡេកមើលឃើញមហាព្រហ្មបិតនៅឰដ៏អាកាស ទើបផ្តង់អញ្ជលីសួរថា លោកជានរណា? លំដាប់នោះ ព្រហ្មបានពោលនឹងពាហិយ:ថា យើងជាសម្ងាញ់ចាស់របស់លោក គ្រានោះយើងសម្រេចអនាគមិផល កើតក្នុងព្រហ្មលោក តែលោកមិនអាចនឹងធ្វើគុណវិសេសអ្វីឱ្យកើតឡើងបាន ក៏ធ្វើកាលកិរិយាក្នុងភាពជាបុគ្គលអន្ទោលទៅ តែក្នុងឥឡូវអ្នកទ្រទ្រង់នូវភាពជាតិរ្ជិយ មិនមែនព្រះអរហន្តឡើយ នៅតែប្រកាន់លទ្ធិនេះថា យើងជាព្រះអរហន្ត (យើង)ដឹងដូច្នេះ ទើបបានមក ម្នាលពាហិយ: អ្នកមិនមែនជាព្រះអរហន្ត អ្នកចូរលះបង់ទិដ្ឋិដ៏លាមកដូច្នោះ ចេញចុះ អ្នកកុំប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដើម្បីសេចក្តីទុក្ខអស់កាលយូរឡើយ ព្រះសម្មាសម្ពុទ្ធឧប្បត្តិឡើងហើយក្នុងលោក ។ សេចក្តីពិត ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្ត សម្ងាញ់អ្នកចូរទៅ ចូលទៅគាល់ព្រះអង្គចុះ ។

ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា លំដាប់នោះ ទេវតាដែលជាសាលោហិតអំពីដើមរបស់ពាហិយៈបុរស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុកម្បិកា** បានដល់ អ្នកមានប្រក្រតីអនុគ្រោះ គឺអ្នកក្រៃលែងដោយករុណា ។ បទថា **អត្ថកាមា** បានដល់ អ្នកប្រាថ្នាប្រយោជន៍ គឺអ្នកក្រៃលែងដោយមេត្តា ។ ក៏ក្នុងទីនេះ ដោយបទដំបូង លោកសម្តែងដល់សេចក្តី ដែលទេវតានោះប្រាថ្នានឹងបំបាត់ទុក្ខរបស់ពាហិយៈ ដោយបទក្រោយ សម្តែងដល់ការនាំប្រយោជន៍ជួយសង្គ្រោះចូលទៅ ។ បទថា **ចេតសា** បានដល់ ដោយចិត្តរបស់ខ្លួន ។ ក៏ក្នុងទីនេះ គប្បីជ្រាបថា លោកកាន់យកចេតោបរិយញ្ញាណ ដោយផ្តងចិត្តឡើងជាប្រធាន ។ បទថា **ចេតោបវិតក្កំ** បានដល់ ការប្រព្រឹត្តទៅនៃចិត្តរបស់លោក ។ បទថា **អញ្ញាយ** ប្រែថា ដឹងហើយ ។ បទថា **តេនុបសង្កមិ** សេចក្តីថា ព្រហ្មនោះបាត់អំពីព្រហ្មលោក ហើយប្រាកដចំពោះមុខរបស់ពាហិយៈ ប្រៀបដូចជាបុរសដែលមានកម្ទាំងលានូវដើមដៃដែលបត់ ឬបត់ដើមដៃដែលលាចេញ ក៏ដូច្នោះដែរ ។ បទថា **ឯតទវោច** សេចក្តីថា ព្រហ្មបានពោលពាក្យនេះ គឺពាក្យដែលនឹងពោលក្នុងឥឡូវនេះ មានជាអាទិ៍ថា អ្នកមិនមែនព្រះអរហន្តទេ នឹងពាហិយៈ អ្នកមានមិច្ឆាបវិតក្កៈដែលប្រព្រឹត្តទៅ មានជាអាទិ៍ថា អ្នកណាម្នាក់ក្នុងលោកនេះនឹងជាព្រះអរហន្តដូច្នេះ ប្រៀបដូចជាបុគ្គលចាប់ចោរព្រមទាំងរបស់ ។ ដោយបទថា **នេវ ខោ ត្វं ពាហិយ អរហា** នេះ ព្រហ្មបដិសេធថា ពាហិយៈមិនមែនជាព្រះអសេក្ខៈក្នុងកាលនោះ ។ ដោយបទថា **ន ចាបិ អរហត្តមក្តំ វ សមាបន្នោ** នេះសម្តែងថា ពាហិយៈនៅ

ជាសេក្ខបុគ្គល ។ សូម្បីដោយបទទាំងពីរនោះសម្តែងថា ពាហិយ: មិនមែនព្រះអរិយបុគ្គលឡើយ ។ ក៏ដោយពាក្យថា **សាបិ តេ បដិបទា ឧត្តិ យាយ ត្វं អរហា ភ អស្ឍសិ អរហត្តមត្តं ភ សមាបជ្ជោ** នេះ ព្រហ្មបដិសេធថា ពាហិយ:ត្រឹមតែជាកល្យាណបុថុជ្ជន ។ បណ្តាបទទាំងនោះ បទថា **បដិបទា** បានដល់ វិសុទ្ធិ ៦ មានសីលវិសុទ្ធិជាដើម ។ ដែលឈ្មោះថា **បដិបទា** ព្រោះជាគ្រឿងប្រព្រឹត្តទៅក្នុងអរិយមគ្ត ។ បទថា **អស្ឍសិ** ប្រែថា គប្បីមាន ។

សួរថា ក៏ការសម្គាល់ខ្លួនថា ជាព្រះអរហន្តនេះ កើតឡើងដល់ពាហិយ: ព្រោះអាស្រ័យអ្វី? ឆ្លើយថា អាចារ្យពួកខ្លះពោលថា សេចក្ត្ីសម្គាល់ខ្លួនថា ជាព្រះអរហន្តកើតឡើងដល់ពាហិយ: ព្រោះលោកកម្ចាត់កិលេសបានដោយតទង្គ-បហាន ព្រោះហេតុលោកបានសាងបុញ្ញាធិការទុករហូតអស់កាលយូរ ដោយភាពដែលលោកជាអ្នកប្រាជ្ញាតិច សន្ធោសនិងជាអ្នកដុសខាត់ ។ តែអាចារ្យពួកដទៃទៀតពោលថា ពាហិយ:បានឈាន ៤ មានបឋមជ្ឈានជាដើម ព្រោះដូច្នោះ សេចក្ត្ីសម្គាល់ខ្លួនថាជាព្រះអរហន្ត ទើបកើតឡើងដល់លោក ព្រោះកិលេសមិនកើតឡើងដោយវិក្ខម្ភនបហាន ។ ទាំងពីរយ៉ាងនោះត្រឹមតែជាមតិរបស់ភេចិអាចារ្យប៉ុណ្ណោះ ព្រោះមកក្នុងអដ្ឋកថាថា ពាហិយ:ប្រាជ្ញាតែសេចក្ត្ីលើកតម្កើង និងថាពាហិយ:មិនប្រាជ្ញាលាភសក្ការ: និងការសរសើរ ។ ព្រោះដូច្នោះ គប្បីជ្រាបសេចក្ត្ីក្នុងសេចក្ត្ីនេះ ដោយន័យដូចពោលហើយនុ៎ះឯង ។

លំដាប់នោះ ពាហិយ:ក្រឡេកមើលមហាព្រហ្មអ្នកឈរពោលឲ្យដ៏អាកាស ទើបគិតថា ឱហ្ន៎ ! អំពើណាដែលខ្ញុំគិតថាជាព្រះអរហន្ត អំពើនោះជាអំពើធ្ងន់ពិត ទាំងព្រហ្មនេះពោលថា សូម្បីបដិបទាជាគ្រឿងសម្រេចព្រះអរហត្តក៏មិនមាន

ដល់ខ្ញុំ ព្រះអរហន្តណាមួយក្នុងលោកនេះ មានដែរឬហ្ន៎ ។ លំដាប់នោះ ទើបសួរមហាព្រហ្មនោះ ព្រោះហេតុនោះ លោកទើបពោលថា **អថ កោ ចរហិ ខេវតេ លោកេ អរហាន្តោ វា អរហត្តមគ្គំ វាសមាបជ្ជោ** ។

បណ្តាបទទាំងនោះ សព្ទថា **អថ** ជានិបាតប្រើក្នុងអត្ថផ្តើមពាក្យសួរ ។ បទថា **កោ ចរហិ** កែជា **កោ ឋតរហិ** ។ បទថា **លោកេ** បានដល់ ក្នុងឱកាសលោក ។ ក៏ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះ

គ្រានោះ លើផ្ទៃជម្ពូទ្វីបទាំងមូលដែលជាលោកជាទីទទួលនូវសត្វលោកឥឡូវនេះ ព្រះអរហន្ត ឬអ្នកសម្រេចអរហត្តមគ្គមាននៅទីណា យើងទាំងឡាយនឹងចូលទៅរកព្រះអរហន្តទាំងនោះ តាំងនៅក្នុងឱវាទរបស់ព្រះអរហន្តហើយនឹងរួចផុតពីវដ្តទុក្ខ ។ បទថា **ឧត្តរេសុ** លោកពោលសំដៅយកផ្នែកនៃទិសខាងកើតធ្វើងខាងជើងពីកំពង់សុឃ្ជារក:។

បទថា **អរហំ** បានដល់ ឈ្មោះថាជាព្រះអរហន្ត ព្រោះជាអ្នកឆ្ងាយ ។ មែនពិត ព្រះអរហន្តនោះ ឈ្មោះថា ជាអ្នកឆ្ងាយ គឺតាំងនៅក្នុងទីឆ្ងាយសែនឆ្ងាយចាកកិលេសទាំងពួង ព្រោះជាអ្នកកម្ចាត់កិលេសព្រមទាំងវាសនាដោយមគ្គ ឬសម្ងាប់កិលេសដូចសត្រូវចេញបាន ។ មែនពិត សត្រូវ គឺកិលេសទាំងឡាយដែលព្រះដ៏មានព្រះភាគសម្ងាប់ គឺដកហើយដោយអរហត្តមគ្គមិនឱ្យសេសសល់ ។ ម្យ៉ាងទៀត ឈ្មោះថា **ព្រះអរហន្ត** ព្រោះកម្ចាត់កាំ គឺកិលេសចេញបាន ។ មែនពិត ព្រះដ៏មានព្រះភាគនោះ ទ្រង់ប្រថាប់នៅលើប្រឋពី គឺសីល ដោយព្រះយុគលបាទ គឺវីរិយ: ទ្រង់ប្រើព្រះហស្ត គឺសទ្ធា ចាប់ពួយ គឺញាណ ដែល

ជាហេតុធ្វើកម្មឱ្យអស់ ហើយទ្រង់ប្រហារ គឺកម្ចាត់កាំទាំងអស់នៃសង្សារចក្រ ដែលសម្រេចដោយអវិជ្ជា ភព និងតណ្ហា មានបុញ្ញាភិសង្ខារជាដើមជាកាំ មានជរា និងមរណៈជាកង់ សៀតភ្ជៅដែលសម្រេចដោយអាសវៈ សមុទយៈប្រកបចូលក្នុងរថ គឺភព ៣ ប្រព្រឹត្តទៅរហូតដល់អស់កាលមិនមានខាងដើម ។ ម្យ៉ាងទៀត ឈ្មោះថា **ព្រះអរហន្ត** ព្រោះជាអ្នកគួរ ។ សេចក្ដីពិត ព្រះដ៏មានព្រះភាគរមែងគួរដល់បច្ច័យមានចីវរជាដើមដ៏ក្រៃលែង និងគួរដល់ការបូជាដ៏ពិសេស ព្រោះព្រះអង្គជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក ។ ម្យ៉ាងទៀត ឈ្មោះថា **ព្រះអរហន្ត** ព្រោះមិនមានទីកំបាំង ។ មែនពិត ព្រះតថាគតលោកហៅថា **ព្រះអរហន្ត** ព្រោះមិនធ្វើអំពើបាបក្នុងទីកំបាំង ដោយកិលេសដ៏លាមកមិនមាន ព្រោះព្រះអង្គដកកិលេសមានរាគៈជាដើមបានដោយប្រការទាំងពួង ។

ឈ្មោះថា **សម្មាសម្ពុទ្ធៈ** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងចំពោះព្រះអង្គឯង ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹងដ៏ក្រៃលែង ដោយធម៌ជាគ្រឿងធ្វើឱ្យត្រាស់ដ៏ក្រៃលែង នូវធម៌ដែលគួរកំណត់ដឹង ដោយធម៌ជាគ្រឿងគួរកំណត់ដឹង នូវធម៌ដែលគួរលះ ដោយធម៌ជាគ្រឿងគួរលះ នូវធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់ ដោយធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់ នូវធម៌ដែលគួរចម្រើនដោយធម៌ដែលគួរចម្រើន ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា

អភិញ្ញេយ្យំ អភិញ្ញាតំ ភាវេតព្វញ្ច ភាវិតំ
បហាតព្វំ បហីនំ មេ តស្មា ពុទ្ធោស្មិ ព្រាហ្មណា។

វិជ្ជា នឹងវិមុត្តិដែលគប្បីដឹងច្បាស់ *តថាគតដឹងច្បាស់ហើយ* មគ្គសច្ចៈ ដែលគប្បីចម្រើន *តថាគតបានចម្រើនហើយ* សមុទយសច្ចៈ ដែលគប្បីលះ *តថាគតបានលះបង់ហើយ* ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ទើបតថាគតឈ្មោះថា **ពុទ្ធ**:[1]។

ម្យ៉ាងទៀត បណ្ឌិតគប្បីនាំអត្ថនេះ ដោយធម៌ពួក ៣ និងធម៌ពួក ២ ទាំងពួងជាដើម ដោយន័យមានជាអាទិ៍ថា ធម៌ឈ្មោះថា ជាកុសល ព្រោះមិនមានទោស មានសុខជាផល ធម៌ឈ្មោះថា ជាអកុសល ព្រោះមានទោស មានទុក្ខជាផល ។ ក្នុងសេចក្ដីនេះមានសេចក្ដីសង្ខេបដូចេ្នះថា ឈ្មោះថា **សម្មាសម្ពុទ្ធ**: ព្រោះត្រាស់ដឹងក្រៃលែងនូវធម៌ទាំងពួងដោយអាការទាំងពួង ដោយសយម្ភូញាណ ដែលមិនវិបរិតដោយប្រការដូចេ្នះ ។ ចំណែកសេចក្ដីពិស្តារគប្បីជ្រាបដោយន័យដែលមកហើយក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។ បទថា **អរហត្តាយ** បានដល់ បាននូវអរហត្ត-ផល ។ បទថា **ធម្មំ ទេសេតិ** សេចក្ដីថា រមែងអាង គឺសម្ដែងធម៌ជាបដិបទាមានសីលជាដើម ដែលគួរដល់គុណពិសេសមានលម្អក្នុងខាងដើមជាដើម ឬធម៌គឺសមថៈ និងវិបស្សនា ដែលសមគួរដល់អធ្យាស្ស័យរបស់វេនេយ្យសត្វនុ៎ះឯង ។ បទថា **សំវេជិតោ** សេចក្ដីថា បានដល់ ញ្ជាំងសេចក្ដីតក់ស្ទុតឱ្យកើតឡើងថា នែ៎អ្នកដ៏ចម្រើន ភាពជាបុថុជ្ជនគួរតិះដៀលពិត ខ្ញុំនេះមិនមែនជាព្រះអរហន្ត ហើយសម្គាល់ថាជាព្រះអរហន្ត ទាំងជាអ្នកមិនដឹងនូវព្រះសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោក ព្រះអង្គកំពុងសម្ដែងព្រះធម៌ ក៏ការរស់នៅ គឺគេដឹងបានលំបាក សេចក្ដីស្លាប់ គឺគេដឹងបានលំបាក ។ *អធិប្បាយថា* មានចិត្តស្ទុតដោយអាការ

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១៩៧ ។

តាមដែលពោលហើយ ដោយពាក្យនិយាយរបស់ទេវតា ។ បទថា **តាវទេវ** ប្រែថា ក្នុងខណៈនោះឯង ។ បទថា **សុប្បារកា បក្កាមិ** សេចក្តីថា អ្នកមានហឫទ័យ គឺបីតិមានព្រះពុទ្ធជាអារម្មណ៍កើតឡើង ព្រោះបានឮនូវព្រះនាមថា **ពុទ្ធោ** និង ត្រូវសេចក្តីសង្វេគដាស់តឿន ទើបបានចេញពីកំពង់សុប្បារកៈ ឆ្ពោះទៅកាន់ក្រុង-សាវត្ថី ។ បទថា **សព្វត្ថ ឯករត្តិបរិវាសេន** សេចក្តីថា បានទៅដោយនៅតែ ក្នុងផ្លូវទាំងពួងអស់ ១ យប់ ។ មែនពិត ចម្ងាយពីក្រុងសាវត្ថីទៅកំពង់សុប្បារកៈ មានប្រវែង ១២០ យោជន៍ តែពាហិយៈនេះ បានទៅកាន់ក្រុងសាវត្ថី នោះ ដោយស្នាក់នៅតែមួយរាត្រីអស់រយៈផ្លូវចម្ងាយប៉ុណ្ណោះ ។ ពាហិយៈនោះ ចេញ ពីកំពង់សុប្បារកៈក្នុងថ្ងៃណា ក៏ដល់ក្រុងសាវត្ថីក្នុងថ្ងៃនោះ ។ សួរថា ក៏យ៉ាងណា ក៏ពាហិយៈបានទៅកាន់ទីនោះដោយរបៀបណា? ឆ្លើយថា ពាហិយៈ ទៅទីនោះ បានដោយអានុភាពរបស់ទេវតា ។ អាចារ្យពួកខ្លះពោលថា ព្រោះពុទ្ធានុភាពក៏ មាន ។ ជាការសម្តែងអធិប្បាយទុកដូច្នេះថា ក៏ព្រោះលោកពោលថា ដោយ សម្រាកតែមួយរាត្រីក្នុងទីទាំងពួង និងព្រោះផ្លូវមានចម្ងាយ ១២០ យោជន៍ ក្នុង ចន្លោះផ្លូវលោកមិនឱ្យអរុណទី ២ តាំងឡើងក្នុងទីដែលខ្លួនស្នាក់នៅក្នុងយប់ ក្នុងស្រុក និគម និងរាជធានី ទើបទៅដល់ក្រុងសាវត្ថីដោយសម្រាកតែមួយរាត្រី ក្នុងទីគ្រប់កន្លែង ។ ប្រការនេះ បណ្ឌិតមិនគប្បីយល់នេះទេ ព្រោះភាវៈនៃ សេចក្តី នោះ គឺលោកបំណងយកយ៉ាងនេះថា ពាហិយៈអាស្រ័យនៅក្នុងផ្លូវ ប្រមាណ ១២០ យោជន៍ទាំងអស់ ដោយការស្នាក់ត្រឹមតែមួយរាត្រី ។ ពាហិយៈ នោះ នៅលើផ្លូវទាំងអស់ត្រឹមតែមួយរាត្រីដល់ក្រុងសាវត្ថីក្នុងវេលាល្ងាច ។

ចំណែកព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវការមករបស់ពាហិយៈ ព្រះអង្គ

ទ្រង់ត្រិះរិះថា ដំបូងឥន្ទ្រិយរបស់ពាហិយៈមិនទាន់ចាស់ក្លា តែក្នុងចន្លោះនៃខណៈនោះ ឥន្ទ្រិយនឹងដល់នូវភាពចាស់ក្លា ដូច្នេះហើយ រង់ចាំឱ្យលោកមានឥន្ទ្រិយចាស់ក្លា ព្រះដ៏មានព្រះភាគទ្រង់មានភិក្ខុសង្ឆដ៏ច្រើនហែហមជាបរិវារ យាងបិណ្ឌបាតទៅកាន់ក្រុងសាវត្ថីក្នុងខណៈនោះ ។ ចំណែកពាហិយៈនោះ ក៏ចូលទៅកាន់វត្តជេតពន ឃើញភិក្ខុជាច្រើនធាន់ភត្តាហារពេលព្រឹក ហើយចង្ក្រមនៅក្នុងទីវាល ដើម្បីបន្ទោបង់នូវសេចក្ដីខ្ជិលច្រអូសកាយ ទើបសួរថា ឥឡូវនេះ ព្រះដ៏មានព្រះភាគប្រថាប់នៅទីណា ។ ភិក្ខុទាំងឡាយពោលថា ព្រះដ៏មានព្រះ-ភាគទ្រង់បានទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ហើយសួរថា ចុះលោកមកពីណា? ពាហិយៈធ្វើយថា ខ្ញុំព្រះករុណាមកពីកំពង់សុប្បារកៈ ។ ភិក្ខុទាំងឡាយពោលថា អ្នកមកអំពីឆ្ងាយ អញ្ជើញអង្គុយសិនចុះ ចូរលាងជើង លាបប្រេង ហើយសម្រាកមួយភ្លេតក្នុងវេលាព្រះអង្គយាងត្រឡប់មក អ្នកនឹងបានជួបព្រះ-សាស្ដា ។ ពាហិយៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនដឹងសេចក្ដីអន្ដរាយនៃជីវិតរបស់ខ្លួនទេ ខ្ញុំព្រះករុណាមិនឈរមិនអង្គុយអស់កាលយូរក្នុងទីណាៗ សូម្បីដោយរាត្រីមួយមកអស់ផ្លូវ ១២០ យោជន៍ សមគួរនឹងមកគាល់ព្រះសាស្ដា ហើយសម្រាក ទើបប្រញាប់ទៅកាន់ក្រុងសាវត្ថី ឃើញព្រះដ៏មានព្រះភាគ ព្រះអង្គរុងរោចន៍ដោយពុទ្ធសិរីរកបុគ្គលណាផ្ទឹមពុំបាន ។ ព្រោះហេតុនោះ លោកទើបពោលថា សម័យនោះ គាប់ជួនភិក្ខុច្រើនរូបកំពុងដើរចង្ក្រមក្នុងទីវាល ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ក៏ឈានទៅរកពួកភិក្ខុជាដើម ។

បណ្ដាបទទាំងនោះ បទថា **ककॡं** ជា **कत्त** ប្រែថាក្នុងទីណា ។ ស័ព្ទថា

ជ ប្រើក្នុងអត្ថថា សង្ស័យ ។ ស័ព្ទថា **ខោ** ប្រើក្នុងអត្ថថា ធ្វើបទឱ្យពេញ ។ អធិប្បាយថា ក្នុងប្រទេសណាហ្ន៎ ។ បទថា **ឧស្សុនកាមម្ហា** ប្រែថា ជាអ្នកប្រាថ្នានឹងឃើញ ។ លោកសម្តែងទុកថា ក៏យើងប្រាថ្នានឹងគាល់ និងចូលទៅជិតព្រះដ៏មានព្រះភាគនោះ ដូចមនុស្សខ្វាក់ប្រាថ្នាចក្ខុបសាទ ដូចអ្នកថ្ងង់ប្រាថ្នាសោតប្បសាទ ដូចមនុស្សគប្រាថ្នាការពោលឱ្យដឹងរឿង ដូចអ្នកមានដៃជើងវិកលប្រាថ្នាដៃជើង ដូចអ្នកខ្វះខាតប្រាថ្នាទ្រព្យសម្បត្តិ ដូចអ្នកធ្វើដំណើរផ្លូវដាច់សង្ខែង ប្រាថ្នាកន្ទែងដែលរួចផុតភ័យ ដូចអ្នកត្រូវរោគគ្របសង្កត់ប្រាថ្នាសេចក្តីមិនមានរោគ ដូចអ្នកត្រូវទឹកក្រឡាប់ក្នុងមហាសមុទ្រប្រាថ្នាកប្ជនធំដូច្នោះ ។ បទថា **តរមានរូចោ** បានដល់ ជាអ្នកមានអាការប្រញាប់ប្រញាល់ ។

បទថា **ចាសាឥកំ** សេចក្តីថា នាំមកនូវសេចក្តីជ្រះថ្លាជុំវិញ ដល់ជនអ្នកខ្ជិលខ្ជាយក្នុងការឃើញព្រះរូបកាយ ព្រោះបរិបូរនូវភាពស្អាតនៃសរីរៈរបស់ព្រះអង្គ ដែលនាំសេចក្តីជ្រះថ្លាមកជុំវិញ ដែលប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ អនុព្យញ្ជនៈ ៨០ ព្រះរស្មីមួយព្យាម និងព្រះកេតុមាលា ។ បទថា **បសាទនីយំ** សេចក្តីថា ជាទីតាំងនៃសេចក្តីជ្រះថ្លា សមគួរដែលនឹងគួរជ្រះថ្លា ឬគួរដល់សេចក្តីជ្រះថ្លារបស់ជនអ្នកមានបញ្ញាឃើញប្រចក្ស ព្រោះបរិបូរដោយកាយសម្បត្តិ ដែលប្រកបដោយព្រះគុណប្រមាណមិនបាន មានទសពលញាណ ១០ វេសារជ្ជញាណ ៤ អសាធារណញាណ ៦ អាវេណិកពុទ្ធធម៌ ១៨ ជាដើម ។ បទថា **សន្តិន្ទ្រិយំ** បានដល់ ឥន្ទ្រិយ ៥ ដែលស្ងប់រម្ងាប់ ព្រោះប្រាសចាកសេចក្តីញាប់ញ័រក្នុងឥន្ទ្រិយទាំង ៥ មានចក្ខុន្ទ្រិយជាដើម ។ បទថា **សន្តមានសំ** បានដល់ មានចិត្តស្ងប់រម្ងាប់ ព្រោះចូលដល់ភាវៈដែល

មនិន្ទ្រិយទី ៦ អស់អស្មិមាន: ។ បទថា **ឧត្តមឧមថសមថមនុប្ឍត្តំ** សេចក្ដីថា ដល់ដោយលំដាប់ គឺសម្រេចសេចក្ដីទូន្មាននិងសេចក្ដីស្ងប់ដ៏ខ្ពង់ខ្ពស់បំផុត ពោលគឺបញ្ញាវិមុត្តិ និងចេតោវិមុត្តិដែលជាលោកុត្តរៈហើយតាំងនៅ ។ បទថា **ឧដ្ឋំ** សេចក្ដីថា ឈ្មោះថា ទូន្មានកាយ ព្រោះមានកាយសមាចារបរិសុទ្ធល្អ និងព្រោះមិនមានការលេង ដោយមិនមានការធ្ពាំធ្ពងដៃ និងជើងជាដើម ។ បទថា **ឋិតំ** សេចក្ដីថា ឈ្មោះថា ឃុំគ្រងវាចា ព្រោះមានវចីសមាចារបរិសុទ្ធល្អ និងព្រោះមិនមានការលេង ដោយមិនមានវាចាគ្មានប្រយោជន៍ជាដើម ។ បទថា **យតិ-ន្ទ្រិយំ** បានដល់ ឈ្មោះថា មានឥន្ទ្រិយសង្រួមហើយ ដោយការប្រកបឫទ្ធិដែលជារបស់ព្រះអរិយៈ ព្រោះមានមនោសមាចារបរិសុទ្ធដោយល្អ និងដោយអំណាចមនិន្ទ្រិយ ព្រោះមានសេចក្ដីព្រងើយក្នុងការមិនខ្ជិលខ្ជាយ និងការមិនពិចារណា ។ បទថា **ឌាតំ** សេចក្ដីថា ឈ្មោះថា អ្នកប្រសើរព្រោះហេតុទាំងនេះ គឺការមិនលុះក្នុងអំណាចឆន្ទាគតិជាដើម កិលេសមានរាគៈជាដើម ដែលលះបានហើយមិនត្រឡប់កើតទៀត គឺមិនវិលត្រឡប់មក បាបសូម្បីអ្វីក៏មិនធ្វើសូម្បីដោយប្រការទាំងពួង និងមិនទៅកាន់ភពថ្មី ។ ក៏ដោយបទថា **ចាសនិកំ** នេះ ក្នុងអធិការនេះ លោកសម្ដែងដល់សេចក្ដីសម្គាល់របស់ព្រះដ៏មានព្រះភាគដោយរូបកាយ ។ ដោយបទថា **ឧសាឧនីយំ** នេះ សម្ដែងដល់សេចក្ដីសម្គាល់របស់ព្រះដ៏មានព្រះភាគដោយធម្មកាយ ។ ដោយបទមានជាអាទិ៍ថា **សន្ដិន្ទ្រិយំ** នេះ សម្ដែងដល់សេចក្ដីសម្គាល់របស់ព្រះគុណដែលនៅសល់ ។ ព្រោះហេតុនោះ គប្បីជ្រាបថា លោកប្រកាសសេចក្ដីសម្គាល់របស់ព្រះដ៏មានព្រះភាគដល់ពួក

សត្វដោយមិនឱ្យសេសសល់ ក្នុងលោកសន្និវាសដែលកាន់ប្រមាណ ៦ ពួក ។

ចំណែកឯពាហិយ:បុរស ឃើញព្រះដ៏មានព្រះភាគអ្នកប្រកបដោយគុណយ៉ាងនោះកំពុងយាងតាមផ្លូវ ជាអ្នកមានចិត្តរីករាយត្រេកអរគិតថា កាលយូរណាស់ហើយ ខ្ញុំទើបបានឃើញព្រះដ៏មានព្រះភាគ ជាអ្នកមានសរីរ:ត្រូវបីតិ ៥ ប្រការពាល់ត្រូវរហូតដល់កាលយូរ ជាអ្នកមានភ្នែកមិនប៉ះប្រិច ព្រោះបីតិជ្រួតជ្រាប ជាអ្នកមានសរីរ:បង្ហើន តាំងពីបានឃើញព្រះដ៏មានព្រះភាគមកម្ល៉ះ ក៏លិចត្រង់កណ្ដាលរស្មីព្រះរកាយរបស់ព្រះដ៏មានព្រះភាគ លុះលិចចុះក្នុងព្រះរស្មីនោះហើយ ក៏ចូលទៅជិតព្រះដ៏មានព្រះភាគថ្វាយបង្គំដោយបញ្ចង្គ-ប្រតិស្ឋាន គក់ច្រមាច់ ជញ្ជក់ទូវព្រះយុគលបាទរបស់ព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ មេត្តាសម្ដែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ពាហិយ:មានសិរសាខ្ពិនចុះទៀបព្រះបាទនៃព្រះដ៏មានព្រះភាគ ហើយអាងធនាព្រះដ៏មាន-ព្រះភាគនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្ដែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្ដែងដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់រាត្រីដ៏វែងដល់ខ្ញុំព្រះអង្គឱ្យទាន ។

បណ្ដាបទទាំងនោះ បទថា **សុគតោ** *សេចក្ដីថា ឈ្មោះថា សុគត: ព្រោះព្រះអង្គយាងទៅដោយល្អ គឺទៅកាន់ទីដ៏ល្អ យាងទៅដោយប្រពៃ មានព្រះវាចាប្រពៃ ។ មែនពិត ដំណើរទៅលោកហៅថា* **គត:** *។ ក៏ដំណើរទៅនោះ របស់ព្រះដ៏មានព្រះភាគជាដំណើរល្អ គឺបរិសុទ្ធមិនមានទោស ។ សួរថា ដំណើរទៅគឺអ្វី? ឆ្លើយថា គឺអរិយមគ្គ ។ មែនពិត ព្រះដ៏មានព្រះភាគនោះ ស្ដេចយាង*

ទៅកាន់ទិសដ៏ក្សេម មិនជាប់ដោយដំណើរទៅនោះ ។ សូម្បីអ្នកដទៃ ក៏ព្រះអង្គ ញ៉ាំងឱ្យទៅ ព្រោះដូច្នោះ ទើបឈ្មោះថា **សុគត** ព្រោះស្តេចយាងទៅដោយល្អ ។ ក៏ព្រះដ៏មានព្រះភាគអង្គនោះស្តេចយាងទៅកាន់ទីដ៏ល្អ ជាអមត: គឺនិព្វាន ព្រោះដូច្នោះ ទើបឈ្មោះថា **សុគត** ព្រោះស្តេចយាងទៅកាន់ទីដ៏ល្អ ។ ឈ្មោះថា **សុគត** ព្រោះព្រះអង្គយាងទៅដោយប្រពៃ ព្រោះហេតុមិនវិលត្រឡប់មកកាន់កិលេសដែលព្រះអង្គប្រហារដោយមគ្គនោះ។ ។ សមដូចដែលលោកពោលទុកថា កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយដោយសោតាបត្តិមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មក ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះថា **សុគត** ។ កិលេសទាំងឡាយណា ដែលព្រះដ៏មានព្រះភាគ ព្រះអង្គលះហើយ ដោយសកទាគាមិមគ្គ ដោយអនាគាមិមគ្គ ដោយអរហត្តមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មកកាន់កិលេសនោះទេ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគអង្គនោះ ទើបឈ្មោះថា **សុគត**[1] ។ ម្យ៉ាងទៀត បទថា **សម្មាកតត្តា** សេចក្តីថា ព្រោះស្តេចយាងទៅ គឺដំណើរទៅដោយល្អ ដោយសម្មាបដិបត្តិ សូម្បីក្នុងការកំណត់ទាំង ៣ យ៉ាង ។ មែនពិត ឈ្មោះថា **សុគត** ព្រោះស្តេចទៅដោយប្រពៃ សូម្បីដោយអាការយ៉ាងនេះថា ព្រះអង្គទ្រង់សម្រេចទីបំផុតញ្ញាតត្ថចរិយា លោកត្ថចរិយា ពុទ្ធត្ថចរិយា ដោយសម្មាបដិបត្តិដែលបរិបូរដោយបារមី ៣០ គត់ ចាប់ផ្តើមតាំងពីបាទមូលព្រះពុទ្ធទីបង្ករ ដរាបដល់មហាពោធិមណ្ឌាល ទ្រង់កពូនចំពោះនូវប្រយោជន៍សុខដល់លោកទាំងពួង

១-សុត្តន្តបិដក ខុទ្ទកនិកាយ ចូឬនិទ្ទេស លេខ ៦៧ ទំព័រ ១៦២ ។

*តអំពីនោះ ទើបស្តេចយាងទៅ គឺដំណើរទៅដោយភាពជាធំក្នុងធម៌ ដែលព្រះអង្គទ្រង់សម្រេចក្នុងអរិយសច្ច: ៤ ដោយមជ្ឈិមាបដិបទាពោលគឺ ពោជ្ឌង្គ-ភាវនាដ៏កំពូលមិនជាប់ជំពាក់ក្នុងធម៌អមទាំងនេះ គឺ"សស្សតទិដ្ថិ ឧច្ឆេទទិដ្ថិ កាមសុខល្ងិកានុយោគ និងអត្តកិលមថានុយោគ" និងដោយសម្មាបដិបត្តិដែលមិនមែនជាវិស័យនៃសត្វទាំងពួង ។ ក៏ព្រះដ៏មានព្រះភាគអង្គនោះ ត្រាស់ដោយប្រពៃ គឺត្រាស់នូវវាចាដ៏សមគួរក្នុងទីដ៏គួរ ព្រោះហេតុនោះ ឈ្មោះថា **សុគត** ។ សមដូចព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គ ពោលពាក្យក្នុងកាលគួរ ពោលតែពាក្យពិតប្រាកដ ពោលតែពាក្យដែលជាអត្ថ ពោលតែពាក្យដែលជាធម៌ ពោលតែពាក្យដែលជាវិន័យ ពោលតែពាក្យមានឱកាសជាទីតម្កល់ទុកក្នុងហ្ជឺទ័យប្រកបដោយគ្រឿងអាង មានគ្រឿងកំណត់ប្រកបដោយប្រយោជន៍ដោយការដ៏គួរ[1] ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកទៀត មានជាអាទិ៍ថា វាចាឯណានោះ ជាវាចាមិនពិត វាចាមិនទៀង វាចាមិនប្រកបដោយប្រយោជន៍ ១ វាចាឯណា ជាវាចាមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តដល់ជនដទៃ ១ តថាគតមិនពោលនូវវាចានោះទេ[2] ។ ឈ្មោះថា **សុគត** ព្រោះត្រាស់ប្រពៃដោយប្រការដូច្នេះ ។ បទថា **យំ មមស្ស ឌីឃរត្តំ ហិតាយ សុខាយ** សេចក្តីថា ការសម្តែងអាងដល់កម្មណា គប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ឈាន និងវិមោក្ខជាដើម និងដើម្បីសុខដែលនឹងគប្បីសម្រេចឈាន និងវិមោក្ខជាដើមនោះដល់ខ្ញុំព្រះអង្គរហូតអស់កាលយូរ ។*

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ១០ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក លេខ ២៣ ទំព័រ ១៥៣ ដល់ ១៥៧ ។

បទថា **អកាលោ ខោ តាវ ពហិយ** *សេចក្ដីថា ម្នាលពហិយ: កាលនេះ មិនមែនកាលដើម្បីសម្ដែងធម៌ដល់លោកមុនទេ ។ អធិប្បាយថា ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគទើបមិនមានកាលក្នុងការបដិបត្តិប្រយោជន៍ដល់សត្វហ្នឹ ព្រោះព្រះដ៏មានព្រះភាគជាកាលវាទី ។ ក៏ក្នុងពាក្យថា* **កាលោ** *នេះ ប្រាជ្ញាយកកាលដែលពួកវេនេយ្យសត្វមានឥន្ទ្រិយចាស់ក្លា ។ ដោយហេតុថា ក្នុងខណ:នោះ ការដឹងបានដោយលំបាកនូវឥន្ទ្រិយទាំងឡាយរបស់ពាហិយ:ចាស់ក្លា ឬមិនខ្លាំងក្លាដូច្នោះ ព្រះដ៏មានព្រះភាគទើបមិនត្រាស់ទេសនានោះ កាលទ្រង់អាងដល់ការប្រថាប់របស់ព្រះអង្គចន្ទោះថ្នល់ ទើបត្រាស់ថា* **អន្តរឃរំ បវិដ្ឋម្ហា** *ដូច្នេះ ។*

បទថា **ឧជ្ជានំ** *ប្រែថា គប្បីដឹងបានដោយលំបាក ។ ដោយបទថា* **ជីវិត-ន្តរាយានំ** *ពាហិយ:ប្រាជ្ញានឹងពោលថា ការប្រព្រឹត្តទៅ ឬមិនប្រព្រឹត្តទៅនៃធម៌ដែលធ្វើអន្តរាយចំពោះជីវិត ទើបពោលថា* **ជីវិតន្តរាយានំ** *ដូច្នេះ ដោយអំណាចនៃការផ្ទាស់ប្ដូរ ។ ពិតយ៉ាងនោះ ជីវិត គឺការប្រព្រឹត្តទៅជាប់ដោយបច្ច័យជាច្រើន និងអន្តរាយចំពោះជីវិតនោះក៏មានច្រើន ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ថា*

អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។

បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុដែលមានសេនាដ៏ច្រើន

នោះ មិនមានសោះឡើយ[1] ។

ក៏ព្រោះហេតុអ្វី ពាហិយៈនេះទើបប្រាថ្នាតែអន្តរាយជីវិតប៉ុណ្ណោះ ជាការរលត់ដំបូង ។ អាចារ្យពួកខ្លះធ្វើយថា ព្រោះលោកដឹងតែអារម្មណ៍ដែលជានិមិត្ត ឬធ្លាតក្នុងវត្ថុដែលខ្លួនមិនឃើញ ។ អាចារ្យមួយពួកទៀតពោលថា ព្រោះលោកបានឮសេចក្ដីអន្តរាយជីវិតក្នុងសម្ផាក់របស់ទេវតា ។ ក៏លោកត្រូវឧបនិស្សយសម្ផត្តិដាស់តឿន ទើបពោលយ៉ាងនោះ ព្រោះជាអ្នកមានកពចុងក្រោយ ។ មែនពិត សេចក្ដីអន្តរាយនៃជីវិតរមែងមិនមានដល់បុគ្គលអ្នកដល់ព្រមដោយឧបនិស្សយសម្ផត្តិទាំងឡាយនោះដែលមិនទាន់សម្រេចអរហត្តឡើយ ។ ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគមានព្រះបំណងនឹងទ្រង់សម្ដែងធម៌ដល់ពាហិយៈ ន៏ុះឯង បែរជាបដិសេធអស់វារៈ ២ ដងទៅវិញ បានឮថា ព្រះអង្គមានព្រះតម្រិះយ៉ាងនេះថា តាំងពីវេលាដែលពាហិយៈនេះ ឃើញតថាគតសរីរៈទាំងអស់ ដែលបីតិពាល់ត្រូវអស់កាលយូរ ជាបីតិដ៏មានកម្ទាំងខ្ទាំងក្ដា សូម្បីនឹងស្ដាប់ធម៌ហើយ ក៏មិនអាចធ្វើឱ្យជាក់ច្បាស់ដដែល ទើបបដិសេធ ដរាបដល់មជ្ឈត្ដុបេក្ខានឹងតាំងនៅមុន សូម្បីសេចក្ដីខ្ជល់ខ្ជាយក្នុងកាយរបស់ពាហិយៈក៏មានកម្ទាំង ព្រោះពាហិយៈមកកាន់ផ្ទូវមានចម្ងាយ ១២០ យោជន៍ សូមឱ្យពាហិយៈនោះសូប់រម្ងាប់សិន ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់បដិសេធអស់វារៈ ២ ដង ។ តែអាចារ្យពួកខ្លះពោលថា ព្រះដ៏មានព្រះភាគបានទ្រង់ធ្វើយ៉ាងនោះ ដើម្បីឱ្យយកចិត្ដទុកដាក់ក្នុងការស្ដាប់ធម៌ ។ តែព្រះអង្គរង់ចាំឱ្យពាហិយៈអង្វរអស់វារៈ

១-សុត្ដន្ដបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក លេខ ២៨ ទំព័រ ២ ។

៣ ដង ទើបទ្រង់ឃើញមជ្ឈត្តុបេក្ខាជាគ្រឿងរម្ងាប់សេចក្តីខ្ជល់ខ្ជាយ និងអន្តរាយជីវិត ដែលប្រាកដដល់ពាហិយៈនោះ ទ្រង់មានព្រះតម្រិះថា ឥឡូវនេះជាកាលគួរដើម្បីសម្តែងធម៌ ទើបផ្តើមសម្តែងធម៌ ដោយន័យមានជាអាទិ៍ថា **តស្មាតិហ តេ** ជូនេះ ។

បណ្តាបទទាំងនោះ បទថា **តស្មា** សេចក្តីថា ព្រោះពាហិយៈជាអ្នកមានសេចក្តីខ្ជល់ខ្ជាយអង្វរតថាគតយ៉ាងក្រៃលែង ឬព្រោះលោកពោលថា អន្តរាយជីវិតដឹងបានលំបាក និងឥន្ទ្រិយរបស់ពាហិយៈចាស់ក្លាហើយ ។ ស័ព្ទថា **តិហ** ត្រឹមតែជានិបាត ។ បទថា **តេ** ប្រែថា គឺលោក ។ ដោយពាក្យថា **ឯវํ** នេះ ត្រាស់ដល់អាការដែលនឹងពោលក្នុងឥឡូវនេះ ។

បទថា **សិក្ខិតព្វํ** សេចក្តីថា គប្បីសិក្សាដោយអំណាចសិក្ខា សូម្បីទាំង ៣ មានអធិសីលសិក្ខាជាដើម ។ តែកាលព្រះអង្គនឹងទ្រង់សម្តែងអាការ ដែលនឹងគប្បីសិក្សា ទើបត្រាស់ពាក្យមានជាអាទិ៍ថា **ឥធ្ឍ ឥធ្ឍមត្តํ ភវิស្សតិ** កាលឃើញក៏ត្រឹមតែជាការឃើញ ។

បណ្តាបទទាំងនោះ បទថា **ឥធ្ឍ ឥធ្ឍមត្តํ** បានដល់ ត្រឹមតែការឃើញរូបាយតនៈ ដោយចក្ខុវិញ្ញាណ ។ អធិប្បាយថា លោកគប្បីសិក្សាថា ចក្ខុ-វិញ្ញាណ ឃើញរូបក្នុងរូបប៉ុណ្ណោះ មិនបានឃើញសភាពលក្ខណៈ មានអនិច្ច-លក្ខណៈជាដើមទេ យ៉ាងណា រូបដែលនៅសល់តែជារូបដែលយើងបានឃើញដោយវិញ្ញាណដែលប្រព្រឹត្តទៅតាមចក្ខុទ្វារនោះប៉ុណ្ណោះ ។ ម្យ៉ាងទៀត អធិប្បាយថា ការដឹងច្បាស់នូវរូបក្នុងរូបដោយចក្ខុវិញ្ញាណ ឈ្មោះថា ឃើញរូបក្នុងរូប

ដែលឃើញ ។ បទថា **មត្តំ** ប្រែថា ប្រមាណ ។ ប្រមាណនៃរូបនេះ ដែលឃើញ ហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **ទិដ្ឋមត្ត** ។ អធិប្បាយថា ចិត្តត្រឹមតែជាចក្ខុ-វិញ្ញាណជាប្រមាណប៉ុណ្ណោះ ។ លោកអធិប្បាយទុកថា ចក្ខុវិញ្ញាណរមែងមិនមានតម្រេក ជំទាស់ រង្វើងក្នុងរូបដែលមកប្រាកដយ៉ាងណា យើងនឹងតាំងជវនចិត្តទុកដោយប្រមាណនៃចក្ខុវិញ្ញាណយ៉ាងនេះថា ជវនចិត្តរបស់យើងត្រឹមតែជាចក្ខុវិញ្ញាណប៉ុណ្ណោះរមែងមាន ព្រោះរៀរចាកវាគៈជាដើម យើងញ៉ាំងជវនចិត្តឱ្យតាំងនៅដោយចក្ខុវិញ្ញាណជាប្រមាណ ។

ម្យ៉ាងទៀត រូបដែលចក្ខុវិញ្ញាណឃើញ ឈ្មោះថា **ទិដ្ឋៈ** ។ ចិត្ត ៣ ដួង គឺសម្បដិច្ឆន្នចិត្ត សន្ទីរណចិត្ត និងវោដ្ឋព្វនចិត្ត ដែលកើតឡើងដូចយ៉ាងនោះ ឯង ឈ្មោះថា **ទិដ្ឋមត្ត** ។ គប្បីជ្រាបសេចក្ដីក្នុងសេចក្ដីនេះយ៉ាងនេះថា ចិត្ត ៣ ដួងនេះ រមែងមិនតម្រេក ជំទាស់ រង្វើងយ៉ាងណា កាលរូបមកប្រាកដ យើងក៏នឹងឱ្យជវនចិត្តកើតឡើង ដោយប្រមាណសម្បដិច្ឆន្នចិត្តជាដើមនុ៎ះឯង យើងនឹងមិនឱ្យឈានកន្ទងប្រមាណនោះ កើតឡើងដោយការតម្រេកជាដើមដូច្នោះ ។ ក្នុងសុតៈ និងមុតៈក៏នយនេះដូចគ្នា ។ ក៏បទថា **មុតំ** គប្បីជ្រាបគន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ នឹងដោយវិញ្ញាណ ដែលមានគន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈនោះជាអារម្មណ៍ ។ ក៏ក្នុងពាក្យថា **វិញ្ញាតេ វិញ្ញាតមត្តំ** នេះ មានវិនិច្ឆ័យដូចតទៅនេះ

ឈ្មោះថា **វិញ្ញាតៈ** បានដល់ អារម្មណ៍ដែលមនោទ្វារជវនចិត្តឱ្យដឹងច្បាស់ហើយ ។ ប្រមាណនៃការដឹងច្បាស់នូវវិញ្ញាតៈនោះ ឈ្មោះថា មានអា-ជ្ជនចិត្តជាប្រមាណ ។ ក្នុងសេចក្ដីនេះមានអធិប្បាយដូច្នេះថា អាជ្ជនចិត្តរមែង

មិនមានត្រេកអរ ជំទាស់ និងវង្វេងយ៉ាងណា យើងនឹងញ៉ាំងចិត្តទុកដោយ ប្រមាណនៃអារម្មណ៍ចិត្តប៉ុណ្ណោះ មិនព្រមឱ្យកើតឡើងដោយសេចក្តីតម្រេកជា ដើមដូច្នោះ ។ បទថា **ឯវញ្ហិ តេ ពាហិយ សិក្ខិតព្វំ** សេចក្តីថា ម្នាលពាហិយ: អ្នកចូរគប្បីសិក្សា ដោយអំណាចនៃការអនុវត្តនូវសិក្ខាទាំងឡាយ ៣ ដោយ បដិបទានេះយ៉ាងនេះ ។

ព្រោះហេតុដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ចែកប្រភេទនៃអារម្មណ៍ ទាំង ៦ ព្រមទាំងវិញ្ញាណកាយ ៦ យ៉ាងសង្ខេប និងតាមសេចក្តីពេញចិត្តរបស់ ពាហិយ: ដោយវិបស្សនា ដោយកោដ្ឋាស:ទាំង ៤ មានរូបដែលខ្លួនឃើញ ហើយជាដើម ទើបទ្រង់សម្តែងញាតបរិញ្ញា និងតីរណបរិញ្ញា ក្នុងសេចក្តីនោះ ដល់លោក ។ ព្រោះហេតុអ្វី ព្រោះថា ក្នុងសេចក្តីនេះរូបារម្មណ៍ ដែលឈ្មោះថា **ទិដ្ឋ:** ព្រោះអត្ថថា ចក្ខុវិញ្ញាណគប្បីឃើញ ។ ចំណែកចក្ខុវិញ្ញាណ ដែលប្រព្រឹត្ត ទៅមួយអន្ទើដោយវិញ្ញាណតាមចក្ខុទ្វារនោះ ឈ្មោះថា **ទិដ្ឋ:** ព្រោះអត្ថថា ឃើញ ។ សូម្បីទាំងពីរយ៉ាងនោះ ត្រឹមតែជាធម៌ដែលប្រព្រឹត្តទៅ តាមបច្ច័យ ប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះ បុគ្គលណាមួយធ្វើខ្លួនឯង ឬឱ្យអ្នកដទៃធ្វើក៏មិន បាន ។ មែនពិត ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា ចក្ខុវិញ្ញាណនោះ ឈ្មោះថា **អនិច្ច:** ព្រោះអត្ថថា មានហើយមិនមាន ឈ្មោះថា **ទុក្ខ** ព្រោះអត្ថថា កើតឡើង រលត់ទៅ និងបៀតបៀន ឈ្មោះថា **អនត្តា** ព្រោះអត្ថថា មិនប្រព្រឹត្ត ទៅក្នុងអំណាច ហេតុនោះក្នុងសេចក្តីនោះ នឹងចាត់ជាឱកាសរបស់ធម៌មាន សេចក្តីកំណត់ជាដើមនៃបណ្ឌិតបានក្នុងទីណា ។ គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុង

សុត:ជាដើមក៏ដូចគ្នា ។

ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងបហានបរិញ្ញា ដោយមគ្គផលខាងលើ ដល់បណ្ឌិតអ្នកតាំងនៅក្នុងញាតបរិញ្ញា និងតីរណបរិញ្ញា ទើបព្រះដ៏មានព្រះភាគ ប្រារព្ធពាក្យមានជាអាទិ៍ថា **យតោ ខោ តេ ពាហិយ** *ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* **យតោ** *បានដល់ ក្នុងកាលណា ឬព្រោះហេតុណា ។ បទថា* **តេ** *បានដល់* **តវ** *ប្រែថា ដល់អ្នក ។ បទថា* **តតោ** *បានដល់ ក្នុងកាលនោះ ឬព្រោះហេតុនោះ ។ បទថា* **តេន** *សេចក្តីថា ដោយរូបដែលលោកឃើញហើយជាដើម ឬដោយកិលេសមានរាគ:ជាដើម ដែលជាប់នឹងរូប គឺលោកឃើញហើយជាដើម ។ សមដូចពាក្យរបស់ព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលពាហិយ:ក្នុងកាលណា ឬព្រោះហេតុអ្វី ត្រឹមតែរូបដែលលោកឃើញហើយជាដើម នឹងមានដល់លោកអ្នកបដិបត្តិតាមវិធីដែលតថាគតពោលហើយ ក្នុងរូបដែលឃើញហើយជាដើម ដោយការយល់ដឹងសភាពដែលមិនវិបរិត ក្នុងកាលនោះ ឬព្រោះហេតុនោះ លោកនឹងមិនមានព្រមដោយកិលេសមានរាគ:ជាដើម ដែលជាប់ដោយរូប ដែលលោកឃើញហើយជាដើម លោកនឹងជាអ្នកមិនត្រេកអរ មិនប្រទូស្ត កំណត់ជំទាស់ ឬមិនវង្វេង ឬនឹងមិនជាអ្នកជាប់នឹងរូបដែលលោកឃើញហើយជាដើមនោះ ព្រោះលះរាគ:ជាដើមបានហើយ ។*

បទថា **តតោ ត្វं ពាហិយ ន តត្ត** *សេចក្តីថា ក្នុងកាលណា ឬព្រោះហេតុណា លោកនឹងជាអ្នកមិនត្រេកអរព្រោះរាគ: មិនប្រទូស្តព្រោះទោស: ឬមិនវង្វេងព្រោះមោហ: ក្នុងកាលនោះ ព្រោះហេតុនោះ លោកនឹងមិនមាន ក្នុងរូបដែលឃើញហើយជាដើមនោះ ឬកាលរូបនោះដែលឃើញហើយ ឬសំឡេង*

និងអារម្មណ៍ដែដឹងច្បាស់ហើយ លោកនឹងមិនជាអ្នកជំពាក់តាំងនៅដោយតណ្ហាមាន: និងទិដ្ឋិថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ[១] ។ ដោយពាក្យត្រឹមតែប៉ុណ្ណោះ ព្រះអង្គទ្រង់ឱ្យបហានបរិញ្ញាដល់ទីបំផុតហើយសម្តែងខីណាសវភូមិ ។

បទថា **តតោ ត្វं ពាហិយ នេវិធ ន ហុរំ ន ឧភយមន្តរេន** សេចក្តីថា ម្នាលពាហិយ: ក្នុងកាលណា អ្នកនឹងជាអ្នកមិនជាប់ក្នុងរូបដែលឃើញហើយជាដើមនោះ ដោយកិលេសមានរាគ:ជាដើមនោះ ក្នុងកាលនោះលោកនឹងមិនមានក្នុងលោកនេះ ក្នុងលោកខាងមុខ និងក្នុងលោកទាំងពីរ ។ បទថា **ឯសេ-វន្តោ ឧក្ខ្ស្ស** សេចក្តីថា មែនពិត ក្នុងសេចក្តីនេះមានអធិប្បាយត្រឹមតែប៉ុណ្ណោះថា នេះជាទីបំផុត នេះជាដែនកំណត់ ជាការវិលវល់នៃកិលេសទុក្ខ និងវដ្តទុក្ខប៉ុណ្ណោះ ។ ក៏អាចារ្យពួកណាកាន់យកនូវបទនេះថា **ឧភយមន្តរេន** ហើយទើបប្រាថ្នាឈ្នោះចន្ទោះកព ពាក្យនេះរបស់អាចារ្យទាំងនោះជាពាក្យខុស ។ មែនពិត ភាវ:នៃចន្ទោះកពលោកជំទាស់ហើយក្នុងព្រះអភិធម្មតែម្តង ។ ក៏ពាក្យថា **អន្តរេន** ជាការសម្តែងវិកប្បដទៃ ។ ព្រោះហេតុនោះ ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា ក៏វិកប្បដទៃមិនមានក្នុងលោកនេះ លោកខាងមុខ ឬទាំងពីរ ។

ម្យ៉ាងទៀត បទថា **អន្តរេន** ជាការសម្តែងសេចក្តីមិនមានវិកប្បដទៃ ។ ពាក្យនោះមានអធិប្បាយដូច្នេះថា ក៏ទីតាំងដទៃមិនមានក្នុងលោកនេះ លោកខាងមុខ ថែមទាំងមិនមានក្នុងចន្ទោះលោកទាំងពីរ ។ ម្យ៉ាងទៀត សូម្បីអាចារ្យពួកណាកាន់យកដោយមិនឈ្វាសវៃ ដល់អត្ថនៃសុត្តបទទាំងនេះថា អន្តរាបរិ-

---

១-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ៤៤ ។

*និព្វាយីថាជាសម្ភវេសី ហើយពោលថា ភពដទៃនៅមានដូចគ្នា អាចារ្យសូម្បីទាំងនោះ ព្រោះត្រូវជំទាស់ថា អត្ថនៃសុត្តបទដើមថា ឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះមិនកន្ទ្រាំងពាក់កណ្តាលនៃអាយុក្នុងភូមិនោះ មានអវិហាព្រហ្មជាដើម ហើយបរិនិព្វាន ដោយកិលេសបរិនិព្វានមិនឱ្យសេសសល់ ព្រោះសម្រេចអរហត្តមគ្គក្នុងចន្ទោះ មិនកើតក្នុងភពដទៃទេ និងត្រូវជំទាស់អត្ថនៃសុត្តបទក្រោយថា សត្វពួកណាមិនមានក្នុងភពក្រោយ សត្វទាំងនោះនឹងជាអ្នកអស់អាសវៈ ដែលមានក្នុងភពមុន ។ អធិប្បាយថា ឈ្មោះថា **សម្ភវេសី** ព្រោះសត្វអ្នកស្វែងរកភពថ្មីផ្ទុយនឹងអន្តរាបរិនិព្វាយីបុគ្គលនោះ និងឈ្មោះថា សេក្ខបុថុជ្ជនព្រោះលះកវសំយោ-ជនៈមិនបាន ។ ម្យ៉ាងទៀត បណ្តាកំណើត ៤ អណ្ឌជសត្វ និងជលាពុជសត្វមិនទាន់ទម្លាយសំបកពង និងស្រោមសុកចេញមកដរាបណា ដរាបនោះ ឈ្មោះថា **សម្ភវេសី** សត្វដែលទម្លាយសំបក និងស្រោមសុកចេញមកខាងក្រៅ ឈ្មោះថា **ភូត** ។ សត្វជាសំសេទជៈ និងឱបបាតិកៈ ឈ្មោះថា **សម្ភវេសី** ក្នុងខណៈបឋម-ចិត្តបន្ទាប់ពីទុតិយចិត្តទៅ ឈ្មោះថា **ភូត** ។ ម្យ៉ាងទៀត ពួកសត្វទាំងឡាយដែលកើតឡើងដោយឥរិយាបថណា នៅមិនទាន់ប្តូរទៅឥរិយាបថដទៃដរាបណា ដរាបនោះ ឈ្មោះថា **សម្ភវេសី** ។ ក្រៅពីនេះហៅថា **ភូត** ។ ព្រោះហេតុនោះ ទើបលោកបដិសេធថាមិនមានដូច្នេះ ។ ក៏កាលអត្ថដែលមកតាមបាលីត្រង់ៗ នឹងជាប្រយោជន៍អ្វីដោយអត្ថ ដែលកំណត់ដោយភពដទៃដែលមិនអាចនឹងពង្រីកសេចក្តីបាន ។*

ក៏អាចារ្យពួកណាពោលនូវការប្រកបថា ការឃើញធម៌ដែលប្រព្រឹត្តទៅដោយអំណាចនៃការបន្ត ប្រាកដក្នុងចំណែកដទៃមិនដាច់ ប្រការនោះគប្បី

ប្រាកដ សូម្បីក្នុងសេចក្តីបន្តនៃអវិញ្ញាណកទ្រព្យ មានស្រូវជាដើម យ៉ាងណា សូម្បីក្នុងសេចក្តីបន្តនៃសវិញ្ញាណកទ្រព្យ គប្បីប្រាកដក្នុងចំណែកដទៃដោយមិនដាច់ដូច្នោះ ។ ម្យ៉ាងទៀត នយ៉ាងនេះ រមែងសមគួរក្នុងកាលមានកពដទៃមិនមែនដោយប្រការដទៃទេ ។ ក៏ព្រោះហេតុនោះ បុគ្គលអ្នកមានឫទ្ធិសម្រេចសេចក្តីស្ទាត់ជំនាញផ្ទូរចិត្ត អធិដ្ឋានកាយបណ្តាយតាមចិត្ត គប្បីពោលការប្រកបដោយការពីព្រហ្មលោកមកកាន់លោកនេះ ឬពីលោកនេះទៅកាន់ព្រហ្មលោក ដោយខណៈតែមួយ ។ បើប្រាជ្ញាការប្រព្រឹត្តទៅនៃធម៌ ក្នុងចំណែកដែលមិនដាច់ក្នុងទីទាំងពួង សូម្បីបើបុគ្គលអ្នកមានឥទ្ធិទាំងឡាយ នឹងគប្បីមានឥទ្ធិវិស័យជាអចិន្ត្រៃយ្យ ។ ពាក្យនោះនឹងគប្បីស្មើគ្នាសូម្បីក្នុងទីនេះ ព្រោះព្រះបាលីថា **កម្មវិចាកោ អចិន្ត្រៃយ្យោ** វិបាកនៃកម្មជាអចិន្ត្រៃយ្យ ។ ព្រោះហេតុនោះ ពាក្យនោះត្រឹមតែជាមតិរបស់អាចារ្យទាំងនោះប៉ុណ្ណោះ ។ ព្រោះថា សភាវធម៌មានសភាពជាអចិន្ត្រៃយ្យ សភាវធម៌ទាំងនោះកន្ទ្រែងខ្ទ្ះ ទើបប្រាកដក្នុងចំណែកដែលដាច់ខ្សែដោយបច្ច័យ កន្ទ្រែងខ្ទ្ះប្រាកដក្នុងចំណែកដែលមិនដាច់ ។ ពិតយ៉ាងនោះ វត្ថុដែលកើតឡើងព្រោះបច្ច័យ មានរូបនឹងសំឡេងជាដើមដែលជះត្រឡប់ រមែងកើតប្រាកដក្នុងចំណែកមួយ មានចំណែកនៃកញ្ចក់ និងភ្នំជាដើម ពីបច្ច័យមានសំឡេងគឺកកងខាងមុខជាដើម ។ ព្រោះហេតុនោះ ទើបមិនគប្បីបង្ហោនវត្ថុទាំងអស់ក្នុងទីទាំងពួង ។ ក្នុងសេចក្តីនេះមាន សេចក្តីសង្ខេបប៉ុណ្ណោះ ។

ចំណែកសេចក្តីពិស្តារមានការពិចារណាក្នុងអន្តរការកថា[1] ដែលឱ្យសម្រេចឧទាហរណ៍ជាដើមរបស់រូប គប្បីមើលក្នុងដីកាកថាវត្ថុបករណ៍ចុះ ។

ចំណែកអាចារ្យមួយពួកទៀតពោលថា បទថា **ឥ** លោកពោលសំដៅយកកាមភព ។ បទថា **ហុរំ** ពោលសំដៅយកអរូបភព ។ បទថា **ឧភយមន្តរេន** ពោលសំដៅយករូបភព ។ អាចារ្យពួកដទៃពោលថា បទថា **ឥ** បានដល់ អាយតនៈខាងក្នុង ។ បទថា **ហុរំ** បានដល់ អាយតនៈខាងក្រៅ ។ បទថា **ឧភយមន្តរេន** បានដល់ ចិត្ត និងចេតសិក ។ ម្យ៉ាងទៀត អាចារ្យមួយពួកទៀតពោលថា បទថា **ឥ** បានដល់ បច្ចយធម៌ ។ បទថា **ហុរំ** បានដល់ បច្ចុប្បន្នធម៌ ។ បទថា **ឧភយមន្តរេន** បានដល់ បណ្ណត្តិធម៌ ។ ពាក្យនោះទាំងអស់ មិនមានក្នុងអដ្ឋកថាទាំងឡាយទេ ។ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មាន ៤ ប្រការ គឺលោកសង្គ្រោះដោយអំណាចរូបដែលចក្ខុវិញ្ញាណឃើញហើយជាដើម ដោយពាក្យមានជាអាទិ៍ថា **ឥធ ឥដ្ឋមត្តំ ភវិស្សតិ** កាលចក្ខុវិញ្ញាណឃើញរូប ក៏ត្រឹមតែជាការឃើញប៉ុណ្ណោះ ។ ក្នុងធម៌ទាំងនោះ លោកសម្តែងដល់អសុភ-ភាវនា ទុក្ខានុបស្សនា អនិច្ចានុបស្សនា និងអនត្តានុបស្សនាដោយប្រធាន គឺការរៀរចាកការប្រកាន់ថា ល្អជាសុខ ជារបស់ទៀង និងជាតួខ្លួនឯង ។ ការពោលវិបស្សនាដោយសង្ខេប មួយអន្ទើដោយវិសុទ្ធិមានខាងក្រោម ។ ដោយបទថា **តតោ ត្វំ ពាហិយ ន តេន** នេះ ត្រាស់ដល់មគ្ គ ព្រោះប្រាជ្ញាការកាត់កិលេសមាន ភាគៈជាដើមបានដាច់ជាសមុច្ឆេទ ។ ដោយបទថា **តតោ ត្វំ ពាហិយ ន**

---

[1]-***អន្តរការកថា*** *មានសេចក្តីពិស្តារក្នុងគម្ពីរ បរមត្ថទីបនី អដ្ឋកថា អភិធម្មបិដក ច្បាប់ប្រែជាខេមរ-ភាសា ភាគ ៨ ទំព័រ ១៣០ ដល់ ១៣៣ ។*

តត្ត នេះ ត្រាស់ដល់ផលចិត្ត ។ ដោយពាក្យថា **ឧវិធ** ជាដើម គប្បីឃើញថា ត្រាស់ដល់អនុបាទិសេសនិព្វានធាតុ ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហ-កាចារ្យពោលថា **អថ ខោ ពាហិយ ។ បេ ។ អាសវេហិ ចិត្តំ វិមុច្ចិ** ដូច្នេះ ។

ចិត្តរបស់ពាហិយ:រួចផុតពីអាសវ: ដោយការសម្តែងធម្មទេសនា យ៉ាងសង្ខេបនេះ ។ បទថា **តាវទេវ** បានដល់ ក្នុងខណ:នោះឯង មិនមែនកាលដទៃ ។ បទថា **អនុចាឌាយ** ប្រែថា មិនប្រកាន់មាំ ។ បទថា **អាសវេហិ** សេចក្តីថា ចាកកាមរាគ:ជាដើម ដែលមានឈ្មោះថា អាសវ: ព្រោះហូរទៅ គឺប្រព្រឹត្តទៅពីកវគ្គព្រហ្មដរាបដល់គោត្រភូ និងដូចជាគ្រឿងត្រាំមានសុរាជាដើម ដោយអត្ថថា ច្រើននឹងទុកបានយូរ ។ បទថា **វិមុច្ចិ** សេចក្តីថា រួចផុត គឺរលាស់ចេញ (កាមរាគ:ជាដើម) ដោយសមុច្ឆេទវិមុត្តិ និងបដិប្បស្សទ្ធិវិមុត្តិ ។ ក៏ពាហិយ:នោះ ស្តាប់ធម៌របស់ព្រះសាស្តាប៉ុណ្ណោះហើយ ជម្រះសីលឱ្យបរិសុទ្ធអាស្រ័យសមាធិ ចិត្តតាមដែលបានហើយ ផ្តើមវិបស្សនាជាខិប្បាភិញ្ញាបុគ្គល ញ្ចាំងអាសវ:ទាំងពួងឱ្យអស់ទៅ សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាក្នុងខណ:នោះឯង ។ ពាហិយ:នោះកាត់កិលេសដូចជាក្រសៃទឹកក្នុងសង្ហារ ធ្វើទីបំផុតនៃវដ្តទុក្ខ ទ្រទ្រង់រាងកាយគ្រាចុងបង្អស់ ត្រូវធម៌ឱ្យប្រព្រឹត្តទៅដោយបច្ចវេក្ខណញ្ញាណ ១៩ យ៉ាងដាស់តឿនហើយ ទើបទូលសូមបព្វជ្ជានឹងព្រះដ៏មានព្រះភាគ ។ ពាហិយ:ត្រូវព្រះដ៏មានព្រះភាគត្រាស់សួរថា អ្នកមានបាត្រ និងចីវរបរិបូរហើយឬ ទើបធ្វើយថា មិនទាន់បរិបូរទេ ព្រះអង្គ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ចំពោះពាហិយ:ថា បើដូច្នោះ អ្នកចូរទៅស្វែងរកបាត្រ និង

ចីវរចុះ ដូច្នេះហើយព្រះអង្គក៏យាងចេញទៅ ។ ព្រោះហេតុនោះ ទើបព្រះធម្ម-សង្គាហកាចារ្យពោលថា **អថ ខោ ភគវា ។បេ។ បក្កាមិ** ដូច្នេះ ។

បានឮថា ពាហិយៈនោះ កាលធ្វើសមណធម៌អស់ ២០០០០ ឆ្នាំ ក្នុងព្រះសាសនារបស់ព្រះកស្សបទសពលគិតថា ធម្មតាភិក្ខុ កាលបានបច្ច័យហើយធ្វើទានតាមសមគួរ ទើបធាន់ដោយខ្លួនឯង ទើបគួរ ដូច្នេះហើយ មិនបានធ្វើការសង្គ្រោះដោយបាត្រ ឬចីវរសូម្បីដល់ភិក្ខុមួយរូប ។ ព្រោះហេតុនោះ លោកទើបមិនមានឧបនិស្សយ្យឯហិភិក្ខុឧបសម្បទា ។ តែអាចារ្យពួកខ្លះពោលថា បានឮថា ពាហិយៈនោះធ្លាប់ជាចោរ ក្នុងកាលដែលព្រះពុទ្ធមិនមានក្នុងលោក ធ្វើធ្នូតាំងខ្លួនជាចោរក្នុងព្រៃ ឃើញព្រះបច្ចេកពុទ្ធអង្គមួយ ព្រោះសេចក្ដីលោភក្នុងបាត្រ និងចីវរ ទើបបាញ់ព្រះបច្ចេកពុទ្ធនោះនឹងធ្នូ ហើយកាន់យកបាត្រ និងចីវរ ព្រោះហេតុនោះ ទើបបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិមិនកើតមានដល់ពាហិយៈនោះ ដូច្នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបអាការយ៉ាងនេះ ទើបទ្រង់មិនប្រទានបព្វជ្ជាដោយឯហិភិក្ខុភាវៈទេ ។ សូម្បីពាហិយៈកំពុងត្រាច់ទៅស្វែងរកបាត្រ និងចីវរ មានមេគោមួយក្បាលរត់មកយ៉ាងលឿន ដល់ពាហិយៈឱ្យស្លាប់ ដែលលោកពោលសំដៅថា **អថ ខោ អចិរបក្កន្តស្ស ភគវតោ ពាហិយं ទារុចីរិយं តារី តរុណវច្ឆា អជ្ជិចាតេត្វា ជីវិតា ហរិហរេសិ ។** *កាលដែល ព្រះមានព្រះភាគ ស្តេចចេញផុតទៅមិនយូរប៉ុន្មាន មេគោមានកូនខ្ចីបុះផ្ទួល ពាហិយទារុចីរិយបុរស ឱ្យដាច់ចាកជីវិតទៅ ។*

បណ្ដាបទទាំងនោះ បទថា **អចិរបក្កន្តស្ស** ប្រែថា *កាលព្រះដ៏មានព្រះភាគស្តេចដៀសចេញទៅមិនយូរប៉ុន្មាន* ។ បទថា **តារី តរុណវច្ឆា** *បាន-*

ដល់ នាងយក្ខិណីម្នាក់ប្លែងជាមេគោកូនខ្ចី ។ បទថា **អជ្ឌិបតិត្វា** បានដល់ សង្កត់សង្កិន គឺញាំញ៉ី ។ បទថា **ជីវិតា ភោ ភោ ឯសិ** សេចក្តីថា មេគោនោះ ញ៉ាំងចិត្តដែលមានពៀរឱ្យកើតឡើង ដោយហេតុត្រឹមតែបានឃើញ ព្រោះបាន ចងអាឃាតក្នុងអត្តភាពមុន ទើបដល់ឱ្យស្លាប់ ។

ព្រះសាស្តាទ្រង់ត្រាច់ទៅបិណ្ឌបាត ព្រះអង្គមានកត្តកិច្ចធ្វើរួចហើយ មួយអន្ទើដោយកិក្ខុសង្ឆដ៏ច្រើន យាងចេញពីនគរទ្រង់ទតឃើញសរីរៈរបស់ ពាហិយៈដួលលើគំនរសំរាម ហើយទ្រង់បានបង្គាប់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយចូរឈរទៀបទ្វារនៃផ្ទះមួយខ្នង ញ៉ាំងគេឱ្យនាំយកគ្រែ ហើយនាំយកសរីរៈនេះចេញពីនគរធ្វើឌាហកិច្ច រួចធ្វើព្រះស្តូប ។ ភិក្ខុទាំងឡាយ បានធ្វើដោយប្រការយ៉ាងនោះ ។ ក៏ភិក្ខុទាំងឡាយ ធ្វើរួចហើយ ទៅកាន់វិហារ គាល់ព្រះសាស្តាក្រាបទូលកិច្ចដែលខ្លួនធ្វើហើយ ទើបទូលសួរដល់អភិសម្ពោ-យកពរបស់ពាហិយៈ ។ លំដាប់នោះ ព្រះសម្ពុទ្ធទើបត្រាស់ប្រាប់ដល់ភិក្ខុទាំង នោះថា ពាហិយៈបរិនិព្វានហើយ ។ ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ ដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្តែងអំពីពាហិយទារុចីរិយៈ បានសម្រេច ព្រះអរហត្តហើយឬ តើពាហិយៈសម្រេចព្រះអរហត្តទីណា ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ក្នុងវេលាដែលស្តាប់ធម៌របស់តថាគត ពួកភិក្ខុទើបទូលសួរថា ក៏ព្រះអង្គសម្តែងធម៌ដល់ពាហិយៈក្នុងវេលាណា ។ ព្រះសាស្តាត្រាស់ថា កាល តថាគតកំពុងបិណ្ឌបាតឈរត្រង់កណ្តាលផ្លូវក្នុងថ្ងៃនេះឯង ។ ភិក្ខុទាំងឡាយ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គត្រាស់សម្តែងត្រង់កណ្តាល

ផ្លូវនោះមានប្រមាណតិច តើពាហិយ:ធ្វើគុណវិសេសឱ្យកើតដោយហេតុត្រឹមតែប៉ុណ្ណោះបានយ៉ាងណា ។ ព្រះសាស្តាកាលទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំគិតថា ធម៌របស់តថាគតមានប្រមាណតិច ឬច្រើន សូម្បីគាថាទាំងច្រើនពាន់ តែមិនប្រកបដោយប្រយោជន៍មិនប្រសើរសោះឡើយ ចំណែកបទនៃគាថាសូម្បីបទតែមួយ ដែលប្រកបដោយប្រយោជន៍នូវប្រសើរជាង ទើបព្រះដ៏មានព្រះភាគត្រាស់គាថានេះក្នុងធម្មបទថា

សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើគាថាសូម្បីមួយពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រំងាប់បានបទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង[១] ។

ព្រះដ៏មានព្រះភាគកាលទ្រង់សម្តែងគាថានេះក្នុងធម្មបទហើយ ទើបត្រាស់បន្តថា ពាហិយ:ជាអ្នកគួរដល់ការបូជា ដោយហេតុត្រឹមតែបរិនិព្វានតែម្យ៉ាងក៏ទេ ដោយពិត លោកជាអ្នកសមគួរដល់ការបូជា សូម្បីដោយការ:ដែលប្រសើរជាងភិក្ខុសាវករបស់តថាគត អ្នកជាខិប្បាភិញ្ញា ទើបទ្រង់ស្ថាបនាលោកទុកក្នុងឯតទគ្ក:ថា **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ ។** ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកត្រាស់ដឹងរហ័សដែលជាសាវករបស់តថាគត ស្រេចនឹងពាហិយទារុចីរិយ:[២] ។

១-សុត្តន្តបិដក ខុទ្ទកនិកាយ គាថាធម្មបទ លេខ ៥២ ទំព័រ ២៣ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ២០ ទំព័រ ៥២ ។

ពាក្យថា **អថ ខោ ភគវា សាវត្ថិយំ បិណ្ឌាយ ចរិត្វា ។បេ។ បរិនិព្ពុតោ ភិក្ខវេ ពាហិយោ ឧារុចីរិយោ** នេះជាពាក្យដែលព្រះធម្មសង្គាហាចារ្យ ពោលសំដៅដល់រឿងនោះ ។

បណ្តាបទទាំងនោះ បទថា **បច្ឆាភត្តំ** បានដល់ ក្រោយពីភត្តកិច្ច ។ បទ ថា **បិណ្ឌចាតបដិក្ក្តោ** បានដល់ ស្តេចត្រឡប់ពីបិណ្ឌបាត ។ សូម្បីទាំងពីរ បទ លោកក៏អធិប្បាយថា សោយព្រះក្រយាហារសម្រេចហើយ ។ បទថា **នីហ-រិត្វា** សេចក្តីថា ឱ្យនាំចេញទៅខាងក្រៅព្រះនគរ ។ បទថា **ឈាបេថ** ប្រែថា ចូរធ្វើឈាបនកិច្ច ។ បទថា **ថូបញ្ចស្ស ការេថ** សេចក្តីថា និងចូរនាំ សរីរធាតុរបស់ពាហិយៈនោះ មកសាងព្រះចេតិយ ។ ក្នុងសេចក្តីនោះ ព្រះអង្គ ត្រាស់ហេតុទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សព្រហ្មចារីរបស់ពួកអ្នកបរិនិព្វាន ហើយ ។ ប្រការនោះមានអធិប្បាយថា ពាហិយៈនោះបានប្រព្រឹត្តធម៌ គឺការ បដិបត្តិ មានអធិសីលជាដើម ដែលពួកអ្នកប្រព្រឹត្តហើយ និងកំពុងប្រព្រឹត្តដោយ ល្អ ឈ្មោះថា **ព្រហ្ម** ព្រោះអត្ថថា ប្រសើរ បានប្រសើរស្មើនឹងពួកអ្នក ព្រោះ ហេតុនោះ ទើបឈ្មោះថា សព្រហ្មចារី បានធ្វើកាលៈហើយតាមប្រក្រតីនៃ មរណកាល ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា អ្នកទាំងឡាយ ចូរនាំសរីរៈដោយគ្រែទៅធ្វើឈាបនកិច្ចផង និងសាងស្តូបផង ។ បទថា **តស្ស ការ កតិ** សេចក្តីថា បណ្តាគតិទាំង ៥ យ៉ាង គតិណាមួយនឹងកើត គឺថានឹង មានដល់ពាហិយៈនោះ ។ ម្យ៉ាងទៀត បទថា **កតិ** ប្រែថា កើត អធិប្បាយថា គតិរបស់លោកនឹងសម្រេចយ៉ាងណា ជាព្រះអរិយៈ ឬបុថុជ្ជន ។ បទថា **អកិ-**

សម្បរាយោ *បានដល់ ពាហិយៈលះលោកនេះទៅហើយកើតក្នុងភព ឬរលត់ចាកភព ។ ពោលអំពីអត្ត ជាការទ្រង់ប្រកាសថា លោកបរិនិព្វាន ដោយការត្រាស់បង្គាប់ឱ្យសាងស្តូបទុកក៏ពិតមែន ក៏ប៉ុន្តែថា មានពួកភិក្ខុអ្នកមិនដឹងដោយហេតុត្រឹមតែប៉ុណ្ណោះ ក៏នឹងទូលសួរថា គតិរបស់លោកជាយ៉ាងណា ។ ក៏ភិក្ខុអ្នកប្រាថ្នានឹងឱ្យធ្វើឱ្យប្រាកដច្បាស់ ទើបទូលសួរព្រះដ៏មានព្រះភាគយ៉ាងនោះ ។*

បទថា **បណ្ឌិតោ** *សេចក្តីថា ឈ្មោះថា* **បណ្ឌិត** *ព្រោះទៅ គឺដំណើរទៅបានដល់ ប្រព្រឹត្តទៅដោយបញ្ញា ឈ្មោះថា* **បណ្ឌៈ** *ព្រោះសម្រេចដោយបញ្ញាដែលសម្បយុត្តដោយអរហត្តមគ្គ ។ បទថា* **បច្ចបាទិ** *ប្រែថា ប្រតិបត្តិហើយ ។ បទ-ថា* **ធម្មស្ស** *បានដល់ លោកុត្តរធម៌ ។ បទថា* **អនុធម្មំ** *បានដល់ ធម៌ជាបដិបទាមានសីលវិសុទ្ធិជាដើម ។ ម្យ៉ាងទៀត បទថា* **ធម្មស្ស** *បានដល់ និព្វានធម៌ ។ បទថា* **អនុធម្មំ** *បានដល់ ធម៌ គឺអរិយមគ្គ និងអរិយផល ។ បទថា* **ន ច មំ ធម្មាធិករណំ** *សេចក្តីថា ក៏ហេតុនៃការសម្តែងធម៌ មិនធ្វើឱ្យតថាគតលំបាកព្រោះបដិបត្តិតាមធម៌ដែលតថាគតទូន្មាន ។ មែនពិត ភិក្ខុអង្គណាស្តាប់ធម៌ក្តីរៀននូវកម្មដ្ឋានក្តី ក្នុងសម្នាក់របស់ព្រះសាស្តា មិនបដិបត្តិធម៌តាមដែលទ្រង់ទូន្មានហើយ ភិក្ខុអង្គនោះ ឈ្មោះថា ធ្វើព្រះសាស្តាឱ្យលំបាក ។ ព្រះដ៏មានព្រះភាគត្រាស់ថា*

វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ

ម្នាលមហាព្រហ្ម តថាគតមានសេចក្ដីសម្គាល់ក្នុងការលំបាក បានជាមិនសម្ដែងធម៌ដ៏ឧត្តម ដែលស្ងាត់ក្នុងសម្នាក់មនុស្សទាំងឡាយ[១] សំដៅដល់ហេតុនោះ ។ ម្យ៉ាងទៀត បទថា **ន ច មំ ឧម្ហាឯ្ចការណា** សេចក្ដីថា នឹងជាហេតុនៃធម៌នេះក៏មិនមែន ។ លោកអធិប្បាយពាក្យនេះទុកថា ឈ្មោះថា មិនធ្វើតថាគតឱ្យលំបាក ព្រោះបដិបត្តិសាសនធម៌របស់តថាគតនេះដោយល្អ ដែលជាហេតុនាំសត្វសត្វចេញចាកវដ្ដទុក្ខ ។ ក៏អ្នកបដិបត្តិអាក្រក់ ទម្ងាយសាសនធម៌ ឈ្មោះថា ឱ្យនូវការប្រហារសរីរៈ គឺធម៌របស់ព្រះសាស្តា ។ តែពាហិយៈនេះ ធ្វើសម្មាបដិបត្តិឱ្យដល់ទីបំផុតហើយបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា **បរិនិព្ពុតោ ភិក្ខវេ ពាហិយោ ជារុចីរិយោ** ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ព្រះពាហិយត្ថេរ បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ និងថាគតិរបស់ព្រះខីណាស្រពទាំងឡាយ បរិនិព្វានហើយដូច្នោះ ដែលជនចំនួនច្រើនដឹងបានលំបាកដោយអាការទាំងពួង ។ បទថា **ឥមំ ឧទានំ** បានដល់ ព្រះដ៏មានព្រះភាគទ្រង់បន្ទឺនូវឧទាន ដែលសម្ដែងអានុភាពនៃការបរិនិព្វានដែលមិនតាំងនៅនេះ ។

បណ្ដាបទទាំងនោះ បទថា **យត្ត** សេចក្ដីថា អាបោធាតុ បថវីធាតុ តេជោធាតុ និងវាយោធាតុមិនមាន គឺមិនតាំងនៅក្នុងនិព្វានធាតុ ។ ព្រោះហេតុ

១-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ១៩ ។

អ្វី? ព្រោះព្រះនិព្វានមានសភាវៈជាអសង្ខតធម៌ ។ មែនពិត សូម្បីវត្ថុបន្តិចបន្តួចនៃសង្ខតធម៌ក៏មិនមានក្នុងព្រះនិព្វាននោះ ។ បទថា **សុក្កា** សេចក្តីថា ផ្កាយព្រះគ្រោះហ៍ និងផ្កាយនក្ខត្តឫក្ស ដែលឈ្មោះថា **សុក្កៈ** ព្រោះមានរស្មី-ស ។ បទថា **ន ជោតន្តិ** ប្រែថា មិនភ្លឺ ។ បទថា **អាទិច្ចោ នប្បកាសតិ** សេចក្តីថា សូម្បីព្រះអាទិត្យដែលអាចផ្សាយភ្លឺស្វាងទៅខណៈតែមួយ ៣ ទ្វីប ក៏មិនសូវភ្លឺដោយអំណាចរស្មី ។ បទថា **ន តត្ថ ចន្ទិមា ភាតិ** សេចក្តីថា សូម្បីកាលព្រះអាទិត្យមានរស្មីខ្លាំងក្លា ចំណែកព្រះចន្ទមានរស្មីត្រជាក់គួរប្រាថ្នា ក៏មិនរុងរោចន៍ដោយពន្លឺរបស់ខ្លួន ព្រោះមិនមានក្នុងព្រះនិព្វាននោះ ។ ព្រះអង្គត្រាស់ថា **តមោ តត្ថ ន វិជ្ជតិ** ភាពងងឹតមិនមានក្នុងព្រះនិព្វាននោះដូច្នេះ ទ្រង់សំដៅយកសេចក្តីសង្ស័យថា បើព្រះចន្ទ និងព្រះអាទិត្យមិនមានក្នុងព្រះនិព្វាននោះសោត ព្រះនិព្វាននោះក៏នឹងគប្បីងងឹតតែម្តង ដូចលោកន្តរនរក ។ មែនពិត កាលបើរូបមិនមាន ឈ្មោះថា ភាពងងឹតក៏មិនមាន ។ បទថា **យទា ច អត្តនា វេទិ មុនិ មោនេន ព្រាហ្មណោ** សេចក្តីថា ព្រាហ្មណ៍អ្នកជា ព្រះអរិយសាវក ដែលឈ្មោះថា **មុនី** ព្រោះប្រកបដោយមគ្គញ្ញាណ ដែលឈ្មោះថា **មោនៈ** ព្រោះដឹងសច្ចៈ ៤ និងប្រកបដោយមោនេយ្យបដិបទាផ្លូវកាយជាដើម លះអាការមានការស្តាប់តាមៗគ្នាមកជាដើម ដោយខ្លួន គឺខ្លួនឯង ក្នុងខណៈអរហត្តមគ្គ ក្នុងកាលណា គឺក្នុងវេលាណាដោយបដិវេធញាណ ពោលគឺមោនៈនោះឯង ដឹង គឺដឹងច្បាស់ព្រះនិព្វាន ធ្វើឱ្យប្រចក្សដល់ខ្លួន ។ បាលីថា **អវេទិ** ដូច្នេះក៏មាន ។ អធិប្បាយថា មិនដឹង ។ ស័ព្ទថា **អថ** ក្នុងពាក្យថា **អថ រូចា អរូចា ច សុខទុក្ខា បមុច្ចតិ** ប្រែថា ខាងក្រោយអំពីការត្រាស់ដឹងព្រះនិព្វាននោះ ។ បទថា **រូចា** បានដល់ រូបធម៌ ។ ដោយបទថា **រូចា** នោះ ជាការកាន់យកនូវ

បញ្ចវោការភព និងឯកវោការភព ។ បទថា **អរូចា** *បានដល់ អរូបធម៌ ។ ដោយ*
បទថា **អរូចា** *នោះ ជាការកាន់យកនូវអរូបភព ព្រោះមិនលាយឡំជាមួយនឹង*
រូប ។ ស័ព្ទនោះលោកហៅថា ចតុវោការភពក៏មាន ។ បទថា **សុខុក្ខា**
សេចក្តីថា ពីវដ្ត: សូម្បីមានទាំងសុខ ទាំងទុក្ខដែលកើតឡើងក្នុងទីទាំងពួង ។
ម្យ៉ាងទៀត បទថា **រូចា** *បានដល់ ព្រោះបដិសន្ធិក្នុងរូបលោក ។ បទថា* **អរូចា**
បានដល់ ព្រោះបដិសន្ធិក្នុងអរូបលោក ។ បទថា **សុខុក្ខា** *បានដល់ ព្រោះ*
បដិសន្ធិក្នុងកាមាវចរភូមិ ។ មែនពិត កាមភពមានទាំងសុខ និងទុក្ខលាយគ្នា ។
ព្រាហ្មណ៍នោះ រមែងផុតពីវដ្ត:តែម្យ៉ាង សូម្បីទាំងអស់នោះដោយមិនឱ្យសេស-
សល់ដោយប្រការដូច្នេះឯង ។

សូម្បីដោយគាថា ២ គាថា ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា ព្រះនិព្វាន
បែបនេះ ជាគតិនៃពាហិយ:អ្នកជាបុត្ត្ររបស់តថាគត ។

ឧសមសុត្តវណ្ណា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១០

និដ្ឋិតា ច ពោធិវគ្គវណ្ណា

ចប់ពោធិវគ្គវណ្ណនាទី ១

រួមព្រះសូត្រដែលមានក្នុងវគ្គនេះ គឺ

១-បឋមពោធិសូត្រ	*២-ទុតិយពោធិសូត្រ*
៣-តតិយពោធិសូត្រ	*៤-អជបាលនិគ្រោធសូត្រ*
៥-ជេរសូត្រ	*៦-មហាកស្សបសូត្រ*
៧-ជាវិសូត្រ	*៨-សង្គ្រាមជិសូត្រ*
៩-ជដិលសូត្រ	*១០-ពាហិយសូត្រ ។*

២. មុចលិន្ទវគ្គោ

មុចលិន្ទវគ្គទី ២

១. មុចលិន្ទសុត្តវណ្ណនា

អដ្ឋកថាមុចលិន្ទសូត្រ

មុចលិន្ទសូត្រទី ១ *មានវិនិច្ឆ័យដូចតទៅនេះ*

ដើមពាំងអន្ទក់ លោកហៅថា **មុចលិន្ទ** *ក្នុងពាក្យថា* **មុចលិន្ទមូលេ** *នេះ* **មុចលិន្ទ** *នោះ លោកហៅថា* **និចុលៈ** *ដូច្នេះក៏មាន ដែលលោកពោលថា ក្បែរដើមមុចលិន្ទនោះ ។ តែអាចារ្យពួកខ្លះពោលថា បទថា* **មុចលោ** *ជាឈ្មោះរបស់ដើមឈើនោះ តែបទថា* **មុចលោ** *នោះ លោកពោលថា* **មុចលិន្ទ** *ព្រោះជាឈើធំបំផុតក្នុងព្រៃ ។ បទថា* **មហាអកាលមេឃោ** *បានដល់ មហាមេឃដែលកើតឡើងក្នុងកាលនៅមិនទាន់ដល់រដូវក្ដៀង ។ មែនពិត មហាកាលមេឃនោះ កើតឡើងពេញកណ្ដាប់ចក្រវាឡទាំងអស់ ក្នុងខែចុងបង្ហស់របស់គិម្ហរដូវ ។ បទថា* **សត្តាហវទ្ទលិកា** *សេចក្ដីថា កាលមហាអកាលមេឃនោះកើតឡើងហើយ មានក្ដៀងធ្លាក់ចុះមិនដាច់រហូតដល់អស់ ៧ ថ្ងៃ ។ បទថា* **សីតវាតទុទ្ធិ-នី** *សេចក្ដីថា ក៏ក្ដៀងរលឹមរហូតដល់អស់ ៧ ថ្ងៃនោះ ឈ្មោះថា* **ទុទ្ធនី** *ព្រោះជាថ្ងៃដែលខ្យល់ត្រជាក់លាយដោយគ្រាប់ក្ដៀងសាចទៅជុំវិញហើយ ។ បទថា* **មុចលិន្ទោ ជាម ជាតរាជា** *បានដល់ ស្ដេចនាគអ្នកមានអានុភាពច្រើន កើត*

ក្នុងនាគពិភពនៅខាងក្រោមស្រះបោក្ខរណី ជិតដើមមុចលិន្ទនោះឯង ។ បទថា **សកកាយ** ប្រែថា ពីកពនាគរបស់ខ្លួន ។ បទថា **សត្តក្ខត្តុं ភោគេហិ បរិក្ខិបិត្វា** សេចក្តីថា យកខ្លួនឡោមព័ទ្ធព្រះកាយព្រះដ៏មានព្រះភាគ ៧ ជុំ ។ បទថា **ឧបរិមុទ្ធនि មហន្តं ផណं រិហេ** សេចក្តីថា លាពពារយ៉ាងធំរបស់ខ្លួនបាំងខាងលើចំណែកព្រះសិរសារបស់ព្រះដ៏មានព្រះភាគ ។ បាលីថា **ផណं ករិត្វា** ដូច្នេះក៏មាន អត្ថក៏មានន័យយ៉ាងនោះឯង ។

បានឮថា ស្តេចនាគនោះមានការគិតយ៉ាងនេះថា ក៏ព្រះដ៏មានព្រះភាគប្រថាប់នៅក្បែរគល់ឈើជិតកពរបស់យើងនិងក្ងៀងរហូតដល់អស់ ៧ ថ្ងៃនេះ នៅតែប្រព្រឹត្តទៅ ការបានទីនៅសម្រាកសម្រាប់ព្រះអង្គជាការគួរ ។ ស្តេចនាគនោះ អាចនឹងនិមិត្តប្រាសាទដែលសម្រេចដោយរតន: ៧ ប្រការ ក៏គិតថា កាលយើងធ្វើយ៉ាងនេះ នឹងឈ្មោះថា មិនបានប្រើកាយឱ្យជាសារ: យើងនឹងធ្វើសេចក្តីខ្ជល់ខ្ជាយតាមផ្លូវកាយដល់ព្រះទសពល ទើបនិមិត្តកាយឱ្យធំ ប្រើដងខ្លួនឡោម-ព័ទ្ធព្រះសាស្តា ៧ ជុំ ហើយលាពពារបាំងពីខាងលើ ។ លោកពោលទុកក្នុងអដ្ឋកថាខន្ធក:ថា ខាងក្នុងកេ្នងរបស់នាគនោះ មានខ្នាតប៉ុនបន្ទប់ភណ្ឌាគារក្នុងលោហ:ប្រាសាទ ។ តែក្នុងអដ្ឋកថាមជ្ឈិមនិកាយលោកពោលទុកថា មាន

ខ្ទាតប៉ុនខាងក្រោមលោហៈប្រាសាទ ។ បានឮថា ស្តេចនាគមានអធ្យាស្ម័យ ដូច្នេះថា ព្រះសាស្តានឹងប្រថាប់នៅដោយឥរិយាបថ ដែលទ្រង់មានបំណងប្រាថ្នា ។ ចំណែកព្រះដ៏មានព្រះភាគប្រថាប់គង់នៅដូចដើមនុ៎ះឯងអស់មួយសប្តាហ៍ ។ ក៏ទីនោះបានជាកូដាគារ មានបង្ហួចបិទជិតល្អ ទ្វារមានស្នៀត គន្ធ៏ៈ ស្និទ្ធល្អ ។ ពាក្យមានជាអាទ៍ថា **មា ភតវន្តំ សីតំ** ជាពាក្យសម្តែងហេតុដែលស្តេចនាគនោះធ្វើយ៉ាងនោះ ។ មែនពិត ស្តេចនាគនោះគិតថា សូមរដាកុំបៀត-បៀនព្រះដ៏មានព្រះភាគឡើយ កម្តៅកុំបៀតបៀនព្រះដ៏មានព្រះភាគឡើយ សម្ផស្ស និងរបោមជាដើម កុំបៀតបៀនព្រះដ៏មានព្រះភាគឡើយ ទើបបានធ្វើយ៉ាងនោះ ។ ក្នុងការធ្វើយ៉ាងនោះ ចំពោះកម្តៅរមែងមិនមាន ព្រោះភ្ជៀងធ្លាក់រហូតដល់អស់ ៧ ថ្ងៃ ក៏ពិតមែនហើយ ក៏ប៉ុន្តែថា បើភ្ជៀងរាំងមួយរយៈ។ កម្តៅថ្ងៃក៏នឹងមាន សូម្បីកម្តៅនោះ ក៏កុំគប្បីបៀតបៀនឡើយ ព្រោះដូច្នោះ ស្តេចនាគនោះ គិតយ៉ាងនោះជាការគិតត្រូវ ។ តែក្នុងសេចក្តីនេះ អាចារ្យពួកខ្លះពោលថា ស័ព្ទថា **ឧណ្ហា** ជាការបញ្ជាក់ដល់ហេតុក្នុងការយកដងខ្លួនឡោម-ព័ទ្ធឱ្យធំទូលាយ ។ ក៏កាលធ្វើការឡោមព័ទ្ធរាងកាយព្រះដ៏មានព្រះភាគ ដោយរង្វង់តូចនោះ ចំហាយក្តៅដែលកើតពីរាងរបស់ស្តេចនាគ នឹងបៀតបៀនព្រះដ៏-

មានព្រះភាគ តែបើធ្វើរង្វង់ឱ្យធំទូលាយ កម្ពៅនឹងមិនបៀតបៀនព្រះដ៏មាន-ព្រះភាគឡើយបាន ព្រោះដូច្នោះ ស្តេចនាគទើបបានធ្វើដូច្នោះហើយតាំងនៅ ។

បទថា **ឋិកំ** ប្រែថា ត្រចះត្រចង់ ។ អធិប្បាយថា ឃ្នាតធ្វាយពពក ។ បទថា **ឋិកតវលាហកំ** ប្រែថា ប្រាសចាកពពក ។ បទថា **ឌេវំ** បានដល់ អាកាស ។ បទថា **ឋិតិត្វា** បានដល់ ដឹងថា ឥឡូវនេះ អាកាសប្រាសចាកពពក ព្រះដ៏មានព្រះភាគមិនមានអន្តរាយពីវិពោធិប្បច្ច័យ មានភាពត្រជាក់ជាដើម ។ បទថា **ឋិនិវេឌេត្វា** ប្រែថា រំសាយហើយ ។ បទថា **សកវណ្ណ** បានដល់ រូបនាគ របស់ខ្លួន ។ បទថា **បដិសំហរិត្វា** បានដល់ ឱ្យវិនាសទៅហើយ ។ បទថា **មា-ណវកវណ្ណ** បានដល់ រូបកុមារតូច ។

បទថា **ឯតមត្ថំ** សេចក្តីថា ដឹងសេចក្តីនេះដោយអាការទាំងពួងថា សេចក្តីសុខប៉ុណ្ណោះ រមែងមានក្នុងទីកន្លែងណាមួយដល់អ្នកសោយសុខដែល កើតពីវិវេក ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់បន្ទឹនូវ ឧទាននេះ ដែលសម្តែងដល់អានុភាពនៃសេចក្តីសុខដែលកើតពីវិវេក ។ បណ្តា បទទាំងនោះ បទថា **សុខោ វិវេកោ** បានដល់ ឧបធិវិវេក ពោលគឺ ព្រះនិព្វាន ជាហេតុនាំមកនូវសេចក្តីសុខ ។ បទថា **តុដ្ឋស្ស** បានដល់ អ្នកត្រេកអរដោយ

សន្ធោសក្នុងមគ្គញ្ញាណ ៤ ។ បទថា **សុតធម្មស្ស** *បានដល់ អ្នកមានធម៌ដែលព្រះអង្គទ្រង់ប្រកាសហើយ គឺប្រាកដហើយ ។ បទថា* **បស្សតោ** *បានដល់ អ្នកឃើញវិវេកនោះ ឬវត្ថុដែលឈ្មោះថា នឹងគប្បីឃើញយ៉ាងណាមួយទាំងអស់ ដោយញាណចក្ខុដែលសម្រេចដោយកម្លាំងនៃវីរិយៈរបស់ខ្លួន ។ បទថា* **អព្យាបជ្ឌំ** *បានដល់ ការៈដែលមិនកម្រើក ។ ដោយបទថា* **អព្យាបជ្ឌំ** *នោះ ព្រះអង្គទ្រង់សម្តែងដល់ចំណែកខាងដើម មានមេត្តាជាអារម្មណ៍ ។ បទថា* **ចាណាភូ-តេសុ សញ្ញមោ** *សេចក្តីថា ការសង្រួមក្នុងសត្វទាំងឡាយ គឺការមិនបៀតបៀនជាហេតុនាំមកនូវសេចក្តីសុខ ។ ដោយបទថា* **ចាណាភូតេសុ សញ្ញមោ** *នេះ ព្រះអង្គទ្រង់សម្តែងដល់ចំណែកខាងដើម ដែលមានករុណាជាអារម្មណ៍ ។ បទថា* **សុខា វិរាគតាលោកេ** *សេចក្តីថា សូម្បីភាពជាអ្នកប្រាសចាករាគៈ ជាហេតុនាំមកនូវសេចក្តីសុខក្នុងលោក ។ សួរថា តើការប្រាសចាករាគៈដូចម្តេច? ឆ្លើយថា ព្រោះប្រព្រឹត្តកន្ទ ងកាមទាំងឡាយ អធិប្បាយថា សុខណា ដែលលោកហៅថា ការប្រព្រឹត្តកន្ទ ងចាកកាមទាំងឡាយជាសុខ សូម្បីការប្រាសចាករាគៈក៏ជាសុខដែរ ។ ដោយបទថា* **កាមានំ សមតិក្កមោ** *នេះ ព្រះអង្គត្រាស់សំដៅអនាគាមិមគ្គ ។ ក៏ដោយពាក្យថា* **អស្មិមានស្ស វិនយោ**[1] *នេះព្រះអង្គត្រាស់សំដៅយក*

១-ក្នុងច្បាប់ញដ្ឋសង្គាយនាលោកសរសេរថា **អស្មិមានស្ស យោ វិនយោ**

ព្រះអរហត្ត ។ មែនពិត ព្រះអរហត្ត ព្រះអង្គត្រាស់ថា **អស្មិមានស្ស បដិ-បស្សទ្ធិវិនយោ** ការកម្ចាត់អស្មិមាននេះដោយបដិបស្សទ្ធិ ។ ក៏ឈ្មោះថា សេចក្ដីសុខដ៏ក្រៃលែងជាងនេះរមែងមិនមាន ។ ព្រោះហេតុនោះ ទើបត្រាស់ថា **ឯតំ ខ្វ បរមំ សុខំ** បទនេះឯងជាសុខយ៉ាងក្រៃលែង ។ ព្រះអង្គទ្រង់ប្រកាន់យកកំពូលនៃទេសនាដោយព្រះអរហត្តដោយប្រការដូច្នេះឯង ។

បឋមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ១

២. រាជសុត្តវណ្ណនា

អដ្ឋកថារាជសូត្រ

រាជសូត្រទី ២ *មានវិនិច្ឆ័យដូចតទៅនេះ ៖*

បទថា **សម្ពហុលានំ** *សេចក្ដីថា ដោយបរិយាយក្នុងព្រះវិន័យ ភិក្ខុ ៣ រូប ហៅថា* **សម្ពហុលា** *ក្រៅអំពីនោះ ហៅថា* **សង្ឆ** *។ តែដោយបរិយាយក្នុងព្រះសូត្រ ៣ រូបក៏គង់ហៅថា ៣ រូបនុ៎ះឯង ក្រៅអំពីនោះ ហៅថា* **សម្ពហុលា** *។ ព្រោះដូច្នោះ សូម្បីក្នុងទីនេះ ពោលដោយបរិយាយក្នុងព្រះសូត្រ គប្បីជ្រាបថា* **សម្ពហុលា** *។ បទថា* **ឧបដ្ឋានសាលាយំ** *បានដល់ ក្នុងមណ្ឌបជាកន្លែងប្រជុំស្ដាប់ធម៌ ។ មែនពិត ធម្មសភានោះលោកហៅថា* **ឧបដ្ឋានសាលា** *ព្រោះជាកន្លែងដែលពួកភិក្ខុបម្រើព្រះតថាគត ពេលព្រះអង្គយាងមកសម្ដែងធម៌ ។ ម្យ៉ាងទៀត សាលាក្ដី មណ្ឌបក្ដី ជាកន្លែងដែលពួកភិក្ខុវិនិច្ឆ័យវិន័យ សម្ដែងធម៌ ប្រជុំសាកច្ឆា និងជាទីចូលទៅប្រជុំតាមប្រក្រតី ដោយការប្រជុំគ្នា លោកក៏ហៅថា* **ឧបដ្ឋានសាលា** *ដូចគ្នា ។ មែនពិត សូម្បីក្នុងទីនោះ ពុទ្ធាសនៈ គឺគេក្រាលទុកជានិច្ច ។ មែនពិត ប្រការនេះជាចារិតរបស់ពួកភិក្ខុក្នុងសម័យដែលព្រះដ៏មានព្រះភាគទ្រង់ធរមាននៅឡើយ ។ បទថា* **សន្និសិន្ធានំ** *បានដល់ ប្រជុំដោយការអង្គុយ ។ បទថា* **សន្និបតិតានំ** *បានដល់ អ្នកប្រជុំគ្នាដោយមកពីទីនោះ១ ហើយប្រជុំ ។ ម្យ៉ាងទៀត អ្នកប្រជុំដោយប្រាថ្នាយកពុទ្ធាសនៈជាគោល ហើយអង្គុយប្រជុំគ្នាដោយគោរព ដើម្បីឱ្យកើតសេចក្ដីអើតើ ដូចប្រជុំនៅចំពោះព្រះកន្ត្រព្រះសាស្ដា គឺព្រោះមានអធ្យាស្ស័យស្មើគ្នា ទើបប្រជុំតាមអធ្យាស្ស័យនៃគ្នា និងគ្នា និងដោយការព្រមព្រៀងគ្នាដោយល្អដោយប្រពៃ ។ ដោយបទថា*

អយំ លោកសម្តែងដល់ពាក្យដែលកំពុងពោលនៅក្នុងខណៈនេះ ។ បទថា **អន្តរាកថា** បានដល់ ពាក្យតែមួយ គឺម្យ៉ាងក្នុងចន្លោះកិច្ច មានមនសិការ កម្មដ្ឋាន ឧទ្ទេស និងការសាកសួរជាដើម ម្យ៉ាងទៀត ឈ្មោះថា **អន្តរាកថា** ព្រោះ ប្រព្រឹត្តទៅក្នុងចន្លោះនៃសុគតោវាទ ដែលបានក្នុងវេលាថ្ងៃត្រង់ និងក្នុងចន្លោះ ការស្តាប់ធម៌ ដែលនឹងគប្បីបានក្នុងវេលាល្ងាច ម្យ៉ាងទៀត ឈ្មោះថា **អន្តរាកថា** ព្រោះជាពាក្យម្យ៉ាង ដែលប្រព្រឹត្តទៅក្នុងចន្លោះនៃសមណសមាចារនុ៎ះឯង ។ បទថា **ឧឋាសិ** ប្រែថា កើតឡើងហើយ ។

បទថា **ឥមេសំ ទ្វិន្នំ ភន្តេ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងនិទ្ធារណៈ ។ ក្នុងពាក្យ ថា **មហាធនតរោ ភ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា មានទ្រព្យច្រើន ព្រោះអ្នកនោះមានទ្រព្យច្រើន ពោលគឺ សន្សំរតនៈទាំង ៧ ប្រការ កប់ទុកក្នុង ផែនដី ឈ្មោះថា អ្នកមានទ្រព្យច្រើនជាង បណ្តាព្រះរាជាទាំងពីរអង្គ ព្រះរាជា អង្គនេះមានទ្រព្យយ៉ាងច្រើនក្រៃលែង ។ **ភ**-ស័ព្ទជាវិកប្បត្ថៈ ។ សូម្បីក្នុងបទដ៏ សេស ក៏នយនេះដូចគ្នា ។

ចំណែកសេចក្តីប្លែកគ្នាមានដូច្នេះ ឈ្មោះថា អ្នកមានភោគៈច្រើន ព្រោះ អ្នកនោះមានភោគៈច្រើន គឺមានគ្រឿងបរិភោគច្រើន ដោយមានទ្រព្យធន គ្រឿង ប្រើប្រាស់ជានិច្ច ។ ឈ្មោះថា មានឃ្លាំងច្រើន ព្រោះមានឃ្លាំងច្រើន ដោយមាន ប្រាក់ចូលរាល់ថ្ងៃ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា ទ្រព្យដែលជាវត្ថុដែល គេហួងហែង ដែលផ្សេងដោយប្រភេទនៃកែវមណី ទ្រព្យដែលជាសារៈ ទ្រព្យដែល ជាអសារៈ និងទ្រព្យដែលកើតអំពីគុម្ពឈើជាដើម ដែលប្រាក់ចូលរាល់ថ្ងៃ ទ្រព្យ

ទុ:ឯង គេរក្សាទុកក្នុងបន្ទប់ដែលជាសារ:ជាដើម ឈ្មោះថា **ភោស:** *។ កែវ*
មណី ២៤ យ៉ាង គឺវជិរ: មហានីល: ឥន្ទនីល មរកត ពិទូរ្យ បទុមរាគ ផុស្សរាគ
ភក្ខេតន: បុលាក: វិមល: លោហិតង្ក: ផលិក ប្រពាឡ ជោតិរស គោមុត្តក:
គោមេទក: សោគន្ធិក មុក្តា សង្ខ អញ្ជនមូល: រាជបដ្ដ: អមតង្ករ: ឧិយក:
ព្រាហ្មណី ឈ្មោះថា **មណី** *។ លោហ: ៧ ប្រភេទ និងកហាបណ: ឈ្មោះថា*
ទ្រព្យជាសារ: ។ វត្ថុផ្សេងៗ មានទីដេក គ្រឿងស្មៀកដណ្ដប់ និងសំពត់ក្រហម
ជាដើម ឈ្មោះថា **ផេគ្គ** *។ រុក្ខជាតិផ្សេងៗ មានឈើ ចន្ទន៍ ក្រស្នា ស្ដៅយ៉ាផ្ទង*
និងកាប៉ូរ[1]ជាដើម ឈ្មោះថា **គុម្ព:** *។ ក្នុងបទទាំងនោះ ដោយអាទិស័ព្ទជាដើម*
បទដំបូង លោកសង្គ្រោះវត្ថុទាំងអស់ដែលជាគ្រឿងឧបភោគបរិភោគរបស់ពួក
សត្ត្ব តាំងពីប្រភេទធញ្ញជាតិ ដែលផ្សេងដោយបុព្ពណ្ណជាតិ មានស្រូវសាលីជា
ដើម និងអបរណ្ណជាតិ មានសណ្ដែកបាយ និងសណ្ដែករាជមាសជាដើម ។
ឈ្មោះថា **មហាវិជិត:** *ព្រោះលោកមានរដ្ឋ គឺប្រទេសធំ ។ ឈ្មោះថា* **មហាវាហន:**
ព្រោះលោកមានវាហន:ច្រើន មានដំរី និងសេះជាដើម ។ ឈ្មោះថា **មហាពល:**
ព្រោះលោកមានកម្លាំងកងទ័ព និងកម្លាំងកាយច្រើន ។ ឈ្មោះថា **មហិទ្ធិក:**
ព្រោះលោកមានឫទ្ធិច្រើន ដែលសម្រេចដោយបុញ្ញកម្ម ពោលគឺ សេចក្ដីសម្រេច
តាមដែលប្រាថ្នា ។ ឈ្មោះថា **មហានុភាវ:** *ព្រោះលោកមានអានុភាពច្រើន*
ពោលគឺ តេជ: សេចក្ដីឧស្សាហ៍ មានមន្ត ភាពជាធំ និងភាពអង់អាច ។

ក៏បណ្ដាបទទាំងនោះ ដោយបទដើម ជាការដែលព្រះរាជាទាំងនោះ

១-ក័ប្ប សំ. (ន.) ដ៏រមួយយ៉ាងមានកូ្ចនប្រហើរធ្ងន់ សម្រាប់ប្រើជាថ្នាំឈឺក្បាល, ឆ្ងាងច្រមុះ ។ល។
សម្រាប់ជាធម្មទាន

ទ្រង់ប្រកាសអាយសម្បទា សេចក្ដីសម្បូរដោយជនបទ ។ ដោយបទទី ២ ប្រកាសដល់សេចក្ដីសម្បូរដោយគ្រឿងឧបករណ៍ដ៏វិចិត្រ ដោយបទទី ៣ ប្រកាសដល់សេចក្ដីសម្បូរដោយទ្រព្យសម្បត្តិ ដោយបទទី ៤ ប្រកាសដល់សេចក្ដីសម្បូរដោយជនបទ ដោយបទទី ៥ ប្រកាសដល់សេចក្ដីសម្បូរដោយយានពាហនៈ ដោយបទទី ៦ ប្រកាសដល់អត្តសម្បត្តិ និងបរិវារសម្បត្តិ ដោយបទទី ៧ ប្រកាសដល់បុញ្ញសម្បត្តិ ដោយបទទី ៨ ប្រកាសដល់ភាពជាអ្នកមានអំណាច ។ ព្រោះហេតុនោះ បកតិសម្បទាដែលព្រះរាជាគប្បីប្រាថ្នាទាំង ៧ យ៉ាង គឺសាមិសម្បត្តិ អមាច្ចសម្បត្តិ សេនាសម្បត្តិ រដ្ឋសម្បត្តិ រិកវសម្បត្តិ មិត្តសម្បត្តិ និងទុគ្គសម្បត្តិ ទាំងអស់នោះគប្បីជ្រាបថា លោកសម្ដែងទុកហើយតាមសមគួរ ។

ឈ្មោះថា **រាជា** ព្រោះធ្វើបរិស័ទឱ្យត្រេកអរដោយសង្គហវត្ថុ ៤ មានទានជាដើម ។ ឈ្មោះថា **មាតង្គោ** ព្រោះព្រះអង្គជាឥស្សរៈរបស់ជនអ្នកមគធៈ ។ ឈ្មោះថា **សេនិយោ** ព្រោះព្រះរាជាប្រកបដោយកងទ័ពច្រើន ឬព្រោះមានគោត្រជាប់មកពីមេទ័ព ។ **មាស** លោកហៅថា **ពិម្ពិ** ព្រោះដូច្នោះ ទើបឈ្មោះថា **ពិម្ពិសារ** ព្រោះមានពណ៌ដូចមាសដែលជាសារៈ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា ព្រះរាជានោះមានឈ្មោះយ៉ាងនោះឯង ។ ឈ្មោះថា **បសេនទិ** ព្រោះឈ្នះបច្ចាមិត្ត គឺកងទ័ពដែលជាសត្រូវ ។ ឈ្មោះថា **កោសល** ព្រោះជាអធិបតីនៃកោសលរដ្ឋ ។ ស័ព្ទ **ចរហិ** ក្នុងបទថា **អយញ្ចរហិ** នេះ ត្រឹមតែជានិបាត ។ បទថា **វិប្ផកតា** ប្រែថា មិនទាន់អស់ អធិប្បាយថា អន្តរាកថានេះ របស់ភិក្ខុទាំងនោះមិនទាន់ចប់ ។

បទថា **សាយណ្ហសមយំ** *គឺសម័យមួយក្នុងពេលល្ងាច ។ បទថា* **បដិសល្លានារាមោ** *សេចក្ដីថា ព្រះដ៏មានព្រះភាគចេញចាកអារម្មណ៍ មានរូបជាដើមនោះ។ ពីការរក្សាចិត្ត ពីផលសមាបត្តិ ពោលគឺ ការពួនសម្ងំតាមវេលាដែលកំណត់ទុក ។ មែនពិត ក្នុងវេលាព្រឹក ព្រះដ៏មានព្រះភាគហែហមទៅដោយកិក្ខុសង្ឆ ស្ដេចចូលទៅកាន់ក្រុងសាវត្ថី ព្រះអង្គសោយព្រះក្រយាហារដែលពួកកិក្ខុចាត់ចែងថ្វាយហើយ មានកត្តកិច្ចធ្វើស្រេចហើយ ស្ដេចចេញពីក្រុងសាវត្ថីព្រមដោយកិក្ខុទាំងឡាយ ហើយស្ដេចយាងចូលព្រះវិហារប្រថាប់ឈរត្រង់មុខព្រះគន្ធកុដិ ទ្រង់ប្រទានសុគតោវាទតាមដែលលើកឡើងសម្ដែងដល់កិក្ខុទាំងឡាយអ្នកមកឈរហើយ កាលកិក្ខុទាំងនោះទៅកាន់ទីសម្រាកពេលថ្ងៃមានគល់ឈើក្នុងព្រៃជាដើម ទើបស្ដេចចូលព្រះគន្ធកុដិគង់នៅរហូតអស់ចំណែកនៃថ្ងៃ ដោយសុខដែលកើតពីផលសមាបត្តិ ហើយស្ដេចចេញចាកសមាបត្តិតាមវេលាដែលកំណត់ទុក ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះថា បរិស័ទ ៤ រងចាំតថាគត ហើយកិក្ខុចូលទៅអង្គុយពេញវិហារទាំងអស់ ឥឡូវនេះ ដល់វេលាដែលតថាគត នឹងចូលទៅកាន់សភាមណ្ឌលដើម្បីសម្ដែងធម៌ ដូច្នេះ ហើយទើបស្ដេចក្រោកពីអាសនៈ ចេញពីព្រះគន្ធកុដិដែលក្រអូបជានិច្ច ប្រៀបដូចរាជសីហ៍ ចេញចាកស្ពានមាស មានព្រះដំណើរមាំល្អដោយព្រះរកាយ ដែលមិនយោកចុះឡើង ដូចដំរីប្រសើរដែលចូលកាន់ហ្វូងដូច្នោះ ទ្រង់ញ៉ាំងវិហារ

ទាំងអស់ឱ្យក្ងឹស្វាងដោយពន្ធឺតែមួយ ដោយរូបកាយសម្បត្តិដែលរុងរោចន៍ដោយ
មហាបុរិសលក្ខណៈ ៣២ ប្រការ[១] ប្រដាប់ដោយអនុព្យញ្ជនៈ ៨០[២] ប្រកប

១-មានសេចក្ដីពិស្តារក្នុង**លក្ខណសូត្រ** នៃសុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ១ ដល់ ៦៦ ។

២-អនុព្យញ្ជនៈរបស់ព្រះសម្មាសម្ពុទ្ធមាន ៨០ គឺ

១-ម្រាមព្រះហស្ត និងម្រាមព្រះបាទមានពណ៌លឿង ។ ២-ម្រាមព្រះហស្ត និងម្រាមព្រះបាទពណ៌ខៀវ ។

៣-ម្រាមព្រះហស្ត និងម្រាមព្រះបាទមូលល្អ ។ ៤-ក្រចកទាំង ២០ មានពណ៌ក្រហម ។

៥-ក្រចកទាំង ២០ ងស្ងើតឡើង ។ ៦-ក្រចកមានពណ៌រលោងរលើប ។

៧-ក-ព្រះហស្ត និងក-ព្រះបាទត្រួតនៅក្នុងសាច់ ។ ៨-ព្រះបាទស្មើគ្នា ។

៩-ព្រះដំណើរល្អយាងយាសដូចដំណើរដំរី ។ ១០-ព្រះដំណើរល្អដូចជាដំណើរនៃរាជសីហ៍ ។

១១-ព្រះដំណើរល្អដូចជាដំណើរនៃហង្ស ។ ១២-ព្រះដំណើរ ដូចជាដំណើរគោឧសភរាជ ។

១៣-បើទ្រង់ឈរហើយត្រូវយាងទៅ តែងតែលើកព្រះបាទខាងស្តាំបោះទៅមុខជាដរាប ។

១៤-ព្រះមណ្ឌលជង្គង់មូលល្អ ។ ១៥-មានព្យញ្ជនៈជាបុរសគ្រប់គ្រាន់ គឺមិនបានកិរិយាដូចជាស្ត្រីឡើយ ។

១៦-ផ្ទិតមិនខូង មិនផត គឺមូលស្មើល្អ ។ ១៧-ពោះមានព្រះសណ្ឋានជ្រៅ ។

១៨-ពោះមានសណ្ឋានខ្ជៅរិលទៅខាងស្តាំ (ទក្ខិណាវដ្ដ) ។ ១៩-ក្ងៅទាំងគូមូលល្អ ។

២០-ព្រះហស្តទាំងគូល្អ ។ ២១-ព្រះអវយវៈធំតូចទាំងអស់ មានលក្ខណៈ ល្អតាមចំណែកៗ ។

២២-សាច់ដែលគួរក្រាស់ក៏ក្រាស់ ។ ២៣-សាច់មិនយារ ឬជ្រួញជ្រីវ ។

២៤-ព្រះកាយគ្មានប្រជ្រុយ ឬអាចម៍រុយ ។ ២៥-ព្រះកាយវយវៈសមគ្នាតាមលំដាប់លំដោយលើក្រោម ។

២៦-ព្រះកាយបរិសុទ្ធគ្មានមន្ទិល ។ ២៧-មានព្រះកម្ទាំងច្រើន ។

២៨-មានច្រមុះខ្ពស់សម ។ ២៩-មានសណ្ឋាន ច្រមុះល្អ ។

៣០-បបូរព្រះឱស្ថលើ-ក្រោម មិនបានចូលចេញលើសគ្នា ។ ៣១-ព្រះទន្ដតគ្រឿង សៅហ្មង ។

៣២-ព្រះទន្ដសម្ផ្ការស័ង្ខ ។ ៣៣-ព្រះទន្ដរលើបស្អាត ។

៣៤-ព្រះឥន្ទ្រិយទាំង ៥ បរិសុទ្ធល្អ ។ ៣៥-ព្រះចង្កូមទាំង ៤ មូលពេញលេញ ។

៣៦-រង់ព្រះកន្ទ្រមានទម្រង់មូលទ្រវែង សមល្អ ។ ៣៧-ថ្ពាល់ទាំងគូល្អក្ងីថ្ងាស្មើគ្នា ។
៣៨-អញ្ជាញព្រះហស្តមានស្នាមជ្រៅ ។ ៣៩-អញ្ជាញ ព្រះហស្តស្នាមវែង ។
៤០-អញ្ជាញព្រះហស្តមានស្នាមត្រង់ ។ ៤១-អញ្ជាញព្រះហស្តមានស្នាមក្រហមរុងរឿង ។
៤២-រស្មីព្រះកាយមានពន្ធឺជាបរិមណ្ឌល ។ ៤៣-ថ្ពាល់ទាំងគូពេញកំពុងណែនល្អ ។
៤៤-ត្របកព្រះនេត្រទូលាយវែងសម ។ ៤៥-ព្រះនេត្រប្រកបដោយប្រសាទទាំង ៥ ។
៤៦-ចុងសរសៃព្រះលោមាទាំងឡាយមិនបានរៀច ។ ៤៧-អណ្ណាតមានទម្រង់ល្អ ។
៤៨-អណ្ណាតទន់មិនមាំ ។ ៤៩-ដោះទាំងគូ មានទម្រង់វែងដូចជាត្របកបទុមជាតិ ។
៥០-រង្វង់ព្រះសុរងមានទម្រង់មូល ។ ៥១-សរសៃទាំងពួងស្ងួតឥតមានជ្រួញ ។
៥២-ជួរសរសៃទាំងឡាយត្រួតនៅក្នុងសាច់ទាំងអស់ ។ ៥៣-ព្រះសិរមានទម្រង់ដូចឆត្រកែវ ។
៥៤-បរិមណ្ឌលថ្ងាសទូលាយវែងល្មម ។ ៥៥-ថ្ងាសមានទម្រង់ដ៏ល្អ ។
៥៦-ចិញ្ចើមមានទម្រង់ដ៏ល្អដូចធ្នូ ។ ៥៧-ព្រះរោមចិញ្ចើមមានសរសៃដ៏ល្អិត ។
៥៨-សរសៃ ព្រះចិញ្ចើមដុះហើយដួលរាបទៅដោយលំដាប់ ។ ៥៩-ព្រះចិញ្ចើមធំល្មម ។
៦០-ព្រះចិញ្ចើមវែងផុតព្រះនេត្រ ។ ៦១-សម្ផ្ការថ្លៃល្អិតធ្ងារពេញព្រះកាយ ។
៦២-ព្រះកាយរុងរឿង ។ ៦៣-ព្រះសរីរកាយ តែងក្ងីថ្ងាមិនស្អាប់សៅហ្មង ។
៦៤-ព្រះសរីរកាយស្រស់ក្ងីថ្ងាដូចផ្កាឈូក ។ ៦៥-ព្រះសរីរកាយមានសម្ផស្សទន់ភ្ងន់ ។
៦៦-ក្ងិនព្រះកាយក្រអូបឈ្ងុយដូចក្ងិនផ្កា ។ ៦៧-ព្រះរោមសរសៃស្មើគ្នាទាំងអស់ ។
៦៨-ព្រះរោមមានសរសៃល្អិតធ្ងារ ។ ៦៩-ព្រះដង្ហើមចេញចូលល្អិត ។
៧០-ព្រះឱស្ថមានទម្រង់ល្អ ហាក់ដូចជាទ្រង់ញញឹមជានិច្ច ។ ៧១-ក្ងិនព្រះឱស្ថក្រអូបដូចក្ងិនឧប្បល ។
៧២-ព្រះកេសាខ្មៅរលោងរលើប ។ ៧៣-ព្រះកេសាមានក្ងិនក្រអូបឈ្ងុយឈ្ងប់ ។
*៧៤-ព្រះកេសាក្រអូបដូចជាក្ងិននៃផ្កាកោមល (**កោមល** ក្ងាយមកពីពាក្យ **កមល** ប្រែថា ផ្កាឈូក) ។*
៧៥-ព្រះកេសាមានទម្រង់មូលព័ទ្ធព្រះកេសា ។ ៧៦-ព្រះកេសាខ្មៅស្និទ្ធ ។
៧៧-សរសៃ ព្រះកេសាធ្ងារល្អិត ។ ៧៨-សរសៃព្រះកេសាស្ងួត ។
៧៩-សរសៃព្រះកេសាវិលព័ទ្ធព្រះកេសានៅខាងស្តាំ ។ ៨០-មានព្រះរស្មីក្ងីចិញ្ចាចលើព្រះសិរសា ។

សម្រាប់ជាធម្មទាន

សេចក្ដីល្អ ដែលទ្រោមព័ទ្ធដោយព្រះរស្មីមួយព្យាម ដល់ព្រមដោយការយាង-យាស ប្រដាប់ដោយកេតុមាលាដ៏ត្រចះត្រចង់ ព្រះពុទ្ធរស្មីមានពណ៌ ៦ ប្រការ គឺខៀវ លឿង ក្រហម ស ហង្សបាទ និងពណ៌ផ្ទេក មានអានុភាពជាអាចិន្ដេយ្យ ប្រកបដោយពុទ្ធលីលា ដែលរកអ្វីប្រៀបផ្ទឹមមិនបាន ស្ដេចយាងចូលទៅកាន់ឧបដ្ឋានសាលា ។ ព្រោះហេតុនេះ លោកទើបពោលថា **អថ ខោ ភគវា ។បេ។ តេនុបសង្កមិ** ។

កាលព្រះដ៏មានព្រះភាគគ្រាស្ដេចចូលទៅយ៉ាងនេះហើយទ្រង់ឃើញភិក្ខុទាំងនោះអង្គុយសម្ដែងវត្ត ហើយស្ងៀមនៅ ទ្រង់មានព្រះតម្រិះថា កាលតថាគតមិនពោល ភិក្ខុទាំងនេះក៏នឹងមិនពោលសូម្បីរហូតអស់អាយុកប្ប ព្រោះសេចក្ដីគោរពក្នុងព្រះពុទ្ធ ដើម្បីនឹងតាំងរឿងឡើង ទើបត្រាស់ពាក្យមានជាអាទិ៍ថា **កាយ ជុត្ត ភិក្ខវេ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាយ ជុត្ត** កែជា **ភតមាយ ជុ ភវថ** ពួកអ្នកសន្ធនាគ្នារឿងអ្វីហ្ន៎ ។ បាលីថា **ការយ ជោត្ត** ដូច្នេះ ក៏មានសេចក្ដីក៏ដូចគ្នា ។ អាចារ្យពួកខ្លះពោលថា **ការយ ជ្ជេត្ត** ដូច្នេះក៏មាន ។ បាលីនោះមានសេចក្ដីថា **ភតមាយ ជុ ឯត្ត** ។ ក្នុងសេចក្ដីនោះ មានសេចក្ដីសង្ខេបដូចតទៅនេះ

ព្រះដ៏មានព្រះភាគទ្រង់បវារណា ដោយបវារណារបស់ព្រះសព្វញ្ញូយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយសន្ធនាគ្នាក្នុងទីនេះ ដោយរឿង

អ្វីហ្ន៎ និងរឿងរបស់ពួកអ្នកដូចម្តេចមិនទាន់ចប់ស្រេច ព្រោះការមករបស់តថាគត ជាហេតុ អ្នកទាំងឡាយគប្បីឱ្យរឿងនោះចប់ស្រេចចុះ ។

បទថា **ន ខ្ជ្ជតំ** *កាត់បទជា* **ន ខោ ឍតំ** *ម្យ៉ាងទៀតបាលីក៏យ៉ាងនេះដូចគ្នា ។ អាចារ្យពួកខ្លះពោលថា* **ន ខោតំ** *ដូច្នេះក៏មាន មានការចែកបទថា* **ន ខោ ឍតំ** *ដូច្នេះ ដូចគ្នា ។ បទថា* **កុលបុត្តានំ** *បានដល់ កុលបុត្រអ្នកមានមារយាទ និងជាតិ ។ បទថា* **សទ្ធា** *បានដល់ ដោយសទ្ធា គឺដោយជឿកម្ម និងផលនៃកម្ម និងដោយការជឿព្រះរតនត្រ័យ ។ បទថា* **អការស្មា** *ប្រែថា ពីផ្ទះ អធិប្បាយថា ពីភាពជាគ្រហស្ថ ។ បទថា* **អនាការិយំ** *ប្រែថា ការបព្វជ្ជា ។ បទថា* **បព្វជិតានំ** *បានដល់ អ្នកចូលដល់ ។ បទថា* **យំ** *ជាកិរិយាបរាមាស ។ ក្នុងសេចក្តីនោះ មានបទយោជនាដូចតទៅនេះ ព្រះដ៏មានព្រះភាគទ្រង់បដិសេធសេចក្តីមិនសមគួររបស់បព្វជិតអ្នកប្រជុំគ្នាយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មិនមែនត្រូវព្រះរាជបង្គាប់ មិនមែនត្រូវចោរបង្គាប់ មិនមែនមានក្តីព្រោះជាប់បំណុល មិនមែនដើម្បីចិញ្ចឹមជីវិតទើបបួសដោយពិត អ្នកទាំងឡាយចេញចាកផ្ទះបួសក្នុងសាសនារបស់តថាគតដោយសទ្ធា ឥឡូវនេះ អ្នកទាំងឡាយ ពោលតិរច្ឆានកថាដែលជាប់ដោយព្រះរាជាបែបនេះ ការដែលពោលរឿងបែបនោះ មិនសាកសមមិនគួរដល់អ្នកទាំងឡាយឡើយ ។*

ឥឡូវនេះ កាលនឹងទ្រង់អនុញ្ញាតការបដិបត្តិ ដែលសមគួរដល់ភិក្ខុទាំងនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កិច្ច ២ យ៉ាង ដែលអ្នកទាំងឡាយប្រជុំគ្នាគប្បីធ្វើ គឺពោលធម្មីកថា ឬជាអ្នកស្ងៀមដូចព្រះអរិយៈ ។

បណ្តាបទទាំងនោះ **ភោ** *ប្រែថា* **ការណ៏ាយ** *។ មានសេចក្តីអធិប្បាយថា ក៏បទថា* **ភោ** *នេះ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃកត្តុ គឺអ្នកធ្វើប្រាជ្ញាដល់បទថា* **ការណ៏ាយ** *ព្រោះដូច្នោះ បទថា* **ភោ** *ទើបប្រែថា* **ការណ៏ាយ** *។ បទថា* **ទ្វយំ ការណ៏ាយ** *បានដល់ គប្បីធ្វើ ២ យ៉ាង ។ បទថា* **ធ្ម្ម ីកថ** *បានដល់ ពាក្យដែលមិនប្រាសចាកធម៌ គឺសច្ច: ២ អធិប្បាយថា ធម៌ទេសនាដែលសម្តែងដល់ការប្រព្រឹត្តទៅនិង(ទុក្ខសច្ច:) ការមិនត្រឡប់ ។ ក៏ធម្ម ីកថ (និរោធសច្ច:) ពោលគឺ* **កថាវត្ថុ** *១០[1] ជាឯកទេសរបស់ធម្មទេសនានោះឯង ។ បទថា* **អ**ារ**ិយ**ោ *សេចក្តីថា ឈ្មោះថា* ***អ**ារ**ិយ:*** *ព្រោះនាំប្រយោជន៍មកយ៉ាងពិត ។ ម្យ៉ាងទៀត ឈ្មោះថា* ***អ**ារ**ិយ:*** *ព្រោះជាអ្នកបរិសុទ្ធ គឺខ្ពស់បំផុត ។ បទថា* **ត**ុ**ណ្ហ**ីភ**ាវ**ោ *ការ*

---

*១-**កថាវត្ថុ** "ពាក្យដែលគួរនិយាយ" ១០ យ៉ាងគឺ*

១-អប្ប**ិ**ច្ឆ**ីកថ**ា = *ពាក្យដែលដឹកនាំឱ្យមានប្រាជ្ញាតិច*

២-សន្ត**ុ**ដ្ឋ**ីកថ**ា = *ពាក្យដែលដឹកនាំឱ្យមានសន្តោសត្រេកអរដោយបច្ច័យតាមមានតាមបាន*

៣-បវ**ិ**វ**ីកកថ**ា = *ពាក្យដែលដឹកនាំឱ្យស្ងាត់កាយស្ងាត់ចិត្ត*

៤-អស**ំ**ស**ីកថ**ា = *ពាក្យដែលដឹកនាំមិនឱ្យច្រឡំដោយបក្ខពួក*

៥-วิ**ริ**ย**ារ**ម្ភ**ីកថ**ា = *ពាក្យដែលដឹកនាំឱ្យមានការព្យាយាម*

៦-សីល**ីកថ**ា = *ពាក្យដែលដឹកនាំឱ្យតាំងនៅក្នុងសីល*

៧-สม** า**ธ**ิ**ก**ថ**ា = *ពាក្យដែលដឹកនាំឱ្យមានសមាធិចិត្ត*

៨-ปญ**ญ**า**ก**ถ**า = *ពាក្យដែលដឹកនាំឱ្យកើតប្រាជ្ញា*

៩-วิ**มุ**ต**ิ**ก**ថ**ា = *ពាក្យដែលដឹកនាំឱ្យធ្វើចិត្តឱ្យផុតចាកកិលេស*

១០-วิ**มุ**ต**ิ**ญ**า**ณ**ท**ส**ฺ**ส**ะ**ก**ถ**ា = *ពាក្យដែលដឹកនាំឱ្យកើតសេចក្តីដឹង សេចក្តីឃើញក្នុងវិមុត្តិ ។*

(ស្រង់ចាកសុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១៤៧)

សម្រាប់ជាធម្មទាន

មិននិយាយ គឺជាតួសមថការនា និងវិបស្សនាការនា ។ តែអាចារ្យមួយពួកពោលថា ទុតិយជ្ឌានជាសេចក្តីស្ងៀមយ៉ាងប្រសើរ ព្រោះជាបដិបក្ខចំពោះវចីសង្ខារ ។ អាចារ្យមួយពួកទៀតពោលថា ចតុត្ថជ្ឌានជាសេចក្តីស្ងៀមយ៉ាងប្រសើរ ។ ក៏ក្នុងទីនេះមានអធិប្បាយ ដូច្នេះថា ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកលោកមានកាយវិវេកនៅក្នុងសុញ្ញាគារ ដើម្បីកពូនចិត្តវិវេក បើនឹងប្រជុំគ្នាគ្រាខ្លះ គ្រាអ្នកទាំងឡាយប្រជុំគ្នាយ៉ាងនេះ គប្បីញ៉ាំងធម្មីកថាដែលជាប់ដោយអនិច្ចលក្ខណៈជាដើមនៃសការធម៌ មានខន្ធជាដើមឱ្យប្រព្រឹត្តទៅដោយជាឧបការៈដល់គ្នានិងគ្នាតាមន័យដែលពោលទុកថា រមែងបានស្តាប់វត្ថុដែលនៅមិនធ្លាប់ស្តាប់ រមែងធ្វើវត្ថុដែលបានស្តាប់ហើយឱ្យយល់ច្បាស់ ឬគប្បីនៅដោយឈានសមាបត្តិ ដើម្បីនឹងមិនបៀតបៀនគ្នានិងគ្នា ។

បណ្តាករណីទាំងពីរនោះ ដោយករណីដំបូង ព្រះដ៏មានព្រះភាគទ្រង់សម្តែងឧបាយដែលជាហេតុចុះស៊ប់ក្នុងព្រះសាសនា សម្រាប់អ្នកដែលនៅមិនបានចុះស៊ប់ ដោយករណីក្រោយ ព្រះដ៏មានព្រះភាគទ្រង់សម្តែងឧបាយជាគ្រឿងរលាស់ចេញចាកសង្ខារ សម្រាប់អ្នកដែលធ្លាក់ចុះស៊ប់ហើយ ។ ឬដោយករណីដំបូង ព្រះដ៏មានព្រះភាគឱ្យប្រកបភាពជាអ្នកស្ទាត់ជំនាញក្នុងអាគម (ព្រះសូត្រ) ដោយករណីក្រោយ ព្រះដ៏មានព្រះភាគឱ្យប្រកបភាពជាអ្នកស្ទាត់ជំនាញក្នុងអធិគម (មគ្គផលដែលនឹងគប្បីសម្រេច) ។ ម្យ៉ាងទៀត ដោយករណីដំបូង ព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់ហេតុ ដែលសម្មាទិដ្ឋិកើតឡើងគ្រាទីមួយ ដោយករណីក្រោយព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់ហេតុ ដែលសម្មាទិដ្ឋិកើតឡើងគ្រាទីពីរ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ២ យ៉ាងនេះ ជាបច្ច័យឱ្យកើតសម្មាទិដ្ឋិ គឺ សួរសំឡេងអំពីសម្នាក់អ្នកដទៃ(ការស្តាប់ព្រះសទ្ធម្ម) ១ យោនិសោមនសការ ១[1] ។

ម្យ៉ាងទៀត ដោយករណីដំបូង ព្រះដ៏មានព្រះភាគទ្រង់ប្រកាសមូល-ហេតុនៃសម្មាទិដ្ឋិជាលោកិយ: ដោយករណីក្រោយ ព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់មូលហេតុនៃសម្មាទិដ្ឋិជាលោកុត្តរ: គប្បីជ្រាបអត្ថយោជនាដោយន័យមានជាអាទិ៍ដូចពោលមកដូច្នេះ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ជ្រាបដោយប្រការទាំងពួងនូវសេចក្តីនេះថា សម្បត្តិមានឈានជាដើម នៅស្ងប់ជាង និងប្រណីតជាងកាមសម្បត្តិ ដែលភិក្ខុទាំងឡាយនោះសន្ធនាគ្នា ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់បន្ទឹនូវឧទានដែលសម្តែងអានុភាពរបស់សុខដែលកើតពីអរិយវិហារនេះ ។

បណ្តាបទទាំងនោះ ស័ព្ទថា **លោក** ក្នុងបទថា **យញ្ច កាមសុខំ លោកេ** នេះ មកក្នុង**សង្ខារ** មានជាអាទិ៍ថា ខន្ធលោក អាយតនលោក ធាតុលោក ។ មកក្នុង**ឱកាស** មានជាអាទិ៍ថា ព្រះអង្គ្រាស់ថា ព្រះចន្ទ និងព្រះអាទិត្យទាំងឡាយ ដែលបំភ្លឺទិសទាំងឡាយឱ្យភ្លឺបានត្រឹមណា លោក គឺចក្កវាឡទាំង ១.០០០ ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅបានតែ ត្រឹមចក្កវាឡ ១.០០០ ន៏ុ:[2] ។ មកក្នុង**សត្វទាំងឡាយ** មានជាអាទិ៍ថា ព្រះដ៏មានព្រះភាគកាលទ្រង់រមិលមើល

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ២០ ទំព័រ ១៩៧ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២២ ទំព័រ ៣៦៨ ដល់ ៣៦៩ ។

សត្វលោកដោយពុទ្ធចក្ខុ[1]*។ តែក្នុងទីនេះ គប្បីជ្រាបសព្ទថា* **លោក** *ក្នុងអត្ថន័យថា សត្វលោក និងឱកាសលោក ។ ព្រោះដូច្នោះ ក្នុងលោកនេះ ខាងក្រោមចាប់ពីអវិចីឡើងទៅ ខាងលើចាប់តាំងពីព្រហ្មលោកចុះមក សុខ ឈ្មោះថាកើតព្រមដោយកាម ព្រោះអាស្រ័យវត្ថុកាមកើតឡើងដោយកិលេសកាម ។ បទថា* **យញ្ចិទំ ឧ្ចិ ១ យំ សុខំ** *សេចក្ដីថា សុខ ដែលជាទិព្ធនេះឯណា និងសុខដែលកើតពីរូបសមាបត្តិរបស់ព្រហ្ម និងរបស់មនុស្សដែលបានដោយទិព្ធវិហារ ។ បទថា* **តណ្ហាក្ខ្ចយសុ ១ ១ ១ ១** *សេចក្ដីថា សុខដែលកើតអំពីផលសមាបត្តិដែលប្រព្រឹត្តទៅ ព្រោះធ្វើព្រះនិព្ធានដែលតណ្ហាមកដល់ហើយអស់ទៅជាអារម្មណ៍ និងព្រោះសេចក្ដីសូប់រម្ងាប់តណ្ហាបាន ឈ្មោះថា សុខដែលកើត អំពីការអស់តណ្ហានៃសុខដែលកើតអំពីការអស់តណ្ហានោះ ។ បទថា* **ឯ ១ ១**[2]*ជាបទសម្ដែងខ្ចៃលិង្គវិបល្លាស ។ អធិប្បាយថា* **ឯ ១ ១ ១ ១ ១ ១ ១ ១** *សុខពួកនេះ ។ អាចារ្យពួកខ្ចះកាន់ទូវសេចក្ដីសុខ សូម្បីទាំងពីរដោយសាមញ្ញសុខ ហើយពោលថា* **ឯ ១ ១** *។ គប្បីមានបាលីរបស់ភេចិអាចារ្យទាំងនោះថា* **ក ១ ១ ១ ១ ១ ១ ១ ១** *ជ ១ ១ ១ ១ ១ ១ ១ ១*[3]*។*

បទថា **ស ១ ១ ១ ១ ១ ១ ១ ១** *ប្រែថា បរិបូរ ១៦ ចំណែក ។ ក៏ក្នុងសេចក្ដីនេះ មានសេចក្ដីសង្ខេបដូចតទៅនេះ*

កាមសុខដែលកើតក្នុងកាមលោកទាំង ១១ ប្រការ គឺសុខរបស់មនុស្ស

១-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ១៧ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ១៣៦ បន្ទាត់ទី ២ ពាក់ពីក្រោមឡើងលើ មិនមានពាក្យថា **ឯ ១ ១** *ទេ តែលោកប្រើពាក្យថា* **ត ១** *ប៉ុន្តែតាមវេយ្យាករណ៍ពាក្យទាំងពីរនេះមិនខុសគ្នាទេ ។*

៣-ក្នុងច្បាប់ធម្ម១ សង្គាយនា និងច្បាប់មហាមកុដរាជវិទ្យាល័យថា **ក ១ ១ ១ ១ ១ ១ ១ ១** *ជ ១ ១ ១ ១ ១ ១ ១ ១ ។*

ក្នុងមនុស្សលោកទាំងអស់ តាំងពីសុខរបស់ស្តេចចក្រពត្តិ សុខដ៏ប្រសើរជាដើម សេចក្តីសុខដែលសត្វទាំងឡាយ មាននាគជាដើមគប្បីសោយក្នុងពិភពនាគ និងឋានរបស់គ្រុឌជាដើម និងកាមសុខ ៦ យ៉ាង ក្នុងទេវលោក មានជាន់ចាតុម្ម-ហារាជិកាជាដើម ។ និងសេចក្តីសុខដែលកើតពីលោកិយឈាន ដែលបាននាមថា **ទិវិយំ** ព្រោះកើតក្នុងទេវលោកជាន់រូបាវចរ និងអរូបាវចរ និងក្នុងរូបឈាន និងអរូបឈានដែលជាទិព្វវិហារ សូម្បីសេចក្តីសុខទាំងអស់ទាំងពីរយ៉ាងនោះ ក៏មិនទាន់ដល់ចំណែកទី ១៦ នៃការពោលគឺ ចំណែកមួយដែលបានក្នុងការគុណជា ១៦ ចំណែក យកត្រឹមធ្វើចំណែកតែមួយពី ១៦ ចំណែកនោះ ដោយបែងសេចក្តីសុខដែលកើតពីផលសមាបត្តិពោលគឺ សុខដែលកើតពីការអស់តណ្ហាឱ្យជា ១៦ ចំណែក ។

ក៏ការពណ៌នាអត្ថនេះ លោកពោលទុកដោយសេចក្តីស្មើគ្នានៃផល-សមាបត្តិ ព្រោះធម៌ជាទីអស់ទៅនៃតណ្ហាមកក្នុងព្រះបាលីដោយមិនប្លែកគ្នា ។ លោកិយសុខមិនដល់គុណ សូម្បីនៃសុខដែលកើតពីផលសមាបត្តិទីមួយឡើយ សមដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា

បថព្យា ឯករជ្ជេន សគ្គស្ស គមនេន វា
សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំក្នុងលោកទាំងមូលផង[១] ។

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៥៩ ។

សូម្បីក្នុងសោតាបត្តិសំយុត្តក៏ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ពិតមែនថា ស្តេចចក្រពត្តិ សោយរាជសម្បត្តិ មានសភាពជាឥស្សរៈ ជាធំជាងទ្វីបទាំង ២ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាក្នុងស្ថានតាវត្តឹង្ស ។ ទេវបុត្រនោះ មានពួកស្រីអប្សរចោមរោមក្នុងនន្ទនវនឧទ្យាន ក្នុងស្ថានតាវត្តឹង្សនោះ ទ្រង់ផ្ចែតស្ដាប់ស្ដាល់ មូលមិត្តដោយកាមគុណទាំង ៥ ជាទិព្ធ ។ បើទេវបុត្រនោះ ក៏គង់មិនរួចស្រឡះចាកនរក មិនរួចស្រឡះចាកកំណើតតិរច្ឆាន មិនរួចស្រឡះចាកប្រេតវិស័យ មិនរួចស្រឡះចាកអសុរកាយបានឡើយ ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវក រមែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយភោជនជាពំនូតដែលបានមកដោយកម្ទាំងកំភួនជើង ប្រើប្រាស់នូវសំពត់គ្មានជាយក៏ពិតមែនហើយ ។ តែថា អរិយសាវកនោះប្រកបដោយធម៌ ៤ យ៉ាង ។ ទើបអរិយសាវកនោះរួចស្រឡះចាកនរក រួចស្រឡះចាកកំណើតតិរច្ឆាន រួចស្រឡះចាកប្រេតវិស័យ រួចស្រឡះចាកអសុរកាយបាន ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគនោះ ជាអរហន្តសម្មាសម្ពុទ្ធ ។ ល ។ ទ្រង់ខ្ជាក់ចោលនូវត្រៃភព លៃងវិលត្រឡប់មកកើតទៀត ១ ។ ប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ព្រះបរិយត្តធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងហើយដោយប្រពៃ ។ ល ។ គប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ១ ។ ប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឆថា ព្រះសង្ឆជាសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយប្រពៃ ។ល។ ជាបុញ្ញក្ខេត្ត

នៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ១ ។ ប្រកបដោយសីលជាទីត្រេក-អរនៃព្រះអរិយៈ ជាសីលមិនដាច់ មិនធ្ទុះ មិនពព្ទុះ មិនពពាល ជាសីលជានាដែលអ្នកប្រាជ្ញគប្បីសរសើរ មិនបានប៉ះពាល់ (ដោយតណ្ហានឹងទិដ្ឋិ) ប្រព្រឹត្តទៅព្រមដើម្បីសមាធិ ១ អរិយសាវកជាអ្នកប្រកបដោយធម៌ទាំង ៤ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ការដែលបាននូវទ្វីបទាំង ៤ ហើយនឹងការដែលបាននូវធម៌ទាំង ៤ ឯការបាននូវទ្វីបទាំង ៤ មិនដល់នូវចំណិតដែលចែកជាចំណែក ១៦ ដងនៃការបាននូវធម៌ទាំង ៤ ឡើយ[១] ។

ព្រះដ៏មានព្រះភាគទ្រង់ចែកលោកិយសុខថាក្រៃលែង ថាប្រព្រឹត្តទៅនិងដោយសេចក្ដីល្អក្រៃលែង ទ្រង់ចែកនូវលោកុត្តរសុខថាដ៏ផ្ដើម គឺក្រៃលែងក្នុងទីទាំងពួងដោយប្រការដូច្នេះឯង ។

ឧតិយសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ២

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៩ ទំព័រ ៦១ ដល់ ៦៣ ។

៣. ឧណ្ហសុត្តវណ្ណនា

អដ្ឋកថាឧណ្ហសូត្រទី ៣

ទណ្ហសូត្រទី ៣ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ការុមារកា** *បានដល់ ក្មេងទាំងឡាយ ។* **អត្តភ**-*ស័ព្ទ ក្នុងពាក្យថា* **អត្តភ ច សាវត្ថី អត្តភ ច ជេតវនំ** *នេះ មកក្នុង* ***ហេតុ*** *ក្នុងប្រយោគមានជាអាទិ៍ថា* **តទនន្តរំ ការោ ជានេយ្យ អញ្ញត្រ តថាគតេន ។** *លំដាប់តពីនោះ មក អ្នកណាគប្បីដឹងបាននូវហេតុនោះកើត លើកលែងតែព្រះតថាគតចេញ[១] ។ និងប្រយោគថា* **ជនា សង្ហ្ម មន្តេន្តិ មញ្ញ តញ្ញ ការ្ម ។** *ជនទាំងឡាយ មកប្រជុំនិយាយគ្នាចំពោះខ្ញុំផង ចំពោះលោកផង តើព្រោះហេតុអ្វី[២] ។ មកក្នុង* ***ខណ:*** *ក្នុងប្រយោគមានជាអាទិ៍ថា* **អជ្ជ សា ខោ មំ ភន្តេ អញ្ញតរា ឥត្ថី រ្ជ្ជ-ការ ភ ជ ជ ជ ។** *បពិត្រព្រះអង្គដ៏ចម្រើន ស្ត្រីម្នាក់កំពុងលាងភាជន: បានឃើញខ្ញុំព្រះអង្គក្នុងពេលមានផ្ទេកបន្ទោ[៣] ។ មកក្នុង* ***ចិត្ត*** *ក្នុងប្រយោគមានអាទិ៍ថា* **យ ស្ស ន្ត ត ន ។** *សេចក្ដីក្រោធមិនមានក្នុងចិត្តរបស់បុគ្គលណា[៤] ។ មកក្នុង* ***ពាក់កណ្ដាល*** *ក្នុងប្រយោគមានអាទិ៍ថា* **អ ភ ។** *ដល់ទីបំផុតពាក់កណ្ដាល ។ មកក្នុង* ***ចន្ទោ:*** *ក្នុងប្រយោគមានជាអាទិ៍ថា* **ត ។** *ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែស្ទឹងតបោទានេះ មកតាមចន្ទោ:មហានរកទាំងពីរ[៥] ។ សូម្បីក្នុងទីនេះ ស័ព្ទថា* ***អ ***នេះ *នោះគប្បីជ្រាបថា ប្រើក្នុងចន្ទោ: ព្រោះដូច្នោ:*

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឆក្កនិបាត លេខ ៤៦ ទំព័រ ១៤២ ។

២-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ៣០ ទំព័រ ១៩៥ ។

៣-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក: លេខ ២៣ ទំព័រ ៣០៩ ។

៤-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ១៥៧ ។

៥-វិនយបិដក មហាវិភង្គ លេខ ១ ទំព័រ ៣៧៣ ។

តទៅទំព័រ ២១៧ ទៀត

គប្បីជ្រាបអត្ថក្នុង**អន្តរា**-សព្ទនេះយ៉ាងនេះថា ក្នុងចន្ទោះក្រុងសាវត្ថី និងវត្តជេត-ពន ។ ក៏ព្រោះប្រកបដោយ**អន្តរា**-សព្ទ ក្នុងទីនេះទើបជាទុតិយាវិភត្តថា **អន្តរា ច សាវត្ថឺ អន្តរា ច ជេតវនំ** ចន្ទោះក្រុងសាវត្ថី និងចន្ទោះវត្តជេតពន ។ ប្រាកដដូចនេះ អ្នកអក្ខរវិទូទាំងឡាយប្រកប**អន្តរា**-សព្ទតែមួយប៉ុណ្ណោះថា **អន្តរា គាមញ្ច នគិញ្ច គច្ឆតិ** ទៅចន្ទោះស្រុកនិងចន្ទោះទន្ទេ ។ **អន្តរា**-សព្ទ គឺលោកគប្បីប្រកបដោយបទទីពីរ តែក្នុងទីនេះលោកប្រកបទុកហើយ ។

បទថា **អហឺ ឧណ្ហេន ហានន្តិ** សេចក្តីថា ពួកក្មេងដេញវាយពស់ដែក ដែលមានសេចក្តីស្រេកឃ្លានកំពុងវារចេញពីប្រហោងឈើដោយដំបង ។ ក៏សម័យនោះ ព្រះដ៏មានព្រះភាគងស្តេចយាងទៅកាន់ក្រុងសាវត្ថី ឃើញក្មេងទាំងឡាយនោះ ត្រង់ចន្ទោះផ្លូវយកឈើវាយពស់ ទើបត្រាស់សួរថា នែ៎ក្មេងទាំងឡាយ ព្រោះហេតុអ្វី ទើបអ្នកទាំងឡាយយកឈើវាយពស់នេះ និងកាលក្មេងៗទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្លាចវាខាំ ទើបកើតធម្មសង្វេគថា ពួកក្មេងទាំងនេះគិតនឹងធ្វើសេចក្តីសុខឱ្យខ្លួន ទើបវាយពស់នេះ ក្មេងៗទាំងនេះនឹងសោយសេចក្តីទុក្ខក្នុងទីដែលខ្លួនកើតហើយ ឱ!ហ្ន៎ សេចក្តីធ្វាតក្នុងអំពើអាក្រក់ ព្រោះតែអវិជ្ជា ។ ក៏ព្រោះហេតុនោះនុ៎ះឯង ទើបទ្រង់បន្ទឹនូវឧទានដោយធម្ម-សង្វេគ ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា **អថ ខោ ភគវា** ដូច្នេះ ។

អដ្ឋកថាពន្យល់សេចក្តីថា មានមហាបេតលោក គឺលោកជាស្ថានលំនៅដ៏ធំសម្រាប់ពួកប្រេតនៅចំក្រុងរាជគ្រឹះ ស្ទឹងតបោទានេះ មកតាមចន្ទោះនៃមហាលោហកុម្ភីនរកទាំងពីរ ត្រង់មកលើមហាបាតលោកនេះ ព្រោះហេតុដូច្នោះ បានជាមានទឹកក្តៅហូរមក ។

បណ្តាបទទាំងនោះ បទថា **ឯតមត្ថं វិទិត្វា** *សេចក្តីថា អាចារ្យមួយពួកពណ៌នាទុកយ៉ាងនេះថា ព្រះអង្គទ្រង់ជ្រាបសេចក្តីនេះថា ក្មេងទាំងនេះ ធ្វើសេចក្តីទុក្ខឱ្យដល់អ្នកដទៃ ដើម្បីសេចក្តីសុខរបស់ខ្លួន ខ្លួនឯងនឹងមិនបានទទួលសេចក្តីសុខក្នុងលោកខាងមុខ ។ ការដែលជនពួកដទៃអ្នកបដិបត្តិអាក្រក់ស្វែងរកសេចក្តីសុខរមែងប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខក្នុងអនាគត សម្រាប់អ្នកបដិបត្តិល្អ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសុខដោយចំណែកមួយ ព្រោះដូច្នោះ អាចារ្យទាំងឡាយ ទើបពោលថា ព្រះសាស្តាទ្រង់បន្ទឹនូវឧទានសូម្បីនេះ ដោយអំណាចសោមនស្សថា អ្នកដែលរួចផុតចាកពីការបៀតបៀនអ្នកដទៃ ជាអ្នកមានចំណែកនៃសេចក្តីសុខដោយពិតតែម្យ៉ាង ឈ្មោះថា ជាអ្នកធ្វើតាមឱវាទរបស់តថាគត ។ ចំណែកអាចារ្យមួយពួកទៀតពោលថា ព្រះអង្គទ្រង់ជ្រាបការបៀតបៀនអ្នកដទៃ ដែលពួកក្មេងទាំងនោះឱ្យប្រព្រឹត្តទៅយ៉ាងនេះ ដោយទោសដោយប្រការទាំងពួង ទើបទ្រង់បន្ទឹនូវឧទាននេះដែលប្រកាសទោស និងអានិសង្សតាមលំដាប់របស់ការបៀតបៀនអ្នកដទៃនិងការអនុគ្រោះអ្នកដទៃ ។*

បណ្តាបទទាំងនោះ បទថា **សុខកាមានិ** *បានដល់ ជនអ្នកជាប់នៅក្នុងសេចក្តីសុខ ព្រោះប្រាថ្នាសេចក្តីសុខដើម្បីខ្លួនដោយចំណែកតែមួយប៉ុណ្ណោះ ។ បទថា* **ภูตานิ** *ប្រែថា សត្វអ្នកមានប្រាណទាំងឡាយ ។ បទថា* **ឌណ្ឌេន** *ក្នុងពាក្យថា* **យោ ឌណ្ឌេន វិហឹសតិ** *នេះ ត្រឹមតែជាទេសនា អធិប្បាយថា ដោយកំណាត់ឈើ ឬដោយគ្រឿងប្រហារផ្សេងៗ មានដុំដី សស្ត្រា និងការប្រហារដោយដៃជាដើម ។ ម្យ៉ាងទៀត បទថា* **ឌណ្ឌេន** *បានដល់ ដោយការដាក់ទោស ។ ពាក្យនេះមានអធិប្បាយដូច្នេះ បុគ្គលណាបៀតបៀនសត្វទាំង*

ពួងជាអ្នកប្រាថ្នាសេចក្តីសុខធ្វើឱ្យលំបាក ឱ្យបានទទួលសេចក្តីទុក្ខដោយអាជ្ញាយ៉ាងណាមួយ បណ្តាអាជ្ញាទាំងនេះ គឺអាជ្ញាផ្លូវវាចា ដូចជាជេរដោយជាតិជាដើម អាជ្ញាផ្លូវកាយ ដូចជាវាត់ វាយ កាត់ជាដើម ដោយដៃ ញញ្ជរ និងសស្ត្រាជាដើម ឬអាជ្ញាផ្លូវទ្រព្យដូចជាពិន័យលើមួយរយ មួយពាន់ ។ កន្ទុះគាថាថា **អត្តនោ សុខមេសានោ** **បេច្ច** **សោ ន** **លភតិ** **សុខំ** សេចក្តីថា បុគ្គលនោះកាលស្វែងរក ស្រាវជ្រាវ ប្រាថ្នាសេចក្តីសុខដើម្បីខ្លួន លុះលះលោកនេះទៅហើយ រមែងមិនបានទទួលសេចក្តីសុខទាំង ៣ ប្រការ គឺមនុស្សសុខ ទិព្ធ-សុខ និងនិព្វានសុខ ក្នុងលោកខាងមុខដោយពិត រមែងបានទទួលនូវសេចក្តីទុក្ខដោយអាជ្ញានោះតែម្យ៉ាង ។

បាទគាថាថា **បេច្ច** **សោ** **លភតេ** **សុខំ** សេចក្តីថា បុគ្គលណា បរិបូរដោយខន្តិ មេត្តា និងសេចក្តីអាណិត គិតថា យើងប្រាថ្នាសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខយ៉ាងណា សូម្បីសត្វទាំងពួងក៏ដូច្នោះ ទើបតាំងនៅក្នុងសម្បត្តិវិតិជាដើម មិនបៀតបៀន មិនធ្វើសត្វទាំងពួងឱ្យលំបាកដោយអាជ្ញាយ៉ាងណាមួយ តាមន័យដែលពោលហើយ បុគ្គលនោះ បើកើតជាមនុស្សរមែងបានសេចក្តីសុខរបស់មនុស្ស បើកើតទេវតារមែងបានសេចក្តីសុខជាទិព្ធ កាលកន្ទងសុខទាំងពីរនោះទៅ រមែងបានទទួលសេចក្តីសុខក្នុងព្រះនិព្វាន ។ ក៏ក្នុងទីនេះដើម្បីនឹងសម្តែងថា ព្រោះបុគ្គលដូច្នោះ បានអប់រំទុកយ៉ាងពិតប្រាកដ សេចក្តីសុខនោះដូចជាកើតឡើងចំពោះមុខ (ជាបច្ចុប្បន្ន) លោកទើបពោលថា **លភ-តេ** ដូច្នេះ ។ សូម្បីក្នុងគាថាដើមក៏ន័យនេះដូចគ្នា ។

ឥតិយសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៣

សម្រាប់ជាធម្មទាន

៤. សក្ការសុត្តវណ្ណនា

អដ្ឋកថាសក្ការសូត្រទី ៤

សក្ការសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **តេន ខោ បន សមយេន ភគវា សក្ក្ការោ ហោតិ** *សេចក្ដីថា ព្រះដ៏មានព្រះភាគជាអ្នកដែលទេវតា និងមនុស្សបូជាដោយគ្រឿងសក្ការៈជាដើមដែលចម្រើនក្រៃលែងឡើង ដែលជាផលនៃបុញ្ញសម្ភារ និងគុណវិសេសដែលព្រះអង្គបំពេញមក ២ អសង្ខ្យេយ្យ និង ១ សែនកប្ប បីដូចជាកើតសេចក្ដីឧស្សាហ៍ឡើងថា តទៅខាងមុខ យើងមិនមានឱកាស ។ មែនពិត បារមីទាំងពួងហាក់ដូចជាប្រជុំគ្នាថា យើងទាំងឡាយនឹងឱ្យផលក្នុងអត្តភាពតែមួយ ទើបញ្ចុំងសក្ការៈប្រៀបដូចជាអន្ទង់ទឹកធំឱ្យកើតឡើងដល់ព្រះដ៏មានព្រះភាគ ដូចពពកធំជាគ្ងៗ តាំងឡើងគ្រប់ទិសធ្វើឱ្យកើតអន្ទង់ទឹកធំដូច្នោះ ។ បន្ទាប់ពីនោះ ក្សត្រនិងព្រាហ្មណ៍ជាដើមផ្សេងៗ មានបាយ ទឹក សំពត់ យាន ផ្កាឈើ គ្រឿងក្រអូបនិងគ្រឿងលាបជាដើមក្នុងដៃហើយមកស្វែងរកព្រះដ៏មានព្រះភាគថា ព្រះពុទ្ធព្រះអង្គគង់នៅទីណា ព្រះដ៏មានព្រះភាគព្រះអង្គគង់នៅទីណា ព្រះអ្នកជាទេព-នៃទេវព្រះអង្គគង់នៅទីណា ព្រះនរាសភៈព្រះអង្គគង់នៅទីណា ព្រះអង្គដូចជារាជសីហ៍ក្នុងពួកជនគង់នៅទីណា ទើបយករនេះមួយរយផ្ទុកដោយបច្ច័យទាំងឡាយកាលមិនទាន់បានឱកាស ក៏ចងរនេះនិងរនេះ សូម្បីក្នុងទីប្រមាណមួយគាវុតដោយជុំវិញសម្រាកខ្លះ និងទៅជាប់គ្នាខ្លះ ដូចអន្ទកព្រាហ្មណ៍ និងវិន្ទព្រាហ្មណ៍ជាដើម ។ ពាក្យទាំងអស់នោះ គប្បីជ្រាបដោយន័យដែលមកក្នុងខន្ធកៈ[1] និងក្នុងសូត្រនោះៗ ។ កើតដល់ភិក្ខុសង្ឆដូចកើតដល់ព្រះដ៏មានព្រះភាគ ។*

១-សេចក្ដីពិស្តារមានមកក្នុងវិនយបិដក មហាវគ្គ លេខ ៧ ទំព័រ ២៨២ ត្រង់ភេសជ្ជក្ខន្ធកៈ ។

សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា "ម្នាលចុន្ទ: ឥឡូវនេះ ទោះជាសង្ឆ ក្តី គណ:ក្តី របស់តថាគតកើតឡើង ក្នុងលោកហើយ ។ ម្នាលចុន្ទ តថាគតជ្រើស-រើសមិនឃើញសង្ឆដទៃសូម្បីមួយពួក ដែលបានដល់នូវលាភដ៏ប្រសើរ និងយស ដ៏ប្រសើរយ៉ាងនេះ ឱ្យដូចជាកិក្ខុសង្ឆ (ក្នុងសាសនានេះ) ឡើយ[១]" ។ លាភ សក្ការ:នេះនោះ កើតដល់ព្រះដ៏មានព្រះភាគ និងព្រះកិក្ខុសង្ឆរកប្រមាណមិន បាន ដូចផ្ទៃវទឹករបស់ទន្ទេ្ធ ២ មានខ្សែទឹកធំរួមតែមួយ ។ ព្រោះហេតុនោះ លោកទើបពោលថា ក៏សម័យនោះឯង ព្រះមានព្រះភាគ គេធ្វើសក្ការ: គោរព ពាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសន: និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារជាប្រក្រតី ។ សូម្បីកិក្ខុសង្ឆ ក៏គេធ្វើសក្ការ: គោរព ពាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសន: និងគិលានប្បច្ចយភេសជ្ជបរិក្ខារដែរ ។

ចំណែកតិរ្ថិយទាំងឡាយ នរណាៗ មិនបូជា មិនគោរព ព្រោះជាអ្នក មិនបានធ្វើបុណ្យទុកក្នុងកាលមុន និងជាអ្នកបដិបត្តិខុស ពោលដោយវិសេស ក្នុងពុទ្ធុប្បាទនេះ ជាអ្នកមានសេចក្តីល្អ វិបត្តិ អស់រស្មី អស់តេជ: សាបសូន្យ លាភសក្ការ:ដូចអំពិលអំពែកក្នុងពេលព្រះអាទិត្យរះ ។ តិរ្ថិយទាំងនោះអត់ទ្រាំ លាភសក្ការ:ដូច្នោះរបស់ព្រះដ៏មានព្រះភាគ និងកិក្ខុសង្ឆមិនបានត្រូវសេចក្តី ច្រណែនគ្របសង្កត់ ទើបច្រណែនថា យើងនឹងជេរប្រទេចព្រះពុទ្ធ និងកិក្ខុសង្ឆ ទាំងនេះ ដោយផរុសវាចាយ៉ាងនេះ ហើយដេញឱ្យគេចជៀសទៅ ធ្វើការ ច្រណែនជាសត្រូវ ជេរប្រទេចកិក្ខុទាំងឡាយក្នុងទីនោះៗហើយត្រាច់ទៅ ។

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៨ ទំព័រ ២៥៦ ។

ព្រោះហេតុនោះ លោកទើបពោលថា ចំណែកពួកបរិព្វាជក អន្យតិរ្ថិយ គេមិនធ្វើ សក្ការ: មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង មិនបានចីវរ បិណ្ឌបាត សេនាសន: និងគិលានប្បច្ចយភេសជ្ជបរិក្ខារជាប្រក្រតីឡើយ ។ គ្រានោះឯង ពួកបរិព្វាជក អន្យតិរ្ថិយ កាលធន់ទ្រាំនឹងសក្ការ: ចំពោះព្រះមានព្រះភាគ និង ភិក្ខុសង្ឆមិនបាន លុះឃើញពួកភិក្ខុក្នុងស្រុកក្តី ក្នុងព្រៃក្តី ក៏ដេរប្រទេច ខឹងចាក់ រុកដោយសំដីទ្រគោះ ជារបស់អសប្បុរស ។

បណ្តាបទទាំងនោះ បទថា **អសញ្ញាហិ** សេចក្តីថា ដោយផរុសវាចា ជាពាក្យមិនសមគួរក្នុងសភា គឺមិនគួរពោលក្នុងទីប្រជុំនៃជំនុំសាធុជន អធិប្បាយ ថា ដោយវាចាអាក្រក់ ។ បទថា **ផរុសាហិ** បានដល់ ដោយវាចាគ្រោតគ្រាត ជា វាចាកាត់ចេញនូវសេចក្តីស្រឡាញ់ ។ បទថា **អកោសន្តិ** បានដល់ ដេរដោយ អកោសវត្ថុមានជាតិជាដើម ។ បទថា **បរិភាសន្តិ** បានដល់ គំរាមកំហែងឱ្យ កើតសេចក្តីខ្លាច ដោយការឈ្លោះ ។ បទថា **ភេសេន្តិ** សេចក្តីថា ការខឹងក្រោធ មានចំពោះបុគ្គលដទៃយ៉ាងណា បុគ្គលនោះក៏ញ្ជាំងការខឹងក្រោធឱ្យកើតឡើង ដោយអំណាចនៃការដេរស្តីក៏យ៉ាងនោះដែរ ។ បទថា **វិហេសេន្តិ** សេចក្តីថា រមែងបៀតបៀន គឺធ្វើសេចក្តីមិនសប្បាយចិត្តដោយអាការផ្សេងៗ ។ សួរថា ព្រោះហេតុអ្វី តិរ្ថិយទាំងនេះ ទើបនាំគ្នាធ្វើការដេរជាដើម ឱ្យកើតក្នុងព្រះដ៏-មានព្រះភាគ និងភិក្ខុសង្ឆអ្នកជាទីតាំងនៃសេចក្តីជ្រះថ្លាដោយជុំវិញ ។ ឆ្លើយ ថា តិរ្ថិយទាំងនោះ ជាអ្នកមានចិត្តប្រទូស្តហើយ ព្រោះខ្ជូនសាបសូន្យលាភ-សក្ការ: ហេតុតែព្រះដ៏មានព្រះភាគឧប្បត្តិឡើង ទើបណាត់នឹងនាងសុន្ទរិកា-បរិព្វាជិកា ឱ្យនាងប្រកាសទោសរបស់ព្រះសាស្តា និងភិក្ខុទាំងឡាយហើយ

ទើបធ្វើការជេរជាដើម ដូចអ្នកជីកដីផ្ទាតដួលទៅ ឬក៏ដូចបុគ្គលតិះដៀលកែវពិទូរ្យដែលមិន គួរតិះដៀលដូច្នោះ ។ ក៏រឿងនៃនាងសុន្ទរិកាបរិព្វាជិកានេះ នោះនឹងមានច្បាស់ ក្នុងបាលីសុន្ទរីសូត្រខាងមុខនុ៎ះឯង ។ ព្រោះហេតុនោះ ពាក្យដែលគួរពោលក្នុងទីនេះ នឹងពណ៌នាក្នុងសុន្ទរីសូត្រនោះនុ៎ះឯង ។ ភិក្ខុទាំងឡាយ ចូលទៅគាល់ព្រះដ៏មានព្រះភាគហើយក្រាបទូលរឿងនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រានោះឯងភិក្ខុជាច្រើនចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ។ ល ។ ហៀតហៀន ។ ពាក្យនោះ មានអត្ថដូចពោលហើយនុ៎ះឯង ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់ការបដិបត្តិខុសនេះរបស់ពួកតិរ្ថិយអ្នកត្រូវសេចក្ដីច្រណែកគ្របសង្កត់ ។ បទថា **ឥមំ ឧទានំ** សេចក្ដីថា ទ្រង់បន្ទឹនូវឧទាននេះ ដែលសម្ដែងនូវអានុភាពនៃភាពរឹងមាំខុសដែលពួកតិរ្ថិយទាំងនោះធ្វើ និងក្នុងឧបការៈដែលជនពួកដទៃ អ្នកមានចិត្តជ្រះថ្លាហើយធ្វើ ។

បណ្ដាបទទាំងនោះ បទថា **កាមេ អរញ្ញេ សុខទុក្ខជុដ្ឋោ** សេចក្ដីថា អ្នកមានសុខ និងទុក្ខពាល់ត្រូវហើយ គឺសោយសុខ និងទុក្ខក្នុងទីណានីមួយ មិនថាស្រុក ឬព្រៃ ឬមានព្រមដោយហេតុនៃសុខ និងទុក្ខទាំងនោះ ។ បទថា **ណេវត្តតោ ណោ បរតោ ឧហោ ច** សេចក្ដីថា អ្នកទាំងឡាយចូរកំណត់ទុកនូវសុខ និងទុក្ខនោះថា មិនមែនជារបស់ខ្លួន ទាំងមិនមែនជារបស់អ្នកដទៃថា អញបានទទួលសុខ បានទទួលទុក្ខ សុខរបស់អញ ទុក្ខរបស់អញ និងថាសុខទុក្ខនេះ

អ្នកដទៃឱ្យកើតឡើងដល់អញ ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះក្នុងខន្ធបញ្ចក:នេះ មិនមានវត្ថុអ្វីៗ ដែលគួរនឹងឃើញថាជាអញ ថាជារបស់អញ ថាជាអ្នកដទៃ ឬថាជារបស់អ្នកដទៃឡើយ តែចំពោះសង្ខារតែម្យ៉ាងប៉ុណ្ណោះ កើតឡើងតាមបច្ច័យ ហើយបែកទៅ គ្រប់ៗ ខណៈ ។ ក៏ក្នុងទីនេះ ស័ព្ទថា សុខ និងទុក្ខជាកំពូលទេសនា ។ គប្បីជ្រាបអត្ថនៃលោកធម៌សូម្បីទាំងអស់ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ប្រកាសសុញ្ញត:ដែលមានចំណាង ៤ គឺសេចក្តីថា **ជាហំ ក្ខ្ជ**ិ *អាត្មាអញមិនបានឃើញ (នូវខ្លួន) ក្នុងទីបន្តិចបន្តួច ១ សេចក្តីថា* **ក**ស្ច**ិ ក**ិ**ញ្ចនត**ស្មឹ *មិនបានឃើញ (នូវខ្លួន) ដែលគួរបង្ហាន់ទៅ របស់ក្ងស់ របស់បុគ្គលនីមួយទេ ១ សេចក្តីថា* **ន ច មម ក្ខ្ជ**ិ *មួយទៀត មិនបានឃើញ (នូវខ្លួន) របស់បុគ្គលដទៃក្នុងទីនីមួយ ១ សេចក្តីថា* **ក**ត្ត**ិ ក**ិ**ញ្ចនត**ត្ថ*ិ ឯកង្ងស់របស់អាត្មាអញមិនមានឡើយ ១ ឥឡូវនេះ ព្រះអង្គទ្រង់សម្តែងហេតុនៃសេចក្តីមិនតាំងមាំពីរបស់ខ្លួន និងពីរបស់អ្នកដទៃនោះ ដោយបទទាំងឡាយនេះថា* **ផ**ុ**ស**ន្ត**ិ ផ**ស្ស **ឧ**ប**ធ**ឹ **ប**ដ**ិ**ច្ច ។ *សេចក្តីថា ដែលឈ្មោះថា ផស្ស:ជាការដឹងនូវសុខ និងទុក្ខនេះ អាស្រ័យឧបធិ ពោលគឺ ខន្ធ-បញ្ចក:រមែងពាល់ត្រូវនូវអារម្មណ៍ដែលជារបស់ខ្លួន ក្នុងកាលឧបធិនោះមាន គឺប្រព្រឹត្តទៅក្នុងឧបធិនោះឯង ។ មែនពិត អទុក្ខមសុខវេទនាសង្ត្រោះចូលក្នុងសុខដូចគ្នា ព្រោះមានសការ:ស្ងប់ ។ ព្រោះដូច្នោះ លោកទើបពណ៌នាអត្ថនេះ ដោយផស្ស: ២ យ៉ាងនោះឯង ។*

ក៏ដើម្បីសម្តែងប្រការដែលផស្ស:ទាំងនោះមិនពាល់ត្រូវ លោកទើបពោលថា **ន**ិ**រ**ូ**ប**ធ**ឹ ក**ោ**ន ផ**ុ**ស**េ**យ**្**យ**ុ ផ**ស្ស *ផស្ស:គប្បីពាល់ត្រូវធម៌ដែលមិនមាន*

ឧបធិព្រោះហេតុណា ។ មែនពិត កាលឧបធិ គឺខន្ធមិនមានដោយប្រការទាំងពួង ព្រោះហេតុណាហ្ន៎ ផស្ស:ទាំងនោះទើបគប្បីពាល់ត្រូវ ព្រោះថា ហេតុនោះមិនមាន ។ ប្រសិនបើលោកទាំងឡាយមិនប្រាថ្នាសុខ និងទុក្ខដែលកើតព្រោះការជេរជាដើម ពួកលោកគប្បីធ្វើសេចក្តីព្យាយាមក្នុងសេចក្តីមិនមានឧបធិ ដោយប្រការទាំងពួងនោះឯង ។ គាថាបានចប់ស្រេចដោយអនុបាទិសេសនិព្វានធាតុ ។ ព្រះដ៏មានព្រះភាគសម្តែងវដ្ត: និងវិវដ្ត:ដោយឧទាននេះ ដោយប្រការដូច្នេះ ។

ចតុត្ថសុត្តវណ្ណា ជិដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៤

៥. ឧបាសកសុត្តវណ្ណនា

អដ្ឋកថាឧបាសកសូត្រទី ៥

ឧបាសកសូត្រទី ៥ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ឥច្ឆានង្គលកោ** *សេចក្តីថា ស្រុកព្រាហ្មណ៍មួយក្នុងដែនកោសល ដែលមានឈ្មោះថា* ***ឥច្ឆានង្គលៈ*** *។ ឈ្មោះថា* ***ឥច្ឆានង្គលៈ*** *ព្រោះអាស្រ័យនៅក្នុងស្រុកព្រាហ្មណ៍នោះ ឬព្រោះកើត គឺមានក្នុងស្រុកព្រាហ្មណ៍នោះ ។ បទថា* **ឧបាសកោ** *សេចក្តីថា ឈ្មោះថា* ***ឧបាសក*** *ជាអ្នកប្រកាសការៈ ដែលខ្លួនជាឧបាសកក្នុងសំណាក់របស់ព្រះដ៏មានព្រះភាគ ដោយត្រៃសរណ-គមន៍ ជាអ្នកកាន់សិក្ខាបទ ៥ ជាពុទ្ធមាមកៈ ធម្មមាមកៈ សង្ឆមាមកៈ ។ បទថា* **កេនចិទេវ ការណេន** *សេចក្តីថា ដោយការណ៍យកិច្ចយ៉ាងណាមួយ មានការជម្រះឱ្យហ្មត់ចត់ យ៉ាងក្រៃលែងជាដើម ដែលអ្នកទ្រទ្រង់ទុកគប្បីធ្វើ ។ បទថា* **តីណិ** *ប្រែថា ឱ្យសម្រេច ។ បានឮមកថា ឧបាសកនេះ ធ្លាប់ចូលទៅគាល់អង្គុយជិតព្រះដ៏មានព្រះភាគជាប់ជានិច្ច ។ តែគាត់មិនបានគាល់ព្រះសាស្តា ព្រោះមានការណ៍យកិច្ចច្រើនអស់ ២-៣ ថ្ងៃ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ថា* **ចិរស្សុ ខោ ត្វំ ឧបាសក ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ** *ម្នាលឧបាសក ខ្លួនអ្នកធ្វើហេតុជាទំនង ដើម្បីមកទីនេះជាយូរអង្វែងហើយ ។*

បណ្តាបទទាំងនោះ បទថា **ចិរស្សុ** *ប្រែថា ដោយកាលយូរ ។ បទថា* **បរិយាយំ** *ប្រែថា គ្រាមួយ ។ ស័ព្ទថា* **យទិទំ** *ជានិបាត សេចក្តីថា* **យោ អយំ** *។ លោកពោលពាក្យនេះមានអធិប្បាយទុកថា លោកធ្វើវារៈដែលធ្វើក្នុងថ្ងៃនេះ ដោយកាលយូរ គឺធ្វើឱ្យយឺតយូរដោយការមកក្នុងទីនេះ គឺក្នុងសំណាក់របស់*

តថាគត ។ បទថា **ចិរេ**ន**ដិ**ត**ោ**ហ**ំ** កាត់បទជា **ចិ**ន**ដ**ិ**ត**ោ **អ**ហ**ំ** ភ្ជាប់សេចក្តីថា ខ្ញុំព្រះអង្គប្រាថ្នានឹងចូលគាល់ជាយូរមកហើយ ។ បទថា **ត**ោ**ហ**ិ**ច** ត**ោ**ហ**ិ**ច ប្រែថា កិច្ចតូចធំ ។ ម្យ៉ាងទៀត បទថា **ត**ោ**ហ**ិ**ច** បានដល់ កិច្ចណាមួយ ។ ក្នុងសេចក្តីនោះ ទ្រង់សំដែងដល់សេចក្តីអើពើ ។ មែនពិត កាលឧបាសកនោះជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះសាស្តា មិនបានមានសេចក្តីអើពើក្នុងរឿងដទៃដូចក្នុងការគាល់ និងការស្តាប់ធម៌របស់ព្រះសាស្តា ។ បទថា **ក**ិ**ច**្**ច**ក**ា**រ**ណ**ីយ**ោ**ហ**ិ** សេចក្តីថា ការងារត្រូវធ្វើពិតប្រាកដ ក្នុងការគាល់ជាដើមនេះចាត់ជាកិច្ច ក្រៅពីនេះចាត់ជាករណីយ: ។ ម្យ៉ាងទៀត ការងារដែលត្រូវធ្វើមុនចាត់ជាកិច្ច ដែលត្រូវធ្វើខាងក្រោយចាត់ជាករណីយ: ។ ម្យ៉ាងទៀត ការងារបន្តិចបន្តួចចាត់ជាកិច្ច ការងារធំចាត់ជាករណីយ: ។ បទថា **ញ**ា**ណ**ោ ប្រែថា ខ្ជល់ខ្ជាយ ។ បទថា **ឯ**ត**ា**ហ**ំ** សេចក្តីថា ខ្ញុំព្រះអង្គមិនអាចនឹងចូលគាល់ដោយអាការយ៉ាងនេះ គឺដោយប្រការនេះ អធិប្បាយថា មិនអាចនឹងចូលគាល់ដោយមិនគោរពជាដើម ។

បទថា **ឯ**ត**ម**ត្ថ**ំ ว**ิ**ទิ**ត្**ว**ា សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់សេចក្តីនេះថា អន្តរាយនៃកុសលរមែងមាន ព្រោះពួកសត្វទាំងឡាយមានសេចក្តីខ្ជល់ខ្ជាយក្នុងនាទី ដោយមានភាពជាអ្នកកង្វល់ក្នុងកាលព្រះពុទ្ធឧប្បត្តិ ឡើងនិងក្នុងកាលបានអត្តភាពជាមនុស្សដែលបានដោយលំបាក មិនមានអន្ត-រាយនៃកុសលចំពោះការមិនមានសេចក្តីកង្វល់ទេ ។ បទថា **ឥ**ម**ំ ឧ**ទ**ា**ន**ំ** សេចក្តីថា ទ្រង់បន្ទឹទ្ធរ**ឧ**ទ**ា**ន**ន**េ**ះ**ដ**ែ**ល**ស**ម្ដ**ែ**ងដ**ល**ស**ម**ា**ន**ន**េ**ះ**ន**េ**ះ**ឯ**ង ។

បណ្តាបទទាំងនោះ បទថា **ស**ុ**ទ**ុ**ំ ว**ត **ต**ส**ฺ**ส **ห**ោ**ต**ิ **ก**ิ**ญ**ฺ**จ** សេចក្តី

ថា ក្នុងវត្ថុមានរូបជាដើម សូម្បីវត្ថុអ្វីៗ ត្រឹមតែម្យ៉ាង រមែងមិនមាន គឺមិនមាន បានដល់ មិនប្រាកដដល់បុគ្គលណា ដោយការៈដែលកំណត់ដោយតណ្ហាថា នេះរបស់អញ បុគ្គលនោះរមែងមានសេចក្ដីសុខពិត អធិប្បាយថា គឺសេចក្ដីសុខដ៏ក្រៃលែង បាលីថា **ន ហោតិ** *ដូច្នេះក៏មាន ។ គប្បីជ្រាបសេចក្ដីនោះ ដោយសេចក្ដីជាអតីតកាល ។ តែអាចារ្យមួយពួកពណ៌នាសេចក្ដីនៃបទថា* **ន ហោតិ កិញ្ចិ** *ទុកដូច្នេះថា កិលេសជាគ្រឿងកង្វល់មានរាគៈជាដើម រមែងមិនមានដល់អ្នកណា ។ ពាក្យនោះមិនល្អព្រោះមកក្នុងទេសនាដោយអំណាចនៃការកំណត់ធម៌ ។ ដោយពាក្យថា* **ករណីកិញ្ចនំ** *គប្បីជាកន្ទែងដែលលោកពោលតែពាក្យដែលសមរម្យប៉ុណ្ណោះ ក្នុងកាលរួបរួមនូវធម៌គួរដែលគួរកាន់យក ។ ម្យ៉ាងទៀត អធិប្បាយថា បុគ្គលណា មិនមានកិលេសជាគ្រឿងកង្វល់ គឺជាគ្រឿងណានីមួយ សូម្បីបន្ដិចបន្ដួច ព្រោះមិនមានកិលេសជាគ្រឿងកង្វល់មានរាគៈជាដើមនុ៎ះឯង ប្រការនោះរបស់បុគ្គលនោះដែលមិនមានកិលេសជាគ្រឿងកង្វល់ ឈ្មោះថា ជាសេចក្ដីសុខពិត គឺជាសេចក្ដីសុខដ៏ក្រៃលែង ព្រោះជាបច្ច័យនៃសេចក្ដីសុខ ។ សួរថា កិលេសជាគ្រឿងកង្វល់មិនមានដល់អ្នកណាដូច្នេះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា* **សង្ខ្ជាតធម្មស្ស ពហុស្សុតស្ស** *ដូច្នេះ ។ បុគ្គលណាមានធម៌ដែលត្រូវប្រាប់ហើយ គឺមានកិច្ចដែលត្រូវធ្វើហើយ ព្រោះសម្រេចកិច្ច ១៦ យ៉ាង ពោលគឺ មគ្គទាំង ៤ ឈ្មោះថាជាពហុស្សុត ព្រោះដឹងពហុសច្ចៈចាស់លាស់ពីធម៌នោះឯង នៃបុគ្គលនោះ ។*

ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ដើម្បីនឹងសម្ដែងអានិសង្សក្នុងការមិនមានកិលេសជាគ្រឿងកង្វល់ ហើយទើបសម្ដែងទោសក្នុងការមាន

កិលេសជាគ្រឿងកង្វល់ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **សកិញ្ចនំ បស្ស** *ដូច្នេះ ។ ពាក្យនេះមានសេចក្តីអធិប្បាយដូចតទៅនេះ ព្រះសាស្តាទ្រង់ដល់ធម្មសង្វេគហើយ ទើបត្រាស់ចំពោះចិត្តរបស់ព្រះអង្គថា លោកចូរមើលបុគ្គលដែលឈ្មោះថា មានកិលេសជាគ្រឿងកង្វល់ ព្រោះមានកិលេសជាគ្រឿងកង្វល់មានរាគៈជាដើម និងកិលេសជាគ្រឿងកង្វល់ គឺអាមិសដ៏ក្តៅក្រហាយ គឺដល់សេចក្តីចង្អៀតចង្អល់ដោយកិច្ចតូចកិច្ចធំ ព្រោះហេតុនៃការស្វែងរកកាមដែលមិនទាន់បាន និងរក្សាកាមដែលបានហើយ ព្រោះជាអ្នកមានកិលេសជាគ្រឿងកង្វល់ទុ៎ះឯង និងដោយអំណាចការប្រកាន់ថាអញ ថារបស់អញ ដូច្នេះ ។*

បទថា **ជនো ជនម្ហិ** **បដិពទ្ធរូបោ** *សេចក្តីថា ខ្លួនឯងជាជនដទៃ ជាអ្នកមានសការៈជាប់នឹងជនដទៃ ដោយអំណាចតណ្ហាថាអញ របស់អញ នេះជារបស់អញ ទើបក្តៅក្រហាយ គឺដល់សេចក្តីចង្អៀតចង្អល់ ។ បាលីថា* **បដិពទ្ធ-ចិត្តោ** *ដូច្នេះក្តី ។ ក៏សេចក្តីនេះគប្បីសម្តែងដោយសុត្តបទមានជាអាទិ៍ថា*

បុត្តា មត្ថិ ជនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ ជត្ថិ កុតោ បុត្តា កុតោ ជនំ

ជនពាលតែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថាមានអំពីណាបាន[១] ។

បញ្ចមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៥

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៣៤ ។

៦. កញ្ចិនីសុត្តវណ្ណនា

អដ្ឋកថាគញ្ចិនីសូត្រ

គញ្ចិនីសូត្រទី ៦ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **អញ្ញតរស្ស បរិព្ភាជកស្ស** *បានដល់ របស់កុដុម្ពិក៏បរិព្ភាជកមួយនាក់ ។ បទថា* **ឧមាវ** *ប្រែថា ជាក្រមុំ ។ បទថា* **មាណវិកា** *ជារៀបារ ហៅធីតារបស់ព្រាហ្មណ៍ ។ បទថា* **ឧជាបតី** *ប្រែថា ភរិយា ។ បទថា* **គញ្ចិនី** *ប្រែថា ស្ត្រីអ្នកមានគក់ ។ បទថា* **ឧបវិជញ្ញា** *ភ្ជាប់សេចក្តីថា ជាអ្នកមានវេលានៃការប្រសូតថា ថ្ងៃនេះ ឬថ្ងៃស្អែកនេះ ។ បានឮថា បរិព្ភាជកនោះជាតិជាព្រាហ្មណ៍ មានភរិយាតាំងនៅត្រង់អាស្រម ឈ្មោះ* **ភ្ទបត្ត:** *ព្រោះហេតុនោះ ព្រាហ្មណ៍នោះត្រូវបានគេហៅថា បរិព្ភាជក អ្នកមានភរិយា ។ ចំណែកភរិយារបស់គេហៅថា ព្រាហ្មណ៍ ព្រោះមានជាតិជាព្រាហ្មណ៍ ។ បទថា* **តេលំ** *បានដល់ ប្រេងល្ង ។ ក៏ក្នុងសេចក្តីនេះថា ដោយវត្ថុមានប្រេងជាប្រធាន នាងទើបបង្គាប់ថា អ្នកជាម្ចាស់ចូរនាំយកវត្ថុដែលស្ត្រីអ្នកនឹងប្រសូតត្រូវការ ដើម្បីបំបាត់ទុក្ខក្នុងវេលាប្រសូតទាំងអស់ មានទឹកដោះថ្លា និងអំបិលជាដើម ។ បទថា* **យំ មេ វិជាតាយ ករិ-ស្សតិ** *សេចក្តីថា វត្ថុណាមានប្រេងជាដើម នឹងជាឧបការ:ដល់នាងខ្ញុំអ្នកមានគក់នឹងប្រសូត ។ បាលីថា* **បរិព្ភាជិកាយ** *ដូច្នេះក៏បាន ។ បទថា* **កុតោ** *ប្រែថា អំពីទីណា ។ អធិប្បាយថា យើងគប្បីនាំប្រេងជាដើមមកពីទីណា មិនថានាំមកពីត្រកូលញាតិ ត្រកូលមិត្ត ទីនោះមិនមានដល់នាងខ្ញុំឡើយ ។ បទថា* **តេលំ អាហរាមិ** *លោកពោលឱ្យជាបច្ចុប្បន្នកាល ព្រោះជិតកាលដែលជាបច្ចុប្បន្ន សំដៅសេចក្តីថា នឹងនាំប្រេងមក ។* **ភ**-*ស័ព្ទក្នុងបទថា* **សមណាស្ស ភ** *ក្តី* **ព្រាហ្មណាស្ស ភ** *ក្តី* **សប្ជិស្ស ភ** *ក្តី* **តេលស្ស ភ** *ក្តី ជាសមុច្ចយត្ថ: ដូចក្នុងប្រយោគជាមានជា*

អាទ៍ថា **អត្ថិតោ ឯ ឧទកតោ ឯ មិថុភេទា ឯ** ។ បទថា **សម្ផិស្ស ឯ តេលស្ស ឯ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថបឋមាវិភត្តិ ។ អធិប្បាយថា ទឹកដោះថ្លានិងប្រេងដែលគេឱ្យផឹកត្រឹមប្រមាណដែលត្រូវការ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា បទថា **សម្ផិស្ស ឯ តេលស្ស ឯ** ជាឆដ្ឋីវិភត្តិប្រើក្នុងអត្ថថា ចំណែកតិចតួចនិងវត្ថុដែលមានចំណែកតិចតួច ពិតយ៉ាងនោះ ចំណែកតិចតួចរបស់ទឹកដោះថ្លា និងប្រេង ក្នុងទីនេះលោកហៅដោយសព្ទត្រឹមតែប្រមាណដែលត្រូវការ ។ បទថា **ឆោ ឌីហារិតំ** សេចក្តីថា គេមិនឱ្យប្រើកាជនៈ ឬដៃនាំចេញទៅខាងក្រៅ ។ បទថា **ឧច្ឆិន្ទិត្វា** បានដល់ ចង្ហោរចេញមកវិញ ភ្ជាប់សេចក្តីថា ដូចម្តេចហ្ន៎ យើងគប្បីចង្ហោរចេញមកវិញ ។ បានឮថា បរិព្វាជកនោះមានការគិតយ៉ាងនេះថា យើងនឹងទៅកាន់ឃ្វាំងរបស់ព្រះរាជា ផឹកប្រេងត្រឹម-ក ហើយមកផ្ទះវិញភ្លាមក៏ចង្ហោរនូវប្រេងដែលខ្លួនបានផឹកក្នុងកាជនៈមួយ ហើយចម្អិនដោយក្ងើង វត្ថុដែលលាយដោយប្រមាត់ និងស្ងួតជាដើម ក្ងើងនឹងនេះ តែយើងនឹងយកតែប្រេងទៅប្រើក្នុងការងាររបស់នាងបរិព្វាជិកានេះ ។

បទថា **ឧជ្ជំ ការតុំ** បានដល់ ដើម្បីនាំឡើងខាងលើដោយការប្រាសអំណាចនៃការចង្ហោរចេញ ។ បទថា **ន បន អឆោ** សេចក្តីថា តែមិនអាចដើម្បីនឹងនាំចេញខាងក្រោមដោយការបន្ទោបង់ ។ មែនពិត បរិព្វាជកនោះផឹកដោយគិតថា នឹងចង្ហោរវត្ថុដែលយើងផឹកចូលទៅច្រើន ចេញតាមមាត់ដោយខ្លួនឯង កាលវត្ថុដែលផឹកចូលទៅមិនចេញមក ព្រោះមិនជាប្រយោជន៍ដល់ក្រពះ មិនដឹង ឬមិនបានវត្ថុដែលគួរនឹងចង្ហោរ និងបន្ទោបង់ចេញបាន ទើបទទួលទុក្ខ-

ដ្ឋនាតែម្យ៉ាង ក៏បម្រះនទៀលទៅមក ។ បទថា **ឧក្ខាហិ** *ប្រែថា មានទុក្ខ ។ បទថា* **តិប្ផាហិ** *បានដល់ ច្រើន ឬខ្លាំងក្លា ។ បទថា* **ខរាហិ** *បានដល់ ខ្លាំងក្លា ។ បទថា* **កដុកាហិ** *បានដល់ ទារុណកម្ម ព្រោះជារបស់មិនគួរប្រាថ្នាយ៉ាងក្រៃលែង ។ បទថា* **អាវដ្ដតិ** *សេចក្ដីថា កាលមិនដេកនៅក្នុងទីតែមួយនាំរាងកាយរបស់ខ្លួនទៅខាងណេះខាងណោះ ឈ្មោះថា វិលទៅ ។ បទថា* **បរិវដ្ដតិ** *សេចក្ដីថា សូម្បីដេកនៅក្នុងទីតែមួយ កាលរលាស់អវយវៈតូចធំទៅជុំវិញ ឈ្មោះថា វិលទៅជុំវិញ ។ ម្យ៉ាងទៀត កាលវិលទៅត្រង់មុខ ឈ្មោះថា វិលទៅ កាលវិលទៅជុំវិញ ឈ្មោះថា វិលទៅជុំវិញ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្ដីថា កាលទ្រង់ជ្រាបដោយប្រការទាំងពួងដល់សេចក្ដីនេះថា ការកើតទុក្ខយ៉ាងនេះ ព្រោះហេតុបរិភោគដោយមិនពិចារណារបស់អ្នកមានកិលេសជាគ្រឿងកង្វល់ មានតែសម្រាប់អ្នកមិនមានកិលេសជាគ្រឿងកង្វល់ទេ រមែងមិនមានទុក្ខនេះ ដោយប្រការទាំងពួង ដូច្នេះហើយទើបទ្រង់បន្ទឹមនេះ ដែលប្រកាសសេចក្ដីនោះ ។*

បណ្ដាបទទាំងនោះ បទថា **សុខិនោ វត** *សេចក្ដីថា សប្បុរសទាំងឡាយមានសេចក្ដីសុខហ្ន៎ ។ សួរថា ក៏សប្បុរសទាំងនោះ គឺបុគ្គលពួកណា? ឆ្លើយថា គឺបុគ្គលណាដែលមិនមានកិលេសជាគ្រឿងកង្វល់ ដែលឈ្មោះថា* **អកិញ្ចនៈ** *ព្រោះមិនមានកិលេសជាគ្រឿងកង្វល់មានរាគៈជាដើម និងកិលេសជាគ្រឿងកង្វល់ក្នុងវត្ថុដែលហួងហែង ព្រះអង្គទើបត្រាស់ថា* **វេទគុនោ ហិ ជនា អកិញ្ចនា** *ពួកជនអ្នកដល់វេទ មិនមានកិលេសជាគ្រឿងកង្វល់ ។ បុគ្គលដែលឈ្មោះថា វេទគូ ព្រោះដល់ គឺសម្រេចវេទ ពោលគឺ អរិយមគ្គញ្ញាណ ឬដល់ គឺសម្រេច*

ព្រះនិព្វានដោយវេទនោះ ។ អរិយជនទាំងនោះ គឺបុគ្គលដែលអស់អាសវៈ ឈ្មោះថា **អកិញ្ចនៈ** ព្រោះកាត់កិលេសជាគ្រឿងកង្វល់មានរាគៈជាដើមបានដាច់ដោយមិនសេសសល់ ដោយអរហត្តមគ្គ ។ ក៏កាលកិលេសជាគ្រឿងកង្វល់ មានរាគៈជាដើមមិនមានកិលេសជាគ្រឿងកង្វល់ក្នុងវត្ថុដែលហួងហែង នឹងមានមកពីទីណា ។

ព្រះដ៏មានព្រះភាគ គ្រាទ្រង់សរសើរបុគ្គលដែលជាព្រះអរហន្ត ដោយបុព្វភាគនៃគាថាយ៉ាងនេះហើយ កាលនឹងទ្រង់តិះដៀលអន្ធបុថុជ្ជន ដោយអបរភាគ[1]នៃគាថា ទើបត្រាស់ពាក្យមានជាអាទិ៍ថា **សកិញ្ចិំ ២ស្ស** ។ ពាក្យនោះមានអត្ថដូចពោលទុកហើយក្នុងសូត្រដំបូងនុ៎ះឯង ដោយគាថាសូម្បីនេះ ព្រះអង្គត្រាស់ទាំងវដ្ដៈ និងវិវដ្ដៈដូចពណ៌នាមកដូច្នេះ ។

ឆដ្ឋសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៦

១-អបរភាគ អ:ប៉:រ:ភាក សំ. ឋា. (ន.) កាលឬសម័យជាចំណេរតទៅខាងមុខ; ចំណេរកាលតមកក្នុងអបរភាគ ។ ០០. អបរសម័យ ។

(វចនានុក្រមខ្មែរ សម្ដេចព្រះសង្ឆរាជ **ជោតញ្ញាណោ** ជួន ណាត)

៧. ឯកបុត្តសុត្តវណ្ណនា

អដ្ឋកថាឯកបុត្តសូត្រ

ឯកបុត្តសូត្រទី ៧ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ឯកបុត្តកោ** *ប្រែថា បុត្រម្នាក់ ក៏បុត្រនោះ ឈ្មោះថា* **ឯកបុត្តក:** *ព្រោះអត្ថថា ដែលគេអនុគ្រោះ ឈ្មោះថា* **ឯយ:** *ព្រោះអត្ថថា ដែលគេស្រឡាញ់ ឈ្មោះថា* **មនាប:** *ព្រោះអត្ថថា ជាទីចម្រើនចិត្ត ។ ម្យ៉ាងទៀត ឈ្មោះថា* **ឯយ:** *ព្រោះអត្ថថា ដល់ការមើលគួរសរសើរ ព្រោះបរិបូរដោយកាពស្អាតនៃរាងកាយ ឈ្មោះថា* **មនាប:** *ព្រោះជាអ្នកមានកល្យាណធម៌ ព្រោះបរិបូរដោយសីល និងអាចារ: ។ ឈ្មោះថា* **កាល:** *ព្រោះធ្វើសត្វឱ្យអស់ទៅ បានដល់* **មរណ:** *។ ឈ្មោះថា* **កាលង្កត:** *ធ្វើ គឺដល់មរណកាលនោះ ។ ម្យ៉ាងទៀត ឈ្មោះថា* **កាលង្កត:** *ព្រោះកាល: គឺមច្ចុធ្វើហើយ គឺវិនាសទៅហើយ បានដល់ ដល់សេចក្ដីមិនឃើញ អធិប្បាយថា ស្ងាប់ ។*

បទថា **សម្ពហុលា ឧបាសកា** *សេចក្ដីថា ឧបាសកអ្នកនៅក្នុងក្រុងសាវត្ថីជាច្រើន ទៅតាមក្រោយឧបាសកអ្នកមានកូនស្ងាប់ ដរាបដល់ព្រៃស្មសានជាទីចោលសាកសព ព្រមដោយសេចក្ដីសោកឱ្យធ្វើឈាបនកិច្ចសាកសព ហើយក៏ត្រឡប់ ចុះទឹកទាំងដែលស្ងៀកដណ្ដប់សំពត់ទុ:ឯង មានសក់ទទឹក ពួតសំពត់មិនទាន់នឹងស្ងួតឡើយ ស្ងៀកមួយផ្ទាំង ដណ្ដប់ធ្ងៀងស្មាម្ខាងមួយផ្ទាំង នាំគ្នាដើរតាមពីក្រោយដោយគំនិតថា យើងនឹងស្ដាប់ធម៌ដែលជាហេតុបន្ទោបង់សេចក្ដីសោកក្នុងសំណាក់ព្រះសាស្ដា ទើបចូលទៅគាល់ព្រះសាស្ដា ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា* **អល្ងកេសា** *មានសក់ទទឹកជោគ ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **អល្ងវត្ថា** *ប្រែថា មានសំពត់ជោគដោយទឹក ។*

បទថា **ឌិវា ឌិវស្ស** ប្រែថា ជាវេលាពេលថ្ងៃ អធិប្បាយថា វេលាថ្ងៃត្រង់ ។ ព្រោះហេតុនោះ ព្រះតថាគតទាំងឡាយ ទ្រង់ជ្រាបហើយត្រាស់សួរក៏មាន ទ្រង់ជ្រាបហើយមិនត្រាស់សួរក៏មាន ។ ព្រះដ៏មានព្រះភាគទ្រង់ដឹងវេលាត្រាស់សួរក៏មាន ទ្រង់ដឹងវេលាមិនត្រាស់សួរក៏មាន ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបតែម្តង កាលនឹងត្រាស់សួរដើម្បីតាំងរឿងឡើង ទើបត្រាស់ពាក្យមានជាអាទិ៍ថា **កិ ន្ុ ខោ តុម្ហេ ឧបាសកា** ។ ព្រះតម្រាស់នោះមានអត្ថន័យដូច្នេះ ថា ម្នាលឧបាសកទាំងឡាយ ក្នុងថ្ងៃដទៃ ពួកអ្នកកាលមកកាន់សំណាក់ របស់តថាគត ស្ងៀកសំពត់ស្ងួត និងស្អាតមកក្នុងវេលាល្ងាច តែថ្ងៃនេះ ជាអ្នកមានសំពត់ទទឹក មានសក់ទទឹកមកក្នុងទីនេះ វេលាថ្ងៃត្រង់ ហេតុនោះដូចម្តេច ។ បទថា **តេន មយំ** សេចក្តីថា ព្រោះហេតុនោះ ខ្ញុំព្រះអង្គទាំងឡាយ មានសភាពយ៉ាងនេះ ព្រោះត្រូវសេចក្តីសោកយ៉ាងខ្លាំងគ្របសង្កត់ ព្រោះសេចក្តីក្តៅក្រហាយចិត្ត ដែលកើតពីការព្រាត់ប្រាសចាកបុត្រ ទើបបានគាល់ព្រះអង្គក្នុងទីនេះ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ជ្រាបដោយប្រការទាំងពួងដល់រឿងនេះថា សភាវធម៌មានសោក ទុក្ខ និងទោមនស្សជាដើម មានវត្ថុជាទីស្រឡាញ់ជាដែនកើត កាលវត្ថុដែលជាទីស្រឡាញ់មិនមាន សេចក្តីសោកជាដើមទាំងនោះ រមែងមិនមានដោយប្រការទាំងពួង ទើបទ្រង់បន្ទឹឧទាននេះដែលប្រកាសសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **បិយរូបស្ឆាទកទ្ធិតា សេ** សេចក្តីថា ជាប់ជំពាក់ គឺមានចិត្តប្រតិព័ទ្ធក្នុងសភាវៈដែលជាទីស្រឡាញ់ មានរូបខន្ធជាដើម ដោយ

សេចក្ដីត្រេកអរក្នុងសុខវេទនា ។ ក៏បទថា **ឥធ** *សំដៅយក* **ឥធ** *ន៏ុះឯង ។ ម្យ៉ាងទៀតស័ព្ទថា* **សេ** *ត្រឹមតែជានិបាត ។ ចក្ខុបសាទជាដើម និងបិយជន មានបុត្រ និងកិរិយាជាដើម ឈ្មោះថា* **បិយរូប** *។ សមដូចពាក្យដែលលោកពោលទុកថា អារម្មណ៍ដូចម្ដេច មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរក្នុងលោក ចក្ខុមានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរក្នុងលោក ។ ល ។ សេចក្ដីប្រាថ្នាក្នុងធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរក្នុងលោក (សេចក្ដីត្រិះរិះនូវរូប) មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរក្នុងលោក[1]។ និងព្រះដ៏មានព្រះភាគសម្ដែងថា*

ខេត្តំ វត្ថុំ ហិរញ្ញញ្ច កវស្ដ្ដ ទាសចោរិសំ
ឋិយោ ពន្ធូ បុថូ កាមេ យោ ឧភេ អនុកិជ្ឈតិ

មួយទៀត ជនណាជាប់ជំពាក់នឹងស្រែ ចម្ការ កន្ទែង ប្រាក់ គោ សេះ នឹងបុរសជាខ្ញុំ ពួកស្ត្រី ពូជពង្ស និងកាមដ៏ច្រើន (ពួកកិលេសយ៉ាងខ្សោយ រមែងគ្របសង្កត់ជននោះ)[2] ។

ព្រោះហេតុនោះ អ្នកជាប់ជំពាក់ អធិប្បាយថា ត្រេកអរក្នុងបិយរូបទាំងនោះ ។ ដើម្បីនឹងធ្វើយពាក្យសួរថា ជនទាំងនោះ គឺពួកណា អ្នកជាប់នៅក្នុងបិយរូប និងសាតរូប ទើបទ្រង់សម្ដែងជនទាំងនោះថា **ទេវកាយា បុថុមានុសា ច** *ពួកទេវតានិងមនុស្សជាច្រើន បានដល់ ពួកទេវតាជាច្រើន មានទេវតាជាន់ចាតុម្មហារាជិកាជាដើម និងមនុស្សជាច្រើនមានអ្នកជម្ពូទ្វីបខាងដើម ។ បទថា*

១-សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស លេខ ៦៧ ទំព័រ ២៦៩ ដល់ ២៧០ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ២៦៥ ។

អយាវិនោ បានដល់ អ្នកមានទុក្ខផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **បរិជុណ្ណា** បាន-ដល់ អ្នកសាបសូន្យពីសម្បត្តិ មានភាពជាកំលោះក្រមុំ និងភាពមិនមានរោគជាដើម ព្រោះសេចក្តីវិបត្តិមានជរា និងរោគជាដើម ។ គប្បីជ្រាបសេចក្តីនោះ តាមដែលបានក្នុងទេវតា និងមនុស្សទាំងឡាយ ។ ម្យ៉ាងទៀត ទេវតាទាំងឡាយ មានព្រមដោយសុខដោយចំណែកតែមួយ មិនមានទុក្ខ ជរា និងរោគក៏ពិតមែន ហើយ ប៉ុន្តែថា សម្បីទេវតាទាំងនោះ ក៏ព្រះដ៏មានព្រះភាគហៅថា អ្នកមានទុក្ខ និងថាអ្នកមានសេចក្តីសាបសូន្យ ព្រោះមានការមិនផុតពីទុក្ខនោះជាសភាវ: ។ ម្យ៉ាងទៀត គប្បីជ្រាបការកើតមានទុក្ខជាដើម សម្បីរបស់ទេវតាទាំងនោះ ដោយអំណាចការកើតឡើងនៃបុព្វនិមិត្ត បដិច្ចុន្នជរា និងរោគផ្លូវចិត្ត ។ បទថា **មច្ចុ-ជ្ជ្ជ រសំ កច្ឆន្តិ** សេចក្តីថា ជនទាំងនោះទៅកាន់អំណាច គឺដែនៃសេចក្តីស្លាប់ ពោលគឺ មច្ចុរាជ ព្រោះមានធាតុ ៣ ជាធំ ជាហេតុឱ្យកើតក្នុងគភ៌រៀយៗ ព្រោះមិនបានលះនូវតណ្ហា ដែលមានបិយវត្ថុជាអារម្មណ៍ ។

ព្រះដ៏មានព្រះភាគ គ្រាទ្រង់សម្តែងវដ្ដ:ដោយហេតុត្រឹមតែប៉ុណ្ណោះហើយ ឥឡូវនេះទើបសម្តែងវិវដ្ដ: ដោយន័យមានជាអាទិ៍ថា (និព្វាន) ដោយន័យមានជាអាទិ៍ថា **យេ វ ឥភ** ដូច្នេះ ។ បណ្ដាបទទាំងនោះ ដោយបទថា **យេ វ ឥភ ច រត្តោ ច អប្ឍមត្តោ** សេចក្តីថា អ្នកមិនប្រមាទយ៉ាងរឹងមាំ រមែងបំពេញអប្ឍមាទបដិបទាទាំងពេលថ្ងៃ និងពេលយប់ ដោយន័យដូចពោលហើយមានជាអាទិ៍ថា ជម្រះចិត្តឱ្យហ្មត់ចត់អំពីធម៌ដែលជាគ្រឿងការពារ ដោយការចង្ក្រម និងការអង្គុយរហូតអស់មួយថ្ងៃ ។ បទថា **ជហន្តិ បិយរូបំ** សេចក្តីថា ឱ្យ

ខ្វល់ខ្វាយកម្មដ្ឋានភាវនា ដែលសម្បយុត្តដោយសច្ចៈ ៤ លះបិយរូប គឺបិយ-វត្ថុមានចក្ខុបសាទជាដើម ដែលកើតអំពីសត្វនិងសង្ខារដែលជាទីស្រឡាញ់ ដោយការលះឆន្ទរាគៈដែលជាប់និងបិយរូបនោះ ព្រោះសម្រេចព្រះអរិយមគ្គ ។ បទ-ថា **តេ វេ ខណន្តិ អឃមូលំ មច្ចុនោ អាមិសំ ឲរតិវត្តំ** *សេចក្តីថា ព្រះអរិយ-បុគ្គលទាំងនោះប្រើចប គឺអរិយមគ្គញ្ញាណ ជីកតណ្ហាព្រមទាំងអវិជ្ជា ដែលជាឫសគល់នៃវដ្តទុក្ខ ឈ្មោះថា ជាអាមិស ព្រោះមច្ចុ គឺមរណៈពាល់ត្រូវ ឈ្មោះថាកន្លងបានលំបាក ព្រោះសមណព្រាហ្មណ៍ពួកណា ក្រៅអំពីសាសនានេះ មិនអាចត្រឡប់បាន គឺដកឫសឡើងមិនឱ្យនៅសល់ សូម្បីតែវត្ថុបន្តិចបន្តួច សេចក្តីនេះនោះ គប្បីឱ្យពិស្តារដោយសុត្តបទមានជាអាទិ៍ថា*

អប្បមាទោ អមតំបទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា

សេចក្តីមិនប្រមាទ[១]ជាផ្លូវនៃសេចក្តីមិនស្លាប់[២] សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ[៣] ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ[៤] ។

សត្តមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៧

១-បានដល់ ការប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះស្មារតី ដែលបានតាំងប្រុងជានិច្ច ។

២-ពាក្យថា មិនស្លាប់នេះ ជាឈ្មោះព្រះនិព្វាន ព្រោះព្រះនិព្វានមិនមានចាស់ មិនមានស្លាប់ ។

៣-បានដល់ ការមិនប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះនៃការលះបង់ស្មារតី ។

៤-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ២៥ ។

៨. សុប្បវាសាសុត្តវណ្ណនា

អដ្ឋកថាសុប្បវាសាសូត្រ

សុប្បវាសាសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **កុណ្ឌិយាយំ** *បានដល់ ជិតនគររបស់ពួកអ្នកដែនកោលិយ: មានឈ្មោះយ៉ាងនោះ ។ បទថា* **កុណ្ឌិដ្ឋានវនេ** *បានដល់ ក្នុងព្រៃឈ្មោះ* **កុណ្ឌិដ្ឋាន:** *មិនឆ្ងាយពីនគរនោះ ។*

បានឮមកថា កាលពីបូរាណ យក្ខម្នាក់ឈ្មោះ **កុណ្ណ:** *អាស្រ័យនៅត្រង់ព្រៃស្រោងនោះ និងយក្ខនោះពេញចិត្តពលីកម្មដែលលាយដោយកន្ទក់ និងលាជ ព្រោះដូច្នោះ ជនទាំងឡាយ ទើបបង្ហោនតាំពលីកម្ម យ៉ាងនោះចូលទៅក្នុងទីនោះ ដល់យក្ខនោះ ព្រោះហេតុនោះ ព្រៃស្រោងនោះ ទើបប្រាកដថា* **កុណ្ឌិដ្ឋាវ៉ន** *។ ក្នុងទីនេះមិនឆ្ងាយព្រៃស្រោងនោះ មានស្រីជាម្ចាស់ស្រុកម្នាក់នៅទីនោះ ។ សូម្បីនាងក៏ត្រូវហៅថា* **កុណ្ឌិយា** *ព្រោះនាងនៅអាស្រ័យក្នុងទីជាអាណាខេត្តរបស់យក្ខនោះ និងព្រោះត្រូវយក្ខនោះឯងឃុំគ្រង ។ ក្នុងកាលជាខាងក្រោយមក ព្រះរាជាអ្នកដែនកោលិយ: បានសាងនគរឡើងក្នុងទីនោះ ។ សូម្បីនគរនោះ គេក៏ហៅថា* **កុណ្ឌិយា** *ដូចគ្នា តាមឈ្មោះដើម ។ ក៏ក្នុងព្រៃស្រោងនោះ ពួកអ្នកដែនកោលិយ:បានសាងវិហារ ដើម្បីជាទីប្រថាប់ និងជាទីនៅរបស់ព្រះដ៏មានព្រះភាគ និងកិក្ខុសង្ឆ ។ សូម្បីព្រៃស្រោងនោះក៏ប្រាកដថា* **កុណ្ណដ្ឋានវ៉ន***ដូចគ្នា ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ស្តេចចារិកទៅកាន់ជនបទ ដល់វិហារនោះហើយ ប្រថាប់នៅក្នុងទីនោះឯង ។ ព្រោះហេតុនោះ លោកទើបពោលថា* **ឯកំ សមយំ ភគវា កុណ្ឌិយាយំ វិហរតិ កុណ្ឌិដ្ឋានវនេ ។**

បទថា **សុប្ផាសា** ជាឈ្មោះរបស់ឧបាសិកានោះ ។ បទថា **កោលិយ-ធីតា** ប្រែថា ជាបុត្រីរបស់ស្តេចដែនកោលិយ: ។

ក៏រាជបុត្រីនោះ ជាអគ្គឧបដ្ឋាយិការបស់ព្រះដ៏មានព្រះភាគ ទ្រង់ស្ថាបនាទុកក្នុងឯតទគ្គ:កំពូលលើកសាវិកាទាំងឡាយ អ្នកថ្វាយវត្ថុដ៏ប្រណីតជាព្រះអរិយ-សាវិកាថ្នាក់សោតាបន្ន ។ វត្ថុណាមួយមិនថា របស់ទំពាស៊ី របស់បរិភោគ ឬកេសជ្ជ: ដែលសមគួរដល់ព្រះដ៏មានព្រះភាគ មិនមានស្ត្រីដទៃ ដែលគប្បីចាត់ចែងទុកក្នុងទីនោះឡើយ វត្ថុទាំងអស់នោះ ព្រះនាងពិចារណាដោយបញ្ញារបស់ខ្លួនប៉ុណ្ណោះហើយ ចាត់ចែងហើយ និងបង្ហោនចូលទៅថ្វាយដោយគោរព ។ ឯនាងបានថ្វាយសង្ឆ្ការ និងបាដិបុគ្គលិកភត្ត ៨០០ ជារៀងរាល់ថ្ងៃ ។ មិនថា នឹងជាភិក្ខុ ឬភិក្ខុនី ចូលទៅកាន់ត្រកូលនោះដើម្បីបិណ្ឌបាត ជាអ្នកមានដៃទទេមិនមាន ។ ព្រះនាងមានការបរិច្ចាគយ៉ាងជាច់ខាត មានដៃស្អាត ត្រេកអរក្នុងការលះបង់ គួរដល់ការសូម ត្រេកអរក្នុងទាន និងការចែករំលែកទានដោយប្រការដូច្នេះ ។ សាវ៏ពោធិសត្ត្វអ្នកមានភពចុងក្រោយបង្ហ ស់ បានធ្វើបុញ្ញាធិការទុកក្នុងព្រះពុទ្ធកាលមុន បានចាប់បដិសន្ធិក្នុងផ្ទៃរបស់នាង ។ ដោយបាបកម្មយ៉ាងណាមួយនោះឯង ព្រះនាងត្រូវរក្សាគក៌នោះ ដោយការពផ្ទៃអស់ ៧ ឆ្នាំ និងជាអ្នកមានគក៌លំបាកអស់ ៧ ថ្ងៃ ព្រោះហេតុនោះ លោកទើបពោលថា **សត្ត វស្សានិ ឥត្ថ ជ ១ តិ សត្តាហ ១ ម ១ ច្ឆ ១ ត ១ ្ថ** ទ្រទ្រង់គក៌អស់ ៧ ឆ្នាំ មានគក៌លំបាកអស់ ៧ ថ្ងៃ ។

បណ្តាបទទាំងនោះ បទថា **សត្ត វស្សានិ** ប្រែថា អស់ ៧ ឆ្នាំ ។ ក៏ពាក្យ

ថា **សត្ត វស្សានិ** នេះជាទុតិយាវិភត្តិប្រើក្នុងអច្ចន្តសំយោគ: ប្រែថា រហូតអស់ ៧ ឆ្នាំ ។ បទថា **ឧទ្ធំ ជាវេតិ** ប្រែថា ទ្រទ្រង់គភ៌ អធិប្បាយថា មានគភ៌ ។ បទថា **សត្តាហំ មូឡ្ហកុច្ឆិ** បានដល់ ឈឺពោះអស់ ៧ ថ្ងៃ ។ ព្រោះថា គភ៌ដែលគ្រប់រលោនឹងប្រសូតត្រូវខ្យល់កម្មជ្ជវាតបក់ត្រឡប់ទៅមក បង្វិលជើងឡើងខាងលើ បង្វិលក្បាលចុះខាងក្រោម បែរក្បាលឆ្ពោះទៅកាន់ទ្វារមគ្គក្នុងវេលាកើត ។ ទារកនោះប្រសូតមកខាងក្រៅដោយស្រួល ដោយប្រការដូច្នេះ ។ តែការវិបត្តិ ក៏នឹងដេកទទឹងបិទទ្វារមគ្គ ដោយការត្រឡប់ទៅមកខុសប្រក្រតី ឬទ្វារមគ្គបិទដោយខ្លួនឯងតែម្តង ។ សត្វនោះ ព្រោះខ្យល់កម្មជ្ជវាតក្នុងគភ៌នោះ បក់ត្រឡប់ទៅមក លោកទើបហៅថា គភ៌លំបាក សូម្បីទាងក៏មានសភាពយ៉ាងនោះអស់ ៧ ថ្ងៃ ។ ព្រោះហេតុនោះ លោកទើបពោលថា **សត្តាហំ មូឡ្ហកុច្ឆិ** ដូច្នេះ ។

ក៏សត្វអ្នកកើតក្នុងគភ៌នេះបានដល់ ព្រះសីវលិត្ថេរ ។ សួរថា ព្រោះហេតុអ្វី ព្រះសីវលិត្ថេរទើបជាទុក្ខនៅក្នុងគភ៌អស់ ៧ ឆ្នាំ ដល់ភាពជាអ្នកលំបាកក្នុងគភ៌អស់ ៧ ថ្ងៃ ទាំងមាតារបស់លោកដែលជាអរិយសាវិកាថ្នាក់សោតាបន្ន ក៏បានសោយទុក្ខយ៉ាងនោះដូចគ្នា? ឆ្លើយថា

ក្នុងអតីតកាល ព្រះបាទកាសីគ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះចៅ-កោសលមួយអង្គ ទ្រង់ដឹកនាំកងពលយ៉ាងច្រើន ឡោមព័ទ្ធក្រុងពារាណសី ទ្រង់ធ្វើគត់ព្រះរាជាអង្គនោះ បានតែងតាំងព្រះអគ្គមហេសីរបស់ព្រះរាជានោះ ឱ្យជាអគ្គមហេសីរបស់ខ្លួន ។ ចំណែកព្រះរាជឱរសរបស់ព្រះបាទពារាណសីកាលដែលព្រះបិតាអស់ព្រះជន្ម ទើបកៀសព្រះកាយតាមទឹក រួបរួមញាតិមិត្តនិងជនជាសំឡាញ់របស់ព្រះអង្គ ប្រមូលរួមកម្ទាំងដោយលំដាប់ ហើយស្តេចមកកាន់

ក្រុងពារាណសីតាំងបន្ទាយធំទុកក្នុងទីមិនឆ្ងាយ ទ្រង់បញ្ជូនព្រះរាជសារដល់ព្រះ-
រាជាអង្គនោះថា ចូរប្រទានរាជសម្បត្តិ ឬនឹងប្រយុទ្ធគ្នា ។ ព្រះមាតា បានស្តាប់សារ
របស់ព្រះរាជកុមារហើយ ទើបបញ្ជូនព្រះរាជសារតបទៅថា មិនមានការប្រយុទ្ធទេ
កូនចូរកាត់ផ្តាច់ចរាចរទៅមកក្នុងទិសទាំងពួង ឡោមព័ទ្ធក្រុងពារាណសី តអំពី
នោះពួកអ្នកក្នុងក្រុងនឹងលំបាកព្រោះអស់ឈើទឹកនិងអាហារ នឹងចាប់ព្រះរាជា
មកបង្ហាញ រៀងការប្រយុទ្ធចេញហើយ ។ ព្រះរាជកុមារបានស្តាប់សាររបស់ព្រះ-
មាតាហើយ កាលនឹងរក្សាទ្វារធំទាំង ៤ ទើបឡោមព័ទ្ធក្រុងទុក ៧ ឆ្នាំ ។ មនុស្សក្នុង
ក្រុងនាំគ្នាចេញចូលតាមទ្វារតូច នាំយកឈើនិងទឹកជាដើមមកធ្វើកិច្ចទាំងពួង ។

លំដាប់នោះ ព្រះមាតារបស់ព្រះរាជកុមារទ្រង់ស្តាប់រឿងនោះហើយ ទើប
បញ្ជូនព្រះរាជសារកំចាំងដល់ព្រះឱរសថា បុត្រយើងលួងខ្ញៀមិនដឹងឧបាយ ពួក
អ្នកឯងចូរទៅប្រាប់ដល់បុត្ររបស់យើងនោះថា ចូរបិទទ្វារតូចឡោមព័ទ្ធក្រុង ។
ព្រះរាជកុមារទ្រង់ស្តាប់ព្រះរាជសាររបស់ព្រះមាតា ទើបទ្រង់ធ្វើយ៉ាងនោះ អស់
៧ ថ្ងៃ ។ ពួកអ្នកនគរកាលចេញទៅខាងក្រៅមិនបាន ដល់ថ្ងៃទី ៧ ទើបបានយក
ព្រះសិរសារបស់ព្រះរាជាអង្គនោះ ទៅថ្វាយដល់ព្រះរាជកុមារ ព្រះរាជកុមារ
ស្តេចចូលកាន់ក្រុងហើយសោយរាជសម្បត្តិ ។ ព្រោះផលកម្មដែលឡោមព័ទ្ធនគរ
ទុកអស់ ៧ ឆ្នាំក្នុងកាលមុននោះ ឥឡូវនេះ ព្រះអង្គទើបនៅក្នុងលោហិតកុម្ភី
ពោលគឺ ព្រះគភ៌របស់មាតា ៧ ឆ្នាំ ។ តែព្រោះឡោមព័ទ្ធក្រុងទុកអស់ ៧ ថ្ងៃ ទើប
ដល់ភាពជាអ្នកលំបាកក្នុងគភ៌ដល់ទៅ ៧ ថ្ងៃ ។ ចំណែកក្នុងអដ្ឋកថាជាតក លោក
ពោលថា ព្រោះផលកម្មដែលឡោមព័ទ្ធក្រុងទុកអស់ ៧ ថ្ងៃ ។ ព្រះអង្គទើបនៅក្នុង

*លោហិតកុម្ភីអស់ ៧ ឆ្នាំ ហើយដល់ភាពជាអ្នកលំបាកគក់អស់ ៧ ថ្ងៃ ។ ក៏ព្រះអង្គជាអ្នកកំពូលលើសដោយលាភ ព្រោះអានុភាពដែលថ្វាយមហាទាន ហើយតាំងសេចក្តីប្រាថ្នាត្រង់បាទមូលរបស់**ព្រះបទុមុត្តរសម្មាសម្ពុទ្ធ**ថា សូមជាអ្នកកំពូលលើសដោយលាភ និងដែលថ្វាយទឹកអំពៅ និងទឹកដោះជូរមានតម្លៃ ១.០០០ កហាបណៈ ព្រមទាំងអ្នកក្រុង ហើយបានតាំងសេចក្តីប្រាថ្នាក្នុងកាលនៃព្រះដ៏-មានព្រះភាគព្រះនាមថា **វិបស្សី** ។ ចំណែកព្រះនាងសុប្បវាសាពង្ផៃអស់ ៧ ឆ្នាំ លំបាកគក់អស់ ៧ ថ្ងៃ ព្រោះតែបញ្ជូនសារទៅថា បាចូរឡើងមព័ន្ធនគរ ។ ព្រះមាតានិងបុត្រទាំងនោះ បានសោយទុក្ខដូច្នេះ តាមសមគួរដល់កម្មរបស់ខ្លួន ដោយប្រការដូច្នេះ ។*

បទថា **តីហិ វិតក្កេហិ** *សេចក្តីថា ដោយសម្មាវិតក្ក: ៣ ដែលជាប់ដោយការរឭកដល់គុណព្រះរតនត្រ័យ ។ បទថា* **អជ្ঝាសេតិ** *សេចក្តីថា អត់ធន់ទុក្ខដែលកើតឡើង ព្រោះជាអ្នកមានគក់លំបាក ។ សេចក្តីពិត ព្រះនាងរឭករឿយៗដល់សេចក្តីដែលព្រះដ៏មានព្រះភាគ ជាអ្នកត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ការបដិបត្តិល្អរបស់ព្រះអរិយសង្ឆ និងព្រះនិព្វានជាគ្រឿងរលាស់ចេញចាកទុក្ខ ទើបអត់ធន់គ្របសង្កត់ទុក្ខ ដែលកើតដល់ខ្លួនដោយមិនធ្វើទុកក្នុងចិត្តនុ៎ះឯង។ ព្រោះហេតុនោះ លោកទើបពោលថា* **តីហិ វិតក្កេហិ អជ្ঝាសេតិ** *ដូច្នេះ ។*

បទមានជាអាទិ៍ថា **សម្មាសម្ពុទ្ធោ** *រត ជាបទសម្តែងអាការដែលវិតក្ក: ទាំងនោះកើតឡើង ។ ពាក្យនោះមានអធិប្បាយដូច្នេះ ព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះថា ជាលោកនាថ ព្រោះមានភាពជាអ្នកមានភាគ្យធម៌ជាដើម ឈ្មោះថា* **ពុទ្ធ:** *ព្រោះត្រាស់ដឹងនូវធម៌ទាំងពួងដោយប្រពៃ គឺមិនវិបរិតដោយព្រះអង្គឯង*

ព្រះដ៏មានព្រះភាគអង្គនោះ សម្តែងនូវធម៌ដើម្បីលះវដ្តទុក្ខទាំងអស់ ដែលសភាពយ៉ាងនេះ គឺយើងបានទទួលនៅក្នុងឥឡូវនេះ និងដែលមានការកើតយ៉ាងនេះ ដោយចំណែកមួយ និងដើម្បីរលត់មិនកើតឡើងមិនឱ្យសេសសល់ គឺសម្តែងធម៌ដែលមិនវិបរិត ។ សេចក្តីពិត ភាពដែលព្រះសាស្តាសម្រេច ព្រះសម្មាសម្ពោធិញ្ញាណ ព្រោះទ្រង់សម្តែងធម៌មិនវិបរិត ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គមានព្រះអរិយបុគ្គល ៨ ពួក ដែលមានឈ្មោះថា សាវកសង្ឆ ព្រោះកើតក្នុងទីជិតនៃការស្តាប់ធម៌របស់ព្រះដ៏មានព្រះភាគ ព្រះអង្គមានព្រះគុណតាមដែលពោលហើយនោះ និងកើតរួមដោយភាពជាអ្នកមានសីលនិងទិដ្ឋិស្មើគ្នា ដែលជាអរិយសង្ឆអ្នកបដិបត្តិល្អ បដិបត្តិប្រពៃ បដិបត្តិនូវបដិបទាជាដំណើរមិនត្រឡប់ ដើម្បីលះវដ្តទុក្ខដែលមានភាពដូច្នេះ គឺឱ្យរលត់ ។ អរិយសង្ឆទាំងនោះ រមែងមិនបានទទួលវដ្តទុក្ខដូច្នេះ ក្នុងព្រះនិព្វាន ដែលជាគ្រឿងរលាស់សង្ខតធម៌ទាំងពួង ដែលលោកពោលថាជាសុខដ៏ប្រពៃ ជាសុខដ៏ប្រសើរ ។ ក៏ក្នុងទីនេះ សូម្បីអ្នកកំពុងបដិបត្តិ លោកក៏ពោលថា បដិបត្តិហើយដូចគ្នា ព្រោះការបដិបត្តិមិនត្រឡប់ (និព្វាន) ។ ម្យ៉ាងទៀត សព្ទថា **ឋដិបន្ន:** គប្បីជ្រាបដោយអត្ថជាបច្ចុប្បន្ន ដូចសព្ទ **ឧប្បន្ន:** ។ ព្រោះហេតុនោះឯង លោកទើបពោលថា ឈ្មោះថា អ្នកបដិបត្តិដើម្បីធ្វើឱ្យច្បាស់សោតាបត្តិផលដូច្នេះ ។

បទថា **សាមិកំ** បានដល់ ព្រះរាជឱ្យសរបស់ព្រះបាទកោលិយ:អ្នកជាស្វាមីរបស់ព្រះនាង ។ បទថា **អាមន្តេសិ** ប្រែថា បានត្រាស់ហើយ ។ បទថា **មម វចនេន ភតរតោ ចានេ សិរសោ រជ្ជាហិ** សេចក្តីថា សូមព្រះអយ្យបុត្ត

ចូរថ្វាយបង្គំព្រះដ៏មានព្រះភាគដោយសិរសារបស់ព្រះអង្គ ត្រង់ព្រះយុគលបាទ ដ៏មានសិរីដូចផ្កាបទុមរីក ដែលប្រដាប់ដោយចក្រលក្ខណៈ តាមពាក្យរបស់ខ្ញុំ ម្ចាស់ អធិប្បាយថា នាងចូរធ្វើអភិវាទដោយសិរសា ។ បទថា **អាពោធា** ក្នុង ពាក្យមានជាអាទិ៍ថា **អប្ប្ាពាធំ** លោកពោលដល់វេទនាដែលផ្សេងគ្នា សូម្បីកើត ឡើងហើយក្នុងចំណែកណាមួយ ក៏កាន់យកសរីរៈទាំងអស់ ប្រៀបដូចជាជាប់ ដោយបន្ទុះដែក ។ បទថា **អាតង្ក** បានដល់ ពោគដែលធ្វើជីវិតឱ្យរស់បាន កម្រ ។ ម្យ៉ាងទៀត ពោគដែលគប្បីញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបាន ឈ្មោះថា **អាតង្ក** ។ ពោគក្រៅនេះ ឈ្មោះថា **អាពាធ** ។ ម្យ៉ាងទៀត ពោគបន្ទិចបន្ទួច ឈ្មោះថា **អាតង្ក** ពោគខ្លាំងក្លា ឈ្មោះថា **អាពាធ** ។ តែអាចារ្យពួកខ្លះពោលថា ពោគដែលកើតខាងក្នុង ឈ្មោះថា **អាពាធ** ពោគដែលកើតខាងក្រៅ ឈ្មោះថា **អាតង្ក** ។ ព្រះនាងមានព្រះសវនីយ៍ថា ព្រះអង្គចូរទូលសួរដល់សេចក្តីមិនមាន ពោគសូម្បីទាំងពីរយ៉ាងនោះ ។ ក៏ដែលឈ្មោះថា ការកើតឡើងនៃជំងឺ គឺឈឺនុ៎ះឯង ជាការធ្ងន់កាយ គឺមិនមានកម្លាំង ។ ព្រោះហេតុនោះ ព្រះនាងទើបមានសវនីយ៍ ថា ព្រះអង្គសូមទូលសួរដល់ឋានៈដែលរាងកាយស្រាល និងមានកម្លាំង ពោល គឺ ការផ្ទាស់ប្តូររហ័ស ព្រោះមិនមានជំងឺ ។ បទថា **ជាសុវិហារំ** សេចក្តីថា ព្រះនាងមានសវនីយ៍ថា សូមទូលសួរដល់ការនៅសប្បាយក្នុងឥរិយាបថទាំង ៤ ពោលគឺ ឈរ អង្គុយ ដើរ ដេក ។ លំដាប់នោះ ព្រះនាងកាលនឹងសម្តែង អាការដែលនឹងទូលសួរព្រះអង្គ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **សុប្ប្ាសា ភន្តេ** ជូនេះ ។ ដោយពាក្យ ថា **ឯវញ្ច ១ ១ ១ ១ ១** លោកសម្តែងដល់អាការដែល នឹងគប្បីទូលក្នុងឥឡូវនេះ ។

បទថា **បរមំ** *ជាការទទួលពាក្យតប ។ ដោយបទថា* **បរមំ** *នោះ ព្រះរាជ*
មានព្រះរាជឱដ្ការថា ល្អណាស់នាង ខ្ញុំនឹងធ្វើតាមពាក្យរបស់នាង ។ បទថា
កោលិយបុត្តោ *បានដល់ ព្រះរាជឱរសរបស់កោលិយរាជ ជាព្រះស្វាមីរបស់*
ព្រះនាងសុប្បវាសា ។ ដោយបទថា **សុទិនី ហោតុ** *ព្រះសាស្តាជាអគ្គទក្ខិ-*
ណេយ្យបុគ្គលក្នុងលោក ព្រមទាំងទេវលោក ទ្រង់ទទួលពាក្យការសំពះរបស់
ព្រះរាជបុត្រដែលព្រះនាងសុប្បវាសាបញ្ជូនមក ពេលនោះ ទើបទ្រង់ប្រកាស
ការនាំសេចក្តីសុខ ចូលទៅដល់ទីព្រះពុទ្ធាប់ទ្រង់បំពេញមក ជាហេតុឱ្យកើត
មេត្តាវិហារធម៌របស់ព្រះអង្គ ដល់ព្រះនាងសុប្បវាសានោះ ដោយសាមញ្ញទូទៅ
កាលនឹងទ្រង់សម្តែងការនាំសេចក្តីសុខចូលទៅដល់ព្រះនាង និងព្រះរាជឱរស
ទៀត ដោយការបដិសេធការបានទទួលទុក្ខ ដែលមានការវិបត្តិគក់ជាមូលហេតុជា
ប្រធានទើបត្រាស់ថា **សុទិនី ហោតុ សុប្បវាសា កោលិយធីតា អរោគា**
អរោគំ បុត្តំ វិជាយតុ *ព្រះមានព្រះភាគទ្រង់ត្រាស់ថា សូមឱ្យកោលិយធីតា នាម*
សុប្បវាសា បានសេចក្តីសុខ សូមកុំឱ្យមានរោគ ប្រសូតបុត្តកុំឱ្យមានរោគ ។

បទថា **សហ ជាតេ** *បានដល់ ព្រមដោយព្រះតម្រាស់របស់ព្រះមាន-*
ព្រះភាគនុ៎ះឯង ។ ក្នុងវេលាដែលព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នោះនុ៎ះឯង
កម្មសូម្បីនោះក៏អស់ទៅ ។ ព្រះសាស្តាទ្រង់រមិលមើលថា កម្មនោះអស់ហើយ
ទើបបានត្រាស់យ៉ាងនោះ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា កាលពោល
ព្រះសាស្តានឹងមិនត្រាស់យ៉ាងនោះទេ សូម្បីតអំពីនោះ សេចក្តីទុក្ខនោះនឹង
ជាប់តាមព្រះនាងទៅរហូតអស់កាលយូរបន្តិច ។ តែព្រោះហេតុដែលព្រះដ៏មាន-

ព្រះភាគត្រាស់ថា សូមសុប្បវាសាមានសេចក្តីសុខ សូមកុំឱ្យមានរោគ និង ប្រសូតបុត្តមិនមានរោគ ដូច្នោះ ព្រមនឹងវេលាដែលព្រះដ៏មានព្រះភាគត្រាស់ នោះឯង គក់នោះក៏បាត់ឈឺ ប្រសូតបានដោយងាយតែម្តង ព្រះមាតា និង ព្រះឱរសទាំងពីរនោះមានសិរីសួស្តីដោយប្រការដូច្នេះ ។ សេចក្តីពិត ពុទ្ធានុភាព របស់ព្រះពុទ្ធទាំងឡាយជាអចិន្ត្យ ។ សមដូចកាលនាងបជាចាវ ដល់ភាព ជាមនុស្សឆ្លួត ព្រោះសេចក្តីសោកដែលកើតពីសត្វ និងសង្ខារដែលជាទីស្រឡាញ់ មានការរូបដូចពេលកើតនោះ ត្រាច់ទៅនិយាយថា

ឧភោ បុត្តា ការកតា រណេ មយ្ហំ បតិ បតោ
មាតា បិតា ច ភាតា ច ឯកចិត្តម្ហិ ឆយ្ហរេ ។

កូនទាំងពីរធ្វើមរណកាលហើយ ទាំងប្តីរបស់ខ្ញុំក៏ស្លាប់ក្នុងព្រៃ មាតាបិតា និងបងប្រុស ក៏ត្រូវគេដុតលើជើងជ្ជរជាមួយគ្នា[1] ។

ក្នុងខណៈដែលព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលប្អូនស្រី នាងចូរត្រឡប់ បានសតិវិញនោះឯង ភាពជាមនុស្សឆ្លួតក៏បាត់ទៅ យ៉ាងណា សូម្បីនាងសុប្ប-ិ-យាឧបាសិកាក៏ដូចគ្នា កាលមិនអាចនឹងឱ្យដំបៅធំដែលកើតឡើងត្រង់ក្ងៀរបស់ ខ្លួនបាត់បាន ទើបដេកលើគ្រែដេក កាលដំបៅបាត់ទៅជាប្រក្រតី ក្នុងខណៈ ដែលត្រាស់ថា នាងចូរមកថ្វាយបង្គំតថាគត ក៏ទៅថ្វាយបង្គំព្រះដ៏មានព្រះភាគ រួមសេចក្តីថា រឿងមានជាអាទិ៍ដូចពោលមកនេះ គប្បីលើកឡើងជាឧទាហរណ៍ ។

បទថា **ឯវំ ភន្តេ** *សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនោះដូចជា*

១-សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧៦ ទំព័រ ១១៤ ។

ព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគ កាលទ្រង់ប្រាជ្ញាដល់សេចក្តីដែលព្រះនាង ព្រមទាំងព្រះឱរសមិនមានរោគ ទើបត្រាស់ថា ចូរជាអ្នកមានសេចក្តីសុខ ប្រាសចាករោគ ប្រសូតព្រះឱរសប្រាសចាករោគនោះឯង ។ អធិប្បាយថា ក្នុងកាលណា ព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ មិនបានប្រែប្រួលយ៉ាងដទៃឡើយ ។ ចំណែកអាចារ្យពួកខ្លះពោលថា **ឯវមត្តុ** ចូរជាយ៉ាងនោះ ។ អាចារ្យមួយពួកទៀតនាំយកសេចក្តីរបស់បទថា **ហោតុ** ចូរសម្រេចចុះមកពណ៌នា ។ បទថា **អកិនន្ទិត្វា** សេចក្តីថា រីករាយត្រង់ព្រះកក្ត្រ ដោយបានទទួលបីតិ និងសោមនស្ស ក្នុងពាក្យព្រះដ៏មានព្រះភាគត្រាស់ហើយ ព្រះអង្គមានសួរសៀងពីរោះ ដូចសំឡេងសត្វករវិក ។ បទថា **អនុមោទិត្វា** សេចក្តីថា សូម្បីខាងក្រោយអំពីនោះ ក៏ធ្វើឱ្យកើតនូវសេចក្តីសរសើរ គឺរីករាយដោយចិត្ត ហើយអនុមោទនាដោយវាចា ឬរីករាយដោយភាពបរិបូរនៃព្រះតម្រាស់ ហើយអនុមោទនាដោយភាពបរិបូរនៃអត្ត ។ បទថា **សក្កំ ឃរំ បច្ចាយាសិ** បានដល់ ព្រះរាជាត្រឡប់មកកាន់ដំណាក់របស់ព្រះអង្គវិញ ។ ក៏លោកអាចារ្យអ្នកពោលថា **យេន សក្កំ ឃរំ** ជាការពោលបទថា **តេន** ព្រោះសម្ព័ន្ធ **យ ត** ស័ព្ទភ្ជាប់គ្នា ដោយពិត ទោះជាយ៉ាងនោះ គប្បីប្រកបបាលីដែលនៅសល់ថា **បដិយាយិត្វា** (ត្រឡប់) ។

បទថា **ឋិជ្ជាតំ** បានដល់ ប្រសូត អធិប្បាយថា ប្រសូត ។ បទថា **អច្ឆរិ-យំ** សេចក្តីថា ឈ្មោះថា គួរអស្ចារ្យ ព្រោះមិនមាននៅជានិច្ច ដូចមនុស្សខ្វាក់ភ្នែកឡើងភ្នំ ។ ន័យនៃស័ព្ទត្រឹមតែប៉ុណ្ណោះ ។ តែក្នុងអដ្ឋកថាទាំងឡាយពោលទុកថា ឈ្មោះថា គួរអស្ចារ្យ ព្រោះគួរដល់ការទះដៃ អធិប្បាយថា គួរដល់ការ

ទ:ដៃ ។ ស័ព្ទ **វត** ប្រើក្នុងសម្ភាវន: អធិប្បាយថា គួរអស្ចារ្យពិត ។ បទថា **ភោ** ជាពាក្យហៅ ធម្មតា ។ ឈ្មោះថា **អព្ភុត:** ព្រោះមិនធ្លាប់មាន ។

បទថា **តថាគតស្ស** សេចក្ដីថា ព្រះដ៏មានព្រះភាគ ព្រះនាមថា **តថាគត** ដោយហេតុ ៨ ប្រការ គឺព្រះនាមថា **តថាគត** ព្រោះស្ដេចមកយ៉ាងនោះ ព្រះនាមថា **តថាគត** ព្រោះស្ដេចទៅយ៉ាងនោះ ព្រះនាមថា **តថាគត** ព្រោះស្ដេចមកកាន់លក្ខណ:ដែលពិត ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងប្រពៃ ក្រៃលែងនូវធម៌ដ៏ច្បាស់តាមសេចក្ដីពិត ព្រះនាមថា **តថាគត** ព្រោះទ្រង់ឃើញ ធម៌ដ៏ជាក់ច្បាស់ ព្រះនាមថា **តថាគត** ព្រោះមានព្រះតម្រាស់ដែលជាក់ច្បាស់ ព្រះនាមថា **តថាគត** ព្រោះទ្រង់ធ្វើយ៉ាងនោះ ព្រះនាមថា **តថាគត** ព្រោះអត្ថថា គ្របសង្កត់ (សត្វទាំងពួង) ។ សួរថា ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ ព្រះនាមថា **តថាគត** ព្រោះស្ដេចមកយ៉ាងនោះ? ឆ្លើយថា ដូចព្រះសម្មាសម្ពុទ្ធទាំងឡាយ ក្នុងកាលមុន ព្រះអង្គខ្ជាប់ខ្ជាយ ព្រោះស្ដេចមកដើម្បីប្រយោជន៍ដល់លោកទាំង ពួង ។ ពោលអធិប្បាយទុកយ៉ាងណា ពោលទុកថា ព្រះដ៏មានព្រះភាគសូម្បី ព្រះអង្គនេះ ស្ដេចមកដោយអកិនីហារ ៨ ប្រការដែលជាគ្រឿងមករបស់ព្រះដ៏-មានព្រះភាគទាំងនោះ ។ ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគទាំងនោះ ទ្រង់បំពេញ បារមី ៣០ គត់ គឺទ្រង់បំពេញទានបារមី សីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី និងឧបេក្ខាបារមី រួមបារមីទាំងនេះ ចាត់ជាបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ទ្រង់ បរិច្ចាគមហាបរិច្ចាគ ៥ និងទ្រង់បំពេញបុព្វប្រយោគ បុព្វចរិយ: ការត្រាស់ ធម្មទេសនា និងញាតត្ថចរិយាជាដើម ហើយទ្រង់ដល់ទីបំផុតនៃពុទ្ធចរិយា

ស្តេចមកហើយដោយប្រការណា ព្រះដ៏មានព្រះភាគ សូម្បីព្រះអង្គនេះ ក៏ស្តេចមកហើយដោយប្រការនោះ ។ ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ ទ្រង់ចម្រើន គឺធ្វើឱ្យច្រើននូវសតិប្បដ្ឋាន ៤ ។ល។ អរិយមគ្គមានអង្គ ៨ ស្តេចមកដោយប្រការណា ព្រះដ៏មានព្រះភាគសូម្បីព្រះអង្គនេះក៏ស្តេចមកដោយប្រការនោះ ។ ព្រះដ៏មាន-ព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកយ៉ាងនោះដោយប្រការដូច្នេះ ។

សួរថា ព្រះដ៏មានព្រះភាគព្រះនាមថា **តថាគត** ព្រោះស្តេចទៅដោយប្រការនោះដូចម្តេច? ឆ្លើយថា ព្រះដ៏មានព្រះភាគទាំងឡាយដែលឧប្បត្តិឡើងនោះ ប្រថាប់លើផែនដីដោយព្រះយុគលបាទទាំងពីរ បែរព្រះកក្ត្រទៅកាន់ទិសឧត្តរ ស្តេចយាងទៅបាន ៧ ជំហាន កាលទេវតាយកស្វេតឆត្រ័មកបាំងថ្វាយ ទ្រង់រមិលមើលទៅទិសទាំងពួង ទ្រង់បន្ទឺព្រះវាចាយ៉ាងអង់អាច ព្រះដ៏-មានព្រះភាគទាំងនោះ កាលប្រកាសដល់ភាពដែលព្រះអង្គជាចម្បង និងប្រសើរបំផុតក្នុងលោក ទើបបានយាងទៅយ៉ាងច្បាស់ មិនខុសដោយបុព្វនិមិត្តនៃការសម្រេចគុណវិសេសជាច្រើន ដោយប្រការណា ព្រះដ៏មានព្រះភាគសូម្បីព្រះអង្គនេះ ក៏ស្តេចទៅដោយប្រការនោះ និងការស្តេចទៅរបស់ព្រះអង្គនោះ ជាការស្តេចទៅយ៉ាងច្បាស់ មិនខុស ព្រោះជាបុព្វនិមិត្តនៃការសម្រេចគុណវិសេសទាំងនោះដូចគ្នា ។ ព្រះនាមថា **តថាគត** ព្រោះស្តេចទៅដោយប្រការនោះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគទាំងឡាយ ទ្រង់លះកាមធ្នូ:ដោយនេក្ខម្ម: ហើយលះព្យាបាទដោយការមិនព្យាបាទ លះថីនមិទ្ធ:ដោយអាលោក-

*សញ្ញា លះឧទ្ធច្ចកុក្កុច្ច:ដោយការមិនរាយមាយ លះវិចិកិច្ឆាដោយការកំណត់ធម៌ ទម្លាយអវិជ្ជាដោយញាណ បន្ទោបង់សេចក្តីមិនត្រេកអរដោយបាមោជ្ជ: លះធម៌ដែលជាបដិបក្ខនោះ។ ដោយសមាបត្តិ ៨ ដោយមហាវិបស្សនា ១៨ និងដោយអរិយមគ្គ ៤ ស្តេចទៅយ៉ាងណា សូម្បីព្រះដ៏មានព្រះភាគនេះ ក៏ស្តេចទៅយ៉ាងនោះ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅដោយប្រការនោះ សូម្បីដោយប្រការដូច្នេះ ។*

*ព្រះនាមថា **តថាគត** ព្រោះព្រះដ៏មានព្រះភាគមកកាន់លក្ខណ:យ៉ាងច្បាស់ដូចម្តេច? គឺព្រះនាមថា **តថាគត** ព្រោះទ្រង់មានញាណគតិ ស្តេចមកដល់ គឺសម្រេចមិនខុស នូវលក្ខណ:យ៉ាងច្បាស់មិនខុសមិនក្លាយជាយ៉ាងដទៃ ដល់មានធម៌នោះ។ ជាសភាវ:ព្រមដោយកិច្ចជាលក្ខណ:យ៉ាងនេះ គឺ**ឋបវីធាតុ** មានភាពរឹងជាលក្ខណ: **អាបោធាតុ** មានការហូរទៅជាលក្ខណ: **តេជោធាតុ** មានការក្តៅជាលក្ខណ: **វាយោធាតុ** មានការបក់ជាលក្ខណ: **អាកាសធាតុ** (បរិច្ឆេទរូប) មានការមិនពាល់ត្រូវជាលក្ខណ: **រូប** មានការប្រែប្រួលជាលក្ខណ: **វេទនា** មានការសោយនូវអារម្មណ៍ជាលក្ខណ: **សញ្ញា** មានការចាំបានជាលក្ខណ: **សង្ខារ** មានការតាក់តែងជាលក្ខណ: **វិញ្ញាណ** មានការដឹងច្បាស់ជាលក្ខណ: រួមសេចក្តីថា បានដល់ ខន្ធ ៥ អាយតន: ១២ ធាតុ ១៨ ឥន្ទ្រិយ ២២ សច្ច: ៤ បច្ចយាការ ១២ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល: ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ វិសុទ្ធិ ៧ និងអមតនិព្វាន ១ ។ ព្រះនាមថា **តថាគត** ព្រោះស្តេចមកកាន់លក្ខណ:យ៉ាងណា សូម្បីព្រះដ៏មានព្រះភាគអង្គនេះក៏មានលក្ខណ:យ៉ាងនោះ ។*

ព្រះនាមថា **តថាគត** ព្រោះព្រះដ៏មានព្រះភាគត្រាស់ដឹងដ៏ក្រៃលែងនូវ ធម៌យ៉ាងច្បាស់ តាមសេចក្ដីពិតដូចម្ដេច? គឺឈ្មោះថា ធម៌យ៉ាងច្បាស់ បានដល់ អរិយសច្ច: ៤ ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ ធម្មជាត ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃ[1] ។ សេចក្ដីពិស្តារមាននៅក្នុងគម្ពីរ នោះសម្រាប់ហើយ ។ ក៏ព្រះដ៏មានព្រះភាគត្រាស់ដឹងក្រៃលែង នូវអរិយសច្ច: ៤ ទាំងនោះ ព្រោះដូច្នោះ ព្រះមានដ៏ព្រះភាគ ទើបព្រះនាមថា **តថាគត** ព្រោះ ត្រាស់ដឹងនូវអរិយសច្ច: ៤ នោះយ៉ាងច្បាស់ ។

ម្យ៉ាងទៀត អត្តរបស់ជរា និងមរណ:កើតមានការប្រព្រឹត្តទៅ ព្រោះ ជាតិជាបច្ច័យជាសការ:យ៉ាងច្បាស់ មិនខុសមិនក្លាយជាយ៉ាងដទៃ ។ ល ។ អត្ត របស់សង្ខារកើត និងប្រព្រឹត្តទៅព្រោះអវិជ្ជាជាបច្ច័យ ជាសការ:យ៉ាងច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ អត្តរបស់អវិជ្ជាជាបច្ច័យនៃសង្ខារក៏ដូចគ្នា ។ ល ។ អត្តរបស់ជាតិជាបច្ច័យនៃជរា និងមរណ:ក៏ដូចគ្នា ជាសការ:យ៉ាងច្បាស់ មិន ខុស មិនក្លាយជាយ៉ាងដទៃ ព្រះដ៏មានព្រះភាគត្រាស់ដឹងធម៌នោះទាំងអស់ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះ ត្រាស់ដឹងក្រៃលែងនូវអរិយសច្ច: ៤ យ៉ាងច្បាស់ ។ មែនពិត **គត**-ស័ព្ទ ក្នុងបទ ថា **តថាគតោ** នេះ មានអត្ថថា ត្រាស់ដឹងក្រៃលែង ។ ព្រះនាមថា **តថាគត**

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៩ ទំព័រ ២៥៩ ។

ព្រោះត្រាស់ដឹងធម៌យ៉ាងច្បាស់ តាមសេចក្ដីពិតដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ឃើញយ៉ាងច្បាស់ ដូចម្ដេច? គឺព្រះដ៏មានព្រះភាគទ្រង់ដឹង ទ្រង់ឃើញដោយប្រការទាំងពួង នូវធម្មជាតិដែលឈ្មោះថា រូបារម្មណ៍ ដែលប្រាកដតាមចក្ខុទ្វាររបស់សត្វរកប្រមាណមិនបាន ក្នុងលោកធាតុរកប្រមាណមិនបាន ក្នុងលោក ព្រមទាំងទេវលោក ។លម។ ក្នុងពួកសត្វព្រមទាំងទេវតា និងមនុស្ស ។ ធម្មជាតិយ៉ាងច្បាស់ប៉ុណ្ណោះមានធម្មជាតិដែលមិនពិត មិនមាន ដែលព្រះអង្គអ្នកទ្រង់ដឹង ទ្រង់ឃើញយ៉ាងនេះ ចែកដោយនាមជាច្រើន ១៣ វារៈ ៥២ ន័យ ដោយន័យមានជាអាទិ៍ថា រូបជារូបាយតនៈនោះ តើដូចម្ដេច ។ រូបណា គឺពណ៌អាស្រ័យមហាភូតទាំង ៤ ជាវត្ថុដែលអាចឃើញបាន ប្រកបដោយការប៉ះពាល់ ជាពណ៌ខៀវ លឿង[1] ព្រោះអាស្រ័យមហាភូតរូប ៤ ទើបថ្វែងពណ៌នាដោយអំណាចនៃឥដ្ឋារម្មណ៍ និងអនិ-ដ្ឋារម្មណ៍ជាដើម ឬដោយបទដែលមាននៅក្នុងរូបដែលបានឃើញ ក្នុងសំឡេងដែលបានឮ និងធម្មារម្មណ៍ដែលបានដឹងច្បាស់ ។ ក្នុងសទ្ធារម្មណ៍ជាដើម ដែលមកប្រាកដតាមសោតទ្វារជាដើមក៏ន័យនេះ ។ សមដូចព្រះតម្រាស់ដែលព្រះដ៏-មានព្រះភាគត្រាស់ទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នឹងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ នឹងមនុស្ស

១-អភិធម្មបិដក ធម្មសង្គណី លេខ ៧៩ ទំព័រ ៣៥ ។

ជាសម្មតិទេព នឹងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានស្វែងរក ពិចារណារឿយៗដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្ម-លោក នឹងពពួកសត្ត ព្រមទាំងសមណព្រាហ្មណ៍ នឹងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងនូវអារម្មណ៍នោះ ឯអារម្មណ៍នោះ តថាគតដឹងប្រាកដហើយ អារម្មណ៍នោះ មិនបិតនៅក្នុងតថាគតទេ[1] ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ឃើញយ៉ាងច្បាស់ ដោយប្រការដូច្នេះ ។ បទថា **តថាកតោ** គប្បីជ្រាបថា ជាបទប្រើក្នុងអត្ថថា ព្រោះទ្រង់ឃើញយ៉ាងច្បាស់ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះមានវាទ:យ៉ាងច្បាស់ ដូចម្តេច? គឺព្រះដ៏មានព្រះភាគ ត្រាស់ដឹងក្រៃលែងនូវអនុត្តរសម្មាសម្ពោធ-ញ្ញាណក្នុងរាត្រីណា និងទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងរាត្រីណា ចន្លោះនេះ មានវេលាប្រមាណ ៤៥ វស្សា ព្រះដ៏មានព្រះភាគត្រាស់សុត្ត: និងគេយ្យ:ជាដើមណាទាំងអស់នោះ បរិសុទ្ធបរិបូរ កម្ចាត់សេចក្តីស្រវឹងព្រោះរាគ:ជាដើម បានជាមួយគ្នាតែម្យ៉ាងយ៉ាងច្បាស់ មិនមានខុស ។ ព្រោះហេតុនេះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា "ម្នាលចុន្ទ តថាគតត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរ ក្នុងវេលាយប់ណាផង បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងវេលាយប់ណាផង រមែងសម្តែងហៅចង្អុលបង្ហាញនូវហេតុណា ក្នុងចន្លោះនុ๋ះ

---

[1]-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៤២ ទំព័រ ៦០ ដល់ ៦១ ។

*ហេតុទាំងអស់នោះ សុទ្ធតែពិត មិនមែនត្រឡប់ទៅជាដទៃឡើយ ហេតុដូច្នោះ ហើយ បានជាគេហៅថា ព្រះតថាគត[១]" ។ **គត**-ស័ព្ទ ក្នុងបទថា* **តថាគតោ** *នេះ មានអត្ថថា **គទ:** ប្រែថា ត្រាស់ ។ ឈ្មោះថា **តថាគត** ព្រោះមានវាទ:យ៉ាងច្បាស់ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត **អាគទន:** គឺ**អាគទ:** អធិប្បាយថា ត្រាស់ ។ ក្នុងបទនេះ គប្បីជ្រាបបទសម្រេចរូបយ៉ាងនេះថា ព្រះនាមថា **តថាគត** ព្រោះ ផ្ទាស់ **ទ** អក្សរឱ្យជា **ត** អក្សរ ព្រោះអត្ថថា ព្រះអង្គមានព្រះតម្រាស់យ៉ាងច្បាស់ គឺមិនប្រែប្រួល ។*

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** *ព្រោះទ្រង់ធ្វើយ៉ាងនោះ ដូចម្តេច? គឺសេចក្តីពិត ព្រះកាយរបស់ព្រះដ៏មានព្រះភាគអនុលោមតាមព្រះវាចា សូម្បីព្រះវាចាក៏អនុលោមតាមកាយ ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់ជា* **យថា-វាទី តថាការី** *ត្រាស់យ៉ាងណាធ្វើយ៉ាងនោះ និងជា* **យថាការី តថាវាទី** *ទ្រង់ធ្វើយ៉ាងណា ត្រាស់យ៉ាងនោះ អធិប្បាយថា ទាំងព្រះវាចាទាំងព្រះកាយ របស់ព្រះដ៏មានព្រះភាគអ្នកជាយ៉ាងនោះ រមែងមានដោយប្រការណា ព្រះអង្គ ទ្រង់ដំណើរទៅ គឺប្រព្រឹត្តទៅដោយប្រការនោះ ។ ម្យ៉ាងទៀត ព្រះកាយ ប្រព្រឹត្តទៅយ៉ាងណា សូម្បីព្រះវាចាក៏ត្រាស់ទៅ គឺប្រព្រឹត្តទៅយ៉ាងនោះ ព្រោះ ហេតុនោះ ទើបទ្រង់ព្រះនាមថា* **តថាគត** *។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ថា* **យថាវាទី ភិក្ខវេ តថាគតោ តថាការី យថាការី តថាវាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី តស្មា តថាគតោ វុច្ចតិ**

១-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៨ ទំព័រ ២៧៦ ។

ម្នាលភិក្ខុទាំងឡាយ តថាគតថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ហេតុនោះ ទើបបានជាគេហៅថា **តថាគត**[១] ។ ព្រះនាមថា **តថាគត** ព្រោះធ្វើយ៉ាងនោះ ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគព្រះនាមថា **តថាគត** ព្រោះអត្ថថា គ្របសង្កត់ដូចម្តេច? គឺព្រះអង្គទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ធ្វើកវគ្គព្រហ្ម ក្នុងខាងលើដរាបដល់អវិចីមហានរកក្នុងខាងក្រោម ទាំងខាងទទឹង ក៏ទ្រង់គ្របសង្កត់សព្វសត្វក្នុងលោកធាតុរកប្រមាណមិនបាន ដោយសីលខ្លះ សមាធិខ្លះ បញ្ញាខ្លះ វិមុត្តិខ្លះ វិមុត្តិញាណទស្សនៈខ្លះ ព្រះអង្គថ្លឹងមិនបាន ឬប្រមាណមិនបាន ដោយពិត ព្រះអង្គជាអ្នកដែលអ្នកណាៗ ថ្លឹងមិនបាន ប្រមាណមិនបាន កំពូលធ្នើមជាទេវតារបស់ទេវតា ជាស្តេចសក្ក:ក្រៃលែងជាងស្តេចសក្ក: ជាព្រហ្មក្រៃលែងជាងព្រហ្ម ជាអ្នកខ្ពស់បំផុតជាងសព្វសត្ត ។ ព្រោះហេតុនោះ ទើបព្រះដ៏មាន-ព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគត ជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្ត ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេពនឹងមនុស្សដ៏សេសបាន ហេតុនោះ បានជាគេហៅថា **តថាគត**[២]" ។ ក្នុងសេចក្តីនោះ មានបទសន្ធិដូចតទៅនេះ ព្រះតម្រាស់របស់ព្រះអង្គដូចម្តេ

១-២-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៦២ ទំព័រ ៥៨ ។

*វិសេស បានដល់ ទេសនាវិលាសនិងការសន្ធរំបុណ្យ ព្រោះហេតុនោះ ព្រះអង្គ ទើបទ្រង់គ្របសង្កត់ អ្នកដែលជាបរប្បវាទទាំងអស់ និងលោក ព្រមទេវលោក ដូចពេទ្យអ្នកមានអានុភាពច្រើន ប្រើថ្នាំទិព្វបង្ក្រាបពស់ទាំងឡាយដូច្នោះ ដូច្នោះ ទើបថ្វាយព្រះនាមថា **តថាគត** ព្រោះផ្ទាស់ **ទ** អក្សរឱ្យជា **ត** អក្សរ ដោយអត្ថថា ព្រះអង្គមានព្រះតម្រាស់យ៉ាងច្បាស់ មិនប្រែប្រួលតាមដែលពោលមកហើយ ជាហេតុគ្របសង្កត់សត្វលោកបាន ។ ព្រះនាមថា **តថាគត** ព្រោះអត្ថថា គ្របសង្កត់សព្វសត្វ ដោយប្រការដូច្នេះ ។*

*ម្យ៉ាងទៀត ព្រះនាមថា **តថាគត** ព្រោះស្តេចទៅដោយប្រការនោះ ។ ព្រះនាមថា **តថាគត** ព្រោះស្តេចទៅយ៉ាងច្បាស់ ។ ក្នុងបទថា **តថាកតោ** នោះ ព្រះនាមថា **តថាគត** ព្រោះស្តេចដល់ គឺសម្រេចលោកទាំងអស់យ៉ាងច្បាស់ ដោយតីរណបរិញ្ញា ។ ព្រះនាមថា **តថាគត** ព្រោះស្តេចទៅ គឺឈានកន្ធងលោកសមុទយៈយ៉ាងច្បាស់ ដោយបហានបរិញ្ញា ។ ព្រះនាមថា **តថាគត** ព្រោះស្តេចដល់ គឺសម្រេចលោកនិរោធយ៉ាងច្បាស់ ដោយសច្ឆិកិរិយា ។ ព្រះនាមថា **តថាគត** ព្រោះស្តេចទៅ គឺបដិបត្តិលោកនិរោធគামិនីបដិបទាយ៉ាងច្បាស់ ។ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោក (គឺទុក្ខ-សច្ចៈ) តថាគតបានត្រាស់ដឹងហើយ តថាគតផុតចាកលោក (គឺទុក្ខសច្ចៈ) ហើយ ម្នាលភិក្ខុទាំងឡាយ លោកសមុទយៈ តថាគតបានត្រាស់ដឹងហើយ លោកសមុ-ទយៈ តថាគបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធៈ តថាគតបានត្រាស់ដឹងហើយ លោកនិរោធៈ តថាគតបានធ្វើឱ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធគামិនីបដិបទា តថាគតបានត្រាស់ដឹងហើយ លោក-*

និរោធគាមិនីបដិបទា តថាគតបានចម្រើនហើយ ។ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពពួកសត្ត្ব ព្រមទាំងសមណៈព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស ឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ត្រាច់រង្គាត់រកអារម្មណ៍នោះ តថាគតបានដឹងជាក់ស្តែងហើយដោយសារចិត្ត ព្រោះហេតុនោះ បានជាគេហៅថា **តថាគត**[1] ។

ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ដោយហេតុ ៨ ប្រការ ដទៃទៀត គឺព្រះនាមថា **តថាគត** ព្រោះស្តេចមកដោយប្រការនោះ ព្រះនាមថា **តថាគត** ព្រោះស្តេចទៅដោយប្រការនោះ ព្រះនាមថា **តថាគត** ព្រោះមកដល់សច្ចៈយ៉ាងនោះ ព្រះនាមថា **តថាគត** ព្រោះស្តេចទៅយ៉ាងនោះ ព្រះនាមថា **តថាគត** ព្រោះមានប្រការនោះ ព្រះនាមថា **តថាគត** ព្រោះមានការប្រព្រឹត្តទៅដោយប្រការយ៉ាងនោះ ព្រះនាមថា **តថាគត** ព្រោះត្រាស់ដោយញាណយ៉ាងនោះ ព្រះនាមថា **តថាគត** ព្រោះការៈដែលស្តេចទៅយ៉ាងនោះ ។

ព្រះនាមថា **តថាគត** ព្រោះស្តេចមកដោយប្រការនោះ ជាយ៉ាងណា? គឺព្រះដ៏មានព្រះភាគ កាលជាសុមេធតាបសបំពេញអភិនីហារ ដែលប្រកបដោយអង្គ ៨ ប្រការ ទៀបបាទមូលរបស់ព្រះទសពលព្រះនាមថា **ទីបង្ករ** ដូចដែលលោកពោលទុកយ៉ាងនេះថា

មនុស្សត្តំ លិង្គសម្បត្តិ សត្ថារទស្សនំ ហេតុ
បព្វជ្ជា គុណសម្បត្តិ អធិការោ ឆន្ទតា

១-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៦២ ទំព័រ ៥៧ ដល់ ៥៨ ។

អត្តធម្មសមោធានា អកិនីហារោ សមិជ្ឌតិ ។

និយតពោធិសត្ត ត្រូវសម្រេចដោយអកិនីហារប្រជុំដោយធម៌ទាំងឡាយ ៨ គឺជាមនុស្ស ១ ដល់ព្រមដោយភេទ ១ ដល់ព្រមដោយហេតុ ១ បានជួបព្រះ-សាស្តា ១ បព្វជ្ជា ១ ដល់ព្រមដោយគុណធម៌ ១ បុញ្ញាធិការ ១ ភាពជាអ្នកមានឆន្ទៈ ១ [១]។ ទ្រង់ប្រកាសមហាបដិញ្ញាថា តថាគតធ្វើលោក ព្រមទាំងទេវលោកបានហើយ នឹងញ៉ាំងសត្វឱ្យធ្វើ តថាគតរួចផុតហើយ នឹងញ៉ាំងសត្វឱ្យផុត តថាគតទូន្មានខ្លួនហើយ នឹងទូន្មានអ្នកដទៃ តថាគតស្ងប់ហើយ នឹងឱ្យអ្នកដទៃស្ងប់ តថាគតធូរចិត្តហើយ នឹងញ៉ាំងអ្នកដទៃឱ្យធូរចិត្ត តថាគតបរិនិព្វានហើយ នឹងញ៉ាំងអ្នកដទៃឱ្យបរិនិព្វាន តថាគតត្រាស់ដឹងហើយ នឹងញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹង ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា "តែថាប្រយោជន៍អ្វីអាត្មាអញធ្វើឱ្យជាក់ច្បាស់នូវធម៌ ដោយភេទដែលគេមិនស្គាល់ ក្នុងទីនេះ អាត្មាអញគប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញ៉ាំងលោក ព្រមទាំងទេវលោក ឱ្យរួចដោះ (ចាកសង្សារ) ។ ប្រយោជន៍អ្វីអាត្មាអញជាបុរស សម្តែងកម្ទាំងធ្វើទៅម្នាក់ឯង អាត្មាអញគួរដល់នូវសព្វញ្ញុតញ្ញាណ ចម្ងងមនុស្សលោក ព្រមទាំងទេវលោក ។ អាត្មាអញនឹងបានដល់នូវសព្វញ្ញុត-ញ្ញាណ ចម្ងងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ខ្ពស់ ។ តថាគតនឹងកាត់ខ្សែសង្សារ កម្ចាត់បង់ភពទាំង ៣ ឡើងជិះលើនាវា គឺធម៌ នឹងចម្ងងមនុស្សលោក ព្រមទាំងទេវលោក" [២] ។

---

*១-ត្រង់ភន្ទៃងនេះ មានសេចក្តីពិស្តារក្នុងសៀវភៅ **មាគ៌ាជីវិតនៃព្រះពោធិសត្ត** ទំព័រ ៩ ដល់ ២៣ ។*
២-សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវំសៈ លេខ ៧៧ ទំព័រ ៣១ ។

ក៏ព្រះដ៏មានព្រះភាគជាលោកនាថ កាលត្រាស់មហាបដិញ្ញានេះនោះ ដែលជាហេតុនៃការស្រាវជ្រាវ ការពិចារណានិងការសមាទានពួកធម៌ ធ្វើភាពជាពុទ្ធ សូម្បីទាំងអស់មិនឱ្យឃ្ងៀងឃ្ងាត ព្រោះហេតុដែលទ្រង់បំពេញព្រះបារមី ៣០ មានទានបារមីជាដើមបានមិនឱ្យសេសសល់ ជាប់តគ្នាដោយគោរព ទ្រង់បរិច្ចាគ មហាបរិច្ចាគ ៥ មានការបរិច្ចាគអវយវៈជាដើម ចម្រើនអធិដ្ឋាន ៤ មានសច្ចាធិដ្ឋានជាដើម ទ្រង់បង្កើនបុញ្ញសម្ភារៈនិងញាណសម្ភារៈ ទ្រង់ឱ្យបុព្ព-ប្រយោគ បុព្ពចរិយៈ ធម្មកថា និងញាតត្ថចរិយាជាដើមដ៏ឧក្រិដ្ឋ ញ៉ាំងពុទ្ធចរិយាឱ្យដល់ទីបំផុតយ៉ាងក្រៃលែង អស់ ៤ អសង្ខ្យេយ្យ ១ សែនមហាកប្ប ទើបសម្រេចអនុត្តរសម្មាសម្ពោធិញាណ ព្រោះដូច្នោះ មហាបដិញ្ញានោះរបស់ព្រះអង្គនោះឯង ទើបជារបស់យ៉ាងច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ការខុសរបស់ព្រះអង្គ សូម្បីត្រឹមតែប្រមាណពេមទ្រាយក៏មិនមានទេ ។ ពិតយ៉ាងនោះ ព្រះសម្មាសម្ពុទ្ធ ២៤ ព្រះអង្គទាំងនេះ គឺព្រះទីបង្ករទសពល ព្រះកោណ្ឌញ្ញៈ ព្រះមង្គលៈ ។ ល ។ ព្រះដ៏មានព្រះភាគកស្សបៈ ស្តេចឧប្បត្តិឡើងដោយលំដាប់ ទ្រង់ព្យាករថា នឹងបានជាព្រះពុទ្ធ ។ ព្រះអង្គបានទទួលព្យាករក្នុងសំណាក់របស់ព្រះពុទ្ធ ២៤ ព្រះអង្គ ដោយប្រការដូច្នេះហើយ ទ្រង់បានទទួលអានិសង្សដែលព្រះពោធិសត្វអ្នកបានបំពេញអកិនីហារ នឹងគប្បីបានទ្ទ:ឯង ស្តេចមកហើយ ព្រោះដូច្នោះ ទើបព្រះនាមថា **តថាគត** ព្រោះស្តេចមក គឺសម្រេចភាពជាអ្នកត្រាស់ដឹងក្រៃលែង ដោយមហាបដិញ្ញាតាមដែលត្រាស់ទុកនោះ ។ ព្រះនាមថា **តថាគត** ព្រោះស្តេចមកដោយប្រការនោះ ដោយប្រការដូច្នេះ ។

*ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅដោយប្រការនោះ ដូចម្តេច? គឺព្រះលោកនាថ ទ្រង់ឃើញពួកសត្វអ្នកប្រព្រឹត្តទៅដោយលំបាក ព្រោះទុក្ខធំ ទ្រង់មានព្រះមហាករុណាឱ្យអាចហ៊ានថា ពួកសត្វនោះមិនមានអ្នកណាមួយដទៃជាទីពឹង មានតែតថាគតប៉ុណ្ណោះ ផុតពីសង្សារទុក្ខនេះហើយ នឹងញ៉ាំងសត្វសត្វឱ្យផុតចាកទុក្ខដែរ ហើយទ្រង់ធ្វើមហាអភិនីហារ ។ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ដល់សេចក្តីឧស្សាហ៍ ដែលឱ្យសម្រេចប្រយោជន៍ដល់លោកទាំងអស់ តាមដែលបានធ្វើនិងបណិធានទុក ទ្រង់មិនអាល័យព្រះកាយនិងព្រះជន្មជីវិតរបស់ព្រះអង្គ ទ្រង់បំពេញទុក្ករកិរិយាដែលធ្វើបានដោយលំបាកដែលធ្វើសេចក្តីតក់ស្ទុតចិត្តឱ្យកើតឡើង ព្រោះដោយហេតុត្រឹមតែប្រាកដតាមសោតទ្វាររបស់ជនដទៃ ទ្រង់ប្រព្រឹត្តដោយប្រការដែលបដិបត្តិដើម្បីមហាពោធិ-ញ្ញាណ ដែលមិនមានហានភាគិយ: (ចំណែកនៃការលះ) សង្កិលេសភាគិយ: (ចំណែកនៃសេចក្តីសៅហ្មង) ឬឋិតិភាគិយ: (ចំណែកនៃការតាំងមាំ) ដោយពិតជាវិសេសភាគិយ:យ៉ាងកំពូលធ្នើម មែនពិត ទ្រង់សម្រេចព្រះពោធិសម្ភារ: យ៉ាងក្រៃលែងដោយលំដាប់ ទើបទ្រង់សម្រេចអភិសម្ពោធិញ្ញាណ ។ បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះមហាករុណានោះឯង ជំរុញ ដាស់តឿនទ្រង់លះសេចក្តីត្រេកអរក្នុងទីស្ងាត់ និងសេចក្តីសុខដែលកើតពីវិមោក្ខ ដែលស្ងប់ដ៏ក្រៃលែង មិនរាប់នូវប្រការដែលមិនសមរម្យ គឺលោកដ៏ច្រើនជាពាលជនឱ្យកើតឡើង ទ្រង់សម្រេចពុទ្ធកិច្ចដោយមិនឱ្យសេសសល់ ដោយការណែនាំជនដែលគួរណែនាំ ។ ក្នុងសេចក្តីនោះ អាការដែលព្រះដ៏មានព្រះភាគជាម្ចាស់ញ៉ាំងព្រះមហាករុណាចុះក្នុងពួកសត្វនោះ នឹងមានច្បាស់ខាងមុខ ។ ព្រះលោក-*

នាថជាព្រះសម្ពុទ្ធ មានព្រះមហាករុណាក្នុងសត្វទាំងឡាយយ៉ាងណា សូម្បីជាព្រះពោធិសត្វក៏ដូច្នោះ ទ្រង់មានព្រះមហាករុណាក្នុងពួកសត្វ ក្នុងកាលបំពេញមហាអភិនីហារជាដើម ព្រោះហេតុនោះ ព្រះមហាករុណារបស់ព្រះអង្គ ទើបឈ្មោះថា យ៉ាងជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះមានការៈស្មើគ្នា ក្នុងទីគ្រប់កន្លែង និងក្នុងកាលគ្រប់កាល ។ ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅ គឺប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់លោកទាំងអស់ ដោយព្រះមហាករុណាយ៉ាងជាក់ច្បាស់ មានកិច្ចនាទីស្មើគ្នា ក្នុងសព្វសត្វទាំងឡាយ សូម្បីក្នុងកាលទាំង ៣ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅ ដោយប្រការនោះ ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកដល់សច្ចៈយ៉ាងជាក់ច្បាស់ដូចម្តេច? គឺឈ្មោះថា យ៉ាងជាក់ច្បាស់ បានដល់ អរិយមគ្គ-ញ្ញាណ ៤ ។ មែនពិត អរិយមគ្គញ្ញាណទាំងនោះឈ្មោះថា យ៉ាងជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះមិនពោលលក្ខណៈនៃសភាវធម៌ ព្រមទាំងកិច្ចឱ្យឃ្លៀងឃ្លាតនៃធម៌ គឺអរិយសច្ចៈ ៤ ដែលជាបវត្តិ និវត្តិ និងហេតុទាំង ២ នោះ ជាគ្រឿងរួបរួមញ្ញេយ្យធម៌ទាំងពួងយ៉ាងនេះថា នេះទុក្ខ នេះទុក្ខសមុទយៈ នេះទុក្ខនិរោធ នេះទុក្ខនិរោធគามិនីបដិបទា និងជារិកាគរបស់អរិយសច្ចៈទាំង ៤ នោះមានជាអាទិ៍ថា **ទុក្ខសច្ចៈ** មានអត្ថថា បៀតបៀន មានអត្ថថា ជាសង្ខតៈ មានអត្ថថា ធ្វើឱ្យក្តៅក្រហាយ មានអត្ថថា ប្រែប្រួល **សមុទយសច្ចៈ** មានអត្ថថា ប្រមូលមក មានអត្ថថា ជាហេតុ មានអត្ថថា ប្រកបសត្វក្នុងភព មានអត្ថថា

*កង្វល់ **និរោធសច្ច:** មានអត្ថថា ជាហេតុរលាស់ចេញ មានអត្ថថា ស្ងាត់ មានអត្ថថា ដែលបច្ច័យអ្វីៗ តាក់តែងមិនបាន មានអត្ថថា ជាអមត: មគ្គសច្ច: មានអត្ថថា នាំសត្វចេញ (ពីទុក្ខ) មានអត្ថថា ជាហេតុ មានអត្ថថា ជាទស្សន: មានអត្ថថា ជាអធិបតី (ភាពជាធំ) ដើម្បីការប្រព្រឹត្តទៅនៃអាការដែលមិនខុសពោលគឺ ត្រាស់ដឹងដោយមិនវង្វេងក្នុងធម៌នោះ ដែលបានដោយការកាត់ផ្តាច់ធម៌ដែលជាបក្ខពួកនៃសង្កិលេស ដែលជាហេតុត្រដាងការពារការយល់ដឹងសភាវ:តាមសេចក្តីពិត ព្រះដ៏មានព្រះភាគ ព្រះអង្គមិនមានអ្នកដទៃដែលនឹងណែនាំ ទ្រង់មកដល់ គឺសម្រេចអរិយសច្ច: ៤ ទាំងនោះដោយព្រះអង្គឯងតែម្តង ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកដល់សច្ច:យ៉ាងជាក់ច្បាស់ ។*

សេចក្តីថា គប្បីជ្រាបដល់ភាវ:យ៉ាងជាក់ច្បាស់នូវព្រះញាណដែលបច្ច័យអ្វីៗ មិនប៉ះខ្ទប់ក្នុងកាលទាំង ៣ បដិសម្ភិទាញាណ ៤ វេសារជ្ជញាណ ៤ ញាណដែលកំណត់គតិ ៥ អសាធារណញាណ ៦ ញាណដែលធ្វើឱ្យជាក់ច្បាស់ក្នុងពោជ្ឈង្គ ៧ ញាណដែលជាក់ច្បាស់ក្នុងមគ្គ ៨ ញាណក្នុងអនុបុព្វវិហារសមាបត្តិ ៩ និងពលញ្ញាណ ១០ របស់ព្រះដ៏មានព្រះភាគ ជាក់ច្បាស់ដូចមគ្គ-ញ្ញាណដូច្នោះ ។

ក្នុងសេចក្តីនោះ មានសេចក្តីជាក់ច្បាស់ដូចតទៅនេះ មែនពិត គប្បីជ្រាបវត្ថុណាមួយ មិនថានឹងជាសភាវកិច្ចជាដើម សេចក្តីប្លែកគ្នាក្នុងការកំណត់ជាដើម និងនាម គោត្រដែលជាប់នឹងខន្ធជាដើម ក្នុងខន្ធ អាយតន: និងធាតុដែលជាអតីត ផ្សេងដោយប្រភេទមានហីនធម៌ជាដើម របស់សត្វទាំងឡាយប្រមាណ

មិនបាន ក្នុងលោកធាតុដែលរកប្រមាណមិនបាន ។ ញាណទាំងនេះ គឺព្រះ-ញាណរបស់ព្រះដ៏មានព្រះភាគ ដែលមិនមានបច្ច័យអ្វីៗ ជាគ្រឿងរារាំងប្រព្រឹត្ត-ទៅដោយប្រចក្សក្នុងទីទាំងពួង សេចក្ដីពិសេសនៃវណ្ណៈ សណ្ឋាន ក្លិន រស និងផស្សៈជាដើម របស់បច្ចុប្បន្នធម៌ដែលកើតព្រោះបច្ច័យនិងសេចក្ដីពិសេសនៃបច្ច័យនោះៗ ក្នុងរូបធម៌ដែលមិនជាប់ដោយឥន្ទ្រិយសូម្បីល្អិតសុខុមដ៏ក្រៃលែងដែលនៅខាងក្រៅជញ្ជាំង និងដែលនៅក្នុងទីធ្វាយដូចផ្ទៃកន្ទ្ធតព្រៃដែលនៅលើបាតដៃដូច្នោះ និងញាណដែលប្រព្រឹត្តទៅក្នុងអនាគត និងបច្ចុប្បន្នក៏ដូចគ្នា ឈ្មោះថា ញាណដែលមិនមានបច្ច័យអ្វីៗជាគ្រឿងរារាំងក្នុងកាលទាំង ៣ ។ ដូចដែលលោកពោលទុកថា ញាណរបស់ព្រះពុទ្ធមិនមានអ្វីរារាំងក្នុងអតីតកាល ញាណរបស់ព្រះពុទ្ធមិនមានអ្វីរារាំងក្នុងអនាគតកាល ញាណរបស់ព្រះពុទ្ធមិន-មានអ្វីរារាំងក្នុងបច្ចុប្បន្នកាល[1] ។ ក៏អរិយសច្ចៈ ៤ នេះ នោះឈ្មោះថា យ៉ាងជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះមិនបានត្រាស់លក្ខណៈនៃសភាវៈព្រមដោយកិច្ចនៃធម៌ក្នុងទីនោះៗ បានឱ្យឃ្លៀងឃ្លាត ព្រះដ៏មានព្រះភាគទ្រង់សម្រេចសច្ចៈ ៤ ពួកនោះ ដោយសយម្ភូញាណ ។ ព្រះនាមថា **តថាគត** ព្រោះស្ដេចដល់សច្ចៈ ៤ យ៉ាងជាក់ច្បាស់ សូម្បីដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បដិសម្ភិទា ៤ គឺ**អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិ-សម្ភិទា បដិភាណប្បដិសម្ភិទា** ។ បណ្ដាបដិសម្ភិទាទាំងឡាយ ៤ នោះ ញាណដែលដល់ការបែកធ្វាយក្នុងអត្ថ អាចធ្វើសេចក្ដីជាក់ច្បាស់ និងការកំណត់ព្រម

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧១ ទំព័រ ២៨៣ ។

លក្ខណៈនៃប្រភេទរបស់អត្ត ឈ្មោះថា ***អត្ថប្បដិសម្ភិទា*** *។ ញាណដែលដល់ការបែកធ្លាយក្នុងធម៌ អាចធ្វើសេចក្ដីជាក់ច្បាស់និងការកំណត់ព្រមលក្ខណៈនៃប្រភេទរបស់ធម៌ ឈ្មោះថា* ***ធម្មប្បដិសម្ភិទា*** *។ ញាណដែលដល់ការបែកធ្លាយក្នុងការសម្ដែងភាសា អាចធ្វើសេចក្ដីជាក់ច្បាស់ និងការកំណត់ព្រមលក្ខណៈនៃប្រភេទរបស់ភាសា ឈ្មោះថា* ***និរុត្តិប្បដិសម្ភិទា*** *។ ញាណដែលដល់ការបែកធ្លាយក្នុងបដិភាណ អាចធ្វើសេចក្ដីជាក់ច្បាស់ និងការកំណត់លក្ខណៈនៃប្រភេទរបស់បដិភាណ ឈ្មោះថា* ***បដិភាណប្បដិសម្ភិទា*** *។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា សេចក្ដីដឹងក្នុងអត្ត ឈ្មោះថា* ***អត្ថប្បដិសម្ភិទា*** *សេចក្ដីដឹងក្នុងធម៌ ឈ្មោះថា* ***ធម្មប្បដិសម្ភិទា*** *សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ត និងធម៌នោះ ឈ្មោះថា* ***និរុត្តិប្បដិសម្ភិទា*** *សេចក្ដីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា* ***បដិភាណប្បសម្ភិទា***[1] *។*

ក៏ក្នុងបដិសម្ភិទា ៤ យ៉ាងនោះ ពោលដោយសង្ខេប ផលដែលបានមកពីហេតុ ឈ្មោះថា អត្ត គឺបុគ្គលគប្បីឱ្យប្រព្រឹត្តទៅ និងគប្បីសម្រេចតាមលំអានរបស់ហេតុ ។ ក៏ប៉ុន្តែថា បើពោលដោយប្រភេទធម៌ ៥ យ៉ាងនេះ គឺបច្ចុប្បន្នធម៌ យ៉ាងណាមួយ និព្វាន អត្តនៃកាសិត វិបាក និងកិរិយា ឈ្មោះថា អត្ត ។ ញាណដែលដល់ការបែកធ្លាយក្នុងអត្តនោះ របស់អ្នកពិចារណាក្នុងអត្តនោះ ឈ្មោះថា ***អត្ថប្បដិសម្ភិទា*** *។ កាលពោលដោយសង្ខេប បច្ច័យ ឈ្មោះថា ធម៌ ។ មែនពិត បច្ច័យនោះ លោកហៅថា ធម៌ ព្រោះចាត់ចែង គឺឱ្យអត្តនោះ។ ប្រព្រឹត្ត*

១-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២០ ។

ទៅនិងឱ្យសម្រេច ។ តែបើពោលដោយប្រភេទធម៌ ៥ ប្រការនេះ គឺហេតុដែលញ៉ាំងផលឱ្យកើតឡើងយ៉ាងណាមួយ អរិយមគ្គ ពាក្យភាសិត កុសលកម្ម និងអកុសលកម្ម ឈ្មោះថា ធម៌ ។ ញាណដែលដល់ការបែកធ្លាយក្នុងធម៌នោះ របស់អ្នកពិចារណាធម៌នោះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា សេចក្តីដឹងក្នុងទុក្ខ ឈ្មោះថា **អត្ថប្បដិសម្ភិទា** សេចក្តីដឹង ក្នុងកើតឡើងនៃទុក្ខ **ធម្មប្បដិសម្ភិទា** សេចក្តីដឹងក្នុងការរលត់ទុក្ខ **អត្ថប្បដិសម្ភិទា** សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថា **ធម្មប្បដិសម្ភិទា**[1] ។

ម្យ៉ាងទៀត សេចក្តីដឹងក្នុងហេតុ ឈ្មោះថា **ធម្មប្បដិសម្ភិទា** សេចក្តីដឹងក្នុងផលរបស់ហេតុ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ ធម៌ទាំងឡាយណា កើតហើយ មានហើយ កើតព្រមហើយ កើតហើយ កើតចំពោះហើយ ប្រាកដហើយ សេចក្តីដឹងក្នុងធម៌ទាំងនេះ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ ធម៌ទាំងនោះ កើតហើយ មាន-ហើយ កើតព្រមហើយ កើតហើយ កើតចំពោះហើយ ប្រាកដហើយពីធម៌ណា សេចក្តីដឹងក្នុងធម៌ទាំងនោះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ សេចក្តីដឹងក្នុងជរានិងមរណៈ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ សេចក្តីដឹងក្នុងហេតុជាដែនកើត ជរានិងមរណៈ:ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ សេចក្តីដឹងក្នុងធម៌ជាគ្រឿងរលត់ជរានិងមរណៈ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ សេចក្តីដឹងក្នុងបដិបទាជាហេតុឱ្យរលត់ជរានិងមរណៈ:ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ សេចក្តីដឹងក្នុងជាតិ ភព ឧបាទាន តណ្ហា វេទនា ផស្ស: សឡាយតន: នាមរូប វិញ្ញាណ សង្ខារ ឈ្មោះថា

១-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២០ ។

អត្ថប្បដិសម្ភិទា ។ *សេចក្តីដឹងក្នុងហេតុជាដែនកើតសង្ខារ ឈ្មោះថា* ***ធម្មប្បដិ-សម្ភិទា*** ។ *សេចក្តីដឹងក្នុងធម៌ជាគ្រឿងរលត់សង្ខារ ឈ្មោះថា* ***អត្ថប្បដិសម្ភិទា*** ។ *សេចក្តីដឹងក្នុងបដិបទាជាហេតុឱ្យដល់សេចក្តីរលត់សង្ខារ ឈ្មោះថា* ***ធម្មប្បដិ-សម្ភិទា*** ។ *សេចក្តីពិស្តារមានជាអាទិ៍ថា ភិក្ខុក្នុងសាសនានេះ ដឹងនូវធម៌ គឺសុត្ត: គេយ្យ: ។ល។ វេទល្ល: នេះឈ្មោះថា* ***ធម្មប្បដិសម្ភិទា*** *ភិក្ខុនោះ ដឹងនូវសេចក្តីនៃភាសិតនោះ១ថា នេះសេចក្តីនៃភាសិតនេះ នេះសេចក្តីនៃភាសិតនេះ នេះឈ្មោះថា* ***អត្ថប្បដិសម្ភិទា***[១] *ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្តី ។ល។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណា១ ហើយកើតឡើង ក្នុងសម័យនោះ ផស្ស:ក៏កើតមាន ។ល។ សេចក្តីមិនរាយមាយ ក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា* ***ធម្មប្បដិសម្ភិទា*** *សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា* ***អត្ថប្បដិ-សម្ភិទា***[២] *សេចក្តីពិស្តារបណ្ឌិតគប្បីជ្រាបនៅក្នុងគម្ពីរនោះចុះ ។ ក៏សការនិរុត្តិ (ភាសាដើម) គឺអញ្ញកិចារវោហារ (ពាក្យដែលមិនឃ្លៀងឃ្លាត) អភិលាប: (ការនិយាយ) ក្នុងអត្ថនិងធម៌នេះ តាមមូលភាសារបស់សការ:សត្វដែលជាមគធ-ភាសា ក្នុងការនិយាយមូលភាសានោះ នេះឈ្មោះថា សការនិរុត្តិ នេះមិនឈ្មោះថា សការនិរុត្តិ សេចក្តីដឹងដែលដល់ការផ្សេងគ្នា ដូច្នេះ ឈ្មោះថា* ***និរុត្តិប្បដិ-សម្ភិទា*** ។ *សេចក្តីដឹងដែលដល់ការផ្សេងគ្នាក្នុងញាណនោះ របស់ភិក្ខុអ្នកពិចារណា*

១-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២៣ ។

២-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២៤ ។

ធ្វើញាណទាំងអស់នោះដែលប្រព្រឹត្តទៅ ដោយកិច្ចនៃអារម្មណ៍យ៉ាងពិស្តារ ក្នុងញាណទាំងនោះតាមដែលពោលហើយឱ្យជាអារម្មណ៍ ឈ្មោះថា **បដិភាណប្ប-ដិសម្ភិទា** ។ ព្រោះដូច្នោះ បដិសម្ភិទាញាណ ៤ ទាំងនេះ ព្រះដ៏មានព្រះភាគ ទ្រង់សម្រេចដោយព្រះអង្គឯង ទើបឈ្មោះថា យ៉ាងជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះប្រព្រឹត្តទៅដោយអាការមិនខុសប្លែក ដោយពោលមិនឱ្យឃ្លៀងឃ្លាតក្នុងអារម្មណ៍របស់ខ្លួននោះ។ ដ៏ក្រៃលែងដោយអត្ត និងធម៌ ។ ព្រះអង្គ ទ្រង់ព្រះនាមថា **តថាគត** ព្រោះមកដល់សច្ចៈយ៉ាងជាក់ច្បាស់ សូម្បីដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ធម្មជាតិឯណាមួយ ឈ្មោះថា **ញេយ្យៈ** ធម្មជាតិទាំងអស់នោះ ព្រះដ៏មានព្រះភាគទ្រង់ដឹងហើយ ទ្រង់ឃើញហើយ ទ្រង់សម្រេចហើយ ទ្រង់ត្រាស់ដឹងចំពោះហើយ ដោយអាការទាំងពួង ។ ពិតយ៉ាងនោះ ធម៌ដែលគួរដឹងក្រៃលែង ព្រះអង្គត្រាស់ដឹងហើយដោយធម៌ដែលគួរដឹងក្រៃលែង ធម៌ដែលគួរកំណត់ដឹង ព្រះអង្គត្រាស់ដឹងហើយ ដោយធម៌ជាគ្រឿងកំណត់ដឹង ធម៌ដែលគួរលះ ព្រះអង្គត្រាស់ដឹងហើយ ដោយធម៌ជាគ្រឿងលះ ធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់ ព្រះអង្គត្រាស់ដឹងហើយ ដោយធម៌ជាគ្រឿងធ្វើឱ្យជាក់ច្បាស់ ធម៌ដែលគួរចម្រើន ព្រះអង្គត្រាស់ដឹងហើយ ដោយធម៌ជាគ្រឿងចម្រើន ព្រោះបុគ្គលណាមួយ សូម្បីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី មិនអាចជំទាស់ព្រះអង្គដោយធម៌ថា ព្រះអង្គមិនទាន់បានត្រាស់ដឹងធម៌ឈ្មោះនេះ ឬធម៌នេះ ។

ធម៌ឯណាមួយ ឈ្មោះថា បហាតព្វៈ (ធម៌ទាំងអស់នោះ) ព្រះដ៏មាន-

ព្រះភាគទ្រង់លះបានហើយកៃ្ករគល់ដើមពោធិ៍នោះឯង មិនឱ្យសេសសល់ មិនមានការកើតឡើងជាធម្មតា ករណីយកិច្ចដ៏ក្រៃលែងជាងការលះធម៌ដែលគួរលះនោះមិនមាន ។ ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគនោះទ្រង់លះ កាត់ផ្តាច់ ដកនូវកិលេស ១៥០០ មានប្រភេទ គឺលោភ: ទោស: មោហ: វិបរិតមនសិការ: អហិរិក: អនោត្តប្ប: ថីនមិទ្ធ: កោធ: ឧបនាហ: មក្ខ: បលាស: ឥស្សា មច្ឆរិយ: មាយា សាឋেয্យ: ថម្ភ: សារម្ភ: មានៈ អតិមានៈ មទ: បមាទ: អកុសលមូល ៣ ទុច្ចរិត ៣ វិសម: ៣ វិបរិតសញ្ញា ៣ មល: ៣ វិតក្ក: ៣ បបញ្ច: ៣ ឯនេសនា ៣ តណ្ហា ៣ វិបរិយេស: ៤ អាសវ: ៤ គន្ថ: ៤ ឱឃ: ៤ យោគ: ៤ អគតិ ៤ តណ្ហាបាទាន ៤ អកិនន្ទ: ៥ នីវរណ: ៥ ចេតោខីល: ៥ ចេតសោ-វិនិពន្ធ: ៥ រាគទមូល ៦ អនុស័យ ៧ មិច្ឆត្ត: ៨ អាឃាតវត្ថុ ៩ តណ្ហាមូលក: ៩ អកុសលកម្មបថ ១០ អនេសន: ២១ ទិដ្ឋិ ៦២ និងតណ្ហាវិចរិត ១០៨ ជាដើម ព្រមទាំងវាសនា ព្រោះបុគ្គលណាមួយ សូម្បីសមណ:ក្តី ។ល។ ព្រហ្មក្តី មិនអាចនឹងជំទាស់ចំពោះព្រះអង្គបានដោយធម៌ថា ឈ្មោះថា កិលេសនេះព្រះអង្គមិនទាន់បានលះ ។

ក៏ធម៌ទាំងនេះឯណា មានប្រភេទ គឺកម្មវិបាក កិលេស ឧបវាទ: និងអា-ណាវិតិក្កម: ព្រះដ៏មានព្រះភាគត្រាស់ថា អន្តរាយិកធម៌ ។ ជាធម៌ឱ្យផលក្នុងលំដាប់ដោយចំណែកមួយ ដល់អ្នកសេពធម៌ទាំងនោះតែម្តង ព្រោះបុគ្គលណាមួយ សូម្បីសមណ:ក្តី ។ល។ ព្រហ្មក្តី មិនអាចនឹងជំទាស់ចំពោះព្រះអង្គបានដោយធម៌ថា មិនអាចធ្វើអន្តរាយដល់អ្នកសេពធម៌នោះ ។

ក៏និយ្យានិកធម៌ឯណាដ៏ប្រសើរ មានអរិយមគ្គជាអង្គដ៏ប្រសើរមាន ៣៧ ប្រការ ចែកជា ៧ ក្រុម រួមដោយសីល សមាធិ បញ្ញាដែលជាហេតុរលាស់ចេញ ចាកវដ្តទុក្ខបានមិនឱ្យសេសសល់ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងទុកហើយ និយ្យានិកធម៌នោះ រមែងនាំសត្វចេញចាកទុក្ខបាន ដោយមែនពិតប្រាកដ រមែងធ្វើអ្នកបដិបត្តិឱ្យផុតពីវដ្តទុក្ខបាន ដោយពិតប្រាកដ ព្រោះបុគ្គលណាមួយ សូម្បីសមណៈ ។ល។ ឬព្រហ្មក្តី មិនអាចនឹងជំទាស់ចំពោះព្រះអង្គបានដោយ ធម៌ថា ធម៌ដែលព្រះអង្គទ្រង់សម្តែងថា ជាធម៌នាំចេញចាកទុក្ខ មិននាំចេញ ចាកទុក្ខបាន ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ព្រះអង្គគ្រាន់តែ ប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងដោយប្រពៃ តែធម៌ទាំងនេះព្រះអង្គឥតបានត្រាស់ ដឹងឡើយ[1] ។ គប្បីជ្រាបសេចក្តីពិស្តារនៅក្នុងមហាសីហនាទសូត្រនោះចុះ ។ វេសារជ្ជញ្ញាណ ៤ ទាំងនេះដូចពោលមកនេះរបស់ព្រះដ៏មានព្រះភាគប្រព្រឹត្តទៅ ដោយអាការមិនខុសប្លែក ឈ្មោះថា យ៉ាងជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាង ដទៃ ព្រោះដឹងសេចក្តីពិសេសរបស់ញាណ បហានៈ និងទេសនារបស់ព្រះអង្គ ដោយភាវៈដែលមិនខុស ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះ ដល់វេសារជ្ជញ្ញាណយ៉ាងជាក់ច្បាស់ ដោយប្រការដូច្នេះ ។

គតិ ៥ គឺ**និរយគតិ តិរច្ឆានគតិ បេតគតិ មនុស្សគតិ** និង**ទេវគតិ** ។ បណ្តា គតិទាំង ៥ នោះ មហានរក ៨ មានសញ្ជីវនរកជាដើម ឧស្សុទនរក ១៦ មាន កុក្កុលនរកជាដើម និងលោកន្តរនរករួមទាំងអស់នេះ ឈ្មោះថា **នរក** ព្រោះអត្ត

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២០ ទំព័រ ២៧២ ។

ថា មិនមានសេចក្តីក្ងីថ្ងារីករាយ ដោយភាពជាទុក្ខតែម្យ៉ាង និងឈ្មោះថា **គតិ** ព្រោះដែលសត្វគប្បីទៅតាមយថាកម្ម ព្រោះដូច្នោះ ទើបឈ្មោះថា **និរយគតិ** ។ សូម្បីនរកដែលងងឹតឈឹងនិងត្រជាក់ទីបំផុត ក៏រាប់ចូលក្នុងនិរយគតិដូចគ្នា ។ សត្វទាំងឡាយមានដង្កូវ សត្វល្អិត ពស់ សត្វ ឆ្កែស្រុក ចចកជាដើម ឈ្មោះថា **តិរច្ឆាន** ព្រោះទៅដោយទទឹង គតិ គឺសត្វតិរច្ឆានទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **តិរច្ឆានគតិ** ។ ឈ្មោះថា **ប្រេត** មានបរទត្តុបជីវិកប្រេត និងនិជ្ឌាមតណ្ហិកប្រេតជាដើម ព្រោះជាអ្នកមានសេចក្តីស្រេកឃ្ងាន និងសេចក្តីក្តៅក្រហាយគ្របសង្កត់ ឈ្មោះថា ទៅ គឺប្រាសចាកសេចក្តីសុខដែលល្អក្រៃលែង ព្រោះច្រើនដោយសេចក្តីទុក្ខ ព្រោះហេតុនោះ ទើបឈ្មោះថា ប្រេតគតិ គឺប្រេតទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **ឃេតគតិ** ។ សូម្បីពួកអសុរ មានកាលកញ្ជិកអសុរជាដើម ក៏រាប់ចូលក្នុងឃេតគតិដូចគ្នា ។ អ្នកជម្ពូទ្វីប និងអ្នកមហាទ្វីបទាំង ៤ ព្រមទាំងអ្នកទ្វីបតូចៗ ឈ្មោះថា មនុស្ស ព្រោះជាអ្នកមានចិត្តខ្ពស់ គតិ គឺមនុស្សទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **មនុស្សគតិ** ។ ពួកទេវតា ២៦ ជាន់ទាំងនេះ គឺរាប់តាំងពីជាន់ចាតុម្មហារាជិការហូតដល់នេវសញ្ញានាសញ្ញាយតនឈាន រមែងលេងផង រុងរឿងផងដោយអានុភាពឫទ្ធិរបស់ខ្លួន ព្រោះហេតុនោះ ទើបឈ្មោះថា **ទេវគតិ** គឺទេវតាទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **ទេវគតិ** ។

ក៏គតិទាំងនោះ ព្រោះហេតុសេចក្តីវិសេសនៃឧប្បត្តិភពដែលកើតពីកម្មនោះៗ ដូច្នោះ កាលពោលអំពីអត្ត បានដល់ វិបាកខន្ធ និងកម្មជ្ជរូប ។ បណ្តាគតិទាំងនោះ ញាណរបស់ព្រះដ៏មានព្រះភាគ រមែងប្រព្រឹត្តទៅដោយឋានៈ

ដោយហេតុ ដោយការកំណត់វិភាគហេតុ និងផលដែលកើតពីហេតុតាមឋានៈ
របស់ខ្លួនថា ធម្មតាថា គតិនេះ រមែងកើតពីកម្មឈ្មោះនេះ និងពួកសត្វទាំងនេះ
រមែងផ្សេងគ្នាយ៉ាងនេះជាផ្នែកៗ ព្រោះផ្សេងគ្នាដោយវិភាគយ៉ាងនេះ ដោយ
បច្ច័យពិសេសនៃកម្មនោះ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់
ពាក្យមានជាអាទិ៍ថា ម្នាលសារីបុត្ត គតិនេះមាន ៥ ប្រការ គតិ ៥ ប្រការតើដូច-
ម្តេច គឺនរក ១ កំណើតតិរច្ឆាន ១ បិត្តិវិស័យ ១ ពួកមនុស្ស ១ ពួកទេវតា ១ ។
ម្នាលសារីបុត្ត តថាគតស្គាល់នរកផង ស្គាល់ផ្លូវជាទីទៅកាន់នរកផង ស្គាល់
សេចក្តីប្រតិបត្តិជាទីទៅកាន់នរកផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ លុះបែក-
ធ្លាយរាងការខាងមុខ អំពីសេចក្តីស្លាប់ទៅរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត
នរក តថាគតស្គាល់ច្បាស់នូវប្រតិបត្តិនោះផង[1] ។ ក៏ញាណរបស់ព្រះដ៏មាន
ព្រះភាគទាំងនេះ នោះឈ្មោះថា យ៉ាងជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាង
ដទៃ ព្រោះត្រាស់ដល់ការប្រព្រឹត្តទៅនៃអាការដែលមិនខុសប្លែកក្នុងវិស័យនោះៗ
មិនឱ្យឃ្លៀងឃ្លាត ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះមក
ដល់ញាណទាំងនោះ យ៉ាងជាក់ច្បាស់ សូម្បីដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត **ឥន្ទ្រិយបរោបរិយត្តញ្ញាណ** របស់ព្រះដ៏មានព្រះភាគ ដែល
ប្រព្រឹត្តទៅដោយអាការ ៥០ ដែលជាហេតុជាក់ច្បាស់ដោយពិសេសនៃសេចក្តី
ដែលសត្វមានកិលេសដូចធូលីក្នុងកែវភ្នែកតិច និងភាពនៃសត្វអ្នកមានកិលេស
ដូចធូលីក្នុងកែវភ្នែកច្រើន ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា បុគ្គលដែល

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២០ ទំព័រ ២៧៨ ដល់ ២៧៩ ។

មានសទ្ធា ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក បុគ្គលដែលឥតសទ្ធា ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក[1] *។*

អាសយានុសយញ្ញាណរបស់ព្រះដ៏មានព្រះភាគ ប្រព្រឹត្តទៅដោយអាការ ជាក់ច្បាស់តាមសេចក្តីពិតនៃអាសយៈ គឺសេចក្តីប្រាថ្នាជាដើម របស់សត្វទាំង-ឡាយ ដោយន័យមានជាអាទិ៍ថា បុគ្គលនេះមានកិលេសដូចធូលីក្នុងភ្នែកតិច បុគ្គលនេះមានលទ្ធិជាសស្សតទិដ្ឋិ បុគ្គលនេះមានលទ្ធិជាឧច្ឆេទទិដ្ឋិ បុគ្គលនេះ តាំងនៅក្នុងអនុលោមខន្តិ បុគ្គលនេះតាំងនៅក្នុងយថាភូតញ្ញាណ បុគ្គលនេះ មានកាមាសយៈ និងមិនមាននេក្ខម្មាសយៈជាដើម បុគ្គលនេះមានអធ្យាស្ស័យ ក្នុងនេក្ខម្ម: មិនមានអធ្យាស្ស័យក្នុងកាមជាដើម និងដោយន័យមានជាអាទិ៍ថា កាមរាគ:របស់បុគ្គលនេះមានកម្លាំងខ្លាំងក្លា តែមិនមានបដិឃ: បដិឃ:របស់ បុគ្គលនេះមានកម្លាំងខ្លាំងក្លា តែមិនមានកាមរាគ:ជាដើម និងដោយន័យមាន ជាអាទិ៍ថា បុញ្ញាភិសង្ខារបុគ្គលនេះក្រៃលែង តែមិនមានអបុញ្ញាភិសង្ខារ និងអនេញ្ជាភិសង្ខារ អបុញ្ញាភិសង្ខារបុគ្គលនេះក្រៃលែង តែមិនមានបុញ្ញា-ភិសង្ខារ មិនមានអនេញ្ជាភិសង្ខារ អនេញ្ជាភិសង្ខារបុគ្គលនេះក្រៃលែង តែមិនមានបុញ្ញាភិសង្ខារ មិនមានអបុញ្ញាភិសង្ខារ កាយសុចរិត វចីសុចរិត និង មនោសុចរិតរបស់បុគ្គលនេះក្រៃលែង បុគ្គលនេះមានអធិមុត្តិអាក្រក់ បុគ្គលនេះ មានអធិមុត្តិប្រណីត បុគ្គលនេះប្រកបដោយកម្មាវរណៈ (ហាមកម្ម) បុគ្គលនេះ ប្រកបដោយកិលេសាវរណៈ (ហាមកិលេស) បុគ្គលនេះប្រកបដោយវិបាកាវរណៈ

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ២៧២ ។

មិនប្រកបដោយវិបាការណ: ដែលព្រះអង្គសំដៅយកការត្រាស់ទុកថា ព្រះ-តថាគតជ្រាបនូវអាសយធម៌ ជ្រាបនូវអនុសយធម៌ ជ្រាបនូវចរិត ជ្រាបនូវអធ្យា-ស្រ័យរបស់សត្វទាំងឡាយ ជ្រាបនូវពួកសត្វដែលមានក័ព្ទ និងឥតក័ព្ទក្នុងលោកនេះ (ញាណបែបនេះ ឈ្មោះថា សត្ថាសយានុសយញ្ញាណរបស់ព្រះតថាគត)[១] ដូច្នេះជាដើម ។

ម្យ៉ាងទៀត យមកឫទ្ធិដ្ឋានរិយញ្ញាណរបស់ព្រះដ៏មានព្រះភាគ ដែលជាហេតុនិមិត្តឫទ្ធិដែលធ្វើអាការផ្សេងៗ គ្នា មិនទូទៅដល់បុគ្គលដទៃដែលធ្វើគំនរភ្លើង និងផ្ទារទឹកឱ្យប្រព្រឹត្តទៅតាមកាយខាងលើ ខាងក្រោម និងខាងមុខ ខាងក្រោយ តាមព្រះនេত্রខាងស្តាំ ខាងធ្វេង ប្រហោងព្រះកាណ៌(ត្រចៀក) ផ្នែកខាងស្តាំ ផ្នែកខាងធ្វេង ប្រហោងព្រះនាសិក:(ច្រមុះ) ផ្នែកខាងស្តាំ ផ្នែកខាងធ្វេង នឹងចង្ហួយព្រះអង្ករ:(ស្មា) ផ្នែកខាងស្តាំផ្នែកខាងធ្វេង ព្រះហស្តខាងស្តាំ ខាងធ្វេង និងព្រះបាទផ្នែកខាងស្តាំ ខាងធ្វេង និងចន្ទោះម្រាមដៃចុះក្រោម និងចន្ទោះរណ្តៅព្រះលោមា ។ ពាក្យនេះព្រះដ៏មានព្រះភាគត្រាស់ទុកថា ព្រះ-តថាគតទ្រង់ធ្វើយមកឫទ្ធិដ្ឋានៈ ដែលមិនទូទៅដល់ពួកសាវ័កក្នុងលោកនេះ គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ផ្ទារទឹកចេញអំពីព្រះកាយខាងក្រោម គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម ផ្ទារទឹកចេញអំពីព្រះកាយខាងលើ[២] ដូច្នេះជាដើម ។

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ២៧៦ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ២៨០ ដល់ ២៨១ ។

ម្យ៉ាងទៀត ព្រះមហាករុណាសមាបត្តិញ្ញាណ ដែលជាបច្ច័យឱ្យព្រះដ៏មានព្រះភាគ ផ្សាយព្រះមហាករុណា ដែលប្រព្រឹត្តទៅដោយន័យផ្សេងៗ ដោយសេចក្តី ដែលព្រះអង្គទ្រង់ប្រាជ្ញា នឹងនាំពួកសត្វអ្នកត្រូវទុក្ខធម៌ជាអនេកមានរាគៈជាដើម និងមានជាតិជាដើមរុកកួន ឱ្យចេញចាកទុក្ខធម៌ទាំងនោះ ដូចដែលព្រះដ៏មាន-ព្រះភាគត្រាស់ទុកថា កាលព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញដោយ អាការច្រើន មហាករុណារមែងចុះស៊ីប់ក្នុងពួកសត្វ គឺកាលព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញថា លោកសន្និវាសត្រូវភ្លើងឆេះសព្វ ហើយមហាករុណាចុះស៊ីប់ក្នុង ពួកសត្វ កាលព្រះមានព្រះភាគទ្រង់ឃើញថា លោកសន្និវាស មានសេចក្តីខ្វល់-ខ្វាយ(ជានិច្ច) ។ល។ ថា លោកសន្និវាសមានដំណើរទៅ(ជានិច្ច) ។ល។ ព្រះសម្ពុទ្ធ-មានព្រះភាគទ្រង់ឃើញថា លោកសន្និវាស ដើរទៅកាន់ផ្លូវខុស មហាករុណា ក៏ចុះស៊ីប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា សត្វលោកមិន ទៀង ត្រូវជរានាំចូលទៅ (រកសេចក្តីស្លាប់) មហាករុណា ក៏ចុះស៊ីប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា សត្វលោកឥតមានទីពឹង ឥតមានទីផ្នែក មហាករុណា ក៏ចុះស៊ីប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញថា សត្វលោកគ្មានអ្វីជារបស់ខ្លួន ត្រូវលះចោលរបស់ទាំងអស់ហើយទៅ មហាករុណា ក៏ចុះស៊ីប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា សត្វលោកមាន សេចក្តីខ្វះខាត មិនឆ្អែត ជាទាសៈនៃតណ្ហា មហាករុណាក៏ចុះស៊ីប់ក្នុងពួកសត្វ កាលព្រះពុទ្ធទ្រង់ឃើញថា លោកសន្និវាស ឥតទីពឹង ។ល។ កាលទ្រង់ឃើញថា លោកសន្និវាស ឥតទីពួន ។ល។ ទ្រង់ឃើញថា លោកសន្និវាសឥតទីរឭក ។ល។ ទ្រង់ ឃើញថា លោកសន្និវាសមិនមានវត្ថុជាទីរឭក ។ល។ ទ្រង់ឃើញថា សត្វ

លោកកំពុងរវើរវាយមិនសូប់រម្ងាប់ ។ល។ ទ្រង់ឃើញថា លោកសន្និវាស ប្រកប ដោយសរមុតហើយ ដោយសរផ្សេងៗ បុគ្គលដទៃនីមួយ ក្រៅពីតថាគត នឹងដកសររបស់លោកសន្និវាសនោះមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាស មានងងឹត គឺអវិជ្ជា ជាគ្រឿងពាំង ធ្លាក់ចុះក្នុងទ្រុង គឺកិលេស បុគ្គលដទៃនីមួយ ជាអ្នកបង្ហាញនូវពន្លឺ ដល់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាស លុះក្នុងអំណាចអវិជ្ជា ជាអ្នកងងឹតងងល់ ត្រូវអវិជ្ជារួបរឹត សាំញ្ជាំដូចអំបោះនៃជាងតម្បាញ ស្មុគ្រស្មាញដូចអម្បោះដែលជាងតម្បាញ ប្រឡាក់ដោយទឹកបាយ ដូចស្មៅយាឫង និងស្មៅដំណេកទន្សាយ មិនប្រព្រឹត្តកន្ទងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ ទ្រង់ឃើញថា លោកសន្និវាសជាប់ដោយទោស គឺពិសនៃអវិជ្ជា ប្រកបដោយកំហុស គឺកិលេស ទ្រង់ឃើញថា លោកសន្និវាស ត្រូវរាគៈ ទោសៈ មោហៈ ចាក់ស្រែះហើយ បុគ្គលដទៃនីមួយ ជាអ្នកដោះនូវបណ្ដាញរបស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាស ស៊ីកចុះក្នុងឃ្នាប គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ត្រូវខ្សែតណ្ហាបន្សាត់ទៅហើយ ទ្រង់ឃើញថា លោក-សន្និវាសប្រកបហើយដោយចំណង គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ត្រាំនៅក្នុងតម្រាំ គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាសក្ដៅដោយកម្ដៅ គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ក្ដៅក្រហាយដោយសេចក្ដីក្ដៅក្រហាយ គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ស៊ីកចុះក្នុងឃ្នាប គឺទិដ្ឋិ ទ្រង់ឃើញថា លោក-សន្និវាស ត្រូវបណ្ដាញ គឺទិដ្ឋិរួបរឹតហើយ ទ្រង់ឃើញថា លោកសន្និវាស ប្រកប

ដោយគ្រឿងប្រកប គឺទិដ្ថិ ទ្រង់ឃើញថា លោកសន្ទិវាស ត្រាំនៅក្នុងតម្រាំ គឺទិដ្ថិ ទ្រង់ឃើញថា លោកសន្ទិវាសក្តៅដោយកំដៅគឺទិដ្ថិ ទ្រង់ឃើញថា លោកសន្ទិវាស ក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយ គឺទិដ្ថិ ទ្រង់ឃើញថា លោកសន្ទិវាស ប្រកបដោយជាតិជានិច្ច ។ល។ ទ្រង់ឃើញថា លោកសន្ទិវាស ត្រាំក្នុងជរា ។ល។ ទ្រង់ឃើញថា លោកសន្ទិវាស ត្រូវព្យាធិ គ្រប់សង្កត់ហើយ ។ល។ ទ្រង់ឃើញថា លោកសន្ទិវាស ត្រូវមរណៈបៀតបៀន ។ល។ ទ្រង់ឃើញថា លោកសន្ទិវាស មានទុក្ខធ្លាក់ត្រូវហើយ ទ្រង់ឃើញថា លោកសន្ទិវាសត្រូវតណ្ហាទាក់ជាប់ហើយ ទ្រង់ឃើញថា លោកសន្ទិវាសស្រោបហើយដោយកំពែង គឺជរា ទ្រង់ឃើញថា លោកសន្ទិវាសត្រូវអន្ទាក់ គឺមច្ចុរីតរួត ទ្រង់ឃើញថា លោកសន្ទិវាស ជាប់ដោយចំណងច្រើន គឺចំណងរាគៈ ចំណងទោសៈ ចំណងមោហៈ ចំណងមានៈ ចំណងទិដ្ថិ ចំណងកិលេស ចំណងទុច្ចរិត បុគ្គលដទៃនីមួយ ជាអ្នកស្រាយនូវចំណងរបស់លោកសន្ទិវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្ទិវាស ដើរទៅកាន់ទីចង្អៀតខ្លាំង បុគ្គលដទៃនីមួយ ជាអ្នកបង្ហាញនូវពន្ធឹដល់លោកសន្ទិវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្ទិវាស មានកង្វល់ ដោយកង្វល់ច្រើន បុគ្គលដទៃនីមួយ ជាអ្នកកាត់នូវកង្វល់របស់លោកសន្ទិវាសនោះ ក្រៅពីតថាគតមិនមានឡើយ ។ល។ ទ្រង់ឃើញថា លោកសន្ទិវាស ធ្លាក់ចុះក្នុងជ្រោះធំ បុគ្គលដទៃនីមួយ ជាអ្នកស្រង់លោកសន្ទិវាសនោះ ឱ្យរួចពីជ្រោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្ទិវាស ដើរទៅកាន់ផ្លូវលំបាកខ្លាំង បុគ្គលដទៃនីមួយ ជាអ្នកចម្ងង លោកសន្ទិវាសនោះ ឱ្យទ្ងង់ផ្លូវលំបាក ក្រៅពីតថាគតមិនមានឡើយ

ទ្រង់ឃើញថា លោកសន្និវាសដើរទៅក្នុងមហាសង្ឃរ បុគ្គលដទៃនីមួយ ជាអ្នកស្រាយ លោកសន្និវាសនោះឱ្យរួចចាកសង្ឃរ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសរិលវល់នៅក្នុងផ្ទៃកម្រខ្ទាំង បុគ្គលដទៃនីមួយ ជាអ្នកស្រង់លោកសន្និវាសនោះ ឱ្យរួចចាកផ្ទៃកម្រ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសលិចចុះក្នុងល្បាប់ជ្រៅ ត្រូវភ្ជើង គឺរាគ: ភ្ជើង គឺទោស: ភ្ជើង គឺមោហ: នឹងជាតិ ជរា មរណ: សោក: បរិទេវ: ទុក្ខ: ទោមនស្ស: ឧបាយាស: ញ៉ាំញ៉ីហើយ បុគ្គលដទៃនីមួយ ជាអ្នកលត់ភ្ជើងរបស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសអណ្តែតឡើង ឥតមានទីពឹងជានិច្ច មានអាជ្ញាត្រូវហើយ ធ្វើតាមតែអាជ្ញានោះ រមែងលំបាក ទ្រង់ឃើញថា លោកសន្និវាសជាប់ចំណងវដ្ត: ប្រាកដក្នុងទីសម្រាប់សម្ងាប់ បុគ្គលដទៃនីមួយ ជាអ្នកស្រាយចំណងឱ្យដល់លោកសន្និវាស នោះ ក្រៅពីតថាគត មិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសឥត មានទីពំនាក់ដល់នៅភាពគួរអាណិតក្រៃពេក បុគ្គលដទៃនីមួយ ជាអ្នកជួយស្រោចស្រង់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ។ល។ ទ្រង់ឃើញថា លោក-សន្និវាសត្រូវសេចក្ដីទុក្ខចាក់ដោតហើយ ត្រូវសេចក្ដីទុក្ខបៀតបៀន ហើយអស់កាលយូរ ទ្រង់ឃើញថា លោកសន្និវាសជាប់ចំពាក់ជានិច្ច ស្រេកឃ្ងានជានិច្ច ។ល។ ទ្រង់ឃើញថា លោកសន្និវាស ខ្វាក់ ឥតមានចក្ខុ ទ្រង់ឃើញថា លោកសន្និវាស មានភ្នែកវិនាសហើយ ឥតមានអ្នកដឹកដៃ ទ្រង់ឃើញថា លោកសន្និវាស ស្ទុះទៅកាន់ផ្លូវខុស ដើរខុសផ្លូវ បុគ្គលដទៃនីមួយ ជាអ្នកនាំ

លោកសន្ទិវាសនោះ ឱ្យដើរទៅ កាន់ផ្លូវដ៏ប្រសើរ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្ទិវាសសុះទៅក្នុងជំនន់ធំ បុគ្គលដទៃទីមួយ ជាអ្នកស្រង់នូវលោកសន្ទិវាសនោះអំពីជំនន់ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្ទិវាស ត្រូវទិដ្ឋិទាំងពីររួបរឹត ទ្រង់ឃើញថា លោកសន្ទិវាស ប្រតិបត្តិខុសព្រោះទុច្ចរិត ទាំង ៣ ទ្រង់ឃើញថា លោកសន្ទិវាសពេញ ដោយយោគធម៌ ប្រកបដោយយោគធម៌ទាំង ៤ ទ្រង់ឃើញថា លោកសន្ទិវាស ចាក់ស្រែះហើយ ដោយគណ្ឋកិលេសទាំង ៤ ទ្រង់ឃើញថា លោកសន្ទិវាសប្រកាន់មាំដោយ ឧបាទានទាំង ៤ ទ្រង់ឃើញថា លោកសន្ទិវាសឡើងកាន់គតិទាំង ៥ ទ្រង់ឃើញថា លោកសន្ទិវាសរមែងត្រេកអរដោយកាមគុណទាំង ៥ ទ្រង់ឃើញថា លោកសន្ទិវាសត្រូវនីវរណៈទាំង ៥ គ្របសង្កត់ហើយ ទ្រង់ឃើញថា លោក-សន្ទិវាសរមែងវិវាទ ដោយវិវាទមូលទាំង ៦ ទ្រង់ឃើញថា លោកសន្ទិវាស រមែងត្រេកអរដោយតណ្ហា កាយទាំង ៦ ទ្រង់ឃើញថា លោកសន្ទិវាសត្រូវទិដ្ឋិទាំង ៦ រួបរឹតហើយ ទ្រង់ឃើញថា លោកសន្ទិវាស ត្រាំនៅហើយដោយតម្រាំទាំង ៧ ទ្រង់ឃើញថា លោកសន្ទិវាសប្រកបហើយដោយសញ្ញោជនៈទាំង ៧ ទ្រង់ឃើញថា លោកសន្ទិវាស ប៉ោងឡើងហើយដោយមានៈទាំង ៧ ទ្រង់ឃើញថា លោកសន្ទិវាសវិលវល់ តាមលោកធម៌ទាំង ៨ ទ្រង់ឃើញថា លោកសន្ទិវាស ទៀងដោយមិច្ឆត្តធម៌ទាំង ៨ ទ្រង់ឃើញថា លោកសន្ទិវាសរមែងប្រទូស្ត ដោយទោសសម្រាប់បុរស ៨ ទ្រង់ឃើញថា លោកសន្ទិវាសប៉ោងឡើង ហើយដោយមានៈទាំង ៩ ទ្រង់ឃើញថា លោកសន្ទិវាសរមែងត្រេកអរ ដោយតណ្ហាមូលក-ធម៌ទាំង ៩ ទ្រង់ឃើញថា លោកសន្ទិវាសសៅហ្មង ដោយកិលេសវត្ថុទាំង ១០

ទ្រង់ឃើញថា លោកសន្និវាសចង់គំនុំដោយអឃាតវត្ថុទាំង ១០ ទ្រង់ ឃើញថា លោកសន្និវាសប្រកបព្រមហើយ ដោយអកុសលកម្មបថទាំង ១០ ទ្រង់ឃើញ ថា លោកសន្និវាសប្រកបដោយសញ្ញោជនៈទាំង ១០ ទ្រង់ឃើញថា លោក-សន្និវាសទៀងដោយមិច្ឆត្តធម៌ទាំង ១០ ទ្រង់ឃើញថា លោកសន្និវាសប្រកប ហើយដោយមិច្ឆាទិដ្ឋិមានវត្ថុ ១០ ទ្រង់ឃើញថា លោកសន្និវាសប្រកបហើយ ដោយសក្កាយទិដ្ឋិមានវត្ថុ ១០ ព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញថា លោកសន្និវាសត្រូវបបញ្ចធម៌ គឺតណ្ហាទាំង ១០៨ ឱ្យយឺតយូរហើយ មហា-ករុណាក៏ចុះស៊ប់ក្នុងពួកសត្ត្ব ព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញថា លោកសន្និវាស ត្រូវទិដ្ឋិទាំង ៦២ រួបរឹតហើយ មហាករុណា ក៏ចុះស៊ប់ក្នុងពួក សត្ត្ব ព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញថា តថាគតធ្ងង់រួចហើយ ឯ សត្ត្ববលោក មិនទាន់ធ្ងង់នៅឡើយ តថាគតរួចហើយ ឯសត្ត្ববលោកមិនទាន់រួចនៅ ឡើយ តថាគតហ្វឹកហ្ចឹនហើយ ឯសត្ត្ববលោកមិនទាន់ហ្វឹកហ្ចឹននៅឡើយ តថាគត សូប់ហើយ ឯសត្ត្ববលោកមិនទាន់សូប់នៅឡើយ តថាគតសប្បាយចិត្តហើយ ឯសត្ត្ব លោកមិនទាន់សប្បាយចិត្តនៅឡើយ តថាគតរលត់កិលេសហើយ ឯសត្ត្ববលោក មិនទាន់រលត់កិលេសនៅឡើយ តថាគតធ្ងង់ហើយ ដើម្បីចម្ងង (សត្ត្ববលោក) តថាគតរួចហើយ ដើម្បីញ៉ាំងសត្ត្ববលោកឱ្យរួចតថាគត ហ្វឹកហ្ចឹនហើយ ដើម្បី ហ្វឹកហ្ចឹនសត្ត្ববលោក តថាគតសូប់រម្ងាប់ហើយ ដើម្បីញ៉ាំងសត្ត្ব លោកឱ្យសូប់-រម្ងាប់ តថាគតសប្បាយចិត្តហើយ ដើម្បីញ៉ាំងសត្ត្ববលោកឱ្យសប្បាយចិត្តតថាគត រលត់កិលេសហើយ ដើម្បីញ៉ាំងសត្ត្ববលោក ឱ្យរលត់កិលេស មហាករុណា ក៏ចុះ

ស៊ីប់ ក្នុងពួកសត្ត្ব នេះឈ្មោះថា មហាករុណាសមាបត្តិញ្ញាណរបស់ព្រះតថាគត[1] ។

*ក៏ញាណណារបស់ព្រះដ៏មានព្រះភាគ មានប្រមាណប៉ុនណា ដែលនឹងគប្បីដឹងដោយធម្មធាតុមានប្រមាណប៉ុនណា មិនប្រាថ្នាដល់ការអាងអ្នកដទៃ អាចត្រាស់ដឹងធម៌ទាំងពួងទាំងដែលជាសង្ខ្ត: និងអសង្ខ្ត:ជាដើម ដោយអាការទាំងពួង មិនទូទៅដល់អ្នកដទៃ ដែលប្រព្រឹត្តទៅជាប់ដោយហេតុត្រឹមតែសេចក្ដីប្រាថ្នា ឈ្មោះថា **សព្ពញ្ញុតញ្ញាណ** ព្រោះយល់ដឹងសង្ខ្ត-ធម៌ អសង្ខ្ត្ធធម៌ សម្មតិនិងសច្ច:បានដោយមិនឱ្យសេសសល់ ដោយប្រការទាំងពួង លោកហៅថា អនាវរណញ្ញាណ ព្រោះកាន់យកការប្រព្រឹត្តទៅដែលមិនជំទាស់ដោយមិនមានគ្រឿងត្រដាងការពារក្នុងញ្ញាណនោះ ។ ក៏ញ្ញាណនោះតែម្យ៉ាងប៉ុណ្ណោះ លោកសម្ដែងទុកដល់ ២ យ៉ាង ដើម្បីសម្ដែងការ:ដែលមិនទូទៅនឹងញ្ញាណដទៃ ដោយការប្រព្រឹត្តទៅនៃអារម្មណ៍ជាប្រធាន ។ កាលពោលអំពីប្រការដទៃ សព្ពញ្ញុតញ្ញាណនិងអនាវរណញ្ញាណទូទៅ និងមានធម៌ទាំងអស់ជាអារម្មណ៍ និងពាក្យនោះមិនត្រូវដោយយុតិនេះក៏ពិត ទោះជាយ៉ាងនោះ ក្នុងទីនេះមានព្រះបាលីដូចតទៅនេះ*

ព្រះតថាគត ជ្រាបទ្រង់សង្ខ្ត្ធធម៌និងអសង្ខ្ត្ធធម៌ទាំងអស់ មិនមានសេស-សល់ ហេតុនោះ ឈ្មោះថា សព្ពញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញ្ញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្ពន្ទ្ធ ហេតុជាអនាគត ហេតុនោះ ឈ្មោះថា សព្ពញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញ្ញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគត

១-សុត្តន្ដបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ២៨៣ ដល់ ២៩៣ ។

ទ្រង់ជ្រាបសព្វនូវហេតុជាអតីត: ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគត ទ្រង់ជ្រាបសព្វនូវហេតុជាបច្ចុប្បន្ន ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ[1] ព្រោះសេចក្តីជំទាស់មិនមានក្នុងញាណនោះ ។ សេចក្តីពិស្តារបណ្ឌិតគប្បីជ្រាបនៅក្នុងគម្ពីរនោះចុះ ។

អសាធារណញ្ញាណទាំងឡាយ ៦ នេះ របស់ព្រះដ៏មានព្រះភាគ ឈ្មោះថា យ៉ាងជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះមិនពោលអារម្មណ៍របស់ខ្លួនឱ្យឃ្លៀងឃ្លាតដោយប្រព្រឹត្តទៅតាមអាការដែលមិនខុសប្លែក ដោយប្រការដូច្នេះ ព្រោះហេតុនេះ ព្រះដ៏មានព្រះភាគទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះមកដល់ញាណយ៉ាងជាក់ច្បាស់ ។

ម្យ៉ាងទៀត ព្រះញាណដែលប្រកាសសម្ពោជ្ឈង្គរបស់ព្រះដ៏មានព្រះភាគដែលប្រព្រឹត្តទៅដោយអាការផ្សេងៗ យ៉ាងនេះថា ពោលដោយសរុបយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គនេះ មាន ៧ ពោជ្ឈង្គ ៧ តើដូចម្តេច សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១[2] កាលពោលដោយសាមញ្ញលក្ខណៈយ៉ាងនេះថា ធម្មសាមគ្គីនេះណា ផ្សេងដោយសតិជាដើមដែលជាបដិបក្ខចំពោះឧបទ្រវៈច្រើនប្រការ មានការកើតឡើងនូវសេចក្តីរួញរា

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ២៩៣ ដល់ ២៩៤ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧១ ទំព័រ ៦៤ ។

សេចក្តីរវើរវាយ ការប្រកាន់មាំកាមសុខល្វិកានុយោគ អត្តកិលមថានុយោគ និង ការប្រកាន់មាំដោយឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិ ដែលកើតក្នុងខណៈនៃលោកុត្តរ-មគ្គ ព្រះអរិយសាវកមានមានភ្ជាក់ គឺរមែងក្រោកឡើងពីកិលេសនិទ្រា[1] ឬដឹងច្បាស់សច្ច: ៤ ធ្វើឱ្យច្បាស់ចំពោះព្រះនិព្វាន ដោយធម្មសាមគ្គីណា ធម្មសាមគ្គីនោះ លោកហៅថា **ពោធិ** *។ ឈ្មោះថា* **ពោជ្ឌង្គ** *ព្រោះជាអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងនោះ ម្យ៉ាងទៀត ព្រះអរិយសាវកលោកហៅថា* **ពោធិ** *ព្រោះធ្វើអត្ត-វិគ្រោះថា ត្រាស់ដឹងដោយធម្មសាមគ្គីដូចដែលពោលហើយ ឈ្មោះថា* **ពោជ្ឌង្គ** *ព្រោះជាអង្គនៃព្រះអរិយសាវកអ្នកត្រាស់ដឹងធម៌សាមគ្គីនោះ ។ កាលពោលអំពីលក្ខណៈពិសេសយ៉ាងនេះថា* **សតិសម្ពោជ្ឌង្គ** *មានការប្រាកដជាលក្ខណៈ* **ធម្មវិចយសម្ពោជ្ឌង្គ** *មានការយកចិត្តទុកដាក់ជាលក្ខណៈ* **វិរិយសម្ពោជ្ឌង្គ** *មានការផ្គងទុកជាលក្ខណៈ* **ปีติสម្ពោជ្ឌង្គ** *មានការផ្សាយទៅជាលក្ខណៈ* **ปัสสัทธิสម្ពោជ្ឌង្គ** *មានសេចក្តីស្ងប់ជាលក្ខណៈ* **សមាธิสម្ពោជ្ឌង្គ** *មានសេចក្តីមិនរវើរវាយជាលក្ខណៈ* **ឧបេក្ខាสម្ពោជ្ឌង្គ** *មានការពិចារណាជាលក្ខណៈ ។*

កាលពោលដោយការសម្តែងការប្រព្រឹត្តទៅក្នុងខណៈតែមួយ ជាមួយគ្នា ដោយអំណាចឧបការៈដល់គ្នានឹងគ្នានៃសម្ពោជ្ឌង្គ ដោយន័យមានជាអាទិ៍ថា បណ្តាពោជ្ឌង្គទាំងនោះ សតិសម្ពោជ្ឌង្គ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាខ្ជាប់ខ្ជួនដ៏ប្រសើរ ជាអ្នករឭក

១-និទ្រា និត-ទ្រា សំ. ឋា. (ន.) (និទ្ទា) ដំណើរដេកលក់ ។ ខ្មែរយើងប្រើជា ក. ក៏មាន : កំពុងនិទ្រា គឺកំពុងដេកលក់; ច្រើនប្រើក្ងាយជា និទ្រ្ទា គួរកុំប្រើ ។

(វចនានុក្រមខ្មែរ សម្តេចព្រះសង្ឆរាជ **ជោតញ្ញាណោ** *ជួន ណាត)*

សម្រាប់ជាធម្មទាន

នឹងឃើញនូវអំពើដែលខ្លួន ឬអ្នកដទៃធ្វើហើយ អស់កាលយូរក្តី នូវពាក្យដែលខ្លួន ឬអ្នកដទៃនិយាយហើយ អស់កាលយូរក្តី[១] កាលពោលដោយការសម្តែងការប្រព្រឹត្តទៅ ដោយការចែកអារម្មណ៍នៃពោជ្ឌង្គ្គទាំងនោះ ដោយន័យមានអាទិ៍ថា បណ្តាសម្ពោជ្ឌង្គ្គទាំងនោះ សតិសម្ពោជ្ឌង្គ្គ តើដូចម្តេច ។ សតិក្នុងធម៌ទាំងឡាយ ខាងក្នុងក៏មាន សតិក្នុងធម៌ទាំងឡាយ ខាងក្រៅក៏មាន[២] ។ កាលពោលដោយវិធីការនាដោយន័យមានជាអាទិ៍ថា បណ្តាសម្ពោជ្ឌង្គ្គទាំងនោះ សតិសម្ពោជ្ឌង្គ្គ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើនទូវសម្ពោជ្ឌង្គ្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវនិរោធជាគ្រឿងឈមទៅកាន់ការលះ[៣] កាលពោលដោយវិភាគន័យ ៩៦.០០០ ន័យ ដោយន័យមានជាអាទិ៍ថា បណ្តាធម៌ទាំងនោះ ពោជ្ឌង្គ្គ ៧ តើដូចម្តេច ។ ក្នុងសម្ងយណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឌាន ។ល។ ក្នុងសម្ងយនោះ ពោជ្ឌង្គ្គ ៧ យ៉ាង គឺសតិសម្ពោជ្ឌង្គ្គ ១ ។ល។ ឧបេក្ខាសម្ពោជ្ឌង្គ្គ ១ ក៏កើតមាន ។ បណ្តាសម្ពោជ្ឌង្គ្គទាំងនោះ សតិសម្ពោជ្ឌង្គ្គ តើដូចម្តេច ។ ការរឭក ការនឹកឃើញ[៤] ឈ្មោះថា ជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះមិនពោលអត្ថនោះ។

១-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២០៩ ។

២-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២១០ ។

៣-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២១២ ។

៤-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២១២ ដល់ ២១៥ ។

ឱ្យឃ្លៀងឃ្លាត ព្រោះហេតុនេះ ព្រះដ៏មានព្រះភាគទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះមកដល់ញាណដែលជាក់ច្បាស់ ។

ម្យ៉ាងទៀត ញាណដែលធ្វើអរិយមគ្គឱ្យជាក់ច្បាស់របស់ព្រះដ៏មានព្រះភាគដែលប្រព្រឹត្តទៅដោយអាការច្រើនណាស់យ៉ាងនេះថា កាលពោលដោយសរុបយ៉ាងនេះថា បណ្តាអរិយសច្ចៈទាំង ៤ នោះ ទុក្ខនិរោគាមិនីបដិបទាអរិយសច្ចៈ តើដូចម្តេច ។ មគ្គដ៏ប្រសើរមានអង្គ ៨ ប្រការនេះឯង ។ មគ្គដ៏ប្រសើរមានអង្គ ៨ ប្រការ តើដូចម្តេច ។ សម្មាទិដ្ឋិ សម្មាសង្កប្ប: សម្មាវាចា សម្មាកម្មន្ត: សម្មាអាជីវ: សម្មាវាយាម: សម្មាសតិ សម្មាសមាធិ[១] ។ កាលពោលដោយសាមញ្ញលក្ខណៈយ៉ាងនេះថា ឈ្មោះថា **អរិយ:** ព្រោះឆ្ងាយចាកសព្វកិលេស ព្រោះធ្វើភាពជាព្រះអរិយ: និងព្រោះឱ្យបានអរិយផល ឈ្មោះថា មានអង្គ ៨ ព្រោះមាន ៨ យ៉ាង និងព្រោះជាហេតុឱ្យសម្រេចព្រះនិព្វានដោយចំណែកតែមួយ ឈ្មោះថា **មគ្គ** ព្រោះសម្ងាប់កិលេសដល់ព្រះនិព្វាន ឬអ្នកត្រូវការព្រះនិព្វានហើយស្វែងរក ឬខ្លួនឯងស្វែងរកព្រះនិព្វាន កាលពោលដោយលក្ខណៈពិសេសយ៉ាងនេះថា **សម្មាទិដ្ឋិ** មានការឃើញត្រូវជាលក្ខណៈ **សម្មាសង្កប្ប:** មានការលើកធម៌ឡើងជាលក្ខណៈ **សម្មាវាចា** មានការកំណត់ត្រូវជាលក្ខណៈ **សម្មាកម្មន្ត:** មានការតាំងឡើងត្រូវជាលក្ខណៈ **សម្មាអាជីវ:** មានភាពផូរផង់ត្រូវជាលក្ខណៈ **សម្មាវាយាម:** មានការផ្គងទុកត្រូវជាលក្ខណៈ **សម្មាសតិ** មានការចូលទៅតាំងមាំត្រូវជាលក្ខណៈ **សម្មាសមាធិ** មានការមិនរវើរវាយដោយប្រពៃ

១-អភិធម្មបិដក វិភង្គ លេខ ៨០ ទំព័រ ២០៨ ។

ជាលក្ខណៈ[១] កាលពោលដោយការចែកកិច្ចយ៉ាងនេះថា សម្មាទិដ្ឋិ លះមិច្ឆា-ទិដ្ឋិ នឹងកិលេសយ៉ាងដទៃដែលជាសត្រូវដល់ខ្លួនធ្វើព្រះនិព្វានឱ្យជាអារម្មណ៍ និងឃើញសម្បយុត្តធម៌ដោយមិនវង្វេងភ្ជាប ព្រោះកម្ចាត់មោហៈដែលបិទបាំងព្រះនិព្វាននោះ ម្យ៉ាងទៀត សូម្បីសម្មាសង្កប្ប: ក៏លះមិច្ឆាសង្កប្ប:ជាដើម ធ្វើព្រះនិព្វានឱ្យជាអារម្មណ៍ និងធ្វើការលើកសម្បយុត្តធម៌ឡើងកាន់អារម្មណ៍ដោយប្រពៃ ការកំណត់ ការឧស្សាហ៍ ការផ្ទរផង់ ការផ្ដង ការប្រាកដ និងការតាំងមាំនៃសហជាតធម៌ ។ កាលពោលដោយវិភាគការប្រព្រឹត្តទៅ ក្នុងចំណែកខាងដើម និងចំណែកខាងចុងយ៉ាងនេះថា សម្មាទិដ្ឋិមានខណៈផ្សេងៗ គ្នា ក្នុងខាងដើមមានទុក្ខជាដើមជាអារម្មណ៍ជាផ្នែកៗ ក្នុងខណៈមគ្គ ចិត្តមានខណៈតែមួយ ធ្វើព្រះនិព្វាននោះឯងឱ្យជាអារម្មណ៍ ពោលដោយកិច្ចមានឈ្មោះ ៤ យ៉ាង មានជាអាទិ៍ថា សេចក្ដីដឹងក្នុងទុក្ខ សូម្បីសម្មាសង្កប្ប:ជាដើមក៏មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នាក្នុងខាងដើម ក្នុងខណៈមគ្គ ចិត្តមានខណៈតែមួយ មានអារម្មណ៍តែមួយ ។

បណ្ដាធម៌ទាំងនោះ ពោលដោយកិច្ច សម្មាសង្កប្ប:មានឈ្មោះ ៣ យ៉ាង មាននេក្ខម្មសង្កប្ប:ជាដើម[២]ធម៌ ៣ យ៉ាងមានសម្មាវាចាជាដើម ក្នុងខាងដើមជាវិរតិក៏មាន ជាចេតនាក៏មាន ព្រោះមានវិភាគថា **មុសាវាទា វេរមណី** ជាដើម

១-សទ្ធម្មប្បកាសិនី អដ្ឋកថា បដិសម្ភិទាមគ្គ ភាគ ១ ទំព័រ ៥២៧ ដល់ ៥២៨ ។

២-នេក្ខម្មសង្កប្ប:ចែកចេញជា ៣ ប្រភេទ គឺ**នេក្ខម្មសង្កប្ប:** ត្រិះរិះចេញចាកកាម ១ **អព្យាបាទ-សង្កប្ប:** ត្រិះរិះក្នុងការមិនចង់គំនុំ ១ **អវិហិំសាសង្កប្ប:** ត្រិះរិះក្នុងការមិនបៀតបៀនអ្នកដទៃ ១ ។

ក្នុងខណៈមគ្គជាវិតិតែម្យ៉ាង សម្មាវាយាមៈ និងសម្មាសតិ ពោលដោយកិច្ច មានឈ្មោះ ៤ យ៉ាង គឺដោយអំណាចសម្មប្បធាន ៤ សតិប្បដ្ឋាន ៤ ។ ចំណែកសម្មាសមាធិ សូម្បីក្នុងខណៈមគ្គក៏មានសេចក្ដីផ្សេងគ្នា ដោយអំណាចឈាន មានបឋមជ្ឈានជាដើម ។ ពោលដោយវិធីភាវនា ដោយន័យមានជាអាទិ៍ថា ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាទិដ្ឋិដែលអាស្រ័យវិវេក[១]ពោលដោយចែកន័យ ៨៤.០០០ ន័យ ដោយន័យមានជាអាទិ៍ថា បណ្ដាធម៌ទាំងនោះ មគ្គមានអង្គ ៨ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនទ្ធូរលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់ទ្ធូរការមិនសន្សំ (ទ្ធូរកិលេសវដ្ដ:) ដើម្បីលះទ្ធូរទិដ្ឋិទាំងឡាយ ដើម្បីដល់ទ្ធូរបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ល។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។ល។ សម្មាសមាធិ ក៏កើតមាន[២] ។ ញាណសូម្បីទាំងអស់នោះ ឈ្មោះថា ជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះមិនពោលអត្ថឱ្យ ឃ្ជៀងឃ្ជាត ព្រោះហេតុនេះ ព្រះដ៏មានព្រះភាគទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចមកដល់ញាណដែលជាក់ច្បាស់ ។

ម្យ៉ាងទៀត ញាណរបស់ព្រះដ៏មានព្រះភាគដែលប្រព្រឹត្តទៅក្នុងអនុ-បុព្វវិហារសមាបត្តិ ដោយអត្ថថា គប្បីចម្រើន និងដោយអត្ថថា គប្បីចូលតាមលំដាប់ទាំងនោះ គឺបឋមជ្ឈានសមាបត្តិ និងនិរោធសមាបត្តិ ដោយអំណាចការ

(ស្រង់ចាកគម្ពីរអភិធម្មត្ថវិភាវនីដីកា ទំព័រ ២១៨)

១-អភិធម្មបិដក វិភង្គ លេខ ៨២ ទំព័រ ២០៩ ។

២-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២៣០ ។

ឱ្យសម្រេចនិងការពិចារណាជាដើម និងដោយការប្រកបគ្នាតាមគួរ ឈ្មោះថា ជាក់ច្បាស់ មិនខុសមិនក្លាយជាយ៉ាងដទៃ ព្រោះសម្រេចប្រយោជន៍ពីញាណ នោះ ។ ម្យ៉ាងទៀត ទសពលញ្ញាណរបស់ព្រះដ៏មានព្រះភាគទាំងនេះ គឺការ ដឹងហេតុ និងមិនមែនហេតុនៃផលនោះ ដែលមិនខុសប្លែកដូច្នេះថា នេះជា ឋានៈរបស់ផលនេះ នេះមិនមែនឋានៈរបស់ផលនេះ ១ ការដឹងលំដាប់នៃវិបាក តាមសេចក្ដីពិតដោយមិនឱ្យសេសសល់ នៃការប្រកាន់កម្មដែលផ្សេងដោយ ប្រភេទជាកាល មានអតីតកាលជាដើមរបស់ពួកសត្វនោះ ១ ការដឹងដល់កម្ម និងការចែកកម្មទាំងដែលមានអាសវៈ និងមិនមានអាសវៈតាមសេចក្ដីពិតថា នេះបដិបទាជាគ្រឿងនាំសត្វទៅកាន់នរក ។ល។ នេះបដិបទាជាគ្រឿងនាំសត្វ ទៅកាន់ព្រះនិព្វានរបស់សត្វនោះ ក្នុងខណៈដែលសត្វសន្សំនូវកម្មនុ៎ះឯង ១ សេចក្ដីដឹងភាពផ្សេងគ្នានៃធាតុតាមសេចក្ដីពិត ដោយន័យមានជាអាទិ៍ថា ព្រោះ ធាតុឈ្មោះនេះក្រាស់ សូម្បីសេចក្ដីពិសេសនេះទើបកើតក្នុងកាលជាប់ទាក់-ទងនឹងធម៌នេះរបស់លោកនោះ ដែលសភាវៈនៃខន្ធ និងអាយតនៈជាអនេក ទាំងដែលជាឧបាទិន្នកៈ និងអនុបាទិន្នកៈជាដើម និងមានសភាវៈផ្សេងៗ គ្នា ១ ការដឹងដល់អជ្ឈាស្រ័យ និងអធិមុត្តិដ៏អាក្រក់ជាដើមរបស់សត្វទាំងឡាយ ដោយមិនឱ្យសេសសល់ ១ ការដឹងឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើមថា ចាស់ក្លា ឬទន់ខ្សោយ ១ ការដឹងនូវសេចក្ដីពិសេសរបស់ឈាន និងវិមោក្ខជាដើម ព្រម នឹងសង្គ្រិលេសជាដើម ១ ការដឹងសេចក្ដីបន្តនៃខន្ធ ដែលសត្វធ្លាប់នៅអាស្រ័យ ក្នុងកាលមុនដោយមិនឱ្យសេសសល់ ព្រមដោយការជាប់ទាក់ទងដោយខន្ធនោះ

ក្នុងជាតិដែលរកប្រមាណមិនបានរបស់សត្វទាំងឡាយ ១ ការដឹងចុតិ និងបដិសន្ធិ ព្រមនឹងការចែកសត្វមានសភាពអាក្រក់ជាដើម ១ ការដឹងសច្ច: ៤ ដោយន័យដូចពោលហើយក្នុងកាលមុន ដោយន័យមានជាអាទិ៍ថា នេះទុក្ខ ១ ឈ្មោះថាជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះប្រព្រឹត្តទៅតាមសេចក្ដីពិត ដោយយល់ដឹងដល់អារម្មណ៍តាមដែលជារបស់ខ្លួនដោយមិនខុសភ្លាត់ និងដោយញ៉ាំងប្រយោជន៍តាមដែលប្រាថ្នាឱ្យសម្រេច ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតក្នុងលោកនេះ រមែងជ្រាបច្បាស់នូវហេតុតាមហេតុផង ជ្រាបច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ដោយសេចក្ដីជាក់លាក់[1] ។ ព្រោះហេតុនេះ ព្រះដ៏មានព្រះភាគទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះមកដល់ញាណដែលជាក់ច្បាស់ ។

ក៏ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះមកដល់ គឺសម្រេចញាណដែលជាក់ច្បាស់ ដោយអំណាចបញ្ញាពិសេសដែលមិនទូទៅដល់អ្នកដទៃ មានប្រភេទរកទីបំផុតមិនបាន និងរកប្រមាណមិនបាន មានញាណជាគ្រឿងធ្វើ សេចក្ដីជាក់ច្បាស់នូវសតិប្បដ្ឋាន និងសម្មប្បធានតាមដែលពោលមកហើយ ដូចទ្រង់សម្រេចដោយអំណាចញាណទាំងនេះ ព្រោះហេតុនេះ ព្រះអង្គ ទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះមកដល់ញាណដែលជាក់ច្បាស់ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចទៅដោយជាក់ច្បាស់ ដូចម្ដេច? គឺការប្រសូត ការត្រាស់ដឹង ការបញ្ញត្តិព្រះធម៌ វិន័យ និង

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទព័រ ៧៤ ។

អនុបាទិសេសនិព្វានធាតុនោះណារបស់ព្រះដ៏មានព្រះភាគនោះ ជាការជាក់ច្បាស់ ។ លោកអធិប្បាយទុកយ៉ាងណា? អធិប្បាយទុកថា ការត្រាស់ដឹងដែលព្រះលោកនាថទ្រង់ប្រាជ្ញាហើយ និងឱ្យប្រព្រឹត្តទៅហើយដើម្បីប្រយោជន៍ណា ឈ្មោះថា ជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះឱ្យសម្រេចប្រយោជន៍នោះដោយចំណែកតែមួយ ព្រោះមិនពោលប្រយោជន៍នោះឱ្យឃ្យៀង-ឃ្លាត ព្រោះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដែលមិនខុសប្លែក ។ ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគនេះ កាលជាព្រះពោធិសត្វទ្រង់បំពេញហេតុកាពជាព្រះពុទ្ធទាំងពួង មានប្រកេទដូចពោលហើយ មានការបំពេញបារមី ៣០ ជាដើម ទ្រង់តាំងនៅក្នុងសួគ៌ជាន់តុសិត ទ្រង់ស្តាប់ពុទ្ធកោលាហលដែលទេវតាក្នុងម៉ឺនចក្ក-វាឡប្រជុំព្រមគ្នាចូលទៅគាល់ទូលអាពធនាថា

ការណោយំ តេ មហាវីរ ឧប្ផុជ្ជ មាតុកុច្ឆិយំ
សទេវកំ តារយន្តោ ពុជ្ឈិស្ស អមតំ បទំ ។

បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះគួរដល់ព្រះអង្គហើយ សូមព្រះអង្គទ្រង់កើតក្នុងផ្ទៃនៃព្រះមាតា ចម្ងងមនុស្សលោក ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះ អមត:[1] ។

ព្រះបរមសត្វទ្រង់កើតបុព្វនិមិត្តឡើង ត្រួតមើលមហាវិលោកន: ៥ ប្រការ ទ្រង់មានព្រះតម្រិះថា ឥឡូវនេះ អាត្មាអញនឹងឧប្បត្តិក្នុងកំណើតមនុស្សលោក ហើយត្រាស់ដឹងក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ទ្រង់ចុះចាប់បដិសន្ធិក្នុងព្រះគភ៌របស់

១-សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវង្ស លេខ ៣៣ ទំព័រ ១៨ ។

ព្រះមហាមាយាទេវី ក្នុងសក្យរាជត្រកូល ដែលទេវតា និងមនុស្សថែរក្សាដោយការថែរក្សាយ៉ាងធំក្រៃលែងរហូតអស់ ១០ ខែ ក្នុងវេលាបច្ចូសម័យវិសាខបុណ្ណមី ទើបទ្រង់ប្រសូត ។

ក៏ក្នុងខណៈដែលព្រះអង្គប្រសូត មានកើតបុព្វនិមិត្ត ៣២ ប្រការ ។ គឺផែនដីកម្រើកញាប់ញ័រ ហើយមានរស្មីពេញលោកធាតុ ១ ក្នុងលោកន្តរ-មហានរកដែលធ្លាប់តែ-ងងឹតជានិច្ចត្រឡប់ជាភ្លឺ ១ មនុស្សភ្នែកខ្វាក់ បែរជាមើលឃើញរូបវត្ថុផ្សេងៗ មនុស្សត្រចៀកថ្លង់ បានឮសំឡេង មនុស្សគនិយាយបាន មនុស្សខ្នងគម បែរជាលាត្រង់បាន មនុស្សខ្វិនដើររួច ១ សត្វទាំងឡាយ ដែលត្រូវគុក ច្រវាក់ខ្នោះឃ្នាងបែរជារួចចេញបាន ១ ភ្លើងក្នុងនរកទាំងឡាយ មានអវិចីនរកជាដើមបែរជារលត់ ១ សេចក្ដីស្រេកឃ្លានក្នុងបេតវិស័យរំងាប់ ១ ទ្វារនិងបង្ហួច ដែលបិទ បើកចេញឯង ១ សំពៅ និងទូកទាំងឡាយ ដែលលឿនទៅក្នុងទិសផ្សេងៗ ក៏ទៅដល់កំពង់ដែលគេប្រាថ្នានឹងទៅនោះ ១ ភ័យនៃសត្វតិរច្ឆានទាំងឡាយមិនមានក្នុងខណៈនោះ ១ ពោគនៃសត្វទាំងឡាយរំងាប់ ១ សត្វដែលមានពៀរនឹងគ្នា មានមេត្តាចិត្តដល់គ្នា ១ សត្វទាំងឡាយនិយាយសំដីជាទីស្រឡាញ់ដល់គ្នា ១ ហ្វូងសេះទាំងឡាយបន្ទឺសំឡេងរកគ្នា ១ ហ្វូងដំរីបន្ទឺសំឡេងគឹកកង ១ តូរ្យតន្ត្រីទាំងអស់បន្ទឺសូរសំឡេងឯង ១ គ្រឿងអាភរណៈរបស់មនុស្សទាំងឡាយ មានពន្ធឺភ្ងឺឡើងទង្គិចគ្នាបន្ទឺសំឡេងប្រាកដ ១ ទិសទាំងឡាយភ្ងឺ ១ ខ្យល់ព្យុះធំ មិនមានបក់ផាត់ ១ ខ្យល់បក់តិចៗ ល្មមត្រជាក់សុខដល់សត្វទាំង-ឡាយ បង្កើតមានឡើង ១ អាកាសមេឃបណ្ដាលឱ្យភ្ងៀងធ្លាក់ ១ ទរទឹកទម្លាយផ្ទៃដីផុសឡើង មកហូរទៅក្នុងទីទាំងពួង ១ ហ្វូងសត្វស្លាបទាំងឡាយ លែងហើរ

ទៅក្នុងអាកាស ចុះមកដើរក្នុងភូមិភាគ ១ ខ្សែទឹកក្នុងស្ទឹងមិនបានហូរ នៅនឹងប្តល់ដូចទឹកក្នុងស្រះ ១ ទឹកប្រៃក្នុងមហាសមុទ្រប្រែជាផ្អែម ១ ផ្កាឈូកមានពណ៌ ៥ ទាំងអស់ កើតមានដេរដាសទៅក្នុងសមុទ្រ ស្ទឹង និងផ្ទៃផែនដី ១ ផ្កាដែលកើតក្នុងទឹក លើគោកវ៉ែកទាំងអស់ ១ ព្រឹក្សាលតាវល្លិ៍ទាំងឡាយ កើតជាផ្កាឈូកចេញតាមដើម មែក និងទង ១ ឈូកទាំងឡាយសុទ្ធតែមានដើមទម្ងាយផែនឋ ផុសឡើងមក មួយកន្ទែងមានផ្កា ៧ៗ គ្រប់ឋទាំងអស់ ផ្កាឈូកទាំងឡាយ កើតប្រាកដសំយុតចុះ មកពីលើអាកាស ១ រុក្ខជាតិទាំងឡាយដែលជាឈើមានផ្កានិងផ្លែ ក៏ផ្កាផ្លែក្នុងខណៈនោះទាំងអស់ ១ ក្ងៀងផ្ការ៉ាទិព្ធ មានផ្ការ៉ាមន្ទារបុស្សជាដើមធ្លាក់ចុះមកក្នុងទីទាំងពួងដោយជុំវិញ ១ តូរ្យតន្ត្រីបន្ទឺសំឡេងឡើងឯង ក្នុងអាកាស ១ រៀបទង់ជ័យទិព្ធ មានប្រាកដពេញទូទៅដូចគ្នាទាំងមួយម៉ឺនលោកធាតុ មានពណ៌ និងពន្ធឺក្ងឺអស្ចារ្យ ១ ត្រូវជាបុព្ធនិមិត្ត ៣២ ប្រការដូច្នេះ ក៏បុព្ធនិមិត្តទាំងនោះ បានជានិមិត្តរបស់អ្នកសម្រេចធម៌ពិសេសអនេក ដែលសម្រេចធម៌ជាន់ខ្ពស់ ។ ការកើតចំពោះនេះ ប្រជាប់ដោយសេចក្តីប្រាកដ ដែលគួរអស្ចារ្យច្រើនណាស់យ៉ាងនេះឯង ដែលជាប្រយោជន៍ ដែលព្រះអង្គទ្រង់តាំងនៅដោយបានឈ្មោះថា ជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះសម្រេចយ៉ាងមែនពិត នៃអភិសម្ពោធិញ្ញាណនោះ ។

ម្យ៉ាងទៀត សត្វពួកណា ជាពុទ្ធវនេយ្យ ជាផៅពង្សនៃសត្វអ្នកនឹងត្រាស់ដឹងទាំងអស់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ណែនាំដោយព្រះអង្គឯង មិនឱ្យសេសសល់ ។ ចំណែកសត្វពួកណា ជាសាវកវនេយ្យ និងជាធម្មវនេយ្យ-

សត្វសូម្បីទាំងនោះ ដែលសាវកជាដើមណែនាំហើយ រមែងនាំ គឺនាំទៅដោយ វិសេស ។ ដើម្បីប្រយោជន៍ណា ព្រះដ៏មានព្រះភាគទ្រង់ប្រាថ្នាចំពោះអភិសម្ពោ-ធិញ្ញាណ ព្រោះឱ្យប្រយោជន៍នោះសម្រេចដោយពិតប្រាកដ អភិសម្ពោធិញ្ញាណ ទើបជាគុណ ជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ។

ម្យ៉ាងទៀត សភាវៈណាៗ នៃញេយ្យធម៌ណាៗ ដែលសត្វគប្បីត្រាស់ដឹង សភាវៈនោះៗ ដែលព្រះដ៏មានព្រះភាគត្រាស់ដឹងក្រៃលែងហើយ ដោយមិនឱ្យ សេសសល់ មិនខុសប្លែក ដោយញាណរបស់ព្រះអង្គ ជាប់ដោយហេតុត្រឹមតែ ទ្រង់រំពឹងដល់ ដូចផ្ទៃកន្ទួតព្រៃដែលជាក់លើបាតដៃ ព្រោះហេតុនេះ អភិសម្ពោ-ធិញ្ញាណ (របស់ព្រះអង្គ) ទើបឈ្មោះថា ជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាង ដទៃ ។ ម្យ៉ាងទៀត កាលព្រះដ៏មានព្រះភាគទ្រង់ប្រមើលប្រការនៃធម៌ទាំងនោះ ដែលនឹងគប្បីសម្តែងដោយប្រការនោះៗ និងអធ្យាស្ស័យ អនុស័យ ចរិយា និងអធិមុត្តិរបស់សត្វនោះៗ ដោយប្រពៃតែម្តង ទាំងទ្រង់មិនលះធម្មតា មិន កន្ទងហួសន័យនៃបញ្ញត្ត និងហេតុត្រឹមតែបញ្ញត្ត ធ្វើធម្មតាឱ្យជាក់ច្បាស់ និង ទ្រង់អនុសាសន៍នូវសេចក្តីខុសតាមអធ្យាស្ស័យ និងតាមធម៌ ទើបទ្រង់ណែនាំ វេនេយ្យសត្វឱ្យសម្រេចអរិយភូមិខ្លួនឯង ។ សូម្បីការទ្រង់បញ្ញត្តព្រះធម៌វិន័យ របស់ព្រះអង្គ ក៏ឈ្មោះថា ជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះ ប្រយោជន៍នោះសម្រេច និងប្រព្រឹត្តទៅតាមសេចក្តីពិត ។ ម្យ៉ាងទៀត អមត-មហានិព្វានធាតុ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្រេចហើយដោយលំដាប់ ដែល រួចផុតពីសភាវៈនៃរូប មានបឋវីធាតុជាដើម និងសភាវៈនៃអរូប មានផស្សៈ និងវេទនាជាដើម ឈ្មោះថា កន្ទងចេញពីសភាវៈនៃលោក ព្រោះមិនមាន ភាវៈ

គឺសេចក្ដីបញ្ឆោតបន្ទំ ឈ្មោះថា មិនមានបច្ច័យអ្វីៗ ធ្វើឱ្យកើ ព្រោះប្រាសចាកភាពងងឹត ឈ្មោះថា ប្រាសចាកការៈនៃគតិជាដើម ព្រោះមិនមានឱកាសកើស្ងាងនុ៎ះឯង មិនមានទីតាំងអាស្រ័យ មិនមានអារម្មណ៍ លោកហៅថា អនុបាទិសេស ព្រោះឧបាទិពោលគឺ ខន្ធ សូម្បីតិចតួចក៏មិនមាន សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះរមែងមានពិតដីមិនមាន ទឹកមិនមាន ភ្លើងមិនមាន ខ្យល់មិនមាន អាកាសានញ្ចាយនៈមិនមាន វិញ្ញាណានញ្ចាយនៈមិនមាន អាកិញ្ចញ្ញាយតនៈមិនមាន នេវសញ្ញានាសញ្ញាយតនៈមិនមាន លោកនេះមិនមាន លោកមុខមិនមាន ព្រះចន្ទនឹងព្រះអាទិត្យទាំងពីរក៏មិនមាន ក្នុងព្រះនិព្វានណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលព្រះនិព្វាននោះថា មិនមានដំណើរមក មិនមានដំណើរទៅ មិនមានការតាំងនៅ មិនមានការច្យុតិ មិនមានការកើត មិនមានទី ជាទីតាំង មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍ ព្រះនិព្វាននោះ ជាទីបំផុតនៃទុក្ខតែម្យ៉ាង[1]" ដូច្នេះ ។ អមតមហានិព្វានធាតុនោះ ដល់ការរលត់សូន្យនៃឧបាទានខន្ធសូម្បីទាំងអស់ ជាសការៈសូប់ចាកសង្ខារទាំងពួង ជាសការៈលះបង់នូវឧបធិទាំងពួង ជាទីសូប់ទុក្ខទាំងពួង ជាទីដកសេចក្ដីអាល័យទាំងពួង ជាទីដាច់នៃវដ្ដៈទាំងពួង មានសេចក្ដីសូប់តែម្យ៉ាងជាលក្ខណៈ ព្រោះដូច្នោះ អមតមហានិព្វានធាតុនោះ ទើបឈ្មោះថា ជាក់ច្បាស់ មិនខុស មិនក្លាយជាយ៉ាងដទៃ ព្រោះមិនពោលសការៈតាមសេចក្ដីពិតឱ្យឃ្យៀងឃ្ងាត ក្នុងកាលណាៗ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចទៅ

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ៣២០ ដល់ ៣២១ ។

ស្តេចចូលដល់ សម្រេចដំណើរទៅ ស្តេចយាងជាក់ពិត ដល់អមតមហានិព្វានធាតុ នោះមានអតិជាតិជាដើម ដោយប្រការដូច្នេះ ។ ព្រោះហេតុយ៉ាងនេះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅដោយជាក់ច្បាស់ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះមានសេចក្តីជាក់ច្បាស់ ដូចម្តេច គឺព្រះសម្មាសម្ពុទ្ធទាំងឡាយ ក្នុងកាលមុនមានប្រការយ៉ាងណា ព្រះដ៏មានព្រះភាគសូម្បីអង្គនេះក៏មានប្រការយ៉ាងនោះ លោកពោលអធិប្បាយទុកយ៉ាងណា ដោយសង្ខេប លោកពោលទុកដូច្នេះ ព្រះដ៏មានព្រះភាគទាំងនោះ មានប្រការយ៉ាងណា គឺមានប្រការដោយមគ្គសីល ផលសីល លោកិយលោកុ-ត្តរសីល សូម្បីទាំងមគ្គសមាធិ ផលសមាធិ និងលោកិយលោកុត្តរសមាធិ ទាំងពួង ដោយមគ្គបញ្ញា ផលបញ្ញា លោកិយលោកុត្តរបញ្ញា សូម្បីទាំងពួង ដោយសមាបត្តិវិហារ ២៨០០០០ កោដិ ដែលទ្រង់ប្រើប្រចាំថ្ងៃ ដោយតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិដូច្នេះ តែកាលពោលដោយពិស្តារដោយគុណនៃព្រះសព្វញ្ញូទាំងអស់ ដែលមានអានុភាពជាអចិន្ត្យ ផ្សេងដោយគុណរកទីបំផុតមិនបាន រកប្រមាណមិនបាន ព្រះដ៏មានព្រះភាគ របស់ពួកយើងសូម្បីអង្គនេះ ក៏មានប្រការជាយ៉ាងនោះ ។ សេចក្តីពិត ព្រះសម្មា-សម្ពុទ្ធទាំងពួង គប្បីមានសេចក្តីផ្សេងគ្នា ៥ ប្រការទាំងនេះ គឺសេចក្តីផ្សេងនៃអាយុ ១ សេចក្តីផ្សេងប្រមាណនៃព្រះសរីរៈ ១ សេចក្តីផ្សេងនៃត្រកូល ១ សេចក្តីផ្សេងនៃការបំពេញទុក្ករកិរិយា ១ សេចក្តីផ្សេងនៃព្រះរស្មី ១ ។ តែក្នុងវិសុទ្ធិមានសីលវិសុទ្ធិជាដើម ក្នុងការបដិបត្តិសមថៈ និងវិបស្សនា និងក្នុងព្រះគុណដែលព្រះអង្គបានចំពោះ មិនមានហេតុអ្វីដែលធ្វើឱ្យផ្សេងគ្នាឡើយ ។ ដោយពិតព្រះពុទ្ធ-

មានព្រះភាគទាំងនោះ មិនពិសេសជាងគ្នានិងគ្នា ដូចមាសដែលកាច់បំបាក់ត្រង់កណ្តាលទេ ។ ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធក្នុងកាលមុនមានប្រការយ៉ាងណា ព្រះដ៏មានព្រះភាគ (របស់យើង) សូម្បីព្រះអង្គនេះ ក៏មានប្រការជាយ៉ាងនោះ ព្រោះហេតុយ៉ាងនេះ ព្រះអង្គទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះមានប្រការយ៉ាងនោះ ។ ក៏ក្នុងទីនេះ **គត**-ស័ព្ទ មាន**វិធ**-ស័ព្ទជាអត្ថ ។ ពិតយ៉ាងនោះ លោកពោល**គត**-ស័ព្ទ ដែលប្រកបដោយ**វិធ**-ស័ព្ទ មានប្រការជាអត្ថ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះប្រព្រឹត្តទៅដោយប្រការនោះ ដូចម្តេច? គឺព្រះអង្គព្រះនាមថា **តថាគត** ព្រោះមានការប្រព្រឹត្តទៅតាមកាយ វាចា និងចិត្ត ដែលយាងទៅ ជាទីយាងទៅ ជាការស្តេចទៅដោយប្រការតាមដែលពេញព្រះទ័យ ព្រោះមិនមានសេចក្តីប៉ះទង្គិច ក្នុងអ្វីៗ នៃការប្រព្រឹត្តទៅតាមកាយជាដើមរបស់ព្រះដ៏មានព្រះភាគ ហេតុដែលព្រះអង្គទ្រង់ប្រកបដោយឥទ្ធានុភាព ដែលមិនទូទៅដល់អ្នកដទៃ ហេតុសម្រេចព្រះបារមីយ៉ាងឧក្រិដ្ឋនៃបដិសម្ភិទា មានអត្ថប្បដិសម្ភិទាជាដើម និងហេតុដែលព្រះអង្គទ្រង់បានអនាវរណញ្ញាណ ។ ព្រោះហេតុយ៉ាងនេះ ព្រះអង្គទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ប្រព្រឹត្តទៅដោយប្រការនោះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះមិនប្រាសចាកព្រះញាណដែលជាក់ច្បាស់ដូចម្តេច? គឺព្រះអង្គព្រះនាមថា **អគត** ព្រោះមិនមានការទៅ ពោលគឺ ការប្រព្រឹត្តទៅដែលជាសត្រូវចំពោះព្រះញាណក្នុងការសន្សំពោធិសម្ភារ ។ ក៏សេចក្តីដែលព្រះអង្គមិនប្រាសចាកព្រះញាណនោះ

ព្រះនាមថា **តថាគត** ព្រោះមិនប្រាសចាកញាណដែលប្រព្រឹត្តទៅ ដោយន័យ មានការពិចារណាទោស និងអានិសង្សជាដើម ដោយមិនខុសប្លែកក្នុងធម៌ មានសេចក្តីកំណាញ់ និងទានបារមីជាដើម ។ ម្យ៉ាងទៀត ព្រះអង្គព្រះនាមថា **អគត** ព្រោះមិនមានការដើរទៅ ការទៅក្នុងគតិទាំង ៥ ពោលគឺ ការប្រព្រឹត្ត ទៅនៃអកិសង្ខារ គឺកិលេស ឬពោលគឺ ការប្រព្រឹត្តទៅនៃខន្ធនុ៎ះឯង ។ ការ:ដែល ព្រះអង្គមិនទៅនេះនោះ ដោយទ្រង់សម្រេចសឧបាទិសេសនិព្វាន និងអនុបាទិ-សេសនិព្វាន ដោយអរិយមគ្គញ្ញាណយ៉ាងជាក់ច្បាស់ ។ ព្រោះហេតុយ៉ាងនេះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះមិនទៅប្រាសចាក ញាណដែលជាក់ច្បាស់ ។

ព្រះដ៏មានព្រះភាគព្រះនាមថា **តថាគត** ព្រោះមានការ:ដំណើរទៅ ដោយជាក់ច្បាស់ដូចម្តេច? គឺបទថា **តថាគត ភាវេន** បានដល់ ដោយសការ: ដែលទ្រង់ដំណើរទៅដោយជាក់ច្បាស់ អធិប្បាយថា ការ:ដែលព្រះអង្គទ្រង់ដំណើរ ទៅដោយជាក់ច្បាស់មាននៅ ។ សួរថា ក៏ព្រះដ៏មានព្រះភាគ ដែលបណ្ឌិតថ្វាយ ព្រះនាមថា **តថាគត** ព្រោះសេចក្តីដែលព្រះអង្គទ្រង់ដំណើរដោយជាក់ច្បាស់ នោះគឺអ្វី? ឆ្លើយថា គឺព្រះសទ្ធម្ម ។ មែនពិត ព្រះសទ្ធម្មលំដាប់ដំបូង គឺអរិយមគ្គ អធិប្បាយថា ព្រះអង្គទ្រង់ដំណើរទៅ ដោយប្រការដែលទ្រង់ដកកិលេស ដែល ជាបដិបក្ខបានដោយមិនឱ្យសេសសល់ដោយកម្លាំង គឺសមថ: និងវិបស្សនាដែល ជាប់គ្នាជាគូ ទើបទ្រង់សម្រេចដោយសមុច្ឆេទបហាន បានដល់ ផលធម៌ដែល ព្រះអង្គទ្រង់ទៅ គឺដំណើរទៅ ដោយប្រការដែលព្រះអង្គទ្រង់សម្រេចដោយ បដិបស្សទ្ធិបហានតាមសមរម្យដល់មគ្ត ។ ចំណែកនិព្វានធម៌ ដែលព្រះពុទ្ធជា

ដើមស្តេចដល់ គឺធ្វើឱ្យច្បាស់ដោយប្រការដែលទ្រង់ស្តេចដល់ គឺត្រាស់ដឹងដោយ
បញ្ញា សម្រេចដោយការសូប់ទុក្ខក្នុងវដ្ដៈទាំងអស់ ព្រោះដូច្នោះ ទើបឈ្មោះថា
តថាគត ។ សូម្បីបរិយត្តិធម៌ ក៏ឈ្មោះថា **តថាគត** ព្រោះព្រះដ៏មានព្រះភាគ
របស់យើងទាំងឡាយ ទ្រង់ដំណើរទៅ គឺត្រាស់ បានដល់ ប្រកាសដោយប្រការ
ដែលព្រះបរិយត្តិធម៌នោះ ដែលព្រះពុទ្ធក្នុងកាលមុនទាំងឡាយ ទ្រង់ប្រកាស
ឱ្យសមគួរដល់អធ្យាស្ត្រយជាដើមរបស់វេនេយ្យសត្ត្ব ដោយអំណាចនៃសុត្ត:
និងគេយ្យ:ជាដើម និងដោយការប្រកាសការដំណើរទៅជាដើម ។ ព្រះនាមថា
តថាគត ព្រោះសាវកបស់ព្រះដ៏មានព្រះភាគដំណើរទៅ គឺដំណើរតាម
ដោយប្រការដែលព្រះបរិយត្តិធម៌នោះ ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែង
ហើយ ។ ព្រោះហេតុយ៉ាងនេះ ព្រះសទ្ធម្មសូម្បីទាំងអស់ ទើបឈ្មោះថា **តថាគត**
ដែលដំណើរទៅដោយជាក់ច្បាស់ ។ ព្រោះហេតុនោះ ស្តេចសក្កទេវរាជជាកំពូល
ទេវតាទើបត្រាស់ថា **តថាគតំ ឧេវមនុស្ស្ជ្ជ ធម្មំ ឧមស្ជ្ជ សុត្ថ ហោតុ**
យើងទាំងឡាយ សូមនមស្ការនូវព្រះធម៌ដែលមានមកហើយដូចគ្នា ដែលមនុស្ស
នឹងទេវតាតែងបូជា សូមមានសិរីសួស្ដី[1] ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា
តថាគត ព្រោះព្រះអង្គទ្រង់មានព្រះសទ្ធម្មនោះ ។

ព្រះធម៌មានសភាពយ៉ាងណា សូម្បីព្រះអរិយសង្ឆក៏ដូច្នោះ ព្រះនាមថា
តថាគត ព្រោះដំណើរទៅដោយប្រការដែលអ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួន
និងដើម្បីប្រយោជន៍អ្នកដទៃ បំពេញការបដិបត្តិ គឺសមថ: និងវិបស្សនាដែល

១-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១២ ។

ជាចំណែកខាងដើម ឱ្យបរិសុទ្ធដោយល្អជាប្រមុខ ហើយទើបសម្រេចដោយ
មគ្គនោះៗ ។ ម្យ៉ាងទៀត ឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹង និងព្រោះត្រាស់
ដោយប្រការដែលសច្ចៈ និងបដិច្ចសមុប្បាទជាដើម ដែលព្រះដ៏មានព្រះភាគ
ទ្រង់សម្តែងហើយ ។ ព្រោះហេតុនោះ ស្តេចសក្កទេវរាជទើបត្រាស់ថា **តថាគតំ
ទេវមនុស្ស**ឫ**ជិតំ សង្ឆ្យ ឧមស្ឆ្ឆម សុវត្ថិ ហោតុ** យើងទាំងឡាយ សូម
នមស្ការនូវព្រះសង្ឆ្យដែលមានមកហើយដូចគ្នា ដែលមនុស្សនឹងទេវតាតែងបូជា
សូមមានសិរីសួស្តី[1] ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះព្រះអង្គ
ជាអ្នកមានព្រះសង្ឆ្យនោះជាសាវក ។ ព្រោះហេតុយ៉ាងនេះ ព្រះអង្គទើបទ្រង់
ព្រះនាមថា **តថាគត** ព្រោះមានការៈដំណើរទៅដោយជាក់ច្បាស់នោះឯង ។

បទថា **តថាគត** សូម្បីនេះថា ត្រឹមតែជាប្រមុខក្នុងការសម្តែងការៈដែល
ព្រះតថាគតទ្រង់ដំណើរទៅដោយជាក់ច្បាស់នោះឯង ។ ក៏ព្រះតថាគតប៉ុណ្ណោះ
គប្បីពណ៌នាសេចក្តីដែលព្រះតថាគតដំណើរទៅដោយជាក់ច្បាស់ ។ មែនពិត
បទថា **តថាគត** នេះ មានអត្ថច្រើន មានគតិច្រើន មានអារម្មណ៍ច្រើន ។
ធម្មកថិក អ្នកនាំព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកនៃតថាគតបទនោះមក ដូចអប្ប-
មាទបទដោយសមគួរ ដោយការៈមានប្រយោជន៍ បុគ្គលណាមួយមិនគួរពោល
ថា ធម្មកថិកត្រាច់ទៅដោយខុសកំពង់ ។ ក្នុងសេចក្តីនោះ លោកពោលពាក្យជា
គាថាទុកថា

ព្រះមុនីទាំងឡាយ ក្នុងកាលមុនអ្នកស្វែងរកគុណ

---

[1]-សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ លេខ ៥២ ទំព័រ ១២ ។

ដ៏ធំក្រៃលែង មកដល់ភាពជាព្រះសព្វញ្ញូ ក្នុងលោក
នេះ ដោយប្រការណា សូម្បីព្រះសក្យមុនីអង្គនេះ
ក៏ស្តេចមកដោយប្រការនោះ ព្រោះហេតុនោះ
ព្រះសក្យមុនី អ្នកមានចក្ខុ បណ្ឌិតទើបថ្វាយ
ព្រះនាមថា **តថាគត** ។
ព្រះជិនស្រីទាំងឡាយ ទ្រង់លះមន្ទិលកិលេស
មានកាមជាដើមបាន ដោយមិនឱ្យសេសសល់
ដោយសមាធិ និងបញ្ញាហើយ ទើបដំណើរទៅ
ដោយប្រការណា ព្រះសក្យមុនី ក្នុងកាលមុន
ទ្រង់ទុក ដែលព្រះអង្គធ្វើនូវបន្ទឹមឱ្យរុងរឿង
ស្តេចទៅដោយប្រការនោះ ព្រោះដូច្នោះ
បណ្ឌិតទើបថ្វាយ ព្រះនាមថា **តថាគត** ។
ម្យ៉ាងទៀត ព្រះជិនស្រីស្តេចដល់ព្រមនូវ
លក្ខណៈនៃធាតុ និងអាយតនៈជាដើម ដែល
ជាក់ច្បាស់ ដោយចែកសភាវៈ សាមញ្ញៈ និង
វិភាគៈ ដោយព្រះសយម្ភូញាណព្រោះដូច្នោះ
ព្រះសក្យៈអ្នកប្រសើរ បណ្ឌិតទើបថ្វាយ
ព្រះនាមថា **តថាគត** ។
សច្ចៈដែលជាក់ច្បាស់ និងឥទប្បច្ចយតាដែល

ជាក់ច្បាស់ដែលអ្នកដទៃ ណែនាំមិនបាន ដែល
ព្រះតថាគតអ្នកមានសមន្តចក្ខុទ្រង់ប្រកាស
ហើយដោយន័យដោយប្រការទាំងពួង ព្រោះដូច្នោះ
ព្រះជិនស្រីស្តេចទៅដោយជាក់ច្បាស់ បណ្ឌិតទើប
ថ្វាយព្រះនាមថា **តថាគត** ។
ការដែលព្រះជិនស្រី ទ្រង់ឃើញដោយជាក់ច្បាស់
តែម្យ៉ាង ក្នុងលោកធាតុមានប្រភេទមិនមែនតែមួយ
ក្នុងអារម្មណ៍ មានរូបាយតន:ជាដើម មានសេចក្តី
ផ្សេងដ៏វិចិត្រ ព្រោះដូច្នោះ ព្រះអង្គអ្នកមានសមន្តចក្ខុ
សត្វលោកទើបថ្វាយព្រះនាមថា **តថាគត** ។
ម្យ៉ាងទៀត ព្រោះហេតុដែលព្រះអង្គទ្រង់សម្តែងធម៌
យ៉ាងច្បាស់ពិតតែម្តង ឬទ្រង់ធ្វើព្រះអង្គឱ្យសមគួរ
ដល់ធម៌នោះ ទ្រង់គ្របសង្កត់សត្វលោកដោយ
ព្រះគុណទាំងឡាយ ព្រោះហេតុនោះ ព្រះអង្គ
ជាអ្នកនាំលោក សត្វលោកទើបថ្វាយព្រះនាម
ថា **តថាគត** ។
ម្យ៉ាងទៀត ព្រះអង្គត្រាស់ដឹងដោយបរិញ្ញាដែល
ជាក់ច្បាស់ដោយប្រការទាំងពួង ទ្រង់ធ្វងចាក
លោក ទ្រង់ដល់សេចក្តីរលត់ដោយការធ្វើឱ្យ
ប្រចក្ស និងទ្រង់ដល់អរិយមគ្គ ដូច្នោះ ទើបទ្រង់

ព្រះនាមថា **តថាគត** ។
ម្យ៉ាងទៀត ព្រោះហេតុដែលព្រះអង្គប្រកបដោយ
ប្រយោជន៍ដល់សត្វលោក ទ្រង់ប្តេជ្ញាយ៉ាងជាក់-
ច្បាស់ដោយប្រការទាំងពួង ទ្រង់ជានាថ: (ជាទីពឹង)
របស់លោកដោយព្រះករុណាទាំងពួង ស្តេចយាងទៅ
ព្រោះហេតុនោះ ព្រះជិនស្រី សត្វលោកទើបថ្វាយ
ព្រះនាមថា **តថាគត** ។
ព្រះអង្គទ្រង់ឧប្បត្តិអំពីអកិជាតិយ៉ាងជាក់ច្បាស់ ព្រោះ
ទ្រង់យល់ដឹងអារម្មណ៍តាមសេចក្តីពិត ដូច្នោះសត្ត-
លោកទើបថ្វាយព្រះនាមថា **តថាគត** ។ ព្រះអង្គទ្រង់
ព្រះនាមថា **តថាគត** ព្រោះទ្រង់ញ៉ាំងប្រយោជន៍នោះ
ឱ្យសម្រេច ។
ព្រះមហេសីទាំងឡាយនោះក្នុងកាលមុន មានសភាព
យ៉ាងណា សូម្បីព្រះដ៏មានព្រះភាគអង្គនេះ ក៏មាន
សភាពយ៉ាងនោះ ជាទីរីកវាយ (នៃជនទាំងឡាយ)
ព្រោះព្រះអង្គជាអគ្គបុគ្គល បណ្ឌិតទើបថ្វាយព្រះនាម
ថា **តថាគត** ។ ព្រោះមានព្រះហ្ឫទ័យប្រព្រឹត្តទៅតាម
ព្រះវាចាដែលទ្រង់ប្រកាស ។
ក្នុងកាលមុន ព្រះអង្គមិនទៅពីធម៌ដែលជាសត្ត្រូវ

*ចំពោះពោធិសម្ភារ: ការទៅកាន់សង្ឆារក៏មិនមានដល់ ព្រះអង្គ និងសង្ឆារនេះមិនមានដល់ព្រះលោកនាថ ព្រះអង្គ អ្នកឃើញទីបំផុតនៃភព ព្រោះដូច្នោះ ព្រះអង្គ មិនប្រាសចាកញាណដែលជាប់ច្បាស់ បណ្ឌិតទើបថ្វាយ ព្រះនាមថា **តថាគត** ។*

*ព្រះធម៌ដ៏ប្រសើរ ដែលព្រះមហេសីលះមន្ទិល ដែល គប្បីលះ ព្រោះដូច្នោះ ព្រះធម៌នោះទើបឈ្មោះថា **តថាគត** សូម្បីព្រះអរិយសង្ឆរបស់ព្រះសាស្តា ក៏ឈ្មោះថា **តថាគត** ព្រោះជាអ្នកព្រមព្រៀងដោយ ព្រះធម៌ដ៏ប្រសើរនោះ ។*

បទថា **មហិទ្ធិកតា** *សេចក្តីថា ការប្រកបដោយមហិទ្ធិឫទ្ធិដ៏ច្រើន ពោលគឺ ជាអ្នកអាចញ៉ាំងសេចក្តីដទៃឱ្យសម្រេច ដោយអានុភាពនៃធម៌ ព្រោះ មានការស្ងាត់ជំនាញផ្ទូរចិត្ត និងប្រកបដោយឫទ្ធិផ្សេងៗ ដ៏ក្រៃលែង ឈ្មោះថា* **មហិទ្ធិកតា** *។ សេចក្តីប្រកបដោយតេជៈនៃបុណ្យដែលរុងរឿងក្រៃលែងណាស់ ជាហេតុឱ្យសម្រេចប្រយោជន៍តាមសេចក្តីប្រាថ្នា នៅធ្វើយសៃនធ្វើយចាកសត្រូវ ដែលកើតមកពីកាលយូរ ឈ្មោះថា* **មហានុភាវតា** *។ ស័ព្ទថា* **យត្រ** *ជានិបាត ចុះក្នុងអត្ថបឋមាវិភត្តិ ដែលញ៉ាំងសេចក្តីអស្ចារ្យ សេចក្តីសរសើរ សេចក្តីភ្ញាក់-ផ្អើល និងសេចក្តីរីករាយឱ្យជ្រះថ្លា ។ បទថា* **វិជាយិស្សតិ** *ជាពាក្យប្រាប់អំពីអនាគតកាល ព្រោះប្រកបដោយបទថា* **យត្រ** *នោះ ។ តែអត្ថន័យ ប្រើក្នុងអត្ថ អតីតកាលប៉ុណ្ណោះ ។ ក៏ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះ មែនពិត*

ឈ្មោះថា ព្រះនាងសុប្បវាសានេះ លិចនៅក្នុងកងទុក្ខប្រសព្វសេចក្តីលំបាកដូច្នោះ ព្រមដោយវេលាដែលព្រះដ៏មានព្រះភាគត្រាស់ទ្ទុះឯងទើបមានសេចក្តីសុខ មិនមានរោគ ប្រសូតព្រះឱរសប្រាសចាករោគ ។ បទថា **អត្តមនោ** ប្រែថា មានចិត្តជារបស់ខ្លួន ។ អធិប្បាយថា មានចិត្តប្រាសចាកកិលេស ព្រោះជ្រះថ្លាក្នុងព្រះដ៏មានព្រះភាគ ។ មែនពិត ចិត្តដែលត្រូវកិលេសរុំរឹត បុគ្គលណាមួយ មិនអាចពោលថា មានចិត្តជារបស់ខ្លួន ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ។ ម្យ៉ាងទៀត បទថា **អត្តមនោ** បានដល់ មានចិត្តដែលបីតិ និងសោមនស្សចាប់យកហើយ ។ បទថា **បមុទិតោ** ប្រែថា ប្រកបដោយបាមោជ្ជៈ ។ បទថា **បីតិសោមនស្សជាតោ** ប្រែថា ជាអ្នកមានបីតិ និងសោមនស្សដ៏មានកម្ទាំងកើតឡើងហើយ ។ បទថា **អថ** ប្រែថា ខាងក្រោយ គឺកន្ទងទៅ ២-៣ ថ្ងៃអំពីនោះ ។ បទថា **សត្ត ភត្តានិ** បានដល់ ភត្តដែលគប្បីថ្វាយក្នុង ៧ ថ្ងៃ ។ បទថា **ស្វាតនាយ** សេចក្តីថា ដើម្បីបុណ្យដែលនឹងមានក្នុងថ្ងៃស្អែកនេះ គឺដើម្បីបុណ្យដែលនឹងមានក្នុងថ្ងៃស្អែកនេះ ដោយអំណាចនៃការថ្វាយទាន និងដោយការចូលទៅអង្គុយជិតព្រះសង្ឆមានព្រះពុទ្ធជាប្រធាន ។

បទថា **អថ ខោ ភគវា អាយស្មន្តំ មហាមោគ្គលានំ អាមន្តេសិ** សួរថា ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគទើបត្រាស់ហៅ ។ ឆ្លើយថា ដើម្បីរក្សាសេចក្តីជ្រះថ្លារបស់ព្រះស្វាមីរបស់ព្រះនាងសុប្បវាសា ។ ក៏ព្រះនាងសុប្បវាសាជាអ្នកមានសេចក្តីជ្រះថ្លាមិនកម្រើក ។ តែការរក្សាសេចក្តីជ្រះថ្លារបស់ឧបាសកជាការៈរបស់ព្រះមហាមោគ្គលានត្ថេរ ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា

នាងជាឧបដ្ឋាករបស់លោក ។

បណ្តាបទទាំងនោះ បទថា **តុយ្ហេសោ** *កាត់បទជា* **តុយ្ហំ ឯសោ** *។ ដោយបទថា* **តិណ្ណ្ហ ធម្មានំ ចាដិកោ** *លោកសម្តែងថា បើព្រះមហាមោគ្គល្លានជាម្ចាស់ជាអ្នកទទួលធានា គឺថា ជាអ្នកទទួលរ៉ាប់រងដើម្បីមិនឱ្យធម៌ ៣ ប្រការ មានកោគ:ជាដើមរបស់យើងសាបសូន្យ គឺមិនឱ្យវិនាស គឺថា បើលោកម្ចាស់ដឹងថា ផុតអំពី ៧ ថ្ងៃ ពីថ្ងៃនេះទៅ ខ្ញុំអាចឱ្យទានបាន ។ ចំណែកព្រះថេរ: ឃើញសេចក្តីមិនជាអន្តរាយនៃកោគ: និងជីវិតរបស់ឧបាសកក្នុងថ្ងៃទាំងនោះ ទើបពោលថា អាវុសោ យើងជាអ្នកធានាធម៌ទាំង ២ គឺកោគ: និងជីវិតរបស់លោក ។ ប៉ុន្តែថា សទ្ធាជាគុណជាតិជាប់នៅក្នុងចិត្តរបស់ឧបាសកនោះព្រោះហេតុនោះ ព្រះថេរ:កាលនឹងធ្វើឱ្យជាការ:របស់ឧបាសកប៉ុណ្ណោះ ទើបពោលថា សេចក្តីដែលសទ្ធារបស់ឧបាសកនោះនឹងប្រែជាយ៉ាងដទៃទៅ រមែងមិនមានព្រោះហេតុនោះ ព្រះថេរ:ទើបពោលយ៉ាងនោះ ។ ក៏ព្រោះហេតុនោះនុ៎ះឯង ព្រះដ៏មានព្រះភាគទើបត្រាស់ថា លោកចូរឱ្យឧបាសកព្រមថា លោកនឹងធ្វើខាងក្រោយ ។ ចំណែកឧបាសកប្រាថ្នាសេចក្តីចម្រើន ដោយភាពជាអ្នកគោរពក្នុងព្រះសាស្តា និងព្រះថេរ: និងដោយបុណ្យរបស់ព្រះនាងសុប្បវាសា អ្នកមាន*

សេចក្ដីសុខ ទើបព្រមថា សូមឱ្យកោលិយធីតា នាមសុប្បវាសាធ្វើកត្ត ៧ ថ្ងៃសិន ចុះ ខ្ញុំនខ្ញុំចាំធ្វើក្រោយ ។

បទថា **តញ្ច ជារកំ** សេចក្ដីថា ចាប់ផ្ដើមតាំងពីថ្ងៃដែលប្រសូតមកហើយ កន្ធ ងទៅអស់ ១១ ថ្ងៃ អំពីថ្ងៃនោះ ទើបរង្គាសកិក្ខុសង្ឆមានព្រះពុទ្ធជាប្រធាន ធាន់ ៧ ថ្ងៃ ទើបឱ្យទារកមានអាយុ ៧ ខួបនោះ ថ្វាយបង្គំព្រះដ៏មានព្រះភាគផង នមស្ការកិក្ខុសង្ឆផងក្នុងថ្ងៃទី ៧ ។ បទថា **សត្ត មេ វស្សានិ** ប្រែថា យើងមានអាយុ ៧ ខួប ។ ក៏បទថា **វស្សានិ** នេះ ជាទុតិយាវិភត្ដិ ប្រើក្នុងអត្ថថា អច្ចន្ដសំយោគ: (ប្រែថា អស់) ដោយពាក្យថា **លោហិតកុម្ភិយំ វុដ្ឋានិ** លោកពោលសំដៅយកទុក្ខ ដែលខ្លួននៅក្នុងគភ៌របស់មាតា ។ បទថា **អញ្ញានិបិ ឯវរូបានិ សត្ត បុត្តានិ** សេចក្ដីថា កាលគួរនឹងពោលថា **អញ្ញានិបិ ឯវរូបេ សត្ត បុត្តេ** លោកពោលអំពីជាលិង្គវិបល្ចាសថា **ឯវរូបានិ** ។ អធិប្បាយថា បុត្រអ្នកកើតឡើងបានទទួលទុក្ខយ៉ាងខ្លាំង ព្រោះនៅក្នុងគភ៌អស់ ៧ ឆ្នាំ និងព្រោះគភ៌លំបាកអស់ ៧ ថ្ងៃ ដោយប្រការដូច្នេះ ។ ដោយពាក្យនោះ លោកសម្ដែងថា មាតុគ្រាមទាំងឡាយមិនឆ្អែតព្រោះការចង់បានបុត្រ ព្រោះមាតុគ្រាមជាអ្នកចង់បានបុត្រ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ទ្រង់ជ្រាបអត្ថនេះដែលព្រះនាងពោលអំពីសេចក្ដីចង់បានបុត្រ ព្រោះរួមទុក្ខយ៉ាងខ្លាំងដែលប្រព្រឹត្តទៅដោយការតាំងគភ៌ជាដើម រហូតដល់អស់ ៧ ឆ្នាំ ៧ ថ្ងៃ ចូលក្នុងបទតែមួយគ្នា ។ ដោយបទថា **ឥមំ ឧទានំ** សេចក្ដីថា ព្រះអង្គទ្រង់បន្លឺនូវឧទាននេះដែលសម្ដែងភាវៈ គឺលួងលោមបុគ្គលដែលប្រមាទដោយអាការដែលគួរប្រាថ្នាហើយ ទើបធ្វើប្រយោជន៍ក្នុងការលះសេចក្ដីស្នេហាដោយតណ្ហា ដូចបុគ្គលដែលស្រវឹងនឹងសេចក្ដីសុខក្នុងចិត្តដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **អសាតំ** បានដល់ មិនឆ្ងាញ់ មិនល្អ មិនគួរប្រាថ្នា ។ បទថា **សាតរូបេន** ប្រែថា មានសភាវៈគួរប្រាថ្នា ។ បទថា **បិយរូបេន** ប្រែថា មានភាវៈគួរស្រឡាញ់ ។ បទថា **សុខស្ស រូបេន** បានដល់ មានសភាវៈជាសុខ ។ លោកពោលអធិប្បាយពាក្យនេះទុកថា ព្រោះហេតុដែលសង្ខារដែលប្រព្រឹត្តទៅក្នុងវដ្ដៈទាំងអស់ មិនគួររីករាយ មិនគួរស្រឡាញ់ ជាទុក្ខ មែនពិតប្រាកដដូចជាគួរប្រាថ្នា គួរស្រឡាញ់ និងជាសុខ ព្រោះធ្វើទុកក្នុងចិត្តដោយមិនត្រូវទំនង ព្រោះលះវិបល្លាសមិនបាន រមែងប្រព្រឹត្តកន្លង កៀបសង្កត់ គ្របសង្កត់នូវបុគ្គលប្រមាទ ព្រោះប្រាសចាកសតិ ព្រោះដូច្នោះ ទុក្ខដែលមិនគួររីករាយ

មិនគួរប្រាថ្នាបែបនោះ រមែងគ្របសង្កត់ព្រះនាងសុប្បវាសា សូម្បីអស់ ៧ ដងដោយទុក្ខ ដែលមានចំណែកប្រៀបផ្ទឹមដោយសេចក្តីសប្បាយជាដើម គឺដោយវដ្តទុក្ខ ដែលកើតអំពីសេចក្តីស្រឡាញ់ ពោលគឺ បុត្រ ។

អដ្ឋមសុត្តវណ្ណា ជិដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៨

៩.វិសាខាសុត្តវណ្ណនា

អដ្ឋកថាវិសាខាសូត្រ

វិសាខាសូត្រទី ៩ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **បុព្វារាមេ** *បានដល់ ក្នុងអារាមដែលសាងទុកក្នុងទីប្រាកដស្មើ ឧត្តមទេវវិហារនៃអនុរាធបុរី ស្ថិតក្នុងទិសខាងកើតនៃក្រុងសាវត្ថី ។ បទថា* **មិគារមាតុ ចាសាដេ** *ប្រែថា ក្នុងប្រាសាទរបស់មិគារមាតា ។ ក្នុងសេចក្តីនោះមានអនុបុព្វីកថាដូចតទៅនេះ*

កាលពីអតីតកាល ក្នុងទីបំផុតនៃសែនកប្ប ឧបាសិកាម្នាក់ឃើញព្រះទសពលព្រះនាមថា ***បទុមុត្តរ:*** *ទ្រង់ស្ថាបនាឧបាសិកាម្នាក់ទុកក្នុងតំណែងអគ្គឧបដ្ឋាយិការបស់ព្រះអង្គ ទើបទូលយាងព្រះដ៏មានព្រះភាគ ថ្វាយទានដល់ភិក្ខុមួយសែនអង្គ មានព្រះពុទ្ធជាប្រធាន ធ្វើការនមស្ការចំពោះព្រះដ៏មានព្រះភាគហើយតាំងសេចក្តីប្រាថ្នាទុកថា ក្នុងអនាគតសូមឱ្យនាងខ្ញុំម្ចាស់ជាអគ្គឧបដ្ឋាយិការបស់ព្រះពុទ្ធប្រាកដស្មើដូចព្រះអង្គ ។ ឧបាសិកានោះអន្ទោលទៅក្នុងទេវតា និងមនុស្សរហូតដល់សែនកប្ប ក្នុងកាលនៃព្រះដ៏មានព្រះភាគរបស់យើង ទើបចាប់បដិសន្ធិក្នុងគភ៌របស់សុមនទេវី ក្នុងគេហដ្ឋានរបស់ធនញ្ជយសេដ្ឋី ជាបុត្ររបស់មេណ្ឌកសេដ្ឋី ក្នុងកទ្ទិយនគរ ។ ក៏ក្នុងវេលាដែលនាងកើត ជនទាំងឡាយបានដាក់ឈ្មោះរបស់នាងថា* ***វិសាខា*** *។ ក្នុងកាលដែលព្រះដ៏មានព្រះភាគស្តេចយាងទៅកាន់កទ្ទិយនគរ នាងព្រមដោយទារិកា ៥០០ នាក់ ទៅទទួលព្រះដ៏មានព្រះភាគ បានជាព្រះសោតាបន្ន ដោយគ្រាន់តែការបានគាល់គ្រាដំបូងនុ៎ះឯង ។*

ក្នុងកាលជាខាងក្រោយមក នាងទៅកាន់ត្រកូលរបស់បុណ្ណវឌ្ឍនកុមារ អ្នកជាបុត្ររបស់មិគារសេដ្ឋី ក្នុងក្រុងសាវត្ថី ជាឪពុកក្មេកតាំងនាងទុកក្នុងឋានៈជាមាតា ដោយជាអ្នកមានឧបការៈក្នុងគេហដ្ឋាននោះ ។ ព្រោះដូច្នោះ ជនទាំងឡាយទើបដាក់នាមថា **មិគារមាតា** ។ វិសាខាមិគារមាតានោះចំណាយគ្រឿងប្រដាប់ ឈ្មោះថា **មហាលតា** របស់ខ្លួនដោយញ៉ាំងឱ្យគេកសាងប្រាសាទប្រដាប់ដោយ ១០០០ បន្ទប់ គឺជាន់លើ ៥០០ បន្ទប់ ជាន់ក្រោម ៥០០ បន្ទប់ ក្នុងផ្ទៃដីប្រមាណ ១ ករីស ដើម្បីប្រយោជន៍ដល់ការគង់នៅរបស់ព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឆ អស់ទ្រព្យចំនួន ៩ កោដិ ។ ព្រោះហេតុនោះ លោកទើបពោលថា ក្នុងប្រាសាទរបស់មិគារមាតា ។

បទថា **កោចិទេវ អត្ថោ** ប្រែថា ប្រយោជន៍ខ្លះៗ ។ បទថា **រញ្ញេ** ប្រែថា ព្រះរាជា ។ បទថា **បដិពន្ធោ** ប្រែថា ជាប់ដល់គ្នា ។ ពួកញាតិរបស់នាងវិសាខាបញ្ជូនវត្ថុដូច្នោះដ៏វិចិត្រដោយកែវមណី និងកែវមុក្តាជាដើម ពីត្រកូលញាតិទៅដើម្បីជាបណ្ណាការដល់នាង ។ ជនអ្នកទារសួយសាអាករកាន់យកនូវវត្ថុនោះ ដែលមកដល់ទ្វារនគរឱ្យជាសួយសាអាករក្នុងទីនេះ តែមិនកាន់យកទ្រព្យដែលមានសភាពយ៉ាងនោះ ហើយកាន់យក ។ នាងវិសាខាបានស្តាប់ឮដូច្នោះ ប្រាជ្ញានឹងទូលសេចក្តីនោះដល់ព្រះរាជា ទើបបានទៅកាន់ព្រះរាជនិវេសន៍ ព្រមដោយបរិវារល្មមសមគួរ ខណៈនោះ ព្រះរាជាព្រមដោយព្រះនាងមល្លិកាទេវី បានស្តេចយាងទៅកាន់ខាងក្នុងព្រះដំណាក់ ។ នាងវិសាខាកាលមិនបានឱកាស ទើបគិតថា យើងនឹងបានក្នុងកាលឥឡូវនេះ មានកាលបរិកោគកន្ធងទៅហើយ មាន

កត្តជាច់ហើយ ទើបជៀសទៅ ។ សូម្បីនាងនឹងទៅយ៉ាងនេះអស់ ២-៣ ថ្ងៃ ក៏មិនបានឱកាសឡើយ ។ ព្រោះដូច្នោះ ព្រះរាជា សូម្បីរាជអាមាត្យ គេនឹងមិនក្រាបទូលឱ្យទ្រង់ជ្រាប ក៏ហៅថា ព្រះអង្គមិនញ៉ាំងប្រយោជន៍ឱ្យសម្រេចតាមសេចក្តីប្រាថ្នា ព្រោះមិនបានឱកាសដែលនឹងធ្វើការវិនិច្ឆ័យសេចក្តីនោះ ។ បណ្តាបទទាំងនោះ បទថា **យថាធិប្ផាយំ** *ប្រែថា តាមគួរដល់សេចក្តីប្រាថ្នា ។ បទថា* **ន តីរេតិ** *ប្រែថា មិនទាន់ធ្លាក់ចុះ ។ មែនពិត មហាឧបាសិកាមានសេចក្តីប្រាថ្នានឹងថ្វាយសួយសាអាករ ដែលជាប់ទាក់ទងនឹងព្រះរាជាដល់ព្រះរាជា ហើយលះបង់វត្ថុទាំងនេះ សេចក្តីប្រាថ្នានោះ ព្រះរាជាមិនទាន់បានពិចារណា ព្រោះព្រះអង្គមិនទាន់បានឃើញឡើយ ។ ស័ព្ទថា* **ហន្ទ** *ជានិបាត ប្រើក្នុងអត្ថថា លះបង់ ។ បទថា* **ឌិវ ឌិវស្ស** *ប្រែថា ក្នុងវេលាពេលថ្ងៃ អធិប្បាយថា ក្នុងវេលាថ្ងៃត្រង់ ។ មហាឧបាសិកាកាលនឹងសម្តែងសេចក្តីនេះថា នាងខ្ញុំម្ចាស់ទៅកាន់ទ្វារព្រះរាជនិវេសន៍អស់ ២-៣ ថ្ងៃ ក្នុងវេលាពេលថ្ងៃ ដោយករណីកិច្ចខ្ទះ១ ចូលទៅរកកិច្ចការដោយគ្មានប្រយោជន៍ ព្រោះសេចក្តីនោះមិនទាន់សម្រេចតែការចូលទៅ គាល់ព្រះដ៏មានព្រះភាគប៉ុណ្ណោះ មានប្រយោជន៍ព្រោះជាហេតុឱ្យបានទស្សនានុត្តរិយៈជាដើម បពិត្រព្រះអង្គដ៏ចម្រើន នាងខ្ញុំម្ចាស់ទើបមកក្នុងទីនេះក្នុងវេលានេះ ដូច្នេះ ទើបក្រាបទូលពាក្យមានជាអាទិ៍ថា* **ឥធ មេ ភន្តេ** *។*

បទថា **ឯតមត្ថំ** *សេចក្តីថា ទ្រង់ជ្រាបសេចក្តីនេះ ពោលគឺ ការសម្រេចសេចក្តីប្រាថ្នាដោយជាប់នឹងអ្នកដទៃ ។ ដោយបទថា* **ឥមំ ឧទានំ** *ព្រះដ៏មានព្រះភាគទ្រង់បន្ទឺនូវឧទានេះ ដែលសម្តែងទោស និងអានិសង្សក្នុងការប្រព្រឹត្ត ទៅដែលអាស្រ័យអ្នកដទៃនឹងមិនអាស្រ័យអ្នកដទៃ ។*

បណ្តាបទទាំងនោះ បទថា **សត្ថុ ឥវ** សេចក្តីថា អត្ថគឺប្រយោជន៍យ៉ាងណាមួយ ដែលប្រព្រឹត្តទៅក្នុងអំណាចរបស់អ្នកដទៃ គឺជាប់នឹងអ្នកដទៃចាត់ថាជាទុក្ខ គឺជាហេតុនាំទុក្ខមកឱ្យ ព្រោះមិនអាចឱ្យសម្រេចតាមសេចក្តីប្រាថ្នារបស់ខ្លួន ។ បទថា **សត្ថុ ឥស្សរិយំ សុខំ** សេចក្តីថា ភាពជាធំមាន ២ យ៉ាង គឺជាលោកិយ: ១ លោកុត្តរ: ១ ។ បណ្តាឥស្សរ:ពីរយ៉ាងនោះ ភាពជាធំចំណែកលោកិយ: មានភាពជាធំនៃព្រះរាជាជាដើម និងភាពជាធំនៃចិត្តដែលកើតពីឈាន និងអភិញ្ញាជាលោកិយ: ។ ភាពជាធំចំណែកលោកុត្តរ: បានដល់ ភាពជាធំនៃនិព្វាន ដែលមានការសម្រេចមគ្គ និងផលជានិមិត្ត ។ បណ្តាភាពជាធំជាលោកិយ:នោះ ភាពជាធំក្នុងមនុស្សដែលមានភាពជាស្តេចចក្រពត្តិជាទីបំផុត ១ ភាពជាធំជាអធិបតីក្នុងពួកទេវនោះ។ នៃស្តេចសក្ក:ជាដើម ១ ភាពជាធំទាំងពីរយ៉ាងនោះ សូម្បីបើឈ្មោះថា ជាសុខព្រោះមានសុខជានិមិត្ត ដោយសម្រេចតាមសេចក្តីប្រាថ្នា ដោយអានុភាពនៃកម្មក៏ពិតមែនហើយ ក៏ប៉ុន្តែថា ឈ្មោះថា ជាសុខយ៉ាងពិតប្រាកដ ដោយប្រការទាំងពួងក៏ទេ ព្រោះជាទុក្ខដោយមានសេចក្តីប្រែប្រួលទៅ ។ ម្យ៉ាងទៀត ភាពជាធំតាមផ្លូវចិត្តដែលកើតពីលោកិយឈានជាដើម ឈ្មោះថា មិនជាសុខយ៉ាងពិតប្រាកដ ព្រោះមានសេចក្តីមិនទៀងជាទីបំផុត ។ ចំណែកភាពជាធំនៃនិព្វានប៉ុណ្ណោះ ឈ្មោះថា មានសេចក្តីជាសុខយ៉ាងពិតប្រាកដ ព្រោះមិនញាប់ញ័រដោយលោកធម៌ និងព្រោះមិនមានការវិលត្រឡប់ជាសភាវ: ។ ក៏ក្នុងទីនេះ ព្រះសាស្តាទ្រង់

សំដៅយកសុខផ្លូវចិត្ត ដែលបានដោយមិនជាប់នឹងវត្ថុដទៃក្នុងទីទាំងពួង ទើបត្រាស់ថា **សញ្ញំ ឥស្ឆរិយំ សុខំ** ។

បទថា **សាធារណោ វិហញ្ញន្តិ** *នេះ ជាបទខៃសេចក្តីនៃបទនេះថា* **សញ្ញំ ឧរសេ ឧក្ខិ** ។ *ក៏ក្នុងសេចក្តីនេះមានអធិប្បាយដូច្នេះ កាលប្រយោជន៍ទូទៅនឹងគប្បីឱ្យសម្រេចមាននៅ សត្វទាំងនេះឈ្មោះថា ក្តៅក្រហាយ ដល់សេចក្តីចង្អៀតចង្អល់ គឺសៅហ្មង ព្រោះមិនសម្រេចតាមសេចក្តីប្រាថ្នា ព្រោះហេតុតែប្រយោជន៍នោះជាប់ដោយអ្នកដទៃ ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះកិលេសជាគ្រឿងប្រកប គឺសត្វទាំងឡាយកន្ទ្រង់បានដោយលំបាក ។ អធិប្បាយថា ព្រោះហេតុដែលកាមយោគ: ភវយោគ: ទិដ្ឋិយោគ: និងអវិជ្ជាយោគ: គឺបុគ្គលឱ្យកើតមានរហូតដល់អស់កាលរកខាងដើមមិនបាន ឈ្មោះថា កន្ទ្រង់បានលំបាក ព្រោះអ្នកដែលមិនបានសន្សំកុសលសម្ភារមកមិនអាចនឹងលះបាន ។ បណ្តាយោគ:ទាំងឡាយនោះ ទិដ្ឋិយោគ: គឺបុគ្គលគប្បីកន្ទ្រង់បានដោយបឋមមគ្គ (សោតាបត្តិមគ្គ) កាមយោគ: គឺបុគ្គលគប្បីកន្ទ្រង់បានដោយមគ្គទី ៣ (អនាគាមិ-មគ្គ) យោគ:ក្រៅនេះដែលបុគ្គលគប្បីកន្ទ្រង់បានដោយមគ្គប្រសើរ (អរហត្តមគ្គ) ។ ព្រោះហេតុដូច្នោះ យោគ:ទាំងនេះ ទើបឈ្មោះថា គឺសត្វទាំងឡាយកន្ទ្រង់បានដោយលំបាក ព្រោះអរិយមគ្គទាំងឡាយសម្រេចបានហើយលំបាក ។ ព្រោះដូច្នោះ សត្វទាំងឡាយទើបឈ្មោះថា ក្តៅក្រហាយ ព្រោះហេតុដែលមិនបានវត្ថុដែលប្រាថ្នា ដោយអំណាចកាមយោគ:ជាដើម អធិប្បាយថា ក៏កាលភាពជាធំនៃចិត្ត និងភាពជាធំនៃនិពោធមិនសាធារណ:ដល់អ្នកដទៃមាន សូម្បីក្នុងកាលណាៗ សេចក្តីចង្អៀតចង្អល់ក៏កើតមិនបាន ។

ម្យ៉ាងទៀត បទថា **សត្ថុ បវេស្ស** សេចក្ដីថា ប្រយោជន៍ពោលគឺ ការប្រព្រឹត្តទៅរបស់ខ្លួនជាប់ដោយអ្នកដទៃ និងអ្នកដទៃជាប់នឹងខ្លួនទាំងអស់នោះ ឈ្មោះថា ជាហេតុនាំទុក្ខមកឱ្យ ព្រោះមានភាពមិនទៀងជាសភាវ: ។ សមដូចពាក្យដែលលោកពោលទុកថា "វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ" ។ បទថា **សត្ថុ ឥស្សរិយំ** សេចក្ដីថា ព្រះនិព្វានដែលជាទីរលាស់ចេញចាកសង្ខតធម៌ទាំងពួងដែលបាននាមថា ឥស្សរិយ: ព្រោះជាទីតាំងនៃភាពជាធំ សេចក្ដីសុខទាំងអស់នោះចែកជាសឧបាទិសេសនិព្វានជាដើម ឈ្មោះថា នាំមកដែលសេចក្ដីសុខ ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា **និព្វានំ បរមំ សុខំ** ព្រះនិព្វានជាសុខយ៉ាងក្រៃលែង[1] ។ បទថា **សាធារណេ** សេចក្ដីថា កាលកំណត់ទុក្ខ និងសុខបានយ៉ាងនេះ សត្វទាំងនេះ រមែងក្ដៅក្រហាយលិចនៅក្នុងហេតុនៃទុក្ខដែលទូទៅដល់ទុក្ខដល់សត្វដ៏ច្រើន ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះកិលេសជាគ្រឿងប្រកបសត្វទាំងឡាយកន្ទ្ធងបានដោយលំបាក អធិប្បាយថា ព្រោះហេតុដែលកាមយោគ:ជាដើម ទាំងនោះជាហេតុឱ្យលិចចុះក្នុងទុក្ខទាំងពួងជាការកន្ទ្ធងបានលំបាក ម្នាលនាងវិសាខា ព្រោះហេតុនោះ នាងកាលប្រាថ្នាប្រយោជន៍ដែលជាប់នឹងអ្នកដទៃ កាលមិនបានក៏ក្ដៅក្រហាយ ។

ជរមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៩

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៦២ ។

១០. ភទ្ទិយសុត្តវណ្ណនា

អដ្ឋកថាភទ្ទិយសូត្រ

ភទ្ទិយសូត្រទី ១០ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **អនុបិយាយំ** *បានដល់ ជិតនគរដែលមានឈ្មោះយ៉ាងនេះ ។ បទថា* **អម្ពវនេ** *សេចក្តីថា ក្នុងទីមិនឆ្ងាយអំពីនគរនោះ ពួកមល្ល:ក្សត្រទាំងឡាយ មានសួនស្វាយមួយកន្លែង ក្នុងសួនស្វាយនោះ ពួកមល្ល:ក្សត្រទាំងឡាយ បានសាងវិហារថ្វាយចំពោះព្រះដ៏មានព្រះភាគ វិហារនោះគេហៅថា* ***អម្ពវន*** *។ ព្រះដ៏មានព្រះភាគទ្រង់ធ្វើអនុបិយនគរឱ្យជាគោចរគ្រាម ប្រថាប់នៅក្នុងអម្ពវននោះ ។ ព្រោះហេតុនោះ លោកទើបពោលថា* **អនុបិយាយំ វិហរតិ អម្ពវនេ** *។ បទថា* **ភទ្ទិយោ** *ជាឈ្មោះរបស់ព្រះថេរៈនោះ ។ បទថា* **ការ:ណ្ឌ:ិ:ាយ បុត្តោ** *សេចក្តីថា សក្យរាជទេវី សាកិយានី ព្រះនាមថា* ***ការ:ណ្ឌ:ិ:ាយ*** *ជាព្រះអរិយសាវិកា សម្រេចអរិយផលហើយ អ្នកមានសាសនាធ្វើជាក់ច្បាស់ហើយ ព្រះថេរៈនេះជាបុត្ររបស់ព្រះនាង ។ បព្វជ្ជាវិធីរបស់ព្រះថេរៈនោះ មកក្នុងខន្ធក:[1]នុ:ងឯង ។ ព្រះថេរៈនោះ គ្រាបព្វជ្ជាហើយផ្តើមតាំងវិបស្សនា មិនយូរលោកក៏បានអភិញ្ញា ៦ លោកសមាទានប្រព្រឹត្តធុតង្គ:សូម្បីទាំង ១៣ ។ ក៏ព្រះដ៏-មានព្រះភាគ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងឯតទគ្គ: ជាអ្នកមានត្រកូលខ្ពស់ជាងភិក្ខុទាំងឡាយថា* **ឯតទគ្គ: ភិក្ខវេ មម សាវកានំ ភិក្ខូនំ ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ ការ:ណ្ឌ:ិ:ាយ បុត្តោ ។** *ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុ*

១-សេចក្តីពិស្តារមានក្នុងវិនយបិដក ចុល្លវគ្គ លេខ ១១ ត្រង់សង្ឆភេទ្ធ:ន:ក: ។

អ្នកមានត្រកូលខ្ពស់ ស្រេចនឹងកទ្ទិយកាឡិគោធាយបុត្ត[២] ជាបុត្តរបស់ព្រះនាងកាឡិគោធា ឈ្មោះថា កទ្ទិយ: តែម្នាក់ដែលនៅក្នុងចំនួនព្រះសាវក ៨០ អង្គ ។

ដោយបទថា **សុញ្ញាគារគតោ** លោកពោលថា រៀរស្រុកនិងឧបចារស្រុក ក្រៅអំពីនោះឈ្មោះថា ព្រៃ រៀរព្រៃនិងគល់ឈើចេញ ដែលនៅអាស្រ័យយ៉ាងដទៃមានភ្នំជាដើម ដែលសមគួរដល់បព្វជិត លោកប្រាថ្នាយកថា សុញ្ញាគារក្នុងទីនេះ ព្រោះមិនអ្ងែអរដោយពួកជន ។ ម្យ៉ាងទៀត សូម្បីផ្ទះណាមួយដែលស្ងាត់ក៏គប្បីជ្រាបថា សុញ្ញាគារ ព្រោះមិនមានសំឡេងដែលជាសត្រូវចំពោះឈាន ។ កទ្ទិយ:នោះចូលទៅកាន់សុញ្ញាគារនោះ ។ បទថា **អភិក្ខណំ** ប្រែថា ច្រើនណាស់ ។ បទថា **ឧជ្ជាគមំ ឧជ្ជាគមេសិ** សេចក្ដីថា ព្រោះព្រះកទ្ទិយ:ដ៏មានអាយុនោះ សូម្បីចូលសម្រាកពេលថ្ងៃក្ដី ចូលសម្រាកពេលយប់ក្ដី ដោយច្រើនឱ្យកាលកន្ធងទៅដោយសុខដែលកើតពីផលសមាបត្តិ និងសុខដែលកើតអំពីនិរោធ ព្រោះដូច្នោះ លោកសំដៅយកសុខនោះ ទើបនឿយណាយសុខក្នុងរាជសម្ប្ដត្តិ ដែលប្រកបដោយភ័យ មានសេចក្ដីក្ដៅផ្សា ដែលខ្ជួនធ្ងាប់សោយក្នុងកាលមុន ទើបបន្ទឹខទានដល់សុខដែលកើតព្រមដោយសោមនស្ស មានញាណជាសមុដ្ឋាន មានបីតិជាសមុដ្ឋានថា ឱ្ហ៎ សុខ អ្ហ៎ម្ទ: ឱ្ហ៎ សុខ អ្ហ៎ម្ទ: ដូច្នេះ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ២០ ទំព័រ ៥៣ ។

បទថា **សុត្វាន តេសំ ឯតទហោសិ** *សេចក្តីថា ភិក្ខុជាច្រើនពួកនោះ គ្រាបានស្តាប់ឧទានរបស់ព្រះកទ្ទិយៈដ៏មានអាយុបន្ទឹថា ឱហ្ន៎ សុខ អ្ហីម្ទេ ឱហ្ន៎ សុខ អ្ហីម្ទេ ក៏មានបរិវិតក្ក:ដូច្នេះថា ព្រះកទ្ទិយៈអង្គនេះ នឿយណាយក្នុងការប្រព្រឹត្តព្រហ្មចរិយៈដោយពិត ។ មែនពិត ភិក្ខុទាំងនោះជាបុថុជ្ជន កាលមិនដឹងឧទាន ដែលសំដៅដល់សុខដែលកើតអំពីវិវេករបស់លោកអ្នកមានអាយុនោះ ទើបបានសម្គាល់យ៉ាងនោះ ព្រោះហេតុនោះ លោកទើបពោលពាក្យថា* **និស្សំ-សយំ** *ដូច្នេះ ជាដើម ។*

បណ្តាបទទាំងនោះ បទថា **និស្សំសយំ** *គឺដោយមិនសង្ស័យ អធិប្បាយថា ដោយពិតប្រាកដ ។ អាចារ្យពួកខ្លះពោលបាលីជាដើមថា* **យំ សោ បុព្ពេ អការិយកូតো សមានো** *(លោកអ្នកគ្រប់គ្រងផ្ទះក្នុងកាលមុន សោយសេចក្តីសុខណា) ហើយពណ៌នាអត្ថដោយពាក្យដែលនៅសល់ថា* **អនុភវិ** *(សោយ) អាចារ្យមួយពួកទៀតពោលថា* **យំស ។** *តែបាលីជា* **យំស បុព្ពេ អការិ-យកូតស្ស ។** *ក្នុងបទទាំងនោះ បទថា* **យំស** *កាត់បទជា* **យំ អស្ស** *ព្រោះលុប* **អ** *អក្សរនិង* **ស** *អក្សរ ដោយអំណាចសន្ធិ ដូចក្នុងប្រយោគមានជាអាទិ៍ថា* **ឯវំ ស តេ** *និងថា* **បុច្ឆំសា ឧប្បជ្ជតិ ។** *គប្បីជ្រាបអត្ថន័យរបស់ពាក្យនោះដូចតទៅនេះ ព្រះកទ្ទិយៈដ៏មានអាយុអង្គនោះ កាលពីមុនបួស ជាគ្រហស្ថអ្នកគ្រប់-គ្រងផ្ទះសោយសុខក្នុងរាជសម្បត្តិណា ។ បទថា* **សោ តមនុស្ស្សរមានো** *សេចក្តីថា ឥឡូវនេះ លោកវិលរឭកដល់សុខនោះ ដោយសេចក្តីនឿយណាយ ។*

បទថា **តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ** *សេចក្តីថា ភិក្ខុជាច្រើនអង្គទាំងនោះ តាំងនៅក្នុងសភាពជាអ្នកពោលអួត ទើបបានក្រាបទូលពាក្យនេះចំពោះព្រះដ៏-មានព្រះភាគ ដោយប្រាថ្នានឹងអនុគ្រោះនូវកទ្ទិយ: មិនមែនប្រាថ្នានឹងលើកទោសទេ ។ បទថា* **អញ្ញតរំ** *បានដល់ ភិក្ខុមួយរូប ជាអ្នកមិនប្រាកដនាម និងគោត្រ ។ បទថា* **អាមន្តេសិ** *បានដល់ ព្រះដ៏មានព្រះភាគប្រាថ្នានឹងឱ្យភិក្ខុទាំងនោះយល់ ទើបត្រាស់បង្គាប់ឱ្យគេហៅភិក្ខុនោះមក ។ បទថា* **ឯវំ** *បានដល់ ក្នុងការទទួលព្រះតម្រាស់ ។ អធិប្បាយថា ដូចខ្ញុំព្រះអង្គសូមវ៉ោកាស[1] ។ បទថា* **ឯវំ** *បានដល់ ដោយការប្តេជ្ញាទៀត ។ បទថា* **អភិក្ខណំ អហោ សុខំ អហោ សុខន្តិ ឥមំ ឧទានំ ឧទានេសិ** *សេចក្តីថា ទទួលដឹងនូវឧទានរបស់ខ្លួនយ៉ាងនេះថា ភិក្ខុទាំងឡាយនោះពោលដោយពាក្យយ៉ាងណា ពាក្យនោះជាពាក្យពិត ។ បទថា* **កិំ បន ត្វំ ភទ្ទិយ** *សួរថា ព្រោះហេតុអ្វី បានជាព្រះដ៏មានព្រះភាគទើបត្រាស់សួរ ព្រះអង្គទ្រង់មិនជ្រាបចិត្តរបស់ព្រះកទ្ទិយ: អង្គនោះទេឬ? ឆ្វើយថា ព្រះដ៏មានព្រះភាគទ្រង់មិនជ្រាបក៏មិនមានទេ ក៏ព្រោះហេតុនោះនុ៎ះឯង ព្រះអង្គទើបត្រាស់សួរដើម្បីឱ្យពោលរឿងនោះ ហើយឱ្យភិក្ខុទាំងនោះឮព្រម ។ សមដូចពាក្យដែលលោកពោលទុកមានជាអាទិ៍ថា ព្រះតថាគត*

១-មកពីពាក្យ វ+ឱកាស =វ៉ោកាស (ឱកាសប្រសើរ) ស្រង់ចាកពីវចនានុក្រមខ្មែរ សម្តេចព្រះសង្ឆរាជ **ជោតញ្ញាណោ** *ជ.ណ ។*

ទាំងឡាយទាំងដែលដឹងត្រាស់សួរក៏មាន ទាំងដែលដឹងមិនត្រាស់សួរក៏មាន ។ បទថា **អត្ថវសំ** *ប្រែថា ហេតុ ។*

បទថា **អន្តេបុរេ** *បានដល់ ក្នុងខាងក្នុងព្រះរាជដំណាក់ដែលជាទីសញ្ជ្ញារបស់ក្រមុំរាជវាំង ជាទីដែលព្រះរាជាទ្រង់ស្រង់ ទ្រង់សោយ និងជាទីផ្ទំជាដើមរបស់ព្រះរាជា ។ បទថា* **រក្ខា សុសំវិហិតា** *បានដល់ ការឃុំគ្រងដែលពួករាជបុរសធ្វើការរក្សាយ៉ាងប្រិតប្រៀង បានចាត់ចែងទុកដោយជុំវិញយ៉ាងល្អ ។ បទថា* **ពហិបិ អន្តេបុរេ** *បានដល់ ក្នុងរាជដំណាក់ដែលក្រៅពីខាងក្នុងព្រះរាជវាំង មានប៉ម្មជាដើម ។ បទថា* **ឯវំ រក្ខិតោ គោបិតោ សន្តោ** *សេចក្ដីថា ខ្ញុំព្រះអង្គនោះជាអ្នកដែលរាជបុរសច្រើនរយរក្សាឃុំគ្រង ដើម្បីការរួចផុតពីភ័យ ដើម្បីការនៅសប្បាយដល់ខ្ញុំព្រះអង្គ ដោយការចាត់ចែង ការរក្សា ការការពារ និងឃុំគ្រងយ៉ាងល្អ ក្នុងទីច្រើនកន្លែង ទាំងខាងក្នុងនិងខាងក្រៅ រាជដំណាក់រាជធានី រាជអាណាខេត្ត ដោយប្រការយ៉ាងនេះ ។ បទថា* **ភីតោ** *ជាដើម ជាវេវចនៈរបស់គ្នានិងគ្នា ។ ម្យ៉ាងទៀត បទថា* **ភីតោ** *បានដល់ ជាទីដែលរាជសត្រូវខ្ជាចក្រែង ។ បទថា* **ឧព្វិគ្គោ** *បានដល់ ជាអ្នកខ្ជាច ស្ងប់ស្ងៀញ្ជាប់ញ័ររដោយការភ័យដែលកើតអំពីការបង្ក្រឹកវរ ក្នុងរាជវាំងរបស់ខ្លួន ។ បទ-ថា* **ឧស្សុក្កិ** *បានដល់ ការរង្គៀសទូវរឿងដែលមាននៅខាងមុខ ដោយការមិនដាក់ចិត្តក្នុងទីទាំងពួង និងដោយសេចក្ដីសង្ស័យដល់កិច្ច និងករណីយនោះ ព្រោះពាក្យនិយាយថា ធម្មតាព្រះរាជាមិនគួរទុកដាក់ចិត្តគ្រប់ៗ វេលា ។ បទថា*

ឧត្រាសី បានដល់ តក់ស្ទុត ដោយសេចក្តីតក់ស្ទុតដែលអាចធ្វើឱ្យសរីរៈញ័រ ដែលកើតឡើងថា ក្នុងពេលខ្លះ សេចក្តីវិនាសគប្បីមានដល់យើងជាអ្នកមិនដឹងខ្លួនឡើយ សូម្បីដោយអ្នកនៅក្បែរ ។ អាចារ្យពួកខ្លះពោលថា **ឧត្រាសো** ដូច្នេះក៏មាន ។ បទថា **វិហាសិ** បានដល់ ខ្ញុំព្រះអង្គនៅដោយសភាពភ័យខ្លាច ។

បទថា **ឯតរហិ** បានដល់ ឥឡូវនេះ រាប់តាំងពីវេលាដែលបួសមក ។ បទថា **ឯកো** បានដល់ មិនមានសម្ងាញ់ ដោយបទថា **ឯកো** នោះ លោកសម្តែងដល់ភាពជាអ្នកមានខ្លួនជ្រៀសចេញហើយ ។ គប្បីជ្រាបអត្ថនៃបទថា **អកីតো** ជាដើម ដោយបរិយាយផ្ទុយគ្នា នឹងពាក្យដែលពោលហើយ ។ លោកសម្តែងដល់ចិត្តវិវេក ដោយពាក្យមានជាអាទិ៍ថា សេចក្តីដែលលោកមិនមានភាពខ្លាចជាដើម ព្រោះមិនមានការកំណត់ចាប់និមិត្តមានភ័យជាដើម និងភ័យគឺកិលេសដែលមានការកំណត់នោះជានិមិត្ត ។ បទថា **អប្ប្យាសុ្ស្ស** បានដល់ ប្រាសចាកសេចក្តីខ្ជិលខ្លាយក្នុងការឃុំគ្រងរាងកាយ ។ បទថា **បន្ធលោមো** បានដល់ មិនមានរោមបះឡើង ព្រោះមិនមានសេចក្តីភ័យព្រឺព្រួចដែលធ្វើឱ្យរោមបះឡើងជាដើម ។ ដោយបទទាំងពីរ លោកសម្តែងដល់ការនៅយ៉ាងសប្បាយ ។ បទថា **បរេ**ឧ**ត្តো** សេចក្តីថា ប្រព្រឹត្តទៅដោយចីវរជាដើមដែលអ្នកដទៃឱ្យ ដោយបទនោះ លោកសម្តែងដល់ការវៀរចាកហេតុនៃភ័យដោយមិនឱ្យសេស-សល់ ដោយបំណង គឺការមិនមានសេចក្តីជាប់ជំពាក់ដោយប្រការទាំងពួង ។

បទថា **មិតភ្ជូតេន ចេតសា** *បានដល់ មានចិត្តកើតដូចជាម្រឹគ ព្រោះនៅដោយ ឥតកង្វល់ ។ មែនពិត ម្រឹគអាស្រ័យនៅក្នុងព្រៃត្រង់កន្លែងដែលមិនមានមនុស្ស នឹងឈរ ដើរ ដេកក៏ឥតកង្វល់ និងឈានទៅតាមសេចក្តីប្រាថ្នា ត្រាច់ទៅដោយ មិនជាប់ជំពាក់ លោកសម្តែងថា សូម្បីយើងក៏នៅយ៉ាងនោះ ។ សមដូចដែល ព្រះបច្ចេកពុទ្ធត្រាស់ទុកថា*

មិគោ អរញ្ញម្ហិ យថា អពន្ធោ
យេនិច្ឆកំ កច្ឆតិ គោចរាយ
វិញ្ញូ ជនោ សេវិតំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ម្រឹគក្នុងព្រៃជាសត្វមិនជាប់ចំណង ទៅរកចំណីតាមចំណង់ចិត្ត បានយ៉ាងណា វិញ្ញូជន កាលបើឃើញសេរីភាព (យ៉ាងនោះ) គប្បីត្រាច់ទៅតែ ម្នាក់ឯង ដូចកុយរមាស[1] ។

បទថា **ឥមំ ខោ អហំ ភន្តេ អត្ថវសំ** *សេចក្តីថា បពិត្រព្រះដ៏មាន ព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គកាលពិចារណាឃើញហេតុ គឺសុខដែលកើតពីវិវេក និងសុខដែលកើតពីផលសមាបត្តិដ៏ក្រៃលែងនេះប៉ុណ្ណោះ ទើបបន្ទឹមទានថា ឱហ្ន៎ សុខ អ្វីម្ល៉ះ ឱហ្ន៎ សុខ អ្វីម្ល៉ះ ។*

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ១៤ ។

បទថា **ឯតមត្ថំ** សេចក្តីថា ទ្រង់ជ្រាបសេចក្តីនោះដោយប្រការទាំងពួង ដល់សេចក្តីនេះពោលគឺ សុខដែលកើតពីវិវេកដែលកន្ធង់វិស័យបុថុជ្ជនរបស់ព្រះកទ្ទិយត្ថេរ ។ បទថា **ឥមំ ឧទានំ** ព្រះដ៏មានព្រះភាគទ្រង់បន្ទឹនូវឧទាននេះ ដើម្បីសម្តែងអំពីអានុភាពការចេញចាកកាយ សោយសោកព្រមទាំងហេតុ ។

បណ្តាបទទាំងនោះ បទថា **យស្ស ន្តរតោ ន សន្តិ កោចា** សេចក្តីថា កិលេស មានរាគ:ជាដើម ឈ្មោះថា ធ្វើចិត្តឱ្យកម្រើក ព្រោះជាហេតុធ្វើចិត្តឱ្យហុយឡើងតាមវេលា (និង) សេចក្តីក្រោធមានច្រើនប្រភេទ ផ្សេងដោយហេតុមានអាឃាតវត្ថុជាដើម រមែងមិនមានក្នុងខាងក្នុង គឺក្នុងចិត្តរបស់ខ្លួនពីចិត្តរបស់ព្រះអរិយបុគ្គលណា ឈ្មោះថា រមែងមិនមាន ព្រោះព្រះអរិយបុគ្គលលះបានដោយមគ្គ ។ មែនពិត **អន្ត** សព្ទនេះ ប្រាកដក្នុងហេតុ ក្នុងប្រយោគមានជាអាទិ៍ថា ចំណែកយើងនិងលោកជាអ្វី ។ ប្រាកដត្រង់កណ្តាល ក្នុងប្រយោគមានជាអាទិ៍ថា ក្នុងសម័យប៉ុមដែលតាំងត្រង់កណ្តាល ។ ប្រាកដក្នុងចន្ទោះ ក្នុងប្រយោគមានជាអាទិ៍ថា ចន្ទោះវត្តជេតពននិងក្រុងសាវត្ថី ។ ប្រាកដក្នុងចិត្ត ក្នុងប្រយោគមានជាអាទិ៍ថា ភ័យកើតពីចិត្តដូច្នេះ សូម្បីក្នុងទីនេះ គប្បីឃើញ **អន្ត**-សព្ទ ប្រើក្នុងចិត្តប៉ុណ្ណោះ ។ ព្រោះហេតុនោះ លោកទើបពោលថា **អន្ត-តោ អត្តនោ ចិត្តេ** ពីចិត្ត គឺក្នុងចិត្តរបស់ខ្លួន ។

បទថា **ឥតិ ភវាភវតញ្ច រីតិវត្តោ** សេចក្តីថា ព្រោះហេតុដែលសម្បត្តិ

ឈ្មោះថា **ភព** វិបត្តិឈ្មោះថា **អភព** ។ ម្យ៉ាងទៀត សេចក្តីចម្រើនឈ្មោះថា **ភព** សេចក្តីសាបសូន្យឈ្មោះថា **អភព** ។ ម្យ៉ាងទៀត សេចក្តីទៀងឈ្មោះថា **ភព** សេចក្តីដាច់សូន្យឈ្មោះថា **អភព** ។ ម្យ៉ាងទៀត បុណ្យឈ្មោះថា **ភព** បាបឈ្មោះថា **អភព** ។ ម្យ៉ាងទៀត សុគតិឈ្មោះថា **ភព** ទុគតិឈ្មោះថា **អភព** ។ ម្យ៉ាងទៀត ភពតូច ឈ្មោះថា **ភព** ភពធំ ឈ្មោះថា **អភព** ។ ព្រោះហេតុនោះ លោកទើបហៅថាជា **ភវាភវៈ** ភព អភព មានប្រការជាអនេក គឺអំណាចសម្បត្តិ វិបត្តិ សេចក្តីចម្រើន សេចក្តីសាបសូន្យ សេចក្តីទៀង សេចក្តីដាច់សូន្យ បុណ្យ បាប សុគតិ ទុគ្គតិ និងឧប្បត្តិ ភពតូចធំ ។ ព្រះអរិយបុគ្គលកន្ធង់ផុត គឺឈានកន្ធង់សេចក្តីក្រោធនោះ និងភព អភព ដូចពោលមកក្នុងន័យនោះ។ តាមសេចក្តីពិត ដោយអរិយមគ្គទាំង ៤ ។ គប្បីផ្ទាស់រិកត្តិដោយអំណាចនៃអត្ត ។ បទថា **តំ វិតតភយំ** សេចក្តីថា ព្រះខីណាស្រពអ្នមានសភាពបែបនោះ អ្នកប្រកបដោយគុណដូចពោលហើយ ឈ្មោះថា **អ្នកប្រាសចាកភ័យ** ព្រោះប្រាសចាកហេតុនៃភ័យដោយមិនមានសេចក្តីកម្រើកនៃចិត្ត និងដោយឈានកន្ធង់ភវាភវៈដូចពោលហើយ ឈ្មោះថា **មានសេចក្តីសុខ** ដោយសុខដែលកើតពីវិវេក និងសុខដែលកើតពីមគ្គចិត្ត និងផលចិត្ត ឈ្មោះថា **អ្នកមិនមានសេចក្តីសោក** ព្រោះប្រាសចាកភ័យនុ៎ះឯង។ បទថា **ឧភាជានុភវន្តិ ឧស្សុជាយ** សេចក្តីថា ឧបបត្តិទេពសូម្បីទាំងអស់ រៀរអ្នកសម្រេចមគ្ត សូម្បីព្យាយាមក៏មិនបាន មិនអាចដើម្បីនឹងឃើញ គឺក្រឡេកឃើញ ដោយការឃើញដោយការ

ទន្ទេញ ត្រាប់ទៅនៃចិត្ត នឹងចាំបាច់ពោលទៅថ្វីដល់ពួកមនុស្សហ្ន៎ ក៏សូម្បីព្រះសេក្ខៈទាំងឡាយ ក៏មិនដឹងការប្រព្រឹត្តទៅនៃចិត្តរបស់ព្រះអរហន្តបាន ដូចបុថុជ្ជនមិនដឹងការប្រព្រឹត្តទៅនៃចិត្តរបស់ព្រះសេក្ខៈឯង ។

ឩសមសុត្តវណ្ណា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១០

និដ្ឋិតា ច មុចលិន្ទវគ្គវណ្ណា

ចប់មុចលិន្ទវគ្គវណ្ណនាទី ២

រួមព្រះសូត្រដែលមានក្នុងវគ្គនេះ គឺ

១-មុចលិន្ទសូត្រ	២-រាជសូត្រ
៣-ទណ្ឌសូត្រ	៤-សក្ការសូត្រ
៥-ឧបាសកសូត្រ	៦-គណ្ដិនីសូត្រ
៧-ឯកបុត្តសូត្រ	៨-សប្បវាសាសូត្រ
៩-វិសាខាសូត្រ	១០-ឩទ្ទិយសូត្រ ។

៣. ឆក្ខវគ្គោ

ឆឆ្នវគ្គទី ៣

១. កម្មវិបាកជសុត្តវណ្ណនា

អដ្ឋកថាកម្មវិបាកជសូត្រ

កម្មវិបាកជសូត្រទី ១ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **អញ្ញតរោ ភិក្ខុ** *បានដល់ ភិក្ខុជាព្រះខីណាស្រពមួយរូបដែលមិនប្រាកដនាមនិងគោត្រ ។*

បានឮមកថា ភិក្ខុនោះជាកុលបុត្រអ្នកក្រុងរាជគ្រឹះ ដែលព្រះមហាមោគ្គ-ល្លានញ៉ាំងឱ្យសង្វេគហើយឃើញទោសក្នុងសង្សារ ទើបបព្វជ្ជាក្នុងសម្នាក់ព្រះសាស្តា ជម្រះសីលឱ្យបរិសុទ្ធប្រកាន់យកនូវកម្មដ្ឋានដែលសម្បយុត្តដោយសច្ច: ៤ មិនយូរប៉ុន្មាន ចម្រើនវិបស្សនាក៏បានសម្រេចព្រះអរហត្ត ។ ក្នុងកាលជាខាងក្រោយមក ព្រះថេរៈកើតអាពាធយ៉ាងខ្លាំងក្លា គ្របសង្កត់អាពាធនោះដោយការពិចារណាបច្ចវេក្ខណ: ។ មែនពិត ធម្មតាថា ព្រះខីណាស្រពមិនមានទុក្ខផ្លូវចិត្ត តែទុក្ខផ្លូវកាយមាននៅដូចគ្នា ។ ក្នុងថ្ងៃមួយ កាលព្រះសាស្តាកំពុងសម្តែងព្រះធម៌ ព្រះថេរៈអង្គនោះ អត់ទ្រាំនូវសេចក្តីទុក្ខអង្គុយសមាធិនៅក្នុងទីមិនឆ្ងាយពីទីនោះ ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា **ភតវតោ អវិទូរេ និសិន្នោហោតិ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **បល្លঙ្ក** *ប្រែថា អង្គុយបត់ជើងដោយជុំវិញ ។ បទថា* **អាភុជិត្វា** *ប្រែថា បត់ ។ បទថា* **ឧជុं កាយं បណិធាយ** *សេចក្តីថា*

លោកតាំងកាយខាងលើឱ្យត្រង់ ហើយឱ្យធ្ងន់ខ្នង ១៨ កំណាត់ទល់ដល់គ្នា ។ ក៏កាលលោកអង្គុយយ៉ាងនេះ ស្បែក សាច់ និងសរសៃនឹងមិនតឹង ព្រោះដូច្នោះ លោកទើបបានអង្គុយយ៉ាងនោះ ។ បទថា **បុរាណកម្មវិបាកជំ** ប្រែថា កើតដោយជាវិបាកនៃកម្មដែលធ្វើទុកហើយក្នុងកាលមុន ។ ម្យ៉ាងទៀត កើតដោយចំណែកមួយនៃកម្មនោះ ក្នុងកាលវិបាករបស់កម្មចាស់ ដែលមានអាការជាសុខ និងទុក្ខ កើតជាវិបាកវដ្ត: ។ ប្រការនោះគឺអ្វី? គឺទុក្ខ ។ ក៏ដោយពាក្យថា **បុរាណកម្មវិបាកជំ** នេះលោកសម្តែងដល់អាពាធនោះ មានកម្មជាសមុដ្ឋានទើបហាមនូវកម្មដែលកើតអំពីរដូវប្រែប្រួលជាដើម ដែលធ្វើឱ្យឈឺចុកចាប់ ។ បទថា **ឧក្កំ** បានដល់ សេចក្តីទុក្ខ គឺជនចំនួនច្រើនមិនអាចនឹងអត់ទ្រាំបាន ។ បទថា **តិប្បំ** ប្រែថា ខ្លាំងក្លា គឺរឹង ព្រោះគ្របសង្កត់ឱ្យប្រព្រឹត្តទៅ ។ បទថា **ខរំ** ប្រែថា រឹងមាំ ។ បទថា **កដុកំ** ប្រែថា មិនសប្បាយ ។ បទថា **អធិវាសេន្តោ** ប្រែថា បញ្ឈប់ អត់ធ្មត់ គឺអត់ធន់យ៉ាងក្រៃលែង ។

បទថា **សតោ សម្ផជានោ** បានដល់ មានសតិ មានសម្ផជញ្ញ: ដោយអំណាចសតិ និងសម្ផជញ្ញ: ដែលជាតួកំណត់វេទនា ។ លោកពោលពាក្យអធិប្បាយនេះទុកថា ធម្មតាវេទនានេះ ឈ្មោះថា មិនទៀង ព្រោះអត្ថថា មិនមាន ឈ្មោះថា បដិច្ចសមុប្បន្ន: ព្រោះអាស្រ័យបច្ច័យ មានអារម្មណ៍ដែលមិនគួរប្រាថ្នាជាដើមកើតឡើង ឈ្មោះថា ខយធម៌ វយធម៌ វិរាគធម៌ និរោធធម៌ ព្រោះមានការកើតឡើងហើយបែកធ្លាយទៅ ដោយចំណែកតែមួយជាសភាវ: ព្រោះ

ដូច្នោះ ទើបឈ្មោះថា **សតោ** មានសតិ ព្រោះជាអ្នកធ្វើសតិដោយកំណត់ វេទនាថាជាអនិច្ចតា សេចក្តីមិនទៀង និងឈ្មោះថា ជាអ្នកមានសម្បជញ្ញៈ ព្រោះចាក់ធ្ងុនូវសការៈដែលមិនប្រែប្រួល ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមានសតិ ព្រោះមានសតិប្រាកដដោយល្អ ក្នុងកាយ វេទនា ចិត្ត និងធម៌ ក្នុងទីទាំងពួង ដោយដល់ភាពជាអ្នកបរិបូណ៌ដោយសតិ ឈ្មោះថា ជាអ្នកមានសម្បជញ្ញៈ ព្រោះជាអ្នកកំណត់សង្ខារ ដោយដល់ភាពជាអ្នកបរិបូណ៌ដោយបញ្ញាដោយប្រការនោះ ។ បទថា **អវិហញ្ញមានោ** សេចក្តីថា មិនក្តៅក្រហាយដូចអន្ធ-បុថុជ្ជន ដោយន័យដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្តាប់ កាលត្រូវទុក្ខធម៌ឯណាមួយគ្របសង្កត់ រមែងសោកសៅ លំបាក កន្ទក់កន្ទេញ ទួញយំ គក់ទ្រូង ដល់នូវភាពជាអ្នកលង់ ដូច្នេះ មិនឱ្យទុក្ខផ្ទូរចិត្តកើតឡើង ព្រោះដកឡើងបានដោយមគ្គនុ៎ះឯង អង្គុយគ្របសង្កត់នូវទុក្ខក្នុងរាងកាយ ដែលកើតអំពីវិបាកនៃកម្មតែម្យ៉ាង ដូចបុគ្គលអង្គុយចូលសមាបត្តិ ។ បទថា **អទ្ទស** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ឃើញព្រះថេរៈនោះគង់នៅយ៉ាងនោះដោយអធិវាសនខន្តិ ។

បទថា **ឯតមត្ថំ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ជ្រាបដោយប្រការទាំងពួងដល់អត្ថនេះ ពោលគឺ ព្រះខីណាស្រពមិនត្រូវលោកធម៌ពាល់ត្រូវ ដែលជាហេតុឱ្យដល់សេចក្តីមិនខ្ជល់ខ្ជាយ ដើម្បីឱ្យពេទ្យព្យាបាលរោគដូច្នោះ ។ ដោយ

បទថា **ឥមំ ឧទានំ** ព្រះអង្គទ្រង់បន្ទឺនូវឧទាននេះ ដែលជាសេចក្ដីជាក់ច្បាស់នៃសង្ខ្ជតធម៌ដែលដល់ការមិនចង្អៀតចង្អល់ ដោយទុក្ខធម៌យ៉ាងណាមួយ ។

បណ្ដាបទទាំងនោះ បទថា **សព្ពកម្មជហស្ស** បានដល់ អ្នកលះកម្មទាំងអស់បានហើយ ។ មែនពិត ចាប់ផ្ដើមតាំងពីវេលាដែលអរហត្តមគ្គកើតឡើង កុសលកម្ម និងអកុសលកម្មទាំងពួង ឈ្មោះថា គឺព្រះអរហន្ដលះបានហើយ ព្រោះមិនអាចនឹងឱ្យបដិសន្ធិបាន ដែលជាហេតុឱ្យហៅអរិយមគ្គញ្ញាណថា ធ្វើការអស់ទៅនៃកម្ម ។ បទថា **ភិក្ខុនោ** បានដល់ ឈ្មោះថា ជាភិក្ខុ ព្រោះទម្លាយកិលេស ។ បទថា **ឆុជមានស្ស បុរេកតំ រជំ** សេចក្ដីថា ទុក្ខវេទនីយ-កម្មដែលបានឈ្មោះថា **រជំ** ព្រោះលាយដោយកិលេស ដូចធូលីមានរាគៈជាដើម ដែលធ្វើទុកក្នុងកាលមុន តែការសម្រេចព្រះអរហត្តអ្នកកម្ចាត់ គឺលះបង់នូវទុក្ខ-វេទនីយកម្មនោះ ដោយការសោយវិបាក បន្ទាប់អំពីការសម្រេចព្រះអរហត្ត រមែងមិនកើតកិរិយាដែលមានទោសឡើយ និងកិរិយាដែលមិនមានទោស ក៏ត្រឹមតែកិរិយាប៉ុណ្ណោះ ព្រោះអាចដែលនឹងឱ្យផលជាហេតុកាត់ឫសរបស់ភពបានមិនឱ្យសេសសល់ ដូចផ្លាឈើមិនអាចនឹងឱ្យផល ព្រោះត្រូវកាត់ឫសដូច្នោះ ។

បទថា **អមមស្ស** សេចក្ដីថា ឈ្មោះថា មិនប្រកាន់ថារបស់យើង គឺរៀរចាកមមង្ការ ព្រោះមិនប្រកាន់ថារបស់យើងក្នុងអារម្មណ៍ណា? មានរូបារម្មណ៍ជាដើម ។ ព្រោះអ្នកដែលមានមមង្ការ រមែងឱ្យពេទ្យជាដើមរក្សាកាយ ដោយសេចក្ដីស្រឡាញ់ខ្លួន ។ ចំណែកព្រះអរហន្ដមិនមានមមង្ការ

ព្រោះដូច្នោះ លោកទើបព្រមើយ សូម្បីក្នុងការប្រតិបត្តិពាងកាយ ។ បទថា **ឋិត្តស្ស** បានដល់ អ្នកឆ្ងងឱ្ឃៈ សូម្បីទាំង ៤ ហើយតាំងនៅលើគោក គឺព្រះ-និព្វាន ឬតាំងនៅដោយមិនមានការអន្ទោលទៅ ដោយអំណាចការបដិសន្ធិ ។ មែនពិត ព្រះសេក្ខៈ និងបុថុជ្ជន ឈ្មោះថា រមែងអន្ទោលទៅដោយអំណាចចុតិ និងបដិសន្ធិ ព្រោះលោកលះកិលេស និងអភិសង្ខារមិនទាន់បាន ម្យ៉ាងទៀត ព្រះអរហន្តលោកហៅ **ឋិតោ** អ្នកតាំងនៅ ព្រោះមិនមានចុតិ និងបដិសន្ធិនោះ ។ ម្យ៉ាងទៀត បានដល់ អ្នកតាំងនៅក្នុងអរិយធម៌ ១០ ប្រការ ពោលគឺ ព្រះខីណា-ស្រព ។ បទថា **តាឥនោ** បានដល់ អ្នកប្រកបដោយអរិយឫទ្ធិ ៥ ប្រការដែលលោកពោលទុកដោយន័យមានជាអាទិ៍ថា ភិក្ខុមានសេចក្តីសម្គាល់ថា មិនគួរខ្ពើម ថារបស់គួរខ្ពើម[1] និងប្រកបដោយឧបេក្ខាមានអង្គ ៦ ដែលមិនញាប់ញ័រដោយលោកធម៌ ៨ ឈ្មោះថា អ្នករឹងមាំដែលព្រោះជាអ្នករឹងមាំពោលគឺ ភាពជាអ្នកដូចគ្នាក្នុងឥដ្ឋារម្មណ៍ជាដើម ។ បទថា **អត្ថো ន ត្ថិ ជនំ លបេតវេ** សេចក្តីថា មិនមានប្រយោជន៍ដែលនឹងពោល គឺនិយាយចំពោះជនថា លោកទាំងឡាយ ចូរផ្សុំថ្នាំជាដើមដល់យើង ព្រោះមិនមានសេចក្តីអាល័យក្នុងពាងកាយ ។ មែនពិត អធ្យាស្ស័យរបស់ព្រះខីណាស្រព(មាន)ថា កាយនេះចូរបែកធ្លាយទៅឯងតែម្តង ដូចស្លឹកឈើពណ៌លឿងជ្រុះពីទងដូច្នោះ ។ សមដូចពាក្យដែលលោកពោលទុកថា

ជាកិនជ្ជាមិ មរណំ ជាកិនជ្ជាមិ ជីវិតំ

---

[1]-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧១ ទំព័រ ២៨១ ។

កាលញ្ច បដិកង្ខামិ និព្ពិសំ ភតកោ យថា[១]

អាត្មាមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មារង់ចាំតែកាលនឹងបរិនិព្វាន ដូចជាអ្នកស៊ីឈ្នួល ទទឹងតែអស់ថ្ងៃ[២] ។

ម្យ៉ាងទៀត ព្រះខីណាស្រពមិនមានសេចក្តីត្រូវការដើម្បីនឹងសម្តែងនិមិត្តយ៉ាងណាមួយ ហើយពោលនឹងជនថា លោកម្ចាស់ត្រូវការអ្វី គឺដើម្បីឱ្យជននិយាយដោយការនិមន្តដោយបច្ច័យទាំងឡាយ ព្រោះលោកដកមិច្ឆាជីវៈដូច្នោះចេញបានដោយមគ្គចិត្តនុ៎ះឯង ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទើបទ្រង់ប្រកាសហេតុក្នុងការឱ្យព្យាបាលព្រះថេរៈ សម្រាប់ពួកជនអ្នកគិតថាដើម្បីប្រយោជន៍អ្វី ព្រះថេរៈនេះទើបឱ្យពេទ្យព្យាបាលរោគរបស់ខ្លួនហើយអង្គុយក្នុងទីមិនឆ្ងាយព្រះដ៏មានព្រះភាគ ។

បឋមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១

១-ក្នុងច្បាប់ឆដ្ឋសង្គាយនា និងក្នុងអដ្ឋកថាបរមត្ថទីបនីច្បាប់មហាវិទ្យាល័យមហាមកុដ មានព្រះបាលីផ្សេងគ្នាយ៉ាងនេះថា

ជាកិកង្ខামិ មរណំ, ជាកិកង្ខামិ ជីវិតំ;
កាលញ្ច បដិកង្ខামិ, និព្ពិសំ ភតកោ យថា ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា លេខ ៥៧ ទំព័រ ២៧ ។

២. ឧទ្ធសុត្តវណ្ណនា

អដ្ឋកថានទ្ធសូត្រ

ទ្ធសូត្រទី ២ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ឧទ្ធো** *ជាឈ្មោះរបស់ព្រះថេរៈនោះ ។ មែនពិត ព្រះថេរៈនោះ បាននាមថា* **ទ្ធ** *ព្រោះមាតាបិតា បរិវារជន និងសាច់ញាតិទាំងអស់កើតសេចក្តីត្រេកអរ ព្រោះលោកប្រកបដោយលក្ខណៈនៃស្តេចចក្រពត្តិ ។ បទថា* **ភគវតো ភាតា** *សេចក្តីថា ឈ្មោះថា ជាព្រះអនុជ ព្រោះជាឱរសរួមបិតាតែមួយនឹងព្រះដ៏មានព្រះភាគ ។ មែនពិត មិនមានព្រះឱរសដែលកើតរួមគភ៌នឹងព្រះដ៏មានព្រះភាគ ព្រោះហេតុនោះ លោកទើបពោលថា* **មាតុច្ឆាបុត្តো** *អធិប្បាយថា ជាឱរសរបស់ព្រះមាតុច្ឆា (ម្តាយមីង) ។ ព្រោះថា លោកជាឱរសរបស់ព្រះមាតុច្ឆានាមថា មហាបជាបតិគោតមី ។ បទថា* **អនភិរតো** *កាត់បទជា* **ន អភិរតো** *ប្រែថា មិនត្រេកអរ ។ បទថា* **ព្រហ្មចរិយំ** *បានដល់ ការប្រព្រឹត្តដូចព្រហ្ម គឺប្រសើរឧត្តុង្គឧត្តម មានការអង្គុយទីតែមួយ ដេកក្នុងទីតែមួយ រៀរមេថុនធម្ម ។ បទថា* **សង្ខារេតុំ** *បានដល់ ដើម្បីនឹងញ៉ាំងចិត្តដួងដំបូងដរាបដល់ចិត្តដួងចុងបង្ស់ឱ្យដំណើរទៅ គឺឱ្យប្រព្រឹត្តទៅដោយប្រពៃ គឺបរិបូណ៌ បរិសុទ្ធ ។ ក៏ក្នុងសេចក្តីនេះ គប្បីជ្រាបសង្គ្រហៈ គឺការសង្គ្រោះមគ្គព្រហ្មចរិយៈ ដោយបទថា ព្រហ្មចរិយៈបទទី ២ ។ បទថា* **សិក្ខំ បច្ចក្ខាយ** *សេចក្តីថា ហាមគឺលះបង់សិក្ខា ៣ ដែលសមាទានព្រមនឹងភាពជាកិក្ខុការៈក្នុងវេលាឧបសម្បទា ដែលមិនតាំងឡើងដោយការៈដែលគួរនឹងកើត ។ បទថា* **ហីនាយ** *ប្រែថា ដើម្បីភាពជាគ្រហស្ថ ។ បទថា* **អាវត្តិស្សាមិ** *បានដល់ នឹងត្រឡប់ទៅ ។ សួរថា ក៏ព្រោះហេតុអ្វី លោកទើបក្រាបទូលយ៉ាងនោះ? ក្នុងសេចក្តីនោះ មានអនុបុព្វីកថា*

ដូចតទៅនេះ

ព្រះដ៏មានព្រះភាគទ្រង់ប្រកាសព្រះធម្មចក្រដ៏ប្រសើរ ហើយស្តេចយាងទៅកាន់ក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងវត្តវេឡុវ័ន គឺព្រះកាឡុទាយិត្ថេរ ជាទូតចុងក្រោយគេបង្ហស់ បណ្តាទូត ១០ នាក់ ដែលមានបរិវារម្នាក់ ១.០០០ ។ ដែលព្រះបាទសុទ្ធោទនមហារាជទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា អ្នកទាំងឡាយចូរនាំបុត្រមកបង្ហាញដល់យើង បានសម្រេចព្រះអរហត្តព្រមដោយបរិវារ សម្រេចព្រះអរហត្តហើយដឹងកាលស្តេចទៅរបស់ព្រះអង្គ បានពណ៌នាផ្លូវ ហើយទូលអារាធនាដើម្បីស្តេចទៅកាន់ព្រះជាតិភូមិ ហៃហមដោយព្រះខីណាស្រពពីរម៉ឺន (២.០០០០) អង្គ ស្តេចដល់ក្រុងកបិលវត្ថុ ទ្រង់ធ្វើភ្ជៀងបោក្ខរព័ស្ថក្នុងសមាគមព្រះញាតិឱ្យកើតឡើង ហើយទ្រង់សម្តែងវេស្សន្តរជាតក ក្នុងថ្ងៃបន្ទាប់មកព្រះអង្គយាងបិណ្ឌបាតទ្រង់ឱ្យព្រះបិតាតាំងនៅក្នុងសោតាបត្តិផល ដោយព្រះគាថាថា **ឧត្តិដ្ឋេ ឧប្បមជ្ជេយ្យ** បុគ្គលមិនគួរប្រមាទក្នុងដុំបាយដែលខ្លួនគប្បីក្រោកឡើងទទួល[១] ហើយស្តេចទៅកាន់ព្រះរាជនិវេសន៍ ទ្រង់ឱ្យព្រះនាងមហាបជាបតិ-គោតមីតាំងនៅក្នុងសោតាបត្តិផល ទ្រង់ឱ្យព្រះរាជាតាំងនៅក្នុងសកទាគামិផលដោយព្រះគាថាថា **ធម្មញ្ចរេ** បុគ្គលគួរប្រព្រឹត្តធម៌ (ឱ្យសុចរិត)[២] ជាដើម។

ក៏ក្នុងការជាទីបំផុតកត្តកិច្ច ទ្រង់អាស្រ័យការពណ៌នាព្រះគុណរបស់ពហុលមាតា សម្តែងចន្ទកិន្នរីជាតក ក្នុងថ្ងៃទី ៣ នាកាលថ្ងៃវិវាហមង្គលដែលជា

១-២-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៥៧ ។

ទីយ៉ាងនន្ទកុមារចូលផ្ទះដើម្បីអភិសេកឱ្យប្រព្រឹត្តទៅ ក៏ព្រះដ៏មានព្រះភាគចូលទៅបិណ្ឌបាត ប្រទានបាត្រក្នុងព្រះហស្តរបស់នន្ទកុមារត្រាស់មង្គលព្រះដ៏មាន-ព្រះភាគក្រោកពីអាសនៈហើយយាងជៀសចេញទៅ មិនបានទ្រង់ទទួលបាត្រពីព្រះហស្តរបស់នន្ទកុមារទេ ។ ចំណែកនន្ទកុមារនោះ ដោយសេចក្តីគោរពក្នុងព្រះតថាគត ទើបមិនអាចទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទទួលបាត្រចុះ ។ តែគិតយ៉ាងនេះថា ព្រះសាស្តាគង់នឹងទ្រង់ទទួលបាត្រត្រង់ក្បាលជណ្តើរ ក្នុងទីនោះព្រះសាស្តាក៏ទ្រង់មិនទទួល ។ ចំណែកនន្ទកុមារ ក៏គិតថា គង់នឹងទទួលត្រង់ជើងជណ្តើរ សូម្បីក្នុងទីនោះ ព្រះសាស្តាក៏ទ្រង់មិនទទួល ។ នន្ទកុមារគិតថា នឹងទ្រង់ទទួលត្រង់ព្រះរាជវាំង សូម្បីក្នុងទីនោះ ព្រះសាស្តាក៏ទ្រង់មិនទទួល ។ ព្រះរាជកុមារមានបំណងនឹងត្រឡប់វិញ កាលទៅដោយសេចក្តីមិនពេញព្រះទ័យ តែមិនហ៊ានពោល ទើបមិនអាចទូលថា សូមព្រះអង្គទ្រង់ទទួលបាត្រចុះ ដោយសេចក្តីគោរពទ្រង់ដើរគិតថា ព្រះអង្គនឹងទ្រង់ទទួលក្នុងទីនេះ ព្រះអង្គនឹងទ្រង់ទទួលក្នុងទីនោះ ។

ខណៈនោះ ជនទាំងឡាយពោលនឹងនាងជនបទកល្យាណីថា បពិត្រព្រះនាងម្ចាស់ ព្រះដ៏មានព្រះភាគទ្រង់នាំនន្ទកុមារស្តេចទៅហើយ ព្រះនាងគង់នឹងវិនាសពីនន្ទកុមារ ។ នាងជនបទកល្យាណីនោះ មានតំណក់ទឹកភ្នែកស្រក់ចុះមក មានសក់លាពាក់កណ្តាល ប្រញាប់ឡើងកាន់ប្រាសាទ ឈរទ្រង់ទ្វារនៃសីហបញ្ជរ (បង្ហួច) ទូលថា បពិត្រព្រះអយ្យបុត្ត សូមព្រះអង្គចូរប្រញាប់ត្រឡប់មកវិញញាប់ ។ ពាក្យរបស់នាងនោះ ដូចជាធ្លាក់ទៅទទឹងតាំងនៅក្នុងហ្ឫទ័យរបស់នន្ទកុមារនោះ ។ សូម្បីព្រះសាស្តាក៏ទ្រង់មិនទទួលបាត្រពីព្រះហស្តរបស់

នន្ទកុមារនោះឡើយ ទ្រង់នាំនន្ទកុមារនោះទៅកាន់វិហារ ហើយត្រាស់ថា នន្ទ លោកចង់បួសទេ? នន្ទនោះដោយសេចក្តីគោរពក្នុងព្រះពុទ្ធ ទើបមិនទូលថា នឹងមិនបួសទូលទទួលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបួស ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយបើដូច្នោះ អ្នកទាំងឡាយ ចូរឱ្យនន្ទបួសចុះ ទើបស្តេចទៅកាន់ក្រុងកបិលវត្ថុក្នុងថ្ងៃទី ៣ ទ្រង់ឱ្យនន្ទកុមារបួសហើយ ។ ក្នុង ថ្ងៃទី ៧ ព្រះសាស្តាឱ្យរាហុលកុមារ ដែលព្រះមាតាតាក់តែងបញ្ជូនទៅដោយតម្រាស់ថា បពិត្រព្រះសមណៈ លោកចូរប្រទានទ្រព្យមរតកដល់ខ្ញុំព្រះអង្គចុះ ដូច្នេះហើយ មកកាន់អារាមជាមួយនឹងព្រះអង្គឱ្យបព្វជ្ជាហើយ ។ ថ្ងៃស្អែកទើប ព្រះដ៏មាន-ព្រះភាគត្រាស់មហាធម្មបាលជាតក ឱ្យព្រះរាជាតាំងនៅក្នុងអនាគាមិផល ។

ព្រះដ៏មានព្រះភាគ ទ្រង់ឱ្យព្រះនាងមហាបជាបតិគោតមីតាំងនៅក្នុងសោតាបត្តិផល ទ្រង់ឱ្យព្រះបិតាតាំងនៅក្នុងផល ៣ ទ្រង់ហៅហមទៅដោយភិក្ខុទាំងឡាយ ស្តេចទៅកាន់ក្រុងរាជគ្រឹះទៀត តអំពីនោះបានទទួលប្តេជ្ញាដែលអនាថបិណ្ឌិកៈយាង ដើម្បីស្តេចមកកាន់ក្រុងសាវត្ថី នាកាលជេតពនមហាវិហារសម្រេចហើយ ក៏ស្តេចទៅប្រថាប់នៅក្នុងទីនោះ ដោយប្រការដូច្នេះ ។ នាកាលព្រះសាស្តាប្រថាប់នៅក្នុងវត្តជេតពន ដោយអាការយ៉ាងនេះ ព្រះនន្ទក៏មានអាយុបួសដោយមិនពេញព្រះទ័យ មិនឃើញទោសក្នុងកាម តែងរឭករឿយៗ នូវពាក្យដែលនាងជនបទកល្យាណីពោល កើតសេចក្តីអផ្សុកប្រាប់សេចក្តីមិនត្រេកអរដល់ភិក្ខុទាំងឡាយ ។ ព្រោះហេតុនោះ លោកទើបពោលថា **តេន ខោ បន សមយេន អាយស្មា នន្ទោ ។បេ។ ហីនាយាវត្តិស្សាមិ** ដូច្នេះ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ ទើបឱ្យនន្ទបួសយ៉ាងនោះ ។ ឆ្លើយថា ព្រោះព្រះសាស្តា ជាអ្នកឆ្ងាតក្នុងការទូន្មានវេនេយ្យសត្ត្ব ដោយប្រាជ្ញា ថា តថាគតនឹងសម្តែងទោសមុនតែម្តង ទើបមិនឱ្យនន្ទស្ងាត់ពីកាមទាំងឡាយ បាន កាលឱ្យបួសហើយ ទើបឱ្យស្ងាត់ចាកកាមនោះដោយឧបាយ ទើបញ្ជាំង គុណវិសេសខាងលើឱ្យកើតឡើង កាលបើដូច្នេះ ទើបឱ្យនន្ទនោះបួសមុន ។ បទថា **សាកិយានី** *បានដល់ ធីតានៃស្តេចសក្យ: ។ បទថា* **ជនបទកល្យាណី** *ប្រែថា ស្ត្រីជាលម្អក្នុងជនបទ អ្នកល្អដោយរូប រៀរទោសក្នុងរាងកាយ ៦ យ៉ាង ប្រកបដោយសេចក្តីល្អ ៥ យ៉ាង ។ មែនពិត នាងជនបទកល្យាណីនោះមិន ខ្ពស់ពេក មិនទៀបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិន-សពេក ព្រោះថា នាងជនបទកល្យាណីនោះ កន្ធ:វណ្ណ:របស់មនុស្ស តែមិនដល់វណ្ណ: របស់ទេវតាទេ ព្រោះដូច្នោះ ទើបឈ្មោះថា រៀរទោសក្នុងរាងកាយ ៦ ប្រការ ។ ប្រកបដោយសេចក្តីល្អទាំងនេះ គឺលម្អសម្ផ្ការស្បែក លម្អសាច់ លម្អក្រចក (កន្ទែងខ្ញុះពោលថា លម្អសក់) លម្អធ្មេ៏ង និងលម្អវ័យ[1] ។ បណ្តាលម្អ ៥ យ៉ាង នោះ សម្ផ្ការស្បែករមែងធ្វើសេចក្តីភ្ញ៏ក្នុងទីប្រមាណ ១០-១២ ហត្ថ ដោយភ្ញ៏ចេញ ពីសរីរ:របស់ខ្លួន មានសម្ផ្ការស្បែកស្មើដោយផ្ការប្រយង្គ[2] ឬស្មើដោយមាស*

១-ក្នុងគម្ពីរធម្មបទដ្ឋកថា អដ្ឋកថា ធម្មបទ បានពោលថា **កេសកល្យាណំ មំសកល្យាណំ អដ្ឋិកល្យាណំ ឆវិកល្យាណំ វយកល្យាណំ** *។ លម្អសក់ លម្អសាច់ លម្អធ្មេ៏ង លម្អសម្ផ្ការ-ស្បែក លម្អវ័យ ។*

២-ប្រយង្គ ប្រយ៉ង់ សំ.; បា. (ន.) (ប្រិយង្គ; ឫ ២ យ) ឈ្មោះឈើតូចពួកមួយមានផ្ការជាចង្កោមកម្រងល្អិតៗ សម្ផ្ការលឿងក្ងិនក្រអូបធ្ងាញ់ ប៉ុន្តែក្រអូបស្ពើយ; មាន ២ ប្រភេទគឺ ប្រយង្គ៏ធំ ស្ងឹកស្រដៀងនឹងស្ងឹកឈើកែវ; ប្រយង្គ៏តូច ស្ងឹកតូចៗ ។

នេះឈ្មោះថា ជាលម្អសម្បុរស្បែករបស់នាង ។ ចំណែកដៃទាំងពីរ ជើង ទាំងពីរ និងបបូរមាត់របស់នាង ប្រាកដស្មើដោយកែវប្រវាឡនិងសំពត់កម្ពលក្រហម ហាក់ដូចជាទឹកលក្ខ្ម ដែលលាបហើយ នេះឈ្មោះថា លម្អសាច់របស់នាង ។ ចំណែកក្រចកទាំង ២០ ដែលជាប់នឹងសាច់ ប្រាកដស្មើដោយលក្ខ្ម ដែលគេលាបហើយ ក្រចកដែលផុតពីពីសាច់ ប្រាកដស្មើដោយ-ទនៃទឹកដោះ នេះឈ្មោះថា លម្អក្រចករបស់នាង ។ ធ្មេញ ៣២ ដែលជិតស្និទ្ធល្អ ប្រាកដដូចជាជួររបស់កែវប្រវាឡដែល-សបរិសុទ្ធរមែងប្រាកដដូចរបៀបនៃពេជ្រ នេះឈ្មោះថា លម្អធ្មីងរបស់នាង ។ នាងសូម្បីមានអាយុ ១២០ ឆ្នាំ ដូចជាស្ត្រីក្រមុំអាយុ ១៦ ឆ្នាំ មិនមានសក់ស្គរឡើយ នេះឈ្មោះថា លម្អវ័យរបស់នាង ។ និងនាងជាអ្នកមានសេចក្ដីល្អស្អាត ប្រកបដោយគុណសម្បត្តិបែបនេះ ។ ព្រោះហេតុនេះ លោកទើបពោលថា **ជនបទកល្យាណី** ស្ត្រីជាអ្នកលម្អក្នុងជនបទ ។

បទថា **ឃ ឧ ក្ខ ម ន្ត ស្ស** ជាធដ្ឋីវិភត្តិប្រើក្នុងអត្ថអនាទរ[1] អធិប្បាយថា នាកាលចេញចាកផ្ទះ ។ អាចារ្យពួកខ្លះពោលថា **ឃ ឧ ក្ខ ម ន្តិ** ដូច្នេះក៏មាន ។ បទថា **ឧ ប ឌ្ឍ ល្ងិ ទ ិ ត េ ហ ិ ។ ក ោ ស េ ហ ិ** ជាតតិយាវិភត្តិ ប្រើក្នុងឥតម្ហូត-លក្ខណៈ[2] អធិប្បាយថា នាងមានសក់ស្ងិតស្អាងបានពាក់កណ្ដាល ។ អាចារ្យពួកខ្លះពោលថា **អ ឌ្ឍ ល្ងិ ទ ិ ត េ ហ ិ** ដូច្នេះក៏មាន ។ ក៏ពាក្យថា **ឧ ល្ងិ ទ ំ** ជាការ

១-អនាទរ ជាឈ្មោះសម្ព័ន្ធនៃធដ្ឋីវិភត្តិដែលប្រើក្នុងប្រយោគអនាទរ មានពាក្យប្រៃថា **កាល កាលបើ កាលដែល** ។

២-ជាប្រភេទនៃស័ព្ទដែលប្រកដដោយតតិយាវិភត្តិ ដែលសម្ដែងអាការជាបទវិសេសនៈរបស់បទដែលមានវិភត្តិផ្សេងគ្នា មានពាក្យប្រៃថា **មាន** ។

ធ្វើសក់ឱ្យបាសជាដើម ។ អាចារ្យមួយពួកទៀតពោលថា **អឞ្ឌការវិធានំ** ដូច្នេះ ក៏មាន ។ បទថា **អបលោកេត្វា** បានដល់ រមិលមើលដោយនេត្រា ដែលបំភ្ជឿ ដល់សេចក្ដីជ្រួតជ្រាបទៅនៃរសស្នេហា ហាក់ដូចជាការចងទុក ។ បទថា **មំ ឧត្តេ** សេចក្ដីថា សូម្បីក្នុងកាលមុនលោកពោលពាក្យថា **មំ** ហើយលោកពោលពាក្យ ថា **មំ ឯតទវោច** ម្ដងទៀត ព្រោះនាងមានចិត្តក្រវល់ក្រវាយដោយសេចក្ដី អផ្សុក ។ បទថា **តុវដំ** ប្រែថា រហ័ស ភ្លាមៗ ។ បទថា **តមត្ថសារមាណো** សេចក្ដី ថា ព្រះនន្ទដ៏មានអាយុរឭកដល់ពាក្យរបស់នាងនោះ ឬពាក្យដែលប្រកបដោយ អាការរបស់នាងនោះ ។

ព្រះដ៏មានព្រះភាគ កាលដែលទ្រង់ស្ដាប់ពាក្យរបស់ព្រះនន្ទដ៏មានអាយុ នោះហើយ ទ្រង់ត្រិះរិះនឹងរម្ងាប់ភាគ:របស់នន្ទដោយឧបាយ ដូច្នេះហើយ ក៏នាំ នន្ទនោះទៅ កាន់ភពតាវត្ដឹង្សដោយកម្ទាំងឫទ្ធិ ទើបទ្រង់បង្ហាញមេស្វាមានពោម រចមួយក្បាល មានត្រចៀក ច្រមុះ និងកន្ទុយដាច់ អង្គុយនៅលើដង្គត់ឈើ ដែលត្រូវភ្លើងឆេះ ក្នុងស្រែដែលត្រូវភ្លើងឆេះមួយកន្ទ្ធេង ក្នុងចន្ទោះផ្ទ្ធរ ហើយ ទ្រង់នាំទៅកាន់ភពតាវត្ដឹង្ស ។ តែក្នុងព្រះបាលី ព្រះសាស្ដាត្រាស់ដូចទៅកាន់ ភពតាវត្ដឹង្សដោយ ត្រឹមតែមួយភ្នែតប៉ុណ្ណោះ មិនត្រាស់ការទៅយ៉ាងនោះ ត្រាស់សំដៅយកភពតាវត្ដឹង្ស ។ មែនពិត ព្រះដ៏មានព្រះភាគ កាលស្ដេចទៅ យ៉ាងនោះ ទ្រង់បង្ហាញមេស្វាមានពោមរចមួយក្បាលនោះដល់ព្រះនន្ទដ៏មាន អាយុត្រង់ចន្ទោះផ្ទ្ធរ ។ កាលបើដូច្នោះ ការសម្ដែងការបត់ (ដៃ) ជាដើម ជាយ៉ាង ណា? ការសម្ដែងយ៉ាងនោះគួរកាន់យកថា ជាការសម្ដែងការអន្ដរធានទៅ ។ ព្រះសាស្ដាទ្រង់នាំព្រះនន្ទដ៏មានអាយុទៅកាន់ភពតាវត្ដឹង្ស ដោយប្រការយ៉ាង

នោះ ហើយទ្រង់បង្ហាញនាងអប្សរ ៥០០ នាក់ អ្នកមានជើងដូចជើងសត្វព្រាប ដែលមកបម្រើស្តេចសក្កទេវរាជ ឈរថ្វាយបង្គំព្រះអង្គ ហើយត្រាស់សួរសេចក្តីប្ញែកគ្នា ដោយធៀបរូបសម្បត្តិរបស់នាងអប្សរ ៥០០ នាក់ទាំងនោះនឹងនាងជនបទកល្យាណី ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ ភគវា អាយស្មន្តំ ឧទ្ទំ ពាហាយ គហេត្វា ។ បេ ។ ភិក្ខុជ្ជ ចាតានិ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ពាហាយ គហេត្វា** ប្រែថា ដូចជាការចាប់ដៃ ។ មែនពិតក្នុងវេលានោះ ព្រះដ៏មានព្រះភាគទ្រង់តាក់តែងឥទ្ធាភិសង្ខារ ដូចដែលព្រះនន្ទដ៏មានអាយុ ដូចជាត្រូវព្រះដ៏មានព្រះភាគចាប់ដៃនាំទៅដូច្នោះ ។ ក៏ក្នុងកាលនោះ បើព្រះដ៏មានព្រះភាគទ្រង់ប្រាថ្នាឱ្យព្រះនន្ទដ៏មានអាយុឃើញ ឬចូលទៅកាន់ទេវលោកជាន់តាវត្តឹង្ស ព្រះអង្គក៏គប្បីទ្រង់បង្ហាញទេវលោកនោះដល់នន្ទ អ្នកអង្គុយយ៉ាងនោះឯង ដូចក្នុងវេលាសម្តែងឫទ្ធិក្នុងការបើកលោក ឬគប្បីបញ្ជូន ព្រះនន្ទដ៏មានអាយុនុ៎ះឯងទៅក្នុងទេវលោកដោយឫទ្ធិ ។ ក៏ដើម្បីនឹងកាន់យកដោយងាយ ដល់ការៈនៃអត្តភាពរបស់មនុស្សជាវត្ថុដែលអាក្រក់ និងគួរស្អប់ជាងអត្តភាពដែលជាទិព្ធ ព្រះអង្គប្រាថ្នានឹងទ្រង់បង្ហាញមេស្វាមានពោមរមៃនោះ ក្នុងចន្លោះផ្ទៃដល់ព្រះនន្ទដ៏មានអាយុ និងមានប្រាថ្នានឹងទ្រង់បង្ហាញឱ្យនន្ទប្រកាន់យកសិរីសម្បត្តិ និងភវសម្បត្តិក្នុងទេវលោកដូច្នោះ ទើបទ្រង់នាំនន្ទទៅក្នុងទេវលោកនោះ ។ សូម្បីដោយអាការយ៉ាងនេះ នន្ទក៏នឹងមានសេចក្តីត្រេកអរយ៉ាងក្រៃលែង ជាពិសេសក្នុងការប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីសម្បត្តិនោះឯង ។

បទថា **កកុដ្ដបាទិនិ** សេចក្ដីថា ឈ្មោះថា មានជើងប្រាកដស្មើដូចសត្វព្រាបព្រោះមានពណ៌ក្រហម ។ បានឮមកថា នាងអប្សរសួគ៌ទាំងអស់នោះមានជើងស្អាតល្អដូច្នោះ ព្រោះបានថ្វាយប្រេងសម្រាប់លាបជើងដល់សាវករបស់ព្រះដ៏មានព្រះភាគព្រះនាមថា **កស្សបៈ** ។ បទថា **បស្សសិ នោ** កាត់បទជា **បស្សសិ នុ** ។ បទថា **អភិរូបតរា** ប្រែថា មានរូបវិសេសជាង ។ បទថា **ទស្ស-នីយតរា** សេចក្ដីថា ឈ្មោះថា គួរសរសើរជាង ព្រោះអត្ថថា ធ្វើអ្នកក្រឡេកមើលសូម្បីរហូតដល់អស់មួយថ្ងៃក៏មិនឆ្អែត ។ បទថា **បាសាទិកតរា** បានដល់ នាំមកនូវភាពដែលគួរឱ្យសរសើរដោយទូទៅ ព្រោះមានអវយវៈគ្រប់ចំណែកល្អ ។

ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគទើបទ្រង់ឱ្យព្រះនន្ទដ៏មានអាយុ អ្នកមានចិត្តដែលជោគដោយរាគៈ ក្រឡេកមើលនាងអប្សរហ្ន៎? ដើម្បីនឹងនាំកិលេសរបស់នន្ទចេញដោយការសប្បាយតែម្យ៉ាង ។ គប្បីជ្រាបសេចក្ដីឧបមាថា ពេទ្យអ្នកឆ្លាត ព្យាបាលបុគ្គលអ្នកមានរោគជាដំបូង ជម្រះរោគដោយការផឹកប្រេងជាដើម ខាងក្រោយទើបឱ្យនាំចេញ ដោយការក្អួតនិងការបន្ទោបង់ បានដោយងាយយ៉ាងណា ព្រះដ៏មានព្រះភាគអ្នកឆ្លាតក្នុងការទូន្មានវេនេយ្យសត្វក៏ដូច្នោះ ទ្រង់បង្ហាញនាងទេវអប្សរដល់នន្ទ អ្នកមានរាគៈក្រាស់ឱ្យអស់ទោស ទ្រង់ប្រាថ្នានឹង នាំនន្ទចេញដោយដាច់ខាតដោយថ្នាំ គឺអរិយមគ្គ ។

បទថា **បលុដ្ឋមក្កដី** បានដល់ មេស្វាមានរោមរេចមួយក្បាល មានអវយវៈដែលត្រូវភ្លើងឆេះ ។ បទថា **ឯវមេវខោ** សេចក្ដីថា បពិត្រព្រះអង្គដ៏ចម្រើន មេស្វាមានរោមរេច ដែលមានត្រចៀក និងច្រមុះដាច់ដែលព្រះអង្គទ្រង់បង្ហាញដល់ខ្ញុំព្រះអង្គនោះ ធៀបនឹងនាងជនបទកល្យាណីយ៉ាងណា នាង

ជនបទកល្យាណីធៀបនឹងនាងអប្សរ ៥០០ នាក់ទាំងនេះ ក៏ដូច្នោះដែរ ។ បទថា **បញ្ចន្នំ អច្ឆរាសតានំ** ជាឆដ្ឋីវិភត្តិប្រើក្នុងអត្ថទុតិយាវិភត្តិ សេចក្តីថា នូវនាងអប្សរ ៥០០ ។ ម្យ៉ាងទៀត បទថា **បញ្ចន្នំ អច្ឆរាសតានំ** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងការសម្ព័ន្ធនឹងអវយៈ ។ ដោយពាក្យនោះមានអធិប្បាយថា ធៀបរូបសម្បត្តិរបស់នាងអប្សរ ៥០០ នាក់ ។ ក៏បទថា **ឧបនិធាយ** បានដល់ តាំងនៅក្នុងទីជិតគ្នា អធិប្បាយថា ប្រៀបផ្ទឹមគ្នា ។ បទថា **សង្ខ្យំ** បានដល់ ការរាប់ពណ៌នាថា ស្រី ។ បទថា **កលភាគំ** ប្រែថា បែងចំណែកមួយឱ្យជា ១៦ ចំណែក ហើយកាន់យកចំណែកតែមួយពី ១៦ ចំណែកនោះ ហើយពាប់ដោយ ១៦ ចំណែក ក្នុង ១៦ ចំណែកនោះ តែមួយចំណែកលោកប្រាជ្ញាយកថា ចំណែកនៃចំណិត ។ លោកពោលថា មិនចូលដល់ចំណែកនៃចំណិតសូម្បីនោះ ។ បទថា **ឧបនិធី** បានដល់ សូម្បីដាក់ទុកក្នុងទីជិតគ្នា ដោយកាន់យកដោយសេចក្តីប្រៀបផ្ទឹមថា ស្រីនេះដូចគ្នានឹងស្រីនេះ ។ ព្រហ្មចរិយៈដែលព្រះនន្ទដ៏មានអាយុនេះ មិនត្រេកអរនោះពោលទុកហើយនិងប្រាកដក្នុងកាលមុន ព្រោះដូច្នោះ ដើម្បីមិនប៉ះពាល់ប្រការនោះ ទើបឱ្យលោកកើតសេចក្តីអើពើក្នុងសេចក្តីត្រេកអរយ៉ាងក្រៃលែងក្នុងព្រហ្មចរិយៈនោះ ទើបត្រាស់ដដែលថា ម្នាលនន្ទ អ្នកចូរត្រេកអរចុះ ម្នាលនន្ទ អ្នកចូរត្រេកអរចុះ ដូច្នេះ ។ បទថា **អហំ តេ ចាជិកោ** សេចក្តីថា ព្រោះហេតុអ្វីព្រះដ៏មានព្រះភាគ ទ្រង់ប្រាជ្ញាឱ្យនន្ទនៅប្រព្រឹត្តព្រហ្ម-ចរិយៈ ទើបទ្រង់ជានាមិនឱ្យនន្ទនៅប្រព្រឹត្តព្រហ្មចរិយធម៌ទៅវិញ? ឆ្វើយថា ព្រោះព្រះអង្គ ដើម្បីនឹងធ្វើអារម្មណ៍ដែលនន្ទមានរាគៈជាប់នៅយ៉ាងមាំ ហើយ

ឱ្យឈានទៅក្នុងអារម្មណ៍ថ្មី ទើបអាចឱ្យលះបានដោយងាយ ព្រោះហេតុនោះ ទើបទ្រង់ទទួលជានា ។ ក្នុងអនុបុព្វីកថា មានសគ្គកថាជាគ្រឿងចង្អុលដល់អត្ថនេះ ។ បទថា **អស្សោសុំ** បានដល់ ភិក្ខុទាំងឡាយបានស្តាប់មកយ៉ាងណាក៏ព្រោះក្នុងវេលានោះ ព្រះដ៏មានព្រះភាគ កាលព្រះនន្ទដ៏មានអាយុសម្តែងវត្ត ហើយទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន ត្រាស់រឿងនោះដល់ភិក្ខុអ្នកមកឧបដ្ឋាក មានព្រះបំណងនឹងនាំសេចក្តីកំណត់របស់នន្ទ ក្នុងអារម្មណ៍ដែលធ្លាប់ជិនណាយ ដោយអារម្មណ៍ថ្មី ហើយទើបនាំចេញទៅ ធ្វើអារម្មណ៍សូម្បីនោះឱ្យជាហេតុ ក្នុងមគ្គព្រហ្មចរិយៈ ដូចបុរសអ្នកធ្នាត យកស្នៀតថ្មីមកដំបញ្ចេញស្នៀតចាស់ ហើយយកដៃជាដើមចាប់ស្នៀតនោះលើកទៅមកហើយទាញចេញ ទើបទ្រង់បញ្ជាថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទៅហៅនន្ទភិក្ខុដោយវាទៈថា អ្នកស៊ីឈ្នួល និងដោយវាទៈថា ជាអ្នកគឺព្រះដ៏មានព្រះភាគទ្រង់លោះ ។ ភិក្ខុទាំងឡាយបានស្តាប់មកយ៉ាងនោះ ។ ចំណែកអាចារ្យពួកខ្លះពោលថា ព្រះដ៏-មានព្រះភាគទ្រង់តាក់តែងឥទ្ធាភិសង្ខារ ដូចដែលភិក្ខុទាំងឡាយដឹងសេចក្តីនោះ ។

បទថា **ភតកាវ**ន ប្រែថា ដោយវាទៈថា កូនឈ្នួល ។ ក៏អ្នកណាធ្វើការងារដើម្បីតម្លៃឈ្នួល អ្នកនោះគេហៅថា កូនឈ្នួល ។ ព្រះនន្ទដ៏មានអាយុសូម្បីនេះ ប្រព្រឹត្តព្រហ្មចរិយៈដើម្បីបាននៅរួមនឹងនាងអប្សរជាហេតុ ទើបលោកដូចជាកូនឈ្នួល ព្រោះដូច្នោះ ទើបត្រាស់ថា **ភតកាវ**ន ដូច្នេះ ។ បទថា **ឧបញ្ញិតកាវ**ន សេចក្តីថា អ្នកណាទិញអ្វីដោយកហាបណៈជាដើម អ្នកនោះគេហៅថា អ្នកត្រូវលោះមក ។ សូម្បីព្រះនន្ទដ៏មានអាយុ ក៏ទិញព្រហ្មចរិយៈរបស់ខ្លួនព្រោះហេតុនៃនាងអប្សរ ព្រោះដូច្នោះ ភិក្ខុទាំងឡាយ ទើបហៅព្រះនន្ទ-

ដ៏មានអាយុដោយពាក្យយ៉ាងនេះថា អ្នកត្រូវលោះមក ។ ម្យ៉ាងទៀត ព្រះនន្ទដ៏-
មានអាយុញ៉ាំងជីវិត ពោលគឺ ការប្រព្រឹត្តព្រហ្មចារ្យឱ្យប្រព្រឹត្តទៅដោយតម្លៃ
ឈ្នួលពោលគឺ ការនៅរួមនឹងនាងអប្សរតាមបញ្ជារបស់ព្រះដ៏មានព្រះភាគ ដូច
ជាព្រះអង្គទ្រង់ចិញ្ចឹម ដោយការញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅដោយតម្លៃឈ្នួលនោះ
ព្រោះដូច្នោះ គេទើបហៅថា អ្នកដែលព្រះដ៏មានព្រះភាគទ្រង់ចិញ្ចឹម ។ ម្យ៉ាង
ទៀត លោកធ្វើការលក់ ពោលគឺ ការនៅរួមនឹងនាងអប្សរឱ្យជាវត្ថុដែលខ្លួន
គប្បីប្រកាន់យក ហើយតាំងនៅក្នុងបញ្ជារបស់ព្រះដ៏មានព្រះភាគ ទើបដូចជា
ព្រះដ៏មានព្រះភាគទ្រង់លោះមក ដោយការលក់នោះ ព្រោះដូច្នោះ លោកទើប
ហៅថា អ្នកដែលព្រះដ៏មានព្រះភាគទ្រង់លោះមក ។

បទថា **អដ្ឋិយមានោ** បានដល់ ត្រូវបៀតបៀន គឺបានទទួលសេចក្តី
លំបាក ។ បទថា **ហាយមានោ** បានដល់ ខ្ទាស ។ បទថា **ជិគុច្ឆមានោ** បាន-
ដល់ តិះដៀលដោយវត្ថុជារបស់គួរស្អប់ ។ បទថា **ឯកោ** ប្រែថា មិនមាន
សម្ងាញ់ ។ បទថា **វូបកដ្ឋោ** សេចក្តីថា មានកាយនិងចិត្តស្ងប់ហើយពីវត្ថុកាម
និងកិលេសកាម ។ បទថា **អប្ឋមត្តោ** បានដល់ មិនលះសតិក្នុងកម្មដ្ឋាន ។
បទថា **អាតាបី** បានដល់ ឈ្មោះថាញ៉ាំងកិលេសឱ្យក្តៅផ្សា ព្រោះឱ្យក្តៅដោយ
សេចក្តីព្យាយាមផ្លូវកាយ និងសេចក្តីព្យាយាមផ្លូវចិត្ត ។ ឈ្មោះថា **អាតាបៈ** ព្រោះ
ញ៉ាំងកិលេសឱ្យក្តៅគ្រប់ បានដល់ សេចក្តីព្យាយាម ។ បទថា **បហិតត្តោ** ប្រែថា
មានកាយបញ្ជូនទៅហើយ គឺមានអត្តភាពលះបង់ហើយដោយមិនអាល័យក្នុង
កាយនិងជីវិត ឬមានចិត្តបញ្ជូនទៅហើយកាន់ព្រះនិព្វាន ។ បទថា **ឧចិរស្សេ**

បានដល់ មិនយូរបន្ទាប់ពីការផ្តើមកម្មដ្ឋាន ។ បទថា **យស្សត្ថាយ** *កាត់បទជា* **យស្ស អត្ថាយ** *។ បទថា* **កុលបុត្តា** *បានដល់ កុលបុត្រ ២ ពួក គឺកុលបុត្រដោយកំណើត ១ កុលបុត្រដោយមារយាទ ១ ។ តែព្រះនន្ទដ៏មានអាយុនេះជាបុត្រមានត្រកូលទាំងពីរចំណែក ។ បទថា* **សទ្ធាយ** *បានដល់ ដោយហេតុ និងដោយការណ៍ ។ បទថា* **អការស្មា** *ប្រែថា ចេញពីផ្ទះ ។ បទថា* **អនការិយំ** *បានដល់ ការបព្វជ្ជា ។ មែនពិត កម្មមានកសិកម្ម និងពាណិជ្ជកម្មជាដើម ជាប្រយោជន៍ដល់ផ្ទះ ព្រោះដូច្នោះ ទើបឈ្មោះថា* **អាគារិយ:** *។ កម្មនោះមិនមានក្នុងបព្វជ្ជានេះ ព្រោះដូច្នោះ បព្វជ្ជា ទើបហៅថា* **អនគារិយ:** *។ បទថា* **បព្វជន្តិ** *ប្រែថា ចូលដល់ ។ បទថា* **តទនុត្តរំ** *កាត់បទជា* **តំ អនុត្តរំ** *។ បទថា* **ព្រហ្មចរិយបរិយោសានំ** *បានដល់ អរហត្តផល ដែលជាទីបំផុតនៃមគ្គព្រហ្មចារ្យ ។ មែនពិត កុលបុត្រទាំងឡាយ រមែងបួសក្នុងព្រះសាសនានេះ ដើម្បីប្រយោជន៍ដល់អរហត្តផលនោះ ។ បទថា* **ឥជ្ជេव ឆម្ហេ** *គឺក្នុងអត្តភាពនោះឯង ។ បទថា* **សយं អភិញ្ញា សច្ឆិកត្វា** *សេចក្តីថា ធ្វើឱ្យជាក់ច្បាស់ដោយបញ្ញាខ្លួនឯងតែម្តង អធិប្បាយថា ដឹងដោយមិនមានអ្នកដទៃជាហេតុ ។ បទថា* **ឧបសម្ជ្ជ វិហាสิ** *បានដល់ ដល់ឫសម្រេចនៅ ។ លោកសម្តែងបច្ចវេក្ខណភូមិ (របស់ព្រះនន្ទដ៏-មានអាយុ)ដោយពាក្យនេះថា ព្រះនន្ទដ៏មានអាយុរស់នៅយ៉ាងនេះឯង ទើបដឹងច្បាស់ថា ជាតិអស់ហើយ ។ល។*

បណ្តាបទទាំងនោះ បទថា **ខীณา ជาติ** *បានដល់ ជាតិមុនដែលជាអតីតរបស់ព្រះនន្ទដ៏មានអាយុនោះអស់ទៅក៏មិនមែន ព្រោះអស់ទៅក្នុងអតីត ហើយជាតិដែលជាអនាគតរបស់លោកអស់ទៅហើយក៏មិនមែន ព្រោះមិនទាន់*

មក ទាំងក្នុងអតីត និងបច្ចុប្បន្នជាតិ ដែលជាបច្ចុប្បន្នរបស់លោកអស់ទៅហើយ ក៏មិនមាន ព្រោះមាននៅ ។ ម្យ៉ាងទៀត ជាតិណាដែលផ្សេងដោយខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ក្នុងឯកវោការភព ចតុវោការភព និងបញ្ចវោការភព នឹងគប្បីកើតឡើងព្រោះមិនទាន់ចម្រើនមគ្គ ជាតិនោះ ឈ្មោះថា អស់ទៅហើយ ព្រោះដល់សេចក្តីមិនកើតឡើងជាធម្មតា ព្រោះបានចម្រើនមគ្គហើយ ។ ព្រះនន្ទដ៏មានអាយុនោះ ពិចារណាដល់កិលេសដែលលះហើយដោយមគ្គភាវនា ទើបដឹងក្រៃលែងនូវជាតិនោះ ដោយការដឹងថា កម្មសូម្បីមាននៅក៏មិនមានបដិសន្ធិ-តទៅ ព្រោះមិនមានកិលេស ។ បទថា **វុសិតំ** សេចក្តីថា នៅហើយគឺ នៅចប់ហើយ បានដល់ធ្វើហើយ ប្រព្រឹត្តហើយ អធិប្បាយថា សម្រេចហើយ ។ បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយ: ។ ក៏ព្រះសេក្ខ: ៧ ពួក រួមនឹងកល្យាណបុថុជ្ជន ឈ្មោះថា កំពុងនៅប្រព្រឹត្តព្រហ្មចរិយ: ។ ព្រះខីណាស្រព ឈ្មោះថា អ្នកមានព្រហ្មចរិយធម៌នៅរួចហើយ ។ ព្រោះដូច្នោះ ព្រះនន្ទដ៏មានអាយុនោះ កាលពិចារណានូវការនៅប្រព្រឹត្តព្រហ្មចរិយ:របស់ខ្លួន ទើបដឹងច្បាស់ថា ព្រហ្មចរិយ: យើងនៅចប់ហើយ ។ បទថា **កតំ ករណីយំ** សេចក្តីថា ឱ្យកិច្ច ១៦ យ៉ាង សម្រេច ដោយបរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និងភាវនាកិច្ចក្នុងសច្ច: ៤ ដោយមគ្គ ៤ ។ មែនពិត កល្យាណបុថុជ្ជនជាដើម ឈ្មោះថា កំពុងធ្វើកិច្ចនោះ ។ ព្រះខីណាស្រព ឈ្មោះថា ធ្វើករណីយកិច្ចធ្វើរួចហើយ ។ ព្រោះហេតុនោះ ព្រះនន្ទដ៏មានអាយុកាលពិចារណាករណីយកិច្ចរបស់ខ្លួន ទើបដឹងច្បាស់ថា ករណីយកិច្ចធ្វើហើយ ។ បទថា **ឆាបរំ ឥត្ថត្តាយ** សេចក្តីថា ដឹង ច្បាស់ថា

ឥឡូវនេះ យើងមិនមានភាពជាយ៉ាងនេះតទៅ គឺដើម្បីកិច្ច ១៦ យ៉ាង យ៉ាងនេះ ឬការចម្រើនមគ្គធ្វើឱ្យអស់កិលេស ។ ម្យ៉ាងទៀត បទថា **ជាបរំ ឥត្តត្តាយ** *សេចក្តីថា ដឹងច្បាស់ថា ខន្ធសន្តានដទៃចាកភាពជាយ៉ាងនេះ គឺពីខន្ធសន្តានដែលជាបច្ចុប្បន្ននេះ មានប្រការដូចពោលនេះមិនមានដល់យើង តែខន្ធទាំង ៥ ទាំងនេះយើងកំណត់ដឹងហើយតាំងនៅដូចដើមឈើជាច់ឫសហើយ ខន្ធ ៥ ទាំងនោះ នឹងរលត់ គឺដល់សេចក្តីមិនមានបញ្ញត្ត ព្រោះរលត់ចិត្តចុងក្រោយ ដូចភ្លើងរលត់មិនមានគ្រឿងឆេះដូច្នោះ ។ បទថា* **អញ្ញតរោ** *បានដល់ នន្ទមួយអង្គឯង ។ បទថា* **អរហត្តំ** *បានដល់ នន្ទមួយអង្គឯង ជាព្រះមហាសាវកមួយអង្គ បណ្តាព្រះអរហន្តជាសាវករបស់ព្រះដ៏មានព្រះភាគ ។*

បទថា **អញ្ញតរា ទេវតា** *បានដល់ ព្រហ្មទេវតាមួយអង្គអ្នកសម្រេចមគ្គ ។ មែនពិត ព្រហ្មទេវតានោះ ដឹងច្បាស់ដល់អារម្មណ៍របស់ព្រះអសេក្ខៈ ព្រោះខ្លួនឯងជាព្រះអសេក្ខៈ ។ ក៏ព្រះសេក្ខៈទាំងឡាយ រមែងដឹងអារម្មណ៍របស់ព្រះសេក្ខៈនោះ។ បាន ចំណែកបុថុជ្ជន រមែងដឹងចំពោះអារម្មណ៍បុថុជ្ជនរបស់ខ្លួនតែម្យ៉ាង ។ បទថា* **អភិក្ក្រន្តាយ រត្តិយា** *បានដល់ កាលរាត្រីកន្ធងទៅ អធិប្បាយថា ក្នុងមជ្ឈិមយាម ។ បទថា* **អភិក្ក្រន្តវណ្ណា** *ប្រែថា មានរស្មីដ៏ក្រៃលែង ។ បទថា* **កេវលកប្បំ** *បានដល់ ដោយជុំវិញ មិនមានចំណែកនៅសល់ ។ បទថា* **ឱភាសេត្វា** *បានដល់ ធ្វើវត្តជេតពនឱ្យមានពន្លឺតែមួយដោយរស្មីរបស់ខ្លួន ដូចព្រះចន្ទនិងព្រះអាទិត្យ ។ បទថា* **តេឧបសង្កមិ** *សេចក្តីថា ព្រហ្មទេវតានោះជ្រាបថា ព្រះនន្ទដ៏មានអាយុសម្រេចព្រះអរហត្តហើយ ទើបកើតបីតិសោមនស្សចូលទៅគាល់ដោយគំនិតថា យើងនឹងក្រាបទូលសេចក្តី*

នោះចំពោះព្រះដ៏មានព្រះភាគ ។

ក្នុងបទថា **អាសវានំ ខយា** នេះ មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **អាសវៈ** ព្រោះអត្ថថា ហូរទៅ អធិប្បាយថា ប្រព្រឹត្តទៅតាមចក្ខុទ្វារជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **អាសវៈ** ព្រោះអត្ថថា ហូរទៅដរាបដល់គោត្រភូ ឬដរាបដល់ភវគ្គព្រហ្ម អធិប្បាយថា ធ្វើធម៌ទាំងនេះនិងឱកាសទាំងនេះឱ្យប្រព្រឹត្តទៅក្នុងខាងក្នុង ។ ឈ្មោះថា **អាសវៈ** ព្រោះអត្ថថា ដូចទឹកត្រាំមានសុវាជាដើម ព្រោះត្រាំទុកយូរ ។ គប្បីជ្រាបសេចក្តីអាសវៈទាំងនោះធ្ងន់នៅយូរ ដោយព្រះតម្រាស់មានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់អវិជ្ជាមិនប្រាកដទេ[1] ។ ម្យ៉ាងទៀត ឈ្មោះថា **អាសវៈ** ព្រោះអត្ថថា ដល់ គឺប្រសព្វ សង្សារទុក្ខដ៏វែងអន្ទាយ ។ ក៏ក្នុងសេចក្តីនេះ អត្ថដើមរមែងគួរក្នុងកិលេស អត្ថក្រោយរមែងគួរត្រឹមតែកម្ម ។ ក៏មិនមែន តែកម្មកិលេសតែម្យ៉ាងប៉ុណ្ណោះទេ មានឈ្មោះថា **អាសវៈ** ដោយដែលពិត ឧបទ្ទវៈមានប្រការផ្សេងៗ ក៏ឈ្មោះថា **អាសវៈ** ដែរ ។ ពិតយ៉ាងនោះ កិលេសដែលជាវ៉ាទមូលឈ្មោះថា **អាសវៈ** ក្នុងព្រះតម្រាស់នេះថា ម្នាលចុន្ទ តថាគតមិនសម្តែងធម៌ ដើម្បីការពារនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នតែមួយយ៉ាងដល់ពួកអ្នកទាំងឡាយ[2] ។ កម្មដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងអកុសលធម៌ទាំងអស់មកដោយឈ្មោះថា អាសវៈ ក្នុងពាក្យជាគាថានេះថា

១-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ២៤៦ ។

២-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៨ ទំព័រ ២៦៤ ។

តថាគតគប្បីកើតជាទេវតា ឬកើតជាគន្ធព្វត្រាច់ទៅតាមអាកាស ព្រោះអាសវៈណាក្តី គប្បីដល់នូវភាពនៃខ្លួនជាយក្ខនឹងជួបប្រទះនូវភាពនៃខ្លួនជាមនុស្ស ព្រោះអាសវៈណាក្តី អាសវៈទាំងអស់នោះរបស់តថាគតអស់ហើយ បានកម្ចាត់បង់ហើយ ធ្វើឱ្យរបូតចំណងហើយ[១] ។

*ក៏ឧបទ្ទវៈមានប្រការផ្សេងៗ មានការបៀតបៀនអ្នកដទៃ សេចក្តីក្តៅក្រហាយការសម្ងាប់ និងការឃុំឃាំង និងដែលជាអបាយទុក្ខទាំងនោះ ឈ្មោះថា **អាសវៈ** ព្រោះបាលីថា ដើម្បីរារាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១[២] ។ មកក្នុងព្រះវិន័យដោយចំណែក ២ គឺដើម្បីរារាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១[៣] ។ មកក្នុងសឡាយតនសូត្រដោយចំណែក ៣ គឺអាវុសោ អាសវៈ ៣ ទាំងនេះ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១[៤] ។ និងមកក្នុងសុត្តន្តៈដទៃក៏ដូចគ្នា ។ ក្នុងអភិធម្ម អាសវៈ ៣ នោះឯងមកជា ៤ និងទិដ្ឋាសវៈ ។ ក្នុងនិព្វេធិកបរិយាយមកជា ៥ យ៉ាង ដោយព្រះតម្រាស់មានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយនាំសត្វទៅកាន់នរកក៏មាន[៥] ។ ក្នុងឆក្កនិបាតមកជា ៦ យ៉ាង ដោយន័យមានជាអាទិ៍ថា*

១-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៦២ ទំព័រ ៩៥ ។

២-វិនយបិដក មហាវិភង្គ លេខ ១ ទំព័រ ៦៥ ។

៣-វិនយបិដក មហាវិភង្គ លេខ ១ ទំព័រ ៦៥ ។

៤-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ លេខ ១៩ ទំព័រ ១៣៧ និងសុត្តន្តបិដក អង្គុត្តនិកាយ ឆក្កនិបាត លេខ ៦៦ ទំព័រ ២៧០ ។

៥-សុត្តន្តបិដក អង្គុត្តនិកាយ ឆក្កនិបាត លេខ ៦៦ ទំព័រ ២៧០ ។

ម្នាលភិក្ខុទាំងឡាយ អាសវៈដែលនឹងគប្បីលះដោយសំវរៈធម៌មាននៅ ។ ក្នុងសញ្ញាសវបរិយាយ អាសវៈទាំងនោះឯងរួមជាមួយទស្សនបហាតព្វធម៌ មកជា ៧ យ៉ាង ។ តែក្នុងទីនេះ គប្បីជ្រាបអាសវៈ ៤ តាមន័យដែលមកក្នុងអភិធម្ម ។

ក៏ក្នុងបទថា **ខយា** នេះត្រាស់សេចក្តីបែកផ្សេងអាសវៈព្រមដោយកិច្ចថា អាសវក្ខយៈក្នុងប្រយោគមានជាអាទិ៍ថា ការអស់ទៅ ការបែកទៅ ការទម្លាយទៅនៃអាសវៈណា ។ ត្រាស់សេចក្តីមិនកើតឡើងតទៅនៃអាសវៈថា អាសវក្ខយៈក្នុងប្រយោគមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវធម៌ទាំឡាយ របស់បុគ្គលអ្នកដឹង អ្នកឃើញ[១] ។ ត្រាស់មគ្គចិត្តថា ***អាសវក្ខយៈ*** ក្នុងប្រយោគមានជាអាទិ៍ថា

ញាណជាបឋមក្នុងកិរិយាអស់ទៅ របស់សេក្ខបុគ្គលដែលជាអ្នកកំពុងសិក្សា អ្នករឭករឿយៗនូវផ្លូវដ៏ត្រង់កើតឡើង លំដាប់ពីនោះមកអរហត្ត ក៏កើតឡើង លំដាប់អំពីអរហត្តផលនោះមក[២] ។

ត្រាស់ផលចិត្តថា ***អាសវក្ខយៈ*** ក្នុងប្រយោគមានជាអាទិ៍ថា តថាគតហៅបព្វជិតនោះថាជាសមណៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ[៣] ។ ត្រាស់

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ២១ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ លេខ ៥៣ ទំព័រ ៧១ ។

៣-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ២៣៦ ។

ព្រះនិព្វានថា **អាសវក្ខយៈ** ក្នុងប្រយោគមានជាអាទិ៍ថា កាលបុគ្គលគយឃ្លាំ មើលទោសរបស់បុគ្គលដទៃជាប្រក្រតី មានការសម្គាល់ហេតុក្នុងការពោលទោស (អ្នកដទៃ) ជានិច្ចជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះតែងចម្រើន បុគ្គលនោះ ឈ្មោះថា បិតនៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ[1] ។ តែក្នុងទីនេះ ត្រាស់ការអស់ទៅនៃអាសវៈដោយចំណែកតែមួយ គឺសេចក្ដីមិនកើតឡើងដល់អាសវៈ ឬមគ្គចិត្តថា **អាសវក្ខយៈ** ។

បទថា **អនាសវំ** បានដល់ បុគ្គលអ្នកមានអាសវៈដោយប្រការទាំងពួងដោយអំណាចបដិបស្សទ្ធិសម្ពោជ្ឌង្គ ។ បទថា **ចេតោវិមុត្តឺ** បានដល់ សមាធិដែលសម្បយុត្តដោយអរហត្តផល ។ បទថា **បញ្ញាវិមុត្តឺ** បានដល់ បញ្ញាដែលសម្បយុត្តដោយអរហត្តផល ។ ពាក្យទាំងពីរ មានអត្ថសម្ដែងភាវៈដែលសមថៈ និងវិបស្សនាជាប់គ្នាជាគូ សូម្បីក្នុងផលចិត្តក៏ដូចក្នុងមគ្គចិត្ត ។ បទថា **ញាណំ** បានដល់ សព្វញ្ញុតញ្ញាណ ។ ក្នុងលំដាប់ពាក្យរបស់ទេវតានោះឯង សូម្បីកាលព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាថា ជាយ៉ាងនោះឬហ្ន៎ ញាណក៏កើតឡើងថា នន្ទធ្វើឱ្យជាក់ច្បាស់ព្រះអរហត្តហើយ ។ មែនពិត ព្រះនន្ទដ៏មានអាយុត្រូវកិក្ខុអ្នកជាសម្ងាញ់ចំអកឡកឡាយ[2]ដូច្នោះ ទើបកើតសេចក្ដីសង្វេគឡើងថា យើងបួសក្នុងព្រះធម្មវិន័យ ដែលព្រះតថាគតត្រាស់ល្អហើយយ៉ាងនេះ បានធ្វើព្រះ-

---

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៧៤ ។

២-ឡកឡាយ (កិ.) និយាយឡកដោយពាក្យលៃបខាយ ឬនិយាយឡកឱ្យរឿយៗ : ឡកឡាយឱ្យដឹងខ្ជូន, និយាយឡកឡាយ (ស្រង់ចាកវចនានុក្រមខ្មែរ សម្ដេចព្រះសង្ឆរាជ **ជោតញ្ញាណ** ជួន ណាត ទំព័រ ១៥៦៣) ។

សាស្តាឱ្យជាអ្នកទទួលធានា ដើម្បីបាននាងអប្សរនោះ ចាត់ថាយើងធ្វើកម្មធ្ងន់ហ្ន៎ ទើបញ្ជាំងហិរិ និងឱ្ចិត្តប្ប:ឱ្យតាំងឡើង ព្យាយាមប្រឹងប្រែងសម្រេចព្រះអរហត្ត ហើយគិតថា ដូចម្តេចហ្ន៎ យើងគប្បីឱ្យព្រះដ៏មានព្រះភាគផុតពីការធានា ។ ព្រះនន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលសេចក្តីប្រាថ្នារបស់ខ្លួនចំពោះព្រះសាស្តា ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ អាយស្មា ឧន្ទោ ។បេ។ ឯតស្ស បដិស្សវោ** *ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* **បដិស្សវោ** *សេចក្តីថា ពីការធានា គឺពីបដិញ្ញាថា តថាគតជាអ្នកធានា ដើម្បីឱ្យបាននាងអប្សរ ។*

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់នឹងព្រះនន្ទដ៏មានអាយុថា ព្រោះហេតុដែលតថាគតដឹងប្រការនេះថា អ្នកត្រេកអរព្រះអរហត្តផល ទាំងទេវតាក៏ប្រាប់ដល់តថាគត ព្រោះដូច្នោះ តថាគតទើបមិនត្រូវអ្នកឱ្យផុតពីការធានាក្នុងឥឡូវនេះ ព្រោះអ្នកផុតហើយដោយការសម្រេចព្រះអរហត្តនោះឯង ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា **យនេវ ខោ តេ ឧន្ទ** *ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* **យនេវ** *កាត់បទជា* **យនា ឯវ** *។ បទថា* **តេ** *កែជា* **តវ** *ប្រែថា របស់លោក ។ បទថា* **មុត្តោ** *ប្រែថា ផុតហើយ ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះថា ក្នុងកាលណា ចិត្តរបស់អ្នកផុតពីអាសវ: ក្នុងកាលនោះ គឺក្នុងលំដាប់នោះឯង តថាគតផុតពីការធានានោះ ។*

ចំណែកព្រះនន្ទដ៏មានអាយុ ក្នុងវេលាចម្រើនវិបស្សនានុ៎ះឯង កើតសេចក្តីឧស្សាហ៍ឡើងថា យើងនឹងគ្របសង្កត់ការមិនសង្រួមឥន្ទ្រិយ ដែលយើង

អាស្រ័យដល់ប្រការដែលបែកនេះប៉ុណ្ណោះដោយល្អ មានហិរិនិងឱ្ចិត្តប្ប:យ៉ាងចាស់ក្តា និងបានដល់បដិបទាយ៉ាងឧក្រិដ្ឋក្នុងឥន្ទ្រិយសំវរ: ព្រោះបានធ្វើបុញ្ញាធិការទុកក្នុងរឿងនោះ ។ សមដូចព្រះតម្រាស់ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើនន្ទកិក្ខុរមិលមើលទៅទិសខាងកើត លុះតែប្រមូលនូវហេតុទាំងអស់ ដោយចិត្តទើបនន្ទកិក្ខុរមិលមើលនូវទិសខាងកើត ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឌានិងទោមនស្សនឹងមិនជាប់តាមអាត្ម-អញ ដែលកំពុងរមិលមើលទិសខាងកើតយ៉ាងនេះ ។ ព្រោះហេតុនោះ ក្នុងសាសនានេះ នន្ទកិក្ខុទើបឈ្មោះថាជាអ្នកមានសេចក្តីដឹងខ្លួន ក្នុងការគ្រប់គ្រងទ្វារនោះ ។ ម្នាលភិក្ខុទាំងឡាយ បើនន្ទកិក្ខុរមិលមើលទិសខាងលិច រមិលមើលទិសខាងជើង រមិលមើលទិសខាងត្បូង ងើយមើលទៅទិសខាងលើ ឱនមើលទិសខាងក្រោម ងាកមើលទៅទិសជាលំដាប់ លុះតែប្រមូលនូវហេតុទាំងអស់ ដោយចិត្ត ទើបនន្ទកិក្ខុងាកមើលនូវទិសជាលំដាប់ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឌានិងទោមនស្សនឹងមិនជាប់តាមអាត្មាអញដែលកំពុងងាកមើលទិសជាលំដាប់ ។ ព្រោះហេតុនោះ ក្នុងសាសនានេះ នន្ទកិក្ខុទើបឈ្មោះថា ជាអ្នកមានសេចក្តីដឹងខ្លួនក្នុងការគ្រប់គ្រងទ្វារយ៉ាងនេះ[1] ។ ព្រោះហេតុនោះ ព្រះសាស្តាទើបស្ថាបនាព្រះនន្ទដ៏មានអាយុនោះទុកក្នុងឯតទគ្គ:ថា **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ** *។ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយដែលជាសាវករបស់តថាគត ស្រេចនឹងនន្ទ:[2] ។*

១-សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត លេខ ៤៨ ទំព័រ ៣១ ដល់ ៣២ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ២០ ទំព័រ ៥៥ ។

បទថា **ឯតមត្ថं វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់សេចក្តីនោះ ពោលគឺ ការដែលព្រះនន្ទដ៏មានអាយុធ្វើអាសវៈទាំងពួងឱ្យអស់ហើយ ដល់ភាពជាអ្នករឹងមាំក្នុងលោកធម៌មានសុខជាដើម ។ បទថា* **ឥមं ឧទានं** *សេចក្តីថា ទ្រង់បន្ទឹនូវឧទាននេះ ដែលប្រកាសសេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **យស្ស តិណ្ណោ កាមបង្កោ** *សេចក្តីថា កក់ គឺទិដ្ឋិទាំងអស់ដែលព្រះអរិយបុគ្គលណាឆ្លងហើយ ដោយស្ពាន គឺអរិយមគ្គ ឬកក់ គឺសង្សារៈនុ៎ះឯង ដែលព្រះអរិយបុគ្គលណាឆ្លងហើយ ដោយការដល់ត្រើយ គឺព្រះនិព្វាន ។ បទថា* **មច្ចិតោ កាមកណ្ដកো** *សេចក្តីថា កិលេសកាមទាំងអស់ គឺថា បន្ទា គឺកាមទាំងអស់ដែលបានឈ្មោះថា កាមកណ្ដកៈ ព្រោះចេញចាកពួកសត្ត្ব ដែលព្រះអរិយបុគ្គលណាញ៉ាំញ៉ីហើយ គឺកាច់បំបាក់ចេញហើយទម្លាយហើយដោយមិនឱ្យសេសសល់ ដោយអាជ្ញា គឺអរហត្តមគ្គ-ញ្ញាណ ។ បទថា* **មោហក្ខយं អនុប្ផត្តো** *សេចក្តីថា ក៏ព្រះនន្ទដ៏មានអាយុអ្នកជាយ៉ាងនេះ សម្រេចការអស់មោហៈ ដោយធម៌សម្មោហៈទាំងអស់ដែលមានទុក្ខជាដើម ជាអារម្មណ៍ឱ្យអស់ទៅ គឺសម្រេចព្រះអរហត្តផល និងព្រះនិព្វាន ។ បទថា* **សុខុក្ខេសុ ន វេធតិ ស ភិក្ខុ** *សេចក្តីថា ភិក្ខុអ្នកទម្លាយកិលេសនោះ រមែងមិនញ័ររន្ធត់ មិនញ័រក្នុងសុខដែលកើតឡើង ព្រោះជួបប្រសព្ធគ្នាជាមួយនឹងឥដ្ឋារម្មណ៍ និងក្នុងទុក្ខដែលកើតឡើងព្រោះ ជួបប្រសព្ធនឹងអនិដ្ឋារម្មណ៍ គឺមិនដល់សេចក្តីផ្ទាស់ប្តូរនៃចិត្តដែលមានសុខទុក្ខនោះជាហេតុ ។ ក៏បទថា* **សុខុក្ខេសុ** *នេះ ត្រឹមតែជាទេសនា ។ គប្បីជ្រាបថា ព្រះនន្ទដ៏មានអាយុមិនញាប់-ញ័រក្នុងលោកធម៌សូម្បីទាំងអស់ ។*

ឧតិយ សុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ២

សម្រាប់ជាធម្មទាន

៣. យសោជសុត្តវណ្ណនា

អដ្ឋកថាយសោជសូត្រ

យសោជសូត្រទី ៣ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **យសោជោ** *ក្នុងពាក្យថា* **យសោជឃ្ឃមុខានិ** *នេះ ជាឈ្មោះ*
របស់ព្រះថេរៈនោះ ។ ភិក្ខុ ៥០០ រូបនោះ លោកពោលថាមានយសោជភិក្ខុជា
ប្រធាន ព្រោះបួសធ្វើយសោជៈឱ្យជាប្រធាន និងព្រោះត្រាច់ទៅតាមគ្នា ។
ភិក្ខុទាំងនោះមានការប្រកបបុញ្ញកម្មទុកក្នុងកាលមុន ដូចតទៅនេះ

បានឮមកថា ក្នុងអតីតកាល សាសនារបស់ព្រះកស្សបទសពល មាន
ភិក្ខុនៅព្រៃមួយរូប នៅក្នុងកុដិប្រក់ដោយស្លឹកឈើ គឺគេសាងទុកលើថ្មក្នុងព្រៃ ។
ក៏សម័យនោះឯង ចោរ ៥០០ ធ្វើការសម្ងាប់អ្នកស្រុកជាដើម ចិញ្ចឹមជីវិតបែប
ចោរកម្ម ធ្វើចោរកម្មត្រូវពួកមនុស្សក្នុងជនបទនាំគ្នាដេញតាម ក៏រត់ចូលទៅព្រៃ
មិនឃើញអ្វីជាទីកាន់យក ឬជាទីពឹងក្នុងទីនោះ ឃើញតែភិក្ខុអង្គនោះអង្គុយ នៅ
លើថ្មក្នុងទីមិនឆ្ងាយទើបថ្វាយបង្គំ ហើយប្រាប់រឿងរ៉ាវនោះ ហើយអង្វរថា បពិត្រ
លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ជាទីពឹងដល់ខ្ញុំព្រះករុណាទាំងឡាយ ។
ព្រះថេរៈពោលថា ទីពឹងដទៃស្មើដោយសីលមិនមានដល់អ្នកទាំងឡាយទេ អ្នក
ទាំងឡាយ ចូរសមាទានសីល ៥ ទាំងអស់គ្នានេះចុះ ។ ចោរទាំងនោះទទួល
ពាក្យរបស់ព្រះថេរៈថា ប្រពៃហើយលោកម្ចាស់ ហើយសមាទានន្ទូវសីល ។
ព្រះថេរៈពោលថា ឥឡូវអ្នកទាំងឡាយតាំងនៅក្នុងសីលហើយ អ្នកទាំងឡាយ

កុំមានចិត្តប្រទូស្តសូម្បីដល់ជីវិតរបស់ខ្លួនត្រូវវិនាសទៅ ក៏កុំខឹងក្រោធដោយការបៀតបៀនដូច្នេះហើយ ទើបប្រាប់កកចូបមាវិធី[1] (វិធីឧបមាដោយរណា) ។ ចោរទាំងនោះ ទទួលថា ប្រពៃហើយលោកម្ចាស់ ។ លំដាប់នោះ អ្នកស្រុកទាំងនោះទៅកាន់ទីនោះ ស្វែងរកពីទីនេះផង ពីទីនោះផង ជួបពួកចោរទាំងនោះ ក៏ផ្តាច់ជីវិតទាំងអស់ ។ ចោរទាំងនោះ មិនបានធ្វើសូម្បីត្រឹមតែចិត្តប្រទូស្តនឹងអ្នកស្រុកទាំងនោះ ភាពជាអ្នកមានសីលមិនដាច់ ស្ងាប់ទៅកើតក្នុងទេវលោកជាន់កាមាវចរ ។ បណ្តាចោរទាំងនោះ មេចោរបានជាប្រធានទេវបុត្រ ។ ចំណែកចោរក្រៅនោះបានជាបរិវារបស់ទេវបុត្រអ្នកជាប្រធាននោះឯង ។

*ទេវបុត្រទាំងឡាយនោះ អន្ទោលទៅមកអស់មួយពុទ្ធន្តរក្នុងទេវលោក ក្នុងកាលព្រះដ៏មានព្រះភាគជាម្ចាស់របស់យើង (ព្រះអង្គឧប្បត្តិឡើង) បានចុតិពីទេវលោក ហើយទេវបុត្រអ្នកជាប្រធាន កើតជាបុត្រអ្នកនេសាទ អ្នកជាមេស្រុកក្នុងត្រកូល ៥០០ ក្នុងកេវដ្ដគ្រាម ជិតទ្វារក្រុងសាវត្ថី ។ ជនទាំងឡាយ ដាក់ឈ្មោះលោកថា **យសោជ:** ។ ចំណែកទេវបុត្រក្រៅនោះកើតជាបុត្រអ្នកនេសាទក្រៅនោះ ។ ដោយបុព្វេសន្និវាស ជនទាំងឡាយនោះបានជាសម្ងាញ់នឹងគ្នា លេង*

---

*១-សេចក្ដីឧបមាដោយកកចូបមាវិធីនេះ មានពិស្តារនៅក្នុងគម្ពីរសុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក លេខ ២១ ទំព័រ ១ ដល់ ២៥ ត្រង់**កកចូបមសូត្រ** ។*

ធ្លាលីជាមួយគ្នា ចម្រើនវ័យដោយលំដាប់ យសោជ:ជាប្រសើរជាងជនទាំងនោះ ។ ជនទាំងអស់នោះ ប្រើសំណាញ់ចាប់ត្រីក្នុងទន្ទ្រ និងក្នុងបឹងជាដើម ។

ថ្ងៃមួយ កាលជនទាំងឡាយបង់សំណាញ់ក្នុងស្ទឹងអចិរវតី ក៏បានត្រីពណ៌មាស ។ អ្នកនេសាទទាំងអស់ឃើញដូច្នោះ នាំគ្នារីករាយត្រេកអរថា កូនៗរបស់ពួកយើងកាលចាប់ត្រី ក៏ចាប់បានត្រីពណ៌មាស ។ លំដាប់នោះសម្ងាញ់ទាំង ៥០០ នាក់ទាំងនោះ ដាក់ត្រីលើទូកយកទៅបង្ហាញចំពោះព្រះរាជា ។ ព្រះរាជាទ្រង់ទតឃើញដូច្នោះទ្រង់ព្រះតម្រិះថា ព្រះដ៏មានព្រះភាគនឹងទ្រង់ជ្រាបហេតុ ដែលត្រីនេះជាត្រីពណ៌មាស ទើបឱ្យចាប់ត្រីនោះទៅបង្ហាញចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាត្រាស់ថា ត្រីនេះ កាលសាសនារបស់ព្រះសម្មាសម្ពុទ្ធសាបសូន្យទៅ បួសបដិបត្តិខុស ញ៉ាំងសាសនាឱ្យសាបសូន្យ ក៏កើតក្នុងនរក ឆេះនៅក្នុងនរកនោះអស់មួយពុទ្ធន្តរ ចុតិពីអត្តភាពនោះ កើតជាត្រីក្នុងស្ទឹងអចិរវតី ដូច្នេះ ហើយទើបទ្រង់ឱ្យត្រីនោះឯងប្រាប់នូវភាពនៃខ្លួន មាតាប្អូនស្រីកើតក្នុងនរក និងព្រះថេរ:អ្នកជាបងប្រុសរបស់គេបរិនិព្វានហើយ ទើបព្រះដ៏មានព្រះភាគទ្រង់សម្តែងកបិលសូត្រ ព្រោះហេតុកើតរឿងនេះ ឡើងបុត្ររបស់អ្នកនេសាទ ៥០០ នាក់ ទាំងនោះស្តាប់ទេសនារបស់ព្រះសាស្តា ហើយកើតសេចក្តីសង្វេគ បានបព្វជ្ជាឧបសម្បទាក្នុងសម្ងាក់ព្រះដ៏មានព្រះភាគ នៅដោយការនៅក្នុងវិវេកធម៌ ហើយមកគាល់ព្រះដ៏មានព្រះភាគ ។ ព្រោះហេតុ

នេះ លោកទើបពោលថា **តេន ខោ បន សមយេន យសោជប្បមុខានិ បញ្ចមត្តានិ ភិក្ខុសតានិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **តេ** កាត់បទជា **តេ ឥ** ។ បទថា **ឧវាសិ-ភេហិ** បានដល់ អ្នកនៅប្រចាំ ។ បទថា **បដិសម្ពោធមានា** សេចក្តីថា កាលនេវាសិកភិក្ខុធ្វើការប្រាស្រ័យ ដោយការបដិសណ្ឋារៈមានជាអាទិ៍ថា ម្នាលអាវុសោ តើលោកអត់ទ្រាំបានឬ កាលនឹងប្រាស្រ័យទៀត ទើបប្រាស្រ័យនឹងនេវាសិកភិក្ខុទាំងនោះ ដោយន័យមានជាអាទិ៍ថា ខ្ញុំព្រះករុណា អត់ទ្រាំបានលោកម្ចាស់ ។ បទថា **សេនាសនានិ បញ្ញាបយមានា** សេចក្តីថា សួរនូវសេនាសនៈមានដល់អាចារ្យ ឧបជ្ឌាយ៍ និងដល់ខ្លួន គឺនេវាសិកភិក្ខុទាំងឡាយនោះ នាំគ្នាចាត់ចែងសេនាសនៈដល់ភិក្ខុទាំងនោះថា នេះសម្រាប់អាចារ្យរបស់លោក នេះសម្រាប់ឧបជ្ឌាយ៍របស់លោក នេះសម្រាប់ពួកលោក ហើយខ្លួនឯងទៅក្នុងទីនោះ បើកទ្វារនិងបង្ហួច នាំមកនូវស្រោមគ្រែតាំង និងកន្ទេលផែងជាដើម ហើយតាក់តែងក្រាលតាមទីតាំងនៅជាដើម ។

បទថា **បត្តចីវរានិ បដិសាមយមានា** សេចក្តីថា ឱ្យរក្សាសមណ-បរិក្ខារដោយនិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន សូមលោករក្សាបាត្រ ចីវរ ភាជនៈ បំពង់ទឹក និងឈើច្រត់របស់ខ្ញុំនេះ ។ បទថា **ឧច្ចាសទ្ធា មហា-**

សង្ហា សេចក្ដីថា ភិក្ខុដែលឈ្មោះថា អ្នកមានសំឡេងខ្ជាំង ព្រោះអត្ថថា មានសំឡេងខ្ពស់ ដោយហេតុធ្វើ **អ** អក្សរ ឱ្យជា **អា** អក្សរ ។ ភិក្ខុដែលឈ្មោះថា អ្នកមានសំឡេងធំ ព្រោះអត្ថថា ផ្សាយទៅដោយជុំវិញ ។ បទថា **កេវដ្ដា មញ្ញេ មច្ឆរិលោបេ** បានដល់ ក្នុងការដណ្ដើមបន្ទុំយកត្រីដូចអ្នកនេសាទ ។ លោកសម្ដែងថា ភិក្ខុទាំងនោះ ដូចជាអ្នកនេសាទ អ្នកចាប់ត្រីបានឈ្មោះថា **កេវដ្ដ:** ព្រោះវិលវល់នៅក្នុងទឹក គឺប្រព្រឹត្តទៅដើម្បីចាប់ត្រី បង់សំណាញ់ចុះក្នុងទឹកដើម្បីចាប់ត្រី មានសំឡេងគងរំពងដោយន័យមានជាអាទិ៍ថា ចូល ឬមិនចូល ចាប់បាន ឬចាប់មិនបាន និងដូចអ្នកនេសាទទាំងនោះ កាលមហាជននាំគ្នាទៅក្នុងទីដែលគេដាក់ទ្រុងត្រីជាដើមទុក ហើយដណ្ដើមគ្នានិយាយជាដើមថា ពួកលោកឱ្យត្រីមួយដល់យើង ចូរឱ្យត្រីមួយដល់យើង ដែលឱ្យដល់អ្នកឯណោះ ត្រីធំ ដែលឱ្យដល់យើងត្រីតូច ដូច្នោះ និងឈ្មោះថា អ្នកមានសំឡេងកងរំពងដោយការបដិសេធជាដើមរបស់ជនទាំងនោះ ។

បទថា **តេ** **តេ** កាត់បទជា **តេ ឯ** **តេ** ។ បទថា **កិន្ទ** កែជា **កិ** **ស្ស ន** អធិប្បាយថា **កិ** **មត្ថं ន** ប្រែថា ដើម្បីហេតុអ្វីហ្ន៎ ។ បទថា **តេ** **មេ** កាត់ជា **តេ** **ឥ** **មេ** ។ បទថា **បណ្ណាមេមិ** ប្រែថា នាំចេញ ។ បទថា **ភោ** កែបទជា **តុម្ហេ** ប្រែថា លោកទាំងនោះ ។ បទថា **ន ភោ** **មម** **សន្តិ** **កេ** **វត្ត** **ពុ** សេចក្ដីថា ពួកលោកកុំនៅក្នុងសម្ងាត់របស់តថាគត ។ ទ្រង់សម្ដែងថា លោកពួកណាមកកាន់ទី

ប្រថាប់របស់ព្រះពុទ្ធប្រាកដស្មើដូចជាតថាគត ធ្វើសំឡេងខ្លាំងយ៉ាងនេះ នៅតាមធម្មតារបស់ខ្លួន នឹងធ្វើឱ្យសមគួរយ៉ាងណា អ្នកដូចពួកលោកមិនមានកិច្ច ដែលនិងនៅក្នុងសម្ងាត់របស់តថាគតដូច្នេះ ។

បណ្តាភិក្ខុទាំងនោះដែលព្រះដ៏មានព្រះភាគ ទ្រង់បណ្តេញយ៉ាងនេះ សូម្បីតែមួយរូបក៏មិនបានពោលពាក្យតបយ៉ាងណានីមួយថា បពិត្រព្រះដ៏មាន-ព្រះភាគ សូមព្រះអង្គទ្រង់បណ្តេញខ្ញុំព្រះអង្គ ដោយហេតុត្រឹមតែសំឡេងខ្លាំង ហើយព្រមទទួលពាក្យរបស់ព្រះដ៏មានព្រះភាគ ដោយការគោរពក្នុងព្រះពុទ្ធ ថា ព្រះករុណាព្រះអង្គ ហើយក៏ជៀសចេញទៅ ។ ក៏ភិក្ខុទាំងនោះមានគំនិតគិតយ៉ាងនេះថា ពួកយើងនឹងគាល់ព្រះសាស្តា នឹងស្តាប់ធម៌ នឹងនៅក្នុងសម្ងាត់ព្រះសាស្តា ព្រោះដូច្នោះ ទើបនាំគ្នាមក តែពួកយើងមកកាន់សម្ងាត់ព្រះសាស្តា ព្រះអង្គជាគ្រូមានសភាពបែបនេះ ធ្វើសំឡេងខ្លាំង នេះជាទោសរបស់ពួកយើងប៉ុណ្ណោះ ពួកយើងត្រូវបណ្តេញព្រោះទោស យើងមិនបាននៅក្នុងសម្ងាត់ព្រះសាស្តា មិនបានក្រឡេកឃើញព្រះសរីរៈ មានពណ៌ដូចជាពណ៌មាសជាទីនាំមកនូវសេចក្តីជ្រះថ្លាជុំវិញ មិនបានស្តាប់ធម៌ដែល ទ្រង់សម្តែងដោយព្រះសូរសៀងដ៏ពីរោះ ។ ភិក្ខុទាំងនោះមានការតូចចិត្តយ៉ាងខ្លាំងក្លា ហើយជៀសចេញទៅ ។

បទថា **សំសាមេត្វា** *បានដល់ គ្របគ្រងដោយល្អ ។ បទថា* **វជ្ជី** *បានដល់ ជនបទដែលមានឈ្មោះយ៉ាងនេះ ។ សម្បីជនបទមួយដែលជាទីប្រថាប់របស់ ព្រះរាជកុមារអ្នកជនបទឈ្មោះថា* **វជ្ជី** *គេទើបហៅថា វជ្ជីនុ៎ះឯង ដោយកាសា ដែលច្រើនសន្ធឹកសន្ធាប់ ។ ព្រោះហេតុនោះ លោកទើបពោលថា* **វជ្ជីសុ** *ដូច្នេះ ។ ស្ទឹងមួយដែលគេសន្មតិគ្នាថា ជាបុណ្យរបស់លោក មានឈ្មោះយ៉ាងនេះថា* **វត្តុមុ**ា *។ បាលីថា* **វត្តមុ**ា *ដូច្នេះក៏មាន ។ បទថា* **អត្តកាមេ**ន *បានដល់ ប្រាថ្នាតែប្រយោជន៍តែម្យ៉ាងប៉ុណ្ណោះ មិនប្រាថ្នាប្រយោជន៍ដទៃក្រៅពីនោះទេ ។ បទថា* **ហិតេសិ**ា *បានដល់ ប្រាថ្នាប្រយោជន៍ គឺមានប្រក្រតីស្វែងរក ប្រយោជន៍ ពោលគឺ ប្រយោជន៍ដែលជាហេតុរបស់ប្រយោជន៍នោះថា សាវ័ក របស់តថាគត គប្បីរួចផុតពីវដ្តទុក្ខ ព្រោះហេតុណា ព្រោះហេតុនោះនុ៎ះឯង ព្រះអង្គទើបឈ្មោះថា ទ្រង់អនុគ្រោះ ព្រោះអនុគ្រោះទៅតាមសម្នាក់របស់ វេនេយ្យសត្វសម្បីក្នុងទីឆ្ងាយ មិនរាប់ដោយសេចក្ដីលំបាកព្រះវរកាយឡើយ យើងទាំងឡាយ គឺព្រះដ៏មានព្រះភាគទ្រង់បណ្ដេញចេញហើយ ព្រោះអាស្រ័យ សេចក្ដីអនុគ្រោះនោះ មិនមែនត្រូវបណ្ដេញព្រោះប្រាថ្នាសេចក្ដីខ្វល់ខ្វាយជាដើម របស់ខ្លួន ។ ព្រោះហេតុដែលព្រះពុទ្ធជាព្រះដ៏មានព្រះភាគ ព្រះអង្គជាអ្នកធ្ងន់ ក្នុងធម៌ ព្រះអង្គទ្រង់បណ្ដេញយើងទាំងឡាយ សម្បីហេតុត្រឹមតែធ្វើសំឡេងខ្ទាំង ព្រះអង្គគួរដល់ការបូជាដោយសម្មាបដិបត្តិប៉ុណ្ណោះ ដូច្នោះ អាវុសោ ណ្ហើយចុះ*

យើងសម្រេចការនៅយ៉ាងនោះ គឺយើងនឹងបំពេញអបណ្ណកបដិបទា ដោយការប្រកបសតិសម្បជញ្ញៈក្នុងទីទាំងពួង ធ្វើកម្មដ្ឋានតាមដែលកំណត់ទុកឱ្យដល់ទីបំផុត ឈ្មោះថា សម្រេច គឺនៅដោយឥរិយាបថវិហារទាំង ៤ ។ បទថា **យថា ឌោ វិហរតំ** សេចក្ដីថា កាលយើងនៅដោយប្រការណា ព្រះដ៏មានព្រះភាគ គប្បីជាអ្នកមានព្រះទ័យត្រេកអរ គឺដែលពួកយើងគប្បីឱ្យប្រោសប្រាណដោយសម្មាបដិបត្តិបូជា ។

បទថា **តេនេវន្តរវស្សេន** បានដល់ មិនកន្ធងថ្ងៃមហាបវារណាក្នុងខាងក្នុងវស្សានោះឯង ។ បទថា **សព្ពេយេវ តិស្សេ វិជ្ជា សច្ឆាកំសុ** សេចក្ដីថា ភិក្ខុ ៥០០ អង្គនោះឯង បានធ្វើឱ្យជាក់ច្បស់នូវវិជ្ជា ៣ ទាំងនេះ គឺ បុព្វេនិវាសានុសតិញាណ ១ ទិព្វចក្ខុញាណ ១ អាសវក្ខយញ្ញាណ ១ ព្រោះអត្ថថា ចាក់ធ្ទុះនូវខន្ធដែលមានក្នុងកាលមុន និងខន្ធ គឺមោហៈដែលជាតួបិទបាំង ។ ក្នុងទីនេះ ព្រះអង្គទ្រង់លើកវិជ្ជា ៣ ឡើងសម្ដែង ដោយសម្ដែងដល់ការដែលភិក្ខុទាំងនោះសម្រេច ដើម្បីសម្ដែងថា បណ្ដាលោកិយអភិញ្ញា អភិញ្ញា ២ នេះប៉ុណ្ណោះ មានឧបការៈច្រើនដល់អាសវក្ខយញ្ញាណ ចំណែកទិព្វសោត ចេតោបរិយញ្ញាណ និងឥទ្ធិវិធញ្ញាណដូច្នោះទេ ។ ពិតយ៉ាងនោះ ក្នុងវេរញ្ជសូត្រ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងនូវការសម្រេចដល់វេរញ្ជព្រាហ្មណ៍ សម្ដែងត្រឹមតែវិជ្ជា ៣

ប៉ុណ្ណោះ ព្រោះមិនមានទិព្វសោតជាដើម ។ កាលបើយ៉ាងនេះ ព្រះអង្គទើបទ្រង់មិនលើកឡើងនូវទិព្វសោតជាដើម សម្បីមានដល់ភិក្ខុទាំងនោះ ។ ព្រោះថា ភិក្ខុទាំងនោះមានអភិញ្ញា ៦ ។ ព្រោះធ្វើអធិប្បាយដូចពោលមកនេះ ព្រះដ៏មានព្រះ-ភាគទើបត្រាស់ដល់ការសម្តែងឫទ្ធិរបស់ភិក្ខុទាំងនោះថា ភិក្ខុទាំងនោះបាត់ពីឆ្នេរនៃស្ទឹងវគ្គុមុទា មកប្រាកដចំពោះព្រះភក្ត្ររបស់ព្រះដ៏មានព្រះភាគ ក្នុងកូដាគារ-សាលា នាព្រៃមហាវ័ន ។

បទថា **យថាភិរន្តំ** បានដល់ សមគួរព្រះទ័យ គឺតាមព្រះអជ្ឌាស្រ័យ ។ មែនពិត ធម្មតាព្រះពុទ្ធទាំងឡាយ ព្រះអង្គប្រថាប់នៅក្នុងទីមួយកន្លែង រមែងមិនមានសេចក្តីត្រេកអរ ព្រោះអាស្រ័យសេចក្តីវិបត្តិនៃម្ទប់ស្រមោល និងទឹក ឬសេនាសន:ដែលមិនជាទីសប្បាយ ឬភាពដែលពួកមនុស្សមិនមានសទ្ធាជាដើម សម្បីការប្រថាប់នៅយូរដោយទ្រង់មានព្រះតម្រិះថា នៅសប្បាយព្រោះសម្បត្តិនោះ ក៏មិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ក៏កាលព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងទីណា មនុស្សទាំងឡាយក្នុងទីនោះ តាំងនៅក្នុងសរណ: សមាទានសីល បព្វជ្ជា ឬសម្រេចសោតាបត្តិមគ្គជាដើម ទើបព្រះសាស្តាប្រថាប់នៅ ដើម្បីឱ្យមនុស្សទាំងនោះតាំងនៅក្នុងសម្បត្តិទាំងនោះ កាលមិនមានសម្បត្តិយ៉ាងនោះ ព្រះអង្គក៏ស្តេចដៀសចេញទៅ ។ ក៏ក្នុងកាលនោះ ព្រះអង្គមិនមានពុទ្ធកិច្ចដែលនឹងគប្បីធ្វើក្នុងក្រុងសាវត្ថី ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រា

នោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងសាវត្ថីតាមសមគួរដល់អធ្យាស្ស័យ ហើយស្តេចដៀសចេញទៅកាន់ចារិកក្នុងក្រុងវេសាលី ។

បទថា **ចារិកញ្ចរមានោ** បានដល់ ស្តេចយាងទៅកាន់ផ្លូវឆ្ងាយ ។ ក៏ឈ្មោះថា ការចារិករបស់ព្រះដ៏មានព្រះភាគនេះមាន ២ យ៉ាង គឺចារិកទៅដោយប្រញាប់ប្រញាល់ ១ ចារិកទៅដោយមិនប្រញាប់ប្រញាល់ ១ ។ បណ្តាចារិកទាំង ២ យ៉ាងនោះ ការដែលព្រះអង្គទ្រង់ឃើញពោធនេយ្យបុគ្គលសូម្បីក្នុងទីឆ្ងាយ ក៏ប្រញាប់ទៅដើម្បីឱ្យបុគ្គលនោះត្រាស់ដឹង ឈ្មោះថា ចារិកទៅដោយប្រញាប់ប្រញាល់ ។ ការទៅដោយប្រញាប់ប្រញាល់នោះ គប្បីឃើញក្នុងការទទួលព្រះមហាកស្សបជាដើម ។ ចំណែកការចារិកទៅអនុគ្រោះសត្វលោក ដោយការស្តេចត្រាច់បិណ្ឌបាតជាដើម ដោយផ្លូវមួយយោជន៍ និងកន្ទះយោជន៍ រាល់ថ្ងៃ តាមលំដាប់ស្រុក និគម និងរាជធានី នេះឈ្មោះថា ការចារិកទៅដោយមិនប្រញាប់ប្រញាល់ ។ ក៏ការចារិកដោយមិនប្រញាប់ប្រញាល់នេះឯង លោកប្រាថ្នាយកក្នុងទីនេះ ។ បទថា **តជ្ជសិ** កែជា **តេន អ្ជសិ** ឬ **តំ អ្ជសិ** គឺស្តេចទៅ អធិប្បាយថា ស្តេចចូលទៅដោយប្រការនោះ ។ បទថា **ត** ត្រ បានដល់ ជិតក្រុងវេសាលីនោះ ។ បទថា **សុ** ត្រឹមតែជានិបាត ។ បទថា **វេសាលិយំ** បានដល់ នគររបស់ពួកស្តេចលិច្ឆវី ដែលបានឈ្មោះថា **វេសាលី** ព្រោះគេពង្រីកឱ្យ

ជំទូលាយអស់ ៣ ដង ។ បទថា **មហាវនេ** សេចក្ដីថា ឈ្មោះថា ព្រៃមហាវ័ន បានដល់ ព្រៃដែលកើតឯង មិនមានអ្នកណាដាំ ជាព្រៃធំមានព្រំកំណត់ ។ ក៏ព្រៃមហាវ័នជិតខាងក្រុងកបិលវត្ថុ ជាព្រៃមិនមានព្រំកំណត់ ជាប់នឹងព្រៃហិមវន្ត ទល់នឹងមហាសមុទ្រ ។ ព្រៃមហាវ័ននេះ មិនមែនដូច្នោះទេ ។ ឈ្មោះថា ព្រៃ-មហាវ័ន ព្រោះជាព្រៃធំមានព្រំកំណត់ ។ បទថា **កូដាគារសាលាយំ** សេចក្ដីថា ក្នុងអារាមដែលសាងឧទ្ទិសចំពោះព្រះដ៏មានព្រះភាគក្នុងព្រៃមហាវ័ននោះ ព្រះគន្ធកុដិរបស់ព្រះពុទ្ធជាព្រះដ៏មានព្រះភាគ សម្បូរដោយអាការទាំងពួង សាងដោយការប្រក់ដំបូលជាវង់មូលស្រដៀងហង្ស ដោយមានកូដាគារនៅខាងក្នុងឈ្មោះថា **កូដាគារសាលា** ។ ក្នុងកូដាគារសាលានោះ ។ បទថា **វគ្គុមុ-ឌ-ាតីរិយានំ** បានដល់ អ្នកនៅមាត់ច្រាំងនៃស្ទឹងវគ្គុមុទា ។ បទថា **ចេតសា ចេតោ-ប-រិ-ច្ច មនសិការ-ិ-ត្វា** សេចក្ដីថា ទ្រង់ធ្វើមនសិការកំណត់ចិត្តរបស់ភិក្ខុទាំងនោះ ដោយព្រះទ័យរបស់ព្រះអង្គ ។ អធិប្បាយថា ទ្រង់ជ្រាបគុណវិសេស ដែលភិក្ខុទាំងនោះសម្រេច ដោយចេតោបរិយញ្ញាណ ឬសព្វញ្ញុតញ្ញាណ ។

បទថា **អាលោកជាតា ។ យ** ប្រែថា ហាក់ដូចជាមានពន្លឺភ្លឺស្វាង ។ ក្រៅអំពីនោះជាវេចនៈរបស់បទថា **អាលោកជាតា** នោះដូចគ្នា ។ អធិប្បាយថា ដូចពន្លឺភ្លឺស្វាងរបស់ព្រះចន្ទ ១.០០០ ដួង និងព្រះអាទិត្យ ១.០០០ ដួង ។ ក៏ព្រោះហេតុដែលភិក្ខុ ៥០០ រូប ដែលមានព្រះយសោជៈជាប្រធាននោះ ជាអ្នក

ស្វាងសៃ្ង ព្រោះកម្ចាត់ងងឹត គឺអវិជ្ជាដោយប្រការទាំងពួង ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទើបទ្រង់សរសើរភិក្ខុទាំងនោះ ដោយការអាងដល់ការពណ៌នាគុណក្នុងទីភិក្ខុទាំងនោះស្ថិតនៅ ដោយន័យមានជាអាទិ៍ថា ម្នាលអានន្ទ ទិសនុ៎ះឯងដូចជាមានពន្ធឹដល់តថាគត ។ ព្រោះហេតុនេះ លោកទើបពោលថា **យស្សុំ ឧិសាយំ វត្តុមុបាតីវិយា ភិក្ខូ វិហរន្តិ** ភិក្ខុទាំងឡាយអ្នកនៅត្រង់មាត់ ប្រាំងនៃស្ទឹងវត្តុមុទានៅក្នុងទិសណា ។

បទថា **អប្ឆដិកូលា** ប្រែថា មិនគួរស្អប់ អធិប្បាយថា គួរពេញចិត្ត គឺគួររីករាយចិត្ត ។ មែនពិត អាវាសរបស់បុគ្គលអ្នកស្វែងរកគុណដ៏ធំក្រៃលែងជាអ្នកដល់ព្រមដោយគុណ មានសីលគុណជាដើមនៅនោះ មានអាការដូចទីទំនាប មិនស្មើក៏ពិតមែនហើយ ក៏ប៉ុន្តែថា ស្ថានទីនោះ ជាទីគាប់ចិត្ត ជាទីរីករាយចិត្តតែម្តង ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា

តមេ ភ យនិ ភារញ្ញេ
ជិន្ធ ភ យនិ ភ ថលេ
យត្ត អរហន្តោ វិហរន្តិ
តំ ភូមិភមណេយ្យកំ ។

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ[1] ។

បទថា **បហិណេយ្យាសិ** ប្រែថា គប្បីបញ្ជូនទៅ ។ បទថា **សត្ថា អាយស្មន្តានំ ឧស្សុកាមោ** នេះ ជាបទសម្តែងដល់អាការដែលបញ្ជូនទៅ ក្នុងសម្នាក់របស់ភិក្ខុទាំងនោះ ។ ព្រោះហេតុដូច្នោះ ព្រះដ៏មានព្រះភាគទ្រង់ បណ្តេញភិក្ខុទាំងឡាយនោះ ដើម្បីប្រយោជន៍ណា ទ្រង់ឃើញការដល់នូវទីបំផុត នៃប្រយោជន៍នោះ ព្រះអង្គមានព្រះទ័យត្រេកអរ ទើបត្រាស់ប្រាប់នូវសេចក្តីប្រាថ្នា ដើម្បីនឹងឃើញភិក្ខុទាំងឡាយនោះ នឹងព្រះថេរៈ ។ បានឮថា ព្រះអង្គមានព្រះ តម្រិះយ៉ាងនេះថា តថាគតបណ្តេញភិក្ខុទាំងឡាយនេះ ព្រោះធ្វើសំឡេងឮ ខ្លាំង កាលបើដូច្នោះ ភិក្ខុទាំងនោះក៏ត្រូវអានន្ទជាស់តឿន ដូចសេះអាជានេយ្ય ដ៏ចម្រើនត្រូវវាយដោយខ្សែ បានទទួលសេចក្តីតក់ស្ទុតហើយ ទើបចូលទៅកាន់ ព្រៃដើម្បីឱ្យតថាគតប្រាស ព្យាយាមប្រឹងប្រែង នឹងធ្វើឱ្យបានសម្រេចនូវព្រះអរហត្ត យ៉ាងធាប់រហ័ស ។ ក្នុងកាលឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ឃើញភិក្ខុទាំង ឡាយនោះ សម្រេចនូវព្រះអរហត្ត ព្រះអង្គមានព្រះទ័យត្រេកអរដោយការ សម្រេចព្រះអរហត្តនោះ មានប្រាថ្នានឹងឃើញភិក្ខុទាំងនោះ ទើបទ្រង់បញ្ជា ព្រះអានន្ទជាធម្មកណ្ឌាគារិកយ៉ាងនោះ ។

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៦២ ។

បទថា **សោ ភិក្ខុ** បានដល់ ភិក្ខុមួយរូបអ្នកបានអភិញ្ញា ៦ ត្រូវ ព្រះអានន្ទត្ថេរបង្គាប់ដូច្នោះ ។ បទថា **បមុខេ** ប្រែថា ក្នុងទីចំពោះមុខ ។ បទថា **អានេញ្ជសមាធិនា** បានដល់ ដោយសមាធិដែលសម្បយុត្តដោយអរហត្តផល ដែលមានចតុត្ថជ្ឈានជាបាទ ។ អាចារ្យមួយពួកទៀតពោលថា មានអរូបឈាន ជាបាទ ដូច្នេះក៏មាន ។ បាលីថា **អានេញ្ជេន សមាធិនា** ដោយសមាធិដែល មិនញាប់ញ័រ ដូច្នេះក៏មាន ។ ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ កាលទ្រង់ ជ្រាបការមករបស់ភិក្ខុទាំងនោះ ទ្រង់មិនធ្វើបដិសណ្ឋារៈ បែរជាទ្រង់ចូលសមាបត្តិ ទៅវិញ? ដើម្បីឱ្យភិក្ខុទាំងនោះដឹងថា ព្រះអង្គចូលសមាបត្តិ ទើបចូលដើម្បី សម្តែងការនៅរួមរបស់ភិក្ខុទាំងនោះ ដែលព្រះអង្គទ្រង់បណ្តេញក្នុងកាលមុន ស្មើនឹងព្រះអង្គក្នុងឥឡូវនេះ ដើម្បីសម្តែងអានុភាព និងដើម្បីសម្តែងការព្យាករ អរហត្តផលដោយរៀការថ្វែងវាចា ។ អាចារ្យមួយពួកទៀតពោលថា ដើម្បីទ្រង់ ធ្វើបដិសណ្ឋារៈដែលមិនទូទៅដល់អ្នកដទៃ ដោយការបានសេចក្តីសុខដ៏កំពូល ឱ្យកើតឡើងដល់ភិក្ខុទាំងនោះ អ្នកដែលព្រះអង្គទ្រង់បណ្តេញក្នុងកាលមុន ឥឡូវនេះមកកាន់សម្ងាក់របស់ព្រះអង្គ ។ ព្រះថេរៈទាំងឡាយទាំងអស់អង្គនោះ ជ្រាបអធ្យាស្ស័យរបស់ព្រះដ៏មានព្រះភាគ ទើបចូលសមាបត្តិនោះឯង ។ ព្រោះ

ហេតុនោះ លោកទើបពោលថា **ककमेन नु खो कतमा विहारेन वतरहि विहरति** ឥឡូវនេះ ព្រះមានព្រះភាគទ្រង់គង់នៅដោយវិហារធម៌ដូចម្តេចហ្ន៎ ។

ក៏ក្នុងទីនេះ រូបាវចរចតុត្ថជ្ឌានដល់សេចក្តីមិនញាប់ញ័រ ព្រោះប្រកបដោយវោទានធម៌ ១៦ ប្រការ មានការមិនផ្ទាប់មុខចុះជាដើម ដែលជាមូលហេតុនៃឫទ្ធិ ព្រោះធម៌ដែលជាសត្រូវមានកោសជ្ជៈជាដើម នៅឆ្ងាយសែនឆ្ងាយ លោកហៅថា **អានេញ្ជៈ** ព្រោះអត្តថា ខ្លួនឯងក៏មិនញាប់ញ័រ ។ សមពិតដូចពាក្យដែលលោកពោលទុកថា

ចិត្តដែលមិនទ្រាមរមែងមិនញាប់ញ័រ ក្នុងការខ្ជិលច្រអូស ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ (ទុកជាមូល) ១ ចិត្តដែលមិនប៉ោងឡើង រមែងមិនញាប់ញ័រ ក្នុងសេចក្តីរវើរវាយ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ (ទុកជាមូល) ១ ចិត្តដែលមិនទន់ទោរ រមែងញាប់ញ័រ ក្នុងរាគៈ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនបង្ហើន រមែងមិនញាប់ញ័រក្នុងព្យាបាទ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនអាស្រ័យ រមែងមិនញាប់ញ័រ ក្នុងទិដ្ឋិ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនជាប់ជំពាក់ រមែងមិនញាប់ញ័រក្នុងឆន្ទរាគៈ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលផុតស្រឡះ រមែងមិនញាប់ញ័រក្នុងកាមរាគៈ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលគ្មានគ្រឿងប្រកប រមែងមិនញាប់ញ័រក្នុងកិលេស ហេតុ

នោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលគ្មានក្ងីគឺកិលេស រមែងមិនញាប់-ញ័រក្នុងក្ងីគឺកិលេស ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានអារម្មណ៍តែមួយ រមែងមិនញាប់ញ័រ ក្នុងកិលេសមានសភាពផ្សេងៗ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសទ្ធាថែរក្សារមែងមិនញាប់ញ័រ ក្នុងវត្ថុមិនគួរជឿ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានវិរិយៈថែរក្សា រមែងមិនញាប់ញ័រក្នុងការខ្ជិលច្រអូស ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសតិថែរក្សា រមែងមិនញាប់ញ័រក្នុងប្រមាទ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសមាធិថែរក្សា រមែងមិនញាប់ញ័រ ក្នុងសេចក្ដីវាយមាយ ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានបញ្ញាថែរក្សា រមែងមិនញាប់ញ័រ ក្នុងអវិជ្ជា ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលក្ងីស្វាង រមែងមិនញាប់ញ័រក្នុងងងឹតគឺអវិជ្ជា ហេតុនោះ ឈ្មោះថា ចិត្តមិនញាប់ញ័រ ១[1] ។

ម្យ៉ាងទៀត ព្រះបោរាណាចារ្យទាំងឡាយពោលទុកថា ការបញ្ញត្តឈាន ៥ ទាំងនេះថាជាអានេញ្ជៈ គឺរូបាវចរចតុត្ថជ្ឌានប៉ុណ្ណោះដែលប្រព្រឹត្តទៅដោយអំណាចការចម្រើនការប្រាសចាករូប ១ អរូបាវចរឈាន ៤ ដែលប្រព្រឹត្តទៅ

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧១ ទំព័រ ២៦៦ ដល់ ២៦៨ ។

ដោយចែកតាមអារម្មណ៍ ។ បណ្តាឈានទាំងនោះ អរហត្តផលសមាបត្តិដែលធ្វើឈានយ៉ាងណាមួយឱ្យជាបាទហើយទើបចូល ឈ្មោះថា **អានេញ្ជសមាធិ** ។

បទថា **អភិក្កន្តាយ** ប្រែថា កន្ទងទៅហើយ ។ បទថា **ឯ**ក្ខ**ន្តេ** ប្រែថា កន្ទងទៅហើយ ។ អធិប្បាយថា ប្រាសទៅហើយ ។ បទថា **តុណ្ហី អហោសិ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ជាអ្នកស្ងៀមដោយតុណ្ហីភាពដ៏ប្រសើរ ។ បទថា **ឧ**ទ្ធ**ស្តេ អ**រុ**ណេ** ប្រែថា កាលអរុណរះទៅ ឈ្មោះថា **អ**រុ**ណ** បានដល់ពន្ធឺដែលរះឡើងមុនព្រះអាទិត្យរះក្នុងបុរត្ថិមទិស ។ បទថា **ឧ**ន្ន**ិ**ម**ុ**ទ**ិ**យ**ា** សេចក្តីថា កាលរាត្រីកើតហើយ ភ្ញីហើយ ដូចពន្ធឺអរុណដែលជាប្រធានក្នុងការធ្វើពួកសត្វអ្នកអាស្រ័យពន្ធឺព្រះអាទិត្យឱ្យរីកពាយ ព្រោះអរុណនៃរាត្រីឡើងនុ៎ះឯង ។

បទថា **ត**ម្ហ**ា** **ស**មា**ធ**ិ**ម**្ហ**ា** **វ**ុ**ដ**្ឋ**ហ**ិ**ត**្វ**ា** សេចក្តីថា ចេញចាកអានេញ្ជៈសមាធិ គឺពីផលសមាបត្តិ ដែលសម្បយុត្តដោយអរហត្តផលនោះ តាមវេលាដែលកំណត់ ។ បទថា **ស**ចេ **ខ**ោ **ត**ំ**ភ**ន្ត **ជ**ានេ**យ**្យ**ាសិ** សេចក្តីថា ម្នាលអានន្ទ បើលោកគប្បីដឹងយ៉ាងនេះថា ព្រះដ៏មានព្រះភាគ និងភិក្ខុទាំងនោះញ៉ាំងកាលឱ្យកន្ទងទៅ ដោយសុខដែលកើតអំពីសមាបត្តិឈ្មោះនេះ រហូតអស់កាលត្រឹមតែប៉ុណ្ណោះ ។ ដោយបទថា **ឯ**ត្ត**ក**ម្ម**ិ** **ត**េ **ន**ប្ប**ដ**ិ**ភ**ា**ស**េ**យ**្យ** ព្រះដ៏មានព្រះភាគកាលនឹងទ្រង់សម្តែងថា សេចក្តីជាក់ច្បាស់ដែលប្រាកដដល់លោក ៣ ដង ដោយន័យមានជាអាទិ៍ថា ពាត្រីកន្ទងទៅហើយព្រះអង្គដូច្នេះ ដែលសំដៅ

ដល់ការប្រាស្រ័យដែលជាចំណែកលោកិយ: សូម្បីត្រឹមតែប៉ុណ្ណោះក៏មិនទាន់ប្រាកដដល់លោក ។ ម្នាលអានន្ទ ក៏ព្រោះហេតុដែលលោកជាសេក្ខបុគ្គល មិនដឹងសមាបត្តិវិហារធម៌ដែលជារបស់ព្រះអសេក្ខ:ដូច្នោះ លោកទើបដល់សេចក្តីខ្ជល់ខ្ជាយដែលនឹងឱ្យយើងធ្វើការប្រាស្រ័យ ដែលជាចំណែកលោកិយ:ដល់ភិក្ខុទាំងនេះ ។ តែយើងព្រមដោយភិក្ខុទាំងនេះញ៉ាំងកាលឱ្យកន្ទងទៅរហូតដល់អស់រាត្រីទាំង ៣ យាម ដោយការប្រាស្រ័យដែលជាលោកុត្តរ:នុ៎ះឯង ទើបត្រាស់ថា **អហាញ្ចានន្ទ ឥមានិ ច បញ្ចកិក្ខុសតានិ សព្វេ អានេញ្ជសមាធិនា និសិន្នា** ម្នាលអានន្ទ (ព្រោះថា) តថាគតផង ភិក្ខុ ៥០០ រូបផង ទាំងអស់គ្នាសុទ្ធតែអង្គុយនៅដោយសមាធិមិនកម្រើក ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់អត្ថ គឺសេចក្តីដែលភិក្ខុទាំងនោះមានសេចក្តីជំនាញពោលគឺ សេចក្តីអាចក្នុងការចូលអានេញ្ជសមាបត្តិស្មើនឹងព្រះអង្គនេះ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺនូវឧទាននេះ ដែលសម្តែងដល់សភាវ:ដែលភិក្ខុទាំងនោះជាអ្នកសម្រេចក្នុងការលះរាគ:ជាដើមមិនឱ្យសេសសល់ ។

បណ្តាបទទាំងនោះ បទថា **យស្ស ជិតោ កាមកណ្ដកោ** សេចក្តីថា កាម គឺកិលេស ឈ្មោះថាជាបន្ទា ព្រោះអត្ថថា រុកចាក់ធម៌ដែលជាបដិបក្ខ

ចំពោះកុសលធម៌ដែលជាហេតុឱ្យព្រះអរិយបុគ្គលឈ្នះ គឺលះបានដោយមិនឱ្យសេសសល់ដោយពាក្យនោះ ព្រះអង្គទ្រង់សម្តែងដល់ការ:ដែលព្រះអរិយ-បុគ្គលនោះមិនមានសេចក្តីត្រេកអរ ។ បាលីថា **តាមកណ្ណាតោ** ដូច្នេះក៏មាន ។ ព្រះបាលីនោះមានអធិប្បាយដូច្នេះ បន្ទាក្នុងស្រុក បានដល់ វត្ថុកាមទាំងអស់ដែលជាទីតាំងនៃបន្ទា គឺព្រះអរិយបុគ្គលណាឈ្នះហើយ ព្រោះដូច្នោះ សេចក្តីឈ្នះរបស់ព្រះអរិយបុគ្គលនោះ គប្បីជ្រាបដោយការលះឆន្ទរាគ:ដែលជាប់ដោយវត្ថុកាមនោះ ដោយពាក្យនោះ ជាហេតុ គឺព្រះដ៏មានព្រះភាគត្រាស់ដល់អនាគាមិមគ្គរបស់ភិក្ខុទាំងនោះ ។ ភ្ជាប់សេចក្តីថា ក៏ការជេរដែលព្រះអរិយ-បុគ្គលឈ្នះហើយ ។ សូម្បីក្នុងបទថា **វធោ ច ពន្ធនញ្ច** នេះ ក៏នំយនេះដូចគ្នា ។ បណ្តាការជេរជាដើមនោះ ទ្រង់សម្តែងសេចក្តីមិនមានវចីទុច្ចរិត ដោយការឈ្នះការជេរ ។ ទ្រង់សម្តែងសេចក្តីមិនមានកាយទុច្ចរិត ដោយធម៌ក្រៅនេះ ។ ដោយពាក្យនោះ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់មគ្គទី ៣ ដោយការលះព្យាបាទដែលមានការជេរជាដើមនោះ ជានិមិត្តបានដោយមិនឱ្យសេសសល់ ។ ម្យ៉ាងទៀត គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដល់មគ្គទី ៣ ដោយពាក្យដែលឈ្នះការជេរជាដើម ។ ការគ្របសង្កត់ការជេរជាដើមបានកាត់ផ្តាច់ ជាការទ្រង់ប្រកាសក្នុងមគ្គទី ៣ នោះ ។ សូម្បីទាំង ២ បទ ក៏ទ្រង់សម្តែងដល់សេចក្តីដែលភិក្ខុទាំងនោះមិនមានសេចក្តីប្រទូស្តរ៉ាយ ។ បទថា **បញ្ចោ វិយ សោ ឋិតោ**

អនេជោ សេចក្ដីថា អន្ដរាយ គឺកិលេសដែលជាតួញាប់ញ័រ លោកហៅថា **ឯជា** ឈ្មោះថា **អនេជា** ព្រោះមិនមានកិលេសដែលនៅសល់ដែលជាហេតុឱ្យញាប់-ញ័រតាំងនៅ គឺដូចជានឹងភ្នំថ្មតាន់ ព្រោះមិនញាប់ញ័រដោយកិលេសទាំងពួង និងដោយខ្យល់ពោលគឺ ការប្រទូស្ដរបស់អ្នកដទៃ ព្រោះមិនមានការញាប់ញ័ររុ៉ុនៈឯង ។ បទថា **សុខុក្ខេ សុ ន វេធតិ ស ភិក្ខុ** សេចក្ដីថា ភិក្ខុនោះជាអ្នកមានកិលេសទម្លាយហើយ រមែងមិនញាប់ញ័រដែលមានសុខនិងទុក្ខជាហេតុ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្ដីនោះដោយន័យដូចពោលហើយ ក្នុងកាលមុនន៏ុ:ឯង ។

ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវភាពជាអ្នកមាំមួន ដោយការសម្រេចព្រះ-អរហត្តរបស់ភិក្ខុទាំង ៥០០ រូបនោះ ទើបទ្រង់បន្ទឺនូវឧទានដែលមានបុគ្គលឯកជាទីតាំងដោយប្រការដូច្នេះឯង ។

ततिय सुत्तवण्णना निट्ठिता

ចប់ អដ្ឋកថាសូត្រទី ៣

៤- សារីបុត្តសុត្តវណ្ណនា

អដ្ឋកថាសារីបុត្តសូត្រ

សារីបុត្តសូត្រទី ៤ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **បរិមុខំ សតឺ ឧបដ្ឋបេត្វា** *សេចក្តីថា តាំងសតិឱ្យត្រង់ចំពោះអារម្មណ៍ គឺតាំងសតិឱ្យឆ្ពោះទៅមុខ ។ ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងវិភង្គថា សតិនេះដែលបុគ្គលតម្កល់ទុកហើយ តាំងទុកល្អហើយ ត្រង់ទីបំផុតនៃច្រមុះ ត្រង់និមិត្តនៃមាត់ក្តី ព្រោះហេតុនោះ ទើបពោលថា តម្កល់សតិឱ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន)[១] ។ ម្យ៉ាងទៀត បទថា* **បរិ** *មានអត្ថថា កំណត់ ។*

បទថា **មុខំ** *មានអត្ថថា នាំចេញ ។ បទថា* **សតិ** *មានអត្ថថា ប្រាកដ ។ ព្រោះហេតុនេះលោកទើបពោលថា* **បរិមុខំ សតឺ** *។ ក៏ក្នុងទីនេះ គប្បីជ្រាបអត្ថដោយន័យដូចពោលហើយក្នុងបដិសម្ភិទា ដោយប្រការដូច្នេះ ។ ក្នុងសេចក្តីនោះ មានសេចក្តីសង្ខេបដូចតទៅនេះ ក៏បទថា* **និយ្យានំ** *ក្នុងបទថា* **បរិក្តហិ-តនិយ្យានសតឺ កត្វា** *នេះគប្បីឃើញអារម្មណ៍ដែលសតិជ្ជាក់ចុះ ។ ក៏ក្នុងសេចក្តីនេះ សេចក្តីដើម និងសេចក្តីក្រោយ គប្បីឃើញសតិឃុំគ្រងអារម្មណ៍ទុកបានទាំងអស់ ក្រៅនោះ គប្បីឃើញការប្រមូលចំណែកខាងដើមនៃសមាបត្តិ ។ ម្យ៉ាងទៀត ឈាន លោកហៅថា សតិ ដោយលើកសតិឡើងជាប្រធានដូចក្នុង*

១-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២៨៦ ។

ប្រយោគមានជាអាទិ៍ថា ភិក្ខុណាបរិកោគកាយគតាសតិ ។ សួរថា ក៏ឈាននោះ ដូចម្តេច? ឆ្លើយថា បានដល់ ឈានដែលសម្បយុត្តដោយអរហត្តផល ដែលធ្វើ រួបារ១ចតុត្ថជ្ឌានឱ្យជាបាទហើយទើបចូល ។ សួរថា ក៏ឈាននោះនឹងគប្បីដឹង បានយ៉ាងណា? ឆ្លើយថា ព្រះដ៏មានព្រះភាគកាលទ្រង់ប្រកាសសេចក្ដីដែល ព្រះថេរៈមិនញាប់ញ័ររ្ម១ដោយគុណវិសេស ព្រោះប្រកបដោយអានេញ្ជ-សមាធិ និងសេចក្ដីដែលព្រះថេរៈនោះជាអ្នកដែលអ្វីៗ ឱ្យញាប់ញ័ររ្ម១មិនបាន ដោយប្រៀបផ្ទឹ១ដោយភ្នំ ទើបទ្រង់បន្ទឺនូវ១ទានេះ ព្រោះហេតុនោះ ១ម្ងែងដឹង សេចក្ដីនេះបានដោយគាថានុ៎ះឯង ។ ក៏សេចក្ដីនេះ មិនមែនព្រះថេរៈអង្គ១ ដើម្បីចាក់ធ្ងុ១ហូតដល់សច្ចៈ ដោយពិត ព្រះថេរៈអង្គ១ដើម្បីនៅជាសុ១ក្នុង បច្ចុប្បន្ន ។ ១ម្ងែងពិត ក្នុងកាលមុននោះឯង កាលព្រះដ៏មានព្រះភាគទ្រង់សម្ដែង ធម៌ដល់ទីឃនខបរិព្វាជក ជាក្ជ១ យរបស់ព្រះថេរៈត្រង់ណ្ឌាងសុ១ខាតា ព្រះមហា-ថេរៈនេះដល់ទីបំផុតកិច្ចនៃការចាក់ធ្ងុ១ហូតដល់សច្ចៈនោះឯង ។

បទថា **ឯតមត្ថំ** សេចក្ដីថា ព្រះអង្គ១ទ្រង់ជ្រាបដោយប្រការទាំងពួងដល់ អត្ថនេះពោលគឺ ការ:ដែលព្រះថេរៈជាអ្នកដល់នូ១ភាពរ១ងមាំ និងគឺអ្វីៗ ឱ្យញាប់-ញ័ររ្ម១មិនបាន ព្រោះប្រកបដោយអានេញ្ជសមាធិ ទើបទ្រង់បន្ទឺនូ១ទានេះ ប្រកាសសេចក្ដីនោះ ។

បណ្តាបទទាំងនោះ បទថា **យថាបិ ឋ្ងតោ** *សេចក្តីថា ដូចក្នុំថ្មតាន់ដែលសម្រេចហើយដោយថ្ម មិនមែនក្នុំដីសុទ្ធ ឬមិនមែនក្នុំលាយដី ។ បទថា* **អចលោ សុឋ្ឋិតិដ្ឋិតោ** *សេចក្តីថា មានឫសតាំងនៅដោយល្អ មិនកម្រើក គឺមិនញ័ររដោយខ្យល់តាមប្រក្រតី ។ បទថា* **ឯវំ មោហក្ខយា ភិក្ខុ ឋ្ងតោ ន ឯជតិ** *សេចក្តីថា ភិក្ខុឈ្មោះថា លះអកុសលទាំងពួងបាន ព្រោះលះមោហៈបានមិនឱ្យសេសសល់ និងព្រោះលះអកុសលទាំងពួងមានមោហៈជាមូល រមែងមិនកម្រើក គឺញាប់ញ័ររដោយលោកធម៌ទាំងឡាយ ដូចក្នុំថ្មតាន់នោះមិនញ័ររញ្ជួយដោយខ្យល់តាមប្រក្រតី ។ ម្យ៉ាងទៀត ព្រោះហេតុដែលព្រះនិព្វាន និងព្រះអរហត្តលោកហៅថា* **មោហក្ខយៈ** *ដូច្នោះ ភិក្ខុនោះទើបឈ្មោះថា តាំងនៅដោយល្អហើយក្នុងអរិយសច្ចៈ ៤ ព្រោះសម្រេចព្រះនិព្វាន និងព្រះអរហត្តហេតុ អស់ទៅនៃមោហៈ សូម្បីក្នុងវេលា ដែលមិនចូលសមាបត្តិក៏មិនញាប់ញ័ររដោយអ្វីៗ ដូចក្នុំថ្មតាន់តាមដែលពោលមកហើយ ។ អធិប្បាយថា នឹងចាំបាច់ពោលទៅថ្មីក្នុងវេលាចូលសមាបត្តិហ្ន៎ ។*

ចតុត្ថសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៤

៤. កោលិតសុត្តវណ្ណនា[1]

អដ្ឋកថាកោលិតសូត្រ

កោលិតសូត្រទី ៤ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **កាយគតាយ សតិយា** *សេចក្តីថា មានសតិដែលតាំងនៅក្នុងកាយ គឺមានកាយជាអារម្មណ៍ ដោយអំណាចកាយានុបស្សនា ។ បទថា* **សតិយា** *នេះ ជាតតិយាវិភត្តិប្រើក្នុងលក្ខណៈឥត្ថម្ភូត ។ ខាងក្នុងខ្លួនឈ្មោះថា អជ្ឈត្តៈ ក្នុងបទនេះ* **អជ្ឈត្តំ** *នេះ ។ ព្រោះដូច្នោះ ទើបមានសេចក្តីថា ក្នុងខ្លួន គឺក្នុងសន្តានរបស់ខ្លួន ។ ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីរបស់បទថា* **អជ្ឈត្តំ** *ថា* **គោចរជ្ឈត្តំ** *ព្រោះលោកប្រាថ្នាយកប្រជុំចំណែកទាំង ៣២ មានសក់ជាដើម ដែលជាតួកម្មដ្ឋានថា កាយក្នុងទីនេះ ។ បទថា* **សុប្បតិដ្ឋិតាយ** *សេចក្តីថា ប្រាកដដោយល្អក្នុងកាយ ដែលមានក្នុងខ្លួន ឬដែលមានក្នុងអារម្មណ៍ ។ សួរថា ក៏សតិដែលលោកពោលថា ប្រាកដដោយល្អក្នុងខ្លួន គឺអ្វី? ឆ្លើយថា គឺសតិដែលប្រាកដក្នុងកាយ ដោយអំណាចឧបចារៈនិងអប្បនារបស់ព្រះយោគី អ្នកញ៉ាំងបដិកូលមនសិការឱ្យប្រព្រឹត្តទៅក្នុងអាការ ៣២ មានសក់ជាដើម ដែលមានខាងក្នុងដែលព្រះដ៏មានព្រះភាគត្រាស់ថា កាយដោយន័យមានជាអាទិ៍ថា សក់ ពោម មានទៅក្នុងកាយនេះ នោះលោកហៅថា* **កាយគតាសតិ** *។ ក៏កាយគតាសតិនេះយ៉ាងណា សតិដែលប្រាកដក្នុងកាយដោយអំណាចឧបចារៈនិងអប្បនាតាមគួររបស់ព្រះយោគី អ្នកញ៉ាំងមនសិការឱ្យប្រព្រឹត្តទៅដោយអំណាច*

១-ក្នុងអដ្ឋកថាឫស្សាសធម្មសង្គាយនា ព្រះសូត្រនេះមានឈ្មោះថា **មហាមោត្តល្លានសុត្តវណ្ណនា** *។*

សតិសម្បជញ្ញៈក្នុងអានាបាណៈ និងឥរិយាបថ ៤ និងដោយអំណាចឧទ្ទុមាត-
កអសុកៈ និងវិនីលកអសុកៈជាដើម ក៏ហៅថា **កាយគតាសតិ** ដូច្នោះ ។ ក៏ក្នុងទី
នេះ កាយគតាសតិខាងក្នុងខ្លួន កំណត់ធាតុទាំង ៤ មានបថវីធាតុជាដើម
ដោយអាការយ៉ាងណាមួយ គឺដោយអាការមួយ បណ្តាអាការទាំង ៤ មាន
សម្ភារៈសង្ខេបជាដើម ប្រាកដដោយការកំណត់អនិច្ចលក្ខណៈជាដើមរបស់ធាតុ
ទាំងនោះជាសតិដែលសម្បយុត្តដោយវិបស្សនា លោកប្រាថ្នាយកថា កាយគ-
តាសតិ ។ ក៏ព្រះថេរៈ ឃើញច្បាស់យ៉ាងនោះទើបអង្គុយចូលផលសមាបត្តិ
របស់ខ្លួនប៉ុណ្ណោះ ។ សូម្បីក្នុងទីនេះ សេចក្តីនៃព្រះគាថានេះនឹងដឹងច្បាស់បាន
យ៉ាងនោះ គប្បីប្រកបតាមលំអាននៃន័យដែលពោលទុកដោយន័យថា **ន
ចារយំ និសជ្ជា** ក៏ការអង្គុយនេះមិនមែន... ដូច្នេះជាដើម ។

បទថា **ឯតមត្ថំ** សេចក្តីថា ទ្រង់ជ្រាបអត្ថនេះពោលគឺ ការដែលព្រះថេរៈ
ចម្រើនវិបស្សនាក្នុងកាយានុបស្សនាសតិប្បដ្ឋាន ដោយការកំណត់ធាតុ ៤ ជា
ប្រធានហើយ ទើបចូលផលសមាបត្តិ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺ
នូវឧទាននេះ ដែលសម្តែងការសម្រេចព្រះនិព្វានដោយសតិប្បដ្ឋានភាវនា ។

បណ្តាបទទាំងនោះ បទថា **សតិ កាយគតា ឧបដ្ឋិតា** សេចក្តីថា
សតិមានលក្ខណៈដូចពោលហើយក្នុងកាលមុន ឈ្មោះថា លះធម៌ដែលជាបដិបក្ខ
ចេញបាន ព្រោះដល់ភាវៈដែលជួយក្នុងការធ្វើកិច្ចរបស់សមាធិ វិរិយៈ និងបញ្ញា

ដែលមានសទ្ធាជាបុព្វភាគឱ្យសម្រេចតាមនាទីរបស់ខ្លួន អំពីនោះជាភាពស្អាតឥតខ្ចោះ ចូលទៅកំណត់សភាវៈដែលមិនខុសប្លែកដោយអំណាចកាយសំវរៈ តាមដែលពោលហើយ និងដោយអំណាចការរួមអត្តទុកដោយចំណែកតែមួយ ហើយតាំងនៅ ។ ដោយពាក្យនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់សតិដែលទៅមក នៅនឹងបញ្ញាដែលកំណត់បច្ច័យទាំងឡាយ ដោយការកំណត់ធាតុ ៤ ពោលគឺ កាយ និងឧបាទារូបដែលអាស្រ័យធាតុ ៤ នោះ តអំពីនោះ ទើបប្រព្រឹត្តទៅដោយអំណាចកំណត់បច្ច័យទាំងនោះ មានជាអនិច្ចលក្ខណៈជាដើម ម្យ៉ាងទៀតកាលពោលដោយសតិជាប្រធាន ទើបទ្រង់សម្តែងចំពោះការបន្តៗ គ្នាមកនៃបញ្ញាដែលរាប់បញ្ចូលក្នុងបរិញ្ញា ៣ ដែលសម្បយុត្តដោយសតិនោះ ។ បទថា **ឆសុ ផស្សាយតនេសុ សំវុតោ** សេចក្តីថា ព្រះយោគីអ្នកប្រកបដោយភាពជាអ្នកមានសតិប្រាកដក្នុងកាយ តាមដែលពោលហើយ ទើបបដិសេធការប្រព្រឹត្តទៅនៃបញ្ញា ព្រោះការទៅចម្រើនកាយានុបស្សនាក្នុងទ្វារទាំង ៦ មានចក្ខុទ្វារជាដើមដែលជាហេតុនៃផស្សៈ អកិណ្ណជាដើមដែលគួរនឹងកើតក៏កើតឡើង កាលនឹងបិទបាំងនូវអកិណ្ណជាដើមនោះ ទើបត្រាស់ហៅថា អ្នកសង្រួមក្នុងទ្វារ ៦ មានចក្ខុទ្វារជាដើមនោះ។ ដោយពាក្យនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់ញាណសំវរៈ។

បទថា **សតតំ ភិក្ខុ សមហិតោ** សេចក្តីថា ភិក្ខុនោះមានសតិប្រាកដហើយយ៉ាងនោះនិងសង្រួមហើយក្នុងទ្វារទាំងពួង មិនបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដែលច្រើន ពិចារណាដោយអំណាចអនិច្ចលក្ខណៈជាដើម ចម្រើន

វិបស្សនា កាលញាណចាស់ក្លាវីងមាំប្រព្រឹត្តទៅ ក៏មានចិត្តតាំងមាំដោយសមាធិ ដែលសម្បយុត្តដោយវិបស្សនា ប្រព្រឹត្តទៅជាប់តមិនដាច់រយៈតែម្តង តាំងពីលំដាប់អនុលោមញាណដរាបដល់កើតគោត្រភូញាណ ។ បទថា **ជ ញ្ញា និ ព្វា-ន មត្ត ណោ** សេចក្តីថា ព្រះនិព្វានដែលជាអសង្ខតធាតុនាំមកដែលសេចក្តីសុខ យ៉ាងពិតប្រាកដ ដោយជាអារម្មណ៍ដែលល្អធ្វើមដល់មគ្គញ្ញាណ និងផលញ្ញាណ ដែលបានបញ្ញត្តថា **អត្តា** ព្រោះមិនជាអារម្មណ៍របស់បុថុជ្ជនដទៃ ដោយហោចទៅសូម្បីត្រឹមតែយល់សប្តិ តែព្រោះជាផ្នែកមួយនៃមគ្គញ្ញាណនិងផលញ្ញាណ នោះ។ របស់ព្រះអរិយៈទាំងឡាយ និងព្រោះដូចជានឹងអត្តា ទើបហៅថា **អ ត្ត ណោ** (របស់ខ្លួន) គប្បីដឹង គឺគប្បីជ្រាបព្រះនិព្វានៃ អធិប្បាយថា គប្បីចាក់ធុះ គឺគប្បីធ្វើឱ្យច្បាស់ដោយមគ្គញ្ញាណនិងផលញ្ញាណទាំងឡាយ ។ ដោយពាក្យនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់សេចក្តីដែលព្រះអរិយៈទាំងឡាយ មានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ។ មែនពិត ព្រះអរិយៈទាំងឡាយរមែងនៅ សូម្បីក្នុងវេលាដែលអធិចិត្តប្រព្រឹត្តទៅ ក៏នៅដោយការៈដែលបង្អោនទោរទន់ ទៅក្នុងព្រះនិព្វានដោយចំណែកតែមួយប៉ុណ្ណោះ ។ ក៏ក្នុងទីនេះ សតិប្រព្រឹត្តទៅ ក្នុងកាយប្រាកដដល់ភិក្ខុណា ភិក្ខុនោះសង្រួមហើយក្នុងផស្សាយតនៈ ៦ តអំពីនោះក៏មានចិត្តតាំងមាំរឿយៗ គប្បីដឹងព្រះនិព្វានរបស់ខ្លួន ដោយការធ្វើឱ្យប្រចក្ស ដល់ខ្លួន គប្បីជ្រាបការភ្ជាប់បទនៃគាថាយ៉ាងនេះដោយប្រការដូច្នេះ ។ ព្រះដ៏-

មានព្រះភាគជាធម្មរាជា ទ្រង់សម្តែងផ្លូវជាគ្រឿងនាំចេញដល់ភិក្ខុមួយរូបដោយ
កាយានុបស្សនាសតិប្បដ្ឋានជាប្រមុខ ដរាបដល់ព្រះអរហត្តដោយប្រការដូច្នេះ ។

ន័យមួយទៀត ដោយបទថា **សតិ កាយគតា ឧបដ្ឋិតា** *នេះ ទ្រង់*
សម្តែងដល់កាយានុបស្សនាសតិប្បដ្ឋាន ។ បទថា **ឆសុ ផស្សាយតនេសុ**
សំវុតោ *សេចក្តីថា ឈ្មោះថា ផស្សាយតន: ព្រោះជាដែនមកចំពោះ គឺជា*
ហេតុនៃផស្ស: ក្នុងផស្សាយតន:ទាំងនោះ ។ ឈ្មោះថា សង្រ្ទួមហើយ ព្រោះ
តណ្ហាជាដើមមិនប្រព្រឹត្តទៅក្នុងវេទនា ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម
ដែលមាន ផស្ស:ជាហេតុ គឺកើតឡើងព្រោះផស្ស:ជាបច្ច័យ ដោយពាក្យនោះ
ព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់វេទនានុបស្សនាសតិប្បដ្ឋាន ។ បទថា **សតតំ**
ភិក្ខុ សមាហិតោ *សេចក្តីថា ភិក្ខុ ឈ្មោះថា តាំងមាំជាប់តរហូតដល់អស់កាល*
ជានិច្ចមិនមានចន្ទោះ ព្រោះមិនមានសេចក្តីរវើរវាយ ក៏ភិក្ខុនេះ ឈ្មោះថា ជាអ្នក
មិនរវើរវាយព្រោះដល់ទីបំផុតដោយសតិប្បដ្ឋានភាវនា ដោយប្រការទាំងពួង ។
មែនពិត កាលលោកពិចារណាកំណត់បានមិនឱ្យសេសសល់ក្នុងឧបាទានខន្ធ ៥
ដែលផ្សេងដោយប្រភេទនៃកាល មានអតីតកាលជាដើម ។ ដោយពាក្យនេះ
ព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់សតិប្បដ្ឋានដែលនៅសល់ ។ បទថា **ជញ្ញា**
និព្វានមត្តនោ *សេចក្តីថា ភិក្ខុអ្នកទម្លាយកិលេស ជាអ្នកដល់នូវទីបំផុតនៃ*
សតិប្បដ្ឋានភាវនាទាំង ៤ តាំងនៅដោយអាការយ៉ាងនេះ ខ្លួនឯងនុ៎ះឯង គប្បី
ដឹងនូវខ្លួនឯងនូវកិលេសនិព្វានរបស់ខ្លួនដោយបច្ចវេក្ខណញ្ញាណ ។

សម្រាប់ជាធម្មទាន

ម្យ៉ាងទៀត ដោយបទថា **សតិ កាយគតា ឧបដ្ឋិតា** នេះ ទ្រង់សម្តែងដល់សេចក្តីដែលព្រះថេរៈជាអ្នកមានសតិចាស់ក្លា ដោយការសម្តែងដល់ការកំណត់ដឹងតាមសភាវៈនៃកាយរបស់ខ្លួននិងរបស់អ្នកដទៃ ។ ដោយបទថា **ឆសុ ឆស្សាយតនេសុ សំវុតោ** នេះ ព្រះអង្គទ្រង់សម្តែងដល់ការដែលព្រះថេរៈដល់ភាពជាអ្នកបរិបូណ៌ដោយបញ្ញា ដែលប្រកាសដល់សម្បជញ្ញៈ ដោយអំណាចនៃការនៅដោយសេចក្តីស្ងប់ជាដើម ដែលសម្តែងដល់សេចក្តីសង្រ្ទួមយ៉ាងពិតប្រាកដក្នុងទ្វារ ៦ មានចក្ខុទ្វារជាដើម ។ ដោយបទថា **សតតំ ភិក្ខុ សមាហិតោ** នេះ ទ្រង់សម្តែងអនុបុព្វវិហារសមាបត្តិ ៩ ដោយសម្តែងដល់ភាពជាអ្នកច្រើនដោយសមាបត្តិ ។ ក៏ភិក្ខុអ្នកជាយ៉ាងនេះ គប្បីដឹងនិព្វានរបស់ខ្លួន គឺគប្បីដឹងគប្បីគិតដល់អនុបាទិសេសនិព្វានធាតុរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ព្រោះមិនមានករណីយកិច្ចដែលក្រៃលែង ព្រោះធ្វើកិច្ចសម្រេចហើយអធិប្បាយថា សូម្បីកិច្ចដែលលោកនឹងគប្បីគិតក៏មិនមាន ។

បញ្ចម សុត្តវណ្ណា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៥

៦. **ពិលិន្ទវច្ឆសុត្តវណ្ណនា**

អដ្ឋកថាពិលិន្ទវច្ឆសូត្រ

ពិលិន្ទវច្ឆសូត្រទី ៦ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ពិលិន្ទវច្ឆោ** *សេចក្ដីថា បទថា* **ពិលិន្ទ:** *ជាឈ្មោះរបស់ព្រះថេរៈ ជនទាំងឡាយស្គាល់ព្រះថេរៈបានដោយគោត្រថា* **វច្ឆ:** *។ បទថា* **រសលវានេន សមុទាចរតិ** *សេចក្ដីថា ព្រះថេរៈរមែងពោល រមែងហៅកិក្ខុទាំងឡាយដោយវាទៈថា អ្នកថោកទាប ដោយន័យមានជាអាទិ៍ថា នែ៎អ្នកថោកទាប ចូរមក នែ៎អ្នកថោកទាប ចូរជៀសចេញទៅចុះ។*

បទថា **សម្ពហុលា ភិក្ខូ** *ប្រែថា ភិក្ខុជាច្រើន ។ ភិក្ខុទាំងនោះឃើញ ព្រះថេរៈស្រែកហៅដូច្នោះ កាលមិនដឹងថា ព្រះថេរៈជាព្រះអរហន្ដពោលយ៉ាងនោះ ព្រោះនូវលះវាសនាមិនបាន ទើបគិតថា ព្រះថេរៈនេះទំនងជាអ្នកប្រាជ្ញ ប្រទូស្ដទើបស្រែកហៅយ៉ាងនេះ មានប្រាជ្ញានឹងនិយាយអួត ទើបក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ដើម្បីនឹងឱ្យព្រះថេរៈចេញចាកភាពជាអ្នកប្រាជ្ញ ប្រទូស្ដនោះ ។ ព្រោះហេតុនេះ លោកទើបពោលថា បពិត្រព្រះអង្គដ៏ចម្រើន ពិលិន្ទវច្ឆៈដ៏មានអាយុ ហៅកិក្ខុទាំងឡាយដោយវាទៈថា អ្នកថោកទាប ។*

ចំណែកកេចិអាចារ្យពោលថា កិក្ខុទាំងឡាយស្គាល់ព្រះថេរៈនេះបានថា ជាព្រះអរហន្ដ គិតថា ក៏ព្រះថេរៈនេះហៅកិក្ខុទាំងឡាយយ៉ាងនេះ ដោយពាក្យគ្រោតគ្រាត ឧត្ដរិមនុស្សធម្មក្នុងព្រះថេរៈនេះ ទំនងមិនមានទេ ដូច្នេះ មិនដឹងការហៅយ៉ាងនោះរបស់ព្រះថេរៈដោយអំណាចវាសនា និងមិនជឿថា លោកជាព្រះអរិយៈ ទើបសម្គាល់ក្នុងការសម្ដឹងទោស បានក្រាបទូលរឿងនោះដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគប្រាជ្ញានឹងទ្រង់ប្រកាសថា ព្រះថេរៈ

មិនមានសេចក្ដីប្រាថ្នាប្រទូស្ត ទើបព្រះថេរៈបង្គាប់ភិក្ខុមួយរូបហៅព្រះថេរៈមក ហើយត្រាស់ដល់ព្រះថេរៈចំពោះមុខថា ភិក្ខុនេះហៅយ៉ាងនោះ ដោយហេតុដែលធ្លាប់សន្សំក្នុងកាលមុន មិនបានប្រាថ្នាក្នុងការពោលពាក្យគ្រោតគ្រាតទេ ។ ព្រោះហេតុនេះលោកទើបពោលថា គ្រានោះឯង ព្រះដ៏មានព្រះភាគបានត្រាស់ហៅភិក្ខុមួយរូបមក ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **បុព្ពនិវាសំ មនសិការិត្វា** សេចក្ដីថា ព្រះសាស្ដាត្រាស់សួរព្រះថេរៈថា ម្នាលវច្ছ: បានឮថា លោកហៅភិក្ខុទាំងឡាយដោយវាទ:ថា អ្នកថោកទាបពិតមែនឬ កាលព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតយ៉ាងនោះ ព្រះអង្គកាលទ្រង់រំពឹងថា វច្ছ:នេះមិនលះបង់វាទ:ថាអ្នកថោកទាប ព្រោះវាសនាដែលសៅហ្នង សូម្បីក្នុងអត្តភាពដែលជាអតីតលោកក៏បានកើតក្នុងជាតិព្រាហ្មណ៍ឬហ្ន៎ ទើបទ្រង់មនសិការដល់ខន្ធសន្ដានដែលលោកធ្លាប់នៅក្នុងអតីតជាតិ ដែលជាទីនៅនៃខន្ធក្នុងកាលមុនរបស់លោកដោយបុព្វេនិវាសញ្ញាណ និងសព្វញ្ញុតញ្ញាណ គឺធ្វើទុកក្នុងព្រះទ័យរបស់ព្រះអង្គដោយធ្វើឱ្យប្រចក្ស ដូចផ្ទែកន្ទួតព្រៃដែលជាក់លើបាតដៃ ។ បទថា **ភិក្ខូ អាមន្តេសិ** សេចក្ដីថា ត្រាស់ហៅដើម្បីឱ្យភិក្ខុទាំងនោះឮព្រម ។ ព្រោះហេតុនេះ លោកទើបពោលថា **មា ខោ តុម្ហេ ភិក្ខវេ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ សព្ទថា **មា** ជានិបាតប្រើក្នុងអត្ថបដិសេធ ។ **មា** សព្ទនោះគប្បីភ្ជាប់នឹងបទថា **ឧជ្ঝាយិត្ថ** នេះ ។ បទថា **មា ឧជ្ঝាយិត្ថ** សេចក្ដី

ថា ពួកលោកកុំគិត គឺសម្ងឹងមើលទៅផ្លូវក្រោម ។ ក៏បទថា **វច្ឆ ! ភិក្ខុ** ជាចតុត្ថីវិភត្តិ ព្រោះការសម្ងឹងទោសជាការឫស្យា ។

ឥឡូវនេះ កាលនឹងទ្រង់សម្តែងហេតុក្នុងសេចក្តីដែលលោកមិនគួរនឹងសម្ងឹងទោស ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វច្ឆ:មិនបានប្រាថ្នាប្រទូស្តហៅភិក្ខុទាំងឡាយដោយវាទ:ថា អ្នកថោកទាបទេ ។ ព្រះតម្រាស់នោះមានសេចក្តីអធិប្បាយដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វច្ឆ:នេះមិនប្រាថ្នាប្រទូស្ត មានចិត្តគិតនឹងប្រទូស្ត៉ាយ មានចិត្តត្រូវទោស: ព្យាបាទប្រទូស្ត៉ាយ ហៅភិក្ខុទាំងឡាយដោយវាទ:ថា អ្នកថោកទាបទេ លោកដកព្យាបាទបានដោយមគ្គនុ៎ះឯង ។ កាលនឹងទ្រង់សម្តែងហេតុ ដែលសម្រេចមកពីជាតិមុននៃការហៅដូច្នោះរបស់លោក សូម្បីក្នុងកាលលោកមិនមានសេចក្តីប្រាថ្នាប្រទូស្តដោយប្រការយ៉ាងនេះ ទើបត្រាស់ថា **វច្ឆ ! ភិក្ខវេ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អញ្ញោកិណ្ណានិ** បានដល់ ការលាយឡំ គឺជាប់ជាលំដាប់ដោយលំដាប់នៃជាតិ មានខត្តិយជាតិជាដើម ។ បទថា **បញ្ចសតានិ ព្រាហ្មណកុលេ បច្ចាជាតានិ** សេចក្តីថា វច្ឆ:បានកើតក្នុងត្រកូលព្រាហ្មណ៍រហូត ៥០០ ជាតិ ។ បទថា **សោ តស្ស វសលវាទោ ឧីឃរត្តំ សមុជ្ជាចិណ្ណោ** សេចក្តីថា វាទ:អ្នកថោកទាបរបស់វច្ឆភិក្ខុនោះ ដែលលោកសូម្បីជាព្រះខីណាស្រព ក៏នៅតែប្រព្រឹត្តក្នុងកាលឥឡូវនេះ ជាវាទ:ដែលលោកសន្សំប្រព្រឹត្តមករហូតអស់កាលយូរ ព្រោះលោកកើតជាជាតិព្រាហ្មណ៍មានកាលប្រមាណ ៥០០ ជាតិ ដោយលើកឡើងខាងលើរាប់អំពីជាតិនេះទៅ ។ មែនពិត ព្រាហ្មណ៍ទាំងឡាយជាអ្នករឹងប៉ឹងដោយមាន: ដែលសម្រេចមកពី

ជាតិ ទើបស្រែកហៅអ្នកដទៃដោយវាទ:ថា អ្នកថោកទាប ។ អាចារ្យពួកខ្លះ ពោលថា **អជ្ឌាចិណ្ណោ** ដូច្នេះក៏មាន ។ សេចក្តីនេះក៏យ៉ាងនោះដូចគ្នា ។ បទថា **តេន** សេចក្តីថា ដោយការ:ដែលលោកធ្លាប់ប្រព្រឹត្តមកដូច្នោះអស់កាលយូរ ។ ដោយពាក្យនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា ជាហេតុ គឺជាវាសនារបស់ការស្រែកហៅដូច្នោះរបស់លោក ។ ក៏ឈ្មោះថា វាសនានេះ គឺអ្វី? អាចារ្យពួកខ្លះពោលថា គឺ **អនិមុត្តិ** ប្រដូចត្រឹមតែថាសេចក្តីអាចដែលកិលេសគឺលោកចម្រើនមករហូតអស់កាលខាងដើមមិនបានជាប់នៅ ជាហេតុនៃការប្រព្រឹត្ត ដូចការប្រព្រឹត្តរបស់អ្នកនូវកិលេសមិនទាន់លះក្នុងសន្តាន សូម្បីរបស់លោកអ្នកវៀរចាកកិលេសបានហើយ ។ ក៏ពោលអំពីការលះកិលេសជាគ្រឿងត្រដាងការពាររាវាំងនូវញ្ញេយ្យធម៌ដោយអកិនិហារសម្បត្តិ ហេតុនៃសេចក្តីប្រព្រឹត្តនេះ នោះមិនមានក្នុងសន្តានរបស់ព្រះដ៏មានព្រះភាគទេ ។ ក៏ការលះកិលេសបានហើយ តែនៅមានក្នុងសន្តានរបស់ព្រះសាវក និងព្រះបច្ចេកពុទ្ធដែលលះកិលេសយ៉ាងនោះមិនបាន ព្រោះព្រះតថាគតប៉ុណ្ណោះទ្រង់ឃើញអនាវរណញ្ញាណ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបអត្ថនេះ ពោលគឺសេចក្តីមិនមានការប្រាថ្នាប្រទូស្ត ក្នុងកាលព្រះបិលិន្ទវច្ឆ:ដ៏មានអាយុ សូម្បីនឹងហៅអ្នកដទៃថា អ្នកថោកទាប ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺនូវឧទាននេះ ដែលប្រកាសការសម្រេចព្រះអរហត្តផលរបស់ព្រះថេរ: ។

បណ្តាបទទាំងនោះ បទថា **យម្ហិ ន មាយា វត្តតិ ន មានো** សេចក្តីថា

មាយា មានលក្ខណៈបិទបាំងទោសដែលមាននៅ និងមានះមានលក្ខណៈប៉ោងឡើងដែលប្រព្រឹត្តទៅដោយការលើកតម្កើង ដោយន័យមានជាអាទិ៍ថា យើងជាអ្នកប្រសើរដូច្នេះ រមែងមិននៅក្នុងព្រះអរិយបុគ្គលណា គឺមិនប្រព្រឹត្តទៅ មិនកើតឡើង ព្រោះលោកដកបានហើយដោយមគ្គចិត្ត ។ បទថា **យោ វីណលោភោ អមមោ និរាសោ** *សេចក្តីថា ក៏បុគ្គលណា ឈ្មោះថា ប្រាស-ចាកលោភៈ ព្រោះប្រាសចាកលោភៈ ដែលមានលក្ខណៈតោងអារម្មណ៍ដោយប្រការទាំងពួង ដែលប្រព្រឹត្តទៅដោយអំណាចនៃបរិយាយនៃកិលេស មានរាគៈជាដើម ឈ្មោះថា មិនប្រកាន់ថាជារបស់យើង គឺមិនហួងហែង ព្រោះមិនមានការប្រកាន់ក្នុងអារម្មណ៍ មានរូបជាដើម យ៉ាងណាមួយថាជារបស់យើងនុ៎ះឯង ឈ្មោះថា មិនមានសេចក្តីប្រាថ្នា ព្រោះមិនប្រាថ្នាភពជាដើម សូម្បីជាអនាគត ។ បទថា* **បនុណ្ណកោធោ** *សេចក្តីថា ឈ្មោះថា បន្ទោបង់សេចក្តីក្រោធបានហើយ គឺដកអាឃាតបានហើយ ព្រោះលះសេចក្តីក្រោធដែលមានលក្ខណៈតូចចិត្តដោយប្រការទាំងពួង ដោយអនាគាមិមគ្គ ។ បទថា* **អភិនិព្វុ-តត្តោ** *សេចក្តីថា បុគ្គលណា ឈ្មោះថា មានចិត្តត្រជាក់ គឺត្រជាក់ ដោយការរលត់កិលេសដោយប្រការទាំងពួង ព្រោះដកមាយា មានះ លោភៈ និងក្រោធបាន និងព្រោះលះដោយល្អនូវធម៌ដែលជាចំណែកសង្កិលេសទាំងពួងបានដាច់ខាត ដោយសេចក្តីដែលសង្កិលេសទាំងនោះ តាំងនៅក្នុងឋានៈតែមួយជាមួយគ្នានឹងមាយាជាដើមនោះ ។ បទថា* **សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ** *សេចក្តីថា បុគ្គលនោះ គឺអ្នកឃើញបែបនោះ ជាព្រះខីណាស្រព ឈ្មោះថា* **ព្រាហ្មណ៍** *ព្រោះជាអ្នកមានបាបបន្សាត់ចោលហើយដោយប្រការ*

ទាំងពួង អ្នកនោះឯងឈ្មោះថា **សមណៈ** ព្រោះជាអ្នកសូប់ចាកបាប និងជាអ្នកប្រព្រឹត្តស្មើ និងអ្នកនោះឯងឈ្មោះថា **ភិក្ខុ** ព្រោះជាអ្នកទម្លាយកិលេសដោយប្រការទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ រ្ចួ:ជាម្នកមានសភាពយ៉ាងនោះឯង គប្បីជាអ្នកប្រាថ្នាប្រទូស្តធ្វើកាយកម្មជាដើមណាៗ ឱ្យប្រព្រឹត្តទៅយ៉ាងណា ក៏លោករមែងស្រែកហៅដោយវាទ:ថា អ្នកថោកទាប ព្រោះលះវាសនាមិនបានតែម្យ៉ាងឯង ។

ឆដ្ឋ សុត្តវណ្ណា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៦

៧. មហាកស្សបសុត្តវណ្ណនា[1]

អដ្ឋកថា មហាកស្សបសូត្រ

មហាកស្សបសូត្រទី ៧ *មានវិនិច្ឆ័យដូចតទៅនេះ*

ក្នុងពាក្យថា **សត្តាហំ ឯកបល្លঙ្ខេន និសិន្នោ អញ្ញតរំ សមាធឿ សមាបជ្ជិត្វា** *នេះ លំដាប់ដំបូងកេចិអាចារ្យពោលទុកថា សមាធិដែលសម្បយុត្តដោយអរហត្តផល លោកប្រាថ្នាយកថា សមាធិយ៉ាងណាមួយ ក្នុងសូត្រនេះ ។ ក៏ព្រះមហាកស្សបដ៏មានអាយុនោះ ចូលសមាធិនោះច្រើន ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន និងអាចទប់ទល់នៅដល់ ៧ ថ្ងៃ ដោយផលសមាបត្តិ ។ ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្តាបនាលោកទុកក្នុងឋាន:ដែលស្មើនឹងព្រះអង្គ ក្នុងឧត្តរិមនុស្សធម្មផ្សេងដោយអនុបុព្វវិហារ ៩ និងអភិញ្ញា ៦ ជាដើម ដោយន័យមានជាអាទ៍ថា "ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដរាបណា ដ៏សូប់ស្ងាត់ចាកកាមទាំងឡាយ សូប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្ក: វិចារ: មានបីតិ និងសុខ:ដែលកើតអំពីសេចក្ដីស្ងាត់នោះ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សប: ប្រាថ្នាដរាបណា សូប់ស្ងាត់ចាកកាមទាំងឡាយ សូប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក: វិចារ: មានបីតិ និងសុខ: ដែលកើតអំពីសេចក្ដីស្ងាត់នោះ ដរាបនោះដែរ"[2] ។ ក៏ក្នុងទីនេះមិនគួរពោលថា*

១-ក្នុងអដ្ឋកថាច្បាប់ឆដ្ឋសង្គាយនា ព្រះសូត្រនេះមានឈ្មោះថា **សក្ខ្ខិធានសុត្តវណ្ណនា** *។*
២-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣២ ទំព័រ ១៦៩ ។

កាលបើយ៉ាងនោះ ព្រះថេរៈគប្បីធ្វើសូម្បីយមកប្បាដិហារិយ៍បាន ព្រោះលោកប្រាថ្នាយកឈានជាដើម ដែលទូទៅដល់ព្រះសាវកប៉ុណ្ណោះ ។

ចំណែកព្រះបូរាណចារ្យពោលទុកថា បទថា **អញ្ញតរំ សមាធឺ សមាបជ្ជិត្វា** *បានដល់ ចូលនិរោធសមាបត្តិ ។ សួរថា តើនិរោធសមាបត្តិដូចម្តេច លោកទើបពោលថា* ***សមាធि***? *ឆ្វើយថា ព្រោះអត្ថថា តាំងមាំ ។ ក៏អត្ថថា ការតាំងមាំនេះគឺអ្វី? គឺព្រោះនិរោធសមាបត្តិជាគុណធម៌ គឺបុគ្គលតាំងមាំដោយប្រពៃ ។ មែនពិត និរោធសមាបត្តិនេះឯណា ជាគុណធម៌មិនញាប់ញ័រដោយធម៌ដែលជាសត្រូវ ជាគុណធម៌ដ៏មានកម្ទាំង ព្រោះភាពជាធម៌ដែលគប្បីតាំងមាំទុកដោយប្រពៃ គឺព្រះអរហន្តឬព្រះអនាគាមី អ្នកចាស់សេចក្តីស្ងាត់ជំនាញក្នុងឋានៈដែលពោលហើយប្រាថ្នានឹងនៅយ៉ាងនោះ គប្បីតាំងមាំការមិនប្រព្រឹត្តទៅ (គឺនិរោធសមាបត្តិ) ដោយប្រពៃតែម្តង នៃសេចក្តីបន្តនៃចិត្តនិងចេតសិករហូតដល់អស់វេលាតាមដែលប្រាថ្នាដោយការសម្រេចដោយពលៈ ២ គឺសមថពលៈ វិបស្សនាពលៈ ដោយញាណចរិយា ១៦ គឺញាណ ១៦ ទាំងនេះ គឺអនិច្ចានុ-បស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា និព្វិទានុបស្សនា វិរាគានុបស្សនា និរោធានុបស្សនា បដិនិស្សគ្គានុបស្សនា វិវដ្ដានុបស្សនា មគ្គញ្ញាណ ២ ផល-ញ្ញាណ ២ ដោយសមាធិចរិយា ៩ គឺដោយអំណាចសមាធិ ៩ បានដល់ សមាធិ ៨ មានបឋមជ្ឈានសមាធិជាដើម និងឧបចារសមាធិរបស់សមាធិ ៨ នោះ ដែល*

រួមចូលតែមួយ ដោយការសូប់រម្ងាប់សង្ខារ ៣ ទាំងនេះក្នុងធម៌នោះ។ គឺកាយ-សង្ខារ វចីសង្ខារ ចិត្តសង្ខារ ភាពដែលនិរោធសមាបត្តិនោះ គប្បីតាំងមាំយ៉ាងនោះ ឈ្មោះថា ជាការតាំងមាំក្នុងទីនេះ ព្រោះហេតុនេះ វិហារធម៌នេះ លោកទើបពោលថា ***សមាធិ*** *ព្រោះអត្ថថា មិនរវើរវាយ ។ ព្រោះហេតុនេះ សូម្បីអត្ថនៃការចូលនិរោធសមាធិនោះគប្បីជ្រាបថា លោកពោលទុកហើយ ។ មែនពិត ក្នុងបដិសម្ភិទាមគ្គ លោកសំដៅយកនិរោធសមាបត្តិនេះ សួរថា យ៉ាងណា ឈ្មោះថា ញាណក្នុងសញ្ញានិរោធសមាបត្តិព្រោះប្រកបដោយពល: ២ ព្រោះសូប់រម្ងាប់សង្ខារ ៣ ព្រោះញាណចរិយា ១៦ ព្រោះសមាធិចរិយា ៩ ព្រោះភាពជាអ្នកស្ទាត់ជំនាញ ដូច្នេះហើយ ទើបពោលថា បទថា* **ទ្វីហិ ពលេហិ** *បានដល់ ពល: ២ គឺសមថពល: វិបស្សនាពល: គប្បីជ្រាបសេចក្តីពិស្តារតទៅ កថាពោលអំពីនិរោសមាបត្តិនេះនោះ លោកពណ៌នាទុកហើយក្នុងវិសុទ្ធិមគ្គនោះឯង ។ ក៏ព្រោះហេតុណា ព្រះថេរ:នេះមិនចូលផលសមាបត្តិ បែរជាចូលនិរោធសមាបត្តិវិញ? ព្រោះនឹងអនុគ្រោះពួកសត្ត ។ មែនពិត ព្រះមហាថេរ:នេះ ប្រើសមាបត្តិបានសូម្បីទាំងអស់ តែដោយច្រើនលោកចូលនិរោធសមាបត្តិ ព្រោះអនុគ្រោះសត្ត ។ ព្រោះថា កាលលោកចូលនិរោធសមាបត្តិនោះហើយ ចេញ សក្ការ:សូម្បីមានប្រមាណតិចដែលគេបូជា រមែងមានផលច្រើន មានអានិសង្សច្រើនយ៉ាងពិសេស ។*

បទថា **រុដ្ធាសិ** បានដល់ ចេញដោយអរហត្តផលចិត្តកើតឡើង ។ មែនពិត អ្នកចូលនិរោធសមាបត្តិ បើជាព្រះអរហន្ត រមែងឈ្មោះថា ចេញដោយអរហត្តផលកើតឡើង បើជាព្រះអនាគামី រមែងឈ្មោះថា ចេញដោយអនាគាមិផលកើតឡើង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ក៏សម័យនោះឯង ស្តេចសក្ក: ជាស្តេចនៃទេវតាមានសេចក្តីប្រាថ្នានឹងថ្វាយបិណ្ឌបាតដល់ព្រះមហា-កស្សប:ដូចតទៅនេះ ។ យ៉ាងណា ស្តេចសក្ក:ទើបមានសេចក្តីប្រាថ្នានឹងថ្វាយដល់ព្រះថេរ:? ទេវតាដែលលោកពោលថា មានប្រមាណ ៥០០ នោះ ជាបរិចារិការបស់ស្តេចសក្កទេវរាជ នាងមានជើងដូចជើងសត្វព្រាប ធ្លាប់ត្រូវស្តេចសក្ក:បញ្ជូនទៅដោយពាក្យថា ព្រះមហាកស្សប:ជាលោកម្ចាស់របស់យើង ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ពួកនាងចូរទៅថ្វាយទានចំពោះព្រះថេរ: ទើបចូលទៅរកហើយឈរប្រាថ្នានឹងថ្វាយអាហារទិព្ធ ត្រូវព្រះថេរ:ហាម ទើបត្រឡប់ទៅកាន់ទេវលោកដូចដើម ។ ឥឡូវនេះ គិតដល់ការហាមគ្រាមុន ទើបគិតថា ព្រះថេរ:នឹងទទួលក្នុងកាល ពេលខ្ញុ:មានសេចក្តីប្រាថ្នានឹងថ្វាយទានដល់ព្រះថេរ:លោកចេញចាកសមាបត្តិ ទើបមិនក្រាបទូលឱ្យស្តេចសក្ក:ទ្រង់ជ្រាបខ្លួនឯង បង្ហោនកោជនដែលជាទិព្ធចូលទៅថ្វាយ ត្រូវព្រះថេរ:ហាមទុកដោយន័យមុនដូចគ្នា ទើបត្រឡប់ទៅទេវលោក ត្រូវស្តេចសក្ក:សួរថា ពួកនាងទៅណាមកណា ទើបក្រាបទូលសេចក្តីនោះ កាលស្តេចសក្ក:សួរថា ពួក

នាងថ្វាយបិណ្ឌបាតដល់ព្រះថេរៈហើយឬ ទើបទូលថា ព្រះថេរៈមិនប្រាថ្នានឹងទទួល ។ ស្តេចសក្ក:សួរថា ព្រះថេរៈមានថេរដីកាយ៉ាងណា ។ ទើបទូលថា បពិត្រទេវ: ព្រះថេរៈមានថេរដីកាថា នឹងសង្គ្រោះអ្នកក្រខ្សត់ ។ ស្តេចសក្ក:សួរថា ពួកនាងទៅដោយអាការយ៉ាងណា ។ ទើបទូលថា ទៅដោយអាការនេះឯង ព្រះអង្គ ។ ស្តេចសក្ក:ពោលថា អ្នកប្រាកដ ស្ទើដូចពួកនាង នឹងថ្វាយបិណ្ឌបាតចំពោះព្រះថេរៈបានយ៉ាងណា មានប្រាថ្នា នឹងថ្វាយដោយព្រះអង្គឯង ទើបថ្ងៃងខ្ជូនជាជាងតម្បាញជរា ធ្មេញបាក់ សក់ស្កូរ ខ្នងកោង សូម្បីនាងសុជាតា អ្នកជាអសុរធីតា ឱ្យមានសភាពដូចគ្នា ហើយនិមិត្តថ្នល់នៃអ្នកជាងតម្បាញខ្សែមួយ កំពុងរវៃអំបោះ នាងសុជាតាធ្វើ(អំបោះ)ឱ្យពេញបំពង់ ។ ព្រោះហេតុនោះ លោកទើបពោលថា **តេន ខោ បន សមយេន សក្ក្លោ ទេវានមិន្ទោ ។បេ។ តសរំ ឫវតិ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **តន្តំ វិនាតិ** *បានដល់ ស្តេចសក្ក:ក្ងែងធ្វើដូចជាតម្បាញសំពត់ ។ បទថា* **តសរំ ឫវតិ** *បានដល់ នាងសុជាតាក្ងែងធ្វើជារវៃអំបោះ ។ បទថា* **យេន សក្ក្លស្ស ទេវានមិន្ទស្ស និវេសនំ តេនុបសង្កមិ** *សេចក្តីថា ព្រះថេរៈស្ងៀកស្បង់ហើយកាន់បាត្រនិងចីវរ ដើរប្រាថ្នាមុខទៅកាន់នគរដោយបំណងថា នឹងសង្គ្រោះអ្នកក្រខ្សត់ ធ្វើដំណើរទៅតាមថ្នល់ជាងតម្បាញដែលស្តេចសក្ក:និមិត្តទុកក្រៅនគរ ត្រូតមើលនៅបានឃើញសាលាចាស់យោលទៅយោលមក និងស្វាមីភរិយាទាំងពីរ អ្នកមានរូបរាងដូចពោល*

ហើយ កំពុងត្បាញសំពត់នៅក្នុងសាលានោះ គ្រាឃើញហើយទើបគិតថា ពីរនាក់ប្តីប្រពន្ធនេះសូម្បីក្នុងវេលាចាស់ក៏នៅធ្វើការងារនៅក្នុងក្រុងនេះ នឹងមិនឃើញមានអ្នកដែលក្រខ្សត់ជាងពីរនាក់ប្តីប្រពន្ធនេះ យើងនឹងទទួលវត្ថុពីប្តីប្រពន្ធនេះសូម្បីឱ្យត្រឹមតែថា ជ្រក់បន្ទៃ សង្ក្រោះពីរនាក់ប្តីប្រពន្ធនេះ ។ ព្រះថេរៈមានមុខឆ្ពោះទៅកាន់ផ្ទះពីរនាក់ប្តីប្រពន្ធនោះ ។ ស្តេចសក្ក:ឃើញព្រះថេរៈកំពុងដើរមក ទើបត្រាស់ចំពោះនាងសុជាតាថា ន៏ៃនាង លោកម្ចាស់របស់យើងកំពុងមកទីនេះ នាងចូរស្ងៀមធ្វើដូចជាមិនឃើញលោក យើងនឹងបញ្ជោតក្នុងខណៈនេះហើយទើបថ្វាយបិណ្ឌបាត ។ ព្រះថេរៈបានទៅឈរក្បែរទ្វារផ្ទះ ។ ចំណែកពីរនាក់ប្តីប្រពន្ធនោះធ្វើជាមិនឃើញ ធ្វើការងាររបស់ខ្លួនតែម៉ាង ហើយរង់ចាំវេលាបន្ទិច ។ លំដាប់នោះស្តេចសក្ក:ត្រាស់ថា មើលដូចព្រះថេរៈមួយរូបឈរក្បែរទ្វារផ្ទះ នាងចូរទៅមើលសិនមើល៎ ។ នាងសុជាតាទូលថា បពិត្រស្វាមី សូមព្រះអង្គមេត្តាទៅពិចារណាមើលចុះ ។ ស្តេចសក្ក:ចេញពីផ្ទះទៅថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន យកដៃទាំងពីរច្រត់ជង្គង់ក្រោកឡើងសួរថា លោកម្ចាស់ ជាព្រះថេរៈអ្នកណាហ្ន៏ ទើបថយទៅបន្ទិចហើយពោលថា ក្ងៃករបស់ខ្ញុំព្រះករុណាស្រវាំងហើយ ទើបបាំងដៃលើថ្ងាស់ដើយមើលហើយត្រាស់ថា ឱ! ព្រះមហាកស្សបត្ថេរជាលោកម្ចាស់របស់យើង មកកាន់ទ្វារខ្ទមរបស់យើងយូរហើយ ក្នុងផ្ទះមានអ្វីខ្លះឬ ។ នាងសុជាតាធ្វើជា

ប្រញាប់ប្រញាល់បន្ទិច ហើយធ្វើយថា បពិត្រលោកប្តីមាន ។ ស្តេចសក្ក:ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកមិនគិតថា ភោជនសៅហ្មង ឬប្រណីតមេត្តាសង្គ្រោះញ្ជោមចុះ ដូច្នេះហើយទើបទទួលបាត្រ ។ ព្រះថេរ:កាលនឹងឱ្យបាត្រគិតថា យើងគួរសង្គ្រោះអ្នកក្រខ្សត់ជាជនចាស់ជរាទាំងនេះឯង ។ ស្តេចសក្ក:នោះចូលទៅខាងក្នុង ដួសបាយក្នុងឆ្នាំងដាក់ពេញបាត្រ ហើយដាក់ទុកក្នុងព្រះហស្តព្រះថេរ: ។ ព្រោះហេតុនេះ លោកទើបពោលថា សក្ក:ជាធំជាងពួកទេវតាបានឃើញព្រះមហាកស្សប:ដ៏មានអាយុហើយ ។ ល ។ បានថ្វាយហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃដិយា** ប្រែថា ចេញពីឆ្នាំងបាយ ។ បាលីថា **ឃដិឋិតំ** ដូច្នេះក៏មាន ។ អាចារ្យពួកខ្លះពោលអត្ថរបស់បាលីនោះថា ឈ្មោះថា បាយក្នុងឆ្នាំង បានដល់ អាហារពិសេសណានីមួយរបស់ពួកទេវ: ។ បទថា **ឧទ្ធរិត្វា** បានដល់ លើកឡើងពីភាជន:ណាៗ ។ អាហារនុ៎ះឯងមានសម្ងួតច្រើនមុខក្នុងវេលាដាក់ចុះក្នុងបាត្រ ហើយដាក់ក្នុងដៃព្រះថេរ:ប្រាកដដូចអាហារក្រខ្លក់ៗ ដែលសម្រេចដល់មនុស្សកំព្រា តែអាហារនោះត្រឹមតែដាក់ទុកក្នុងដៃបានតាំងនៅដោយភាវ:ដូចរបស់ទិព្វសម្រាប់ខ្លួន ។ បទថា **អនេកសូបោ** បានដល់ សម្ងួតច្រើនយ៉ាង មានសម្ងួសណ្តែកបាយ និងសម្ងួសណ្តែកពាជមាសជាដើម និងដោយរបស់ទំពាស៊ីជាច្រើនមុខ ។ បទថា **អនេកព្យញ្ជនោ**

បានដល់ សម្ងួរ្ប្រភេទផ្សេងៗ ។ បទថា **អនេកសូបព្យញ្ជនោ**[១] សេចក្ដីថា មានសូប:(សម្ងួទឹក) និងព្យញ្ជន:(ម្ហូបក្រៀម)រសដ៏ប្រសើរផ្សេងៗ ដែលប្រកាសដល់រសពីដើម មានទឹកផ្អែមជាដើម និងរសដែលលាយគ្នាដោយសូប: និងព្យញ្ជន:ច្រើនមុខ ។

បានឮថា បិណ្ឌបាតនោះ ក្នុងវេលាដាក់ទុកក្នុងដៃរបស់ព្រះថេរ: ផ្សាយក្ងិនទិព្វរបស់ខ្លួនទូទៅក្រុងរាជគ្រឹះ ។ លំដាប់នោះ ព្រះថេរ:គិតថា បុរសនេះមានសក្ដិតូច តែបិណ្ឌបាតរបស់គេប្រណីតក្រៃលែងណាស់ ដូចភោជនរបស់ស្ដេចសក្កទេវរាជ បុរសនោះជានរណាហ្ន៎ ។ លំដាប់នោះ ព្រះថេរ:ជ្រាបថា បុរសនោះស្ដេចសក្ក: ទើបពោលថា បពិត្រស្ដេចកោសិយ ប្រការដែលព្រះអង្គ ដណ្ដើមសម្ប្ដត្ដិរបស់អ្នកក្រខ្សត់ចាត់ថាធ្វើកម្មធ្ងន់ហើយ ថ្ងៃនេះអ្នកក្រខ្សត់ណានីមួយថ្វាយទានដល់អាត្មាហើយ គប្បីបានតំណែងជាសេនាបតី ឬតំណែងជាសេដ្ឋី ។ ស្ដេចសក្ក:ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន អ្នកណាដែលក្រខ្សត់ជាងខ្ញុំមានឬ លោកម្ចាស់ ។ ព្រះថេរ:ពោលថា ព្រះអង្គសោយសិរីរាជ-សម្ប្ដត្ដិក្នុងទេវលោក នឹងជាអ្នកក្រខ្សត់បានយ៉ាងណា ។ ស្ដេចសក្ក:ពោលថា ប្រការនោះឈ្មោះថា ជាយ៉ាងនោះ លោកម្ចាស់ ក៏ខ្ញុំព្រះករុណាបានធ្វើកម្ម

១-ក្នុងអដ្ឋកថាច្បាប់ធ្ងន់ សង្ហាយនាមានបាលីថា **អនេការសព្យញ្ជនោ** ។

ដែលល្អទុក ក្នុងកាលព្រះពុទ្ធមិនទាន់ឧប្បត្តិឡើង តែក្នុងពុទ្ធុប្បាទកាលនេះ ប្រព្រឹត្តទៅទេវបុត្រ ៣ អង្គនេះ គឺចូឡរថទេវបុត្រ មហារថទេវបុត្រ អនេក-វណ្ណទេវបុត្រ ធ្វើបុញ្ញកម្មហើយកើតក្នុងទីជិតនឹងខ្ញុំព្រះករុណា មានតេជៈច្រើនជាងខ្ញុំព្រះករុណា ។ កាលទេវបុត្រទាំងនោះគិតនិងលេងនក្ខត្តឬក្ស ទើបនាំនាងបម្រើចុះកាន់ចន្ទោះថ្នល់ ខ្ញុំព្រះករុណាទើបគេចជៀសចូលវិមាន ព្រោះតេជៈចេញពីសរីរៈរបស់ទេវបុត្រទាំងនោះ គ្របសង្កត់រាងរបស់ខ្ញុំព្រះករុណា តេជៈពេញពីរាងរបស់ខ្ញុំព្រះករុណា មិនបានគ្របសង្កត់រាងរបស់ទេវបុត្រទាំងនោះបានទេ អ្នកណានឹងជាអ្នកក្រខ្សត់ជាងខ្ញុំព្រះករុណាមែនទេ លោកម្ចាស់ ។ ព្រះថេរៈពោលថា សូម្បីកាលបើយ៉ាងនោះ តាំងពីនេះទៅ ព្រះអង្គកុំបញ្ជោតយ៉ាងនេះ ហើយថ្វាយទានដល់អាត្មាទៀត ។ ស្តេចសក្ក:ពោលថា កាលខ្ញុំបញ្ជោតហើយថ្វាយទានដល់លោកម្ចាស់ តើខ្ញុំព្រះករុណាមានកុសល ឬមិនមាន ព្រះថេរៈពោលថា មានលោកដ៏មានអាយុ ។ ស្តេចសក្ក:ពោលថា កាលបើដូច្នេះ ដែលឈ្មោះថា ការធ្វើកុសលជានាទីរបស់ខ្ញុំព្រះករុណា ដូច្នេះហើយ ទើបនមស្ការព្រះថេរៈ នាំនាងសុជាតាធ្វើប្រទក្សិណព្រះថេរៈហើយទៅកាន់ទេវលោកវិញ ហើយបន្ទឹមទានឡើង ៣ ដងថា ឱ ! ទានដែលអាត្មាអញបានដំកល់ទុកល្អហើយ ក្នុងព្រះមហាកស្សបៈ ហៅពេញជាទានឧត្តម ។ ព្រោះហេតុនេះ លោកទើបពោលថា **អថ ខោ អាយស្មតោ មហាកស្ស-បស្ស ឯតទហោសិ** ដូច្នេះ ។

ព្រះមហាកស្សបហៅស្តេចសក្ក:ចមទេវដោយគោត្រថា កោសិយ: ក្នុងព្រះបាលីនោះ ។ បទថា **ឃុញ្ញេន អត្តោ** ប្រែថា ត្រូវការដោយបុណ្យ ។ បទថា **អត្ថិ** ជាបាលីដែលនៅសល់ ។ បទថា **វេហាសំ អព្ភុគ្គន្ត្វា** សេចក្តីថា ហោះឡើងពីផែនដីទៅកាន់វេហា ។ អាចារ្យពួកខ្លះពោលថា បទថា **អាកាសេ អន្តតលិក្ខេ** ក្នុងអាកាសជាទីឃើញរូបក្នុងចន្ទោះ ដោយបរិយាយស័ព្ទក៏គឺអាកាស ។ ម្យ៉ាងទៀត លោកពោលទុកដោយពិសេសថា ក្នុងអាកាសពោលគឺទីជាទីឃើញរូបក្នុងចន្ទោះ មិនមែនក្នុងអាកាសដែលបើកកសិណជាដើម ។ ស័ព្ទថា **អហោ** ក្នុងបទថា **អហោ ឌានំ** នេះ ជានិបាតប្រើក្នុងអត្ថថា គួរអស្ចារ្យ ។ មែនពិត ស្តេចសក្ក:ចមទេវ: នឹកក្នុងព្រះហ្ឫទ័យគួរអស្ចារ្យថា ព្រោះហេតុដែលយើងធ្វើសេចក្តីកោតក្រែងដោយដៃរបស់ខ្លួន ដោយគោរពចំពោះព្រះមហាកស្សបត្ថេរ អ្នកចេញចាកនិរោធសមាបត្តិ ហើយធ្វើសម្មាទិដ្ឋិមិនឱ្យផ្ទាស់ប្តូរ មិនឱ្យប៉ះទង្គិចអ្នកដទៃដោយកាល ទើបថ្វាយទានដោយគោជនជាទិព្វដូច្នេះ ព្រោះដូច្នោះ យើងជាអ្នកប្រកបដោយសម្បត្តិ ៣ ប្រការ គឺខេត្ត-សម្បត្តិ ទេយ្យធម្មសម្បត្តិ និងចិត្តសម្បត្តិ ទើបបំពេញទានដែលប្រកបព្រមដោយអង្គទាំងពួងហ្នឹ ក្នុងគ្រានោះកាលនឹងបង្ហូរចេញនូវបីតិ និងសោមនស្សដែលនៅខាងក្នុងព្រះហ្ឫទ័យរបស់ព្រះអង្គ ទើបពោលថា **អហោ ឌានំ** ទានគួរអស្ចារ្យ កាលទ្រង់ប្រកាសថា ទាននោះជាទានខ្ពស់បំផុត និងថាជាខេត្តដោយ

ន័យដូចពោលហើយ ទើបទ្រង់បន្ទឹនូវឧទានថា **ឋមេ ជាតំ កស្សបេ សុបតិដ្ឋិតំ** *ដូច្នេះ ។*

ក៏កាលស្តេចសក្ក:ទ្រង់បន្ទឹនូវឧទានយ៉ាងនេះ ព្រះដ៏មានព្រះភាគ ប្រថាប់នៅក្នុងវិហារនុ៎ះឯង ទ្រង់ស្តាប់សំឡេងដោយទិព្វសោត ហើយត្រាស់ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញទេ ស្តេចសក្ក ចម-ទេវ: ទ្រង់បន្ទឹឧទានហើយហោះទៅកាន់អាកាស ដែលភិក្ខុទាំងនោះទូលសួរថា ក៏ស្តេចសក្ក:នោះទ្រង់ធ្វើអ្វីព្រះអង្គ ទើបត្រាស់ថា ស្តេចសក្ក:បញ្ជោតព្រះកស្សប: បុត្ររបស់តថាគតហើយថ្វាយទាន ព្រោះហេតុនោះឯង ស្តេចសក្ក:ពេញព្រះទ័យទើបទ្រង់បន្ទឹឧទាន ។ ព្រោះហេតុនេះ ទើបពោលពាក្យមានជាអាទ៍ថា ព្រះដ៏មានព្រះភាគបានទ្រង់ស្តាប់ហើយដោយទិព្វសោតធាតុ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥ ញ្ញាយ សោតធាតុយា** *សេចក្តីថា ឈ្មោះថា* **ទិព្ព** *ព្រោះដូចគ្នានឹងរបស់ទិព្ព ។ មែនពិត ទិព្ពបសាទសោតធាតុ ដែលកើតដោយសុចរិតកម្មរបស់ពួកទេវតា មិនពាក់ព័ន្ធដោយវត្ថុមិនស្អាត មានប្រមាត់ស្ងួស្ម និងឈាមជាដើម អាចទទួលអារម្មណ៍សូម្បីក្នុងទីឆ្ងាយបាន ព្រោះរួចផុតពីឧបកិលេស ។ សូម្បីសោតធាតុសម្រេចដោយញាណ ដែលកើតពីកម្ទាំងនៃសេចក្តីព្យាយាមភាវនារបស់ព្រះដ៏មានព្រះភាគនេះ ដូច្នោះដែរ ព្រោះហេតុនោះ ឈ្មោះថា* **ទិព្ព** *ព្រោះដូចជានឹងរបស់ទិព្ព ។ ម្យ៉ាងទៀត ឈ្មោះថា* **ទិព្ព** *ព្រោះបានដោយអំណាចទិព្ពវិហារធម៌ និងសូម្បីព្រោះខ្លួនឯងអាស្រ័យទិព្ពវិហារ*

ឈ្មោះថា **សោតធាតុ** ព្រោះអត្ថថា ស្តាប់ និងអត្ថថា ទ្រទ្រង់នូវតាមសការៈ ។ ឈ្មោះថា សោតធាតុដែលជាទិព្វនោះ ។ បទថា **វិសុទ្ធាយ** បានដល់ បរិសុទ្ធ គឺរួចផុតពីឧបកិលេស ។ បទថា **អតិក្កន្តមានុសិកាយ** សេចក្តីថា កន្ធង ឧបចារៈមនុស្ស ឈានកន្ធងមំសសោតធាតុរបស់មនុស្សដោយការស្តាប់សំឡេង ។

បទថា **ឯតមត្ថं វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបសេចក្តីនេះថា ទេពក្តី មនុស្សក្តី កើតសេចក្តីអើពើប្រព្រឹត្តស្រឡាញ់យ៉ាងក្រៃលែង នូវបុរសអ្នកល្អធ្វើមតម្រង់នៅក្នុងគុណវិសេសដោយសម្មាបដិបត្តិ ហើយទើបបន្ទឹនូវឧទាននេះដែលសម្តែងសេចក្តីនោះ ។

ក្នុងអត្ថនោះ ភិក្ខុអ្នកឈ្មោះថា **បិណ្ឌបាតិកៈ** ព្រោះសមាទានធុតង្គ ពោលគឺ អង្គរបស់ភិក្ខុអ្នកត្រាច់បិណ្ឌបាតជាវត្ត ហើយទើបបំពេញធុតង្គនោះ ។ សួរថា ព្រះគាថានេះ គឺព្រះដ៏មានព្រះភាគត្រាស់ធ្វើព្រះមហាកស្សបៈដ៏មាន-អាយុឱ្យជាហេតុ ត្រាស់សម្តែងមិនមែនឬ និងព្រះថេរៈជាអ្នកប្រសើរជាងធុតវាទ ភិក្ខុទាំងអស់ ជាអ្នកទ្រទ្រង់ធុតង្គ ១៣ មិនមែនឬ ព្រោះហេតុអ្វី ព្រះថេរៈទើបត្រូវគេសរសើរដោយបិណ្ឌបាតិកធុតង្គតែមួយប៉ុណ្ណោះ? ឆ្លើយថា នេះជាការសម្តែងក្នុងអត្ថុប្បត្តិហេតុ ។ ម្យ៉ាងទៀត នេះត្រឹមតែជាទេសនា ។ ដោយពាក្យនេះគប្បីជ្រាបថា ត្រាស់ធុតង្គសូម្បីទាំងអស់ដល់ព្រះថេរៈនោះ ដោយលើកទេសនាឡើងជាប្រធាន ។ ម្យ៉ាងទៀត ដើម្បីប្រកាសខបដិបត្តិដែលល្អធ្វើមក្នុង

ព្រះថេរៈនោះ មិនធ្វើបិណ្ឌបាតិកវត្តទាំងអស់ឱ្យដាច់ ព្រោះលោកប្រាថ្នាតិចយ៉ាងក្រៃលែង និងអនុគ្រោះចំពោះត្រកូល ទើបពោលថា **បិណ្ឌាចាតិកស្ស** ដោយន័យដូចពោលហើយដោយគាថាមានជាអាទិ៍ថា **យថាបិ ភមរោ បុប្ផំ** ជាដូច្នេះ ។ ក៏បទថា **បិណ្ឌាចាតិកស្ស** នោះគប្បីឃើញថា ប្រើក្នុងអត្ថទុតិយាវិភត្តិ ។ បទថា **អត្តភរស្ស** សេចក្ដីថា អ្នកចិញ្ចឹមចំពោះខ្លួនប៉ុណ្ណោះដោយបច្ច័យ ៤ ដែលតិច មិនមានទោស និងបានងាយ ដែលលោកពោលទុកយ៉ាងនេះថា បច្ច័យទាំងនោះ តិចបានងាយ ដោយមិនមានទោស[1] ។ បទថា **អនញ្ញោ-សិនោ** សេចក្ដីថា ឈ្មោះថា មិនចិញ្ចឹមអ្នកដទៃ ព្រោះមិនមានសេចក្ដីខ្ជល់-ខ្ជាយដែលនិងចិញ្ចឹមអ្នកដទៃមានសិស្សជាដើម ដោយការសង្គ្រោះដោយអាមិស ។ ដោយទាំង ២ បទ ព្រះអង្គទ្រង់សម្ដែងការប្រព្រឹត្តស្រាលព្រមដោយភាពជាអ្នកចិញ្ចឹមងាយ និងភាពជាអ្នកសន្ដោសយ៉ាងក្រៃលែងរបស់ព្រះមហា-កស្សប: ព្រោះព្រះថេរៈត្រាច់ទៅដោយមានចីវរជាគ្រឿងរក្សាកាយ និងមានបិណ្ឌបាតជាគ្រឿងចិញ្ចឹមផ្ទៃ ។ ម្យ៉ាងទៀត បទថា **អត្តភរស្ស** សេចក្ដីថា ឈ្មោះថា ជាអ្នកចិញ្ចឹមខ្លួន ព្រោះចិញ្ចឹមខ្លួនតែមួយនេះប៉ុណ្ណោះ ពោលគឺអត្តភាព ដោយត្រូវការនឹងនិយាយថា ចិញ្ចឹមខ្លួន ពាក្យតែមួយមិនមែនចិញ្ចឹមអ្នកដទៃពីការងារនេះ ។ តអំពីនោះឯង ឈ្មោះថា មិនមែនចិញ្ចឹមអ្នកដទៃ ព្រោះមិនមានអ្នកដទៃដែលខ្លួននឹងគប្បីចិញ្ចឹម ។ ដែលកិក្ខុនោះអ្នកចិញ្ចឹមខ្លួន

---

[1]-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ១៣៥ ។

គឺមិនចិញ្ចឹមអ្នកដទៃ ។ ដោយទាំង ២ បទ ទ្រង់សម្តែងដល់សេចក្តីមិនប្រកាន់មាំ ព្រោះព្រះថេរៈជាព្រះខីណាស្រព ។ បទថា **ឧភ បិហាយន្តិ ។បេ។ សតីម-តោ** *សេចក្តីថា ទេវៈមានស្តេចសក្ក:ជាដើម រមែងញញឹម គឺរមែងប្រាថ្នាព្រះខីណាស្រពនោះ ឈ្មោះថា អ្នកចូលទៅស្ងប់ដោយបដិបស្សទ្ធិ ព្រោះស្ងប់សេចក្តីខ្ជល់ខ្ជាយ និងសេចក្តីក្តៅផ្សាដែលកើតតែកិលេសទាំងពួង ដោយសម្រេចអរហត្តផល ឈ្មោះថា អ្នកមានសតិព្រោះជាអ្នកមានសតិធ្វើរហូតអស់កាលជានិច្ច ដោយដល់សេចក្តីបរិបូណ៌ដោយសតិតអំពីនោះ ដល់លក្ខណៈភាពជាអ្នកតាំងមាំក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម គឺញ៉ាំងសេចក្តីពប់អានយ៉ាងច្រើនឱ្យកើតឡើង ទើបកើតសេចក្តីអើពើក្នុងគុណវិសេសរបស់លោក មានសីលជាដើម នឹងនិយាយទៅថ្វីដល់មនុស្ស ។*

សត្តមសុត្តវណ្ណនា

ចប់អដ្ឋកថាសូត្រទី ៧

៨. បិណ្ឌាចាតកសុត្តវណ្ណនា

អដ្ឋកថាបិណ្ឌាចាតកសូត្រ

បិណ្ឌបាតកសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **បច្ឆាភត្តំ** *សេចក្ដីថា សម្ដីវេលាខាងក្នុងថ្ងៃត្រង់របស់ភិក្ខុអ្នកកាន់ឯកាសនិកង្គធុតង្គនិងខលុបច្ឆាភត្តិកង្គធុតង្គ អ្នកធាន់អាហារព្រឹកហើយ ក៏ជាបច្ឆាភត្តដូចគ្នា ។ តែក្នុងទីនេះ ខាងក្រោយអំពីធាន់អាហារតាមប្រក្រតីនុ៎ះឯង គប្បីជ្រាបថាជាបច្ឆាភត្ត ។ បទថា* **បិណ្ឌាចាតបដិក្កន្តានំ** *សេចក្ដីថា អ្នកត្រឡប់អំពីបិណ្ឌបាត គឺស្វែងរកបិណ្ឌបាត ហើយត្រឡប់អំពីបិណ្ឌបាតនោះ ដោយធ្វើកត្តកិច្ចឱ្យសម្រេច ។ បទថា* **ការេ** *ក្នុងបទថា* **ការេមណ្ឌលមាឡេ** *ជាឈ្មោះរបស់ដើមថ្ងាន់ ។ បានឮមកថា ដើមថ្ងាន់នោះនៅខាងក្នុងចន្ទោះមណ្ឌបនឹងសាលព្រះគន្ធកុដិ ព្រោះហេតុនេះ សម្ដីព្រះគន្ធកុដិ លោកក៏ហៅថា* ***ការេ-កុដិកា*** *។ មណ្ឌបក្ដី សាលក្ដី លោកក៏ហៅថា* ***ការេមណ្ឌលមាឡ*** *ពោងមូលជិតដើមថ្ងាន់នោះ ។ ព្រោះហេតុនោះ ក្នុងពោងមូលពោលគឺ សាលសម្រាប់អង្គុយដែលគេសាងទុកមិនឆ្ងាយដើមថ្ងាន់នោះ ។ អាចារ្យពួកខ្លះពោលដល់ដំបូលដែលប្រក់ដោយស្មៅនិងស្លឹកឈើ ក្ងៀងមិនលិច លោកហៅថា* ***ពោងមូល*** *។ អាចារ្យមួយពួកទៀតពោលថា មណ្ឌបដែលប្រក់ដោយវល្ជ៏ មានអតិមុត្តកវល្ជ៏ជាដើម ឈ្មោះថា* ***ពោងមូល*** *។*

បទថា **កាលេន កាលំ** *បានដល់ ក្នុងចន្ទោះវេលាមួយៗ អធិប្បាយថា ក្នុងសម្ងាត់នោះ ។ បទថា* **មនាបិកេ** *ប្រែថា គួរចម្រើនចិត្ត អធិប្បាយថា បិយរូបដែលគួរប្រាថ្នា ។ ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ គប្បីកាន់យកដោយអំណាចបុគ្គល និងដោយអំណាចទ្វារ ។ មែនពិត ឥដ្ឋារម្មណ៍ជាវត្ថុគួរប្រាថ្នារបស់អ្នក*

ខ្ញុះ មិនគួរប្រាថ្នារបស់អ្នកខ្ញុះ អនិដ្ឋារម្មណ៍ជាវត្ថុគួរប្រាថ្នារបស់អ្នកខ្ញុះ មិនគួរប្រាថ្នារបស់អ្នកខ្ញុះ ។ ម្យ៉ាងទៀត គួរប្រាថ្នារបស់ទ្វារមួយ មិនគួរប្រាថ្នារបស់ទ្វារមួយ ។ តែក្នុងទីនេះគប្បីជ្រាបវិនិច្ឆ័យដោយអំណាចវិបាក ។ មែនពិត កុសលវិបាក គួរប្រាថ្នាដោយចំណែកតែមួយ អកុសលវិបាកមិនគួរប្រាថ្នាឡើយ ។ បទថា **ចក្ខុនា រូបេ បស្សិតុំ** សេចក្តីថា ភិក្ខុទៅកាន់ស្រុកដើម្បីបិណ្ឌបាត កាលពួកឧបាសកនិមន្តឱ្យចូលទៅកាន់ផ្ទះ នាំអាសនៈនិងពិតានជាដើមចូលទៅ ដើម្បីប្រយោជន៍ដល់សក្ការៈ និងការបូជាបានឃើញរូបដែលគួរត្រេកអរ ពោលគឺ រូបដែលរុងរឿងដោយភាពស្រស់ល្អផ្សេងៗ និងរូបដែលប្រកបដោយវិញ្ញាណយ៉ាងដទៃដែលគេជ្រលក់ហើយ ដោយវិញ្ញាណដែលប្រព្រឹត្តទៅតាមចក្ខុទ្វារ ។ បទថា **សន្ធេ** សេចក្តីថា ភិក្ខុចូលទៅកាន់ផ្ទះឥស្សរជន បានឮសំឡេងចម្រៀងនិងប្រគំ ដែលគេលេងក្ងេងដើម្បីឥស្សរជនទាំងនោះ ក៏ដូច្នោះដែរ ។ បទថា **ឥធ** សេចក្តីថា ដើម្បីហិតក្ងិន មានក្ងិនផ្កាឈើ និងក្ងិនធូបជាដើម ដែលគេទាំងនោះបង្ហោនចូលទៅដើម្បីបូជា និងសក្ការៈក៏ដូចគ្នា ។ បទថា **រសេ** សេចក្តីថា ដើម្បីភ្ជក់រសកំពូលលើសផ្សេងៗ ក្នុងការបរិភោគអាហារដែលគេទាំងនោះប្រគេន ។ បទថា **ផោដ្ឋព្ពេ** សេចក្តីថា ដើម្បីពាល់ត្រូវផោដ្ឋព្វារម្មណ៍ ជាសុខសម្ផស្ស ក្នុងកាលអង្គុយលើអាសនៈមានតម្លៃច្រើនដែលគេក្រាលទុក ។ ក៏ឯគ្រាទ្រង់សរសើរការបានឥដ្ឋារម្មណ៍ដែលប្រព្រឹត្តទៅផ្លូវទ្វារ ៥ ដូចពោលមកហើយនេះ ឥឡូវនេះ ដើម្បីសម្តែងការបានឥដ្ឋារម្មណ៍ដែលប្រព្រឹត្តទៅ

ផ្លូវមនោទ្វារ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **សក្កោ** ដូច្នេះ ។ ពាក្យនោះ មានអត្ថដូចពោលហើយក្នុងកាលមុននុ៎ះឯង ។

សួរថា ក៏ន័យនេះ សម្រាប់ភិក្ខុអ្នកមិនកាន់បិណ្ឌបាតជាវត្ត រមែងមិនបានឬ ? ឆ្លើយថា បាន ។ មែនពិត ក្នុងវេលាដែលភិក្ខុសូម្បីទាំងនោះ ចូលទៅកាន់ស្រុកដើម្បីនិមន្តកត្តនិងសលាកភត្តជាដើម ឧបាសកទាំងឡាយ អ្នកមានសម្បត្តិច្រើន រមែងធ្វើសក្ការៈនិងសម្មានៈដូច្នោះដែរ ។ តែប្រការនោះ មិនពិតប្រាកដឡើយ ។ ចំណែកភិក្ខុអ្នកត្រាច់បិណ្ឌបាតជាវត្ត ពិតប្រាកដក្នុងកាលនោះ ។ ភិក្ខុទាំងនោះ ឃើញគេកំពុងធ្វើការបូជានិងសក្ការៈក្នុងទីនោះ តាំងនៅក្នុងផ្លូវមិនជាទីរលាស់ចេញ (ពីទុក្ខ) ព្រោះធ្ងន់ក្នុងសក្ការៈ ទើបពោលយ៉ាងនោះដោយអំណាចអយោនិសោមនសិការ ។ ព្រោះហេតុនោះនុ៎ះឯង ទើបពោលពាក្យមានជាអាទិ៍ថា **ហន្ទាវុសោ មយំ បិណ្ឌចាតិកា ហោម** អាវុសោទាំងឡាយ ណ្ហើយចុះ ពួកយើងចូរជាអ្នកប្រព្រឹត្តបិណ្ឌបាតជាវត្ត ។

បណ្ដាបទទាំងនោះ ស័ព្ទថា **ហន្ទ** ជានិបាត ប្រើក្នុងអត្ថថា លះបង់ បទថា **លច្ឆាម** ប្រែថា នឹងបាន ។ បទថា **តេឩបសង្កមិ** សេចក្ដីថា ព្រះអង្គប្រថាប់គង់ក្នុងព្រះគន្ធកុដិមានក្លិនដ៏ក្រអូបនោះ ទ្រង់ស្ដាប់ការចរចាប្រាស្រ័យនោះរបស់ភិក្ខុទាំងនោះ ទើបស្ដេចចូលទៅកាន់រោងមូល ដោយបំណងថា ភិក្ខុទាំងនេះ បួសក្នុងព្រះសាសនារបស់ព្រះពុទ្ធប្រាកដដូចតថាគត សូម្បីនៅក្នុងវិហារតែមួយគ្នានឹងតថាគត ក៏នូវប្រើពាក្យដោយអយោនិសោមនសិការយ៉ាងនេះមិនប្រព្រឹត្តក្នុងការជុសខាត់ ណ្ហើយចុះ តថាគតនឹងឱ្យភិក្ខុទាំងនោះ

ចេញពីមណ្ឌលនោះ ហើយប្រកបទុកក្នុងវិហារធម៌ជាគ្រឿងដុសខាត់ ។ ពាក្យដ៏សេសមានន័យដូចពោលហើយក្នុងកាលមុននុ៎ះឯង ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបសេចក្តីនេះថា សូម្បីទេវតាទាំងឡាយ រមែងត្រេកអរចំពោះកិក្ខុអ្នកត្រាច់ទៅដើម្បីបិណ្ឌបាតជាវត្ត អ្នកមានសតិដើម្បីកម្ចាត់កិលេស ដើម្បីធ្វើតណ្ហាឱ្យស្ងួតហួតហែង ដោយធម៌ជាគ្រឿងដុសខាត គឺប្រាជ្ញាតិចនិងសន្តោស កើតសេចក្តីអើពើក្នុងការបដិបត្តិ ប្រព្រឹត្តស្រឡាញ់ចំពោះកិក្ខុអង្គនោះ មិនប្រព្រឹត្តស្រឡាញ់ដទៃអំពីនោះឡើយ ដូច្នេះហើយ ទើបទ្រង់បន្ទឹទ្ធូវឧទានេះ ដែលសម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **ធោ ចេ សទ្ធសិលោកនិសិ្ជ្ជតោ** សេចក្តីថា បើមិនចង់បានអាស្រ័យសេចក្តីសរសើរពោលគឺ សំឡេងដែលជនពួកដទៃលើកតម្កើងដោយន័យមានជាអាទិ៍ថា គួរអស្ចារ្យណាស់ហ្ន៎ លោកម្ចាស់អង្គនេះ ជាអ្នកប្រាជ្ញាតិច ជាអ្នកសន្តោស មានការប្រព្រឹត្តដុសខាត់យ៉ាងក្រៃលែង ។ អធិប្បាយថា ជាអ្នកមិនអាស្រ័យដោយតណ្ហា ។ ម្យ៉ាងទៀត ឈ្មោះថា សំឡេងបានដល់ ការឃោសនាសរសើរគុណចំពោះមុខ សរសើរ បានដល់ ការសរសើរក្រោយខ្នង ពោលគឺ ចំពោះមុខជនដទៃ ។ ពាក្យដ៏សេសមានន័យដូចដែលពោលទុកក្នុងសូត្រដែលជាលំដាប់នោះឯង ។

អដ្ឋម សុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៨

៩. **សិប្បសុត្តវណ្ណនា**

អដ្ឋកថាសិប្បសូត្រ

សិប្បសូត្រទី ៩ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **គោ ឧ ខោ អាវុសោ សិប្ប ជានាតិ** *សេចក្តីថា អាវុសោ កាលពួកយើងប្រជុំគ្នាក្នុងទីនេះ អ្នកណាហ្ន៎នឹងដឹងច្បាស់អាជីវៈយ៉ាងណាមួយដែលមានជីវិតជាហេតុ ដែលឈ្មោះថា* ***សិល្ប:*** *ព្រោះអត្ថថា ត្រូវសិក្សា ។ បទថា* **គោ ឆ សិប្ប សិក្ខិ** *សេចក្តីថា អ្នកណានឹងចូលទៅរកត្រកូលនៃសិប្បាចារ្យអស់កាលយូរ ហើយសិក្សានូវសិល្ប: សិក្សាសិល្ប: អ្វីៗ បណ្តាសិល្ប:ទូន្មានដំរីជាដើមដោយការរៀនសូត្រ និងដោយការអនុវត្តន៍ ។ បទថា* **ឆ តតរ សិប្ប សិប្ជ ជ អ ក្ត** *សេចក្តីថា សិល្ប:យ៉ាងណាមួយជាកំពូល គឺប្រសើរជាងសិល្ប:ទាំងពួងដោយការគ្រប់គ្រងផ្ទះ មានផលច្រើន និងសម្រេចបានមិនលំបាក អធិប្បាយថាបុគ្គលអាស្រ័យសិល្ប:ណាហើយ អាចរស់នៅបានងាយ ។ បទថា* **ត ត្ត ឆ ចេ** *សេចក្តីថា បណ្តាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះ ។ ភិក្ខុណាដែលចេញបួសអំពីត្រកូលនាយហត្ថាចារ្យ គឺភិក្ខុនោះ ។ បទថា* **ឯ ម ហ ំ ស** *សេចក្តីថា លោកទាំងនោះបានពោលយ៉ាងនោះ ។ សូម្បីក្នុងទីនេះដែលលោកពោលទុកថា* **ឯ ឆ ចេ** *ក៏នំយនេះដូចគ្នា ។ បទថា* **ហ ត្ថ សិប្ប** *សេចក្តីថា សិល្ប:សូម្បីគ្រប់យ៉ាងផ្សេងដោយការចាប់ដំរី ការទូន្មាន ការបរ ការរក្សាពោគជាដើម ដែលចាំត្រូវធ្វើ លោកប្រាថ្នាយកថា សិល្ប:ក្នុងការទូន្មានដំរីក្នុងទីនេះ ។ សូម្បីក្នុង*

ពាក្យថា **អស្ស**សិប្បំ នេះ ក៏នយនេះដូចគ្នា ។ ចំណែកសិល្ប:ការដេញរថ គប្បីជ្រាបដោយវិធីហ្វឹកហាត់ និងដេញទៅជាដើមរបស់អ្នកដេញរថ និងដោយការប្រកបរថ ។ បទថា **ឆត្ត**សិប្បំ បានដល់ សិល្ប:របស់នាយខ្នាន់ធ្នូ ដែលហៅថា អ្នកស្ទាត់ជំនាញធ្នូ ។ បទថា **ថរុ**សិប្បំ បានដល់ សិល្ប:ខាងអាវុធដ៏ពិសេស ។ បទថា **មុទ្ធា**សិប្បំ បានដល់ សិល្ប:ក្នុងការរាប់ចុងម្រាមដៃ ។ បទថា **គណនា**សិប្បំ បានដល់ សិល្ប:ក្នុងការរាប់មិនជាច់រយ: ។ បទថា **សង្ខ**សិប្បំ បានដល់ សិល្ប:ក្នុងការរាប់ជាដុំដោយការបន្ថែម និងការលុបជាដើម ។ អ្នកដែលពោលរហ័សរហួនសិល្ប:នោះ ល្មមឃើញដើមឈើក៏ពាប់បានថា ដើមឈើនេះមានស្លឹកប៉ុណ្ណោះ ។ បទថា **លេខា**សិប្បំ បានដល់ សិល្ប:ក្នុងការសរសេរអក្សរដោយអាការផ្សេងៗ ឬសេចក្ដីដឹងក្នុងការសរសេរ ។ បទថា **កាវ**យ្យសិប្បំ សេចក្ដីថា សិល្ប:ការតែងកាព្យរបស់កវី ៤ ពួក មានចិន្តកវីជាដើម ដោយការគិតរបស់ខ្លួន ដោយការស្ដាប់ដែលបានអំពីអ្នកដទៃ ដោយប្រយោជន៍យ៉ាងនេះថា វត្ថុនេះមានប្រយោជន៍ យើងនឹងប្រកបវត្ថុនេះយ៉ាងនេះ ឬដោយការឃើញកាព្យអ្វីៗ ហើយកើតបដិភាណឡើងក្នុងឋាន: ថា យើងនឹងតែងកាព្យឱ្យដូចគ្នានឹងកាព្យនោះ ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញនេះមាន ៤ ពួក ។ អ្នកប្រាជ្ញ ៤ ពួក

តើដូចម្តេច ។ គឺអ្នកប្រាជ្ញព្រោះគិត ១ អ្នកប្រាជ្ញព្រោះស្តាប់ ១ អ្នកប្រាជ្ញព្រោះអាស្រ័យសេចក្តី ១ អ្នកប្រាជ្ញព្រោះប្រាជ្ញារាងវៃ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញមាន ៤ ពួកនេះឯង[1] ។ បទថា **លោកាយតសិប្បំ** *សេចក្តីថា សិល្ប:ក្នុងវិតណ្ឌសាស្ត្រ ដែលបដិសេធបរលោកនិងនិព្វានប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា ក្អែក-ស ព្រោះធ្ពើងស សត្វកុកក្រហម ព្រោះឈាមក្រហម ។ បទថា* **ឆត្តវិជ្ជាសិប្បំ** *សេចក្តីថា សិល្ប:ក្នុងនិតិសាស្ត្រមានការរក្សាកូរត្រជាដើម ។ បានឮថា សិល្ប:ទាំង ១២ នេះ ឈ្មោះថា មហាសិល្ប: ព្រោះហេតុនោះ ទើបពោលទុកក្នុងទីនោះ។ ថា* **សិប្បានំ អគ្គំ** *ដូច្នេះ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងដោយការមិនរលាស់ចេញចាកវដ្តទុក្ខ ដើម្បីប្រយោជន៍ដល់ការរស់នៅនៃសិប្បាយតន:ទាំងពួងនេះ តែក៏ទ្រង់ជ្រាបការមិនរលាស់ចេញ (ពីវដ្តទុក្ខ) នៃសេចក្តីបរិសុទ្ធមានសីលជាដើម និងភាពជាភិក្ខុអ្នកព្រមព្រៀងដោយសីលជាដើមនោះ ទើបទ្រង់បន្ទឹនូវឧទានេះដើម្បីប្រកាសនូវសេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **អសិប្បជីវី** *សេចក្តីថា ឈ្មោះថា* **អសិប្បជីវី** *ព្រោះអត្ថថា មិនទៅអាស្រ័យសិល្ប:ណានីមួយចិញ្ចឹមជីវិត ព្រោះសេចក្តីប្រាថ្នាក្នុងបច្ច័យសួតហួតហែងទៅ ដោយលះជាសមុច្ឆេទនូវតណ្ហាបាទាន ៤ ឱ្យ*

១-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ២៣ ទំព័រ ២២៧ ។

នៅឆ្ងាយ ។ ដោយពាក្យ **អសិប្បជីវី** *នេះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងដល់អាជីវបារិសុទ្ធិសីល ។ បទថា* **លហុ** *បានដល់ ការប្រព្រឹត្តស្រាល គឺមិនមានសម្ភារៈច្រើន ព្រោះមានកិច្ចតិចនិងមានការប្រព្រឹត្តស្រាលព្រម ។ ដោយពាក្យ* **លហុ** *នេះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងដល់ភាពជាអ្នកចិញ្ចឹមងាយ ដែលសម្រេចដោយការសន្តោសក្នុងបច្ច័យ ៤ ។ បទថា* **អត្ថកាមោ** *សេចក្ដីថា ឈ្មោះថា* **អត្ថកាមៈ** *ព្រោះអត្ថថា ប្រាថ្នា គឺប្រាថ្នាចំពោះប្រយោជន៍របស់លោកព្រមទេវលោកប៉ុណ្ណោះ ។ ដោយពាក្យ* **អត្ថកាមោ** *នេះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងដល់បាតិមោក្ខសំវរសីល ព្រោះប្រកាសដល់ការវៀរចាកវត្ថុ មិនមែនប្រយោជន៍ដល់សត្វទាំងឡាយ ព្រោះសម្ដែងដល់ការវៀរចាកសេចក្ដីវិនាស មានបាណាតិបាតជាដើម ។ បទថា* **យតិន្ទ្រិយោ** *សេចក្ដីថា ឈ្មោះថា មានឥន្ទ្រិយសង្រួមហើយ ព្រោះសង្រួមឥន្ទ្រិយ ៦ មានចក្ខុន្ទ្រិយជាដើម ដោយមិនឱ្យអកុសលធម៌ មានអភិជ្ឈាជាដើមកើតឡើង ។ ដោយពាក្យ* **យតិន្ទ្រិយោ** *នេះ ព្រះដ៏មានព្រះភាគត្រាស់ដល់ឥន្ទ្រិយសំវរសីល ។ បទថា* **សព្វធិ វិប្បមុត្តោ** *សេចក្ដីថា អ្នកមានសីលបរិសុទ្ធល្អយ៉ាងនេះ តាំងមាំនៅក្នុងសេចក្ដីសន្តោសដោយបច្ច័យ ៤ កំណត់នាមរូបព្រមទាំងបច្ច័យ ពិចារណាសង្ខារដោយលក្ខណៈមានអនិច្ចលក្ខណៈជាដើម ញ៉ាំងវិបស្សនាឱ្យកើតឡើង តពីនោះ ក៏ឈ្មោះថា*

ជាអ្នករួចផុតក្នុងធម៌ទាំងពួង គឺក្នុងកូមិទាំងពួងមានភពជាដើម ព្រោះលះសញ្ញោជនៈបានដោយអរិយមគ្គ ៤ ដែលប្រព្រឹត្តទៅតាមលំដាប់ ។

បទថា **អនោកសារី អមមោ និរាសោ** សេចក្តីថា ឈ្មោះថា **អនោកសារី** ព្រោះមិនមានសេចក្តីជ្រួតជ្រាបតណ្ហា ក្នុងអាយតនៈទាំង ៦ ពោលគឺ **ឱកៈ** (ទឹក) ព្រោះរួចផុតហើយក្នុងធម៌ទាំងពួងដូច្នោះ ឈ្មោះថា **អមមៈ** ព្រោះមិនមានមមង្ការក្នុងអារម្មណ៍ណានីមួយ មានរូបារម្មណ៍ជាដើម ឈ្មោះថា **និរាសៈ** ព្រោះមិនមានសេចក្តីប្រាថ្នាដោយប្រការទាំងពួង ។ បទថា **ហិត្វា មានំ ឯកចរោ ស ភិក្ខុ** សេចក្តីថា ក៏ភិក្ខុនោះមានសភាពយ៉ាងនោះ លះមានៈបានមិនឱ្យសេសសល់ ព្រមនឹងវេលាដែលសម្រេចអរហត្តមគ្គតែម្តង ទើបមិនច្របូកច្របល់ដោយពួកគណៈដូចភិក្ខុទាំងនេះ ជាអ្នកត្រាច់ទៅតែម្នាក់ឯង ក្នុងឥរិយាបថទាំងពួង ព្រោះប្រាថ្នាសេចក្តីស្ងាត់និងវៀរចាកមិត្ត គឺតណ្ហា បុគ្គលនោះឈ្មោះថា ភិក្ខុដោយបរមត្ថ ព្រោះទម្ងាយកិលេសដោយប្រការទាំងពួង ។ ក៏ក្នុងទីនេះត្រាស់ដល់គុណជាចំណែកលោកិយៈដោយន័យមានជាអាទិ៍ថា **អសិប្បជីវី** អ្នកមិនអាស្រ័យសិល្បៈហើយចិញ្ចឹមជីវិត ។ ដោយពាក្យមានជាអាទិ៍ថា **សព្វធិ វិប្ផមុត្តោ** ត្រាស់ដល់គុណជាចំណែកលោកុត្តរៈ ។ ក្នុងពាក្យនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា ធម៌នេះសម្រាប់អ្នកតាំងនៅក្នុងភាពជាអ្នកមិនអាស្រ័យសិល្បៈ ហើយចិញ្ចឹមជីវិតជាដើមប៉ុណ្ណោះ មិនមែនជារបស់

អ្នកអាស្រ័យសិល្ប: ហើយចិញ្ចឹមជីវិតដោយមិច្ឆាជីវ: ព្រោះដូច្នោះ ពួកលោកចូរវៀរចាកការកាន់ក្នុងសិល្ប:ថាជារបស់មានសារ: ហើយសិក្សាក្នុងអធិសីលជាដើមប៉ុណ្ណោះ។

ឧរម សុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៩

១០. លោកសុត្តវណ្ណនា

អដ្ឋកថាលោកសូត្រ

លោកសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

អាសយានុសយញ្ញាណ និងឥន្ទ្រិយបរោបរិយត្តញ្ញាណ ឈ្មោះថា ពុទ្ធចក្ខុក្នុងពាក្យថា **ពុទ្ធចក្ខុនា** *នេះ ។ សមដូចដែលលោកពោលពាក្យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ កាលតថាគត កំពុងរមិលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញនូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក (ខ្លះ) មានធូលីច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយក្លៀវក្លា (ខ្លះ) មានឥន្ទ្រិយទន់ (ខ្លះ)[១] ។ បទថា* **លោកំ** *បានដល់ លោក ៣ គឺឱកាសលោក ១ សង្ខារលោក ១ សត្វលោក ១ ។ បណ្តាលោកទាំង ៣ នោះ ឱកាសលោក ព្រះដ៏មានព្រះភាគ ត្រាស់ទុកក្នុងប្រយោគមានជាអាទិ៍ថា*

ព្រះចន្ទ្រនឹងព្រះអាទិត្យទាំងឡាយ ដើរបំភ្លឺទាំងឡាយឱ្យភ្លឺបានត្រឹមណា លោក គឺចក្កវាឡទាំងមួយពាន់ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅ បានតែត្រឹមចក្កវាឡមួយពាន់នុ៎ះ[២] ។

សង្ខារលោក ត្រាស់ទុកក្នុងប្រយោគមានជាអាទិ៍ថា លោក ១ បានដល់ ពួកសត្វទាំងអស់ដែលតាំងនៅបានដោយអាហារ លោក ២ បានដល់ នាម ១ រូប ១ លោក ៣ បានដល់វេលា ៣ លោក ៤ បានដល់អាហារ ៤ លោក ៥ បានដល់ ឧបាទានក្ខន្ធ ៥ លោក ៦ បានដល់អាយតនៈខាងក្នុង ៦ លោក ៧ បានដល់ទី

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក: លេខ ២១ ទំព័រ ១៤៩ ។

២-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក: លេខ ២២ ទំព័រ ៣៦៨ ។

តាំងនៃវិញ្ញាណ ៧ លោក ៨ បានដល់លោកធម៌ ៨ លោក ៩ បានដល់ទីនៅ
របស់សត្ត ៩ លោក ១០ បានដល់ អាយតនៈទាំង ១០ លោក ១២ បានដល់
អាយតនៈ ១២ លោក ១៨ បានដល់ ធាតុ ១៨[1] ។ សត្តលោក ព្រះដ៏មាន-
ព្រះភាគត្រាស់ទុកក្នុងប្រយោគមានជាអាទិ៍ថា លោកទៀង លោកមិនទៀង ។
សូម្បីក្នុងទីនេះ គប្បីជ្រាបសត្តលោក ។ បណ្តាលោកទាំងនោះ លោក ពោលគឺ
ចក្កវាឡ ឈ្មោះថា ឱកាសលោក ព្រោះអត្ថថា ឃើញ គឺប្រាកដដោយអាការ
វិចិត្រ ។ សង្ខារ ឈ្មោះថា លោក ព្រោះអត្ថថា វិនាស គឺផុយរលួយ ។ ឈ្មោះថា
សត្តលោក ព្រោះអត្ថថា ជាទីមើលបុណ្យ និងបាប និងផលនៃបុណ្យ និងបាប ។
ព្រះដ៏មានព្រះភាគ ទ្រង់អនុគ្រោះនូវសត្តទាំងនោះដោយព្រះមហាករុណាមាន
ប្រាជ្ញានឹងឱ្យសត្តទាំងនោះផុតពីសង្សារទុក្ខ ទើបរមិលមើលសត្តលោក ។
ក៏ព្រះអង្គទ្រង់រមិលមើលក្នុងសប្តាហ៍ទីប៉ុន្មាន? ក្នុងសប្តាហ៍ទី ១ ។ មែនពិត
ក្នុងទីបំផុតនៃបច្ឆិមយាម ក្នុងថ្ងៃបំផុតសប្តាហ៍ដែលទ្រង់ចូលសមាធិ ព្រះដ៏មាន
ព្រះភាគទ្រង់បន្ទឺឧទានដែលសម្តែងអានុភាពនៃអរិយមគ្គនេះថា កាលណាធម៌
ទាំងឡាយប្រាកដ ។ល។ ដូចព្រះអាទិត្យបំភ្លឺស្វាងស្ងែកណ្តាលអាកាសដូច្នេះ
ទើបប្រមើលសត្តលោកថា ជាដំបូង តថាគតប្រើទូក គឺធម៌នេះឆ្លងអន្ទង់ ទឹកធំ
គឺសង្សារដែលសែនឆ្ងាយ នឹងឆ្លងបានដោយលំបាកយ៉ាងនេះ ទើបឈរ
ត្រង់ត្រើយ គឺព្រះនិព្វាន ណ្តើយចុះ ឥឡូវនេះ តថាគតនឹងញ៉ាំងសត្តលោកឱ្យឆ្លង

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ២៧៥ ដល់ ២៧៦ ។

សត្វលោកមានយ៉ាងណាហ្ន៎ ដូច្នេះ ។ ពាក្យនេះដែលលោកសំដៅពោលទុកថា កាលកន្លង ៧ ថ្ងៃនោះទៅ ព្រះដ៏មានព្រះភាគ ស្តេចចេញចាកសមាធិនោះ ទ្រង់រមិលមើលសត្វលោកដោយពុទ្ធចក្ខុ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វោលោកេសិ** សេចក្ដីថា ទ្រង់ឃើញដោយអាការផ្សេងៗ គឺធ្វើឱ្យប្រចក្សដោយញាណរបស់ព្រះអង្គ ដូចផ្លែកន្ទួតព្រៃដែលដាក់លើបាតដៃ ។ បទមានជាអាទិ៍ថា **អនេកេហិ សន្តាបេហិ** ជាបទសម្ដែងអាការថៃរក្សា ។ បទថា **អនេកេហិ សន្តាបេហិ** បានដល់ ដោយសេចក្ដីទុក្ខជាអនេក ។ មែនពិត ទុក្ខលោកហៅថា **សន្តាបៈ** ព្រោះអត្ថថា ធ្វើឱ្យក្ដៅក្រហាយ ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា **ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ** ប្រែថា **ទុក្ខ** មានអត្ថថា បៀតបៀន មានអត្ថថា បច្ច័យប្រជុំតាក់តែង មានអត្ថថា ក្ដៅក្រហាយ មានអត្ថថា ប្រែប្រួល មានអត្ថថា ចាក់ធ្លុះចំពោះ[១] ។ ទុក្ខនោះ មានអត្ថច្រើនប្រការដោយអំណាចទុក្ខទុក្ខជាដើម និងដោយអំណាចជាតិជាដើម ។ ព្រោះហេតុនេះ លោកទើបពោលថា **អនេកេហិ សន្តាបេហិ** ។ អ្នកក្ដៅក្រហាយ គឺត្រូវទុក្ខជាអនេកគ្របសង្កត់ បៀតបៀន ។ បទថា **បរិឡាហេហិ** ប្រែថា ដោយសេចក្ដីក្ដៅផ្សា ។ បទថា **បរិឌយ្ហមានេ** បានដល់ អ្នកត្រូវភ្លើងឆេះជុំវិញដូចប្រេង ។ បទថា **រាគជេហិ** ប្រែថា កើតអំពីរាគៈ ។ សូម្បីក្នុងបទដ៏សេសក៏ន័យនេះ ។ មែនពិត កិលេសមានរាគៈជាដើម រមែងកើតក្នុងសន្ដានណា រមែងបៀតបៀន

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧១ ទំព័រ ៤៩ ។

សន្ធានៃ្ទ ដូចដុត ។ ព្រោះហេតុនេះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភ្លើងនេះ មាន ៣ យ៉ាង ។ ភ្លើង ៣ យ៉ាង តើដូចម្តេច ។ ភ្លើង គឺរាគ: ១ ភ្លើង គឺទោស: ១ ភ្លើង គឺមោហ: ១[1]។ ព្រោះភ្លើងទាំងនោះធ្វើចិត្ត និងកាយឱ្យសៅហ្មង ដូច្នោះ ទើបហៅថា **កិលេស** ។ ក៏ក្នុងបទទាំងនេះ ដោយបទថា **ឧរិ ឆ្ហ ឆ្ហ** នេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់កិលេសមានរាគ:ជាដើម ជាបវត្តិទុក្ខ និងសេចក្តីដែលសត្វត្រូវបវត្តិទុក្ខនោះគ្របសង្កត់ ។ ម្យ៉ាងទៀត ដោយបទថា **ឆ្ហ ឆ្ហ** នេះ ទ្រង់សម្តែងដល់សេចក្តីដែលសត្វទាំងនោះ ជាទុក្ខគ្រប់រយៈកាល និងសេចក្តីជាអ្នកមានអន្តរាយមិនដាច់រយៈ ព្រោះទុក្ខនោះ ។

មែនពិត ព្រះដ៏មានព្រះភាគប្រថាប់គង់លើអបរជិតបល្ល័ঙ្ক ត្រង់គល់ពោធិព្រឹក្ষ ក្នុងបឋមយាមទ្រង់រឭកដល់បុព្វនិវាសញ្ញាណ ក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុ ក្នុងបច្ឆិមយាម ទ្រង់បង្ហើនញាណចុះក្នុងបដិច្ចសមុប្បាទ ទ្រង់ដឹងក្រៃលែងវដ្តទុក្ខដែលមានកិលេសជាមូល ទ្រង់ពិចារណាកំណត់សង្ខារ ចម្រើនវិបស្សនាដោយលំដាប់ ទ្រង់កម្ចាត់កិលេសឱ្យប្រាសចាកទៅ ត្រាស់ដឹងក្រៃលែងដោយព្រះអង្គឯង ដោយការសម្រេចព្រះអរិយមគ្គ ព្រោះទ្រង់លះកិលេសមិនឱ្យសេសសល់ក្នុងលំដាប់បច្ចវេក្ខណញ្ញាណ ហើយទើបទ្រង់បន្ទឹនូវឧទានថា **អនេកជាតិសំសារំ** ដូច្នេះជាដើម ដែលសម្តែងដល់ភាពដែលព្រះអង្គអស់

---

[1]-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ១២២ ។

វដ្តទុក្ខ ជាឧទានដែលព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់មិនលះ ប្រថាប់គង់ចម្រើនសមាធិ សោយវិមុត្តិសុខរហូតដល់អស់ ៧ ថ្ងៃ ក្នុងយាម ៣ នៃរាត្រីទី ៧ ទ្រង់បន្ទឺឧទាន ៣ យ៉ាង ដោយន័យដូចពោលហើយ ក្នុងលំដាប់នៃឧទានទី ៣ ទ្រង់រមិលមើលលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញថា វដ្តទុក្ខរបស់សត្វទាំងអស់នេះ មានកិលេសជាមូល ដែលឈ្មោះថា កិលេសទាំងនេះជាបវត្តិទុក្ខ (ទុក្ខក្នុងបច្ចុប្បន្ន) និងជាហេតុនៃទុក្ខសម្បីតទៅ ព្រោះដូច្នោះ សត្វទាំងនេះ ទើបក្តៅក្រហាយ ខ្វាចផ្សា ព្រោះកិលេសទាំងនោះ ។ ព្រោះហេតុនេះ លោកទើបពោលថា **អទ្ធសា ខោ ភគវា ។ បេ ។ មោហាដេហិបិ** *ដូច្នេះ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់សេចក្តីដែលសត្វលោកត្រូវសេចក្តីក្តៅខ្វាចផ្សា ដូចពោលហើយគ្របសង្កត់នៅ ។ បទថា* **ឧទានំ ឧទានេសិ** *សេចក្តីថា ទ្រង់បន្ទឺនូវមហាឧទាននេះ ដែលប្រកាសដល់សេចក្តីរលត់ សេចក្តីក្តៅខ្វាចផ្សាទាំងពួង ។*

បណ្តាបទទាំងនោះ បទថា **អយំ លោកោ សន្តាបជាតោ** *សេចក្តីថា សត្វលោកនេះសូម្បីទាំងអស់កើតសេចក្តីក្តៅក្រហាយ ព្រោះជរា ពោគ និងមរណៈ ព្រោះសេចក្តីវិនាសផ្សេងៗ និងព្រោះសេចក្តីរ៉ាវ៉ៃនៃកិលេស អធិប្បាយថា ត្រូវទុក្ខផ្លូវកាយនិងចិត្តដែលកើតឡើងហើយគ្របសង្កត់ ។ បទថា* **ផស្សបរេតោ** *សេចក្តីថា អ្នកត្រូវទុក្ខសម្ផស្សជាអនេកនុ៎ះឯងគ្របសង្កត់ គឺបៀតបៀន ។ ម្យ៉ាងទៀត បទថា* **ផស្សបរេតោ** *សេចក្តីថា អ្នកត្រូវផស្សៈទាំង ៦ ដែលជាបច្ច័យដល់ទុក្ខវេទនា ៣ ពោលគឺ សុខវេទនាជាដើមគ្របសង្កត់ គឺជាប់ជំពាក់នៅដោយ*

ការប្រព្រឹត្តទៅក្នុងអារម្មណ៍នោះៗ តាមទ្វារនោះៗ ។ បទថា **ពោកំ ១ឧតិ អត្តតោ** សេចក្តីថា សត្វលោកកាលមិនដឹងតាមសេចក្តីពិតដល់ពោគ ទុក្ខ ឬបញ្ចក្ខន្ធពោលគឺ វេទនាដែលកើតឡើងព្រោះផស្ស:ជាបច្ច័យរមែងថា អត្តា យើងបានទទួលសុខ ទទួលទុក្ខ ដោយអំណាចការកាន់ខុសដោយសម្គាល់ថា ជាយើង ។ អាចារ្យពួកខ្លះពោលថា **អត្តនោ** ដូច្នេះក៏មាន ។ ពាក្យនោះមានអធិប្បាយដូច្នេះថា សត្វលោកនេះនោះត្រូវទុក្ខធម៌យ៉ាងណាមួយគ្របសង្កត់ កាលមិនអាចអត់ទ្រាំទុក្ខបាន ព្រោះមិនបានចម្រើនអត្តា ទើបរវើរវាយទៅ ដោយន័យមានជាអាទិ៍ថា ១! ទុក្ខ ទុក្ខដូច្នេះ ចូរកុំមានសូម្បីដល់ខ្លួនរបស់យើង ទើបពោលដល់ពោគរបស់ខ្លួនតែម្យ៉ាង តែមិនបដិបត្តិដើម្បីលះពោគនោះ ។ ម្យ៉ាងទៀត សត្វលោកកាលមិនដឹងតាមសេចក្តីពិតដល់ទុក្ខតាមដែលពោលហើយនោះ ទើបពោលថា របស់ខ្លួន ដោយសេចក្តីសម្គាល់ថា របស់យើង គឺបន្ទឹនូវ ១ចាថា នេះរបស់យើង ដោយអំណាចតណ្ហា ការប្រកាន់ដោយអំណាចតណ្ហា ។

បទថា **យេន ១ហិ ១មញ្ញតិ** សេចក្តីថា សត្វលោកកាលពោលបញ្ចក្ខន្ធដែលជាតួពោគនេះ ដោយភាពជាខ្លួន ឬរបស់ខ្លួន ដោយអាការយ៉ាងនេះ ទើបសម្គាល់ដោយទិដ្ឋិ មាន:និងតណ្ហាដោយប្រការដែលជាហេតុមានរូបនិងវេទនាជាដើមណា ឬដោយប្រការមានភាពជារបស់ទៀងជាដើមណា ។ បទថា **តតោ តំ ហោតិ ១អ១ញ្ញ១ថា** សេចក្តីថា បញ្ចក្ខន្ធដែលជាវត្ថុនៃសេចក្តីសម្គាល់នោះ រមែងជាការសម្គាល់ ដោយប្រការដទៃពីអាការដែលខ្លួនកំណត់ទុកនោះ និង

ជាការប្រកាន់ថា ខ្លួនក្នុងវត្ថុដែលមិនមែនខ្លួន អធិប្បាយថា មិនធ្វើសេចក្តីអហង្ការ មមង្ការឱ្យសម្រេច ព្រោះមិនអាចឱ្យនៅក្នុងអំណាចបាន ។ ម្យ៉ាងទៀត បទថា **តតោ** សេចក្តីថា បញ្ចក្ខន្ធនោះដែលបុគ្គលសម្គាល់ថា ទៀងជាដើម រមែងជាដោយប្រការដទៃ គឺជាសភាវៈមិនទៀងជាដើមតែម្យ៉ាង ព្រោះភាវៈត្រឹមតែថា សេចក្តីសម្គាល់នោះ ។ ក៏សេចក្តីសម្គាល់មិនអាចធ្វើភាវៈឬលក្ខណៈឱ្យជាយ៉ាងដទៃបាន ។

បទថា **អញ្ញថាភាវី ភវសត្តោ** សេចក្តីថា សត្វលោកអ្នកជាប់ជំពាក់ក្នុងសេចក្តីចម្រើនក្នុងហិតសុខដែលមិនកើត សូម្បីនឹងគិតតាមសេចក្តីពេញចិត្ត ដោយការសម្គាល់ក៏មានភាពជាយ៉ាងដទៃ ពីសេចក្តីសម្គាល់នោះដោយការបដិបត្តិខុស មានការប្រែក្លាយទៅជាប្រយោជន៍ដទៃ មានតែវត្ថុដែលគ្មានប្រយោជន៍ និងជាទុក្ខ ប្រសព្វតែសេចក្តីចង្អៀតចង្អល់ ។ បទថា **ភវមេវាភិនន្ទតិ** សេចក្តីថា កាលបើយ៉ាងនោះ ក៏នូវរីករាយ គឺប្រាថ្នាភព គឺសេចក្តីចម្រើនដែលមិនមានដែលខ្លួនកំណត់ដោយសេចក្តីសម្គាល់ខុសនោះប៉ុណ្ណោះ ។ ម្យ៉ាងទៀត បទថា **អញ្ញថាភាវី** សេចក្តីថា មានសេចក្តីជាយ៉ាងដទៃដោយតួខ្លួនពីអាការដែលកំណត់ដោយសេចក្តីសម្គាល់ដោយន័យមានជាអាទិ៍ថា អត្តារបស់យើងទៀង តែជារបស់មិនទៀង មិនរឹងមាំ ។ បទថា **ភវសត្តោ** សេចក្តីថា សត្វលោកជាប់ជំពាក់ គឺប្រកាន់ខ្ជាប់ ព្រោះភវតណ្ហាក្នុងកាមភពជាដើម ។ បទថា **ភវមេវាភិ-នន្ទតិ** សេចក្តីថា ប្រកាន់ភពដែលមានសភាវៈមិនទៀងនុ៎ះឯងថាជារបស់ទៀង ហើយក្ងើតក្ងើន ដោយសេចក្តីសម្គាល់ដែលបង្ហោនទៅក្នុងភពនុ៎ះឯង

ដោយសេចក្តីត្រេកអរកពដោយអំណាចតណ្ហានិងទិដ្ឋិ គឺមិនទៀយណាយក្នុងកពនោះ ។ បទថា **យទភិនន្ទតិ តំ ភយំ** សេចក្តីថា កព គឺសេចក្តីចម្រើន ឬកពមានកាមជាដើម ដែលសត្វលោកក្ងើតក្ងើននោះ ឈ្មោះថា ជាភ័យ ព្រោះអត្ថថា គួរខ្លាចយ៉ាងក្រៃលែង ព្រោះជាហេតុកើតកព ព្រោះមានសភាវៈប្រែប្រួលមានមិនទៀងជាដើម និងព្រោះត្រូវសេចក្តីវិនាសច្រើនប្រការជាប់តាម ។ បទថា **យស្ស ភាយតិ** សេចក្តីថា ជរានិងមរណៈជាដើម ដែលជាហេតុឱ្យសត្វលោកភ័យខ្លាចនោះ ចាត់ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ និងព្រោះជាតួទុក្ខ ។ ម្យ៉ាងទៀត បទថា **យស្ស ភាយតិ** សេចក្តីថា សត្វលោក រមែងភ័យខ្លាចចំពោះការសេពណា ព្រោះសេចក្តីក្ងើតក្ងើនក្នុងកព ការសេព ពោលគឺ សេចក្តីជាប់សួន្ស (ខវេ្ជទទិដ្ឋិ) នោះ និងសេចក្តីភ័យខ្លាចអំពីការសេពនោះ ចាត់ថាជាទុក្ខ គឺមានសភាវៈជាទុក្ខតែម្តង ព្រោះជាទីតាំងនៃទុក្ខ និងព្រោះទុក្ខ គឺមានសភាវៈជាទុក្ខតែម្តង ព្រោះជាទីតាំងនៃទុក្ខ និងព្រោះទុក្ខ មានជាតិទុក្ខជាដើម មិនត្រឡប់ក្ងាយ (ជាយ៉ាងដទៃ) ។ ម្យ៉ាងទៀត បទថា **យស្ស ភាយតិ តំ ទុក្ខំ** សេចក្តីថា សេចក្តីភ័យខ្លាចដែលសត្វលោក អ្នកមិនដឹងការរលាស់ចេញនូវអនិច្ចលក្ខណៈជាដើម ដែលខ្លួនភ័យខ្លាចនោះ ជាទុក្ខ គឺនាំទុក្ខមកឱ្យខ្លួន ។

ព្រះដ៏មានព្រះភាគ ត្រាទ្រង់សម្តែងវដ្តៈដោយហេតុត្រឹមតែប៉ុណ្ណោះហើយ ឥឡូវនេះ ដើម្បីនឹងសម្តែងវិវដ្តៈ(និព្វាន) ទើបត្រាស់ថា ក៏បុគ្គលនៅប្រព្រឹត្តព្រហ្មចរិយៈនេះដើម្បីលះកព ។ បណ្តាបទទាំងនោះ បទថា **ភវិប្ផហានាយ**

បានដល់ ដើម្បីលះកាមកពជាដើម ។ ស័ព្ទថា **ទោ** *ប្រើក្នុងអត្ថអវធារណៈ:ហាមសេចក្ដីដទៃ ។ ស័ព្ទថា* **បន** *ជានិបាតប្រើក្នុងអត្ថបទបូរណៈ: ធ្វើឱ្យពេញបទ ។ បទថា* **ឥធ** *ជាបទពោលចំពោះទីជិត ។ បទថា* **ព្រហ្មចរិយំ** *បានដល់ មគ្គ-ព្រហ្មចរិយ: ។ បទថា* **វុស្សតិ** *ប្រែថា រមែងបំពេញ ។ លោកអធិប្បាយពាក្យនេះទុកថា មគ្គព្រហ្មចរិយ:ដែលប្រកបដោយអង្គ ៨ នេះ សង្គ្រោះដោយខន្ធ ៣ មានសីលខន្ធជាដើម គឺតថាគតប្រព្រឹត្តវត្ថុដែលធ្វើបានលំបាកយ៉ាងក្រៃលែង បំពេញបារមីមកអស់ ៤ អសង្ខ្យេយ្យ កម្រៃមួយសែនកប្ប ហើយជាន់ឈ្លីក្បាលមារទាំង ៣ ត្រង់គល់ដើមពោធិព្រឹក្សបានសម្រេចហើយ ទើបប្រព្រឹត្តបំពេញដើម្បីប្រយោជន៍ដល់ការលះបានមិនឱ្យសេសសល់ ដោយការលះហេតុកើតនៃកាមកពជាដើមដោយចំណែកតែមួយ ។*

ព្រះដ៏មានព្រះភាគ គ្រាទ្រង់សម្ដែងអរិយមគ្គដែលជាហេតុនាំសត្វចេញពីទុក្ខដោយពិតប្រាកដដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងដល់សេចក្ដីមិនមានមគ្គដទៃពីអរិយមគ្គនោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **យេ ហិ កេចិ** *ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា* **យេ** *ជាបទសម្ដែងខ្ចីសេចក្ដីមិនពិតប្រាកដ ។ ពាក្យថា* **ហិ** *ត្រឹមតែជានិបាត ។ បទថា* **កេចិ** *បានដល់ ពួកខ្ញុ: ។ សូម្បីដោយបទទាំងពីរ លោកកាន់យកអ្នកមានវាទ:យ៉ាងនោះដែលមានទិដ្ឋិជាគតិ ដោយមិនកំណត់យ៉ាងពិតប្រាកដ ។ បទថា* **សមណា** *បានដល់ ជាសមណ:ដោយហេតុត្រឹមតែការចូលទៅបួស មិនមែនដោយការសូប់ចាកបាបទេ ។ បទថា* **ព្រាហ្មណា** *បានដល់ ជាព្រាហ្មណ៍ដោយហេតុត្រឹម*

តែកំណើត មិនមែនជាអ្នកមានបាបបន្សាត់ចោលទេ ។ **ภ**-ស័ព្ទជាវិកប្បបត្ត: ។ បទថា **ภเวน ภาสฺสาวิปฺปโมกฺขมาหํสุ** សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះ ពោលសេចក្តីរួចផុតពីភពទាំងពួង គឺសេចក្តីបរិសុទ្ធពីសង្សារ ដោយកាមភព ឬ រូបភព ។ សួរថា ក៏សមណព្រាហ្មណ៍ពួកណាពោលយ៉ាងនេះ? ឆ្លើយថា ពួក ដែលពោលដល់និព្វានក្នុងបច្ចុប្បន្ន ។ ក៏បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកខ្លះពោលថា អត្តា ដែលជាប់ជំពាក់ដោយកាមគុណ ៥ យ៉ាងខ្ពស់ រមែង ដល់សេចក្តីរលត់ (និព្វាន) យ៉ាងក្រៃលែងក្នុងបច្ចុប្បន្ន ។ សមណព្រាហ្មណ៍ ពួកខ្លះពោលថា បណ្តាឈានចំណែករូបាវចរ អត្តា អ្នកជាប់ជំពាក់ដោយ បឋមជ្ឈាន ។ល។ សមណព្រាហ្មណ៍ពួកខ្លះពោលថា អត្តា អ្នកជាប់ជំពាក់ដោយ ចតុត្ថជ្ឈានរមែងដល់ព្រះនិព្វានយ៉ាងក្រៃលែងក្នុងបច្ចុប្បន្ន ។ សមដូចដែល ព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោក នេះជាសមណ: ឬព្រាហ្មណ៍មានពាក្យយ៉ាងនេះ មានសេចក្តីយល់ឃើញយ៉ាង នេះថា នែ៎អ្នកដ៏ចម្រើន កាលណាបើខ្លួននេះឆ្អែតស្កប់ស្កល់ឱ្យគេបម្រើដោយ កាមគុណ ៥[1] ។ សេចក្តីពិស្តារបណ្ឌិតគប្បីជ្រាបនៅក្នុងគម្ពីរនោះចុះ ។

តែកេចិអាចារ្យទាំងនោះពោលថា ព្រោះហេតុដែលការស្វែងរកកាមជា-ដើមដើម្បីខ្លួន នឹងមិនមានដល់អ្នកដែលព្រមដោយសុខជាដើម ដូចឈ្វីងដែល ឆ្អែតហើយព្រោះបឹតឈាមទុក ដែលមិនមានការក្តៅក្រហាយឈាម ក៏កាលមិន

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ៨៦ ដល់ ៨៧ ។

*មានការស្វែងរកកាម ភពក៏មិនមានដូចគ្នា ក៏ន័យនេះគួរ បានដល់ អ្នកតាំងនៅក្នុងភពណាៗ សេចក្ដីរួចផុតពីភពទាំងពួង រមែងមានបានដោយភពនោះៗ ដូច្នោះ ទើបត្រាស់ថា សមណព្រាហ្មណ៍ទាំងឡាយពោលថា ការរួចផុតពីភពដោយភពដូច្នេះ ។ ក៏សូម្បីអ្នកដែលមានលទ្ធិថា ជនពាលនិងបណ្ឌិតអន្ទោលទៅរហូតដល់អស់កាលប៉ុណ្ណោះ តាំងនៅក្នុងភពចុងបង្ស្ស នឹងរួចផុតពីសង្សារ ឈ្មោះថា ពោលការរួចផុតភពដោយភព ។ សមដូចដែលព្រះដ៏-មានព្រះភាគ្រាស់ទុកថា ជនពាលក្ដី ជនជាបណ្ឌិតក្ដី អន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងវដ្ដសំសារ) អស់កាលចំនួន ៨ លាន ចុល្លមហាកប្ប ហើយនឹងធ្វើនូវទីបំផុតនៃទុក្ខបាន[1] ដូច្នេះ ។ ម្យ៉ាងទៀត បទថា **ភវេ** បានដល់ ភវទិដ្ឋិ ។ សស្សតទិដ្ឋិ លោកហៅថា ភវទិដ្ឋិ ព្រោះប្រព្រឹត្តទៅដោយអត្ថថា កើតមាន គឺតាំងនៅជាប់តគ្នា ។ ក្នុងទីនេះ ភវទិដ្ឋិនុ៎ះឯង លោកហៅថា ភព ដូចក្នុងប្រយោគថា ភវតណ្ហា ដោយលុបបទខាងចុង ។ ក៏កាលពោលអំពីអំណាចទិដ្ឋិ សមណព្រាហ្មណ៍ពួកខ្លះ រមែងសម្គាល់ភពពិសេសប៉ុណ្ណោះ ដែលមានសភាវៈទៀងជាដើមថា ជាការរួចផុតពីភព ព្រោះមានការប្រព្រឹត្តទៅស្ងប់កិលេស និងព្រោះអាយុរស់នៅបានយូរ ដូចពាក្យព្រហ្មពោលទុកថា វត្ថុនេះទៀង វត្ថុនេះយឺនយូរ វត្ថុនេះមានការប្រព្រឹត្តទៅជាប់តគ្នា វត្ថុនេះមានសេចក្ដីមិនប្រែប្រួលជាធម្មតា ។ សមណព្រាហ្មណ៍ទាំងនោះនុ៎ះឯង អ្នកកាន់ខុសផ្ទុយគ្នាមានការឃើញក្នុងវត្ថុដែលមិនមែនជាគ្រឿងរលាស់ចេញថា ជាគ្រឿងរលាស់ចេញ (ពីទុក្ខ) សេចក្ដីរួចផុតពីភពនឹងមាន*

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ១៣៣ ។

មកអំពីណា ។ ព្រោះហេតុនេះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ថា តថាគត ពោលថា សមណព្រាហ្មណ៍ទាំងនោះទាំងអស់មិនរួចផុតពីកព ។

បទថា **វិភវេន** ប្រែថា ដោយការដាច់សូន្យ(ឧច្ឆេទទិដ្ឋិ) ។ បទថា **ភវស្ស ជិស្សរណមាហំសុ** សេចក្ដីថា សមណព្រាហ្មណ៍ទាំងនោះពោលការប្រាស-ចាកទៅ ការចេញទៅពីកពទាំងពួងថា សង្សារសុទ្ធិ (សេចក្ដីបរិសុទ្ធពីសង្សារ) ។ ព្រោះសមណព្រាហ្មណ៍នោះ កាលមិនដឹងវាទ:របស់អ្នកដែលពោលថា សេចក្ដីរួចផុតពិសេសពីកពដោយកព រមែងបដិញ្ញាការលាស់ចេញចាកទុក្ខ ដោយការកាត់ផ្ដាច់ពីកព ។ ម្យ៉ាងទៀត បទថា **វិភវេន** បានដល់ ឧច្ឆេទទិដ្ឋិ ។ ឧច្ឆេទទិដ្ឋិលោកពោលថា វិភវ: ប្រាសចាកកព ដោយន័យដូចពោលហើយ ព្រោះប្រព្រឹត្តទៅដោយអត្ថថា អត្តានិងលោកមិនមាន គឺវិនាសដាច់សូន្យ ។ មែនពិត សត្វទាំងឡាយ រមែងបង្ហោនទៅដោយឧច្ឆេទទិដ្ឋិ ហើយកើតក្នុងកពនោះ។ ដាច់សូន្យទៅ ។ ឧច្ឆេទទិដ្ឋិនោះឯង ជាសង្សារសុទ្ធិ ព្រោះហេតុនោះ សត្វទាំងនោះទើបឈ្មោះថា ឧច្ឆេទវាទ: មានវាទ:ថា ដាច់សូន្យ ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា លោកដ៏ចម្រើន ព្រោះអត្តានេះឯង ជាវត្ថុមានរូប អាស្រ័យមហាភូតរូប ៤ ។ល។ ចូលដល់នេវសញ្ញានាសញ្ញាយតន-ឌ្ឌានៅដ៏ចម្រើន ដោយហេតុត្រឹមតែប៉ុណ្ណោះ អត្តានេះជាវត្ថុដែលដាច់សូន្យដោយប្រពៃ[1] ។ ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគត្រាស់ទុកថា បពិត្រ

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ៨១ ដល់ ៨៥ ។

មហាវាជ ទានដែលបុគ្គលឱ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ។ល។ ជនពាលក្តី ជនជាបណ្ឌិតក្តី លុះបែកធ្លាយរាងកាយ ទៅរមែងដាច់សូន្យ បាត់ទៅ មិនកើតទៀត ខាងមុខអំពីសេចក្តីស្លាប់ឡើយ[1]។ សមណព្រាហ្មណ៍សូម្បីទាំងនោះអ្នកប្រកាន់ខុសផ្ទុយគ្នាយ៉ាងនេះ នឹងរលាស់ចេញចាកកពបានមកអំពីទីណា ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា តថាគតពោលថា សមណព្រាហ្មណ៍ទាំងអស់នោះមិនរលាស់ចេញចាកកពទៅបាន ។ មែនពិត សត្វលោកមិនទាន់បានដកកិលេសដែលនៅសល់ឱ្យអស់ដោយអរិយមគ្គភាវនា សូម្បីក្នុងកាលណាៗ ក៏មិនបានសេចក្តីរួចផុតដោយការរលាស់ចេញចាកកព ។ ពិតយ៉ាងនោះ សមណព្រាហ្មណ៍ទាំងនោះជាអ្នកធ្លាក់ទៅក្នុងចំណែកទីបំផុតទាំងពីរថា មាន ឬមិនមាន ព្រោះមិនទាន់ដឹងតាមសេចក្តីពិត ទើបរសាប់រសល់និងក្តៅក្រហាយ ព្រោះអំណាចតណ្ហានិងទិដ្ឋិ ព្រោះគេទាំងនោះមានទិដ្ឋិជាគតិ ឈ្លក់រវៃងសូម្បីក្នុងហេតុនៃការប្រព្រឹត្តទៅ (គឺ សមុយ:) ត្រូវគ្រឿងចង គឺតណ្ហាចងទុកត្រង់សសរ គឺទស្សន:ខុសគ្នា កប់ទុកត្រង់ផែនដី គឺសក្កាយទិដ្ឋិ រមែងមិនលះទីដែលចងបាន ដូចសុនខដែលចងទុកដោយគ្រឿងចង សមណព្រាហ្មណ៍ទាំងនោះនឹងមានការរួចផុតពីកពមកអំពីទីណា ។

ព្រះសាស្តាកាលទ្រង់សម្តែងថា សមណព្រាហ្មណ៍ពួកណា មិនជាប់ជំពាក់ក្នុងអន្តធម៌ទាំង ២ យ៉ាងនោះ ព្រោះមិនមោហ:ក្នុងបវត្តិជាដើម ដោយការធ្វើឱ្យជាក់ច្បាស់ក្នុងសច្ច:ទាំង ២ រមែងឡើងកាន់មជ្ឈិមបដិបទា សមណព្រាហ្មណ៍

១-សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ លេខ ១៤ ទំព័រ ១៣៥ ដល់ ១៣៧ ។

ទាំងនោះឯង នឹងការរួចផុត នឹងការរលាស់ចេញទៅពីភពបាន ទើបត្រាស់ថា **ឧបធិ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **ឧបធិ** បានដល់ **ឧបធិ** មានខន្ធជាដើម ។ ស័ព្ទថា **ហិ** ត្រឹមតែជានិបាត ។ បទថា **បដិច្ច** ប្រែថា អាស្រ័យ គឺធ្វើឱ្យជាទីអាស្រ័យ ។ បទថា **ទុក្ខំ** បានដល់ ទុក្ខ មានជាតិទុក្ខជាដើម ។ លោកពោលអធិប្បាយយ៉ាងណា? លោកពោលអធិប្បាយថា សត្វទាំងនេះមានទិដ្ឋិជាគតិ សម្គាល់ថារួចផុតក្នុងទីណា ពួកគេក៏បានប្រសព្ធនឹងឧបធិ គឺខន្ធកិលេស និងអភិសង្ខារក្នុងទីនោះ សត្វលោកនោះនឹងរលាស់ចេញចាកទុក្ខបានអំពីទីណា ។ ក៏ព្រោះអភិសង្ខារកើតមានក្នុងទីដែលកិលេសកើតមាន ការបន្ត នូវភពទើបមិនដាច់ ព្រោះដូច្នោះ វដ្ដទុក្ខ (របស់សត្វលោក) ទើបមិនរលត់ ។ ព្រោះហេតុនេះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ក៏ទុក្ខនេះ រមែងកើតមាន ព្រោះអាស្រ័យឧបធិ ។

ឥឡូវនេះ ដើម្បីសម្ដែងហេតុជាគ្រឿងរលាស់ទុក្ខដោយបរមត្ថ ទើបព្រះដ៏-មានព្រះភាគត្រាស់ថា ព្រោះឧបាទានទាំងពួងអស់ទៅ ទើបទុក្ខមិនកើត ។ បណ្ដាបទទាំងនោះ បទថា **សព្ពុចានានក្ខយា** សេចក្ដីថា ព្រោះលះបានដោយដាច់ខាតនូវឧបាទានទាំងអស់ ៤ យ៉ាងនេះ គឺកាមុបាទាន ទិដ្ឋុបាទាន សីលព្ធុតុបាទាន អត្ដវាទុបាទាន ដោយការសម្រេចអរិយមគ្គ ។ បណ្ដាឧបាទានទាំង ៤ នោះ ឧបាទាន ៣ ទាំងនេះ គឺទិដ្ឋុបាទាន សីលព្ធុតុបាទាន និងអត្ដវាទុ-បាទាន ដែលឱ្យអស់ទៅដោយសោតាបត្ដិមគ្គ គឺដល់ការមិនកើតឡើងជាធម្មតា ។ គប្បីជ្រាបថា កាមុបាទានដែលញ៉ាំងសត្វឱ្យទៅអបាយលះដោយមគ្គទី ១ លះ

កាមរាគៈដ៏គ្រោតគ្រាតដោយមគ្គទី ២ ។ កាមរាគៈ និងព្យាបាទយ៉ាងល្អិតល្អន់ ដោយមគ្គទី ៣ ។ លៈរូបរាគៈ អរូបរាគៈដោយមគ្គទី ៤ រួមសេចក្ដីថា កាមុ-បាទានត្រូវលះដោយមគ្គទាំង ៤ គឺដល់ការមិនកើតឡើងជាធម្មតា ។ បទថា **ឧត្ថ ឧក្ខ្ងស្ស សម្ភវោ** *សេចក្ដីថា ព្រោះឧបាទានអស់ទៅដោយប្រការទាំងពួងយ៉ាងនេះ គឺព្រោះពួកកិលេសទាំងអស់ដោយរួមនៅក្នុងឋានជាមួយគ្នា នឹងឧបាទាន នោះមិនកើតឡើង វដ្ដទុក្ខសូម្បីមានប្រមាណតិចក៏មិនកើត គឺមិនប្រាកដ ។*

ព្រះដ៏មានព្រះភាគគ្រាទ្រង់សម្ដែងបវត្ដិ គឺ(ទុក្ខសច្ចៈ និងនិវត្ដិ គឺនិរោធសច្ចៈ) ព្រមដោយហេតុដូចពណ៌នាមកដូច្នេះហើយ កាលនឹងទ្រង់សម្ដែងថា សត្ត លោកនេះ កាលមិនដឹងន័យនេះ ក៏ងើយក្បាលឡើងពីវដ្ដៈមិនបាន ទើបត្រាស់ ពាក្យមានជាអាទិ៍ថា **លោកមិមំ បស្ស** *។ បណ្ដាបទទាំងនោះ បទថា* **លោកមិមំ បស្ស** *សេចក្ដីថា ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់ដឹកនាំសត្ត ឱ្យ ពិចារណាមើល ទើបត្រាស់ចំពោះដោយព្រះអង្គឯងថា ចូរមើលលោកនេះ ព្រោះព្រះអង្គចូលដល់ការវិស័យ (របស់លោក) ដោយប្រចក្សដោយពុទ្ធចក្ខុ ។ បទថា* **ពុជ** *ប្រែថា ច្រើន ។ ម្យ៉ាងទៀត បទថា* **ពុជ** *ប្រែថា ជាពួកៗ ។ បទថា* **អវិជ្ជា ឧបេតា** *សេចក្ដីថា ត្រូវអវិជ្ជាដែលជាតួបិទបាំងសច្ចៈ ៤ គ្របសង្កត់ ដែលត្រាស់ទុកដោយន័យមានជាអាទិ៍ថា សេចក្ដីមិនដឹងក្នុងទុក្ខ ។ បទថា* **ភូតា** *ប្រែថា កើតហើយ គឺកើតហើយ ព្រោះកម្មនិងកិលេស ។ បទថា* **ភូតរតា** *សេចក្ដីថា ត្រេកអរក្រៃលែងដោយតណ្ហាក្នុងសត្ត ទាំងឡាយ គឺក្នុងសត្ដ ដទៃ ដោយសេចក្ដីសម្គាល់ថា បិតា មាតា បុត្ដនិងភរិយាជាដើម ឬក្នុងកូត គឺបញ្ចក្ខន្ធ*

ដោយកំណត់ថាជាស្ត្រី បុរសជាដើម ដោយការៈថា ទៀងជាដើម និងដោយការប្រកាន់ថា ខ្លួននិងមានក្នុងខ្លួន ដោយមិនទាន់ដឹងសការៈនៃបញ្ចក្ខន្ធថា មិនទៀងមិនល្អ ជាទុក្ខ នឹងជាអនត្តា ។ បទថា **ភវាអបរិមុត្តា** សេចក្ដីថា មិនរួចផុតពីភព ពីសង្សារ ដោយការប្រកាន់ដោយអំណាចតណ្ហា និងទិដ្ឋិដូចដែលពោលហើយ ។

ក៏ក្នុងបទទាំងនោះ ដោយបទថា **លោកមិមំ** នេះ លំដាប់ដំបូងកាលនឹងទ្រង់នាំពួកសត្វសូម្បីទាំងអស់ចូលជាក្រុមតែមួយគ្នា ដោយការៈស្មើគ្នាមុនទើបទ្រង់សម្ដែងស័ព្ទដោយមិនចំពោះដោយឯកវចនៈ ហើយទ្រង់ប្រកាសអានុភាពនៃពុទ្ធចក្ខុញាណរបស់ព្រះអង្គថា សត្វលោកនេះ នោះមានសេចក្ដីផ្សេងគ្នាជាច្រើនប្រភេទដោយភព កំណើត គតិ ឋិតិ និងសត្តាវាសជាដើម និងដោយពួកសត្វនោះៗ ជាដើម ក្នុងភពជាដើមសូម្បីនោះ តថាគតរមិលមើលហើយតែម្យ៉ាង ទើបធ្វើប្រភេទនៃពាក្យទៀត ហើយទ្រង់សម្ដែងស័ព្ទចំពោះពហុវចនៈ ដោយព្រះតម្រាស់មានជាអាទិ៍ថា សត្វជាច្រើនត្រូវអវិជ្ជាគ្របសង្កត់ ។ ក៏កាលធ្វើការអធិប្បាយមកនេះ ហើយធ្វើឱ្យជាទុតិយាវិភត្តិថា **លោកមិមំ** សូម្បីនិទ្ទេសដែលជាបឋមាវិភត្តិពហុវចនៈដោយព្រះបាលីថា **អវិជ្ជាយ បរេតា** ជាដើម ក៏ជាការមិនខុស ព្រោះមានពាក្យផ្សេងគ្នា ។ តែកាលពោលអំពីសេចក្ដីប្រាជ្ញាឱ្យជាពាក្យដែលតែមួយ អាចារ្យពួកខ្លះពោលថា ភ្ជួតដែលអវិជ្ជាគ្របសង្កត់ត្រេកអរក្នុងភ្ជួតមិនរួចផុតចាកភពបាន ។ តែបាលីចាស់ពោលអំពីភាពផ្សេងនៃ

រិកត្តិប៉ុណ្ណោះ ។

ឥឡូវនេះ កាលនឹងសម្តែងវិបស្សនាវិធីដែលជាគោចររបស់ព្រះពុទ្ធមិនជាវិស័យនៃតិរ្ថិយ ដែលជាឧបាយឱ្យផុតពីកពទាំងអស់ទើបត្រាស់ពាក្យមានជាអាទិ៍ថា **យេ ហិ កេចិ** *ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* **យេ ហិ កេចិ ភវា** *សេចក្តីថា ក៏កពពួកណាមួយដែលមានអាយុវែង ឬមានអាយុត្រឹមតែមួយខណៈ ដែលមានប្រភេទបែកផ្សេងគ្នាដោយចែកជាកាមកពជាដើម សញ្ញីកពជាដើម និងឯកពជាការកពជាដើម ដែលសន្ទនគ្នាថា មានសេចក្តីសប្បាយដែលផ្សេងគ្នាដោយសារ: និងវៀរចាកសេចក្តីសប្បាយ ។ បទថា* **សព្ពេ** *បានដល់ក្នុងទីទាំងពួងដោយវិភាគមានជាអាទិ៍ថា ខាងលើ ខាងក្រោម ខាងទទឹង ។ បទ-ថា* **សព្ពត្តតាយ** *បានដល់ ដោយការ:ទាំងពួង មានសួគ៌ អបាយ និងមនុស្សជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា* **សព្ពេ តេ** *ដូចតទៅនេះ ។*

កពទាំងអស់នោះមានរូប និងវេទនាជាដើមជាធម៌ ឈ្មោះថា មិនទៀង ព្រោះអត្តថា មានហើយត្រឡប់មិនមាន ។ ឈ្មោះថា ទុក្ខ ព្រោះការកើត និងរលត់ និងបៀតបៀន ។ ឈ្មោះថា មានសេចក្តីប្រែប្រួលទៅជាធម្មតា ព្រោះនឹងត្រូវប្រែប្រួលទៅដោយហេតុ ២ ប្រការ គឺជរា និងមរណៈ ។ ***ឥតិ***-*សព្ទ* *មានអាទិជាអត្ត ឬមានប្រការ:ជាអត្ត ។ គឺយ៉ាងណា? គឺដោយ* ***ឥតិ***-*សព្ទនោះ ព្រះអង្គទ្រង់សង្គ្រោះសូម្បីអនត្តលក្ខណៈហើយត្រាស់ថា ឈ្មោះថា* ***អនត្តា*** *ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ឬឈ្មោះថា អនត្តា ព្រោះអត្តថា មិនប្រព្រឹត្តទៅក្នុងអំណាច ហេតុមានការប្រែប្រួលទៅជាធម្មតា ។*

សត្វលោកពិចារណា ឃើញបញ្ចក្ខន្ធនេះពោលគឺ ភព តាមសេចក្តីពិត គឺមិនប្រែប្រួលដោយបញ្ញាដ៏ប្រពៃ គឺដោយញាណដ៏ប្រពៃ បានដល់ ដោយបញ្ញាដែលសម្បយុត្តដោយមគ្គដែលប្រកបដោយវិបស្សនា គឺចាក់ធ្ងុះដោយបរិញ្ញាកិ-សម័យជាដើម ទើបលះតណ្ហា ក្នុងភពដែលប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា ភពទៀងដោយប្រការដូច្នេះ គឺដោយអាការចាក់ធ្ងុះនូវលក្ខណៈ ៣ គឺរលត់បានមិនឱ្យសេសសល់ព្រមនឹងការសម្រេចអរហត្តមគ្គនុ៎ះឯង រមែងមិនរីករាយ គឺរមែងមិនប្រាថ្នា វិភវៈ គឺសេចក្តីកាត់ផ្តាច់ ព្រោះលះឧច្ឆេទទិដ្ឋិបានដោយប្រការទាំងពួង ។ ព្រោះការអស់ទៅ គឺព្រោះលះតណ្ហា ១០៨ ប្រភេទ មានកាមតណ្ហាជាដើម និងមានប្រភេទរកទីបំផុតមិនបានដោយវិភាគការកំណត់ជាដើមរបស់សត្វលោកអ្នករស់នៅយ៉ាងនោះ ដោយអាការទាំងពួង គឺដោយប្រការទាំងពួង ការរលត់ដោយមិនកើតឡើងនៃធម៌ដែលជាបក្ខពួកនៃសង្ខិលេសទាំងអស់ដែលរួមនៅក្នុងឋានតែមួយនឹងតណ្ហានោះ ដោយមិននៅសេសសល់ គឺដោយដាច់ខាត ដោយធម៌ជាគ្រឿងប្រាសចាក គឺដោយអរិយមគ្គនោះ គឺព្រះនិព្វាន ។

គ្រាទ្រង់សម្តែងសឧបាទិសេសនិព្វាន ដោយការលះតណ្ហាជាប្រធានដូចពណ៌នាមកដូច្នេះ ឥឡូវនេះ កាលទ្រង់សម្តែងអនុបាទិសេសនិព្វាន ទើបត្រាស់គាថាថា **តស្ស ឥធ្ឫតស្ស** ដូច្នេះជាដើម ។ ពាក្យដែលជាគាថានោះ មានអធិប្បាយដូច្នេះ ភិក្ខុជាព្រះខីណាស្រព អ្នកទម្ងាយកិលេសដោយន័យដូចពោល

ហើយ រលត់ដោយកិលេសបរិនិព្វាន ព្រោះអស់តណ្ហាដោយប្រការទាំងពួង មិនមានឧបាទាន គឺអស់ឧបាទាន ឬព្រោះមិនប្រកាន់មាំកិលេសមារ និងអភិសង្ខារ-មារ កពច្ចីទើបមិនមាន គឺមិនមានឧប្បត្តិកពដោយការបដិសន្ធិតទៅ ។ ភិក្ខុដែលមានសភាពយ៉ាងនោះ គ្របសង្កត់មារបាន គឺគ្របសង្កត់កិលេសមារ អភិសង្ខារ-មារ និងទេវបុត្តមារក្នុងខណៈអរិយមគ្គ គ្របសង្កត់ខន្ធមារ និងមច្ចុមារចេញបាន ក្នុងខណៈចរិមកចិត្ត រួមសេចក្ដីថា មារទាំង ៥ គឺភិក្ខុទាំងនោះគ្របសង្កត់ គឺឱ្យចាលចាញ់ បានដល់ ធ្វើឱ្យអស់អស្មិមានៈដោយការមិនឱ្យដើយក្បាលឡើងបានទៀត ព្រោះលោកឈ្នះសង្គ្រាមដែលមារឱ្យប្រព្រឹត្តទៅ ឈ្មោះថា អ្នករីងមាំ គឺជាព្រះអរហន្ត ព្រោះដល់លក្ខណៈរបស់អ្នករីងមាំ ព្រោះមិនមានវិការក្នុងអារម្មណ៍ទាំងពួង មានឥដ្ឋារម្មណ៍ជាដើម ឈ្មោះថា ឈានកន្ធង គឺឈានកន្ធងដោយល្អនូវកពទាំងពួង គឺកពសូម្បីទាំងអស់មានប្រភេទតាមដែលពោលហើយ មិនចាត់ចូលក្នុងទីណានីមួយ តាមពិត ជាអ្នករកបញ្ញត្តមិនបានខាងមុខតែបរិនិព្វានទៅដូចភ្លើងអស់គ្រឿងឆេះ ដូច្នោះ ។ ព្រះដ៏មានព្រះភាគទ្រង់កាន់យកកំពូលនៃអនុបាទិសេសនិព្វានធាតុ ទើបឱ្យមហាឧទានេះចប់ស្រេចដោយប្រការដូច្នេះ ។

ឧសម សុត្តវណ្ណា ឯដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១០

ឯដ្ឋិតា ច ឆក្ខាវគ្គវណ្ណា

ចប់ឆក្ខាវគ្គវណ្ណនាទី ៣

សម្រាប់ជាធម្មទាន

រួមព្រះសូត្រដែលមានក្នុងវគ្គនេះ គឺ

១-កម្មសូត្រ	២-ន្ធសូត្រ
៣-យសោជសូត្រ	៤-សារីបុត្តសូត្រ
៥-កោលិតសូត្រ	៦-បិលិន្ទវច្ឆសូត្រ
៧-មហាកស្សបសូត្រ	៨-បិណ្ឌបាតសូត្រ
៩-សិប្បសូត្រ	១០-លោកសូត្រ

៤. មេឃិយវគ្គោ

មេឃិយវគ្គទី ៤

១. មេឃិយសុត្តវណ្ណនា

អដ្ឋកថាមេឃិយសូត្រ

មេឃិសូត្រទី ១ *នៃមេឃិយវគ្គមានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ចាលិកាយំ** *បានដល់ ជិតក្រុងឈ្មោះយ៉ាងនេះ ។ បានឮថា ហួសពីទ្វារនគរនោះទៅមានកក់នៅជុំវិញ ។ ព្រោះអាស្រ័យកក់នោះហើយ ឋិតនៅនគរនោះ ទើបប្រាកដដល់អ្នកដែលក្រឡេកមើលដូចជាញ័រនៅ ព្រោះដូច្នោះ ក្រុងនោះគេទើបហៅថា* **ចាលិកា** *។ បទថា* **ចាលិកេ បព្ពតេ** *សេចក្តីថា ក្នុងទីមិនឆ្ងាយនគរនោះមានកូនភ្នំមួយ សូម្បីភ្នំនោះ ក៏ប្រាកដដល់អ្នកក្រឡេកមើលដូចជាញ័រ ក្នុងថ្ងៃឧបោសថខាងខ្នើត ព្រោះភ្នំនោះស-សុទ្ធ ព្រោះដូច្នោះ ភ្នំនោះទើបរាប់ថា* **ចាលិកបព្ពត** *។ ជនទាំងឡាយនាំគ្នាសាងវិហារធំ ក្នុងទីនោះ ថ្វាយចំពោះព្រះដ៏មានព្រះភាគ ។ ក្នុងកាលនោះ ព្រះដ៏មានព្រះភាគ បានទ្រង់ធ្វើនគរនោះឱ្យជាគោចរគ្រាម ប្រថាប់នៅត្រង់មហាវិហារជិត ចាលិកបព្ពតនោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ប្រថាប់នៅ ក្នុងចាលិកបព្ពតជិតក្រុងចាលិកា ។*

បទថា **មេឃិយោ** *ជាឈ្មោះរបស់ព្រះថេរៈនោះ ។ បទថា* **ឧបដ្ឋាកោ ហោតិ** *បានដល់ ជាអ្នកបម្រើ ។ មែនពិត ក្នុងបឋមពោធិកាល ព្រះដ៏មាន-ព្រះភាគមិនមានឧបដ្ឋាកប្រចាំ ពេលខ្លះមានព្រះនាគសមាលៈ ពេលខ្លះព្រះនាគិតៈ ពេលខ្លះព្រះឧបវានៈ ពេលខ្លះព្រះសុនក្ខត្តៈ ពេលខ្លះព្រះចុន្ទសមណុ-*

ទ្ធេសៈ ពេលខ្ទះព្រះសាគតៈ ពេលខ្ទះព្រះមេឃិយៈ ។ សូម្បីក្នុងកាលនោះ ព្រះមេឃិយថេរៈនុ៎ះឯងជាឧបដ្ឋាក ។ ព្រោះហេតុនោះ លោកទើបពោលថា ក៏សម័យនោះឯង ព្រះមេឃិយត្ថេរដ៏មានអាយុ ជាឧបដ្ឋាកព្រះដ៏មានព្រះភាគ ។

បទថា **ជន្តុ** គាមំ បានដល់ វិហារនោះឯង បានមានគោចរគ្រាមដទៃដែលមានឈ្មោះយ៉ាងនោះ ។ បាលីថា **ជត្តុ**គាមំ ដូច្នេះក៏មាន ។ បទថា **កិមិ-**ការ**ណ្ឌ**ាយ បានដល់ ទន្ទេដែលមានឈ្មោះថា **កិមិ**ការ**ណ្ឌ**ា ព្រោះមានសត្វល្អិតពណ៌ខ្មៅច្រើន ។ បទថា **ជ**ង្ឆ**ារ**ិ**ហ**ារ**ំ** សេចក្ដីថា ត្រាច់ទៅដើម្បីបន្ទោបង់ភាពទ្រៀយណាយ ដែលកើតត្រង់ជើង ព្រោះអង្គុយយូរ ។ បទថា **ចាសានិ**ក**ំ** សេចក្ដីថា ឈ្មោះថា គួរជ្រះថ្លា ព្រោះនាំសេចក្ដីជ្រះថ្លាមកដល់អ្នកឃើញ ព្រោះមានដើមឈើមិនធ្ងាយ និងមានស្លឹកជិតស្និទ្ធ ។ ឈ្មោះថា គួរជាទីគាប់ចិត្ត ព្រោះមាន ម្ងប់ត្រឈឹងត្រឈៃ និងព្រោះមានភូមិភាគគួរជាទីគាប់ចិត្ត ។ ឈ្មោះថា គួររីករាយ ព្រោះធ្វើចិត្តឱ្យរីករាយ ដោយអត្ថថា ធ្វើអ្នកចូលទៅខាងក្នុងឱ្យកើតបីតិសោមនស្ស ។ បទថា **អ**ល**ំ** ប្រែថា អាច ។ ប្រែថា គួរក៏បាន ។ បទថា **ប**ធ**ានត្ថ**ិ**ក**ស្ស បានដល់ អ្នកត្រូវការដោយសេចក្ដីព្យាយាម ។ បទថា **ប**ធ-**ាន**យ បានដល់ ដោយការធ្វើសមណធម៌ ។ បទថា **អ**ាត**ច្ឆ**យ្យ**ាហ**ំ កាត់បទថា **អ**ាត**ច្ឆ**យ្យ**ុ** និង **អ**ហ**ំ** ។ បានឮថា កាលមុន ទីនោះជាព្រះរាជឧទ្យានដែលព្រះថេរៈធ្លាប់ជាព្រះរាជាគ្រប់គ្រងមក ៥០០ ជាតិតាមលំដាប់ ព្រោះហេតុនោះ ចិត្តរបស់ព្រះថេរៈនោះទើបបង្ហោនទៅដើម្បីនឹងនៅក្នុងទីនោះ ត្រឹមតែបានឃើញប៉ុណ្ណោះ ។

បទថា **អាកមេហិ តាវ** *សេចក្ដីថា ព្រះសាស្ដាកាលទ្រង់ស្ដាប់ពាក្យ*
របស់ព្រះថេរៈហើយ កាលទ្រង់ពិចារណា ទើបទ្រង់ជ្រាបថា ញាណរបស់លោក
មិនទាន់ដល់សេចក្ដីចាស់ក្លានៅឡើយ ទើបត្រាស់ហាមយ៉ាងនោះ ។ ក៏ព្រះដ៏មាន-
ព្រះភាគ ដើម្បីនឹងញ៉ាំងព្រះថេរៈឱ្យកើតចិត្តទន់ភ្ន់ឡើងទើបត្រាស់ថា កាលបើ
ដូច្នេះ ព្រះថេរៈ ភិក្ខុអង្គនេះសូម្បីទៅហើយ កាលកម្មមិនទាន់សម្រេច ជាអ្នក
មិនសង្ស័យ នឹងត្រឡប់មកដោយអំណាចសេចក្ដីស្រឡាញ់ ទើបត្រាស់ពាក្យ
នេះថា **ឯកកម្ហិ តាវ** *។ បទថា* **យាវ អញ្ញោបិ កោចិ ភិក្ខុ អាគច្ឆតិ**
សេចក្ដីថា លោកចូររង់ចាំរហូតដល់ភិក្ខុអង្គណា នឹងមកកាន់សំណាក់របស់
តថាគត ។ បាលីថា **កោចិ ភិក្ខុ ឧិស្សតិ** *ភិក្ខុណាៗ នឹងប្រាកដដូច្នេះក៏មាន ។*
អាចារ្យពួកខ្លះពោលថា **អាគច្ឆតុ** *។ ពួកខ្លះពោល* **ឧិស្សតុ** *ដូចគ្នា ។*

បទថា **ឧត្ដិ ភិញ្ជ ឧត្ដរឺ ការណីយំ** *សេចក្ដីថា ព្រោះព្រះអង្គធ្វើកិច្ច*
១៦ យ៉ាង មានបរិញ្ញាកិច្ចជាដើម ក្នុងសច្ចៈ៤ ដោយមគ្គ ៤ ឬព្រោះទ្រង់សម្រេច
អភិសម្ពោធិញ្ញាណ ឈ្មោះថា ករណីយកិច្ចដទៃដែលក្រៃលែងជាងនោះមិនមាន ។
បទថា **ឧត្ដិ ភតស្ស ភ បដិចយោ** *សេចក្ដីថា ឬកិច្ចដែលទ្រង់ធ្វើសម្រេចហើយ*
ក៏មិនត្រូវសន្សំតទៅ ។ មែនពិត មគ្គដែលត្រូវចម្រើន ក៏មិនត្រូវចម្រើន កិលេស
ដែលលះបានហើយ ក៏មិនមានកិច្ចដទៃដើម្បីលះទៀតដែរ ។ បទថា **អត្ដិ ភត-**
ស្ស បដិចយោ *សេចក្ដីថា ព្រោះខ្ញុំព្រះអង្គមិនទាន់សម្រេចអរិយមគ្គ ខ្ញុំព្រះអង្គ*
ទើបចាំបាច់ត្រូវតែសន្សំ ពោលគឺ ចម្រើនឡើងដើម្បីធម៌ មានសីលជាដើម
ដែលសម្រេចក្នុងសន្ដានរបស់ខ្ញុំព្រះអង្គ ។ បទថា **បជានន្ដិ ខោ មេឃិយ**
វនមានំ ភិន្ដ្ជ រនេយ្យាម *សេចក្ដីថា តថាគតនឹងពោលឈ្មោះអ្វីដទៃនឹងលោក*

អ្នកពោលថា នឹងធ្វើសមណធម៌ ។

បទថា **ឥភវិហារំ ឥសីឥ** សេចក្តីថា ព្រះថេរៈអង្គុយសម្រាកក្នុងពេលថ្ងៃ ។ ក៏ព្រះថេរៈគង់ ក៏គង់លើផ្ទាំងថ្មមង្គល ក្នុងកាលមុន ព្រះថេរៈធ្លាប់ជាព្រះរាជា ៥០០ ជាតិតាមលំដាប់ ទ្រង់លេងកីឡាក្នុងព្រះរាជឧទ្យាន គង់ហែហមដោយអ្នករបាំផ្សេងៗ ។ តាំងពីពេលដែលព្រះថេរៈគង់កាលណា ដូចជាភាពជាសមណៈបាត់ទៅ មានភេទដូចជាព្រះរាជា ហែហមដោយបរិវារជាអ្នករបាំប្រថាប់លើបល្ល័ង្កដែលមានតម្លៃច្រើន ខាងក្រោមស្វេតឆ័ត្រ ។ កាលដែលព្រះថេរៈត្រេកអរនឹងសម្បត្តិនោះ កាមវិតក្កៈក៏កើតឡើង ។ ខណៈនោះឯង ព្រះថេរៈហាក់ដូចជាបានឃើញចោរ ២ នាក់ ត្រូវចាប់ខ្លួនព្រមដោយរបស់ទ្រព្យដែលគេនាំមកត្រង់ទីចំពោះមុខ ។ បណ្តាចោរ ២ នាក់នោះ ចោរម្នាក់ញ៉ាំងព្យាបាទវិតក្កៈឱ្យកើតឡើងដោយអំណាចការបង្ក្រាប់ឱ្យសម្ងាប់ ចោរម្នាក់ទៀតញ៉ាំងវិហិង្សាវិតក្កៈឱ្យកើតឡើងដោយអំណាចការបង្ក្រាប់ឱ្យឃុំឃាំង ។ កាលបើដូច្នោះ ព្រះថេរៈបានជាអ្នកហែហម ពាសពេញដោយអកុសលវិតក្ក: ដូចដើមឈើត្រូវឡោមព័ទ្ធដោយវល្លិ៍ និងដូចសំបុកឃ្មុំដែលចោមរោមដោយឃ្មុំដូច្នោះ ។ លោកសំដៅយកអាការនោះ ទើបពោលថា **អថ ខោ អាយស្មតោ មេឃិយស្ស** ជ្រូច្នេះជាដើម ។

បានឮថា ពាក្យថា **អច្ឆរិយំ វត ភោ** នេះ ឈ្មោះថា អស្ចារ្យក្នុងការតិះដៀល ដូចព្រះអានន្ទឃើញព្រះដ៏មានព្រះភាគមានព្រះកាយប្រែប្រួលទៅព្រោះស្នាមជ្រួញ ទើបបានទូលថា គួរអស្ចារ្យណាស់ព្រះអង្គ រឿងមិនធ្លាប់មាន

ទេព្រះអង្គ ។ តែអាចារ្យមួយពួកទៀតពោលថា សម័យនោះ កាមវិតក្ក:រមែងកើតឡើងដល់ព្រះថេរ: ដោយអំណាចលោភ:ក្នុងផ្លាឈើ ផ្ទៃឈើ និងស្ទឹកខ្ចីជាដើម ព្យាបាទវិតក្ក:កើតឡើង ព្រោះបានស្តាប់សំឡេងសត្វជាដើម ដែលស្រែកសំឡេងគគ្រាត វិហិង្សាវិតក្ក:កើតឡើង ព្រោះប្រាថ្នាប្រហារសត្វទាំងនោះ ដោយដុំដីជាដើម កាមវិតក្ក:កើតឡើង ព្រោះបំណងក្នុងទីនោះថា យើងនឹងនៅទីនេះឯង ព្យាបាទវិតក្ក:កើតឡើង ព្រោះបានឃើញព្រានព្រៃទាំងឡាយក្នុងទីនោះ។ ហើយមានចិត្តប្រាថ្នាប្រទូស្តក្នុងព្រានព្រៃទាំងនោះ វិហិង្សាវិតក្ក:រមែងកើតឡើង ព្រោះប្រាថ្នានឹងបៀតបៀនព្រានព្រៃទាំងនោះ ដូច្នេះក៏មាន ។ ការដែលមិច្ឆាវិតក្ក:កើតឡើងដល់ព្រះថេរ:យ៉ាងណាមួយនុ៎ះឯង ជាហេតុគួរអស្ចារ្យ ។ បទថា **អជ្ឌាសត្តា** ប្រែថា គ្របសង្កត់ គឺជាប់តាម ។ ការនិយាយច្រើនសូម្បីក្នុងសេចក្តីជាអ្នកតែមួយ ក៏ប្រាកដទាំងក្នុងខ្លួន និងក្នុងគ្រូ ។ បាលីថា **អជ្ឌាសត្តោ**[1] ដូច្នេះក៏មាន ។

បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា ព្រះថេរ:ពាសពេញទៅដោយមិច្ឆាវិតក្ក:យ៉ាងនេះ កាលមិនអាចធ្វើកម្មដ្ឋានឱ្យសប្បាយ ទើបកំណត់ថា ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ឃើញកាលវែង បានឃើញហេតុដែលគួរអស្ចារ្យនេះហ្ន៎ ទើបទ្រង់ហាម ព្រះថេរ:គិតថា អាត្មាអញនឹងក្រាបទូលហេតុនេះចំពោះព្រះទសពល ទើបក្រោកឡើងពីអាសន:ដែលអង្គុយ ចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ។ ព្រះថេរ: ចូលទៅដល់ហើយក្រាបទូល

១-ក្នុងច្បាប់ញដ្ឋសង្គាយនាថា **អជ្ឌសត្តោ** ។

រឿងរបស់ខ្លួន ដោយន័យមានជាអាទិ៍ថា **ឥធ មយ្ហំ ភន្តេ** ជូរ្ចេះ ។

បណ្តាបទទាំងនោះ បទថា **យេកុយ្យេ** បានដល់ ច្រើនដង គឺញយ១ ។ បទថា **ចាបកា** ប្រែថា លាមក ។ បទថា **អកុសលា** ប្រែថា កើតតែអកុសល ។ ម្យ៉ាងទៀត ឈ្មោះថា **បាប** ព្រោះអត្ថថា នាំសត្វឱ្យដល់ទុគ្គតិ ឈ្មោះថា **អកុសល** ព្រោះជាសត្រូវចំពោះកុសល ។ ឈ្មោះថា **វិតក្ក:** ព្រោះត្រិះរិះ គឺគិតបានដល់ លើកចិត្តឡើងកាន់អារម្មណ៍ ។ វិតក្ក:ដែលកើតព្រមនឹងកាម ឈ្មោះថា **កាមវិតក្ក:** អធិប្បាយថា វិតក្ក:ដែលសម្បយុត្តដោកិលេលកាម មានវត្ថុកាមជាអារម្មណ៍ ។ វិតក្ក:ដែលកើតព្រមដោយព្យាបាទ ឈ្មោះថា **ព្យាបាទវិតក្ក:** វិតក្ក:ដែលកើតព្រមដោយវិហិង្សា ឈ្មោះថា **វិហិង្សាវិតក្ក:** ។ បណ្តាវិតក្ក:ទាំ-ងនោះ ធម៌ដែលជាសត្រូវចំពោះនេក្ខម្ម: ដែលប្រព្រឹត្តទៅដោយអំណាចការត្រេកអរក្នុងកាម ឈ្មោះថា **កាមវិតក្ក:** ធម៌ដែលជាសត្រូវចំពោះមេត្តា ដែលប្រព្រឹត្តទៅដោយអំណាចការប្រទូសរ៉ាយក្នុងសត្វទាំងឡាយ ដោយគិតថា សូមឱ្យសត្វទាំងនេះចូរក្តៅក្រហាយ ចូរវិនាស ឬកុំមាន ឈ្មោះថា **ព្យាបាទវិតក្ក:** ធម៌ដែលជាសត្រូវចំពោះករុណា ដែលប្រព្រឹត្តទៅដោយអំណាចភាពជាអ្នកប្រាថ្នានឹងបៀតបៀនពួកសត្វដោយបហរណាវត្ថុ មានបាតដៃ ដុំដី និងកំណាត់ឈើជាដើម ឈ្មោះថា **វិហិង្សាវិតក្ក:** ។

ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ ទើបទ្រង់អនុញ្ញាតឱ្យព្រះថេរៈទៅក្នុងទីនោះ? ព្រោះព្រះអង្គទ្រង់អនុញ្ញាត ដោយទ្រង់មានព្រះតម្រិះថា មេឃិយ: នេះ សូម្បីតថាគតមិនអនុញ្ញាត ក៏នៅតែលះបង់តថាគតហើយទៅ ទាំងលោក

ក៏នឹងមានការគិតជាយ៉ាងដូចនេះថា ប្រហែលជាព្រះដ៏មានព្រះភាគនឹងមិនអនុញ្ញាតឱ្យអាត្មាអញទៅ ព្រោះប្រាថ្នាឱ្យនៅបម្រើ ប្រការនោះគប្បីប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខរហូតអស់កាលយូរដល់លោក ។

កាលព្រះថេរៈអង្គុយក្រាបទូលរឿងរ៉ាវរបស់ខ្លួនយ៉ាងនេះ លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់សម្តែងធម៌ ដែលជាសប្បាយដល់លោក ទើបត្រាស់ពាក្យមានជាអាទិ៍ថា ម្នាលមេឃិយៈ ចេតោវិមុត្តិយង្គៈ មិនទាន់ចាស់-ក្លា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបរិបក្ការ** *ប្រែថា មិនទាន់ដល់សេចក្តីចាស់ក្លា ។ បទថា* **ចេតោវិមុត្តិយា** *បានដល់ ចិត្តរួចផុតពីកិលេស ។ ពិតមែនក្នុងខាងដើម ចិត្តរមែងរួចផុតពីកិលេសដោយតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ខាងក្រោយរមែងរួចផុតដោយសមុច្ឆេទវិមុត្តិ និងបដិបស្សទ្ធិវិមុត្តិ ។*

ក៏វិមុត្តិនេះនោះ ខ្ញុំពោលទុកពិស្តារហើយក្នុងកាលជាខាងក្រោយនោះឯង ។ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយក្នុងអធិការដែលពោលអំពីវិមុត្តិនោះ ។ ក្នុងសេចក្តីនោះ កាលលោកអប់រំ គឺដាស់អធ្យា-ស្រ័យ ឱ្យក្ងាក់ដោយធម៌ដែលជាគ្រឿងអប់រំវិមុត្តិ កាលវិបស្សនាកាន់យកបន្ទប់មគ្គ ដល់សេចក្តីចាស់ក្លា ចេតោវិមុត្តិ ឈ្មោះថា ជាការចាស់ក្លា កាលវិបស្សនាមិនទាន់កាន់យកបន្ទប់មគ្គ ឈ្មោះថា មិនទាន់ចាស់ក្លា ។

ក៏ធម៌ជាគ្រឿងអប់រំវិមុត្តិ ដូចម្តេច? គឺគប្បីជ្រាបធម៌ ១៥ យ៉ាង ដោយធ្វើសទ្ធិន្ទ្រិយជាដើមឱ្យហ្មត់ចត់ ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា សទ្ធិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលឥតសទ្ធា ១

សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានសទ្ធា ១ ពិចារណាព្រះសូត្រដែលជាទីជ្រះថ្លា ១ វីរិយិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលខ្ជិលច្រអូស ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានសេចក្តីព្យាយាម ១ ពិចារណាសម្មប្បធាន ១ សតិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលភ្លេចស្មារតី ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានស្មារតីតម្កល់មាំ ១ ពិចារណាសតិប្បដ្ឋាន ១ សមាធិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលមានចិត្តមិននឹងធឹង ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានចិត្តនឹងធឹង ១ ពិចារណាឈាន នឹងវិមោក្ខ ១ បញ្ញិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលអាប់ឥតបញ្ញា ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានបញ្ញា ១ ពិចារណានូវញាណចរិយាដ៏ជ្រៅ ១ នេះឯង ឥន្ទ្រិយទាំង ៥ បរិសុទ្ធដោយអាការ ១៥ នេះ គឺបុគ្គលវៀរបុគ្គល ៥ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គល ៥ ពិចារណាកង់ព្រះសូត្រ ៥ ដូចពោលមកនេះឯង[1] ។ ធម៌ ១៥ ប្រការសូម្បីដទៃទៀត ជាគ្រឿងអប់រំវិមុត្តិ គឺឥន្ទ្រិយ ៥ មានសទ្ធាជាដើម សញ្ញាដែលជាចំណែកនៃការត្រាស់ដឹង ៥ ទាំងនេះ គឺអនិច្ចសញ្ញា ទុក្ខសញ្ញា អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា ភាពជាអ្នកមានកល្យាណមិត្ត សេចក្តីសង្រួមក្នុងសីល ភាពជាអ្នកដុសខាត់យ៉ាងក្រៃលែង ការប្រារព្ធសេចក្តីព្យាយាមបញ្ញាដែលប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹង ។

១-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៧០ ទំព័រ ១៩០ ដល់ ១៩១ ។

បណ្តាធម៌ទាំងនោះ ព្រះសាស្តាព្រះអង្គជាអ្នកធ្វាតក្នុងការទូន្មានវិនេយ្យ-បុគ្គល កាលនឹងទ្រង់សម្តែងធម៌ដែលជាគ្រឿងអប់រំវិមុត្តិ មានកល្យាណមិត្ត ជាដើម ក្នុងទីនេះ តាមអធ្យាស្ស័យរបស់ព្រះមេឃិយត្ថេរ អ្នកគួរដល់ការណែនាំ ទើបត្រាស់ថា ធម៌ទាំង ៥ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីចាស់ក្លា កាលនឹងឱ្យធម៌ទាំងនោះពិស្តារ ទើបត្រាស់ពាក្យមានជាអាទិ៍ថា មេឃិយ: ភិក្ខុក្នុងធម្មវិន័យនេះ ជាកល្យាណមិត្ត ។

បណ្តាបទទាំងនោះ បទថា **កល្យាណមិត្តោ** *សេចក្តីថា ឈ្មោះថា កល្យាណមិត្ត ព្រោះមានមិត្តល្អ ចម្រើន គឺប្រសើរ ។ បុគ្គលដែលមានមិត្តបរិបូណ៌ ដោយសីលគុណជាដើម មានឧបការ:ដោយអាការទាំងពួងយ៉ាងនេះ គឺបំបាត់ទុក្ខ សាងប្រយោជន៍ បុគ្គលនោះឈ្មោះថា ជាកល្យាណមិត្តពិតប្រាកដ ។ ឈ្មោះថា កល្យាណសម្ងាញ់ ព្រោះទៅ គឺឱ្យប្រព្រឹត្តទៅដោយកល្យាណបុគ្គលតាមដែលពោលហើយនុ៎ះឯង គឺមិនប្រព្រឹត្តទៅប្រាសចាកកល្យាណមិត្ត បុគ្គលទាំងនោះ ។ ឈ្មោះថា មានពួកល្អ ព្រោះប្រព្រឹត្តទៅដោយការ:ដែលបង្ហោនទៅតាមផ្លូវចិត្ត និងផ្លូវកាយ ក្នុងកល្យាណបុគ្គលនុ៎ះឯង ។ ដោយ ៣ បទ រមែងញ៉ាំងសេចក្តីអើពើឱ្យកើតឡើងក្នុងការនៅរួមនឹងកល្យាណមិត្ត ។*

ក្នុងសេចក្តីនោះ មានលក្ខណ:កល្យាណមិត្តមានលក្ខណ:ដូចតទៅនេះ

កល្យាណមិត្តក្នុងព្រះសាសនានេះ ជាអ្នកដល់ព្រមដោយសទ្ធា សីល: សុត: ចាគ: វិរិយ: សតិ សមាធិ និងបញ្ញា ។ បណ្តាលក្ខណ:កល្យាណមិត្តនោះ បុគ្គលដែលដល់ព្រមដោយសទ្ធាសម្បត្តិ រមែងជឿការត្រាស់ដឹងរបស់ព្រះតថាគត ជឿកម្ម និងផលនៃកម្ម មិនលះចោលការស្វែងរកប្រយោជន៍ក្នុងពួកសត្ត្ব ដែល

ជាហេតុនៃព្រះសម្មាសម្ពោធិញាណដោយការជឿនោះ ។ ឈ្មោះថា ព្រមដោយសីលសម្បត្តិ រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរពសរសើរ ជាអ្នកចោទជាអ្នកតិះដៀលបាប ជាអ្នកសរសើរនូវសេចក្តីអត់ធន់ចំពោះពាក្យរបស់សម្ងាញ់សព្រហ្មចារីទាំងឡាយ ។ ឈ្មោះថា ដល់ព្រមដោយសុតសម្បត្តិ រមែងធ្វើពាក្យដែលជ្រាលជ្រៅជាប់ដោយសច្ច: និងបដិច្ចសមុប្បាទជាដើមឱ្យងាយ ។ ឈ្មោះថា ដល់ព្រមដោយចាគសម្បត្តិ រមែងជាអ្នកប្រាថ្នាតិច សន្ធោសពេញចិត្តទីស្ងាត់ មិនច្របូកច្របល់ដោយពួកគណ: ។ ឈ្មោះថា ដល់ព្រមដោយវីរិយសម្បត្តិ រមែងជាអ្នកប្រារព្ធសេចក្តីព្យាយាម ដើម្បីបដិបត្តិប្រយោជន៍ដល់សត្វទាំងឡាយ ។ ឈ្មោះថា ដល់ព្រមដោយសតិសម្បត្តិ រមែងមានសតិតាំងមាំ ។ ឈ្មោះថា ដល់ព្រមដោយសមាធិសម្បត្តិ រមែងជាអ្នកមានចិត្តមិនរវើរវាយ មានចិត្តជាសមាធិ ។ ឈ្មោះថា ដល់ព្រមដោយបញ្ញាសម្បត្តិ រមែងដឹងសការ:ដែលមិនខុសប្លែក ។ កល្យាណមិត្តនោះ ជាអ្នកដល់ព្រមដោយគតិធម៌ដែលជាកុសលដោយសតិ ដឹងវត្ថុដែលមានប្រយោជន៍ និងមិនមានប្រយោជន៍នៃសត្វទាំងឡាយតាមសេចក្តីពិត ដោយបញ្ញាជាអ្នកមានចិត្តតម្កល់មាំក្នុងកុសលធម៌ទាំងនោះដោយសមាធិ រមែងរារាំងសត្វទាំងឡាយពីវត្ថុដែលមិនជាប្រយោជន៍ ហើយដឹកនាំចូលទៅកាន់វត្ថុដែលជាប្រយោជន៍ដោយវីរិយ: ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ភិក្ខុជាអ្នក(ធ្វើខ្លួន)ឱ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ឧស្សាហ៍ប្រឹងប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុមិនគួរផង[1] ។

១-សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត លេខ ៦៧ ទំព័រ ៨១ ។

បទថា **អយំ បឋមោ ធម្មោ បរិចាកាយ សំវត្តតិ** *សេចក្ដីថា ធម៌ដែលមិនមានទោសនេះ ពោលគឺ ភាពជាអ្នកមានមិត្តដ៏ល្អប្រសើរ ឈ្មោះថា ជាទី ១ ព្រោះជាខាងដើមនៃព្រហ្មចរិយវាស និងព្រោះត្រាស់ទុក ជាប្រការដំបូងក្នុងធម៌ ៥ ប្រការនេះ ព្រោះមានឧបការៈច្រើន និងភាពជាប្រធាននៃកុសលធម៌ទាំងពួង រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីចាស់ក្លានៃចេតោវិមុត្តិ ដោយអំណាចនៃការធ្វើសទ្ធាជាដើម ដែលមិនបរិសុទ្ធិឱ្យបរិសុទ្ធ ។ ក៏ក្នុងទីនេះ ភាពជាប្រធាន ភាពជាកល្យាណមិត្តមានឧបការៈច្រើន និងជាប្រធាននៃកុសលធម៌ទាំងពួង គប្បីជ្រាបដោយសុត្តបទមានជាអាទិ៍ថា ម្នាលអានន្ទ មគ្គព្រហ្មចរិយៈនុ៎ះ កើតប្រាកដដល់ភិក្ខុអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ នេះចាត់ជាព្រហ្មចរិយៈទាំងមូល[1] ព្រោះទ្រង់បដិសេធនឹងព្រះអានន្ទ ជាធម្មកណ្ឌាគារិកថា បពិត្រព្រះអង្គដ៏ចម្រើន ភាពនៃបុគ្គលអ្នកមានមិត្តល្អ នេះជាគុណពាក់កណ្ដាលរបស់ព្រហ្មចរិយៈ រហូតដល់អស់វារៈ ២ ដងថា* **មា ហេវំ អានន្ទ** *ម្នាលអានន្ទ កុំពោលយ៉ាងនេះឡើយ ។*

បទថា **បុន ចបរំ** *ប្រែថា ក៏ធម៌ប្រការដទៃនៅមាននៅទៀត ។ ក្នុងបទថា* **សីលវា** *នេះ មានវិនិច្ឆ័យដូចតទៅនេះ*

ដែលឈ្មោះថា **សីល** *ព្រោះអត្ថថាអ្វី? ដែលឈ្មោះថា* **សីល** *ព្រោះអត្ថថាតាំងទុកមាំ ។ ដែលឈ្មោះថា តាំងទុកមាំគឺអ្វី? គឺតាំងមាំទុកដោយល្អ អធិប្បាយថា ការៈនៃកាយកម្មជាដើមសមរម្យ ព្រោះភាពជាអ្នកមានសីលល្អ ។ ម្យ៉ាង-*

១-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ២៩ ទំព័រ ២៣៨ ។

ទៀត ជាទីទ្រទ្រង់ទុក អធិប្បាយថា ការៈជាទីទ្រទ្រង់ទុកដោយភាពជាទីតាំងនៃកុសលធម៌ មានឈានជាដើម ព្រោះដូច្នោះ ទើបឈ្មោះថា សីល ព្រោះតាំងទុកមាំ ឬទ្រទ្រង់ទុក ។ នេះជាអត្ថនៃសីល ដោយន័យនៃលក្ខណៈរបស់ស័ព្ទជាដំបូង ។ តែអាចារ្យមួយពួកទៀត ពណ៌នាអត្ថដោយនិរុត្តិន័យថា អត្ថនៃសីល មានអត្ថថា សីសៈ មានអត្ថថា ត្រជាក់ មានអត្ថថា តាំងមាំ មានអត្ថថា សំវរៈ ។ សីលនេះ នោះមានចំពោះបុគ្គលនោះដោយគ្រប់គ្រាន់ដោយល្អណាស់ ព្រោះដូច្នោះ ទើបឈ្មោះថា **សីលវា** អ្នកមានសីល អធិប្បាយថា អ្នកដល់ព្រមដោយសីល ។

ម្យ៉ាងទៀត ដើម្បីនឹងសម្តែងប្រការដែលបុគ្គលអ្នកមានសីល ដល់ព្រមដោយសីល ទើបត្រាស់ពាក្យមានជាអាទិ៍ថា **ចាតិមោក្ខសំវរសំវុតោ** ជ្រើសរើស ។ បណ្តាបទទាំងនោះ បទថា **ចាតិមោក្ខ** បានដល់ សីលសិក្ខាបទ ។ មែនពិត សីលសិក្ខាបទនោះ ឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថា ធ្វើបុគ្គលអ្នករក្សាសីលសិក្ខាបទនោះឱ្យរួចផុតចាកទុក្ខ មានទុក្ខក្នុងអបាយជាដើម ។ ការបិទបាំងឈ្មោះថា **សំវរៈ** បានដល់ ការមិនកន្ទងល្មើសផ្លូវកាយ និងវាចា ។ បាតិមោក្ខ និងសំវរៈ ឈ្មោះថា **បាតិមោក្ខសំវរៈ** ។ ភិក្ខុអ្នកសង្រ្ទមគឺមានកាយ និងវាចាបិទដោយបាតិមោក្ខសំវរៈនោះ ទើបឈ្មោះថា សង្រ្ទមក្នុងបាតិមោក្ខសំវរៈ ។ នេះជាការសម្តែងការៈនៃភិក្ខុនោះតាំងនៅក្នុងសីលនោះ ។ បទថា **វិហរតិ** ជាបទសម្តែងការៈនៃភិក្ខុព្រមព្រៀង ដោយការនៅដ៏សមគួរក្នុងបាតិមោក្ខសំវរៈនោះ ។ បទថា **អាចារគោចរសម្បន្នោ** ជាបទសម្តែងដល់ធម៌ ដែលមាន

ឧបការៈដល់បាតិមោក្ខសំវរៈក្នុងខាងក្រោម និងដល់សេចក្តីឧស្សាហ៍ព្យាយាមដើម្បីគុណវិសេសក្នុងខាងលើ ។ បទថា **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** ជាបទសម្តែងការៈដែលកិក្ខុមិនឃ្លាតចាកបាតិមោក្ខសីលជាធម្មតា ។ បទថា **សមាទាយ** ជាបទសម្តែងការកាន់យកសិក្ខាបទ ដោយមិនមានចំណែកនៅសល់ ។ បទថា **សិក្ខតិ** ជាបទសម្តែងដល់ការៈដែលកិក្ខុត្រូវសិក្សា ។ បទថា **សិក្ខាបទេសុ** ជាបទសម្តែងដល់ធម៌ដែលគួរសិក្សា ។

ន័យមួយទៀត ឈ្មោះថា **ចាតិ** ព្រោះមានប្រក្រតីធ្លាក់ទៅក្នុងអបាយច្រើនដង ព្រោះកិលេសខ្លាំងក្លា ព្រោះការធ្វើអាក្រក់បានងាយ និងព្រោះការធ្វើបុណ្យធ្វើបានដោយលំបាក បានដល់ បុថុជ្ជន ។ ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** ព្រោះត្រូវកម្ចាំងកម្មបោះទៅក្នុងកពជាដើម ដោយការៈមិនទៀង និងមានប្រក្រតីទៅដោយការវិលទៅកំណត់មិនបាន ដូចពងទឹកដូចផ្ទាំងយន្ត ។ ម្យ៉ាងវិញទៀត ឈ្មោះថា ប្រក្រតី ព្រោះមានប្រក្រតីធ្លាក់ទៅនៃអត្តភាពក្នុងសត្ត-និកាយនោះៗ ដោយអំណាចមរណៈ ឬសន្ធានរបស់សត្ត្ব គឺចិត្តនោះឯង ។ ឈ្មោះថា **បាតិមោក្ខ** ព្រោះញ៉ាំងសត្ត្ববឱ្យធ្លាក់ទៅនោះ ឱ្យផុតពីសង្សារទុក្ខ ។ ក៏សត្ត្ববដែលហៅថា វិមុត្ត: ព្រោះចិត្តរួចផុត ។ សមដូចពាក្យដែលព្រះដ៏មាន-ព្រះភាគត្រាស់ទុកថា ពួកសត្ត្ববដែលមានធម៌ជាគ្រឿងផ្ទរផង់នៃចិត្តរមែងបរិសុទ្ធ[1] និងត្រាស់ទុកថា ចិត្តក៏រួចផុតស្រឡះចាកអាសវធម៌ទាំងឡាយ ឥតជាប់ជំពាក់ដោយឧបាទានឡើយ[2] ។

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៣ ទំព័រ ៣៦៣ ។

២-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ៥៤ ។

ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** ព្រោះធ្លាក់ទៅ គឺទៅ បានដល់ ប្រព្រឹត្តទៅ ក្នុងសង្សារ ដោយហេតុមានអវិជ្ជាជាដើម ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា សត្វអ្នកមានអវិជ្ជាជារនាំង មានតណ្ហាជាចំណងចង អន្ទោលទៅ ត្រាច់រង្គាត់ទៅ (មិនប្រាជកឡើយ)[១] ។ ធម៌ ឈ្មោះថា **បាតិមោក្ខ:** ព្រោះជាហេតុឱ្យសត្វអ្នកធ្លាក់ទៅនោះផុតពីសង្កិលេស ៣ មានតណ្ហាជាដើម ។ គប្បីជ្រាបសេចក្តីសម្រេចសមាស ដូចសេចក្តីសម្រេចពាក្យមានជាអាទិ៍ថា **តណ្ហាកាលោ**[២] ។

ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** ព្រោះធ្វើសត្វឱ្យធ្លាក់ទៅ គឺឱ្យធ្លាក់ទៅ មិនទៅសល់ពីទុក្ខ បានដល់ ចិត្ត ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ចិត្តតែងនាំសត្វលោកទៅ ចិត្តតែងកើចកន្ត្រាក់សត្វលោកទៅ[៣] ។ ឈ្មោះថា **បាតិមោក្ខ** ព្រោះជាគ្រឿងធ្វើសត្វអ្នកធ្លាក់ទៅនោះ ឱ្យរួចផុត(ពីទុក្ខ) ។ ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** ព្រោះជាគ្រឿងធ្លាក់ទៅក្នុងអបាយទុក្ខ និងសង្សារ-ទុក្ខរបស់សត្វ បានដល់ សង្កិលេស មានតណ្ហាជាដើម ។ សមដូចព្រះដ៏មាន-ព្រះភាគត្រាស់ទុកថា តណ្ហាតែងញ៉ាំងបុរសឱ្យកើត[៤] និងត្រាស់ទុកថា បុរសអ្នកមានតណ្ហាជាគម្រប់ពីរ[៥] ។ ឈ្មោះថា **បាតិមោក្ខ** ព្រោះផុតចាកការធ្លាក់ទៅពីតណ្ហាសង្កិលេសនោះ ។ ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** ព្រោះជាទីធ្លាក់ទៅ

១-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣២ ទំព័រ ៧៩ ។

២-ក្នុងអដ្ឋកថាច្បាប់ឆដ្ឋសង្គាយនាថា **ककण्हाकालो** ។

៣-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ២៩ ទំព័រ ១០២ ។

៤-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ២៩ ទំព័រ ៩៧ ។

៥-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ១៣ ។

របស់សត្វ បានដល់ អាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា (ម្នាលហេមវតៈ) សត្វលោកកើតឡើងព្រោះវត្ថុ ៦ ធ្វើសេចក្តីស្និទ្ធស្នាលព្រោះវត្ថុ ៦[1] ។ ឈ្មោះថា **បាតិមោក្ខ** *ព្រោះផុតពីការធ្លាក់ទៅពោលគឺ អាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ នោះ ។ ម្យ៉ាងទៀត ឈ្មោះថា* **ចាតិ** *គឺសង្សារ ព្រោះមានការធ្លាក់ទៅ គឺការធ្វើឱ្យធ្លាក់ទៅ ឈ្មោះថា* **ចាតិមោក្ខ** *ព្រោះរួចផុតពីសង្សារនោះ ។*

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គជាធម្មិស្សរៈ សត្វលោកថ្វាយព្រះនាមថា **បតិ** *ព្រោះព្រះអង្គជាអធិបតីរបស់សព្វសត្វ ។ ឈ្មោះថា* **មោក្ខៈ** *ព្រោះជាគ្រឿងរួចផុតរបស់សត្វ ។ ឈ្មោះថា* **បតិមោក្ខ** *ព្រោះជាគ្រឿងផុតនៃព្រះដ៏មានព្រះភាគ អ្នកបាននាមថា* **បតិ** *ដោយហេតុព្រោះទ្រង់បញ្ញត្តទុក ។ បតិមោក្ខនុ៎ះឯង ជាបាតិមោក្ខ ។ ម្យ៉ាងទៀត ឈ្មោះថា* **បតិមោក្ខ** *ព្រោះព្រះដ៏មានព្រះភាគនោះ ព្រះអង្គជាធំ ដោយអត្ថថា មានគុណទាំងពួងខ្ពស់ បំផុតដែលមានគុណនោះជាមូល និងឈ្មោះថា ជាអ្នកផុតដោយអត្ថ តាមដែលពោលហើយ ។ បតិមោក្ខនោះឯង ជាបាតិមោក្ខ ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា* **ចាតិមិក្ខន្តិ អាជិមេតំ មុខមេតំ បមុខមេតំ កុសលានំ ធម្មានំ តេន វុច្ចតិ ចាតិមោក្ខំ** *។ ត្រង់ពាក្យថា* **បាតិមោក្ខ** *សេចក្តីថា ធម្មជាតនេះជាដើម ធម្មជាតនេះជាប្រធាន ធម្មជាតនេះជាចម្បងនៃកុសលធម៌ទាំងឡាយ ហេតុនេះតថាគតហៅថា* **បាតិមោក្ខ**[2] *។ គប្បីជ្រាបពិស្តារដូចតទៅនេះ ។*

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ៥៦ ។

២-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ៣២១ ។

ម្យ៉ាងទៀត សព្ទថា **ប** ប្រើក្នុងអត្ថថា បការៈ សព្ទថា **អតិ** ជានិបាត ប្រើក្នុងអត្ថថា អច្ចន្ត: ។ ព្រោះដូច្នោះ ទើបឈ្មោះថា **ចាតិមោក្ខ** ព្រោះកន្ទ្ធងផុតដ៏ក្រៃលែងដោយប្រការទាំងពួង ។ មែនពិត សីលនេះ ឈ្មោះថា **បាតិមោក្ខ** ព្រោះតួសីលធ្វើឱ្យរួចផុតបានពិត ដោយអំណាចតទង្គវិមុត្តិ ដែលប្រកបដោយសមាធិ និងបញ្ញាធ្វើឱ្យរួចផុតបានពិត ដោយអំណាចវិក្ខម្ភនវិមុត្តិ និងសមុច្ឆេទ-វិមុត្តិ ។ ម្យ៉ាងទៀត ឈ្មោះថា **បាតិមោក្ខ** ព្រោះរួចផុត អធិប្បាយថា រួចផុតពីវិតិក្កមទោសនោះ។ បតិមោក្ខនោះឯង ជាបាតិមោក្ខ ។ ម្យ៉ាងទៀត និព្វានឈ្មោះថា **មោក្ខ:** ។ ឈ្មោះថា **បតិមោក្ខ** ព្រោះប្រៀបផ្ទឹមនឹងមោក្ខ:នោះ ។ មែនពិត សីលសំវរ: ជាហេតុធ្វើព្រះនិព្វានឱ្យកើត ដូចព្រះអាទិត្យធ្វើអរុណឱ្យកើត និងមានចំណែកប្រៀបផ្ទឹមដោយព្រះនិព្វាននោះ ព្រោះធ្វើកិលេសឱ្យរលត់តាមសមគួរ ។ បតិមោក្ខនោះឯង ជាបាតិមោក្ខ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **ចាតិមោក្ខ** ព្រោះប្រែទៅ គឺធ្វើទុក្ខឱ្យរួចផុតទៅ ។ បតិមោក្ខនោះឯង ជាបាតិមោក្ខ ក្នុងសេចក្ដីនេះ គប្បីជ្រាបអត្ថរបស់សព្ទថា បាតិមោក្ខប៉ុណ្ណោះយ៉ាងនេះ ដោយប្រការដូច្នេះ ។

ឈ្មោះថា **សំវរ:** ព្រោះជាគ្រឿងបិទ ការពារ ។ បាតិមោក្ខ និងសំវរ: ឈ្មោះថា បាតិមោក្ខសំវរ: ។ តែកាលពោលអំពីអត្ថន័យ បានដល់ រៀរចាកទោសដែលគប្បីឈានកន្ទ្ធងនោះ។ និងចេតនា ។ ភិក្ខុអ្នកចូលដល់ប្រកបដោយបាតិមោក្ខសំវរនោះ លោកហៅថា អ្នកសង្រួមក្នុងបាតិមោក្ខសំវរ: ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងគម្ពីរវិភង្គថា គឺជាអ្នកព្រមព្រៀង មូលមិត្ត

ចូលទៅជិត អែបនែប ក្ងៀកកើយ ប្រដិតប្រដី ប្រកបព្រម ដោយការសង្រ្ងួម ក្នុងបាតិមោក្ខនេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកសង្រ្ងួមក្នុងបាតិមោក្ខ-សំវរ:[1] ។ បទថា **វិហរតិ** សេចក្តីថា រមែងនៅ គឺផ្ទាស់ប្តូរ បានដល់ ផ្ទាស់ប្តូរ ទៅដោយឥរិយាបថវិហារ ។

បទថា **អាចារគោចរសម្បន្នោ** សេចក្តីថា ឈ្មោះថា ដល់ព្រមដោយ អាចារ: និងគោចរ: ព្រោះវៀរអនាចារ:ទាំងពួង ហេតុមិនធ្វើមិច្ឆាជីវ: មានការ ឱ្យឫស្សីជាដើម និងការធ្វើឫកគ្រាន់បើដោយកាយជាដើម ហើយប្រកបដោយ អំណាចអាចារសម្បត្តិ ដែលសមគួរដល់ភិក្ខុ ដែលត្រាស់ទុកយ៉ាងនេះថា ការ មិនប្រព្រឹត្តកន្ទ្ងប្រកបដោយកាយ ការមិនប្រព្រឹត្តកន្ទ្ងប្រកបដោយវាចា ការ មិនប្រព្រឹត្តកន្ទ្ងប្រកបដោយកាយនិងវាចា[2] និងវៀរអគោចរ: មានស្រីពេស្យា ជាដើម ហើយប្រកបដោយគោចរ: ពោលគឺ កន្ទ្ងដែលសមគួរចូលទៅ បិណ្ឌបាតជាដើម ។

ម្យ៉ាងទៀត ភិក្ខុណាមានសេចក្តីគោរពកោតក្រែងក្នុងព្រះសាស្តា មាន សេចក្តីគោរពកោតក្រែងក្នុងសម្ងាញ់សព្រហ្មចារី ដល់ព្រមដោយហិរិឱ្ត្តប្ប: ស្ងៀកដណ្តប់រៀបរយ មានដំណើរឈានដើរទៅមុខ ឈានថយក្រោយ ក្រឡេក មើលទៅមុខ ក្រឡេកមើលចំហៀង បត់ចូលនឹងលាចេញ គួរជាទីជ្រះថ្លា ដល់ ព្រមដោយឥរិយាបថ ឃុំគ្រងទ្វារក្នុងឥន្ទ្រិយ ស្គាល់ប្រមាណក្នុងភោជន ដល់ ព្រមដោយសេចក្តីព្យាយាម ប្រកបដោយសតិ និងសម្បជញ្ញ: ជាអ្នកប្រាជ្ញាតិច

១-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២៨៩ ។

២-អភិធម្មបិដក វិភង្គ លេខ ៨១ ទំព័រ ២៥០ ។

សន្ធោស ពេញចិត្តទីស្ងាត់ មិនច្របូកច្របល់ដោយពួក ធ្វើសេចក្តីគោរពក្នុងអភិសមាចារិកវត្ត ច្រើនដោយសេចក្តីគោរព និងកោតក្រែង ភិក្ខុនេះ លោកហៅថា ដល់ព្រមដោយអាចារ: ។

*ចំណែក គោចរមាន ៣ យ៉ាង គឺ**ឧបនិស្សយគោចរ: ១ អារក្ខគោចរ: ១ ឧបនិពន្ធគោចរ: ១** ។ បណ្តាគោចរ:ទាំង ៣ យ៉ាងនោះ ភិក្ខុណា ប្រកបដោយគុណ គឺកថាវត្ថុ ១០ មានមិត្តល្អ មានលក្ខណ:ដូចពោលហើយ កាលអាស្រ័យមិត្តល្អហើយ រមែងបានស្តាប់វត្ថុដែលមិនធ្លាប់បានស្តាប់ រមែងញ៉ាំងវត្ថុដែលធ្លាប់ស្តាប់ហើយឱ្យផ្ទូរផង់ កាត់សេចក្តីសង្ស័យចេញបាន ធ្វើទិដ្ឋិឱ្យត្រង់ ញ៉ាំងចិត្តឱ្យជ្រះថ្លា កាលសិក្សាតាមរមែងចម្រើនដោយសទ្ធា ដោយសីល ដោយសុត: ដោយចាគ: និងដោយបញ្ញា នេះលោកហៅថា **ឧបនិស្សយគោចរ:** ។*

*ភិក្ខុណា ចូលទៅកាន់ចន្ទោះស្រុក ដើរទៅតាមថ្នល់ មានចក្ខុសម្ងឹងចុះក្រឡេកមើលមួយជួរនឹម ដើរសង្រួមចក្ខុន្ទ្រិយទៅ មិនដើរក្រឡេកមើលពលដំរី មិនដើរក្រឡេកមើលពលសេះ មិនដើរក្រឡេកមើលពលរថ មិនដើរក្រឡេកមើលពលថ្មើរជើង មិនដើរក្រឡេកមើលស្ត្រី មិនដើរក្រឡេកមើលប្រុស មិនងើយមើល មិនឱនមើល មិនដើរក្រឡេកមើលតាមទិសតូចធំ នេះលោកហៅថា **អារក្ខគោចរ:** ។*

*ចំណែក **ឧបនិពន្ធគោចរ:** បានដល់ សតិប្បដ្ឋាន ៤ ដែលជាទីដែលភិក្ខុចូលទៅចង់ចិត្តរបស់ខ្លួនទុក ។ សមដូចដែលព្រះដ៏មានព្រះភាគបានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ចុះទីជាគោចររបស់ភិក្ខុ ជាដែននៃបិតារបស់ខ្លួន*

តើដូចម្តេច ។ គឺសតិប្បដ្ឋានទាំង ៤ នេះឯង[1] ។ បណ្តាគោចរៈ ៣ យ៉ាងនោះ ព្រោះឧបនិស្សយគោចរៈលោកពោលទុកមុនហើយ ក្នុងទីនេះគប្បីជ្រាបគោចរៈ ២ យ៉ាងក្រៅនោះ ។ ភិក្ខុនោះឈ្មោះថា អ្នកដល់ព្រមដោយអាចារៈ និងគោចរៈ ព្រោះប្រកបដោយអាចារសម្បត្តិ តាមដែលពោលហើយ និងគោចរ-សម្បត្តិនេះដោយប្រការដូច្នេះ ។

បទថា **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** *សេចក្តីថា អ្នកមានប្រក្រតីឃើញភ័យក្នុងទោស ផ្សេងដោយសេក្ខិយវត្តសិក្ខាបទដែលភិក្ខុមិនភ្លេង មិនមានសតិ និងអកុសលចិត្តុប្បាទជាដើម ឈ្មោះថា មានប្រមាណតិច ព្រោះមានប្រមាណបន្តិចបន្តួច ។ មែនពិត ភិក្ខុណាឃើញទោសមានប្រមាណតិចតួច ធ្វើឱ្យដូចជាស្តេចឈ្មោះភ្នំសិនេរុមានកម្ពស់ ១០០០៦៨ យោជន៍ ចំណែកភិក្ខុណាឃើញអាបត្តិត្រឹមតែទុព្ភាសិតដែលជាអាបត្តិស្រាលជាងអាបត្តិទាំងពួង ធ្វើឱ្យដូចអាបត្តិបារាជិក ភិក្ខុសូម្បីនេះ ឈ្មោះថា មានប្រក្រតីឃើញភ័យក្នុងទោសមានប្រមាណតិច ។ បទថា* **សមាទាយ សិក្ខតិ សិក្ខាបទេសុ** *សេចក្តីថា ភិក្ខុកាន់យកនូវសិក្ខាបទដែលគួរសិក្សាយ៉ាងណាមួយ ក្នុងសិក្ខាបទទាំងឡាយទាំងអស់ ដោយមិនមានចំណែកនៅសល់ ដោយប្រការទាំងពួង ហើយសិក្សាអធិប្បាយថា រមែងប្រព្រឹត្ត គឺធ្វើឱ្យបរិបូណ៌ដោយប្រពៃ ។*

បទថា **អកិសលេ្ទ ១ិ ១ា** *បានដល់ អ្នកមានប្រក្រតីដុសខាត់កិលេសយ៉ាងតឹងរ៉ឹង គឺជាអ្នកសមគួរដើម្បីលះកិលេសទាំងនោះ ដោយធ្វើឱ្យស្រាលខ្ទះ ។*

១-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ លេខ ៣៨ ទំព័រ ១៨ ។

បទថា **ចេតោវិវណ្ណសប្ប៉ាយា** បានដល់ ជាសប្ប៉ាយរបស់សមថ: និងវិបស្សនា ពោលគឺ បើកចិត្តដោយធ្វើនីវរណ:ដែលជាតួបិទបាំងចិត្តឱ្យឃ្វាតធ្វាយ ។ សមថ: និងវិបស្សនានោះឯងជាសប្ប៉ាយ គឺជាឧបការ:ដល់ការបើកចិត្ត ឬការធ្វើចិត្តនោះឯងឱ្យប្រាកដ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **ចេតោ-វិវណ្ណសប្ប៉ាយា** ។

ឥឡូវនេះ ដើម្បីនឹងសម្តែងហេតុជាគ្រឿងនាំមកនូវសេចក្តីនឿយណាយជាដើម ដែលជាកថាដុសខាត់កិលេស និងជាទីសប្ប៉ាយទូលាយចិត្ត ទើបត្រាស់ពាក្យមានជាអាទ៍ថា **ឯកន្តនិព្ពិន្ទាយ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឯកន្តនិព្ពិន្ទាយ** បានដល់ ដើម្បីនឿយណាយ ចាកវដ្តទុក្ខដោយពិតប្រាកដ ។ បទថា **វិរាគាយ និរោធាយ** បានដល់ ដើម្បីបំបាត់ គឺដើម្បីរលត់នូវវដ្តទុក្ខនោះៗឯង បទថា **ឧបសមាយ** បានដល់ ដើម្បីស្ងប់សព្វកិលេស ។ បទថា **អភិញ្ញាយ** បានដល់ ដើម្បីដឹងក្រៃលែងនូវធម៌ដែលគប្បីដឹងក្រៃលែង ។ បទថា **សម្ពោធាយ** បានដល់ ដើម្បីត្រាស់ដឹងមគ្គចិត្ត ៤ ។ បទថា **និព្ពានាយ** បានដល់ ដើម្បីអនុបាទិសេសនិព្ពានធាតុ ។ ក៏បណ្តាបទទាំងនេះព្រះដ៏មាន-ព្រះភាគត្រាស់វិបស្សនាដោយបទ ៣ ខាងដើម ។ ត្រាស់មគ្គដោយបទ ២ ត្រាស់និព្ពានដោយបទ ២ ។ លោកសម្តែងថា ឧត្តរិមនុស្សធម្មទាំងអស់នេះ ចាប់ផ្តើមតាំងពីសមថ: និងវិបស្សនាជរាបដល់និព្ពានជាទីបំផុត រមែងកើតមានដល់អ្នកបានកថាវត្ថុ ១០ ។

ឥឡូវនេះ កាលនឹងទ្រង់សម្តែងចែកកថានោះ ទើបត្រាស់ពាក្យមានជាអាទ៍

ថា **អប្ឍិច្ឆកថា** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **អប្ឍិច្ឆោ** ប្រែថា អ្នកមិនប្រាថ្នា ។ កថានៃអប្ឍិច្ឆៈនោះ ឈ្មោះថា **អប្ឍិច្ឆកថា** ឬកថាដែលជាប់ដោយភាពជាអ្នកប្រាថ្នាតិច ឈ្មោះថា **អប្ឍិច្ឆកថា** ។ ក៏ក្នុងទីនេះ ពោលដោយអំណាចសេចក្ដីប្រាថ្នាមានបុគ្គល ៤ ពួក គឺ**អត្រិច្ឆោ** អ្នកប្រាថ្នាក្រៃលែង ១ **ចាបិច្ឆោ** អ្នកប្រាថ្នាអាក្រក់ ១ **មហិច្ឆោ** អ្នកប្រាថ្នាច្រើន ១ **អប្ឍិច្ឆោ** អ្នកប្រាថ្នាតិច ១ ។ បណ្ដាបុគ្គល ៤ ទាំងនោះ អ្នកមិនឆ្អែតលាភតាមដែលខ្លួនបានមក ប្រាថ្នាលាភក្រៃលែង ឈ្មោះថា **អត្រិច្ឆៈ** ពាក្យនេះសមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា (ពោធិសត្ត្ববោលថា អ្នកចេញ) អំពីវេមានិកប្រេត ៤ នាក់ទៅក៏បានទូវវេមានិកប្រេត ៨ នាក់ (ចេញ) អំពីវេមានិកប្រេត ៨ នាក់ទៅ ក៏បានទូវវេមានិកប្រេត ១៦ នាក់ (ចេញ) អំពីវេមានិកប្រេត ១៦ នាក់ទៅ ក៏បានទូវវេមានិកប្រេត ៣២ នាក់ អ្នកកាលប្រាថ្នាខ្ចាំងពេក ទើបមកប្រទះនឹងចក្រ ចំណែកខាងចក្រក៏រិលកិនអម្បែងក្បាលរបស់សត្ត្ব ដែលត្រូវសេចក្ដីច្រណែនបៀតបៀនដូច្នេះ[1] ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា បុគ្គលមានសេចក្ដីប្រាថ្នាលើសលុបរមែងសាបសូន្យចាកប្រយោជន៍ ព្រោះលោភហួសហេតុផង ព្រោះសេចក្ដីស្រវឹងក្នុងការចង់បានហួសហេតុផង[2] ។ អ្នកមានសេចក្ដីប្រាថ្នាក្នុងការលើកតម្កើងគុណដែលមិនមាន ឈ្មោះថា អ្នកប្រាថ្នាអាក្រក់ ព្រោះមានសេចក្ដីត្រូវការក្នុងលាភសក្ការៈ និងការសរសើរ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា

១-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៥៩ ទំព័រ ២៥ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក លេខ ៥៨ ទំព័រ ១២៥ ។

បណ្តាធម៌ទាំងនោះ ការកុហក តើដូចម្តេច ។ ការប្រុងប្រៀបខាងខ្ញើម អាការប្រុងប្រៀប ការរៀបចំនូវឥរិយាបថ ការធ្វើមុខស្រពោន ការមានមុខស្រពោន ការធ្វើគេឱ្យស្ងើច អាការធ្វើគេឱ្យស្ងើច ភាពនៃសេចក្តីធ្វើគេឱ្យស្ងើច ដោយការសេពនូវបច្ច័យក្តី ដោយការខ្សឹបខ្សៀវក្តី របស់ភិក្ខុអ្នកអាស្រ័យលាភសក្តារៈ និងការសរសើរ[១] ដូច្នេះជាដើម ។ អ្នកមានសេចក្តីប្រាថ្នាក្នុងការលើកតម្កើងរបស់គុណដែលមាន និងមិនដឹងប្រមាណក្នុងការទទួល ឈ្មោះថា អ្នកប្រាថ្នាច្រើន សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធាប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានសទ្ធា ជាអ្នកទ្រុស្តសីលប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានសីល[២] ដូច្នេះជាដើម ។ ពិតយ៉ាងនោះ សូម្បីមាតាបង្កើត ក៏មិនអាចនឹងយកចិត្តគេបាន ព្រោះហេតុនោះ លោកទើបពោលពាក្យនេះទុកថា បុគ្គលអ្នកឱ្យបច្ច័យជាច្រើនរទេះ ក៏មិនគប្បីញ៉ាំងសូម្បីសការៈ ៣ ទាំងនេះ គឺគំនរក្ងើង ១ មហាសមុទ្រ ១ បុគ្គលដែលប្រាថ្នាច្រើន ១ ឱ្យពេញបាន ។

បុគ្គលវៀរទោស មានភាពជាអ្នកប្រាថ្នាច្រើនពេកទៅជាដើម ទាំងនេះ ឱ្យឃ្វាតឆ្ងាយ ហើយមានសេចក្តីប្រាថ្នាលាក់គុណដែលមាន និងស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា ជាអ្នកប្រាថ្នាតិច ។ ព្រោះបុគ្គលនោះប្រាថ្នានឹងបិទ-ចាំងគុណ ដែលមាននៅក្នុងខ្លួន កាលមានសទ្ធា ក៏មិនប្រាថ្នាថា សូមអ្នកដឹង

១-អភិធម្មបិដក វិភង្គ លេខ ៨២ ទំព័រ ១៥៧ ។

២-អភិធម្មបិដក វិភង្គ លេខ ៨២ ទំព័រ ១៥៤ ។

យើងថាមានសទ្ធា កាលមានសីល ជាពហុស្សូត ពេញចិត្តទីស្ងាត់ ជាអ្នកប្រារព្ធ សេចក្តីព្យាយាម មានសតិតាំងមាំ មានចិត្តជាសមាធិ មានបញ្ញា ក៏មិនប្រាថ្នាថា អ្នកចូរដឹងយើងថា មានបញ្ញា ។ បុគ្គលប្រាថ្នាតិចនេះនោះ មាន ៤ ពួក គឺអ្នកប្រាថ្នាតិចក្នុងបច្ច័យ ១ អ្នកប្រាថ្នាតិចក្នុងធុតង្គ ១ អ្នកប្រាថ្នាតិចក្នុងបរិយត្តិ ១ អ្នកប្រាថ្នាតិចក្នុងអធិគម: (ការត្រាស់ដឹង) ១ ។ បណ្តាបុគ្គល ៤ ពួកនោះ អ្នកប្រាថ្នាតិចក្នុងបច្ច័យ ៤ ពិចារណាមើលអ្នកឱ្យបច្ច័យផង ទេយ្យធម៌ផង កម្ទាំងរបស់ខ្លួនផង ក៏ប្រសិនបើទេយ្យធម៌មានច្រើន ទាយកប្រាថ្នានឹងប្រគេនតិច ក៏ទទួលតិចដោយអំណាចទាយក ។ បើទេយ្យធម៌មានតិច ទាយកប្រាថ្នានឹងប្រគេនច្រើន ក៏ទទួលតិច ដោយអំណាចទេយ្យធម៌ ។ ប្រសិនបើ ទេយ្យធម៌មានច្រើន ទាំងទាយកក៏ប្រាថ្នានឹងប្រគេនច្រើន គួរនឹងដឹងកម្ទាំងរបស់ខ្លួន ហើយទទួលតែល្មមប្រមាណប៉ុណ្ណោះ ។ ក៏ភិក្ខុឃើញបែបនេះ រមែងធ្វើលាភដែលនៅមិនទាន់កើតឱ្យកើតឡើង រមែងធ្វើលាភដែលកើតឡើងហើយឱ្យរឹងមាំ ញ៉ាំងចិត្តទាយកទាំងឡាយឱ្យត្រេកអរ ។ ក៏អ្នកមិនប្រាថ្នានឹងឱ្យដឹងថា ការសមាទានធុតង្គមាននៅក្នុងខ្លួន ឈ្មោះថា អ្នកប្រាថ្នាតិចក្នុងធុតង្គ ។ បុគ្គលណាមិនប្រាថ្នា ដើម្បីនឹងឱ្យអ្នកដទៃដឹងថា ខ្លួនជាពហុស្សូត បុគ្គលនោះ ឈ្មោះថា អ្នកប្រាថ្នាតិចក្នុងបរិយត្តិ ។ ចំណែកបុគ្គលណាជាព្រះអរិយបុគ្គលថ្នាក់សោតាបន្នជាដើមរូបណាមួយ ក៏មិនប្រាថ្នានឹងឱ្យដើម្បីសព្រហ្មចារីដឹងថា ខ្លួនជាព្រះសោតាបន្នជាដើម បុគ្គលនោះ ឈ្មោះថា អ្នកប្រាថ្នាតិចក្នុងអធិគម: (ការត្រាស់ដឹង) ។ កថាដែលប្រព្រឹត្តទៅដោយអំណាចប្រកាសទោស និងអានិសង្សមានអាការជាអនេក និងដោយអំណាចប្រកាសទោសរបស់ឥច្ឆាចារ

ដែលមានភាពជាអ្នកប្រាថ្នាច្រើនជាដើម ជាបដិបក្ខចំពោះសេចក្តីប្រាថ្នាតិចនោះ ព្រមជាមួយវិធីមានការចង្អុលដល់សេចក្តីត្រេកអរ ការប្រាថ្នាតិចរបស់បុគ្គលដែលប្រាថ្នាតិចនេះ ឈ្មោះថា **អប្ចិច្ឆកថា** ដោយប្រការដូច្នេះ ។

បទថា **សន្ដុដ្ឋិ** ក្នុងពាក្យថា សន្ដុដ្ឋិកថានេះ បានដល់ សេចក្តីត្រេកអរនឹងរបស់ខ្លួន គឺនឹងរបស់ដែលខ្លួនបានមក ឈ្មោះថា **សន្ដុដ្ឋិ** ។ ម្យ៉ាងទៀត ការលះសេចក្តីប្រាថ្នាបច្ច័យដែលមិនស្មើ ហើយត្រេកអរបច្ច័យដែលស្មើ ឈ្មោះថា **សន្ដុដ្ឋិ** ។ ម្យ៉ាងទៀត សេចក្តីត្រេកអរដោយរបស់ដែលមាន គឺប្រាកដនៅ ឈ្មោះថា **សន្ដុដ្ឋិ** ។ សមដូចពាក្យដែលលោកពោលទុកថា អ្នកមិនសោកសៅចំពោះវត្ថុដែលជាអតីត មិនត្អូញត្អែរចំពោះវត្ថុដែលជាអនាគត ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយវត្ថុជាបច្ចុប្បន្ន លោកហៅថា អ្នកសន្ដោស ។

ម្យ៉ាងទៀត សេចក្តីត្រេកអរដោយបច្ច័យដោយវិធីដែលព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ ដោយញ្ញេយ្យធម៌ដោយប្រពៃ ឈ្មោះថា សន្ដុដ្ឋិ ដោយអត្ថថា បានដល់ សេចក្តីសន្ដោសក្នុងបច្ច័យតាមមានតាមបាន ។ សន្ដោសនោះ មាន ១២ យ៉ាង អ្វីខ្លះ គឺសេចក្តីសន្ដោសក្នុងចីវរមាន ៣ យ៉ាង គឺ **យថាលាភសន្ដោស ១ យថាពលសន្ដោស ១ យថាសារុប្បសន្ដោស ១** ។ សន្ដោសក្នុងបិណ្ឌបាតជាដើមក៏ដូចគ្នា ។

ក្នុងសន្ដោសទាំងនោះ មានសំវណ្ណនាដោយប្រភេទដូចតទៅនេះ

ភិក្ខុក្នុងធម្មវិន័យនេះ បានចីវរល្អក៏ដោយ មិនល្អក៏ដោយ លោកញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយចីវរនោះឯង មិនប្រាថ្នាចីវរដទៃ ដែលនឹងបាន ក៏

មិនទទួល អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា យថាលាភសន្តោសក្នុងចីវរ ។ តែគ្រាលោកទុព្វលភាពតាមប្រក្រតី ឬត្រូវការឈឺចាប់ និងជរាគ្របសង្កត់ លោកដណ្តប់ចីវរធ្ងន់រមែងលំបាក លោកផ្ទាស់ចីវរធ្ងន់នោះ នឹងភិក្ខុអ្នកពេញចិត្តស្មើគ្នា សូម្បីញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយចីវរស្រាល ក៏ឈ្មោះថា ជាអ្នកសន្តោសពិត អាការរបស់ភិក្ខុនោះ នេះឈ្មោះថា យថាលាភសន្តោសក្នុងចីវរ ។ ភិក្ខុមួយរូបទៀត បានចីវរមានតម្លៃច្រើនផ្ទាំង ផ្ទាំងណាមួយ មានចីវរសំពត់ថ្មីជាដើម គិតថា នេះសមគួរដល់ព្រះថេរៈអ្នកបួសយូរ នេះសមគួរដល់ព្រះថេរៈអ្នកជាពហុស្សូត នេះសមគួរដល់ព្រះថេរៈឈឺ នេះសមគួរដល់ព្រះថេរៈអ្នកមានលាភតិច ទើបប្រគេនដល់ព្រះថេរៈទាំងនោះ ហើយស្វែងរកសំពត់ដែលមានជាយពីគំនរសំរាមជាដើមដោយខ្លួនឯង ធ្វើសង្ឆាដិ ឬទទួលចីវរចាស់របស់លោកទាំងនោះមកគ្រង ក៏ចាត់ថាជាអ្នកសន្តោសដោយពិត ។ អាការរបស់ភិក្ខុនោះ នេះឈ្មោះថា យថាសារុប្បសន្តោសក្នុងចីវរ ។

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះបានបិណ្ឌបាតដែលមិនប្រណីត ឬប្រណីត លោកញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះឯង មិនប្រាថ្នាបិណ្ឌបាតដទៃ ដែលនឹងបានក៏មិនទទួល អាការរបស់ភិក្ខុនោះ នេះឈ្មោះថា យថាលាភសន្តោសក្នុងបិណ្ឌបាត ។ ក៏កាលភិក្ខុនោះអាពាធ បរិភោគបិណ្ឌបាតដែលមិនប្រណីត ដែលជារបស់ប៉ះពាល់ដល់សុខភាពតាមប្រក្រតី ឬប៉ះពាល់ដល់ជំងឺ ដល់ភាពជាអ្នកមានរោគធ្ងន់ លោកប្រគេនដល់ភិក្ខុអ្នកពេញចិត្តគ្នា បរិភោគភោជនដែលជាទីសប្បាយអំពីដៃរបស់ភិក្ខុ អ្នកពេញចិត្តគ្នានោះ ធ្វើសមណធម៌ ក៏ឈ្មោះថា ជាអ្នកសន្តោសពិត អាការរបស់ភិក្ខុនោះនេះ ឈ្មោះ

ថា យថាពលសន្ដោសក្នុងបិណ្ឌបាត ។ ភិក្ខុមួយរូបទៀត បានបិណ្ឌបាតដ៏ប្រណីត លោកគិតថា បិណ្ឌបាតនេះ សមគួរដល់ព្រះថេរៈអ្នកបួសយូរជាដើម ប្រគេនដល់ព្រះថេរៈទាំងនោះដូចចីវរដែរ ឬកាន់យកបាត្រដែលជារបស់ព្រះថេរៈទាំងនោះ ត្រាច់ទៅបិណ្ឌបាតដោយខ្លួនឯង ហើយធាន់អាហារលាយ ចាត់ថាជាអ្នកសន្ដោសពិត អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាសារុប្បសន្ដោសក្នុងបិណ្ឌបាត ។ ក៏សេនាសនៈដែលភិក្ខុក្នុងធម្មវិន័យនេះ នឹងជាទីពេញចិត្ត ឬមិនពេញចិត្តក៏ដោយ ដោយហោចទៅសូម្បីខ្ទមដែលប្រក់ដោយស្មៅក្ដី ដែលក្រាលដោយស្មៅក្ដី លោករមែងត្រេកអរដោយសេនាសនៈនោះឯង ឬសេនាសនៈដទៃដែលល្អជាង ដែលចូលមកដល់ទៀតក៏មិនទទួល អាការរបស់ភិក្ខុនោះ នេះឈ្មោះថា យថាលាភសន្ដោសក្នុងសេនាសនៈ ។ ក៏កាលលោកអាពាធមានរាងកាយទុព្វល បានសេនាសនៈដែលប៉ះពាល់តាមប្រក្រតី ឬប៉ះពាល់ដល់ការឈឺថ្កាត់ កាលនៅក៏មិនមានសេចក្ដីសុខស្រួល លោកប្រគេនសេនាសនៈនោះដល់ភិក្ខុអ្នកពេញចិត្តគ្នា ចេញទៅនៅក្នុងសេនាសនៈដែលជាសប្បាយ ជារបស់ភិក្ខុអ្នកពេញចិត្តគ្នានោះ ធ្វើសមណធម៌ ក៏ចាត់ថាជាអ្នកសន្ដោសពិត អាការរបស់ភិក្ខុនោះ នេះឈ្មោះថា យថាពលសន្ដោសក្នុងសេនាសនៈ ។ ភិក្ខុមួយរូបទៀត មិនទទួលសេនាសនៈដែលល្អ សូម្បីដែលចូលដល់ដោយគិតថា សេនាសនៈនេះជារបស់ប្រណីត ជាទីតាំងនៃសេចក្ដីប្រមាទ ឬបានសេនាសនៈដ៏ប្រណីតមានណ្ដាង មណ្ដប និងកូដាគារជាដើម ព្រោះតម្លៃដែលលោកមានបុណ្យច្រើន លោកប្រគេនសេនាសនៈទាំងនោះ ដល់ព្រះថេរៈអ្នកបួសយូរជាដើមដូចចីវរជាដើម ដែលនឹងនៅក្នុងទីណានីមួយ ក៏ចាត់ថាជាអ្នកសន្ដោសដោយពិត អាការរបស់ភិក្ខុនោះ នេះឈ្មោះថា យថាសារុប្បសន្ដោសក្នុងសេនាសនៈ ។

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានកេសជ្ជៈមិនប្រណីត ឬប្រណីត លោកត្រេកអរដោយកេសជ្ជៈនោះឯង មិនប្រាថ្នាកេសជ្ជៈដទៃ ដែលនឹងបានក៏មិនទទួល អាការរបស់ភិក្ខុនោះ នេះឈ្មោះថា យថាលាភសន្តោសក្នុងគិលានប្បច្ច័យ ។ ក៏កាលលោកត្រូវការប្រេង បានទឹកអំពៅ លោកប្រគេនទឹកអំពៅនោះ ដល់ភិក្ខុអ្នកពេញចិត្តគ្នា កាន់យកកេសជ្ជៈអំពីដៃរបស់ភិក្ខុអ្នកពេញចិត្តគ្នានោះ ធ្វើសមណធម៌ ក៏ចាត់ថាជាអ្នកសន្តោសដោយពិត អាការរបស់ភិក្ខុនោះ នេះឈ្មោះថា យថាពលសន្តោសក្នុងគិលានប្បច្ច័យ ។ ភិក្ខុមួយរូបទៀត មានបុណ្យច្រើន បានកេសជ្ជៈដ៏ប្រណីត មានប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើមជាច្រើន លោកប្រគេនកេសជ្ជៈនោះដល់ព្រះថេរៈអ្នកបួសយូរជាដើម ដូចចីវរជាដើម ប្រកបកេសជ្ជៈដោយវត្ថុយ៉ាងណាមួយ ដែលខ្លួនបានមកដល់ព្រះថេរៈទាំងនោះ ក៏ចាត់ថាជាអ្នកសន្តោសដោយពិត ចំណែកភិក្ខុណាដាក់សម៉ត្រាំ ដោយទឹកមូត្រស្អុយក្នុងភាជនៈមួយ ដាក់ចតុមធុរសទុកក្នុងភាជនៈមួយ កាលគេនិយាយថា វត្ថុណាដែលលោកត្រូវការ ទទួលយកទៅចុះ បើពោតរបស់លោករម្ងាប់ទៅដោយកេសជ្ជៈណាមួយ បណ្ដាកេសជ្ជៈទាំងនោះ លោករឭកដល់ពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ថា ឈ្មោះថា សម៉ត្រាំដោយទឹកមូត្រស្អុយនេះ បណ្ឌិតមានព្រះពុទ្ធជាដើម សរសើរហើយ បព្វជ្ជាអាស្រ័យកេសជ្ជៈដែលលាយដោយទឹកមូត្រស្អុយ បព្វជ្ជាត្រូវអាស្រ័យនូវថ្នាំ ដែលត្រាំដោយទឹកមូត្រ អ្នកឯងត្រូវធ្វើសេចក្ដីឧស្សាហ៍ក្នុងថ្នាំនោះដរាបដល់អស់ជីវិត[1] ទើបហាម

១-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ១៧៦ ។

ចតុមធុរសប្រកបកេសជ្ជ: ដោយសម័ត្រាំដោយទឹកមូត្រស្អុយ ចាត់ថាជាអ្នកសន្ដោស យ៉ាងក្រៃលែងតែម្ដង អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា យថាសារុ-ប្ប សន្ដោសក្នុងគិលានប្បច្ច័យ ។

សន្ដោសទាំងអស់ ដែលមានប្រភេទ ដូចពោលហើយនោះ លោកហៅថា **សន្ទុដ្ឋី** ។ ព្រោះហេតុនោះ លោកទើបពោលថា ដោយអត្ថ ក៏គឺឥតវិតរ-ប ច្ច យ សន្ដោស សន្ដោសដោយបច្ច័យតាមមានតាមបាន ។ កថាដែលប្រព្រឹត្ដទៅ ដោយអំណាចប្រកាសអានិសង្សរបស់សន្ទុដ្ឋិនោះ ព្រមនឹងវិធីដែលចង្អុលជាដើម និងដោយអំណាចប្រកាសទោសរបស់ភិក្ខុអ្នកធ្លាក់នៅក្នុងចំណង់ ដែលផ្សេងដោយសេចក្ដីប្រាថ្នាពេកទៅជាដើម ដែលជាបដិបក្ខចំពោះសេចក្ដីសន្ដោសនោះ ឈ្មោះថា **សន្ទុដ្ឋិកថា** ។ សូម្បីក្នុងកថាដទៃអំពីនេះ ក៏នយនេះដូចគ្នា ។ ខ្ញុំនឹងពោលត្រឹមតែសេចក្ដីប្ដូរគ្នាប៉ុណ្ណោះ ។

វិវេក ក្នុងបទថា **បវិវេককথា** នេះ មាន ៣ យ៉ាង គឺ**កាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១** ។ បណ្ដាវិវេកទាំង ៣ យ៉ាងនោះ ភាវៈនៃភិក្ខុលុះការនៅច្របូកច្របល់ដោយពួកហើយនៅស្ងាត់ក្នុងកិច្ចទាំងពួង គ្រប់ឥរិយាបថ យ៉ាងនេះ គឺភិក្ខុមួយអង្គនិមន្ដដើរ ភិក្ខុមួយអង្គគង់ ភិក្ខុមួយអង្គសឹង ភិក្ខុមួយអង្គចូលស្រុកដើម្បីបិណ្ឌបាត ភិក្ខុមួយអង្គត្រឡប់មកពីបិណ្ឌបាត ភិក្ខុមួយអង្គឈានទៅ ភិក្ខុមួយអង្គអធិដ្ឋានទីចង្ក្រម ភិក្ខុមួយអង្គត្រាច់ទៅ ភិក្ខុមួយអង្គនៅ ឈ្មោះថា **កាយវិវេក** ។ ម្យ៉ាងទៀត សមាបត្ដិ ៨ ឈ្មោះថា **ចិត្ដវិវេក** ។ ព្រះនិព្វាន ឈ្មោះថា **ឧបធិវិវេក** ។ សមដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា

កាយវិវេក (កើតមាន) ដល់ពួកបុគ្គលដែលចេញចាកពួក ត្រេកអរក្នុងការចេញចាកកាមផង ចិត្តវិវេក (កើតមាន) ដល់ពួកបុគ្គលដែលមានចិត្តបរិសុទ្ធ ដល់នូវសេចក្តីផូរផង់ក្រៃលែងផង ឧបធិវិវេក (កើតមាន) ដល់ពួកបុគ្គលដែលមិនមានកិលេស ដល់នូវព្រះនិព្វាន ដែលប្រាសចាកសង្ខារផង[1] ។ វិវេកនោះឯង គឺ បរិវេក ។ កថាដែលជាប់ដោយសេចក្តីស្ងាត់ ឈ្មោះថា បរិវេកកថា ។

សំសត្តា *ក្នុងបទថា* ***អសំសត្តកថា*** *នេះ មាន ៥ យ៉ាង គឺ* ***សវនសំ-សគ្គ: ១ ទស្សនសំសគ្គ: ១ សមុល្លបនសំសគ្គ: ១ សម្ភោគសំសគ្គ: ១ កាយសំសគ្គ: ១*** *។ បណ្តាសំសគ្គ:ទាំង ៥ យ៉ាងនោះ ភិក្ខុរូបខ្ញុះក្នុងធម្មវិន័យនេះ បានឮថា ស្ត្រីក្នុងស្រុក ឬក្នុងនិគមឯណោះ មានរូបល្អ គួរសរសើរ គួរជ្រះថ្លា ប្រកបដោយភាពជាអ្នកមានពណ៌សម្បុរកាយល្អយ៉ាងក្រៃលែង ភិក្ខុណាបានឮដូច្នោះហើយ (មានចិត្ត) ជ្រួតជ្រាបទៅ ផ្សាយទៅ មិនអាចនឹងតម្រង់ព្រហ្មចរិយ:នៅបាន ទើបលាសិក្ខាជាគ្រហស្ថ សេចក្តីស្និទ្ធស្នាលដោយកិលេសកើតឡើង ដោយបានស្តាប់វិសភាគារម្មណ៍ដោយអាការយ៉ាងនេះ ឈ្មោះថា* ***សវនសំសគ្គ:*** *។ ភិក្ខុមិនបានស្តាប់ដូច្នោះទេ លោកមែងឃើញស្ត្រីល្អឯកគួរមើល គួរជ្រះថ្លា ប្រកបដោយពណ៌កាយស្រស់ល្អយ៉ាងក្រៃលែង ភិក្ខុត្រឹមតែឃើញប៉ុណ្ណោះ (មានចិត្ត) ជ្រួតជ្រាបទៅ ផ្សាយទៅ មិនអាចនឹងតម្រង់ព្រហ្មចរិយ:នៅបាន ទើបលាសិក្ខាជាគ្រហស្ថ សេចក្តីស្និទ្ធស្នាលដោយកិលេសដែលកើតឡើង ព្រោះបានឃើញវិសភាគារម្មណ៍ ដោយអាការយ៉ាងនេះ ឈ្មោះថា*

១-សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស លេខ ៦៤ ទំព័រ ៤៩ ។

ទស្សនសំសគ្គៈ ។ ក៏ព្រោះបានឃើញស្ត្រីនោះហើយ សេចក្តីស្និទ្ធស្នាលដោយកិលេសកើតឡើងដល់ភិក្ខុនោះ ដោយការចរចាប្រាស្រ័យគ្នានឹងគ្នា ឈ្មោះថា ***សមុល្លបនសំសគ្គៈ*** ។ ដោយការចរចាប្រាស្រ័យនេះឯង ទើបចូលរួមនឹងការចំអកលេងជាដើមក៏បាន ។ ក៏ព្រោះវត្ថុណាមួយជារបស់ខ្លួនដែលឱ្យក៏ដោយ មិនឱ្យក៏ដោយដល់មាតុគ្រាម សេចក្តីស្និទ្ធស្នាលដោយកិលេសកើតឡើងដោយការឱ្យវត្ថុដែលមានតម្លៃដែលខ្លួនឱ្យជាដើម ឈ្មោះថា ***សម្ភោគសំសគ្គៈ*** ។ សេចក្តីស្និទ្ធស្នាលដោយកិលេសកើតឡើងដល់ភិក្ខុនោះ ដោយការចាប់ដៃមាតុ-គ្រាមជាដើម ឈ្មោះថា ***កាយសំសគ្គៈ*** ។ ការដែលភិក្ខុនោះ លុះសេចក្តីច្រឡូក-ច្រឡំដោយគ្រហស្ថ ដែលមិនប្រព្រឹត្តទៅតាមអនុលោម និងការច្រឡូក-ច្រឡំដែលជាហេតុកើតកិលេសនឹងសម្ងាញ់សព្រហ្មចារីទាំងឡាយ ដែលព្រះដ៏-មានព្រះភាគត្រាស់ទុកយ៉ាងនេះថា ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកច្រឡូក-ច្រឡំ ដោយគ្រហស្ថទាំងឡាយ មានសេចក្តីរីករាយជាមួយ មានសោកជាមួយ កាលបើគ្រហស្ថទាំងឡាយដល់នូវសុខ ក៏ដល់នូវសុខ កាលបើគ្រហស្ថទាំងឡាយដល់នូវទុក្ខ ក៏ដល់នូវទុក្ខ កាលបើកិច្ចការដែលគ្រហស្ថទាំងឡាយ គប្បីធ្វើកើតឡើងហើយ ក៏ដល់នូវការចូលទៅប្រកប (ជួយ) ដោយខ្លួនឯង[1] ដូច្នេះ ទាំងអស់ចេញបាន ចូលទៅតាំងចំពោះនូវធម៌ទាំងពួង គឺសេចក្តីសង្វេគក្នុងសង្ឃារដែលរឹងមាំជាង សេចក្តីសម្គាល់ក្នុងវត្ថុដែលមានសង្ហារថា ជាកំ‌យយ៉ាងខ្ជាំងក្លា សេចក្តីសម្គាល់ក្នុងវាងកាយថា ជាវត្ថុបដិកូល មានហិរិ និងឱ្ចិត្តប្ប:

១-សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស លេខ ៦៥ ទំព័រ ៣៣ ។

ដែលមានការស្អប់អកុសលទាំងអស់ជាហេតុខាងមុខ ទាំងមានសតិ និងសម្បជញ្ញៈ ក្នុងការធ្វើគ្រប់យ៉ាង ហើយមិនមានសេចក្តីជាប់ជំពាក់ក្នុងធម៌ទាំងពួង ដូចតំណក់ទឹកមិនជាប់លើស្លឹកឈូកដូច្នោះនេះ ឈ្មោះថា **អសំសគ្គៈ** ព្រោះជាបដិបក្ខចំពោះអសំសគ្គៈទាំងពួង ។ កថាដែលជាប់ដោយអសំសគ្គៈ ឈ្មោះថា **អសំសគ្គកថា** ។

ក្នុងបទថា **វិរិយារម្ភកថា** នេះ មានវិនិច្ឆ័យដូចតទៅនេះ ។ ភាវៈនៃបុគ្គលដែលក្ងៀវក្ងា ឬកម្មនៃបុគ្គលដែលក្ងៀវក្ងា ព្រោះដូច្នោះ ទើបឈ្មោះថា **វិរិយៈ** ម្យ៉ាងទៀត ឈ្មោះថា **វិរិយៈ** ព្រោះបុគ្គលគប្បីឱ្យដំណើរទៅ គឺគប្បីឱ្យប្រព្រឹត្តទៅតាមវិធី ក៏សេចក្តីព្យាយាមនោះផង ការប្រារព្ធសេចក្តីព្យាយាមដើម្បីលះអកុសលធម៌នោះផង និងញុំាងកុសលធម៌ឱ្យកើតឡើង ឈ្មោះថា **វិរិយារម្ភៈ** ។ វិរិយារម្ភៈនោះ មាន ២ យ៉ាង គឺប្រព្រឹត្តទៅតាមផ្លូវកាយ ១ ប្រព្រឹត្តទៅតាមផ្លូវចិត្ត ១ ។ មាន ៣ យ៉ាង គឺ**អារម្ភធាតុ ១ និក្កមធាតុ ១ បរក្កមធាតុ ១** ។ មាន ៤ យ៉ាងដោយអំណាចសម្មប្បធាន ៤ ។ វិរិយារម្ភៈទាំងអស់នោះ គប្បីជ្រាបដោយអំណាចការប្រារព្ធសេចក្តីព្យាយាមយ៉ាងនេះ របស់ភិក្ខុអ្នកមិនឱ្យកិលេសដែលកើតឡើងក្នុងពេលដើរ មិនឱ្យកិលេសកើតឡើងក្នុងពេលឈរ ឬអង្គុយ មិនឱ្យកិលេសកើតឡើងក្នុងពេលដេក គ្របសង្កត់ដោយកម្លាំងសេចក្តីព្យាយាម មិនឱ្យងើយសីសៈឡើងបានក្នុងឥរិយាបថនោះ។ ដូចមនុស្សយកឈើមានលក្ខណៈដូចជើងពពែសង្កត់ពស់វែក និងដូចជាយកដាវដ៏មុតប្រហារសត្វត្រង់-កដូច្នោះ ។ កថាដែលជាប់ដោយវិរិយារម្ភៈនោះ ឈ្មោះថា **វិរិយារម្ភកថា** ។

សីលក្នុងបទថា **សីលកថា** ជាដើម មាន ២ យ៉ាង គឺលោកិយសីល ១ លោកុត្តរសីល ១ ។ បណ្ដាសីល ២ យ៉ាងនោះ លោកិយសីល បានដល់ ចតុបារិសុទ្ធិសីល មានបាតិមោក្ខសំវរសីលជាដើម ។ លោកុត្តរសីល បានដល់ មគ្គសីល និងផលសីល ។ ម្យ៉ាងទៀត សមាបត្តិ ៨ ព្រមដោយឧបចារៈដែលជាបាទនៃវិបស្សនា ឈ្មោះថា លោកិយសមាធិ ។ ក៏ក្នុងទីនេះ សមាធិដែលសម្បយុត្តដោយមគ្គ ឈ្មោះថា លោកុត្តរសមាធិ ។ ចំណែកបញ្ញាក៏ដូចគ្នា ដែលសម្រេចដោយការស្ដាប់ សម្រេចដោយការគិត ដែលសម្បយុត្តដោយ ឈាន និងវិបស្សនាញាណ ចាត់ជាលោកិយបញ្ញា តែក្នុងទីនេះ កាលពោលអំពីពិសេសគឃ្ជីប្រកាន់យកវិបស្សនាបញ្ញា ។ បញ្ញាដែលសម្បយុត្តដោយមគ្គ និងផល ចាត់ជាលោកុត្តរបញ្ញា ។ សូម្បីវិមុត្តិ ក៏បានដល់វិមុត្តិដែលសម្បយុត្ត ដោយអរិយផល និងនិព្វាន ។ ចំណែកអាចារ្យមួយពួកទៀត ពណ៌នាសេចក្ដីក្នុងសេចក្ដីនេះទុក ដោយអំណាចតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ និងសមុច្ឆេទវិមុត្តិ ។ សូម្បីវិមុត្តិញាណទស្សនៈ ក៏បានដល់ បច្ចវេក្ខណញ្ញាណ ១៩ ។ កថាដែលប្រព្រឹត្តទៅដោយអំណាចការប្រកាសទោស និងអានិសង្ស មានអាការជាអនេកនៃគុណមានសីលជាដើមទាំងនេះ ព្រមដោយវិធីមានការចង្អុលបង្ហាញជាដើម និងដោយអំណាចការប្រកាសទោសនៃភាពជាអ្នកទ្រុស្ដសីលជាដើម ដែលជាសត្រូវចំពោះគុណមានសីល ជាដើមនោះ ឬកថាដែលជាប់ដោយអានិសង្ស និងទោសរបស់សីលនោះ ឈ្មោះថា សីលាទិកថាជាដើម ។

ក៏ក្នុងទីនេះ ព្រោះបាលីមានជាអាទិ៍ថា ភិក្ខុក្នុងសាសនានេះ ជាអ្នក

ប្រាជ្ញាតិច ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីប្រាជ្ញាតិច ដល់ភិក្ខុទាំងឡាយផង[1] និងឈ្មោះថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលសន្តោសដោយចីវរ តាមមានតាមបានផង ថ្វែងគុណសន្តោសដោយចីវរ តាមមានតាមបានផង[2] កថាបែបនោះ ដែលភិក្ខុអ្នកប្រកបដោយគុណ មានភាពជាអ្នកប្រាជ្ញាតិចជាដើមដោយខ្លួនឯង គប្បីឱ្យប្រព្រឹត្តទៅតាមអធ្យាស្ស័យ ជួយសង្គ្រោះ សូម្បីដល់ជនដទៃ ដើម្បីប្រយោជន៍ដល់សេចក្តីប្រាជ្ញាតិច និងសន្តោសនោះ ដែលលោកពោលទុកដោយពិសេស ដោយភាពជាអ្នកដុសខាត់យ៉ាងក្រៃលែងជាដើម ក្នុងទីនេះ គប្បីជ្រាបថា កថាពោលអំពីសេចក្តីប្រាជ្ញាតិចជាដើម ។ មែនពិត កថារបស់អ្នកធ្វើនុ៎ះឯង រមែងធ្វើប្រយោជន៍តាមដែលប្រាជ្ញាឱ្យសម្រេចដោយពិសេស ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលមេឃិយ: នេះជាសេចក្តីប្រាជ្ញារបស់ភិក្ខុជាកល្យាណមិត្ត ។ល។ ជាការបានដោយមិនលំបាក ។

បទថា **ឯវមេតាយ** បានដល់ ដូច្នេះ គឺតាមដែលពោលហើយ ។ បទថា **និកាមលាភី** សេចក្តីថា ជាអ្នកបានតាមប្រាថ្នា គឺបានតាមសេចក្តីពេញចិត្ត បានដល់ បានតាមសប្បាយដើម្បីនឹងស្តាប់ និងពិចារណាកថាទាំងនេះគ្រប់ពេល ។ បទថា **អកិច្ឆលាភី** បានដល់ ជាអ្នកបានដោយមិនលំបាក ។ បទថា **អកសិរលាភី** បានដល់ ជាអ្នកបានដោយបរិបូណ៌ ។

បទថា **អារទ្ធវីរិយោ** បានដល់ ផ្គងសេចក្តីព្យាយាមទុក ។ បទថា **អកុ-សលានំ ធម្មានំ បហានាយ** បានដល់ ដើម្បីនឹងលះបាបធម៌

---

[1]-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ២៨២ ។

[2]-សុត្តន្តបិដក ខុទ្ទកនិកាយ ចូឬនិទ្ទេស លេខ ៦៨ ទំព័រ ២៣៩ ។

ដែលឈ្មោះថា អកុសល ព្រោះអត្ថថា កើតពីភាពជាអ្នកមិនធ្វាត ។ បទថា **កុសលានំ ធម្មានំ** បានដល់ ធម៌ដែលសម្បយុត្តដោយមគ្គ និងផលព្រមទាំងវិបស្សនា ដែលឈ្មោះថា **កុសល** ព្រោះអត្ថថា កាត់បាបធម៌ដែលបណ្ឌិតស្អប់ជាដើម និងព្រោះអត្ថថា មិនមានទោស ។ បទថា **ឧបសម្ផាយ** បានដល់ ឱ្យដល់ព្រម គឺឱ្យកើតឡើងក្នុងសន្ធានរបស់ខ្លួន ។ បទថា **ថាមវា** បានដល់ អ្នកប្រកបដោយកម្លាំងសេចក្តីព្យាយាមពោលគឺ សេចក្តីឧស្សាហ៍ ។ បទថា **ឧជ្ជុបវ្ហោ** បានដល់ មានសេចក្តីព្យាយាមមាំ គឺមានសេចក្តីព្យាយាមមិនធូររលុង ។ បទថា **អនិក្ខិត្តធុរោ** បានដល់មិនលះចោលធុរៈ គឺមានសេចក្តីព្យាយាមមិនថមថយ ។

បទថា **បញ្ញវា** បានដល់ អ្នកមានបញ្ញា ដោយបញ្ញាដែលសម្បយុត្តដោយវិបស្សនា ។ បទថា **ឧទយត្ថគាមិនិយា** បានដល់ ចាក់ធ្ងុនូវការកើតឡើងនិងការរលត់ទៅនៃបញ្ចខន្ធ ។ បទថា **អរិយាយ** បានដល់ ឃ្វាតធ្វាយ គឺតាំងនៅក្នុងទីធ្វាយចាកកិលេស ដោយអំណាចវិក្ខម្ភនវិមុត្តិ គឺប្រាសចាកទោស ។

បទថា **និព្ពេធិកាយ** ប្រែថា ជាចំណែកនៃការត្រាស់ដឹង ។ បទថា **សម្មា ទុក្ខក្ខយគាមិនិយា** បានដល់ សម្រេចដោយប្រពៃ គឺដោយហេតុដោយញ្ញាណដែលអរិយមគ្គ ដែលបានឈ្មោះថា **ទុក្ខក្ខយៈ** ព្រោះធ្វើវដ្តទុក្ខឱ្យអស់ទៅ ។

ក៏ធម៌ទាំង ៥ ប្រការនេះ គឺសីល វីរិយៈ និងបញ្ញា ជាអង្គប្រកបខាងក្នុង ២ អង្គក្រៅនេះ ជាអង្គប្រកបខាងក្រៅសម្រាប់ព្រះយោគី សូម្បីយ៉ាងនោះ ព្រះយោគីក៏នូវប្រាជ្ញាធម៌ ៤ ប្រការក្រៅនោះ ដោយជាទីអាស្រ័យរបស់កល្យាណមិត្តនុ៎ះឯង ។

ក្នុងទីនេះ ព្រះសាស្តាកាលទ្រង់សម្តែងថា កល្យាណមិត្តនុ៎ះឯងជាអ្នកមានឧបការៈច្រើន ទើបទ្រង់បន្ថែមព្រះធម៌ទេសនាដោយន័យមានជាអាទិ៍ថា ម្នាលមេឃិយៈ ប្រការនេះភិក្ខុអ្នកមានកល្យាណមិត្តគប្បីប្រាជ្ញ ។

បណ្តាបទទាំងនោះ បទថា **ចាដិកង្ខំ** ប្រែថា គប្បីប្រាជ្ញាដោយចំណែកតែមួយ អធិប្បាយថា មានការៈពិតប្រាកដ ។ បទថា **យំ** ជាកិរិយាបរាមាសៈ ។ លោកអធិប្បាយពាក្យនេះថា ក្នុងពាក្យថា **សីលវា ភវិស្សតិ** នេះមានអធិប្បាយថា ភាពដែលភិក្ខុអ្នកមានមិត្តល្អ ។ មានសីល គឺដល់ព្រមដោយសីលនោះ គប្បីប្រាជ្ញ ព្រោះភិក្ខុនោះជាអ្នកដល់ព្រមដោយសីល គឺជាអ្នកមានការៈពិតប្រាកដ ព្រោះបបួលកល្យាណមិត្តក្នុងសេចក្តីនោះ ដោយពិតប្រាកដតែម្តង ។ សម្បីក្នុងពាក្យថា **ចាតិមោក្ខសំវរសំវុតោ វិហរិស្សតិ** ដូច្នេះជាដើមក៏ន័យនេះដូចគ្នា ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងសាសនសម្បត្តិទាំងអស់ ដោយភាពជាអ្នកមានកល្យាណមិត្តជាដើម តែព្រះមេឃិយៈអ្នកមិនអើពើនឹងព្រះតម្រាស់របស់ព្រះអង្គ ទ្រង់ជាកល្យាណមិត្តដ៏ឧត្តមក្នុងលោក ព្រមទាំងទេវលោក ហើយចូលទៅកាន់ព្រៃស្រោងនោះ ដល់ប្រការដែលប្លែកដូច្នោះ ឥឡូវនេះ ទើបទ្រង់ប្រកាសការនាន័យ ដល់លោកអ្នកកើតសេចក្តីអើពើក្នុងព្រៃស្រោងនោះ ព្រោះលោកត្រូវកាមវិតក្កៈជាដើមប្រទូស្ត្រ៉ាយក្នុងគ្រាមុន និងព្រោះកាមវិតក្កៈជាដើមទាំងនោះជាសត្រូវដោយត្រង់កម្មដ្ឋាន ទើបមិនសម្រេចដល់លោក តអំពីនោះ កាលនឹងត្រាស់ប្រាប់កម្មដ្ឋាននៃព្រះអរហត្ត ទើបត្រាស់ពាក្យមានជាអាទិ៍ថា ម្នាលមេឃិយៈ ក៏ឯភិក្ខុនោះគប្បីតាំងនៅក្នុងធម៌ ៥ ប្រការនេះ ហើយគប្បីចម្រើនឱ្យក្រៃលែងនូវធម៌ ៤ ប្រការនេះ ។ បណ្តាបទទាំងនោះ បទថា **តេន** បានដល់

អ្នកប្រកបដោយគុណ មានសីលជាដើម តាមដែលពោលហើយ ដោយមានកល្យាណមិត្តជាទីអាស្រ័យយ៉ាងនេះ ។ ព្រោះហេតុនោះនុ៎ះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា តាំងនៅក្នុងធម៌ ៥ ប្រការទាំងនេះជាដើម ។ បទថា **ឧត្តរិ** សេចក្ដីថា បើអន្ដរាយមានរាគៈជាដើម គប្បីកើតឡើងដល់អ្នកប្រារព្ធតវុណ-វិបស្សនា ដើម្បីនឹងជម្រះអន្ដរាយទាំងនោះ ឱ្យហ្មត់ចត់ បន្ទាប់អំពីនោះ ត្រឹមតែចម្រើន គឺធ្វើឱ្យកើត និងគប្បីឱ្យច្រើនឡើងនូវធម៌ ៤ ប្រការនោះ ។

បទថា **អសុភា** បានដល់ ចម្រើនអសុភកម្មដ្ឋានយ៉ាងណាមួយ តាមសមគួរ បណ្ដាអសុភកម្មដ្ឋានទាំង ១១ ។ បទថា **ភគ្ឍ្ឍ បហានាយ** បានដល់ ដើម្បីលះកាមរាគៈ ។ បណ្ឌិតគប្បីប្រកាសសេចក្ដីនេះ ដោយឧបមាដូចជាបុគ្គលដែលច្រូតស្រូវសាលី ។ មែនពិត បុរសម្នាក់កាន់កណ្ដៀវ ច្រូតស្រូវ-សាលីក្នុងស្រែ តាំងពីទីបំផុតទៅ កាលគោទម្ងាយរបងចូលទៅ ម្ចាស់ស្រែក៏ដាក់កណ្ដៀវ ហើយកាន់ឈើដេញគោឱ្យចេញទៅដោយផ្លូវនោះនុ៎ះឯង ហើយធ្វើរបងឱ្យដូចពីដើម ហើយកាន់កណ្ដៀវច្រូតស្រូវសាលីទៀត ។

ក្នុងឧបមាប្រការនោះ គប្បីជ្រាបយ៉ាងនេះថា ព្រះពុទ្ធសាសនា ដូចស្រែស្រូវសាលី ព្រះយោគាវចរដូចអ្នកច្រូតស្រូវ មគ្គបញ្ញាដូចកណ្ដៀវ វេលាធ្វើកម្មក្នុងវិបស្សនា ដូចវេលាច្រូត អសុភកម្មដ្ឋានដូចឈើ សំវរៈដូចរបង ការដែលរាគៈកើតឡើងព្រោះអាស្រ័យសេចក្ដីប្រមាទ ដោយមិនពិចារណាពេលភ្ជាមនោះ ដូចការដែលគោទាំងឡាយទម្ងាយរបងចូលទៅ វេលាដែលគ្របសង្កត់រាគៈ ដោយអសុភកម្មដ្ឋាន ហើយផ្ដើមធ្វើកម្មក្នុងវិបស្សនាទៀត គប្បីឃើញ

ដូចអ្នកច្រូតស្រូវដាក់កណ្តៀវ ហើយកាន់ឈើដេញគោ ឱ្យចេញទៅតាមផ្លូវដែលចូលនុ៎ះឯង ធ្វើរបង១ឱ្យដូចពីដើមហើយច្រូតស្រូវតាំងពីកន្ទែងដែលខ្ជួនឈរទៀត ក្នុងសេចក្តីនេះ មានឧបមាដូចពោលមកដូច្នេះ ។ ពាក្យនេះព្រះដ៏-មានព្រះភាគទ្រង់សំដែងយកការនាវិធី ដូចដែលពោលមកនេះ ទើបត្រាស់ថា គប្បីចម្រើនអសុភ:ដើម្បីលះរាគ: ។

បទថា **មេត្តា** បានដល់ កម្មដ្ឋានមានមេត្តាជាអារម្មណ៍ ។ បទថា **ព្យាបាទស្ស បហានាយ** បានដល់ ដើម្បីលះសេចក្តីក្រោធដែលកើតឡើងដោយន័យដូចពោលហើយនុ៎ះឯង ។ បទថា **អានាបានស្សតិ** បានដល់ អានាបានស្សតិដែលមានវត្ថុ ១៦ ។ បទថា **វិតក្ក**ុ**ប**ច្ឆេ**ទ**ាយ បានដល់ ដើម្បីកាត់វិតក្ក:ដែលកើតឡើងហើយ ដោយន័យដូចពោលហើយនុ៎ះឯង ។ បទថា **អស្មិ**ានសមុ**ក្ឃ**ាតាយ បានដល់ ដើម្បីដកមាន: ៩ យ៉ាង ដែលកើតឡើងថា អញមាន ។ បទថា **អនិ**ច្ចសញ្ញ**ិ**នោ បានដល់ អ្នកមានសេចក្តីសម្គាល់ថាមិនទៀង ដោយអនិច្ចានុបស្សនាដែលប្រព្រឹត្តទៅថា សង្ខារទាំងពួង ឈ្មោះថាមិនទៀង ព្រោះមានហើយត្រឡប់ជាមិនមានវិញ ព្រោះមានការកើតឡើងនិងរលត់ទៅជាទីបំផុត ព្រោះមានការបែករលត់ ព្រោះប្រព្រឹត្តទៅតាមកាល ព្រោះបដិសេធភាពជារបស់ទៀង ។ បទថា **អនត្ត**សញ្ញ**ា** ស**ណ្ឋ**ាតា បានដល់ អនត្តសញ្ញា ពោលគឺ អនត្តានុបស្សនា ដែលប្រព្រឹត្តទៅយ៉ាងនេះថា ធម៌ទាំងពួងឈ្មោះថា ជាអនត្តា ព្រោះមិនមានខ្លឹមសារ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះជារបស់ដទៃ ព្រោះជារបស់ទទេ ព្រោះជារបស់ឥតបានការ និងព្រោះសោះសូន្យ រមែងមិនតាំងនៅ គឺមិនតាំងមាំនៅក្នុងចិត្ត ។

មែនពិត កាលឃើញអនិច្ចលក្ខណៈ ក៏ឈ្មោះថា ឃើញអនត្តលក្ខណៈដូចគ្នា ។ ក៏បណ្តាលក្ខណៈទាំង ៣ កាលឃើញលក្ខណៈមួយ ក៏ឈ្មោះថា ឃើញលក្ខណៈ ២ យ៉ាងក្រៅអំពីនេះដូចគ្នា ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមេឃិយៈ ក៏អនត្តសញ្ញា រមែងតាំងនៅដល់អ្នកមានសេចក្តីសម្គាល់ក្នុងសង្ខារថា ជារបស់មិនទៀង ។ កាលឃើញអនត្តលក្ខណៈមានៈដែលកើតឡើងថា អញមាន ក៏ឈ្មោះថា លះបានដោយល្អនុ៎ះឯង ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា អ្នកមានសេចក្តីសម្គាល់ក្នុងសង្ខារថា ជាអនត្តា រមែងដល់ការដកអស្មិមានៈចេញបាន ។ បទថា **ឥជ្ជេវ ធម្មេ និព្ពានំ** សេចក្តីថា រមែងសម្រេចការបរិនិព្វានដែលរកបច្ច័យមិនបាន ក្នុងបច្ចុប្បន្ននេះឯង គឺក្នុងអត្តភាពនេះឯង ។ ក្នុងទីនេះមានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណោះ តែកាលពោលអំពីពិស្តារន័យនៃការនាដែលពោលអំពីអសុភកម្មដ្ឋានជាដើម បណ្ឌិតគប្បីជ្រាបដោយន័យដែលសម្តែងទុកក្នុងគម្ពីរវិសុទ្ធិមគ្គ[១] ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបសេចក្តីនេះ ពោលគឺ ការដែលព្រះមេឃិយៈដ៏មានអាយុត្រូវពួកចោរ គឺមិច្ឆាវិតក្កៈបួនកណ្ឌៈ គឺកុសល ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឹមឧទាននេះដែលសម្តែងទោសក្នុងការមិនបន្ទោបង់កាមវិតក្កៈជាដើម និងអានិសង្សក្នុងការបន្ទោបង់កាមវិតក្កៈជាដើម ។ បណ្តាបទទាំងនោះ បទថា **ឧជ្ជា** បានដល់ អាក្រក់ គឺលាមក ។ បទថា **វិតក្កា** បានដល់ បាបវិតក្កៈ (អកុសលវិតក្ក) ៣ មានកាមវិតក្កៈជាដើម ។ ក៏អកុសល-

---

១-វិសុទ្ធមគ្គបាលី ភាគ ១ ទំព័រ ៣៦៥ ដល់ ៣៧៥ ត្រង់ **អសុភកម្មដ្ឋាននិទ្ទេស** ។

វិតក្ក:ទាំងនោះ លោកហៅថា ខុទ្ទក:ក្នុងទីនេះ ព្រោះត្រូវវិតក្ក:ទាំងពួងធ្វើឱ្យអាក្រក់ ដូចក្នុងប្រយោគមានអាទិ៍ថា មិនគប្បីប្រព្រឹត្តអាក្រក់ ។ បទថា **សុខុមា** *លោកប្រាថ្នាយកសេចក្តីត្រិះរិះដល់ញាតិជាដើម ។ ក៏វិតក្ក:ទាំងនេះ គឺសេចក្តីត្រិះរិះដល់ញាតិ ត្រិះរិះដល់ជនបទ ត្រិះរិះដល់ទេវតា សេចក្តីត្រិះរិះដែលជាប់ទាក់ទងនឹងសេចក្តីអាណិតអ្នកដទៃ សេចក្តីត្រិះរិះដែលជាប់ដោយលាភសក្ការ: និងការសរសើរ សេចក្តីត្រិះរិះដែលជាប់ទាក់ទងនឹងការមិនមើលងាយ រមែងមិនប្រទូស្តកម្ចាំងដូចកាមវិតក្ក:ជាដើម ព្រោះដូច្នោះ ទើបលោកពោលថា សុខុម ព្រោះមានសភាវ:មិនគ្រាតគ្រាត ។ បទថា* **អនុកតា** *បានដល់ អនុវត្តទៅតាមចិត្ត ។ មែនពិត កាលវិតក្ក:កើតឡើង ចិត្តក៏ទៅតាមវិតក្ក:នោះឯង ព្រោះលើកវិតក្ក:នោះឡើងកាន់អារម្មណ៍។ បាលីថា* **អនុក្ខតា** *ដូច្នេះក៏មាន សេចក្តីថា* **អនុ-ឧដ្ឋិតា** *មិនតាំងមាំ ។ បទថា* **មនសោ ឧព្ភិលាចា**[1] *ប្រែថា ធ្វើចិត្តឱ្យរវើរវាយ ។*

បទថា **ឯតេ អវិជ្ជា មនសោ វិតក្កេ** *សេចក្តីថា មិនដឹងតាមសេចក្តីពិតដែលមនោវិតក្ក: មានកាមវិតក្ក:ជាដើមទាំងនោះ ដោយញ្ញាតបរិញ្ញា តីរណ-បរិញ្ញា និងបហានបរិញ្ញា ដោយរលាស់ចេញចាកទោស គឺសេចក្តីត្រេកអរ ។ បទថា* **ហុរា ហុរំ ធាវតិ ភន្តចិត្តោ** *សេចក្តីថា ឈ្មោះថា មានចិត្តមិនតាំងមាំ ព្រោះលះមិច្ឆាវិតក្ក: មិនបានទើបត្រាច់ទៅ គឺវិលទៅមក ដោយអំណាចសេចក្តីត្រេកអរជាដើមក្នុងអារម្មណ៍នោះៗ ដោយន័យមានអាទិ៍ថា ពេលខ្លះក្នុងរូបារម្មណ៍ ពេលខ្លះក្នុងសទ្ទារម្មណ៍ ។ ម្យ៉ាងទៀតបទថា* **ហុរា ហុរំ ធាវតិ ភន្តចិត្តោ** *សេចក្តីថា មានចិត្តវិលទៅ ដោយអំណាចអវិជ្ជា និងតណ្ហា ដែលមានវិតក្ក:*

១-ក្នុងអដ្ឋកថាច្បាប់ធម្មសង្គាយនាថា **ឧព្ភិលាភ** *។*

នោះជាហេតុ ព្រោះកំណត់វិតក្ក:មិនបាន ទើបត្រាច់ទៅ គឺអន្ទោលទៅមក ដោយចុតិ និងបដិសន្ធិពីលោកនេះ ទៅកាន់លោកខាងមុខ ។

បទថា **ឯតេ ច ឌ្ហា មនសោ វិតក្ក** សេចក្ដីថា ដឹងតាមសេចក្ដីពិត នូវសេចក្ដីត្រេកអរជាដើម ដែលមនោវិតក្ក: មានកាមវិតក្ក:ជាដើម មានប្រភេទតាមដែលពោលហើយនោះ ។ បទថា **អាតាបិយោ** ប្រែថា មានសេចក្ដីព្យាយាម ។ បទថា **សំវរតិ** ប្រែថា រមែងបិទ ។ បទថា **សតិមា** ប្រែថា ដល់ព្រមដោយសតិ ។ បទថា **អនុក្ខតេ** បានដល់ មិនកើតឡើងដោយអំណាចការបានដោយលំបាក ។ លោកពោលពាក្យអធិប្បាយនេះទុកថា ដឹងមនោវិតក្ក: មានកាមវិតក្ក:ជាដើម មានប្រការដូចពោលហើយនោះថា ជាសេចក្ដីរវើរវាយនៃចិត្ត ព្រោះជាហេតុធ្វើចិត្តឱ្យរវើរវាយ គឺដឹងដោយប្រពៃ ដោយមគ្គបញ្ញាដែលប្រកបដោយវិបស្សនា-ញាណ ឈ្មោះថា អ្នកមានសេចក្ដីព្យាយាម មានសតិ ព្រោះមានសម្មាវាយាម: និងសម្មាសតិដែលមានមគ្គបញ្ញានោះជាមិត្រ បិទមនោវិតក្ក:ទាំងនោះដែលគួរនឹងកើតតទៅ មិនឱ្យកើត គឺមិនឱ្យផុសឡើងឡើយ ក្នុងខណ:មគ្គ ដោយអរិយ-មគ្គភាវនា គឺបិទការពារដោយញាណសំវរ: បានដល់ កាត់សេចក្ដីប្រាកដ (របស់វិតក្ក:ទាំងនោះ) ក៏ព្រះអរិយសាវកអ្នកជាយ៉ាងនោះ ឈ្មោះថា **ពុទ្ធ:** ព្រោះត្រាស់ដឹងសច្ច:ទាំង ៤ លះដាច់ គឺកាត់ផ្ដាច់កាមវិតក្ក:ជាដើមទាំងនោះ ដោយមិនឱ្យសេសសល់ គឺមិនមានចំណែកនៅសល់ ហេតុសម្រេចព្រះអរហត្ត ។ សូម្បីក្នុងបទនេះ អាចារ្យពួកខ្លះពោលថា **អនុកតេ** ដូច្នេះក៏មាន ។ សេចក្ដីនៃបទ **អនុកតេ** នោះ បានពោលទុកក្នុងកាលមុននុ៎ះឯង ។

បឋមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១

២.ឧទ្ធតសុត្តវណ្ណនា

អដ្ឋកថាឧទ្ធតសូត្រ

ឧទ្ធតសូត្រទី ២ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **កុសិនារាយំ** *បានដល់ ជិតនគររបស់ស្តេចមល្ល: ឈ្មោះថា* *កុសិនារា ។ បទថា* **ឧបវត្តនេ មល្លានំ សាលវនេ** *សេចក្តីថា ឧទ្យានៃកុសិនារា-* *នគរ មាននៅក្នុងទិសទក្ខិណ និងទិសបស្ចិម ដូចជូបារាមនៃអនុរាធបុរី ។ ផ្លូវ* *ពីជូបារាមចូលទៅកាន់នគរ ដោយទ្វារខាងទិសទក្ខិណ ទ្រង់ទៅតាមទិស* *បស្ចិម រិលត្រឡប់ផ្លូវខាងទិសឧត្តរ យ៉ាងណា ជួរឈើសាល:ពីឧទ្យានទ្រង់ទៅ* *ខាងបស្ចិមទិស រិលត្រឡប់ផ្លូវខាងទិសឧត្តរ ក៏ដូច្នោះ ព្រោះដូច្នោះ ទើបគេហៅ* *ថា* ***ឧបវត្តន:*** *ជាទីធ្វើងចូលរិល (ផ្លូវគោ) ។ ក្នុងសាលវ័នរបស់ស្តេចមល្ល:ដែល* *ជាទីធ្វើងចូលរិលនោះ ។ បទថា* **អញ្ញតរកុដិកាយំ** *បានដល់ កុដិតូចៗដែល* *សាងទុកក្នុងទីដែលដេរដាស់ទៅដោយដើមឈើ និងគុម្ពឈើ មិនឆ្ងាយពីជួរ* *ដើមសាល:ដែលលោកពោលសំដៅទុកថា* **អញ្ញតរកុដិកាយំ វិហរន្តិ** *។ ក៏ភិក្ខុ* *ទាំងនោះរៀរការពិចារណា មានសេចក្តីព្យាយាមធូរថយ នៅដោយសេចក្តី* *ប្រមាទ ។ ព្រោះហេតុនោះ ទើបលោកពោលថា* **ឧទ្ធតា** *ដូច្នេះជាដើម ។*

បណ្តាភិក្ខុទាំងនោះ ភិក្ខុអ្នកឈ្មោះថា ***ឧទ្ធត:*** *ព្រោះមានចិត្តមិនស្ងប់* *ហេតុច្រើនទៅដោយ**ឧទ្ធច្ច:*** *។ មាន:* *ឈ្មោះថា* ***នល:*** *ព្រោះដូចជាឈើបបុស* *ដោយជារបស់ទទេ ។ ភិក្ខុឈ្មោះថា* ***ឧន្ធល:*** *ព្រោះមាន* ***នល:*** *ពោលគឺ* *មាន:*

ខ្ពស់ អធិប្បាយថា មានមានះខ្ពស់ទទេ ។ ឈ្មោះថា **ចបលៈ** ព្រោះប្រកប ឬ ច្រើនទៅដោយការរវើរាយ មានប្រដាប់បាត្រ និងចីវរជាដើម ។ ឈ្មោះថា **មុខរៈ** ព្រោះមានមាត់រីង មានវាចាអាក្រក់ ។ ឈ្មោះថា **វិកិណ្ណវាចា** ព្រោះមានសំដីផ្តេសផ្តាស គឺមិនគួរឱ្យជឿបាន ច្រើនទៅដោយតិរច្ឆានកថា ។ ឈ្មោះថា **មុដ្ឋស្សតិនោ** ព្រោះមានសតិវង្វេងភ្លេច ។ អធិប្បាយថា រៀរចាកសតិ គឺនៅដោយសេចក្តីប្រមាទ ។ ឈ្មោះថា **អសម្បជានៈ** ព្រោះមិនមានសម្បជញ្ញៈដោយប្រការទាំងពួង ។ ឈ្មោះថា **អសមាហិតៈ** ព្រោះមានចិត្តមិនតាំងមាំ ដោយមិនមានសេចក្តីតាំងមាំនៃចិត្ត រហូតដល់អស់វេលា មានការនិយាយគ្នាលេងជាប្រមាណ ។ ឈ្មោះថា **វិព្ភន្តចិត្តៈ** ព្រោះមានចំណែកប្រៀបផ្ទឹមដោយម្រឹគភ្ញាក់ផ្អើល ហេតុមានសេចក្តីមិននឹងធឹងជាសភាវៈ ។ ឈ្មោះថា **បាកតិន្ទ្រិយ** ព្រោះជាអ្នកមិនសង្រួមឥន្ទ្រិយ ដោយមិនសង្រួមឥន្ទ្រិយ មានមនិន្ទ្រិយជាគម្រប់ ៦ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបថា ភិក្ខុទាំងនោះ នៅដោយសេចក្តីប្រមាទ ដោយអំណាច **ឧទ្ទច្ចៈ** ជាដើមនេះ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះដែលប្រកាសទោស និងអានិសង្សតាមលំដាប់ក្នុងការនៅដោយសេចក្តីប្រមាទ និងនៅដោយសេចក្តីមិនប្រមាទ ។

បណ្តាបទទាំងនោះ បទថា **អរក្ខិ តេន** *សេចក្តីថា ឈ្មោះថា មិនឃុំគ្រង ព្រោះមិនមានសតិជាគ្រឿងរក្សា ។ បទថា* **កាយេន** *បានដល់ ដោយកាយ វិញ្ញាណ ៦ ។ ក៏ព្រោះឃើញរូបដោយចក្ខុវិញ្ញាណ ហើយមិនប្រើសតិរក្សាទ្វារ នៃវិញ្ញាណ ដោយឱ្យអកិដ្ឌាជាដើមឱ្យប្រព្រឹត្តទៅដោយអំណាចការកាន់យក និមិត្ត និងអនុព្យញ្ជនៈក្នុងរូបនោះ ។ សូម្បីក្នុងសោតវិញ្ញាណក៏នយនេះដូចគ្នា ។ ព្រះអង្គត្រាស់ថា* **អរក្ខិតេន កាយេន** *សំដៅដល់ការៈដែលភិក្ខុមិនរក្សា វិញ្ញាណកាយ ៦ ដោយអាការយ៉ាងនេះ ។ តែអាចារ្យពួកខ្លះពោលអត្ថថា* **កាយេន** *ដូច្នេះ ។ គប្បីប្រកបដោយសតិ ដោយអត្ថយោជនារបស់អាចារ្យពួក ខ្លះ សូម្បីទាំងនោះដោយន័យដូចពោលហើយនុ៎ះឯង ។ អាចារ្យមួយពួកទៀត ពោលថា* **អរក្ខិតេន ចិត្តេន** *។ អត្ថរបស់អាចារ្យមួយពួកទៀតសូម្បីនោះ ក៏ន័យនេះដូចគ្នា ។ បទថា* **មិច្ឆាឌិដ្ឋិហតេន** *បានដល់ ត្រូវការកាន់ខុសថា ទៀងជាដើមប្រទូសរ៉ាយហើយ ។ បទថា* **ថីនមិទ្ធាភិភូតេន** *សេចក្តីថា ត្រូវ ថីនៈមានសភាព គឺចិត្តមិនគួរដល់ការងារជាលក្ខណៈ និងត្រូវមិទ្ធៈមានសភាព គឺកាយមិនគួរដល់ការងារជាលក្ខណៈគ្របសង្កត់ហើយ ភ្ជាប់សេចក្តីពោលអំពី កាយនោះ ឬពោលអំពីចិត្តនោះ ។ បទថា* **វសំ មារស្ស គច្ឆតិ** *សេចក្តីថា ចូល ដល់អំណាច គឺការៈដែលខ្លួនត្រូវមារទាំងអស់ មានកិលេសមារជាដើមធ្វើឱ្យ*

ប្រព្រឹត្តទៅតាមប្រាជ្ញា អធិប្បាយថា មិនកន្ទ្ធងហួសវិស័យរបស់មារទាំងនោះ ទៅបាន ។

មែនពិត ដោយព្រះគាថានេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងវដ្ដៈជាប្រធាន គឺទ្រង់តិះដៀលភិក្ខុទាំងនោះអ្នកនៅដោយសេចក្ដីប្រមាទថា ភិក្ខុពួកណាមិនរក្សាចិត្តដោយប្រការទាំងពួង ព្រោះមិនមានសតិជាគ្រឿងរក្សា អ្នកប្រកាន់ការស្វែងរកខុសដោយន័យមានអាទិ៍ថា **ទៀង** ដោយអយោនិសោប៉ោងឡើង ព្រោះមិនមានបញ្ញាដែលជាហេតុនៃយោនិសោមនសិការ ព្រោះហេតុនោះឯង ភិក្ខុទាំងនោះទើបឈ្មោះថា ត្រូវកោសជ្ជៈគ្របសង្កត់ ព្រោះមិនមានវិរិយារម្ភៈក្នុងការបំពេញកុសល នឹងមិនដកសីសៈឡើងពីវដ្ដៈមិនបាន ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងវិវដ្ដៈ(គឺនិព្វាន)ទើបត្រាស់ព្រះគាថាទី ២ ថា **តស្មា រក្ខិតចិត្តស្ស** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **តស្មា រក្ខិតចិត្តស្ស** សេចក្ដីថា ក៏ព្រោះហេតុដែលភិក្ខុជាអ្នកមិនរក្សាចិត្ត ត្រូវមារធ្វើឱ្យប្រព្រឹត្តទៅតាមប្រាជ្ញា ទើបនៅក្នុងសង្សារប៉ុណ្ណោះ ដូច្នោះ ភិក្ខុគប្បីជាអ្នករក្សាចិត្តដោយការរក្សា គឺបិទការពារឥន្ទ្រិយទាំងឡាយមានមនិន្ទ្រិយជាគម្រប់ ៦ ដោយសតិសំវរៈ ។ ព្រោះកាលលោករក្សាចិត្តបានហើយ ឈ្មោះថា រក្សាឥន្ទ្រិយមានចក្ខុន្ទ្រិយជាដើមបានដោយ

ខ្លួនឯងដែរ ។ បទថា **សម្មាសង្កប្បគោចរោ** សេចក្តីថា ព្រោះហេតុដែលភិក្ខុ មានមិច្ឆាសង្កប្បៈជាអារម្មណ៍ ទើបត្រិះរិះដោយអយោនិសោ ប្រកាន់មិច្ឆាទស្សនៈ ផ្សេងៗ មានចិត្តដែលមិច្ឆាទិដ្ឋិកម្ចាត់ហើយ ជាអ្នកត្រូវមារធ្វើឱ្យប្រព្រឹត្តទៅតាម ប្រាថ្នា ដូច្នោះ កាលនឹងធ្វើកម្មដោយយោនិសោមនសិការ គប្បីជាអ្នកមាន សេចក្តីត្រិះរិះដោយប្រពៃ មានសេចក្តីត្រិះរិះក្នុងការចេញចាកកាមជាដើមជា អារម្មណ៍គប្បីធ្វើសេចក្តីត្រះរិះប្រពៃ ដែលសម្បយុត្តដោយឈានជាដើមប៉ុណ្ណោះ ឱ្យជាឋានៈដែលប្រព្រឹត្តទៅនៃចិត្តរបស់ខ្លួន ។ បទថា **សម្មាទិដ្ឋិបុរេក្ខារោ** សេចក្តីថា ភិក្ខុអ្នកកម្ចាត់មិច្ឆាទស្សនៈ ដោយភាពជាអ្នកមានសម្មាសង្កប្បៈជា អារម្មណ៍ គប្បីប្រាថ្នាធ្វើសម្មាទិដ្ឋិដែលមានសេចក្តីល្អ ដែលសត្វមានកម្មជា របស់ខ្លួន ខាងមុខជាលក្ខណៈ និងតពីនោះ មានយថាភូតញាណជាលក្ខណៈ ទើបខ្វល់ខ្វាយប្រកបក្នុងសីល និងសមាធិ ដោយន័យដូចពោលហើយក្នុងកាល មុនទុំះឯង ផ្តើមវិបស្សនាពិចារណាសង្ខារ ដឹងការកើត និងការរលត់នៃសង្ខារ កំណត់ការកើត និងការរលត់ក្នុងឧបាទានខន្ធ ៥ ដោយអាការ ៥០ គត់ សម្រេច ឧទយព្វយញ្ញាណដោយចំពោះ តពីនោះ ទើបបំពេញវិបស្សនា ដោយអំណាច ភង្គានុបស្សនាញាណជាដើម កាន់យកអរិយមគ្គបានដោយលំដាប់ ឈ្មោះថា ភិក្ខុអ្នកគ្របសង្កត់ថីនមិទ្ធៈ លះទុគ្គតិទាំងពួងបានដោយអរហត្តមគ្គ ។ ដោយ អាការយ៉ាងនេះ លោកឈ្មោះថា ជាភិក្ខុជាព្រះខីណាស្រព ទម្លាយកិលេស

ដោយប្រការទាំងពួង ព្រោះលះកិលេសដោយមគ្គខាងក្រោម គប្បីសម្ងាប់បានមុន ព្រោះកាត់ផ្តាច់ថីនមិទ្ធ:ដែលកើតក្នុងចិត្តុប្បាទ ដែលកើតព្រមដោយលោក: ដែលជាទិដ្ឋិវិប្បយុត្ត ដោយអរហត្តមគ្គដែលខ្ជួនសម្រេច តពីនោះ ទើបលះកិលេសមានមាន:ជាដើម ដែលនៅរួមក្នុងទីជាមួយគ្នានឹងលោក:នោះ ព្រោះកាត់មូលនៃភពបានមិនឱ្យសេសសល់ ទើបឈ្មោះថា លះ គឺលះជាច់គតិទាំងពួង ពោលគឺ ទុគ្គតិ ព្រោះប្រកបដោយសេចក្ដីទុក្ខ ៣ ប្រការ អធិប្បាយថា គប្បីតាំងនៅក្នុងចំណែកដទៃរបស់គតិទាំងនោះ គឺក្នុងព្រះនិព្វាន ។

ឧតិយសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ២

៣. គោចាលសុត្តវណ្ណនា

អដ្ឋកថាគោចាលសូត្រទី ៣

គោបាលសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **កោសលេសុ** *សេចក្តីថា ព្រះរាជកុមារអ្នកនៅជនបទ ឈ្មោះ*ថា **កោសល** *។ ជនបទមួយកន្លែង ដែលជាទីនៅរបស់ព្រះរាជកុមារទាំងនោះ* ក៏ហៅថា *កោសលដូចគ្នា ក្នុងកោសលជនបទនោះ ។ បទថា* **ចារិកំ ចរតិ** *បានដល់ ស្តេចត្រាច់ចារិកទៅក្នុងជនបទ ដោយការទៅដោយមិនប្រញាប់-ប្រញាល់ ។ បទថា* **មហតា** *សេចក្តីថា ឈ្មោះថា ធំ ព្រោះធំដោយគុណខ្លះ* ឈ្មោះថា *ធំ ព្រោះធំដោយចំនួន ព្រោះកំណត់រាប់មិនបានខ្លះ ។ បទថា* **ភិក្ខុ-សង្ឆេន** *បានដល់ ដោយពួកសមណៈដែលក្រើនរឭកគ្នាដោយទិដ្ឋិ និងសីល ។ បទថា* **សង្ខ្លី** *ប្រែថា ព្រមគ្នា ។ បទថា* **មក្តាឧក្ត្ថ** *ប្រែថា ចេញចាកផ្លូវ ។ បទថា* **អញ្ញតរំ រុក្ខមូលំ** *បានដល់ មូល ពោលគឺ ទីជិតដើមឈើធំ មានស្លឹកខៀវក្រាស់ មានម្លប់ត្រឈឹងត្រឈៃ ។*

បទថា **អញ្ញតរោ គោចាលកោ** *សេចក្តីថា អ្នករក្សាហ្វូងគោម្នាក់ ដោយឈ្មោះ ឈ្មោះថា* **ឧន្ទ:** *។ បានឮមកថា នាយនន្ទ:នោះជាអ្នកមានទ្រព្យ ច្រើន មានភោគ:ច្រើន រក្សាហ្វូងគោរបស់លោកអានាថបិណ្ឌិកសេដ្ឋីជៀសវាង ការសង្កត់សង្កិនរបស់ព្រះរាជា ដោយធ្វើជាអ្នកចិញ្ចឹមគោ រក្សាទ្រព្យរបស់ខ្លួន*

ដូចកេណិយជដិលជៀសវាងការសង្ក្ត់សង្កិនដោយកេទបពូជ្ជាដូច្នោះ ។ នន្ទ:នោះ
កាន់យកបញ្ចគោរសតាមកាលវេលា មកកាន់សំណាក់របស់មហាសេដ្ឋីហើយ
ប្រគល់ឱ្យ ហើយទៅកាន់សំណាក់ព្រះសាស្តា ជួបព្រះសាស្តាស្តាប់ធម៌ និង
អង្វរព្រះសាស្តាដើម្បីស្តេចមកកាន់ទីនៅរបស់ខ្លួន ។ ព្រះសាស្តាទ្រង់រង់ចាំសេចក្តី
ចាស់ក្លានៃញាណរបស់នន្ទ:ន៏ុះឯង ខាងក្រោយមក ព្រះដ៏មានព្រះភាគទ្រង់
ហែហមដោយកិក្ខុសង្ឆ្យពួកធំ ស្តេចចារិកទៅក្នុងជនបទ ជ្រាបថា ឥឡូវនេះ
នន្ទ:មានញាណចាស់ក្លាហើយ ទើបស្តេចយាងចុះចាកផ្លូវមិនឆ្ងាយពីទីជាទី
នៅរបស់នន្ទ:នោះ ប្រថាប់គង់ក្បែរគល់ឈើមួយកន្លែង រង់ចាំការមករបស់
នន្ទ: ។ ចំណែកនាយនន្ទ: ជ្រាបដំណឹងថា បានឮមកថា ព្រះសាស្តាស្តេច
ចារិកទៅកាន់ជនបទ ហើយយាងត្រឡប់អំពីនោះមកវិញ ទើបរីករាយប្រញាប់
ទៅគាល់ព្រះសាស្តាថ្វាយបង្គំ ត្រូវព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារ: ហើយអង្គុយ
ក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់នន្ទ: ។
នន្ទ:នោះតាំងនៅក្នុងសោតាបត្តិផល ហើយយាងព្រះដ៏មានព្រះភាគដើម្បីបាន
ថ្វាយបាយបាយាស ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៧ ព្រះដ៏មានព្រះភាគទ្រង់ធ្វើអនុមោទនា
ហើយស្តេចជៀសទៅ ។ ព្រោះហេតុនោះ លោកទើបពោលថា លុះនាយគោ-

បាលនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់សម្តែងពន្យល់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយដោយធម្មីកថា ។ល។ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចជៀសចេញទៅ ។

បណ្តាបទទាំងនោះ បទថា **សន្ធស្សេសិ** សេចក្តីថា ព្រះអង្គកាលទ្រង់សម្តែងធម៌មានកុសលជាដើម វិបាករបស់កម្ម លោកនេះ លោកខាងមុខ ដោយប្រចក្សក្នុងន័យមានជាអាទិ៍ថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះជាអកុសល ក្នុងវេលាចប់អនុបុព្វីកថា ទើបទ្រង់សម្តែងដោយប្រពៃនូវអរិយសច្ចៈ ៤ ។ បទថា **សមាទបេសិ** សេចក្តីថា ឱ្យលោកកាន់យកធម៌ មានសីលជាដើមដោយប្រពៃ គឺឱ្យលោកតាំងនៅក្នុងធម៌មានសីលជាដើមនោះ ដោយន័យមានជាអាទិ៍ថា ដើម្បីសម្រេចសច្ចៈ លោកត្រូវញ៉ាំងឱ្យធម៌ទាំងនេះកើតឡើងក្នុងខ្លួន ។ បទថា **សមុត្តេជេសិ** សេចក្តីថា ទ្រង់ឱ្យធម៌ទាំងនោះដែលសមាទានហើយ អប់រំដោយលំដាប់ ដែលជាចំណែកនៃធម៌ជាគ្រឿងត្រាស់ដឹង មានសេចក្តីរឹងមាំ និងសេចក្តីស្អាតបរិសុទ្ធ ឱ្យត្រាស់ដឹងដោយប្រពៃ គឺឱ្យរុងរឿងដោយប្រពៃតែម្តង ដោយប្រការដែលនឹងនាំមកនូវអរិយមគ្គដោយឆាប់រហ័ស ។ បទថា **សម្ប-ហំសេសិ** សេចក្តីថាទ្រង់ឱ្យរីករាយដោយល្អ ដោយធ្វើចិត្តឱ្យផ្ទរផង់ដោយការសម្តែងការៈនៃការនា មានគុណវិសេសទាំងខាងដើម និងខាងចុង ។ ម្យ៉ាងទៀត

ក្នុងសេចក្តីនេះ គប្បីជ្រាបការចង្អុលបង្ហាញដោយបន្ទោបង់ សម្មោហៈ ក្នុងធម៌ដែលមានទោស និងរកទោសមិនបាន និងក្នុងសច្ចៈ មានទុក្ខសច្ចៈជាដើម ការឱ្យសមាទាន ដោយការបន្ទោបង់សេចក្តីប្រមាទក្នុងសម្មាបដិបត្តិ ការឱ្យអាចហ៊ានក្នុងការបន្ទោបង់ ការដល់សេចក្តីខ្ជិលច្រអូសនៃចិត្ត និងសេចក្តីរីករាយដោយការសម្រេចសម្មាបដិបត្តិ ។ ដោយអាការយ៉ាងនេះ លោកទើបតាំងនៅក្នុងសោតាបត្តិផល ដោយសាមុក្កំសិកធម្មទេសនា[១] របស់ព្រះដ៏មានព្រះភាគ ។ បទថា **អធិវាសេសិ** សេចក្តីថា ព្រះអង្គដែលនាយគោបាលនោះ អ្នកមានសច្ចៈឃើញហើយទូលនិមន្តដោយន័យមានជាអាទិ៍ថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តរបស់ខ្ញុំព្រះអង្គចុះ ព្រះអង្គទ្រង់មិនធ្វើអង្គ

១-សាមុក្កំសិកាតិ សាមំ ឧក្កំសិកា អត្តនោយេវ ឧទ្ធរិត្វា គហិត្វា សយម្ភូញាណេន ទិដ្ឋា អសាធារណា អញ្ញេសន្តិ អត្ថោ ។ ឈ្មោះថា **សាមុក្កំសិកាទេសនា** គឺជាទេសនាដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គសម្តែងឡើង គឺទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង តាមការយល់ឃើញដោយសយម្ភូញាណ អធិប្បាយថា ជាធម្មទេសនាមិនទូទៅដល់ជនដទៃ ។

ស្រង់ចាកគម្ពីរសមន្តប្បាសាទិកា អដ្ឋកថា វិនយបិដក ត្រង់ភេសជ្ជក្ខន្ធកៈ។

គម្ពីរសុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ ត្រង់អម្ពដ្ឋសូត្រ

គម្ពីរបបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ ត្រង់គហបតិវគ្គ បាលិសុត្តវណ្ណនា ។

គម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ ត្រង់សីហសូត្រ ។

គម្ពីរបរមត្ថទីបនី អដ្ឋកថា ខុទ្ទកនិកាយ ឧទាន ត្រង់សោណថេរវគ្គវណ្ណនាទី ៥ សុប្បពុទ្ធកុដិសូត្រ ។

គឺកាយនិងវាចាឱ្យញ័រ ទ្រង់ទទួល គឺត្រេកអរដោយព្រះទ័យនុ៎ះឯង ។ ព្រោះ
ហេតុនោះនុ៎ះឯង លោកទើបពោលថា **តុណ្ហីភាវេន** *។*

បទថា **អម្ពោឧកចាយ៑ាសំ** *ប្រែថា បាយបាយាសមានទឹកតិច ។*
បទថា **បដិយាតាបេត្វា** *ប្រែថា ចាត់ចែង គឺត្រៀម ។ បទថា* **ជវញ្ច សប្បឺ**
បានដល់ យកទឹកដោះមកផ្សំឱ្យរាវ និងឱ្យជាទឹកដោះថ្លាក្នុងខណៈនោះឯង ។
បទថា **សហត្ថា** *សេចក្តីថា ធ្វើសេចក្តីអើពើ គឺអង្គាសដោយដៃរបស់ខ្លួនឯង ។*
បទថា **សន្តប្ប៑ាសិ** *សេចក្តីថា ឱ្យសោយភោជនដែលចាត់ចែងទុក ។ បទថា*
សម្ប្ប៑ាវ៑ាសិ *បានដល់ ទ្រង់ហាមដោយព្រះវាចាថា ល្មមហើយ ល្មមហើយ ។*
បទថា **កុត្តារ៑ី** *បានដល់ មានកត្តកិច្ចធ្វើរួចហើយ ។ បទថា* **ឱនីតបត្តចាណ៑ី**
បានដល់ ដកព្រះហស្តចេញពីបាត្រ ។ បាលីថា **ឧោតបត្តចាណ៑ី** *ដូច្នេះក៏មាន ។*
សេចក្តីថា លាងព្រះហស្តក្នុងបាត្រ ។ បទថា **នីចំ** *ប្រែថា មិនខ្ពស់ ។ ការកាន់*
យកអាសនៈ (ដែលមិនខ្ពស់) ហើយអង្គុយលើអាសនៈនោះឯង ជាចារិតរបស់
អ្នកនៅក្នុងអារ្យប្រទេស ក៏លោកអង្គុយក្នុងទីជិតនៃអាសនៈដែលធ្វើដោយផែន
ក្ដារ ដែលគេក្រាលទុកដោយជាឧបចារៈក្នុងទីជិតសំណាក់ព្រះសាស្តា ។ បទថា
ឧម្ម៑ាយ កថ៑ាយ *ជាដើម ត្រាស់សំដៅយកអនុមោទនាដែលទ្រង់ធ្វើក្នុងថ្ងៃទី*
៧ ។ បានឮមកថា នន្ទៈសេដ្ឋីនោះនិមន្តព្រះដ៏មានព្រះភាគ និងកិក្ខុនៅក្នុងទី

នោះរហូតអស់ ៧ ថ្ងៃ ហើយបំពេញមហាទាន ។ ក៏ក្នុងថ្ងៃទី ៧ បានថ្វាយ
មធុបាយាសមានទឹកតិច ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយស្តេចជៀសចេញ
ទៅ ព្រោះនន្ទ:នោះមិនមានញាណចាស់ក្លាដើម្បីមគ្គជាន់ខ្ពស់ក្នុងអត្តភាពនោះ ។

បទថា **សីមន្តរិកាយ** បានដល់ ក្នុងចន្លោះដែន គឺក្នុងចន្លោះស្រុកនោះ ។
បានឮមកថា ពួកអ្នកស្រុកអាស្រ័យស្រះមួយកន្លែង បានឈ្លោះនឹងនន្ទ:សេដ្ឋី
នោះ ។ លោកសេដ្ឋីគ្របសង្កត់ពួកអ្នកស្រុកនោះហើយកាន់យកស្រះនោះ ។
ព្រោះហេតុនោះ ប្រុសម្នាក់ទើបចង់អាឃាត ប្រើកូនសរបាញ់សម្លាប់នន្ទ: អ្នក
កាន់បាត្ររបស់ព្រះសាស្តាតាមទៅធ្វាយ កាលព្រះអង្គត្រាស់ថា ត្រឡប់ទៅវិញ
ចុះឧបាសក នន្ទ:ទើបថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ និងធ្វើអញ្ជលី
ចំពោះភិក្ខុសង្ឆ ហើយផ្តង់អញ្ជលីដ៏រុងរឿងដោយទសនខសមោធាន ដរាបកំបាំង
ភ្នែក ហើយត្រឡប់ទៅតែម្នាក់ឯង ក្នុងអរញ្ញប្រទេសក្នុងចន្លោះស្រុកទាំងពីរ ។
ព្រោះហេតុនោះ លោកទើបពោលថា **អចីរបក្ខ្ជន្ត ។បេ។ ភោ ភោ ឥសិ**
ដូច្នេះ ។ ភិក្ខុទាំងឡាយអ្នកយឺតយូរដោយការណីយកិច្ចយ៉ាងណាមួយ ទៅតាម
ក្រោយ ឃើញនាយគោបាលស្ងាប់ដូច្នោះ ទើបក្រាបទូលសេចក្តីនោះចំពោះ

ព្រះដ៏មានព្រះភាគ ដែលលោកសំដៅពោលទុកថា **អថ ខោ សម្ពហុលា ភិក្ខូ** ដូច្នេះជាដើម ។

បទថា **ឯតមត្ថं វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបសេចក្តីយ៉ាងនេះថា ព្រោះហេតុដែលបុរសអ្នកសម្ងាប់ន្ទ:ជាអរិយសាវក អ្នកដល់ព្រមដោយទិដ្ឋិ (សម្ម-ទិដ្ឋិ) រមែងទទួលអនន្តរិយកម្ម មិនមែនជាបុញ្ញកម្ម តែជាកម្មធ្ងន់ ដូច្នោះ ចិត្តដែលតាំងទុកខុសរបស់សត្វទាំងនេះ រមែងធ្វើកម្មដែលមានកម្ទាំងជាងកម្ម ដែលចោរនឹងអ្នកមានពៀរគប្បីធ្វើដល់គ្នា ដូច្នេះហើយទើបទ្រង់បន្ទឹ្ទ ១ ទាននេះ ដែលសម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **ឥសោ ឥសំ** សេចក្តីថា អ្នកប្រទូស្តឃើញអ្នកប្រទូស្ត គឺចោរឃើញចោរ ។ បាលីដែលនៅសល់ថា **ឥស្ស** គប្បីនាំមកភ្ជាប់ចូល ។ បទថា **យត្ថ ឧយ្យាត** បានដល់ គប្បីធ្វើសេចក្តីវិនាសឱ្យដល់ចោរ ឬអ្នកមានពៀរនោះ ។ សូម្បីក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះថា ចោរអ្នកប្រាថ្នាប្រទូសវ៉ាយមិត្តម្នាក់ ធ្វើសេចក្តីអន្តរាយក្នុងវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យមានបុត្រ ភរិយា ស្រែ ចម្ការ គោ និងក្របីជាដើមរបស់ចោរម្នាក់ ខ្ជូនធ្វើសេចក្តីអន្តរាយចំពោះចោរណា ឃើញចោរសូម្បីនោះធ្វើសេចក្តីអន្តរាយក្នុងខ្ជូនដូចយ៉ាងនោះឯង ឬក៏ថាអ្នកមានពៀរ

ឃើញ អ្នកមានពៀរ ដែលមានពៀរវេរាចង់ដោយហេតុយ៉ាងណាមួយ គប្បីធ្វើសេចក្តីខ្ជល់ខ្ជាយដល់អ្នកមានពៀរនោះ ឬគប្បីបៀតបៀនបុត្រនិងកសិយា ឬធ្វើវត្ថុទាំងឡាយមានស្រែជាដើមឱ្យវិនាស ឬក៏សម្ងាប់ ព្រោះភាពដែលខ្លួនជាអ្នកគ្រោតគ្រាតនិងទារុណ ចិត្តដែលឈ្មោះថា តាំងទុកខុស ព្រោះតាំងទុកខុសក្នុងអកុសលកម្មបថ ១០ គប្បីធ្វើគេឱ្យអាក្រក់ជាងនោះ គឺគប្បីធ្វើបុរសនោះឱ្យអាក្រក់ជាងនោះ ។ សេចក្តីពិត ចោរ ឬអ្នកមានពៀរមានប្រការដូចពោល ហើយគប្បីធ្វើទុក្ខឱ្យកើតឡើងដល់ចោរ ឬអ្នកមានពៀរ ឬធ្វើចោរ ឬអ្នកមានពៀរឱ្យអស់ជីវិតក្នុងអត្តភាពនេះប៉ុណ្ណោះ ចំណែកចិត្តដែលតាំងទុកខុសក្នុងអកុសល-កម្មបថ ១០ នេះ រមែងធ្វើគេឱ្យដល់សេចក្តីវិនាសក្នុងបច្ចុប្បន្ននេះនុ៎ះឯង រមែងបោះទៅក្នុងអបាយ ៤ មិនឱ្យគេងើយក្បាលឡើងបាន សូម្បីក្នុងសែនអត្តភាព ។

តតិយសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៣

៤.យក្ខបហារសុត្តវណ្ណនា

អដ្ឋកថាយក្ខបហារសូត្រ

យក្ខបហារសូត្រទី ៤ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **កាចោតកន្ធរាយំ** *បានដល់ ក្នុងវិហារមានឈ្មោះយ៉ាងនោះ ។ បានឮមកថា កាលមុនសត្វព្រាបជាច្រើននៅក្នុងញ្ជកភ្នំនោះ ។ ព្រោះហេតុនោះ ញ្ជកភ្នំនោះទើបហៅថា* **កាចោតកន្ធ** *។ ខាងក្រោយមកដល់គេសាងវិហារទុកក្នុងទីនោះ ក៏ទូវប្រាកដថា* **កាចោតកន្ធ** *ទុ:ឯង ។ ព្រោះហេតុនោះ លោកទើបពោលថា* **កាចោតកន្ធរាយន្តិ ឯវ: នាមកេ វិហារេ** *។ បទថា* **ជុណ្ហាយ រត្តិយា** *បានដល់ ក្នុងរាត្រីសុក្ខបក្ខ (រាត្រីខាងខ្នើត) ។ បទថា* **ឧភេ ភេមិតេហិ កេសេហិ** *បានដល់ មានសក់ទើបកោរថ្មីៗ ក៏ពាក្យថា* **កេសេ-ហិ** *នេះ ជាតតិយាវិភត្តិ ប្រើក្នុងលក្ខណ:ឥត្ថម្ភូត ។ បទថា* **អញ្ញេ ការ:ាសេ** *បានដល់ ទីវាលដែលមិនមានគ្រឿងប្រក់ ឬគ្រឿងបិទបាំង ។*

បណ្តាព្រះថេរ:ទាំងឡាយនោះ ព្រះសារីបុត្តដ៏មានអាយុមានសម្ផ្ការ:ដូចមាស ព្រះមហាមោគ្គល្លានដ៏មានអាយុ មានសម្ផ្ការ:ដូចផ្ការ:ឧប្ផលខ្ចៀ ក៏គឺព្រះមហាថេរ:ទាំងពីរអង្គនេះឯងជាជាតិព្រាហ្មណ៍ ដល់ព្រមដោយអកិនីហារ អស់ ១ អសង្ខ្យេយ្យ និង ១ សែនកប្ប គប្ប៉ីសម្រេចអភិញ្ញា ៦ និងបដិសម្ភិទា ៨ ជាព្រះមហាខីណាស្រព បានសមាបត្តិគ្រប់យ៉ាង ដល់ទីបំផុតសាវ:ាកបារមីញាណ ៦៧ ប្រការ ធ្វើ:ាកបោតកន្ធ:ាវិហារនោះ:ាឱ្យ:ាស្ងាត់ស្ងៀ:ាជាមួយគ្នា ដូចសីហ: ២ ក្បាលនៅណ្ដាងមាសតែមួយជាមួយគ្នា ដូចខ្ទាធំ ២ ក្បាល ទម្រេតខ្ជួនលើផែនដីតែមួយជាមួយគ្នា ដូចស្ដេចដំរីធ:ន្ត ២ ក្បាល ចូលព្រៃសាលវ:ានដែលមានផ្ការ:ីកស្ពុ:ស្ពាយ

តែមួយជាមួយគ្នា ដូចស្តេចគ្រុទ ២ ក្បាល នៅព្រៃសិម្ពលីតែមួយជាមួយគ្នា ដូចស្តេចវេស្សវ័ណ ២ អង្គ ឡើងយានដែលនាំដោយមនុស្សតែមួយជាមួយគ្នា ដូចស្តេចសក្ក: ២ អង្គ ប្រថាប់អង្គុយលើបណ្ដុកម្ពលសិលាសន:តែមួយជាមួយគ្នា ដូចស្តេចមហាព្រហ្ម ២ អង្គ នៅក្នុងវិមានតែមួយជាមួយគ្នា ដូចដួងចន្ទ ២ ដួង និងព្រះអាទិត្យ ២ ដួង នៅក្នុងផ្ទៃអាកាសតែមួយជាមួយគ្នាដូច្នោះ ។ បណ្ដាព្រះថេរ:ទាំងពីរអង្គនោះ ព្រះមហាមោគ្គល្លានដ៏មានអាយុបានគង់នៅស្ងៀម ចំណែកព្រះសារីបុត្តដ៏មានអាយុចូលសមាបត្តិ ។ ព្រោះហេតុនោះ លោកទើបពោលថា **អញ្ញតរំ សមាធឿ សមាបជ្ជិត្វា** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អញ្ញតរំ សមាធឿ** *បានដល់ ឧបេក្ខាព្រហ្ម-*
វិហារសមាបត្តិ ។ អាចារ្យពួកខ្ះពោលថា សញ្ញាវេទយិតនិរោធសមាបត្តិ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា ផលសមាបត្តិដែលមានអរូបឈានជាបាទ ។ ពិតយ៉ាងនោះ សមាបត្តិទាំង ៣ នេះឯង ជាសមាបត្តិដែលអាចរក្សាកាយ ។ បណ្ដាសមាបត្តិទាំងនោះ ការកើតដោយបរិយាយនៃសមាធិរបស់និរោធ-
សមាបត្តិ បានពោលទុកក្នុងកាលក្រោយហើយ ។ តែអាចារ្យទាំងឡាយពណ៌នា
សមាបត្តិគ្រាចុងបង្ហស់ប៉ុណ្ណោះ ។ បទថា **ឧត្ដរាយ ទិសាយ ឧក្ខិណ្ណា ទិសំ ឧច្ឆន្តិ** *សេចក្ដីថា យក្ខទាំងពីរទៅកាន់សមាគមយក្ខក្នុងឧត្ដរទិស ហើយទៅកាន់ទក្ខិណទិស ដើម្បីទៅកាន់ភពរបស់ខ្លួន ។ បទថា* **បដិភាតិ មំ** *បានដល់ ចិត្តរបស់យើងប្រាកដ ។ មែនពិត បទថា* **មំ** *ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថឆដ្ឋីវិភត្តិ ព្រោះប្រកបដោយបដិ-ស័ព្ទ សេចក្ដីថា ចិត្តរបស់យើងកើតឡើងដើម្បីនឹងវាយ*

សីសៈព្រះថេរៈនេះ ។ បានឮមកថា យក្ខនោះចង់អាឃាតនឹងព្រះថេរៈមកពីជាតិមុន ព្រោះហេតុនោះ គ្រាន់តែឃើញព្រះថេរៈភ្ញាម យក្ខនោះក៏មានចិត្តគិតប្រទូសរ៉ាយយ៉ាងនោះ ។ ចំណែកយក្ខជាសម្ងាញ់ដទៃទៀត ជាអ្នកមានបញ្ញា ព្រោះដូច្នោះ កាលនឹងហាមយក្ខនោះ ទើបពោលពាក្យមានជាអាទិ៍ថា **កុំឡើយសម្ងាញ់** *។ បណ្តាបទទាំងនោះ បទថា* **មា អាសាឧេសិ** *បានដល់ កុំព្យាយាមអធិប្បាយថា ចូរកុំប្រហារ ។ បទថា* **ឧឬ្ធ** *សេចក្តីថា ប្រកបដោយគុណមានសីលជាដើមដ៏ក្រៃលែង គឺខ្ពស់បំផុត ។*

បទថា **អជានិយិត្វា** *សេចក្តីថា មិនធ្វើសេចក្តីអើពើ គឺមិនកាន់យកពាក្យរបស់យក្ខជាសម្ងាញ់នោះ ។ ក៏ព្រោះហេតុដែលយក្ខមិនកាន់យកពាក្យរបស់យក្ខជាសម្ងាញ់នោះ ទើបឈ្មោះថា មិនអើពើពាក្យរបស់យក្ខនោះ ព្រោះដូច្នោះ លោកទើបពោលថា* **តំ យក្ខំ អជានិយិត្វា** *។ បទថា* **សីសេ បហារំ អជាសិ** *សេចក្តីថា ធ្វើសេចក្តីឧស្សាហ៍ឱ្យកើតដោយកម្លាំងទាំងអស់ ឈរលើអាកាសនុ៎ះឯង ប្រហារចំសីសៈ អធិប្បាយថា យកកណ្តាប់ដៃវាយសីសៈ ។ បទថា* **តាវ មហា** *សេចក្តីថា បានប្រហារយ៉ាងធ្ងន់ដែលនោះដោយកម្លាំងដ៏ខ្លាំង ។ បទថា* **តេន បហារេន** *បានដល់ ដោយការប្រហារនោះដែលជាតួហេតុ ។ បទថា* **សត្តរតនំ** *បានដល់ ៧ ហត្ថ ដោយហត្ថរបស់បុរសយ៉ាងកណ្តាល ។ បទថា* **សោ** *បានដល់ យក្ខនោះ ។ បទថា* **ឆាតំ** *បានដល់ ស្តេចដំរី ។ បទថា* **ឱសាឧេយ្យ** *បានដល់ គប្បីឱ្យលិចចុះ គឺគប្បីស្រុតទៅក្នុងផែនដី ។ បាលីថា* **ឱសាឧេយ្យ** *គប្បីឱ្យប្រជុំចុះ ដូច្នេះក៏មាន អធិប្បាយថា គប្បីធ្វើឱ្យបែកខ្ទេចខ្ទី*

ល្អិតល្អន់ ។ បទថា **អឌ្ឍដ្ឋមរតនំ** សេចក្ដីថា ជាទីពេញនៃវត្ថុ ៨ ដោយកន្ទុះ ព្រោះដូច្នោះ ទើបឈ្មោះថា ទី ៨ កន្ទុះ ហត្ថទី ៨ កន្ទុះ ជាខ្នាតរបស់ដំរីនោះ ព្រោះហេតុនោះ ដំរីនោះមានខ្នាត ៧ ហត្ថកន្ទុះ ដែលដំរីនោះមានខ្នាត ៨ ហត្ថ កន្ទុះ ។ បទថា **មហន្តំ បព្វតកូដំ** បានដល់ កំពូលភ្នំដ៏ធំទូលាយប្រមាណប៉ុន កំពូលភ្នំកៃលាស[1] ។ បទថា **បតាលេយ្យ** បានដល់ គប្បីទម្លាយដោយអាការ ឱ្យជាក្រមរ ភ្ជាប់សេចក្ដីថា ឱ្យលិចចុះទៅខ្ទុះ ឱ្យទម្លាយទៅខ្ទុះ ។

ក៏ក្នុងខណៈនោះឯង សេចក្ដីក្ដៅផ្សាដ៏ក្រៃលែង កើតឡើងក្នុងរាងកាយ របស់យក្ខនោះ ។ យក្ខនោះទុក្ខសោកដោយវេទនា កាលមិនអាចនឹងតាំងនៅ ក្នុងអាកាសបាន ទើបធ្លាក់លើផែនដី ។ ក្នុងខណៈនោះឯង មហាប្រថពីដែល មានកម្រាស់ ២៤.០០០០ យោជន៍ ដែលអាចទ្រស្ដេចភ្នំទាំងឡាយ មានភ្នំសិនេរុ មានកម្ពស់ ១៦៨.០០០ យោជន៍ ហាក់ដូចជាមិនអាចនឹងទ្រសត្វអាក្រក់នោះបាន ផែនដីក៏ប្រេះជាពីរ ។ អណ្ដាតភ្លើងក៏តាំងឡើងពីអវិចីមហានរក ចាប់យក្ខនោះ ដែលកំពុងទួញយំនោះឯង ។ យក្ខនោះកំពុងទួញយំគ្ជួញគ្ជែররវៃរាយហើយ ធ្លាក់ទៅ ។ ព្រោះហេតុនោះ លោកទើបពោលថា លំដាប់នោះ ស្រាប់តែយក្ខ នោះពោលថា ខ្ញុំក្ដៅណាស់ ខ្ញុំក្ដៅណាស់ ដូច្នេះ ហើយធ្លាក់ទៅកាន់មហានរក ត្រង់ទីនោះឯង ។

បណ្ដាបទទាំងនោះ បទថា **អបតាសិ** ប្រែថា បានធ្លាក់ទៅហើយ ។ សួរ

១-កៃលាស កៃលាស សំ.; ជា. (ន.) (កេលាស) ឈ្មោះភ្នំវិសេសមួយក្នុងពួកភ្នំហិមាល័យ (មាន និយាយក្នុងរឿងបុរាណ) ។(ស្រង់ចាកវចនានុក្រមខ្មែរ សម្ដេចព្រះសង្ឆរាជ ជោតញ្ញាណ ជ.ណ)

ថា ក៏យក្ខនោះធ្លាក់ទៅកាន់នរក ទាំងអត្តភាពជាយក្ខនុ៎ះឯងឬ? ធ្វើយថា មិនមែនធ្លាក់ទាំងអត្តជាយក្ខទេ ។ ក៏ក្នុងទីនេះ ព្រោះកម្ទាំងនៃបាបកម្មដោយអំណោយទិដ្ឋធម្មវេទនីយកម្ម យក្ខទើបសោយទុក្ខធ្ងន់ក្នុងអត្តភាពជាយក្ខ ។ ម្យ៉ាងទៀត ព្រោះឧបបជ្ជវេទនីយកម្មដែលជាអនន្តរិយកម្ម យក្ខទើបកើតក្នុងនរកបន្ទាប់ពីចុតិ ។ តែរាងកាយរបស់ព្រះថេរៈដែលត្រូវកម្ទាំងនៃសមាបត្តិគាំទ្រ ទើបមិនមានវិការអ្វីឡើយ ។ សេចក្ដីពិត យក្ខប្រហារព្រះថេរៈ ក្នុងវេលាដែលព្រះថេរៈមិនទាន់ចេញចាកសមាបត្តិ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុឃើញយក្ខនោះ កំពុងប្រហារ(ព្រះសារីបុត្ត)យ៉ាងនោះ ដោយទិព្វចក្ខុ ទើបចូលទៅរកព្រះធម្ម-សេនាបតី ។ ក៏កាលដែលព្រះមហាមោគ្គល្លានដ៏មានអាយុ ដែលចូលទៅរកនុ៎ះឯង ព្រះធម្មសេនាបតីក៏ចេញចាកសមាបត្តិ ។ ក្នុងលំដាប់នោះ ព្រះមហា-មោគ្គល្លានដ៏មានអាយុ ទើបសួរនូវការប្រព្រឹត្តទៅនៃសរីរៈនឹងព្រះធម្មសេនាបតី ។ ចំណែកព្រះធម្មសេនាបតីក៏បានធ្វើយតបនូវសេចក្ដីនោះ នឹងព្រះមហាមោគ្គល្លានដ៏មានអាយុ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រះមហាមោគ្គល្លានដ៏-មានអាយុបានឃើញយក្ខនោះ ។ល។ តែថា មានសេចក្ដីទុក្ខបន្ដិចត្រង់ក្បាលរបស់ខ្ញុំ ។

បណ្ដាបទទាំងនោះ បទថា **ថោកំ ឧក្ខុ** សេចក្ដីថា សីសៈរបស់ខ្ញុំជាទុក្ខ គឺបានទទួលសេចក្ដីទុក្ខបន្ដិចបន្ដួច គឺមានប្រមាណបន្ដិចបន្ដួចស្រដៀងជាតិឃ្ចុំបន្ដិច មែនពិត សីសៈដែលជាទីតាំងនៃទុក្ខ លោកហៅថា មានទុក្ខ ។ បាលីថា **សីសេ ថោកំ ឧក្ខុ** ដូច្នេះក៏មាន ។ សួរថា ក៏កាលសរីរៈត្រូវកម្ទាំង

នៃសមាបត្តិគាំទ្រ សីស:របស់ព្រះថេរ:ជាទុក្ខបន្ទិចយ៉ាងណា? ឆ្វើយថា ព្រោះ ព្រះថេរ:ចេញចាកសមាបត្តិមិនយូរឡើយ ។ មែនពិត សេចក្តីទុក្ខមិនប្រាកដ ដល់លោកអ្នកដែលចូលសមាបត្តិទេ តែប្រាកដបន្ទិចបន្ទួចដល់បុគ្គលដែលទើប ចេញចាកសមាបត្តិ ប្រៀបដូចជាសត្វល្អិតទាំងឡាយ មានមូសជាដើមខាំ មិន ប្រាកដដល់បុគ្គលអ្នកដេកលក់ តែប្រាកដបន្ទិចបន្ទួចដល់បុគ្គលអ្នកភ្ញាក់ឡើង ព្រោះអាស្រ័យកាយ ។

កាលព្រះមហាមោគ្គល្លានដ៏មានអាយុ កើតគំនិតអស្ចារ្យឡើងថា ដែល ឈ្មោះថា អាការប្ញែករមែងមិនមានសូម្បីក្នុងរាងកាយ ដែលត្រូវយក្ខមាន កម្ទាំងខ្លាំងប្រហារដោយការញ្ជាយាមទាំងអស់ ព្រោះដូច្នោះ ដើម្បីប្រកាសសេចក្តី ដែលព្រះធម្មសេនាបតី មានអានុភាពច្រើន ដោយន័យមានជាអាទិ៍ថា ម្នាល អាវុសោសារីបុត្ត អស្ចារ្យណាស់ ។ ចំណែកព្រះធម្មសេនាបតី ក៏សម្តែងនូវភាព ដែលខ្ជួនលះបានមិនឱ្យសេសសល់នូវមន្ទិល មានឥស្សាមច្ឆរិយៈ និងអហង្ការ[១] ជាដើម ដោយការប្រកាសថាខ្ជួនមានឫទ្ធានុភាពច្រើន ដល់ព្រះមហាមោគ្គល្លាន នោះ ដោយន័យមានជាអាទិ៍ថា ម្នាលអាវុសោមោគ្គល្លាន អស្ចារ្យណាស់ ។ បទថា **បំសុបិសាចកម្ជ ន បស្សាម** សេចក្តីថា ពួកយើងមើលមិនឃើញ ត្រឹមតែខុទ្ទកប្រេតទាំងឡាយ ត្រាច់ទៅតាមស្ថានទី មានគំនរសំរាមជាដើម ។ ព្រោះដូច្នោះ ព្រះមហាថេរ: អ្នកជាកំពូលជាងអ្នកប្រាជ្ញាមគ្គផល ទើបបាន

១-សេចក្តីប្រកាន់ថាអញ គឺសេចក្តីប្រកាន់ថាអញថាគេ; សេចក្តីប្រកាន់ខ្ជួន : មិនព្រមចុះចាញ់គ្នា ដោយមានអហង្ការទាំងពីរខាង ។ (វចនានុក្រមខ្មែរ **ជោតញ្ញាណ** ជួន ណាត)

ពោលសំដៅដល់សេចក្តីមិនឃើញប្រេតទាំងនោះ ព្រោះមិនមានការតិះដៀលក្នុងកាលនោះ ។ ព្រោះហេតុនោះនុ៎ះឯង លោកទើបពោលថា **ឯតរហិ** ក្នុងឥឡូវនេះ ។

ក៏ព្រះដ៏មានព្រះភាគ ព្រះអង្គប្រថាប់នៅវត្តវេឡុវ័ន បានស្តាប់ការចរចាប្រាស្រ័យនេះរបស់ព្រះអគ្គសាវកទាំងពីរដោយទិព្វសោតញ្ញាណ ។ ព្រោះហេតុនោះ លោកទើបពោលថា **អស្សោសិ ខោ ភគវា** ដូច្នេះជាដើម ។ ពាក្យនោះមានអត្ថដូចដែលពោលទុកហើយនុ៎ះឯង ។

បទថា **ឯតមត្ថំ វិទិត្វា** បានដល់ ទ្រង់ជ្រាបសេចក្តីដែលព្រះសារីបុត្តដ៏មានអាយុ អ្នកប្រកបដោយកម្លាំងនៃសមាបត្តិ មានឫទ្ធានុភាពច្រើននេះ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះ សម្តែងដល់ការៈដែលព្រះសារីបុត្តដ៏មានអាយុនោះនុ៎ះឯង ដល់ភាពជាអ្នករឹងមាំ ។

បណ្តាបទទាំងនោះ បទថា **យស្ស សេលូបមំ ចិត្តំ ឋិតំ ជានុបកម្បតិ** សេចក្តីថា ចិត្តរបស់ព្រះខីណាស្រពណា ឧបមាដូចកំ្ពថ្មតាន់យ៉ាងក្រាស់ តាំងនៅដោយភាពជាអ្នកស្ងាត់ជំនាញ ព្រោះមិនមានកិលេសជាគ្រឿងធ្វើឱ្យញាប់ញ័រក្នុងទីទាំងពួង ចិត្តរបស់ព្រះខីណាស្រពនោះមិនកម្រើក គឺមិនញ័ររន្ធត់ដោយលោកធម៌ទាំងឡាយទាំងពួង ។ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងអាការដែលចិត្តរបស់ព្រះខីណាស្រពនោះ មិនញ័ររន្ធត់ព្រមដោយហេតុ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **វិរត្តំ** ។ បណ្តាបទទាំងនោះ បទថា **វិរត្តំ រជនីយេសុ** សេចក្តីថា អ្នកប្រាសចាកសេចក្តីត្រេកអរ ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិបីសូម្បីទាំងអស់

ដែលជាហេតុកើតរាគ: ដែលជាទីតាំងនៃសេចក្ដីត្រេកអរដោយអរិយមគ្គ គឺវិរាគ-ធម៌ អធិប្បាយថា កាត់រាគ:បានមិនឱ្យសេសសល់ដោយប្រការទាំងពួង ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិបីនោះ ។ បទថា **កោបនេយ្យ** សេចក្ដីថា រមែងមិនក្រោធ គឺរមែងមិនប្រទូស្ត បានដល់ មិនដល់អាការដែលខុសប្លែក ក្នុងអាយាត-វត្ថុ សូម្បីទាំងអស់ដែលជាទីតាំងនៃសេចក្ដីប្រទូស្ត ។ បទថា **យស្ស្យ ការិតំ ចិត្តំ** សេចក្ដីថា ចិត្តរបស់ព្រះអរិយបុគ្គលតាមដែលពោលហើយ ជាចិត្តបានអប់រំហើយ ដោយការ:ដែលនាំមកនូវភាពជារឹងមាំដោយអាការយ៉ាងនេះ គឺដោយន័យដូចពោលហើយ ។ បទថា **ការោ តំ ទុក្ខមេស្ស្យតិ** សេចក្ដីថា ទុក្ខនឹងមានដល់បុគ្គលដ៏ឧត្តមនោះអំពីណា គឺអំពីសត្ត ឬសង្ខារ អធិប្បាយថា បុគ្គលដូច្នោះរមែងមិនមានទុក្ខ ។

ចតុត្ថសុត្តវណ្ណា ជិដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៤

៥. ជាតសុត្តវណ្ណនា

អដ្ឋកថានាគសូត្រ

នាគសូត្រទី ៥ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **កោសម្ពិយំ** *សេចក្តីថា ជិតនគរដែលមានឈ្មោះយ៉ាងនេះថា កោសម្ពី ព្រោះសាងទុកក្នុងទីដែលតសីឈ្មោះកុសម្ព:អាស្រ័យនៅ ។ បទថា* **ឃោសិតារាមេ** *បានដល់ ក្នុងអារាមដែលឃោសិតសេដ្ឋីសាងទុក ។ បទថា* **ភគវា អាកិណ្ណោ វិហរតិ** *បានដល់ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅដោយភាពច្រឡូកច្រឡំ ។ សួរថា ក៏ព្រះដ៏មានព្រះភាគ មានភាពច្រឡូកច្រឡំ ហើយគង់នៅយ៉ាងណា ឆ្លើយថា មិនមានទេ ព្រោះថា បុគ្គលណាមួយ មិនអាចនឹងចូលគាល់ព្រះដ៏មានព្រះភាគ ដោយមិនប្រាថ្នា ។ មែនពិត ព្រះពុទ្ធជាព្រះដ៏-មានព្រះភាគ គឺជនទាំងឡាយ ចូលគាល់បានដោយលំបាក ក៏ព្រោះទ្រង់មិនជាប់នៅក្នុងទីទាំងពួង ។ ក៏ព្រះដ៏មានព្រះភាគ ទ្រង់អាស្រ័យសេចក្តីអនុគ្រោះក្នុងពួកសត្ត្ব ដោយទ្រង់ស្វែងរកប្រយោជន៍ ដើម្បីនឹងដកពួកសត្ត្ববចេញចាកឱឃ: ៤ ដោយសមគួរដល់បដិញ្ញាថា តថាគតរួចផុតហើយ នឹងឱ្យពួកសត្ត្ববរួចផុតដែរ ទើបទ្រង់ទទួលឱ្យបរិស័ទទាំង ៨ ចូលគាល់កាន់សម្ងាត់របស់ព្រះអង្គ តាមកាលតាមវេលា ។ ក៏ព្រះដ៏មានព្រះភាគ ត្រូវព្រះមហាករុណាជាស់តឿន ហើយ ព្រះអង្គជាអ្នកដឹងកាលចូលទៅក្នុងបរិស័ទនោះ ។ ប្រការនេះ ដែលព្រះពុទ្ធគ្រប់ព្រះអង្គ ធ្លាប់ប្រព្រឹត្តតៗមក ។ សេចក្តីនេះ លោកប្រាថ្នាថា ការនៅដោយច្រឡូកច្រឡំក្នុងទីនេះ ។*

តែក្នុងទីនេះ កាលកិក្ខុអ្នកក្រុងកោសម្ពីកើតជម្លោះ ព្រះសាស្តាទ្រង់នាំរឿងរបស់ព្រះចៅរបស់ដែនកោសលទ្រង់ព្រះនាមថា **ទីឃីតិ** មកប្រទានព្រះឱវាទ ដោយន័យមានជាអាទិ៍ថា ពិតមែន តាំងពីកាលណាមក ក្នុងលោក នេះ ពៀរទាំងឡាយមិនរម្ងាប់ ដោយការចងពៀរឡើយ[1] ។ ថ្ងៃនោះ កាលកិក្ខុទាំងនោះ ជម្លោះរបស់កិក្ខុទាំងឡាយនោះ មានរហូតមួយរាត្រី ។ សូម្បីក្នុងថ្ងៃទីពីរ ព្រះដ៏មានព្រះភាគ ក៏ត្រាស់រឿងនោះដូចគ្នា ។ សូម្បីក្នុងថ្ងៃនោះកិក្ខុទាំងនោះ ក៏ឈ្លោះគ្នានុ៎ះឯង រហូតមួយរាត្រី ។ សូម្បីក្នុងថ្ងៃទីបីព្រះដ៏មានព្រះភាគ ក៏ទ្រង់សម្តែងរឿងនោះដូចគ្នា ។ លំដាប់នោះ កិក្ខុមួយរូបក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់មានសេចក្តីខ្ជល់ខ្ជាយតិចចុះ ចូរប្រកបដោយការនៅជាសុខក្នុងបច្ចុប្បន្នចុះ ពួកខ្ញុំព្រះអង្គនឹងប្រាកដដោយការប្រេះធា ការឈ្លោះ ការទាស់ទែង និងការវិវាទនេះ ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា មោឃបុរសទាំងនេះ មានចិត្តត្រូវការប្រេះធាជាដើមគ្រប់សង្កត់ហើយ ឥឡូវនេះ តថាគតមិនអាចនឹងឱ្យពួកលោកព្រមព្រៀងគ្នាបានទេ និងក្នុងទីនេះ ក៏មិនមានអ្នកណានឹងញ៉ាំងកិក្ខុទាំងនេះឱ្យព្រមព្រៀងគ្នាបាន បើយ៉ាងហ្នឹង តថាគតក៏គប្បីត្រាច់ទៅតែមួយអង្គឯង កាលបើយ៉ាងនេះ កិក្ខុទាំងនេះក៏នឹងរៀការឈ្លោះគ្នា ។ ព្រោះការនៅក្នុងវិហារជាមួយគ្នានឹងកិក្ខុ

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ២២ ។

អ្នកឈ្លោះគ្នាទាំងនោះ និងការដែលពួកឧបាសកជាដើម ចូលទៅគាល់ដោយមិនមានអ្នកណែនាំរមែងធ្វើវិហារឱ្យច្រឡូកច្រឡំ ដោយប្រការដូច្នេះ លោកទើបពោលថា **តេន ខោ បន សមយេន ភិក្ខវ អាកិណ្ណា វិហរតិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ទុក្ខំ** បានដល់ មិនមែនសុខ អធិប្បាយថា មិនគួរប្រាថ្នា ព្រោះមានចិត្តមិនគួរត្រេកអរ ។ ព្រោះហេតុនោះនុ៎ះឯង លោកទើបពោលថា **ន ឆាសុ វិហរាមិ** តថាគតនៅមិនសប្បាយ ។ បទថា **រូបកដ្ឋោ** ប្រែថា ដៀសចេញ គឺនៅក្នុងទីឆ្ងាយ ។

ក៏ព្រះដ៏មានព្រះភាគ គ្រាទ្រង់ព្រះតម្រិះយ៉ាងនោះហើយ ទើបទ្រង់ជម្រះព្រះវរកាយពីព្រឹកព្រលឹម ស្តេចត្រាច់បិណ្ឌបាតក្នុងក្រុងកោសម្ពី មិនត្រាស់ប្រាប់អ្នកណាម្នាក់ ស្តេចយាងទៅតែមួយអង្គឯង មិនមានភិក្ខុជាឧបដ្ឋាក ទ្រង់ប្រថាប់គង់ត្រង់គល់ឈើភទ្ទសាល: ក្នុងបាលិលេយ្យព្រៃស្រោងនៃកោសលរដ្ឋ ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ ភគវ បុព្ពណ្ហសមយំ ។បេ។ ភទ្ទសាលមូលេ** ដូច្នេះជាដើម ។ បណ្តាទាំងនោះ បទថា **សាមំ** ប្រែថា ដោយព្រះអង្គឯង ។ បទថា **សំសាមេត្វា** ប្រែថា បិទបាំង ។ គប្បីនាំបទថា **សាមំ** មកប្រកបចូល សូម្បីក្នុងបទថា **បត្តចីវរមាទាយ** នេះ ។ បទថា **ឧបដ្ឋាកំ** បានដល់ មិនបានលាឧបដ្ឋាក មានឃោសិតសេដ្ឋីជាដើម អ្នកក្រុងកោសម្ពី និងព្រះអានន្ទ អ្នកជាអគ្គឧបដ្ឋាកក្នុងវិហារ ។

កាលព្រះសាស្តាស្តេចទៅហើយយ៉ាងនេះ ភិក្ខុ ៥០០ រូបពោលនឹង ព្រះ-អានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ ព្រះសាស្តាស្តេចយាងទៅតែមួយអង្គឯង ពួកយើងនឹងទៅតាម ។ ព្រះអានន្ទដ៏មានអាយុហាមថា ម្នាលអាវុសោ ក្នុងកាលដែលព្រះដ៏មានព្រះភាគទ្រង់ទុកដាក់សេនាសនៈ ដោយព្រះអង្គឯង ហើយទ្រង់កាន់បាត្រនិងចីវរ មិនទ្រង់លាពួកឧបដ្ឋាក និងមិនបានប្រាប់ភិក្ខុសង្ឆ ស្តេចយាងទៅមិនមានភិក្ខុជាគម្រប់ពីរ ជាព្រះអធ្យាស្ស័យរបស់ព្រះដ៏មានព្រះ-ភាគ ធម្មតាថា សាវកគួរបដិបត្តិឱ្យសមនឹងព្រះអធ្យាស្ស័យរបស់ព្រះសាស្តា ។ ព្រោះដូច្នោះ មិនគួរតាមព្រះដ៏មានព្រះភាគក្នុងថ្ងៃទាំងនេះដូច្នេះទេ សូម្បីខ្លួនឯងក៏មិនគួរទៅដែរ ។

បទថា **អនុបុព្វេន** *ប្រែថា តាមលំដាប់ ។ ព្រះសាស្តាស្តេចចារិកទៅតាមលំដាប់ស្រុក និងនិគម ទ្រង់ព្រះតម្រិះថា តថាគតនឹងជួបភិក្ខុអ្នកត្រាច់ទៅតែម្នាក់ឯងជាដំបូង ព្រោះដូច្នេះហើយ ទើបស្តេចយាងទៅកាន់ស្រុកឈ្មោះ ពាលកលោណការាម ហើយទ្រង់សម្តែងអានិសង្សក្នុងការនៅតែម្នាក់ឯង របស់ព្រះកគុត្តេរក្នុងទីនោះ រហូតដល់អស់បច្ឆាភត្ត និងរហូតដល់អស់រាត្រី ៣ យាម ក្នុងថ្ងៃស្អែក ព្រះអង្គមានកគុត្តេរជាបច្ឆាសមណៈស្តេចត្រាច់ទៅបិណ្ឌបាត ក្រោយមកឱ្យកគុត្តេរត្រឡប់មកពីទីនោះវិញ ហើយទ្រង់មានព្រះតម្រិះថា តថាគតនឹងជួបកុលបុត្រ ៣ រូប អ្នកនៅដោយការនៅព្រមព្រៀងគ្នា ទើបស្តេចទៅកាន់*

*បាចីនវង្សមិគទាយវ័ន ហើយទ្រង់សម្តែងអានិសង្សក្នុងការដែលកុលបុត្រទាំងនោះ អ្នកនៅដោយការនៅព្រមព្រៀងគ្នា រហូតដល់អស់មួយយប់ ទ្រង់ញ៉ាំងកុលបុត្រទាំងនោះត្រឡប់មកពីទីនោះវិញ ស្តេចដល់បាលិលេយ្យគ្រាមតែមួយព្រះអង្គឯង ។ អ្នកបាលិលេយ្យគ្រាមនាំគ្នាទទួលថ្វាយទានចំពោះព្រះដ៏មានព្រះភាគ ហើយសាងបណ្ណសាលាថ្វាយចំពោះព្រះដ៏មានព្រះភាគ ក្នុងដងព្រៃឈ្មោះរក្ខិត: ដែលនៅមិនឆ្ងាយបាលិលេយ្យគ្រាម ហើយទូលអាយាចនាព្រះអង្គ ឱ្យប្រថាប់នៅដោយពាក្យថា សូមព្រះដ៏មានព្រះភាគ ប្រថាប់នៅក្នុងទីនេះចុះ ។ ក៏ក្នុងរក្ខិតវ័ននោះ មានដើមសាល:មួយដើម គួរជាទីពេញចិត្ត ដែលមានឈ្មោះថា **ភទ្ទសាល:** ។ ព្រះដ៏មានព្រះភាគទ្រង់អាស្រ័យស្រុកនោះ ប្រថាប់នៅក្បែរគល់ឈើនោះជិតបណ្ណសាលាក្នុងព្រៃស្រោង ។ ព្រោះហេតុនោះ លោកទើបពោលថា* **ចាលិលេយ្យកេ វិហរតិ រក្ខិតវនសណ្ឌេ ភទ្ទសាលមូលេ** *ដូច្នេះ ។*

បទថា **ហត្ថិនាគោ** *បានដល់ ស្តេចដំរី គឺមេហ្វូង ។ បទថា* **ហត្ថិកុលកេហិ** *ប្រែថា ដំរីស្ទាវ ។ បទថា* **ហត្ថិច្ឆាបេហិ** *បានដល់ កូនដំរីដែលផឹកទឹកដោះ ។ ដែលគេហៅថា* **ភិង្គា** *ដូច្នេះក៏មាន ។ បទថា* **ឆិន្ទក្ការិ** *សេចក្តីថា ទំពាស៊ីស្មៅដែលមានចុងជាច់ គឺស្រជៀងដង្គត់ឈើ ដែលនៅសល់ពីដំរីទាំងឡាយដើរទៅខាងមុខៗហើយ ។ បទថា* **ឱកណ្ដោកកំ** *បានដល់ រុក្ខាវយវ: គឺមែកឈើដែលស្តេចដំរីនោះកាច់បំបាក់ធ្លាក់ចុះពីទីខ្ពស់ ។ បទថា* **អស្ស សាខាភङ្គំ** *សេចក្តីថា ដំរីទាំងនោះទំពាស៊ីរុក្ខាវយវ:ដែលកាច់បំបាក់ គឺមែកឈើដែលជារបស់ស្តេច*

ដំរីនោះ ។ បទថា **អាវិលានិ** សេចក្ដីថា រមែងផឹកទឹកដែលល្អក់ គឺដែលលាយដោយកក់ ព្រោះត្រូវដំរីទាំងនោះចុះទៅផឹកមុន ទើបធ្វើឱ្យល្អក់ ។ បទថា **ឋិតា-ហា** ប្រែថា ចាកកំពង់ ។ បាលីថា **ឋិតាហំ** ដូច្នេះក៏មាន ។ បទថា **អស្ស** ប្រកបជាមួយនឹង **ហត្ថិនាគស្ស** ។ បទថា **ឧបនិយ្យំសន្តិយោ** ប្រែថា ត្រដុស ។ ស្ដេចដំរីនោះ សូម្បីនឹងត្រូវពួកដំរីត្រដុស ក៏មិនក្រោធ ព្រោះភាពដែលខ្លួនមានចិត្ត ធំទូលាយ ព្រោះហេតុនោះ ដំរីញីទាំងនោះ ទើបនាំគ្នាត្រដុសស្ដេចដំរីនុ៎ះឯង ។ បទថា **យូថា** ប្រែថា គេចចេញពីហ្វូងដំរី ។

បទថា **យេន ភគវា តេនុបសង្កមិ** សេចក្ដីថា បានឮថា ស្ដេចដំរីនោះនឿយណាយនឹងការនៅក្នុងហ្វូង ទើបចូលទៅកាន់ព្រៃស្រោងនោះ ឃើញព្រះដ៏មានព្រះភាគ ក្នុងទីនោះ ជាសត្វមានចិត្តត្រជាក់ ដូចយកទឹក ១ពាន់ឆ្នាំងមករលត់ភាពក្ដៅ មានចិត្តជ្រះថ្លា បាននៅក្នុងសម្ងាត់របស់ព្រះដ៏មានព្រះភាគ ។ តាំងពីនោះមកស្ដេចដំរីនោះ ក៏តាំងនៅក្នុងវត្តបដិបត្តិ យកមែកឈើបោសជុំវិញដើមកទ្ទសាលៈ និងបណ្ណសាលាឱ្យប្រាសចាករបស់ខៀវ ថ្វាយទឹកខ្ពុរព្រះឱ្ស នាំទឹកសម្រាប់ស្រង់មកថ្វាយ ហើយថ្វាយឈើសម្រាប់ជម្រះព្រះទន្តចំពោះព្រះដ៏មានព្រះភាគ នាំផ្ទៃឈើមានរសធ្ងាញ់មកពីព្រៃ ហើយបង្ហោនថ្វាយចំពោះព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់សោយផ្ទៃឈើទាំងនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា បានឮថា ដំរីដ៏ប្រសើរនោះ ក៏ធ្វើប្រទេសនោះ មិនឱ្យមានស្មៅស្រស់

ទាំងតម្កល់ទឹកធាន់ ទឹកប្រើប្រាស់ថ្វាយព្រះមានព្រះភាគដោយប្រមោយដូច្នេះ ។ ស្តេចដំរីនោះយកប្រមោយត្រកងឱ្យសមក ក្ងួតគ្នានិងគ្នាឱ្យកើតជាក្ងើង ធ្វើឱ្យក្ងើងនេះសន្ធោសន្ធៅ ធ្វើដុំថ្មក្នុងទីនោះឱ្យក្តៅ យកឈើប្រមៀលដុំថ្មនោះមកបោះចុះទៅក្នុងទឹក ដឹងថាទឹកក្តៅហើយ ទើបចូលទៅក្នុងសម្ងាត់របស់ព្រះដ៏-មានព្រះភាគហើយឈរ ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ស្តេចដំរីប្រាថ្នានឹងឱ្យតថាគតស្រង់ ហើយក៏យាងព្រះអង្គទៅកាន់ទីនោះ ហើយស្រង់ទឹក ។ សូម្បីក្នុងការថ្វាយទឹកសម្រាប់សោយក៏ដូចគ្នា ។ ក៏កាលទឹកសោយនោះត្រជាក់ឡើងហើយ ក៏ចូលទៅគាល់ដែលលោកសំដៅពោលទុកថា ដំរីតម្កល់ទឹកធាន់ ទឹកប្រើប្រាស់ ទុកថ្វាយចំពោះព្រះដ៏មានព្រះភាគដោយប្រមោយ ។ បទមានជាអាទិ៍ថា **អថ ខោ ភគវតោ រហោគតស្ស** ជាបទសម្តែងការដែលមហានាគទាំង ២ ពិចារណាដល់សេចក្តីសុខដែលកើតអំពីវិវេក ។ ពាក្យនោះ មានអត្ថដូចដែលពោលទុកហើយនុ៎ះឯង ។

បទថា **អត្តនោ ច បវិវេកំ វិចិន្ត្វា** សេចក្តីថា ទ្រង់ជ្រាបកាយវិវេកដែលបានដោយមិនច្រឡូកច្រឡំ ដោយចំណែកណាមួយ ។ ចំណែកចិត្តវិវេក និងឧបធិវិវេក រមែងមានដល់ព្រះដ៏មានព្រះភាគគ្រប់កាលតែម្តង ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់ព្រះអង្គ និងស្តេចដំរីមានអធ្យាស្រ័យស្មើគ្នា ក្នុងសេចក្តីត្រេកអរក្រៃលែងក្នុងទីស្ងាត់ ។

ក្នុងសេចក្ដីនោះមានសេចក្ដីសង្ខេប ដូចតទៅនេះ ចិត្តរបស់ស្ដេចដំរីអ្នកមានកុ-ងទន្ទាំនេះ គឺមានកុ-ងទន្ទាំដូចនឹងទន្ទាំរថ សមគ្នា គឺធៀបគ្នាបាននឹងចិត្តដែលប្រសើររបស់ព្រះពុទ្ធអ្នកប្រសើរ ។ បើមានពាក្យសួរសិកថា សមគ្នាបានយ៉ាងណា? ឆ្លើយថា ព្រោះបុគ្គលត្រេកអរតែម្នាក់ឯងនៅក្នុងព្រៃ អធិប្បាយថា ព្រោះហេតុដែលព្រះពុទ្ធនាគទ្រង់មានព្រះតម្រិះថា កាលមុននៅដោយការច្រឡូកច្រឡំ ព្រោះដូច្នេះ ទើបទ្រង់រង្គៀសការនៅច្រឡូកច្រឡំក្នុងកាលមុន កាលនឹងទ្រង់ចម្រើនវិវេក ឥឡូវនេះ ទើបព្រះអង្គនៅតែមួយអង្គឯង គឺមិនមានជនជាគម្រប់ពីរ ត្រេកអរ គឺអភិរម្យក្នុងព្រៃ គឺក្នុងព្រៃស្រោងយ៉ាងណា សូម្បីស្ដេចដំរីនេះក៏ដូច្នោះ កាលមុនរង្គៀសការនៅច្រឡូកច្រឡំនឹងពួកដំរីជាដើម កាលនឹងកពូនវិវេក ឥឡូវនេះ ទើបជាដំរីឯកោ គឺមិនមានសម្ងាញ់ ត្រេកអរ គឺរីករាយនៅឯកោក្នុងព្រៃ ។ ព្រោះដូច្នោះ ចិត្តរបស់ស្ដេចដំរីនោះដូចដែលពោលមកនេះ ទើបដូចនឹងចិត្តរបស់ព្រះដ៏មានព្រះភគ ព្រោះមានសេចក្ដី អធិប្បាយថា ជាអ្នកត្រេកអរក្នុងការនៅតែម្នាក់ឯង គឺប្រាកដស្មើតែមួយអង្គឯង ។

បញ្ចមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៥

៦. បិណ្ឌោលសុត្តវណ្ណនា

អដ្ឋកថាបិណ្ឌោលសូត្រ

បិណ្ឌោលការទ្វាជសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **បិណ្ឌោលការទ្វាជោ** *សេចក្ដីថា ឈ្មោះថា* **បិណ្ឌោលៈ** *ព្រោះបួសស្វះស្វែងរកដុំបាយ ។ បានឮថា បិណ្ឌោលៈជាព្រាហ្មណ៍អស់កោគៈ ឃើញលាភនិងសក្ការៈជាច្រើនរបស់ភិក្ខុសង្ឆ ទើបចេញបួសដើម្បីត្រូវការដុំបាយ ។ ព្រះបិណ្ឌោលៈនោះ កាន់យកនូវផែនក្បឿងដ៏ធំ យល់ថាជាបាត្រ ត្រាប់ទៅនាន់ បបរយាគូដែលពេញក្បឿង បរិភោគកត្តនិងនំព្រមរបស់ទំពាស៊ី ។ លំដាប់នោះ ពួកភិក្ខុក្រាបទូលសេចក្ដី ដែលព្រះបិណ្ឌោលៈបរិភោគគ្រប់គ្រាន់ ដល់ព្រះសាស្តា ។ ព្រះសាស្តាទើបទ្រង់មិនអនុញ្ញាតឱ្យលោកប្រើស្ងោកបាត្រ ។ ទើបផ្ទាប់បាត្រទុកក្រោមគ្រែ ។ ព្រះបិណ្ឌោលៈកាលនឹងដាក់ក៏រុញដាក់ទុក កាលនឹងកាន់យកក៏ទាញយកមកកាន់ ។ កាលកន្ទងទៅ ក្បឿងនោះក៏រិចរិលទៅ ព្រោះការចេញពណ៌ ដាក់ត្រឹមតែបាយមួយនាឡិតែប៉ុណ្ណោះ ។ លំដាប់នោះ ពួកភិក្ខុទើបក្រាបទូលសេចក្ដីនោះចំពោះព្រះសាស្តា ។ បន្ទាប់មក ព្រះសាស្តាទើបទ្រង់អនុញ្ញាតឱ្យភិក្ខុមានស្ងោកបាត្របាន ។ សម័យតមក ព្រះថេរៈចម្រើនឥន្ទ្រិយតាំងនៅក្នុងព្រះអរហត្តផល ។ ព្រោះដូច្នោះ គេទើបហៅព្រះថេរៈថា* **បិណ្ឌោលៈ** *ព្រោះកាលមុនព្រះថេរៈស្វែងរកអាមិសដើម្បីដុំបាយ តែដោយគោត្រហៅថា* **ការទ្វាជៈ** *ព្រោះរួមស័ព្ទទាំង ២ ស័ព្ទចូលជាមួយគ្នាផង ទើបហៅថា* **បិណ្ឌោលការទ្វាជៈ** *។*

បទថា **អារញ្ញិកា** *សេចក្ដីថា ឈ្មោះថា* **អារញ្ញិកៈ** *ព្រោះព្រះថេរៈនៅក្នុងព្រៃ ដោយហាមសេនាសនៈជាយស្រុកចេញ ។ បទថា* **អារញ្ញិកា** *នេះ*

ជាឈ្មោះរបស់ភិក្ខុអ្នកប្រព្រឹត្តសមាទានអរញ្ញិកធុតង្គ ។ ម្យ៉ាងទៀត ការធ្លាក់ចុះនៃដុំអាមិស គឺភិក្ខាហារ ឈ្មោះថា **បិណ្ឌបាត** ។ អធិប្បាយថា ដុំបាយដែលអ្នកដទៃឱ្យធ្លាក់ចុះក្នុងបាត្រ ។ ភិក្ខុឈ្មោះថា **បិណ្ឌបាតិកៈ** ព្រោះស្វែងរកបិណ្ឌបាត គឺចូលទៅស្វែងរកត្រកូលនោះៗ ។ ម្យ៉ាងទៀត ឈ្មោះថា **បិណ្ឌបាតី** ព្រោះមានដែលធ្លាក់ទៅ គឺត្រាច់ទៅដើម្បីបិណ្ឌៈជាវត្ត ។ **បិណ្ឌបាតី** នុ៎ះឯង ជា**បិណ្ឌបាតិកៈ** ។ សំពត់ ឈ្មោះថា **បង្សុកូលៈ** ព្រោះដូចជាប្រលាក់អំបិលដោយធូលី ព្រោះអត្ថថាហុយឡើង ដោយហេតុតាំងនៅលើធូលី ក្នុងទីមានគំនរសំរាមជាដើម ។ ម្យ៉ាងទៀត សំពត់ ឈ្មោះថា **បង្សុកុលៈ** ព្រោះទៅ គឺដល់ភាពជារបស់គួរខ្ពើមដូចធូលី ។ ការទ្រទ្រង់សំពត់បង្សុកូល ឈ្មោះថា **បង្សុកុលៈ** ។ ការទ្រទ្រង់សំពត់បង្សុកូលនោះជាប្រក្រតីរបស់ភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះឈ្មោះថា **បង្សុកូលិកៈ** ។ ចីវរ ៣ គឺសង្ឆាដិ ឧត្តរាសង្គៈ (ចីវរ) និងអន្តរវាសកៈ (ស្បង់) ឈ្មោះថា ត្រៃចីវរ ។ ការទ្រទ្រង់សំពត់ត្រៃចីវរ ឈ្មោះថា **តិចីវរៈ** ។ ការទ្រទ្រង់សំពត់ត្រៃចីវរនោះជាប្រក្រតីរបស់ភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា **តេចីវរិកៈ** ។ អត្ថនៃបទថា **អឃ្ឌិច្ចោ** ជាដើម ខ្ញុំបានពោលទុកហើយក្នុងកាលមុននុ៎ះឯង ។ បុគ្គលដែលកម្ចាត់កិលេស លោកហៅថា **ធុតៈ** ក្នុងបទថា **ធុតវាឌោ** ។ ម្យ៉ាងទៀត ធម៌ជាគ្រឿងកម្ចាត់កិលេស លោកក៏ហៅថា **ធុតៈ** ។ បណ្តាធុតៈ ២ យ៉ាងនោះ ភិក្ខុឈ្មោះថា មានធុតៈ តែមិនមានធុតវាទក៏មាន មិនមានធុតៈ តែមានធុតវាទក៏មាន មិនមានទាំងធុតៈ មិនមានទាំងធុតវាទក៏មាន មានទាំងធុតៈ មានទាំងធុតវាទក៏មាន គប្បីជ្រាបពួក ៤ នៃធុតៈដូចពោលមកនេះ ។ បណ្តាធុតៈ ២

*យ៉ាងនោះ ភិក្ខុណាសមាទានប្រព្រឹត្តធុតធម៌ដោយខ្លួនឯង មិនបបួលអ្នកដទៃ ព្រោះការប្រព្រឹត្តសមាទានធុតធម៌នោះនេះជាធុត:ពួកទី ១ ។ ចំណែកភិក្ខុណា មិនប្រព្រឹត្តសមាទានធុតធម៌ដោយខ្លួនឯង តែបបួលអ្នកដទៃ នេះឈ្មោះថា ជាធុតធម៌ទី ២ ។ ភិក្ខុណាវៀរទាំងពីរ នេះជាធុត:ទី ៣ ។ ចំណែកភិក្ខុណា ដល់ព្រមដោយធុត:ទាំង ២ នេះឈ្មោះថា ជាធុត:ទី ៤ ។ ក៏ព្រះបិណ្ឌោលការទ្វាជ: ក៏មានសភាពដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា **ធុតវាទ:** ។ ក៏នេះជានិទ្ទេសពោលអំពីសមាស ដែលលោកសង្ខេបស័ព្ទមួយ នៅសល់ទុកស័ព្ទមួយ ដូចថា **នាមញ្ច រូបញ្ច នាមរូបញ្ច នាមរូបំ** ប្រែថា នាម ១ រូប ១ នាមរូប ១ ជានាមរូប ។*

ក្នុងបទថា **អជ្ঝិចិត្តមនុយុត្តោ** *នេះ មានវិនិច្ឆ័យដូចតទៅនេះ គប្បីជ្រាបសេចក្តីដែលចិត្តជាអធិចិត្ត ព្រោះប្រកបដោយសមាបត្តិ ៨ ឬប្រកបដោយអរហត្តផលសមាបត្តិ ។ តែក្នុងទីនេះ គប្បីជ្រាបថា អរហត្តផលចិត្ត ។ សមាធិក្នុងសមាបត្តិនោះ ។ នុ៎ះឯង ឈ្មោះថា* **អធិចិត្ត** *។ ចំពោះក្នុងទីនេះគប្បីជ្រាបថា អរហត្តផលសមាធិ ។ តែអាចារ្យពួកខ្លះពោលថា ចិត្តដែលប្រកបដោយសមថ: និងវិបស្សនា លោកហ្ការ៉ាក្នុងទីនេះថា អធិចិត្ត ដូចព្រះដ៏មានព្រះភាគត្រាស់នៅក្នុងអធិចិត្តសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបនូវអធិចិត្តហើយ ត្រូវធ្វើទុកក្នុងចិត្តនូវនិមិត្ត ៣ យ៉ាង ក្នុងកាលដ៏គួរ[1] ។ ពាក្យនោះមិនត្រូវ គប្បីកាន់យកសេចក្តីខាងដើមមុននុ៎ះឯង ។*

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៦១ ទំព័រ ៣៨៥ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្ដីថា ទ្រង់ជ្រាបដោយប្រការទាំងពួងនូវអត្ថនេះពោលគឺ ការប្រកបអធិចិត្ត ដែលដល់ព្រមដោយការអធិដ្ឋានបរិក្ខារ និងការមិនខ្ជះខាតរបស់ព្រះបិណ្ឌាលការទ្វាជ:ដ៏មានអាយុ ។ កាលនឹងទ្រង់សម្ដែងថាការប្រកបអធិចិត្ត ក៏គឺការតាំងមាំនៃព្រះសាសនារបស់តថាគត ទើបទ្រង់បន្ទឺឧទាននេះដោយប្រការដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **អនូបវាទោ** *បានដល់ មិនចូលទៅថាប្រទូស្ដចំពោះជនណាមួយដោយវាចា ។ បទថា* **អនូបឃាតো** *បានដល់ មិនបៀតបៀនដោយកាយចំពោះជនណាមួយ ។ អត្ថនៃបទថា* **ចាតិមោក្ខ** *ក្នុងបទថា* **ចាដិមោក្ខេ** *នេះ លោកពោលមានប្រការផ្សេងៗ ក្នុងកាលមុន ។ ធម៌ដែលមានការមិនកន្ទ្ងលើ្ងសអាបត្តិ ៧ កង ក្នុងព្រះបាដិមោក្ខនោះ ជាលក្ខណ: ឈ្មោះថា* ***សំវរ:*** *។ ការស្គាល់ប្រមាណ ដោយអំណាចការទទួលនិងការបរិភោគ ឈ្មោះថា* **មត្តញ្ញុតា** *។ បទថា* **បន្តញ្ច សយនាសនំ** *បានដល់ ទីដេកនិងទីអង្គុយដ៏ស្ងាត់ គឺរឿងការនៅរួមគ្នា ។ បទថា* **អធិចិត្តេ ច អាយោគោ** *បានដល់ ការប្រកបការនាដើម្បីសម្រេចសមាបត្តិ ៨ ។ ន័យម្យ៉ាងទៀត បទថា* **អនូបវាទោ** *បានដល់ មិនពោលពាក្យប្រទូស្ដសូម្បីចំពោះជនណាមួយ ។ ព្រោះហេតុនោះ លោកទើបសង្គ្រោះសីល ដែលប្រព្រឹត្តទៅតាមវាចាសូម្បីទាំងអស់ ។ បទថា* **អនូបឃាតោ** *បានដល់ មិនធ្វើការបៀតបៀនចំពោះជនណាមួយ គឺការបៀតបៀនអ្នកដទៃដោយកាយ ។ ព្រោះហេតុនោះ លោកទើបសង្គ្រោះសីលដែលប្រព្រឹត្តទៅតាមកាយទាំងអស់ ក៏ដើម្បីនឹងទ្រង់សម្ដែងសីល*

ទាំង ២ ដែលធ្លាក់ចុះក្នុងខាងក្នុងសាសនារបស់ព្រះពុទ្ធទាំងអស់ ទើបត្រាស់ថា **ចាដិមោក្ខេ ច សំវរោ** ដូច្នេះ ច-ស័ព្ទ ត្រឹមតែជានិបាត ។ បទថា **ចាដិមោក្ខេ ច សំវរោ** សេចក្ដីថា ការមិនទៅប្រទូស្ត និងការមិនចូលទៅបៀតបៀន ដែលជាហេតុសង្រួមក្នុងព្រះបាតិមោក្ខ ។ ម្យ៉ាងទៀត បទថា **ចាដិមោក្ខេ** ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថអធិករណៈ ។ សំវរៈជាទីអាស្រ័យក្នុងបាតិមោក្ខ ។ សួរថា ក៏សំវរៈនោះគឺអ្វី? ឆ្លើយថា គឺការមិនទៅប្រទូស្ត ការមិនបៀតបៀន ។ មែនពិត ក្នុងកាលឧបសម្បទា កាលពោលដោយការមិនបែកគ្នា បាតិមោក្ខសីល ឈ្មោះថា ភិក្ខុសមាទានហើយ ។ កាលភិក្ខុតាំងនៅក្នុងបាដិមោក្ខនោះ តពីនោះ សំវរៈរមែងមានដោយអំណាចការមិនប្រទូស្ត និងការមិនបៀតបៀន សំវរៈនោះ លោកហៅថា ការមិនប្រទូស្ត និងការមិនបៀតបៀន ។ ម្យ៉ាងទៀត បទថា **ចាដិមោក្ខេ** ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថថា គប្បីឱ្យសម្រេច ដូចពាក្យថា ការមិនសូន្យនៃចិត្ត មានអយោនិសោមនសិការជាហេតុជិត ។ អធិប្បាយថា ការមិនប្រទូស្ត ការមិនបៀតបៀន ញ៉ាំងបាដិមោក្ខគប្បីឱ្យសម្រេច គឺការមិនប្រទូស្ត និងការមិនបៀតបៀន សង្គ្រោះចូលក្នុងបាតិមោក្ខសំវរៈដូចគ្នា ។ ក៏ដោយពាក្យថា **សំវរោ ច** នេះ ជាស័ព្ទនៃសំវរៈ ៤ នេះ គឺសតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយសំវរៈ ១ ។ សំវរៈ ៤ ទាំងនេះ មានការធ្វើបាដិមោក្ខឱ្យសម្រេច ។

បទថា **មត្តញ្ញុតា ច ភត្តស្មឿ** បានដល់ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ដោយអំណាចនៃការស្វែងរក ការទទួល ការបរិភោគ និងការលះបង់ ។ បទថា **បន្តញ្ច សយនាសនំ** បានដល់ ទីដេកនិងទីអង្គុយដែលស្ងាត់ មានព្រៃនិងគល់ឈើជាដើម ដែលសមគួរដល់ភាវនា ។ បទថា **ចិត្តេ ច អាយោគោ**

សេចក្ដីថា កាលអរហត្តផលចិត្ត ពោលគឺ ឈ្មោះថា អធិចិត្ត ព្រោះជាចិត្តក្រៃ-លែង គឺព្រោះខ្ពស់បំផុតជាងចិត្តទាំងពួងឱ្យសម្រេច ការប្រារព្ធសេចក្ដីព្យាយាមរមែងមានដោយអំណាចសមថភាវនានិងវិបស្សនាភាវនា ដើម្បីធ្វើអរហត្តផលចិត្តនោះឱ្យសម្រេច ។ បទថា **ឯតំ ពុទ្ធាន សាសនំ** សេចក្ដីថា កិរិយាមិនតិះដៀលអ្នកដទៃ ១ កិរិយាមិនបៀតបៀនអ្នកដទៃ ១ កិរិយាសង្រួមក្នុងព្រះបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ មានការស្វែងរក និងកាន់យកជាដើម ១ ទីដេកទីអង្គុយដ៏ស្ងាត់ ១ ការប្រកបសេចក្ដីព្យាយាមក្នុងអធិចិត្ត តាមដែលពោលហើយ ១ នេះជាពាក្យទូន្មាន គឺជាឱវាទ អធិប្បាយថា ជាពាក្យទូន្មានរបស់ព្រះពុទ្ធទាំងឡាយ សិក្ខា ៣ គប្បីជ្រាបថា ព្រះដ៏មានព្រះភាគត្រាស់ហើយ ដោយព្រះគាថានេះ ដោយប្រការដូច្នេះ ។

ឆដ្ឋមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៦

៧. សារីបុត្តសុត្តវណ្ណនា

អដ្ឋកថាសារីបុត្តសូត្រ

ក្នុងសូត្រទី ៧ នេះ ពាក្យដែលមិនបានពោលក្នុងកាលមុន មិនមានទេ ។ ក្នុងគាថាគប្បីជ្រាបសេចក្តីដូចតទៅនេះ

បទថា **អជ្ঝិចេតសោ** ប្រែថា អ្នកមានអធិចិត្ត ។ អធិប្បាយថា អ្នកប្រកបដោយអរហត្តផលចិត្ត ដែលក្រៃលែងជាងចិត្តទាំងពួង ។ បទថា **អប្បជ្ជតো** ប្រែថា អ្នកមិនប្រមាទ លោកអធិប្បាយថា អ្នកប្រកបដោយការធ្វើរឿយៗក្នុងធម៌ដែលរកទោសមិនបាន ដោយសេចក្តីមិនប្រមាទ ។ បទថា **មុនិនো** សេចក្តីថា ព្រះខីណាស្រពឈ្មោះថា **មុនី** ព្រោះដឹងលោកទាំងពីរយ៉ាងនេះថា បុគ្គលណាដឹងប្រយោជន៍ទាំងពីរក្នុងលោក បុគ្គលនោះ ឈ្មោះថា មុនី ដោយហេតុនោះ[1] ឬព្រោះប្រកបដោយញាណ ពោលគឺ បញ្ញាដែលសម្បយុត្តដោយអរហត្តផលនោះ លោកហៅថា **មុនី** ។ ដល់ព្រះមុនីនោះ ។ បទថា **មុនិបថេសុ សិক্খតো** សេចក្តីថា អ្នកសិក្សាក្នុងពោធិបក្ខិយធម៌ ៣៧ ប្រការ ឬក្នុងសិក្ខា ៣ ដែលជាផ្លូវនៃមោនៈ ពោលគឺ អរហត្តមគ្គញ្ញាណ ។ ក៏ពាក្យនេះលោកសំដៅយកបដិបទាដែលជាចំណែកខាងដើម ។ មែនពិត អ្នកសម្រេចការសិក្សា ឈ្មោះថា ព្រះអរហន្ត ព្រោះដូច្នោះ គប្បីឃើញសេចក្តីក្នុងទីនេះថា ដល់ព្រះមុនីអ្នកសម្រេចការសិក្សាដូចពោលមកនេះ គឺអ្នកដល់នូវភាពចាស់ក្លាលោកហៅថាជាមុនី ដោយការសិក្សានេះ ។ ក៏ព្រោះប្រការនោះឯងដូច្នោះ អត្ថនៃបទទាំង ៣ នេះយ៉ាងនេះ គឺរបស់លោកអ្នកមានអធិចិត្ত (ចិត្តជាសមាធិថ្នាក់ឈាន) គឺមគ្គចិត្ত ផលចិត្តខាងក្រោម អ្នកមិនប្រមាទដោយសេចក្តីមិនប្រមាទ ក្នុងការបដិបត្តិដែលជាប់ដោយការត្រាស់ដឹងសច្ចៈ ៤ ឈ្មោះថា អ្នក

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៧៧ ។

ជាមុនី ព្រោះប្រកបដោយមគ្គញ្ញាណទើបសម ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃ ហេតុរបស់បទថា **អប្បមជ្ជតោ ច សិក្ខតោ** ថា ឈ្មោះថា មានអធិចិត្ត ព្រោះ ហេតុនៃសេចក្ដីមិនប្រមាទ និងព្រោះហេតុនៃការសិក្សា ។ បទថា **សោកា ន ភវន្តិ តាទិនោ** សេចក្ដីថា សេចក្ដីសោកសៅ គឺសេចក្ដីព្រាត់ប្រាស់ចាកវត្ថុដែល គួរប្រាថ្នាជាដើម ជាទីតាំងរមែងមិនមានក្នុងខាងក្នុងរបស់អ្នករឹងមាំ គឺរបស់ មុនីអ្នកជាព្រះខីណាស្រព ។ ម្យ៉ាងទៀត ក្នុងបទថា **តាទិនោ** នេះ មានអធិប្បាយ ដូច្នេះថា សេចក្ដីសោកសៅ រមែងមិនមានដល់មុនីឃើញបែបនេះ អ្នកប្រកប ដោយលក្ខណៈនៃភាពជារឹងមាំ ។ បទថា **ឧបសន្តស្ស** បានដល់ អ្នកស្ងប់-រម្ងាប់ ព្រោះស្ងប់កិលេស មានរាគៈជាដើមបានមិនឱ្យសេសសល់ ។ បទថា **សទា សតីមតោ** បានដល់ អ្នកមិនរឿរ សតិរហូតដល់អស់កាលជានិច្ច ។ ក៏ក្នុងទីនេះ ដោយបទថា **អធិចេតសោ** នេះ គប្បីជ្រាបថា លោកប្រាថ្នាយក អធិចិត្តសិក្ខា ។ ដោយបទថា **អប្បមជ្ជតោ** នេះ លោកប្រាថ្នាយកអធិសីល-សិក្ខា ។ ដោយបទថា **មុនិនោ មោនបថេសុ សិក្ខតោ** នេះ លោកប្រាថ្នាយក អធិបញ្ញាសិក្ខា ។ ម្យ៉ាងទៀតដោយបទថា **មុនិនោ** នេះ លោកប្រាថ្នាយកអធិ-បញ្ញាសិក្ខា ។ ដោយបទថា **មោនបថេសុ សិក្ខតោ** នេះ លោកប្រាថ្នាយក បដិបទា ដែលជាចំណែកខាងដើមនៃលោកុត្តរសិក្ខាទាំងនោះ ។ ដោយបទថា **សោកា ន ភវន្តិ** ជាដើម គប្បីជ្រាបថា លោកប្រកាសអានិសង្សនៃការ បំពេញសិក្ខា ។ ពាក្យដែលនៅសល់មានន័យដូចពោលហើយនុ៎ះឯង ។

សត្តមសុត្តវណ្ណនា

ចប់ អដ្ឋកថាសូត្រទី ៧

សម្រាប់ជាធម្មទាន

៨. សុន្ទរីសុត្តវណ្ណនា

អដ្ឋកថាសុន្ទរីសូត្រ

សុន្ទរីសូត្រទី ៨ *មានវិនិច្ឆ័យដូចតទៅនេះ*

អត្ថនៃបទមានជាអាទិ៍ថា **សក្ក្លោ** *ខ្ញុំបានពោលទុកហើយក្នុងកាលមុននុ៎ះឯង ។ បទថា* **អសហមានា** *ប្រែថា អត់ធន់មិនបាន ។ អធិប្បាយថា ច្រណែន ក្លាប់សេចក្ដីថា មិនអត់ធន់នឹងសក្ការៈរបស់ភិក្ខុសង្ឆ ។ បទថា* **សុន្ទរី** *ជាឈ្មោះរបស់នាង ។*

បានឮថា ក្នុងវេលានោះ បណ្ដានាងបរិព្វាជិកាទាំងអស់ នាងជាអ្នកមានរូបល្អ គួរសរសើរ គួរជ្រះថ្លា ប្រកបដោយពណ៌កាយល្អយ៉ាងក្រៃលែង ព្រោះហេតុនោះនុ៎ះឯង នាងទើបប្រាកដថា ***សុន្ទរី*** *។ ក៏នាងកាលនូវវ័យក្រមុំ មានមារ-យាទមិនគួរឱ្យចាប់ចិត្ត ។ ព្រោះហេតុនោះ អន្យតិ្ថយទាំងនោះ ទើបបញ្ជូនបន្ទៃមនាងទៅក្នុងបាបកម្ម ។ មែនពិត អន្យតិ្ថយទាំងនោះ សាបសូន្យលាភសក្ការៈទៅឯង ចាប់ផ្ដើមអំពីវេលាដែលព្រះពុទ្ធឧប្បត្តិឡើង ឃើញលាភ និងសក្ការៈច្រើនរកប្រមាណមិនបាន ប្រព្រឹត្តទៅដល់ព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឆ ដោយន័យដែលមកហើយក្នុងអដ្ឋកថាអក្កោសសូត្រ ក្នុងកាលមុនទើបនាំគ្នាច្រណែន រួមប្រឹក្សាគ្នាថា ចាប់ផ្ដើមតាំងពីកាលដែលព្រះសមណ-គោតមឧប្បត្តិហើយ ពួកយើងវិនាសសាបសូន្យលាភសក្ការៈ អ្នកណាៗ មិនដឹងថាពួកយើងមាននៅ ព្រោះអាស្រ័យហេតុអ្វីហ្ន៎ សត្វលោកទើបនាំគ្នាជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះសមណគោតម ទើបបង្ហោននាំសក្ការៈចូលទៅថ្វាយជាច្រើន ។ បណ្ដាអន្យតិ្ថយទាំងនោះ អន្យតិ្ថយម្នាក់ឡើងថា ព្រះសមណគោតមប្រសូតអំពីត្រកូលខ្ពស់ ទ្រង់ប្រសូតតាមប្រពៃណីរបស់មហាសម្មតិរាជ ដែលមិន*

លាយឡំគ្នា ។ អន្យតិរ្ថិយម្នាក់ទៀតពោលឡើងថា ក្នុងកំណើតនៃត្រកូលសក្យ-
វង្ស ព្រះអង្គមានហេតុគួរអស្ចារ្យប្រាកដច្រើនណាស់ ។ អន្យតិរ្ថិយម្នាក់ទៀត
ពោលឡើងថា ព្រះបាទទាំង ២ របស់ព្រះអង្គ ដែលជនទាំងឡាយបង្ហោនៀ
ចូលទៅសំពះកាឡទេវិលតាបស ត្រឡប់ជាទៅតាំងនៅលើជជារបស់ទេវិល-
តាបសនោះ ។ អន្យតិរ្ថិយម្នាក់ទៀតពោលឡើងថា ក្នុងទិវាវប្ផមង្គល កាល
ព្រះអង្គទ្រង់ផ្ទុំក្នុងស្រមោលនៃដើមឈើ សូម្បីកាលថ្ងៃជ្រេកទ្ងងទៅហើយ
ស្រមោលនៃដើមព្រីងគង់តាំងនៅមិនផ្ទាស់ទៅតាម ។ អន្យតិរ្ថិយម្នាក់ទៀត
ពោលឡើងថា ព្រះអង្គមានរូបល្អ គួរសរសើរ គួរជ្រះថ្លា ព្រោះដល់ព្រមដោយ
ព្រះធោម ។ អន្យតិរ្ថិយម្នាក់ទៀតពោលឡើងថា ព្រះអង្គទតព្រះនេត្រឃើញ
និមិត្ត គឺមនុស្សចាស់ មនុស្សឈឺចាប់ មនុស្សស្លាប់ និងបព្វជិត ទ្រង់កើតសេចក្ដី
សង្វេគ ទ្រង់លះចក្រពត្តិសម្បត្តិ ដែលនឹងមកដល់ ហើយទ្រង់បព្វជ្ជា ។ ពួក
អន្យតិរ្ថិយមិនដឹងបុញ្ញសម្ភារៈរបស់ព្រះដ៏មានព្រះភាគ ដែលមិនទូទៅដល់ជន
ដទៃ ដែលព្រះអង្គធ្វាប់សន្សំមករហូតដល់អស់កាលរកប្រមាណមិនបាន
សល្ទេខបដិបទា ដែលរកអ្នកប្រៀបស្មើមិនបាន ដល់ភាពជាអ្នកមានបារមីដ៏
ឧក្រិដ្ឋ និងពុទ្ធានុភាពមានញាណសម្ផទា និងហានសម្ផទាជាដើមដ៏ក្រៃលែង
ទើបធ្វើឱ្យដល់ហេតុ ដែលព្រះដ៏មានព្រះភាគដល់នូវហេតុ ជាទីវាប់អានច្រើន
នោះ។ តាមដែលខ្ជួនបានឃើញ បានឮមក ទើបស្វែងរកហេតុដែលព្រះអង្គ
នឹងមិនជាទីវាប់អាន កាលមិនជួប ទើបគិតគ្នាថា ព្រោះហេតុអ្វីហ្ន៎ ពួកយើងនឹង
គប្ជីដល់សេចក្ដីសាបសូន្យយសឱ្យកើត នឹងញ្ជាំងលាភសក្ការៈរបស់ព្រះសមណ-

គោតមឱ្យសាបសូន្យ ។ បណ្ដាអន្យតិរ្ថិយទាំងនោះ អន្យតិរ្ថិយម្នាក់មានគំនិតវាងវៃ ពោលឡើងយ៉ាងនេះថា នែលោកដ៏ចម្រើនទាំងឡាយ ធម្មតាថា សត្វទាំង-ឡាយ អ្នកនឹងមិនជំពាក់នៅក្នុងសេចក្ដីសុខដែលកើតពីមាតុគ្រាមរមែងមិនមានក្នុងសត្វលោកនេះ ក៏ព្រះសមណគោតមនេះ មានរូបល្អ ប្រៀបស្មើដោយទេវនៅកម្ទោ: គួរនឹងបានមាតុគ្រាមដែលមានរូបវាងស្មើខ្លួនមកជិត បើបានរួមពិសម័យក្ដី មិនបានរួមពិសម័យក្ដី ចំណែកជនទាំងឡាយ ក៏នឹងគប្ដីរជ្ជៀសណ្ដើយចុះ ពួកយើងនឹងបញ្ជូនសុន្ទរីបរិព្វាជិកាទៅ ដើម្បីឱ្យកេរ្ដ៍ឈ្មោះអាក្រក់របស់ព្រះសមណគោតម ផ្សព្វផ្សាយទៅលើផែនដី ។

ចំណែកអន្យតិរ្ថិយក្រៅនេះ បានស្ដាប់ដូច្នោះ ទើបគិតថា រឿងនេះលោកគិតត្រូវល្អហើយ ក៏កាលយើងធ្វើយ៉ាងនេះហើយ ព្រះសមណគោតមក៏និងមានព្រះហ្ឫទ័យក្រវល់ក្រវាយទៅដោយកេរ្ដ៍ឈ្មោះ មិនអាចនឹងដើរ សីស:ឡើងបាន ក៏នឹងគេចជ្ជៀសទៅដោយអាការយ៉ាងណាមួយ ដូច្នេះហើយ ទើបមានអធ្យាស្ស័យតែមួយទាំងអស់គ្នា នាំគ្នាទៅរកនាងសុន្ទរីដើម្បីនឹងបញ្ជូននាងទៅ ។ នាងសុន្ទរីឃើញអន្យតិរ្ថិយទាំងនោះ ទើបពោលថា ព្រោះហេតុដូចម្ដេច បានជាពួកលោកមកកាន់ទីនេះព្រមគ្នា ។ ពួកតិរ្ថិយទាំងឡាយ ធ្វើជាមិននិយាយគ្នា អង្គុយក្នុងទីកំបាំងចុងអាវាម ។ នាងក៏ទៅក្នុងទីនោះនិយាយ ហើយនិយាយទៀត ក៏មិនបានទទួលពាក្យតប ទើបសួរថា ខ្ញុំម្ចាស់មានកំហុសអ្វីចំពោះលោក ហេតុដូចម្ដេចទើបមិនធ្វើយតបនឹងនាងខ្ញុំ? ពួកតិរ្ថិយទាំងឡាយពោលថា ក៏នាងពិចារណា យើងទាំងឡាយដែលត្រូវគេបៀតបៀន ។ នាងសុន្ទរីសួរថា អ្នកណាបៀតបៀនលោកម្ចាស់ ។ ពួកតិរ្ថិយធ្វើយថា ព្រះសមណ-

គោតមបៀតបៀនពួកយើង ធ្វើយើងឱ្យសាបសូន្យលាភសក្ការៈ នាងមិនឃើញទេឬ កាលនាងសុន្ទរីសួរថា ខ្ញុំម្ចាស់នឹងធ្វើយ៉ាងណាក្នុងរឿងនោះ ទើបអន្យ-តិត្ថិយពោលថា បើយ៉ាងនោះ នាងចូរទៅទីជិតវត្តជេតពនញយៗ គប្បីនិយាយយ៉ាងនេះផង និងយ៉ាងនោះផងនឹងមហាជន ។ ចំណែកនាងទទួលថា ប្រពៃហើយលោកម្ចាស់ ។ ព្រោះហេតុនោះ លោកទើបពោលថា ពួកបរិព្វាជក ជាអន្យតិត្ថិយ អត់ធន់មិនបាននូវសក្ការៈរបស់ព្រះមានព្រះភាគ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧស្សហាសិ** ប្រែថា រមែងអាច ។ បទថា **អត្តំ** បានដល់ ប្រយោជន៍ ឬកិច្ច ។ បទថា **ការាហំ** កាត់ជា **ការ អហំ** ប្រែថា ខ្ញុំនឹងធ្វើយ៉ាងណា? ព្រោះហេតុតិត្ថិយទាំងនោះ សូម្បីមិនមែនជាញាតិរបស់នាង តែក៏ដូចជាញាតិ ដើម្បីនឹងសង្គ្រោះនាង ដោយហេតុត្រឹមតែជាប់ទាក់ទងក្នុងការផ្ទូរបួស ទើបពោលថា នែប្អូនស្រី នាងអាចដើម្បីនឹងធ្វើប្រយោជន៍ដល់ពួកញាតិបានឬ ។ ព្រោះដូច្នោះ សូម្បីនាងក៏នៅជាប់ជំពាក់ដូចវល្ជ៌ជាប់ដើងម្រ៉ីគ ទើបពោលថា សូម្បីជីវិតរបស់ខ្ញុំម្ចាស់ ក៏លះបង់បានដើម្បីប្រយោជន៍ដល់ពួកញាតិ ។

បទថា **តេនហិ** សេចក្តីថា ពួកតិត្ថិយពោលថា ព្រោះហេតុនាងពោលថា សូម្បីជីវិតរបស់នាងខ្ញុំ ក៏លះបង់បានដើម្បីប្រយោជន៍ដល់ពួកលោកម្ចាស់ និងនាងក៏តាំងនៅក្នុងបឋមវ័យ មានរូបល្អ ធោមល្អ ព្រោះដូច្នោះ នាងគប្បីធ្វើប្រការដែលព្រះសមណគោតម នឹងមានកេរ្តិ៍ឈ្មោះអាក្រក់ឡើង ព្រោះអាស្រ័យនាង ដូច្នេះហើយទើបបញ្ជូនទៅដោយពាក្យថា នាងចូរទៅកាន់វត្តជេតពនញយៗ ។ ចំណែកនាងសុន្ទរីជាមនុស្សល្ងង់ ដូចជាប្រាជ្ញានឹងលេងខ្សែក្រង

ដោយផ្ការណ៍ តាមគន្ធងនៃធ្នេញរណា ដូចចាប់ដំរីចុះប្រេងត្រង់ប្រមោយ និងដូចមុខចូលទៅរកសេចក្តីស្ងាប់ ទើបទទួលពាក្យរបស់ពួកតិរ្ថិយ ហើយកាន់យកផ្ការណ៍របស់ក្រអូបគ្រឿងលាប ស្វាមូ និងគ្រឿងអប់មុខជាដើម ក្នុងវេលាដែលមហាជនកំពុងស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ហើយចូលទៅកាន់នគរ នាងបែរមុខទៅកាន់វត្តជេតពន និងត្រូវមហាជនសួរថា នាងនឹងទៅណា? ទើបធ្វើយថា ទៅសំណាក់ព្រះសមណគោតម ព្រោះនាងខ្ញុំនៅក្នុងព្រះគន្ធកុដិតែមួយជាមួយគ្នានឹងព្រះសមណគោតមនោះ ដូច្នេះហើយ ក៏ចូលទៅក្នុងអាវាសរបស់តិរ្ថិយមួយកន្លែង លុះព្រឹកព្រលឹមក៏ធ្វើងចូលផ្លូវវត្តជេតពន មានមុខឆ្ពោះទៅកាន់នគរ និងត្រូវមហាជនសួរថា សុន្ទរីទៅណាមកណា ទើបតបថា ខ្ញុំនៅក្នុងព្រះគន្ធកុដិតែមួយជាមួយគ្នានឹងព្រះសមណគោតម ឱ្យលោកវីក-ពាយត្រេកអរដោយកិលេស ហើយទើបមក ។ ព្រោះហេតុនោះ លោកទើបពោលថា នាងបរិព្វាជិកា ឈ្មោះ សុន្ទរី បានទទួលពាក្យបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះថា ព្រះករុណាលោកម្ចាស់ ហើយទៅកាន់វត្តជេតពនញយ១ ។

ដោយកន្ធងទៅ ២-៣ ថ្ងៃ ពួកតិរ្ថិយទើបឱ្យតម្លៃឈ្នួលដល់ពួកអ្នកលេងហើយពោលថា ពួកលោកចូរទៅសម្ងាប់នាងសុន្ទរី ហើយយកទៅកប់ទុកក្នុងគំនរសំរាមមិនឲ្យាយពីព្រះគន្ធកុដិរបស់ព្រះសមណគោតម ហើយចូរមកវិញ ។ ពួកអ្នកលេងក៏បានធ្វើយ៉ាងនោះ ។ លំដាប់នោះ ពួកតិរ្ថិយធ្វើជាភ្ញាក់ផ្អើលថា មិនឃើញនាងសុន្ទរី ទើបក្រាបទូលដល់ព្រះរាជា ព្រះរាជាត្រាស់សួរថា ពួកលោកសង្ស័យក្នុងទីណាហ្ន៎ ទើបក្រាបទូលថា ច្រើនថ្ងៃមកនេះ នាងនៅក្នុងវត្តជេតពន ពួកខ្ញុំព្រះអង្គមិនជ្រាបរឿងរបស់នាងក្នុងទីនោះ ព្រះរាជាត្រាស់

អនុញ្ញាតថា បើយ៉ាងនោះ ពួកលោកចូរទៅស្វែងរកនាងត្រង់វត្តជេតពននោះ ទើបនាំពួកឧបដ្ឋាករបស់ខ្លួនទៅកាន់វត្តជេតពន ធ្វើទីដូចស្វែងរកកកាយគំនរសំរាមហើយ លើកសាកសពរបស់នាងដាក់លើគ្រែហើយឱ្យគេសែងទៅកាន់នគរ ហើយក្រាបទូលចំពោះព្រះរាជាថា ពួកសាវករបស់ព្រះសមណគោតមគិតនឹងបិទបាំងកម្មអាក្រក់ដែលសាស្តាខ្លួនធ្វើ ទើបនាំគ្នាសម្ងាប់នាងសុន្ទរីហើយយកទៅកប់ទុកក្នុងត្រង់គំនរសំរាម ។ ចំណែកព្រះរាជាមិនទ្រង់ពិចារណាទើបទទួលបង្គាប់ថា បើយ៉ាងនោះ ពួកលោកចូរត្រាច់ទៅកាន់នគរដើម្បីស្វែងរក ។ ពួកតិរ្ថិយទាំងនោះត្រាច់ពោលតាមថ្នល់ទូទៅព្រះនគរមានជាអាទិ៍ថា លោកទាំងឡាយ ចូរមើលអំពីអាក្រក់របស់ពួកសមណសក្យបុត្រចុះ ហើយក៏បានទៅកាន់ទ្វារព្រះរាជនិវេសន៍វិញ ។ ព្រះរាជាបង្គាប់ឱ្យលើកសាកសពរបស់នាងសុន្ទរីឡើងកាន់គ្រែតូច ហើយឱ្យរក្សាទុកក្នុងព្រៃស្មសាន ។ អ្នកក្រុងសាវត្ថីដោយច្រើនរៀរព្រះអរិយសាវកចេញពោលពាក្យមានជាអាទិ៍ថា ពួកលោកចូរមើលសេចក្តីអាក្រក់របស់សមណសក្យបុត្រចុះ ដូច្នេះហើយត្រាច់ជេរពួកភិក្ខុទាំងក្នុងក្រុងនិងក្រៅក្រុង ។ ព្រោះហេតុនោះ លោកទើបពោលថា កាលណាបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ បានដឹងថា ជនច្រើនបានឃើញនាងបរិព្វាជិកា ឈ្មោះ **សុន្ទរី** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អញ្ញិសុ** ប្រែថា ដឹងហើយ ។ បទថា **ភេ ឌិដ្ឋា** ប្រែថា ឃើញដោយពិសេស អធិប្បាយថា នាងទៅមកកាន់វត្តជេតពនដែលឃើញគ្នាដោយពិសេស គឺឃើញគ្នាច្រើន ។ បទថា **បរិក្ខ្វាកូបេ** បាន

ដល់ គួរដែរ ។ បទថា **យា សា មហារាជ សុន្ទរី** *សេចក្តីថា បពិត្រមហារាជ នាងសុន្ទរីបរិព្វាជិកាដែលប្រាកដ គឺប្រាកដច្បាស់ថា សុន្ទរី ព្រោះនាងមានរូបល្អ ក្នុងក្រុងនេះ ។ បទថា* **សា ខោ ន ឥិស្សតិ** *សេចក្តីថា នាងជាទីស្រឡាញ់ ដូចដួងភ្នែក និងជីវិតរបស់ខ្ញុំព្រះអង្គ ឥឡូវនេះមិនប្រាកដ ។ បទថា* **យថានិក្ខិត្តំ** *សេចក្តីថា តាមដែលខ្ជនបង្គាប់ពួកបុរសឱ្យរក្សាទុកក្នុងខាងក្នុងគំនរសំរាម ។ បាលីថា* **យថានិខាតំ** *តាមដែលកប់ទុក ដូច្នេះក៏មាន អធិប្បាយថា មានប្រការដែលកប់ទុកក្នុងដី ។*

បទថា **រថិយាយ រថិយំ** *ប្រែថា ចេញពីថ្នល់នេះ ទៅកាន់ថ្នល់ឯណោះ ។ ក៏ច្រកផ្លូវដែលធ្លុះរហូតដល់អស់ ហៅថា* **រថិ** *។ ច្រកផ្លូវចែកជាបី ឈ្មោះថា* **សិង្ឆាដកំ** *។ បទថា* **អលជ្ជិនោ** *ប្រែថា អ្នកមិនខ្មាស អធិប្បាយថា រៀរចាកការរង្គៀសបាប ។ បទថា* **ឧស្សីលា** *ប្រែថា អ្នកទ្រុស្តសីល ។ បទថា* **ចាបធម្មា** *បានដល់ មានសភាវៈលាមក គឺមានការប្រព្រឹត្តអាក្រក់ ។ បទថា* **មុសាវ-ទិនោ** *បានដល់ ជាអ្នកទ្រុស្តសីល ឈ្មោះថា ជាអ្នកនិយាយមុសា ព្រោះច្រើននិយាយតែពាក្យឡេះឡោះថា យើងជាអ្នកមានសីល ។ បទថា* **អព្រហ្មចារិ-នោ** *បានដល់ ឈ្មោះថា អ្នកប្រព្រឹត្តមិនប្រសើរ ព្រោះចូលចិត្តសេពមេថុន ។ ពួកតិរ្ថិយពោលមើលងាយដោយពាក្យទាំងនេះឯង ។ បទថា* **ធម្មចារិនោ** *បានដល់ អ្នកប្រព្រឹត្តកុសលធម៌ ។ បទថា* **សមចារិនោ** *បានដល់ ប្រព្រឹត្តស្មើក្នុងកាយកម្មជាដើម ។ បទថា* **កល្យាណធម្មា** *បានដល់ អ្នកមានសភាវៈដែលស្រស់ល្អ ។ ភ្ជាប់សេចក្តីថា ឈ្មោះថា នឹងដឹងចំពោះ ។ ក៏ពាក្យថា* **បដិជានិ-ស្សន្តិ** *ក្នុងបាលីនេះជាពាក្យបញ្ជេញដល់អនាគតកាល ព្រោះប្រកបដោយ*

នាមស័ព្ទ ។ ភាពជាសមណៈ ឈ្មោះថា **សាមញ្ញៈ** បានដល់ ភាពជាអ្នកសូប់បាប ។ ភាពជាអ្នកមានធម៌ដ៏ប្រសើរ ឈ្មោះថា **ព្រហ្មញ្ញៈ** បានដល់ ភាពជាអ្នកមានបាបបន្សាត់បង់ហើយ ។ បទថា **ការណា** ប្រែថា ដោយហេតុអ្វី ។ បទថា **អបត-ត្ថា** ប្រែថា ទៅប្រាសចាកហើយ គឺរបូតហើយ ។ ដោយពាក្យថា **ឧបាសកិ** លោកអាចារ្យពោលសំដៅដល់សេពមេថុន ។

លំដាប់នោះ ពួកភិក្ខុក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើយ៉ាងនោះ សូម្បីពួកលោកក៏ចូរធ្វើយនឹងមនុស្សទាំងនោះដោយគាថានេះ ទើបត្រាស់គាថាថា **អកូតភាឌី** ជាដើម ដែលលោកសំដៅពោលទុកថា គ្រានោះឯង ភិក្ខុជាច្រើន ។ ល ។ អ្នកមានកម្ម ដ៏ថោកទាប លុះលះលោកនេះទៅហើយ ជាអ្នកស្មើក្នុងលោកខាងមុខជាដើម ។ ព្រះសាស្តាទ្រង់ជ្រាបភាពសម្រេចនៃសេចក្តីសាបសូន្យយសនោះ ដោយព្រះ-សព្វញ្ញុតញ្ញាណ កាលនឹងទ្រង់លួងលោមភិក្ខុទាំងឡាយ ទើបត្រាស់ពាក្យនេះ ក្នុងបាលីនោះថា ភិក្ខុទាំងឡាយ សំឡេងនេះ នឹងមានមិនយូរ ។

ក្នុងគាថា មានវិនិច្ឆ័យដូចតទៅនេះ

បទថា **អកូតភាឌី** បានដល់ មិនឃើញទោសរបស់អ្នកដទៃឡើយ និយាយមុសាវាទពោលចំពោះអ្នកដទៃដោយពាក្យកុហក គឺមិនពិត ។ បទថា **យោ ភាមិ ការ្ចា** សេចក្តីថា ក៏ឬថាអ្នកណាធ្វើកម្មអាក្រក់ហើយនិយាយថា យើងមិនបានធ្វើកម្មអាក្រក់នេះ ។ បទថា **ឧភេ ០ សមា ភវន្តិ** សេចក្តីថា បុគ្គលទាំងពីរនោះ ពីលោកនេះទៅកាន់បរលោក ជាអ្នកមានគតិស្មើគ្នាដោយការ

ចូលដល់នរក ។ មែនពិត គតិរបស់ជនទាំងនោះឯងនូវកំណត់ទុកតែអាយុ កំណត់មិនបាន ។ ព្រោះថា បុគ្គលធ្វើកម្មអាក្រក់ទុកច្រើន ឆេះក្នុងនរកអស់ កាលយូរ ធ្វើកម្មអាក្រក់ទុកតិច ក៏ឆេះត្រឹមតែវេលាបន្តិចបន្តួចប៉ុណ្ណោះ ។ ក៏ព្រោះជនទាំងពីរមានកម្មដ៏លាមកនោះឯង ព្រោះដូច្នោះ លោកទើបពោលថា **និហីនកម្មា មនុជា បតេ** ជាដើម ។ ក៏បទថា **បតេ** នេះ ភ្ជាប់នឹងបទថា **បេចេ** ខាងមុខ អធិប្បាយថា អ្នកមានកម្មដ៏លាមកទាំងនោះ នឹងទៅក្នុងលោកខាងមុខ គឺចាកលោកនេះ ជាអ្នកស្ងើគ្នាក្នុងលោកខាងមុខ ។

បទថា **បរិយាបុណិត្វា** ប្រែថា រៀនហើយ ។ បទថា **អការកា** ប្រែថា អ្នកមិនធ្វើខុស ។ បទថា **ឧយិមេហិ កតំ** សេចក្ដីថា បានឮថា ពួកមនុស្សទាំងនោះ មានការគិតយ៉ាងនេះថា ព្រះសមណសក្យបុត្រទាំងនេះ មិនបានធ្វើកម្មអាក្រក់ តាមដែលពួកអន្យតិរ្ថិយ ត្រាច់ទៅដើម្បីឃោសនាទូទាំងនគរពិតប្រាកដ ព្រោះអន្យតិរ្ថិយទាំងនេះ សូម្បីពោលមួលបង្ខាច់ដោយផរុសវាចា មិនមែនជាពាក្យរបស់សប្បុរសយ៉ាងនេះ ក៏នូវតែសម្ដែងអាការប្ញកអ្វីៗ ទាំងមិនលះខន្ដិ និងសោរច្ច: ត្រឹមតែពោលធម៌តែម្យ៉ាងប៉ុណ្ណោះថា អ្នកពោលពាក្យមិនពិត រមែងធ្លាក់នរក សមណសក្យបុត្រទាំងនេះ ជាអ្នកមានសច្ច:ក្នុងពាក្យដែលពួកយើងទាំងឡាយមិនពិចារណា ហើយប្រទេចបណ្ដាសា និយាយដូចជាបានសច្ចាទុក ។ ម្យ៉ាងទៀត និយាយពិតថា សូម្បីថាអ្នកណាធ្វើ តែពោលថាមិនធ្វើ អធិប្បាយថា សមណ:ទាំងនេះធ្វើស្បថដល់ពួកយើង ដើម្បីឱ្យដឹងថាខ្លួនមិនបានធ្វើ ។ ក៏សេចក្ដីត្រេកអរធ្លាក់ចុះដោយពុទ្ធានុភាពក្នុងលំដាប់ ព្រមដោយការស្ដាប់ព្រះគាថាដែលព្រះដ៏មានព្រះភាគត្រាស់ ដល់ពួកមនុស្សទាំង

នោះ ។ សេចក្ដីសង្ខេបកើតឡើងហើយថា រឿងនេះពួកយើងមិនបានឃើញ ដោយប្រចក្ស ធម្មតារឿងដែលបានឮហើយ រមែងពិតខ្លះ រមែងមិនពិតខ្លះ មែនពិត អន្យតិរ្ថិយទាំងនោះ ប្រាថ្នាវត្ថុដែលមិនជាប្រយោជន៍ និងមិនជា ប្រយោជន៍ដល់ព្រះសមណៈទាំងនេះ ព្រោះដូច្នោះ ពួកយើងមិនគប្បីនិយាយ រឿងនេះដោយជឿពួកគេ ព្រោះថា សមណៈទាំងឡាយ គឺយើងដឹងបាន លំបាក ។ ចាប់ផ្ដើមតាំងពីនោះ ពួកមនុស្សក៏រៀរចាកការយល់នោះចេញ ។

ចំណែកព្រះរាជា ទើបបង្គាប់ពួករាជបុរស ដើម្បីជ្រាបដល់អ្នកដែល សម្ងាប់នាងសុន្ទរី ។ លំដាប់នោះឯង ពួកអ្នកលេងទាំងនោះ យកកហាបណៈ ទាំងនោះទិញសុរាផឹក បង្ក្ការឈ្លោះគ្នានិងគ្នាឡើង ។ បណ្ដាអ្នកលេងទាំងនោះ អ្នកលេងម្នាក់និយាយនឹងអ្នកលេងម្នាក់ទៀតថា អ្នកឯងសម្ងាប់នាងសុន្ទរីដោយ ការវាយតែម្ដងឱ្យស្ងាប់ ហើយបក់ទុកត្រង់ចន្ទោះគំនរសំរាម យកកហាបណៈ ដែលបានពីការទទួលឈ្នួលនោះ ហើយទិញសុរាយកមកផឹក ។ ពួករាជបុរស បានឮដូច្នោះហើយ ទើបចាប់ពួកអ្នកលេងទាំងនោះ ប្រគល់ថ្វាយចំពោះ ព្រះរាជា ។ ព្រះរាជាត្រាស់សួរពួកអ្នកលេងទាំងនោះថា ពួកអ្នកឯងសម្ងាប់ នាងសុន្ទរីឬ? ពួកអ្នកលេងក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំជាអ្នក សម្ងាប់ដោយខ្លួនឯង ។ ព្រះរាជាត្រាស់សួរថា អ្នកណាជួលឱ្យពួកឯងសម្ងាប់ នាងសុន្ទរី ។ ពួកអ្នកលេងក្រាបទូលថា ពួកអន្យតិរ្ថិយព្រះអង្គ ។ ព្រះរាជា បង្គាប់ឱ្យហៅតិរ្ថិយទាំងនោះមកហើយដើម្បីដឹងរឿងនោះ ហើយទើបទ្រង់បញ្ជា ថា ពួកអ្នកឯងចូរត្រាច់និយាយទៅទូទាំងនគរយ៉ាងនេះថា ពួកខ្ញុំមានប្រាថ្នា

នឹងលើកទោសព្រះសមណគោតម ទើបបានសម្ងាប់នាងសុន្ទរីនេះ ព្រះគោតម មិនមានទោស សាវ័ករបស់ព្រះគោតមក៏មិនមានទោសឡើយ ពួកខ្ញុំប៉ុណ្ណោះ មានទោស ។ អន្យតិ្ថរិយទាំងនោះ បានធ្វើដូចយ៉ាងនោះ ។ មហាជនដឹងយ៉ាង ពិតប្រាកដហើយ នាំគ្នាតិះដៀលពួកតិ្ថរិយ ។ ពួកតិ្ថរិយបានទទួលទោសទណ្ឌ ព្រោះសម្ងាប់នាងសុន្ទរី ។ ចាប់ផ្តើមតាំងពីនោះមក ព្រះពុទ្ធ និងព្រះភិក្ខុសង្ឆ មានសក្ការ: និងសម្មាន:ច្រើនលើសប្រមាណ ។ ពួកភិក្ខុកើតសេចក្តីអស្ចារ្យ ក្នុងចិត្ត ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយប្រកាសសេចក្តីនោះឱ្យ ទ្រង់ជ្រាប ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ សម្ពហុលា ភិក្ខូ ។បេ។ អន្តហិតោ សោ ភគ្គេ សង្ឆោ** *ដូច្នេះជាដើម ។*

ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគទើបមិនត្រាស់ប្រាប់ដល់ពួកភិក្ខុថា នេះជាទង្វើរបស់ពួកតិ្ថរិយ? ព្រោះការប្រាប់ដល់ព្រះអរិយសាវ័កមុន មិនមាន ប្រយោជន៍ឡើយ ។ តែពួកបុថុជ្ជនមិនត្រាស់ប្រាប់ដោយទ្រង់ព្រះតម្រិះថា កម្ម របស់ជនដែលមិនជឿនោះ គប្បីប្រព្រឹត្តទៅដើម្បីមិនមែនជាប្រយោជន៍ ដើម្បី សេចក្តីទុក្ខអស់កាលយូរ ។ ម្យ៉ាងទៀត ការប្រាប់រឿងដូច្នេះ គឺមិនធ្លាប់មានមក ដែលព្រះពុទ្ធទាំងឡាយមិនធ្លាប់ទ្រង់ប្រព្រឹត្តមកឡើយ ។ មែនពិត ព្រះដ៏មាន-ព្រះភាគទ្រង់ប្រកាសបក្ខពួកនៃសង្ខិលេស ដែលទ្រង់សម្តែងមកដោយលំដាប់ ។ ក៏អ្នកណាៗមិនអាចនឹងឱ្យឱកាសដែលខ្ជូនធ្វើកម្មហើយ រ៉ាលត្រឡប់បាន ព្រោះ ហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ប្រថាប់គង់ពិចារណាមើលការពោល មួលបង្ក៏ាច់ និងហេតុនៃការពោលមួលបង្ក៏ាច់នោះ ។ សមដូចព្រះដ៏មាន-ព្រះភាគត្រាស់ទុកថា

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្ភតានំ វិវរំ បវិសំ
ន វិជ្ជតី សោ ជគតិប្បទេសោ
យត្រដ្ឋិតោ មុញ្ចេយ្យ ចាបកម្មា ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្ទោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបកម្មបាន នោះមិនដែលមានឡើយ[1] ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដល់រឿងនេះថា សូម្បីកាលពោលអំពីអំណាចការកាត់ចេញនូវសេចក្តីស្រឡាញ់ ពាក្យនិយាយអាក្រក់ដែលពាលជនឱ្យប្រព្រឹត្តទៅហើយ ឈ្មោះថា ជាការអត់ទ្រាំបានលំបាក សម្រាប់ជីវជនអ្នកប្រកបដោយកម្លាំងនៃខន្តិរមែងមិនមាន ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះដែលប្រកាសកម្លាំងនៃអធិវាសនខន្តិ ។*

បណ្តាបទទាំងនោះ បទថា **តុឧន្តិ ឯកាយ ជនា អសញ្ញតា សរេហិ សង្គ្រាមគតំវ កុញ្ជរំ** *សេចក្តីថា ពួកពាលជន ឈ្មោះថា អ្នកមិនសង្រ្ទម គឺអ្នកដែលណែនាំមិនបាន ព្រោះមិនមានសំវរៈ មានសំវរៈផ្លូវកាយជាដើម រមែងចាក់ គឺចាក់រុកដោយលំពែង គឺវាចា ដូចទាហានដែលជាសត្រូវចាក់រុកដំរីកុញ្ជរ គឺមេដំរី នៅក្នុងសង្គ្រាម គឺក្នុងសមរភូមិច្បាំងដោយកូនសរ ដែលជ្រលក់ (ដោយថ្នាំពិស) ។ នេះជាសភាវៈរបស់ពាលជនទាំងនោះ ។ បទថា* **សុត្វាន ឯកាឃ**

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៦៨ ។

ជរុសំ ឧជីវិតំ អជិវាសយេ ភិក្ខុ អឧុជ្ជចិត្តោ សេចក្តីថា ក៏ភិក្ខុ ដែលពាលជន ទាំងនោះបន្ទ្ធ គឺពោលពាក្យមិនពិត ជាពាក្យអាក្រក់គ្រាតគ្រាតឱ្យប្រព្រឹត្តទៅ ដោយអំណាចនៃពាក្យបៀតបៀនខ្លួន ដោយសេចក្តីពិត រឭកដល់ឱ្យាទ ដែលប្រៀបស្មើដោយរណារបស់តថាគត ជាអ្នកមានចិត្តមិនប្រទូសរ៉ាយសូម្បីបន្ដិចបន្ដួច ជាអ្នកមានប្រក្រតីឃើញកន្ល័ងក្នុងសង្សារថា នេះមានសង្សារជាសការ: គឃ្លីអត់ទ្រាំ គឺគឃ្លីតាំងនៅក្នុងអធិវាសនខន្ដិ ។

ក្នុងសេចក្ដីនេះ មានអ្នកជំទាស់ថា ប្រការដែលព្រះសាស្ដាមានបុញ្ញសម្ភារដ៏បរិបូណ៌ដែលព្រះអង្គសន្សំមក ដោយប្រពៃរហូតដល់អស់កាលរកប្រមាណមិនបាន ទ្រង់បានទទួលការពោលមួលបង្ផ្ដាច់យ៉ាងនេះ ជាការប្រទូសរ៉ាយយ៉ាងនេះ នោះជាកម្មអ្វី ? ខ្ញុំនឹងធ្វើយដូចតទៅនេះ

ព្រះដ៏មានព្រះភាគនេះនោះ ធ្ងាប់ជាព្រះពោធិសត្ត្ব ក្នុងអតីតជាតិជាអ្នកលេង ឈ្មោះថា **បុនាលិ** សេពគប់តែមនុស្សអាក្រក់ ច្រើនទៅដោយអយោនិសោមនសិការ ។ ថ្ងៃមួយ បុនាលិនោះឃើញព្រះបច្ចេកពុទ្ធ នាមថា **សុរភី** កំពុងដណ្ដប់ចីវរដើម្បីចូលទៅបិណ្ឌបាតនូវព្រះនគរ ។ ក៏ក្នុងសម័យនោះ ស្ត្រីម្នាក់ដើរទៅមិនឆ្ងាយពីព្រះបច្ចេកពុទ្ធ ។ អ្នកលេងពោលមួលបង្ផ្ដាច់ថា សមណ: នេះ មិនមែនជាព្រហ្មចារីបុគ្គលទេ ។ ដោយកម្មនោះ បុនាលិនោះទើបធ្លាក់ក្នុងនរកច្រើនសែនឆ្នាំ ព្រោះសេសសល់នៃវិបាកកម្មនោះនុ៎ះឯង សូម្បីបានជាព្រះពុទ្ធក្នុងឥឡូវនេះ ក៏នូវតែនាងសុន្ទរី ពោលមួលបង្ផ្ដាច់ ។ ក៏ប្រការនេះយ៉ាងណា ទុក្ខ មានការពោលមួលបង្ផ្ដាច់ជាដើម ដែលស្ត្រីអ្នកធ្វើអាការដែលប្ញែកមាននាងចិញ្ចមានវិកាជាដើម ឱ្យប្រព្រឹត្តទៅហើយដល់ព្រះដ៏មានព្រះភាគ

ទាំងអស់នោះ ជាសេសសល់វិបាកនៃកម្មដែលព្រះអង្គទ្រង់ធ្វើទុកក្នុងកាលមុន ដែលហៅថា កម្មបិលោតិក: ។ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគ ត្រាស់ទុកក្នុងអបទានថា

ព្រះលោកនាយក មានភិក្ខុសង្ឆច្រើនចោមរោម ទ្រង់គង់លើផ្ទៃនៃថ្ម ជាទីរីករាយ ជិតស្រះអនោតត្ត រុងរឿងដោយរតន:ផ្សេងៗ ក្នុងចន្ទោះនៃព្រៃ មានក្ងិនផ្ការផ្សេងៗ ទ្រង់ព្យាករនូវបុព្វកម្មរបស់ព្រះអង្គ ក្នុងទីនោះថា ម្នាលភិក្ខុ-ទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវអំពើរបស់តថាគតដែលបានធ្វើទុកមកហើយ ដូចតទៅនេះ តថាគតបានឃើញនូវភិក្ខុមួយរូបនៅក្នុងព្រៃ ហើយបានប្រគេនកំណាត់សំពត់ ។ ក្នុងកាលនោះ តថាគតបានប្រាថ្នាជាព្រះសម្ពុទ្ធ ជាដំបូងដើម្បីការត្រាស់ដឹង ឯសេចក្ដីប្រាថ្នានោះ ក៏ឱ្យផលក្នុងការបានត្រាស់ជាព្រះពុទ្ធ ដោយអំណាចនៃបិលោតិកម្ម ។ កាលកពមុន ក្នុងជាតិដទៃ តថាគតជា អ្នកលេង ឈ្មោះ បុនាលិ បានពោលបង្ការ៉ាប់នូវព្រះបច្ចេកពុទ្ធ ព្រះនាមសុរកី ព្រះអង្គជាបុគ្គលមិនប្រទូស្តឡើយ ។ ដោយវិបាកនៃកម្មនោះ តថាគតអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ រងទុក្ខវេទនាអស់ពាន់នៃឆ្នាំដ៏ច្រើន ។ ដោយសំណល់នៃកម្មនោះ ក្នុងបច្ឆិមកពនេះ តថាគត បាននូវការពោលបង្ការ៉ាប់ ព្រោះហេតុនៃនាងសុន្ទរិកា ។ មួយទៀត តថាគតពោលបង្ការ៉ាប់សាវ័ក ឈ្មោះ នន្ទ របស់ព្រះពុទ្ធ ទ្រង់គ្របសង្កត់នូវសត្វលោកទាំងពួង តថាគតបានអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ ព្រោះការពោលបង្ការ៉ាប់នូវសាវ័កនោះ ។ តថាគតបាន អន្ទោលទៅក្នុងនរក អស់កាលដ៏យូរ ចំនួនមួយហ្នឹងឆ្នាំ

លុះតថាគត បានមកជាមនុស្ស ក៏បានទទួវការពោលបង្ការ៉ាប់ជាច្រើន ។ ដោយ សំណាល់នៃកម្មនោះ នាងចិញ្ចមានវិកាមកពោលបង្ការ៉ាប់តថាគត ក្នុងប្រជុំជន ដោយពាក្យមិនពិត ។ តថាគតកើតជាព្រាហ្មណ៍ តែងជាអ្នកបេះមន្ត មានគេធ្វើ សក្ការបូជា បង្ហាញមន្តដល់មាណព ៥០០ នាក់ក្នុងព្រៃធំ ។ ឥសីកិម: បាន អភិញ្ញា ៥ មានឫទ្ធិច្រើន មកក្នុងទីនោះ តថាគតបានឃើញឥសីនោះ លោកជា អ្នកមិនប្រទូស្ត និមន្តមកក៏បានពោលបង្ការ៉ាប់ ។ លំដាប់នោះ តថាគត និយាយ នឹងពួកសិស្សថា ឥសីនេះ ជាអ្នកបរិភោគកាម កាលតថាគតនិយាយប្រាប់ ឯពួកមាណព ក៏បានរីកវាយតាម ។ លំដាប់នោះ មាណពទាំងអស់ត្រាច់ទៅ សូមក្នុងត្រកូល តូចធំនិយាយប្រាប់ មហាជនថា ឥសីនេះ ជាអ្នកបរិភោគកាម ។ ដោយវិបាកនៃកម្មនោះ ភិក្ខុទាំងអស់ចំនួន ៥០០ នេះ ក៏បានទទួវការពោលបង្ការ៉ាប់ ព្រោះហេតុនៃនាងសុន្ទរិកា ។ កាលកពមុន តថាគតសម្ងាប់បងប្រុសម្នាក់ មានមាតាផ្សេងគ្នា ព្រោះហេតុនៃទ្រព្យ ហើយបោះចោលទៅក្នុងជ្រោះភ្នំឱ្យ៉ាប់ នឹងថ្ម ។ ដោយវិបាកនៃកម្មនោះ ទេវទត្តបានប្រមៀលថ្ម ដុំថ្មក៏រមៀលមកប៉ះ អង្គុដ្ឋបាទ (មេជើង) នៃតថាគត ។ កាលពីជាតិមុន តថាគតជាទារកកំពុង លេងក្នុងផ្ទះធំ បានឃើញព្រះបច្ចេកពុទ្ធ ក៏ដុតព្រៃទាំងមូលក្បែរផ្ទះ ។ ដោយ វិបាកនៃកម្មនោះ ក្នុងបច្ឆិមកពនេះ ទេវទត្តក៏ប្រើខ្ទាន់ធ្នូឱ្យសម្ងាប់តថាគត ។ កាលពីជាតិមុន តថាគតកើតជាហ្នុដំរី បានបរដំរីបំព្រេចព្រះបច្ចេកមុនីដ៏ឧត្តម ព្រះអង្គកំពុងត្រាច់ទៅដើម្បីបិណ្ឌបាត ។ ដោយវិបាកនៃកម្មនោះ ដំរីនាឡាគិរី ចុះប្រេងកាច ចូលមកព្រេចតថាគតក្នុងគិរិព្វជបុរីដ៏ប្រសើរ (រាជគហ:) ។ តថាគតកើតជាស្តេច ឈ្មោះបត្តិក: បានយកលំពែង សម្ងាប់បុរសទាំងឡាយ

ដោយវិបាកនៃកម្មនោះ តថាគតនេះក្នុងក្ងើងនរកក្ងាខ្ចាំង ។ ដោយសំណល់នៃកម្មនោះ ក្នុងកាលឥឡូវនេះ កម្មវិបាកនោះ ក៏ធ្វើឱ្យរបកស្បែកជើងទាំងអស់របស់តថាគត ព្រោះថាកម្មនៅតែមិនទាន់វិនាស ។ តថាគត កើតជាទារកនៃព្រានត្រី ក្នុងកេរដ្ឋគ្រាម បានឃើញពួកជនអ្នកសម្ងាប់ត្រី ក៏កើតសោមនស្ស ។ ដោយវិបាកនៃកម្មនោះ ស្តេចវិដុដភ: សម្ងាប់ពួកសក្យ: ក្នុងកាលណា ទុក្ខក្នុងក្បាល ក៏មានដល់តថាគត (ក្នុងកាលនោះ) ព្រោះពួកសក្យ: ត្រូវគេសម្ងាប់ ។ តថាគត បានពោលផ្តន្ទា នូវពួកសាវ័កក្នុងសាសនា នៃព្រះពុទ្ធព្រះនាម ផុស្ស: ថា ចូរលោកទាំងឡាយទំពាស៊ីបរិភោគនូវបាយដំណើបចុះ កុំបរិភោគនូវបាយស្រូវសាលីឡើយ ។ ដោយវិបាកនៃកម្មនោះ ក្នុងកាលនោះ តថាគត នៅក្នុងស្រុកវេរញ្ជា ព្រាហ្មណ៍និមន្តឱ្យធាន់តែបាយដំណើរអស់ ៣ ខែ ។ តថាគតបានហាមឃាត់កូនអ្នកចំបាប់ ក្នុងកាលដែលគ្មានព្រះពុទ្ធត្រាស់ ដោយវិបាកនៃកម្មនោះ ជំងឺខ្នងក៏កើតឡើងដល់តថាគត ។ តថាគតកើតជាទេព្យ បានដាក់ថ្នាំបញ្ចុះសេដ្ឋីបុត្ត ដោយវិបាកនៃកម្មនោះ ជំងឺចុះឈាមក៏កើតឡើងដល់តថាគត ។ ក្នុងភពមួយនោះ តថាគតកើតជាជោតិបាល បានផ្ទួញ់ផ្ទាល់ ព្រះសុគតព្រះនាមកស្សប:ថា ព្រោះអ្វីក៏ថា ត្រាស់ដឹងពោធិញ្ញាណ ជាទីផ្ទរផង់ គេរកបានដោយកម្រក្រៃលែង ។ ដោយវិបាកនៃកម្មនោះ តថាគតប្រព្រឹត្តទុក្ករកិរិយាជាច្រើន ក្នុងឧរុវេលប្រទេស អស់ ៦ វស្សាទើបបានត្រាស់ដឹងឡើង ។ តថាគតមិនបាននូវពោធិញ្ញាណដ៏ខ្ពស់ដោយផ្ទ្រ ទ្ធ:ទេ តថាគតហេតុតែ បុព្វកម្មនោះដាស់-តឿន ក៏ស្វែងរកតាមផ្ទ្ធ:ខ្ស ។ តថាគតមានបុណ្យ និងអស់រលីងហើយ បាន

រៀរបង់នូវកម្តៅទាំងពួង មិនមានសេចក្តីសោក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះជិនស្រី ទ្រង់ដល់នូវអភិញ្ញា និងពលៈទាំងពួង បានព្យាករដោយសេចក្តីពិស្តារដល់ភិក្ខុសង្ឆ ជិតមហាស្រះឈ្មោះ អនោតត្ត ដូចរៀបរាប់មកនេះឯង[1] ។

អដ្ឋមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៨

១-សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧៤ ទំព័រ ១២៤ ដល់ ១២៩ ។

៩. ឧបសេនសុត្តវណ្ណនា

អដ្ឋកថាឧបសេនសូត្រ

ឧបសេនសូត្រទី ៩ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ឧបសេនោ** *ក្នុងបទថា* **ឧបសេនស្ស** *នេះ ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ក៏ព្រោះព្រះថេរៈជាបុត្ររបស់វង្គន្តព្រាហ្មណ៍ គេទើបហៅថា* ***វង្គន្តបុត្ត*** *។ សេចក្ដីពិស្តារថា ព្រះថេរៈអង្គនេះ ជាប្អូនប្រុសរបស់ព្រះសារីបុត្ត បួសក្នុងព្រះសាសនា កាលមិនទាន់ទ្រង់បញ្ញត្តសិក្ខាបទឧបសម្បទាបាន ២ វស្សា ក៏ក្លាយជាព្រះឧបជ្ឈាយ៍ ឱ្យឧបសម្បទាកិក្ខុមួយរូបព្រមនឹងកិក្ខុនោះទៅឧបដ្ឋាកព្រះដ៏មានព្រះភាគ ត្រូវព្រះដ៏មានព្រះភាគ ត្រាស់សួរថា ម្នាលកិក្ខុ នោះជាសទ្ធិ-វិហារិករបស់អ្នកទេ ហើយទ្រង់តិះដៀលដោយន័យដែលមកក្នុងខន្ធកៈថា នែមោឃបុរស អ្នកប្រញាប់ពេលណាស់ ព្រោះអ្នកប្រព្រឹត្ត ដើម្បីសេចក្ដីល្មោកច្រើន ឯសេចក្ដីល្មោកច្រើននេះ បានដល់ការចង់ជាពួក ជាអ្នកមានចិត្តស្ទុតដូចសេះដែលត្រូវវាយដោយខ្សែ ទើបកើតឧស្សាហ៍ឡើងថា សូម្បីឥឡូវនេះ យើងអាស្រ័យបរិស័ទត្រូវព្រះដ៏មានព្រះភាគទ្រង់តិះដៀល និងក៏ព្រោះអាស្រ័យបរិស័ទដូចគ្នា ទើបបានទទួលការសរសើរដូច្នេះហើយ ទើបសមាទានធុតធម៌ទាំងអស់ប្រព្រឹត្តផ្ដើមវិបស្សនា មិនយូរលោកក៏បានអភិញ្ញា ៦ សម្រេចបដិសម្ភិទាជាព្រះមហាខីណាស្រព ឱ្យសទ្ធិវិហារិករបស់ខ្ញុំនទ្រង់ធុតង្គដូចគ្នាព្រមនឹងសទ្ធិ-វិហារិកទាំងនោះ ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ បានទទួលការសរសើរអំពីសំណាក់ព្រះដ៏មានព្រះភាគ ជាប់ដោយបរិស័ទដោយន័យដែលមកហើយ ក្នុងសន្ដតសិក្ខាបទថា ម្នាលឧបសេន បរិស័ទរបស់អ្នកប្រកបដោយសេចក្ដីជ្រះថ្លា[1] ទើបទ្រង់ស្ថាបនាទុកក្នុងឯតទគ្គៈថា* **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ**

១-វិនយបិដក មហាវិភង្គ លេខ ៣ ទំព័រ ១០៧ ។

សមន្តប្បាសាឌិកានំ យឌិនំ ឧបសេនោ វঙ্ক្ខន្តបុត្តោ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកមានសេចក្តីជ្រះថ្លះគ្រប់គ្រាន់ ដែលជាសាវ:ករបស់តថាគត ស្រេចនឹងឧបសេនវঙ্ক្ខន្តបុត្ត[1] ។ បណ្តាព្រះមហាសាវ:ក ៨០ រូប ព្រះឧបសេនដ៏មានអាយុមួយអង្គដែរ ។ ថ្ងៃមួយ ព្រះថេរ:ត្រឡប់ពីបិណ្ឌបាត ខាងក្រោយកត្តកាលពួកអន្តេវាសិកទៅកាន់ទីសម្រាកពេលថ្ងៃរបស់រៀងៗខ្លួន ទើបកាន់យកទឹកអំពីធ្នាំងទឹកលាងជើងហើយ ស្រឡាបខ្លួនឱ្យត្រជាក់ក្រាលកំណាត់ស្បែកហើយអង្គុយសម្រាកពេលថ្ងៃ នឹកដល់សេចក្តីល្អរបស់ខ្លួន ។ ពួកសទ្ធិវិហារិករបស់ព្រះថេរ: ច្រើនរយច្រើនពាន់រូបជួយគ្នាទំនុកបម្រុងព្រះថេរ:មិនដាច់ ។ ព្រះថេរ:ពិចារណាចំពោះគុណរបស់ព្រះដ៏មានព្រះភាគថា លំដាប់ដំបូងសេចក្តីល្អរបស់យើង ជារបស់នៅមានប្រមាណដល់ត្រឹមនេះ តើព្រះគុណរបស់ព្រះសាស្តាជាម្ចាស់របស់យើងនឹងមានសភាពដូចម្តេចហ្ន៎ ។ ពួកសទ្ធិវិហារិកទាំងនោះ ច្រើនពាន់កោដិ នាំគ្នាទំនុកបម្រុងព្រះថេរ:តាមសមគួរដល់ពលញ្ញាណ ។ ព្រះថេរ:រឭកដល់ព្រះគុណរបស់ព្រះសាស្តា ដែលសមរម្យដល់ការ:ដែលប្រាកដជាក់ច្បាស់ដោយន័យមានជាអាទិ៍ថា ព្រះសាស្តារបស់យើងទ្រង់មានសីលយ៉ាងនេះ មានធម៌យ៉ាងនេះ មានបញ្ញាយ៉ាងនេះ មានវិមុត្តិយ៉ាងនេះ និងដោយន័យមានជាអាទិ៍ថា ព្រោះហេតុនោះព្រះដ៏មានព្រះភាគព្រះអង្គនោះ ជាព្រះអរហន្តត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯង តអំពីនោះទើបរឭកដល់គុណរបស់ព្រះធម៌ដោយន័យមានជាអាទិ៍ថា ព្រះធម៌ គឺព្រះដ៏មានព្រះភាគត្រាស់ល្អហើយ និងគុណ

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៦០ ទំព័រ ៥៤ ។

របស់ព្រះអរិយសង្ឆ ដោយន័យមានជាអាទិ៍ថា ព្រះសង្ឆជាអ្នកបដិបត្តិហើយ ។ កាលគុណរបស់ព្រះរតនត្រ័យ ប្រាកដជាក់ច្បាស់ដោយអាការយ៉ាងនេះ ព្រះមហា-ថេរៈទើបមានចិត្តលើកសរសើររីករាយ អង្គុយសោយបីតិ និងសោមនស្សដ៏ឱឡារិក មានវេការមានអាការជាអនេក ។ ដើម្បីនឹងសម្តែងដល់សេចក្តីនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា **អាយស្មតោ ឧបសេនស្ស វង្គន្តបុត្ត-ស្ស រហោគតស្ស** ។

បណ្តាបទទាំងនោះ បទថា **រហោគតស្ស** *ប្រែថា ទៅក្នុងទីស្ងាត់ ។ បទថា* **បដិសល្លីនស្ស** *បានដល់ តែម្នាក់ឯង ។ បទថា* **ឯវํ ចេតសោ បរិវិត-ក្កោ ឧទបាឧិ** *សេចក្តីថា សេចក្តីវិតក្ក:នៃចិត្ត ដែលមានអាការដែលនឹងពោលក្នុងឥឡូវនេះ កើតឡើងហើយដោយអាការយ៉ាងនេះ ។ បទថា* **លាភា វត មេ** *សេចក្តីថា ការបានអត្តភាពជាមនុស្ស ការឧប្បត្តិឡើងនៃព្រះពុទ្ធ ការមានសទ្ធា និងការសម្រេចមគ្គផលជាដើមទាំងនោះ ចាត់ជាលាភរបស់យើងដែលគួរអស្ចារ្យ ពិតណាស់ហ្ន៎ ។ បទថា* **សុលទ្ធํ វត មេ** *សេចក្តីថា ការបព្វជ្ជាឧបសម្បទា និងការចូលទៅអង្គុយជិតព្រះរតនត្រ័យជាដើម យើងបានហើយក្នុងព្រះសាសនារបស់ព្រះដ៏មានព្រះភាគនេះ នោះជាការបានដោយល្អគួរអស្ចារ្យណាស់ហ្ន៎ ។ លោកពោលហេតុក្នុងសេចក្តីនោះដោយន័យមានជាអាទិ៍ថា* **សត្ថា ច មេ** *ដូច្នេះ ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សត្ថា វត មេ** *ជាដើមនោះ ឈ្មោះថា* **សត្ថា** *ព្រោះទូន្មានពួកសត្វតាមសមគួរក្នុងទិដ្ឋធម្មិកត្ថប្រយោជន៍ សម្ប្រាយិកត្ថ-ប្រយោជន៍ និងបរមត្ថប្រយោជន៍ ។ ឈ្មោះថា* **ភគវា** *ព្រោះហេតុមានភាពជាអ្នកមានភាគ្យធម៌ជាដើម ។ ឈ្មោះថា* **អរហํ** *(ព្រះអរហន្ត) ព្រោះជាអ្នកឆ្ងាយ*

ចាកកិលេសទាំងឡាយ ១ ព្រោះកម្ចាត់កាំនៃសង្សារចក្ក ១ ព្រោះកម្ចាត់សត្រូវ គឺកិលេស ១ ព្រោះជាអ្នកសមគួរដល់សក្ការៈមានបច្ច័យជាដើម ១ ព្រោះមិនធ្វើបាបក្នុងទីកំបាំង ១ ។ ឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ។ ក្នុងសេចក្តីនេះមានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណោះទេ ។ ចំណែកសេចក្តីពិស្តារបណ្ឌិតគប្បីជ្រាបក្នុងពុទ្ធានុសតិនិទ្ទេសក្នុងគម្ពីរវិសុទ្ធិមគ្គនោះចុះ ។

បទថា **ស្វាក្ខាតេ** ប្រែថា ត្រាស់ល្អហើយ គឺត្រាស់ឱ្យនាំសត្វចេញ-ចាកទុក្ខដោយចំណែកតែមួយ ។ បទថា **ធម្មវិនយេ** បានដល់ បាវចនៈ ។ មែនពិត បាវចនៈនោះលោកហៅថា ធម្មវិន័យ ព្រោះទ្រទ្រង់ទុកនូវអ្នកបដិបត្តិតាមដែលទូន្មាន ពីការធ្លាក់ទៅក្នុងសង្សារទុក្ខ និងព្រោះកម្ចាត់កិលេស មានរាគៈជាដើម ។ បទថា **សព្រហ្មចារិនោ** សេចក្តីថា ឈ្មោះថា សព្រហ្មចារី ព្រោះប្រព្រឹត្ត គឺបដិបត្តិស្មើនូវព្រះសាសនា ពោលគឺ ព្រហ្ម ដោយអត្ថថា ប្រសើរ បានដល់ អរិយមគ្គសច្ចៈរបស់ព្រះដ៏មានព្រះភាគ ។ បទថា **សីលវន្តោ** បានដល់ អ្នកមានសីល គឺសីលក្នុងមគ្គ និងសីលក្នុងផល ។ បទថា **កល្យាណ-ធម្មា** សេចក្តីថា ឈ្មោះថា អ្នកមានកល្យាណធម៌ ព្រោះមានធម៌ដែលល្អ គឺល្អដោយសមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈជាដើម ។ ដោយពាក្យនេះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងការបដិបត្តិល្អរបស់ព្រះសង្ឆ ។ ដោយបទថា **សីលេសុ ចម្ហិ បរិបូរិការី** នេះ ព្រះដ៏មានព្រះភាគត្រាស់ថា សូម្បីតថាគតបួសហើយ ក៏មិនបានពោលតិះដៀលតិរច្ឆានកថាជាអ្នកច្រើនទៅដោយសេចក្តីព្យាយាមដ៏រឹងមាំ តាមពិត តថាគតបំពេញសីលទាំង ៤ មានបាតិមោក្ខសំវរ-

សីលជាដើម មិនឱ្យដាច់ មិនឱ្យធ្ងុះ មិនឱ្យពពាល មិនឱ្យព្រមឱ្យជាអ្នកគ្មានបំណុល ឱ្យជាសីលដែលវិញ្ញូជនសរសើរ ឱ្យជាសីលដែលតណ្ហា និងទិដ្ឋិពាល់ត្រូវមិនបាន ឱ្យសម្រេចចំពោះអរិយមគ្គប៉ុណ្ណោះ ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់សម្បត្តិ ដែលព្រមដោយអរិយផលទាំងពីរខាងក្រោមរបស់ព្រះអង្គ ។ មែនពិត ព្រះសោតាបន្ន និងព្រះសកទាគামី ជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។ បទថា **សុសមាហិតោ ចម្ហិ ឯកគ្គចិត្តោ** *សេចក្តីថា យើងជាអ្នកមានចិត្តតាំងមាំដោយសមាធិផ្សេងដោយឧបចារៈ និងអប្បនា និងជាអ្នកមានចិត្តមិនរវើរវាយ សូម្បីដោយប្រការទាំងពួង ។ ដោយពាក្យនេះ គឺភាពជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសមាធិនេះ ទ្រង់សម្តែងដល់សម្បត្តិដែលដល់ព្រមដោយអរិយផលទី ៣ របស់ព្រះអង្គ ។ មែនពិត ព្រះអនាគামី ជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសមាធិ ។ បទថា* **អរហា ចម្ហិ ខីណាសវោ** *សេចក្តីថា តថាគតឈ្មោះថា ខីណាស្រព ព្រោះអាសវៈទាំងឡាយ មានកាមាសវៈជាដើម អស់ទៅដោយប្រការទាំងពួង ព្រោះហេតុនោះនុ៎ះឯង តថាគត ទើបឈ្មោះថា អស់កិលេសជាគ្រឿងចងសត្វទុកក្នុងភព និងឈ្មោះថា ជាព្រះអរហន្ត ព្រោះមានទក្ខិណេយ្យ-បុគ្គលដ៏កំពូលក្នុងលោក ព្រមទាំងទេវលោក ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ភាពដែលព្រះអង្គទ្រង់ធ្វើករណីយកិច្ចសម្រេចហើយ ។ បទថា* **មហិទ្ធិ-កោ ចម្ហិ មហានុភាវោ** *សេចក្តីថា តថាគតឈ្មោះថា ជាអ្នកមានឫទ្ធិច្រើន ព្រោះប្រកបដោយភាពជាអ្នកមានសេចក្តីជំនាញច្រើនក្នុងឫទ្ធិ មានការអធិដ្ឋាន និងមានការធ្វើឱ្យផ្សេងៗជាដើម និងឈ្មោះថា មានអានុភាពច្រើន ព្រោះដល់ព្រមដោយបុញ្ញានុភាព និងគុណានុភាពដ៏ឧឡារិក ។ ដោយពាក្យនេះ ព្រះអង្គទ្រង់*

សម្តែងដល់ការប្រកបដោយលោកិយអភិញ្ញា និងអនុបុព្វវិហារសមាបត្តិ ៩ របស់ព្រះអង្គ ។ មែនពិត សាវកឈ្មោះថា ជាអរិយ: ព្រោះជាអ្នកជំនាញក្នុងអភិញ្ញាទាំងឡាយ ឈ្មោះថា មានឫទ្ធិច្រើន ព្រោះញុំាងវត្ថុតាមដែលខ្លួនប្រាថ្នាឱ្យសម្រេច និងឈ្មោះថា មានអានុភាពច្រើន ព្រោះជម្រះសន្ធានឱ្យហ្មត់ចត់ ដោយឧប-និស្សយ សម្បត្តិក្នុងកាលមុន និងដោយវិហារសមាបត្តិផ្សេងៗ ដូច្នេះឯង ។

បទថា **ភទ្ធកំ មេ ជីវិតំ** សេចក្តីថា កាយនេះរបស់យើងអ្នកប្រកបគុណ មានសីលយ៉ាងនេះជាដើម នឹងទ្រទ្រង់នៅត្រឹមណា ប្រយោជន៍សុខនុ៎ះឯង ក៏នូវចម្រើនដល់ពួកសត្វត្រឹមនោះ ជីវិតរបស់យើង ក៏ឈ្មោះថា ចម្រើនគឺល្អ ល្អ ព្រោះថា ជាបុញ្ញខេត្ត ។ ដោយបទថា **ភទ្ធកំ មរណំ** នេះ ព្រះអង្គទ្រង់សម្តែងដល់ភាពជាអ្នករឹងមាំ ក្នុងអត្តទាំង ២ ថា ក៏បើបញ្ចខន្ធនេះ នឹងរលត់ទៅក្នុងថ្ងៃនេះ ឬក្នុងខណៈនេះឯង ដូចភ្លើងអស់ប្រេងដូច្នោះ សូម្បីមរណៈ គឺបរិនិព្វានដែលរកបដិសន្ធិមិនបានរបស់យើងនោះ ក៏ចាត់ថាជាការបរិនិព្វាន ។ ព្រោះដូច្នោះ ព្រះមហាថេរៈ ទើបត្រិះរិះដល់សេចក្តីដែលខ្លួនមានសោមនស្ស យ៉ាងឱឡារ ដោយសេចក្តីរាប់អានច្រើនក្នុងធម៌ និងដោយការសោយបីតិដែលកើតអំពីធម៌ ព្រោះខ្លួននូវលះសេចក្តីក្រាស់ទៅដោយភាពជាអ្នកក្រអឺតក្រអោងក្នុងសោមនស្សមិនបាន ។ ព្រះសាស្តាប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបរឿងនោះដោយព្រះសព្វញ្ញុតញ្ញាណ ទើបទ្រង់បន្ទឹមឧទានេះ ដែលប្រកាសភាពជាអ្នករឹងមាំរបស់ព្រះថេរៈទាំងក្នុងជីវិត និងមរណៈ ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ ភគវា ។បេ។ ឧទានេសិ** ដូច្នេះ ជាដើម ។

បណ្តាបទទាំងនោះ បទថា **យំ ជីវិតំ ន តបតិ** *សេចក្តីថា ជីវិតរមែងធ្វើ*
បុគ្គលដែលជាព្រះខីណាស្រព មិនឱ្យក្តៅក្រហាយ គឺមិនឱ្យលំបាកព្រោះការ
កើតឡើងនៃខន្ធតទៅ មិនមានដោយប្រការទាំងពួង ។ ម្យ៉ាងទៀត ជីវិតដែល
ជាបច្ចុប្បន្ននុ៎ះឯង រមែងមិនបៀតបៀន ព្រោះប្រកបដោយសតិសម្បជញ្ញៈក្នុង
ទីទាំងពួង ព្រោះហេតុដែលដល់សេចក្តីបរិបូណ៌ដោយសតិបញ្ញា ព្រោះជីវិត
នោះជាសង្ខតធម៌ដោយប្រការទាំងពួង ។ មែនពិត អន្ធបុថុជ្ជន គប់រកមនុស្ស
អាក្រក់ ច្រើនទៅដោយអយោនិសោមនសិការៈ មិនបំពេញកុសល មិនបំពេញ
បុណ្យ រមែងក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយ មានជាអាទិ៍ថា យើងមិន
បានធ្វើកម្មល្អទុកហ្ន៎ ព្រោះហេតុនោះ ជីវិតរបស់គេទើបធ្វើឱ្យគេក្តៅក្រហាយ ។
ចំណែកបុគ្គលក្រៅនេះ អ្នកមិនធ្វើបាប ធ្វើតែបុណ្យ ឬព្រះសេក្ខបុគ្គល ៧ ពួក
នឹងកល្យាណបុថុជ្ជន រមែងមិនក្តៅក្រហាយ ដោយសេចក្តីក្តៅក្រហាយក្នុងកាល
ជាខាងក្រោយ ព្រោះវៀរចាកធម៌ដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ និង
ព្រោះប្រកបដោយធម៌ដែលមិនជាទីតាំងនៃសេចក្តីក្តៅក្រហាយ ព្រោះហេតុនោះ
ជីវិតរបស់គេទាំងនោះ ទើបមិនក្តៅក្រហាយ ។ ចំណែកក្នុងព្រះខីណាស្រព
មិនចាំបាច់ពោលដល់ឡើយ ព្រោះហេតុនោះ លោកទើបតែងអត្តវណ្ណនា ដោយ
អំណាចបវត្តិទុក្ខ ។ បទថា **មរណន្តេ ន សោចតិ** *សេចក្តីថា ក្នុងទីបំផុត គឺ*
ក្នុងទីបំផុតជុំវិញ ពោលគឺ មរណៈ ឬក្នុងវេលាជិតនឹងស្លាប់ គេរមែងមិនសោក-
សៅ ព្រោះដកសេចក្តីសោកឡើងបាន ដោយអនាគាមិមគ្គនោះឯង ។ បទថា
សវេ ឥជ្ជមនោ ជីពោ សោកមជ្ឈេ ន សោចតិ *សេចក្តីថា អ្នកប្រាជ្ញនោះ*
ឈ្មោះថា ឃើញបទ ព្រោះឃើញបទធម៌ ៤ មានអនកិណ្ណាជាដើម ឬឃើញ
ព្រះនិព្វានទ្ធ៎ះឯង ឈ្មោះថា អ្នកប្រាជ្ញ គឺព្រះខីណាស្រព ព្រោះដល់ព្រមដោយ

បញ្ញាសូម្បីតាំងនៅត្រង់កណ្ដាលសត្វ អ្នកមិនទាន់ប្រាសចាកវាគ: ដែលបាននាមថា សោក: ព្រោះមានសេចក្ដីសោកជាធម៌ ឬត្រង់កណ្ដាលនៃលោកធម៌ ដែលជាហេតុនៃសេចក្ដីសោក រមែងមិនសោកសៅ ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងសេចក្ដីដែលកិក្ខុនោះ មិនមានហេតុនៃសេចក្ដីសោកដោយប្រការទាំងពួង ទើបត្រាស់ព្រះតម្រាស់មានជាអាទ៍ថា **ឧច្ឆិ-ន្នកវតណ្ហោ** *ជ្ជ ដូច្នេះ ។ ក្នុងពាក្យថា* **ឧច្ឆិន្នកវតណ្ហោ** *នោះមានវិនិច្ឆ័យដូចតទៅនេះ កវតណ្ហា ដែលអ្នកណាកាត់ដាច់ហើយ ដោយប្រការទាំងពួងដោយអរហត្តមគ្គ អ្នកនោះ ឈ្មោះថា មានកវតណ្ហាដែលកាត់ដាច់ ហើយ ។ កិក្ខុនោះ គឺកិក្ខុអ្នកជាខីណាស្រព ឈ្មោះថា អ្នកមានចិត្តសូប់ ព្រោះសូប់កិលេសដែលនៅសល់បានមិនឱ្យសេសសល់ ។ បទថា* **វិក្ខីណោ ជាតិសំសារោ** *សេចក្ដីថា សង្សារមានការកើតជាដើម ដែលលក្ខណ:ដូចពោលថា លំដាប់នៃខន្ធ ធាតុ និងអាយតន: ប្រព្រឹត្តទៅមិនដាច់ លោកហៅថា សង្សារដូច្នេះអស់ហើយ ដោយពិសេស ។ ព្រោះហេតុអ្វី? ព្រោះកពថ្មីរបស់កិក្ខុនោះមិនមាន អធិប្បាយថា ព្រោះហេតុដែលព្រះអរិយបុគ្គលនោះ គឺបែបនោះ មិនកើតតទៅទៀត ព្រោះដូច្នោះ សង្សារ គឺការកើតរបស់លោកទើបអស់ទៅ ។ ក៏ព្រោះហេតុអ្វី លោកទើបមិនកើតទៀត គួរនិយាយទៀតថា ព្រោះលោកកាត់កវតណ្ហា បានដាច់ និងជាអ្នកមានចិត្តសូប់ ។ ម្យ៉ាងទៀត គប្បីប្រកបសេចក្ដីថា សង្សារ គឺជាតិអស់ហើយ ព្រោះហេតុនោះឯង លោកទើបមិនកើតទៀត ។*

ជរមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៩

សម្រាប់ជាធម្មទាន

១០. សារីបុត្តឧបសមសុត្តវណ្ណនា

អដ្ឋកថាសារីបុត្តឧបសមសូត្រ

សារីបុត្តឧបសមសូត្រទី ១០ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **អត្តនោ ឧបសមំ** *សេចក្តីថា ការស្ងប់កិលេសដោយមិនឱ្យសេសសល់ របស់ខ្លួនបានដោយអរហត្តមគ្គ ដែលជាហេតុនៃការសម្រេចទីបំផុតសាវកបារមីញាណ ។*

ក៏ព្រះសារីបុត្តដ៏មានអាយុ ឃើញប្រចក្សសេចក្តីក្តៅក្រហាយសេចក្តីក្រវល់ក្រវាយ សេចក្តីក្តៅផ្សា និងសេចក្តីទុក្ខដែលកើតអំពីកិលេស មានភគ:ជាដើម និងទុក្ខមានជាតិ ជរា ព្យាធិ មរណ: សោក: និងបរិទេវ:ជាដើម មានអកិសង្ខារ គឺកិលេសជាហេតុរបស់ពួកសត្វអ្នកមិនទាន់ស្ងប់កិលេស ហើយពិចារណាទុក្ខមានវដ្ត:ជាមូលរបស់សត្វទាំងនោះ ទាំងក្នុងអតីត និងអនាគតផ្សាយករុណាវព្ចកដល់ទុក្ខមានប្រមាណមិនតិច ដែលមានកិលេសជាហេតុក្នុងកាលដែលខ្លួនសោយក្នុងភាពជាបុថុជ្ជន ទើបពិចារណារឿយៗ ដល់សេចក្តីស្ងប់កិលេសរបស់ខ្លួនថា កិលេសដែលជាហេតុនៃទុក្ខច្រើនណាស់ឈ្មោះដូច្នេះ ឥឡូវនេះ យើងលះបានដោយល្អហើយ ។ ម្យ៉ាងទៀត កាលនឹងពិចារណារមែងពិចារណាដល់សេចក្តីស្ងប់កិលេសដោយពិត ដោយមគ្គញាណនោះ។ថា កិលេសមានប្រមាណប៉ុណ្ណោះស្ងប់ហើយដោយសោតាបត្តិមគ្គ កិលេសមានប្រមាណប៉ុណ្ណោះស្ងប់ហើយដោយសកទាគามិមគ្គ កិលេសមានប្រមាណប៉ុណ្ណោះ ស្ងប់ហើយដោយអនាគามិមគ្គ កិលេសមានប្រមាណប៉ុណ្ណោះស្ងប់ហើយដោយអរហត្តមគ្គ ។ ព្រោះហេតុនោះ លោកទើបពោលថា **អត្តនោ ឧបសមំ បច្ចវេក្ខមានោ** *ដូច្នេះជាដើម ។*

អាចារ្យមួយពួកទៀតពោលថា ព្រះថេរៈចូលអរហត្តផលសមាបត្តិ ពិចារណាសមាបត្តិនោះ ហើយពិចារណាសេចក្តីស្ងប់រៀយៗ យ៉ាងនេះថា ការៈដែលឧបសមៈនេះមានសេចក្តីស្ងប់ និងប្រណីត ព្រោះជាអារម្មណ៍នៃអសង្ខ-ធាតុ ដែលមានសេចក្តីស្ងប់ដោយចំណែកតែមួយ និងព្រោះស្ងប់កិលេសដោយប្រពៃដោយខ្លួនឯង ។ ចំណែកអាចារ្យពួកដទៃទៀតពោលថា ក៏ក្នុងទីនេះ អរហត្តផលដែលកើតក្នុងទីបំផុតនៃសេចក្តីស្ងប់កិលេសបាន ឈ្មោះថា **ឧបសមៈ** លោកគង់ពិចារណាឧបសមៈនោះនៅ ។

បទថា **ឯតមត្ថំ វិនិត្វា** សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងដល់អត្ថ គឺការពិចារណាការលះកិលេស ដែលជាហេតុឱ្យព្រះសារីបុត្តដ៏មានអាយុ មានបញ្ញាច្រើនជាដើម មិនទូទៅដល់សាវកដទៃ ក្នុងចំណោមសាវកទាំងឡាយ ឬព្រះអរហត្តផល ដែលពោលអំពីការបរិយាយនៃឧបសមៈ ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងអានុភាពរបស់ឧបសមៈនោះ ។

បណ្តាបទទាំងនោះ បទថា **ឧបសន្តសន្តចិត្តស្ស** សេចក្តីថា ឈ្មោះថាអ្នកមានចិត្តស្ងប់រម្ងាប់ ព្រោះលោកជាអ្នកមានចិត្តស្ងប់រម្ងាប់នុ៎ះឯង ។ មែនពិតចិត្ត ឈ្មោះថា ចូលទៅស្ងប់ ព្រោះកិលេសចូលទៅស្ងប់ ដែលគ្របសង្កត់បានដោយសមាបត្តិ លោកទើបមិនពោលថា **ឧបសន្តសន្តំ** សេចក្តីស្ងប់រម្ងាប់ដោយប្រការទាំងពួង ព្រោះឧបសមៈនោះមិនទាន់ស្ងប់ ព្រោះមិនដូចជាស្ងប់ដោយអរហត្តមគ្គ ។ ចំណែកចិត្តរបស់លោកអ្នកឈ្មោះថា ព្រះអរហន្ត ព្រោះលោកកាត់កិលេសបានដាច់តែម្តង ជាកិលេសដែលស្ងប់ដោយមគ្គខាងដើម

ដែលសម្បយុត្តដោយសមថ: និងវិបស្សនា ដោយជាការ:ដែលមិនចាំបាច់សូប់
កិលេសទៀតលោកទើបហៅថា សូប់រម្ងាប់ព្រោះសូប់បានដោយមិនឱ្យសេសសល់ ។

ព្រោះហេតុនោះ លោកទើបពោលថា ឈ្មោះថា អ្នកមានចិត្តសូប់រម្ងាប់
ព្រោះលោកមានចិត្តសូប់រម្ងាប់នោះឯង ។ ម្យ៉ាងទៀត **ឧបសម:** លោកហៅថា
ឧបសន្ត: ។ ព្រោះដូច្នោះ បទថា **ឧបសន្តសន្តចិត្តស្ស** ទើបសំដៅសេចក្តីថា
អ្នកមានចិត្តសូប់ដោយចូលទៅសូប់ដោយដាច់ខាត ។ ម្យ៉ាងទៀត ព្រះសាស្តា
កាលនឹងទ្រង់សម្តែងថា កាលព្រះខីណាស្រពសូប់កិលេសទាំងអស់ តែសេចក្តី
សូប់កិលេសរបស់ព្រះធម្មសេនាបតីពិសេសជាង ដែលជាហេតុដល់ទីបំផុតនៃ
សាវកបារមីញាណមិនទូទៅដល់សាវកដទៃ បណ្តាសាវកទាំងឡាយ ទើបត្រាស់
ឱ្យពិសេសដោយឧបសន្ត-ស័ព្ទ ហើយត្រាស់ថា **ឧបសន្តសន្តចិត្តស្ស** ។ ក្នុង
សេចក្តីនោះ មានអធិប្បាយដូចតទៅនេះ ចិត្តសូប់យ៉ាងក្រៃលែង គឺរឹងមាំ
ឈ្មោះថា **ឧបសន្ត** ចិត្តដែលសូប់រម្ងាប់ដោយឧបសន្តចិត្តនោះឯង ឈ្មោះថា
ឧបសន្តសន្តចិត្ត ។ ចិត្តរបស់ព្រះថេរៈក៏មានសភាពដូច្នោះដែរ ពាក្យទាំងអស់
ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។ ពិតយ៉ាងនោះ ព្រះដ៏មាន-
ព្រះភាគ ទើបត្រាស់សរសើរព្រះសារីបុត្តដ៏មានអាយុនោះ ដោយអនេកបរិយាយ
ដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តមានប្រាជ្ញាច្រើន មាន
ប្រាជ្ញាក្រាស់ មានប្រាជ្ញារហ័ស មានប្រាជ្ញាវាងវៃ មានប្រាជ្ញាមុត មានប្រាជ្ញាជា
គ្រឿងទម្ងាយនូវកិលេសដូច្នេះ[1] ។ បទថា **ឧត្តិណ្ណេ** សេចក្តីថា ភវតណ្ហា

១-សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក: លេខ ២៦ ទំព័រ ២១៤ ។

លោកហៅថា **នេត្តិ** ព្រោះនាំសង្សារវដ្តទៅ ។ ឈ្មោះថា អ្នកមាននេត្តិច្ឆិន្ន: ព្រោះលោកកាត់នេត្តិបានហើយ ។ ចិត្តរបស់បុគ្គលអ្នកមាននេត្តិជាប់ហើយ នោះ អធិប្បាយថា អ្នកលះតណ្ហាបានហើយ ។ បទថា **មុត្តោ សោ មារពន្ធនា** សេចក្តីថា អ្នកនោះ គឺអ្នកជាយ៉ាងនោះ បានដល់ អ្នកមានកិលេសជាគ្រឿងចង សត្វទុកឱ្យអស់ហើយ រួចផុតហើយ អំពីគ្រឿងចងនៃមារទាំងពួង លោកមិនមាន កិច្ចដែលនឹងត្រូវធ្វើ ព្រោះលោករួចផុតពីគ្រឿងចងនៃមារ ព្រោះដូច្នោះ ព្រះធម្មសេនាបតី ទើបពិចារណាសេចក្តីសូប់របស់ខ្លួន ។ ពាក្យដែលនៅសល់ មានន័យដូចពោលហើយនុ៎ះឯង ។

ឧសមសុត្តវណ្ណា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១០

និដ្ឋិតា ច មេឃិយវគ្គវណ្ណា

ចប់មេឃិយវគ្គវណ្ណនាទី ៤

រួមព្រះសូត្រដែលមានក្នុងវគ្គនេះគឺ

១-មេឃិយសូត្រ	២-ឧទ្ធតសូត្រ
៣-គោបាលសូត្រ	៤-យក្ខបហារសូត្រ
៥-នាគសូត្រ	៦-បិណ្ឌោលសូត្រ
៧-សារីបុត្តសូត្រ	៨-សុទ្ទរីសូត្រ
៩-ឧបសេនសូត្រ	១០-សារីបុត្តឧបសមសូត្រ

៥. សោណត្ថេរវគ្គោ

សោណត្ថេរវគ្គទី ៥

១. បិយតរសុត្តវណ្ណនា

អដ្ឋកថាបិយតរសូត្រ

បិយតរសូត្រ **ទី ១** *នៃសោណត្ថេរវគ្គ មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **មល្លិកា ទេវិយា សទ្ធិ** *សេចក្តីថា នឹងព្រះមហេសីរបស់ព្រះអង្គទ្រង់ព្រះនាមថា* **មល្លិកា** *។ បទថា* **ឧបរិបាសាទវរគតោ** *បានដល់នៅខាងលើប្រាសាទដ៏ប្រសើរ ។ បទថា* **កោចញ្ញោ អត្តនោ បិយតរោ** *សេចក្តីថា បុគ្គលណាជទៃជាទីពេញចិត្ត ជាទីស្រឡាញ់ជាងរបស់នាង ។ បទថា* **អត្ថិ នុ ខោ តេ** *ជាពាក្យ គឺព្រះរាជាសួរព្រះនាងទេវីថា មានដែរឬ ។*

ព្រោះហេតុអ្វី ព្រះរាជាទើបត្រាស់សួរ ។ ព្រោះព្រះនាងមល្លិកានេះ ជាធីតារបស់នាយមាលាកាអ្នកក្រខ្សត់ក្នុងក្រុងសាវត្ថី ។ ថ្ងៃមួយ នាងមល្លិកានោះ ទិញនំអំពីផ្សារទៅសួនផ្កាឈើ គិតថានឹងបរិភោគ ទើបដើរទៅជួបព្រះដ៏មាន-ព្រះភាគហៃហមដោយភិក្ខុសង្ឆ កំពុងចូលទៅកាន់ភិក្ខាចារត្រង់ផ្លូវទៅកាន់សួន មានចិត្តជ្រះថ្លា បានថ្វាយនំនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាទ្រង់សម្តែងអាការប្រថាប់គង់ក្នុងទីដ៏សមគួរ ។ ព្រះអានន្ទត្ថេរបានក្រាលចីវរថ្វាយ ។ ព្រះដ៏មានព្រះភាគប្រថាប់គង់ក្នុងទីនោះ ទ្រង់សោយនំហើយខ្ពុរព្រះឱស្ថ ទ្រង់

ធ្វើការញញឹមឱ្យប្រាកដ ។ ព្រះថេរៈទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន វិបាកនៃទានរបស់ស្ត្រីនេះ នឹងទៅជាយ៉ាងណា ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទ ថ្ងៃនេះនាងមល្លិកាបានថ្វាយភោជនដល់តថាគតជាគ្រាដំបូង ក្នុងថ្ងៃនេះឯង នាងនឹងជាអគ្គមហេសី ជាទីស្រឡាញ់ ជាទីប្រោសប្រាណរបស់ព្រះបាទ-កោសល ។ ក៏ក្នុងថ្ងៃនោះនុ៎ះឯង ព្រះរាជាច្បាំងនឹងក្ជយក្នុងកាសិគាម ចាល-ចាញ់ គេចដៀសមកចូលក្រុង ប្រាថ្នានឹងរងចាំឱ្យពួកពលមក ទើបស្តេចចូលទៅកាន់សួនផ្ការឈើនោះ ។ នាងមល្លិកានោះ ឃើញព្រះរាជាយាងមក ទើបប្រណិបត្តិព្រះរាជា ។ ព្រះរាជាទ្រង់ប្រោសប្រាណក្នុងការប្រណិបត្តិរបស់នាង ហើយបង្គាប់ឱ្យហៅបិតាមក ទ្រង់ប្រទានឥស្សរិយយសយ៉ាងធំ ហើយឱ្យនាំនាងចូលមកកាន់ខាងក្នុងព្រះរាជវាំង ទ្រង់តែងតាំងជាអគ្គមហេសី ។ ថ្ងៃខាងក្រោយមក ព្រះរាជាទ្រង់មានព្រះចិន្តាថា យើងឱ្យឥស្សរិយយសយ៉ាងធំដល់នាង បើយ៉ាងណា យើងគប្បីសួរនាងថា អ្នកណាជាទីស្រឡាញ់របស់នាង ព្រះនាង-មល្លិកាទូលថា បពិត្រមហារាជ ព្រះអង្គជាទីស្រឡាញ់របស់ខ្ញុំ ហើយនឹងត្រឡប់សួរយើង កាលបើដូច្នេះ យើងនឹងតបដល់នាងថា នាងប៉ុណ្ណោះជាទីស្រឡាញ់របស់យើង ។ ព្រោះដូច្នោះ ព្រះរាជាកាលនឹងទ្រង់ធ្វើសម្មោទនីយៈដើម្បីឱ្យកើតសេចក្តីស្និទ្ធិស្នាលដល់គ្នានិងគ្នា ទើបត្រាស់សួរ ។ ក៏ព្រះទេវីជាបណ្ឌិត

ជាឧបដ្ឋាយិការបស់ព្រះពុទ្ធ ជាឧបដ្ឋាយិការបស់សង្ឆ ទ្រង់មានព្រះចិន្តាថា បញ្ហានេះមិនគួរយល់ដល់ព្រះរាជា ហើយធ្វើយឡើង កាលនឹងទូលតាមសេចក្តីពិតនោះឯង ទើបទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គមិនមានអ្នកណាដទៃដែលនិងជាទីស្រឡាញ់ក្រៃលែងជាងខ្លួនឡើយ ។ ព្រះទេវីសូម្បីត្រាស់ដូច្នេះ ហើយប្រាជ្ញានឹងធ្វើអត្ថដែលខ្លួនបានព្យាករឱ្យប្រាកដដល់ព្រះរាជា ដោយឧបាយ ទើបទូលសួរព្រះរាជាដូចជាដែលព្រះរាជាត្រាស់សួរខ្លួនឯងថា បពិត្រមហារាជ ក៏ព្រះអង្គ មានអ្នកដទៃណាជាទីស្រឡាញ់ក្រៃលែងជាងខ្លួនរបស់ព្រះអង្គឬ ។ ចំណែកព្រះរាជាមិនអាចត្រឡប់(សេចក្តី)បាន ព្រោះព្រះទេវីត្រាស់ដោយលក្ខណៈ:ព្រមទាំងកិច្ច សូម្បីព្រះអង្គឯងក៏ត្រាស់ដោយលក្ខណៈ:ព្រមទាំងកិច្ច ទើបត្រាស់ព្យាករដូចព្រះទេវីត្រាស់ព្យាករ ។

ក៏កាលត្រាស់ព្យាករហើយ ព្រោះភាពដែលព្រះអង្គមានបញ្ញាទន់-ខ្សោយ ទើបទ្រង់មានព្រះចិន្តាយ៉ាងនេះថា យើងជាព្រះរាជាជាធំលើផែនដីគ្រប់គ្រងផែនដី ការនឹងព្យាករថា យើងមិនឃើញអ្នកដទៃដែលជាទីស្រឡាញ់ក្រៃលែងជាងខ្លួន ដូច្នេះ មិនសមគួរដល់យើងឡើយ តែនាងនេះ ជាស្រីថោក-ទាប ជាតិអាក្រក់យើងតាំងទុកក្នុងតំណែងខ្ពស់ ក៏មិនទាន់ស្រឡាញ់យើងជាស្វាមីយ៉ាងពិតមែន នូវតែពោលចំពោះមុខយើងថា ខ្លួនឯងប៉ុណ្ណោះជាទីស្រឡាញ់

ដល់ខ្លួន ដូច្នេះហើយ ទើបមិនពេញព្រះទ័យថា នាងស្រឡាញ់ព្រះរតនត្រ័យ ច្រើនជាងឬ ។ ព្រះទេវីក្រាបទូលថា បពិត្រមហារាជ នាងខ្ញុំប្រាថ្នាសុខក្នុងសួគ៌ និងសុខក្នុងមគ្គដើម្បីខ្លួន សូម្បីព្រះរតនត្រ័យនាងខ្ញុំក៏ស្រឡាញ់ ព្រោះដូច្នោះ ខ្លួនន៏ុះឯង ទើបជាទីស្រឡាញ់ក្រៃលែងរបស់នាងខ្ញុំ ។ ក៏សត្វលោកទាំងអស់ នេះ ស្រឡាញ់អ្នកដទៃក៏ដើម្បីប្រយោជន៍ខ្លួនឯងប៉ុណ្ណោះ សូម្បីកាលប្រាថ្នាបុត្រ ក៏ប្រាថ្នាថា បុត្រនេះនឹងចិញ្ចឹមយើងក្នុងកាលដែលខ្លួនចាស់ កាលប្រាថ្នាធីតា ក៏ប្រាថ្នាថា ត្រកូលរបស់យើងនឹងចម្រើនឡើង កាលប្រាថ្នាភរិយា ក៏ប្រាថ្នាថា នឹងបម្រើដើងយើង កាលប្រាថ្នាសូម្បីអ្នកដទៃមិនថាជាញាតិមិត្ត នឹងអ្នកជាប់ខ្សែស្រឡាយ ក៏ប្រាថ្នាជាប់ដោយកិច្ចនោះ។ ព្រោះដូច្នោះ សត្វលោក ជាអ្នកឃើញតែប្រយោជន៍ខ្លួនប៉ុណ្ណោះ ទើបស្រឡាញ់អ្នកដទៃ រួមសេចក្ដីថា ព្រះទេវីមានសេចក្ដីប្រាថ្នាយ៉ាងនេះឯង ។

លំដាប់នោះ ព្រះរាជាទ្រង់មានព្រះចិន្តាថា នាងមល្លិកានេះ ជាអ្នកឆ្លាត ជាបណ្ឌិត ជាអ្នកវាងវៃ ហើយពោលថា ខ្លួនន៏ុះឯង ជាទីស្រឡាញ់ក្រៃលែងរបស់ខ្លួនយើង សូម្បីខ្លួនរបស់យើងនោះឯង ក៏ប្រាកដថាជាទីស្រឡាញ់ ណ្ហើយចុះ យើងនឹងក្រាបទូលរឿងនេះចំពោះព្រះសាស្តា យើងនឹងចាំទុកនូវសេចក្ដីនេះ តាមដែលព្រះសាស្តាទ្រង់ព្យាករដល់យើង ។ ក៏ត្រាទ្រង់មានព្រះចិន្តា

យ៉ាងនេះហើយ ទើបស្តេចទៅគាល់ព្រះសាស្តាក្រាបទូលសេចក្តីនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ រាជា បសេនទិ កោសលោ ។បេ។ បិយតរោ** ដូច្នេះជាដើម ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះសាស្តាទ្រង់ជ្រាបដោយប្រការទាំងពួងនូវសេចក្តីនេះ គឺដែលព្រះរាជាត្រាស់ថា សព្វសត្វក្នុងលោកដែលមានខ្លួនជាទីស្រឡាញ់ក្រៃលែងជាងខ្លួន ទើបបន្ទឹមទាននេះ ដែលសម្តែងដល់សេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **សព្វា ទិសា អនុបរិគម្ម ចេតសា** សេចក្តីថា បញ្ជូនចិត្តទៅដោយអំណាចការស្វែងរកទូទៅទិសទាំង ១០ ទិស ។ បទថា **នេវ-ជ្ឈគា បិយតរមត្តនា ក្វចិ** សេចក្តីថា បុគ្គលខ្លះ មានសេចក្តីឧស្សាហ៍យ៉ាងខ្លាំង ស្វែងរកបុគ្គលដទៃ អ្នកជាទីស្រឡាញ់ក្រៃលែងដល់ខ្លួន មិនគប្បីជួប គឺមិនគប្បីប្រសព្វក្នុងទីណាទីមួយ គឺក្នុងទីទាំងពួង ។ បទថា **ឯវំ បិយោ បុថុ អត្តា បរេសំ** សេចក្តីថា សត្វទាំងនោះ។ ក៏មានខ្លួនជាទីស្រឡាញ់ច្រើន គឺជាពួកៗ ដូចយ៉ាងនោះ គឺនឹងរកអ្នកណាៗ អ្នកជាទីស្រឡាញ់ក្រៃលែងជាងខ្លួនមិនបាន ។ បទថា **តស្មា ន ហឺសេ បរំ មត្តកាមោ** សេចក្តីថា ព្រោះហេតុដែលសត្វទាំងអស់ស្រឡាញ់ខ្លួនឯង គឺស្រឡាញ់សុខ ស្អប់ទុក្ខយ៉ាងនេះ ដូច្នោះ អ្នក

ស្រឡាញ់ខ្លួន កាលប្រាថ្នាហិតសុខដើម្បីខ្លួន ទើបមិនបៀតបៀន មិនសម្ងាប់សត្វដទៃ ដោយហោចទៅសូម្បីតែស្រមោចខ្មៅ ស្រមោចក្រហម ទាំងមិនបៀត-បៀន ដោយបហរណាវុត្ត មានបាតដៃ ជុំដី និងកំណាត់ឈើជាដើម ។ មែនពិត កាលខ្លួនធ្វើទុក្ខឱ្យដល់អ្នកដទៃ ទុក្ខនោះដូចជាឈានចេញ មកពីកម្មដែលខ្លួនធ្វើទុកហើយនោះ នឹងប្រាកដក្នុងខ្លួន រហូតជិតស្លាប់ ។ ក៏ប្រការនេះ ជាធម្មតារបស់កម្មនុ៎ះឯង ។

បឋមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ១

២. អប្ប៉ាយុកសុត្តវណ្ណនា

អដ្ឋកថាអប្ប៉ាយុកសូត្រ

អប្ប៉ាយុកសូត្រទី ២ *មានវិនិច្ឆ័យដូចតទៅនេះ*

ពាក្យថា **អច្ឆរិយំ ភន្តេ** *សូម្បីនេះ គប្បីជ្រាបដោយប្រការអស្ចារ្យដែលគួរតិះដៀលដូចក្នុងមេឃិយសូត្រ ។ បទថា* **យាវ អប្ប៉ាយុកា** *ប្រែថា មានអាយុតិចត្រឹមណា អធិប្បាយថា មានជីវិតប្រមាណតិច គឺតិចណាស់ ។ បទថា* **សត្តាហជាតេ** *សេចក្តីថា ប្រសូតដោយសប្តាហ៍ ១ ឈ្មោះថា សត្តាហជាត: ក្នុងកាលព្រះអង្គប្រសូតបាន ៧ ថ្ងៃ អធិប្បាយថា ក្នុងថ្ងៃទី ៧ ដែលព្រះអង្គប្រសូត ។ បទថា* **តុសិតំ កាយំ ឧបបជ្ជតិ** *សេចក្តីថា ចូលដល់ទេវនិកាយជាន់តុសិតដោយការកាន់បដិសន្ធិ ។*

ដំណាលមកថា ថ្ងៃមួយ ខាងក្រោយកត្ត ព្រះថេរ:គង់សម្រាកពេលថ្ងៃ ដាក់ចិត្តដល់ព្រះរូបឆោមរបស់ព្រះដ៏មានព្រះភាគ ដែលប្រដាប់ដោយលក្ខណ: និងអនុព្យញ្ជន: មានព្រះរូបឆោម ជាទស្សនានុត្តរិយ: ហើយទើបគិតថា គួរអស្ចារ្យណាស់ ព្រះពុទ្ធទាំងឡាយព្រមទៅដោយព្រះរូបកាយគួរសរសើរ នាំមកនូវសេចក្តីជ្រះថ្លាដោយជុំវិញ គួររីករាយនៃចិត្ត ដូច្នេះហើយ ទើបសោយបីតិ និងសោមនស្សយ៉ាងក្រៃលែង ទើបគិតយ៉ាងនេះថា ធម្មតាមាតាបង្កើតនឹងមានបុត្ររូបរាងមិនល្អ ក៏នៅមានសេចក្តីពេញចិត្ត ដូចជាបុត្ររូបរាងល្អ ដូច្នោះ

ក៏បើថា ព្រះនាងមហាមាយាទេវីជាព្រះពុទ្ធមាតា នៅមានព្រះជន្ម ព្រះនាងក៏នឹងគប្បីកើតបីតិសោមនស្ស ព្រោះបានឃើញព្រះរូបនោមរបស់ព្រះដ៏មាន-ព្រះភាគ ដូចជាអ្វីទៅហ្ន៎ កាលព្រះដ៏មានព្រះភាគប្រសូតបាន ៧ ថ្ងៃ ព្រះទេវី-មហាមាតារបស់ព្រះដ៏មានព្រះភាពសោយវិលាល័យ ជាការសោបសូន្យយ៉ាងធំ ។ ក៏គ្រាគិតយ៉ាងនេះហើយ ទើបចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលការបរិវិតក្ក:របស់ខ្លួន កាលនឹងតិះដៀលការសោយវិលាល័យរបស់ព្រះនាងមហា-មាយាទេវី ទើបក្រាបទូលពាក្យមានជាអាទិ៍ថា **អច្ឆរិយំ ភន្តេ** ។

តែអាចារ្យពួកខ្លះពោលថា ព្រះនាងមហាបជាបតីគោតមី ទុកជាអង្វរសូមបព្វជ្ជាចំពោះព្រះដ៏មានព្រះភាគ ដោយសេចក្ដីលំបាកក្រៃលែង ក៏នូវតែព្រះអង្គទ្រង់ហាម តែយើងទូលសូមដោយឧបាយហើយ ព្រះដ៏មានព្រះភាគទើបទ្រង់អនុញ្ញាតការបព្វជ្ជា និងឧបសម្បទាដោយការទទួលគរុធម៌ ៨ ប្រការ ព្រះនាងទទួលធម៌ទាំងនោះហើយ បានបព្វជ្ជាឧបសម្បទា ហើយទើបកើតបរិស័ទទី ២ របស់ព្រះដ៏មានព្រះភាគឡើយ បានជាបច្ច័យដល់បរិស័ទទី ៤ ។ ក៏ប្រសិនបើព្រះមហាមាយាទេវីព្រះជននីរបស់ព្រះដ៏មានព្រះភាគ មានព្រះជន្ម នៅឡើយ កាលបើដូច្នេះ ព្រះនាងខន្ដិយកគិនីសូម្បីទាំងពីរនេះរួមគ្នា ក៏នឹងគប្បីធ្វើព្រះសាសនានេះឱ្យស្រស់ល្អ ក៏ព្រោះការរាប់អានក្នុងព្រះមាតាច្រើន

ព្រះដ៏មានព្រះភាគ គប្បីទ្រង់អនុញ្ញាតការបព្វជ្ជានិងឧបសម្បទាក្នុងព្រះសាសនា ដល់មាតុគ្រាមដោយងាយតែម្តង តែដោយព្រះនាងមហាមាយាទេវីមានព្រះជន្ម-យុតិច រឿងនោះទើបសម្រេចបានដោយលំបាក ដោយការអធិប្បាយមកនេះ ព្រះថេរៈទើបក្រាបទូលពាក្យមានជាអាទិ៍ថា **អច្ឆរិយំ ភន្តេ** ក្នុងសម្ងាត់របស់ព្រះដ៏មានព្រះភាគ ។ ប្រការនោះមិនមែនជាហេតុទេ ។ មែនពិត ព្រះដ៏មាន-ព្រះភាគ កាលនឹងទ្រង់អនុញ្ញាតការបព្វជ្ជាក្នុងសាសនារបស់ព្រះអង្គដល់មាតា ឬមាតុគ្រាមដទៃ ទើបទ្រង់អនុញ្ញាតឱ្យតឹងតែម្តង មិនមែនទ្រង់អនុញ្ញាតយ៉ាងធូរ ព្រោះទ្រង់មានប្រាជ្ញាឱ្យព្រះសាសនាតាំងនៅបានយូរ ។

ចំណែកអាចារ្យមួយពួកទៀតពោលថា ព្រះថេរៈមនសិការដល់ព្រះពុទ្ធ-គុណរកទីបំផុតរកប្រមាណមិនបាន មិនទូទៅដល់អ្នកដទៃ មានទសពល-ញាណ និងចតុវេសារជ្ជញ្ញាណជាដើម ទើបកើតសេចក្តីអស្ចារ្យក្នុងចិត្តឡើងថា ព្រះពុទ្ធមាតារក្សាព្រះសាស្តាជាអគ្គបុគ្គលក្នុងលោក អ្នកមានអានុភាពច្រើនដល់ត្រឹមនេះ ក្នុងព្រះគភ៌អស់ ១០ ខែ នឹងជាបរិចារិការបស់អ្នកណាៗ ព្រោះដូច្នោះ ប្រការនេះទើបមិនសមគួរ ។ ព្រោះហេតុអ្វី ប្រការនេះ កាលព្រះដ៏មាន-ព្រះភាគប្រសូតបាន ៧ ថ្ងៃ ព្រះពុទ្ធមាតាទ្រង់សោយវិលាល័យ និងកាលសោយវិលាល័យហើយ ព្រះនាងកើតក្នុងជាន់តុសិត នេះជាការសមគួរដល់ព្រះគុណ

របស់ព្រះសាស្តាយ៉ាងមែនពិត កាលនឹងក្រាបទូលការវិតក្ក:ថា ដែលកើតឡើងដល់ខ្លួននោះ ចំពោះព្រះដ៏មានព្រះភាគ ទើបបានពោលពាក្យមានជាអាទិ៍ថា **អច្ឆរិយំ ភន្តេ** ដូច្នេះ ។

ក៏ព្រះសាស្តា កាលនឹងទ្រង់សម្តែងប្រការដែលព្រះពោធិសត្វប្រសូតបាន ៧ ថ្ងៃ ព្រះមាតារបស់ព្រះពោធិសត្វក៏សោយវិលាល័យចាត់ជាការសម្រេចដោយធម្មតា ទើបត្រាស់ពាក្យមានជាអាទិ៍ថា **ឯវមេតំ អានន្ទ** ។ ក៏ធម្មតានេះនោះគប្បីជ្រាប ដោយអំណាចដែលព្រះពោធិសត្វគ្រប់ព្រះអង្គធ្លាប់ប្រព្រឹត្តជាអាចិណវត្តស្មើមក ព្រោះព្រះពោធិសត្វគ្រប់ព្រះអង្គ ទ្រង់បំពេញព្រះបារមីហើយ កើតក្នុងជាន់តុសិត ទ្រង់តាំងនៅក្នុងតុសិតនោះរហូតដល់អស់អាយុ ក្នុងទីបំផុតនៃអាយុ គឺទេវតាក្នុងម៉ឺនចក្រវាឡប្រជុំគ្នាទូលអាពធនាដើម្បីឱ្យទ្រង់កាន់បដិសន្ធិក្នុងមនុស្សលោកដើម្បីអភិសម្ពោធិញ្ញាណ ទើបពិចារណាមើលប្រមាណអាយុរបស់ព្រះពុទ្ធមាតា ដូចពិចារណាមើលកាល ទ្វីប ប្រទេស និងត្រកូល ហើយទើបកាន់បដិសន្ធិ យ៉ាងណា ព្រះមានព្រះភាគសូម្បីអង្គនេះ ជាព្រះពោធិសត្វ តាំងនៅក្នុងជាន់តុសិត ក៏ដូច្នោះដែរ ទ្រង់ពិចារណាមើលមហាវិលោកន: ៥ ប្រការ ទ្រង់កំណត់ប្រមាណអាយុរបស់ព្រះពុទ្ធមាតា ១០ ខែនឹង ៧ ថ្ងៃ ឲ្យទ្រង់ជ្រាបថា នេះជាវេលាដែលយើងនឹងកាន់បដិសន្ធិ ឥឡូវ

នេះ យើងគួរឧប្បត្តិ ដូច្នេះហើយ ទើបទ្រង់កាន់បដិសន្ធិ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ថា **អ**ប្ប**ាយ**ុ**ការ ហ**ិ **អ**ានន្ទ**ពោ**ធិ**ស**ត្ត**ម**ា-**ត**ោ **ហ**ោ**ន**្ត**ិ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ការ**ំ **ក**ោ**ន**្ត**ិ** *សេចក្តីថា ធ្វើកាលៈដោយអស់ទៅនៃអាយុតាមដែលពោលហើយនុ៎ះឯង មិនមែនព្រោះការប្រសូតជាបច្ច័យ ។ មែនពិត ស្ថានទីដែលព្រះពោធិសត្ត្វនៅក្នុងអត្តភាពចុងក្រោយដូចជាឃរចេតិយ មិនមែនជាស្ថានទីដែលអ្នកពួកដទៃនឹងប្រើប្រាស់ និងអ្នកណាៗមិនអាចដែលនិងដកព្រះមាតារបស់ព្រះពោធិសត្ត្វចេញ ហើយតាំងស្ត្រីដទៃទុកក្នុងតំណែងជាអគ្គមហេសី ។ ត្រឹមតែប៉ុណ្ណោះឯង ចាត់ជាប្រមាណអាយុរបស់ព្រះមាតាព្រះពោធិសត្ត្ব ព្រោះដូច្នោះ ទើបបានធ្វើកាលៈក្នុងវេលានោះ ។ ក៏ព្រះមហាពោធិសត្ត្វទាំងឡាយ សំដៅដល់សេចក្តីនេះនុ៎ះឯង ទើបធ្វើមហា-វិលោកនៈ ៥ ប្រការ ។*

សួរថា ក៏ព្រះមាតារបស់ព្រះពោធិសត្ត្ব ធ្វើកាលៈក្នុងវ័យណា? ឆ្លើយថា ក្នុងមជ្ឈិមវ័យ ។ មែនពិត ក្នុងបឋមវ័យ សត្ត្ববទាំងឡាយមានធន្ធ្ববគៈខ្ជាំងក្លាក្នុងអត្តភាព ព្រោះដូច្នោះ ស្ត្រីទាំងឡាយ អ្នកតាំងគក៌ក្នុងវ័យនោះ ដោយច្រើនមិនអាចនឹងតាមរក្សាគក៌បាន ។ បើគប្ភ៌កាន់បដិសន្ធិបានសោត សត្ত্ববដែលកើតក្នុង

គក់ក៏នឹងមានជំងឺច្រើន ។ ក៏គ្រាកន្ទ ២ ចំណែករបស់មជ្ឈិមវ័យទៅហើយ ក្នុងចំណែកទី ៣ គក់ក៏បរិសុទ្ធ ក្មេងដែលកើតក្នុងគក់ដែលបរិសុទ្ធ ក៏នឹងមិនមានរោគ ព្រោះដូច្នោះ មាតារបស់ព្រះពោធិសត្ត ទើបបានសោយសម្បត្តិក្នុងបឋម-វ័យ ប្រសូតក្នុងចំណែកទី ៣ របស់មជ្ឈិមវ័យ ហើយទ្រង់សោយវិលាស័យឯង ។

បទថា **ឯតមត្ថំ ១ ១ ១ ១** សេចក្ដីថា ទ្រង់ជ្រាបថា អាយុក្នុងអត្តភាពរបស់មាតាព្រះពោធិសត្ត និងសព្វសត្វពួកដទៃ មានសេចក្ដីស្ងាប់ជាទីបំផុត ទើបទ្រង់បន្ទឺឧទានៈ ដែលសម្ដែងដល់សេចក្ដីឧស្សាហ៍ ក្នុងការបដិបត្តិដែលរកទោសមិនបានជាប្រធាន ដែលសម្ដែងដល់សេចក្ដីនោះយ៉ាងជាក់ច្បាស់ ។

បណ្ដាបទទាំងនោះ បទថា **យេកេចិ** ជាបទសម្ដែងអត្ថដែលមិនពិតប្រាកដ ។ បទថា **ភូតា** ប្រែថា កើតហើយ ។ បទថា **ភវិស្សន្តិ** ប្រែថា នឹងកើតក្នុងអនាគត ។ **ភ**-ស័ព្ទ ជាវិកប្បត្ត: ។ **អ**-ស័ព្ទ ជាសម្ជ្ញានត្ថ: ។ ដោយ **អ**-ស័ព្ទនោះ លោកសង្គ្រោះយកសត្វអ្នកកំពុងកើត ។ ដោយលំដាប់ពាក្យត្រឹមតែប៉ុណ្ណោះ លោកកំណត់កាន់យកពួកសត្ត អ្នករាប់បញ្ចូលក្នុងបដិសន្ធិ ដោយអំណាចកាល មានអតីតកាលជាដើម ដោយមិនមានចំណែកនៅសល់ ។ ម្យ៉ាងទៀត គព្ភសេយ្យកសត្ត សត្វអ្នកកើតក្នុងគក់ តាំងពីវេលាចេញចាកគក់ ឈ្មោះថា **ភូតា** (សត្វកើតហើយ) ។ មុនអំពីកើតនោះ ឈ្មោះថា នឹងកើត ។

ពួកសំសេទជសត្ត និងឧបបាតិកសត្ត ក្រោយអំពីបដិសន្ធិចិត្តទៅ ឈ្មោះថា កើតហើយ ។ មុនអំពីនោះ ឈ្មោះថា នឹងកើត ដោយអំណាចកពដែលនឹងគប្បីកើត ។ ឬថា សត្តសូម្បីទាំងអស់ឈ្មោះថា កើតហើយ ដោយអំណាចបច្ចុប្បន្ន-កព ។ ឈ្មោះថា នឹងកើត ដោយអំណាចកពថ្មីក្នុងអនាគត ។ អ្នកអស់អាសវៈ ឈ្មោះថា កើតហើយ ។ មែនពិត បុគ្គលអ្នកអស់អាសវៈទាំងនោះ កើតហើយ ប៉ុណ្ណោះ ក៏នឹងមិនកើតតទៅទៀត ។ សត្តពួកដទៃពីអ្នកអស់អាសវៈទាំងនោះ ឈ្មោះថា នឹងកើត ។ បទថា **សព្ពេ ឥមិស្សន្តិ ឯហាយ ឯហំ** សេចក្តីថា សត្តទាំងពួងផ្សេងគ្នាតាមដែលពោលហើយ និងផ្សេងគ្នាជាច្រើនប្រភេទ ដោយកព កំណើត គតិ វិញ្ញាណឋិតិ និងសត្តាវាសជាដើម ទាំងអស់នឹងលះ គឺលះចោលរាងកាយ គឺសរីរៈរបស់ខ្លួនទៅកាន់បរលោក ចំណែកព្រះអសេក្ខបុគ្គលក៏បរិនិព្វាន ។ ក្នុងសេចក្តីនេះ លោកសម្តែងទុកថា អ្នកណាៗ ឈ្មោះថា មិនមានការចុតិជាធម៌ មិនមានទេ ។ បទថា **តំ សព្ពជានឺ កុសលោ វិនិត្វា** សេចក្តីថា បណ្ឌិតអ្នកឈ្វាស គឺបណ្ឌិតជ្រាបសេចក្តីសាបសូន្យ គឺសេចក្តីបាត់ទៅ បានដល់ សេចក្តីស្ងាប់របស់សព្វសត្តនេះនោះ ឬថា ជ្រាបដល់សេចក្តីសាបសូន្យ គឺសេចក្តីវិនាស បានដល់ សេចក្តីស្ងាប់របស់សព្វសត្តទាំងអស់នោះ ដោយអំណាចមរណានុស្សតិ ឬដោយអំណាចអនិច្ចតាមនសិការជាដើម ។

បទថា **អាតាបិយោ ព្រហ្មចរិយំ ចរេយ្យ** *សេចក្តីថា កាលបំពេញវិបស្សនា ឈ្មោះថា មានសេចក្តីព្យាយាម ព្រោះប្រកបដោយសេចក្តីព្យាយាម គឺសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ឈ្មោះថា ប្រារព្ធសេចក្តីព្យាយាមដោយអំណាចសម្មប្បធាន ៤ គប្បីប្រព្រឹត្ត គឺបដិបត្តិមគ្គព្រហ្មចរិយៈ ដែលជាឧបាយជាគ្រឿងឈានកន្ធងមរណៈដោយមិនឱ្យសេសសល់ ។*

ឧតិយសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ២

៣. សុប្បពុទ្ធកុដ្ឋិសុត្តវណ្ណនា

អដ្ឋកថាសុប្បពុទ្ធកុដ្ឋិសូត្រ

សុប្បពុទ្ធកុដ្ឋិសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

បទថា ** រាជគហេ សុប្បពុទ្ធោ នាម កុដ្ឋី អហោសិ** *សេចក្តីថា* *បុរសម្នាក់ នាមថា* ***សុប្បពុទ្ធ:*** *បាននៅក្នុងក្រុងរាជគ្រឹះ ។ សុប្បពុទ្ធ:នោះមានខ្លួនត្រូវរោគឃ្ងង់ឃ្ងៀតឃ្ងៀនយ៉ាងធ្ងន់ ។ បទថា* **មនុស្សឧលិត្តោ** *សេចក្តីថា* *គាត់ជាមនុស្សកំសត់ជាងគេទាំងអស់ បណ្តាមនុស្សក្នុងក្រុងរាជគ្រឹះ ។ ក៏គាត់ដេរកំណាត់សំពត់ចាស់ដែលពួកមនុស្សចោល ត្រង់គំនរសំរាម និងត្រង់របងជាដើមយកមកស្ងៀកដណ្តប់ ។ គាត់កាន់ក្បឿងទៅតាមផ្ទះ អាស្រ័យបាយ និងកត្តដែលជារបស់សល់ដើម្បីចិញ្ចឹមជីវិត ។ សូម្បីរបស់នោះ គាត់ក៏មិនបានតាមសេចក្តីត្រូវការ ព្រោះកម្មដែលខ្លួនធ្វើទុកក្នុងកាលមុន ។ ព្រោះហេតុនោះ លោកទើបពោលថា ជាមនុស្សខ្ទះខាត ។ បទថា* **មនុស្សកបណោ** *បានដល់ បណ្តាមនុស្ស គាត់ជាមនុស្សកំព្រាយ៉ាងក្រៃលែង ។ បទថា* **មនុស្សវរាកោ** *បានដល់ ជាមនុស្សថោកទាប ព្រោះត្រូវពួកមនុស្សតិះដៀលនិងមើលងាយ ។ បទថា* **ម-ហាតិយា បរិសាយ** *សេចក្តីថា ដោយកិក្ខុបរិស័ទ និងឧបាសកបរិស័ទដ៏ច្រើន ។*

បានឮថា ថ្ងៃមួយ ព្រះដ៏មានព្រះភាគ ហែហមទៅដោយកិក្ខុសង្ឆដ៏ច្រើន ស្តេចចូលទៅបិណ្ឌបាតនូវក្រុងរាជគ្រឹះ ទ្រង់សោយបិណ្ឌបាតដែលពួកកិក្ខុបានមកដោយល្អ ស្តេចត្រឡប់ពីបិណ្ឌបាតក្នុងកាលជាខាងក្រោយភត្ត ព្រះអង្គហែហមដោយកិក្ខុ ២-៣ អង្គ ព្រះអង្គចេញមករង់ចាំការមករបស់ឧបាសកអ្នកថ្វាយទាន និងកិក្ខុដែលនៅសល់បានប្រថាប់ឈរ ក្នុងអាវាសដែលជារីក-

ពាយមួយកន្ទ្ធ ខាងក្នុងព្រះនគរនុ៎ះឯង ។ ក្នុងទីណានុ៎ះឯង ភិក្ខុទាំងឡាយ មកពីទីនោះ។ នាំគ្នាហៅហាមព្រះដ៏មានព្រះភាគ ។ ចំណែកឧបាសកទាំងឡាយ ចូលទៅគាល់ព្រះដ៏មានព្រះភាគដោយគំនិតថា នឹងស្តាប់ជាអនុមោទនា ថ្វាយ បង្គំហើយត្រឡប់មក ។ លំដាប់នោះ ក៏មានការប្រជុំធំមួយ ។ ព្រះដ៏មាន-ព្រះភាគទ្រង់សម្តែងអាការគង់ ។ ក្នុងខណៈនោះឯង ភិក្ខុទាំងឡាយក្រាលអាសនៈដែលសមគួរចំពោះព្រះពុទ្ធ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើប្រទេសនោះទាំងអស់ឱ្យស្វាងស្ងៃ ដោយព្រះរូបពោមដែលរកឧបមាមិនបានដែលរុងរោចន៍ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ដែលប្រដាប់ដោយអនុព្យញ្ជនៈ ៨០ ប្រការ ដែលរុងរឿង ហៅហាមទៅដោយព្រះរស្មីខាងស្តាំ ដែលបញ្ចាំងព្រះពុទ្ធរស្មី មានពណ៌ ៦ ប្រការ គឺខៀវ លឿង ក្រហម ស ហង្សបាទ និងផ្ទេក ហៅហាមទៅដោយពួកភិក្ខុ ដូចព្រះចន្ទពេញវង្ស ហៅហាមទៅដោយពួកផ្កាយ ប្រថាប់គង់លើបវរពុទ្ធាសនៈ ដែលជនទាំងឡាយចាត់ចែងថ្វាយព្រះដ៏មានព្រះ-ភាគទ្រង់បន្ទឹសីហនាទ ដូចរាជសីហ៍លើផ្ទៃមនោសិលា ទ្រង់សម្តែងធម៌ដោយព្រះសូរសៀងដូចសំឡេងព្រហ្មដ៏ពីរោះដូចសំឡេងស្រែករបស់សត្វកវរិក ។

ចំណែកភិក្ខុទាំងឡាយ ជាអ្នកប្រាជ្ញាតិច សន្តោស ត្រេកអរក្នុងទីស្ងាត់ ជាអ្នកមិនច្រឡូកច្រឡំ ជាអ្នកប្រារព្ធសេចក្តីព្យាយាម មានចិត្តជាសមាធិ ជាអ្នកដាស់តឿនខ្លួនឯង ជាអ្នកតិះដៀលបាប ជាអ្នកពោលពាក្យទូន្មាន ជាអ្នកអត់-ធន់ចំពោះពាក្យសំដី ដល់ព្រមដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិ-

ញាណទស្សនៈ ដណ្តប់បង្ស៊ុកូលចីវរពណ៌ផ្ទៃមេឃ ហៃហមព្រះដ៏មានព្រះភាគ ដូចដំរីត្រកូលគន្ធៈដែលប្រដាប់ដោយគ្រឿងក្រោះទុកដោយល្អ ដាក់សោតៈចុះស្តាប់ព្រះធម្មទេសនា ។ ចំណែកឧបាសកឧបាសិកាទាំងឡាយ ស្ងៀកដណ្តប់សំពត់រៀបរយ មានឧត្តរាសង្គៈស្អាត ក្នុងវេលាព្រឹកញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ បូជាព្រះដ៏មានព្រះភាគដោយសក្ការៈមានរបស់ក្រអូប និងកម្រងផ្កាជាដើម ថ្វាយបង្គំហើយសម្តែងអាការនមស្ការដល់ភិក្ខុសង្ឆ ហៃហមព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឆ សង្ត្រួមដៃនិងជើង ដាក់សោតៈចុះស្តាប់ធម៌ដោយគោរព ។ ព្រោះហេតុនោះ លោកទើបពោលថា ក៏ដោយសម័យនោះឯង ព្រះដ៏មានព្រះភាគ មានបរិស័ទច្រើនគាល់ជុំវិញ កំពុងគង់សម្តែងធម៌ ដូច្នេះជាដើម ។

ក៏សុប្បពុទ្ធៈ ត្រូវសេចក្តីទុព្ភលៈ គឺសេចក្តីស្រេកឃ្ងានគ្របសង្កត់ ទើបត្រាច់ស្វែងរកអាហារ ឃើញមហាជននោះប្រជុំគ្នាពីចម្ងាយ កើតការសប្បាយចិត្តឡើងថា ពួកមហាជននេះ ប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ប្រហែលជាក្នុងទីនោះ គេគង់នឹងចែកអាហារជាពិតប្រាកដ ដូចម្តេចហ្ន៎ យើងទៅក្នុងទីនោះអាចនឹងបានអ្វីៗ ត្រឹមតែមិនថាខាទនីយៈ ឬភោជនីយាហារ ដូច្នេះ ហើយទើបទៅក្នុងទីនោះបានឃើញព្រះដ៏មានព្រះភាគ ព្រះអង្គ គួរជ្រះថ្លា គួរសរសើរ គួរជាទីរីក-រាយនៃចិត្ត ព្រះអង្គដល់សេចក្តីស្ងប់ដោយការទូន្មានខ្ជួនឧត្រិដ្ឋ ទ្រង់ទូន្មានហើយឃុំគ្រង ហើយប្រកបដោយឥន្ទ្រិយដែលសង្ត្រួមហើយ ហៃហមទៅដោយបរិស័ទនោះ ព្រះអង្គគង់សម្តែងធម៌ គ្រាសុប្បពុទ្ធកុដ្ឋិឃើញហើយ ត្រូវឧនិ-ស្សយសម្បត្តិដ៏ចាស់ក្លា បានសន្សំទុកហើយក្នុងជាតិមុន ដាស់តឿនហើយ ទើប

គិតថា ដូចម្តេចហ្ន៎ សូម្បីយើងក៏គួរស្តាប់ធម៌ ដូច្នេះហើយទើបបានអង្គុយខាងចុងបរិស័ទ ។ ពាក្យនេះដែលលោកសំដៅដល់ហេតុនោះ ទើបពោលទុកថា សុប្បពុទ្ធកុដ្ឋិបានឃើញអំពីចម្ងាយ ។ល។ គាត់ក៏អង្គុយក្នុងទីសមគួរក្នុងទីនោះគិតថា អាត្មាអញនឹងស្តាប់ធម៌ដែរ ដូច្នេះជាដើម ។

បទថា **សព្វាវន្តំ** ប្រែថា មានបុគ្គលគ្រប់ពួក គឺមានបុគ្គលគ្រប់ពួក មានអ្នកថោកទាបជាដើម ។ ក្នុងសេចក្តីនោះមានអធិប្បាយថា មិនសេសសល់សូម្បីអ្នកណាម្នាក់ ។ អាចារ្យពួកខ្លះពោលថា **សព្វវន្តំ** ដូច្នេះក៏មាន ។ បទថា **ចេតសា** សេចក្តីថា ដោយហ្ឫទ័យដែលសម្បយុត្តដោយពុទ្ធចក្ខុ ។ មែនពិតលោកសម្តែងព្រះញាណដោយលើកចិត្តឡើងជាប្រធាន ព្រោះដូច្នោះ ទើបមានសេចក្តីអធិប្បាយថា ដោយអាសយានុសយញ្ញាណ និងឥន្ទ្រិយបរោបរិយត-ញ្ញាណ ។ បទថា **ចេតោ បរិច្ច មនសាកាសិ** សេចក្តីថា ព្រះអង្គកំណត់ចិត្តរបស់បរិស័ទនោះជាចំណែកមួយ ហើយទ្រង់ធ្វើទុកក្នុងព្រះហ្ឫទ័យ គឺទ្រង់ពិចារណាមើលជនទាំងនោះ ។ បទថា **ភព្វោ ឧម្មុំ វិញ្ញាតុំ** សេចក្តីថា ជាអ្នកអាច គឺដល់ព្រមដោយឧបនិស្សយ ដើម្បីសម្រេចធម៌ គឺមគ្គនិងផល ។ បទថា **ឯតទហោសិ** សេចក្តីថា ព្រះដ៏មានព្រះភាគមានព្រះតម្រិះដូច្នេះថា សុប្បពុទ្ធ-កុដ្ឋិនេះ មានកំហុសក្នុងព្រះបច្ចេកពុទ្ធ ព្រះនាមថា **តគរសិខី** ទើបមានសភាពយ៉ាងនេះមែនហើយ ក៏ប៉ុន្តែថា សុប្បពុទ្ធកុដ្ឋិនេះក៏នៅមានឧបនិស្សយនៃមគ្គនិងផល រុងរឿងនៅក្នុងខាងចិត្តនុ៎ះឯង ដូចដុំមាសត្រូវធូលីលប់ទុក ព្រោះ

ដូច្នោះ គេទើបគួរនឹងដឹងច្បាស់ ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ត្រាស់ថា សុប្ផពុទ្ធកុដ្ឋិនេះឯង គួរដើម្បីដឹងធម៌បានក្នុងទីនេះ ដូច្នេះជាដើម ។

បទថា **អនុបុព្វីកថំ** បានដល់ កថាតាមលំដាប់យ៉ាងនេះថា សីល បន្ទាប់ពីទាន ស្ថានសួគ៌បន្ទាប់ពីសីល មគ្គបន្ទាប់ពីស្ថានសួគ៌ ។ មែនពិត ព្រះដ៏-មានព្រះភាគ ទ្រង់សម្តែងសេចក្តីត្រេកអរព្រមដោយហេតុ តអំពីនោះ ទ្រង់ប្រកាសទោសដោយន័យផ្សេងៗ ដើម្បីឱ្យពួកសត្វងាកចិត្តពីនោះ ហើយទើបសម្តែងវិវដ្ដ: ដោយការប្រកាសគុណនៃនេក្ខម្ម:ជាប្រធាន របស់ពួកសត្វអ្នក មានហ្ជ្ឈ័យ តក់ស្ទុតព្រោះការស្តាប់ទោសនៃវដ្ដ: ។

បទថា **ទានកថំ** បានដល់ កថាដែលជាប់ទាក់ទងដោយគុណរបស់ទានមានជាអាទិ៍យ៉ាងនេះថា ដែលឈ្មោះថា ទាន នេះជាហេតុនៃសេចក្តីសុខ ជាមូលនៃសម្បត្តិ ជាទីតាំងនៃភោគ: ជាទីការពារ ជាទីពឹង ជាគតិ ជាទីទៅក្នុងខាងមុខ របស់សត្វអ្នកធ្វើដំណើរទៅតាមផ្លូវដែលមិនស្មើ ជាទីពឹង ជាទីការពារ ជាគតិ ជាទីតោង ជាទីតាំងនៅ ជាទីពួនសម្ងំ ជាគតិ ជាទីទៅខាងមុខ ស្មើដោយទាននេះ រមែងមិនមាន ក្នុងលោកនេះនិងលោកខាងមុខ ។ មែនពិត ទាននេះ មានអត្ថថា ជាទីពឹង ដូចជាអាសន:របស់សីហ:ដែលសម្រេចដោយកែវ មានអត្ថថា ជាទីពំនាក់ ដូចជាមហាប្រថពី មានអត្ថថា ជាគ្រឿងតោង ដូចខ្សែសម្រាប់តោង មានអត្ថថា ជាគ្រឿងធ្វង់ចាកទុក្ខ ដូចវ៉ានា មានអត្ថថា ជាទីស្រឡះចិត្ត ដូចអ្នកក្ងាហានក្នុងសង្គ្រាម មានអត្ថថា ជាទីការពារកំ័យជុំវិញ ដូចជានគរដែលគេរក្សាដោយល្អ មានអត្ថថា មន្ទិល គឺសេចក្តីកំណាញ់ជាដើម

ដូចផ្កាឈូក មានអត្ថថា ដុតមន្ទិល គឺសេចក្តីកំណាញ់ជាដើមទាំងនោះ ដូចជាក្ងើង មានអត្ថថា ត្រេកអរបានលំបាក ដូចជាអាសិរពិស មានអត្ថថា មិនតក់ស្ទុត ខ្ជាចដូចជារាជសីហ៍ មានអត្ថថា ទ្រទ្រង់កម្ទាំង ដូចដំរី មានអត្ថថា ដែលអ្នកលោកសន្ទ្ធតិគ្នាថាជាមង្គលក្រៃលែង ដូចជាគោឧសុភ: មានអត្ថថា បញ្ជូនទៅឱ្យដល់ភូមិដែលរួចផុតភ័យ ដូចជាស្ពេចសេះឈ្មោះវលាហក: ។ មែនពិតទានរមែងឱ្យសិរីរាជសម្ប្ដត្តិក្នុងលោក ឱ្យចក្រពត្តិសម្ប្ដត្តិ សក្ដសម្ប្ដត្តិ មារសម្ប្ដត្តិ ព្រហ្មសម្ប្ដត្តិ សាវកបារមីញាណ បច្ចេកពោធិញាណ និងឱ្យសម្ចាសម្ពោធិ-ញ្ញាណ ។

ក៏ព្រោះហេតុដែលបុគ្គលអ្នកឱ្យទានអាច ដើម្បីនឹងសមាទានសីលព្រោះដូច្នោះ ព្រះអង្ដ ទើបទ្រង់សម្ដែងសីលកថាទុកក្នុងលំដាប់នៃទានកថា ។ បទថា **សីលកថំ** បានដល់ កថាដែលជាប់ទាក់ទងដោយគុណនៃសីលមានជាអាទិ៍យ៉ាងនេះថា ដែលឈ្មោះថា សីល នេះជាទីពឹង ជាទីពំនាក់ ជាទីតោងជាទីការពារ ជាទីពួនសម្ងំ ជាគតិ ជាទីទៅក្នុងខាងមុខរបស់សត្វទាំងឡាយ ។ មែនពិត ទីពឹង ទីពំនាក់ ទីតោង ទីការពារ ជាទីពួនសម្ងំ ជាគតិ ទីទៅក្នុងខាងមុខរបស់សម្ប្ដត្តិក្នុងលោកនេះ និងលោកខាងមុខ ស្មើដោយសីល រមែងមិនមាន អលង្ការស្មើដោយអលង្ការ គឺសីលមិនមាន ផ្ការ ស្មើដោយផ្ការ គឺសីលមិនមាន ក្ងិនស្មើដោយក្ងិន គឺសីលមិនមាន ។ មែនពិត លោកព្រមទាំងទេវលោកក្រឡេកមើលអ្នកប្រដាប់ដោយគ្រឿងប្រដាប់ គឺសីល អ្នកទ្រទ្រង់ផ្ការណ៏ គឺសីល

លាបដោយរបស់ក្រអូប គឺសីល រមែងមិនឆ្អែតឆ្អន់ ។ ព្រះដ៏មានព្រះភាគ ដើម្បីនឹងទ្រង់សម្តែងថា បុគ្គលបានស្ថានសួគ៌នេះ ក៏ព្រោះអាស្រ័យសីលនេះ ដូច្នេះ ហើយ ទើបទ្រង់សម្តែងសគ្គកថាទុកក្នុងលំដាប់នៃសីល ។

បទថា **សត្ត** កំ បានដល់ កថាដែលជាប់ទាក់ទងដោយគុណនៃស្ថានសួគ៌ មានជាអាទិ៍យ៉ាងនេះថា ដែលឈ្មោះថា ស្ថានសួគ៌ជាវត្ថុគួរប្រាថ្នា ជាទីស្រឡាញ់ គួរពេញចិត្ត រមែងបានសេចក្តីរីករាយក្នុងស្ថានសួគ៌នោះជានិច្ច គឺរមែងបានសម្បត្តិជានិច្ច ។ ទេវតាជាន់ចាតុម្មហារាជ រមែងបានសេចក្តីសុខជាទិព្ធ និងសម្បត្តិជាទិព្ធរហូត ៩ លានឆ្នាំ ទេវតាជាន់តាវត្តឹង្ស រមែងបានសេចក្តីសុខជាទិព្ធ និងសម្បត្តិជាទិព្ធរហូត ៣ កោដិ ៦ លានឆ្នាំ ។ កាលព្រះសម្ពុទ្ធទ្រង់មិនបញ្ចប់ព្រះឱស្ថដោយត្រឹមតែការសម្តែងសគ្គកថាប៉ុណ្ណោះឡើយ ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ តថាគតគប្បីសម្តែងសគ្គ-កថា ដោយអនេកបរិយាយ ។

ព្រះដ៏មានព្រះភាគ ដើម្បីនឹងទ្រង់លួងលោមដោយសគ្គកថា ព្រមដោយហេតុដូចពណ៌នាមកយ៉ាងនេះ ទើបសម្តែងថា សូម្បីស្ថានសួគ៌នេះ ក៏មិនទៀងមិនបិតថេរ មិនគួរធ្វើសេចក្តីត្រេកអរដោយអំណាចសេចក្តីពេញចិត្តក្នុងស្ថានសួគ៌នោះ ប្រៀបដូចបុគ្គលប្រជាប់ដំរី ហើយកាត់ក្ងុករបស់ដំរីនោះទៀត ទើបទ្រង់សម្តែងទោស សេចក្តីថោកទាប សេចក្តីសៅហ្មងរបស់កាមទាំងឡាយដោយន័យមានជាអាទិ៍ថា កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន មានសេចក្តី

ចង្អៀតចង្អ‌ល់ច្រើន ទោសរបស់កាមទាំងឡាយនោះមានច្រើនក្រៃពេក[1] ។

បណ្តាបទទាំងនោះ បទថា **អាទីនវំ** ប្រែថា ទោស ។ បទថា **ឱការំ** បានដល់ មានភាពអាក្រក់សភាវៈ អធិប្បាយថា ពួកអ្នកមិនប្រសើរ គប្បីសេព ពួកអ្នកប្រសើរ មិនគប្បីសេព ទើបឈ្មោះថា មានភាពអាក្រក់ជាសភាវៈ ។ បទថា **សង្ខ្លិលេសំ** សេចក្តីថា ព្រោះកាមទាំងនោះ សត្វទាំងឡាយ ទើបមានសេចក្តីសៅហ្មងក្នុងសង្សារ ។ ព្រោះហេតុនោះនុ‌ះឯង លោកទើបពោលថា នៃលោកដ‌៏ចម្រើន សត្វទាំងឡាយ នឹងសៅហ្មងហ‌ុ‌ ។ កាលព្រះដ‌៏មានព្រះភាគ ទ្រង់ឱ្យនឿ‌យណាយ ដោយទោសនៃកាមយ‌ាងនេ‌ះហ‌ើយ ទ‌ើបទ្រ‌ង់ប្រ‌ក‌ាស អានិ‌ស‌ង្ស‌ក្នុ‌ងនេ‌ក្ខ‌ម្ម: គ‌ឺ‌ស‌ម្ដ‌ែ‌ងព‌ណ‌៌‌នា‌គ‌ុ‌ណ‌រ‌ប‌ស‌ប‌ព‌ជ្ជ‌ា និ‌ងគ‌ុ‌ណ‌ក្នុ‌ងឈ‌ាន ជ‌ាដ‌ើ‌ម ។ ប‌ទ‌ថា **ក‌ល‌្ម‌ចិ‌ត្ត‌ំ** ក្នុ‌ងប‌ទ‌ថា **ក‌ល‌្ម‌ចិ‌ត្ត‌ំ** ជ‌ាដ‌ើ‌ម ប‌ាន‌ដ‌ល‌់ ចិ‌ត្ត‌ដ‌ែ‌ល‌គ‌ួ‌រ‌ដ‌ល‌់ក‌ារ‌ងារ គ‌ឺ‌ចិ‌ត្ត‌ជ‌ាទ‌ីតាំ‌ង‌នៃ‌ក‌ារ‌ងារ អ‌ធិ‌ប្ប‌ាយ‌ថ‌ា ជ‌ាចិ‌ត្ត‌ដ‌ែ‌ល‌ស‌ម‌គ‌ួ‌រ‌ដ‌ល‌់ ក‌ារ‌ងារ ដ‌ោ‌យ‌ចូ‌ល‌ដ‌ល‌់ភ‌ាវ:ជ‌ាទ‌ីទ‌ទ‌ួ‌ល‌ទ‌េ‌ស‌នា ដ‌ែ‌ល‌ទ្រ‌ង‌់ប្រ‌ក‌ាស‌ទ‌ុ‌ក‌ខ‌ាង‌ចុ‌ង និ‌ងទ‌េ‌ស‌នា‌ខ‌ាង‌ដ‌ើ‌ម‌ព្រោ‌ះ‌ប្រ‌ាស‌ចា‌ក‌ទ‌ោ‌ស‌នៃ‌ចិ‌ត្ត ម‌ាន‌ភ‌ាព‌ជ‌ាអ‌្ន‌ក‌មិ‌ន‌ស‌ទ្ធ‌ា ជ‌ាដ‌ើ‌ម ។ ភ‌្ជ‌ាប‌់‌ស‌េ‌ច‌ក‌ីថ‌ា ក‌្នុ‌ង‌គ្រ‌ា‌ដ‌ែ‌ល‌ព្រ‌ះ‌ដ‌ម‌ាន‌ព្រ‌ះ‌ភ‌ាគ‌ទ្រ‌ង‌់ជ្រ‌ាប‌ថ‌ា ស‌ុ‌ប្ប‌-ពុ‌ទ្ធ‌ក‌ុ‌ដ‌ិ‌នោ‌ះ ម‌ាន‌ចិ‌ត្ត‌ទ‌ន‌់ក‌ូ‌ន‌់ ព្រោ‌ះ‌ប្រ‌ាស‌ចា‌ក‌ក‌ិ‌ល‌េ‌ស ម‌ាន‌ទ‌ិ‌ដ‌្ឋ‌ិ និ‌ងម‌ាន‌ន‌ះ‌ជ‌ាដ‌ើ‌ម ម‌ាន‌ចិ‌ត្ត‌ប្រ‌ាស‌ចា‌ក‌ន‌ីវ‌ណ: ព្រោ‌ះ‌ប្រ‌ាស‌ចា‌ក‌ន‌ីវ‌ណ: ម‌ាន‌ក‌ាម‌ឆ‌ន្ទ‌ន‌ីវ‌ណ:ជ‌ាដ‌ើ‌ម ម‌ាន‌ចិ‌ត្ត‌រ‌ីក‌រ‌ាយ ព្រោ‌ះ‌ប្រ‌ក‌ប‌ដ‌ោ‌យ‌ប‌ីត‌ិ និ‌ងប‌ាមោ‌ជ្ជ:យ‌ាង‌ក្រ‌ៃ‌ល‌ែ‌ង ក្នុ‌ង‌ស‌ម្ម‌-

---

[1]-ស‌ុ‌ត្ត‌ន្ត‌ប‌ិ‌ដ‌ក ម‌ជ្ឈ‌ិ‌ម‌និ‌ក‌ាយ ម‌ូ‌ល‌ប‌ណ្ណ‌ាស‌ក: ល‌េ‌ខ ២០ ទ‌ំ‌ព‌រ ៣៣‌៨ ។

បដិបត្តិ និងមានចិត្តថ្វាផ្ទរផង់ ព្រោះដល់ព្រមដោយសទ្ធាក្នុងសម្មាបដិបត្តិនោះ ។

ម្យ៉ាងទៀត ។ បទថា **កល្យចិត្តំ** *បានដល់ ចិត្តមិនមានរោគ ព្រោះប្រាសចាកកាមឆន្ទនីវរណៈ ។ បទថា* **មុឌុចិត្តំ** *បានដល់ ចិត្តមិនរឹងរុះ ដោយអំណាចមេត្តាព្រោះប្រាសចាកព្យាបាទ ។ បទថា* **វិនីវរណចិត្តំ** *បានដល់ ចិត្តដែលមិនត្រូវបិទ ព្រោះមិនរវើរវាយ ដោយប្រាសចាកឧទ្ធច្ចៈ និងកុក្កុច្ចនីវរណៈ ។ បទថា* **ឧឡារចិត្តំ** *បានដល់ ចិត្តមិនរួញរា ដោយអំណាចការឧបត្ថម្ភ ដោយប្រាសចាកថីនមិទ្ធនីវរណៈ ។ បទថា* **បសន្នចិត្តំ** *បានដល់ ចិត្តដែលបង្ហានទៅក្នុងសម្មាបដិបត្តិដោយប្រាសចាកវិចិកិច្ឆានីវរណៈ ។*

ស័ព្ទ **អថ** *ប្រែថា ខាងក្រោយ ។ បទថា* **សាមុក្ក្ក\ំសិកា** *បានដល់ ទេសនាដែលព្រះអង្គទ្រង់សម្តែង គឺទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង បានដល់ ទ្រង់ឃើញដោយព្រះអង្គឯង ដោយព្រះសយម្ភូញាណ អធិប្បាយថា ជាធម្មទេសនាដែលមិនទូទៅដល់ជនដទៃ ។ សួរថា ក៏ទេសនានោះ ឈ្មោះអ្វី? ឆ្លើយថា ឈ្មោះ អរិយសច្ចទេសនា ។ ព្រោះហេតុនោះនុ\ះឯង ព្រះអង្គទើបត្រាស់ថា ទុក្ខអរិយសច្ចៈ សមុយអរិយសច្ចៈ និរោធអរិយសច្ចៈ មគ្គអរិយសច្ចៈ ។ ក៏ប្រការនេះ ជាការសម្តែងសច្ចៈដោយសរុប ។ ព្រោះដូច្នោះ ក្នុងទីនេះ ទើបគួរសម្តែងអរិយសច្ចៈ ។ អរិយសច្ចៈទាំងនោះ កាលពោលអំពីអាការទាំងពួង គឺដោយពិស្តារលោកពោលទុកហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលទុកហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនុ\ះចុះ ។*

ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងការលះកិលេស និងការញ\ាំងអរិយមគ្ត

ឱ្យកើតឡើងដល់សុប្បពុទ្ធកុដ្ឋិ ដោយអំណាចឧបមា ដោយពាក្យមានជាអាទិ៍ថា **សេយ្យថាបិ** ដូច្នេះ ។ បទថា **អបគតតាឍ្ឍកំ** ប្រែថា ប្រាសចាកធម៌ចំណែកខ្មៅ ។ បទថា **សម្ផុដេ** ប្រែថា ដោយល្អនុ៎ះឯង ។ បទថា **រជនំ** បានដល់ ទឹកជ្រលក់មានពណ៌ខៀវ លឿង ក្រហម និងហង្សបាទជាដើម ។ បទថា **បដិគ្គណ្ហេយ្យ** ប្រែថា គប្បីទទួល គឺគប្បីបាននូវសំពត់ដែលមានសាច់ម៉ដ្ត ។ បទថា **តស្មិំយេវ អាសនេ** បានដល់ ក្នុងទីអង្គុយនោះឯង ។ ដោយពាក្យនេះ ជាការទ្រង់សម្តែងដល់ការ:ដែលសុប្បពុទ្ធកុដ្ឋិនោះ ជាអ្នកឃើញច្បាស់ដោយរហ័ស មានបញ្ញាវាងវៃ និងជាសុខាបដិបទាខិប្បាភិញ្ញាបុគ្គល ។ បទថា **វិរជំ វីតមលំ** សេចក្តីថា ឈ្មោះថា ប្រាសចាកធូលី ព្រោះមិនមានធូលី គឺរាគ:ជាដើមដែលជាហេតុនាំសត្វទៅកាន់អបាយ ឈ្មោះថា ប្រាសចាកមន្ទិល ព្រោះប្រាស-ចាកមន្ទិល គឺទិដ្ឋិ និងវិចិកិច្ឆាមិនសេសសល់ ។ ម្យ៉ាងទៀត ឈ្មោះថា ប្រាសចាកធូលីព្រោះមិនមានធូលី គឺកិលេស ដែលសោតាបត្តិមគ្គគប្បីសម្ងាប់ ឈ្មោះថាប្រាសចាកមន្ទិល ព្រោះប្រាសចាកភាពជាអ្នកទ្រុស្តសីល ៥ ។ បទថា **ធម្មចក្ខុ** លោកសំដៅដល់សោតាបត្តិផល ។ ដើម្បីនឹងទ្រង់សម្តែងអាការកើតឡើងនៃធម្មចក្ខុនោះ ទើបត្រាស់ថា ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងនោះ តែងរលត់ទៅវិញជាធម្មតា ដូច្នេះ ។ ក៏ធម្មចក្ខុនោះ សូម្បីធ្វើនិរោធឱ្យជាអារម្មណ៍ ហើយក៏ចាក់ធ្លុះនូវសង្ខ្តធម៌ ដោយអំណាចកិច្ចនោះឯង ។ ក្នុងសេចក្តីនោះ មានការប្រៀបឧបមាដូចតទៅនេះ ចិត្តដូចជាសំពត់ ។ ការ:ដែល

ចិត្តសៅហ្មងដោយមន្ទិលមានរាគៈជាដើម ដូចជាការៈដែលសំពត់ប្រឡាក់ដោយមន្ទិលដូច្នោះ ។ អនុបុព្វីកថា ដូចជាផែនក្ការសម្រាប់លាង ។ សទ្ធាដូចជាទឹក ។ ការប្រើទឹក គឺសទ្ធាលាងឱ្យសើម ហើយប្រើសតិ សមាធិ និងបញ្ញា ធ្វើទោសៈឱ្យថយចុះ ហើយប្រារព្ធសេចក្តីព្យាយាម ជម្រះចិត្តឱ្យស្អាត ដោយវិធីមានសុតៈជាដើម[1] ប្រៀបដូចបុគ្គលបោកសំពត់ដោយជាន់ឈ្លីជាមួយទឹកក្បាងគោម័យ ។ ការគ្របសង្កត់កិលេសបានដោយការប្រារព្ធសេចក្តីព្យាយាម ដូចជាការជម្រះពណ៌ខ្មៅដែលប្រឡាក់សំពត់ដោយការជ្រលក់បោកនោះ ។ អរិយមគ្គដូចជាទឹកជ្រលក់ ។ ការជម្រះចិត្តដែលគ្របសង្កត់កិលេសបានហើយឱ្យផ្ទរផង់ដោយមគ្គដូចជាសំពត់ដែលស្អាត ព្រោះ យការជ្រលក់នោះដូច្នោះ ។

ក៏សុប្ផពុទ្ធកុដ្ឋិ អង្គុយខាងចុងបរិស័ទ ស្តាប់ព្រះធម៌ទេសនាសម្រេចសោតាបត្តិផលយ៉ាងនេះហើយ មានសេចក្តីប្រាថ្នានឹងក្រាបទូលដល់គុណ ដែលខ្លួនបានទទួលចំពោះព្រះសាស្តា កាលមិនអាចនឹងទៅកាន់កណ្តាលជំនុំនៃបរិស័ទបាន ក្នុងវេលាដែលមហាជនថ្វាយបង្គំព្រះសាស្តា ហើយតាមជូនដំណើរព្រះដ៏-មានព្រះភាគ ហើយមហាជនក៏ត្រឡប់មកវិញ កាលព្រះដ៏មានព្រះភាគស្តេចទៅកាន់ព្រះវិហារ សូម្បីខ្លួនឯងក៏បានទៅកាន់ព្រះវិហារផង ។ ខណៈនោះ ស្តេច-សក្កទេវរាជទ្រង់ជ្រាបថា សុប្ផពុទ្ធកុដ្ឋិនេះ មានសេចក្តីប្រាថ្នានឹងប្រកាសគុណដែលខ្លួនបានក្នុងព្រះសាសនារបស់ព្រះសាស្តាឱ្យប្រាកដ គិតនឹងសាកល្បង

១-ក្នុងបរមត្ថទីបនី អដ្ឋកថា ឧទាន ត្រង់សុប្ផពុទ្ធកុដ្ឋិសុត្តវណ្ណនា ចាប់ធដ្ឋសង្ហ៊ាយមានសេចក្តីថា **ដោយវិធីមានសទ្ធាជាដើម** ។

ព្រះអង្គទើបស្តេចទៅប្រថាប់នៅក្នុងអាកាស បានត្រាស់ពាក្យនេះថា នែសុប្បពុទ្ធ-
កុដ្ឋិ លោកជាមនុស្សកំសត់ ជាមនុស្សកំព្រា ជាមនុស្សថោកទាប យើងនឹងឱ្យ
ទ្រព្យដែលរកប្រមាណមិនបានដល់អ្នក ប្រសិនបើអ្នកចូរនិយាយថា ព្រះពុទ្ធ
មិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឆមិនមែនព្រះសង្ឆ ប្រយោជន៍
ដោយព្រះពុទ្ធ មិនគួរដល់អាត្មាអញឡើយ ប្រយោជន៍ដោយព្រះធម៌ មិនគួរ
ដល់អាត្មាអញឡើយ ប្រយោជន៍ដោយព្រះសង្ឆ មិនគួរដល់អាត្មាអញឡើយ ។
លំដាប់នោះ សុប្បពុទ្ធកុដ្ឋិទើបពោលនឹងស្តេចសក្ក:នោះថា អ្នកឯងជាណា? ស្តេច-
សក្កទេវរាជធ្វើយថា យើងជាស្តេចសក្កទេវរាជ ។ សុប្បពុទ្ធកុដ្ឋិពោលថា ម្នាល
អន្ធពាល អ្នកមិនមានអៀនខ្មាស លោកពោលពាក្យដែលមិនគួរនឹងពោលយ៉ាង
នេះ មិនសមគួរនិយាយនឹងយើងឡើយ ម្យ៉ាងទៀត ព្រោះហេតុអ្វី លោកទើប
និយាយ នឹងយើងថា ជាមនុស្សកំសត់ មនុស្សកំព្រា មនុស្សថោកទាប យើងជា
ឱរសរបស់ព្រះលោកនាថ អ្នកឯងមិនមែន ឬយើងមិនមែនជាមនុស្សកំសត់
មិនមែនជាមនុស្សកំព្រា មិនមែនជាមនុស្សថោកទាប តាមពិត យើងនឹងទទួល
សេចក្តីសុខ ដោយសេចក្តីសុខយ៉ាងក្រៃលែង មានទ្រព្យច្រើនដូច្នេះហើយ ទើប
ពោលថា

សទ្ធាធនំ សីលធនំ ហិរី ឱត្តប្ប្យិយំ ធនំ
សុតធនញ្ច ចាគោ ច បញ្ញាវេ សត្តមំ ធនំ
យស្ស ឯតា ធនា អត្ថិ ឥត្ថិយា ឧតបុរិសស្ស វា

អទលិទ្ទោតិ តំ អាហុ អមោឃំ តស្ស ជីវិតំ ។

ទ្រព្យគឺសទ្ធា ទ្រព្យគឺសីល ទ្រព្យគឺហិរិ ទ្រព្យគឺឱត្តប្បៈ
ទ្រព្យគឺសុតៈ ទ្រព្យគឺចាគៈ ទ្រព្យគឺបញ្ញា ជាគម្រប់ ៧
បុគ្គលណា ទោះស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ
អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាអ្នកមិនទ័លក្រ ការរស់
នៅរបស់បុគ្គលនោះ មិនសោះសូន្យឡើយ[១] ។

ព្រោះដូច្នោះ យើងនោះ ទើបឈ្មោះថា មានអរិយទ្រព្យ ៧ ប្រការនេះ ព្រោះបុគ្គលដែលមានអរិយទ្រព្យទាំងនេះ ព្រះពុទ្ធ ឬព្រះបច្ចេកពុទ្ធ មិនត្រាស់ហៅថា ជាមនុស្សកំសត់ ។ ស្តេចសក្កៈទ្រង់សណ្តាប់ពាក្យរបស់សុប្បពុទ្ធកុដ្ឋិនោះ ហើយទើបទុកសុប្បពុទ្ធកុដ្ឋិនៅចន្លោះផ្លូវនោះ ទៅគាល់ព្រះសាស្តា ហើយក្រាបទូលពាក្យសួរ និងពាក្យឆ្លើយទាំងអស់នោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ចំពោះស្តេចសក្កៈថា ម្នាលសក្កៈ ទេវតាដូចព្រះអង្គ សូម្បីទាំងរយទាំងពាន់ ក៏មិនអាចនឹងឱ្យសុប្បពុទ្ធកុដ្ឋិពោលថា ព្រះពុទ្ធ មិនមែនព្រះពុទ្ធ ព្រះធម៌ មិនមែនព្រះធម៌ ព្រះសង្ឃ មិនមែនព្រះសង្ឃ ។ សូម្បីសុប្បពុទ្ធកុដ្ឋិ ក៏ទៅគាល់ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈហើយ ទើបក្រាបទូលដល់គុណដែលខ្លួនបានទទួល ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ សុប្បពុទ្ធោ កុដ្ឋី ទិដ្ឋធម្មោ បត្តធម្មោ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ទិដ្ឋធម្មោ** *សេចក្តីថា ឈ្មោះថា អ្នកឃើញ*

១-សុត្តន្តបិដក អង្គុត្តរនិកាយ សត្តមនិបាត លេខ ៤៧ ទំព័រ ៩ ដល់ ១០ ។

ធម៌ ព្រោះឃើញអរិយសច្ចធម៌ ។ សូម្បីក្នុងបទដែលនៅសល់ក៏នយនេះដូចគ្នា ។ បណ្តាបទទាំងនោះ **ធម្ម**-សព្ទ ក្នុងបទថា **ទិដ្ឋធម្មោ** នេះ បញ្ជាក់ដល់ពាក្យសាមញ្ញ ។ ឈ្មោះថា **ទស្សនៃ** សូម្បីដទៃទៅពីញាណទស្សនៃក៏នៅមាន ព្រោះហេតុនោះ ទស្សនៃនោះ លោកហៅថា **បត្តធម្មោ** ដើម្បីសម្តែងនិវត្តនៃ (និរោធសច្ចៃ) ។ ក៏ការសម្រេចសូម្បីដទៃពីញាណសម្បត្តិក៏នៅមាន ព្រោះហេតុនោះ លោកទើបហៅថា **វិទិតធម្មោ** ដើម្បីឱ្យបែកទៅពីញាណទស្សនៃនោះ ។ ក៏ភាពជាអ្នកដឹងច្បាស់ធម៌នេះ នោះចាត់ជាចំណែកមួយក្នុងធម៌ទាំងឡាយ ព្រោះដូច្នោះ ដើម្បីនឹងសម្តែងភាពជាអ្នកដឹងច្បាស់ធម៌នោះ ដោយគ្រប់ចំណែក លោកទើបពោលថា **បរិយោគាឌ្ឍធម្មោ** ។ ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់សម្តែងចំពោះការត្រាស់ដឹងសច្ចៃ តាមដែលពោលហើយដល់សុប្បពុទ្ធកុដ្ឋិនោះ ។ មែនពិត មគ្គញាណឱ្យសម្រេចបរិញ្ញាកិច្ចជាដើម ដោយអំណាចការត្រាស់ដឹងគ្រាតែមួយ ឈ្មោះថា ធ្វាក់ចុះកាន់ញ្ញេយ្យធម៌ ដោយគ្រប់ចំណែកជុំវិញទាំងអស់ មិនមែនញាណដទៃក្រៅពីមគ្គញាណនោះទេ ។ ព្រោះហេតុនោះ លោកទើបពោលថា **ទិដ្ឋោ អរិយសច្ចធម្មោ ឯតេនាតិ ទិដ្ឋធម្មោ** ដូច្នេះជាដើម ។ ព្រោះហេតុនោះនុ៎ះឯង លោកទើបពោលពាក្យមានជាអាទិ៍ថា **តិណ្ណាវិចិកិច្ឆោ** ដូច្នេះ ។

បណ្តាធម៌ទាំងនោះ ឈ្មោះថា អ្នកឆ្លងសេចក្តីសង្ស័យបានហើយ ព្រោះឆ្លងសេចក្តីសង្ស័យមានវត្ថុ ១៦ ប្រការ និងមានវត្ថុ ៨ ប្រការ ដែលដូចជាផ្លូវកន្ទារ

ដែលមានភ័យ ។ បណ្ដាធម៌មានបវត្តិ (ទុក្ខសច្ច:) ជាដើម ពីធម៌នោះនុ៎ះឯង ឈ្មោះថា អ្នកប្រាសចាកសេចក្ដីងឿងឆ្ងល់ ព្រោះប្រាសចាក គឺកាត់ដាច់សេចក្ដីងឿងឆ្ងល់ដែលប្រព្រឹត្តទៅយ៉ាងនេះថា យើងមានសភាពយ៉ាងនេះឬទេហ្ន៏ ។ ឈ្មោះថា ដល់ភាពជាអ្នកក្ដៀវក្ដា ព្រោះដល់ភាពក្ដៀវក្ដា គឺការ:នៃអ្នកអង់អាចបានដល់ ភាពជាអ្នកស្ងាត់ជំនាញ ព្រោះលះបាបធម៌ដែលធ្វើភាពមិនក្ដៀវក្ដា និងព្រោះតាំងនៅដោយល្អក្នុងគុណ មានសីលជាដើម ដែលជាសត្រូវចំពោះបាបធម៌នោះ ។ ឈ្មោះថា មិនជឿបុគ្គលដទៃក្នុងសាសនារបស់ព្រះសាស្ដា ព្រោះមិនមានបុគ្គលដទៃដើម្បីនឹងជឿ គឺមិនបានប្រព្រឹត្តក្នុងសាសនានេះ ដោយជឿចំពោះអ្នកដទៃក្នុងសាសនានៃព្រះសាស្ដា ។

ក្នុងពាក្យថា **អភិក្ខ្ណំ ភន្តេ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ **អភិក្ខ្ណ**-**ស័ព្ទ**នេះ ប្រាកដក្នុងអត្ថច្រើនយ៉ាង មានអត្ថថា អស់ទៅ ល្អ ស្អាត និងអនុមោទ-នាដ៏ក្រៃលែងជាដើម ក៏ពិតមែនហើយ ក៏ប៉ុន្តែថា ក្នុងទីនេះ គប្បីឃើញ**អភិក្ខ្ណ**-**ស័ព្ទ** ប្រើក្នុងអត្ថថា អនុមោទនាដ៏ក្រៃលែង ។ ព្រោះហេតុនោះនុ៎ះឯង **អភិក្ខ្ណ**-**ស័ព្ទ** នោះ លោកទើបពោលទុកដល់ ២ គ្រា គឺដោយសេចក្ដីជ្រះថ្លា ១ ដោយសេចក្ដីសរសើរ ១ អធិប្បាយថា ប្រពៃណាស់ ប្រពៃណាស់ព្រះអង្គ ។ ម្យ៉ាងទៀតបទថា **អភិក្ខ្ណំ** ប្រែថា គួរត្រេកអរ គួរប្រាថ្នា គួរពេញចិត្តដ៏ក្រៃលែង អធិប្បាយថា ល្អដ៏ក្រៃលែង ។ បណ្ដាស័ព្ទទាំង ២ នោះ **អភិក្ខ្ណ**-**ស័ព្ទ** ១ **សុប្ផ**-**ពុទ្ធកុដ្ឋិកុដ្ឋិ** សរសើរទេសនារបស់ព្រះដ៏មានព្រះភាគ **អភិក្ខ្ណ**-**ស័ព្ទ** ១ ទៀត **សុប្ផពុទ្ធកុដ្ឋិ** សរសើរសេចក្ដីជ្រះថ្លារបស់ខ្លួន ។

មែនពិត ក្នុងសេចក្តីនោះ មានអធិប្បាយដូចតទៅនេះ បពិត្រព្រះអង្គដ៏ចម្រើន ព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគដែលសម្តែងយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ណាស់ សេចក្តីជ្រះថ្លារបស់ខ្ញុំព្រះអង្គមានព្រោះអាស្រ័យព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគយ៉ាងនេះ ។ ម្យ៉ាងទៀត សុប្បពុទ្ធកុដ្ឋិ ពោល ២ បទ សរសើរព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគប៉ុណ្ណោះ ដោយន័យយ៉ាងនេះថា ជាក់ច្បាស់ព្រោះឱ្យទោសៈវិនាសទៅ ជាក់ច្បាស់ព្រោះសម្រេចគុណ ជាក់ច្បាស់ព្រោះនាំមកនូវសទ្ធា ព្រោះឱ្យកើតបញ្ញា ព្រោះព្រមដោយអត្ថ ព្រោះព្រមដោយព្យញ្ជនៈ ព្រោះបទដែលងាយ ព្រោះអត្ថដែលជ្រាលជ្រៅ ព្រោះស្រួលស្តាប់ ព្រោះជាប់ចិត្ត ព្រោះមិនលើកខ្ជួន ព្រោះមិនគ្របសង្កត់អ្នកដទៃ ព្រោះភាពជាអ្នកត្រជាក់ដោយករុណា ព្រោះសេចក្តីផ្ទរផង់នៃបញ្ញា ព្រោះប្រសព្វអារម្មណ៍ជាទីរីករាយ ព្រោះអត់ធន់ចំពោះការញ៉ាំញៀ ព្រោះជាសេចក្តីសុខដល់អ្នកស្តាប់ ព្រោះជាប្រយោជន៍ដល់អ្នកពិចារណា ។ បន្ទាប់អំពីនោះ ទើបសរសើរចំពោះទេសនាដោយឧបមា ៤ ប្រការតទៅទៀត ។ បណ្តាបទទាំងនោះ បទថា **ឧក្ខិត្ត** បានដល់ ផ្តាប់មាត់ ឬយកមាត់ចុះក្រោម ។ បទថា **ឧក្ខ**ជ្ជ**យ្យ** បានដល់ គប្បីផ្ទារឡើង ។ បទថា **ឧ**ជ្ជ**ន្ត**ំ បានដល់ បិទទុកដោយស្មៅ និងស្ទឹកឈើជាដើម ។ បទថា **វិ**វ**យ្យ** ប្រែថា គប្បីបើក ។ បទថា **ម**ូ**ឌ**្ហ**ស្ស** បានដល់ អ្នកវង្វេងទិស ។ បទថា **ម**ក្ខ**ំ អ**ាចិ**ក្ខ**េ**យ្ យ** សេចក្តីថា គប្បីចាប់ដៃហើយចង្អុលផ្លូវថា នោះផ្លូវ ។ បទថា **អ**ន្ធ**ការ**េ បានដល់ ក្នុងទី

ងងឹតប្រកបដោយអង្គ ៤ នេះជាអត្ថចំពោះបទមុន ។ ចំណែកការប្រកបសេចក្តីអធិប្បាយ មានដូចតទៅនេះ ព្រះដ៏មានព្រះភាគកាលឱ្យយើងអ្នកបែរមុខពីព្រះសទ្ធម្ម ធ្លាក់នៅក្នុងអសទ្ធម្ម ហើយឱ្យចេញចាកអសទ្ធម្ម ដូចអ្នកណាៗ គប្បីផ្ទារកាជនៈដែលផ្ការីកដូច្នោះ ទ្រង់បើកផ្សាយសាសនាដូចព្រៃ គឺមិច្ឆាទិដ្ឋិ បិទបាំងទុកតាំងពីព្រះសាសនារបស់ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **កស្សបៈ** អន្តរធានទៅ ដូចបុគ្គលបើកកាជនៈដែលបិទបាំងទុកដូច្នោះ ទ្រង់ធ្វើឱ្យច្បាស់នូវផ្លូវស្ថានសួគ៌ និងនិព្វានដល់យើងអ្នកធ្វើដំណើរទៅក្នុងផ្លូវអាក្រក់ ផ្លូវខុស ដូចបុគ្គលប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវដូច្នោះ កាលយើងលិចនៅក្នុងភាពងងឹត គឺមោហៈ មិនឃើញរូបរតនៈ មានពុទ្ធរតនៈជាដើម ទើបទ្រង់ប្រកាសធម៌ដោយអនេកបរិយាយ ព្រោះប្រកាសដោយន័យផ្សេងៗ ដោយទ្រទ្រង់ទុកនូវសេចក្តីរុងរឿងនៃទេសនាដែលកម្ចាត់ងងឹត គឺមោហៈ ដែលជាតួបិទបាំងរតនៈ មានពុទ្ធរតនៈជាដើម ដូចបុគ្គលត្រាលប្រទីបទុកក្នុងទីងងឹតដូច្នោះ ។

កាលសុប្ផពុទ្ធកុដ្ឋិនោះសរសើរទេសនាយ៉ាងនេះហើយ មានចិត្តជ្រះថ្លាក្នុងព្រះរតនត្រ័យដោយទេសនានោះ កាលនឹងធ្វើអាការជ្រះថ្លា ទើបពោលពាក្យមានជាអាទិ៍ថា **ឯសាហំ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឯសាហំ** កាត់បទជា **ឯសោ អហំ** ។ បទថា **ភគវន្តំ សរណំ គច្ឆាមិ** សេចក្តីថា ខ្ញុំព្រះអង្គសូមដល់ព្រះដ៏មានព្រភាគ សូមសេពគប់ សូមដឹង ឬថា សូមត្រាស់ដឹង ដោយបំណងយ៉ាងនេះថា ព្រះដ៏មានព្រះភាគជាសរណៈ ជាទីពឹង ជាទីកម្ចាត់ទុក្ខ ជាទីទ្រទ្រង់ទុកនូវប្រយោជន៍របស់ខ្ញុំព្រះអង្គ ។ មែនពិត គតិ ជាអត្ថរបស់ធាតុពួក

ណា ដល់ពុទ្ធិ ជាអត្តរបស់ធាតុទាំងនោះ ។ បទថា **ធ**ម្មំ សេចក្ដីថា ឈ្មោះថា ធម៌ ព្រោះទ្រទ្រង់ទុកនូវអ្នកសម្រេចមគ្គ អ្នកធ្វើឱ្យច្បាស់នូវនិរោធ អ្នកបដិបត្តិ តាមដែលទ្រង់ទូន្មាន មិនឱ្យធ្លាក់ទៅក្នុងអបាយទាំង ៤ ។ ព្រះធម៌នោះ ដោយ អត្ត ក៏គឺអរិយមគ្គនិងព្រះនិព្វានទុ:ឯង ។ សមដូចព្រះតម្រាស់ដែលព្រះដ៏មាន ព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មានដែលជាសង្ខ្ចតធម៌ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺការឃើញត្រូវ ១ ។ល។ ការតាំងចិត្តមាំត្រូវ ១ នេះប្រាកដជាប្រសើរជាងធម៌ទាំងនោះ[១] និងថា ម្នាលភិក្ខុទាំងឡាយ ធម៌ ទាំងប៉ុន្មាន ដែលជាសង្ខ្ចតធម៌ (ធម៌ដែលមានបច្ច័យប្រជុំតាក់តែង) ក្ដី វិរាគ: (ការប្រាសចាកតម្រេក) ដែលជាគ្រឿងញ៉ាំញីនូវសេចក្ដីស្រវឹង នាំចេញនូវ សេចក្ដីស្រេកឃ្ងាន ដល់នូវសេចក្ដីអាល័យ កាត់ផ្ដាច់នូវវដ្ដ: អស់តណ្ហាប្រាសចាក តម្រេក រលត់មិនសេសសល់ មិនមានតណ្ហា នេះប្រាកដជាប្រសើរជាងធម៌ ទាំងនោះ[២] ។ មិនមែនត្រឹមតែអរិយមគ្គ និងព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះទេ ដែល តថាគតពោលថា ប្រសើរ សូម្បីព្រះបរិយត្តិធម៌ ព្រមដោយអរិយផល តថាគត ក៏ពោលថា ប្រសើរដូចគ្នា ។ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគ ត្រាស់ទុកថា

អ្នកចូរដល់នូវធម៌ ដែលប្រាសចាកវាគ:(អរិយមគ្គ) មិនរំកើប

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ១១៧ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ១១៦ ។

មិនមានសោក(អរិយផល) ជាសភាវធម៌ដែលបច្ច័យប្រជុំតាក់
តែង មិនបាន ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត ដែល
លោកចែកត្រឹមត្រូវហើយ ដើម្បីជាសរណៈចុះ[1] ។

មែនពិត ក្នុងព្រះគាថានេះ មគ្គជាធម្មជាតិប្រាសចាករាគៈ ។ បទថា **អនេជមសោកំ** *បានដល់ អរិយផល ។ បទថា* **អសង្ខ្ជតំ** *បានដល់ ព្រះនិព្វាន ។ ដោយពាក្យថា* **អប្ឍដិកូលំ មធុរមិមំ បតុណ្ណ សុវិភត្តំ** *នេះ ទ្រង់ប្រាជ្ញាដល់ព្រះបរិយត្តិធម៌ ។*

បទថា **ភិក្ខុសង្ឆ** *បានដល់ ពួកព្រះអរិយបុគ្គល ៨ អ្នកស្មើគ្នាដោយ ភាពស្មើគ្នាដោយទិដ្ឋិនិងសីល ។ ដោយលំដាប់ពាក្យត្រឹមតែប៉ុណ្ណោះ សុប្ផពុទ្ធកុដ្ឋិ បានប្រកាសដល់ត្រៃសរណគមន៍ ។ បទថា* **អជ្ជតគ្គ** *ក្នុងពាក្យថា* **ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គ ចាណុបេតំ សរណំ គតំ** *នេះ ប្រែថា តាំងពីថ្ងៃ នេះជាដើមទៅ ។ បាលីថា* **អជ្ជ ឧគ្គ** *ដូច្នេះក៏មាន ។ ឧ អក្សរក្នុងបទថា* **អជ្ជ ឧគ្គ** *នេះ ធ្វើការភ្ជាប់បទ សេចក្ដីថា* **អជ្ជ អគ្ត អជ្ជ អាធ ឆ ត្ត** *ប្រែថា ក្នុងទីបំផុតថ្ងៃនេះ គឺតាំងពីថ្ងៃនេះជាដើមទៅ ។ បទថា* **ចាណុបេតំ** *បានដល់ ប្រកបដោយខ្យល់ដង្ហើម អធិប្បាយថា ជីវិតរបស់ខ្ញុំព្រះអង្គនៅប្រព្រឹត្តទៅដរាប ណា សូមព្រះដ៏មានព្រះភាគ ចូរទ្រង់ចាំ គឺចូរទ្រង់ជ្រាបខ្ញុំព្រះអង្គថាអ្នកចូល ដល់ គឺអ្នកដល់សរណៈ ដោយត្រៃសរណគមន៍ដែលមិនទូទៅដល់សាស្ដាដទៃ ឈ្មោះថា ជាឧបាសក គឺជាកប្ដិយការកៈ ព្រោះចូលដល់ព្រះរតនត្រ័យដរាប*

១-សុត្តន្តបិដក ខុទ្ទកនិកាយ វិមានវត្ថុ លេខ ៥៥ ទំព័រ ១១៦ ។

នោះ ។ ក៏ការដល់សរណគមន៍របស់សុប្ឋពុទ្ធកុដ្ឋិនេះសម្រេចហើយ ដោយការសម្រេចអរិយមគ្គនោះឯង តែកាលនឹងធ្វើអធ្យាស្ស័យ (របស់ខ្លួន)ឱ្យជាក់ច្បាស់ ទើបបានក្រាបទូលយ៉ាងនោះ ។

បទថា **ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា** សេចក្ដីថា កាលសុប្ឋពុទ្ធកុដ្ឋិនោះ មានការរីករាយនឹងព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគហើយ កាលនឹងប្រកាសថា ខ្លួនរីករាយនឹងព្រះតម្រាស់នោះនុ៎ះឯង ទើបអនុ-មោទនាដោយវាចា ដោយន័យដូចពោលទុកហើយ ។ បទថា **អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ** សេចក្ដីថា គ្រាថ្វាយបង្គំព្រះដ៏មានព្រះភាគនោះ ដោយបញ្ចង្គប្រតិស្ឋានហើយ ធ្វើប្រទក្សិណ ៣ ជុំវិញ មានចិត្តបង្ហោនទៅក្នុងគុណរបស់ព្រះសាស្ដាបណ្ដើរ សម្ងឹងមើលផ្គងអញ្ជលី បង្ហោនមស្ការព្រះដ៏មាន-ព្រះភាគនោះឯង រហូតផុតចក្ខុវិស័យរបស់ខ្លួនហើយទើបជៀសចេញទៅ ។

ក៏សុប្ឋពុទ្ធកុដ្ឋិអ្នកជៀសទៅ ដែលមានម្រាមដៃ ម្រាមជើងកំបុត ព្រោះត្រូវពោគឃ្ងង់គ្របសង្កត់ មានខ្លួនប្រឡាក់លាមក មានរបស់មិនស្អាតហូរចេញជុំវិញខ្លួន ត្រូវបូសបៀតបៀន មិនស្អាត មានក្លិនស្អុយ គួរខ្ពើមយ៉ាងក្រៃលែង ដល់ភាពជាអ្នកគួរឱ្យអាណិតយ៉ាងក្រៃលែង ត្រូវមេគោកូនខ្ចី ត្រូវបាបកម្មចូលទៅកាត់បង់ឱ្យប្រព្រឹត្តទៅដើម្បីមានអាយុតិច ដែលខ្លួនសន្សំទុក ដាស់តឿនលួមកាលបុញ្ញកម្មដែលឱ្យប្រព្រឹត្តទៅដើម្បីស្ថានសួគ៌បានឱកាស ដូចសេចក្ដីសំដៅយកដែលកើតឡើងថា កាយនេះមិនសមគួរ ដើម្បីជាទីទទួលអរិយធម៌

ដ៏ប្រណីតក្រៃលែងដែលស្ងប់យ៉ាងមែនពិតនេះ ដូច្នេះ ទើបដល់ឱ្យដួលស្ងាប់ទៅ ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រានោះ មេគោកូនខ្ចីបុះសុប្ឍ-ពុទ្ធកុដ្ឋិ ដែលទើបនឹងចេញទៅមិនយូរប៉ុន្មានឱ្យដាច់ចាកជីវិតដូច្នេះជាដើម ។

មានសេចក្តីដំណាលមកថា ក្នុងអតីតកាល សុប្ឍពុទ្ធកុដ្ឋិនោះជាសេដ្ឋីបុត្តម្នាក់ កំពុងលេងនឹងសេដ្ឋីបុត្ត ៣ នាក់ទៀត ដែលជាសម្ងាញ់របស់ខ្លួន នាំស្រីផ្កាមាសម្នាក់ ទៅកាន់ឧទ្យាន សោយសម្បត្តិរហូតដល់អស់មួយថ្ងៃ កាលព្រះអាទិត្យអស្តង្គតទៅ បានពោលពាក្យនេះចំពោះសម្ងាញ់ទាំងឡាយថា មាសមានចំនួនច្រើនពាន់កហាបណៈ និងគ្រឿងប្រដាប់មានតម្លៃច្រើន មាននៅក្នុងដៃរបស់ស្ត្រីម្នាក់នេះ ក្នុងទីនេះមិនមានអ្នកណាដទៃ និងវេលាក៏ព្រលប់ហើយ ណ្តើយចុះ ពួកយើងនឹងជួយគ្នាសម្ងាប់ស្ត្រីនេះឱ្យស្ងាប់ ហើយកាន់យកទ្រព្យទាំងអស់ទៅ ។ សេដ្ឋីបុត្តទាំង ៤ នោះ មានអធ្យាស្ស័យតែមួយ ទើបចូលទៅដើម្បីនឹងសម្ងាប់ស្ត្រីនោះ ។ ស្រីផ្កាមាសម្នាក់នោះ កាលត្រូវពួកសេដ្ឋីបុត្តទាំង ៤ នាក់សម្ងាប់ ទើបតាំងសេចក្តីប្រាថ្នាថា អ្នកទាំងនេះមិនមានអៀនខ្មាស គ្មានសេចក្តីករុណា ធ្វើសន្ថវៈ (សេពមេថុនធម្ម) ដោយអំណាចកិលេសនឹងយើងហើយ ហើយសម្ងាប់យើងជាមនុស្សមិនមានទោស ព្រោះសេចក្តីលោភក្នុងទ្រព្យតែម្យ៉ាង អ្នកទាំងនេះ សម្ងាប់យើងដោយវារៈតែមួយ ចំណែកយើងសូមឱ្យកើតជាយក្ខិនី ក៏អាចដើម្បីនឹងសម្ងាប់អ្នកទាំងនេះបានច្រើនដង ដូច្នេះហើយទើបស្ងាប់ទៅ ។ បានឮថា បណ្តាសេដ្ឋីបុត្តទាំងនោះ សេដ្ឋីបុត្តម្នាក់បានជាកុលបុត្ត ឈ្មោះថា **បុក្ខសៈ** សេដ្ឋីបុត្តម្នាក់ឈ្មោះថា **ពាហិយទារុចីរិយៈ** សេដ្ឋីបុត្តម្នាក់ជា

ពេជ្ឈឃាតឈ្មោះថា **តម្ពទាឋិកៈ** (ពុកចង្កាក្រហម) និងសេដ្ឋីបុត្តម្នាក់ឈ្មោះថា **សុប្បពុទ្ធកុដ្ឋិ** ក្នុងច្រើនរយអត្តភាពរបស់អ្នកទាំង ៤ ដូចពោលមកនេះ នាង កើតជាមេគោក្នុងកំណើតយក្ខិនី ផ្តាច់ជីវិត (របស់អ្នកទាំងនោះ) ។ ក៏ដោយ វិបាករបស់កម្មនោះ អ្នកទាំងនោះ ទើបដល់សេចក្តីស្លាប់ក្នុងចន្លោះអត្តភាព នោះៗ ។ សុប្បពុទ្ធកុដិ ស្លាប់ដោយធាប់រហ័សដោយអាការយ៉ាងនេះ ។ ព្រោះ ហេតុនោះ លោកទើបពោលថា **អថ ខោ អចិរបក្កន្តំ ។បេ។ ជោរោបេសិ** ដូច្នេះជាដើម ។

គ្រានោះឯង ភិក្ខុច្រើនរូប ក្រាបទូលការធ្វើកាលកិរិយារបស់សុប្បពុទ្ធកុដ្ឋិ ចំពោះព្រះដ៏មានព្រះភាគហើយ ទើបទូលសួរដល់ភពខាងមុខ (របស់គេ) ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្យាករហើយ ។ ព្រោះហេតុនោះ លោកទើប ពោលថា **អថ ខោ សម្ពហុលា ភិក្ខុ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **តិណ្ណំ សំយោជនានំ បរិក្ខយា** សេចក្តីថា ព្រោះការលះដោយសមុច្ឆេទ ដែលជាគ្រឿងចងក្នុងភពបីនេះ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ។ បទថា **សោតបន្នោ** បានដល់ អ្នកសម្រេច អរិយមគ្គ ពោលគឺ ក្រសែគ្រាដំបូង ។ សមដូចពាក្យដែលលោកពោលទុកថា អាវុសោសារីបុត្ត លោកពោលថា **សោតោ សោតោ** នេះ អាវុសោ សោតៈ ដូច ម្តេចហ្ន៎ គឺអរិយមគ្គមានអង្គ ៨ នេះឯង ឈ្មោះថា **សោតៈ** ដូច្នេះ ជាដើម ។ បទថា **អវិនិបាតធម្មោ** ប្រែថា មិនមានការធ្លាក់ចុះទៅជាធម្មតា ។ ឈ្មោះថា

អ្នកមានការមិនធ្លាក់ចុះទៅជាធម្មតា ព្រោះលោកមិនមានការធ្លាក់ចុះទៅជាធម្មតា អធិ‌ប្ប‌ាយ‌ថា មិ‌ន‌មា‌ន‌ការ‌ធ្លាក់‌ទៅ‌ដោ‌យ‌អំ‌ណា‌ច‌ការ‌កើ‌ត‌ក្នុ‌ង‌អ‌បា‌យ ៤ ជាសការ: ។ ប‌ទ‌ថា **និ‌យ‌តោ** *ប‌ា‌ន‌ដ‌ល់ ពិ‌ត‌ប្រា‌ក‌ដ‌ដោ‌យ‌ធ‌ម្ម‌និ‌យា‌ម គឺ‌ដោ‌យ‌ការ‌កំ‌ណ‌ត់ ពិ‌ត‌ប្រា‌ក‌ដ ។ ប‌ទ‌ថា* **ស‌ម្ពោ‌ធ‌ិ‌ប‌រា‌យ‌ណោ** *‌សេ‌ច‌ក្តី‌ថា ឈ្មោ‌ះ‌ថា ជា‌អ្នក‌ដែ‌ល‌និ‌ង‌ត្រា‌ស់‌ដឹ‌ង‌ក្នុ‌ង‌ខា‌ង‌មុ‌ខ‌ព្រោ‌ះ‌ការ‌ត្រា‌ស់‌ដឹ‌ង ពោ‌ល‌គឺ មគ្គ‌ប‌ី‌ខា‌ង‌លើ‌ត‌ប្ប‌ី‌ជា‌ទី‌ទៅ‌ជា‌ត‌ិ ជា‌ទី‌ពឹ‌ង‌អា‌ស្រ‌យ‌ក្នុ‌ង‌ខា‌ង‌មុ‌ខ គឺ‌ខ្ជួ‌ន‌នឹ‌ង‌ត‌ប្ប‌ី‌ស‌ម្រ‌ច‌ពិ‌ត‌ប្រា‌ក‌ដ ។ ព្រោ‌ះ‌ហ‌េ‌តុ‌នោ‌ះ ព្រ‌ះ‌ដ‌ម‌ា‌ន‌ព្រ‌ះ‌ភា‌គ ទើ‌ប‌ស‌ម្ដែ‌ង‌‌សេ‌ច‌ក្តី‌នេ‌ះ‌ទុ‌ក‌ថា ‌ក‌ាល‌ម‌ា‌ន‌ព‌ាក្យ‌ស‌ួ‌រ‌ថា ‌ค‌ติ‌ร‌ប‌ស់‌ស‌ុ‌ប្ប‌ពុ‌ទ្ធ‌ក‌ុ‌ដ្ឋ‌ិ‌យ‌ាង‌ណ‌ា ‌ก‌ព‌ខា‌ង‌មុ‌ខ‌ร‌ប‌ស់‌ស‌ុ‌ប្ប‌ពុ‌ទ្ធ‌ក‌ុ‌ដ្ឋ‌ិ‌ជា‌យ‌ាង‌ណ‌ា ‌ก‌៏‌ព្រ‌ះ‌ដ‌ម‌ា‌ន‌ព្រ‌ះ‌ភា‌គ‌ត្រា‌ស់‌ថ‌ា ‌ค‌ติ‌ร‌ប‌ស់‌ស‌ុ‌ប្ប‌ពុ‌ទ្ធ‌ក‌ុ‌ដ្ឋ‌ិ‌ជា‌ค‌ติ‌ច‌ម្រ‌ើ‌ន ‌ម‌ិ‌ន‌ជា‌ค‌ติ‌អា‌ក្រ‌ក់ ។ ‌ត‌ែ‌ค‌ติ‌ส‌ម្ប‌ត្ត‌ិ‌ម‌ិ‌ន‌ម‌ា‌ន ‌ព្រ‌ោ‌ះ‌ก‌ម្ម‌នោ‌ះ ។ ‌ก‌៏‌ព្រ‌ះ‌អ‌ង្ក‌ជា‌ព្រ‌ះ‌ធ‌ម្ម‌រ‌ា‌ជ‌ទ្រ‌ង‌ដ‌ម‌ា‌ន‌ប្រ‌ា‌ថ្នា‌នឹ‌ង‌ប្រ‌ក‌ា‌ស‌‌សេ‌ច‌ក្ដ‌ីនោ‌ះ ‌ដ‌ែ‌ល‌ជ‌ាប់‌ដោ‌យ‌‌សេ‌ច‌ក្ដ‌ីប‌ន្ត‌ន‌ៃ‌ព‌ាក្យ‌ស‌ួ‌រ‌ទើ‌ប‌ប‌ា‌ន‌ត្រា‌ស់‌‌សេ‌ច‌ក្ដ‌ីទ‌ុ‌ក‌ត្រ‌ឹ‌ម‌ត‌ែ‌ប‌ុ‌ណ្ណោ‌ះ‌ឯ‌ង ។ ‌ម‌ែ‌ន‌ពិ‌ត ‌ព្រ‌ះ‌ដ‌ម‌ា‌ន‌ព្រ‌ះ‌ភា‌គ‌ទ្រ‌ង‌ឃ‌ើ‌ញ‌ថ‌ា ‌ก‌ាល‌យ‌ើ‌ង‌ព‌ោ‌ល‌ព‌ាក្យ‌ត្រ‌ឹ‌ម‌ត‌ែ‌ប‌ុ‌ណ្ណោ‌ះ ‌ប‌ណ្ដ‌ា‌អ្នក‌ម‌ា‌ន‌ส‌ติ‌ជ‌ុ‌ំ‌វ‌ិ‌ញ‌ទ‌ាំ‌ង‌នេ‌ះ‌ប‌ុ‌ណ្ណោ‌ះ ‌ก‌ិ‌ក្ខ‌ុ‌ម‌ួ‌យ‌រ‌ូ‌ប ‌ជា‌អ្នក‌ធ‌ូ‌ត‌ក្នុ‌ង‌អ‌នុ‌ส‌ន្ធ‌ិ ‌នឹ‌ង‌ស‌ួ‌រ‌ដ‌ល់‌ហ‌េ‌តុ‌ថ‌ា ‌ส‌ុ‌ប្ប‌ពុ‌ទ្ធ‌ก‌ុ‌ដ្ឋ‌ិ ‌ជ‌ា‌ม‌នុ‌ស‌ស‌ូ‌ម‌ា‌ន‌ព‌ោ‌ค‌ឃ‌ូ‌ង‌ ‌ជ‌ា‌ม‌នុ‌ស‌ស‌ក‌ំ‌ส‌ត់ ‌ជ‌ា‌ม‌នុ‌ស‌ស‌ក‌ំ‌ព្រ‌ា ‌ន‌ិ‌ង‌ជ‌ា‌ม‌នុ‌ស‌ស‌ថ‌ោ‌ก‌ទ‌ាប ‌ก‌ាល‌ប‌ើ‌ដ‌ូ‌ច‌ន្ន‌ោ‌ះ ‌ต‌ថ‌ា‌ค‌ต‌នឹ‌ង‌ប្រ‌ក‌ា‌ស‌ហ‌េ‌តុ‌នោ‌ះ‌ร‌ប‌ស់‌ស‌ុ‌ប្ប‌ពុ‌ទ្ធ‌-ก‌ុ‌ដ្ឋ‌ិ ‌ដ‌ោ‌យ‌‌សេ‌ច‌ក្ដ‌ីប‌ន្ត‌ន‌ៃ‌ព‌ាក្យ‌ស‌ួ‌រ‌នោ‌ះ‌ហ‌ើ‌យ‌ប‌ញ្ច‌ប‌់‌ธ‌ម‌ទ‌េ‌ส‌ន‌ា ។ ‌ព្រ‌ោ‌ះ‌ហ‌េ‌តុ‌នោ‌ះ‌ន‌ុ‌ং‌ឯ‌ង ‌ล‌ោ‌ก‌ទ‌ើ‌ប‌ត្រា‌ស់‌ថ‌ា* **ฉ‌ำ ‌ว‌ุ‌ត‌្ត‌ោ ‌អ‌ញ្ញ‌ត‌ោ ‌ก‌ิ‌ก្ខ‌ុ** *ដ‌ូ‌ច‌ន្ន‌ោ‌ះ‌ជ‌ា‌ដ‌ើ‌ម ។*

បណ្តាបទទាំងនោះ បទថា **ហេតុ** បានដល់ ហេតុដែលមិនទូទៅ ។ ចំណែកហេតុដែលទូទៅបានដល់បច្ច័យ ។ ហេតុទាំងពីរយ៉ាងនោះ មានសេចក្តីប្លែកគ្នាដូច្នេះ ។ បទថា **យេន** បានដល់ ដោយហេតុនិងដោយបច្ច័យណា ។ បទថា **ភូតបុព្វំ** បានដល់ ហេតុដែលកើតហើយ ។ ដើម្បីនឹងសម្តែងហេតុកើតក្នុងអតីតកាល លោកទើបពោលពាក្យថា **សុប្ឍពុន្ធោ** ជ្រៃ ។

សួរថា ក៏ហេតុកើតឡើងក្នុងកាលណា? ខ្ញុំនិងធ្វើយ ។ មានសេចក្តីដំណាលមកថា ក្នុងអតីតកាល កាលព្រះតថាគតមិនទាន់ឧប្បត្តិឡើង កុលធីតាម្នាក់ ក្នុងស្រុកមួយ រក្សាស្រែជុំវិញក្រុងពារាណសី ។ នាងឃើញព្រះបច្ចេកពុទ្ធមួយអង្គ មានចិត្តជ្រះថ្លា ទើបថ្វាយផ្ការ៉ាយមួយទង ព្រមដោយលាជ ៥០០ ចំពោះព្រះបច្ចេកពុទ្ធនោះ ហើយតាំងសេចក្តីប្រាថ្នាឱ្យបានបុត្រ ៥០០ អង្គ ។ ក៏ក្នុងខណៈនោះឯង ព្រានម្រឹគ ៥០០ នាក់ ក៏ថ្វាយសាច់មានរសឆ្ងាយចំពោះព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាថា សូមពួកយើងគប្បីជាកូនរបស់នាងនិងថា សូមពួកយើងគប្បីបានគុណវិសេសដូចលោកម្ចាស់បានទទួលហើយ ។ នាងមានជីវិតតាំងនៅដរាបដល់អស់អាយុ ហើយកើតក្នុងទេវលោក ចុតិពីទេវលោកនោះហើយ កើតក្នុងត្រពកផ្ការ៉ាយក្នុងជាតស្រះ ។ តាបសម្នាក់ បានឃើញនាង ក៏យកមកចិញ្ចឹមរក្សា ។ កាលនាងដើរទៅ ផ្ការ៉ាយទាំងឡាយ ក៏ផុសឡើងពីផែនដីទ្រចាតជើងគ្រប់ៗ ជំហាន ។ ព្រានម្រៃម្នាក់ឃើញហើយ ចូលទៅក្រាបទូលចំពោះព្រះបាទពារាណសី ។ ព្រះរាជាទ្រង់ត្រាស់ឱ្យនាំនាងមក

ហើយតាំងឱ្យជាអគ្គមហេសី ។ នាងក៏មានគភ៌តាំងឡើង ។ ព្រះមហាបទុមរាជ-
កុមារនៅក្នុងផ្ទៃរបស់នាង ចំណែកព្រះកុមារដ៏សេសសល់អាស្រ័យមន្ទិលគភ៌
ទើបកើតឡើង ។ ព្រះរាជកុមារទាំងនោះ ចម្រើនវ័យ ហើយនាំគ្នាលេងក្នុងស្រះ
ឈូក ក្នុងព្រះរាជឧទ្យានអង្គុយក្នុងផ្កាឈូកមួយអង្គមួយផ្ការ មានញាណចាស់ក្លា
ផ្តើមតាំងការអស់ទៅ និងការសូន្យទៅក្នុងសង្ខារទាំងឡាយ ហើយសម្រេចបច្ចេក-
ពោធិញ្ញាណ ។ ព្រះបច្ចេកពុទ្ធទាំងអស់អង្គនោះមានគាថាព្យាករថា

លោកចូរមើលស្ទឹក និងត្របករបស់ផ្កាឈូក ដែលរីកក្នុងស្រះកើតឡើង
ហើយក៏មានពួកភមរ: (ឃ្មុំ ឬកន្ទង់) ចោមរោមហើយ ជារបស់មិនទៀង ល្មម
ឃើញការមិនទៀងនោះ ហើយគប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ព្រះបច្ចេកសម្ពុទ្ធនាមថា ***តគរសិខី*** *ក្នុងចំណោមព្រះបច្ចេកពុទ្ធ ៥០០ អង្គ*
នោះ ដែលបានសម្រេចបច្ចេកពោធិញ្ញាណយ៉ាងនោះ ចូលនិរោធសមាបត្តិ
រហូតអស់ ៧ ថ្ងៃ ត្រង់នន្ទមូលក:ក្នុងគន្ធមាទបព៌ត កន្ទងទៅ ៧ ថ្ងៃ ទើបចេញ
ចាកនិរោធ ហោះមកចុះត្រង់ឥសិគិលិបព៌ត ក្នុងវេលាព្រឹក ស្ងៀកស្បង់ ហើយ
កាន់បាត្រ និងចីវរ ហើយចូលទៅបិណ្ឌបាតនូវក្រុងរាជគ្រឹះ ។ ក៏ក្នុងសម័យនោះ
ក្នុងក្រុងរាជគ្រឹះ មានសេដ្ឋីបុត្តម្នាក់ ព្រមដោយបរិវារជាច្រើន ចេញពីនគរដើម្បី
លេងកីឡាក្នុងឧទ្យាន ជួបព្រះបច្ចេកពុទ្ធនាមថា ***តគរសិខី*** *។ សេដ្ឋីបុត្តគិតថា*
អ្នកណានេះ ក្បាលត្រដោល គ្រង់សំពត់កាសាវ: នឹងជាមនុស្សពោគឃ្ងង់ យក
សំពត់របស់មនុស្សពោគឃ្ងង់ គ្របរាងកាយទៅយ៉ាងនោះឯង ដូច្នេះហើយ ទើប
ស្ពោះទឹកមាត់ ធ្វើដោយអាការពេបជ្រាយ ហើយជៀសចេញទៅផ្លូវខាងធ្វេង

ដែលលោកសំដៅពោលទុកថា **សុប្បពុទ្ធោ កុដ្ឋី ឥមស្មឹ យេវ រាជគហេ ។បេ។ បក្កាមិ** *ដូច្នេះជាដើម ។*

បណ្ដាបទទាំងនោះ បទថា **ក្វាយំ** *កាត់បទជា* **កោ អយំ** (គឺ) *យើង ពោលអំពីការគំរាម ។ បាលីថា* **កោវាយំ** *ដូច្នេះក៏មាន ។ ដោយបទថា* **កុដ្ឋិ** *សេដ្ឋីបុត្តពោលសំដៅដល់ព្រះបច្ចេកពុទ្ធ ដែលមិនមានរោគឃ្លង់ថា មានរោគឃ្លង់ ដោយអក្កោសវត្ថុ ។ បទថា* **កុដ្ឋិចីវរេន** *ប្រែថា ដោយចីវររបស់មនុស្សរោគ-ឃ្លង់ ។ លោកសម្ដែងថា ក៏សូម្បីព្រះបច្ចេកពុទ្ធនេះ ដូចជាមនុស្សមានរោគឃ្លង់ ដោយច្រើន ដែលកាន់យកសំពត់យ៉ាងណាមួយ ស្លៀកដណ្ដប់ដើម្បីការពារ របោម មូសជាដើម និងដើម្បីការពាររោគ ។ម្យ៉ាងទៀត ព្រោះហេតុដែលលោក ទ្រទ្រង់សំពត់បង្សុកូលចីវរ សេដ្ឋីបុត្តនោះទើបមើលងាយថា ដូចជារាងកាយ របស់មនុស្សកើតរោគឃ្លង់ ព្រោះសំពត់ប៉ះ មានពណ៌ច្រើនយ៉ាង ទើបពោលថា* **កុដ្ឋិចីវរេន** *ដូច្នេះ ។ បទថា* **និដ្ឋុហិត្វា** *បានដល់ ស្ដោះទឹកមាត់ ។ បទថា* **អបព្យាមតោ ករិត្វា** *សេចក្ដីថា បណ្ឌិតទាំងឡាយ ឃើញព្រះបច្ចេកពុទ្ធ មានសភាពដូច្នោះ សំពះហើយធ្វើប្រទក្សិណ តែសេដ្ឋីបុត្តនេះដើរទៅផ្លូវខាង ឆ្វេងព្រះបច្ចេកពុទ្ធនោះ គឺឱ្យព្រះបច្ចេកពុទ្ធនៅខាងឆ្វេងដៃរបស់ខ្លួន ហើយដើរ ទៅដោយសេចក្ដីមើលងាយ ព្រោះភាពដែលខ្លួនមិនជាវិញ្ញូជន ។ បាលីថា* **អបសព្យាមតោ** *ដូច្នេះក៏មាន ។ បទថា* **តស្ស កម្មស្ស** *បានដល់ កម្មអាក្រក់ ដែលប្រព្រឹត្តទៅដោយការមើលងាយព្រះបច្ចេកពុទ្ធនាមថា* ***តគរសិខី*** *ថា អ្នកនេះ*

ជាមនុស្សរោគឃ្លង់ ហើយទើបស្ពោះទឹកមាត់ ហើយជៀសចេញទៅផ្លូវខាងធ្វេង ។ បទថា **និរយេ បចិត្ត** បានដល់ សេដ្ឋីបុត្តនោះត្រូវភ្ជើងនរកឆេះ ។ អាចារ្យពួកខ្លះពោលថា **បចិត្វា និរយក្ខិជា** ដូច្នេះក៏មាន ។ បទថា **តស្ស្ យ កម្ម្ សួ្ស វិចាកសេន** បានដល់ សេដ្ឋីបុត្តនោះកាន់បដិសន្ធិក្នុងនរកដោយកម្មណា កម្មនោះ រមែងមិនឱ្យផលក្នុងមនុស្សលោក ។ ម្យ៉ាងទៀត ចេតនារបស់គេដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងគ្នា ប្រព្រឹត្តទៅដោយអំណាចការបដិបត្តិខុសក្នុងព្រះបច្ចេកពុទ្ធ ក្នុងវេលានោះ ជាកម្មឱ្យផលក្នុងភព-តៗ ទៅ កាលវិបាកកម្មឱ្យបដិសន្ធិជាត្រៃហេតុ ក្នុងពួកមនុស្សព្រោះបុញ្ញកម្មដែលជាបរាបរិយវេទនីយកម្មនោះឯង តែឱ្យដល់ភាពជាមនុស្សកើតរោគឃ្លង់ ជាមនុស្សកំសត់ និងជាមនុស្សគួរឱ្យអាណិតយ៉ាងក្រៃលែងក្នុងបវត្តិកាល ។ ដែលលោកសំដៅពោលទុកថា ដោយសេសសល់របស់វិបាកកម្មនោះឯង ដោយអំណាចកម្មមានសភាពស្មើគ្នា ។ មែនពិត ការបញ្ញត្តិកម្មនោះ ប្រាកដហើយក្នុងលោកសូម្បីដូច្នេះ ដូចការបញ្ញត្ត នុ៎ះឯងថា វត្ថុដែលមានរសល្វីងប៉ុណ្ណោះជាឱសថ ។

ដើម្បីនឹងទ្រង់ដោះស្រាយបញ្ហា ដែលកិក្ខុនោះទូលសួរថា ហេតុអ្វីហ្ន៎ ព្រះអង្គ ដោយលំដាប់ពាក្យត្រឹមតែប៉ុណ្ណោះ ឥឡូវនេះ ភពខាងមុខរបស់សុប្ផ-ពុទ្ធកុដ្ឋិនោះយ៉ាងណា ទើបត្រាស់ពាក្យមានជាអាទិ៍ថា **សោ តថាគតប្ផ-ជ្ជ-ិ តំ ធ ម្ម្ ិ ន យ ំ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **តថាគតប្ផ-ជ្ជ-ិ តំ** សេចក្តីថា ឈ្មោះថា **តថាគតប្ផ-ជ្ជ-ិ តំ** ព្រោះព្រះតថាគត គឺព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយត្រាស់ហើយ ទ្រង់ប្រកាសហើយ ។ បទថា **អ ាកម្ម** បានដល់

សម្រេច ម្យ៉ាងទៀត បទថា **អាកម្ម** ព្រោះអាស្រ័យហើយទើបដឹង ។ បាលីថា **តថាគតប្ប្ដវេទិតេ ធម្មវិនយេ** ដូច្នេះក៏មាន ។ បទថា **សទ្ធំ សមាទិយិ** សេចក្ដីថា គេកាន់យកដោយប្រពៃដែលសទ្ធាទាំង ២ យ៉ាង គឺសទ្ធាដែលជាចំណែក បុព្វភាគ ដែលជាទីអាស្រ័យនៃព្រះរតនត្រ័យថា ព្រះដ៏មានព្រះភាគត្រាស់ដោយប្រពៃ និងដោយព្រះអង្គឯង ១ ព្រះធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ទុកល្អហើយ ១ ព្រះសង្ឆសាវករបស់ព្រះដ៏មានព្រះភាគអ្នកបដិបត្តិល្អហើយ ១ និងសទ្ធាដែលជាលោកុត្តរៈ ។ មានសេចក្ដីអធិប្បាយថា កាន់យកដរាបអស់កាល ដែលមិនត្រូវកាន់យកទៀត គឺធ្វើឱ្យកើតឡើងក្នុងចិត្តសន្ដានរបស់ខ្លួន ។ សូម្បីក្នុងបទមានជាអាទិ៍ថា **សីលំ សមាទិយិ** ក៏ន័យនេះដូចគ្នា ។ បទថា **សីលំ** បានដល់ សីលដែលសម្បយុត្តដោយមគ្គចិត្ត និងដែលសម្បយុត្តដោយផលចិត្ត ព្រមដោយសីលដែលជាចំណែកខាងដើម ។ បទថា **សុតំ** បានដល់ សុតៈទាំង ២ យ៉ាង គឺភាពជាអ្នកមានបរិយត្តិធម៌ដែលស្ដាប់ហើយច្រើន ១ ភាពជាអ្នកមានបដិវេធដែលស្ដាប់ហើយច្រើន ១ មែនពិត សូម្បីបរិយត្តិធម៌មានប្រការ តាមដែលសាវកទាំងឡាយបានហើយ ដោយការចាក់ធ្ងុនូវសច្ចៈក្នុងវេលាស្ដាប់ធម៌ លោកក៏បានស្ដាប់ហើយ ទ្រទ្រង់ចាំហើយ បានសន្សំហើយ បានសម្ងឹងដោយចិត្តហើយ និងបានចាក់ធ្ងុះដោយល្អនូវទិដ្ឋិ ។ បទថា **ចាគំ** បានដល់ ចាគៈ ពោលគឺ ការរួចអកិសង្ខារ គឺកិលេសដែលបឋមមគ្គ (សោតាបត្តិមគ្គ) គប្បីសម្ងាប់ ដែលជាហេតុឱ្យព្រះអរិយសាវកទាំងឡាយ ជាអ្នកលះបង់ជាច់ក្នុងទេយ្យធម៌ មានដៃស្អាត

ត្រេកអរក្នុងការចេញលះបង់ ។ បទថា **បញ្ញា** បានដល់ បញ្ញាដែលសម្បយុត្ត ដោយមគ្គចិត្ត និងបញ្ញាដែលសម្បយុត្តដោយផលចិត្ត ព្រមដោយវិបស្សនាបញ្ញា ។

បទថា **កាយស្ស ភេទា** បានដល់ ព្រោះលះខន្ធដែលមានចិត្តគ្រប់គ្រង ។ បទថា **បរម្មរណា** បានដល់ ការកាន់យកខន្ធដែលកើតចំពោះក្នុងខណៈនោះ ។ ម្យ៉ាងទៀត បទថា **កាយស្ស ភេទា** បានដល់ ព្រោះជីវិតិន្ទ្រិយដាច់ទៅ ។ បទថា **បរម្មរណា** បានដល់ ខាងមុខបន្ទាប់ពីចុតិចិត្ត ។ សូម្បីដោយបទទាំង ៣ គឺ**សុគតឺ** **សគ្គំ** **លោកំ** លោកពោលដល់ទេវលោកប៉ុណ្ណោះ ។ មែនពិត ទេវលោកនោះ ឈ្មោះថា **សុគតិ** ព្រោះជាគតិល្អ ហេតុស្រស់ល្អដោយសម្បត្តិ ទាំងឡាយ ។ ឈ្មោះថា **សគ្គ:** ព្រោះប្រសើរដោយល្អនូវអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ម្យ៉ាងទៀតហៅថា **លោក** ព្រោះឃើញតែសេចក្តីសុខ សព្វៗកាល ឬហៅថា **លោក** ព្រោះផុយរលួយ ។ បទថា **ឧបបន្នោ** បានដល់ ចូលដល់ ដោយអំណាចកាន់បដិសន្ធិ ។ បទថា **សហាព្យតំ** បានដល់ ភាពជា សម្ងាញ់ ។ តែអត្ថនៃពាក្យមានដូច្នេះថា ឈ្មោះថា **សហាព្យ:** ព្រោះអត្ថថា ទៅ គឺ ប្រព្រឹត្តទៅ បានដល់ នៅរួមគ្នា គឺ**សហដ្ឋាយី** ឬ**សហវាសី**[1] ។ ភាវៈនៃសហាព្យ: ឈ្មោះថា **សហាព្យតា** ។ បទថា **អតិភេចតិ** បានដល់ ឈ្មោះថា រុងរោចន៍ ព្រោះកន្ទ្ធ ឬថា រុងរោចន៍ព្រោះគ្រប់សង្កត់ ។ បទថា **រណ្ណេន** បានដល់ ដល់ ព្រមដោយរូប ។ បទថា **យសសា** ប្រៃថា ដោយបរិវារ ។ មែនពិត សុប្ផពុទ្ធកុដ្ឋិ

១-ក្នុងអដ្ឋកថាច្បាប់សីហឬ:ថា **ហតិ** **សហ** **ภาติ** **ภ** ។ ក្នុងអដ្ឋកថាច្បាប់ធម្ម្ដសង្ហ៍យនាថា **សហហាយី** **សហภายี** **ภ** ។

នោះ លះបង់រាងកាយមានប្រការដូចពោលទុកក្នុងលោកនេះ ហើយបានអត្ត-ភាពទិព្វតាមដែលពោលហើយ ព្រមដោយបរិវារជាច្រើន ដោយខណៈតែមួយ ដូចបុគ្គលចោលកាជនៈដ៏ ដែលប្រឡាក់របស់មិនស្អាតទ្រុឌទ្រោម ហើយកាន់យកកាជនៈមាសសុទ្ធដែលបរិសុទ្ធ វិចិត្រដោយរតនៈចម្រុះច្រើន ដណ្តប់ដោយសំណាញ់ គឺរស្មីដែលផ្សាយចេញ ។

បទថា **ឯតមត្ថំ វិជិត្វា** សេចក្តីថា ទ្រង់ជ្រាបដោយប្រការទាំងពួងនូវទោសក្នុងការមិនវៀរចាកបាប និងអានិសង្សក្នុងការវៀរចាកបាបនេះ ទើបទ្រង់បន្ទឺឧទាននេះ ដែលប្រកាសនូវសេចក្តីនោះ ។ ឧទាននោះ មានសេចក្តីសង្ខេបដូចតទៅនេះ

បុរសអ្នកមានចក្ខុ កាលសេចក្តីព្យាយាម គឺសេចក្តីព្យាយាមផ្ទូវកាយមាននៅ គឺប្រព្រឹត្តទៅក្នុងរាងកាយ រមែងវៀរចាកទីមិនស្មើ មានជ្រោះជាដើម ឬរូបដែលមិនស្មើ មានរូបដំរី រូបសេះ រូបពស់ រូបមាន់ និងរូបគោជាដើម ព្រោះមានការប្រទូសរ៉ាយជាសភាវៈ យ៉ាងណា បណ្ឌិត គឺបុរសអ្នកមានបញ្ញាក្នុងជីវលោក គឺក្នុងសត្វលោកនេះ ក៏ដូច្នោះ កាលដឹងប្រយោជន៍ជួយសង្គ្រោះដល់ខ្លួន ព្រោះភាពជាអ្នកមានបញ្ញានោះ គប្បីវៀរចាកបាបទាំងឡាយ គឺទុច្ចរិតដ៏លាមក ។ មានសេចក្តីអធិប្បាយថា ក៏កាលបើដូច្នេះ មិនគប្បីប្រព្រឹត្តដូចសុប្ប-ពុទ្ធកុដ្ឋិនេះ មិនវៀរចាកបាបក្នុងព្រះបច្ចេកពុទ្ធនាមថា **តគរសិខី** ហើយដល់ភាពវិនាសយ៉ាងធំ ម្យ៉ាងទៀត អធិប្បាយថា សុប្ប ពុទ្ធកុដ្ឋិ អាស្រ័យធម៌ទេសនា

ប‌ស់ត‌ថា‌គ‌ត ឥ‌ឡូ‌វ‌នេ‌ះ ដ‌ល់ភា‌ព‌ជា‌អ្ន‌ក‌ស‌ង្វេ‌គ រៀ‌ប‌ចា‌ក‌ប‌ា‌ប‌ទា‌ំ‌ង‌ឡា‌យ ស‌ម្រេ‌ច‌គុ‌ណ‌វិ‌ស‌ស‌យ៉ា‌ង‌ក្រ‌ៃ‌ល‌ង យ៉ា‌ង‌ណា សូ‌ម្ប‌ីអ្ន‌ក‌ដ‌ទ‌ៃ‌ក‌ក‌ដូ‌ច‌ន្ទោ‌ះ កា‌ល‌ប្រា‌ជ្ញា‌នូ‌វ‌ការ‌ស‌ម្រេ‌ច‌គុ‌ណ‌វិ‌ស‌ស‌យ៉ា‌ង‌ក្រ‌ៃ‌ល‌ង ក‌ក‌ម្ប‌ីរៀ‌ប‌ប‌ា‌ប ។

ត‌តិ‌យ ស‌ុ‌ត្ត‌វ‌ណ្ណ‌នា ន‌ិ‌ដ្ឋិ‌តា

ចប់អដ្ឋកថាសូ‌ត្ត‌ទី ៣

៤. កុមារកសុត្តវណ្ណនា

អដ្ឋកថាកុមារកសូត្រ

កុមារកសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **កុមារកា** *បានដល់ ក្មេងជំទង់ ។ តែក្នុងទីនេះ ក្មេងជំទង់ដែលដឹងអត្ថរបស់សុភាសិត និងទុព្ភាសិត លោកបំណងថា* **កុមារកៈ** *។ មែនពិត សត្វទាំងនេះ ចាប់ផ្តើមតាំងពីថ្ងៃទីកើតមក ដរាបដល់អាយុ ១៥ ឆ្នាំ លោកហៅថា* **កុមារកៈ** *ឬ* **ពាលៈ** *បន្ទាប់ពីនោះ មានអាយុ ២០ ឆ្នាំ លោកហៅថា កំលោះក្រមុំ ។ បទថា* **មច្ឆកេ ពាឡ្ហេ** *សេចក្តីថា ក្មេងជំទង់ទាំងនោះ ក្នុងរដូវរំហើយ កាលទឹកក្នុងស្រះមួយកន្លែងជិតផ្ទូវរីងហើយ ទើបនាំគ្នាបាចទឹកដែលជក់នៅក្នុងត្រង់កន្ទុក ចាប់និងសម្ងាប់ត្រីតូចៗ ដោយតាំងចិត្តថា យើងនឹងចម្អិន ហើយបរិភោគ ។ បទថា* **តេឧបសង្កមិ** *សេចក្តីថា ព្រះអង្គស្តេចដៀសចេញពីផ្ទូវចូលទៅកាន់ស្រះទឹកតែបន្តិច ហើយប្រថាប់ឈរ ព្រោះហេតុនោះ លោកទើបពោលថា* **ឧបសង្កមិ** *។ ក៏ព្រោះហេតុណា ទើបស្តេចចូលទៅរក ។ ព្រោះដើម្បីនឹងឱ្យក្មេងទាំងនោះកើតសេចក្តីស្និទ្ធស្នាលនឹងព្រះអង្គ ទើបស្តេចចូលទៅរក ។ ស័ព្ទថា* **ភៅ** *ក្នុងពាក្យនេះថា* **ភាយថ ភៅ** *ត្រឹមតែជានិបាត ។ បទថា* **ឧក្ខ្ស្ស** *ជាធ្ជីវិកត្តិចុះក្នុងអត្ថបញ្ចមីវិភត្តិ អធិប្បាយថា* **ឧក្ខ្ស្មា** *ចាកទុក្ខ ។ ដោយបទថា* **អប្ឌិយំ ភៅ ឧក្ខំ** *ព្រះអង្គត្រាស់សួរថា ទុក្ខដែលកើតក្នុងរាងកាយរបស់អ្នកមិនគួរស្រឡាញ់មិនគួរប្រាថ្នាមិនមែនឬ?*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថនេះថា សត្វទាំងនេះ មិនប្រាថ្នាទុក្ខដើម្បីខ្លួនឡើយ តែបដិបត្តិហេតុនៃ*

ទុក្ខ ដោយហេតុថា ប្រាថ្នាទុក្ខនុ៎ះឯង ។ បទថា **ឥមំ ឧទានំ** សេចក្ដីថា ទ្រង់បន្ទឺ ឧទាននេះ ដែលរាាំងការធ្វើអាក្រក់ និងប្រកាសទោសរបស់ការធ្វើអាក្រក់ ។

ឧទាននោះមានអត្ថន័យដូចតទៅនេះ បើថា ទុក្ខដែលនឹងឱ្យប្រព្រឹត្តទៅ ក្នុងអបាយទាំងអស់ និងដែលផ្សេងដោយភាពជាអ្នកមានអាយុតិច និងភាពជា អ្នកមានចំណែកអាក្រក់នៃមនុស្សជាដើមក្នុងសុគតិ ជាធម្មជាតិមិនគួរស្រឡាញ់ មិនគួរប្រាថ្នាសម្រាប់ពួកអ្នកទាំងឡាយ បើពួកអ្នកទាំងឡាយខ្ជាចទុក្ខនោះ ពួក អ្នកកុំធ្វើ គឺកុំបង្កកម្មអាក្រក់ គឺកម្មលាមកសូម្បីមានប្រមាណតិច មានបាណាតិ-បាតជាដើម ដោយកាយ ឬដោយវាចា ទាំងក្នុងទីវាល គឺមិនបិទបាំង ព្រោះ ប្រាកដដល់អ្នកដទៃ និងអកិញ្ចាជាដើម ក្នុងមនោទ្វារ ទាំងក្នុងទីកំបាំង គឺបិទបាំង ដោយការមិនប្រាកដដល់អ្នកដទៃ បើថា អ្នកទាំងឡាយធ្វើកម្មអាក្រក់នោះក្នុង កាលឥឡូវនេះ ឬនឹងធ្វើក្នុងកាលអនាគត ទុក្ខដែលជាផលរបស់កម្មនោះ ក្នុង អបាយទាំង ៤ មាននរកជាដើម និងក្នុងមនុស្សទាំងឡាយ នឹងមិនជាប់តាមពួក យើងឡើយ អ្នកគេចជៀសទៅខាងឯណោះឯណេះ ដោយសេចក្ដីអធិប្បាយ ដូចពោលមកនេះ សូម្បីពួកអ្នកទាំងឡាយនឹងរត់គេចជៀស គឺជៀសគេចទៅ ក៏មិនរួច គឺមិនផុតពីទុក្ខនោះទៅបាន លោកសម្ដែងទុកថានឹងឱ្យផល ក្នុងកាល កើតព្រមនៃបច្ច័យដទៃមានគតិ និងកាលជាដើមនោះឯង ។ អាចារ្យពួកខ្លះ ពោលថា **បលាយនេ** ដូច្នេះក៏មាន សេចក្ដីថា កាលទៅ គឺការជៀសទៅក្នុងទី ណាមួយ មានទៅដោយន័យដូចពោលហើយ ។ ក៏សេចក្ដីនេះ គប្បីសម្ដែង ដោយគាថានេះថា

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្ពតានំ វិវរំ បវិសំ
ន វិជ្ជតី សោ ឧតតិប្ប ទេសោ
យត្រដ្ឋិតោ សមុ ច្ចេ យ្យ ចាបកម្មា ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្ទោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបកម្ម បានន្ទោះមិនដែលមានឡើយ[១] ។

ចតុត្ថ សុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៤

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៤៨ ។

៥. ឧចោសថសុត្តវណ្ណនា

អដ្ឋកថាឧចោសថសូត្រ

ឧបោសថសូត្រទី ៥ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **តឧហុ** *បានដល់ ក្នុងថ្ងៃនោះ គឺក្នុងពេលថ្ងៃនោះ ។ ក្នុងពាក្យ*
ថា **ឧចោសថេ** *មានវិនិច្ឆ័យដូចតទៅនេះ ។ ថ្ងៃ ឈ្មោះថា* ***ឧបោសថ*** *ព្រោះជា*
ទីចូរចាំរបស់អ្នកទាំងឡាយ ។បទថា **ឧបវសន្តិ** *សេចក្តីថា ជាអ្នកចូលចាំដោយ*
សីល ឬដោយការវៀរចាកអាហារ ។ មែនពិត សព្ទថា ***ឧបោសថ*** *នេះ មកក្នុង****សីល***
ក្នុងប្រយោគមានជាអាទិ៍ថា យើងចូលចាំឧបោសថដែលប្រកបដោយអង្គ ៨[1] *។*
មកក្នុង ***វិនិយកម្មមានបាតិមោក្ខុទ្ទេសជាដើម*** *ដូចប្រយោគមានជាអាទិ៍ថា ឧបោសថ*
ឬបវារណា ។ មកក្នុង ***ឧបវាស*** *ក្នុងប្រយោគមានជាអាទិ៍ថា ឧបោសថរបស់*
នាយគោបាល ឧបោសថរបស់និគ្រន្ថ[2] *។ មកក្នុង* ***បញ្ញត្ត*** *ដូចប្រយោគមានជា*
អាទិ៍ថា ស្តេចដំរី ឈ្មោះថា ឧបោសថ ។ មកក្នុង ***ថ្ងៃ*** *ក្នុងប្រយោគមានជាអាទិ៍ថា*
ថ្ងៃនេះជាថ្ងៃឧបោសថ ១៥ រោច ។ សូម្បីក្នុងទីនេះ គប្បីឃើញថា មកក្នុងថ្ងៃ
នោះឯង ។ ព្រោះដូច្នោះ បទថា **តឧហុចោសថេ** *សេចក្តីថា ក្នុងថ្ងៃដែលជាថ្ងៃ*
ឧបោសថនោះ ។ បទថា **និសិន្នោ ហោតិ** *សេចក្តីថា ព្រះអង្គមានកិក្ខុសង្ឆដ៏*
ច្រើនចោមរោម ប្រថាប់គង់ដើម្បីទ្រង់សម្តែងឱវាទបាតិមោក្ខ ។ ក៏កាលប្រថាប់
គង់ហើយ ទ្រង់ប្រមើលឃើញថា ចិត្តរបស់កិក្ខុទាំងនោះ ទ្រង់ឃើញកិក្ខុ
ទ្រុស្តសីល ១ រូប ទ្រង់មានព្រះតម្រិះថា បើតថាគត នឹងសម្តែងបាតិមោក្ខ ក្នុង
កាលបុគ្គលនេះអង្គុយនៅក្នុងទីនេះនុ៎ះឯង ក្បាលរបស់អ្នកនោះនឹងបែកទៅជា

១-សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត លេខ ៨៨ ទំព័រ ២៧៩ ។

២-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៦១ ទំព័រ ២៥៩ ។

៧ ចំរៀក ព្រោះដូច្នេះហើយ ទើបទ្រង់គង់នៅដោយតុណ្ហីភាពដើម្បីអនុគ្រោះ ដល់ភិក្ខុអង្គនោះនុ៎ះឯង ។

ក៏ក្នុងទីនេះជួបថា **ឧទ្ធេ្ធ អរុណេ** សេចក្ដីថា វេលាដល់អរុណរះ ព្រះអានន្ទដ៏មានអាយុអង្វរព្រះដ៏មានព្រះភាគ ដើម្បីឱ្យទ្រង់សម្ដែងបាតិមោក្ខ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្ដែងបាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ។ ព្រោះក្នុងវេលានោះ ព្រះអង្គមិនទាន់បានទ្រង់បញ្ញត្ត សិក្ខាបទថា **ន ភិក្ខវេ អនុចោសថេ ឧចោសថោ ការេតព្ពោ** ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុមិនត្រូវធ្វើឧបោសថក្នុងថ្ងៃមិនមែនឧបោសថឡើយ[1] ។ បទថា **អបរិ-សុទ្ធា អានន្ទ បរិសា** សេចក្ដីថា ព្រោះព្រះអង្គត្រូវព្រះអានន្ទត្ដេរទូលសូមឱ្យ ទ្រង់សម្ដែងបាតិមោក្ខអស់វារៈ ៣ ដង ត្រាកាលនឹងត្រាស់ប្រាប់ហេតុការណ៍ដែល ទ្រង់មិនសម្ដែង មិនត្រាស់ថា បុគ្គលឯណោះមិនបរិសុទ្ធ តែត្រាស់ថា ម្នាលអានន្ទ បរិស័ទមិនបរិសុទ្ធទេ ។ ក៏ព្រោះហេតុអ្វីបានជាព្រះដ៏មានព្រះភាគញ៉ាំង ៣ យាម នៃរាត្រីកន្ទ្ធងទៅយ៉ាងនោះ? ព្រោះចាប់ផ្ដើមតាំងពីនោះ ព្រះអង្គមានប្រាជ្ញានឹង មិនសម្ដែងឱ្យាទបាតិមោក្ខ ដើម្បីធ្វើវត្ថុនៃការមិនទ្រង់សម្ដែងនោះឱ្យប្រាកដ ។

បទថា **អទ្ធសា** បានដល់ បានឃើញយ៉ាងណា ។ ព្រះមហាមោគ្គល្លាន ដ៏មានអាយុ កំណត់ដឹងចិត្តរបស់ភិក្ខុទាំងឡាយក្នុងបរិស័ទនោះ ដោយចេតោ-បរិយញ្ញាណរបស់ខ្លួន ទើបឃើញចិត្ត គឺភាពជាអ្នកទ្រុស្ដសីលរបស់មោឃបុរស នោះ ។ កាលដែលព្រះថេរៈឃើញចិត្តហើយ ក៏ឈ្មោះថា ឃើញបុគ្គលដែល

១-វិនយបិដក មហាវគ្គ លេខ ៦ ទំព័រ ៤២០ ។

ព្រមដោយចិត្តនោះ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា លុះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញបុគ្គលទ្រុស្តសីលនោះ ។ មែនពិត ជាបុគ្គលអ្នកបានចេតោបរិយញ្ញាណ រមែងដឹងចិត្តរបស់បុគ្គលដទៃ ដែល ប្រព្រឹត្តទៅក្នុងថ្ងៃទាំង ៧ ក្នុងអនាគតយ៉ាងណា សូម្បីក្នុងអតីតក៏ដូច្នោះដែរ ។ បទថា **ឧុស្សីលំ** ប្រែថា អ្នកមិនមានសីល អធិប្បាយថា អ្នកវៀរចាកសីល ។ បទថា **ចាបធម្មំ** បានដល់ អ្នកមានធម៌ដ៏លាមក ព្រោះជាអ្នកមានអធ្យាស្ស័យ អាក្រក់ ដោយភាពជាអ្នកទ្រុស្តសីលនោះឯង ។ បទថា **អសុចឺ** ឈ្មោះថា អ្នក មិនស្អាត ព្រោះប្រកបដោយកាយកម្មជាដើមដែលមិនបរិសុទ្ធ ។ បទថា **សង្ក-ស្សរសមាចារំ** សេចក្តីថា អ្នកមានសមាចារដែលគប្បីរព្ងកដោយសេចក្តីរង្កៀស ព្រោះអ្នកដទៃឃើញកម្មដែលមិនសមគួរខ្ជះ ហើយរង្កៀសយ៉ាងនេះថា នេះ ប្រហែលជាកម្ម គឺអ្នកនេះធ្វើហើយ ។ ម្យ៉ាងទៀត ព្រោះបានឃើញកិក្ខុទាំង ឡាយប្រឹក្សាគ្នាដោយករណីយកិច្ចណាមួយ អ្នកមានសមាចារដែលគប្បីរព្ងក ដោយសេចក្តីរង្កៀសរបស់ខ្លួនឯងថា កិក្ខុទាំងនោះ ដឹងកម្មដែលយើងធ្វើ ទើប ប្រឹក្សាគ្នាទេដឹងហ្ន៎ ។

ឈ្មោះថា អ្នកមានការងារពួនសម្ងំ ព្រោះលោកមានការងារបិទបាំងទុក ដោយធ្វើកម្មដែលគប្បីបិទបាំង ហេតុជាកម្មដែលគប្បីខ្មាស ។ ឈ្មោះថា មិនមែនជាសមណៈ គឺមិនមែនសមណៈ ព្រោះទ្រទ្រង់ទុកនូវភេទនៃសមណៈ ដែលគួរស្អប់ ។ ឈ្មោះថា ប្តេជ្ញាថាជាសមណៈ ក្នុងការរាប់ថា សមណៈមាន ចំនួនប៉ុនណា ក្នុងការចាប់ស្វាកជាដើម និងក្នុងការប្តេជ្ញាខុសថា សូម្បីយើងក៏ ជាសមណៈដែរ ។ ឈ្មោះថា **អព្រហ្មចារី** ព្រោះជាអ្នកមានការប្រព្រឹត្តមិន

ប្រសើរ ។ ឈ្មោះថា **ប្តេជ្ញាថាជាព្រហ្មចារី** ព្រោះអ្នកមិនជាព្រហ្មចារី ឃើញសព្រហ្មចារីពួកដទៃ ស្ងៀកដណ្តប់រៀបរយ កាន់បាត្ររៀបរយ កំពុងត្រាច់ទៅបិណ្ឌបាតក្នុងស្រុក និងនិគមជាដើមចិញ្ចឹមជីវិត សូម្បីខ្លួនឯងក៏បដិបត្តិដោយអាការដូច្នោះ និងប្រាកដក្នុងថ្ងៃឧបោសថជាដើម ដូចជាឱ្យប្តេជ្ញាថា សូម្បីយើងក៏ជាព្រហ្មចារីដែរ ។ ឈ្មោះថា **ស្អុយខាងក្នុង** ព្រោះកម្ម គឺសីលវិបត្តិនៅខាងក្នុង ។ ឈ្មោះថា **មានចិត្តជោកដោយរាគៈ** ព្រោះជោកដោយកិលេសជាគ្រឿងហូរចេញមក មានរាគៈជាដើមតាមទ្វារទាំង ៦ ។ ឈ្មោះថា **កខ្វក់ដូចសំរាម** ព្រោះកើតមានសំរាម គឺរាគៈជាដើម និងព្រោះត្រូវអ្នកមានសីលទាំងឡាយលះចោល ។ បទថា **មជ្ឈេ ភិក្ខុសង្ឆស្ស ឯសិន្នំ** សេចក្តីថា អង្គុយក្នុងកណ្តាលភិក្ខុសង្ឆ ដូចរាប់បញ្ចូលក្នុងសង្ឆ ។ បទថា **ឥជ្ឌោសិ** សេចក្តីថា ជាអ្នកដែលព្រះដ៏មាន-ព្រះភាគទ្រង់ឃើញហើយថា អ្នកនេះមិនមែនជាភិក្ខុតាមប្រក្រតី ។ ក៏ក្នុងសេចក្តីនេះ គប្បីឃើញការប្រកបបទយ៉ាងនេះថា ព្រោះហេតុដែលព្រះដ៏មានព្រះភាគទ្រង់ឃើញអ្នក ដូច្នោះអ្នក គឺអ្នកមិនមានធម៌ជាគ្រឿងនៅរួមនោះ ដោយកម្មជាមួយនឹងភិក្ខុទាំងឡាយទេ ក៏ព្រោះហេតុដែលអ្នកមិនមានធម៌ជាគ្រឿងនៅរួមនោះ អាវុសោ បើដូច្នោះ អ្នកចូរក្រោកឡើងចុះ ។ បទថា **តតិយម្ឌិ ខោ សោ បុគ្ក-លោ តុណ្ហី អហោសិ** សេចក្តីថា បុគ្គលនោះជាអ្នកស្ងៀមដោយសេចក្តីប្រាថ្នាថា ព្រះថេរៈសូម្បីនិយាយញយ។ ក៏នឹងនឿយណាយដោយខ្លួនឯងហើយបន្ទូរបន្ទយ ឬថា ឥឡូវនេះ យើងនឹងដឹងការបដិបត្តិរបស់ភិក្ខុទាំងនេះ ។ បទថា **ពហាយំ ឯហេតុ** សេចក្តីថា បុគ្គលដែលទ្រុស្តសីលនោះ ដែល

ព្រះដ៏មានព្រះភាគ និងយើងឃើញតាមសេចក្តីពិតហើយ និងយើងក៏ពោលថា អ្នកចូរក្រោកឡើងអស់វារៈ ៣ ដង ក៏មិនក្រោកឡើង ទើបចាប់ដើមដៃបុគ្គលដែលទ្រុស្តសីលនោះ ដោយគិតថា ឥឡូវនេះ ជាវេលាដែលទាញចេញ អន្តរាយឧបោសថកុំបានមានដល់សង្ឆឡើយ គឺលោកចាប់ដោយសភាពយ៉ាងនោះហើយ ។ បទថា **ពហិទ្វារកោដ្ឋកា ឯក្ខាមេត្វា** សេចក្តីពិត ទើបឱ្យចេញទៅខាងក្រៅស៊ុមទ្វារ គឺពីទ្វារសាលា ។ ក៏បទថា **ពហិ** ជាបទសម្តែងទីដែលព្រះថេរៈទាញឱ្យចេញទៅ ។ ម្យ៉ាងទៀត បទថា **ពហិ ទ្វារកោដ្ឋកា** សេចក្តីថា ឱ្យចេញទៅពីខាងក្រៅស៊ុមទ្វារ មិនមែនឱ្យចេញទៅពីខាងក្នុងស៊ុមទ្វារទេ អធិប្បាយថា ធ្វើឱ្យនៅក្រៅវិហារ សូម្បីដោយប្រការទាំងពីរដោយប្រការដូច្នេះ ។ បទថា **សុចិយដិកំ ឧត្វា** សេចក្តីថា ដាក់រនុក និងស្នៀតគន្ធីៈទុកខាងលើ អធិប្បាយថា ការពារទុកដោយល្អ ។ ដោយបទថា **យាវ ពាហាតហាណាបិ ជាម** នេះ លោកសម្តែងថា ក៏ព្រោះបានស្តាប់ព្រះតម្រាស់ថា ម្នាលអានន្ទបរិស័ទមិនបរិសុទ្ធដូច្នេះ ក៏កាលបើយ៉ាងនោះ លោកគប្បីជៀសចេញទៅ គ្រាមិនជៀសចេញទៅយ៉ាងនោះ មោឃបុរសនោះ នឹងឈ្មោះថា ត្រូវចាប់ដៃអូសចេញទៅដូច្នោះ ប្រការនេះទើបគួរអស្ចារ្យ ។ គប្បីជ្រាបថាសូម្បីប្រការនេះ ក៏អស្ចារ្យដែលគួរតិះ-ដៀលតែម្តង ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះតម្រិះថា ឥឡូវនេះ ភិក្ខុសង្ឆកើតឡើងហើយ ពួកបុគ្គលមិនបរិសុទ្ធមកកាន់ឧបោសថ និងព្រះតថាគតទាំងឡាយ រមែងមិនធ្វើឧបោសថមិនសម្តែងបាតិមោក្ខ ដល់បរិស័ទអ្នកមិនបរិសុទ្ធ និងកាលមិនសម្តែងឧបោសថ ឧបោសថរបស់ភិក្ខុសង្ឆក៏ដាច់ បើដូច្នោះ មានតែ

តថាគតគប្បីអនុញ្ញាតបាតិមោក្ខុទេស(សូត្របាតិមោក្ខ) ដល់ភិក្ខុទាំងឡាយចាប់តាំងពីពេលនេះតទៅ ក៏ឯគ្រាទ្រង់មានព្រះតម្រិះយ៉ាងនេះហើយ ទើបទ្រង់អនុញ្ញាតបាតិមោក្ខុទេសចំពោះភិក្ខុទាំងឡាយ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ ភគវា ។បេ។ ចាដិមោក្ខំ ឧទ្ទិសេយ្យាថ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ ដោយបទថា **ឧជានាហំ** *នេះ ភ្ជាប់ដោយ* **ន** *អក្សរ ចំពោះបទថា ឥឡូវនេះ តថាគតនឹងមិនធ្វើឧបោសថ នឹងមិនសម្តែងបាតិមោក្ខ ។ ក៏បាតិមោក្ខនោះមាន ២ យ៉ាង គឺ***អាណាបាតិមោក្ខ ១ ឱវាទបាតិមោក្ខ ១** *។ បណ្តា ២ យ៉ាងនេះ ពាក្យមានជាអាទ៍ថា***សុណាតុ មេ ភន្តេ** *ឈ្មោះថា* ***អាណា-បាតិមោក្ខ*** *។ អាណាបាតិមោក្ខទាំងនោះ សាវកទាំងឡាយប៉ុណ្ណោះ រមែងសម្តែងរាល់កន្ទះខែម្តង ព្រះពុទ្ធទាំងឡាយមិនសម្តែងទេ ។ ក៏គាថាទាំងឡាយ ៣ នេះ គឺ*

ខន្តិ បរមំ តបោ តីតិក្ខា
និព្ពានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្ពជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ ។

ខន្តិ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយតែងពោលថា ព្រះនិព្វាន ជាធម្មជាតដ៏ឧត្តម បុគ្គលដែលសម្ងាប់សត្វដទៃ មិនឈ្មោះថា បព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថា សមណៈឡើយ ។

សព្វបាបស្ស អការណំ កុសលស្សូបសម្ផទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។

ការមិនធ្វើបាបទាំងពួង ការញ៉ាំងកុសលឱ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

អនូបឃាតោ អនូបឃាតោ ចាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។

ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួមក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងកត្ត ១ ការដេក និងអង្គុយក្នុងទីស្ងាត់ ១ ការព្យាយាមក្នុងអធិចិត្ត ១ នុ៎ះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ដូច្នេះ ឈ្មោះថា ***ឱវាទ-បាតិមោក្ខ*** *។ ឱវាទបាតិមោក្ខនោះ ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ រមែងសម្តែងសាវកមិនសម្តែងទេ កន្ធងទៅ ៦ ឆ្នាំ ទើបទ្រង់សម្តែង ។ ក៏ក្នុងកាលដែលព្រះពុទ្ធទាំងឡាយព្រះអង្គមានព្រះជន្មវែង ក៏ទ្រង់សម្តែងបាតិមោក្ខនេះឯង ។ តែក្នុងកាលដែលព្រះពុទ្ធទាំងឡាយព្រះអង្គមានព្រះជន្មតិច រមែងទ្រង់សម្តែងតែក្នុងបឋមពោធិកាលប៉ុណ្ណោះទេ ។ ក៏បាតិមោក្ខនុ៎ះឯង គឺភិក្ខុទាំងឡាយប៉ុណ្ណោះរមែងសម្តែង ព្រះពុទ្ធទាំងឡាយមិនសម្តែងទេ ព្រោះដូច្នោះ សូម្បីព្រះដ៏មានព្រះភាគ សូម្បីរបស់យើងទាំងឡាយ ទើបទ្រង់សម្តែងឱវាទបាតិមោក្ខ ត្រឹមតែ ២០ ឆ្នាំ គ្រាន់តែទ្រង់ឃើញអន្តរាយនេះហើយ ក្រោយពីនោះ ក៏ទ្រង់មិនសម្តែង ។ បទថា* **អដ្ឋានំ** *ប្រែថា ហេតុដែលមិនសមគួរ ។ បទថា* **អនវកាសោ** *ជាវេចនៈ:របស់ហេតុដែលមិនសមគួរនោះដូចគ្នា ។ មែនពិត ហេតុ លោកហៅថា* **ឋានៈ** *ព្រោះជាទីតាំងនៅនៃផល ហេតុមានការប្រព្រឹត្តទៅជាប់នឹងផលនោះ យ៉ាងណា ហេតុដែលមិនសមគួរនោះ លោកទើបហៅថា* **អនវកាសោ** *ដូច្នេះក៏មាន ។*

បទថា **យំ** *ជាកិរិយាបរាមាស ។ បទថា* **យំ** *នោះ គប្បីប្រកបដោយន័យដែលពោលហើយក្នុងកាលមុន ។*

សួរថា ក្នុងបទថា **អដ្ឋិមេ ភិក្ខវេ មហាសមុទ្ទេ** *នេះ មានអនុសន្ធិយ៉ាងណា? ឆ្លើយថា ការមិនសម្តែងព្រះបាតិមោក្ខដល់បរិស័ទអ្នកមិនបរិសុទ្ធដែលព្រះដ៏មានព្រះភាគត្រាស់ទុកហើយនោះចាត់ជាអច្ឆរិយអព្ភុតធម៌ ក្នុងព្រះធម្ម-វិន័យនេះ ព្រោះដូច្នោះ ព្រះសាស្តា មានប្រាជ្ញានឹងចែកសម្តែងការមិនសូត្រព្រះបាតិមោក្ខនោះ ព្រមនឹងអច្ឆរិយអព្ភុតធម៌ ៧ ប្រការក្រៅនេះ លំដាប់ដំបូងកាលនឹងទ្រង់សម្តែងអច្ឆរិយអព្ភុតធម៌ ៨ ប្រការ ក្នុងមហាសមុទ្រ ដោយសេចក្តីឧបមាដល់ភិក្ខុទាំងនោះមុន ទើបត្រាស់ព្រះតម្រាស់មានជាអាទិ៍ថា* **អដ្ឋិមេ ភិក្ខវេ មហាសមុទ្ទេ** *ដូច្នេះ ។*

បទថា **អសុរា** *សេចក្តីថា ឈ្មោះថា អសុរៈ ព្រោះមិនលេង គឺមិនរីករាយ បានដល់ មិនរុងរោចន៍ ដូចទេវៈ (ប្រក្រតី) ម្យ៉ាងទៀត ទេវៈ ឈ្មោះថា អសុរ ព្រោះជាសត្រូវចំពោះទេវៈ អ្នកឈ្មោះថា សុរៈទាំងនោះ បានដល់ ទេវៈអ្នកឱ្យការប្រហារចំពោះទេវវេបចិត្តិអសុរជាដើម ។ កពរបស់អសុរទាំងនោះ មានក្នុងចំណែកខាងក្រោមភ្នំសិនេរុ ។ ទេវៈទាំងនោះ កំពុងចូលចេញក្នុងកពនៃអសុរទាំងនោះៗនិម្មិតមណ្ឌបជាដើម ក្នុងជើងភ្នំសិនេរុ លេងអភិរម្យនៅ ។ ព្រោះឃើញគុណទាំងនោះ ដោយសេចក្តីត្រេកអរក្រៃលែងរបស់ទេវៈទាំងនោះ ក្នុងកពនោះ ព្រោះហេតុនោះ លោកទើបពោលថា ទេវអសុរពួកណា ល្មមបានឃើញ បានឃើញចូល ទើបអភិរម្យក្នុងមហាសមុទ្រ ដូច្នេះ ជាដើម ។*

បណ្តាបទទាំងនោះ បទថា **អភិរមន្តិ** *ប្រែថា រមែងប្រសព្វសេចក្តីត្រេកអរ អធិប្បាយថា មិននឿយណាយនៅ ។ បទទាំងអស់មានជាអាទិ៍ថា* **អនុបុព្វនិន្នោ** *ជាវេវចន:នៃសេចក្តីជាស្ថានទីក្រាលកន្ទុក តាមលំដាប់នោះឯង ។*

បទថា **ជាយតកេនេវ បថាតោ** *សេចក្តីថា មិនមែនជ្រោះពីមុនមក តែដូចបឹងធំដែលបង្ហូរទឹក ។ មែនពិត ជ្រោះនោះ ជាប់ផ្តើមតាំងពីចំណែកនៃត្រើយទៅជាចំណែកដែលជ្រាលជ្រៅ ដោយអង្គុលីមួយ ពីរអង្គុលី មួយចំអាម មួយហត្ថ សសរមួយ រយ:មួយគោឧសភ: កន្ទុះគាវុត មួយគាវុត និងមួយយោជន៍ជាដើម ជ្រៅទៅ ជ្រៅទៅ ដរាបដល់ខ្នាតជម្រៅ ៨៦០០ យោជន៍ ក្នុងជើងសិនេរុបព្វត លោកសម្តែងទុកដូច្នេះ ។ បទថា* **ចិតឆម្ហោ** *បានដល់ មានសេចក្តីតាំងនៅជាសការ: គឺមានសេចក្តីតាំងចុះជាសការ: ។ បទថា* **មតេន ឧណ្ណាបេន** *បានដល់ ដោយសាកសពដំរី និងសេះជាដើមយ៉ាងណាមួយ ។ បទថា* **ឱហោតិ** *ប្រែថា អណ្តែតទៅ ។ បទថា* **ថលំ ឧស្សាវេតិ** *សេចក្តីថា បោះឡើងលើគោក ដោយរលកប៉ះខ្ទប់ត្រាតែមួយប៉ុណ្ណោះដូចយកដៃចាប់បោះទៅដូច្នោះ ។ បទថា* **តជ្ជា យមុនា** *សេចក្តីថា ទន្ទេដែលហូរចេញចាកផ្លូវផ្នែកខាងទិសត្បូងនៃស្រះអនោតត្ត ចាត់ជាទន្ទេ ៥ ខ្សែ ដល់ការរាប់ដោយ ៥ ខ្សែ មានទន្ទេគង្គាជាដើម ក្នុងទីដែលហូរទៅ ។*

ក្នុងសេចក្តីនោះ មានកថាសម្តែងការកើតឡើងតាំងពីដើមនៃទន្ទេ ៥ ខ្សែ ពួកនេះ ដូចតទៅនេះ មែនពិត ជម្ពូទ្វីបនេះ មានប្រមាណមឺនយោជន៍ ។ ក្នុងជម្ពូទ្វីបនោះប្រទេសមានប្រមាណ ៨០០០ យោជន៍ ត្រូវទឹកច្រោះ ដល់ការរាប់ថា សមុទ្រ ។ ពួកអ្នកអាស្រ័យនៅក្នុងទីប្រមាណ ៣០០០ យោជន៍ ។ ភ្នំហិម-

ពាន្តតាំងទល់ក្នុងទីប្រមាណ ៣០០០ យោជន៍ កម្ពស់ ៥០០ យោជន ប្រដាប់ដោយ កំពូល ៨៦០០០ កំពូល វិចិត្រទៅដោយទន្ទេធំ ៥ ខ្សែ ដែលហូរមកដោយជុំវិញ ដែលពោលដោយផ្នែកបណ្ដាយ ទទឹងនិងជ្រៅ មានប្រមាណ ៥០ យោជន៍ រាស់ដោយមូលប្រមាណ ១៥០ យោជន៍ ដែលជាដែលតាំងនៅនៃស្រះធំ ៧ ស្រះ គឺស្រះអនោតត្ត ស្រះកណ្ណមុណ្ឌ: ស្រះរថការ: ស្រះឆទ្ទន្ត: ស្រះកុណាល: ស្រះមន្ទាកិនি និងស្រះសីហប្បបាត: ។ ក្នុងស្រះធំ ៧ ស្រះនោះ ស្រះអនោត្ត: ទ្បោមព័ទ្ធជុំវិញទៅដោយកំពូលបព្ពត: ៥ កំពូលទាំងនេះ គឺកំពូលក្ដុំសុទស្សន: កំពូលក្ដុំចិត្ត: កំពូលក្ដុំកាឡ: កំពូលក្ដុំគន្ធមាទន៍ និងកំពូលក្ដុំកៃលាស ។ បណ្ដាកំពូលក្ដុំ ៥ កំពូលទាំងនោះ កំពូលក្ដុំសុទស្សន: សុទ្ធសឹងដោយមាស កម្ពស់ ៣០០ យោជន៍ ខាងក្នុងគុជ មានទ្រង់ទ្រាយស្រដៀងមាត់ក្អែក តាំងបិទបាំងស្រះនោះឯងទុក ។ កំពូលក្ដុំចិត្ត: សុទ្ធសឹងដោយកែវ ៧ ប្រការ ។ កំពូលក្ដុំកាឡ: សុទ្ធសឹងហើយដោយផ្ការអញ្ជ៉ន ។ កំពូលក្ដុំគន្ធមាទន៍ សុទ្ធសឹងដោយពេជ្រក្ដែកធ្មា ខាងក្នុងមានពណ៌ដូចសណ្ដែកបាយ តាំងរុងរឿង ដូចរងើកភ្លើងដែលឆេះសន្ធោសន្ធៅ ក្នុងថ្ងៃឧបោសថខាងខ្នើត ដែលដេរដាស់ទៅដោយ ឱសថប្រការផ្សេងៗ ច្រើនទៅដោយកូនិន ១០ កូនទាំងនេះ គឺកូនត្រង់ឫស កូនត្រង់ខ្ចីម កូនត្រង់ស្រាយ កូនត្រង់សំបក កូនត្រង់ក្រមរ កូនត្រង់ដើម កូនត្រង់រស កូនត្រង់ផ្ការ កូនត្រង់ផ្លែ និងកូនត្រង់ស្លឹក ។ កំពូលក្ដុំកៃលាស សុទ្ធសឹងទៅដោយ ប្រាក់ ។ កំពូលក្ដុំទាំងអស់នោះ មានទ្រង់ទ្រាយស្មើគ្នា នឹងក្ដុំសុទស្សន: តាំងបិទ បាំងស្រះនោះនុ៎ះឯងទុក ។ បណ្ដាកំពូលក្ដុំទាំងនោះ ក្ងៀងធ្លាក់ដោយទេវានុភាព

និងទឹកហូរដោយនាគានុភាព ។ ទឹកទាំងអស់នោះហូរចូលទៅកាន់ស្រះអនោតត្ត ប៉ុណ្ណោះ ។ ព្រះចន្ទនិងព្រះអាទិត្យ គោចរផ្លូវផ្នែកខាងទិសត្បូង ឬផ្លូវផ្នែកខាងទិសឧត្តរ ធ្វើក្ងីស្ងាងក្នុងទីនោះ ដោយចន្ទោះនៃភ្នំ ។ តែកាលគោចរទៅដោយត្រង់ៗរកធ្វើទេ ។ ព្រោះហេតុនោះឯង ស្រះនោះទើបកើតការរាប់ថា **អនោតត្ត** ។ ក្នុងស្រះអនោតត្តនោះផែនដីនៃមនោសិលា មិនមានត្រីនិងអណ្តើក ដូចកែវ-ផលឹកដែលប្រាសចាកមន្ទិល ទឹកមិនកករណ្ដក់ កើតអំពីកម្មតែម្តង ជាកំពង់សម្រាប់ងូត របស់ពួកសត្វអ្នកប្រើទឹកនោះ ជាទីដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវក ទាំងឥសី អ្នកមានឫទ្ធិ ធ្វើការងូតជាដើម ចំណែកទេវតា និងយក្ខជាដើម ក៏នាំគ្នាលេងទឹក ។ ក្នុងខាងទាំង ៤ របស់ស្រះអនោតត្តនោះ មានផ្លូវទឹកហូរនៅ ៤ ផ្លូវ គឺផ្លូវរាជសីហ៍ ផ្លូវដំរី ផ្លូវសេះ និងផ្លូវគោឧសុភ: ដែលជាហេតុឱ្យទន្ទេទាំង ៤ ហូរទៅ ។ ក្នុងត្រើយទន្ទេដែលហូរចេញចាកផ្លូវរាជសីហ៍ មានរាជសីហ៍នៅជាច្រើន ។ ដោយផ្លូវដំរីជាដើមក៏ដូចគ្នា មានដំរី សេះ និងគោឧសុភ: ជាចំនួនច្រើន ។ មេទឹកដែលហូរចេញពីទិសខាងកើតហូររិលទៅខាងស្តាំ ៣ ជុំវិញ ស្រះអនោតត្ត មិនហូរទៅកាន់ទន្ទេ ៣ ខ្សែ ក្រៅនេះ ហូរទៅផ្លូវដែលមិនមានអ្នកផ្នែកខាងភ្នំហិមពាន្តទិសខាងកើតនោះឯង ហើយហូរចូលមហាសមុទ្រ ។ ចំណែកមេទឹកដែលហូរចេញពីទិសខាងលិច និងទិសឧត្តរ ហូររិលទៅខាងស្តាំយ៉ាងនោះដូចគ្នា ហូរទៅផ្លូវដែលមិនមានអ្នកផ្នែកខាងភ្នំហិមពាន្តទិសខាងលិច និងទិសឧត្តរដូចគ្នា ហើយហូរចូលមហាសមុទ្រ ។ ចំណែកមេទឹកដែលហូរពីផ្លូវទិសត្បូង ហើយហូររិលទៅខាងស្តាំ ៣ ជុំវិញស្រះអនោតត្តនោះ ហូរទ្រង់ទៅផ្លូវទិសត្បូងដំបូលថ្មក្រាលនោះឯងបាន ៦០ យោជន៍ ហើយប៉ះភ្នំបាញ់ឡើងជា

ខ្សែទឹកប្រមាណ ៣ គាវុតដោយជុំវិញ ហូរទៅផ្លូវអាកាស ៦០ យោជន៍ហើយ ក៏ធ្លាក់ចុះត្រង់ថ្មក្រាល ឈ្មោះ **តិយង្គលៈ** ។ ថ្មក្រាលបែកចេញ ព្រោះកម្ទាំងខ្សែទឹក ។ ក្នុងទីនោះ កើតជាស្រះបោក្ខរណីធំ ឈ្មោះ តិយង្គលៈ មានប្រមាណបាន ៥០ យោជន៍ ។ ធ្លាយច្រាំងស្រះបោក្ខរណី ហូរចូលថ្មក្រាលហូរទៅបាន ៦០ យោជន៍ អំពីនោះក៏ធ្លាយផែនដីចោះជាឧម្មគ្គបាន ៦០ យោជន៍ប៉ះខ្ទប់ភ្នំដែលតាំងទទឹង ឈ្មោះថា វិជណៈ កើតជាទន្ទេ ៥ ខ្សែ ដូចនឹងធ្នាប់ ៥ ធ្នាប់ដែលបាតដៃ ។ ក្នុងទីដែលហូរទៅហូរទៅ រិលទៅខាងស្តាំស្រះអនោតត្ត ទន្ទេនោះហៅថា **អាវត្តគង្គា** ។ ក្នុងទីដែលហូរទៅទ្រង់ផ្លូវខ្នងថ្មក្រាល ប្រមាណ ៦០ យោជន៍ ហៅថា **កណ្ណគង្គា** ។ ក្នុងទីដែលហូរទៅផ្លូវអាកាស ប្រមាណ ៦០ យោជន៍ ហៅថា **អាកាសគង្គា** ។ ដែលឃាំងនៅលើថ្មក្រាល ឈ្មោះ **តិយង្គលៈ** មានឱកាសប្រមាណបាន ៥០ យោជន៍ ហៅថា **តិយង្គលបោក្ខរណី** ។ ក្នុងទីដែលធ្លាយត្រើយហូរទៅកាន់ថ្មក្រាលបានប្រមាណ ៦០ យោជន៍ ហៅថា **ពហ-លគង្គា** ។ ក្នុងទីដែលប៉ះខ្ទប់ភ្នំទីតាំងទទឹងឈ្មោះថា **វិជណៈ** កើតជា ៥ ខ្សែ ពាប់ជា ៥ ខ្សែ គឺ**ទន្ទេគង្គា យមុនា អចិរវតី សរភូ និងមហី** ។ ទន្ទេ ៥ ខ្សែទាំងនេះ ដូចពោលមកនេះ គប្បីជ្រាបថា ហូរចេញចាកភ្នំហិមពាន្ត ។ បណ្តាបទទាំងនោះ ពាក្យថា **ឧទី និន្នា** ដូច្នេះជាដើម ចាត់ជាគោត្រ ។ ពាក្យថា **គង្គា យមុនា** ដូច្នេះជាដើម ចាត់ជាឈ្មោះ ។

បទថា **សវន្តិយោ** បានដល់ ទន្ទេធំ ឬមេទឹកតិចប្រភេទណាមួយ ដែលហូរទៅ ។ បទថា **អឃ្សេន្តិ** ប្រែថា រមែងហូរទៅ គឺរមែងហូររួមគ្នាទៅ ។ បទថា

ជាវ បានដល់ ភ្ជៀង ។ បទថា **ឋ្ងវត្ថំ** ប្រែថា សេចក្ដីដែលខ្សែភ្ជៀងឃាំងពេញ ។ មែនពិត មហាសមុទ្រជាធម្មតាតទៅនេះ អ្នកណាៗមិនអាចនឹងពោលមហា-សមុទ្រនោះថា ក្នុងវេលានេះភ្ជៀងធ្លាក់តិច ពួកយើងកាន់យកគ្រឿងអន្ទាក់សត្វ មានសំណាញ់ និងទ្រូជាដើម ចាប់យកត្រីនិងអណ្ដើក ឬថាក្នុងវេលានេះ ភ្ជៀងមានច្រើនពេកទៅ ពួកយើងមិនបានស្ថានទីជាទីទម្រេតខ្ជង ។ មែនពិត តាំងតែវេលាបឋមកប្បមក ភ្ជៀងធ្លាក់ទឹកឃាំងទល់នឹងដែនភ្នំសិនេរុ អំពីនោះទឹកសូម្បីប្រមាណមួយអង្គុលី ក៏ហូរចុះខាងក្រោមឡើយ មិនហូរឡើងខាងលើ ។

បទថា **ឯការសោ** បានដល់ មានរសមិនលាយ ។ បទថា **មុត្តា** បានដល់ កែវមុក្តាច្រើនប្រភេទ មានប្រភេទតូចធំមូល និងវែងជាដើម ។ បទថា **មណិ** បានដល់ កែវមណីច្រើនប្រភេទ មានប្រភេទក្រហម និងខៀវជាដើម ។ បទថា **វេឬរិយោ** បានដល់ កែវពិទូរ្យច្រើនប្រភេទ ដោយសណ្ឋានមានពណ៌ឫស្សី និងពណ៌ផ្ការ្ចេសជាដើម ។ បទថា **សង្ខោ** បានដល់ ស័ង្ខច្រើនប្រភេទ មានប្រភេទស័ង្ខទក្ខិណាវដ្ដ ស័ង្ខផ្ទៃក្រហម និងស័ង្ខសម្រាប់ផ្ដុំជាដើម ។ បទថា **សិលា** បានដល់ សិលាច្រើនប្រភេទ មានប្រភេទពណ៌ស ខ្មៅ និងពណ៌សណ្ដែកបាយជាដើម ។ បទថា **បវាឡំ** បានដល់ កែវប្រវាឡច្រើនប្រភេទ មានប្រភេទតូចធំ ក្រហមខ្ចី និងក្រហមចាស់ជាដើម ។ បទថា **លោហិតង្គំ** បានដល់ ត្បូងទន្ទឹមច្រើនប្រភេទ មានប្រភេទបទុមរាគជាដើម ។ បទថា **មសារគ្លំ** បានដល់ កែវធ្ងូត (ពេជ្រភ្នែកធ្មា) ។ អាចារ្យពួកខ្លះពោលថា **ចិត្តផលិកំ** កែវផលឹកដែលល្អវិចិត្រ ដូច្នេះក៏មាន ។

បទថា **មហាតំ ភូតានំ** បានដល់ សត្វធំ ។ ត្រី ៣ ប្រភេទ គឺត្រីតិមិ ១

ត្រីតិមិង្គិលៈ ១ ត្រីតិមិតិង្គិលៈ ១ ។ ត្រីដែលអាចនឹងលេបស៊ីត្រីតិមិ ឈ្មោះថា ត្រីតិមិង្គិលៈ ។ បទថា **ជាតា** បានដល់ នាគដែលនៅលើខ្នងរលកខ្លះ នាគដែលនៅក្នុងវិមានខ្លះ ។

ដោយបទថា **ឯវមេវ ខោ** ព្រះសាស្តា ទ្រង់អាចដើម្បីនឹងសម្តែងចែកអច្ឆរិយអព្ភុតធម៌ ១៦ ខ្លះ ៣២ ខ្លះ ក្រៃលែងជាងនោះខ្លះ ក្នុងព្រះធម្មវិន័យនេះ ក៏ពិត ទោះជាយ៉ាងនោះ កាលទ្រង់សម្តែងចែកធម៌ ដែលគួរនឹងគប្បីឧបមាទាំងនោះ ត្រឹមតែ ៨ យ៉ាង ដោយសមគួរដល់អត្ត ដែលកាន់យកដោយសេចក្តីជាឧបមាក្នុងខណៈនោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថាយ៉ាងនោះនុ៎ះឯង ភិក្ខុទាំងឡាយអច្ឆរិយអព្ភុតធម៌ ៨ យ៉ាង រមែងមានក្នុងធម្មវិន័យនេះ ដូច្នេះ ។

ក្នុងធម៌ទាំងនោះ លោកកាន់យកសិក្ខា ៣ ដោយ អនុបុព្វសិក្ខា ការសិក្សាទៅតាមលំដាប់ ។ ធុតង្គធម៌ ១២ កាន់យកដោយអនុបុព្វកិរិយា ការធ្វើទៅតាមលំដាប់ ។ អនុបស្សនា ៧ មហាវិបស្សនា ១៨ ការចែកអារម្មណ៍ ៣៨ និងពោធិបក្ខិយធម៌ ៣៨ លោកកាន់យកដោយអនុបុព្វបដិបទា ការបដិបត្តិទៅតាមលំដាប់ ។ បទថា **ជាយតេកេនេវ អញ្ញាបដិវេធោ** សេចក្តីថា ធម្មតាការមិនធ្វើសីលជាដើមឱ្យបរិបូណ៌ តាំងពីដើមមកហើយចាក់រហូតអស់ព្រះអរហត្ត រមែងមិនមាន ដូចការទៅកើតឡើងនៃមណ្ឌុកទេវបុត្រ ដូច្នោះ ចំណែកការធ្វើសីល សមាធិ និងបញ្ញាឱ្យបរិបូណ៌ទៅតាមលំដាប់មុនហើយ ទើបសម្រេចព្រះអរហត្តបានរមែងមាន ។

ដោយបទថា **មម សាវកា** ព្រះអង្គត្រាស់សំដៅដល់ព្រះអរិយបុគ្គល

មានព្រះសោតាបន្នជាដើម ។ បទថា **ន សំវសតិ** *បានដល់ រមែងមិនធ្វើសំវាស ដោយអំណាចឧបោសថកម្មជាដើម ។ បទថា* **ឧក្ខិបតិ** *ប្រែថា រមែងច្រានលួចចេញទៅ ។ បទថា* **អារកា រ** *បានដល់ ក្នុងទីឆ្ងាយនុ៎ះឯង ។ បទថា* **ន តេន និព្ពានជាតុយា ន ត្តំ ភ ឋ្ងត្តំ ភ** *សេចក្តីថា អ្នកណាៗ មិនអាចនឹងពោលថា សូម្បីកាលកប្ប មិនទាន់អស់ទៅ ព្រះពុទ្ធទាំងឡាយ មិនទាន់ស្តេចឧប្បត្តិ សូម្បីសត្វម្នាក់ ក៏មិនអាចនឹងបរិនិព្វានបាន សូម្បីក្នុងកាលនោះ ក៏មិនអាចនឹងនិយាយថា និព្វានជាតុជាក់តែក្នុងគ្រាពុទ្ធកាល សត្វទាំងឡាយ សូម្បីរាប់មិនបានក្នុងសមាគមមួយៗ ក៏នាំគ្នាត្រេកអរផឹកអមតធម៌ សូម្បីក្នុងកាលនោះ អ្នកណាៗ ក៏មិនអាចនឹងនិយាយបានថា និព្វានជាតុពេញ ។ បទថា* **វិមុត្តិរសោ** *ប្រែថា មានការរួចផុតពីកិលេសជារស ។ មែនពិត សាសនសម្បត្តិទាំងអស់ រមែងតាំងនៅត្រឹមតែដើម្បីចិត្តរួចផុតពីអាសវៈទាំងឡាយព្រោះមិនប្រកាន់មាំ ។*

បទថា **រតនានិ** *សេចក្តីថា ឈ្មោះថា រតនៈ ព្រោះអត្ថថា ឱ្យកើតសេចក្តីត្រេកអរ ។ មែនពិត កាលចម្រើនសតិប្បដ្ឋានជាដើម បីតិ និងបាមោជ្ជៈ មានប្រមាណមិនតិច រមែងកើតក្នុងចំណែកខាងដើម ។ ក្នុងចំណែកខាងចុង មិនត្រូវពោលដល់ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា*

ព្រះយោគី រមែងពិចារណាឃើញការកើត និងការរលត់នៃខន្ធទាំងឡាយ ក្នុងកាលណាៗ ក្នុងកាលនោះៗ លោករមែងបានបីតិ និងបាមោជ្ជៈនោះជាអមតៈរបស់អ្នកដឹងច្បាស់ ។

ក៏បីតិ និងបាមោជ្ជៈដែលមានលោកិយរតនៈជាហេតុ រមែងមិនដល់ចំណែកនៃចំរៀករបស់អមតធម៌នោះ អត្ថដូចថា មកនេះលោកសម្តែងទុកក្នុងកាលក្រោយ

ហើយឯង ម្យ៉ាងទៀត

វត្ថុដែលធម្មតាធ្វើឱ្យវិចិត្រ មានតម្លៃច្រើនរកដែលប្រៀបផ្ទឹមបែបមិនបាន ឃើញបានលំបាកជាគ្រឿងប្រើប្រាស់របស់សត្ត្ব អ្នកមិនក្រាមខ្សោយ លោកហៅថា រតនៈឯង ។

ក៏បើឈ្មោះថា រតនៈ រមែងបានដោយការៈដែលធម្មតាធ្វើឱ្យវិចិត្រជាដើមសោត ដល់យ៉ាងនោះ សតិប្ឋានជាដើមនោះឯង ក៏ជារតនៈបាន ព្រោះជារបស់មាននៅពិត មែនពិត ការៈនៃសតិប្ឋានជាដើមនោះ ជាអានុភាពរបស់ពោធិបក្ខិយធម៌ ព្រោះជាហេតុជិតដែលធ្វើឱ្យព្រះសាវកសម្រេចសាវកបារមីញាណ ព្រះបច្ចេកពុទ្ធសម្រេចបច្ចេកពោធិញាណ ព្រះសម្មាសម្ពុទ្ធសម្រេចព្រះសម្ម-សម្ពោធិញាណ ។ មែនពិត ហេតុដែលបន្ត១ គ្នាមកជាឧបនិស្សយនៃទានជាដើម រួមសេចក្ដីថា សតិប្ឋានជាដើមជារតនៈជាសេចក្ដីល្អក្រៃលែងនៃពោធិ-បក្ខិយធម៌ ព្រោះអត្ថថា ធ្វើឱ្យកើតសេចក្ដីត្រេកអរ និងព្រះអត្ថថា ជារបស់ដែលធម្មតាធ្វើឱ្យវិចិត្រ ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា ក្នុងធម៌ទាំងនោះ រតនៈទាំងនេះ គឺសតិប្ឋាន ៤ ។

បណ្ដាធម៌ទាំងនោះ ឈ្មោះថា **ឋាន** ព្រោះអត្ថថា ធ្លាក់ចុះប្រាកដក្នុងអារម្មណ៍ កម្មផ្ដើមដំបូង គឺសតិ ឈ្មោះថា **សតិប្ឋាន** ។ ក៏ព្រោះអារម្មណ៍មាន ៤ យ៉ាង ដោយអំណាចកាយជាដើម លោកទើបពោលថា សតិប្ឋាន ៤ ។ ពិតយ៉ាងនោះសតិប្ឋាន ៤ ទាំងនោះ លោកចែកចេញជាកាយានុបស្សនាជាដើម ព្រោះលះសេចក្ដីសម្គាល់ក្នុងកាយថា ល្អ វេទនាថាជា សុខ ចិត្តថា ជា

របស់ទៀង និងក្នុងធម៌ថាជាអត្តា និងព្រោះប្រកាន់ក្នុងកាយថា ជារបស់មិនល្អ ក្នុងវេទនាថា ជាទុក្ខក្នុងចិត្តថា ជារបស់មិនទៀង និងក្នុងធម៌ថា ជាអនត្តា ។

ឈ្មោះថា **សម្មប្បធាន** *ព្រោះជាហេតុ ឱ្យព្រះយោគីផ្តើមតាំងដោយប្រពៃ ឬថាខ្លួនឯងផ្តើមតាំងដោយប្រពៃ ឬការផ្តើមតាំងដែលបណ្ឌិតសរសើរឬជាសេចក្តីល្អ ។ ម្យ៉ាងទៀត ឈ្មោះថា* **សម្មប្បធាន** *ព្រោះជាហេតុ ឱ្យបុគ្គលធ្វើសេចក្តីព្យាយាមដោយប្រពៃនោះឯង ពាក្យថា សម្មប្បធាននេះជាឈ្មោះរបស់វីរិយៈសេចក្តីព្យាយាម ។ ក៏សម្មប្បធានសេចក្តីព្យាយាមនោះ ក៏ហៅថាសម្មប្ប-ធាន ៤ ព្រោះធ្វើកិច្ច ៤ យ៉ាង គឺមិនឱ្យអកុសលធម៌ដែលមិនទាន់កើត មិនឱ្យកើតឡើង ១ លះអកុសលធម៌ដែលកើតឡើង ១ ធ្វើកុសលធម៌ដែលនៅមិនកើតឱ្យកើតឡើង ១ ធ្វើកុសលធម៌ដែលកើតឡើងហើយឱ្យចម្រើន ១ ។*

ឈ្មោះថា ឫទ្ធិ ព្រោះអត្ថថា សម្រេច អធិប្បាយថា សំរិទ្ធិ គឺបញ្ចេញផល ។ ម្យ៉ាងទៀត ឈ្មោះថា ឫទ្ធិ ព្រោះជាហេតុសម្រេច គឺសំរិទ្ធិចម្រើនដល់សេចក្តីខ្ពស់បំផុតនៃសត្វទាំងឡាយ ។ ដោយអត្ថដំបូងបាទ គឺសេចក្តីសម្រេច ឈ្មោះថា ឥទ្ធិបាទ អធិប្បាយថា ចំណែកនៃសេចក្តីសម្រេច ។ ដោយអត្ថទី ២ បាទគឺទីតាំងបានដល់ ឧបាយជាគ្រឿងសម្រេចដល់សេចក្តីសម្រេច ព្រោះហេតុនោះ ទើបឈ្មោះថា **ឥទ្ធិបាទ** *។ មែនពិត សត្វទាំងឡាយ រមែងដល់ គឺសម្រេចសេចក្តីសម្រេច ពោលគឺ គុណវិសេសខ្ពស់ៗ ឡើងទៅដោយឥទ្ធិបាទនោះ ។ ឥទ្ធិបាទនេះ នោះលោកហៅថា ឥទ្ធិបាទ ៤ ព្រោះធ្វើអធិបតីធម៌ ៤ មានឆន្ទាធិបតីជាដើម ឱ្យជាធុរៈ គឺឱ្យជាធំកើតឡើង ។*

បទថា **បញ្ចិន្ទ្រិយានិ** *បានដល់ ឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ។ ក្នុង*

ឥន្ទ្រិយ ៥ នោះ សទ្ធា ឈ្មោះថា **ឥន្ទ្រិយ** ព្រោះគ្របសង្កត់ភាពជាអ្នកមិនមានសទ្ធា ហើយធ្វើឱ្យជាធំក្នុងលក្ខណៈនៃការបង្អោនចិត្តជឿ ។ បញ្ញា ឈ្មោះថា ឥន្ទ្រិយ ព្រោះគ្របសង្កត់កោសជ្ជៈហើយធ្វើឱ្យជាធំក្នុងលក្ខណៈនៃការផ្គងទុក គ្របសង្កត់បមាទៈហើយធ្វើឱ្យជាធំ ក្នុងលក្ខណៈប្រាកដគ្របសង្កត់សេចក្តីរវើរវាយ ហើយធ្វើឱ្យជាធំ ក្នុងលក្ខណៈនៃសេចក្តីមិនរវើរវាយ គ្របសង្កត់សេចក្តីមិនដឹង ហើយធ្វើឱ្យជាធំក្នុងលក្ខណៈនៃទស្សនៈ ឥន្ទ្រិយ ៥ ទាំងនោះឯង គប្បីជ្រាបថា ពលៈ ព្រោះភាពជាធម្មជាតិរឹងមាំក្នុងសម្បយុត្តធម៌ទាំងឡាយ ដោយអត្ថថា មិនញាប់ញ័រ ដោយភាពមិនមានសទ្ធាជាដើមគ្របសង្កត់មិនបាន ។

បទថា **សត្ត** ពោជ្ឌង្គា សេចក្តីថា **ពោជ្ឌង្គៈ** ព្រោះអត្ថថា ជាអង្គនៃធម្ម-សាមគ្គីជាគ្រឿងត្រាស់ដឹង ឬរបស់បុគ្គលដែលត្រាស់ដឹង ។ ព្រះអរិយសាវកមានត្រាស់ដឹង គឺចេញចាកកិលេសនិទ្រា គឺចាក់រហូតអស់អរិយសច្ចៈ ៤ ឬធ្វើឱ្យច្បាស់ចំពោះព្រះនិព្វាន ដោយធម្មសាមគ្គីណា ពោលគឺ **សតិ ធម្មវិចយៈ វីរិយៈ ปีติ ปัสสัทธิ សមាធិ** និង**ឧបេក្ខា** ដែលជាបដិបក្ខចំពោះអន្តរាយជាអនេកដូចការតាំងនៅ និងការប្រមូលមកនូវសេចក្តីរួញរា និងសេចក្តីហុយជ្រួតជ្រាប ការប្រកបក្នុងកាមសុខល្វិកានុយោគ និងអត្តកិលមថានុយោគ និងការប្រកាន់មាំនូវទេ្ធទិដ្ឋិ និងសស្សតទិដ្ឋិជាដើម ដែលកើតឡើងក្នុងខណៈលោកុត្តរមគ្គ ព្រោះហេតុនោះ ធម្មសាមគ្គីនោះ លោកហៅថា **ពោធិ** ឈ្មោះថា ពោជ្ឌង្គ ព្រោះជាអង្គនៃពោធិ ពោលគឺ ធម្មសាមគ្គីនោះខ្លះ ដូចអង្គរបស់ឈាន និងអង្គរបស់មគ្គជាដើម ។ ឈ្មោះថា **ពោជ្ឌង្គៈ** សូម្បីព្រោះជាអង្គនៃព្រះអរិយសាវកអ្នកត្រាស់ដឹងដែលហៅថា **ពោធិ** ព្រោះវិគ្រោះថា ត្រាស់ដឹងដោយធម្មសាមគ្គី

មានប្រការដូចពោលហើយ ដូចអង្គ្ករបស់សេនា និងអង្គ្ករបស់រថជាដើម ។ ព្រោះហេតុនោះ ព្រះបោរាណាចារ្យទាំងឡាយ ទើបពោលថា ឈ្មោះថា **ពោជ្ឌង្គ:** *ព្រោះជាអង្គ្ករនៃបុគ្គលដែលត្រាស់ដឹង គឺប្បីជ្រាបអត្ថនៃពោជ្ឌង្គ: សូម្បីដោយន័យមានជាអាទិ៍ថា ឈ្មោះថា* **ពោជ្ឌង្គ:** *ព្រោះប្រព្រឹត្តទៅដើម្បីធម៌ ។ សាមគ្គីជាគ្រឿងត្រាស់ដឹង ដូច្នេះ ។*

បទថា **អរិយោ អដ្ឋង្គិកោ មគ្គោ** *សេចក្ដីថា ឈ្មោះថា* **អរិយ:** *ព្រោះធ្វាយចាកកិលេសដែលមគ្គនោះ។ គឺប្បីសម្ងាប់ ព្រោះធ្វើសេចក្ដីជាព្រះអរិយ: និងព្រោះឱ្យបានអរិយផល ។ ឈ្មោះថា* **អដ្ឋង្គិក:** *ព្រោះមគ្គនោះមានអង្គ ៨ មានសម្មាទិដ្ឋិជាដើម ម្យ៉ាងទៀត អង្គ ៨ នុ៎ះឯង ឈ្មោះថា* **អដ្ឋង្គិក:** *។ ឈ្មោះថា* **មគ្គ** *ព្រោះសម្ងាប់កិលេសទាំងឡាយឱ្យស្ងាប់ទៅ ឬព្រោះអ្នកត្រូវការព្រះនិព្វានស្វែងរក ឬខ្ជួនឯងស្វែងរកព្រះនិព្វាន ។ គឺប្បីជ្រាបការចែកអត្ថដល់សតិប្ឋានជាដើមទាំងនោះយ៉ាងនេះ ដោយប្រការដូច្នេះ ។*

បទថា **សោតាបន្នោ** *បានដល់ ព្រះអរិយបុគ្គលដែលចាស់ គឺសម្រេចក្រសៃពោលគឺ មគ្គតាំងនៅ អធិប្បាយថា អ្នកតាំងនៅក្នុងសោតាបត្តិផល ។ បទថា* **សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ** *បានដល់ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងបឋមមគ្គ អ្នកកំពុងបដិបត្តិ ដើម្បីធ្វើសោតាបត្តិផលឱ្យប្រចក្សដល់ខ្ជួន ដែលហៅព្រះអរិយបុគ្គលទី ៨ ដូច្នេះក៏មាន ។ បទថា* **សកទាគামី** *បានដល់ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងផលទី ២ អ្នកនឹងមកកាន់លោកនេះ គ្រាតែមួយប៉ុណ្ណោះ ដោយការកាន់បដិសន្ធិ ។ បទថា* **អនាគামី** *បានដល់ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងផលទី ៣ អ្នកមានប្រក្រតីមិនមកកាន់កាមលោកដោយការកាន់បដិសន្ធិ ។ ក៏ការចែកព្រះអរិយបុគ្គលមានជាអាទិ៍យ៉ាងនេះថា*

សទ្ធានុសារី ១ ធម្មានុសារី ១ ឯកពីជី ១ ជាប្រភេទរបស់ព្រះអរិយបុគ្គលទាំងនោះនុ៎ះឯង ។ ពាក្យដែលនៅសល់មានន័យដូចពោលហើយឯង ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបសេចក្តីពោលគឺ សេចក្តីមិនមានធម៌ជាគ្រឿងនៅរួមគ្នា នឹងបុគ្គលទ្រុស្តសីលអ្នកប្រដូចសាកសពសត្វស្លាប់ក្នុងព្រះធម្មវិន័យរបស់ព្រះអង្គនេះ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ទ្រង់បន្ទឺឧទាននេះដែលសម្តែងហេតុនៃការចែកបុគ្គលដែលមិនគួរនៅរួម និងអ្នកគួរនៅរួម ។*

បណ្តាបទទាំងនោះ បទថា **ឆន្ទមតិវស្សតិ** *សេចក្តីថា ភិក្ខុត្រូវអាបត្តិហើយបិទបាំងទុក រមែងត្រូវអាបត្តិដទៃថ្មីទៀត រមែងត្រូវអាបត្តិច្រើនឡើងៗ ក្ងៀង គឺអាបត្តិ បានដល់ ក្ងៀង គឺកិលេស រមែងរួតរឹតច្រើនឡើងយ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា* **វិវដំ ជានិវស្សតិ** *សេចក្តីថា ភិក្ខុអ្នកត្រូវអាបត្តិហើយមិនបិទបាំងអាបត្តិនោះទុក បើកប្រកាសដល់មិត្តសព្រហ្មចារី ធ្វើសង សម្តែងចេញ (ពីអាបត្តិ) តាមធម៌ តាមវិន័យមិនត្រូវអាបត្តិដទៃថ្មី ព្រោះហេតុនោះ ក្ងៀង គឺអាបត្តិ ក្ងៀង គឺកិលេស ដែលភិក្ខុនោះបើកផ្សាយហើយ រមែងមិនរួតរឹតទៀត ក៏ព្រោះហេតុដែលប្រការនោះជាយ៉ាងនោះ ព្រោះដូច្នោះ លោកទាំងឡាយគប្បីបើក គឺប្រកាសអាបត្តិដែលបិទ គឺដែលបិទបាំងទុក ។ បទថា* **ឯវន្តំ ជានិ-វស្សតិ** *សេចក្តីថា កាលបើយ៉ាងនោះ ក្ងៀង គឺកិលេស រមែងមិនទម្ងាយអត្ត-ភាពហើយរួតរឹត គឺមិនសើមបុគ្គលដែលត្រូវអាបត្តិនោះ ។ អធិប្បាយថា បុគ្គលនោះមិនត្រូវកិលេសរួតរឹតយ៉ាងនោះ ជាអ្នកមានសីលបរិសុទ្ធមានចិត្តមាំ ផ្តើមតាំងវិបស្សនាពិចារណានៅ រមែងសម្រេចដល់ព្រះនិព្វានដោយលំដាប់ ។*

បញ្ចមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៥

សម្រាប់ជាធម្មទាន

៦. សោណសុត្តវណ្ណនា

អដ្ឋកថាសោណសូត្រ

សោណសូត្រទី ៦ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **អវន្ត្តីសុ** *បានដល់ ក្នុងអវន្ទីរដ្ឋ ។ បទថា* **ការុ** យ*ោ* *បានដល់ នគរដែលមានឈ្មោះយ៉ាងនោះ ។ បទថា* **ឧ**ត្ត*ោ* **ឧ**ត*ោ* *បានដល់ ភ្នំដែលឈ្មោះថា* **ឧ**ត្ត*ៈ* *អាចារ្យខ្ទះពោលថា* **ឧ**ចាត*ោ* **ឧ**ត*ោ* *ដូច្នេះដ៏មាន ។ បទថា* **សោ**ណ*ោ* **ឧ**ចាសក*ោ* **ការ**ណ្ណ*ោ* *សេចក្ដីថា ដោយនាមឈ្មោះថា សោណៈ ឈ្មោះថា* ***ឧ**ចាសក* *ព្រោះប្រកាសភាពជាឧបាសកដោយការដល់សរណៈ ៣ ព្រោះទ្រទ្រង់គ្រឿងប្រដាប់ត្រចៀកមានតម្លៃមួយកោដិ ទើបហៅថា* ***ការ**ណ្ណ*ៈ *តែគេស្គាល់ច្រើនគ្នាថា* ***ការ**ណ*ៈ *អធិប្បាយថា សោណៈជាក្មេងល្អ*[1] *។*

ក៏សោណៈឧបាសកនោះ ស្ដាប់ធម៌ក្នុងសម្ងាត់របស់ព្រះមហាកច្ចាយនៈដ៏មានអាយុ ជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះសាសនា តាំងនៅក្នុងសរណៈ និងសីល ទើបចាត់គេឱ្យសាងវិហារក្នុងទីដែលសម្បូរដោយម្ទប់ និងទឹកជិតបវត្តបព្ពតៈ ហើយនិមន្តព្រះថេរៈឱ្យនៅក្នុងវិហារនោះ ទំនុកបម្រុងដោយបច្ច័យទាំង ៤ ។ ព្រោះហេតុនោះ លោកទើបពោលថា ជាឧបដ្ឋាករបស់ព្រះមហាកច្ចានៈដ៏មានអាយុ ។ សោណឧបាសកនោះទៅកាន់ទីទំនុកបម្រុងរបស់ព្រះថេរៈតាមវេលាដែលសមគួរ ទាំងព្រះថេរៈក៏បានសម្ដែងធម៌ដល់គាត់ ។ ព្រោះហេតុនោះ សោណៈនោះ ទើបមានសេចក្ដីតក់ស្ទុតយ៉ាងក្រៃលែង កើតសេចក្ដីឧស្សាហ៍ក្នុងការប្រព្រឹត្តធម៌ ។ ត្រាមួយ សោណឧបាសកបានទៅក្រុងឧជ្ជេនីជាមួយនឹងពួករទេះ ដើម្បីធ្វើជំនួញ កាលសម្រាកពួករទេះទុកសោណៈនោះចោលក្នុងព្រៃ

១-ក្នុងអដ្ឋកថាច្បាប់ធម្មសង្គ្រាយនាបានពោលថា សោណៈជាអ្នកមានសុខមាលភាពមិនល្អ ។

ត្រង់ចន្លោះផ្លូវនោះ ព្រោះភ័យពីការបៀតបៀនរបស់ជនទាំងឡាយ ក្នុងពេលរាត្រីកន្លែងដ៏សមគួរមួយ ។ ក្នុងវេលាជិតភ្លឺ ពួកអ្នករទេះក៏ក្រោកចេញទៅ សូម្បីមួយនាក់ក៏មិនបានដាស់ឱ្យសោណឧបាសកភ្ញាក់ អ្នកសូម្បីទាំងអស់មិនបាននឹកដល់សោណៈនោះ ក៏បាននាំគ្នាចេញទៅ ។ កាលរាត្រីភ្លឺហើយ សោណ-ឧបាសកនោះភ្ញាក់ពីដេក ហើយក្រោកឡើងមិនឃើញអ្នកណាឡើយ ទើបកាន់យកផ្លូវដែលពួករទេះនុ៎ះឯងទៅ កាលដើរទៅដោយប្រញាប់ប្រញាល់ ក៏ទៅដល់ដើមជ្រៃមួយដើម ។ ក្នុងទីនោះ សោណឧបាសកបានឃើញបុរសម្នាក់មានពាងកាយធំសម្បើម មានអាការប្ញែក កំពុងទំពាស៊ីសាច់របស់ខ្លួនដែលជ្រុះពីឆ្អឹងដោយខ្លួនឯង ទើបសួរថា លោកជាអ្នកណា?

ប. នែលោកដ៏ចម្រើន ខ្ញុំជាប្រេត ។

សោ. ព្រោះហេតុអ្វី លោកទើបធ្វើយ៉ាងនេះ?

ប. ព្រោះបុព្វកម្មរបស់ខ្លួនឯង ។

សោ. ក៏កម្មនោះជាកម្មអ្វី? ប្រេតដំណាលថា កាលជាតិមុន ខ្ញុំជាឈ្មួញកោងនៅក្នុងក្រុងភារុកច្ឆនគរ បញ្ឆោតបន្ទំយករបស់អ្នកដទៃមកទំពាស៊ី និងកាលសមណៈចូលទៅបិណ្ឌបាត ក៏ជេរថា ចូរទំពាស៊ីសាច់របស់ខ្លួនឯងទៅ ព្រោះកម្មនោះ ខ្ញុំទើបបានសោយទុក្ខនេះក្នុងឥឡូវនេះ ។ សោណឧបាសកបានស្តាប់ដូច្នោះហើយ ទើបបានចំពោះនូវសេចក្តីតក់ស្លុតយ៉ាងខ្លាំងក្លា ។

តពីនោះ កាលដើរទៅជួបកូនប្រេត ២ រូប ខ្លួនមានលោហិតខ្ចៅហូរចេញតាមមាត់ ទើបសួរដូចមុនទៀត ។ ចំណែកប្រេតទាំងនោះ ក៏បានប្រាប់កម្មរបស់

ខ្ជួនដល់សោណៈនោះ ។ បានឮថា ក្នុងកាលនៅពីក្មេង ប្រេតទាំងនោះចិញ្ចឹមជីវិតដោយការធ្វើជំនួញវត្ថុ ក្នុងការុកច្ចនគរ កាលមាតារបស់ខ្ជួននិមន្តព្រះខីណាស្រពទាំងឡាយ ឱ្យមកធាន់ ទើបទៅកាន់ផ្ទះ ហើយជេរថា ហេតុដូចម្តេច បានជាម៉ែទើបឱ្យវត្ថុរបស់ពួកយើងចំពោះពួកសមណៈ សូមឱ្យលោហិតខ្ទៅហូរចេញតាមមាត់របស់ពួកសមណៈ អ្នកបរិភោគភោជន ដែលម៉ែឱ្យហើយចុះ ។ ព្រោះកម្មនោះ ក្មេងទាំងនោះ ទើបធ្លាក់ក្នុងនរក ហើយក៏កើតក្នុងកំណើតប្រេតដោយសេសសល់នៃវិបាករបស់កម្មនោះ ទើបសោយទុក្ខយ៉ាងនេះក្នុងកាលឥឡូវនេះ ។ សោណឧបាសក ស្តាប់ពាក្យសូម្បីនោះ បានកើតសេចក្តីតក់ស្ទុតយ៉ាងក្រៃលែង ។

សោណឧបាសកនោះ គ៏ធ្វើដំណើរទៅកាន់ក្រុងឧជ្ជេនី ត្រួតពិនិត្យដល់ការងារដែលខ្ជួននឹងគប្បីធ្វើនោះហើយ ទើបត្រឡប់មកកាន់ផ្ទះប្រចាំត្រកូលចូលទៅរកព្រះថេរៈ បានទទួលការបដិសណ្ឋារៈ ហើយទើបប្រាប់សេចក្តីនោះដល់ព្រះថេរៈ ។ ចំណែកព្រះថេរៈ កាលនឹងប្រកាសទោសក្នុងការកើតទុក្ខ និងអានិសង្សក្នុងការរលត់ទុក្ខ ដល់សោណឧបាសកនោះ ទើបសម្តែងធម៌ ។ សោណឧបាសកថ្វាយបង្គំព្រះថេរៈ ហើយទៅផ្ទះបរិភោគអាហារពេលល្ងាច ហើយទើបចូលដេក គ្រាន់តែលក់ទៅមួយស្របក់ប៉ុណ្ណោះ ក៏ភ្ញាក់ឡើងអង្គុយលើទីដេក ហើយផ្តើមពិចារណាធម៌តាមដែលខ្ជួនបានស្តាប់មក ។ កាលលោកពិចារណាធម៌នោះ និងរឭកដល់អត្តភាពរបស់ប្រេតទាំងនោះ សង្ហរទុក្ខប្រាកដជារបស់គួរខ្ជាចយ៉ាងក្រៃលែងណាស់ ។ ចិត្តក៏បង្អោនទៅក្នុងបព្វជ្ជា ។ កាលរាត្រីកន្ទងទៅហើយ សោណៈជម្រះកាយសម្រេច ហើយចូលទៅរក

ព្រះថេរៈ ប្រកាសអធ្យាស្ស័យរបស់ខ្លួនហើយសូមបព្វជ្ជា ។ ព្រោះហេតុនោះ លោកទើបពោលថា **អថខោ សោណស្ស ឧចាសកស្ស កោដិកណ្ណ-ស្ស រហោគតស្ស ។ ល ។ បព្វជេយ្យន្តិ បព្វាជេតុ មំ ភន្តេ អយ្យោ មហា-កច្ចានោតិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទមានជាអាទិ៍ថា **យថា យថា** មានសេចក្តីសង្ខេប ដូចតទៅនេះ ។ ព្រះមហាកច្ចានៈជាម្ចាស់ សម្តែង ប្រាប់ បញ្ញត្ត ផ្តើមតាំង បើក ចែក ធ្វើឱ្យងាយយល់ ប្រកាសធម៌ ដោយអាការណាៗ កាលយើង (សោណៈ) ពិចារណាដោយអាការនោះៗ រមែងប្រាកដយ៉ាងនេះថា ព្រហ្មចរិយៈ គឺសិក្ខា ៣ នេះ ដែលយើងនឹងធ្វើមិនឱ្យដាច់ត្រឹមតែមួយថ្ងៃ ឱ្យជាព្រហ្មចរិយៈដ៏បរិបូណ៌ ដោយចំណែកមួយ ព្រោះគប្បីធ្វើឱ្យចាក់ធ្ងុនទូវចិត្តជួងចុងក្រោយ (ស្ងាប់) ។ ឱ្យ បរិសុទ្ធដោយចំណែកតែមួយ ដោយធ្វើមិនឱ្យមានមន្ទិលដោយមន្ទិល គឺកិលេស ត្រឹមតែមួយថ្ងៃដ៏បរិសុទ្ធដោយចំណែកមួយ គប្បីធ្វើឱ្យចាក់ធ្ងុនទូវចិត្តចុងក្រោយ។ បទថា **សង្ខ្ហលិខិតំ** គឺដូចជាស័ង្ខដែលគេខាត់ល្អហើយ គឺប្រៀបដោយស័ង្ខដែល ជម្រះដរាបស្អាត ព្រហ្មចរិយៈនេះ គឺបុគ្គលគ្រប់គ្រងផ្ទះ គឺអ្នកនៅផ្ទះ នឹងមិន ងាយធ្វើឱ្យបរិបូណ៌ដោយចំណែកតែមួយបានឡើយ ។ល។ បើដូច្នោះ មានតែ យើងគប្បីដាក់ គឺគប្បីកោរសក់ និងពុកមាត់ ពុកចង្កា ហើយបិទចាំង គឺស្លៀក និងដណ្តប់ទូវសំពត់កាសាយៈ ដែលជ្រលក់ដោយទឹកអម្ចត់ ជាសំពត់ដ៏សមគួរ ដល់អ្នកប្រព្រឹត្តព្រហ្មចរិយៈ ចេញចាកផ្ទះហើយបួស ដោយភាពជាអ្នកមិនមាន ផ្ទះ ។ ព្រោះហេតុដែលកម្ម មានកសិកម្ម និងពាណិជ្ជកម្មជាដើម ដែលជា

ប្រយោជន៍ដល់ផ្ទះ លោកហៅថា **អការិយំ** និងអគារិយៈនោះមិនមានក្នុងបព្វជ្ជា ព្រោះដូច្នោះ បព្វជ្ជាទើបឈ្មោះថា **អនគារិយៈ** (កម្មមិនជាប្រយោជន៍ដល់ផ្ទះ) អធិប្បាយថា យើងគប្បីចេញ គឺគប្បីចូលដល់ បានដល់ គប្បីបដិបត្តិធម៌ដែលមិនជាប្រយោជន៍ដល់ផ្ទះ គឺបព្វជ្ជានោះ ។

សោណឧបាសក ច្បាស់ដល់ហេតុដែលខ្ជួនត្រិះរិះក្នុងទីកំបាំង ដោយអាការយ៉ាងនេះដល់ព្រះថេរៈ ហើយមានសេចក្ដីប្រាថ្នានឹងបដិបត្តិតាមនោះ ទើបពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំ ព្រះករុណាផង ចំណែកព្រះថេរៈពិចារណាថា ញាណរបស់លោកមិនទាន់ចាស់ក្លានៅឡើយ ទើបរង់ចាំសេចក្ដីចាស់ក្លារបស់ញាណ ហាមសេចក្ដីពេញចិត្តក្នុងបព្វជ្ជាដោយន័យមានជាអាទិ៍ថា **ឧក្លារំ** ជាដូច្នេះ ។

បណ្ដាបទទាំងនោះ ដោយបទថា **ឯកភត្តំ** នេះ លោកពោលសំដៅដល់ការវៀរចាកការបរិភោគក្នុងវេលាវិកាល ដែលពោលទុកយ៉ាងនេះថា ព្រះអរហន្តទាំងឡាយ បរិភោគតែម្ដង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល[1] ។ បទថា **ឯកសេយ្យំ** បានដល់ ដេកមិនមានបុគ្គលជាគម្រប់ពីរ ។ ក៏ក្នុងពាក្យថា **ឯកសេយ្យំ** នេះ កាលប្រាថ្នាដល់ការដេកជាប្រធាន លោកទើបសម្ដែងកាយវិវេកក្នុងឥរិយាបថទាំង ៤ ដែលពោលហើយ ដោយន័យមានជាអាទិ៍ថា ភិក្ខុនោះដើរម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង[2] ជាដូច្នេះ មិនមែនសម្ដែងត្រឹមតែជាអ្នកដេកតែម្នាក់ឯងទេ ។ បទថា **ព្រហ្មចរិយំ**

១-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ២៧៧ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស លេខ ៦៤ ទំព័រ ២៤៥ ។

បានដល់ ព្រហ្មចរិយៈ គឺការវៀរចាកមេថុន ឬសាសនព្រហ្មចរិយៈ គឺការប្រកបរឿយៗ ក្នុងត្រៃសិក្ខា ។ បទថា **ឥជ្ឈ** ជានិបាត ក្នុងចោទនត្ថៈ ។ បទថា **តត្ថេវ** បានដល់ ក្នុងផ្ទះនុ៎ះឯង ។ បទថា **ពុទ្ធំ សាសនំ អនុយុញ្ជ** សេចក្តីថា ចូរប្រកបរឿយៗ នូវសីលមានអង្គ ៥ មានអង្គ ៨ និងមានអង្គ ១០ ផ្សេងដោយការកំណត់ជានិច្ចសីល និងឧបោសថសីលជាដើម និងសមាធិភាវនា និងបញ្ញាភាវនាដែលសមគួរដល់សីលនោះ ។ មែនពិត ព្រហ្មចរិយៈនេះ ដែលឧបាសកគប្បីប្រព្រឹត្តរឿយៗ ក្នុងចំណែកខាងដើម ឈ្មោះថា ព្រះពុទ្ធសាសនា ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រហ្មចរិយៈមានការបរិភោគកត្តតែមួយពេល មានការដេកនៅតែម្នាក់ឯងសមគួរដល់កាលចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាលយុត្តំ** សេចក្តីថា ប្រកបដោយកាលពោលគឺ ថ្ងៃ ១៤-១៥-៨ ពេច និងថ្ងៃបាដិហារិយបក្ខ ។ ម្យ៉ាងទៀត យើងគប្បីអាចរហូតអស់កាលដែលគួរ គឺដែលសមរម្យដល់លោកអ្នកប្រកបរឿយៗ ក្នុងកាលតាមដែលពោលហើយ អធិប្បាយថា មិនមែនបួសរហូតអស់កាលទាំងពួងទេ ។ ពាក្យនោះទាំងអស់លោកពោលទុក ដើម្បីធ្វើឱ្យសមរម្យក្នុងសម្មាបដិបត្តិ ព្រោះកាមទាំងឡាយលះបានលំបាក ព្រោះហេតុដែលញាណ របស់សោណៈនោះ មិនទាន់ចាស់ក្លា មិនមែនពោលដើម្បីហាមសេចក្តីពេញចិត្តក្នុងការបព្វជ្ជា ។ បទថា **បព្វជ្ជាភិសង្ខ្លោ** បានដល់ ផ្តើម គឺឧស្សាហ៍ ដើម្បីបព្វជ្ជា ។ បទថា **បដិបស្ស្ធ** សេចក្តីថា រំងាប់ទៅ ព្រោះឥន្ទ្រិយមិនទាន់ចាស់ក្លា និងព្រោះសេចក្តីសង្វេគមិនទាន់ខ្លាំងក្លា ។ ការបព្វជ្ជារបស់សោណៈនោះ រំងាប់ទៅក៏ពិត

បើយ៉ាងនោះ សោណៈក៏នូវតែតម្រង់តាមវិជីដែលព្រះថេរៈប្រាប់ ហើយចូលទៅ រកព្រះថេរៈតាមកាលដែលសមគួរ ហើយអង្គុយស្តាប់ធម៌ ។ ចិត្តរបស់សោណៈ កើតឡើងក្នុងការបព្វជ្ជាជាលើកទីពីរ ដោយន័យដូចពោលហើយនុ៎ះឯង ។ សោណៈប្រាប់ដល់ព្រះថេរៈឱ្យជ្រាប ។ សូម្បីលើកទីពីរ ព្រះថេរៈក៏នូវតែហាម ។ តែក្នុងវារៈទីបី ព្រះថេរៈដឹងថា សោណៈមានញាណចាស់ក្លាហើយ ទើបឱ្យ សោណៈបព្វជ្ជាដោយគំនិតថា ឥឡូវនេះ ជាវេលាដែលនឹងឱ្យសោណៈបាន បព្វជ្ជ ។ ក៏ព្រះថេរៈឱ្យសោណៈនោះបព្វជ្ជ ហើយស្វែងរកគណៈកន្ធង ទៅបានបីឆ្នាំ ទើបឱ្យឧបសម្បទា ដែលលោកពោលទុកថា **ឧតិយម្បិ ខោ សោណោ ។បេ។ ឧបសម្ផាឡេសិ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **អប្ផកិក្ខុកោ** *ប្រែថា មានកិក្ខុពីរបីរូប ។ បានឮថា ក្នុងកាលនោះ កិក្ខុទាំងឡាយដោយច្រើន នៅក្នុងមជ្ឈិមប្រទេស ប៉ុណ្ណោះ ។ ព្រោះដូច្នោះ ក្នុងទីនោះទើបមានកិក្ខុ ២-៣ រូបប៉ុណ្ណោះ ។ ក៏កិក្ខុ ទាំងនោះចែកគ្នានៅយ៉ាងនេះ គឺក្នុងនិគមខ្លះមាន ១ អង្គ ក្នុងនិគមខ្លះមាន ២ អង្គ ។ បទថា* **កិញ្ចេន** *ប្រែថា ដោយក្រ ។ បទថា* **ករសិរេន** *ប្រែថា ដោយ លំបាក ។ បទថា* **តតោ តតោ** *បានដល់ ពីស្រុក និងនិគមជាដើមនោះៗ ។ មែនពិត កាលព្រះថេរៈនាំកិក្ខុ ២-៣ រូបមក បណ្តាកិក្ខុពួកដទៃដែលនាំមកមុន ក៏នាំគ្នាជៀសចេញទៅដោយករណីយកិច្ចណានីមួយ ។ កាលរង់ចាំកាលបន្តិច-បន្តួច ហើយនាំកិក្ខុទាំងនោះត្រឡប់មកទៀត ចំណែកកិក្ខុក្រៅនេះក៏ជៀសចេញ ទៅ ។ ការប្រជុំដោយការមករឿយៗយ៉ាងនេះ បានប្រព្រឹត្តទៅយ៉ាងយូរ ។ ក៏ ក្នុងកាលនោះ ព្រះថេរៈគង់នៅតែមួយអង្គឯង ។ បទថា* **ឧសវត្តំ កិក្ខុសង្ឆំ**

សន្ធិចាតេត្វា សេចក្ដីថា ក្នុងកាលនោះ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតការឧបសម្បទាដោយសង្ឆសទវគ្គប៉ុណ្ណោះ សូម្បីក្នុងបច្ចន្តប្រទេស ។ មែនពិត ក្នុងកាលឥឡូវនេះ ព្រះដ៏មានព្រះភាគត្រូវព្រះថេរៈទូលអង្វរដល់ហេតុឧបសម្បទានេះ ទើបទ្រង់អនុញ្ញាតការឧបសម្បទាក្នុងបច្ចន្តប្រទេសដោយសង្ឆបញ្ចវគ្គ ។ ព្រោះហេតុនោះ លោកទើបពោលថា **តិណ្ណំ** **វស្សានំ** ។បេ។ **សន្ធិចាតេត្វា** ដូច្នេះជាដើម ។

បទថា **វស្សំ** **វុដ្ឋស្ស** បានដល់ អ្នកឧបសម្បទាហើយចូលវស្សាដំបូងហើយចេញ ។ បទថា **ឌ្ឍ**ិ**ណ**ិ**សោ ច ឌ្ឍ**ិ**ណ**ិ**សោ ច** សេចក្ដីថា ព្រះដ៏មាន-ព្រះភាគយើងបានស្ដាប់មកថា បែបនេះ។ គឺទ្រង់ប្រកបដោយនាមកាយសម្បត្តិ និងរូបកាយសម្បត្តិបែបនេះ និងប្រកបដោយធម៌កាយសម្បត្តិបែបនេះ ដោយពាក្យថា **ន ខោ មេ សោ ភគវា សម្មុ**ខ**ា ឌ**ិ**ដ្ឋោ** នេះ អាចារ្យទាំងឡាយសំដៅយកភាពជាបថុជ្ជនប៉ុណ្ណោះ ពោលថា សោណៈដ៏មានអាយុមានសេចក្ដីប្រាថ្នានឹងគាល់ព្រះដ៏មានព្រះភាគ តែខាងក្រោយសោណៈដ៏មានអាយុនៅក្នុងព្រះគន្ធ-កុដិជាមួយនឹងព្រះសាស្ដា ក្នុងវេលាជិតភ្ជឿព្រះសាស្ដាទ្រង់ហៅ ទើបធ្វើទុកក្នុងចិត្តឱ្យមានប្រយោជន៍ ដល់ព្រះសូត្រ ១៦ ជាវគ្គ ៨ វគ្គ ចំពោះព្រះកត្ត្រព្រះសាស្ដា ហើយប្រមូលមកទុកក្នុងចិត្តទាំងអស់ ជាអ្នកដឹងច្បាស់អត្ថនិងធម៌ កាលនឹងពោលជាអ្នកមានចិត្ត ជាសមាធិដោយជាប្រធាន គឺបាមោជ្ជៈដែលកើតអំពីធម៌ជាដើមក្នុងវេលាចប់សរភញ្ញៈ ផ្ដើមតាំងវិបស្សនាពិចារណាសង្ខារ សម្រេចព្រះអរហត្ត ដោយលំដាប់ ។ ក៏ដើម្បីប្រយោជន៍នេះប៉ុណ្ណោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់

បង្គាប់ឱ្យសោណៈនៅក្នុងព្រះគន្ធកុដិជាមួយនឹងព្រះអង្គ ។

ចំណែកអាចារ្យពួក ខ្ទះពោលថា ពាក្យថាយើងនៅមិនបានឃើញព្រះដ៏-មានព្រះភាគ ចំពោះព្រះភក្ត្រ ដូច្នេះ លោកពោលសំដៅយកចំពោះការឃើញរូបកាយប៉ុណ្ណោះ ។ មែនពិត ព្រះសោណៈដ៏មានអាយុគ្រាន់តែបួសហើយក៏រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះថេរៈ ព្យាយាមប្រឹងប្រែងនៅមិនទាន់បានឧបសម្បទាឡើយ បានជាព្រះសោតាបន្ន គ្រាឧបសម្បទាហើយគិតថា សូម្បីឧបាសកទាំងឡាយក៏ជាព្រះសោតាបន្ន ទាំងយើងក៏ជាព្រះសោតាបន្ន ក្នុងសេចក្តីនេះនឹងគិតទៅហេតុដូចម្តេចហ្ន៎ ទើបចម្រើនវិបស្សនាដើម្បីមគ្គជាន់ខ្ពស់បានអកិញ្ចា ៦ ខាងក្នុងវស្សានោះឯង ហើយបវារណាដោយវិសុទ្ធិបវារណា ។ ក៏ព្រោះឃើញអរិយសច្ចៈ ទើបឈ្មោះថា ព្រះថេរៈបានឃើញធម្មកាយរបស់ព្រះដ៏មានព្រះភាគ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា

យោ ខោ វក្កលិ ធម្មំ បស្សតិ សោ ធម្មំ បស្សតិ យោ មំ បស្សតិ សោ ធម្មំ បស្សតិ ។ *ម្នាលវក្កលិ បុគ្គលណាឃើញធម៌ បុគ្គលនោះឈ្មោះថាឃើញតថាគត បុគ្គលណាឃើញតថាគត បុគ្គលនោះឈ្មោះថា ឃើញធម៌[1] ។ ព្រោះដូច្នោះ ការឃើញធម្មកាយ ទើបសម្រេចដល់ព្រះសោណដ៏មានអាយុមុនតែម្តង ក៏ឯគ្រាបវារណាហើយ ព្រះសោណដ៏មានអាយុមានសេចក្តីប្រាថ្នានឹងឃើញរូបកាយ ។ បាលីថា បើព្រះឧបជ្ឈាយ៍អនុញ្ញាតដល់ខ្ញុំព្រះករុណា ខ្ញុំព្រះករុណានឹងទៅដូច្នេះក៏មាន ។ តែអ្នកសរសេរ សរសេរថា **ភន្តេ** ។ ម្យ៉ាងទៀត បាលីថា*

១-សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ លេខ ៣៣ ទំព័រ ២៧៥ ។

ប្រពៃហើយ ប្រពៃហើយ អាវុសោសោណ: អ្នកចូរទៅចុះ ដូច្នេះក៏មាន ។ តែ ពាក្យថា **មា**[1] **អាវុសោ** មិនមានក្នុងគម្ពីរច្បាប់ខ្ញុះទេ ។ ម្យ៉ាងទៀត បទថា **ឯវមាអាសោ** បាលីថា **ខោ អាយស្មា សោណោ** ដូច្នេះក៏មាន ។ មែនពិត វាទ:ថា អាវុសោនុ៎ះ ពួកភិក្ខុធ្លាប់ប្រព្រឹត្តហៅគ្នានិងគ្នាមក ក្នុងកាលដែលព្រះដ៏-មានព្រះភាគទ្រង់ធរមាននៅ ។ អត្ថនៃបទមានជាអាទិ៍ថា **ភគវន្តំ ចាសាឧិកំ** ខ្ញុំបានពោលទុកហើយនោះឯង ។

បទថា **ភិក្ខ ចមនីយំ** សេចក្តីថា ម្នាលភិក្ខុ យន្ត គឺសរីរ:របស់ លោកនេះមានចក្រ ៤ មានទ្វារ ៩ អ្នកគប្បីអត់ធន់បានឬ គឺអ្នកអាចដើម្បីនឹង អត់ធន់ គឺអត់ទ្រាំ រក្សាបានឬ បានដល់ ការ: គឺទុក្ខមិនគ្របសង្កត់អ្នកឬ ។ បទ ថា **ភិក្ខ យាបនីយំ** សេចក្តីថា អ្នកអាចញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ គឺឱ្យដំណើរ ទៅក្នុងកិច្ចនោះៗ បានដែរឬ អ្នកមិនមានអន្តរាយអ្វីឬ ។ បទថា **ភិក្ខ សិ អប្ប-ភិលមជេន** សេចក្តីថា អ្នកមកអស់ផ្លូវចម្ងាយប៉ុណ្ណោះមិនមានសេចក្តីលំបាក ខ្ញុះទេឬ ។

បទថា **ឯតទ ឧហោសិ** សេចក្តីថា ព្រះអានន្ទ កាលរត្ងកដល់ព្រះពុទ្ធ-ចរិយា ទើបបានពោលពាក្យនេះក្នុងឥឡូវនេះ ដោយន័យមានជាអាទិ៍ថា **យស្ស ខោ មំ ភគវា** នេះបានជាពាក្យដែលលោកធ្លាប់គិត មកជាអាចិន្ត្រ ។ បទថា **ឯកវិហារេ** បានដល់ ក្នុងព្រះគន្ធកុដិជាមួយគ្នា ។ មែនពិត ព្រះគន្ធ-កុដិក្នុងទីនេះ លោកសំដៅយកវិហារ ។ បទថា **រត្តំ** ប្រែថា ដើម្បីនៅ ។

១-បទថា **មា** មិនមានក្នុងអដ្ឋកថាច្បាប់ធម្ម្ជសង្ខ្យាយនាទេ ។

ក្នុងបទថា **ឌិសជ្ជាយ វិតជាមេត្វា** នេះ មានវិនិច្ឆ័យដូចតទៅនេះ អាចារ្យពួកខ្លះពោលថា ព្រោះហេតុដែលព្រះដ៏មានព្រះភាគ កាលទ្រង់ធ្វើបដិ-សណ្ឋារ: ក្នុងការចូលសមាបត្តិ ដល់ព្រះសោណ:ដ៏មានអាយុ ទ្រង់ចូលសមាបត្តិទាំងអស់ដែលទូទៅដល់សាវក ដោយអនុលោម និងបដិលោមអស់រាត្រីជាច្រើន ។ល។ ហើយទើបស្តេចចូលកាន់វិហារ ព្រោះដូច្នោះ ចំណែកព្រះសោណ-ដ៏មានអាយុជ្រាបបំណងរបស់ព្រះដ៏មានព្រះភាគ ទើបចូលសមាបត្តិនោះទាំងអស់ ដែលសមគួរដល់សេចក្តីបំណងនោះ អស់រាត្រីជាច្រើន ។ល។ ហើយចូលកាន់វិហារ ។ ក៏ឯគ្រាចូលទៅហើយ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាត សូម្បីព្រះថេរ:ក៏ធ្វើចីវរឱ្យជាករណីយកិច្ចខាងក្រៅ (ដោះចីវរ) ហើយញ៉ាំងការកន្ទងទៅ ដោយការអង្គុយចុងព្រះបាទរបស់ព្រះដ៏មានព្រះភាគ ។ បទថា **អជ្ឌ្ឍេសិ** បាន-ដល់ ទ្រង់បង្ហាប់ ។ បទថា **បដិភាតុ តំ ភិក្ខុ ឌម្ហោ ភាសិតុំ** បានដល់ ម្នាលភិក្ខុ ការពោលធម៌ ចូរប្រាកដដល់អ្នក គឺចូរមកក្នុងមុខ គឺញាណរបស់អ្នក អធិប្បាយថា ចូរពោលធម៌តាមដែលបានស្តាប់មក តាមដែលបានរៀនសូត្រមក ។

បទថា **សោឡស អដ្ឋកវត្ថុកានិ** បានដល់ សូត្រ ១៦ សូត្រ មានកាមសូត្រជាដើម ដែលចែកជាវគ្គ ៨ វគ្គ ។ បទថា **សរេន អភណិ** បានដល់ បានពោលដោយសំឡេងដែលដេញទៅតាមសូត្រ អធិប្បាយថា ពោលអំពីសរភញ្ញ: ។ បទថា **សរភញ្ញបរិយោសានេ** បានដល់ ក្នុងកាលទីបញ្ចប់នៃការសម្តែង ។ បទថា **សុត្តហិតានិ** បានដល់ រៀនសូត្រដោយប្រពៃ ។ បទថា **សុមនសិកតានិ** បានដល់ ធ្វើទុកក្នុងចិត្តដោយល្អ ។ បុគ្គលខ្លះក្នុងវេលារៀនសូត្រ សូម្បីរៀនដោយប្រពៃ ខាងក្រោយក្នុងវេលាធ្វើទុកក្នុងចិត្ត ដោយការ

ស្វាធ្យាយជាដើម ក៏ពោលព្យញ្ជនៈឱ្យខុសទៅ ឬធ្វើបទមុន បទក្រោយឱ្យខុសភ្ជាត់ទៅ ព្រះសោណដ៏មានអាយុអង្គនេះ មិនដូច្នោះទេ ។ តែព្រះសោណដ៏-មានអាយុនេះ ដាក់ចិត្តតាមដែលរៀនសូត្រមកដោយប្រពៃតែម្តង ។ ព្រោះហេតុនោះ លោកទើបពោលថា បទថា **សុមនសិកតានិ** បានដល់ ធ្វើទុកក្នុងចិត្តដោយល្អ ។ បទថា **សូបធារិតានិ** បានដល់ សូម្បីដោយអត្តលោកក៏ទ្រទ្រង់ចាំទុកល្អហើយ ។ ក៏កាលព្រះថេរៈទ្រទ្រង់ចាំអត្តទុកល្អហើយ ក៏អាចសូត្របាលីបានយ៉ាងត្រឹមត្រូវ ។ បទថា **កល្យាណិយាសិ វាចាយ សមន្នាគតោ** សេចក្តីថា លោកជាអ្នកប្រកបដោយវាចារបស់អ្នកក្រុង បរិបូណ៌ដោយបទនិងព្យញ្ជនៈដែលមូល ដោយការពោលតាមវិធីនៃសិថិល និងធនិតជាដើម ។ បទថា **វិសដ្ឋាយ** ប្រែថា រួចផុត ។ ដោយពាក្យនោះលោកសម្តែងដល់ភាពជាអ្នកមានវាទៈថា រួចផុត ។ បទថា **ឯណេលកលាយ** សេចក្តីថា ទោស លោកហៅថា **ឯលៈ** ទោសរបស់វាចានោះមិនហូរចេញទៅ ព្រោះហេតុនោះ វាចានោះឈ្មោះថា **ឯណេលកលា** អធិប្បាយថា វាចានោះ រកទោសមិនបាន ។ ម្យ៉ាងទៀត បទថា **ឯណេលកលាយ** សេចក្តីថា ដោយវាចា ជាវាចាមិនមានទោស និងមិនឃ្យៀងឃ្វាតទៅ ឈ្មោះថា វាចារកទោសមិនបាន អធិប្បាយថា មានបទ និងព្យញ្ជនៈ មិនឃ្យៀងឃ្វាត គឺមានបទនិងព្យញ្ជនៈមិនខូច ។ ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ស្តាបនាព្រះថេរៈទុកក្នុងឯតទគ្គៈថា **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ កល្យាណវាក្ការណានំ យទិទំ សោណោ កុដិកណ្ណោ** ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកពោលពាក្យពីរោះ

ដែលជា សាវករបស់តថាគត ស្រេចនឹងសោណកុដិកណ្ណៈ[១] *។ បទថា* **អត្ថស្ស វិញ្ញាបនិយា** *សេចក្តីថា ជាវាចាដែលអាចឱ្យដទៃដឹងនូវអត្ថ ដែលខ្លួនបំណងយក ។*

បទថា **កតិវស្សោ** *សេចក្តីថា បានឮថា ព្រះថេរៈតាំងនៅក្នុងចំណែកទី ៣ នៃមជ្ឈិមវ័យ បរិបូណ៌ដោយអាកប្បកិរិយា រមែងប្រាកដដល់ជនពួកដទៃប្រាកដដូចជាបព្វជិតដែលបួសយូរ ។ អាចារ្យពួកខ្លះពោលថា ព្រះដ៏មានព្រះភាគត្រាស់សួរ ព្រោះអាស្រ័យសំដៅដល់សេចក្តីនោះ ពាក្យនោះមិនមែនជាហេតុឡើយ ។ កាលបើដូច្នោះ ព្រះថេរៈសមគួរដើម្បីនឹងសោយសុខដែលកើតអំពីសមាធិ តែព្រោះហេតុណា លោកទើបដល់សេចក្តីប្រមាទរហូតអស់កាលត្រឹមតែប៉ុណ្ណោះ ព្រោះហេតុនោះ ដើម្បីនឹងប្រកបសេចក្តីនេះទៀត ព្រះសាស្តាទើបត្រាស់សួរព្រះថេរៈថា អ្នកមានវស្សាប៉ុន្មាន? ព្រោះហេតុនោះនុ៎ះឯង ព្រះដ៏-មានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុ ព្រោះអ្វី អ្នកបង្អែបង្អង់នៅយូរយ៉ាងនេះ ។*

បណ្តាបទទាំងនោះ បទថា **កិស្ស** *ប្រែថា ព្រោះហេតុអ្វី ។ បទថា* **ឯវំ ចិរំ អកាសិ** *ប្រែថា ប្រព្រឹត្តយូរយ៉ាងនេះ អធិប្បាយថា ព្រោះហេតុអ្វី អ្នកទើបមិនចូលទៅបព្វជ្ជា បែរជានៅគ្រប់គ្រងផ្ទះយូរម្ល៉េះយ៉ាងនេះ ។ បទថា* **ចិរំ ទិដ្ឋោ មេ** *បានដល់ ខ្ញុំព្រះអង្គបានឃើញទោសក្នុងកាមទាំងឡាយមកជាយូរ គឺអស់កាលយូរ ។ បទថា* **កាមេសុ** *បានដល់ ក្នុងកិលេសកាម និងវត្ថុកាម ។ បទថា* **អាទីនវោ** *ប្រែថា ទោស ។ បទថា* **អបិច** *សេចក្តីថា សូម្បីកាលខ្ញុំព្រះអង្គឃើញទោសក្នុងកាមទាំងឡាយ ដោយប្រការខ្លះ ខ្ញុំព្រះអង្គ ក៏មិនអាចដើម្បីនឹង*

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៤០ ទំព័រ ៩៤ ។

ចេញចាកផ្ទះបាន ។ ព្រោះហេតុអ្វី? ព្រោះការគ្រប់គ្រងផ្ទះចង្អៀត គឺការៈនៃការគ្រប់គ្រងផ្ទះមានកិច្ចតូចធំច្រើនចូលមកពាក់ព័ន្ធ ។ ព្រោះហេតុនោះនុ៎ះឯង លោកទើបពោលថា **ពហុកិច្ចោ ពហុការណីយោ** ដូច្នេះជាដើម ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថនេះថា ចិត្តរបស់អ្នកឃើញទោសក្នុងកាមទាំងឡាយតាមសេចក្ដីពិត សូម្បីបង្ហែបង្ហង់នៅមិនត្រាច់ទៅ គឺមិនជ្ងាក់ទៅដោយពិតតែម្ដង ដូចតំណក់ទឹកលើស្លឹកឈូកដូច្នោះ ។ បទថា **ឥមំ ឧទានំ** សេចក្ដីថា ទ្រង់បន្ទឺឧទាននេះ ដែលសម្ដែងដល់អត្ថនេះថា លោកកាលជ្រាបបវត្តិ និងនិវត្តិ ដោយប្រពៃតែម្ដងរមែងមិនត្រេកអរក្នុងបវត្តិកាល និងសូម្បីក្នុងពេលខ្លះ ដែលមានបវត្តិកាលនិងនិវត្តិនោះជានិមិត្ត ។

បណ្ដាបទទាំងនោះ បទថា **ឥស្សា អាទីនវំ លោកេ** សេចក្ដីថា ឃើញអាទីនវៈ គឺទោសដោយចក្ខុ គឺបញ្ញាក្នុងសង្ខារលោកសូម្បីទាំងអស់ ដោយន័យមានជាអាទិ៍ថា មិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជាធម្មតាដូច្នេះ ។ ដោយពាក្យនេះ ព្រះអង្គទ្រង់សម្ដែងដល់វិបស្សនាវារៈ ។ បទថា **ញត្វា ឆមំ ឥរ្យបឆឿ** សេចក្ដីថា ដឹងសេចក្ដីមិនមានឧបធិ គឺនិព្វានធម៌ ព្រោះលះបង់ឧបធិទាំងពួងបានជាប់ គឺធ្វើអមតធម៌ ពោលគឺ វិវេកដែលជាគ្រឿងរលាស់ទុក្ខឱ្យជាក់ច្បាស់ ចាក់ធ្ងុះដោយមគ្គញ្ញាណ តាមសេចក្ដីពិត ។ គប្បីឃើញហេតុ និងអត្ថរបស់បទទាំងនេះថា **ឥស្សា ញត្វា** ដូចក្នុងប្រយោគមានជាអាទិ៍ថា ព្រោះផឹកទឹកដោះស្រស់ទើបមានកម្លាំង ឃើញរាជសីហ៍ ភ័យទើបមាន ឃើញដោយបញ្ញា

អាសវៈទើបអស់ទៅ ។ បទថា **អរិយោ ន រមតិ ចាបេ** *សេចក្តីថា សប្បុរសឈ្មោះថា* ***អរិយៈ*** *ព្រោះឆ្ងាយចាកកិលេស រមែងមិនត្រេកអរក្នុងបាប សូម្បីប្រមាណតិច ។ ព្រោះហេតុអ្វី? ព្រោះអ្នកស្អាត រមែងមិនត្រេកអរក្នុងបាប អធិប្បាយថា បុគ្គលបរិសុទ្ធ ព្រោះមានកាយសមាចារហ្មត់ចត់ដោយល្អ រមែងមិនត្រេកអរ គឺរមែងមិនក្ងើតក្ងើនក្នុងបាប គឺក្នុងសង្កិលេសធម៌ ដូចស្តេចហង្ស មិនត្រេកអរក្នុងទីស្មោកគ្រោកដូច្នោះ ។ បាលីថា* **ចាចោ ន រមតី សុចឺ** *ដូច្នេះក៏មាន ។ ពាក្យនោះមានអធិប្បាយ ដូចតទៅនេះ អ្នកមានបាប គឺអ្នកអាក្រក់ រមែងមិនត្រេកអរនឹងរបស់ស្អាត គឺរបស់ដែលមិនមានទោស មានភាពផូរផង់ជាធម៌ពិត ត្រេកអរតែរបស់មិនស្អាត គឺសង្កិលេសធម៌ប៉ុណ្ណោះ ដូចសត្វទាំងឡាយមានជ្រូកស្រុកជាដើម ត្រេកអរតែស្ថានទីស្មោកគ្រោកដូច្នោះ ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់ផ្ទាស់ទេសនា ដោយធម៌ដែលជាបដិបក្ខគ្នា ។*

កាលព្រះដ៏មានព្រះភាគ ទ្រង់បន្ទឹមឧទានយ៉ាងនេះហើយ ព្រះសោណៈ ក្រោកពីអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ទូលសូមវត្ថុ ៥ ប្រការ មានឧបសម្បទា ដោយសង្ឃបញ្ជាវគ្គក្នុងបច្ចន្តប្រទេសជាដើម តាមពាក្យឧបជ្ឈាយ៍របស់ខ្លួន ។ ពាក្យថា **ភគវាបិ តានិ អនុជានិ** *គប្បីជ្រាបដោយន័យដែលពោលមកហើយក្នុងខន្ធកៈ[1]ចុះ ។*

ធម្មសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៦

១-សេចក្តីពិស្តារមានក្នុងវិនយបិដក មហាវគ្គ ត្រង់ចម្មក្ខន្ធកៈ ចាប់ពីទំព័រ ២១៤ ដល់ ២១៦ ។

៧. សង្ខារវេតសុត្តវណ្ណនា

អដ្ឋកថាកង្ខារេវតសូត្រ

កង្ខារេវតសូត្រទី ៧ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **រេវតោ** *ជាឈ្មោះរបស់ព្រះថេរៈនោះ ។ មែនពិត ព្រះថេរៈអង្គនោះ បានបព្វជ្ជាឧបសម្បទាក្នុងព្រះសាសនាហើយ ជាអ្នកមានសីល មានកល្យាណ-ធម៌ជាគ្រឿងនៅ តែលោកជាអ្នកច្រើនទៅដោយសេចក្តីសង្ស័យ ពោលគឺ សេចក្តីរង្គៀសក្នុងព្រះវិន័យ ដោយមានជាអាទិ៍ថា សណ្តែកបាយដែលជាអកប្បិយៈ រមែងមិនគួរដើម្បីនឹងបរិភោគ និងថា ដុំស្ករអំពៅដែលជាអកប្បិយៈ រមែងមិនគួរដើម្បីនឹងបរិភោគ ។ ព្រោះហេតុនោះ លោកទើបប្រាកដឈ្មោះថា* ***កង្ខារេវតៈ*** *។ ក្នុងកាលជាខាងក្រោយមក ព្រះថេរៈរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ព្យាយាមប្រឹងប្រែងធ្វើឱ្យច្បាស់អភិញ្ញា ៦ ញ៉ាំងកាលឱ្យកន្ទងទៅដោយសេចក្តីសុខក្នុងឈាន ដោយសេចក្តីក្នុងផល ។ ព្រះថេរៈពិចារណាអរិយមគ្គដែលខ្ជួនសម្រេចហើយដោយច្រើនដើម្បីធ្វើឱ្យជាធំ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រះថេរៈ រំពឹងនូវកង្ខាវិតរណវិសុទ្ធិ (សេចក្តីបរិសុទ្ធព្រោះឆ្លងនូវសេចក្តីសង្ស័យ) ដូច្នេះជាដើម ។ មែនពិត បញ្ញាដែលសម្បយុត្តដោយមគ្គ ក្នុងទីនេះ លោកប្រាថ្នាយកថាកង្ខាវិតរណវិសុទ្ធិ ព្រោះឆ្លង គឺឈានកន្ទងសេចក្តីសង្ស័យទាំងពួងដោយមិនមានចំណែកនៅសល់ គឺសេចក្តីសង្ស័យមានវត្ថុ ១៦ ដែលប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា អំពីអតីតកាល អាត្មាអញបានកើតដែរឬ[1] សេចក្តីសង្ស័យមានវត្ថុ ៨ ដែលលោកពោលទុកយ៉ាងនេះថា រមែងសង្ស័យក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។ល។ រមែងសង្ស័យក្នុងបដិច្ចសមុប្បន្នធម៌ នឹងចាំបាច់*

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២០ ទំព័រ ២៥ ។

ពោលទៅថ្វីដល់សេចក្តីសង្ស័យក្រៅនេះហ្ន៎ ព្រោះសេចក្តីបរិសុទ្ធដោយចំណែកតែមួយ ពីកិលេសពួកដទៃដែលខ្ជូនគប្បីលះ ។ ក៏ព្រះកង្ខាវេតដ៏មានអាយុ អង្គនេះ ព្រោះហេតុដែលព្រះថេរៈមានសេចក្តីសង្ស័យជាប្រក្រតីមកយូរ ព្រះថេរៈទើបអង្គុយពិចារណាអរិយមគ្គដែលខ្ជូនសម្រេចហើយនោះ ឱ្យធ្ងន់សូម្បីជាងយើងលះសេចក្តីសង្ស័យទាំងនេះបានដាច់ខាត ព្រោះអាស្រ័យមគ្គធម៌នេះ មិនមែនអង្គុយពិចារណាឃើញនាមរូបព្រមដោយបច្ច័យ ព្រោះការធ្វើងសេចក្តីសង្ស័យចេញបាននោះ មានសេចក្តីមិនទៀងជាទីបំផុត ។

បទថា **ឯតមត្ថं វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបអត្ថនេះ គឺការធ្វើងសេចក្តីសង្ស័យនៃអរិយមគ្គបានដាច់ខាត ហើយទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់សេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **យាកាចិ កង្ខា ឥធ វា ហុរំ វា** សេចក្តីថា សេចក្តីសង្ស័យក្នុងអត្តភាពនេះ គឺអត្តភាពដែលជាបច្ចុប្បន្ននេះដែលកើតឡើងដោយន័យមានជាអាទិ៍ថា អាត្មាអញមាន ឬមិនមានហ្ន៎ ឬក្នុងអត្តភាពដទៃ គឺក្នុងអត្តភាពដែលជាអតីត និងអនាគតដែលកើតឡើង ដោយន័យមានជាអាទិ៍ថា អំពីអតីតកាល អាត្មាអញបានកើតដែរឬ ។ បទថា **សកវេទិយា ឯ បរវេទិ-យា ឯ** សេចក្តីថា សេចក្តីសង្ស័យនោះ គឺសេចក្តីងឿងធ្ងល់យ៉ាងណាមួយ ក្នុងសេចក្តីដឹងរបស់ខ្ជូនដែលនឹងគប្បីបាន គឺដែលប្រព្រឹត្តទៅដោយជាអារម្មណ៍ក្នុងអត្តភាពរបស់ខ្ជូនយ៉ាងនេះ គឺដោយន័យដូចពោលហើយ ឬក្នុងសេចក្តីដឹងរបស់អ្នកដទៃ ដែលនឹងគប្បីបានក្នុងអត្តភាពរបស់អ្នកដទៃ គឺដែលនឹងគប្បីបានបានដល់ ដែលប្រព្រឹត្តទៅក្នុងអត្តភាពដែលខ្ពស់បំផុត ដោយន័យមានជាអាទិ៍

ថា ព្រះពុទ្ធមាន ឬមិនមាន ។ គាថាថា **យេ ឈាយិនោ តា ឋ ជ្ឈានិ សញ្ញា អាតាបិនោ ព្រហ្មចរិយំ ចរន្តា** *សេចក្តីថា អ្នកពួកណា ឈ្មោះថា អ្នកសម្ងឹងឈាន ដោយអារម្មណ៍ឧបនិជ្ឈាន និងលក្ខណ:ឧបនិជ្ឈាន ចម្រើនវិបស្សនា ឈ្មោះថា មានសេចក្តីព្យាយាម ព្រោះបរិបូណ៌ដោយសម្មប្បធាន ៤ ប្រព្រឹត្តនៅ គឺបានទទួលមគ្គព្រហ្មចរិយ: អ្នកតាំងនៅក្នុងបឋមមគ្គ ផ្សេងដោយប្រភេទមានសទ្ធានុសារីបុគ្គលជាដើម រមែងលះ គឺរមែងកាត់ផ្តាច់ ដែលសេចក្តីសង្សយ៍ទាំងពួងនោះ ក្នុងខណ:នៃមគ្គ ។ តអំពីនោះមក មគ្គនោះបានឈ្មោះថា អ្នកទាំងនោះលះសេចក្តីសង្សយ៍ទាំងនោះចេញបាន ។ ព្រោះដូច្នោះ ទើបមានអធិប្បាយថា ការលះសេចក្តីសង្សយ៍ដោយចំណែកមួយផ្សេងពីនោះមិនមាន ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់សរសើរការសម្រេចអរិយមគ្គរបស់ព្រះកង្ខាវេត: ដោយឈានជាប្រមុខ គឺដោយលើកឈានឡើងជាប្រធាន ទើបទ្រង់បន្ទឹ ឧទានដោយអំណាចសេចក្តីសរសើរ ។ ក៏ព្រោះហេតុនោះនុ៎ះឯង ព្រះដ៏មានព្រះភាគ ទើបទ្រង់ស្តាបនាព្រះថេរ:ទុកក្នុងឯតទគ្គ:ដោយភាពជាអ្នកមានឈានថា* **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ឈាយីនំ យទិទំ កង្ខាវេតោ** *ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកបានឈាន ដែលជាសាវករបស់តថាគត ស្រេចនឹងកង្ខាវេត:[1] ។*

សត្តមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៧

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៦០ ទំព័រ ៥៤ ។

៨. អានន្ទសុត្តវណ្ណនា[1]

អដ្ឋកថាអានន្ទសូត្រ

អានន្ទសូត្រទី ៨ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **អាយស្មន្តំ អានន្ទំ ឯតទវោច** *សេចក្តីថា ទេវទត្តបបួលក្នុងការសម្ងាប់ ឱ្យលែងដំរីនាឡាគិរី ប្រមៀលដុំថ្ម កាលមិនអាចធ្វើសេចក្តីវិនាសដល់ព្រះដ៏មានព្រះភាគបាន ទើបបានពោលពាក្យមានជាអាទិ៍ថា* **អជ្ជតគ្គេ** *ជាដើម ដោយប្រាថ្នានឹងបំបែកសង្ឆ ធ្វើឱ្យបែកធ្លាយចក្រ ។ បទថា* **អញ្ញត្រ ភគវតា** *ប្រែថា រៀវតែព្រះដ៏មានព្រះភាគ ។ អធិប្បាយថា មិនធ្វើ(ឧបោសថ)នឹងព្រះ-សាស្តា ។ បទថា* **អញ្ញត្រ ភិក្ខុសង្ឆា** *ប្រែថា រៀវភិក្ខុសង្ឆប៉ុណ្ណោះ ។ បទថា* **ឧបោសថំ ការិស្សាមិ សង្ឆកម្មានិ ច** *សេចក្តីថា នឹងរៀវភិក្ខុសង្ឆអ្នកធ្វើតាមឱ្យ៉ាទរបស់ព្រះមានព្រះភាគ ហើយធ្វើឧបោសថ និងសង្ឆកម្មជាមួយនឹងភិក្ខុអ្នកធ្វើតាមយើង ។ បទថា* **ឧវេឧត្តោ សង្ឆ្យ៌ ភិន្ទិស្សតិ** *សេចក្តីថា ថ្ងៃនេះ ភិក្ខុទេវទត្ត និងធ្វើការទម្ងាយសង្ឆចែកជា ២ ចំណែក ដោយពិតប្រាកដ ព្រោះភិក្ខុទេវទត្ត និងបក្សពួកធ្វើការបំបែកទាំងអស់ហើយ ។ មែនពិត កាលភិក្ខុទេវទត្តសម្តែងវត្ថុសូម្ប៉ីយ៉ាងណាមួយ បណ្តាវត្ថុជាគ្រឿង និងធ្វើការបំបែក ១៨ ប្រការ មានជាអាទិ៍ថា សម្តែងអធម៌ ថាជាធម៌ ហើយឱ្យឮព្រមថា ពួកលោកចូរកាន់យកវត្ថុនេះ ចូរពេញចិត្តចំពោះវត្ថុនេះ ព្រោះហេតុនោះ។ ហើយឱ្យចាប់ស្ងាក ចែកនិងធ្វើសង្ឆ-កម្ម សង្ឆក៏បែកហើយ ។*

សមដូចព្រះដ៏មានព្រះភាគដែលត្រាស់ទុកថា ម្នាលឧបាលិ សង្ឆបែកគ្នាដោយអាការ ៥ ។ អាការ ៥ តើដូចម្តេច ។ គឺដោយកម្ម (មានអបលោកន-កម្មជាដើម) ១ ដោយឧទ្ទេស (មាននិទានុទ្ទេសជាដើម) ១ ដោយសម្តែងភេទករ-

---

១-ក្នុងប្បាប់ធម្ម្ជសង្គ៌ាយនា ព្រះសូត្រនេះមានឈ្មោះថា **សង្ឆ្យ៌ភេឧសុត្តវណ្ណនា** *។*

វត្ថុ ១៨ យ៉ាង ១ ដោយអនុស្សាវនៈ គឺសូត្របញ្ជាក់អំពីសេចក្ដីស្មោះត្រង់របស់ខ្លួន[១] ១ ដោយប្រគល់ស្ងាក[២] ១ ។ ម្នាលឧបាលិ សង្ឆបែកគ្នាដោយអាការ ៥ យ៉ាងនេះឯង[៣] ។ បណ្ដាបទទាំងនោះ បទថា **ការ**ម្ភេ*ន បានដល់ ដោយកម្ម ណាមួយ បណ្ដាកម្មទាំង ៤ យ៉ាង មានអបលោកនកម្មជាដើម ។ បទថា* **ឧ**ទ្ទេ*ស*េ*ន បានដល់ ដោយឧទ្ទេសណាមួយ បណ្ដាបាតិមោក្ខុទ្ទេស ៥ យ៉ាង ។ បទថា* **ភេ**ទ*ារ*ណ្ដ*ោ បានដល់ សម្ដែងដល់វត្ថុជាគ្រឿងធ្វើការបំបែក ១៨ យ៉ាង មានការសម្ដែងវត្ថុដែលមិនជាធម៌ ថាជាធម៌ជាដើម ដោយឧបត្ដិទាំងនោះ១ ។ បទថា* **អ**នុ*ស្ស*ាវ*ន*េ*ន សេចក្ដីថា ដោយការបន្ទឹរ៉ាចា ប្រកាសជិតគុម្ពត្រចៀក ដោយន័យមានជាអាទ៍ថា ពួកលោកចូរដឹងចុះ ឬថា យើងបួសមកអំពីត្រកូលខ្ពស់ ឬថាជាពហុស្សូត គួរឬពួកលោកនឹងឱ្យកើតការគិតឡើងថា ឈ្មោះថាមនុស្សដូចយើងនឹងគប្បីឱ្យកាន់ក្រៅធម៌ ក្រៅវិន័យ យើងមិនខ្វាចអបាយឬ ។*

---

*១-**ក្នុងសមន្តបាសាទិកាបញ្ជាក់ថា** ភិក្ខុអ្នកបំបែកសង្ឆសូត្របញ្ជាក់ដោយពាក្យដូច្នេះជាដើមថា លោកទាំងឡាយចូរដឹងចុះ ខ្ញុំនេះជាអ្នកចេញចាកត្រកូលខ្ពង់ខ្ពស់មកបួស ហើយជាពហុស្សូតផង សូមលោកគ្រប់រូបទុកចិត្ដចុះថា ខ្ញុំមិនមែននាំលោកឱ្យគ្រប់រូបកាន់ខុសធម៌វិន័យទេ មួយទៀត ខ្ញុំមិនមែនសម្គាល់អវិចីនរកថាត្រជាក់ដូចជាផ្ការីឧប្បលខៀវទេ ខ្ញុំមិនមែនជាមិនខ្វាចអបាយទេ ។ **បើតាមដីកាពន្យល់បន្ថែមថា** សូត្របញ្ជាក់ពាក្យខ្លួនដល់ភិក្ខុដែលខ្លួនគួរបំបែក ។*

*២-**អដ្ឋកថាថា** លុះសូត្របញ្ជាក់យ៉ាងនេះហើយ ក៏ញ៉ាំងចិត្ដភិក្ខុទាំងនោះឱ្យជឿសិប់មិនឱ្យងាកបែរត្រឡប់វិញបានហើយស្ងាកឱ្យទៅថា លោកទាំងឡាយចូរយកស្ងាកនេះទៅចុះ ។ ឯអាការទាំង ៥ នេះ ត្រង់អាការទី ១ ទី ២ ជាសំខាន់ក្នុងការបំបែកសង្ឆនេះ ចំណែកឯអាការទី ៣ ទី ៤ ទី ៥ គ្រាន់តែជាបុព្វភាគទេ ។*

៣-វិនយបិដក បរិវារៈ លេខ ១៣ ទំព័រ ៣៣៦ ។

បទថា **សលាកគ្គាហេន** *សេចក្ដីថា ដោយការសូត្រប្រកាសយ៉ាងនេះហើយ ទើបទំនុកបម្រុងការគិតរបស់ភិក្ខុទាំងនោះ និងធ្វើឱ្យមានការមិនវិលត្រឡប់ជាធម៌ ហើយឱ្យចាប់ស្វាក ពួកលោកចូរចាប់ស្វាកនេះ ។*

ក៏ក្នុងអាការពួកនេះ កម្ម ឬឧទ្ទេសប៉ុណ្ណោះរមែងជាសំខាន់ ចំណែកការបបួលការសូត្រប្រកាស និងការឱ្យចាប់ស្វាកជាចំណែកខាងដើម ។ មែនពិតកាលលោកបបួលដោយការសម្ដែងវត្ថុ ១៨ ប្រការ ហើយសូត្រប្រកាសដើម្បីឱ្យកើតសេចក្ដីត្រេកអរក្នុងការបបួលនោះ ហើយទើបឱ្យចាប់ស្វាក សង្ឆ្ក ឈ្មោះថា នូវមិនបែកគ្នា ។ តែកាលភិក្ខុ ៤ រូប ឬលើសជាងនោះ នាំគ្នាចាប់ស្វាកហើយ នាំគ្នាធ្វើឧទ្ទេស ឬកម្មចែកគ្នា ដោយអាការយ៉ាងនេះ សង្ឆ្ក ឈ្មោះថាបែកហើយ ។ ចំណែកភិក្ខុទេវទត្ត ឲ្យមឱ្យចំណែកខាងដើមនៃសង្ឆ្ករកេទទាំងអស់សម្រេចហើយ ក៏គិតថា ថ្ងៃនេះយើងនឹងចែកការធ្វើឧបោសថ និងសង្ឆ្ককម្មមានចំណែកតែមួយ ទើបបានពោលពាក្យមានជាអាទិ៍ថា **អជ្ជតគ្គេ** *ដូច្នេះ ។ ព្រោះហេតុនោះ ព្រះអានន្ទត្ថេរទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះ ភិក្ខុទេវទត្តនិងបំបែកសង្ឆ ដូច្នេះជាដើម ។ ព្រោះយើងទាំងឡាយបានពោលទុកហើយថា ព្រោះភិក្ខុទេវទត្ត និងបក្សពួកអ្នកធ្វើការបំបែក ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្ដីថា ទ្រង់ជ្រាបដោយប្រការទាំងពួងដែលសង្ឆ្ករកេទកម្ម ដែលជាផ្លូវឱ្យកើតក្នុងអវិចីមហានរក តាំងនៅរហូតកប្ចកៃមិនបាន ដែលភិក្ខុទេវទត្តឱ្យកើតឡើងនេះ ។ បទថា* **ឥមំ ឧទានំ** *សេចក្ដីថា ទ្រង់បន្ទឺឧទាននេះ ដែលប្រកាសអត្ថនេះថា ក៏បុគ្គលអ្នកធ្ងាតវាងវៃ អាស្រ័យដោយភាពជាសប្បុរសបដិបត្តិត្រូវក្នុងចំណែកកុសល និងជាអសប្បុរសបដិបត្តិមិនត្រូវក្នុងចំណែកជាកុសលតាមលំដាប់ ។*

បណ្តាបទទាំងនោះ បទថា **សុការំ សាធុជា សាធុ** *សេចក្តីថា ឈ្មោះថា មនុស្សល្អព្រោះញ៉ាំងប្រយោជន៍ខ្លួន និងប្រយោជន៍របស់អ្នកដទៃឱ្យសម្រេចបានដល់ អ្នកបដិបត្តិដោយប្រពៃ ។ កម្មល្អ គឺកម្មស្អាត ជាកម្មចម្រើនដែលនាំមកដល់ប្រយោជន៍សុខដល់ខ្លួន និងអ្នកដទៃដែលមនុស្សល្អនោះ គឺសាវ័ក មានព្រះសារីបុត្រជាដើម ព្រះបច្ចេកសម្ពុទ្ធ ព្រះសម្មាសម្ពុទ្ធ ឬលោកិយសាធុជនដទៃ ធ្វើបានដោយងាយ គឺអាចដើម្បីនឹងធ្វើបានដោយងាយ ។ បទថា* **សាធុ ចាបេន ឧក្ការំ** *សេចក្តីថា ក៏កម្មល្អ មានលក្ខណៈដូចពោលហើយនោះនុ៎ះឯង ដែលមនុស្សអាក្រក់ គឺបាបបុគ្គល មានកិក្ខុទេវទត្តជាដើម ធ្វើបានលំបាក គឺមិនអាចនឹងធ្វើបាន អធិប្បាយថា គេមិនអាចនឹងធ្វើកម្មល្អនោះបាន ។ បទថា* **ចាបំ ចាបេន សុការំ** *សេចក្តីថា កម្មអាក្រក់ គឺកម្មមិនល្អ បានដល់ កម្មដែលនាំសេចក្តីវិនាសមកឱ្យដល់ខ្លួន និងអ្នកដទៃដែលមនុស្សអាក្រក់ គឺបាបបុគ្គលតាមដែលពោលហើយ ធ្វើបានងាយ ។ បទថា* **ចាបមរិយេហិ ឧក្ការំ** *សេចក្តីថា ចំណែកកម្មអាក្រក់នោះ។ ដែលព្រះអរិយៈទាំងឡាយ គឺបណ្ឌិតមានព្រះពុទ្ធជាដើមធ្វើបានលំបាក គឺមិនមានសេចក្តីត្រេកអរយ៉ាងក្រៃលែងជាដែនកើត ។ ក៏ព្រះសាស្តាទ្រង់សម្តែងថា ព្រះអរិយបុគ្គលទាំងនោះ ជាអ្នកសម្ងាប់កិលេសជ្រះស្រឡះហើយ។*

អដ្ឋមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៨

៩. សង្ហាយមានសុត្តវណ្ណនា

អដ្ឋកថាសង្ហាយមានសូត្រ

សង្ហាយមានសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **មាណវកា** *បានដល់ មនុស្សកំលោះ គឺអ្នកតាំងនៅក្នុងបឋម-វ័យ គឺក្នុងវ័យកំលោះក្រមុំ ។ ព្រាហ្មណ៍វ័យក្មេង លោកបំណងយកក្នុងទីនេះ ។ បទថា* **សង្ហាយមានរូចា** *នេះ លោកពោលសំដៅយកពាក្យដែលកើតអំពីការ កោកកាង ។ អធិប្បាយថា ពោលកោកកាងចំពោះបុគ្គលដទៃ និងជាអ្នកមាន ក្រប្រតីពោលពាក្យនោះ ។ ក្នុងសេចក្តីនោះមានអត្ថនៃពាក្យដូចតទៅនេះ ។ ការគួរនឹងពោលថា* **សឆយមានា** *ព្រោះវិគ្រោះថា ការពោលពាក្យគួរស្អប់ ឈ្មោះថា* **សឆ:** *ការពោលពាក្យគួរស្អប់នោះ ទើបពោលថា* **សឆាយមានា** *ព្រោះ ធ្វើឱ្យជាទីយ: ។ ម្យ៉ាងទៀត តអំពីនោះ ទើបពោលថា សឆាយមានរូប ព្រោះ មានសការ:ជាយ៉ាងនោះ ។ បាលីថា* **សង្ហាយមានរូចា** *ដូច្នេះក៏មាន អធិប្បាយថា ធ្វើសំឡេងកឹកកង គឺធ្វើសំឡេងខ្ទាំង ។ បទថា* **ភកវតោ អវិទូរេ អតិក្ក្ហមន្តិ** *សេចក្តីថា ព្រាហ្មណ៍ក្មេងទាំងនោះពោលពាក្យដែលធ្ងាប់មាត់នោះ។ ធ្ងងទៅក្នុងវិស័យនៃការសណ្ដាប់របស់ព្រះមានព្រះភាគ ។*

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបអត្ថនេះ គឺជ្រាបថា មនុស្ស ទាំងនោះមិនសង្ស្រួមវាចា ទើបទ្រង់បន្ទឹ្ទ្ធទានេះ ដែលសម្ដែងអត្ថនោះ ដោយ ធម្មសង្វេគ ។*

បណ្ដាបទទាំងនោះ បទថា **បរិមុដ្ឋា** *ប្រែថា អ្នកល្ងង់ខ្ចៅ គឺមានសតិ ភ្ជ្ជចភ្ជាំង ។ បទថា* **បណ្ឌិតាកាសា** *សេចក្តីថា ឈ្មោះថា បណ្ឌិតឋ្ម ព្រោះ បន្ទឹ្ទ្ធវាចាថា ខ្ជ្ជនទ:ដឹងក្នុងអត្ថនោះ។ ដោយយល់ថា អ្នកដទៃមិនដឹង ពួកយើង ប៉ុណ្ណោះ អ្នកដទៃដឹងក្នុងអត្ថនេះ ។ បទថា* **ភ្ជ្ជាតោ ចរ ភ្ជ្ជណ្ឌ្ជ្ជ ជ្ជ** *សេចក្តីថា*

វាចាប៉ុណ្ណោះជាគោចរ គឺជាអារម្មណ៍របស់ជនពួកណា ជនទាំងនោះ ឈ្មោះថា មានការពោលវាចាជាអារម្មណ៍ ឈ្មោះថា អ្នកមានប្រក្រតីពោលត្រឹមតែវាចាជាទីតាំងប៉ុណ្ណោះព្រោះមិនកំណត់ដឹងដល់អត្ត ម្យ៉ាងទៀត ឈ្មោះថា អ្នកមានប្រក្រតីពោលវាចាជាអារម្មណ៍ ព្រោះនិយាយមុសាវាទ ដែលមិនជាវិស័យរបស់វាចា គឺមិនមែនជាវិស័យនៃពាក្យរបស់ព្រះអរិយៈ ។ ម្យ៉ាងទៀត លោកធ្វើរស្សៈ **អា** អក្សរឱ្យជា **អ** អក្សរ ក្នុងបទថា **គោចរកាណ្ហោ** នេះ ។ អ្នកប្រាជ្ញានិយាយមានវាចាជាអារម្មណ៍ មិនមែននិយាយមានសតិប្បដ្ឋានជាអារម្មណ៍ទេ ។ តើនិយាយយ៉ាងណា? គឺនិយាយវៃងអន្ទាយតាមប្រាជ្ញា បានដល់ និយាយទៅតាមមាត់ដែលចង់និយាយ អធិប្បាយថា ធ្វើមុខក្រញ្ជូវ ព្រោះមិនគោរពអ្នកដទៃ និងព្រោះមិនសូប់អារម្មណ៍ខ្លួនឯង ។ ម្យ៉ាងទៀត អធិប្បាយថា និយាយតែវាចាជាអារម្មណ៍ប៉ុណ្ណោះ គឺខ្លួនឯងក៏មិនដឹងដល់បទនិយាយក៏និយាយទៅ ។ អធិប្បាយថា ព្រោះហេតុនោះនុ៎ះឯង ទើបនិយាយវៃងអន្ទាយតាមប្រាជ្ញា គឺមិនគិតដល់ពាក្យដែលជាហេតុឱ្យសម្រេច ប្រាជ្ញាត្រឹមតែនិយាយទៅតាមមាត់របស់ខ្លួនប៉ុណ្ណោះ ។ បទថា **យេន នីតា ន តំ វិទូ** សេចក្ដីថា បុគ្គលដែលមិនដឹង គឺអ្នកល្ងង់ ត្រូវបុគ្គលដែលមានសតិវង្វេងភ្ជាប់ជាដើមណែនាំនូវភាពមិនអៀនខ្មាស និងការសម្គាល់ថា ខ្លួនជាបណ្ឌិត យើងប៉ុណ្ណោះ និយាយបាន ដូច្នេះ ព្រោះហេតុណា រមែងមិនដឹងនូវហេតុនោះរបស់ខ្លួនអ្នកនិយាយយ៉ាងនោះ ។

ជរមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៩

១០. ចូឡបន្ថកសុត្តវណ្ណនា

អដ្ឋកថាចូឡបន្ថកសូត្រ

ចូឡបន្ថកសូត្រទី ១០ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ចូឡបន្ថកោ** *សេចក្ដីថា សម្ដីក្នុងកាលខាងក្រោយ ព្រះថេរៈដ៏មានអាយុនេះ ប្រាកដនាមថា* ***ចូឡបន្ថកៈ*** *នុ៎ះឯង ដោយបានរៀបរាប ក្នុងវេលាដែលខ្លួននៅជាកំលោះ ព្រោះជាប្អូនប្រុសរបស់ព្រះមហាបន្ថកត្ថេរៈ និងកើតត្រង់ផ្ទៃ ។ តែពោលអំពីគុណពិសេស លោកសម្រេចអភិញ្ញា ៦ បែកធ្វាយ បដិសម្ភិទា ចាត់ចូលក្នុងព្រះមហាសាវក ៨០ អង្គ ដែលព្រះដ៏មានព្រះភាគទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ ២ តំណែង ដោយព្រះតម្រាស់ថា* **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្លបន្ថកោ ។ ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ ។** *ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកនិមិត្តកាយ សម្រេចតាមចិត្តបាន ដែលជាសាវករបស់តថាគត ស្រេចនឹងចុល្លបន្ថកៈប្រសើរជាងគេ ។ ពួកភិក្ខុអ្នកឈ្វាសក្នុងការបើកចិត្ត ស្រេចនឹងចុល្លបន្ថកៈ[1] ។*

ថ្ងៃមួយ ខាងក្រោយភត្ត ព្រះថេរៈត្រឡប់ពីបិណ្ឌបាត អង្គុយសម្រាកក្នុងទីសម្រាកពេលថ្ងៃរបស់ខ្លួន ញ៉ាំងចំណែកនៃថ្ងៃឱ្យកន្ទងទៅដោយសមាបត្តិផ្សេងៗ រហូតអស់មួយថ្ងៃ ល្ម្មក្នុងវេលាល្ងាច កាលពួកឧបាសកមិនទាន់មកស្ដាប់ធម៌ឡើយ កាលព្រះដ៏មានព្រះភាគ ស្ដេចចូលទៅកាន់កណ្ដាលវិហារ ប្រថាប់គង់ក្នុងព្រះគន្ធកុដិ ព្រះថេរៈគិតថា កាលនេះ មិនមែនជាកាលទៅឧបដ្ឋាកព្រះដ៏មានព្រះភាគទេ ទើបអង្គុយចម្រើនសមាធិ ក្នុងទីដ៏សមគួរម្ខាង មុខ

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៦០ ទំព័រ ៥៣ ។

ព្រះគន្ធកុដិ ។ ព្រោះហេតុនោះ លោកទើបពោលថា សម័យនោះ ព្រះចុល្ល:ជ:ដ៏មានអាយុ អង្គុយផ្គត់ភ្នែន តម្រង់កាយឱ្យត្រង់ តាំងសតិ (ចំពោះកម្មដ្ឋាន) ក្នុងទីជិតនៃព្រះមានព្រះភាគ ។ មែនពិត ក្នុងវេលានោះ លោកកំណត់វេលាហើយ អង្គុយចូលសមាបត្តិ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបអត្ថនេះ គឺសេចក្តីដែលព្រះចុល្ល:ជ:ដ៏មានអាយុ តាំងកាយ និងចិត្តទុកដោយប្រពៃ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលប្រកាសសេចក្តីប្រាកដក្នុងការសម្រេចគុណវិសេស ដែលមានអនុបាទាបរិនិព្វានជាទីបំផុតរបស់ភិក្ខុសូម្បីដទៃ អ្នកមានកាយសូប់ អ្នកមានសតិប្រាកដក្នុងឥរិយាបថទាំងពួង អ្នកមានចិត្តជាសមាធិ ។

បណ្តាបទទាំងនោះ បទថា **ឋិតេន កាយេន** សេចក្តីថា អ្នកមានកាយមិនញាប់ញ័រ ពោលគឺ ភាពជាអ្នកមិនមានវិការដោយសង្ខេបថា មានចោបន-កាយ ដែលបុគ្គលតាំងទុកប្រពៃ ព្រោះការមិនសង្ត្រួមធ្វើនូវការសង្ត្រួមផ្ទូវកាយ ម្យ៉ាងទៀត មានកាយដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ដែលតាំងទុកដោយល្អ ព្រោះធ្វើឥន្ទ្រិយ មានចក្ខុន្ទ្រិយជាដើម ឱ្យអស់អស្មិមានៈ ឬមានករជ្ជកាយដែលតាំងនៅដោយភាពមិនប្រែប្រួល ព្រោះមានដៃមិនរពិសជាដើម ព្រោះសង្ត្រួមដៃ និងជើងបានហើយ ។ ដោយពាក្យនោះ ព្រះអង្គទ្រង់សម្តែងដល់ភាពបរិសុទ្ធនៃសីលរបស់ព្រះថេរ: ។ ក៏បទថា **កាយេន** នេះ ជាតតិយាវិភត្តិ ប្រើក្នុងឥត្ថម្ភូតលក្ខណ: ។ ដោយពាក្យថា **ឋិតេន ចេតសា** នេះ ទ្រង់សម្តែងភាពដល់ព្រមនៃសមាធិ ដោយសម្តែងដល់សេចក្តីតាំងមាំនៃចិត្ត ។ មែនពិត

សមាធិ លោកហៅថា ការតាំងមាំនៃចិត្ត ។ ព្រោះដូច្នោះ កាលដែលចិត្តមានអារម្មណ៍ជាមួយ ដោយអំណាចសមថ: ឬដោយអំណាចវិបស្សនា ចិត្តនោះ ឈ្មោះថា តាំងនៅដោយចូលដល់ការ:ជាចិត្តតែមួយក្នុងអារម្មណ៍ មិនមែនតាំងនៅដោយប្រការដទៃទេ ។ ក៏ព្រះដ៏មានព្រះភាគកាលទ្រង់សម្តែងថា ការតាំងនៅ គឺការតាំងមាំនូវកាយ និងចិត្តតាមដែលពោលហើយនេះ គប្បីប្រាជ្ញាគ្រប់ៗកាល និងគ្រប់ៗ ឥរិយាបថ ទើបត្រាស់ថា ឈរក្តី អង្គុយក្តី ដេកក្តីដូច្នេះជាដើម ។

ភ-ស័ព្ទ ក្នុងបាទព្រះគាថានោះ មានអត្ថមិនពិតប្រាកដ ។ ដោយ ភ-ស័ព្ទ នោះ ជាការសម្តែងដល់អត្ថនេះថា ឈរ ឬថា អង្គុយ ដេក ឬក៏ឥរិយាបថដទៃពីនោះ ព្រោះដូច្នោះ សូម្បីការចង្ក្រមក៏គប្បីជ្រាបថា លោកសង្គ្រោះយកក្នុងទីនេះ ។ បទថា **ឯតំ សតឺ ភិក្ខុ អធិដ្ឋហានោ** *សេចក្តីថា ភិក្ខុតាំងទុក គឺតម្រង់ទុក ញ៉ាំងចិត្តឱ្យរហ័សរហួន ឱ្យទន់ភ្ញន់ គួរដល់ការងារដោយប្រពៃ ដោយអំណាចការសូប់កាយ និងចិត្តដោយការអធិដ្ឋាន ដល់សេចក្តីសុខដែលរកទោសមិនបានដែលមិនមានទោស ព្រោះធ្វើកាយ និងចិត្តមិនឱ្យរសាប់រសល់ ដោយការសូប់កាយ និងចិត្តយ៉ាងគ្រាតគ្រាត មិនចាំបាច់ពោលទៅថ្វីដល់អ្នកមានសមាចារដ៏បរិសុទ្ធ ទើបចម្រើនកម្មដ្ឋាន និងឱ្យកម្មដ្ឋានដល់ទីបំផុតដោយ សតិណា ភិក្ខុឃុំគ្រងសតិនោះនុ៎ះឯង ដែលមានឧបការ:ច្រើន ក្នុងខាងដើម កណ្តាល និងទីបំផុត នៃការប្រកបកម្មដ្ឋាន ឃុំគ្រងទុកក្នុងកិច្ចនោះៗ តាំងពីផ្តើមជម្រះសីលឱ្យហ្មត់ចត់ ដរាបដល់សម្រេចគុណវិសេស ។ បទថា* **លភេថ បុញ្ញាបរិយំ វិសេសំ** *សេចក្តីថា លោកមានចិត្តដែលសតិឃុំគ្រងហើយយ៉ាងនេះ ចម្រើន ក-ពូន ធ្វើឱ្យច្រើនឡើង នូវកម្មដ្ឋានឱ្យក្រៃលែងឡើងទៅ គប្បីបាន*

គុណវិសេស ផ្សេងដោយគុណវិសេសដ៏ក្រៃលែង និងក្រៃលែងជាងខាងដើម និងខាងចុង គឺដែលប្រព្រឹត្តទៅដោយចំណែកខាងដើម និងខាងចុង ។

ក្នុងពាក្យនោះ គុណវិសេសដែលជាចំណែកខាងដើម និងខាងចុងមាន ២ យ៉ាង គឺសមថ: ១ វិបស្សនា ១ ។ បណ្តាគុណវិសេសទាំង ២ យ៉ាងនោះ គុណវិសេសដែលប្រព្រឹត្តទៅដោយអំណាចសមថ: បានដល់ ភាពជាអ្នកស្ងាត់ជំនាញ តាំងពីកើតនិមិត្តឡើង ដរាបដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន គុណ-វិសេសចំណែកការនា ដែលប្រព្រឹត្តទៅយ៉ាងនោះ បានដល់ គុណវិសេស ដែលជាចំណែកខាងដើម និងខាងចុង ។ តែកាលពោលអំពីគុណវិសេស ដែលប្រព្រឹត្តទៅដោយអំណាចវិបស្សនា បានដល់ គុណវិសេសចំណែកការនា ដែលប្រព្រឹត្តទៅ ដោយការកំណត់រូបធម៌របស់អ្នកប្រកាន់មាំ ដោយលើករូបឡើងជាប្រធាន ចំណែករបស់អ្នកប្រកាន់មាំក្រៅពីនេះ ប្រព្រឹត្តទៅតាំងពីកំណត់ធម៌ក្រៅពីនេះ ដរាបដល់សម្រេចព្រះអរហត្ត ឈ្មោះថា គុណវិសេសដែលប្រព្រឹត្ត-ទៅក្នុងចំណែកខាងដើម និងខាងចុង ។ ក៏គុណវិសេសនេះឯង លោកប្រាថ្នាយកក្នុងទីនេះ ។

បទថា **លទ្ធាន បុញ្ញាបរិយំ វិសេសំ** សេចក្តីថា បានសម្រេចបារមីយ៉ាងខ្ពស់បំផុត គឺព្រះអរហត្តក្នុងគុណវិសេស ដែលជាចំណែកខាងដើម និងខាងចុង ។ បទថា **អឧស្សរំ មច្ចុភាជស្ស ឋានេ** សេចក្តីថា គប្បីដល់ស្ថានទីដែលមច្ចុមើលមិនឃើញ គឺស្ថានទីដែលមិនជាអារម្មណ៍ ព្រោះឈានកន្ធងកព

៣ ដែលជាអារម្មណ៍របស់មរណៈ ពោលគឺ មច្ចុរាជ ព្រោះគ្របសង្កត់សព្វសត្ត ដោយអំណាចការចូលទៅផ្តាច់ជីវិត ។

ពាក្យដែលខ្ញុំមិនបានពោលទុកក្នុងវគ្គនេះ មានន័យដូចពោលហើយ ក្នុងវគ្គនុ៎ះឯង ។

ឧសមសុត្តវណ្ណា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ១០

និដ្ឋិតា ច សោណត្ថេរវត្តវណ្ណា

ចប់សោណត្ថេរវគ្គវណ្ណនាទី ៥

រួមព្រះសូត្រដែលមានក្នុងវគ្គនេះ គឺ

១-រាជសូត្រ	*២-អប្ផាយុកាសូត្រ*
៣-សុប្ផពុទ្ធកុដ្ឋិសូត្រ	*៤-កុមារកសូត្រ*
៥-ឧបោសថសូត្រ	*៦-សោណសូត្រ*
៧-កង្ខារេវតសូត្រ	*៨-អានន្ទសូត្រ*
៩-សទ្ធាយមានសូត្រ	*១០-ចូឡបន្ថកសូត្រ ។*

៦. ជចុន្ទវគ្គោ

ជចុន្ទវគ្គៈ ៦

១. អាយុសមឧិសជ្ជនសុត្តវណ្ណនា[1]

អដ្ឋកថាអាយុសមឧិសជ្ជនសូត្រ

អាយុសមឧិសជ្ជនសូត្រទី ១ *មានវិនិច្ឆ័យដូចតទៅនេះ*

បទមានជាអាទិ៍ថា **វេសាលិយំ** *មានអត្ថដូចពោលហើយក្នុងកាលមុន នុ៎ះឯង។ បទថា* **វេសាលឺ បិណ្ឌាយ ចារិសិ** *សេចក្តីថា ព្រះអង្គស្តេចចូលទៅ ក្នុងកាលណា? ក្នុងកាលដែលស្តេចចេញចាកឧក្កាចេលវិហារ ហើយស្តេចទៅ កាន់ក្រុងវេសាលី ។*

សេចក្តីពិស្តារថា ព្រះដ៏មានព្រះភាគ ទ្រង់ចាំវស្សាក្នុងវេឡុវគ្រាម ហើយ ស្តេចចេញចាកវេឡុវគ្រាមនោះ ដល់ក្រុងសាវត្ថីដោយលំដាប់ ហើយប្រថាប់នៅ ក្នុងវត្តជេតពន ។ ក្នុងកាលនោះ ព្រះធម្មសេនាបតីពិចារណាមើលអាយុសង្ខារ របស់ខ្លួនដឹងថា នឹងប្រព្រឹត្តទៅបានត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ទើបសូមអនុញ្ញាត ពីព្រះដ៏មានព្រះភាគទៅកាន់នាលកគ្រាម ឱ្យមាតាតាំងនៅក្នុងសោតាបត្តិផល ហើយបរិនិព្វានក្នុងទីនោះ ។ ព្រះសាស្តាទ្រង់កាន់យកព្រះធាតុរបស់ព្រះធម្ម-សេនាបតីដែលព្រះចុន្ទ:នាំមក ហើយឱ្យសាងចេតិយជាទីបញ្ចុះព្រះធាតុ ហៃ-ហមទៅដោយកិត្តិសង្ឆ្យដ៏ច្រើន បានស្តេចទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងកាលស្តេច ទៅកាន់ក្រុងរាជគ្រឹះនោះ ព្រះមហាមោគ្គល្លានបរិនិព្វានហើយ ។ ព្រះដ៏មាន-ព្រះភាគ ទ្រង់កាន់យកព្រះធាតុរបស់ព្រះមហាមោគ្គល្លានសូម្បីនោះ ហើយឱ្យ សាងជាចេតិយ ហើយស្តេចចេញចាកក្រុងរាជគ្រឹះ ស្តេចទៅកាន់ឧក្កាចេលវិហារ

១-ក្នុងអដ្ឋកថាច្បាប់ធម្មសង្គាយនាព្រះសូត្រនេះមានឈ្មោះថាអាយុសង្ខារោសុជ្ជនសុត្តវណ្ណនា ។

តាមលំដាប់ ។ ក្នុងឧក្កាចេលវិហារនោះ ព្រះមានព្រះភាគហែហមទៅដោយ ភិក្ខុសង្ឆ ប្រថាប់អង្គុយទៀបឆ្នេរទន្ទេគង្គា សម្តែងធម៌ដែលជាប់ទាក់ទងដោយ បរិនិព្វានរបស់ព្រះអគ្គសាវកទាំង ២ អង្គ ព្រះមានព្រះភាគចេញចាកឧក្កាចេល-វិហារ ហើយស្តេចទៅកាន់ក្រុងវេសាលី ។ ព្រះដ៏មានព្រះភាគ ស្តេចយាងទៅ យ៉ាងនោះ លោកទើបពោលថា ព្រះដ៏មានព្រះភាគ ទ្រង់ប្រដាប់បាត្រក្នុងវេលា ព្រឹក ព្រះអង្គទ្រង់ស្ងៀកស្បង់ ហើយកាន់បាត្រចីវរចូលទៅក្រុងវេសាលី ដើម្បី បិណ្ឌបាតក្នុងបុព្វណ្ហសម័យ ។ ព្រោះហេតុនោះ លោកទើបពោលថា **ឧក្ក-ចេលតោ និក្ខមិត្វា វេសាលឹ តតកាលេ** ដូច្នេះជាដើម ។

ក្នុងបទថា **និសីឌនំ** នេះ លោកប្រាថ្នាយកកំណាត់ស្បែក ។ បទថា **ចាវាលចេតិយំ** សេចក្តីថា ស្ថានទីដែលយក្ខឈ្មោះថា **ចាវាលៈ**អាស្រ័យនៅ ក្នុងកាលមុន ប្រាកដថា **ចាវាលចេតិយ** ។ សូម្បីវិហារដែលគេសាងថ្វាយព្រះដ៏ មានព្រះភាគ ក្នុងទីនោះគេក៏ហៅថា **ចាវាលចេតិយ** ដោយពាក្យដែលពាស ពេញ ។ សូម្បីក្នុងបទមានជាអាទិ៍យ៉ាងនេះថា **ឧទ្ធេនចេតិយំ** ក៏នយនេះដូច គ្នា ។ បទថា **សត្តមំ** សេចក្តីថា បានឮថា ព្រះរាជកុមារី ៧ ព្រះអង្គ ជាព្រះធីតា របស់ព្រះបាទកាសី ទ្រង់ព្រះនាម **កិកិ** កើតសេចក្តីសង្វេគ ព្រះនាងស្តេចចេញ ចាកក្រុងរាជគ្រឹះ ផ្តើមតាំងសេចក្តីព្យាយាមក្នុងទីណា ទីនោះជនទាំងឡាយនាំ គ្នាហៅថា **សត្តមួចេតិយ** ។ បទថា **ពហុបុត្តំ** សេចក្តីថា ពួកមនុស្សជាច្រើន ប្រាថ្នាបុត្រចំពោះទេវតាអ្នកស្ថិតនៅត្រង់ដើមជ្រៃមួយដើម ជាតំបន់ដែលមានជ្រៃ ច្រើន ព្រោះអាស្រ័យហេតុនោះ ស្ថានទីនោះទើបប្រាកដថា **ពហុបុត្តចេតិយ** ។

បទថា **សារន្ធំ** *បានដល់ ស្ថានទីដែលយក្ខឈ្មោះថា សារន្ធ:អាស្ត្រយនៅ ។ ព្រោះដូច្នោះ ស្ថានទីទាំងអស់នោះនុ៎ះឯងគេហៅដោយរោហារថា* **ចេតិយ** *ព្រោះទេវតាគ្រប់គ្រងតាំងពីមុនពុទ្ធកាល ។ សូម្បីកាលសាងវិហារថ្វាយព្រះដ៏-មានព្រះភាគ ជនទាំងឡាយក៏នៅចាំបានយ៉ាងនោះដូចគ្នា ។ ក្នុងបទថា* **រមណី-យា** *នេះគប្បីជ្រាបថា ក្រុងវេសាលី ជាទីគួររីករាយ ព្រោះសម្បូរដោយភូមិភាគ និងបុគ្គលព្រមព្រៀងគ្នា មានបច្ច័យរកបានងាយជាដំបូង ។ ចំណែកវិហារទាំងឡាយគប្បីជ្រាបថា ជាទីគួររីករាយ ព្រោះមិនធ្វាយពេក មិនជិតពេកពីនគរ សម្បូរដោយគមាគមន៍ ព្រោះជាស្ថានទីមិនច្រឡូកច្រឡំគ្នា សម្បូរដោយម្ទប់និងទឹក និងជាស្ថានទីសមគួរដល់សេចក្តីស្ងាត់ ។ អត្ថនៃបទថាឥទ្ធិបាទ ក្នុងបទថា* **ចត្តារោ ឥទ្ធិបាទា** *នេះ លោកពោលទុកហើយក្នុងកាលមុននោះឯង ។ បទថា* **ភាវិតា** *ប្រែថា បានចម្រើនហើយ ។ បទថា* **ពហុលីកតា** *ប្រែថា ធ្វើរឿយៗ ។ បទថា* **យានីកតា** *បានដល់ ធ្វើឱ្យដូចជាយានដែលទឹមហើយ ។ បទថា* **វត្ថু-កតា** *បានដល់ ធ្វើឱ្យដូចជាវត្ថុ ព្រោះអត្ថថា ជាទីតាំងអាស្ត្រយ ។ បទថា* **អនុ-ដ្ឋិតា** *ប្រែថា តាំងមាំហើយ ។ បទថា* **បរិចិត្តា** *បានដល់ សន្សំដោយជុំវិញ គឺចម្រើនដោយល្អ ។ បទថា* **សុសមារព្ធា** *បានដល់ ប្រារព្ធដោយល្អ គឺឱ្យសម្រេចដោយប្រពៃយ៉ាងក្រៃលែង ។*

ព្រះដ៏មានព្រះភាគ គ្រាទ្រង់សម្តែងដោយមិនកំណត់ដោយប្រការដូច្នេះហើយ កាលនឹងកំណត់សម្តែងបន្ថែមទៀត ទើបត្រាស់ពាក្យមានជាអាទិ៍ថា **តថា-គតស្ស ខោ** *ដូច្នេះ ។ ក៏ក្នុងបទទាំងនេះ បទថា* **កប្បំ** *បានដល់ អាយុកប្ប ។ បទថា* **តិដ្ឋেយ្យ** *បានដល់ គប្បីតាំងនៅគឺ គប្បីទ្រទ្រង់ទុកនូវប្រមាណនៃអាយុ*

របស់មនុស្សក្នុងកាលនោះឱ្យបរិបូណ៌ ។ បទថា **ការ្យាវសេសំ វ** សេចក្ដីថា ក្រៃលែងជាងមួយរយឆ្នាំ ដែលពោលថា **អឍ្ឍំ វ ភ**ិ**យ្យោ** ដូច្នេះជាដើម ។ ចំណែកព្រះមហាសិវត្ថេរ ពោលថា ដែលឈ្មោះថា សំឡេងដែលគ្រហឹម ក្នុងទីដែលមិនគួរ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ តួយ៉ាងដូចថា ព្រះមាន-ព្រះភាគទ្រង់គ្របសង្កត់នូវវេទនា ដែលធ្វើឱ្យព្រះអង្គបរិនិព្វាន ដែលកើតឡើងក្នុងវេឡុវគ្រាម រហូតអស់ ១០ ខែ យ៉ាងណា ក៏ទ្រង់ចូលសមាបត្តិនោះរឿយៗ ហើយគ្របសង្កត់បាន (ដល់ ១០ ខែ) គប្បីតាំងនៅរហូតដល់អស់កទ្ទកប្បនេះ ដូច្នោះ ។ សួរថា ព្រោះហេតុអ្វី ទើបមិនតាំងនៅ? ឆ្លើយថា ព្រោះសរីរៈដែលមានចិត្តគ្រប់គ្រងត្រូវទុក្ខវេទនា មានធ្មេញបាក់ជាដើម ចូលមកគ្របសង្កត់ចំណែក ព្រះពុទ្ធទាំងឡាយ មិនដល់នូវភាវៈនៃទុក្ខវេទនា មានធ្មេញបាក់ជាដើម រមែងបរិនិព្វានក្នុងវេលាដែលជនជាច្រើន នាំគ្នាស្រឡាញ់ពេញចិត្ត ក្នុងចំណែកទី ៥ នៃព្រះជន្មាយុ ក៏កាលព្រះអគ្គសាវក និងព្រះមហាសាវក អ្នកត្រាស់ដឹងតាមព្រះពុទ្ធបរិនិព្វានហើយ គឺព្រះពុទ្ធគប្បីគង់នៅតែមួយព្រះអង្គឯង ត្រឹមតែមិនមានបរិវា ឬមានត្រឹមតែភិក្ខុកំណោះ និងសាមណេរជាបរិវាក៏ដោយ បន្ទាប់ពីនោះ ព្រះអង្គគប្បីដល់នូវភាពជាអ្នកត្រូវបុគ្គលដទៃ មើលងាយថា គួរតក់ស្ទុតបរិស័ទរបស់ព្រះពុទ្ធទាំងឡាយ ព្រោះដូច្នោះ ទើបមិនតាំងនៅ ។ សូម្បីកាលលោកពោលយ៉ាងនោះ តែព្រះមានព្រះភាគក៏ថា មិនតាំងនៅ ។ ពាក្យថា **អាយុ**ក**ប្ប**ោ នេះឯង លោកកំណត់ទុកក្នុងអដ្ឋកថា ។

បទថា **ឱ**ឍ**ារ**ិ**ក**ោ **ន**ិ**ម**ិ**ត្ត**ោ បានដល់ ឱ្យសញ្ញាគ្រោតគ្រាតកើតឡើង ។

មែនពិត ការឱ្យសញ្ញាគ្រាតគ្រាតកើតឡើងនេះ គឺការអង្ករការតាំងនៅរហូតដល់អស់កប្បទាំងអស់ថា សូមព្រះមានព្រះភាគ តាំងនៅរហូតអស់កប្ប គឺជាការប្រកាសភាពជាអ្នកអាចតាំងនៅរហូតអស់កប្ប ដោយអានុភាពនៃការចម្រើនឥទ្ធិបាទ ៤ របស់ខ្លួន ដោយការអាងប្រការដទៃ ដោយន័យមានជាអាទិ៍ថា ម្នាលអានន្ទ ឥទ្ធិបាទ ៤ ដែលអ្នកណាម្នាក់អប់រំហើយ ដូច្នេះ ។ បទថា **ឱ្ភាសេ** *គឺក្នុងព្រះតម្រាស់ដែលប្រាកដ ។ មែនពិត ព្រះតម្រាស់ដែលប្រាកដនេះ គឺការលះពាក្យបរិយាយដោយអម ហើយទើបទ្រង់ប្រកាសសេចក្ដីប្រាថ្នារបស់ព្រះអង្គដោយត្រង់តែម្ដង ។*

បទថា **ពហុជនហិតាយ** *បានដល់ ដើម្បីប្រយោជន៍ដល់មហាជន ។ បទថា* **ពហុជនសុខាយ** *បានដល់ ដើម្បីសេចក្ដីសុខដល់មហាជន ។ បទថា* **លោកនុកម្បាយ** *បានដល់ ព្រោះអាស្រ័យសេចក្ដីអនុគ្រោះដល់សត្វលោក ។ ដល់សត្វលោកណាខ្លះ? គឺដល់អ្នកដែលស្ដាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគហើយចាក់ធ្លុះ គឺផឹកទឹកអម្រឹត ។ មែនពិត ព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធាន ចាក់ធ្លុះនូវធម៌ ដោយទេសនាធម្មចក្កប្បវត្តនសូត្ររបស់ព្រះដ៏មានព្រះភាគ ។ សត្វដែលសម្រេចធម៌ ដរាបដល់ណែនាំសុកទ្ធ-បរិព្វាជក ដោយប្រការយ៉ាងនេះរាប់មិនបាន ។ ពួកសត្វអ្នកបានត្រាស់ដឹងក្នុងវេលាដែលទ្រង់សម្ដែងព្រះសូត្រទាំង ៤ នេះ គឺ**មហាសមយសូត្រ មង្គលសូត្រ ចូឡរាហុលោវាទសូត្រ** និង**សមចិត្តសូត្រ**មិនមានដែនកំណត់ ។ ស្ថានទីកើតមានដល់ព្រះដ៏មានព្រះភាគ ដើម្បីទ្រង់អនុគ្រោះសត្វលោករកប្រមាណមិនបាន ។ ក្នុងទីនេះ លោកពោលអធិប្បាយថា ទ្រង់អនុគ្រោះ សូម្បីក្នុងអនាគត*

ក៏នឹងមានយ៉ាងនេះ ។ បទថា **ទេវមនុស្សានំ** សេចក្តីថា ស្ថានទីរមែងមានដល់ព្រះដ៏មានព្រះភាគ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សតែម្យ៉ាងប៉ុណ្ណោះក៏ទេ សូម្បីដល់សត្វដែលនៅសល់មាន នាគ និងគ្រុទជាដើមក៏មាន ។ ក៏ដើម្បីនឹងសម្តែងកព្វបុគ្គលដែលកាន់បដិសន្ធិដែលមានហេតុ ដោយធ្វើឱ្យច្បាស់នូវមគ្គ និងផល ទើបត្រាស់ទុកហើយយ៉ាងនោះ អធិប្បាយថា ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះជន្មនៅ ដើម្បីប្រយោជន៍ ដើម្បីជួយសង្គ្រោះ ដើម្បីសេចក្តីសុខសូម្បីដល់សត្វពួកដទៃ ។ បណ្តាបទទាំងនោះ បទថា **អត្ថាយ** បានដល់ ដើម្បីប្រយោជន៍ដល់សម្បត្តិក្នុងលោកនេះ ។ បទថា **ហិតាយ** បានដល់ ដើម្បីជាប្រយោជន៍ ជួយសង្គ្រោះដែលជាហេតុនៃសម្បត្តិ ក្នុងលោកខាងមុខ ។ បទថា **សុខាយ** បានដល់ ដើម្បីជាប្រយោជន៍ ដល់សេចក្តីសុខក្នុងព្រះនិព្វាន ។ ក៏ស័ព្ទថា **ហិតៈ** និង**សុខៈ** ដំបូងគប្បីជ្រាបដោយទូទៅដោយអំណាចជាសាធារណស័ព្ទ ។

បទថា **តំ** ក្នុងបទថា **យថាតំ មារេន បរិយុដ្ឋិតចិត្តោ** នេះ ត្រឹមតែជានិបាត អធិប្បាយថា បុថុជ្ជនសូម្បីដទៃអ្នកត្រូវមារចូលបណ្តាលចិត្ត គឺត្រូវមារគ្របសង្កត់ចិត្ត មិនអាចនឹងដឹងច្បាស់បានយ៉ាងណា ព្រះអានន្ទក៏ដូច្នោះ ដែលមិនអាចនឹងដឹងច្បាស់បាន ។ មែនពិត មារមែងគ្របសង្កត់ចិត្តរបស់បុគ្គលដែលនៅលះវិបល្ងាសមិនទាន់បាន ។ ចំណែកក្នុងបុគ្គលដែលនៅលះវិបល្ងាស ១២ យ៉ាង ដោយប្រការទាំងពួងមិនទាន់បាន មិនចាំបាច់ពោលដល់ឡើយ ។ ព្រោះព្រះថេរៈលះវិបល្ងាស ៤ មិនទាន់បានដូច្នោះ ចិត្តរបស់លោកទើបត្រូវមារ

គ្របសង្កត់ ។ សួរថា ក៏មារកាលនឹងគ្របសង្កត់ចិត្តធ្វើយ៉ាងណា? ធ្វើយថា សម្តែងរូបារម្មណ៍ដែលគួរខ្ជាប ឬឱ្យបានឮសទ្ទារម្មណ៍ដែលគួរខ្ជាប ។ បន្ទាប់ពីនោះ សត្វទាំងឡាយ បានឃើញបានឮអារម្មណ៍ ដែលគួរខ្ជាបនោះ ហើយបញ្ចេញសតិ (ធ្លាក់ស្រឡាំងកាំង) ហាមាត់ ។ មារសិកដៃចូលទៅតាមមាត់របស់សត្វទាំងនោះ ហើយច្របាច់បេះដូង ។ បន្ទាប់ពីនោះ សត្វទាំងនោះក៏សន្ធប់ ។ ចំណែកមារ នឹងអាចសិកដៃចូលទៅតាមមាត់របស់ព្រះថេរៈបានយ៉ាងណា តែសម្តែងអារម្មណ៍ដែលគួរខ្ជាបបាន ។ ព្រះថេរៈគ្រាបានឃើញដូច្នោះហើយ ទើបមិនដឹងច្បាស់និមិត្តឱ្យ ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ជ្រាបតែមួយព្រះអង្គឯង ដើម្បីប្រយោជន៍អ្វី ទើបព្រះអង្គត្រាស់ ៣ ដង? គឺតទៅខាងមុខ ដើម្បីធ្វើសេចក្តីសោកសៅឱ្យស្រាលខ្លះ ដោយលើកទោសឡើងថា ប្រការនោះ ជាការធ្វើមិនល្អរបស់លោក ប្រការនោះជាកំហុសរបស់លោក ក្នុងកាលលោកអង្វរថា សូមព្រះដ៏មានព្រះភាគតាំងនៅ ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់ឃើញថា អានន្ទនេះមានចិត្តស្និទ្ធក្នុងតថាគតយ៉ាងក្រៃលែងតទៅខាងមុខ លោកបានឮហេតុផែនដីញ័រ និងការដាក់អាយុសង្ខារ នឹងអាចធនាឱ្យតថាគត តាំងនៅរហូតអស់កាលយូរ កាលបើដូច្នោះ តថាគត នឹងឱ្យទោសធ្លាក់ចុះលើសីសៈរបស់លោកប៉ុណ្ណោះថា ពីដំបូង ព្រោះហេតុអ្វី បានជាអ្នកមិនអាចធនាតថាគតមុន ។ ក៏ព្រោះទោសរបស់ខ្លួន សត្វទាំងឡាយក៏នឹងមិនក្តៅតក្រហាយដូច្នោះ ព្រោះហេតុនោះ សេចក្តីសោកសៅរបស់លោក ក៏នឹងស្រាលខ្លះ ។

បទថា **កច្ច ត្វं អានន្ទ** *សេចក្តីថា ព្រោះហេតុដែលលោកមកក្នុងទីនេះ ដើម្បីសម្រាកក្នុងពេលថ្ងៃ ព្រោះដូច្នោះ ម្នាលអានន្ទ អ្នកចូរទៅកាន់ស្ថានទីតាម*

ដែលអ្នកពេញចិត្ត ដើម្បីសម្រាកពេលថ្ងៃចុះ ។ ព្រោះហេតុនោះនុ៎ះឯង ព្រះអង្គទើបត្រាស់ថា ម្នាលអានន្ទ អ្នកចូរសម្គាល់កាល ដែលសមគួរដល់ករណីយៈឥឡូវនេះចុះ ដូច្នេះជាដើម ។

ក្នុងបទថា **មារោ បាបិមា** នេះ មានវិគ្រោះដូចតទៅនេះ ឈ្មោះថាមារព្រោះប្រកបពួកសត្វទុកក្នុងសេចក្តីវិនាស ធ្វើឱ្យស្លាប់ ។ បទថា **បាបិមា** នេះជាវេវចនៈរបស់បទថា **មារ** នោះនុ៎ះឯង ។ មែនពិត មារនោះ លោកហៅថា **បាបិមា** ព្រោះប្រកបដោយបាបធម៌ ។ បទថា **ភាសិតា ខោ បនេសា** សេចក្តីថា មែនពិត មារនេះ កាលព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់នៅត្រង់ដើមអជ-បាលនិគ្រោធកន្លងទៅ ៧ ថ្ងៃត្រង់ពោធិមណ្ឌល ធីតាទាំងឡាយរបស់ខ្លួនបាននាំគ្នាមក ត្រូវសេចក្តីប្រាថ្នាកាត់ផ្តាច់ ហើយក៏នាំគ្នាទៅ មារនេះគិតថាឧបាយនេះប្រើបាន ទើបមកពោលថា បពិត្រព្រះដ៏មានព្រះភាគ ព្រះអង្គបំពេញបារមីមកដើម្បីប្រយោជន៍ណា ប្រយោជន៍នោះព្រះអង្គសម្រេចហើយដោយលំដាប់ សព្វញ្ញុតញ្ញាណព្រះអង្គបានចាក់ធ្លុះចំពោះហើយ ព្រះអង្គនឹងមានប្រយោជន៍អ្វី ដោយការនៅក្នុងលោកដូច្នេះ ហើយទើបទូលអារាធនាថា សូមព្រះដ៏មានព្រះភាគ ចូរបរិនិព្វានក្នុងកាលឥឡូវនេះចុះព្រះអង្គ ពាក្យដែលមារបានពោលក្នុងកាលឥឡូវនេះ ក៏ដូចគ្នា ។ ចំណែកព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហាមមារនោះមានជាអាទិ៍ថា តថាគតមិនទាន់បរិនិព្វានទេ ព្រោះដូច្នេះដែលលោកសំដៅពោលទុកក្នុងកាលឥឡូវនេះថា **ភាសិតា ខោ បនេសា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **វិយត្តា** *បានដល់ អ្នកស្ទាត់ជំនាញដោយការសម្រេចអរិយមគ្គ ។ បទថា* **វិនីតា** *បានដល់ អ្នកបានទទួលការណែនាំដោយការកម្ចាត់កិលេសយ៉ាងនោះនុ៎ះឯង ។ បទថា* **វិសារទា** *បានដល់ អ្នកដល់នូវភាពក្លៀវក្លា ព្រោះការលះទិដ្ឋិ និងវិចិកិច្ឆាជាដើម ដែលធ្វើនូវសេចក្តីតម្រេក ។ បទថា* **ពហុស្សុតា** *សេចក្តីថា ឈ្មោះថា* **ពហុស្សុត** *ព្រោះមានព្រះពុទ្ធវចនៈ ដែលស្តាប់ហើយច្រើន ដោយអំណាចបិដកទាំង ៣ ។ ឈ្មោះថា* **ធម្មធរ** *ព្រោះទ្រទ្រង់ទុកនូវធម៌នោះនុ៎ះឯង ។ ម្យ៉ាងទៀត បទថា* **ពហុស្សុតា** *បានដល់ ព្រោះមានព្រះបរិយត្តិដែលស្តាប់ហើយច្រើន និងព្រោះមានបដិវេធដែលស្តាប់ហើយច្រើន ។ គប្បីជ្រាបអត្ថក្នុងបទថា* **ធម្មធរ** *នេះ សូម្បីដោយអាការយ៉ាងនេះថា ឈ្មោះថា* **ធម្មធរ** *ព្រោះទ្រទ្រង់ទុកនូវព្រះបរិយត្តិធម៌ និងបដិវេធធម៌ ។ បទថា* **ធម្មានុធម្មប្បដិបន្ន** *បានដល់ អ្នកបដិបត្តិវិបស្សនាធម៌ដែលជាធម៌សមគួរដល់អរិយធម៌ ។ បទថា* **សាមីចិប្បដិបន្ន** *បានដល់ អ្នកបដិបត្តិបដិបទាដែលបន្តៗ គ្នាមកដោយវិសុទ្ធិ ដែលសមគួរដល់ញាណទស្សនៈ-វិសុទ្ធិ ។ បទថា* **អនុធម្មចារិនោ** *បានដល់ អ្នកមានប្រក្រតីប្រព្រឹត្តធម៌ មានសេចក្តីប្រាថ្នាតិចជាដើម ដែលដុសខាត់យ៉ាងក្រៃលែង គឺដែលសមគួរដល់បដិបទានោះ ។ បទថា* **សកំ អាចរិយកំ** *បានដល់ ដែលកាន់តាមវាទៈ-របស់អាចារ្យនៃខ្លួន ។ បទថា* **អាចិក្ខិស្សន្តិ** *បានដល់ នឹងសម្តែងតែខាងដើម អធិប្បាយថា នឹងឱ្យអ្នកដទៃរៀនសូត្រ តាមទំនងដែលខ្លួនរៀនមក ។ បទថា* **ទេសិស្សន្តិ** *បានដល់ នឹងប្រាប់ អធិប្បាយថា នឹងប្រាប់បាលីដោយប្រពៃ ។ បទថា* **បញ្ញបេស្សន្តិ** *ប្រែថា នឹងឱ្យដឹងច្បាស់ អធិប្បាយថា នឹងប្រកាស ។*

បទថា **បជ្ជបេស្សន្តិ** *ប្រែថា នឹងតាំងទុកដោយប្រការទាំងឡាយ ។ បទថា* **វិវរិស្សន្តិ** *ប្រែថា នឹងធ្វើឱ្យបើកចំហ ។ បទថា* **វិភជិស្សន្តិ** *ប្រែថា នឹងធ្វើការចែក ។ បទថា* **ឧត្តានីការិស្សន្តិ** *បានដល់ នឹងធ្វើអត្ថដែលមិនងាយយល់ គឺដ៏ជ្រាលជ្រៅ ឱ្យជាអត្ថងាយយល់ គឺប្រាកដ ។ បទថា* **សហេតុកេន** *បានដល់ ដោយពាក្យដែលប្រព្រឹត្តទៅនឹងដោយហេតុ គឺដែលប្រព្រឹត្តទៅដោយការណ៍ ។ បទថា* **សប្បដិហារិយំ** *បានដល់ ធ្វើដរាបឱ្យចេញពីទុក្ខ ។ បទថា* **ឆម្ភិនេសេស្សន្តិ** *សេចក្ដីថា នឹងញ៉ាំងពួកសត្វឱ្យត្រាស់ដឹង គឺនឹងប្រកាសលោកុត្តរធម៌ ៩ ។*

ក៏ក្នុងបទទាំងនោះ ដោយបទ ៦ បទ មានជាអាទ៍ថា **បញ្ញបេស្សន្តិ** *លោកសម្ដែងដល់បទដែលជាអត្ថ ៦ បទ ។ ក៏ដោយ ២ បទខាងដើម លោកសម្ដែងដល់បទដែលជាព្យញ្ជនៈ ៦ បទនោះឯង ។ ដោយលំដាប់ពាក្យត្រឹមតែប៉ុណ្ណោះព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ជាពាក្យដែលលោកសម្ដែងសង្គ្រោះដោយន័យនៃសំវណ្ណនា ។ សមដូចពាក្យដែលលោកពោលទុកក្នុងនេត្តិប្បករណ៍ថា បទ ១២ បទ ចាត់ជាសូត្រ សូត្រទាំងអស់នោះ ជាព្យញ្ជនៈ ១ ជាអត្ថៈ ១ ។*

បទថា **ព្រហ្មចរិយំ** *បានដល់ សាសនព្រហ្មចរិយៈទាំងអស់ដែលសង្គ្រោះដោយត្រៃសិក្ខា ។ បទថា* **ឥទ្ធំ** *បានដល់ សម្រេចដោយការញ៉ាំងឈានឱ្យកើតឡើង ។ បទថា* **ផីតំ** *បានដល់ ដល់សេចក្ដីចម្រើន គឺបញ្ចេញផលឱ្យផ្សាយទៅដោយការដល់ព្រមដោយអភិញ្ញា ។ បទថា* **វិត្ថារិកំ** *បានដល់ ធំទូលាយដោយការប្រតិស្ថានទៅក្នុងទិសាភាគនោះៗ ។ បទថា* **ពហុជញ្ញំ** *បានដល់ ជនជាច្រើនស្គាល់គ្នា គឺដឹងចាក់ធ្ងុះរហូតអស់ដោយអំណាចការត្រាស់ដឹងរបស់ជនជាច្រើន ។*

បទថា **បុថុភូតំ** *បានដល់ ដល់សេចក្តីសូម្បីក្រាស់ដោយអាការទាំងពួង ។ យ៉ាងណា? គឺដរាបប៉ុនដែលទេវតា និងមនុស្សប្រកាសល្អហើយ អធិប្បាយថា ទេវតា និងមនុស្សអ្នកមានជាតិនៃវិញ្ញូជនមានប្រមាណប៉ុនណា ទេវតា និងមនុស្សទាំងនោះទាំងអស់ប្រកាសល្អហើយ ។*

បទថា **អប្ប្ហាសុ្ពុ ្ហ** *បានដល់ អស់សេចក្តីឧស្សាហ៍ គឺប្រាសចាកសេចក្តីហួងហែង ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមារមានចិត្តបាប ក៏តាំងពី ៧ សប្តាហ៍កន្ទងទៅ លោកត្រាប់ស្រែកថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏-មានព្រះភាគ ចូរបរិនិព្វានក្នុងកាលឥឡូវនេះចុះ សូមព្រះសុគត ចូរបរិនិព្វានក្នុងកាលឥឡូវនេះចុះ ឥឡូវនេះ ចាប់ពីថ្ងៃនេះទៅ អ្នកចូរប្រាសចាកសេចក្តីព្យាយាមចុះ ចូរកុំធ្វើសេចក្តីព្យាយាមដើម្បីឱ្យតថាគតបរិនិព្វានឡើយ ។*

បទថា **សតោ សម្ប្ជានោ អាយុសង្ខារំ ឱ្ សុ្ជ្ជិ** *សេចក្តីថា ព្រះអង្គទ្រង់មានសតិតាំងមាំហើយកំណត់ដោយញាណដាក់ គឺលះបង់អាយុសង្ខារ ។ ក្នុងការដាក់អាយុសង្ខារនោះ ព្រះដ៏មានព្រះភាគមិនបានទ្រង់ដាក់អាយុសង្ខារដូចយកដៃដាក់ដុំដី តែព្រះអង្គកើតព្រះតម្រិះឡើងថា រហូតអស់រយៈត្រឹមតែ ៣ ខែប៉ុណ្ណោះ តថាគតនឹងចូលសមាបត្តិទៀត ក្រោយពីនោះនឹងមិនចូលសមាបត្តិទៀតទេ ដែលលោកសំដៅពោលទុកថា ព្រះអង្គទ្រង់ដាក់ហើយ ។ បាលីថា* **ភោ សុ្ជ្ជិ** *ដូច្នេះក៏មាន ។*

ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគអាចតាំងនៅរហូតអស់កប្ប ឬលើសពីកប្ប តែព្រះអង្គមិនតាំងនៅរហូតដល់អស់កាលត្រឹមនោះ ទ្រង់ដាក់អាយុសង្ខារតាមដែលមារមកអារាធនាដើម្បីឱ្យព្រះអង្គបរិនិព្វាន ព្រោះព្រះដ៏មានព្រះភាគ

មិនបានទ្រង់ដាក់អាយុសង្ខារ តាមការអាវជនារបស់មារ និងមិនមែនដាក់អាយុសង្ខារ តាមដែលព្រះថេរៈសូមអង្វរដែរ តែថា ក្រោយចពី ៣ ខែទៅ ព្រះអង្គទ្រង់ដាក់អាយុសង្ខារ ព្រោះមិនមែនពុទ្ធវេនេយ្យទេ ធម្មតាថា ការតាំងនៅនៃព្រះពុទ្ធជាព្រះភាគទាំងឡាយ ក៏ស្ថិតនៅដើម្បីនឹងណែនាំវេនេយ្យសត្ត្ব កាលវេនេយ្យជនមិនមាន ព្រះពុទ្ធជាព្រះមានព្រះភាគទាំងឡាយ នឹងតាំងនៅដោយហេតុណា ក៏បើថា ព្រះអង្គ នឹងគប្បីបរិនិព្វានតាមដែលមារមកសូមអង្វរ ក៏នឹងគប្បីបរិនិព្វានតាំងពីមុននោះតែម្តង ។ ម្យ៉ាងទៀត លោកពោលសេចក្តីនេះទុកថា មែនពិត សូម្បីត្រង់ពោធិមណ្ឌល មារក៏មកអាវជនាទុកហើយដល់ការធ្វើនិមិត្តឱ្យកាសក៏ដើម្បីធ្វើសេចក្តីសោករបស់ព្រះថេរៈឱ្យស្រាលខ្លះ ។ ម្យ៉ាងទៀត ការធ្វើនិមិត្តឱ្យកាស ក៏ដើម្បីសម្តែងកម្ទាំងរបស់ព្រះពុទ្ធ ។ ព្រះពុទ្ធជាព្រះមាន-ព្រះភាគទាំងឡាយ ព្រះអង្គមានអានុភាពច្រើនយ៉ាងនេះ សូម្បីតាំងនៅ ក៏តាំងនៅតាមសេចក្តីពេញព្រះទ័យរបស់ព្រះអង្គ សូម្បីការបរិនិព្វាន ក៏និងបរិនិព្វានតាមព្រះទ័យរបស់ព្រះអង្គដែរ ។

បទថា **មហាភូមិចាលោ** បានដល់ ផែនដីញ័រយ៉ាងខ្លាំង ។ បានឮថា ក្នុងកាលនោះ ម៉ឺននៃលោកធាតុញាប់ញ័រហើយ ។ បទថា **ភីសនកោ** ប្រែថា ឱ្យកើតសេចក្តីភ័យខ្លាច ។ បទថា **ទេវទុន្ទុភិយោ ច ផលឹសុ** សេចក្តីថា ស្គររបស់ទេវតាក៏លាន់ឮ ។ មេឃក៏បន្ទឹផ្គរឡើង ផ្ទេកបន្ទោរដែលកើតក្នុងវេលាមិនមែនរដូវកាល ក៏បញ្ចេញពន្ទឹចាំង អធិប្បាយថា ភ្លៀងខ្លាំងក៏បង្អុរឡើង ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ដឹងអាការទាំងពួងដល់អត្ថនេះ

ពោលគឺ សេចក្ដីពិសេសនៃសង្ខារ និងវិសង្ខារ ។ បទថា **ឥមំ ឧជានំ** *សេចក្ដីថា ទ្រង់បន្ទឺឧទាន ដែលសម្ដែងដល់ការដែលព្រះអង្គទ្រង់លះបង់សង្ខារមិនមាន នៅសល់ហើយដល់វិសង្ខារ ។*

ព្រោះហេតុអ្វី ព្រះអង្គទើបទ្រង់បន្ទឺឧទាននេះ? ព្រោះអ្នកណាៗក៏ជឿថា ព្រះអង្គត្រូវមារជាប់តាមពីខាងក្រោយៗ ហើយពោលដដែលៗថា សូមព្រះអង្គ បរិនិព្វានចុះ សូមព្រះអង្គបរិនិព្វានចុះ ព្រះអង្គទើបទ្រង់លះបង់អាយុសង្ខារ ព្រោះខ្ជាចមារ ។ ដើម្បីនឹងសម្ដែងសេចក្ដីនេះថា មារនោះចូរកុំមានឱកាសឡើយ ព្រោះធម្មតាថា អ្នកពោលរមែងមិនមានការបន្ទឺឧទាន ព្រះអដ្ឋកថាចារ្យទើប ពោលទុកក្នុងអដ្ឋកថាថា ទ្រង់បន្ទឺឧទានដែលកើតពីបីតិ ។ ក៏ពុទ្ធកិច្ចដែលនឹង សម្រេចដោយវេលាត្រឹមតែ ៣ ខែប៉ុណ្ណោះ កាលព្រះអង្គទ្រង់ឃើញថា តថាគត រក្សាការ: គឺទុក្ខនេះមកយូរយ៉ាងនេះ មិនយូរទេតថាគតនឹងដាក់ចុះ ដូច្នេះ បីតិ និងបាមោជ្ជ: ដ៏ក្រៃលែងទើបកើតឡើង ដោយការពិចារណាគុណនៃព្រះនិព្វាន ដែលគួរនឹងពោលថា ទ្រង់បន្ទឺឧទានដោយកម្លាំងបីតិ ។ មែនពិត ព្រះសាស្ដា ទ្រង់ បង្អោនក្នុងវិសង្ខារ គឺមានព្រះនិព្វានជាអធ្យាស្ស័យដោយចំណែកតែមួយ ទើប ទ្រង់តាំងនៅក្នុងលោករហូតអស់កាលយូរ ដើម្បីជាប្រយោជន៍ដល់សត្ត្ব ដោយ ព្រះមហាករុណាដូចតាំងនៅក្នុងពលក្ការ[1] ។ ពិតយ៉ាងនោះ ព្រះអង្គទ្រង់ចូល

១-ពលក្ការ ព:ល័ក-កា បា.; សំ. (ន.) (ពលាត្ការ) ការកំហែង, គំរាម : វាហ៊ានធ្វើពលក្ការតាមអំពើចិត្ត ឥតកោតក្រែងច្បាប់ ។(ស្រង់ចាកវចនានុក្រមខ្មែរសម្ដេចព្រះសង្ឆរាជ **ជោតញ្ញាណោ** *ជ.ណ)*

សមាបត្តិបានពីរលានបួនសែនកោដិវាល់ថ្ងៃ ឥឡូវនេះព្រះអង្គបែរព្រះកក្ត្រ ចំពោះព្រះនិព្វាន ព្រោះអធិការដែលប្រកបដោយព្រះមហាករុណា សម្រេចហើយ ទើបសោយបីតិ និងសោមនស្សមិនតិច ។ ក៏ព្រោះហេតុនោះនុ៎ះឯង រស្មីនៃព្រះរូបធោមរបស់ព្រះដ៏មានព្រះភាគ ទើបបរិសុទ្ធផូរផង់ ជាពិសេស សូម្បីក្នុងថ្ងៃរលត់ខន្ធបរិនិព្វាន ក៏ដូចក្នុងថ្ងៃរលត់កិលេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះគាថាដូចតទៅនេះ ។ កាមាវចរកម្ម ឈ្មោះថា **តុលៈ** ព្រោះថ្លឹងបាន គឺកំណត់បាន ដោយការៈប្រចក្សសូម្បីដល់ផ្ដែស្រុក និងចចកជាដើម ។ មហគ្គតកម្ម ឈ្មោះថា **អតុលៈ** ព្រោះថ្លឹងមិនបាន ឬព្រោះមិនមានលោកិយកម្មដទៃដែលថ្លឹងបាន គឺស្មើដូចគ្នា ។ កាមាវចរកម្ម ឬរូបាវចរកម្ម ឈ្មោះ **តុលៈ** អរូបាវចរកម្ម ឈ្មោះ **អតុលៈ** ម្យ៉ាងទៀត កម្មដែលមានវិបាកតិច ឈ្មោះ **តុលៈ** កម្មដែលមានវិបាកច្រើន ឈ្មោះ **អតុលៈ** ។ បទថា **សម្ភវំ** សេចក្ដីថា ជាហេតុនៃការកើត គឺធ្វើឱ្យកើត ។ បទថា **ភវសङ्खारं** បានដល់ ធ្វើសង្ខារក្នុងភពថ្មីឱ្យកើត ។ បទថា **អវស្សជ្ជि** បានដល់ បញ្ចេញដាក់ ។ បទថា **មុនि** បានដល់ ពុទ្ធមុនि ។ បទថា **អជ្ឈត្តរតោ** ប្រែថា ត្រេកអរខាងក្នុងខ្លួន ។ បទថា **សមาហิតោ** បានដល់ មានចិត្តជាសមាធិដោយឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា **អភិនฺทि ภวเจมิว** សេចក្ដីថា ទម្ងាយទៅ ដូចទាហានទម្ងាយគ្រឿងក្រោះដូច្នោះ ។ បទថា **អត្តสម្ภวํ** បានដល់ កិលេសដែលកើតក្នុងខ្លួន ។ លោកពោលអធិប្បាយទុកថា មុនីដាក់ចុះលោកិយកម្ម ពោលគឺ កម្មដែលថ្លឹងបាន និងថ្លឹង

*មិនបាន ដែលមានឈ្មោះថា **សម្ភវ:** ព្រោះអត្ថថា មានវិបាក និងឈ្មោះមានថា **ភវសង្ខារ** ព្រោះអត្ថថា តាក់តែងកត និងជាអ្នកត្រេកអរក្នុងខាងក្នុងមានចិត្តជាសមាធិ បានទម្លាយកិលេសដែលមានខ្ជួនជាដែនកើត ដូចមេទាហានអ្នកជំទម្លាយគ្រឿងក្រោះក្នុងសមរភូមិ ដូច្នោះ ។*

*ម្យ៉ាងទៀត បទថា **តុលំ** បានដល់ ថ្លឹង គឺពិចារណា ។ បទថា **អតុ-លញ្ច សម្ភវំ** បានដល់ ព្រះនិព្វាននិងកត ។ បទថា **ភវសង្ខារំ** បានដល់ កម្ម ដែលនាំសត្វទៅកាន់កត ។ បទថា **អវិជ្ជ មុនិ** សេចក្ដីថា ព្រះពុទ្ធមុនី ទ្រង់ពិចារណាដោយន័យមានជាអាទិ៍ថា បញ្ចខន្ធមិនទៀង ការរលត់បញ្ចខន្ធ គឺព្រះនិព្វានទៀង ទ្រង់ឃើញទោសក្នុងកត និងអានិសង្សក្នុងព្រះនិព្វាន ទ្រង់ដាក់ចុះនូវភវសង្ខារកម្ម ដែលជាមូលនៃខន្ធទាំងឡាយនោះ ដោយអរិយមគ្គ ដែលធ្វើការអស់ទៅនៃកម្ម ដែលលោកពោលទុកយ៉ាងនេះថា រមែងប្រព្រឹត្ត ទៅដើម្បីការអស់កម្ម ។ យ៉ាងណា? គឺលោកត្រេកអរក្នុងខាងក្នុង មានចិត្តជាសមាធិ បានទម្លាយកិលេសដែលកើតក្នុងខ្ជួន ដូចទាហានទម្លាយគ្រឿងក្រោះ ។ មែនពិត ព្រះពុទ្ធមុនី ក៏ព្រះអង្គត្រេកអរក្នុងខាងក្នុង ដោយវិបស្សនា មានចិត្តជាសមាធិដោយសមថ: រួមសេចក្ដីថា លោកទម្លាយកិលេសទាំងអស់ដែលរួបរឹតអត្តភាព ដែលបាននាមថា **អត្តសម្ភវ:** ព្រោះកើតក្នុងខ្ជួនដោយកម្ទាំងនៃសមថ:និងវិបស្សនា តាំងពីចំណែកខាងដើម ដូចទាហានទម្លាយគ្រឿងក្រោះដូច្នោះ និងកាលមិនមានកិលេស ដែលឈ្មោះថា លះបង់កម្មបានដាច់ខាត*

ព្រោះមិនមានបដិសន្ធិ ។ លោកលះបង់កម្ម ព្រោះលះបង់កិលេស ដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ព្រះអង្គដាក់ចុះនូវភវសង្ខារក្នុងកពត្រង់គល់នៃពោធិព្រឹក្សនុ៎ះឯង សូម្បីញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយគ្រឿងជួសជុល គឺសមាបត្តិ ដូចធ្វើរទេះចាស់ឱ្យទៅបាន ដោយគ្រឿងជួសជុល ទើបទ្រង់ដាក់ចុះនូវអាយុសង្ខារ ដោយធ្វើព្រះហឫទ័យឱ្យកើតឡើងថា បន្ទាប់ពី ៣ ខែនេះទៅ តថាគតនឹងមិនឱ្យគ្រឿងជួសជុល គឺសមាបត្តិដល់សង្ខារនេះ ដូច្នេះឯង ។

បឋមសុត្តវណ្ណា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១

២-បដិសល្លានសុត្តវណ្ណនា[១]

អដ្ឋកថាបដិសល្លានសូត្រ

បដិសល្លានសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **ពហិទ្វារកោដ្ឋកេ** *បានដល់ ខាងក្រៅស៊ុមទ្វារប្រាសាទ មិនមែនខាងក្រៅស៊ុមទ្វារវិហារ ។ បានឮថា ប្រាសាទនោះដូចជាលោហប្រាសាទ ដោយជុំវិញឡោមព័ទ្ធដោយកំពែង ដែលមានខ្លោងទ្វារទាំង ៤ ដោយជុំវិញ ។ ត្រង់ម្លប់ប្រាសាទខាងក្រៅស៊ុមទ្វារ នៃទិសខាងកើត បណ្ដាស៊ុមទ្វារទាំងនោះ ព្រះមានព្រះភាគ ព្រះអង្គប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេចាត់ចែងទុក ទ្រង់រមិលមើលលោកធាតុទិសខាងកើត ។*

បទថា **ជដិលា** *បានដល់ អ្នកទ្រទ្រង់ភេទតាបសអ្នកមានជដា ។ បទថា* **និគ្គណ្ឋា** *បានដល់ អ្នកទ្រទ្រង់រូបនិគ្រន្ថ ដែលស្លៀកសំពត់ស ។ បទថា* **ឯកសាដកា** *បានដល់ អ្នកយកសំពត់ចាស់មួយកំណាត់ចងដៃ បិទបាំងផ្នែកខាងមុខរបស់រាងកាយ ដោយជាយសំពត់ចាស់ដទៃទៀតត្រាច់ទៅ ដូចពួកនិគ្រន្ថ អ្នកមានសំពត់តែមួយផ្ទាំង ។ បទថា* **បរូឡ្ហកច្ឆនខលោមា** *បានដល់ អ្នកមានរោមក្លៀកដុះហើយ ក្រចកដុះហើយ និងរោមក្រៅនោះក៏ដុះហើយ អធិប្បាយថា រោមក្លៀកជាដើមវែង និងក្រចកវែង ។ បទថា* **ខារិវិវិធមាទាយ** *សេចក្ដីថា ប្រើសង្រែកផ្សេងៗ អម្រែកជាគ្រឿងបរិក្ខាររបស់បព្វជិតមានប្រការផ្សេងៗ ។ បទថា* **អវិទូរេ អតិក្កាមន្តិ** *សេចក្ដីថា ចូលទៅកាន់នគរតាមផ្លូវដែលមិនឆ្ងាយពីព្រះវិហារ ។*

បទថា **រាជាហំ ភន្តេ បសេនទិកោសលោ** *សេចក្ដីថា បពិត្រលោកដ៏*

១-ក្នុងអដ្ឋកថាច្បាប់ឆដ្ឋសង្គាយនា ព្រះសូត្រនេះមានឈ្មោះថា **សត្តជដិលសុត្តវណ្ណនា** *។*

ចម្រើនទាំងឡាយ យើងជាព្រះរាជានាមបសេនទិកោសល អ្នកទាំងឡាយចូរដឹងឈ្មោះយើងយ៉ាងនេះ ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះរាជាប្រថាប់នៅក្នុងសម្នាក់របស់អគ្គបុគ្គលក្នុងលោក បែរជាផ្តងអញ្ជលីចំពោះអ្នកអាក្រាត អ្នកមិនមានសិរីបែបនេះហ្ន៎ ។ ឆ្លើយថា ដើម្បីនឹងទ្រង់សង្គ្រោះ ។ មែនពិត ព្រះបាទបសេនទិកោសល មានព្រះតម្រិះយ៉ាងនេះថា ប្រសិនបើយើងនឹងមិនធ្វើហេតុសូម្បីត្រឹមតែប៉ុណ្ណោះដល់ពួកនិគ្រន្ថទាំងនេះ ពួកនិគ្រន្ថទាំងនេះ ក៏នឹងគិតថា ពួកយើងលះបុត្រនិងភរិយា បានទទួលការបរិភោគ និងការដេកដ៏លំបាកជាដើម ដើម្បីប្រយោជន៍ដល់ព្រះរាជាអង្គនេះ ព្រះរាជាអង្គនេះទ្រង់មិនធ្វើសូម្បីត្រឹមតែសេចក្តីកោតក្រែងដល់ពួកយើង ។ ព្រោះកាលទ្រង់ធ្វើសេចក្តីកោតក្រែងជាដើមនោះ អ្នកនឹងមិនជឿពួកយើងថាជាពួកសិក្ខាកាម នឹងយល់ថា យើងជាបព្វជិតពិត នឹងប្រយោជន៍អ្វីដោយការប្រាប់សេចក្តីពិតដល់ព្រះរាជាអង្គនេះ ទើបបិទបាំងវត្ថុដែលខ្ជិនឃើញនឹងបានឮមកមិនប្រាប់ តែកាលទ្រង់ធ្វើយ៉ាងនោះ ជនទាំងនោះនឹងប្រាប់ដោយមិនបិទបាំង ។ ម្យ៉ាងទៀត សូម្បីទ្រង់ជ្រាបអធ្យាស្ស័យរបស់ព្រះសាស្តា ព្រះរាជាទើបទ្រង់ធ្វើយ៉ាងនោះឯង ។ បានឮថា ព្រះរាជាសូម្បីកាលចូលទៅគាល់ព្រះដ៏មានព្រះភាគ ក៏ទ្រង់មិនជឿព្រះសម្មាសម្ពោធិញ្ញាណអស់កាលបន្តិចបន្តួច ។ ព្រោះហេតុនោះ ព្រះរាជាទើបមានព្រះតម្រិះយ៉ាងនេះថា បើព្រះដ៏មានព្រះភាគទ្រង់ជ្រាបហេតុទាំងពួង កាលយើងធ្វើសេចក្តីកោតក្រែងចំពោះជនទាំងនេះហើយនិយាយថា ជនទាំងនេះជាព្រះអរហន្ត ក៏នឹងមិនគប្បីដឹង បើថា ព្រះអង្គទ្រង់ជឿតាមយើង ព្រះអង្គនឹងជាព្រះសព្វញ្ញូ

មានមកពីណា ។ ព្រះរាជាបានធ្វើយ៉ាងនោះ ដើម្បីនឹងទ្រង់ជ្រាបអធ្យាស្ស័យ
របស់ព្រះសាស្តាដោយប្រការដូច្នេះ ។ តែព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា កាល
យើងបសេនទិកោសលពោលទៅត្រង់ៗថា ជនទាំងនេះមិនមែនជាសមណៈ ជា
អ្នកពោលពាក្យសិក្ខាសៀត សូម្បីបើព្រះរាជាគប្បីជឿសោត ចំណែកមហាជន
កាលមិនជ្រាបសេចក្ដីនោះ ក៏នឹងមិនគប្បីជឿ គប្បីពោលថា ព្រះសមណគោតម
ត្រាស់ពាក្យអ្វីៗ ដរាបស្ងាត់ព្រះឱសថ ព្រះរាជាស្ដាប់ពាក្យរបស់ព្រះដ៏មាន-
ព្រះភាគប្រការនោះនឹងគប្បីប្រព្រឹត្តទៅដើម្បីមិនមែនជាប្រយោជន៍ ដើម្បីសេចក្ដី
ទុក្ខអស់កាលយូរដល់មហាជននោះ ទាំងការងារកំចាំងរបស់ព្រះរាជានឹងគប្បី
បើកផ្សាយឡើង ព្រះរាជានឹងត្រាស់ថា ពួកទាំងនោះជាអ្នកសិក្ខាសៀតដោយ
ព្រះអង្គឯង ទើបត្រាស់ពាក្យមានជាអាទិ៍ថា ប្រការនោះដឹងបានដោយលំបាក ។

បណ្ដាបទទាំងនោះ បទថា **កាមភោគិនា** *បានដល់ ត្រូវរាគៈគ្រប-*
សង្កត់ ។ សូម្បីដោយបទទាំង ២ នោះ លោកសម្ដែងដល់ជនទាំងនោះមានចិត្ត
ពយមាយ ។ បទថា **បុត្តសម្ពាធសយនំ** *បានដល់ ទ្រង់ដេកជ្រៀតជ្រៀតដោយ*
ឱរស និងមហេសី ។ ក៏ក្នុងការនេះ លោកសម្ដែងដល់ការកំណត់យកមហេសី
ដោយលើកឱរសឡើងជាប្រធាន ។ លោកសម្ដែងដល់ភាពនៃចិត្តដែលជន
ទាំងឡាយនោះសៅហ្មង ដោយត្រូវសេចក្ដីសោក មានរាគៈជាដើមគ្របសង្កត់
ដោយភាពដែលព្រះរាជាមានចិត្តជាប់ជំពាក់នៅក្នុងបុត្រនិងភរិយា ។ បទថា **ការិកចន្ទនំ** *បានដល់ លម្អិតខ្ចីមចន្ទន៍ ។ ម្យ៉ាងទៀត បានដល់ សំពត់*
ដែលធ្វើក្នុងដែនកាសី និងដើមចន្ទន៍ ។ បទថា **មាលាគន្ធវិលេបនំ** *បានដល់*
ទ្រទ្រង់នូវរបៀបផ្ការណ៍ ដើម្បីត្រូវការពណ៌ និងក្លិន ទ្រទ្រង់របស់ក្រអូប ដើម្បី

ត្រូវការភាពក្រអូប ការលាបលន ដើម្បីត្រូវការពណ៌សម្បុរ ។ បទថា **ជាតរូប្ប-រជតំ** បានដល់ មាស និងទ្រព្យដែលនៅសល់ ។ បទថា **សាឌិយន្តេន** បានដល់ ទទួលទុក ។ សូម្បីដោយគ្រប់បទក៏ប្រកាសដល់ភាពដែលជនទាំងនោះជាប់នៅ ក្នុងកាមទាំងនោះ ។

បទថា **សំវាសេន** ប្រែថា ដោយការនៅរួម ។ បទថា **សីលំ** **ឧតិតញ្ចំ** សេចក្តីថា ដែលអ្នកនៅរួម គឺនៅរួមក្នុងទីជាមួយគ្នា ក៏គប្បីជ្រាបថា អ្នកនេះជា អ្នកមានសីល ឬជាអ្នកទ្រុស្តសីល ។ បទថា **តញ្ច ខោ ឧ**ីយេន **អ**ន្ធ**ុ**ជ**ា ន ឥ**ត្ត**ុ**ណ សេចក្តីថា ក៏សីលនោះគប្បីជ្រាបដោយកាលយូរ មិនគប្បីជ្រាបដោយកាលដទៃ ទេ ។ មែនពិត ក្នុងថ្ងៃ ២-៣ អ្នកណាៗ អាចសម្តែងនូវភាពជាអ្នកមានអាការ សង្រ្ទួម និងអាការសង្រ្ទួមឥន្ទ្រិយ ។ បទថា **មនសិ**ការ**ោ ជ**ោ **អ**ម**ន**ិ**ស**ិ**ក-ោ** សេចក្តីថា សីលសូម្បីនោះបុគ្គលដែលដាក់ចិត្ត គឺពិចារណាថា យើង នឹងកំណត់សីលរបស់គេអាចដឹងបាន បុគ្គលក្រៅនេះមិនដឹងទេ ។ បទថា **ប**ញ្ញ-**ាតា** សេចក្តីថា សីលសូម្បីនោះចំពោះអ្នកមានបញ្ញា គឺបណ្ឌិតអាចដឹងបាន ។ ព្រោះអ្នកលង់ខ្ចៅដាក់ចិត្តក៏មិនអាចដឹង ។ បទថា **សំ**ហ**ារ**េ**ន** ប្រែថា ដោយការពោល ។ មែនពិត វាណិជកម្ម ឈ្មោះថា **ហ**ារ ក្នុងប្រយោគនេះថា

យោ ហិ កោចិ **ម**នុ**ស្ស**េ**សុ ហ**ារ**ំ ឧ**ប**ជ**ីវ**តិ**
ឯរ**ំ ភ**ាសេ**ដ្ឋ ជ**ានា**ហ**ិ ភ**ណ**ិ**ជ**ោ **ស**ោ **ន ព្រ**ាហ្ម**ណ**ោ ។

បណ្តាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយការជួញប្រែ ម្នាល ភាសេដ្ឋ: អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាពាណិជ មិនមែនព្រាហ្មណ៍ទេ[1] ។

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ២១៣ ។

*ចេតនា ឈ្មោះថា ភោហារ ក្នុងប្រយោគនេះថា **អរិយ**ភោហារ ៤ **អនរិយ**-ភោហារ ៤ ។ បញ្ញត្ត ឈ្មោះថា ភោហារ ក្នុងប្រយោគនេះថា ការរាប់ សមញ្ញ: បញ្ញត្ត ឈ្មោះថា ភោហារ ។ ពាក្យ ឈ្មោះថា ភោហារ ក្នុងប្រយោគនេះថា គេគប្បីពោលអំពីហេតុត្រឹមតែដោយការពោល ។ សូម្បីក្នុងទីនេះ លោកប្រាជ្ញ ភោហារ គឺពាក្យនោះឯង ។ មែនពិត ការពោលចំពោះមុខរបស់អ្នកខ្ជះ រមែងមិនសមនឹងពាក្យដែលពោលកំបាំងមុខ និងពាក្យដែលពោលកំបាំងមុខ មិនសមនឹងពាក្យដែលពោលចំពោះមុខ ពាក្យដែលពោលមុនក៏ដូចគ្នាមិនសមនឹងពាក្យដែលពោលពេលក្រោយ និងពាក្យដែលពោលពេលក្រោយក៏មិនសមនឹងពាក្យដែលពោលមុន អ្នកនោះកាលពោលនុ៎ះឯង អ្នកណាៗ អាចដឹងបានថា បុគ្គលនោះ មិនស្អាត ។ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់ប្រកាសថា សម្រាប់អ្នកដែលមានភាពស្អាតជាប្រក្រតី ពាក្យដែលពោលទុកមុន រមែងសមនឹងពាក្យដែលពោលទុកក្រោយ និងពាក្យដែលពោលទុកក្រោយ រមែងសមនឹងពាក្យដែលពោលទុកមុន ពាក្យដែលពោលទុកចំពោះមុខ រមែងសមនឹងពាក្យដែលពោលទុកកំបាំងមុខ និងពាក្យដែលពោលទុកកំបាំងមុខ រមែងសមនឹងពាក្យដែលពោលទុកចំពោះមុខ ព្រោះដូច្នោះ អ្នកដែលពោលទើបអាចដឹងបានថា អ្នកនេះជាអ្នកស្អាត ទើបត្រាស់ពាក្យមានជាអាទិ៍ថា បណ្ឌិតគប្បីជ្រាបសេចក្តីស្អាតដោយការពោលដូច្នេះ ។*

បទថា **ថ្ងៃ** *បានដល់ កម្លាំងនៃញាណ ។ ក៏អ្នកដែលមិនមានកម្លាំងនៃញាណ រមែងមិនមើលឃើញវត្ថុដែលគួរកាន់យក គឺកិច្ចដែលគួរធ្វើក្នុងកាលអន្តរាយកើតឡើង ទើបត្រាច់ទៅដូចចូលផ្ទះដែលមិនមានទ្វារ ។ ព្រោះហេតុនោះ*

ព្រះអង្គទើបត្រាស់ថា បពិត្រមហារាជ គប្បីជ្រាបកម្ចាំង ក្នុងកាលអន្តរាយកើតឡើងដូច្នេះជាដើម ។ បទថា **សាកច្ឆាយ** ប្រែថា ដោយការសន្ទនាគ្នា ។ មែនពិត ពាក្យរបស់អ្នកមានបញ្ញាទន់ខ្សោយ រមែងអណ្តែតទៅ ដូចសីអណ្តែតលើទឹក ។ សម្រាប់អ្នកមានបញ្ញា កាលនិយាយរមែងមានបដិភាណមិនមានទីបំផុត ។ មែនពិត ត្រីគេដឹងបានថា ខ្ជូនធំ ឬតូច ក៏ដោយទឹកដែលរញ្ជួយនុ៎ះឯង។

ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់ដល់អ្នកទាំងនោះដល់ព្រះរាជា ដោយត្រង់តែម្តងថា ពួកជនទាំងនេះហើយ ទើបប្រកាសឧបាយជាហេតុដឹងនូវភាពជាព្រះអរហន្ត ឬនូវភាពមិនមែនជាព្រះអរហន្ត ។ ព្រះរាជាទ្រង់ជ្រាបដូច្នោះហើយ ព្រះអង្គមានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែង ក្នុងព្រះសព្វញ្ញុតញ្ញាណ និងទេសនាវិលាសរបស់ព្រះដ៏មានព្រះភាគ ទើបទ្រង់ប្រកាសសេចក្តីជ្រះថ្លារបស់ព្រះអង្គដោយន័យមានជាអាទិ៍ថា អស្ចារ្យណាស់ ព្រះអង្គ ឥឡូវនេះ កាលនឹងត្រាស់ប្រាប់អ្នកទាំងនោះ ចំពោះព្រះដ៏មានព្រះភាគតាមសេចក្តីពិត ទើបត្រាស់ពាក្យមានជាអាទិ៍ថា បុរសរបស់ខ្ញុំព្រះអង្គទាំងនេះជាចោរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចោរា** សេចក្តីថា បុគ្គលដែលមិនមែនជាបព្វជិតឡើយ បរិភោគដុំបាយរបស់អ្នកដែន ដោយរូបរបស់បព្វជិត ព្រោះជាអ្នកបិទបាំងកម្មអាក្រក់ទុក ។ បទថា **ឱចរកា** ប្រែថា ជាអ្នកស៊ីកសៀត ។ ពិតមែនពួកចោរ កាលត្រាច់ទៅតាមកំពូលភ្នំ ក៏ឈ្មោះថា ជាអ្នកស៊ីកសៀតដូចគ្នា ព្រោះមានកម្មដ៏អាក្រក់ ។ ម្យ៉ាងទៀត បទថា **ឱចរកា** បានដល់ ចារបុរស ។ បទថា **ឱតរិត្វា** បានដល់ អ្នកត្រាច់ពិចារណាស៊ីកសៀតបំភ្ជ អធិប្បាយថា ដឹងរឿង

នោះៗ ក្នុងទីនោះៗ ។ បទថា **ឋិតវិស្ឆាមិ** *ប្រែថា នឹងប្រព្រឹត្តទៅ អធិប្បាយថា នឹងធ្វើ ។ បទថា* **រជោ៨ល្ងំ** *បានដល់ ធូលី និងមន្ទិល ។ បទថា* **ឧបហោតូ** *បានដល់ កម្ចាត់ គឺជម្រះឱ្យស្អាត ។ បទថា* **ឧប្ឆិតកេសមស្ស** *បានដល់ ប្រើជាងកោរកាត់ ឱ្យកាត់សក់ កោរពុកមាត់តាមវិធីដែលពោលហើយក្នុងអលង្ការ-សាស្ត្រ ។ បទថា* **កាមកុណេហិ** *បានដល់ ចំណែកនៃកាម ឬគ្រឿងចង គឺកាម ។ បទថា* **សមប្ឆិតា** *បានដល់ ជាប់ជំពាក់ដោយល្អ ។ បទថា* **សមជ្ជ-ភូតា** *ប្រែថា ព្រមព្រៀង ។ បទថា* **ឧបចារិយន្តិ** *បានដល់ ឱ្យឥន្ទ្រិយត្រាច់ទៅដោយជុំវិញ ឬនឹងលេង ។*

បទថា **ឯតមត្ថំ ១ិ១ិត្វា** *សេចក្ដីថា ទ្រង់ជ្រាបសេចក្ដីនេះ ពោលគឺ ការដែលរាជបុរសទាំងនោះ ជាអ្នកលួងលោមលោកដោយកេទបពូជិត ព្រោះហេតុនៃផ្ទៃរបស់ខ្លួន ។ បទថា* **ឥមំ ឧ១ានំ** *បានដល់ ទ្រង់បន្ទឹមទាននេះ ដែលប្រកាសដល់ប្រការដែលហាមការខុស និងភាពជាអ្នកលួងលោមលោក ។*

បណ្ដាបទទាំងនោះ បទថា **ន ១ាយមេយ្យ សព្ជ្ជ** *សេចក្ដីថា បពូជិតមិនគប្បីព្យាយាម គឺមិនគប្បីធ្វើសេចក្ដីព្យាយាមខ្ជល់ខ្ជាយ ក្នុងការធ្វើសេចក្ដីអាក្រក់ទាំងអស់ មានភាពជាទូត និងធ្វើការសឹកសៀតជាដើម ដូចរាជបុរសទាំងនេះ អធិប្បាយថា មិនគប្បីធ្វើសេចក្ដីព្យាយាមក្នុងកម្មយ៉ាងណាមួយទាំងអស់ គប្បីព្យាយាមក្នុងបុណ្យតែម្យ៉ាង សូម្បីមានប្រមាណតិចប៉ុណ្ណោះ ។ បទថា* **ជាញ្ញ១ ១ុ១ិសោ សិយា** *បានដល់ មិនគប្បីជាអ្នកនៅបម្រើអ្នកដទៃ ដោយរូបបពូជិត ។ ព្រោះហេតុអ្វី? ព្រោះនឹងត្រូវធ្វើកម្មអាក្រក់មានសៀតសឹកជាដើម សូម្បីមានសភាពបែបនេះ ។ បទថា* **ជាញ្ញ ១ិ១្ជ១ យ ១ីវេយ្យ** *បានដល់ ជាអ្នក*

មិនអាស្រ័យបុគ្គលដទៃមានឥស្សរជនជាដើម មានការគិតយ៉ាងនេះថា សុខទុក្ខ
របស់យើងជាប់ដោយអ្នកនោះ ដូច្នេះហើយចិញ្ចឹមជីវិត គឺជាអ្នកមានខ្លួនជាទីពឹង
ជាទីអាស្រ័យ កុំមានអ្នកដទៃជាទីពឹង ជាទីអាស្រ័យឡើយ ។ ម្យ៉ាងទៀត មិន
គប្បីអាស្រ័យអកុសលកម្មដទៃចិញ្ចឹមជីវិត ព្រោះបាននាមថា អ្នកដទៃ ហេតុនាំ
មកនូវសេចក្តីវិនាស ។ បទថា **ឧម្មេន ន រណ្ហាចរេ** សេចក្តីថា មិនគប្បីពោល
ធម៌ដើម្បីត្រូវការទ្រព្យ ។ ព្រោះអ្នកសម្តែងធម៌ដល់ជនពួកដទៃ ដោយហេតុនៃ
ទ្រព្យជាដើម រមែងឈ្មោះថា ជាអ្នកធ្វើជំនួញធម៌ មិនមែនជាអ្នកប្រព្រឹត្តតាមធម៌
ឡើយ ។ ម្យ៉ាងទៀត បុគ្គលដែលធ្វើកម្ម មានការសិក្សៀតជាដើម ដូចរាជបុរស
ព្រះរាជាព្រះបាទកោសល ធ្វើការសិក្សៀតដើម្បីប្រយោជន៍ ដល់ទ្រព្យជាដើម
តម្រង់តាមកិច្ច មានការសមាទានកេទបពូជ្ជាជាដើម ដោយមិនឱ្យអ្នកដទៃសង្ស័យ
ឈ្មោះថា ធ្វើជំនួញដោយធម៌ ។ ចំណែកបុគ្គលណា សូម្បីប្រព្រឹត្តព្រហ្មចរិយ:
បរិសុទ្ធក្នុងសាសនានេះ ក៏ប្រព្រឹត្តព្រហ្មចរិយ: ដើម្បីប្រាថ្នាទេវនិកាយពួកណា
មួយ សូម្បីបុគ្គលនោះក៏ឈ្មោះថា ធ្វើជំនួញដោយធម៌ អធិប្បាយថា មិនគប្បី
ប្រព្រឹត្ត គឺមិនគប្បីធ្វើជំនួញដោយធម៌យ៉ាងនេះ ។

ឧតិយសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ២

៣. អាហុសុត្តវណ្ណនា[1]

អដ្ឋកថាអាហុសូត្រ

អាហុសូត្រទី ៣ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **អត្តនោ អនេកេ ចាបកេ អកុសលេ ធម្មេ បហីនេ** *សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ពិចារណាកិលេស ១០០៥ ដែលប្រព្រឹត្តទៅអស់កាលខាងដើមមិនបាន ក្នុងសន្ធានរបស់ព្រះអង្គ មានលោភ: ទោស: មោហ: វិបរិត-មនសិការ: អហិរិក: អនោត្តប្ប: កោធ: ឧបនាហ: មក្ខ: បលាស: ឥស្សា មច្ឆរិយ: មាយា សាឋেយ្យ: ថម្ភ: សារម្ភ: មានៃ: អតិមានៃ: មទ: បមាទ: តណ្ហា អវិជ្ជាអកុសលមូល ៣ ទុច្ចរិត ៣ សង្កិលេស ៣ មល: ៣ វិសមសញ្ញា ៣ វិតក្ក: ៣ បបញ្ច: ៣ វិបល្លាស ៤ អាសវ: ៤ ឱឃ: ៤ យោគ: ៤ គណ្ឋ: ៤ ដល់អគតិ ៤ តណ្ហុប្បាទ: ៤ ចេតោខីល: ៥ ចេតោវិនិពន្ធ: ៥ នីវរណ: ៥ អកិនន្ទ: ៥ រាគទមូល ៦ តណ្ហាកាយ ៦ អនុស័យ ៧ មិច្ឆត្ត: ៨ តណ្ហាមូលក: ៩ អកុសលកម្មបថ ១០ ទិដ្ថ ៦២ និងតណ្ហាវិបរិត ១០៨ ជាដើមជាប្រភេទក្តី ធម៌ដែលថោកទាបលាមកជាអនេក ដែលឈ្មោះថា ជាអកុសល ព្រោះអត្តថា កើតអំពីភាពជាអ្នកមិនធ្ងាត សូម្បីដែលកើតរួមនឹងកិលេស ១០០៥ នោះក្តី ដែលព្រះអង្គទ្រង់លះហើយ គឺកាត់ដាច់ហើយដោយអរិយមគ្គត្រង់គល់នៃពោធិព្រឹក្ស នុ៎ះឯង ព្រមដោយវាសនា គឺព្រះអង្គគង់ពិចារណាតាមលំដាប់បទថា* ***កិលេស*** *សូម្បីនេះ យើងលះបានហើយ កិលេសសូម្បីនេះយើងលះបានហើយដូច្នេះ ។*

បទថា **អនេកេ ច កុសលេ ធម្មេ** *បានដល់ ព្រះអង្គទ្រង់គង់ពិចារណាកុសល គឺធម៌ដែលរកទោសមិនបានរបស់ព្រះអង្គជាអនេកមានជាអាទិ៍យ៉ាងនេះ*

១-ក្នុងអដ្ឋកថាច្បាប់ធម្ម្ដសង្គ្ដាយនា ព្រះសូត្រនេះមានឈ្មោះថា **បញ្ចវេក្ខណសុត្តវណ្ណនា** *។*

គឺសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សន: សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ មគ្គ ៤ ផល ៤ បដិសម្ភិទា ៤ ញាណជាគ្រឿងកំណត់កំណើត ៤ អរិយវង្ស ៤ វេសារជ្ជញ្ញាណ ៤ អង្គជាទីតាំងនៃសេចក្តីព្យាយាម ៥ សម្មាសមាធិមានអង្គ ៥ សម្មាសមាធិដែលប្រកបដោយញាណ ៥ ឥន្ទ្រិយ ៥ ពល: ៥ និស្សារណីធាតុ ៥ វិមុត្តាយតនញ្ញាណ ៥ វិមុត្តិបរិបាចនីយសញ្ញា ៥ អនុស្សតិ-ដ្ឋាន ៦ គារវ: ៦ និស្សារណីធាតុ ៦ សតតវិហារធម៌ ៦ អនុតរិយ: ៦ និព្វេធភា-គិយសញ្ញា ៦ អកិញ្ចា ៦ អសាធារណញ្ញាណ ៦ អបរិហានិយធម៌ ៧ អរិយ-ទ្រព្យ ៧ ពោជ្ឌង្គ: ៧ សប្បុរិសធម៌ ៧ រិជ្ជវត្ថុ ៧ សញ្ញា ៧ ទក្ខិណេយ្យបុគ្គល-ទេសនា ៧ ខីណាសវពលទេសនា ៧ បញ្ញាបដិលាភហេតុទេសនា ៨ សម្មត្ត: ៨ លោកធម្មាតិក្កម: ៨ អារម្ភវត្ថុ ៨ អក្ខណទេសនា ៨ មហាបុរិសវិតក្ក: ៨ អកិភាយតនទេសនា ៨ វិមោក្ខ ៨ ធម៌ដែលមានយោនិសោមនសិការជាមូល ៩ អង្គនៃធម៌ជាទីតាំងនៃសេចក្តីព្យាយាមដែលបរិសុទ្ធ ៩ សត្តាវាសទេសនា ៩ អាឃាតបដិវិនយទេសនា ៩ សញ្ញា ៩ នានត្ត: ៩ អនុបុព្វវិហារ ៩ នាថករណ-ធម៌ ១០ កសិណាយតន: ១០ កុសលកម្មបថ ១០ សម្មត្ត: ១០ អរិយវាស ១០ អសេក្ខធម៌ ១០ តថាគតពល: ១០ អានិសង្សនៃមេត្តា ១១ អាការនៃចក្រ ១២ ធុតង្គគុណ ១៣ ពុទ្ធញ្ញាណ ១៤ វិមុត្តិបរិបាចនីយធម៌ ១៥ អានាបានស្សតិ ១៦ អបរន្តបនីយធម៌ ១៦ មហាវិបស្សនា ១៨ ពុទ្ធធម៌ ១៨ បច្ចវេក្ខណញ្ញាណ ១៩ ញាណវត្ថុ ៤៤ ឧទយព្វយញ្ញាណ ៥០ កុសលធម៌លើស ៥០ ញាណវត្ថុ ៣៣ សមាបត្តិមហាវជិរញ្ញាណ ២.៤០០.០០០ កោដិ បច្ចវេក្ខណទេសនាញ្ញាណ

ដែលជាវិស័យនៃសមន្តប្បដ្ឋានដែលមានន័យរកទីបំផុតមិនបាន ញាណដែលប្រកាសអធ្យាស្ស័យជាដើមរបស់សត្វទាំងឡាយ អ្នករកទីបំផុតមិនបានក្នុងលោក-ធាតុ ដែលរកទីបំផុតមិនបាន ដូចគ្នាដែលដល់ហើយដែលចម្រើនបរិបូណ៌នៃការបំពេញព្រះបារមី និងការចម្រើនមគ្គ រហូតអស់កាលរកទីបំផុតមិនបាន ធ្វើពុទ្ធគុណដែលបែរមុខចំពោះមនសិការឱ្យជាវគ្គៗ គឺឱ្យជាគំនរៗ ដោយអំណាចព្រះហ្ឫទ័យថា ធម៌ដែលរកទោសមិនបាន សូម្បីទាំងនេះមាននៅក្នុងយើង ធម៌ដែលរកទោសមិនបាន សូម្បីទាំងនេះមាននៅក្នុងតថាគត ។ ក៏ធម៌ទាំងនោះ អាចមនសិការបាន ដោយមានការសម្តែងនៅសល់តែម្តង មិនអាចមនសិការបានដោយអស់ ។ ពុទ្ធគុណទាំងអស់ ព្រះដ៏មានព្រះភាគ ក៏មិនអាចមនសិការតាមលំដាប់បទបានអស់ ព្រោះជាធម៌រកទីបំផុតមិនបាន រកប្រមាណមិនបាន ។ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា

សូម្បីព្រះពុទ្ធត្រាស់ព្រះគុណរបស់ព្រះពុទ្ធ មិនត្រាស់យ៉ាងដទៃឡើយ ក្នុងកប្បមួយ ក៏នឹងគប្បីអស់ទៅក្នុងចន្លោះ ជាវេលាយូរ ព្រះគុណរបស់ព្រះតថាគតមិនអស់ទៅទេ ដូច្នេះ[១] ។

ត្រាស់ទុកទៀតថា

ក៏អ្នកណាៗ មិនអាចរាប់នាមរបស់ព្រះមហេសីដោយព្រះគុណបាន គប្បីលើកព្រះនាមឡើងដោយព្រះគុណ សូម្បីពាន់នៃនាម ។

១-សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ សីលក្ខន្ធវគ្គ (ប្រែជាខ្មែរភាសា) ភាគ ១៤ ទំព័រ ៦៥៣ ។

ក៏ក្នុងកាលនោះ ព្រះដ៏មានព្រះភាគស្តេចត្រឡប់ពីបិណ្ឌបាត ខាងក្រោយ ភត្ត ស្តេចចូលព្រះវិហារប្រថាប់ឈរត្រង់មុខព្រះគន្ធកុដិ កាលភិក្ខុទាំងឡាយ សម្តែងវត្តហើយជៀសទៅ ទើបស្តេចចូលមហាគន្ធកុដិ ប្រថាប់គង់លើពុទ្ធាសនៈ ដ៏ប្រសើរ ដែលគេក្រាលទុក ទ្រង់បញ្ជូនញាណដែលមានអតីតជាតិរបស់ព្រះអង្គ ជាអារម្មណ៍ទៅ ។ លំដាប់នោះ អតីតជាតិរបស់ព្រះអង្គមានប្រភេទរកទីបំផុត រកប្រមាណមិនបាន ប្រាកដច្បាស់រហូតអស់កាលរកចន្ទោះមិនបាន ។ ព្រះដ៏-មានព្រះភាគព្រះអង្គទ្រង់បញ្ជូនញាណចារៈ ដែលមានកិលេសជាអារម្មណ៍ថា កិលេសទាំងនេះ ជាមូលនៃទុក្ខខន្ធដ៏ធំយ៉ាងនេះ ទ្រង់ពិចារណាកិលេសទាំង នោះតាមលំដាប់ដោយមុខ គឺបហានៈ កាលនឹងពិចារណាអរិយមគ្គព្រមទាំង អាការ ព្រមទាំងបរិវាស ព្រមទាំងឧទ្ទេស ដែលធ្វើការលះកិលេសទាំងនោះ ទៀតថា ឱហ្ន៎! កិលេសទាំងនេះ តថាគតលះបានដាច់ហើយដោយល្អ ទើបទ្រង់ ធ្វើទុកក្នុងព្រះទ័យ ដែលធម៌ដែលរកទោសមិនបាន មានសីលជាដើមរបស់ ព្រះអង្គ ដែលមានប្រភេទរកទីបំផុតរកប្រមាណមិនបាន ។

ព្រោះហេតុនោះ លោកទើបពោលថា ក៏សម័យនោះឯង ព្រះដ៏មាន ព្រះភាគប្រថាប់អង្គុយពិចារណាអកុសលធម៌ដ៏លាមកជាអនេក ដែលព្រះអង្គ លះបានហើយ និងកុសលធម៌ជាអនេក ដែលដល់ភាពបរិបូណ៌ដោយភាវនា ។ គ្រាទ្រង់ពិចារណាយ៉ាងនេះហើយ ទើបទ្រង់បន្ទឺឧទានេះ ដែលសម្តែងដល់ ប៉ីតិ និងបាមោជ្ជៈដែលកើតឡើងហើយ ។

បណ្តាបទទាំងនោះ បទថា **អហុ ឃុ** សេចក្តីថា ក៏មុនអំពីការកើត

អរហត្តមគ្គញ្ញាណ ពួកកិលេសមានរាគៈជាដើមទាំងអស់នេះមានក្នុងសន្ធាន
របស់តថាគត ហើយពួកកិលេសនេះ សូម្បីកិលេសណាៗ នឹងមិនមានក៏មិន
មែន ។ បទថា **តតា ជាហុ** *សេចក្តីថា ក្នុងកាលនោះ គឺវេលានោះ បានដល់*
ក្នុងខណៈអរិយមគ្គ ពួកកិលេសមិនមាន គឺមិនមានឡើយ ។ ពួកកិលេសនោះ
កិលេសសូម្បីមានប្រមាណតិច ឈ្មោះថា តថាគតមិនទាន់បានលះក្នុងខណៈ
អរិយមគ្គមិនមាន ។ អាចារ្យពួកខ្លះពោលថា **តតោ ជាហុ** *ដូច្នេះក៏មាន ។*
អធិប្បាយថា តពីខណៈនៃអរិយមគ្គនោះ កិលេសមិនមានហើយ ។ បទថា
ជាហុ បុព្វេ *សេចក្តីថា ក៏ធម៌ដែលរកទោសមិនបាន រកប្រមាណមិនបានរបស់*
តថាគតនេះណា ឥឡូវនេះ តថាគតបានប្រសព្វបរិបូណ៌ហើយដោយការនា
ធម៌ដែលរកទោសមិនបានសូម្បីនោះ ក្នុងកាលមុនតែខណៈអរិយមគ្គមិនមាន
ហើយ គឺគ្មានឡើយ ។ បទថា **តតា អហុ** *សេចក្តីថា ក៏អរហត្តមគ្គញ្ញាណកើត*
ឡើងដល់តថាគតក្នុងកាលណា ក្នុងកាលនោះ ធម៌ដែលរកទោសមិនបានទាំង-
អស់មានហើយដល់តថាគត ។ មែនពិត គុណនៃព្រះសព្វញ្ញូទាំងអស់ព្រមដោយ
ការសម្រេចអរហត្តមគ្គ រមែងនៅក្នុងចេញព្រះហស្តរបស់ព្រះពុទ្ធទាំងឡាយ
តែម្តង ។ បទថា **ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ** *សេចក្តីថា ក៏ធម៌*
ដែលរកទោសមិនបាន គឺអរិយមគ្គនោះណា កើតឡើងហើយដល់តថាគត
ត្រង់ពោធិមណ្ឌល ដែលជាហេតុឱ្យតថាគតលះពួកកិលេសទាំងអស់បានដាច់ ។
អរិយមគ្គនោះ មុនខណៈមគ្គ មិនមាននិងមិនមានដល់យើងឡើយ យ៉ាងណា
សូម្បីអរិយមគ្គនេះក៏ដូច្នោះ នឹងមិនមាន គឺនឹងមិនកើតក្នុងអនាគតដូចកិលេស
ទាំងនោះ ព្រោះមិនមានកិលេសដែលខ្ជួននឹងត្រូវលះក្នុងឥឡូវនេះ គឺក្នុងបច្ចុប្បន្ន

ក៏មិនមាន គឺមិនកើត ព្រោះមិនមានកិច្ចដែលខ្ជួននឹងត្រូវធ្វើ ។ ព្រោះអរិយមគ្គ មិនប្រព្រឹត្តទៅច្រើនដង ព្រោះហេតុនោះនុ៎ះឯងព្រះអង្គទើបត្រាស់ថា រមែងមិនដល់ត្រើយ ២ ដង ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់ពិចារណាដល់អកុសលធម៌ ដែលព្រះអង្គលះបានដាច់ក្នុងសន្ធានរបស់ព្រះអង្គដោយអរិយមគ្គ និងធម៌ដែលរកទោសមិនបាន រកប្រមាណមិនបាន ដែលដល់ភាពបរិបូណ៌ដោយការនា ទើបទ្រង់បន្ទឺឧទានដែលកើតដោយកម្ទាំងបីតិដែលបង្ហោនចូលមកក្នុងខ្ជួន ។ ដោយគាថាដើមត្រាស់ដល់វេសារជ្ជញ្ញាណខាងដើមទាំងពីរប៉ុណ្ណោះ វេសារជ្ជញ្ញាណ ២ ប្រការក្រោយជាការទ្រង់ប្រកាសហើយតែម្តង ព្រោះប្រកាសដល់ព្រះសម្មាសម្ពោធិញ្ញាណដូច្នេះឯង ។

តតិយសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៣

៤.បឋមជាតិត្ថិយសុត្តវណ្ណនា

អដ្ឋកថាបឋមនានាតិត្ថិយសូត្រ

បឋមនានាតិត្ថិយសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

ក្នុងបទថា **ជាតិត្ថិយា សមណាព្រាហ្មណា បរិព្វាជកា** *នេះ មានវិគ្រោះដូចតទៅនេះ ឈ្មោះថា* **កំពង់** *ព្រោះជាទីធ្វើនឱ្យសង្សារ បានដល់មគ្គជាទីទៅកាន់ព្រះនិព្វាន ។ តែក្នុងទីនេះ ទិដ្ឋិទស្សនៈ សេចក្តីឃើញ គឺទិដ្ឋិដែលពួកអ្នកមានទិដ្ឋិប្រកាន់ជាគតិដូច្នោះ ដោយវិបល្លាសដែលខុសប្លែក លោកប្រាថ្នាយកថា* **កំពង់** *។ អ្នកប្រកបក្នុងកំពង់មានអាការផ្សេងៗ មានថា ទៀងជាដើមនោះ ឈ្មោះថា* **នានាទិដ្ឋិ** *។ សមណៈ:អាក្រាត និងនិគ្រន្ថជាដើមក្តី កបកលាបព្រាហ្មណ៍ជាដើមក្តី បរិព្វាជកឈ្មោះបោកន្ធរសាតជាដើមក្តី ឈ្មោះថា សមណៈ ព្រាហ្មណ៍ និងបរិព្វាជក ។ សមណៈ ព្រាហ្មណ៍ និងបរិព្វាជកទាំងនោះ អ្នកប្រកបក្នុងកំពង់ទីផ្សេងៗ ដូចគ្នា ។ ឈ្មោះថា* **ទិដ្ឋិ** *ព្រោះជាគ្រឿងឃើញ ដោយន័យមានជាអាទ៍ថា អត្តា និងលោកទៀង ឬទិដ្ឋិនេះ ជាឈ្មោះរបស់ការប្រកាន់ខុស ។ ទិដ្ឋិផ្សេងៗ គឺមានជាអនេក ដោយឃើញថា ទៀងជាដើមរបស់ជនទាំងនោះមាននៅ ហេតុនោះជនទាំងនោះឈ្មោះថា មានទិដ្ឋិផ្សេងៗ ។ សេចក្តីអត់ធន់ដោយយល់ឃើញថា ទៀងជាដើម ឈ្មោះថា* **ខន្តិ** *សេចក្តីពេញចិត្ត ឈ្មោះថា* **រុចិ** *ដោយអត្ត ចិត្តវិបល្លាស និងសញ្ញាវិបល្លាសដែលប្រព្រឹត្តទៅដោយន័យមានជាអាទ៍ថា អត្តា និងលោកទៀង ។ សេចក្តីអត់ធន់ផ្សេងៗ ដូច្នោះរបស់ជនទាំងនោះមាននៅ ព្រោះហេតុនោះ ជនទាំងនោះឈ្មោះថា មានសេចក្តីអត់ធន់ផ្សេងៗ គ្នា ។ សេចក្តីពេញចិត្តរបស់ជនទាំងនោះមាននៅ ព្រោះហេតុនោះ ជនទាំងនោះមានឈ្មោះថា មានសេចក្តីពេញចិត្តផ្សេងៗ គ្នា ។ មែនពិត ក្នុង*

ចំណែកខាងដើម បុគ្គលដែលមានទិដ្ឋិជាគតិ រមែងធ្វើចិត្តឱ្យពេញចិត្ត និងឱ្យពេញចិត្តដោយប្រការនោះ ខាងក្រោយប្រកាន់ថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទេ ។ ម្យ៉ាងទៀត ទិដ្ឋិពោលអំពីសេចក្តីឃើញ ឈ្មោះថា **ខន្តិ** ដោយសេចក្តីពេញចិត្ត ឈ្មោះថា **រុចិ** ដោយសេចក្តីពេញចិត្តដោយប្រការនោះ។ ដោយន័យមានជាអាទិ៍ថា លោកមិនទៀង លោកទៀង ។ ដោយបទទាំង ៣ ដូចពោលមកនេះ ទិដ្ឋិប៉ុណ្ណោះគប្បីជ្រាបសេចក្តីថា លោកពោលទុកហើយ ។ បទថា **ជាជានិដ្ឋិនិស្សយនិស្សិតា** សេចក្តីថា អាស្រ័យ អែបជិត គឺចូលទៅអាស្រ័យ គឺទីតាំង បានដល់ ហេតុនៃទិដ្ឋិមានផ្សេងៗ ដោយកំណត់ថា ទៀងជាដើម ឬទីអាស្រ័យ ពោលគឺ ទិដ្ឋិនុ៎ះឯង អធិប្បាយថា មិនលះបង់ទិដ្ឋិនោះតាំងនៅ ។ ដោយថា សូម្បីទិដ្ឋិទាំងឡាយ ក៏ជាទីអាស្រ័យរបស់អាការប្រកាន់របស់ជនពួកដែលមានទិដ្ឋិជាគតិ ។

បទថា **សន្តិ** ប្រែថា មាននៅ គឺមាននៅព្រម បានដល់ កើតឡើង ។ បទថា **ឯកេ** បានដល់ ពួកខ្លះ ។ បទថា **សមណាព្រាហ្មណា** សេចក្តីថា លោកកាន់យកយ៉ាងនេះថា ឈ្មោះថា **សមណៈ** ព្រោះចូលដល់ការបព្វជ្ជា ឈ្មោះថា **ព្រាហ្មណ៍** ព្រោះជាតិកំណើត ។ ម្យ៉ាងទៀត បុគ្គលដែលលោកកាន់យកយ៉ាងនេះថា សមណៈ និងថា ជាព្រាហ្មណ៍ ។ បទថា **ឯវំ ភាគិនោ** បានដល់ អ្នកមានវាទៈយ៉ាងនេះថា អ្នកពោលយ៉ាងនេះ គឺដោយអាការដែលនឹងគប្បីពោលក្នុងឥឡូវនេះ ។ ឈ្មោះថា អ្នកមានទិដ្ឋិយ៉ាងនេះ ព្រោះអ្នកទាំងនោះមានទិដ្ឋិដែលជាយ៉ាងនេះ គឺដោយអាការដែលនឹងគប្បីពោលក្នុងឥឡូវនេះ ។ ក្នុងបទ

ទាំងនោះ ដោយបទទី ២ លោកសម្តែងដល់ការប្រកាន់ខុសរបស់អ្នកមានទិដ្ថិជាគតិ ។ ដោយបទទី ១ លោកសម្តែងដល់ការពោល ដោយឱ្យជនពួកដទៃតាំងនៅក្នុងទិដ្ថិនោះ តាមសេចក្តីប្រកាន់របស់ពួកខ្លួន ។ បទថា **លោកោ** ក្នុងបទថា **សស្សតោ លោកោ ឥធមេវ សច្ចំ មោឃមញ្ញ** នេះជាអត្តា ។ មែនពិត អត្តានោះលោកប្រាថ្នាយកថា លោកព្រោះជាទីដែលអ្នកមានទិដ្ថិជាគតិឃើញបុណ្យបាប និងវិបាករបស់បុណ្យ និងបាបនោះ ឬថាអ្នកប្រកបដោយភាពជាអ្នកឃើញ ។ អធិប្បាយថា សេចក្តីយល់ឃើញរបស់ពួកយើង ដែលថាលោកនេះនោះទៀង មិនស្ងាប់ រឹងមាំ យឺនយូរនេះឯងជារបស់ពិត គឺមិនប្រែ-ប្រួល ចំណែកសេចក្តីយល់ឃើញយ៉ាងដទៃរបស់អ្នកដទៃថា លោកមិនទៀងជាដើមទទេ គឺខុស ។ ដោយពាក្យនេះ ជាការសម្តែងសស្សតវាទ:ទាំង ៤ ។ បទថា **អសស្សតោ** ប្រែថា មិនទៀង អធិប្បាយថា មិនទៀង មិនយឺនយូរ មានចុតិជាធម៌ ។ ដោយបទថា **អសស្សតោ** នេះ លោកសម្តែងដល់ឧច្ឆេទទិដ្ថិ សេចក្តីយល់ឃើញថា ជាច់សូន្យ ដោយបដិសេធការ:ដែលលោកទៀងនុ:ឯង ព្រោះហេតុនោះ រមែងជាការសម្តែងឧច្ឆេទវាទ:សូម្បីទាំង ៣ ។

បទថា **អន្តវា** បានដល់ មានទីបំផុតវិលទៅជុំវិញ (មូល) មានប្រមាណកំណត់បាន អធិប្បាយថា មិនទៅរហូតដល់អស់ ។ ដោយពាក្យនេះ ជាការសម្តែងវាទ:មានជាអាទិ៍យ៉ាងនេះថា អត្តា មានសរីរ:ជាប្រមាណ មានផ្ទាប់មេ-ដៃជាប្រមាណ មានអវយវ:ជាប្រមាណ (និង)មានម្រាមមេដៃជាប្រមាណ ។ បទថា **អនន្តវា** ប្រែថា មិនមានទីបំផុត អធិប្បាយថា ទៅរហូត ។ ដោយបទថា **អនន្តវា** នេះ រមែងជាការសម្តែងវាទ:របស់កបិលព្រាហ្មណ៍ជាដើម ។

ដោយបទថា **តំ ជីវំ តំ សរីរំ** នេះ សមណៈ ឬព្រាហ្មណ៍ រមែងពិចារណាឃើញជីវៈ និងសរីរៈ មិនជាគូគ្នាថា សរីរៈនុ៎ះឯងជាវត្ថុពោលគឺ ជីវៈ វត្ថុពោលគឺ ជីវៈនុ៎ះឯងជាសរីរៈ ។ ដោយបទនេះ ជាការសម្តែងវាទៈនេះថា អត្តាដែលមានរូប ដូចវាទៈរបស់អាជីវក ក៏ដោយបទថា **អញ្ញំ ជីវំ អញ្ញំ សរីរំ** នេះ ជាការសម្តែងវាទៈអត្តាមិនមានរូប ។ បទថា **តថាគតោ** ក្នុងបទថា **ហោតិ តថាគតោ បរម្មរណា** នេះ បានដល់ **អត្តា** ។ មែនពិត អត្តានោះ ទិដ្ឋិគតិ-កបុគ្គលពោលថា **តថាគត** ព្រោះដល់ការៈដែលប្រព្រឹត្តទៅយ៉ាងនោះ ពោលគឺ អ្នកធ្វើ និងអ្នកសោយជាដើម ឬពោលគឺ ទៀងនិងយឹនយូរជាដើម អធិប្បាយថា ក្នុងទីនេះ អត្តានោះ ខាងមុខ គឺក្រោយអំពីស្លាប់ព្រោះកាយបែក រមែងមាន គឺមានប្រាកដ ។ ដោយពាក្យនេះដែលមានសស្សតវាទៈជាប្រធានជាការសម្តែងសញ្ញីវាទៈ ១៦ អសញ្ញីវាទៈ ៨ និងនេវសញ្ញីនាសញ្ញីវាទៈ ៨ ។ បទថា **ន ហោតិ** បានដល់ មិនមាន គឺមិនកើត ។ ដោយពាក្យនេះ លោកសម្តែងដល់ឧច្ឆេទវាទៈ ។ បទថា **ហោតិ ច ន ហោតិ ច** ប្រែថា មាន និងមិនមាន ។ ដោយពាក្យនេះ ជាការសម្តែងដល់សស្សតវាទៈខ្ទះ និងសញ្ញីវាទៈ ៧ ។ ក៏ដោយបទថា **នេវ ហោតិ ន ន ហោតិ** នេះ គប្បីជ្រាបថា ជាវាទៈដែលលោកសម្តែងដើម្បីដោះខ្លួនមិនឱ្យស្លាប់ ។ បានឮថា ទិដ្ឋិគតិកបុគ្គលទាំងនេះ មកពីអាវាសផ្សេងៗ អាស្រ័យនៅក្នុងក្រុងសាវត្ថី គ្រាមួយប្រជុំគ្នាក្នុងទីប្រជុំសម្តែងលទ្ធិ លើកតម្លើងវាទៈរបស់ខ្លួនៗ ត្រូវសង្ក្តត់វាទៈរបស់អ្នកដទៃបានទប់ស្កាត់រ៉ាវគ្នា និងគ្នា ។ ព្រោះហេតុនោះ លោកទើបពោលថា **តេ ភណ្ឌនជាតា** ដូច្នេះ ជាដើម ។

ក្នុងវាទ:ទាំងនោះ ចំណែកខាងដើមរបស់ការឈ្លោះ ឈ្មោះថា ការប្រេះធា ។ បទថា **ភណ្ឌនជាតា** ប្រែថា កើតប្រេះធា ។ ការឈ្លោះនុ៎ះឯងឈ្មោះថា **កលហ:** ។ ម្យ៉ាងទៀត គប្បីឃើញការឈ្លោះព្រោះកម្ចាត់សំឡេងខ្សោវ ។ ឈ្មោះថា **វិវាទាបន្ន** ព្រោះដល់វាទ:ដែលខុសគ្នា និងគ្នា ។ លំពែង គឺមាត់ ព្រោះប៉ះទង្គិចសេចក្តីស្រឡាញ់ ព្រោះដូច្នោះ ទើបឈ្មោះថា **មុខសត្តិ** បានដល់ ផរុសវាចា ។ មែនពិត **ហេតុ** លោកពោលថា ផលក៏មាន ព្រោះជិតខាងនឹងហេតុ ដូចជិតខាងនឹងផល សមដូចដែលលោកពោលទុកថា ការឧប្បត្តិឡើងនៃព្រះពុទ្ធនាំមកនូវសេចក្តីសុខ និងថា កម្មអាក្រក់ប្រាកដច្បាស់ ។ ចាក់ដោយលំពែង គឺមាត់ទាំងនោះ ។ បទថា **ឯឌិសោ ធម្មោ** បានដល់ ធម៌ គឺសភាវ:ដែលមិនខុសប្លែក ដូច្នេះ គឺបែបនេះ ដូចដែលយើងពោលទុកថា លោកទៀង ។ បទថា **នេឌិសោ ធម្មោ** បានដល់ ធម៌ដូច្នេះមិនមែន ។ ដូចដែលលោកពោលទុកថា លោកមិនទៀង ។ សូម្បីដោយបទដែលនៅសល់ ក៏គប្បីប្រកបយ៉ាងនេះ ។ ក៏វាទ:របស់ពួកតិរ្ថិយនោះ កើតប្រាកដទៅទូទាំងនគរ ។ លំដាប់នោះ ភិក្ខុទាំងឡាយ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី បានស្តាប់ដូច្នោះ ទើបគិតថា ចំណុចចាំបាច់នៃពាក្យនេះមាន បើយ៉ាងនោះ យើងគប្បីក្រាបទូលរឿងនេះ ចំពោះព្រះដ៏មានព្រះភាគ ដូចម្តេចហ្ន៎ យើងគប្បីបានព្រះធម្មទេសនាដ៏សុខុម ល្អិតល្អន់ ព្រោះអាស្រ័យរឿងនេះ ភិក្ខុទាំងនោះក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ក្នុងវេលាដែលព្រះដ៏មានព្រះភាគសម្តែងធម៌ខាងក្រោយភត្ត ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ សម្ពហុលា ភិក្ខូ** ដូច្នេះជាដើម ។

ព្រះដ៏មានព្រះភាគគ្រាទ្រង់ស្តាប់ដូច្នោះហើយ កាលនឹងទ្រង់ប្រកាសការ

ដែលពួកអន្យតិរ្ថិយមិនដឹងធម៌តាមសេចក្ដីពិត ទើបត្រាស់ថា **អញ្ញត្ថិយា ភិក្ខវេ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **អន្ធា** សេចក្ដីថា ឈ្មោះថា អ្នកខ្វាក់ ព្រោះរៀរបញ្ញាចក្ខុ ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា **អចក្ខុកា** មែនពិត បញ្ញាលោកប្រាជ្ញាថា ចក្ខុក្នុងទីនេះ ។ ពិតយ៉ាងនោះ ព្រះអង្គ ទើបត្រាស់ថា **អត្ថំ ន ជានន្តិ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អត្ថំ ន ជានន្តិ** សេចក្ដីថា មិនដឹងប្រយោជន៍លោកនេះ និងប្រយោជន៍លោកខាងមុខ គឺមិនយល់ដឹងសេចក្ដីចម្រើនលូតលាស់ល្អក្នុងលោកនេះ និងលោកខាងមុខ នឹងពោលទៅថ្វីដល់ប្រយោជន៍យ៉ាងក្រៃលែង គឺព្រះនិព្វានហ្ន៎ ។ មែនពិត ធម្មតាថា អ្នកលង់ក្នុងហេតុត្រឹមតែថា បវត្តិ (គឺទុក្ខ) នឹងដឹងនិវត្តិ (គឺនិរោធ) បានយ៉ាងណា ។ បទថា **អនត្ថំ ន ជានន្តិ** សេចក្ដីថា ជនទាំងនោះ រមែងមិនដឹងប្រយោជន៍ដោយចំណែកណា រមែងមិនដឹងសូម្បីវត្ថុដែលមិនជាប្រយោជន៍ ចំណែកនោះ ។ ព្រោះហេតុដែលមិនដឹងធម៌ ព្រោះដូច្នោះ សូម្បីអធម៌ក៏មិនដឹង ។ មែនពិត ព្រោះការកាន់អាការស្វែងរកខុស ជនទាំងនោះ រមែងធ្វើកុសលធម៌ឱ្យជាអកុសលធម៌ខ្វះ ធ្វើអកុសលធម៌ឱ្យជាកុសលធម៌ខ្វះ ។ មិនមែនមិនដឹងតែក្នុងធម៌ និងអធម៌តែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត សូម្បីក្នុងវិបាករបស់ធម៌ និងអធម៌ក៏មិនដឹងដែរ ។ ពិតយ៉ាងនោះ គេទាំងនោះសូម្បីកម្មក៏នូវពោលថា ឱ្យជាវិបាក សូម្បីវិបាក ក៏ពោលថា ឱ្យជាកម្ម ម្យ៉ាងទៀត រមែងមិនដឹងធម៌ គឺសភាវធម៌ខ្វះ រមែងមិនដឹងអធម៌ គឺមិនមែនសភាវធម៌ខ្វះ ។ ក៏អ្នកជាយ៉ាងនោះ រមែងប្រកាសសភាវធម៌ឱ្យជាអសភាវធម៌ និងប្រកាសអសភាវធម៌ ឱ្យជាសភាវធម៌ ។

ព្រះដ៏មានព្រះភាគគ្រាទ្រង់ប្រកាសថា តិរ្ថិយទាំងនោះដូចជាកែ្នកខ្វាក់ ព្រោះខ្វះបញ្ញាចក្ខុ ដោយបានចំពោះមោហៈ និងទិដ្ឋិ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងប្រកាសសេចក្តីនោះដោយឧបមាដោយអ្នកខ្វាក់អំពីកំណើត ទើបត្រាស់ពាក្យថា **ភូតបុព្វំ ភិក្ខវេ** ជ្រូងជាដើម ។ បណ្តាបទទាំងនោះ បទថា **ភូតបុព្វំ** បានដល់ មានហើយក្នុងកាលមុន គឺកើតហើយក្នុងអតីតកាល ។ បទថា **អញ្ញតរោ រាជា អហោសិ** សេចក្តីថា គ្រាមុនមានព្រះរាជាមួយអង្គ មិនប្រាកដនាម និងគោត្រក្នុងលោក ។ បទថា **សោ រាជា អញ្ញតរំ បុរិសំ អាមន្តេសិ** សេចក្តីថា ដំណាលមកថា ព្រះរាជាអង្គនោះ គ្រាទតព្រះនេត្រ ឃើញដំរីទ្រទ្រង់របស់ដ៏កំពូលដោយភាពស្អាត មានសព្វង្គកាយបរិបូណ៌មក កាន់ទីបម្រុង ទើបមានព្រះត្រិះរិះថា នៃអ្នកដ៏ចម្រើន យាន គឺដំរីដ៏ប្រសើរ ណាស់ហ្ន៎ ។ ក៏សម័យនោះ មនុស្សខ្វាក់អំពីកំណើតម្នាក់ដើរមកតាមព្រះរាជ-រាំង ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ទើបទ្រង់មានព្រះតម្រិះថា មនុស្សខ្វាក់ទាំងនេះ មានសេចក្តីសាបសូន្យយ៉ាងធំ ដែលមិនបានឃើញដំរីដែលគួរសរសើរបែបនេះ ធ្វើយ៉ាងណា យើងនឹងឱ្យមនុស្សខ្វាក់អំពីកំណើតទាំងអស់ ឱ្យប្រជុំគ្នាក្នុងក្រុងសាវត្ថីនេះ ឱ្យយកដៃចាប់ដំរីម្នាក់ម្តងៗ ហើយនឹងគប្បីស្តាប់ពាក្យរបស់មនុស្ស ខ្វាក់ទាំងនោះ ។ ព្រះរាជាអ្នកមានព្រះទ័យលេងសើច បានបញ្ជាឱ្យរាជបុរស ម្នាក់ ឱ្យប្រជុំមនុស្សខ្វាក់ទាំងអស់ក្នុងក្រុងសាវត្ថី ហើយបានឱ្យសញ្ញាដល់រាជ-បុរសនោះថា អ្នកឯងចូរធ្វើដោយប្រការដែលមនុស្សខ្វាក់តែមួយ អ្នកពាល់ ត្រូវអវយវៈរបស់ដំរីតែមួយចំណែកៗមានក្បាលជាដើមប៉ុណ្ណោះ ហើយឱ្យសញ្ញា ឡើងថា យើងឃើញដំរីហើយ ។ រាជបុរសបានធ្វើដូចយ៉ាងនោះ ។ លំដាប់នោះ

ព្រះរាជាត្រាស់សួរមនុស្សខ្វាក់ទាំងនោះម្នាក់ម្តងថា នែនាយ ដំរីមានសភាពយ៉ាងណា? មនុស្សខ្វាក់ទាំងនោះ ក្រាបទូលសេចក្តីផ្សេងៗចំពោះព្រះរាជា តាមដែលខ្លួនដឹងហើយថា ជាដំរី ទើបបង្ក្តការឈ្លោះគ្នាថា ដំរីជាដូច្នេះ ដំរីមិនជាដូច្នេះទេ ប្រើដៃជាដើម គប់គ្រវែងគ្នា ធ្វើកោលាហលយ៉ាងធំក្នុងព្រះរាជវាំង ។ ចំណែកព្រះរាជាព្រមដោយរាជបរិវារ បានទតព្រះនេត្រឃើញប្រការដែលប្ញែកនោះ របស់មនុស្សខ្វាក់ទាំងនោះ មានព្រះហ្ជ្ជទ័យរីករាយ ទ្រង់សើចយ៉ាងសប្ប្ជាយ ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ ភិក្ខវេ សោ រាជា ។បេ។ អត្តមនោ អហោសិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អម្ភោ** ជាអាលបន: ។ បទថា **យាវតិកា** ប្រែថា មានប្រមាណប៉ុណ្ណា ។ បទថា **ជច្ចន្ធា** ប្រែថា មនុស្សខ្វាក់អំពីកំណើត គឺមិនមានចក្ខុបសាទតាំងពីកើត ។ បទថា **ឯកជ្ឈं** ប្រែថា ជាការតែមួយគ្នា ។ បទថា **ភណោ** ជាការពោលមិនរាប់អាន ។ បទថា **ហត្ថึ ឧស្សេហិ** សេចក្តីថា ចូរសម្តែងដោយឱ្យដំរីដែលពោលហើយដេក ។ ក៏ដំរីនោះដេកដោយមិនបណ្តោះ ព្រោះបានទូន្មានល្អហើយ ។ ដោយបទថា **ឥដ្ឋោ ឧោ ហត្ថី** មនុស្សខ្វាក់យកដៃចាប់ដំរីដូចឃើញដោយភ្នែក ។ បុរសនោះឱ្យមនុស្សខ្វាក់ចាប់ក្បាលដំរី ព្រោះនឹងឱ្យដឹងថា ដំរីជាដូច្នេះ មនុស្សខ្វាក់អំពីកំណើតកាលដឹងថា ដំរីជាដូច្នោះនុ៎ះ ឯង ទើបក្រាបទូលថា ដំរីជាដូច្នេះ គឺដូចធ្នាំង ព្រះអង្គ ។ ក៏សេចក្តីរបស់បទថា **ឧម្ភោ** ប្រែថា ធ្នាំង ។ បទថា **ទីឃោ** បានដល់ ទំពក់ព្យរ ដែលធ្វើដោយកូកដំរី បទថា **សោណ្ហោ** បានដល់ ក្ងុក ។ បទថា **ឧ**ត្ត**លីសោ** បានដល់ ទន្ទាំរបស់

ក្បាលនង្គ័ល ។ បទថា **ការយោ** បានដល់ សរីរៈ ។ បទថា **ការជ្ជោ** ប្រែថា ជង្រុកស្រូវ ។ បទថា **ចាដោ** ប្រែថា ដើង ។ បទថា **ថូដោ** ប្រែថា សសរ ។ បទថា **ឧជ្ជុដ្ឋំ** បានដល់ ចំណែកលើរបស់កន្ទុយ ។ បទថា **ភាលនិ** បានដល់ ចំណែកចុងរបស់កន្ទុយ ។ បទថា **មុជ្ជីហិ សង្ខ្ភុកីសុ** បានដល់ ចំណង់ប្រដាល់ បានដល់ ដាល់គ្នា ។ បទថា **អត្តមដោ អហោសិ** សេចក្ដីថា ព្រោះព្រះអង្គមានប្រក្រតីលេងសើច ទើបព្រះរាជអង្គនោះទ្រង់ពេញព្រះទ័យ គឺមានសេចក្ដីរីករាយ ចាប់ព្រះទ័យ ព្រោះការឈ្លោះរបស់ពួកមនុស្សខ្វាក់ភ្នែកតាំងអំពីកំណើតនោះ ។

បទថា **ឯវមេវ ខោ** ជាការប្រៀបផ្ទឹមដោយឧបមា ។ ការប្រៀបផ្ទឹមដោយឧបមានោះមានសេចក្ដីដូចតទៅនេះ ។ ម្នាលភិក្ខុទាំងឡាយ មនុស្សខ្វាក់តាំងតែពីកំណើតទាំងនោះ មិនមានចក្ខុប្រសាទច្រើនឃើញទៅដោយចំណែកតែមួយ មិនឃើញដំរីចំណែកដែលនៅសល់ កាលមិនដឹងវត្ថុដែលអ្នកដទៃឃើញដោយសម្គាល់ថា ជាដំរីត្រឹមតែអវយវៈដែលខ្លួនឃើញ ក៏កើតវិវាទគ្នា នឹងគ្នាយ៉ាងណា អន្យតិត្ថិយទាំងនោះ ក៏ដូច្នោះដែរ សម្គាល់រូប វេទនាជាដើម ដែលជាចំណែកមួយនៃកាយរបស់ខ្លួន តាមដែលឃើញដោយទិដ្ឋិទស្សនៈរបស់ខ្លួនថា ជាអត្តា លើកឡើងកាន់ភាវៈថា ខ្លួននោះទៀងជាដើម ទើបវិវាទគ្នា នឹងគ្នាដោយប្រកាន់ថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទេ ។ តែមិនដឹងដល់វត្ថុដែលជាប្រយោជន៍ នឹងមិនជាប្រយោជន៍ និងវត្ថុដែលជាធម៌ និងមិនមែនធម៌តាមសេចក្ដីពិត ។ ព្រោះដូច្នោះ ទើបជាមនុស្សខ្វាក់មិនមានចក្ខុប្រសាទ មានចំណែកប្រៀបផ្ទឹមដោយមនុស្សខ្វាក់អំពីកំណើត ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ទ្រង់ជ្រាបដោយប្រការទាំងពួង ដល់

ការដែលពួកតិរ្ថិយមិនដឹង មិនឃើញសភាវធម៌តាមសេចក្ដីពិត ប្រកាន់ខុសតាមដែលឃើញដូចមនុស្សខ្វាក់អំពីកំណើតស្ទាបអង្អែលដំរីដូច្នោះ និងដល់ការវិវាទគ្នា ក្នុងការប្រកាន់ខុសនោះនេះ ទើបទ្រង់បន្ទឹមឧទានដែលសម្ដែងសេចក្ដីនោះ ។

បណ្ដាបទទាំងនោះ ដោយបទថា **ឥមេសុ ការ សជ្ជន្តិ ឯកេ សមណាព្រាហ្មណា** លោកសម្ដែងថា បានឮថា បុគ្គលពួកខ្លះក្នុងលោកនេះ ឈ្មោះថា **សមណៈ** ព្រោះចូលដល់ការបព្វជ្ជ ឈ្មោះថា **ព្រាហ្មណ៍** ព្រោះហេតុត្រឹមតែជាតិរមែងជាប់ជំពាក់ ដោយន័យមានជាអាទិ៍ថា នេះជារបស់យើង ដោយសេចក្ដីរីករាយក្នុងទិដ្ឋិ ក្នុងទិដ្ឋិដែលមិនជាសារៈទាំងនេះប៉ុណ្ណោះ ដែលប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា លោកទៀងជាដើម ឬដោយសេចក្ដីរីក-រាយក្នុងតណ្ហា និងសេចក្ដីរីករាយក្នុងទិដ្ឋិ ក្នុងឧបាទានខន្ធ មានរូបជាដើមទាំង-នេះ ដែលមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតាយ៉ាងនេះ គួរតក់ស្ទុត ជនទាំងនេះមានសេចក្ដីលង់ ។ **ការ**-ស័ព្ទ ក្នុងពាក្យថា **ឥមេ សុការ ។បេ។ សជ្ជន្តិ** នេះ ជាអរុចិសូចនត្ថៈ បំភ្ញីសេចក្ដីមិនពេញចិត្ត ។ ដោយពាក្យនោះ ទ្រង់សម្ដែងដល់សេចក្ដីមិនមានហេតុជាប់ជំពាក់ក្នុងសេចក្ដីនោះឯង ។ មិនមែននឹងជាប់ជំពាក់នៅតែម្យ៉ាងប៉ុណ្ណោះ ដោយសេចក្ដីពិត ការកាន់ខុសនូវទិដ្ឋិនិស្សយនោះ គឺទាស់ទែងវិវាទគ្នា បានដល់ ការវិវាទគ្នាដោយការប្រកបតាមពាក្យដែលកាន់ខុសៗដោយន័យមានជាអាទិ៍ថា លោកមិន ដឹងដល់ធម្មវិន័យនេះ យើងដឹងដល់ធម្មវិន័យនេះ ។ បទថា **ឯ** ក្នុងទីនេះត្រឹមតែជានិបាត ។ ម្យ៉ាងទៀត បទថា **ទិដ្ឋិយ្ហ ឯ** សេចក្ដីថា កាន់ទិដ្ឋិនិស្សយ ឬសក្កាយទិដ្ឋិនោះឯង

ឱ្យខុសគ្នា នឹងគ្នាហើយវិវាទគ្នា គឺពោលឱ្យបែកចេញទៅ ដោយឃើញថា ទៀងជាដើម ព្រោះមានសេចក្ដីឃើញខុសបែកគ្នា គឺពោលប្រកាន់តែវាទ:របស់ខ្លួនប៉ុណ្ណោះឱ្យវិសេស គឺមិនឱ្យខុសបែក ។ ដូចអ្វី ? ដូចជនទាំងឡាយដែលឃើញដោយចំណែកតែមួយ ។ អធិប្បាយថា មនុស្សខ្វាក់តាំងតែពីកំណើតទាំងនោះ ឃើញតែចំណែកមួយរបស់ដំរី គោងកាន់យកថា វត្ថុដែលខ្លួនពាល់ត្រូវដឹងនោះ ឯង គឺដំរី ទើបទាស់ទែងវិវាទគ្នា និងគ្នាយ៉ាងណា ពាក្យឧបមេយ្យដែលញ៉ាំងឧបមាឱ្យដល់ព្រមនេះក៏ដូច្នោះ ។ ក៏ **ឥ**-ស័ព្ទ ក្នុងគាថានោះគប្បីជ្រាបថា លុបទៅហើយ ។

ចតុត្ថសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៤

៤. ទុតិយជាជាតិត្តិយសុត្តវណ្ណនា

អដ្ឋកថាទុតិយនានាតិត្ថិយសូត្រ

ទុតិយនានាតិត្ថិយសូត្រទី ៥ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **សស្សតោ អត្តា ច លោកោ ច** *សេចក្តីថា ជនសូម្បីពួកដទៃ ប្រកាន់រូបារម្មណ៍ជាដើមយ៉ាងណាមួយថា ជាអត្តា និងថាជាលោកហើយប្រកាន់ រូបារម្មណ៍យ៉ាងណាមួយថា ទៀង យឺនយូរ ដូចពោលមកយ៉ាងនោះ ។ ដូចដែល លោកពោលទុកថា ជនទាំងឡាយ រមែងបញ្ញត្ត រូបឱ្យជាអត្តា និងលោកថាជា អត្តា ជាលោក និងទៀង បញ្ញត្តវេទនា ... សញ្ញា... សង្ខារ... វិញ្ញាណឱ្យជាអត្តា និងលោកថាជាអត្តា ជាលោក និងទៀង ។ ម្យ៉ាងទៀត បទថា* **អត្តា** *បានដល់ វត្ថុដែលប្រកាន់ថាជាយើង ។ បទថា* **លោកោ** *បានដល់ វត្ថុដែលប្រកាន់ថា ជារបស់យើង លោកពោលថា មានក្នុងខ្លួន ។ ម្យ៉ាងទៀត បទថា* **អត្តា** *បានដល់ ខ្លួនឯង ។ បទថា* **លោកោ** *បានដល់ អ្នកដទៃ ។ ម្យ៉ាងទៀត បទថា* **អត្តា** *បានដល់ ខន្ធ ១ បណ្តាឧបាទានខន្ធ ៥ ខន្ធក្រៅនោះ បានដល់ លោក ។ ម្យ៉ាង ទៀត បទថា* **អត្តា** *បានដល់ ខន្ធសន្តានដែលមានវិញ្ញាណគ្រប់គ្រង បទថា* **លោក** *បានដល់ ខន្ធសន្តានដែលមិនមានវិញ្ញាណគ្រប់គ្រង ។ ជនទាំងឡាយ ប្រកាន់រូបជាដើមនោះ។ មាន ២ ប្រការ តាមទស្សនៈថាជាអត្តា និងថាជាលោក យ៉ាងនេះហើយប្រកាន់យកទាំងអត្តា និងលោកនោះពោលថាទៀង យឺនយូរ មិនប្រែប្រួល ។ ដោយពាក្យនេះ លោកសម្តែងសស្សតវាទ: ៤ ។ ដោយពាក្យថា* **អសស្សតោ** *នេះ សម្តែងឧច្ឆេទវាទ:សូម្បីទាំង ៧ ។ បទថា* **សស្សតោ ច**

អសស្សតោ ច អធិប្បាយថា ដែលឈ្មោះថា ទៀង ព្រោះអត្តា និងលោកខ្ទះទៀង ដែលឈ្មោះថា មិនទៀង ព្រោះអត្តា និងលោកខ្ទះមិនទៀង ។ ម្យ៉ាងទៀត អត្តា និងលោកនុ៎ះឯង ខ្ទះទៀង ខ្ទះមិនទៀង ដូចរបស់អ្នកឃើញខ្ជូនជាគតិ គប្បីជ្រាបសេចក្តីក្នុងសេចក្តីនេះយ៉ាងនេះថា **សស្សតោ** ទៀង ។ ដោយបទថា **សស្សតោ** នេះ លោកសម្តែងដល់វាទ:ថាទៀងខ្ទះសូម្បីដោយប្រការទាំងពួង ។ ដោយបទថា **នេវ សស្សតោ ជាសស្សតោ** នេះ លោកសម្តែងដល់វាទ:ដើម្បីដោះខ្ជូន មិនឱ្យស្ទាប់ ។ ក៏ជនទាំងនោះឃើញទោសក្នុងសស្សតវាទ: និងអសស្សតវាទ: ពោលឱ្យរួចខ្ជូនថា អត្តានិងលោកទៀងក៏មិនមែន មិនទៀងក៏មិនមែន ។

បទថា **សយङ្ककតោ** ប្រែថា ខ្ជូនឯងសាងឡើង ។ ដូចថាអត្តារបស់ពួកសត្វនោះ។ បដិបត្តិធម៌សមគួរដល់ធម៌របស់ខ្ជូន ហើយសោយសុខទុក្ខយ៉ាងណា អត្តាក៏ដូច្នោះ រមែងធ្វើអត្តា និងលោកពោលគឺ សេចក្តីកង្វល់និងសេចក្តីពាក់-ព័ន្ធឱ្យជាគ្រឿងឧបភោគរបស់អត្តានោះ ជនទាំងនោះមានលទ្ធិសូម្បីយ៉ាងនេះ ដូចលទ្ធិអត្តាថា និម្មិតឡើង ។ បទថា **បរङ्ककតោ** ប្រែថា អ្នកដទៃសាងឡើង អធិប្បាយថា អ្នកដទៃក្រៅពីខ្ជូន នឹងជាឥស្សរជន បុរស ឬស្ត្រីក៏ដោយ សាងគឺនិម្មិតអត្តា និងលោកតាមកាល ឬតាមប្រក្រតី ។ បទថា **សយङ्ककតោ ច បរङ्ककតោ ច** សេចក្តីថា ព្រោះហេតុដែលឥស្សរជនជាដើម កាលនិម្មិតអត្តា និងលោក

នឹងនិម្មិតដោយខ្លួនឯងតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន តាមពិតត្រូវបានហេតុអ្នកធ្វើរួមគ្នារបស់ធម៌និងអធម៌ នៃពួកសត្វនោះៗ ព្រោះដូច្នោះ សត្វពួកខ្លះទើបមានលទ្ធិដូច្នេះថា អត្តា និងលោកខ្លួនឯងធ្វើឡើង និងអ្នកដទៃធ្វើឡើង ។ បទថា **អសយង្ការោ អបរង្ការោ** *សេចក្ដីថា ឈ្មោះថា* **អសយង្ការ** *ព្រោះខ្លួនឯងមិនបានធ្វើ ឈ្មោះថា* **អបរង្ការ** *ព្រោះអ្នកដទៃមិនបានធ្វើ ។ ព្រោះចុះនិគ្គហិតអាគម ទើបពោលថា* **អបរង្ការោ** *។ អ្នកនេះឃើញទោសក្នុងសេចក្ដីដែលខ្លួននិងអ្នកដទៃធ្វើ ទើបបដិសេធហេតុទាំងពីរយ៉ាង ។ ដើម្បីនឹងជៀសវាងពាក្យសួរថា កាលបើដូច្នោះ អត្តានិងលោកកើតឡើងយ៉ាងណា ទើបពោលធ្វើយថា* **អធិច្ចសមុប្បន្នោ** *អាស្រ័យបច្ច័យកើតឡើង ។ លោកសម្ដែងអធិច្ច-សមុប្បន្នវាទ:ថា កើតឡើងតាមសេចក្ដីប្រាថ្នា គឺកើតឡើងដោយវៀរហេតុខ្លះ ។ ក៏ដោយពាក្យនោះ ជាការសង្គ្រោះអហេតុកវាទ:ចូលផង ។*

ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងវាទ:នោះរបស់អ្នកមានទិដ្ឋិជាគតិពោលប្រកាន់សុខ និងទុក្ខ ដែលជាគុណ ឬជាគ្រឿងកង្វល់របស់អត្តានោះ ដោយជារបស់ទៀងជាដើម ដូចពោលប្រកាន់អត្តា ទើបត្រាស់ពាក្យមានជាអាទិ៍ថា **សន្ដេ-ធេ សមណាព្រាហ្មណា** *។ ពាក្យនោះមានន័យដូចពោលហើយនុ៎ះឯង ។*

ក៏ក្នុងបទថា **ឯតមត្ថំ វិទិត្វា** *នេះ ព្រោះការប្រៀបធ្ងឹមដោយមនុស្សខ្វាក់ភ្នែកអំពីកំណើត មិនមកក្នុងព្រះសូត្រនេះ ទើបលះសេចក្ដីនោះហើយប្រកបសេចក្ដីដោយន័យដែលពោលក្នុងកាលមុននុ៎ះឯង ។ ក្នុងគាថាក៏ដូចគ្នា ។*

ក្នុងព្រះគាថានោះមានសេចក្តីបែកគ្នាត្រឹមតែប៉ុណ្ណោះថា មិនទាន់ដល់ព្រះនិព្វានដែលជាទីធ្លាក់ចុះ រមែងលិចចុះក្នុងចន្ទោះពិតមែន ។ ពាក្យនោះមានអធិប្បាយដូចតទៅនេះ ទិដ្ឋិគតិកបុគ្គលទាំងឡាយជាប់ជំពាក់នៅក្នុងទិដ្ឋិ គឺទិដ្ឋិនិស្សរ៉ៃ មិនទាន់ដល់ គឺមិនទាន់សម្រេចព្រះនិព្វាន ពោលគឺ ជាទីធ្លាក់ចុះ ឬអរិយមគ្គជាឧបាយជាគ្រឿងសម្រេចព្រះនិព្វាននោះ ព្រោះជាត្រើយ ឬជាទីពឹងរបស់ទិដ្ឋិគតិកបុគ្គលទាំងនោះ ទើបលិច គឺកប់ទុកនៅក្នុងចន្ទោះ គឺត្រង់កណ្តាលឱឃៈទាំង ៤ មានកាមោឃៈជាដើម ឬអន្ទង់ទឹកធំ គឺសង្សារនុ៎ះឯង ។ អរិយមគ្គនិងព្រះនិព្វាន ឈ្មោះថា ធម៌ជាគ្រឿងធ្លាក់ចុះ ព្រោះជាគ្រឿងធ្លាក់ចុះ ឬជាទីអាស្រ័យ ។ ក្នុងទីនេះ ព្រោះរស្សៈ (ធ្វើឱ្យស្រះខ្វី) **ឱ**ឱ**ឆ**ំ នុ៎ះឯង ទើបពោលថា **ឱ**ឱ**ឆ**ំ ។ មានការចែកបទថា **ត**ំ **ឱ**ឱ**ឆ**ំ ជា **ត**ម្ហា**ឆ**ំ ។

បញ្ចមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៥

៦. តតិយជាជាតិត្ថិយសុត្តវណ្ណា

អដ្ឋកថាតតិយនានាតិត្ថិយសូត្រ

តតិយនានាតិត្ថិយសូត្រទី ៦ *មានវិនិច្ឆ័យដូចតទៅនេះ*

ពាក្យទាំងអស់មានន័យដូចពោលហើយក្នុងកាលមុនទុំ១ងង ។ ក៏ក្នុងពាក្យថា **ឥមំ ឧជានំ** *នេះគប្បីប្រកបសេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់បន្ទឹ ឧទាននេះ ដែលសម្តែងដល់ការប្រព្រឹត្តកន្ទង និងសេចក្តីមិនប្រព្រឹត្តកន្ទងពីសង្ឃារតាមលំដាប់របស់អ្នកដែលឃើញទោសក្នុងទិដ្ឋិ តណ្ហា និងមាន: ហើយរៀរទិដ្ឋិជាដើមទាំងនោះឱ្យឃ្ងាតឆ្ងាយ ហើយពិចារណាសង្ខារតាមសេចក្តីពិត និងរបស់អ្នកប្រកាន់ខុស ព្រោះមិនឃើញទោសក្នុងសង្ខារទាំងនោះ មិនឃើញតាមសេចក្តីពិត ។*

បណ្តាបទទាំងនោះ បទថា **អហង្ការបសុតាយំ បជា** *សេចក្តីថា ពួកសត្វនេះអ្នកខ្ជល់ខ្ជាយ គឺប្រកបតាមអហង្ការ ពោលគឺ យើងធ្វើខ្លួនឯង ដូចពោលហើយយ៉ាងនេះថា អត្តា និងលោក យើងជាអ្នកធ្វើ បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅយ៉ាងនោះ គឺពួកសត្វដែលប្រកាន់ខុស ។ បទថា* **បង្ការូបសំហិតា** *បានដល់ អ្នកប្រកបដោយបង្ការ ព្រោះអាស្រ័យទិដ្ឋិថា អ្នកដទៃធ្វើ ដែលប្រព្រឹត្តទៅយ៉ាងនេះថា អ្នកដទៃៗមានឥស្សរជនជាដើមធ្វើទាំងអស់ បានដល់ អ្នកប្រកបដោយបង្ការទិដ្ឋិនោះ ។ បទថា* **ឯតេ០ កោ ជាពុញ្ញសុ** *សេចក្តីថា សមណ: និងព្រាហ្មណ៍ពួកមួយជាអ្នកមានប្រក្រតីឃើញទោសក្នុងទិដ្ឋិ ២ យ៉ាងនោះ មិនដឹងទិដ្ឋិ ២ យ៉ាងនោះ ។ គឺអ្វី ? គឺក៏កាលធ្វើដោយខ្លួនឯង សត្វទាំងឡាយក៏នឹងគប្បីប្រាថ្នាធ្វើកាមប៉ុណ្ណោះ អ្នកដែលមិនប្រាថ្នាមិនមាន ។ អ្នកណាៗ នឹងប្រាថ្នាទុក្ខដើម្បីខ្លួន និងមានវត្ថុដែលមិនត្រូវការក៏ទេ ព្រោះដូច្នោះ*

ទើបជាអ្នកធ្វើខ្លួនឯង ។ សូម្បីអ្នកដទៃធ្វើ បើមានឥស្សរជនជាហេតុ ឥស្សរជន នេះនោះក៏នឹងធ្វើដើម្បីខ្លួន ឬដើម្បីអ្នកដទៃ ។ បណ្តា ២ យ៉ាងនោះ បើធ្វើដើម្បីខ្លួន ក៏នឹងគប្បីមិនមានកិច្ចដែលខ្លួននឹងធ្វើ ព្រោះនឹងឱ្យកិច្ចដែលមិនទាន់សម្រេចឱ្យសម្រេចចុះ បើធ្វើដើម្បីអ្នកដទៃ ក៏នឹងគប្បីឱ្យសម្រេចចំពោះហិតសុខដល់ជនទាំងអស់ប៉ុណ្ណោះ វត្ថុដែលមិនជាប្រយោជន៍ និងជាទុក្ខក៏នឹងមិនសម្រេច ព្រោះដូច្នោះ អ្នកដទៃធ្វើទើបមិនសម្រេចដោយឥស្សរជន ។ ក៏បើហេតុដោយមិនប្រាថ្នាអ្នកដទៃ ពោលគឺ ឥស្សរជននឹងគប្បីមានដើម្បីការប្រព្រឹត្តទៅជានិច្ចតែម្តង ។ មិនគប្បីកើតឡើង ព្រោះការធ្វើអ្នកទាំងអស់ទ្ងុ:ឯង នឹងគប្បីកើតឡើងរួមគ្នា ព្រោះហេតុជាទីតាំងទុករួមគ្នា ។ បើអ្នកនោះប្រាថ្នាហេតុ មានការធ្វើរួមគ្នាសូម្បីដទៃ ប្រការនោះឯងជាហេតុ ។ នឹងប្រយោជន៍អ្វីដោយឥស្សរជន អ្នកកំណត់ដោយភាពជាអ្នកអាចក្នុងកិច្ចដែលមិនទាន់សម្រេច ។ ឧបមាថា អ្នកដទៃធ្វើ មានឥស្សរជនជាហេតុរមែងមិនសម្រេច យ៉ាងណា សូម្បីខ្លួនឯងធ្វើ មានសត្វបុរស ប្រក្រតី ព្រហ្ម និងកាលជាដើមជាហេតុ ក៏មិនសម្រេចដូច្នោះដែរ ព្រោះជនសូម្បីទាំងនោះ ក៏មិនឱ្យសម្រេច ទើបមិនរួចទោសតាមដែលពោលហើយ ព្រោះហេតុនោះ លោកទើបពោលថា **ឯត្តេ ០ កោ ០ ជាត្ថ ០ ញ្ញ ០ ** ។ ក៏ជនពួកណាមិនដឹងខ្លួនឯងធ្វើ និងអ្នកដទៃធ្វើតាមដែលពោលហើយ រមែងបញ្ញត្តអត្តា និងលោក ដែលកើតឡើងពីបច្ច័យ ជនសូម្បីទាំងនោះមិនឃើញទិដ្ឋិនោះថាជាកូន-សរ គឺសូម្បីបុគ្គលដែលមានវាទ:ថា អត្តានិងលោកកើតឡើងពីបច្ច័យ មិនដឹងតាមសេចក្តីពិត ព្រោះមិនទាន់កន្ទ្ងងផុតការប្រកាន់ខុស ទើបមិនឃើញទិដ្ឋិ

នោះថា ជាកូនសរ ព្រោះអត្ថថា ចាក់ដោត ដោយធ្វើទុក្ខឱ្យកើតឡើងក្នុងអត្តា និងលោកនោះ។ ។ បទថា **ឯត្ថ ញ្ច សលំ្ច បដិកច្ច បស្សតោ** *សេចក្ដីថា ក៏អ្នកណាផ្ដើមបំពេញវិបស្សនា ពិចារណាឃើញឧបាទានខន្ធទាំង ៥ ជាសភាពមិនទៀង ជាទុក្ខ ជាអនត្តា អ្នកនោះរមែងពិចារណាឃើញវិបរិតទស្សនៈ ៣ យ៉ាងនេះ និងមិច្ឆាកិនិវេសៈដទៃទាំងអស់ និងឧបាទានខន្ធទាំង ៥ ដែលជាទីអាស្រ័យរបស់ធម៌នោះ ដោយវិបស្សនាក្នុងខាងដើមនោះឯងថាជាកូនសរ ព្រោះចាក់រុក និងព្រោះដកបានលំបាក ។ កាលព្រះយោគីនោះឃើញនៅយ៉ាងនេះ មិនមានសេចក្ដីគិតថា យើងធ្វើដោយចំណែកប៉ុណ្ណោះ ក្នុងខណៈអរិយមគ្គ ។ ក៏ព្រះយោគីនោះមិនមានសេចក្ដីគិតថា អ្នកដទៃធ្វើដោយប្រការដែលមិនប្រាកដដល់លោកថា ខ្លួនឯងធ្វើ ។ តែនឹងមានត្រឹមតែបដិច្ចសមុប្បន្នធម៌ ពោលគឺសេចក្ដីមិនទៀងតែម្យ៉ាងប៉ុណ្ណោះ ។ ដោយលំដាប់ដំបូងពាក្យត្រឹមតែប៉ុណ្ណោះ ជាការសម្ដែងដល់ភាពជាអ្នកបដិបត្តិដោយប្រពៃ មិនមានទិដ្ឋិ និងមានៈសូម្បីដោយប្រការទាំងពួង ។ ក៏ដោយពាក្យនោះ ជាការប្រកាសដល់ការរួចផុតសង្សារ ដោយការសម្រេចព្រះអរហត្ត ។*

ឥឡូវនេះ ដើម្បីនឹងសម្ដែងថា អ្នកដែលជាប់នៅក្នុងទិដ្ឋិ រមែងមិនអាចដើបក្បាលឡើងពីសង្សារបាន ទើបត្រាស់គាថាថា **មានុសេតា** *ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា* **មានុសេតា អយំ បជា** *សេចក្ដីថា ប្រជា គឺពួកសត្ត្ថ ពោលគឺ ទិដ្ឋិគតិកបុគ្គលនេះទាំងអស់ចូលដល់ គឺប្រកបដោយមានៈដែលមានលក្ខណៈផ្ដងការប្រកាន់របស់ខ្លួនថា ទិដ្ឋិរបស់យើងល្អ ការប្រកាន់របស់យើងត្រឹមត្រូវ ។ បទថា* **មានតណ្ហា មានវិនិព្ធ្ធា** *សេចក្ដីថា តអំពីនោះឯង ពួក*

សត្វទាំងនោះ ឈ្មោះថា អ្នកមានគ្រឿងរួបរឹត គឺមានៈ មានគ្រឿងចង គឺមានៈ ព្រោះមានៈដែលកើតឡើងបន្តៗ គ្នាមកនោះ រួបរឹតនិងចងព័ន្ធនសន្ធានរបស់ខ្លួនទុក ដោយខ្លួនមិនទាន់លះបង់ទិដ្ឋិនោះ ។ បទថា **ឥជ្ជីសុ សារម្ភកថា សំសារំ ជាតិវត្ដតិ** *សេចក្ដីថា មានសារម្ភកថា ពោលដោយការប្រកួតដោយល្អ គឺមានវិវោធកថា ពោលដោយសេចក្ដីជំទាស់ក្នុងទិដ្ឋិរបស់ជនពួកដទៃ ដោយការប្រកាន់ទិដ្ឋិរបស់ខ្លួន ដោយការលើកខ្លួនគ្របសង្កត់លោកថា វត្ថុនេះពិត វត្ថុដទៃមិនពិត រមែងមិនកន្ធងឡើយ គឺរមែងមិនផុតពីសង្សារ ព្រោះមិនទាន់លះអវិជ្ជា និងតណ្ហាជាគ្រឿងនាំសត្វទៅកាន់សង្សារមិនបាន ។*

ឆដ្ឋសុត្ដវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៦

៧. សុភូតិសុត្តវណ្ណនា

អដ្ឋកថាសុភូតិសូត្រ

សុភូតិសូត្រទី ៧ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **សុភូតិ** *ជាឈ្មោះរបស់ព្រះថេរៈនោះ ។ មែនពិត ព្រះថេរៈដ៏មានអាយុអង្គនេះបានសាងអភិនីហារទុក ត្រង់បាទមូលរបស់ព្រះដ៏មានព្រះភាគ ព្រះនាមថា* ***បទុមុត្តរៈ*** *កសាងបុញ្ញសម្ភារទុករហូតអស់សែនកប្ប ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងត្រកូលគហបតីមានទ្រព្យសម្បត្តិច្រើន ស្តាប់ព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគហើយកើតធម្មសង្វេគ ចេញចាកផ្ទះបួស ព្រោះបានសាងបុណ្យអធិការទុក ព្យាយាមប្រឹងប្រែង មិនយូរប៉ុន្មានព្រះថេរៈដ៏មានអាយុអង្គនេះក៏បានអភិញ្ញា ៦ តែព្រោះដល់បារមីខ្ពស់បំផុតនៃព្រហ្មវិហារភាវនា ព្រះដ៏មានព្រះភាគទើបទ្រង់ស្ថាបនាទុកក្នុងឯតទគ្គៈ នៅក្នុងអរណៈវិហារីបុគ្គលថា* **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ អរណៈវិហារីនំ យទិទំ សុភូតិ** *ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកនៅដោយឥតកិលេស ដែលជាសាវករបស់តថាគត ស្រេចលើសុភូតិ[1] ។ ថ្ងៃមួយ វេលារសៀល ព្រះថេរៈចេញពីទីសម្រាកពេលថ្ងៃ ចុះទៅកាន់លានវិហារ ឃើញព្រះដ៏មានព្រះភាគកំពុងទ្រង់សម្តែងធម៌ត្រង់កណ្តាលបរិស័ទទាំង ៤ កំណត់វេលាថា វេលាចប់ទេសនាយើងនឹងក្រោកទៅថ្វាយបង្គំ ទើបអង្គុយចូលផលសមាបត្តិត្រង់គល់ដើមឈើ*

១-សុត្តន្តបិដក អង្គុត្តរនិកាយ ឯក-ទុកនិបាត លេខ ៦០ ទំព័រ ៥៦ ។

មួយកន្ទ្ធ មិនធ្វាយពីព្រះដ៏មានព្រះភាគ ។ ព្រោះហេតុនោះ លោកទើបពោលថា ក៏សម័យនោះឯង ព្រះសុភូតិដ៏មានអាយុ ។ល។ ចូលផលសមាបត្តិ ។

ក្នុងការចូលសមាបត្តិនោះ ផ្តើមតាំងពីទុតិយជ្ឌានទៅ រូបាវចរសមាធិក្តី អរូបាវចរសមាធិទាំងអស់ក្តី ក៏គឺអវិតក្កសមាធិនុ៎ះឯង ។ តែក្នុងទីនេះ អរហត្ត-ផលសមាធិ ដែលមានចតុត្ថជ្ឌានជាបាទ លោកប្រាថ្នាយកថា អវិតក្កសមាធិ ។ មិច្ឆាវិតក្ក: ត្រូវទុតិយជ្ឌានជាដើមលះហើយ ចាត់ថាមិនទាន់លះ ព្រោះមិនមានការលះដាច់ ចំណែកព្រះអរិយមគ្គលះនុ៎ះឯង ចាត់ថាលះដោយល្អ ព្រោះមិនមានកិច្ចដែលនិងលះតទៅ ។ ព្រោះដូច្នោះ អរហត្តផលសមាធិ ជាទីបំផុតនៃអរហត្តមគ្ត ព្រោះកើតឡើងក្នុងទីបំផុតនៃការលះមិច្ឆាវិតក្ក:ទាំងអស់ ពោលដោយពិសេស ទើបគួរពោលទុកថា អវិតក្កសមាធិ នឹងចាំបាច់ពោលទៅថ្ងៃដល់ការមានចតុត្ថជ្ឌានជាបាទហ្ន៎ ព្រោះហេតុនោះ លោកទើបពោលថា ក៏ក្នុងទីនេះ អរហត្តផលសមាធិដែលមានចតុត្ថជ្ឌានជាបាទ លោកប្រាថ្នាយកថា អវិតក្ក-សមាធិ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ដឹងដោយអាការទាំងពួងដល់អត្ថនេះ ពោលគឺ ការដែលព្រះសុភូតិដ៏មានអាយុលះកិលេស គឺមិច្ឆាវិតក្ក: ទាំងអស់បាន ទើបទ្រង់បន្ទ្ធឧទាននេះ ដែលសម្ដែងដល់សេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **យស្ស** *វិតក្កា* ** វិធូបិតា** *សេចក្តីថា ព្រះអរិយបុគ្គលណា កម្ចាត់មិច្ឆាវិតក្ក:សូម្បីទាំងអស់ មានកាមវិតក្ក:ជាដើម គឺ ធ្វើឱ្យស្ងប់ បានដល់ កាត់ផ្តាច់ដោយអរិយមគ្គញ្ញាណ ។* បទថា **អជ្ឌត្តំ** *សុ-* **ឧ**ប្ឌ**ិ**តា **អ**ស**ិ**ស**ា** *សេចក្តីថា កំណត់ទុកល្អ គឺកំណត់ដោយល្អដោយមិនទៅ សល់ ដែលគួរកើតឡើងក្នុងសន្តានរបស់ខ្លួន ពោលគឺ ខាងក្នុងខ្លួន អធិប្បាយ ថា កាត់ផ្តាច់ដោយល្អមិនឱ្យសេសសល់ ។* បទថា **តំ** *ក្នុងបទថា* **តំ** *សង្ខ*ត**ិ**ច**ូ* **អ**ូ**ប**ស**ញ្ញ**ី *នេះ ត្រឹមតែជានិបាត ។ ម្យ៉ាងទៀត* **តំ**-*សទ្ទ មានហេតុជាអត្ថ ។ ក៏ព្រោះហេតុ ដែលព្រះអរិយបុគ្គលកាត់មិច្ឆាវិតក្ក:បានដាច់ដូច្នោះ ព្រះអរិយ-បុគ្គលនោះទើបឈ្មោះថា មានសេចក្តីសម្គាល់ក្នុងអរូបដោយមគ្គសញ្ញា និងផល-សញ្ញាដែលប្រព្រឹត្តទៅដោយធ្វើព្រះនិព្វានដែលបាននាមថា អរូបឱ្យជាអារម្មណ៍ ព្រោះមិនមានសការ:នៃរូប និងមិនមានវិការ: គឺសេចក្តីប្រែប្រួលក្នុងព្រះនិព្វាន នោះ ឬព្រោះមិនមានហេតុនៃសេចក្តីពិការ ហេតុដែលកន្ទងហួសផុតគ្រឿង ជាប់ជំពាក់ ៥ យ៉ាង មានគ្រឿងជាប់ជំពាក់ គឺរាគ:ជាដើម ឬគ្រឿងជាប់ជំពាក់ គឺកិលេស សូម្បីទាំងអស់ ។* បទថា **ចតុយោ**គ**ាតិ**ក**តោ** *បានដល់ ឈានកន្ទង ដែលយោគ: ៤ គឺកាមយោគ: ភវយោគ: ទិដ្ឋិយោគ: និងអវិជ្ជាយោគ: ដោយ មគ្គទាំង ៤ តាមសមគួរ ។* **ម** *អក្សរក្នុងបទថា* **ន ជ**ាតុ **ម**េ**ត**ិ *នេះ ធ្វើការភ្ជាប់ បទ ។ សេចក្តីថា រមែងមិនត្រឡប់មកដើម្បីកើតក្នុងភពថ្មី ដោយចំណែកតែ*

មួយពិត គឺលោកមិនមានការកើតក្នុងភពថ្មីតទៅ ។ អាចារ្យពួកខ្លះពោលថា **ន ជាតិ មេតិ** *ដូច្នេះក៏មាន សេចក្ដីក៏យ៉ាងនោះឯង ។ ព្រោះដូច្នោះ ព្រះដ៏មាន-ព្រះភាគទ្រង់ប្រារឰធម៌ជាគ្រឿងនៅ គឺអរហត្តផលសមាបត្តិ និងអនុបាទិសេស-និព្វានរបស់ព្រះសុភូតិដ៏មានអាយុ ទើបទ្រង់បន្ទឺឧទានដែលកើតពីកម្ទាំងបីតិ ។*

សត្តមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៧

៨. កណ៌ិកាសុត្តវណ្ណនា

អដ្ឋកថាគណ៌ិកាសូត្រ

គណ៌ិកាសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **ទ្វេ ឃ្ងា** *បានដល់ ២ គណៈ ។ បទថា* **អញ្ញតរិស្សា កណ៌ិ-កាយ** *បានដល់ ស្ត្រីលម្អក្រុងម្នាក់ (ស្រីផ្កាមាស) ។ បទថា* **សារត្តា** *ប្រែថា តម្រេកដោយល្អ ។ បទថា* **បដិពទ្ធចិត្តា** *ប្រែថា មានចិត្តជាប់ដោយកិលេស ។*

បានឮថា ក្រុងរាជគ្រឹះ ក្នុងថ្ងៃមហោស្រពមួយ ពួកអ្នកលេងជាច្រើនដើរជាក្រុមៗ ហើយនាំស្រីពេស្យាមកម្នាក់មួយៗ ចូលសួនលេងមហោស្រព ។ ក្រោយពីនោះ ក្នុងថ្ងៃមហោស្រព អ្នកលេង ២-៣ នាក់ នាំស្រីពេស្យានោះៗឯងមកលេងមហោស្រព ។ ថ្ងៃមហោស្រពដទៃទៀត ពួកអ្នកលេងសូម្បីពួកដទៃក៏ប្រាថ្នានឹងលេងមហោស្រពដូច្នោះដែរ កាលនឹងនាំស្រីពេស្យាមក ទើបនាំស្រីពេស្យាម្នាក់ដែលពួកអ្នកលេងមុនធ្លាប់នាំមក ចំណែកអ្នកលេងមុនឃើញដូច្នោះ ទើបពោលថា ស្រីនេះនៅក្នុងការឃុំគ្រងរបស់ពួកយើង ។ ចំណែកអ្នកលេងពួកក្រោយក៏បានពោលយ៉ាងនោះដូចគ្នា ។ អ្នកលេងទាំង ២ ក្រុមនោះ ក៏បង្កជម្លោះឡើងថា កាលបើដូច្នេះ ពួកយើងក៏ឃុំគ្រងបាន ពួកយើងក៏ឃុំគ្រងបាន ទើបបានប្រហារគ្នាដោយដៃជាដើម ។ ព្រោះហេតុនោះ លោកទើបពោលថា **តេន ខោ បន សមយេន ភាគតោ ទ្វេ ឃ្ងា** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **ឧបក្កមន្តិ** *ប្រែថា ប្រហារគ្នា ។ បទថា* **មរណម្បិ និគច្ឆន្តិ** *សេចក្តីថា ចូលដល់មរណភាពដោយការប្រហារគ្នាយ៉ាងខ្លាំងក្លា ។ ចំណែកមួយពួកទៀត បានទទួលទុក្ខ ខ្លះស្លាប់ គឺមានសេចក្តីស្លាប់ជាប្រមាណ ។*

បទថា **ឯតមត្ថं វិទិត្វា** *សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួងនូវ*

សេចក្តីតម្រេកក្នុងកាមទាំងឡាយនោះថា ជាមូលនៃសេចក្តីវិវាទ និងថាជាមូលនៃសេចក្តីវិនាសទាំងពួង ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលប្រកាសទោសក្នុងចំណែកបំផុត ២ យ៉ាង និងអានិសង្សក្នុងមជ្ឈិមាបដិបទា ។

បណ្តាបទទាំងនោះ បទថា **យញ្ច បត្តំ** សេចក្តីថា បញ្ចកាមគុណមានរូបជាដើមដែលបុគ្គលបានទទួល គឺដែលបុគ្គលធ្វើទិដ្ឋិទុកក្នុងខាងមុខ ឬមិនធ្វើទុកក្នុងខាងមុខថា ទោសក្នុងកាមមិនមានបានហើយ គឺសោយនៅក្នុងឥឡូវនេះ ។ បទថា **យញ្ច បត្តព្វំ** សេចក្តីថា កាមគុណណា ដែលទិដ្ឋិគតិកបុគ្គលអាស្រ័យទិដ្ឋិថា កាមយើងគប្បីបរិភោគ កាមយើងគប្បីប្រើប្រាស់ កាមយើងគប្បីសេព កាមយើងគប្បីសេពចំពោះ បុគ្គលណាបរិភោគកាម បុគ្គលនោះឈ្មោះថា ធ្វើលោកឱ្យចម្រើន បុគ្គលណាធ្វើលោកឱ្យចម្រើន បុគ្គលនោះឈ្មោះថា ជួបបុណ្យជាច្រើន ដូច្នេះហើយ គប្បីដល់ គឺគប្បីសោយក្នុងអនាគត ដោយកម្មដែលខ្លួនមិនលះបង់ទិដ្ឋិនោះហើយធ្វើ ។ បទថា **ឧភយមេតំ រជាឧកិណ្ណា** សេចក្តីថា កាមគុណទាំងពីរនោះដែលបុគ្គលដល់ហើយ នឹងពោយពាយដោយធូលី គឺរាគ: ជាដើម ។ មែនពិត បុគ្គលកាលសោយវត្ថុកាមដែលជួបប្រសព្ធ រមែងពោយពាយដោយធូលី គឺរាគ: ក៏ហេតុ ២ យ៉ាងនោះ កាលផលនៃចិត្តដែលសៅហ្មង ក្នុងអនាគត ទើបឈ្មោះថា ពោយពាយដោយធូលី គឺទោស: ព្រោះទោមនស្សកើតឡើងសូម្បីដោយប្រការទាំងពីរ ឈ្មោះថា ពោយពាយដោយធូលី គឺមោហ: ។ ដើម្បីនឹងធ្វើយពាក្យសួរថា ក៏កាមទាំងពីរនោះពោយពាយដោយធូលីដល់អ្នកណា ? ទើបត្រាស់ថា ដល់បុគ្គលរសាប់រសល់ អ្នកកំណត់តាម អធិប្បាយថា ដល់បុគ្គល

ដែលក្តៅផ្សាព្រោះកិលេស ដោយអំណាចប្រាថ្នាកាម និងអ្នកក្តៅផ្សាព្រោះទុក្ខ ដោយផលរបស់កិលេសនោះ អ្នកកំណត់កាមកិលេស និងផលរបស់កិលេស ដោយប្រាថ្នាការតបជំនួស សូម្បីក្នុងទាំង ២ យ៉ាង ។

ម្យ៉ាងទៀត បទថា **យញ្ច បត្តំ** សេចក្តីថា កាមគុណណា ដែលបុគ្គលដល់ហើយ ដោយអំណាចអចេលវត្តជាដើម ឈ្មោះថា ញ៉ាំងខ្លួនឱ្យក្តៅក្រហាយ ។ បទថា **យញ្ច បត្តញ្ច** សេចក្តីថា កាមគុណណា ជាផលដែលនឹងគប្បីសោយ ក្នុងអបាយ ព្រោះហេតុនៃការសមាទានមិច្ឆាទិដ្ឋិកម្ម ។ បទថា **ឧភយមេតំ រជាជុកិណ្ណា** បានដល់ កាមគុណទាំងពីរនោះ ពោយរាយដោយធូលី គឺទុក្ខ ។ បទថា **អាតុរស្ស** បានដល់ អ្នកក្តៅក្រហាយនឹងទុក្ខ ដោយការលំបាកកាយ ។ បទថា **អជុសិក្ខតោ** បានដល់ អ្នកកំណត់តាមមិច្ឆាទិដ្ឋិ និងបុគ្គលដែលប្រកាន់មាំមិច្ឆាទិដ្ឋិនោះ ។

បទថា **យេ ច សិក្ខាសារា** សេចក្តីថា ក៏ពួកជនដែលគេហៅថាបរិសុទ្ធក្នុងសង្សារដោយសីលពូតនេះ ព្រោះកាន់យកសិក្ខា គឺសីលពូតជាដើមដែលខ្លួនប្រកាន់ថាជាខ្ចឹម ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ជនទាំងឡាយណា មានការសិក្សាជាខ្ចឹម សីលពូត ជីវិត ព្រហ្មចរិយៈ នឹងការបម្រើជាខ្ចឹមដូច្នេះជាដើម ។ ក្នុងសេចក្តីនោះ ទីដែលបុគ្គលវៀរចាក រមែងមិនធ្វើចាត់ជាសីល ការប្រព្រឹត្តលំបាកព្រោះនឹងត្រូវបរិភោគតាមវេលាជាដើមចាត់ជាវត្ត ការរស់នៅដោយភាពជាអ្នកមានបន្ទៃជាអាហារជាដើម ចាត់ជាជីវិតមេថុនវិរតិ ចាត់ជាព្រហ្មចរិយៈ ការដែលសីលវត្តទាំងនោះតាំងនៅរឿយៗ ចាត់ជាការបម្រើ ម្យ៉ាងទៀត ការប្រតិបត្តិព្រះខន្ធកុមារ និងព្រះសិវៈជាដើម ដោយ

ការជ្រោះព្រំហាក់បីដូចរបស់ភូតជាដើម ចាត់ជាការបម្រើ សេចក្ដីបរិសុទ្ធក្នុងសង្សារ រមែងមានដោយសីលជាដើម តាមដែលពោលហើយទាំងនោះ ដោយការយ៉ាងនេះ ព្រោះហេតុនោះ សមណព្រាហ្មណ៍ទាំងឡាយ អ្នកប្រកាន់សីលជាដើមទាំងនោះ ដោយជាខ្ជឹមតាំងនៅ គប្បីជ្រាបថា អ្នកមានការសិក្សាជាខ្ជឹម មានសីលពូត ជីវិត ព្រហ្មចរិយ: និងការបម្រើជាខ្ជឹម ។ បទថា **អយមេកោ អន្តោ** សេចក្ដីថា ផ្លូវអមនេះ គឺការប្រកបខ្ជួនឱ្យលំបាក ដោយការប្រកាន់សីលពូត ជាការបដិបត្តិក្រៅមជ្ឈិមាបដិបទា ព្រោះអត្ថថា ថោកទាប ។ បទថា **អយំ ឧតិយោ អន្តោ** សេចក្ដីថា ការប្រកបខ្ជួនឱ្យពាក់ព័ន្ធនៅក្នុងកាមសុខនេះ ចាត់ជាការត្រាំក្នុងកាមទាំងឡាយនេះចាត់ជាផ្លូវអមទី ២ ដោយន័យដូចពោលហើយ ។

បទថា **ឥច្ចេតេ ឧភោ អន្តា** បានដល់ ផ្លូវអម ២ យ៉ាងទាំងនេះ គឺកាមសុខល្ងិកានុយោគ ១ អត្តកិលមថានុយោគ ១ ។ ក៏បណ្ដាផ្លូវអម ២ យ៉ាងនោះឯង ឈ្មោះថា ផ្លូវអម គឺអន់ថយ ថោកទាប ព្រោះជាវត្ថុថោកទាប និងក្រៅផ្លូវជាហេតុញ៉ាំងបុគ្គលឱ្យជាប់ជំពាក់ក្នុងកាមគុណ ដែលពាសពេញដោយធូលី គឺកិលេស និងទុក្ខ ដែលខ្ជួនបានទទួលក្នុងបច្ចុប្បន្ន និងគប្បីបានទទួលក្នុងអនាគត និងជាប់នៅក្នុងការធ្វើខ្ជួនឱ្យក្ដៅក្រហាយ ឈ្មោះថា អ្នកកំណត់តាមសេចក្ដីក្ដៅផ្សាព្រោះកិលេស និងទុក្ខ និងព្រោះបដិបត្តិដើម្បីសេចក្ដីក្ដៅដោយ កិលេស និងទុក្ខដោយខ្ជួនឯង ។ បទថា **ឧជ្ជសិ ច ឱ្ឆ ជ** បានដល់ ធ្វើឱ្យចម្រើនទូវតណ្ហា និងអវិជ្ជា គឺកដសិ ព្រោះអត្ថថា អន្ធបុថុជ្ជនគប្បីសង្ឃឹមចំពោះ ។ បទថា **ឧជ្ជ-សិយោ ឥមិ ជ ឱ្ឆ ជ** សេចក្ដីថា ក៏តណ្ហា និងអវិជ្ជាដែលឈ្មោះថា **ឧជ្ជសិ**

ទាំងនោះធ្វើចម្រើនទូវទិដ្ឋិមានប្រការផ្សេងៗ ។ មែនពិត បុគ្គលមានសេចក្តីត្រេកអរក្នុងវត្ថុកាម បានតណ្ហា និងអវិជ្ជាដែលជាហេតុធ្វើរួមគ្នារបស់បុគ្គលដែលមិនអាចនឹងលះវត្ថុកាមនោះបាន ទើបឱ្យប្រកាន់ដល់នត្ថិកទិដ្ឋិ អកិរិយទិដ្ឋិ និងអហេតុកទិដ្ឋិ ដោយន័យមានជាអាទិ៍ថា ទានដែលបុគ្គលឱ្យហើយមិនមានផល ។ ក៏កាលដែលបានតណ្ហា និងអវិជ្ជាជាហេតុធ្វើរួមគ្នា របស់បុគ្គលដែលប្រកបរឿយៗ នឹងការធ្វើខ្លួនឱ្យក្តៅក្រហាយ រមែងប្រកាន់នូវសីលពត្ត និងការកាន់ខុស ដោយប្រាថ្នាសេចក្តីបរិសុទ្ធចំពោះខ្លួន ដោយន័យមានជាអាទិ៍ថា សេចក្តីបរិសុទ្ធ រមែងបានដោយសីល សេចក្តីបរិសុទ្ធរមែងបានដោយវត្តដូច្នេះ ។ ក៏ការ:នៃសក្កាយទិដ្ឋិ ជាបច្ច័យដល់អន្ធបុថុជ្ជនទាំងនោះ រមែងប្រាកដច្បាស់តែម្តង ។ គប្បីជ្រាបសេចក្តីដែលតណ្ហា និងអវិជ្ជាជាតួចម្រើនទិដ្ឋិ ព្រោះចូលទៅអាស្រ័យផ្លូវអម ២ យ៉ាង ដូចពោលមកនេះ ។ ក៏អាចារ្យពួកខ្លះពោលថា បទថា **ឧជ្ជសិ** នេះ ជាឈ្មោះរបស់បញ្ចក្ខន្ធ ។ អាចារ្យពួកខ្លះទាំងនោះមានសេចក្តីប្រាថ្នាថា សេចក្តីបរិសុទ្ធក្នុងសង្សារ រមែងមិនមានដោយផ្លូវអមទាំង ២ នោះ ក៏ផ្លូវអមទាំង ២ នោះ រមែងធ្វើឱ្យចម្រើនទូវឧបាទានខន្ធដោយចំណែកនោះ ។ តែអាចារ្យមួយពួកទៀតពោលអត្ថរបស់បទថា **ឧជ្ជសិ វឌ្ឍតា** ថា ជាទីចម្រើនព្រៃចោលសាកសព ដោយជរា និងមរណៈបន្តបន្ទាប់គ្នាមក ។ អាចារ្យទាំងនោះ ពោលចំពោះសេចក្តីមាន និងសេចក្តីមិនមាននៃផ្លូវអមទាំង ២ ថា ជាហេតុនៃសេចក្តីបរិសុទ្ធក្នុងសង្សារប៉ុណ្ណោះ ។ តែដល់ពោលតណ្ហានិងអវិជ្ជាដែលឈ្មោះថា **ឧជ្ជសិ** ជាការចម្រើនទិដ្ឋិ ។

បទថា **ឯតេ តេ ឧភោ អន្តេ អនភិញ្ញាយ** សេចក្តីថា អន្ធបុថុជ្ជនទាំងនោះ ព្រោះមិនដឹងផ្លូវអមទាំង ២ តាមដែលពោលហើយនេះ ព្រោះហេតុមិនដឹង គឺព្រោះការណ៍មិនដឹងយ៉ាងនេះថា ផ្លូវអមទាំងនេះ និងទាំងនោះ ដែលអន្ធបុថុជ្ជនប្រកាន់ហើយយ៉ាងនេះ តាំងមាំហើយយ៉ាងនេះ មានគតិយ៉ាងនេះ មានកពជាទីទៅក្នុងខាងមុខយ៉ាងនេះ ។ គប្បីជ្រាបអត្ថនៃបទនោះថា ប្រើក្នុងអត្ថនៃហេតុ ដូចក្នុងប្រយោគមានជាអាទិ៍ថា ក៏ព្រោះឃើញដោយបញ្ញាអាសវៈ ទើបអស់ទៅ ដូច្នេះ ។ បទថា **ឱលីយន្តិ ឯកេ** សេចក្តីថា បុគ្គលមួយពួកដល់សេចក្តីរួញចូល ដោយអំណាចការប្រកបខ្ជិនក្នុងសេចក្តីសុខក្នុងកាម ។ បទថា **អតិធាវន្តិ ឯកេ** សេចក្តីថា បុគ្គលខ្ះឈានកន្ទ្ធដោយអំណាចការប្រកបខ្ជិនឱ្យលំបាក ។ មែនពិត បុគ្គលដែលប្រកបកាមសុខ ឈ្មោះថា រមែងលិចចុះ ព្រោះដល់សេចក្តីរួញចូលពីសម្ទាបដិបត្តិដោយអំណាចសេចក្តីខ្ជិល-ច្រអូស ព្រោះមិនបានធ្វើសេចក្តីព្យាយាម ។ ចំណែកអ្នកប្រកបក្នុងការធ្វើខ្ជិនឱ្យក្តៅក្រហាយ កាលលះសេចក្តីខ្ជិលច្រអូស ធ្វើការប្រារព្ធសេចក្តីព្យាយាមដោយឧបាយខុស ឈ្មោះថា រមែងត្រាច់ទៅ ព្រោះកន្ទ្ធហួសសម្ទាបដិបត្តិ ។ ក៏បទទាំងពីរនោះ ឈ្មោះថា រមែងត្រាច់ទៅ ព្រោះមិនឃើញទោស ក្នុងផ្លូវអម ២ យ៉ាងនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រោះមិនដឹងផ្លូវអមទាំងពីរយ៉ាង បុគ្គលពួកខ្ះទើបលិចចុះ បុគ្គលពួកខ្ះទើបកន្ទ្ធទៅដូច្នេះ ។ ក្នុងពាក្យនោះគប្បីជ្រាបថា លិចដោយសេចក្តីភ្ងើតភ្ងើនក្នុងតណ្ហា ត្រាច់ទៅដោយសេចក្តីភ្ងើតភ្ងើនក្នុងទិដ្ឋិ ។

ម្យ៉ាងទៀត បុគ្គលខ្លះរមែងលិចចុះដោយអំណាចប្រកាន់សស្សតិទដ្ឋិ ខ្លះបុគ្គលរមែងត្រាច់ទៅដោយអំណាចប្រកាន់ឧច្ឆេទទិដ្ឋិ ។ មែនពិត បុគ្គលពួកខ្លះប្រកបដោយការធ្វើខ្លួនឱ្យក្តៅក្រហាយ ដោយអំណាចគោសីលជាដើម កាលប្រកាន់សស្សតទិដ្ឋិថា យើងនឹងជាទេវឬជាទេវតាអង្គណាមួយដោយសីលនេះ ដោយវត្តនេះ ដោយតប:នេះឬដោយព្រហ្មចរិយ:នេះ យើងនឹងជាអ្នកទៀង យឺនយូរ ពិតប្រាកដ មានសេចក្តីមិនប្រែប្រួលជាធម្មតា តាំងនៅជាបត:ស្មើដូចយ៉ាងនោះ ក្នុងទេវលោកនោះ ឈ្មោះថា លិចចុះក្នុងសង្សារ ។ ចំណែកបុគ្គលខ្លះប្រកបក្នុងកាមសុខ ប្រកាន់ឧច្ឆេទទិដ្ឋិ ដែលបណ្តាយតាមសស្សតទិដ្ឋិនោះ ដូចអ្នកប្រព្រឹត្តវត្តប្រាថ្នានឹងធ្វើវត្ថុណាមួយ ហើយធ្វើឥន្ទ្រិយឱ្យក្តៅផ្សា ឈ្មោះថា ត្រាច់ទៅ ព្រោះស្វែងរកការដាច់សូន្យនៃវដ្ត: ដោយរកឧបាយមិនបាន ។ គប្បីជ្រាបសេចក្តីលិចចុះ និងសេចក្តីត្រាច់ទៅ សូម្បីដោយអំណាចសស្សតិទិដ្ឋិ និងឧច្ឆេទទិដ្ឋិដោយអាការយ៉ាងនេះ ។

បទថា **យេ ច ខោ តេ អកិញ្ញាយ** សេចក្តីថា ក៏ព្រះអរិយបុគ្គលពួកណា ដឹងនូវផ្លូវអមទាំង ២ យ៉ាង តាមដែលពោលហើយនោះ ដោយញាណដ៏ពិសេស គឺដោយមគ្គបញ្ញា ដែលប្រកបដោយវិបស្សនាថា ផ្លូវអមទាំងនេះ ដែលបុថុជ្ជនប្រកាន់ហើយយ៉ាងនេះ តាំងមាំហើយយ៉ាងនេះ មានគតិយ៉ាងនេះ មានអភិសម្ពវយកពយ៉ាងនេះ បដិបត្តិដោយប្រពៃនូវមជ្ឈិមាបដិបទា ដោយសម្មាបដិបត្តិនោះ ។ បទថា **តត្រ ច ជាហេសុំ** បានដល់ មិនបានធ្លាក់ទៅក្នុងផ្លូវអមទាំង ២ នោះ អធិប្បាយថា លះផ្លូវអមទាំងពីរនោះ ។ បទថា **តេន ច ជាមញ្ញិសុ** សេចក្តីថា ក៏ព្រោះលះផ្លូវអមទាំង ២ យ៉ាងនោះ ព្រះអរិយបុគ្គល

មិនបានសម្គាល់ដោយសម្គាល់តណ្ហាទិដ្ឋិ និងមានៈដោយន័យមានជាអាទ៍ថា នេះជាការលះផ្លូវអមទាំង ២ របស់យើង យើងបានលះផ្លូវអមទាំង ២ យ៉ាងហើយ ព្រោះការលះផ្លូវអមនេះ ទើបចាត់ថាប្រសើរ ព្រោះលះសេចក្ដីសម្គាល់ទាំងពួង បានដោយប្រពៃតែម្ដង ។ ក៏ក្នុងទីនេះ ព្រោះសំដៅដល់ព្រះអរិយបុគ្គលដែលតាំងនៅក្នុងអរហត្តផល ទើបប្រកាសទេសនានេះដោយអំណាចអតីតកាលថា មិនបានធ្លាក់ទៅក្នុងផ្លូវអមទាំង ២ យ៉ាងនោះ និងមិនបានសម្គាល់ដោយការលះផ្លូវអមទាំង ២ យ៉ាងនោះ ។ ក៏កាលលោកប្រាថ្នាយកខណៈនៃមគ្គ ក៏ចាំត្រូវពោលទៅថ្វីដល់ដោយអំណាចបច្ចុប្បន្នកាលដូចគ្នា ។

បទថា **រដ្ឋំ តេសំ ឧត្តិ បញ្ញាបនាយ** *សេចក្ដីថា ជនពួកណា ជាឧត្ដមបុរស លះសេចក្ដីសម្គាល់ទាំងអស់ចេញបានដោយអាការយ៉ាងនេះ កាលលោកទាំងនោះបរិនិព្វានដោយអនុបាទិសេសនិព្វាន រដ្ឋៈសូម្បីទាំង ៣ គឺកម្មវដ្ដ វិបាកវដ្ដៈ និងកិលេសវដ្ដ រមែងមិនមានដោយបញ្ញត្ត ។ អធិប្បាយថា ក្រោយពីខន្ធដែលជាបច្ចុប្បន្នបែកធ្លាយទៅ ព្រះអរិយបុគ្គលទាំងនោះ ក៏ដល់ការៈកបញ្ញត្ត មិនបានតែម្ដង ដូចភ្លើងអស់គ្រឿងឆេះរលត់ទៅដូច្នោះ ។*

អដ្ឋមសុត្តវណ្ណា ជិដ្ឋតា

ចប់ អដ្ឋកថាសូត្រទី ៨

៩. ឧចាតិជាវន្តិសុត្តវណ្ណនា

អដ្ឋកថាឧចាតិជាតវន្តិសូត្រ

ឧបាតិជាវន្តិសូត្រទី ៩ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **រត្តន្ធការតិមិសាយំ** *បានដល់ សេចក្តីងងឹតអ័ព្ទ ដោយអាការ ងងឹតក្នុងរាត្រី ។ មែនពិត សូម្បីរាត្រីក្នុងយប់ថ្ងៃពេញបូណ៌មីស្វាងស្វែដោយ ពន្លឺចន្ទខាងខ្នើតបានឈ្មោះថា រៀរចាកភាពងងឹតអ័ព្ទ ។ សូម្បីភាពងងឹត ក៏មិន គួរនឹងពោលថា ងងឹតអ័ព្ទក្នុងវេលាថ្ងៃ ប្រាសចាកសេចក្តីសៅហ្មងដោយអ័ព្ទជា-ដើម ។ មែនពិត សេចក្តីងងឹតអ័ព្ទ លោកហៅថា* **តិមិសា** *។ ក៏សេចក្តីងងឹតនេះ គឺ ថ្ងៃអស្តង្គត ពេលយប់ ភ្ជៀងធ្លាក់ និងគ្របដណ្តប់ដោយស្រទាប់ពពក ។ ព្រោះ ហេតុនោះ លោកទើបពោលថា បទថា* **រត្តន្ធការតិមិសាយំ** *បានដល់ សេចក្តី ងងឹតអ័ព្ទ ដោយសេចក្តីងងឹតក្នុងរាត្រី ដូច្នេះ ។ បទថា* **អញ្ញោកាសេ** *បានដល់ ក្នុងឱកាសដែលមិនបិទបាំង បានដល់ ទីលានវិហារ ។ បទថា* **តេលប្ឌីបេសុ ឈាយមានេសុ** *បានដល់ កាលប្រទីបរុងរឿងដោយប្រេង ។*

សួរថា ក៏រស្មីប្រមាណមួយព្យាមរបស់ព្រះដ៏មានព្រះភាគ តាមប្រក្រតី ផ្សាយជ្រួតជ្រាបទៅរហូតដល់អស់ទីប្រមាណមួយព្យាម គ្របសង្កត់ពន្លឺព្រះចន្ទ និងព្រះអាទិត្យ បញ្ចេញពន្លឺក្ងីស្វាងរបស់ព្រះពុទ្ធដ៏ក្រាស់ កម្ចាត់ភាព-ងងឹតអ័ព្ទ សូម្បីរស្មីនៃព្រះរកាយក៏បញ្ចេញពុទ្ធរង្សីដ៏ក្រាស់ មានពណ៌ ៦ ប្រការ មាន ពណ៌ខៀវ និងលឿងជាដើម តាមប្រក្រតីតែម្តង ទាំងធ្វើទីមានប្រមាណ ៨០ ហត្ត

ដោយជុំវិញឱ្យក្ងីស្វាង កាលបើដូច្នោះ ក្នុងឱកាសដែលព្រះដ៏មានព្រះភាគ ប្រថាប់គង់ ទីមានពន្ធឺក្ងីស្វាងជាមួយគ្នា នឹងពន្ធឺក្ងីស្វាងរបស់ព្រះពុទ្ធនុ៎ះឯង មិនចាំបាច់មានកិច្ច គឺការដុសប្រទីបមិនមែនឬ ? ធ្វើយថា មិនមានក៏ពិត សូម្បីជាយ៉ាងនោះ ឧបាសកអ្នកត្រូវការបុណ្យ ក៏ត្រូវការដុសប្រទីបប្រេងជារាល់ថ្ងៃៗ ដើម្បីបូជាព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឆ ។ សមពិតដូចពាក្យដែលព្រះដ៏មាន-ព្រះភាគត្រាស់ទុកក្នុងសាមញ្ញផលសូត្រថា ប្រទីបទាំងនោះរមែងឆេះសន្ធោសន្ធៅ ក្នុងរោងមូល ដូច្នេះ ។ សូម្បីពាក្យថា **រត្តន្ធការតិមិសាយំ** នេះលោកពោលទុកដើម្បីបញ្ជាក់ដល់សេចក្ដីពិតរបស់រាត្រីនោះ តែមិនបានពោលក្នុងឱកាសដែលព្រះដ៏មានព្រះភាគប្រថាប់គង់ក្នុងទីងងឹតអ័ព្ទទេ ។ មែនពិត ដើម្បីនឹងធ្វើការបូជាប៉ុណ្ណោះ សូម្បីកាលនោះ ពួកឧបាសកក៏ដុសប្រទីបទុក ។

ក៏ក្នុងថ្ងៃនោះ ឧបាសក និងឧបាសិកាអ្នកក្រុងសាវត្ថីជាច្រើន ជម្រះរាងកាយពីព្រឹកព្រលឹម ទៅកាន់វិហារសមាទានអង្គឧបោសថ និមន្តភិក្ខុសង្ឆមានព្រះពុទ្ធជាប្រមុខ ចូលទៅកាន់នគរឱ្យមហាទានប្រព្រឹត្តទៅហើយ បញ្ជូនព្រះដ៏-មានព្រះភាគ និងបញ្ជូនភិក្ខុសង្ឆត្រឡប់ហើយ ទៅកាន់ផ្ទះរៀងៗខ្លួន បរិភោគដោយខ្លួនឯង ស្ងៀកដណ្ដប់សំពត់រៀបរយ មានសំពត់ពានាធ្វើងស្មាម្ខាង មានគ្រឿងក្រអូប និងផ្ការីជាដើមក្នុងដៃ នាំគ្នាទៅកាន់វិហារបូជាព្រះដ៏មាន-

ព្រះភាគ ឧបាសកពួកខ្លះចូលទៅរកភិក្ខុដែលខ្ជូនពេញចិត្ត និងរាប់អាន ឧបាសកពួកខ្លះជាក់ចិត្តដោយឧបាយនៃប្រាជ្ញានៅរហូតដល់អស់ថ្ងៃ ។ លុះល្ងាច ឧបាសកទាំងនោះក៏ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគ កាលព្រះសាស្តាប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេក្រាលទុកត្រង់កណ្តាលនៃព្រះគន្ធកុដិ តាំងពីមណ្ឌបនៃធម្មសភា និងកាលភិក្ខុសង្ឆចូលទៅគាល់អង្គុយជិតព្រះដ៏មានព្រះភាគ ហើយដើម្បីនឹងជម្រះឧបោសថឱ្យស្អាត និងដើម្បីនឹង-ពិនិត្យយោនិសោមនសិការ ទើបមិនត្រឡប់ទៅកាន់ព្រះនគរ ប្រាថ្នានឹងនៅក្នុងព្រះវិហារប៉ុណ្ណោះ ទើបនៅ ។ គ្រានោះ ឧបាសក និងឧបាសិកាទាំងនោះ ដុសប្រទីបប្រេងជាច្រើន ដើម្បីបូជាព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឆ ហើយចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំ ហើយផ្តង់អញ្ជលីចំពោះភិក្ខុសង្ឆ អង្គុយត្រង់ទីបំផុតភិក្ខុសង្ឆសន្ធនាគ្នាថា បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកតិរ្ថិយទាំងនេះពោលប្រកាន់ទិដ្ឋិផ្សេងៗ និងកាលពោលយ៉ាងនោះ ពេលខ្លះពោលថា ទៀង ពេលខ្លះពោលថា មិនទៀង មិនតាំងនៅក្នុងទិដ្ឋិយ៉ាងណាមួយ មានឧច្ឆេទទិដ្ឋិជាដើម ដូចជាមនុស្សឆ្ពួតលើកតម្កើងទិដ្ឋិថ្មីៗថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទទេ តិរ្ថិយទាំងនោះ អ្នកប្រកាន់យ៉ាងនោះ មានគតិជាយ៉ាងណា អភិសម្ភវយកពរបស់ពួកគេជាយ៉ាងណា ។ ក៏សម័យនោះ មេភ្ជៀងជាច្រើន កាលធ្លាក់ចុះ ក៏ធ្លាក់ចុះត្រង់ប្រទីប

ប្រេងទាំងនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ក៏សម័យនោះឯង មេភ្ជៀងជាច្រើនធ្លាក់ចុះ ។

បណ្តាបទទាំងនោះ បទថា **អជិចាតកា** ប្រែថា មេភ្ជៀង ដែលលោកពោលថា **សលកា** ដូច្នេះក៏មាន ។ មែនពិត មេភ្ជៀងទាំងនោះ លោកប្រាថ្នាយកថា **អជិចាតកា** ព្រោះធ្លាក់ចុះកាន់អណ្តាតប្រទីប ។ បទថា **អាចាតបរិ-ចាតំ** ចែកជា **អាចាតំ បរិចាតំ** អធិប្បាយថា ធ្លាក់ចុះទូទៅ។ ធ្លាក់ចុះជុំវិញ។ គឺវិលធ្លាក់ចុះត្រង់មុខនោះឯង ហើយធ្លាក់ចុះ ។ អាចារ្យពួកខ្លះពោលថា ធ្លាក់ចុះជុំវិញ។ ត្រង់ផ្លូវទៅមក ។ អធិប្បាយថា ត្រង់ផ្លូវដែលមក កាលមានប្រទីបផ្លូវមករបស់ខ្លួន ក៏ធ្លាក់ចុះ។ ។ បទថា **អនយំ** ប្រែថា សេចក្តីមិនចម្រើន គឺសេចក្តីទុក្ខ ។ បទថា **ព្យសនំ** ប្រែថា សេចក្តីវិនាស ។ មែនពិត ដោយបទដើម លោកសម្តែងដល់មរណទុក្ខ ដោយបទក្រោយ លោកសម្តែងដល់សេចក្តីស្លាប់របស់មេភ្ជៀងទាំងនោះ ។ បណ្តាមេភ្ជៀងទាំងនោះ សត្វពួកខ្លះស្លាប់ព្រមនឹងការធ្លាក់ចុះ ពួកខ្លះក៏ដល់មរណទុក្ខ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបដល់ការដែលមេភ្ជៀងទាំងឡាយ មិនដឹងប្រយោជន៍ខ្លួនដល់សេចក្តីខ្ល់ខ្វាយក្នុងវត្ថុគ្មានប្រយោជន៍ ដោយសេចក្តីព្យាយាមរបស់ខ្លួននេះ ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់សេចក្តី

ខ្ជល់ខ្ជាយរបស់ទិដ្ឋិគតិកបុគ្គល ដោយការកាន់ខុសដូចមេក្ងៀងទាំងនោះ ។

បណ្តាបទទាំងនោះ បទថា **ឧចាតិធាវន្តិ ន សារមេន្តិ** សេចក្តីថា មិនដល់ធម៌ដែលជាសារៈ ផ្សេងដោយសីល សមាធិ បញ្ញា និងវិមុត្តិជាដើម គឺមិនត្រាស់ដឹងសច្ចៈ ៤ ។ តែកាលធម៌ដែលជាសារៈព្រមទាំងឧបាយនោះ តាំងនៅហើយនុ៎ះឯង ពួកគេដូចជាចូលដល់ធម៌ដែលជាសារៈនោះ ព្រោះប្រាថ្នាធម៌ជាគ្រឿងរួចផុតរមែងត្រាច់ទៅកន្ទ្ងទៅគឺដំណើរទៅដោយទិដ្ឋិវិបល្ងាស អធិប្បាយថា ប្រកាន់មាំក្នុងឧបាទានក្ខន្ធ ៥ ថា ទៀង ល្អ សុខ មានតួខ្ជួន ។ បទថា **ឆវំ ឆវំ ពន្ធនំ ត្រូហយន្តិ** សេចក្តីថា ក៏កាលប្រកាន់យ៉ាងនោះឈ្មោះថា រមែងកពូនគឹចម្រើនន្ទូវចំណងថ្មីៗ ពោលគឺ តណ្ហា និងទិដ្ឋិ ។ បទថា **បតន្តិ បជ្ជោតមិវ-ជិចាកា ជិជ្ជ សុតេ ឥតិហេកេ ជិវិជ្ជា** សេចក្តីថា សមណព្រាហ្មណ៍ពួកមួយ ព្រោះត្រូវចងដោយចំណង គឺតណ្ហា និងទិដ្ឋិចងទុកយ៉ាងនេះ ទើបប្រកាន់ក្នុងរូបារម្មណ៍ដែលខ្ជួនឃើញ គឺក្នុងរូបារម្មណ៍ដែលខ្ជួនឃើញ ដោយចក្ខុវិញ្ញាណរបស់ខ្ជួន ឬដោយទិដ្ឋិទស្សនៈរបស់ខ្ជួននុ៎ះឯង និងក្នុងសទ្ទារម្មណ៍ដែលខ្ជួនបានឮមក ដោយហេតុត្រឹមតែបានឮ បានស្តាប់មកប៉ុណ្ណោះថា ព្រោះហេតុនោះឯង វត្ថុនេះ រមែងជាយ៉ាងនេះដោយពិតប្រាកដ ប្រកាន់ដោយន័យមានជាអាទ៍ថា វត្ថុទាំងពួងទៀង ដោយការប្រកាន់ខុសៗ ឬកាលមិនដឹងធម៌ជាហេតុរលាស់ចេញដែលជាប្រយោជន៍ដោយចំណែកមួយ រមែងធ្ងាក់ទៅក្នុង

រណ្តាវរើកក្ងើងបន្ទោបង់តែមួយ ពោលគឺ ភព ៣ ដែលក្ងើង ១១ កង មានពាគ:ជាដើម ឆេះសន្ធោសន្ធៅឡើងហើយ ដូចមេក្ងៀងទាំងនេះធ្លាក់ទៅកាន់អណ្តាតក្ងើងដូច្នោះ អធិប្បាយថា គេមិនអាចនឹងដើយក្បាលឡើងបានពីរណ្តាវរើកក្ងើងនោះ ។

ជរមសុត្តវណ្ណា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៩

១០. ឧប្បជ្ជន្តិសុត្តវណ្ណនា

អដ្ឋកថាឧប្បជ្ជន្តិសូត្រ

ឧប្បជ្ជន្តិសូត្រទី ១០ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **យាវកីរំ** *ប្រែថា រហូតអស់កាលត្រឹមណា ។ បទថា* **យតោ** *សេចក្តីថា ក្នុងកាលណា គឺតាំងពីវេលាណា ឬថាក្នុងកាលណា ។ ដោយបទថា* **ឯវមេតំ អានន្ទ** *ព្រះអង្គទ្រង់សម្តែងថា ម្នាលអានន្ទ សេចក្តីដែលអ្នកពោលថា កាលតថាគតឧប្បត្តិឡើង លាភ និងសក្ការៈ រមែងចម្រើនក្រៃលែងដល់តថាគត និងដល់សាវកបស់តថាគតប៉ុណ្ណោះ ចំណែកពួកតិរ្ថិយ ជាអ្នកគ្មានតេជៈ អស់រស្មី សាបសូន្យលាភ និងសក្ការៈនោះ រមែងជាយ៉ាងនោះ ប្រការនោះមិនជាយ៉ាងដទៃទេ ។ មែនពិត កាលចក្ករតនៈរបស់ស្តេចចក្រពត្តិប្រាកដ សត្វលោកលះចក្ករតនៈ មិនធ្វើការបូជាសក្ការៈ និងសម្មានៈ ឱ្យប្រព្រឹត្តទៅក្នុងទីដទៃ តែសត្វលោកទាំងមូលសុទ្ធតែធ្វើសក្ការៈ គោរព រាប់អាន បូជាចក្ករតនៈប៉ុណ្ណោះ ដោយការៈទាំងពួង ។ ព្រោះដូច្នោះ សូម្បីវិបាកជាគ្រឿងហូរចេញត្រឹមតែជាបុណ្យដែលជ្រួតជ្រាបទៅតាមវដ្តៈ ក៏នៅមានអានុភាពច្រើនដល់ត្រឹមនោះ មិនចាំបាច់ពោលទៅថ្វីពុទ្ធរតនៈ ធម្មរតនៈ សង្ឆរតនៈ ដែលទ្រទ្រង់ទុកនូវគុណរកទីបំផុតមិនបាន ប្រមាណមិនកើត ដែលជាគ្រឿងឧបត្ថម្ភក៏កម្ចាំងនៃបុណ្យដែលមានផលឱ្យទៅដល់ព្រះនិព្វាន ។*

មែនពិត ព្រះដ៏មានព្រះភាគ កាលទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណ ហើយទ្រង់ប្រកាសព្រះធម្មចក្រដ៏ប្រសើរឱ្យប្រព្រឹត្តទៅ កាលព្រះអរហន្ត ៦១ អង្គ កើតឡើងក្នុងលោកតាមលំដាប់ ទើបទ្រង់បញ្ជូនព្រះអរហន្ត ៦០ អង្គ ដើម្បីចារិកទៅតាមជនបទ ព្រះអង្គស្តេចទៅកាន់ឧរុវេលាប្រទេស ញ៉ាំងជដិល ១.០០០ នាក់ មានឧរុវេលកស្សបៈជាប្រធាន តាំងនៅក្នុងព្រះអរហត្ត ហៃហមទៅដោយព្រះអរហន្តទាំងនោះ ប្រថាប់នៅក្នុងឧទ្យានត្នោត ធ្វើជនអ្នកអង្គៈ និងមគធៈ ដែលមានព្រះបាទពិម្ពិសារជាប្រធាន ប្រមាណជា ១២០.០០០ នាក់ ឱ្យចុះកាន់ព្រះសាសនាក្នុងគ្រាដែលព្រះអង្គប្រថាប់នៅក្នុងក្រុងរាជគ្រឹះ ។ ចាប់ផ្តើមតាំងពីនោះ លាភ និងសក្ការៈរបស់តិរ្ថិយគ្រប់ពួក រមែងសាបសូន្យចុះតែម្តង ក្នុងខណៈដែលលាភ និងសក្ការៈចម្រើនក្រៃលែងៗ ឡើងទៅដល់ព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឆ ។ ក្នុងថ្ងៃមួយជាខាងក្រោយមក ព្រះអានន្ទត្ថេរដ៏មានអាយុ គង់សម្រាកក្នុងទីសម្រាកវេលាថ្ងៃ ពិចារណាដល់សម្មាបដិបត្តិរបស់ព្រះដ៏មានព្រះភាគ និងព្រះអរិយសង្ឆ កើតបីតិ និងសោមនស្ស ទើបរំពឹងដល់វត្តបដិបត្តិរបស់តិរ្ថិយទាំងនោះថា ការបដិបត្តិរបស់ពួកតិរ្ថិយជាយ៉ាងណាហ្ន៎ ។ លំដាប់នោះ ការបដិបត្តិអាក្រក់សូម្បីដោយប្រការទាំងពួង របស់ពួកតិរ្ថិយទាំងនោះ ប្រាកដហើយដល់ព្រះអានន្ទ ។ ព្រះអានន្ទត្ថេរដ៏មានអាយុគិតថា កាលព្រះដ៏មាន-

ព្រះភាគ ឈ្មោះថា មានអានុភាពច្រើនដល់យ៉ាងនេះ អ្នកសម្រេចបារមីយ៉ាងឧត្រិដ្ឋនៃឧបនិស្សយរបស់បុណ្យ និងធម្មានុធម្មប្បដិបត្តិ និងកាលព្រះអរិយ-សង្ឆកាលតាំងនៅ អន្យតិ្ថយទាំងនេះ ទើបបដិបត្តិអាក្រក់យ៉ាងនេះ មិនជ្ងាប់ធ្វើបុណ្យ ដូចជាមនុស្សកំព្រា តើនឹងមានលាភ មានគេធ្វើសក្ការៈយ៉ាង ណា ទើបកើតសេចក្តីក�ណាក្នុងការសាបសូន្យលាភ និងសក្ការៈរបស់ពួកតិ្ថយទាំងនោះឡើង ទើបបានក្រាបទូលការបរិវិតក្ក:របស់ខ្លួនដល់ព្រះដ៏មានព្រះភាគ ដោយន័យមានជាអាទិ៍ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតថាគតអរហន្តសម្ម-សម្ពុទ្ធ មិនទាន់ស្តេចឧប្បត្តិឡើងក្នុងលោកត្រឹមណា ។ ក៏ព្រះដ៏មានព្រះភាគ មិនបានត្រាស់នឹងថេរៈថា ម្នាលអានន្ទ អ្នកមានការបរិវិតក្ក:ខុសទៅហើយ ដូច្នេះ ហើយទើបតាំងព្រះសូរង (ក) ឡើងឱ្យត្រង់ ដូចនឹងស្ពរមាស ទ្រង់ធ្វើព្រះកត្ត្រឱ្យ ផ្ទៃតស្ងប់ស្ងុ ស្រស់បស់ដូចផ្ការីកស្ពុះស្ពាយ គួរឱ្យជ្រះថ្លាយ៉ាងក្រៃលែង ទ្រង់រីករាយថា ម្នាលអានន្ទ ប្រការនោះជាយ៉ាងនោះហើយ ទ្រង់ផ្តល់តាមពាក្ យរបស់ព្រះអានន្ទ ដោយន័យមានជាអាទិ៍ថា **យាវតីវញ្ច** ដូច្នេះ ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រានោះឯងព្រះអានន្ទដ៏មានអាយុ ។ល។ និងព្រះភិក្ខុសង្ឆ ដូច្នេះជាដើម ។

ដើម្បីត្រាស់នូវពាក្យនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់បាវេរុជាតកថា សូម្បីក្នុងអតីតកាល តថាគតមិនទាន់ឧប្បត្តិឡើង ជនជំនាន់ក្រោមពួកខ្ញុ: មាន

ការរាប់អានជាច្រើន តាំងពីតថាគតឧប្បត្តិហើយ អន្យតិរ្ថិយទាំងនោះក៏បានជាអ្នកសាបសូន្យលាភ និងសក្ការ: ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថនេះថា ទិដ្ឋិគតិកបុគ្គលមានសក្ការ: និងសម្មាន: រហូតដល់អស់វេលាដែលព្រះសម្មាសម្ពុទ្ធមិនទាន់ស្តេចឧប្បត្តិឡើងក្នុងលោក រាប់តាំងពីវេលាដែលព្រះសម្មាសម្ពុទ្ធទាំងនោះឧប្បត្តិហើយ ពួកគេទាំងនោះក៏សាបសូន្យលាភសក្ការ: អស់រស្មី គ្មានតេជ: និងពួកគេមិនផុតពីទុក្ខទៅបាន ព្រោះការបដិបត្តិអាក្រក់ទើបទ្រង់បន្ទឺឧទានេះ ដែលសម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **ឱកាសតិ តាវ សោ ភិក្ខូ** សេចក្តីថា អំពិលអំពែកនោះញ៉ាំងពន្ធឺឱ្យក្ងី គឺឱ្យរុងរោចន៍ពន្ធឺនៅត្រឹមនោះនុ៎ះឯង ។ បទថា **យាវ ន ឧណ្ហេ ឧ ឧ ណ្ហ ម ត ិ ប ភ ង្ក ោ** សេចក្តីថា ព្រះអាទិត្យដែលមានឈ្មោះថា **ប ភ ង្ក រ** ព្រោះធ្វើឱ្យមានពន្ធឺក្ងីស្ងាត់ក្នុងខណ:តែមួយគ្នា ក្នុងមហាទ្វីបទាំង ៤ មិនទាន់ក្ងី គឺមិនទាន់ចែងចាំងដរាបណា ។ មែនពិត កាលព្រះអាទិត្យមិនទាន់រះ ពួកអំពិលអំពែកក៏បានឱកាសផ្ទាស់ពន្ធឺ ដូចនឹងផ្ទៃឈើមានបន្ទា រមែងបញ្ជូនពន្ធឺក្នុងទីងងឹត ។ កន្ទ:គាថាថា **ស វេ ភ ោ ច ន ម្ហ ិ ឧ ក្ក ត េ ហ ាត ប្ប ភ ោ ហ ោ ត ិ ន ច ាប ិ ភ ាស ត ិ** សេចក្តីថា កាលព្រះអាទិត្យ ដែលមានឈ្មោះថា

វេយ្យាករណ: ព្រោះមានសការ:បំភ្លឺពន្ធឺ ដោយរស្មីផ្សាយចេញពាន់ដួង កម្ចាត់ភាពងងឹតដោយជុំវិញរះឡើងហើយ អំពិលអំពែកក៏អស់រស្មី គ្មានតេជះ ជាពណ៌ខ្មៅ មិនមានពន្ធឺ មិនភ្លឺស្វាង មិនសូរ្យគ្រាស ដូចភាពងងឹតក្នុងរាត្រី ។

បទថា **ឯវំ ឱភាសិតមេវ តិត្ថិយានំ** សេចក្ដីថា អំពិលអំពែកនោះ មុនអំពីព្រះអាទិត្យរះ រមែងបំភ្លឺពន្ធឺយ៉ាងណា ពួកតិរ្ថិយដែលបាននាមថា **តក្ខិកា** ព្រោះប្រកាន់ទិដ្ឋិ ដោយហេតុត្រឹមតែត្រិះរិះកំណត់បំភ្លឺ គឺតាំងបំភ្លឺពន្ធឺ ដោយតេជះនៃលទ្ធិរបស់ខ្លួន ដរាបដែលព្រះសម្មាសម្ពុទ្ធ មិនទាន់ស្ដេចឧប្បត្តិឡើងក្នុងលោក ។ បទថា **ន តក្ខិកា សុជ្ជន្តិ ន ចាបិ សាវកា** សេចក្ដីថា ក៏ក្នុងគ្រាដែលព្រះសម្មាសម្ពុទ្ធ ស្ដេចឧប្បត្តិឡើងក្នុងលោក ទិដ្ឋិគតិកបុគ្គលរមែងមិនបរិសុទ្ធ រមែងមិនល្អ ទាំងសាវករបស់ទិដ្ឋិគតិកបុគ្គលទាំងនោះ ក៏មិនល្អ ទោះជាយ៉ាងនោះ ក៏ត្រូវកម្ចាត់រស្មី មិនប្រាកដដូចកូនសរដែលបាញ់ទៅក្នុងរាត្រី ។ ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធ មិនទាន់ស្ដេចឧប្បត្តិឡើងក្នុងលោកត្រឹមណា ពួកតិរ្ថិយក៏ញ៉ាំងពន្ធឺរុងរឿងតាមលទ្ធិរបស់ខ្លួន ក្រោយពីនោះក៏មិនមានពន្ធឺ ។ ព្រោះហេតុអ្វី? ព្រោះហេតុដែលពួកតិរ្ថិយមិនបរិសុទ្ធ ទាំងសាវករបស់គេក៏មិនបរិសុទ្ធ ។ ព្រោះពួកតិរ្ថិយទាំងនោះ ពោលធម្មវិន័យទុកមិនល្អ គ្មានការបដិបត្តិប្រពៃ រមែងមិនបរិសុទ្ធពីសង្សារទៅបាន ព្រោះពាក្យទូន្មានមិនជាគ្រឿងនាំសត្វចេញចាកទុក្ខ ។ ព្រោះហេតុនោះ ទើបត្រាស់ថា អ្នកមានទិដ្ឋិអាក្រក់

រមែងមិនរួចចាកទុក្ខ ដូច្នេះជាដើម ។ មែនពិត ពួកតិរ្ថិយទាំងឡាយ ឈ្មោះថា អ្នកមានទិដ្ឋិអាក្រក់ គឺមានទិដ្ឋិដែលប្រកាន់ទុកខុស បានដល់ មានការឃើញខុស ព្រោះមិនមានលទ្ធិតាមសេចក្តីពិត មិនលះបង់ទិដ្ឋិនោះហើយ សូម្បីក្នុងកាលណាៗ ក៏មិនរួចចាកពីទុក្ខក្នុងសង្សារបានឡើយ ។

ឧសមសុត្តវណ្ណា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១០

និដ្ឋិតា ច ជចុន្ធវគ្គវណ្ណា ។

ចប់ជចុន្ធវគ្គវណ្ណនាទី ៦

រួមព្រះសូត្រដែលមានក្នុងវគ្គនេះ គឺ

១-អាយុសមឱ្យជ្ជនសូត្រ	២-បដិសល្ងានសូត្រ
៣- អាហុសូត្រ	៤- បឋមនានាតិត្ថិយសូត្រ
៥- ទុតិយនានាតិត្ថិយសូត្រ	៦- តតិយនានាតិត្ថិយសូត្រ
៧- សុភូតិសុត្រ	៨- គណិកាសូត្រ
៩- ឧបាតិសូត្រ	១០- ឧប្ជជ្ជន្តិសូត្រ ។

៧. ចូឡវគ្គោ

ចូឡវគ្គទី ៧

១. បឋមលកុណ្ឌកកដ្ឋិយសុត្តវណ្ណនា

អដ្ឋកថាបឋមលកុណ្ឌកភទ្ទិយសូត្រ

បឋមលកុណ្ឌកកទ្ទិយសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **ភទ្ទិយោ** *ក្នុងពាក្យថា* **លកុណ្ឌកភទ្ទិយំ** *នេះជាឈ្មោះរបស់ព្រះថេរៈដ៏មានអាយុអង្គនោះ ។ ក៏ព្រោះព្រះថេរៈមានរូបរាងតឿ គេទើបស្គាល់ព្រះថេរៈថា* ***លកុណ្ឌកភទ្ទិយៈ*** *។ មានសេចក្ដីដំណាលមកថា ព្រះថេរៈជាកុលបុត្រអ្នកក្រុងសាវត្ថី មានទ្រព្យច្រើន មានភោគៈច្រើន តែមានរូបរាងមិនគួរជ្រះថ្លា មានសម្បុរមិនស្អាត មិនគួរមើល មានខ្នងគម ។ ថ្ងៃមួយ កាលព្រះសាស្ដាប្រថាប់នៅក្នុងវត្តជេតពន ភទ្ទិយៈព្រមដោយឧបាសកទៅកាន់វិហារដើម្បីស្ដាប់ធម្មទេសនា ដល់ព្រមដោយសទ្ធា បានបព្វជ្ជាឧបសម្បទា ហើយរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដា ធ្វើវិបស្សនាសម្រេចសោតាបត្តិផល ។ ក្នុងកាលនោះ ពួកភិក្ខុជាសេក្ខបុគ្គល ជាច្រើនចូលទៅរកព្រះសារីបុត្រដ៏មានអាយុ សូមកម្មដ្ឋាន សូមស្ដាប់ធម្មទេសនា សួរបញ្ហាដើម្បីមគ្គខាងលើ ។ ព្រះសារីបុត្រកាលនឹងធ្វើសេចក្ដីប្រាថ្នារបស់លោកទាំងនោះឱ្យបរិបូណ៌ ទើបប្រាប់កម្មដ្ឋាន សម្ដែងធម៌ដោះស្រាយបញ្ហា ។ ភិក្ខុទាំងនោះព្យាយាមប្រឹងប្រែង ភិក្ខុពួកខ្លះសម្រេចសកទាគামិផល ភិក្ខុពួកខ្លះសម្រេចអនាគামិផល ភិក្ខុពួកខ្លះសម្រេចអរហត្តផល*

ភិក្ខុពួកខ្លះបានវិជ្ជា ៣ ភិក្ខុពួកខ្លះបានអភិញ្ញា៦ ភិក្ខុពួកខ្លះបានបដិសម្ភិទា ៤ ។ ចំណែកលក្ខណ្ឌកកទ្វិយ: ឃើញហេតុនោះហើយ ដល់ភាពជាព្រះសេក្ខបុគ្គល ក៏ស្គាល់កាល និងកំណត់សេចក្ដីដែលខ្ជួនខ្ជះខាតក្នុងផ្លូវចិត្ត ចូលទៅរកព្រះធម្ម-សេនាបតី បានទទួលការបដិសណ្ឋារ: ១ប់អាន ហើយសូមឱ្យសម្ដែងធម្មទេសនា ។ ចំណែកព្រះធម្មសេនាបតី ក៏បានសម្ដែងធម៌ដែលសមរម្យដល់អធ្យាស្ស័យរបស់ព្រះថេរ: ។ ព្រោះហេតុនោះ លោកទើបពោល ថាសម័យនោះឯង ព្រះសារីបុត្ត-ដ៏មានអាយុ បានពន្យល់ព្រះលក្ខណ្ឌកកទ្វិយ:ដ៏មានអាយុ ដោយធម្មីកថាច្រើនប្រការជាដើម ។

បណ្ដាបទទាំងនោះ បទថា **អនេកបរិយាយេន** សេចក្ដីថា ដោយហេតុច្រើនសន្ធឹកសន្ធាប់យ៉ាងនេះថា សូម្បីព្រោះហេតុនេះ បញ្ចខន្ធទើបជារបស់មិនទៀង សូម្បីព្រោះហេតុនេះ បញ្ចខន្ធទើបជាទុក្ខ សូម្បីព្រោះហេតុនេះ បញ្ចខន្ធទើបជាអនត្តា ។ បទថា **ធម្មិយា កថាយ** បានដល់ ដោយធម្មីកថាដែលប្រកាសការកើត និងរលត់ទៅជាដើម នៃឧបាទានខន្ធ ៥ ។ បទថា **សន្ធ-ស្សេតិ** បានដល់ សម្ដែងដោយប្រពៃនូវលក្ខណ: មានអនិច្ចលក្ខណ: ជាដើមទាំងនោះនុ៎ះឯង និងញាណមានឧទយព្ពយញ្ញាណជាដើម គឺសម្ដែងឱ្យជាក់-ច្បាស់ ដូចយកដៃចាប់ ។ បទថា **សមាធេតិ** សេចក្ដីថា ឱ្យកាន់យកដោយ

ប្រពៃនូវវិបស្សនា ដែលមានលក្ខណៈជាអារម្មណ៍ ក្នុងលក្ខណៈទាំងនោះ គឺឱ្យកាន់យកនូវប្រការដែលចិត្តប្រព្រឹត្តទៅតាមវិថី ។ បទថា **សមុត្តេជេតិ** សេចក្តីថា កាលផ្តើមវិបស្សនា កាលឧទយព្វយញ្ញាណជាដើមនៃសង្ខារឱ្យប្រាកដ ព្រះថេរៈរមែងញ៉ាំងវិបស្សនាឱ្យធ្លាក់ចុះកាន់វិថីកណ្តាល ដោយឱ្យប្រព្រឹត្តតាមពោជ្ឌង្គៈ ដោយការកាន់យក ការគ្របសង្កត់ និងការពិចារណា តាមវេលា ហើយញ៉ាំងវិបស្សនាញាណដែលក្ងៀវក្ងា ដែលផ្ទេរផង់ឱ្យកើត ដោយការធ្វើវិបស្សនាចិត្តឱ្យប្រពៃ ព្រោះធ្វើឥន្ទ្រិយឱ្យហ្មត់ចត់ ដូចវិបស្សនាញាណ នាំមកនូវធម្មជាតិខ្ជាំងក្ងាជ្ងាផ្ទេរផង់ដូច្នោះ ។ បទថា **សម្ប្ឌាំសេតិ** សេចក្តីថា រមែងញ៉ាំងចិត្តឱ្យរីករាយដោយប្រពៃ ឬឱ្យត្រេកអរដោយល្អ ដោយសេចក្តីត្រេកអរដែលបានមកដោយការចម្រើនវិបស្សនា ឱ្យប្រព្រឹត្តទៅយ៉ាងនោះ គឺប្រព្រឹត្តទៅដោយស្មើនឹងដោយកម្ទាំងនៃភាវនា ដែលនឹងគប្ប៊ីបានគុណធម៌ខាងលើទៀត ។ បទថា **អនុចាបាយ អាសវេហិ ចិត្តំ វិមុច្ចិ** សេចក្តីថា កាលព្រះថេរៈពិចារណាលក្ខណៈយ៉ាងនោះពិត ញ៉ាំងញាណឱ្យប្រព្រឹត្តទៅតាមក្រសៃទេសនា ព្រោះព្រះថេរៈដល់ភាពចាស់ក្ងានៃញាណ តាមអានុភាពទេសនារបស់ព្រះធម្មសេនាបតី និងព្រោះព្រះថេរៈបរិបូណ៌ដោយឧបនិស្សយ ដោយប្រការដែលព្រះធម្មសេនា-បតីសម្តែងធម៌ ចិត្តរបស់ព្រះថេរៈមិនតោងអាសវៈណាមួយ មានកាមាសវៈជាដើម

ចិត្តក៏ផុតស្រឡះមិនឱ្យសេសសល់តាមលំដាប់នៃមគ្គ អធិប្បាយថា ធ្វើឱ្យច្បាស់នូវអរហត្តផល ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំង-ពួងនូវអត្ថនេះ ពោលគឺ ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ត្រេកអរក្នុងព្រះអរហត្តផល ទើបបន្ទឹឧទាននេះ ដែលសម្តែងដល់សេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **ឧដ្ឋំ** បានដល់ រូបធាតុ និងអរូបធាតុ ។ បទថា **អធោ** បានដល់ កាមធាតុ ។ បទថា **សព្វញ្ចិ** បានដល់ ក្នុងសង្ខារទាំងអស់ ។ បទថា **វិប្ឆមុត្តោ** បានដល់ រួចផុតដោយប្រការទាំងពួង ដោយវិក្ខម្ភនវិមុត្តិ ចំណែកខាងដើម និងដោយសមុច្ឆេទវិមុត្តិ និងបដិបស្សទ្ធិវិមុត្តិ ចំណែកខាងចុង ។ ក៏ក្នុងបទទាំងនោះ ដោយបទថា **ឧដ្ឋំ វិប្ឆមុត្តោ** នេះ ទ្រង់សម្តែងដល់ការលះសញ្ញោជនៈ ដែលជាចំណែកខាងខ្ពស់ ៥ ។ ដោយបទថា **អធោ វិប្ឆមុត្តោ** នេះ ទ្រង់សម្តែងដល់ការលះសញ្ញោជនៈដែលជា ចំណែកខាងក្រោម ៥ ។ ដោយពាក្យថា **សព្វញ្ចិ វិប្ឆមុត្តោ** នេះ ទ្រង់សម្តែង ដល់ការលះអកុសលទាំងពួងដែលនៅសល់ ។ ម្យ៉ាងទៀត បទថា **ឧដ្ឋំ** សព្ទនេះជាការកាន់យកអនាគតកាល ។ បទថា **អធោ** សព្ទនេះជាការកាន់យកអតីតកាល ។ បទថា **អជ្ឌា** សព្ទនេះជាការកាន់យកបច្ចុប្បន្នកាល ព្រោះជាប់ទាក់ទង នឹងចន្ទោះ អតីតកាល នឹងអនា-

គតកាល ។ បណ្ដាស័ព្ទ ២ យ៉ាងនោះ ដោយអនាគតកាល ស័ព្ទជាការកាន់យកខន្ធ អាយតនៈ ធាតុ ដែលជាអនាគត ។ សូម្បីក្នុងបទដែលនៅសល់ ក៏នយនេះដូចគ្នា ។ បទថា **សព្ពិ** បានដល់ ក្នុងភពទាំងពួង មានកាមភពជាដើម ។ មានពាក្យអធិប្បាយដូចតទៅនេះថា រួចផុតហើយក្នុងភពទាំងពួង ដែលសង្គ្រោះដោយ ៣ កាល យ៉ាងនេះ គឺអនាគតកាល អតីតកាល និងបច្ចុប្បន្នកាល ។ បទថា **អយមហមស្មីតិ អនាឧបស្សិ** សេចក្ដីថា អ្នកណា រួចផុតយ៉ាងនេះ អ្នកនោះ រមែងមិនឃើញយ៉ាងនេះក្នុងរូប វេទនាជាដើម យ៉ាងនេះ ដោយការសម្គាល់ដោយអំណាចទិដ្ឋិ និងមានៈថា ធម៌នេះជាយើង អធិប្បាយថា អ្នកនោះ មិនមានហេតុក្នុងទស្សនៈដូច្នោះ ។ ម្យ៉ាងទៀត បទថា **អយមហមស្មីតិ អនា-ឧបស្សិ** នេះ ជាបទសម្ដែងឧបាយជាគ្រឿងសម្រេចវិមុត្តិតាមដែលពោលហើយ ។ វិបស្សនាដែលជាវុដ្ឋានគាមិនិជាចំណែកខាងដើម ដែលធ្វើសេចក្ដីមិនតាំងមាំ ដោយសេចក្ដីសម្គាល់ ដែលមានសការៈ ដែលប្រព្រឹត្តទៅក្នុងសង្ខារ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលសង្គ្រោះដោយកាល ៣ ថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ហើយឱ្យកើតឡើងយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ដូច្នេះ វិបស្សនានោះ ជាបទដ្ឋានរបស់វិមុត្តិ ។ បទថា **ឝ្ឋវ្ហិ មុត្តោ ឧឧតារ ឱឃំ អតិណ្ណបុព្ពំ** អបុនព្ភវាយ សេចក្ដីថា ព្រះអរហន្តអ្នករួចផុតហើយ ដោយប្រការទាំងពួងពីសញ្ញោជនៈ ១០

និងពីអកុសលទាំងពួងដោយប្រការដូច្នេះ ឈ្មោះថា ជាអ្នកធ្វេងឱ្យ: ៤ យ៉ាងនេះ គឺឱ្យ: គឺកាម ១ ឱ្យ: គឺកព ១ ឱ្យ: គឺទិដ្ឋិ ១ ឱ្យ: គឺអវិជ្ជា ១ ដែលខ្លួនមិនទាន់ជ្ងាប់ធ្ងេ សូម្បីក្នុងទីបំផុតនៃសេចក្ដីយល់សប្ដិ ក្នុងកាលមុនតែការសម្រេចអរិយមគ្ គ ឬធ្ងេងឡើង គឺធ្ងេងផុតឱ្យ:ធំ គឺសង្ឃារនុ៎ះឯង ដោយមិនមានកពថ្មី គឺដោយអនុបាទិសេសនិព្ជានធាតុ អធិប្ជាយថា ធ្ងេងផុតតាំងនៅក្នុងត្រើយ ។

បឋមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១

២. ទុតិយលកុណ្ឌកកទ្ទិយសុត្តវណ្ណនា

អដ្ឋកថាទុតិយលកុណ្ឌកកទ្ទិយសូត្រ

ទុតិយលកុណ្ឌកកទ្ទិយសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **សេខោតិ មញ្ញមានោ** *បានដល់ សម្គាល់ថា ព្រះកទ្ទិយៈនេះ ជាព្រះសេក្ខៈ ។ ក្នុងពាក្យនោះ មានវចនត្ថៈដូចតទៅនេះ ឈ្មោះថា* ***សេក្ខៈ*** *ព្រោះនូវការសិក្សា ។ សិក្សាអ្វី ? សិក្សាអធិសីល អធិចិត្ត និងអធិបញ្ញា ។ ម្យ៉ាងទៀត ការសិក្សា ឈ្មោះថា* ***សិក្ខា*** *ការសិក្សានោះជាប្រក្រតីរបស់អ្នកនោះ ព្រោះហេតុនោះ អ្នកនោះ ឈ្មោះថា អ្នកមានការសិក្សា ។ មែនពិត អ្នកនោះ ឈ្មោះថា មានការសិក្សាជាប្រក្រតីដោយចំណែកតែមួយ ព្រោះមានការសិក្សាមិនទាន់ចប់ និងព្រោះបង្ហោនចិត្តទៅក្នុងការសិក្សានោះ តែមិនមែនអ្នកចប់ការសិក្សាដូចជាព្រះអសេក្ខៈ អ្នករម្ងាប់ការខ្ជិលខ្ជាយក្នុងការសិក្សានោះ ទាំងមិនមែនអ្នកលះចោលការសិក្សា ដូចជនច្រើនណាស់អ្នកមិនបង្ហោនចិត្តទៅក្នុងការសិក្សានោះ ។ ម្យ៉ាងទៀត ឈ្មោះថា* ***សេក្ខៈ*** *ព្រោះកើតសិក្ខា ៣ ឬមានក្នុងសិក្ខា ៣ នោះ ដោយអរិយជាតិ ។ បទថា* **កិយ្យោសោ មត្តាយ** *ប្រែថា ក្រៃលែងដោយប្រមាណ អធិប្បាយថា ក្រៃលែងលើសប្រមាណ ។ មែនពិត លកុណ្ឌកកទ្ទិយៈ គង់នៅដូចដើមនុ៎ះឯង សម្រេចធម៌ជាគ្រឿងអស់ទៅនៃអាសវៈដោយ ឱ្យ១ទដំបូងតាមវិធីដូចពោលក្នុងសូត្រដំបូង ។ ចំណែកព្រះធម្មសេនាបតី មិនជ្រាបការសម្រេចព្រះអរហត្តនោះរបស់ព្រះកទ្ទិយៈដ៏មានអាយុអង្គនោះ ដោយ*

សម្គាល់ថា នូវជាព្រះសេក្ខ:ដូចដើម ដូចបុរសអ្នកមានចិត្តល្អ គេសូមតិចក៏ឱ្យច្រើនដូច្នោះ រមែងសម្តែងធម៌ដើម្បីអស់អាសវ: ដោយអនេកបរិយាយយ៉ាងក្រៃលែងៗ ឡើងទៅតែម្តង ។ ចំណែកព្រះលកុណ្ឌកកទ្ទិយ:ដ៏មានអាយុ មិនបានគិតថា ឥឡូវនេះ យើងធ្វើកិច្ចសម្រេចហើយ និងមានប្រយោជន៍អ្វី ដោយឱ្យ៉ាងនេះ ទើបស្តាប់ដោយគោរពដូចក្នុងកាលមុន ព្រោះគោរពក្នុងព្រះសទ្ធម្ម ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបដូច្នោះ ប្រថាប់គង់នៅក្នុងព្រះគន្ធកុដិនុ៎ះឯង ទ្រង់ធ្វើដោយប្រការដែលព្រះធម្មសេនាបតី ដឹងនូវការអស់ទៅនូវកិលេសរបស់ព្រះកទ្ទិយ:ដ៏មានអាយុ ដោយពុទ្ធានុភាព ទើបទ្រង់បន្ទឺឧទាននេះ ។ ព្រោះហេតុនោះ លោកទើបពោលថា **តេនខោ បន សមយេន** ជាដើម ។

ពាក្យដែលនឹងគប្បីពោលក្នុងសេចក្តីនោះ ខ្ញុំបានពោលទុកហើយក្នុងអនន្តរសូត្រនោះឯង ។

ក៏ក្នុងគាថាមានវិនិច្ឆ័យដូចតទៅនេះ បទថា **អច្ឆេច្ឆិ វដ្ដំ** សេចក្តីថា កាត់កិលេសវដ្ដបានដាច់ខាត ក៏កាលកាត់កិលេសវដ្ដបានហើយ ក៏ឈ្មោះថាកាត់កម្មវដ្ដបានផង ។ តណ្ហា លោកហៅថា **អាសា** សេចក្តីប្រាថ្នា ក្នុងពាក្យថា **ឞ្យាតា និរាសំ** នេះ ព្រះនិព្វាន ឈ្មោះថា **និរាសៃ:** ព្រោះមិនមានសេចក្តីប្រាថ្នា ។ ឈ្មោះថា **ឞ្យាតា** ព្រោះដល់ គឺសម្រេចព្រះនិព្វានដែលប្រាសចាកសេចក្តី

ប្រាជ្ញានោះដោយពិសេស ។ អធិប្បាយថា ព្រោះសម្រេចអរហត្តមគ្គហើយ ទើបឈ្មោះថា សម្រេចដោយរៀរចាកហេតុនៃសេចក្ដីសម្រេចទៀត ។ ព្រោះតណ្ហាជាហេតុកើតនៃទុក្ខ កិលេសឈ្មោះថា ដែលលោកលះមិនទាន់បាន ដោយការលះនោះ រមែងមិនមាន ដូច្នោះកាលនឹងសម្ដែងការលះតណ្ហាឱ្យពិសេសដល់លោក ទើបត្រាស់ពាក្យថា តណ្ហាដែលបុគ្គលឱ្យស្ងួតហួតហែង ហើយរមែងមិនហូរទៅដូច្នេះជាដើម ។ ពាក្យនោះមានអធិប្បាយដូចតទៅនេះ ទន្ទេ្ធ គឺតណ្ហាដែលបុគ្គលឱ្យស្ងួតហួតហែង ដោយមិនមានចំណែកនៅសល់ ដោយធ្វើមគ្គ-ញ្ញាណទី ៤ ឱ្យកើតឡើង ដូចទន្ទេ្ធធំស្ងួតហួតហែងទៅ ព្រោះប្រាកដព្រះអាទិត្យដួងទី ៤ ក្នុងឥឡូវនេះ រមែងមិនហូរទៅ គឺតាំងពីនេះទៅរមែងមិនប្រព្រឹត្តទៅ ។ ក៏តណ្ហាលោកហៅថា **សរិតា** ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា

សរិតានិ សិនេហិតានិ ច, សោមនស្សានិ ភវន្តិ ជន្តុនោ

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់ផង រមែងមានដល់សត្ត[1] និងថា **សរិតា វិសត្តិកា** កិលេសជាតិហូតទៅ ផ្សាយទៅ[2] តណ្ហា ដែលឈ្មោះថា **សរិតា** ជ្រួតជ្រាបទៅក្នុងអារម្មណ៍ផ្សេងៗ ដូចវល្ល៍ ។ បទថា **ឆិន្នំ រដ្ដំ ន វត្ដតិ** សេចក្ដីថា រដ្ដ:

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ៨៣ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស លេខ ៦២ ទំព័រ ១២ ។

ដែលជាច់ហើយ ដោយការកាត់ផ្តាច់កិលេសវដ្ដ:យ៉ាងនេះ កម្មវដ្ដ:ដែលកាត់ផ្តាច់ ដោយមិនឱ្យការមិនកើតឡើងជាធម៌ និងការមិនមានវិបាកជាធម៌ រមែងមិនប្រព្រឹត្តទៅ គឺមិនកើត ។ បទថា **ឯសេវណ្ដោ ទុក្ខស្ស** សេចក្ដីថា ការមិនប្រព្រឹត្តទៅនៃកម្មវដ្ដ: ព្រោះកិលេសវដ្ដ:មិនមានដោយប្រការទាំងពួងនោះ គឺជាការមិនកើតឡើងនៃវិបាកវដ្ដ:តទៅ ដោយចំណែកតែមួយពិតៗ ជាទីបំផុត ជាខេត្តកំណត់ជាការ:ដែលវិលរបស់សង្សារទុក្ខសូម្បីទាំងអស់ ។

ទុតិយសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ២

៣. បឋមកាមសុត្តវណ្ណនា[1]

អដ្ឋកថាបឋមកាមសូត្រ

បឋមកាមសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **កាមេសុ** *បានដល់ ក្នុងវត្ថុកាម ។ បទថា* **អតិវេលំ** *បានដល់ កន្ទងវេលា ។ បទថា* **សត្តា** *បានដល់ សត្ត្ব អធិប្បាយថា អ្នកជាប់ គឺជំពាក់ ដោយមិនឃើញទោស សូម្បីដែលមាននៅ រហ្ពកដល់តែសេចក្តីត្រេកអរជាប់ជំពាក់ ព្រោះច្រើនទៅដោយអយោនិសោមនសិការ: ។ បទថា* **រត្តា** *ឈ្មោះថា កំណត់ ហើយ កំណត់ហើយដោយធន្ទ្ធ្ពគ: ដែលជាគ្រឿងធ្វើចិត្តឱ្យប្រែប្រួល ដូចសំពត់ ផ្ទាស់ទៅដោយការជ្រលក់ពណ៌ដូច្នោះ ។ បទថា* **តិដ្ឋា** *សេចក្តីថា ជាប់ គឺដល់ សេចក្តីតម្រេក ដោយការសម្ងឹងដែលមានសេចក្តីប្រាថ្នាជាសភាវ: ។ បទថា* **ឋិតា** *សេចក្តីថា ជាប់ទាក់ទងក្នុងកាមនោះ ព្រោះជាភាវ:ដែលដោះបាន លំបាក ដូចជាការរួបរឹតទុក ។ បទថា* **មុច្ឆិតា** *សេចក្តីថា មិនមានកិច្ចដទៃ គឺ ដល់ការជំពាក់ចិត្តដោយអំណាចកិលេស ដូចអ្នកសន្ធ្ប់ដូច្នោះ ។ បទថា* **អជ្ឌោបន្ន** *សេចក្តីថា លេបឱ្យសម្រេចតាំងនៅ ធ្វើឱ្យដូចជាវត្ថុដែលមិន ទូទៅដល់អ្នកដទៃ ។ បទថា* **សម្ មត្តកជាតា** *សេចក្តីថា ដល់ភាពជាអ្នកត្រាំ ក្នុងកាមទាំងឡាយ គឺជាអ្នកមួមៅស្រវឹងខ្លាំងក្នុងសុខវេទនាមានប្រមាណតិច ។ បាលីថា* **សម្ មោ ឧ ជ ជាតា** *ដូច្នេះក៏មាន អធិប្បាយថា កើតសេចក្តីរីករាយចិត្ត*

១-ក្នុងអដ្ឋកថាច្បាស់ធដ្ឋសង្គ្ភាយនា ព្រះសូត្រនេះមានឈ្មោះថា **បឋមសត្ត**សុត្តវណ្ណនា *។*

គឺសប្បាយចិត្ត ។ ដោយបទសូម្បីទាំងអស់ លោកពោលដល់ភាពដែលជនទាំងនោះជាប់ជំពាក់ចិត្តដោយតណ្ហានុ៎ះឯង ។ ក៏ក្នុងសូត្រនេះ ពាក្យដើមលោកពោលថា **កាមេសុ** ហើយពោលដដែលថា **កាមេសុ** ទៀត ក៏ដើម្បីសម្តែងថា សត្វទាំងនោះមានចិត្តបង្ហោនទៅក្នុងកាមនោះ ។ ដោយពាក្យនោះលោកសម្តែងថា សត្វទាំងនោះ ជាអ្នកព្រមព្រៀងដោយកាមគុណគ្រប់តរិយាបថទាំងពួង ។

ដំណាលមកថា សម័យនោះ រៀរព្រះអរិយសាវកចេញ អ្នកក្រុងសាវត្ថីទាំងអស់ ឃោសនានូវការលេងមហោស្រព ត្រៀមផ្ទៃដីដើម្បីលេងមហោស្រពទៅតាមកម្ទាំងសម្បត្តិ មានការស៊ី ផឹក បរិភោគកាម ទាំងក្នុងទីវាល ទាំងក្នុងទីកំបាំង បម្រើឥន្ទ្រិយ ដេកត្រាំក្នុងកាមទាំងឡាយ ។ ពួកភិក្ខុទាំងឡាយ នាំគ្នាត្រាច់បិណ្ឌបាតក្នុងក្រុងសាវត្ថី ឃើញមនុស្សក្នុងផ្ទះនោះ។ និងក្នុងសួនជាទីរីក-រាយជាដើម នាំគ្នាឃោសនាមហោស្រព មានចិត្តបង្ហោនទៅក្នុងកាម បដិបត្តិយ៉ាងនោះនាំគ្នាគិតថា យើងនឹងទៅវិហារបានស្តាប់ធម្មទេសនាដ៏ល្អិតល្អន់សុខុម ដូច្នេះហើយ ទើបក្រាបទូលសេចក្តីនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ សម្ពហុលា ភិក្ខូ ។ បេ ។ កាមេសុ វិហរន្តិ** ដូច្នេះ ។

បទថា **ឯតមត្ថं វិទិត្វា** *សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួង ដល់សេចក្តីដែលមនុស្សទាំងនោះ មិនឃើញទោសក្នុងកាមទាំងឡាយ ដែលគួរខ្ជាប អត់ទ្រាំមិនបាន និងមានកម្តៅជាផល ជាទីរីករាយ មានសេចក្តីក្តៅផ្សាច្រើន ដែលសេចក្តីវិនាសជាអនេកជាប់តាមនេះ ទើបទ្រង់បន្ទឹ្ទ*ទាននេះ *ដែលប្រកាសទោសនៃកាម និងកិលេស ។*

បណ្តាបទទាំងនោះ បទថា **កាមេសុ សត្តា** *សេចក្តីថា សត្វទាំងឡាយ អ្នកត្រេកអរ ស្រវឹង ជាប់ជំពាក់ ជ្រួតជ្រាប ជាប់ ពាក់ព័ន្ធ ប្រកបក្នុងវត្ថុកាម ដោយកិលេសកាម ។ បទថា* **កាមសង្គ្គសត្តា** *សេចក្តីថា ឈ្មោះថា អ្នកជំពាក់ គឺមកជំពាក់ដោយគ្រឿងជំពាក់ គឺរាគៈ និងធម្មជាតិជាគ្រឿងជំពាក់ គឺទិដ្ឋិ មានៈ ទោសៈ និងអវិជ្ជា ក្នុងវត្ថុកាម ដោយសេចក្តីគិតក្នុងកាមនោះនុ៎ះឯង ។ បទថា* **សំយោជនេ រជ្ជមបស្សមានា** *សេចក្តីថា មិនឃើញទោស គឺទោសៈ បានដល់* ***អាទីនវៈ*** *ដែលឈ្មោះថា មានវដ្តទុក្ខជាមូលជាដើម ព្រោះមានប្រក្រតីឃើញតាមសេចក្តីត្រេកអរក្នុងធម៌ ដែលជាគ្រឿងប្រកបសត្វទុកក្នុងកិលេសមានកាមរាគៈជាដើម ដែលមានឈ្មោះថា* ***សញ្ញោជនៈ*** *ព្រោះប្រកប គឺកម្មវដ្តៈ ដោយវិបាកវដ្តៈ ឬកពជាដើម ដោយកពដទៃជាដើម ឬសត្វទាំងឡាយដោយទុក្ខ ។ បទថា* **ន ហិ ជាតុ សំយោជនសង្គ្គសត្តា ឱឃំ តរេយ្យុं វិបុលं មហន្តं** *សេចក្តីថា សត្វទាំងឡាយអ្នកជាប់ជំពាក់នៅក្នុងធម៌ជាគ្រឿងជាប់ជំពាក់*

ដែលមានសញ្ញោជនៈជាសការៈ ព្រោះមិនមានការឃើញទោសយ៉ាងនេះ ជាប់-ជំពាក់នៅក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាអារម្មណ៍នៃធម៌ជាគ្រឿងជាប់ជំពាក់ទាំងនោះ ដោយធម៌ជាគ្រឿងជាប់ជំពាក់ពោលគឺ សញ្ញោជនៈ ក្នុងកាលណាៗ ក៏ធ្វើមិនបាននូវឱឃៈ មានកាមជាដើម ដែលឈ្មោះថា ជំទូលាយ សូម្បីក្រាស់ និងធំ ឬឱឃៈ គឺសង្សារនុ៎ះឯង ព្រោះមានអារម្មណ៍ ជំទូលាយ និងរកកាលខាងដើមជាដើមមិនបាន អធិប្បាយថា មិនគប្បីដល់ត្រើយនៃឱឃៈនោះ ដោយចំណែកតែមួយនុ៎ះឯង ។

បឋមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៣

៤.ឧតិយកាមសុត្តវណ្ណនា[1]

អដ្ឋកថាឧតិយកាមសូត្រ

ឧតិយកាមសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **អន្ធីកតា** *សេចក្តីថា ដែលឈ្មោះថា* **កាម** *រមែងធ្វើអ្នកមិនងងឹតឱ្យងងឹត ។ សមដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា*

លុទ្ធោ អត្ថं ន ជានាតិ លុទ្ធោ ធម្មं ន បស្សតិ
អន្ធតមं តទា ហោតិ យំ លោភោ សហតេ នរន្តិ ។

បុគ្គលអ្នកលោភ រមែងមិនស្គាល់នូវប្រយោជន៍ បុគ្គលអ្នកលោភ រមែងមិនឃើញនូវធម៌ទេ សេចក្តីលោភគ្របសង្កត់នូវនរជន ក្នុងកាលណា សេចក្តីងងឹតដ៏មានកម្លាំង ក៏កើតឡើងក្នុងកាលនោះ[2]។

ព្រោះដូច្នោះ ទើបឈ្មោះថា **អន្ធីកតា** *ព្រោះត្រូវកាមធ្វើអ្នកមិនងងឹតឱ្យជាអ្នកងងឹត ។ ពាក្យដែលនៅសល់មានន័យដូចពោលហើយក្នុងសូត្រជាប់គ្នានុ៎ះឯង ។ ក៏ក្នុងសូត្រនោះ ពួកភិក្ខុឃើញការប្រព្រឹត្តទៅរបស់មនុស្ស ទើបក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ។ ក្នុងសូត្រនេះមានសេចក្តីប្លែកគ្នាប៉ុណ្ណោះថា ព្រះដ៏មានព្រះភាគទ្រង់ឃើញដោយព្រះអង្គឯងតែម្តង ។ ព្រះសាស្តាស្តេចចេញពីក្រុងសាវត្ថី ស្តេចទៅកាន់វត្តជេតពន ក្នុងចន្លោះផ្លូវទ្រង់ទតព្រះនេត្ត*

១-ក្នុងអដ្ឋកថាច្បាប់ធម្មសង្គាយនា ព្រះសូត្រនេះមាន ឈ្មោះថា ឧតិយសត្តសុត្តវណ្ណនា *។*
២-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ១១២ ។

ឃើញត្រីមានចំនួនច្រើន មិនអាចនឹងចូលទៅកាន់ទ្រូ ដែលពួកអ្នកប្រមង់ (នេសាទ) ដាក់ទុកក្នុងទន្ទេអចិរវតី គ្រាតមក ទ្រង់បានឃើញកូនគោមួយក្បាលស្រែកថា គោ ជាប់តាមមេគោទៅ ខ្ជិន-កចូលទៅដើម្បីផឹកទឹកដោះ បង្ហោនមាត់ចូលទៅក្នុងចន្ទោះជើងមេគោ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគស្តេចចូលទៅកាន់វិហារ លាងព្រះបាទទាំងពីរ ហើយប្រថាប់គង់លើពុទ្ធាសនៈដែលគេក្រាលទុក ទ្រង់កាន់យករឿង ២ រឿងខាងក្រោយដោយជាឧបមារបស់រឿងមុន ទើបទ្រង់បន្ទឹឧទាននេះ ។

បណ្តាបទទាំងនោះ បទថា **កាមន្ធា** បានដល់ ធ្វើសេចក្តីងងឹតក្នុងវត្ថុកាម ដោយកិលេសកាម មិនឱ្យមើលឃើញ ។ បទថា **ជាលសញ្ជន្ធា** សេចក្តីថា ដេរជាស់ ពាក់ព័ន្ធ បានដល់ ត្រូវតណ្ហាដែលដូចជាសំណាញ់ត្រូបសង្កត់ ព្រោះកើតឡើងបន្តៗ ទៅដោយកត អារម្មណ៍ខាងក្រោម និងខាងលើ ក្នុងអត្ត-ភាពរបស់ខ្លួន និងរបស់អ្នកដទៃ ក្នុងអាយតនៈខាងក្នុង និងខាងក្រៅ និងក្នុងធម៌ដែលអាស្រ័យអាយតនៈខាងក្នុង និងខាងក្រៅនោះ ដែលផ្សេងដោយធម៌ច្រើនប្រភេទ ដោយកាល មានអតីតកាលជាដើម និងនាំមកនូវភាពមិនមានប្រយោជន៍ដល់បុគ្គលដែលកប់ទុកនៅខាងក្នុង ដូចអន្ទង់ទឹកធំ ដែលឡោមព័ទ្ធទៅដោយសំណាញ់ ដែលមានប្រហោងដ៏ល្អិត ។ បទថា **តណ្ហាឆទនធានិតា**

បានដល់ ដែលគេបិទបាំង គឺបាំងទុកដោយគ្រឿងប្រក់បាំង គឺតណ្ហា ដូចទឹក ដែលសាវយបិទបាំងដូច្នោះ ។ សូម្បីដោយ ២ បទនេះ លោកក៏សម្តែងដល់ការ នាំកុសលចិត្ត ដែលកាមឆន្ទនីវរណៈ:ពារាំង ។

បទថា **បមត្តពន្ធុនា ពន្ធា** *បានដល់ អ្នកដែលកិលេសមារ និងទេវបុត្ត-មារចងទុក ។ មែនពិត បុគ្គលដែលត្រូវកិលេសមារចងទុក ដោយអារម្មណ៍ណា ក៏ឈ្មោះថា ត្រូវទេវបុត្តមារចងទុកដោយអារម្មណ៍នោះ ។ សមដូចពាក្យដែល មារពោលទុកថា*

អន្តលិក្ខចរោ ចាសោ យ្វាយំ ចរតិ មានសោ
តេន តំ ពាធយិស្សាមិ ន មេ សមណ មោក្ខសិ ។

អន្ទាក់ គឺពាគ:ណាដែលត្រាច់ទៅលើអាកាស តែងតែប្រព្រឹត្តទៅនៅ ក្នុងចិត្ត ខ្ញុំនឹងបៀតបៀនព្រះអង្គដោយសារអន្ទាក់នោះ បពិត្រព្រះសមណ: ព្រះអង្គមិនរួច (ចាកវិស័យ) របស់ខ្ញុំឡើយ[1] ។

បទទាំង៣គឺ **ឆមុចិ ឧណ្ហោ បមត្តពន្ធុ** *ជាឈ្មោះរបស់មារ ។ សូម្បី ទេវបុត្តមារ ក៏ឈ្មោះថា* **បមត្តពន្ធុ** *ព្រោះចងសត្វអ្នកប្រមាទទុក ដោយសេចក្តី វិនាស ដូចកិលេសមារ ដូច្នោះ ។ អាចារ្យពួកខ្លះពោលថា* **បមត្តា ពន្ធនេ ពន្ធា** *ដូច្នេះក៏មាន ។*

១-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ២៩ ទំព័រ ៣០៥ ។

បណ្តាបទទាំងនោះ បទថា **ពន្ធនេ** *សេចក្តីថា គ្រឿងចង គឺកាមគុណ ។ បទថា* **ពទ្ធា** *បានដល់ ដែលត្រូវកំណត់ទុក ។ ប្រៀបផ្ទឹមដូចអ្វី? ប្រៀបផ្ទឹមដូចត្រីក្នុងមាត់ទ្រូ អធិប្បាយថា ត្រីទាំងឡាយ ចូលទៅកាន់មាត់ទ្រូដែលអ្នកប្រមង់ទុក ជាត្រីដែលជាប់ទ្រូ រមែងទៅ គឺដល់សេចក្តីស្លាប់ យ៉ាងណា សត្វទាំងនេះក៏ដូច្នោះដែរ ត្រូវចងទុកដោយគ្រឿងចង គឺកាមគុណ ដែលមារជាក់ទុក រមែងចូលដល់ជរា និងមរណៈតែម្តង ។ ដូចកូនគោដែលនៅជៅទឹកដោះ ជាប់តាមមេគោទៅដូច្នោះ អធិប្បាយថា ដូចគោជំទង់មិនទាន់ចោលទឹកដោះ រមែងជាប់តាម គឺទៅតាមមេរបស់ខ្លួន មិនជាប់តាមគោដទៃ យ៉ាងណា សត្វដែលចងទុកដោយគ្រឿងចង គឺមារ ក៏ដូច្នោះ កាលវិលទៅក្នុងសង្សារ រមែងជាប់តាម គឺទៅតាមមរណៈតែមួយ មិនទៅតាមអមតនិព្វាន ជាទីមិនចាស់ ជាទីមិនស្លាប់ ។*

ចតុត្ថសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៤

៤. អបរលកុណ្ឌកកដ្ឋិយសុត្តវណ្ណនា

អដ្ឋកថាអបរលកុណ្ឌកតដ្ឋិយសូត្រ

អបរលកុណ្ឌកកដ្ឋិយសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **សម្ពហុលានំ ភិក្ខូនំ ឧដ្ឋិតោ ឧដ្ឋិតោ** *សេចក្តីថា ថ្ងៃមួយ ព្រះលកុណ្ឌកកដ្ឋិយ: មួយអន្ទើដោយភិក្ខុជាច្រើន ត្រាច់បិណ្ឌបាតក្នុងចន្ទោះស្រុក ឆាន់ភត្តាហារស្រេចហើយ លាងបាត្រដាក់ស្ងោក ពាក់ទុកត្រង់ស្មា ចងចីវរ ស្ពាយចីវរសូម្បីនោះទុកត្រង់ស្មាធ្វេង មានការឈានទៅ ថយត្រឡប់ ក្រឡេកមើល គន់មើល ទម្រេត គួរជ្រះថ្លា មានភ្នែកសម្ងឹងចុះ បរិបូណ៌ដោយ ឥរិយាបថ ដូចជាប្រកាសសេចក្តីបរិបូណ៌ដោយសតិ និងបញ្ញារបស់ខ្លួន តាំងសតិសម្បជញ្ញ:ឱ្យមាំល្អ មានចិត្តជាសមាធិ កាលឈានដើងដើរទៅ កាលនឹងទៅ ក៏ដើរតាមក្រោយភិក្ខុទាំងឡាយ មិនច្របូកច្របល់ដោយភិក្ខុទាំងនោះ ។ ព្រោះហេតុណា? ព្រោះជាអ្នកនៅដោយការមិនច្របូកច្របល់ ។ ម្យ៉ាងទៀត បុថុជ្ជនទាំងឡាយ រមែងមើលងាយរូបរបស់លោកថា គួរមើលងាយជាទីតាំងនៃសេចក្តីមើលងាយ ។ ព្រះថេរ:ជ្រាបដូច្នោះ ទើបនិមន្តទៅតាមក្រោយ ដោយគិតថា ភិក្ខុទាំងឡាយនេះ ចូរកុំមានបាប ព្រោះអាស្រ័យយើងឡើយ ។ ភិក្ខុទាំងនោះ និងព្រះថេរ:ដល់ក្រុងសាវត្ថី ចូលទៅកាន់វិហារ ចូលគាល់ព្រះសាស្តា ដល់ទីប្រថាប់ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ លោកទើបពោលថា* **តេន ខោ បន សមយេន អាយស្មា លកុណ្ឌកភដ្ឋិយោ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **ឧ**ព្ភ**ណ្ណ**ា បានដល់ រូបគួរស្អប់ ។ ដោយពាក្យនោះ ទ្រង់សម្តែងដល់ព្រះថេរៈ មិនមានការដល់ព្រមដោយវណ្ណៈ និងដល់ព្រមដោយទ្រង់ទ្រាយ ។ បទថា **ឧ**ទ្ធ**សិ**ត**ំ** ប្រែថា ឃើញហើយមិនគួរជ្រះថ្លា ។ ដោយបទនោះ សម្តែងដល់ព្រះថេរៈមិនមានការបរិបូណ៌ដោយអនុព្យញ្ជនៈ និងការបរិបូណ៌ដោយអាការ ។ បទថា **ឱ**ការ**ជ**ិ**ម**ត**ំ** ប្រែថា ត្រី ។ ដោយពាក្យនេះទ្រង់សម្តែងដល់ព្រះថេរៈមិនមានការបរិបូណ៌ដោយចំណែកខ្ពស់ ។ បទថា **យ**េ**ក**ុ**យ**ា**ន** **ភ**ិ**ក**្**ខ**ូ**ន**ំ **ប**រ**ិ**ភ**ូ**ត**រ**ូ**ប**ំ** បានដល់ អ្នកមានរូបរាងដែលភិក្ខុទាំងឡាយ ជាបុថុជ្ជនមើលងាយ ។ ភិក្ខុជាបុថុជ្ជនពួកខ្លះ ដូចធម្ម្ភិយភិក្ខុជាដើម កាលមិនដឹងគុណរបស់ព្រះថេរៈ ចាប់ស្ទាបអង្ហែលលេង ត្រង់ដៃ និងស្ទឹកត្រចៀកជាដើម មើលងាយ ចំណែកព្រះអរិយៈជាម្ចាស់ និងកល្យាណបុថុជ្ជនមិនមើលងាយទេ ។

បទថា **ភ**ិ**ក**្**ខ**ូ **អ**ាម**ន្ត**េ**ស**ិ សេចក្តីថា ត្រាស់ហៅភិក្ខុមកដោយហេតុដូចម្តេច? ដើម្បីប្រកាសគុណរបស់ព្រះថេរៈ ។ បានឮថា ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះយ៉ាងនេះថា ភិក្ខុទាំងនេះមិនដឹងថា បុត្ររបស់តថាគតយើងមានអានុភាពច្រើន ព្រោះហេតុនោះ ទើបនាំគ្នាមើលងាយព្រះថេរៈ ប្រការនោះនឹងប្រព្រឹត្តទៅដើម្បីហេតុមិនជាប្រយោជន៍ ដើម្បីទុក្ខអស់កាលយូរដល់ភិក្ខុទាំងនោះ ណ្តើយចុះ តថាគតនឹងប្រកាសគុណរបស់ភិក្ខុនេះ ដល់ភិក្ខុទាំងឡាយ ហើយនឹងដោះព្រះថេរៈឱ្យផុតពីការមើលងាយ ។

បទថា **បស្ស** *ដោ* *ប្រែថា ពួកលោកចូរមើល ។ បទថា* **ន ច សាសមាបត្តិ សុលភរូចា យា តេន ភិក្ខុនា អសមាបន្ធបុព្វា** *សេចក្ដីថា ឈ្មោះសមាបត្តិយ៉ាងណាមួយ ដែលទូទៅដល់ព្រះសាវក មានប្រភេទយ៉ាងនេះ គឺរូបសមាបត្តិ អរូបសមាបត្តិ ព្រហ្មវិហារសមាបត្តិ និរោធសមាបត្តិ និងផលសមាបត្តិ បណ្ដាសមាបត្តិទាំងនោះ សូម្បីតែសមាបត្តិណាមួយ មិនមែនបានដោយងាយ គឺបានដោយលំបាក ។ ភិក្ខុលកុណ្ឌកកទ្ទិយៈនោះ មិនធ្លាប់ចូលសមាបត្តិនោះមិនមានឡើយ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ គ្រាទ្រង់ប្រកាសភាពដែលព្រះថេរៈនោះមានឫទ្ធិច្រើន ក្នុងពាក្យដែលត្រាស់ទុកថា* **មហិទ្ធិកោ មហានុភាវោ** *ឥឡូវនេះ ដើម្បីនឹងប្រកាសសេចក្ដីដែលព្រះថេរៈមានអានុភាពច្រើន ទើបត្រាស់ពាក្យមានជាអាទិ៍ថា* **យស្ស ចត្ថាយ** *ដូច្នេះ ។ ពាក្យនោះមានន័យដូចពោលហើយក្នុងកាលមុននុ៎ះឯង ។*

ក៏ក្នុងពាក្យទាំងនោះ ដោយពាក្យថា **ឯសោ ភិក្ខវេ ភិក្ខុ** *ជាដើម ព្រះដ៏មានព្រះភាគទ្រង់សម្ដែងថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះមិនមែនជាភិក្ខុគួរដល់ការប្រទូស្ដទេ អ្នកណាៗ មិនគួរមើលងាយដោយហេតុត្រឹមតែប៉ុណ្ណោះ ថា ជាអ្នកមានរូបមិនស្អាត មិនគួរមើល ត្មៀ និងថាដើរតាមក្រោយភិក្ខុទាំងឡាយ ដោយពិតជាភិក្ខុមានឫទ្ធិច្រើន មានអានុភាពច្រើន គុណជាតិណានីមួយ ដែលសាវកបានហើយ គុណជាតិទាំងអស់នោះ ភិក្ខុនោះបានហើយដោយលំដាប់*

ព្រោះដូច្នោះ គប្បីធ្វើកិក្ខុនោះឱ្យធ្ងន់ ដូចធ័ត្រថ្ម ហើយទើបក្រឡេកមើល ប្រការនោះនឹងជាដើម្បីប្រយោជន៍ នឹងជាសេចក្ដីសុខអស់កាលយូរដល់អ្នកទាំងឡាយ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួងដែលជាគំនរនៃគុណរបស់លកុណ្ឌកកទ្ទិយដ៏មានអាយុ ផ្សេងដោយគុណ មានភាពជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើនជាដើមនេះ ទើបទ្រង់បន្ទឹឧទាននេះ ដែលសម្ដែងសេចក្ដីនោះ ។

ទោស លោកហៅថា **ឯលៃ** ក្នុងបទថា **ឯលៃ** ក្នុងព្រះគាថានោះ ។ ទោសរបស់ពាក្យនោះមិនមាន ព្រោះហេតុនោះ ពាក្យនោះទើបឈ្មោះថា **ឯលំ** ។ ក៏ **ឯលៃ** នោះ គឺអ្វី? គឺសីលវិសុទ្ធិ ។ មែនពិត សីលដែលបរិសុទ្ធដោយល្អនោះ លោកបំណងយកថា **ឯលៃ** ក្នុងព្រះគាថានេះ ព្រោះអត្ថថា មិនមានទោស ។ កិក្ខុឈ្មោះថា **ឯលង្គ:** ព្រោះមានអង្គដែលជាប្រធាន ដែលរកទោសមិនបាន ។ សម្ព័ន្ធដោយពាក្យដែលលោកពោលទុកថា **រថ** ព្រោះដូច្នោះ លោកអធិប្បាយថា អ្នកមានអង្គ គឺសីលវិសុទ្ធិដ៏ល្អ ។ មែនពិត សីលដែលសម្បយុត្តដោយអរហត្តផល លោកប្រាថ្នាយកក្នុងទីនេះ ។ អត្តភាពដូចរថ ឈ្មោះថា **សេត-បច្ឆាទោ** ព្រោះមានដំបូលពណ៌ស ។ បទថា **បច្ឆាទោ** បានដល់ សំពត់កម្ពលជាដើម ដែលក្រាលទុកលើខ្នងរថ ។ ក៏រថ គឺអត្តភាពនោះ មានពណ៌សក្ដី មានពណ៌ក្រហម និងពណ៌ខៀវជាដើម យ៉ាងណាមួយក្ដី ព្រោះមានការ:សសុទ្ធដោយល្អ ។ តែក្នុងទីនេះលោកពោលថា **សេតបច្ឆាទោ** មានដំបូល-ស ព្រោះ

អាស្រ័យការ:ដ៏បរិសុទ្ធដោយល្អ ព្រោះប្រាថ្នាយកការរួចផុតដោយអរហត្តផល ដូចឧបមាយ៉ាងណាមួយថា រថមានគ្រឿងបរិក្ខារ-ស ។ កាំមួយ គឺសតិរបស់រថ នោះមាន ព្រោះហេតុនោះ រថនោះ ឈ្មោះថា មានកាំតែមួយ ។ បទថា **វត្ត**តិ *ប្រែថា រមែងប្រព្រឹត្តទៅ ។ ដោយបទថា* **រថោ** *នេះ ព្រះអង្គត្រាស់សំដៅដល់ អត្តភាពរបស់ព្រះថេរ: ។*

បទថា **អនីឃំ** *ប្រែថា មិនមានទុក្ខ អធិប្បាយថា រៀរចាកសេចក្តីកម្រើក នៃកិលេសដូចរថដែលរៀរចាកការញ័ររដូច្នោះ ។ បទថា* **អាយត្តំ** *បានដល់ មកខាងក្រោយៗរបស់ភិក្ខុទាំងឡាយ ។ បទថា* **ឋិន្ទសោតំ** *បានដល់ កាត់ក្រសៃហើយ ។ មែនពិត ក្រសៃនៃទឹកដោះថ្លា និងប្រេងជាដើម ដែលលាបត្រង់ក្ងៅ និងដុំហូរទៅ គឺឱ្យជ្រាបទៅដើម្បីឱ្យរថមានប្រក្រតីវិលទៅស្រួល ព្រោះដូច្នោះ រថនោះទើបឈ្មោះថា មានក្រសៃមិនទាន់ដាច់ ។ តែរថនេះ ជាដែលឈ្មោះថា ដាច់ក្រសៃហើយព្រោះលះក្រសៃកិលេស ៣៦ បានដាច់ជាសមុច្ឆេទ គឺរថ ដែលដាច់ក្រសៃហើយនោះឯង ។ ឈ្មោះថា* **អពន្ធនោ** *ព្រោះរថនោះមិនមាន គ្រឿងចង ។ មែនពិត គ្រឿងចងទាំងឡាយរបស់រថ ដែលមានគ្រឿងផ្សំព្រម នឹងក្ងៅរមែងមានច្រើន ដើម្បីធ្វើមិនឱ្យរថនោះរខេករខាក ព្រោះហេតុនោះ រថនោះទើបឈ្មោះថា មានគ្រឿងចង ។ តែរថនេះ ឈ្មោះថា មិនមានគ្រឿងចង ព្រោះគ្រឿងចង គឺសញ្ញោជន:ទាំងពួងអស់ទៅ ដោយមិននៅសល់ គឺរថដែល*

មិនមានគ្រឿងចងនោះ ។ ព្រះដ៏មានព្រះភាគទ្រង់បានទទួលសោមនស្សដោយគុណរបស់ព្រះថេរៈ ទើបត្រាស់ហៅព្រះថេរៈដោយព្រះតម្រាស់ថា អ្នកចូរមើល ។

ព្រោះដូច្នោះ ព្រះសាស្តាទ្រង់សម្តែងលកុណ្ឌកកទ្ទិយៈដ៏មានអាយុ ឱ្យជាអ្នកមានចក្រដោយល្អ ដោយលើកអរហត្តផលឡើងជាប្រធាន ឱ្យជាអ្នកមានវត្ថុកំចាំងដែលធ្វើងផែនដីដោយល្អ ដោយវិមុត្តិដែលសម្បយុត្តដោយអរហត្តផល ឱ្យជាអ្នកមិនមានកំចាំងដោយល្អ ដោយសតិដែលតាំងមាំដោយល្អឱ្យជាអ្នកមិនកម្រើក ព្រោះកិលេសជាគ្រឿងកម្រើកមិនមាន ឱ្យជាអ្នកមិនមានកិលេសជាគ្រឿងស្ទាប ព្រោះជាគ្រឿងស្ទាប គឺតណ្ហាមិនមាន ឱ្យជាអ្នកមិនមានកិលេសជាគ្រឿងចង ព្រោះមិនមានសញ្ញោជនៈជាដើម ឱ្យដូចជារថទឹមដោយសេះអាជានេយ្យ ដែលប្រកបដោយល្អហើយ ដែលមានគ្រឿងផ្សំល្អហើយ ។

បញ្ចមសុត្តវណ្ណា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៥

៦. តណ្ហាក្ខយសុត្តវណ្ណនា

អដ្ឋកថាតណ្ហាក្ខយសូត្រ

តណ្ហាក្ខយសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **កោណ្ឌញ្ញោ** *ក្នុងបទថា* **អញ្ញាកោណ្ឌញ្ញោ** *នេះ ជាឈ្មោះ*
របស់ព្រះថេរៈដ៏មានអាយុមកដោយគោត្រ ។ ក៏បណ្តាសាវកទាំងឡាយ ព្រះថេរៈ
ប្រាកដក្នុងព្រះសាសនាថា អញ្ញាកោណ្ឌញ្ញៈនុ៎ះឯង ដោយពាក្យឧទានដែល
ព្រះដ៏មានព្រះភាគត្រាស់ទុកថា **អញ្ញាសិ វត ភោ កោណ្ឌញ្ញោ** *ព្រោះត្រាស់*
ដឹងអរិយសច្ចៈ ៤ មុនព្រះសាវកទាំងអស់ ។ បទថា **តណ្ហាសង្ខ្យវិមុត្តឺ**
ឈ្មោះថា ធម៌ជាទីអស់ទៅនៃតណ្ហា ពោលគឺ អស់តណ្ហា បានដល់ ព្រះនិព្វាន ។
ការរួចផុតព្រោះការអស់ទៅនៃតណ្ហានោះ ។ ម្យ៉ាងទៀត អរិយមគ្គ ឈ្មោះថា
ធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះជាហេតុអស់ គឺជាហេតុលះតណ្ហា ។ ឈ្មោះថា
តណ្ហាសង្ខ្យវិមុត្តិ *ព្រោះវិមុត្តិជាផល ឬជាទីបំផុតនៃអរិយមគ្គ ដោយ*
និប្ឆរិយាយ បានដល់ សមាបត្តិដែលសម្បយុត្តដោយអរហត្តផល ។ ព្រះថេរៈ
ជាអ្នកអង្គុយពិចារណាសមាបត្តិ ដែលសម្បយុត្តដោយអរហត្តនោះ ។ មែនពិត
ព្រះអញ្ញាកោណ្ឌញ្ញៈដ៏មានអាយុអង្គនោះ បានចូលផលសមាបត្តិច្រើន ។ ព្រោះ
ដូច្នោះ សូម្បីក្នុងទីនេះលោកក៏បានធ្វើយ៉ាងនេះ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ព្រះអង្គគ្រាទ្រង់ជ្រាបការពិចារណាអរហត្តផលរបស់ព្រះអញ្ញាកោណ្ឌញ្ញៈនេះហើយ ទើបទ្រង់បន្ទឹឧទាននេះដែលសម្ដែងដល់សេចក្ដីនោះ ។

បណ្ដាបទទាំងនោះ បទថា **យស្ស មូលំ ឆមា ជត្តុ** សេចក្ដីថា ព្រះ-អរិយបុគ្គលណាមិនមានអវិជ្ជា ដូចជាឫសរបស់ដើមឈើ គឺអត្តភាព និងមិនមានផែនដី ពោលគឺ អាសវៈ នីវរណៈ និងអយោនិសោមនសិការ ដែលជាហេតុជាទីតាំងរបស់អវិជ្ជានុ៎ះឯង ព្រោះដកបានដោយអរហត្តមគ្គ ។ គប្បីជ្រាបសម្ព័ន្ធបទ ក្នុងបទថា **បណ្ណា ជត្តុ កុតោ លតា** នេះថា វល្លិ៍មិនមានស្លឹកនឹងមានអំពីទីណា ។ អធិប្បាយថា សូម្បីវល្លិ៍ ពោលគឺ មែកធំ មែកតូចជាដើម ដែលផ្សេងដោយមានៈ និងអតិមានៈជាដើម រមែងមិនមាន ស្លឹកឈើ គឺមទៈ បមាទៈ មាយា និងសាឋេយ្យៈជាដើម នឹងមានអំពីទីណាហ្ន៎ ។ ម្យ៉ាងទៀត បទថា **បណ្ណា ជត្តុ កុតោ លតា** សេចក្ដីថា កាលពន្ធកឈើដុះល្អឡើង ស្លឹកឈើក៏កើតឡើងមុន ខាងក្រោយមកលោកពោលតាំងឈ្មោះថា **លតា** គឺមែកធំ មែក-តូច ។ ក្នុងពាក្យនោះ មូល គឺអវិជ្ជា និងកិលេសមានអាសវៈជាដើម ដែលជាដែលតាំងអាស្រ័យរបស់មូល គឺអវិជ្ជានោះ រមែងមិនមានដល់ដើមឈើ គឺអត្តភាព

ណា ដែលគួរដល់ការកើតឡើង ក្នុងកាលមិនមានការចម្រើនអរិយមគ្គ ព្រោះចម្រើនអរិយមគ្គហើយ ។ ក៏ក្នុងទីនេះដោយមូលស័ព្ទនុ៎ះឯង គប្បីជ្រាបថា លោកកាន់យក សូម្បីការៈនៃកម្មដែលជាទីតាំងនៃពួជ ព្រោះជាហេតុនៃមូលនុ៎ះឯង ។ ក៏កាលពួជ គឺកម្មមិនមាន ពន្ធក គឺវិញ្ញាណ ដែលមានពួជ គឺកម្មជាគ្រឿងសំដៅ និងស្ទឹក មែក មាន នាម រូប សឡាយតនៈជាដើម ដែលមានពន្ធក គឺវិញ្ញាណជាគ្រឿងសំដៅ នឹងមិនកើតឡើងឡើយ ។ ព្រោះហេតុនោះ លោកទើបពោលថា ឫស គឺអវិជ្ជា និងផែនដី គឺអាសវៈមិនមានដល់ព្រះអរិយបុគ្គលណា ស្ទឹក គឺសេចក្តីស្រវឹងក៏មិនមានវល្ជ៌ គឺមានៈ និងមានអំពីណា ។

បទថា **តំ ធីរំ ពន្ធនា មុត្តំ** សេចក្តីថា ដែលព្រះអរិយបុគ្គលនោះ អ្នកឈ្នះថា **ធីរៈ** ព្រោះឈ្នះមារ ដោយការប្រកបការព្យាយាម គឺសម្មប្បធាន ៤ រួចផុតពីគ្រឿងចង គឺអភិសង្ខារដែលជាតួកិលេសទាំងអស់នោះនុ៎ះឯង ។ បទថា **តំ** ក្នុងបទថា **តោ តំ ជិនិ្ជតុមរហតិ** នេះ ជានិបាត ។ អ្នកណាហ្ន៎ មានជាតិជាវិញ្ញូជន គួរដើម្បីនឹងនិន្ទា រិះគន់ អ្នកផុតពីកិលេសទាំងពួង អ្នកប្រកបដោយគុណដ៏កំពូល មានសីលគុណជាដើម ដោយប្រការដូច្នេះ ព្រោះមិនមានការនិន្ទាជាគ្រឿងសំដៅនុ៎ះឯង ។ បទថា **ទេវាបិ ំ បសំសន្តិ** សេចក្តីថា ដោយពិត ពួកទេវតាអ្នកដឹងគុណវិសេស មានស្តេចសក្ក:ជាដើម ក៏រមែង

សរសើរដោយ **អ**ឬ*-ស័ព្ទនោះ សូម្បីមនុស្សមានក្សត្រ អ្នកជាបណ្ឌិតជាដើម ក៏រមែងទ្រង់សរសើរ ។ ក្រៃលែងជាងនោះទៀត សូម្បីព្រហ្មពួកខ្លះក៏សរសើរ គឺមហាព្រហ្មក្តី ព្រហ្ម នាគ យក្ខ និងគន្ធព្វជាដើម សូម្បីពួកដទៃក្តី ក៏រមែងសរសើរ គឺរមែងសរសើរដូចគ្នានុ៎ះឯង ។*

ឆដ្ឋមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៦

៧. បបញ្ចាទយសុត្តវណ្ណនា

អដ្ឋកថាបបញ្ចាខយសូត្រ

បបញ្ចាខយសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **បបញ្ចសញ្ញាសង្ខ្យារមហានំ** *សេចក្តីថា* **កិលេស** *ឈ្មោះថា ធម៌ជាគ្រឿងយឺតយូរ ព្រោះជាទីកើតឡើងដោយខ្លួនឯង ធ្វើឱ្យយឺតយូរ គឺ ពង្រីកសេចក្តីបន្តនោះឱ្យធំទូលាយ បានដល់ ឱ្យតាំងនៅយូរដោយពិសេស បានដល់ រាគ: ទោស: មោហ: តណ្ហា ទិដ្ឋិ និងមាន: ។ សមដូចពាក្យដែល លោកពោលទុកថា ធម៌ជាគ្រឿងយឺតយូរ គឺរាគ: ទោស: មោហ: តណ្ហា ទិដ្ឋិ និងមាន: ។ ម្យ៉ាងទៀត ធម៌មានអត្តថា សៅហ្មង ឈ្មោះថា អត្តនៃធម៌ជា គ្រឿងយឺតយូរ ធម៌មានអត្តដូចជានុយ ឈ្មោះថា អត្តនៃធម៌ជាគ្រឿងយឺតយូរ ។ បណ្តាធម៌ទាំងនោះ សុកសញ្ញាជាគ្រឿងសម្គាល់របស់ធម៌ជាគ្រឿងយឺតយូរ គឺ រាគ: អាឃាតវត្ថុជាគ្រឿងសម្គាល់របស់ធម៌ជាគ្រឿងយឺតយូរ គឺទោស: អាសវ: ជាគ្រឿងសម្គាល់របស់ធម៌ជាគ្រឿងយឺតយូរ គឺមោហ: វេទនាជាគ្រឿងសម្គាល់ របស់ធម៌ជាគ្រឿងយឺតយូរ គឺតណ្ហា សញ្ញាជាគ្រឿងសម្គាល់របស់ធម៌ជាគ្រឿង យឺតយូរ គឺទិដ្ឋិ និងវិតក្ក:ជាគ្រឿងសម្គាល់របស់ធម៌ជាគ្រឿងយឺតយូរ គឺមាន: ។ សញ្ញាដែលកើតព្រមនឹងធម៌ជាគ្រឿងយឺតយូរទាំងនោះ ឈ្មោះថា **បបញ្ចសញ្ញា** ។ ចំណែកភាគ: កោដ្ឋាស: នៃសញ្ញាជាគ្រឿងយឺតយូរ ឈ្មោះថា ចំណែកនៃ សញ្ញាជាគ្រឿងយឺតយូរ ។ ពោលអំពីអត្ត បានដល់ កងកិលេស ដែលជាចំណែក នៃធម៌ជាគ្រឿងយឺតយូរនោះ។ ព្រមទាំងនិមិត្ត ។ ក៏ក្នុងទីនេះសំដៅថា សញ្ញា រមែងមានដោយបបញ្ចធម៌នោះ ជាហេតុដែលទូទៅដល់ចំណែកនោះ។ ។ សម ដូចពាក្យដែលលោកពោលទុកថា សេចក្តីពិត ចំណែកនៃបបញ្ចធម៌ មាន

សញ្ញាជាហេតុ ។ ការលះជាចំណែកនៃបបញ្ចធម៌ទាំងនោះ ។ អធិប្បាយថា កាត់កិលេសមានរាគៈជាដើម ដោយមគ្គនោះៗបានដាច់ខាត ។

បានឮថា ក្នុងកាលនោះ ព្រះដ៏មានព្រះភាគទ្រង់ពិចារណាកិលេសដែលជាហេតុនៃសេចក្ដីវិនាសក្នុងអតីតជាតិរបស់ព្រះអង្គ ដែលរាប់ច្រើនសែនកោដិ ដែលទ្រង់លះបាន ព្រមទាំងវាសនាត្រង់ពោធិមណ្ឌល ជាទីថ្វាយផ្ទរផង់នៃពោធិញ្ញាណដោយអរិយមគ្គ ក្នុងភពចុងបង្ស្ន់ស់នេះ និងទ្រង់ឃើញសន្ដានរបស់សត្វដែលប្រៀបទៅដោយកិលេសសៅហ្មង ទៅដោយកិលេសមានរាគៈជាដើមដែលដោះបានយ៉ាងលំបាក ដូចត្រឡោកឃ្លោកដែលពេញទៅដោយទឹកបាយ ដូចកាជនៈដែលពេញទៅដោយខ្ទះធ្ងឹងគោ និងដូចកំណាត់សំពត់ចាស់ដែលជោគដោយប្រេងរាវ ទើបទ្រង់កើតបីតិបាមោជ្ជៈឡើងថា កិលេសវដ្ដៈនេះ ឈ្មោះថា ជារុក្ខជាតិយ៉ាងនេះ ដែលកើតឡើងរហូតដល់អស់កាលរកខាងដើមមិនបាន តថាគតលះបានហើយដោយដាច់ខាត តថាគតលះហើយដោយល្អ គួរអស្ចារ្យ ទើបទ្រង់បន្ទឺឧទាននេះ ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ជ្រាបការលះចំណែកនៃសញ្ញា ដែលជាធម៌គ្រឿងយឺតយូរ ហើយទើបទ្រង់បន្ទឺឧទាននេះក្នុងវេលានោះ ។

បណ្ដាបទទាំងនោះ បទថា **យស្ស** **បបញ្ចា ជិតិ ឧត្ថ** សេចក្ដីថា ព្រោះហេតុដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងចេញចំពោះព្រះអង្គ ឱ្យដូចអ្នកដទៃដូច្នោះ អគ្គបុគ្គលណា មិនមានធម៌ជាគ្រឿងយឺតយូរ ដែលមានលក្ខណៈ ដូចពោលហើយ និងមិនមានសេចក្ដីតាំងចិត្ដនៅក្នុងសង្ខារដែលបបញ្ចធម៌ទាំង-

នោះសាងឡើង ។ តែក្នុងនេត្តិ[1]លោកពោលទុកថា **អនុស័យ** *ឈ្មោះថា* **ឋិតិ** *។ មែនពិត អនុស័យ ក៏ជាឫសរបស់ការកើតក្នុងភព ។ បាលីថា* **សត្តេ សំសារេ បបញ្ចេន្តិ**[2] *និងថា* **បបញ្ចដ្ឋិតិ** *ដូច្នេះក៏មាន ។ បាលីនោះមានអធិប្បាយដូច្នេះ ការតាំងនៅ គឺសេចក្តីនៃបបញ្ចធម៌នូវប្រាកដ បានដល់ នូវកាត់មិនជាប់ដោយមគ្គ ឈ្មោះថា* **បបញ្ចដ្ឋិតិ** *។ ម្យ៉ាងទៀត សេចក្តីតាំងនៅនៃវដ្ត: ដោយជាហេតុនៃការកើតឡើងនៃកុសល អកុសល និងវិបាកដែលនៅសល់ គឺបបបញ្ចធម៌ ឈ្មោះថា* **បបញ្ចដ្ឋិតិ** *។* **បបញ្ចដ្ឋិតិ** *នោះ មិនមានដល់អគ្គបុគ្គលណា ។ បទថា* **សន្ធានំ បលិឃញ្ច រីតិត្តោ** *សេចក្តីថា បុគ្គលណា ឈានកន្ទងតណ្ហា និងទិដ្ឋិ ដែលមានឈ្មោះថា* **សន្ធានៈ** *ព្រោះជាទី-ត ព្រោះអត្តថា ជាគ្រឿងចង និងឈានកន្ទងអវិជ្ជា ពោលគឺ សន្ធ: ព្រោះដូចជាសន្ធ: ព្រោះជំទាស់នឹងការចូលទៅកាន់នគរ គឺព្រះនិព្វាន គឺឈានកន្ទងដោយពិសេស ដោយការលះកិលេសព្រមទាំងវាសនា ។ តែអាចារ្យមួយពួកទៀតពោលសេចក្តីក្រោធថា* **សន្ធានៈ** *។ ពាក្យនោះមិនគួរកាន់យក ។ ក៏* **ឋិតិ** *នោះ លោកហៅថា ធ្វើហេតុឱ្យបុគ្គលដទៃជាប់ជំពាក់ ។*

---

*១-គម្ពីរឈ្មោះ**នេត្តិ** ឬក៏**នេត្តិប្បករណបាលី** ដែលបានតែងឡើងដោយព្រះមហាកច្ចាយន:ដ៏មានអាយុ និងបានរាប់បញ្ចូលក្នុងការសង្គាយនាផង ។ គម្ពីរនេះ មានអដ្ឋកថារបស់ខ្លួនឈ្មោះ **នេត្តិប្បករ-ណដ្ឋកថា** និងមានដីកាដែលពន្យល់គម្ពីរនេះឈ្មោះ **លីនត្ថវណ្ណនា** ដែលតែងដោយព្រះធម្ម-បាលត្ថេរ ព្រមទាំងមានដីកាមួយទៀត ដែលពន្យល់សេចក្តីនេះ ឈ្មោះ **នេត្តិវិភាវនីដីកា** ។*

*២-**បបញ្ចន្តិ សំសារេ ចិរំ ឋបេន្តីតិ បបញ្ចា** ប្រែថា ធម្មជាតិ ធ្វើឱ្យយឺតយូរ គឺឱ្យតាំងនៅក្នុងសង្សារវដ្ត ធម្មជាតិនោះឈ្មោះថា **បបញ្ចធម៌** ។ (ស្រង់ចាកគម្ពីរនេត្តិប្បករណដ្ឋកថា)*

បទថា **តំ ជិត្តណ្ហា មុនឺ ចរន្តំ** *សេចក្តីថា ព្រះអរិយបុគ្គលនោះ ឈ្មោះថា អ្នកប្រាសចាកតណ្ហា ព្រោះមិនមានតណ្ហាសូម្បីដោយប្រការទាំងពួង ឈ្មោះថា* **មុនី** *ព្រោះដឹងលោកទាំងពីរ និងដឹងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ឈ្មោះថា អ្នកត្រាច់ទៅដោយឥរិយាបថ ៤ ដោយការញ៉ាំងសមាបត្តិផ្សេងៗ ឱ្យត្រាច់ទៅ និងដោយការញ៉ាំងញាណ ដែលមិនទូទៅមុនញាណដទៃ ត្រាច់ទៅដើម្បីប្រយោជន៍អ្នកដទៃ ឈ្មោះថា អ្នកត្រាច់ទៅដោយឥរិយាបថ ៤ ដោយការញ៉ាំងសមាបត្តិផ្សេងៗ ឱ្យត្រាច់ទៅ និងដោយការញ៉ាំងញាណដែលមិនទូទៅដល់ញាណដទៃឱ្យត្រាច់ទៅ ដើម្បីប្រយោជន៍ដល់សត្វទាំងឡាយទាំងពួង ដោយចំណែកតែមួយនុ៎ះឯង ។ បទថា* **ជាវជាតិ សទេវកោ បិ លោកោ** *សេចក្តីថា សត្វលោក ដែលកើតមកដោយបញ្ញារបស់ខ្លួន ព្រមទាំងទេវលោក ព្រមទាំងព្រហ្ម សូម្បីក្នុងកាលណាៗ ក៏មិនដឹង មិនបានសោយ ដោយដែលពិតធ្វើឱ្យធ្ងន់ សូម្បីត្រេកអរក្នុងការបូជាសក្ការៈដោយគោរពថា អ្នកនេះប៉ុណ្ណោះ ជាអ្នកកំពូល ប្រសើរ ខ្ពង់ខ្ពស់ ក្រៃលែងក្នុងលោកដូច្នេះ ។*

សត្តមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៧

៨. មហាកច្ចាយនសុត្តវណ្ណនា

អដ្ឋកថាមហាកច្ចាយនសូត្រ

មហាកច្ចានសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ

អជ្ឈត្ត-*ស័ព្ទនេះ ក្នុងបទថា* **អជ្ឈត្តំ** *នេះ មកក្នុងអត្ថថា កើតខាងក្នុង ប្រយោគមានជាអាទ៍ថា អាយតនៈខាងក្នុង ៦ ដូច្នេះ ។ មកក្នុងអត្ថថា កើតក្នុងខ្លួន ក្នុងប្រយោគមានជាអាទ៍ថា ធម៌ទាំងឡាយកើតក្នុងខ្លួន ឬឃើញកាយក្នុងកាយក្នុងខ្លួន ។ មកក្នុងអត្ថថា ជាខាងក្នុងនៃអារម្មណ៍ ក្នុងប្រយោគមានជាអាទ៍ថា ព្រោះមិនមនសិការដល់និមិត្តទាំងពួង ភិក្ខុចូលដល់សុតៈដែលជាខាងក្នុង អធិប្បាយថា ក្នុងកាពជាធំ ។ មែនពិត ផលសមាបត្តិ ឈ្មោះថា ជាឋានៈដ៏ធំ របស់ព្រះពុទ្ធទាំងឡាយ ។ មកក្នុងអត្ថថា ជាខាងក្នុងនៃគោចរក្នុងប្រយោគ មានជាអាទ៍ថា ម្នាលអានន្ទ ភិក្ខុនោះ គប្បីតាំងចិត្តទុកដោយល្អចំពោះខាងក្នុង សមាធិនិមិត្ត ដែលជាខាងដើមនេះប៉ុណ្ណោះ ។ សូម្បីក្នុងទីនេះ លោកគប្បីឃើញថា មកក្នុងអត្ថថាមានគោចរជាខាងក្នុងនុ៎ះឯង ។ ព្រោះដូច្នោះ លោកទើបពោលថា បទថា* **អជ្ឈត្តំ** *បានដល់ ក្នុងអារម្មណ៍កម្មដ្ឋាន ដែលជាអារម្មណ៍ខាងក្នុង ។ បទថា* **បរិមុ១ំ** *ប្រែថា ត្រង់មុខ ។ បទថា* **សុបដ្ឋិតាយ** *បានដល់ មានសតិទៅក្នុងកាយដែលតាំងមាំដោយល្អ ។ ក៏ក្នុងទីនេះ លោកពោលដល់ឈានដោយលើកសតិឡើងជាប្រធាន ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះថា ភិក្ខុចូលឈានដែលជាខាងក្នុង គឺដែលក្រៃលែងដែលខ្លួនបាន ដោយកាយានុ-*

បស្សនាសតិប្ឋាន ។

បានឮមកថា ព្រះថេរៈនេះ កាលព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងក្រុងសាវត្ថី ថ្ងៃមួយ ត្រាច់បិណ្ឌបាតក្នុងក្រុងសាវត្ថី ត្រឡប់ពីបិណ្ឌបាត ជាអ្នកមានកត្តកិច្ចសម្រេចហើយ ចូលទៅកាន់វិហារ សម្តែងវត្តចំពោះព្រះដ៏មានព្រះភាគ អង្គុយសម្រាកក្នុងទីសម្រាកពេលថ្ងៃ ញ៉ាំងចំណែកនៃថ្ងៃឱ្យប្រព្រឹត្តទៅដោយសមាបត្តិផ្សេងៗ ក្នុងវេលាល្ងាច ទៅកាន់កណ្តាលវិហារ កាលព្រះដ៏មានព្រះភាគប្រថាប់គង់ក្នុងព្រះគន្ធកុដិ ព្រះថេរៈទើបគិតថា នេះមិនមែនវេលាដែលនឹងគាល់ព្រះដ៏មានព្រះភាគទេ កំណត់វេលាហើយអង្គុយចូលសមាបត្តិដូចពោលហើយ ត្រង់គល់ឈើមួយកន្លែងមិនឆ្ងាយពីព្រះគន្ធកុដិ ។ ព្រះសាស្តាប្រថាប់គង់ក្នុងព្រះគន្ធកុដិនុ៎ះឯង ទតព្រះនេត្រឃើញព្រះថេរៈអង្គុយនៅយ៉ាងនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា **តេន ខោ បន សមយេន អាយស្មា មហាកច្ចាយនោ** ។បេ។ **សុបដ្ឋិតាយ** ដូច្នេះជាដើម ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួង ដល់ការដែលព្រះមហាកច្ចានត្ថេរ ចូលឈានដែលខ្ជួនសម្រេចដោយសតិប្ឋានភាវនាឱ្យជាបាទហើយ ទើបទ្រង់បន្ទឹឧទាននេះ ដែលសម្តែងដល់សេចក្តីនោះ ។

បណ្តាបទទាំងនោះ *បទថា* **យស្ស សិយា សព្វថា សតិ សតតំ កាយគតា ឧបដ្ឋិតា** *សេចក្តីថា* *សតិដែលទៅហើយក្នុងកាយទាំងពីរយ៉ាង ដោយសេចក្តីផ្សេងនៃនាម និងរូប គឺមានកាយជាអារម្មណ៍ គប្បីជាគុណជាតិដែលតិក្ខណា* *អ្នកផ្តើមបំពេញវិបស្សនា* *តម្រង់ទុកដោយអំណាចសេចក្តីព្យាយាមដែលប្រព្រឹត្តទៅជាប់រឿយៗ* *មិនដាច់រយៈ* *ដោយពិចារណាលក្ខណៈ* *មានអនិច្ចលក្ខណៈជាដើម* *នៃឧបាទានខន្ធ ៥ ក្នុងកាលទាំងអស់* *ដោយបែងចែកថ្ងៃមួយចេញជា ៦ ចំណែក ។*

បានឮមកថា *ព្រះមហាកច្ចានៈអង្គនេះ* *ញ៉ាំងឈានឱ្យកើត* *ដោយកាយ-គតាសតិកម្មដ្ឋានមុន* *ហើយធ្វើឈាននោះឱ្យជាបាទ* *ផ្តើមតាំងវិបស្សនាដោយមុខ* *គឺកាយានុបស្សនាសតិប្បដ្ឋាន* *ហើយសម្រេចព្រះអរហត្ត ។* *ក្នុងកាលជាខាងក្រោយមក* *ដោយច្រើន* *ព្រះថេរៈចូលឈាននោះឯង* *ចេញហើយពិចារណាឃើញដោយប្រការនោះនុ៎ះឯង* *ហើយចូលផលសមាបត្តិ ។* *ព្រះសាស្តា* *កាលទ្រង់សម្តែងវិធីដែលជាហេតុឱ្យលោកសម្រេចព្រះអរហត្ត* *ទើបត្រាស់ថា* *អ្នកដែលមានសតិក្នុងកាលគ្រប់កាល* *គប្បីតាំងកាយគតាសតិទុកជាប់តគ្នា* *ដើម្បីនឹងឱ្យអាការដែលកាយគតាសតិនោះប្រាកដជាក់ច្បាស់* *ទើបត្រាស់ថា* *កិលេស-កម្មដែលរួចផុតពីខន្ធបញ្ចកៈមិនគប្បីមាន* *កិលេសកម្មដែលឈ្មោះថា* *ជារបស់យើង* *មិនគប្បីមាន* *កិលេសកម្ម* *ដែលឈ្មោះថា* *ខ្លួនដែលរួចផុតពីខន្ធនឹងមិន*

មាន និងកិលេសកម្មដែលជាប់ក្នុងខ្លួន នឹងមិនមានដល់យើង ដូច្នេះ ។

សេចក្ដីនោះ កាលពោលអំពីការពិចារណា គប្បីជ្រាបជា ២ ចំណែក គឺដោយចំណែកខាងដើម ១ ដោយខណៈពិចារណា ១ ។ បណ្ដាចំណែកទាំង ២ យ៉ាងនោះ គប្បីជ្រាបដោយចំណែកខាងដើមមុន ។ បទថា **ININININ ININININ** សេចក្ដីថា បើថា ក្នុងអតីតកាល កិលេសកម្មរបស់យើងមិនគប្បីមាន ក្នុងកាលដែលជាបច្ចុប្បន្ននេះ អត្តភាពនេះ នឹងមិនគប្បីមានដល់យើង គឺមិនគប្បីកើតដល់យើង ។ ក៏ព្រោះហេតុដែលកម្ម និងកិលេសមានដល់យើង ក្នុងអតីតកាល ព្រោះដូច្នោះ អត្តភាពរបស់យើងក្នុងឥឡូវនេះ ដែលមានកម្មកិលេសនោះជាគ្រឿងសម្គាល់រមែងប្រព្រឹត្តទៅ ។ បទថា **ININININININININININ** សេចក្ដីថា ក្នុងអត្តភាពនេះ ព្រោះប្រាសចាកពីធម៌ដែលជាបដិបក្ខនោះ និងកម្មកិលេស នឹងមិនមាន គឺនឹងមិនកើតដល់យើង និងវិបាកវដ្ដៈក្នុងអនាគត នឹងមិនមាន គឺនឹងមិនកើតដល់យើង ។ ក្នុងកាលទាំង ៣ ដូចពោលមកហើយនេះ ខន្ធបញ្ចកៈ គឺអត្តភាពរបស់យើងនេះ ដែលមានកម្មកិលេសជាហេតុ មិនមែនមានភាពធំដ៏ក្រៃលែងជាដើមជាហេតុ ជាការដែលលោកប្រកាសដល់ការឃើញនាម និងរូបព្រមទាំងបច្ច័យថា របស់យើងយ៉ាងណា របស់សត្វទាំងពួងក៏ដូច្នោះ ។ តែកាលពោលអំពីវេលាពិចារណា គប្បីជ្រាបសេចក្ដីដូចតទៅនេះ ។

បទថា **ជោចស្ស ជោ ច មេ សិយា** *សេចក្ដីថា ព្រោះហេតុដែលបញ្ចខន្ធនេះ ឈ្មោះថា មិនទៀង ព្រោះមានហើយត្រឡប់ជាមិនមាន ឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា បៀតបៀនរឿយៗ ឈ្មោះថា* ***អនត្តា*** *ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាចកាលជាយ៉ាងនោះ សភាវៈខ្លះដែលឈ្មោះថា អត្តានេះ ដែលរួចផុតពីខន្ធបញ្ចកៈក៏មិនមាន គឺមិនគប្បីមាន មិនគប្បីកើត កាលបើដូច្នោះ ខន្ធបញ្ចកៈខ្លះ ដែលឈ្មោះថា ជារបស់យើងមិនគប្បីមានដល់យើង មិនគប្បីកើតដល់យើង ។ បទថា* **ន ភវិស្សតិ** *បានដល់ កាលអត្តាមាន វត្ថុដែលកើតក្នុងខ្លួនក៏គប្បីមាន មែនពិត ដូចនាមរូបនេះ ដែលកើតក្នុងខ្លួន នឹងក្នុងបច្ចុប្បន្ន និងក្នុងអតីត យ៉ាងណា សភាវៈអ្វីៗ ដែលឈ្មោះថា ជាអត្តា ដែលរួចផុតពីខន្ធក៏ដូច្នោះ នឹងមិនមាន នឹងមិនកើតដល់យើង គឺនឹងមិនមាន នឹងមិនកើតដល់យើងក្នុងអនាគត តពីនោះឯង ខន្ធបញ្ចកៈនេះណានីមួយ ដែលជាទីតាំងនៃសេចក្ដីកង្វល់ នឹងមិនមានដល់យើង គឺធម្មជាតិណានីមួយ ដែលកើតក្នុងខ្លួន នឹងមិនមានដល់យើង សូម្បីក្នុងអនាគត ។ ដោយពាក្យនេះ ព្រះអង្គសម្ដែងដល់ការមិនមានវត្ថុដែលនឹងគប្បីប្រកាន់ថា យើង និងនឹងគប្បីប្រកាន់ថា របស់យើង ព្រោះមិនមានក្នុង ៣ កាល ។ ដោយពាក្យនោះជាការទ្រង់ប្រកាសសុញ្ញតា ២ ។*

បទថា **អនុបព្ជវិហារី ឥត្ថ សោ** *សេចក្ដីថា កាលព្រះយោគាវចរឃើញតាមលំដាប់ ជារបស់សូន្យដែលមានក្នុងខ្លួន ក្នុងសង្ខារនោះ ក្នុងកាល*

ទាំង ៣ ដូចពណ៌នាមកដូច្នេះ កាលវិបស្សនាញាណ មានឧទយព្វយញ្ញាណ ជាដើម កើតឡើងដោយលំដាប់ ឈ្មោះថា អ្នកមានធម៌ជាគ្រឿងនៅដោយ លំដាប់ ដោយអនុបុព្វវិបស្សនាវិហារធម៌ ។ បទថា **ការ**ណេ**ន** ត**េ** **ិ**ស**ត្ត**ិ**ក**ំ សេចក្ដីថា ព្រះយោគាវចរនោះ គឺញ៉ាំងវិបស្សនាឱ្យដល់ទីបំផុត តាំងនៅយ៉ាង នេះ ឈ្មោះថា គប្បីធ្វើតណ្ហា ពោលគឺ តណ្ហាដែលជ្រួតជ្រាបទៅក្នុងអារម្មណ៍ ផ្សេងៗ ព្រោះបន្តវដ្ដ:ទាំង ៣ ដោយវេលាដែលដល់ភាពចាស់ក្លា ដោយវេលា ដែលវុដ្ឋានគាមិនីវិបស្សនាបន្តដោយមគ្គ និងដោយវេលាដែលអរិយមគ្គកើត ឡើង អធិប្បាយថា គប្បីធ្វើទៅតាំងនៅក្នុងត្រើយឯណោះនៃតណ្ហានោះ ។

ព្រះដ៏មានព្រះភាគ ទ្រង់បន្ទឹមឧទានដែលសម្ដែងដល់ការដែលព្រះមហា-កច្ចាន:សម្រេចព្រះអរហត្ត ដោយអាងដល់ព្រះអរហត្តផល ដោយប្រការដូច្នេះ ។

អដ្ឋមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៨

៩. ឧជ្ជាយសុត្តវណ្ណនា

អដ្ឋកថាឧជ្ជាយសូត្រ

ឧទ្ទានសូត្រទី ៩ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **មលេ្យសុ** *សេចក្តីថា ជនបទ សូម្បីជនបទមួយ ដែលជាទីនៅ*
របស់ព្រះរាជកុមារអ្នកជនបទនាមថា **មលៃ្ជ:** *គេហៅថា* **មលៃ្ជ:** *ដោយសន្ធឹក-*
សន្ធាប់ក្នុងមលៃ្ជជនបទ ត្រង់ផ្លូវលោកហៅថា **មលៃ្ជ:** *នោះ ។ តែអាចារ្យពួកខ្លះ*
ពោលថា **មាលេសុ** *។ បទថា* **ចារិកញ្ចរមានោ** *បានដល់ ព្រះដ៏មានព្រះភាគ*
ចារិកទៅក្នុងជនបទ ទីប្រជុំជនធំ ដោយព្រះអង្គចារិកទៅមិនប្រញាប់ប្រញាល់ ។
បទថា **មហតា ភិក្ខុសង្ឃេន** *បានដល់ ក្រុមនៃសមណៈដ៏ច្រើន ដែល*
កំណត់ចំនួនមិនបាន ។ មែនពិត ក្នុងកាលនោះ ព្រះដ៏មានព្រះភាគហែហមទៅ
ដោយភិក្ខុដ៏ច្រើន ។ បទថា **ថូនំ នាម មលៃ្ជនំ ព្រាហ្មណគាមោ** *បានដល់*
ស្រុកព្រាហ្មណ៍ ព្រោះមានព្រាហ្មណ៍ច្រើន ដែលមានឈ្មោះថា **ថូនៃ:** *ក្នុង*
មលៃ្ជប្រទេស ដែលជាទីតាំងនៃមជ្ឈិមប្រទេស ក្នុងទិសអាគ្នេយ៍ ។ បទថា **តទវ-**
សរិ *កាត់បទជា* **តំ អវសរិ** *ស្តេចទៅកាន់ស្រុកព្រាហ្មណ៍នោះ ។ អធិប្បាយថា*
ព្រះអង្គយាងទៅថូនគ្រាម ។

បទថា **អស្សោសុំ** *ប្រែថា បានស្តាប់ហើយ អធិប្បាយថា ដឹងដោយ*
ក្រសៃសំឡេងឃោសនាដែលមកប៉ះខ្ទប់សោតទ្វារ ។ បទថា **ខោ** *ជានិបាតប្រើ*

ក្នុងអត្ថថា ធ្វើបទឱ្យពេញ ឬប្រើក្នុងអត្ថថា អវធារណៈ ហាមសេចក្ដីដទៃ ។ បណ្ដាអត្ថទាំង ២ យ៉ាងនោះ ដោយ **ខោ**-ស័ព្ទ ដែលមានអវធារណៈជាអត្ថ ប្រែថា បានស្ដាប់ហើយ អធិប្បាយថា ព្រាហ្មណ៍ និងគហបតីអ្នកជូនគ្រាម មិនមានអន្ដរាយចំពោះការទៅ ។ ដោយ **ខោ**-ស័ព្ទដែលមានបទបូរណៈជាអត្ថ ត្រឹមតែជាបទ និងព្យញ្ជនៈស្អាតរៀបរយប៉ុណ្ណោះ ។ បទថា **ជូនេយ្យកា** ប្រែថា ជនអ្នកជូនគ្រាម ។ ក្នុងបទថា **ព្រាហ្មណគហបតិកា** នេះ មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា ព្រាហ្មណ៍ ព្រោះពោលពាក្យដ៏ប្រសើរ អធិប្បាយថា ស្វាធ្យាយមន្ត ។ មែនពិត បទថា **ព្រាហ្មណា** នេះ ជាវោចនៈរបស់ព្រាហ្មណ៍ដោយកំណើត ចំណែកព្រះអរិយៈទាំងឡាយ លោកក៏ហៅថា **ព្រាហ្មណ៍** ព្រោះជាអ្នកមានបាបបានបន្សាត់បង់ហើយ ។ ជនអ្នកគ្រប់គ្រងផ្ទះណាមួយ រៀរក្សត្រ និងព្រាហ្មណ៍ លោកហៅថា **គហបតី** ។ តែកាលពោលដោយពិសេសគេហៅថា **វេស្សៈ** ។ ព្រាហ្មណ៍ និងគហបតីហៅថា ព្រាហ្មណ-គហបតី ។

ឥឡូវនេះ ដើម្បីនឹងប្រកាសសេចក្ដីដែលព្រាហ្មណ៍ និងគហបតីទាំងនោះ បានស្ដាប់ (ដំណឹង) លោកទើបពោលថា **សមណោ ខលុ ភោ គោតមោ** ជ្ជ ជ្ជ ។ ក្នុងពាក្យថា **សមណោ ខលុ ភោ គោតមោ** នោះ ព្រះដ៏-

មានព្រះភាគ បណ្ឌិតគប្បីជ្រាបថា **សមណៈ** *ព្រោះសូប់បាប ។ សមដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា អកុសលធម៌ទាំងឡាយដ៏លាមក... ភិក្ខុនោះបានរំងាប់ហើយ[1] ដូច្នេះ ជាដើម ។ ក៏ព្រះដ៏មានព្រះភាគ ជាអ្នកសូប់បាបហើយ ដោយប្រការទាំងពួងដោយព្រះអរិយមគ្គដ៏កំពូល ព្រោះព្រះអង្គ ទ្រង់សម្រេចគុណតាមសេចក្តីពិត ទើបមានព្រះនាមថា* **សមណៈ** *។ បទថា* **ខលុ** *ជានិបាតប្រើក្នុងអនុស្សវនត្ថៈ ។ បទថា* **ភោ** *ត្រឹមតែជាពាក្យហៅដែលកើតមកពីកំណើតនៃជនដែលមានជាតិព្រាហ្មណ៍ ។ សមដូចពាក្យដែលព្រះដ៏មាន-ព្រះភាគទុកថា បុគ្គលនោះគ្រាន់តែបាននាមថា* **ភោវាទី** *(អ្នកពោលថាចម្រើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេស គ្រឿងកង្វល់នៅឡើយ[2] ។ បទថា* **គោតមោ** *ជាបទប្រកាសដល់ព្រះដ៏មានព្រះភាគដោយព្រះគោត្រ ព្រោះដូច្នោះ ក្នុងពាក្យថា* **សមណោ ខលុ ភោ គោតមោ** *នេះ មានអត្ថដូច្នេះថា បានឮថា ព្រះសមណៈ មានគោតមគោត្រដ៏ចម្រើន ។ ក៏បទថា* **សក្យបុត្តោ** *នេះ ជាបទសម្តែងដល់ការៈដែលព្រះដ៏មានព្រះភាគមានត្រកូលខ្ពស់ ។ បទថា* **សក្យកុ-លា បព្វជិតោ** *ជាបទសម្តែងដល់ការៈដែលព្រះដ៏មានព្រះភាគ ទ្រង់សាង*

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ២២១ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លេខ ៥២ ទំព័រ ១០៥ ។

ព្រះផ្ទួសដោយសទ្ធា ។ លោកអធិប្បាយទុកថា ព្រះអង្គមិនមានសេចក្តីសាបសូន្យអ្វីៗ មកគ្របសង្កត់ ទ្រង់លះត្រកូលដែលមិនមានសេចក្តីសាបសូន្យនោះឯង ទ្រង់សាងព្រះផ្ទួសដោយសទ្ធា ក្នុងការសម្រេចដោយការសាងមហាកិនេស្ត្រម៍ ។ បទថា **ឧឧចានំ តិណាសួ ច កុសសួ ច យាវ មុ១តោ ឫ១ សេ** សេចក្តីថា យកស្មៅ និងអង្ការមលុបអណ្តូងទឹកឱ្យពេញដរាបត្រឹមមាត់អណ្តូង អធិប្បាយថា ដាក់ស្មៅជាដើម ចូលទៅហើយបិទអណ្តូង ។

បានឮថា ស្រុកនោះមានអណ្តូងទឹកមួយ ជាទីប្រើប្រាស់របស់ពួកព្រាហ្មណ៍ ជិតផ្លូវជាទីដែលព្រះដ៏មានព្រះភាគព្រះអង្គយាងមក ខាងក្រៅ ។ ទីកន្លែងមានអណ្តូងទឹក និងបឹងជាដើម គ្រប់កន្លែងក្នុងទីនោះ រៀរអណ្តូងទឹកនោះ ក្នុងគ្រានោះបានរីងស្ងួត មិនមានទឹកឡើយ ។ គ្រានោះ អ្នកជូនគ្រាមមិនទាន់ជ្រះថ្លាក្នុងព្រះរតនត្រ័យ ត្រូវសេចក្តីកំណាញ់គ្របសង្កត់ ជ្រាបថា ព្រះដ៏-មានព្រះភាគ ព្រះអង្គយាងមក នាំគ្នាគិតថា បើព្រះសមណគោតម និងសាវ១ គប្បីចូលទៅកាន់ស្រុកនេះ សម្រាកនៅក្នុងស្រុកនេះ ២-៣ ថ្ងៃ នឹងធ្វើឱ្យជនទាំងអស់នេះតាំងនៅក្នុងពាក្យរបស់ខ្លួន តអំពីនោះ ធម៌របស់ព្រាហ្មណ៍ ក៏នឹងតាំងនៅមិនបាន ក៏ព្យាយាមដើម្បីនឹងមិនឱ្យព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងទីនោះបាន ទើបប្រឹក្សាព្រមគ្នាថា ក្នុងស្រុកនេះ មិនមានទឹកទេ ពួកយើងនឹង

ធ្វើអណ្តូងទឹកឯណោះ ឱ្យជាទីប្រើប្រាស់មិនកើត កាលបើដូច្នេះ ព្រះសមណ-គោតមព្រមដោយសាវក នឹងមិនចូលស្រុកនេះ ដូច្នេះហើយ ទើបឱ្យពួកអ្នកស្រុកទាំងអស់ដងទឹករហូតដល់អស់ ៧ ថ្ងៃ ដាក់ពាងឱ្យពេញជាដើម ហើយយកស្មៅ និងអង្ករមលុបអណ្តូងទឹកនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ក៏នាំគ្នាយកស្មៅ និងអង្ករមចាក់បំពេញអណ្តូងដរាបដល់មាត់ ដោយគិតថា កុំឱ្យសមណ:ត្រដោលទាំងនោះផឹកទឹកបាន ។

បណ្តាបទទាំងនោះ បទថា **មុណ្ហាកា សមណា** សេចក្តីថា គួរនឹងពោលអ្នកត្រដោលថា អ្នកត្រដោល និងពោលសមណ:ថា សមណ: តែជនទាំងនោះនាំគ្នាមើលងាយដោយសេចក្តីប្រាថ្នាគំរាម ទើបបានពោលយ៉ាងនោះ ។ បទថា **មា** ប្រើក្នុងអត្ថបដិសេធ ។ អធិប្បាយថា កុំផ្ងូត កុំផឹក ។ បទថា **មក្ខ ិ ក្ខ ិ ម្ម** ប្រែថា ជៀសចេញពីផ្ទ្ រ ។ បទថា **ឯ ត្ត ម្ ហ** បានដល់ ពោលសម្តែងចេញចំពោះអណ្តូងទឹកដែលជនទាំងនោះធ្វើយ៉ាងនោះប៉ុណ្ណោះ ។

សួរថា ក៏ព្រះដ៏មានព្រះភាគ មិនទ្រង់ដល់អាការប្ញែករបស់ពួកព្រាហ្មណ៍ទាំងនោះទេឬ ទើបត្រាស់យ៉ាងនេះថា អ្នកទាំងឡាយនាំទឹកពីអណ្តូងនេះមក ឬថាទ្រង់នឹកដល់ហើយទើបដឹង ឆ្ងើយថា ទាំងដែលទ្រង់ដឹងនុ៎ះឯង ព្រះដ៏មាន-ព្រះភាគ នឹងទ្រង់ប្រកាសពុទ្ធានុភាពរបស់ព្រះអង្គ ទូន្មានព្រាហ្មណ៍ទាំងនោះ

ដើម្បីនឹងធ្វើពួកគេឱ្យអស់អស្មិមានៈ ទើបត្រាស់យ៉ាងនោះ មិនមានប្រាជ្ញានឹងធាន់ទឹកទេ ព្រោះហេតុនោះឯង ក្នុងទីនេះព្រះអង្គមិនត្រាស់ថា តថាគតហេ-ហត់ដូចក្នុងមហាបរិនិព្វានសូត្រទេ ។ ក៏ព្រះធម្មកណ្ណាគារិក កាលមិនដឹងព្រះអធ្យាស្ស័យរបស់ព្រះសាស្តា កាលនឹងក្រាបទូលអាការដែលប្លែក ដែលអ្នកជួនគ្រាមធ្វើ ទើបក្រាបទូលថា **ឥមានិ សោ ភន្តេ** ដូច្នេះជាដើម ។

បណ្តាបទពួកនោះ បទថា **ឥមានិ** ប្រែថា ក្នុងឥឡូវនេះ អធិប្បាយថា ក្នុងវេលាដែលពួកខ្ញុំព្រះអង្គមកដល់ន៏ុះឯង ។ អាចារ្យពួកខ្លះពោលថា **ឯសោ ភន្តេ ឧទចាលោ** បពិត្រព្រះអង្គដ៏ចម្រើន នោះអណ្តូងទឹក ។ ព្រះថេរៈទូលហាមដល់ ២ លើក ក្នុងលើកទី ៣ ទើបគិតថា ព្រះតថាគតទាំងឡាយ គឺបុគ្គលមិនគប្បីបដិសេធនឹងព្រះអង្គ ៣ ដងនោះទេ ព្រះអង្គអ្នកទ្រង់ឃើញ កាលវែងនឹងជាការទ្រង់ឃើញហេតុដូច្នេះហើយ ទើបកាន់បាត្ររបស់ព្រះដ៏មានព្រះភាគដែលស្តេចមហារាជទាំង ៤ ថ្វាយ ហើយបានទៅកាន់អណ្តូងទឹក ។ កាលព្រះថេរៈកំពុងដើរទៅ ទឹកក្នុងអណ្តូងក៏បរិបូណ៌ ហៀរឡើង ហូរទៅជុំវិញៗ ។ ស្មៅ និងអង្ករទាំងអស់អណ្តែតចេញឯងៗ តែម្តង ។ ក៏កាលទឹកដែលហូរទៅនោះ ហៀរឡើងខាងលើជណ្ណាល័យ មានស្រះបោក្ខរណីជាដើម ទាំងអស់ក្នុងស្រុកនោះ ដែលរីងស្ងួតក៏ត្រឡប់ជាមានទឹកបរិបូណ៌វិញ ប្រឡាយ បឹង និងទឹកនទ្ទីកជាដើម

ក៏ដូចគ្នា ។ ផ្ទៃស្រុកទាំងមូលត្រូវអន្ទង់ទឹកធំលិចមសង្កត់បាន ដូចជាក្នុងវេលាភ្លៀងធ្លាក់ច្រើន ។ បុប្ផវារីជាតិទាំងឡាយ ដែលកើតក្នុងទឹកមានផ្កាកុមុទ ឧប្បលបទុម និងផ្កាបុណ្ឌរីក:ជាដើម ផុសឡើងក្នុងជលាល័យនោះ។ រីកស្គុះស្គាយ ។ បក្សីទឹកទាំងឡាយ មានហង្ស សត្វក្រៀល សត្វចក្រពាក សត្វចង្រៀលខ្យង និងសត្វកុកជាដើម កាលភ្លៀងធ្លាក់ ក៏នាំគ្នាស្រែក ហើយហែលទៅក្នុងទីនោះ។ ។ អ្នកជូនគ្រាមឃើញអន្ទង់ទឹកធំនោះហៀរឡើង យ៉ាងនោះ រីវក់ទៅដោយរលកទឹកតូចធំដោយជុំវិញ ផុសឡើងជាពពុសទឹក តាំងនៅដោយជុំវិញ ក៏កើតភាពអស្ចារ្យក្នុងចិត្តមិនធ្លាប់មានមក ទើបប្រឹក្សាគ្នាយ៉ាងនេះថា ពួកយើងព្យាយាមដើម្បីនឹងឱ្យព្រះសមណគោតមដាច់ទឹក ក៏តាំងពីវេលាដែលព្រះសមណគោតមនោះស្តេចមក អន្ទង់ទឹកធំនេះក៏ក្រៃលែង បន្ថែមច្រើនឡើងដល់យ៉ាងនេះ ព្រះសមណគោតមមានឫទ្ធានុភាពដល់យ៉ាងនេះ មិនត្រូវសង្ស័យឡើយ ព្រោះព្រះសមណគោតមនោះមានឫទ្ធិច្រើន មានអានុភាពច្រើន ។ ក៏អន្ទង់ទឹកហៀរឡើងលិចស្រុករបស់យើង ។ ណ្ហើយចុះ ពួកយើងនឹងចូលទៅរក ចូលទៅអង្គុយជិតព្រះសមណគោតមសម្តែងទោស ហើយសូមខមាទោសដែលប្រព្រឹត្តកន្ទងចំពោះព្រះអង្គ ។

អ្នកជូនគ្រាមទាំងអស់ មានអធ្យាស្ស័យតែមួយ ជាពួកតែមួយ ចេញពីស្រុក ចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ។ ក៏កាលចូលទៅគាល់ហើយ អ្នកជូនគ្រាមខ្លះ ថ្វាយបង្គំព្រះយុគលបាទរបស់ព្រះដ៏មានព្រះភាគ ដោយសិរសា អ្នកជូនគ្រាមខ្លះ ផ្គងអញ្ជលី អ្នកជូលគ្រាមខ្លះ ពោលពាក្យ ប្រាស្ស័យនឹងព្រះដ៏មានព្រះភាគ អ្នកជូនគ្រាមខ្លះ ប្រកាសឈ្មោះ និងគោត្រ អ្នកជូនគ្រាមខ្លះ ក៏អង្គុយស្ងៀម ក៏គ្រាធ្លើយ៉ាងនេះហើយ ទើបអង្គុយក្នុងទីដ៏សមគួរមួយ អ្នកជូនគ្រាមទាំងអស់គ្នាសម្តែងទោសយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំទាំងឡាយ កាលធ្វើនូវការរវាំងទឹកចំពោះ ព្រះសមណ-គោតមដ៏ចម្រើនផង និងសាវ៖ករបស់ព្រះគោតមដ៏ចម្រើនផង បានយកស្មៅ និងអង្ករមចោលចុះក្នុងអណ្ណូងទឹកឯណោះ ។ ក៏អណ្ណូងទឹកនោះនឹងមិនមានចេតនា ក៏ដូចជាមានចេតនា ដូចជាដឹងគុណរបស់ព្រះគោតមដ៏ចម្រើន ធ្វើស្មៅ និងអង្ករមទាំងអស់ឱ្យហៀរចេញទៅដោយខ្លួនឯង កើតជាអណ្ណូងទឹកបរិសុទ្ធល្អ ក៏ក្នុងទីនេះស្ពានទឹកនុ្ទកទាំងអស់ពេញទៅដោយទឹកដ៏ច្រើន គួរ៖ីក-ពាយចិត្ត សត្វទាំងឡាយ នាំគ្នាអាស្ស័យទឹកនោះចិញ្ចឹមជីវិត នាំគ្នាត្រេកអរ តែពួកខ្ញុំព្រះអង្គ សូម្បីជាមនុស្ស ក៏មិនទាន់ដឹងគុណរបស់ព្រះសមណគោតមដ៏ចម្រើន ទើបបានធ្វើកម្មយ៉ាងនេះ ដូចជាខ្ញុំព្រះអង្គសូមវ៖ោកាស សូម

ព្រះសមណគោតមដ៏ចម្រើន ធ្វើអន្ទង់ទឹកធំនេះឱ្យស្រកពីស្រុកនេះ ដល់ពួកខ្ញុំ ព្រះអង្គចុះ សូមព្រះគោតមដ៏ចម្រើន អស់ទោសដែលកន្ទងល្មើស តាមដែល ពួកខ្ញុំព្រះអង្គកន្ទងលើស តាមសេចក្ដីលង់ខ្វៅ ដោយទ្រង់អាស្រ័យសេចក្ដី អនុគ្រោះ ។ ចំណែកព្រះដ៏មានព្រះភាគត្រាស់ថា ណ្ហើយចុះ តថាគតនឹង អត់ទោសដែលកន្ទងល្មើស ដែលអ្នកទាំងឡាយ កន្ទងល្មើសតាមសេចក្ដីលង់-ខ្វៅ ដើម្បីនឹងសង្រ្ដួមតទៅ ដូច្នេះហើយ ទើបទ្រង់អត់ទោសដែលជនទាំងនោះ កន្ទងល្មើស ទ្រង់ជ្រាបថា ជនទាំងនោះមានចិត្តជ្រះថ្លា ទើបទ្រង់សម្ដែងធម៌ តាមអធ្យាស្រ័យឱ្យក្រៃលែងឡើង ។ ជនទាំងនោះស្ដាប់ព្រះធម៌ទេសនារបស់ ព្រះដ៏មានព្រះភាគ ហើយមានចិត្តជ្រះថ្លាតាំងនៅក្នុងគុណធម៌ មានសរណៈ ជាដើម ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយធ្វើប្រទក្សិណ នាំគ្នាជៀសចេញទៅ ។ ក៏កាលជនទាំងឡាយនោះជៀសចេញទៅ ព្រះអានន្ទត្ថេរឃើញបាដិហារ្យនោះ កើតសេចក្ដីអស្ចារ្យក្នុងចិត្តដែលមិនធ្លាប់មាន យកបាត្រដងទឹក បង្ហោនចូលទៅ ថ្វាយព្រះដ៏មានព្រះភាគ ហើយក្រាបទូលរឿងនោះ ។ ព្រោះហេតុនោះ លោក ទើបពោលពាក្យមានជាអាទិ៍ថា **ឯវํ ภนฺเต តិ ខោ អាយสฺมา អานนฺโท** *ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **មุขโต ឱวมิตฺวา** *សេចក្ដីថា នាំយកស្មៅជា ដើមទាំងអស់នោះចេញពីមាត់អណ្ដូង ។ បទថា* **วิสฺสชฺชนฺโต มญฺเญ** *សេចក្ដីថា*

កាលមុនអ្នកត្រូវប្រើខ្សែវែងដងទឹកយកពីអណ្ណង្គទឹក ក្នុងវេលា ដែលព្រះថេរៈ ទទួលបាត្ររបស់ព្រះដ៏មានព្រះភាគហើយដើរទៅ ដូចជាហូរចេញពីមាត់អណ្ណង្គ តាំងនៅស្មើមាត់អណ្ណង្គ ល្មមក្អែកផឹកបាន ។ ក៏ពាក្យនេះ លោកពោលសំដៅ យកការកើតឡើងនៃទឹក ក្នុងវេលាដែលព្រះថេរៈដើរទៅ ។ ក៏ក្រោយពីនោះ ទឹកនុ្ទកទាំងអស់ក្នុងស្រុកនោះ បានពេញប្រៀបដោយទឹក ដោយន័យដូចពោល ហើយក្នុងកាលមុន ។ នេះជាឫទ្ធិ មិនមែនព្រោះការអធិដ្ឋានរបស់ព្រះពុទ្ធ ទាំង មិនមែនព្រោះអានុភាពរបស់ទេវតាទាំងឡាយ ដោយពិត ព្រោះជាបុញ្ញានុភាព របស់ព្រះដ៏មានព្រះភាគ ដូចក្នុងគ្រាស្តេចយាងពីក្រុងរាជគ្រឹះ ទៅកាន់ក្រុងវេសាលី ដើម្បីទ្រង់សម្តែងព្រះបរិត្ត ។ តែអាចារ្យពួកខ្ះពោលថា ដើម្បីឱ្យអ្នកចូនគ្រាម កើតសេចក្តីជ្រះថ្លាក្នុងព្រះដ៏មានព្រះភាគ ទេវតាទាំងឡាយ អ្នកប្រាថ្នាប្រយោជន៍ ដល់អ្នកទាំងនោះទើបធ្វើ ។ អាចារ្យមួយពួកទៀតពោលថា ស្តេចនាគដែលនៅ ខាងក្រោមអណ្ណង្គទឹកបានធ្វើយ៉ាងនោះ ។ ទាំងអស់នោះ មិនមែនហេតុដែល សមគួរ ព្រោះលោកសម្តែងការកើតឡើងនៃទឹក ដោយបុញ្ញានុភាពរបស់ព្រះដ៏-
មានព្រះភាគនោះប៉ុណ្ណោះ ។

សម្រាប់ជាធម្មទាន

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ទ្រង់ជ្រាបដោយអាការទាំងពួង នូវអត្ថនេះ ពោលគឺ សេចក្តីសម្រេចដែលខ្លួនប្រាថ្នា ដោយវៀរចាកការអធិដ្ឋាន នោះ ទើបទ្រង់បន្លឺឧទាននេះ ដែលសម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **កឹ កយិរា ឧទបានេន អាបា ចេ សព្វទា សិយុំ** សេចក្តីថា ក៏បើថា ទឹកក្នុងទីគ្រប់កន្លែងគប្បីមាន គឺគប្បីកើត ដល់អណ្តូងទឹកណា រហូតដល់អស់កាលទាំងពួង គឺបើអណ្តូងទឹកគប្បីជាប់ ដោយហេតុត្រឹមតែសេចក្តីប្រាថ្នា គឺអណ្តូងទឹកនោះក៏នឹងបានទឹកទាំងនោះ បុគ្គលគប្បីធ្វើអ្វី គឺគួរធ្វើអ្វីដោយអណ្តូងទឹកនោះ អធិប្បាយថា អណ្តូងទឹកនិង មានប្រយោជន៍អ្វី ។ បទថា **តណ្ហាយ មូលតោ ឆេត្វា កិស្ស បរិយេសនំ ចរេ** សេចក្តីថា សត្វទាំងឡាយ អ្នកមិនបានធ្វើបុណ្យទុក ត្រូវតណ្ហាណា ចង់ រឹត រមែងក្តៅក្រហាយ ព្រោះទុក្ខក្នុងការមិនបានវត្ថុដែលខ្លួនប្រាថ្នា ព្រះសព្វញ្ញុពុទ្ធដូចតថាគត កាត់ឫសគល់របស់តណ្ហានោះតាំងនៅ គប្បីត្រាច់ស្វែងរកទឹក ឬស្វែងរកបច្ច័យដទៃ ដើម្បីហេតុអ្វី គឺព្រោះហេតុអ្វី ។ អាចារ្យពួកខ្លះពោលថា **មូលតោ ឆេត្វា** ដូច្នេះក៏មាន ។ អធិប្បាយថា កាត់ឫសគល់របស់តណ្ហានុ៎ះឯង ។ ម្យ៉ាងទៀត បទថា **មូលតោ ឆេត្វា** សេចក្តីថា កាត់តណ្ហាទាំងឫស ។ លោក អធិប្បាយទុកថា ព្រះអង្គមិនមានព្រះតម្រិះដល់បុញ្ញសម្ភារៈទាំងអស់ ដែលរក

ប្រមាណមិនបាន ដើម្បីព្រះអង្គ ចាប់ផ្តើមតាំងពីសេចក្តីប្រាថ្នាធំ ដែលជាមូល-ហេតុនៃពោធិញ្ញាណ ទ្រង់បំពេញ ដោយបង្ហើនទៅដើម្បីប្រយោជន៍ដល់សត្វ លោកតែម្យ៉ាង មែនពិត ទើបទ្រង់កាត់តណ្ហាទាំងឫស នឹងទ្រង់ស្វែងរកទឹក ដើម្បីអ្វី គឺព្រោះហេតុណា ព្រោះអ្នកមានតណ្ហាជាតួហេតុ មិនមានការបានវត្ថុ ដែលខ្ជិនប្រាថ្នា តែអ្នកជូនគ្រាមទាំងនេះជាអ្នកខ្វាក់លង់ខ្ចៅមិនដឹងហេតុនេះ ទើបបានធ្វើយ៉ាងនេះឯង ។

ជរាមសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៩

១០. ឧទេនសុត្តវណ្ណនា

អដ្ឋកថាឧទេនសូត្រ

ឧទេនសូត្រទី ១០ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **រញ្ញោ ឧទេនស្ស** *បានដល់ ព្រះរាជាព្រះនាមថា* ***ឧទេន*** *ដែលគេហៅថា ព្រះរាជាដែនវដ្ជីក៏មាន ។ បទថា* **ឧយ្យានគតស្ស** *បានដល់ ស្តេចទៅឧទ្យាន ដើម្បីក្រសាលក្នុងឧទ្យាន ។ មែនពិត បទថា* **ឧទេនស្ស** *នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថអនាទរៈ ។ ក៏បទថា* **ឧទេនស្ស** *នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងសាមិសម្ព័ន្ធមិនប្រាថ្នាដល់បទថា* **អន្តេបុរំ** *។ បទថា* **កាលកតានិ** *បានដល់ ត្រូវក្ងើងនេះស្លាប់ហើយ ។ ក្នុងបទថា* **សាមាវតីបមុខានិ** *នេះ មានពាក្យសួរមកថា ក៏នាងសាមាវតីនេះ គឺអ្នកណា និងហេតុដូចម្តេច ទើបត្រូវក្ងើងនេះ? ខ្ញុំនឹងធ្វើយ ធីតារបស់សេដ្ឋីក្នុងក្រុងកទ្ទវតី ដែលឃោសកសេដ្ឋីតាំងទុកក្នុងតំណែងជាធីតា មានស្ត្រី ៥០០ ជាបរិវារ ជាអគ្គមហេសីរបស់ព្រះបាទឧទេន ជាព្រះអរិយសាវិកាច្រើនទៅដោយមេត្តាវិហារធម៌ មានឈ្មោះថា* ***សាមាវតី*** *។ ក្នុងទីនេះ មានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណោះ កាលពោលដោយពិស្តារ គប្បីជ្រាបឧប្បត្តិកថារបស់នាងសាមាវតីតាំងពីដើម ដែលមានន័យដូចពោលក្នុងធម្មបទ ។ នាងមាគណ្ឌិយា ជាធីតារបស់មាគណ្ឌិយព្រាហ្មណ៍ស្តាប់គាថានេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដល់មាតាបិតារបស់ខ្លួនថា*

ឧិស្សាន តណ្ហា អរតិញ្ច ភកំ
ជាហោសិ ធង្ហោ អបិ មេថុនស្មឿ

កិមេវិធំ មុត្តការីសបុណ្ណា
ចាបិ ធំ សម្ពុសិតុំ ន ឥច្ឆេ ។

(ព្រះសម្ពុទ្ធទ្រង់ត្រាស់នឹងមាគណ្ឌិយព្រាហ្មណ៍ថា) អើក៏សេចក្តីប្រាថ្នាក្នុងមេជុនមិន (ដល់តថាគត) ព្រោះឃើញនាងតណ្ហា នាងអរតি និងនាងរាគា (ដែលជាធីតានៃមារ) សោះទៅហើយ ធ្វើម្តេចឡើយ តថាគតនឹងមានសេចក្តីប្រាថ្នាក្នុងមេជុន ព្រោះឃើញរូបរបស់ទារិកា ដែលពោរពេញ ដោយមូត្រនឹងការីសនេះ តថាគតមិនគួរត្រូវការដើម្បីប៉ះពាល់នូវធីតារបស់អ្នកនោះ សូម្បីតែដោយជើងឡើយ[1] ដូច្នេះ នាងទើបចងអាឃាតក្នុងព្រះសាស្តា ក្នុងកាលជាខាងក្រោយមក ព្រះបាទឧទេនទ្រង់ស្ថាបនាទុកក្នុងតំណែងជាមហេសី ព្រះនាងមាគណ្ឌិយាជ្រាបថា ព្រះដ៏មានព្រះភាគស្តេចដល់ក្រុងកោសម្ពី និងថាស្ត្រី ៥០០ មានព្រះនាងសាមាវតីជាប្រធានជាឧបាសិកា ទើបគិតថា ព្រះសមណគោតមអ្នកមកកាន់ព្រះនគរនេះ ឥឡូវនេះ យើងនឹងដឹងកិច្ចដែលគួរធ្វើដល់សមណ-គោតមនោះ ទាំងស្ត្រីទាំងនេះក៏ជាឧបដ្ឋាយិការបស់ព្រះសមណគោតម យើងនឹងដឹង កិច្ចដែលគួរធ្វើដល់ស្ត្រីសូម្បីនេះ ដែលមាននាងសាមាវតីជាប្រធានដូច្នេះ សូម្បីនឹងព្យាយាមដើម្បីធ្វើសេចក្តីវិនាសដល់ព្រះតថាគត និងដល់ស្ត្រីទាំងនោះ ដោយអនេកបរិយាយ កាលមិនអាចធ្វើ ថ្ងៃមួយ ជាខាងក្រោយមក

១-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ២៨២ ដល់ ២៨៣ ។

ព្រះរាជា ស្តេចយាងទៅក្រសាលក្នុងឧទ្យាន ទើបបញ្ជូនសារដល់ឪពុកមារថា សូមលោកឪពុក ចូលទៅកាន់ប្រាសាទរបស់នាងសាមាវតី ហើយឱ្យបើកឃ្លាំងសំពត់ និងឃ្លាំងប្រេង យកសំពត់ជ្រលក់ក្នុងពាងប្រេងរុំព័ន្ធសសរ ហើយឱ្យស្ត្រីទាំងអស់ ទាំងនោះរួមគ្នា បិទទ្វារ ដាក់គន្ធីះខាងក្រៅ យកភ្លើងអុជព្រះដំណាក់ហើយ ជៀសចេញទៅចុះ ។ ឪពុកមាររបស់នាងមាគណ្ឌិយាបានដឹងដូច្នោះ ហើយ ទើបឡើងកាន់ប្រាសាទបើកឃ្លាំង យកសំពត់ជ្រលក់ប្រេងរុំសសរប្រាសាទ ។ លំដាប់នោះឯង ស្ត្រីទាំងឡាយ មាននាងសាមាវតីជាប្រធាន ទើបចូលទៅរក ចុលបិតាពោលថា នេះជាអ្វី ។ ចុលបិតាពោលថា នាងទាំងឡាយ ព្រះរាជា បញ្ជាឱ្យយកសំពត់ជ្រលក់ប្រេងរុំសសរប្រាសាទទាំងនេះ ដើម្បីធ្វើឱ្យរឹងមាំ ឈ្មោះថា ក្នុងព្រះរាជដំណាក់ កម្មល្អ និងអាក្រក់ដឹងបានលំបាក ពួកនាងកុំនៅជិតយើងឡើយ ដូច្នេះហើយ ទើបឱ្យស្ត្រីដែលមកទាំងនោះចូលទៅក្នុងបន្ទប់ រួចដាក់គន្ធីះពីខាងក្រៅ ហើយអុជភ្លើង ទើបចុះមក ។ ព្រះនាងសាមាវតីបានឱ្យ ឱវាទដល់ស្ត្រីទាំងនោះថា នែនាងទាំងឡាយ កាលយើងត្រាច់នៅក្នុងសង្ឆារវដ្ត ដែលរកទីបំផុតខាងដើម និងខាងចុងមិនបាន អត្តភាពត្រូវភ្លើងឆេះយ៉ាងនេះ សូម្បីកំណត់ដោយពុទ្ធញ្ញាណក៏ធ្វើមិនបានងាយ ពួកនាងកុំប្រមាទឡើយ ។ ស្ត្រីទាំងឡាយនោះ សម្រេចសោតាបត្តិផល ក្នុងសម្នាក់របស់នាងខុជ្ជុត្តរា ជាអរិយសាវិកា អ្នកដឹងច្បាស់ពាក្យទូន្មានរបស់ព្រះសាស្តា អ្នកស្តាប់ធម៌ក្នុងសម្នាក់របស់ ព្រះសាស្តាហើយសម្រេចផល អ្នកសម្រេចសេក្ខបដិសម្ភិទា

សម្តែងធម៌តាម ទំនងដែលព្រះសាស្តាទ្រង់សម្តែងនុ៎ះឯង និងខ្ជល់ខ្ជាយក្នុងមនសិការកម្មដ្ឋានដោយលំដាប់ៗ កាលក្ងើងកំពុងឆេះព្រះដំណាក់ ធ្វើទុកក្នុងចិត្តនូវវេទនាបរិគ្គហកម្មដ្ឋាន ពួកខ្លះសម្រេចផលទី ២ ពួកខ្លះសម្រេចផលទី ៣ ហើយក៏កាលកិរិយាទៅ ។

លំដាប់នោះឯង ភិក្ខុទាំងឡាយកំពុងត្រាច់បិណ្ឌបាត ក្នុងក្រុងកោសម្ពីដឹងនូវរឿងរ៉ាវនោះ ខាងក្រោយកត្ត ទើបក្រាបទូលចំពោះព្រះដ៏មានព្រះភាគសួរដល់អភិសម្ពោធយកពរបស់ស្ត្រីទាំងនោះ ។ ក៏ព្រះដ៏មានព្រះភាគបានត្រាស់ប្រាប់ការដែលស្ត្រីទាំងនោះ សម្រេចអរិយផលដល់ភិក្ខុទាំងឡាយ ។ ព្រោះហេតុនោះ លោកទើបពោលថា **តេន ខោ បន សមយេន រញ្ញោ ឧទេនស្ស ។បេ។ អនិច្ចលា ការតតា** ។

បណ្តាបទទាំងនោះ បទថា **អនិច្ចលា** សេចក្តីថា មិនមែនឥតផល គឺសម្រេចសាមញ្ញផលនុ៎ះឯង ។ ចំណែកស្ត្រីទាំងនោះបានទទួលផល ដែលព្រះនាងសាមាវតីឱ្យ៉ាងដោយគាថាថា

អារម្ភថ ជិត្ថមថ
យុញ្ជថ ពុទ្ធសាសនេ
ធុនាថ មចុនោ សេនំ
ជនឌ្ឍ ការ៎ៃ ការ៎ៃ
យោ ឥមស្មឺ ធម្មវិនយេ

អប្បមត្តោ វិហេស្សតិ
បហាយ ជាតិសំសារំ
ទុក្ខស្សន្តំ ករិស្សតីតិ។

ប្រែថា អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាម ក្នុងពុទ្ធសាសនា ចូរកម្ចាត់បង់សេនានៃមច្ចុ ដូចជាកុញ្ជរញាំញីផ្ទះបបុស អ្នកណាមិនប្រហែសក្នុងធម្មវិន័យនេះ អ្នកនោះនឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវទីបំផុតទុក្ខបាន[១] ដូច្នេះ ទើបធ្វើទុកក្នុងចិត្តនូវវេទនាបរិគ្គហកម្មដ្ឋាន បានឃើញច្បាស់ ហើយសម្រេចផលទី ២ និងទី ៣ ។ ចំណែកនាងខុជ្ជុត្តរា ព្រោះមានអាយុនៅសល់ និងព្រោះមិនបានធ្វើកម្មដូច្នោះ ទុកក្នុងកាលមុន ទើបនៅខាងក្រៅប្រាសាទនោះ ។ ក៏អាចារ្យពួកខ្លះពោលថា នាងគេចទៅក្នុងចន្លោះ ១០ យោជន៍ ។ លំដាប់នោះ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាសាលាថា ម្នាលអាវុសោ មរណភាពរបស់ព្រះអរិយសាវិកាដែលមានសភាពយ៉ាងនេះ មិនសមគួរសោះឡើយ ។ ព្រះសាស្តា ព្រះអង្គយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកទាំងឡាយអង្គុយសន្ទនាគ្នា ដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលឱ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីសេចក្តីស្លាប់របស់ស្ត្រីទាំងនោះ មិនសមគួរក្នុងអត្តភាពនេះសោត តែកម្មដែលនាងទាំងឡាយធ្លាប់ធ្វើទុកមុននុ៎ះឯង ជាកម្មដែលសមគួរពិត ដែលពួក

១-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ លេខ ៣០ ទំព័រ ៧៦ ។

នាងទាំងឡាយនឹងបានទទួល ដូច្នេះហើយ ដែលភិក្ខុទាំងនោះទូលអារាធនា ទើបព្រះសាស្តានាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារ-ណាសី ព្រះបច្ចេកពុទ្ធ ៨ រូប ធាន់ភត្តាហារជាប់ជានិច្ច ក្នុងព្រះរាជនិវេសន៍ ។ ស្ត្រី ៥០០ នាក់ នាំគ្នាទំនុកបម្រុងព្រះបច្ចេកពុទ្ធទាំងនោះ ។ បណ្តាព្រះបច្ចេកពុទ្ធទាំង ៨ អង្គនោះ ព្រះបច្ចេកពុទ្ធ ៧ អង្គ និមន្តទៅកាន់ព្រៃហិមពាន្ត ឯ ព្រះបច្ចេកពុទ្ធ ១ អង្គទៀត គង់ចូលសមាបត្តិត្រង់គុម្ពស្មៅមួយកន្ទែង ទៀប ឆ្នេរទន្ទេ ។ ក្នុងថ្ងៃមួយជាខាងក្រោយមក កាលព្រះបច្ចេកពុទ្ធនិមន្តទៅអស់ហើយ ព្រះរាជាទ្រង់ប្រាថ្នានឹងលេងទឹក ជាមួយនឹងពួកស្ត្រីទាំងនោះ ទើបស្តេចយាងទៅ ។ ស្ត្រីទាំងនោះលេងទឹកក្នុងទីនោះ អស់ចំណែកនៃថ្ងៃ ត្រូវសេចក្តីត្រជាក់ បៀតបៀន ប្រាថ្នានឹងអាំងភ្លើង ឈរព័ទ្ធគុម្ពស្មៅនោះ ខាងលើដែលពាសពេញ ទៅដោយស្មៅស្ងួត ដោយសម្គាល់ថា គំនរស្មៅ ទើបដុតភ្លើង កាលស្មៅត្រូវ ភ្លើងឆេះម៉ដ្ឋហើយ ទើបឃើញព្រះបច្ចេកពុទ្ធ គិតថា ព្រះបច្ចេកពុទ្ធរបស់ ព្រះរាជាត្រូវភ្លើងឆេះ ព្រះរាជាទ្រង់ជ្រាបរឿងនោះ នឹងធ្វើយើងទាំងឡាយឱ្យ វិនាស យើងនឹងដុតព្រះបច្ចេកពុទ្ធឆេះសុស ដូច្នេះហើយគ្រប់អ្នកនាំគ្នាប្រមូល អុសមកទីនោះ។ ធ្វើឱ្យជាគំនរទុកខាងលើព្រះបច្ចេកពុទ្ធនោះ នាំគ្នាជៀសទៅ ដោយគិតថា ឥឡូវនេះ ព្រះបច្ចេកពុទ្ធ នឹងឆេះសុសទៅហើយ ។ ស្ត្រីទាំងនោះ កាលមុនមិនមានចេតនា តែឥឡូវនេះស្ត្រីទាំងនោះជាប់ដោយកម្ម ។ ក៏ខាងក្នុង

សមាបត្តិ បើស្ត្រីទាំងនោះនាំគ្នាប្រមូលអុសមកទាំងពាន់រទេះ ហើយដុតព្រះបច្ចេកពុទ្ធ ក៏មិនអាចពាល់ត្រូវ សូម្បីត្រឹមតែចំហាយក្តៅបាន ។ ព្រោះដូច្នោះ ក្នុងថ្ងៃទី ៧ ព្រះបច្ចេកពុទ្ធអង្គនោះ ក្រោកទៅយ៉ាងសប្បាយ ។ ស្ត្រីទាំងនោះ ព្រោះកម្មដែលខ្លួនធ្វើទុក ទើបទៅធ្លាក់ក្នុងនរកអស់ពាន់នៃឆ្នាំ អស់នៃសែនឆ្នាំ ព្រោះផលនៃវិបាករបស់កម្មនោះឯង កាលរាជដំណាក់ត្រូវភ្លើងឆេះដោយទំនងនេះ នាងទាំងនោះក៏ត្រូវភ្លើងឆេះដល់រយអត្តភាព ។ នេះជាបុព្វកម្មរបស់ស្ត្រីទាំងនោះ ។

ក៏ព្រោះហេតុដែលស្ត្រីទាំងនោះ ធ្វើឱ្យច្បាស់នូវអរិយផល ក្នុងអត្តភាពនេះ ទើបចូលទៅអង្គុយជិតព្រះរតនត្រ័យ ព្រោះដូច្នោះ បណ្តាស្ត្រីទាំងនោះ ស្ត្រីពួកខ្លះជាអនាគামិនីបុគ្គលកើតក្នុងជាន់សុទ្ធាវាស ក្រៅនោះស្ត្រីពួកខ្លះ កើតក្នុងកពតាវត្តិង្ស ស្ត្រីពួកខ្លះ កើតក្នុងជាន់យាមា ស្ត្រីពួកខ្លះ កើតក្នុងជាន់តុសិត ស្ត្រីពួកខ្លះ កើតក្នុងជាន់និម្មានរតី ស្ត្រីពួកខ្លះកើតក្នុងជាន់បរនិម្មិតវសវត្តី ។

ចំណែកព្រះបាទឧនេទទ្រង់ជ្រាបដំណឹងថា ព្រះដំណាក់របស់ព្រះនាងសាមាវតីត្រូវភ្លើងឆេះ ទើបប្រញាប់ប្រញាល់ស្តេចយាងទៅទីនោះ ក្នុងកាលស្ត្រីទាំងនោះត្រូវភ្លើងឆេះហើយនោះឯង ។ ក៏កាលគ្រាស្តេចយាងមក បញ្ជាឱ្យរាជបុរស ជួយពន្ធត់ភ្លើងដែលកំពុងឆេះប្រាសាទ ព្រះរាជាទ្រង់កើតទោមនស្ស យ៉ាងខ្លាំង ទ្រង់ជ្រាបថា នាងមាគណ្ឌិយា បង្ក ហេតុ ដូច្នោះដោយឧបាយដែលនាងមាគណ្ឌិយាធ្វើខុសក្នុងព្រះអរិយសាវិកា ត្រូវកម្មដាស់តឿហើយ ទើបឱ្យ

ជាក់អាជ្ញាដល់នាង ព្រមដោយញាតិ ។ នាងមាគណ្ឌិយា ព្រមដោយរាជបរិវារ ព្រមទាំងមិត្ត និងបក្សពួក បានដល់នូវភាពវិនាសដោយប្រការដូច្នេះ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួងដល់ហេតុដែលស្ត្រីទាំងនោះ ដែលមានព្រះនាងសាមាវតីជាប្រធានឆេះសុសក្នុងគំនរភ្លើង និងនិមិត្តដែលនាងមាគណ្ឌិយា ព្រមដោយមិត្ត និងបក្សពួក ដល់ភាពវិនាស ដោយព្រះរាជអាជ្ញានេះ ទើបទ្រង់បន្ទឺឧទាននេះ ដែលសម្តែង សេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **មោហសម្ពន្ធោ លោកោ ភព្ជរូចោ ឥស្សតិ** សេចក្តីថា សត្វលោកណាក្នុងលោកនេះ ប្រាកដដូចជាអ្នកសមគួរពិត គឺដូចជាដល់ព្រមដោយហេតុ សត្វលោកសូម្បីនោះ មានមោហ:ជាគ្រឿងចង គឺអាក្រក់ទៅដោយមោហ: កាលមិនដឹងវត្ថុជាប្រយោជន៍ និងមិនជាប្រយោជន៍ ដល់ខ្លួន ទើបមិនបដិបត្តិក្នុងវត្ថុជាប្រយោជន៍ សន្ទុំតែវត្ថុមិនមែនជាប្រយោជន៍ នាំសេចក្តីទុក្ខមកឱ្យ និងចម្រើនតែអកុសល ។ បាលីថា **ភវូចោ ឥស្សតិ** ដូច្នេះក៏មាន ។ បាលីនោះមានអធិប្បាយដូចតទៅនេះ

លោកនេះមានមោហ:ជាគ្រឿងចង គឺអាក្រក់ដោយមោហ: ព្រោះហេតុនោះឯង ខ្លួនរបស់សត្វលោកនោះ ទើបប្រាកដដូចមានរូប គឺដូចមានសភាវ:ទៀង គឺប្រាកដដូចជាមិនចាស់ មិនស្លាប់ ដែលជាហេតុឱ្យធ្វើវត្ថុ ដែលមិនគួរធ្វើ មានបាណាតិបាតជាដើម ។ បទថា **ឧបនិពន្ធោ ពាលោ តមសា បរិវារិតោ**

សស្សតិ វិយ ខាយតិ សេចក្តីថា ក៏មិនមែនតែសត្វលោក និងមានមោហៈជាគ្រឿងចងតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត សត្វលោកងងឹតល្ងង់ខ្លៅនេះ នៅមានឧបធិជាគ្រឿងចង ត្រូវភាពងងឹត គឺអវិជ្ជាគ្របដណ្តប់ហើយ ។ លោកពោលអធិប្បាយពាក្យនេះទុកថា ព្រោះញាណដែលជាហេតុឱ្យបុគ្គលពិចារណាឃើញកាម និងខន្ធដែលមិនវិបរិត មិនទៀង ជាទុក្ខមានសេចក្តីប្រែប្រួលទៅជាធម្មតា ដូច្នេះមិនមាន ព្រោះហេតុដែលអន្ធបុថុជ្ជនល្ងង់ខ្លៅ ត្រូវភាពងងឹត គឺអវិជ្ជា ពន្ធព័ទ្ធ គ្របដណ្តប់ដោយជុំវិញ ព្រោះដូច្នោះ អន្ធបុថុជ្ជននោះ មានឧបធិជាគ្រឿងចង ដោយឧបធិទាំងនេះ គឺឧបធិ គឺកាម ឧបធិ គឺកិលេស ឧបធិ គឺខន្ធ ក៏ព្រោះហេតុនោះឯង កាលបុគ្គលអ្នកមានឧបធិ រមែងឃើញប្រាកដថាទៀង គឺរមែងប្រាកដថា មានសភាវៈទៀង បានដល់ មាននៅគ្រប់កាល ។ បាលីថា **អសស្សតិរិវ ខាយតិ** ដូច្នេះក៏មាន ។ បាលីនោះមានអធិប្បាយដូចតទៅនេះថា ឧបធិនោះ រមែងប្រាកដ អធិប្បាយថា ចូលទៅតាំងនៅ ដូចចំណែកមួយរបស់លោក ដោយអំណាចការប្រកាន់ខុសថា អត្តា រមែងមាន គឺរមែងកើតគ្រប់កាល និងថា អត្តាដទៃមិនទៀង គឺមានសភាវៈមិនពិតប្រាកដ ។ មែនពិត រ អក្សរ ជាបទសន្ធិ ។ បទថា **បស្សតោ ឥត្ថិ កិញ្ចនំ** សេចក្តីថា ក៏បុគ្គលណាកំណត់សង្ខារទាំងឡាយ ពិចារណាឃើញដោយលក្ខណៈ មានអនិច្ចលក្ខណៈជាដើម កាលបុគ្គលនោះពិចារណាឃើញដឹងច្បាស់ ចាក់ធ្លុះចំពោះតាមសេចក្តីពិត ដោយមគ្គបញ្ញា ដែលប្រកបដោយវិបស្សនាបញ្ញា កិលេសជាគ្រឿងកង្វល់

មានពាគ:ជាដើម ដែលជាហេតុចង់សត្វទុកក្នុងសង្សារវដ្ដមិនមាន ។ អធិប្បាយ ថា សេចក្ដីពិត កាលបុគ្គលមិនឃើញយ៉ាងនោះឯង គប្បីជាអ្នកត្រូវគ្រឿងចង មានអវិជ្ជា តណ្ហា និងទិដ្ឋិជាដើម ចងទុកក្នុងសង្សារ ។

ឧសមសុត្តវណ្ណា និដ្ឋិតា

ចប់អដ្ឋកថាខ្ទេនសូត្រ ១០

និដ្ឋិតា ច ចូឡវគ្គវណ្ណា

ចប់ចូឡវគ្គវណ្ណនាទី ៧

រួមព្រះសូត្រដែលមានក្នុងវគ្គនេះ គឺ

១-បឋមកទ្ទិយសូត្រ	*២-ទុតិយកទ្ទិយសូត្រ*
៣-បឋមកាមសូត្រ	*៤-ទុតិយកាមសូត្រ*
៥-លកុណដ្ឋកកទ្ទិយសូត្រ	*៦-តណ្ហាកខយសូត្រ*
៧-បញ្ចខយសូត្រ	*៨-មហាកច្ចាយនសូត្រ*
៩-ឧទបានសូត្រ	*១០-ឧទេនសូត្រ ។*

៨. ចាដលិកាមិយវគ្គោ

ចាដលិកាមិយវគ្គទី ៨

១. បឋមនិព្វានបដិសំយុត្តសុត្តវណ្ណនា

អដ្ឋកថាបឋមនិព្វានបដិសំយុត្តសូត្រ

បឋមនិព្វានបដិសំយុត្តសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **និព្វានបដិសំយុត្តាយ** *សេចក្តីថា អសង្ខតធាតុដែលអាស្រ័យ អមតធាតុប្រព្រឹត្តទៅដោយអំណាចការប្រកាសឱ្យដឹង ។ បទថា* **ធម្មិយា កថាយ** *ប្រែថា ដោយធម្មទេសនា ។ បទថា* **សន្ធេស្សតិ** *បានដល់ សម្តែងដល់ព្រះនិព្វាន ដោយលក្ខណៈនៃសការៈព្រមដោយកិច្ច ។ បទថា* **សមាទបេតិ** *បានដល់ ឱ្យ ភិក្ខុទាំងនោះ ប្រកាន់យកអត្តនោះនុ៎ះឯង ។ បទថា* **សមុត្តេជេតិ** *បានដល់ កាល ឱ្យកើតនូវឧស្សាហ៍ ក្នុងការប្រកាន់ប្រយោជន៍នោះ ឈ្មោះថា រមែងឱ្យមានតេជៈ គឺឱ្យរុងរឿង ។ បទថា* **សម្បហំសេតិ** *បានដល់ រមែងឱ្យត្រេកអរដោយគុណ គឺ ព្រះនិព្វានដោយប្រពៃ គឺដោយប្រការទាំងពួង ។*

ម្យ៉ាងទៀត បទថា **សន្ធេស្សតិ** *សេចក្តីថា ទ្រង់សម្តែងដោយប្រពៃ ដែលសមរម្យដល់អធ្យាស្ម័យរបស់ភិក្ខុទាំងនោះ។ ដោយប្រការទាំងពួង គឺដោយ បរិយាយនោះ។ ដោយន័យមានជាអាទិ៍ថា ធម៌ជាទីអស់តណ្ហា ជាទីបំបាត់ពាគៈ ជាទីរលត់ ដែលជាគ្រឿងសូប់នូវសង្ខារទាំងពួង ដែលលះឧបធិទាំងពួងនោះ ។ បទថា* **សមាទបេតិ** *សេចក្តីថា ទ្រង់ធ្វើឱ្យភិក្ខុទាំងឡាយ បង្ហោនទៅ ខិនទៅ ជ្រាយទៅក្នុងធម៌នោះ ព្រមដោយបដិបទាជាគ្រឿងសម្រេច ឈ្មោះថា ទ្រង់ បបួល គឺឱ្យភិក្ខុកាន់យកដោយប្រពៃថា លោកគប្បីសម្រេចព្រះនិព្វាននោះ*

ដោយអរិយមគ្គនេះ ។ បទថា **សមុត្តេជេតិ** សេចក្តីថា ទ្រង់ធ្វើកិក្ខុទាំងនោះឱ្យអាចហាន ក្នុងការសម្រេចព្រះនិព្វាន ឬធ្វើចិត្តឱ្យផ្ទេរផង់ក្នុងព្រះនិព្វាននោះ ដោយព្រះតម្រាស់ថា អ្នកទាំងឡាយកុំប្រមាទ គឺដល់ការឈប់ក្នុងចន្ទោះ ក្នុងសម្មាបដិបត្តិថា ព្រះនិព្វាននេះធ្វើបានលំបាក មានសេចក្តីត្រេកអរបានលំបាក ព្រោះព្រះនិព្វាននេះ ដែលអ្នកដល់ព្រមដោយឧបនិស្សរ័យ មានសេចក្តីព្យាយាមមិនមែនធ្វើបានលំបាក ព្រោះដូច្នោះ ពួកអ្នកគប្បីក្រោកឡើង ព្យាយាមដើម្បីបដិបទាដ៏ហ្មត់ចត់ មានសីលវិសុទ្ធជាដើម ។ បទថា **សម្ឆហំសេតិ** សេចក្តីថា កាលទ្រង់ធ្វើចិត្តរបស់កិក្ខុទាំងនោះឱ្យត្រេកអរ ឱ្យរីករាយ ដោយការប្រកាសអានិសង្សនៃព្រះនិព្វាន ដោយន័យមានជាអាទិ៍ថា ព្រះនិព្វានជាគ្រឿងញ៉ាំញៀនូវសេចក្តីស្រវឹង នាំចេញនូវសេចក្តីស្រេកឃ្លាន ដកឡើងនូវសេចក្តីអាល័យ[1] និងដោយន័យមានជាអាទិ៍ថា ព្រះនិព្វានជាការអស់ទៅនៃរាគ: ទោស: មោហ:[2] និងថា នេះជាអសង្ខតធម៌[3] និងថា អមតធម៌ សន្តិធម៌ ដូច្នេះ ឈ្មោះថា ញ៉ាំងកិក្ខុឱ្យរីករាយ ឱ្យស្រាលចិត្ត ។ បទថា **តេ ច ភិក្ខូ អដ្ឋិកត្វា** សេចក្តីថា កិក្ខុទាំងឡាយ កំណត់យ៉ាងនេះថា វត្ថុអ្វីៗ មាននៅ ប្រយោជន៍នេះពួកយើងគួរសម្រេចហើយ ជាអ្នកមានសេចក្តីត្រូវការដោយទេសនានោះ ។ បទថា **មនសិ-**

១-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ១១៦ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តក: លេខ ៥៣ ទំព័រ ៥២ និងសុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ លេខ ៣៦ ទំព័រ ៣៥០ ។

៣-សុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ លេខ ៣៦ ទំព័រ ៣៥០ ។

ឋត្វា *សេចក្ដីថា ដាក់ទុកក្នុងចិត្ត មិនបញ្ជូនចិត្តទៅក្នុងទីដទៃ គឺធ្វើទេសនានោះ ឱ្យនៅក្នុងចិត្តរបស់ខ្លួនប៉ុណ្ណោះ ។ បទថា* **សព្ពំ ចេតសោ សមន្ទ្ធាហរិត្វា** *សេចក្ដីថា នឹកដល់ទេសនាដោយចិត្ត ដែលជាតួនាំទាំងពួង តាំងពីដើមដរាបដល់ទីបំផុត គឺធ្វើសេចក្ដីដែលនៅក្នុងទេសនានោះឯង ។ ម្យ៉ាងទៀត បទថា* **សព្ពំ ចេតសោ សមន្ទ្ធាហរិត្វា** *សេចក្ដីថា នាំមករឿយៗ ដោយប្រពៃនូវទេសនា បើចិត្តទាំងអស់ ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះថា កាលអ្នកសម្ដែងធ្វើទេសនាដោយចិត្តណា មិនឱ្យទេសនាដែលប្រព្រឹត្តទៅពីចិត្តទាំងពួងចេញទៅខាងក្រៅ ហើយនាំមកដោយរឿយៗ ដោយប្រពៃ គឺមិនខុសប្លែកហើយនាំចិត្តសន្ដានរបស់ខ្លួនមកទ្រទ្រង់ទុកដោយល្អ នូវទេសនាតាមដែលសម្ដែងហើយ ។ បទថា* **ឱហិតសោតា** *បានដល់ ផ្ទៀងសោត:ស្ដាប់ គឺតាំងសោត:ទុកដោយល្អ ។ ម្យ៉ាងទៀត បទថា* **ឱហិតសោតា** *បានដល់ មានសោតបសាទដែលអ្វីៗមិនរុកកួន ។ មែនពិត បុគ្គលសូម្បីកាលបានសោតបសាទដែលមិនមានអ្វីរុកកួននោះនុ៎ះឯង ទើបមិនរវើរវាយទៅក្នុងការស្ដាប់ ដូចសតិ-សំវរ: គួរនឹងពោលថា ក្នុងចក្ខុន្ទ្រិយជាដើមខ្លះ ក្នុងសោតិន្ទ្រិយខ្លះ ។ ក៏ក្នុងទីនេះ ដោយបទទាំង ៤ មានបទថា* **អដ្ឋិកត្វា** *ជាដើម ទ្រង់សម្ដែងដល់ការដែលកិក្ខុទាំងនោះស្ដាប់ដោយគោរព ដោយសម្ដែងការអើពើក្នុងការស្ដាប់ដោយមិនជាដទៃពីនោះ ។*

បទថា **ឯតមត្ថំ ១ិ១ិត្វា** *សេចក្ដីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួងនូវការ:ដែលកិក្ខុទាំងនោះ មានការធ្វើអើពើ ក្នុងការស្ដាប់ធម្មកថា ដែលជាប់*

ដោយព្រះនិព្វានៗ ។ បទថា **ឥមំ ឧទានំ** សេចក្តីថា ទ្រង់បន្ទឺឧទាននេះ ដែលប្រកាសការ:ដែលព្រះនិព្វានមានដោយបរមត្ថ ដោយមុខ គឺព្រះធម៌ទេសនាដែលខុសផ្ទុយគ្នាពីធម៌នោះ ។

បណ្តាបទទាំងនោះ បទថា **អត្ថិ** ប្រែថា មាន អធិប្បាយថា កើតដោយបរមត្ថ ។ បទថា **ភិក្ខវេ** ជាពាក្យហៅភិក្ខុទាំងនោះ ។ សួរថា ក៏ការបន្ទឺដែលញ៉ាំងបីតិ និងសោមនស្សឱ្យតាំងឡើងក្តី ដែលញ៉ាំងធម្មសង្វេគឱ្យតាំងឡើងក្តី មិនប្រាថ្នាដល់អ្នកទទួលធម៌ ឈ្មោះថា **ឧទាន** និងឧទាននោះមកក្នុងសូត្រ មានប្រមាណប៉ុណ្ណោះ ដូច្នោះពិតមែនឬ ព្រោះហេតុអ្វី ក្នុងទីនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់បន្ទឺឧទាន ទើបត្រាស់ហៅភិក្ខុទាំងនោះ? ឆ្វើយថា ដើម្បីបញ្ជាក់ដល់ភិក្ខុទាំងឡាយនោះ ។ មែនពិត ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ដល់ភិក្ខុទាំង-នោះ ដែលជាប់ដោយព្រះនិព្វាន ក៏ទ្រង់កើតបីតិសោមនស្សឡើង ដោយរឭកដល់គុណរបស់ព្រះនិព្វាន ទើបទ្រង់បន្ទឺឧទាន ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបការបរិវិតក្ក:នៃចិត្តរបស់ភិក្ខុទាំងនោះថា សភាវធម៌ទាំងអស់ ក្នុងព្រះសាសនានេះ រៀរព្រះនិព្វាន ដែលប្រព្រឹត្តទៅជាប់នឹងបច្ច័យប៉ុណ្ណោះទើបកើតឡើងបាន ដែលប្រាសចាកបច្ច័យ មិនកើតឡើងទេ តែនិព្វានធម៌នេះកើតក្នុងបច្ច័យណា និងមានប្រាថ្នានឹងឱ្យភិក្ខុទាំងនោះយល់ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **ភិក្ខវេ តជាយតនំ** ដូច្នេះ ។ គប្បីជ្រាបថា មិនមែនធ្វើឱ្យភិក្ខុទាំងនោះជាអ្នកទទួលដោយចំណែកតែមួយប៉ុណ្ណោះទេ ។ បទថា **តជាយតនំ** បានដល់ ហេតុនោះ ។

ៈ អក្សរ បទសន្ធិ មែនពិត ព្រះនិព្វាន លោកហៅថា អាយតនៈ ព្រោះអត្ថថា ជាហេតុ ដោយជាអារម្មណបច្ច័យដល់មគ្គញ្ញាណ និងផលញ្ញាណជាដើម ដូចរូបារម្មណ៍ជាដើម ជាអារម្មណបច្ច័យដល់ចក្ខុវិញ្ញាណជាដើម ។ ក៏ពាក្យត្រឹមតែប៉ុណ្ណោះ ព្រះដ៏មានព្រះភាគទ្រង់ប្រកាសដល់សង្ខតធាតុថា មានដោយបរមត្ថដល់ភិក្ខុទាំងនោះ ។

ក្នុងសេចក្តីនោះ មានន័យនៃធម៌ដូចតទៅនេះ

ព្រោះសង្ខតធម៌មាន សូម្បីអសង្ខតធាតុក៏មាន ព្រោះសភាវធម៌ជាបដិបក្ខគ្នា នឹងគ្នា ដូចថា កាលទុក្ខមាន សូម្បីសុខក៏ជាបដិបក្ខគ្នា នឹងគ្នា និងទុក្ខនោះក៏មានដូចគ្នា យ៉ាងណា កាលសេចក្តីក្តៅមាន សូម្បីភាពត្រជាក់ក៏មាន កាលបាបធម៌មាន សូម្បីកល្យាណធម៌ ក៏មានដូចគ្នា ។ សមដូចពាក្យដែលព្រះដ៏-មានព្រះភាគត្រាស់ទុកថា

យថាបិ ទុក្ខេ វិជ្ជន្តេ សុខំ នាមបិ វិជ្ជតិ
ឯវំ ភវេ វិជ្ជមានេ វិភវោ ឥច្ឆិតព្វកោ។
យថាបិ ឧណ្ហេ វិជ្ជន្តេ អបរំ វិជ្ជតិ សីតលំ
ឯវំ តិវិធគ្គិ វិជ្ជន្តេ និព្វានំ ឥច្ឆិតព្វកំ។
យថាបិ បាបេ វិជ្ជន្តេ កល្យាណមបិ វិជ្ជតិ
ឯវមេវ ជាតិ វិជ្ជន្តេ អជាតិ ឥច្ឆិតព្វកំ ។

កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើភពមាន ការប្រាសចាកភព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។ កាលបើក្តៅមាន ត្រជាក់ដទៃដ៏

មាន យ៉ាងណា កាលបើកើ្ងង ៣ ប្រការមាន ព្រះនិញ្ជានដែលបុគ្គលគួរប្រាថ្នា ក៏មាន យ៉ាងនោះដែរ ។ កាលបើបាបមាន បុណ្យក៏មាន យ៉ាងណា កាលបើជាតិមាន ព្រះនិញ្ជានមិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នាក៏មាន យ៉ាងនោះដែរ[១] ។

ម្យ៉ាងទៀត ការខៃសេចក្ដីដល់ព្រះនិញ្ជានថា មានដោយបរមត្ថនឹងមានសេចក្ដីច្បាស់ខាងមុខ ។

ព្រះដ៏មានព្រះភាគ ត្រាទ្រង់សម្ដែងដល់អសង្ខតធាតុថា មានដោយបរមត្ថ ដោយប្រមុខដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងសការៈនៃព្រះនិញ្ជាននោះមាន គឺសេចក្ដីផ្ទរផង់នៃធម៌ដែលខុសពីអសង្ខតធាតុនោះ ទើបត្រាស់ថា **យត្ត នេវ ឋបវី ន អាចោ** ដូច្នេះជាដើម ។

ក្នុងសេចក្ដីនោះ ព្រោះហេតុដែលព្រះនិញ្ជាន មានសការៈផ្ទុយគ្នាពីសង្ខារទាំងពួងមិនមាន បណ្ដាសង្ខតធម៌ណាៗ យ៉ាងណា សូម្បីក្នុងព្រះនិញ្ជាននោះ ក៏មិនមានសង្ខតធម៌ទាំងអស់ ព្រោះដូច្នោះ ព្រោះសង្ខតធម៌ និងអសង្ខតធម៌រួមគ្នាមិនបាន ។ ក្នុងសេចក្ដីនោះ មានការធ្វើអធិប្បាយអត្ថដូចតទៅនេះ **ឋបវីធាតុ** មានសេចក្ដីរឹងជាលក្ខណៈ **អាបោធាតុ** មានការរាវជាលក្ខណៈ **តេជោធាតុ** មានការក្ដៅជាលក្ខណៈ **វាយោធាតុ** មានការបក់ជាលក្ខណៈ:មិនមានក្នុងព្រះនិញ្ជានណា គឺអសង្ខតធាតុណា ព្រោះដូច្នោះ ក្នុងធាតុទាំងនោះ កាលពោលអំពីសេចក្ដីមិនមាននៃមហាភូតរូប ៤ ក៏ជាការពោលដល់សេចក្ដីមិនមាននៃឧបាទាយរូប

១-សុត្តន្ដបិដក ខុទ្ទកនិកាយ ពុទ្ធវង្ស លេខ ៣៧ ទំព័រ ២៣ ។

សូម្បីទាំងអស់ ព្រោះអាស្រ័យមហាភូតរូបនោះ យ៉ាងណា ។ កាមភព និង រូបភពក៏ដូច្នោះ ជាការពោលថា មិនមានក្នុងព្រះនិញ្ជាន នោះដោយមិនឱ្យសេស-សល់ ព្រោះមានការប្រព្រឹត្តទៅមិនជាប់នឹងព្រះនិញ្ជានោះ ។ ព្រោះថា បញ្ចវោ-ការភព ឬឯកវោការភពរៀរចាកការអាស្រ័យមហាភូតរូបហើយ ក៏មិនមាន ។

ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងធម៌ដែលរាប់បញ្ចូលក្នុងអរូបភព មិន មានក្នុងព្រះនិញ្ជានោះ សូម្បីក្នុងព្រះនិញ្ជានមានសភាវៈជាអរូប (ជានាម) ទើប ត្រាស់ពាក្យមានជាអាទិ៍ថា **ន អាកាសានញ្ចាយតនំ** *។បេ។* **ន នេវសញ្ញា-ជាសញ្ញាយតនំ** *ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ន អាកាសានញ្ចាយតនំ** *សេចក្តីថា ចិត្តុប្បាទ ពោលគឺ អាកាសានញ្ចាយតនៈ ទាំង ៣ យ៉ាង ផ្សេងដោយកុសលចិត្ត វិបាកចិត្ត និងកិរិយាចិត្ត ព្រមទាំងអារម្មណ៍រមែងមិនមាន ។ សូម្បីក្នុងបទ ដែលនៅសល់ ក៏នយនេះដូចគ្នា ។ ក៏កាមលោក មិនមានក្នុងព្រះនិញ្ជានដោយ អារម្មណ៍ណា សូម្បីឥធលោក និងបរលោក ក៏មិនមានក្នុងព្រះនិញ្ជានោះ ដោយអារម្មណ៍នោះ ព្រោះហេតុនោះ លោកទើបពោលថា លោកនេះមិនមាន លោកខាងមុខមិនមាន ដូច្នេះជាដើម ។ ពាក្យនោះមានអធិប្បាយដូចតទៅនេះ*

លោក មានខន្ធលោកនេះណា ដែលបានវោហារថា មានសភាពយ៉ាង នេះ បច្ចុប្បន្នធម៌ និងថា លោកនេះ និងខន្ធលោក ដែលបានវោហារថា លោកដទៃពីលោកនោះ បរលោក និងអភិសម្ភវយកពណា ទាំងពីរនោះ មិន មានក្នុងទីណា ។ បទថា **ន ឧភោ ចន្ទិមសុរិយា** *សេចក្តីថា ព្រោះហេតុដែល*

កាលរូបមាន ឈ្មោះថា សេចក្តីងងឹតក៏គប្បីមាន និងដើម្បីកម្ចាត់សេចក្តីងងឹត ព្រះចន្ទ និងព្រះអាទិត្យក៏រិលទៅ តែរូបដោយប្រការទាំងពួងមិនមានក្នុងទីណា សេចក្តីងងឹតក្នុងទីនោះ ក៏នឹងមានមកពីទីណា ។ ម្យ៉ាងទៀត ការកម្ចាត់សេចក្តីងងឹត ក៏គឺព្រះចន្ទ និងព្រះអាទិត្យ ព្រោះដូច្នោះ ព្រះចន្ទ និងព្រះអាទិត្យទាំងពីរមែងមិនមានក្នុងព្រះនិព្វានណា ។ ដោយពាក្យនេះ ទ្រង់សម្តែងដល់ព្រះនិព្វានមានសេចក្តីស្វាងស្ងៃជាសភាវៈ ។

ក៏ពាក្យដំបូងត្រឹមតែប៉ុណ្ណោះ ព្រះធម្មរាជា កាលនឹងទ្រង់ប្រកាសអមត-និព្វាន ដែលមិនធ្លាប់មានក្នុងសង្សារដែលរកខាងដើមមិនបាន សម្បីទីបំផុតនៃសុបិន្ត ជ្រៅដោយបរមត្ថ ឃើញបានលំបាកយ៉ាងក្រៃលែង ល្អិតសុខុម មិនជារបស់ប្រព្រឹត្តទៅតាមសេចក្តីត្រិះរិះ សូប់ដោយចំណែកមួយ មានតែបណ្ឌិតទើបដឹងបាន ដ៏ប្រណីតក្រៃលែងជាអមតៈដល់ភិក្ខុទាំងឡាយ អ្នកមិនទាន់បានសម្រេច ទើបឱ្យភិក្ខុទាំងនោះ កម្ចាត់ភាពលួងជាដើមចេញ ព្រោះព្រះនិព្វាននោះ មាន ដូចបាលីថា **អត្ថि ภิกฺขเว ตทายตนํ** *ដូច្នេះជាដើម ទើបទ្រង់ប្រកាសព្រះនិព្វាននោះដោយប្រមុខ គឺសេចក្តីមិនលួងក្នុងធម៌ដទៃពីព្រះនិព្វាននោះថា* **យตฺถ เนว ปฐวี ។បេ។ น อุโภ จนฺทิมสุริยา** *ដូច្នេះជាដើម ។ ដោយពាក្យនោះ ជាការសម្តែងថា អសង្ខតធាតុ ដែលមានសភាវៈខុសពីសង្ខតធម៌ទាំងពួងមានបឋវីជាដើមថា ព្រះនิព្វាន ។ ព្រោះហេតុនោះនុ៎ះឯង ព្រះអង្គទើបត្រាស់ថា* **ตตฺราหํ ภิกฺขเว เนว อาคตึ วทามิ** *ដូច្នេះជាដើម ។*

បណ្តាបទទាំងនោះ បទថា **តត្រ** *ប្រែថា ក្នុងនិញ្ជននោះ ។* **អបិ**-*ស័ព្ទ ប្រើក្នុងអត្ថសមុច្ចយៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលការមករបស់អ្វីៗ ពីទីណាៗ ដែលប្រព្រឹត្តទៅតាមសង្ខារ ព្រោះហេតុត្រឹមតែថា ធម៌កើតក្នុងព្រះនិញ្ជននោះតាមបច្ច័យ ម្យ៉ាងទៀត តថាគតមិនពោលអនាគមនៈ គឺការមកពីទីណាៗ ក្នុងអាយតនៈ គឺព្រះនិញ្ជននោះយ៉ាងនេះ ព្រោះនិញ្ជនមិនមានឋានៈដែលនឹងគប្បីមក ។ បទថា* **ន ឋានី** *សេចក្ដីថា តថាគតមិនពោលការទៅទីណា ព្រោះឋានៈដែលព្រះនិញ្ជននឹងគប្បីទៅមិនមាន ។ ព្រោះការមក និងការទៅរបស់សត្វទាំងឡាយ រៀរការធ្វើឱ្យជាអារម្មណ៍ដោយញាណ មិនមានក្នុងព្រះនិញ្ជននោះ ។ ម្យ៉ាងទៀត តថាគតមិនពោលដល់ឋិតិ ចុតិ និងឧប្បត្តិ ។ បាលីថា* **ឋ ឧបហំ** *ដូច្នេះក៏មាន ។ សេចក្ដីរបស់ព្រះបាលីនោះមានដូច្នេះ អាយតនៈសូម្បីនោះ ឈ្មោះថា មិនមានការមក ព្រោះជាឋានៈដែលមិនគួរមក ដូចពីចន្លោះស្រុក មកកាន់ចន្លោះស្រុក ។ ឈ្មោះថា មិនមានការទៅ ព្រោះមិនទីដែលនិងគប្បីគួរទៅ ឈ្មោះថា មិនមានឋិតិ ព្រោះមិនមានឋានៈដែលនិងតាំងនៅ ដូចផែនដី និងភ្នំជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា មិនមានការកើត ព្រោះមិនមានបច្ច័យ ឈ្មោះថា មិនមានចុតិ ព្រោះមិនមានការស្លាប់ជាសភាវៈនោះ ។ តថាគតមិនពោលឋិតិ ចុតិ និងឧប្បត្តិ ព្រោះមិនមានការកើត និងការរលត់ និងព្រោះមិនមានការតាំងនៅដែលកំណត់ដោយការកើត និងការរលត់ទាំង ២ នោះ ។ ម្យ៉ាងទៀត ព្រះនិញ្ជននោះសុទ្ធតែមានឈ្មោះថា មិនតាំងនៅក្នុងទីណា ព្រោះមានសភាវៈជាអរូប និងព្រោះមិនមានបច្ច័យ ព្រោះហេតុនោះ ទើបឈ្មោះ*

ថា មិនមានទីតាំង ។ ឈ្មោះថា មិនប្រព្រឹត្តទៅ ព្រោះមិនមានការប្រព្រឹត្តទៅ ព្រម និងព្រោះជាបដិបក្ខចំពោះការប្រព្រឹត្តទៅក្នុងព្រះនិព្វានៃ ។ ឈ្មោះថា មិនមានអារម្មណ៍ ព្រោះមិនមានអារម្មណ៍អ្វីៗ ជាទីតោងស្ពិត និងព្រោះមិនប្រាជ្ញាដល់អារម្មណ៍ដែលឧបត្ថម្ភ ដូចសម្បយុត្តធម៌ មានវេទនាជាដើម សូម្បីសភាវៈជារូប (ជានាម) ព្រោះដូច្នោះ ព្រះនិព្វានៃ លោកទើបពោលថា អាយតនៃ ។ ក៏ **ឯ**-ស័ព្ទនេះ គប្បីប្រកបដោយបទទាំង ២ គឺ**អប្បតិដ្ឋមេវ អប្បវត្តមេវ** ។ បទថា **ឯសេវន្តោ ទុក្ខស្ស** សេចក្ដីថា ព្រះនិព្វានដែលមានលក្ខណៈតាមដែលពោលហើយ ដែលព្រះដ៏មានព្រះភាគត្រាស់សរសើរដោយពាក្យមានជាអាទិ៍ថា **អប្បតិដ្ឋំ** ដូច្នេះនុ៎ះឯង ឈ្មោះថា ជាទីបំផុត គឺចុងបំផុតនៃវដ្ដទុក្ខទាំងអស់ ព្រោះកាលមានការសម្រេចព្រះនិព្វាន ទុក្ខទាំងអស់ក៏មិនមាន ព្រោះហេតុដូច្នោះ ទើបទ្រង់សម្ដែងថា សភាវៈនៃព្រះនិព្វានៃ គឺជាទីបំផុតនៃទុក្ខនុ៎ះឯង ។

បឋមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១

២. ទុតិយនិព្វានបដិសំយុត្តសុត្តវណ្ណនា

អដ្ឋកថាទុតិយនិព្វានបដិសំយុត្តសូត្រ

ទុតិយនិព្វានបដិសំយុត្តសូត្រទី ២ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **ឥមំ ឧទានំ** *សេចក្តីថា ព្រះដ៏មានព្រះភាគ ទ្រង់បន្ទឺឧទាននេះ ដែលសម្តែងដល់ការៈដែលព្រះនិព្វានឃើញបានលំបាក ព្រោះតាមប្រក្រតី ជាគុណជាតិជ្រាលជ្រៅ ។*

បណ្តាបទទាំងនោះ បទថា **ទុទ្ទសំ** *សេចក្តីថា ព្រះនិព្វាន ឈ្មោះថាឃើញបានលំបាក ព្រោះអ្នកណាៗ មិនអាចនឹងឃើញបានដោយគ្រឿងបម្រុងគឺញាណដែលមិនធ្លាប់បានអប់រំមក ព្រោះមានសភាវៈជ្រាលជ្រៅ និងព្រោះមានសភាវៈល្អិតសុខុមយ៉ាងក្រៃលែង ។ សមដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលមាគណ្ឌិយៈ អ្នកត្រូវដឹងនូវការមិនមានរោគ ត្រូវឃើញនូវព្រះនិព្វានដោយចក្ខុ (សំដៅយកវិបស្សនាញាណ និងមគ្គញ្ញាណ) ដ៏ប្រសើរណា ចក្ខុដ៏ប្រសើរនោះ របស់អ្នកមិនមានទេ[១] ។ ព្រះដ៏មានព្រះភាគត្រាស់ទុកទៀតថា នេះជាឋានៈ ដែលពួកសត្វឃើញបានដោយក្រ ធម៌ដែលជាគ្រឿងរំងាប់នូវសង្ខារទាំងពួង[២] ដូច្នេះជាដើម ។ បទថា* **អនត្តំ** *សេចក្តីថា តណ្ហា*

១-សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ លេខ ២៤ ទំព័រ ៨៤ ។

២-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ៧៦ ។

ឈ្មោះថា **នត:** ព្រោះបង្អោនទៅក្នុងអារម្មណ៍ មានរូបជាដើម និងក្នុងភព មានកាមភពជាដើម ព្រោះប្រព្រឹត្តទៅដោយការ: ដែលបង្អោនទៅក្នុងអារម្មណ៍ និងកាមនោះ ព្រោះសត្វទាំងឡាយ បង្អោនទៅក្នុងអារម្មណ៍ និងកាមភពជាដើមនោះ ។ ព្រះនិព្វានទើបឈ្មោះថា **អមត:** ព្រោះមិនជាទីដែលសត្វបង្អោនទៅ ។ អាចារ្យពួកខ្លះពោលថា **អនន្តំ** ដូច្នេះក៏មាន ។ អធិប្បាយថា ព្រះនិព្វាន ឈ្មោះថា វៀរចាកទីបំផុត គឺមិនមានចុតិជាធម៌ ជាការរលត់ បានដល់ ជាអមត: ព្រោះមានសភាវ:ពិត ។ តែអាចារ្យពួកខ្លះពោលសេចក្តីនៃបទថា **អនន្តំ** ថាជា **អប្បមាណំ** ។ ក៏ក្នុងពាក្យទាំងនោះ ដោយពាក្យថា **ទុទ្ទសំ** នេះ ព្រះអង្គទ្រង់សម្តែងដល់សេចក្តីដែលព្រះនិព្វាន ដែលសត្វគប្បីដល់បានដោយបញ្ញា ការដែលសត្វទាំងឡាយធ្វើព្រះនិព្វានដែលរកបច្ច័យមិនបានឱ្យកើត មិនមែនធ្វើបានងាយ ព្រោះសត្វទាំងនោះត្រូវកិលេស មានរាគ:ជាដើម ដែលធ្វើបញ្ញាទុព្វល ឱ្យមានមកយូរ ។ ដោយបទថា **ន ហិ សច្ចំ សុទស្សនំ** សូម្បីនេះ ព្រះអង្គទ្រង់ធ្វើសេចក្តីនោះឯងឱ្យប្រាកដ ។ បណ្តាបទទាំងនោះ បទថា **សច្ចំ** បានដល់ព្រះនិព្វាន ។ មែនពិត ព្រះនិព្វាននោះ ឈ្មោះថា **សច្ច:** ព្រោះអត្ថថា មិនខុសប្លែក ហេតុជាគុណជាតស្ងប់តែម្យ៉ាង ព្រោះមិនមានសភាវ:ដែលមិនស្ងប់

ដោយបរិយាយណាៗ ។

ម្យ៉ាងទៀត ព្រះនិព្វាននោះ ឈ្មោះថា មិនមែនឃើញបានងាយ គឺអ្នកណាៗ មិនគប្បីឃើញបានដោយងាយ ព្រោះដល់នឹងរួបរួមបុញ្ញសម្ភារ និងញាណសម្ភារ មករហូតអស់កាលយូរ ក៏ញ៉ាំងឱ្យសម្រេចបានដោយលំបាកតែម្តង ។ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ព្រះនិព្វានតថាគតសម្រេចបានលំបាក ។ បទថា **បដិវិជ្ឌា តណ្ហា ជាតេ បស្ស្ជ្ជ ជ ន ត្ថ ិ ភ ិ ញ្ជ ំ** សេចក្តីថា បើនិរោធសច្ចៈនោះដែលអ្នកនឹងត្រាស់ដឹងបានដោយការដឹងដល់អារម្មណ៍ និងការដឹងព្រោះមិនមានមោហៈ ដូចទុក្ខសច្ចៈ ដែលត្រាស់ដឹងបានដោយបរិញ្ញាភិសមយ និងមគ្គសច្ចៈ ដែលត្រាស់ដឹងបានដោយភាវនាភិសមយ គឺការដឹងព្រោះមិនមានមោហៈ ដោយអាការយ៉ាងនេះ ជាការដឹងច្បាស់ដល់ការអស់តណ្ហា ដោយបហានាភិសមយ ព្រោះមិនមានមោហៈ ។ ក៏កាលបុគ្គលឃើញសច្ចៈ ៤ ដោយបញ្ញា ដែលសម្បយុត្តដោយអរិយមគ្គតាមពិតយ៉ាងនេះ ឈ្មោះថា រមែងមិនមានតណ្ហា ដែលជាហេតុនាំសត្វទៅក្នុងភពជាដើម កាលតណ្ហានោះមិនមាន កិលេសវដ្តៈ សូម្បីទាំងអស់ ក៏មិនមានតអំពីនោះ កម្មវដ្តៈ និងវិបាកវដ្តៈ ក៏មិនមានដូចគ្នា ។

ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសអានុភាពនៃអមតមហានិព្វានដែលជាហេតុសូប់រំងាប់វដ្តទុក្ខបានដាច់ខាត ដល់ភិក្ខុទាំងឡាយទាំងនោះ ដោយប្រការដូច្នេះ ។ ពាក្យដែលនៅសល់មានន័យដូចពោលហើយនុ៎ះឯង។

ឧតិយសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ២

៣. តតិយនិព្វានបដិសំយុត្តសុត្តវណ្ណនា

អដ្ឋកថាតតិយនិព្វានបដិសំយុត្តសូត្រ

តតិយនិព្វានបដិសំយុត្តសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **អថ ខោ ភគវា ឯតមត្ថំ វិទិត្វា** *សេចក្តីថា បានឮថា ក្នុងកាលនោះ កាលព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសទោសក្នុងសង្ខារ ដោយអនេកបរិយាយ ហើយទ្រង់សម្តែងព្រះធម្មទេសនាដែលជាប់ដោយព្រះនិព្វាន ដោយការសម្តែងប្រៀបធ្ងឹមជាដើម ហើយកិក្ខុទាំងនោះមានការគិតដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសសង្ខារនេះ ព្រមដោយហេតុ មានអវិជ្ជាជាដើម ដែលឈ្មោះថា សហេតុក: តែមិនត្រាស់ដល់ហេតុអ្វីនៃព្រះនិព្វានដែល ជាហេតុសូប់ចាកសង្ខារនោះ ព្រះនិព្វាននេះនោះចាត់ជាអហេតុក: តើអហេតុក:នោះនឹងកើត ព្រោះអត្ថថា មានការធ្វើឱ្យជាក់ច្បាស់ និងមានអត្ថដោយបរមត្ថយ៉ាងណា ។*

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបអត្ថនេះ តាមដែលពោលហើយ របស់កិក្ខុទាំងនោះ ។ បទថា **ឥមំ ឧទានំ** *សេចក្តីថា ព្រះអង្គទ្រង់បន្ទឺឧទាននេះ ដែលជាហេតុប្រកាសអមតមហានិព្វាន ដែលមានដោយបរមត្ថ ដើម្បីកាច់បំបាក់ មិច្ឆាវាទ:របស់សមណព្រាហ្មណ៍ក្នុងលោកនេះ អ្នកបដិបត្តិខុស អ្នកមានទិដ្ឋិគតិ ក្រាស់ សូម្បីក្នុងខាងក្រៅតែម្តង ដូចបុគ្គលដែលប្រកាន់លោកជាធំថា ពាក្យថា*

និព្វាន និព្វាន ត្រឹមតែជារឿងនិយាយគ្នាប៉ុណ្ណោះ តែសេចក្តីពិត កាលពោលដោយ បរមត្ថ ឈ្មោះថា ព្រះនិព្វាន រមែងមិនមាន ព្រោះមានការមិនកើតជាសភាវៈ ។

បណ្តាបទទាំងនោះ បទថា **អជាតំ អភតំ អកាតំ អសង្ខ្ជតំ** ទាំងអស់ ជាវេវចនៈរបស់គ្នា និងគ្នា ។ ម្យ៉ាងទៀត ព្រះនិព្វាន ឈ្មោះថា **អជាតៈ** ព្រោះ មិនកើត គឺមិនគប្បីកើត ព្រោះការដល់ព្រមនៃហេតុ គឺការប្រជុំនៃហេតុ និង បច្ច័យ ដូចវេទនាជាដើម ឈ្មោះថា **អភូតៈ** ព្រោះរៀរចាកហេតុ និងខ្លួនឯងចេញ រមែងមិនមាន គឺមិនប្រាកដ បានដល់ មិនកើត ឈ្មោះថា **អកតៈ** ព្រោះហេតុ យ៉ាងណាមួយ មិនសាងឡើងព្រោះមិនកើត និងព្រោះមិនមានយ៉ាងនេះ ។ ម្យ៉ាងទៀត ដើម្បីនឹងសម្តែងថា សង្ខ្ជតធម៌ មាននាម និងរូបជាដើម មានការកើត ការមានការសាងឡើងជាសភាវៈ ព្រះនិព្វានដែលមានអសង្ខ្ជតធម៌ជាសភាវៈ មិន ដូច្នោះទេ ទើបត្រាស់ថា **អសង្ខ្ជតំ** ដូច្នេះ ។ ម្យ៉ាងទៀត កាលពោលអំពីបដិលោម ទើបត្រាស់ថា សង្ខ្ជតធម៌ ព្រោះត្រូវបច្ច័យអាស្រ័យគ្នា និងគ្នាសាងឱ្យមានឡើង ។ ម្យ៉ាងទៀត លោកពោលថា ជាអសង្ខ្ជតៈ ព្រោះមិនមានបច្ច័យតាក់តែង គឺរៀរ ចាកលក្ខណៈដែលត្រូវបច្ច័យតាក់តែង ។ កាលភាវៈដែលព្រះនិព្វានកើត ដោយ ហេតុច្រើនអនេកយ៉ាងនេះសម្រេចហើយ ដើម្បីនឹងសម្តែងថា ព្រះនិព្វានមិន មានបច្ច័យអ្វីតាក់តែងឡើង ដោយសេចក្តីរង្គៀសថា ព្រះនិព្វាន និងគប្បីមាន

ហេតុតែម្យ៉ាង តាក់តែងឬហ្ន៏ ប្រព្រឹត្តទៅមិនបាន ទើបត្រាស់ថា **អភូតំ** ។ ដើម្បីនឹងសម្តែងថា ព្រះនិញ្ចានេះនោះមិនមានបច្ច័យទំនុកបម្រុង មិនបានតាក់តែង មិនមាន នេះនឹងមានព្រោះព្រះនិញ្ចានមានការមិនកើតជាធម្មតា ដោយប្រការទាំងពួង ទើបត្រាស់ **អជាតំ** ។ បណ្ឌិតគប្បីជ្រាបសេចក្តីនៃបទទាំង ៤ នេះ មានអត្ថយ៉ាងនេះហើយ គប្បីជ្រាបថា ព្រះដ៏មានព្រះភាគទ្រង់ប្រកាសថា ព្រះនិញ្ចានមានដោយបរមត្ថ ដោយព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ព្រះនិញ្ចានេះ នោះមាន ។ ក៏ក្នុងព្រះសូត្រនេះ គប្បីជ្រាបហេតុក្នុងបទអាលបន:ថា **ភិក្ខវេ** ដោយន័យដែលព្រះដ៏មានព្រះភាគ កាលទ្រង់បន្ទ្ធី ទើបត្រាស់ទុកហើយក្នុងកាលមុននោះឯង ។ ព្រោះដូច្នោះ ព្រះសាស្តាកាលត្រាស់ថា ម្នាលភិក្ខុឡាយ ព្រះនិញ្ចានមិនកើត មិនមានបច្ច័យ មិនតាក់តែង មិនសន្សំ មាន កាលនឹងទ្រង់សម្តែងហេតុក្នុងសេចក្តីនោះ ទើបត្រាស់ពាក្យថា **ណោ ចេ តំ ភិក្ខវេ** ដូច្នេះជាដើម ។ ព្រះបាលីនោះមានសេចក្តីសង្ខេបដូចតទៅនេះ ម្នាលភិក្ខុទាំងឡាយ បើអសង្ខ-ធាតុ ដែលមានសភាវ:មិនកើតជាដើម នឹងមិនមាន ឬនឹងមិនគប្បីមាន សេចក្តីរលាស់ចេញ គឺសេចក្តីស្ងប់ដោយមិនឱ្យសេសសល់នូវសង្ខ្ធត: ពោលគឺ ខន្ធ ៥ មានរូបជាដើម ដែលមានសភាវ:កើតឡើងជាដើម មិនប្រាកដ មិនកើត គឺមិនមានក្នុងលោកនេះ ។ មែនពិត ធម៌ គឺអរិយមគ្ត មានសម្មាទិដ្ឋិជាដើម ដែលធ្វើព្រះនិញ្ចានឱ្យជាអារម្មណ៍កើតឡើង រមែងកាត់កិលេសបានដាច់ជាសមុច្ឆេទ ។

ព្រោះហេតុនោះ ក្នុងទីនេះ ការមិនប្រព្រឹត្តទៅ ការប្រាសចាកទៅ ការរលាស់ចេញនៃវដ្តទុក្ខទាំងអស់រមែងប្រាកដ ។

ព្រះដ៏មានព្រះភាគ គ្រាទ្រង់សម្តែងដល់ព្រះនិព្វាន មានដោយការ:ផ្ទុយគ្នា ឥឡូវនេះ ដើម្បីនឹងសម្តែងព្រះនិព្វាននោះ ដោយន័យដែលស្របតាមទើបត្រាស់ពាក្យមានជាអាទិ៍ថា **យស្មា ច ខោ** ដូច្នេះ ។ ពាក្យនោះមានអត្ថដូចពោលហើយនុ៎ះឯង ។ ក៏ក្នុងទីនេះ ព្រោះហេតុដែលព្រះសម្មាសម្ពុទ្ធ កាលនឹងទ្រង់អនុគ្រោះដល់សត្វលោកទាំងអស់ ទើបទ្រង់សម្តែងការកើតមាននៃនិព្វាន-ធាតុដោយបរមត្ថ ដោយសុត្តបទជាអនេក មានជាអាទិ៍ថា ពួកធម៌ដែលមិនមានបច្ច័យ ពួកធម៌ឥតបច្ច័យតាក់តែង[១] ម្នាលភិក្ខុទាំងឡាយ អាយតន:នោះរមែងមានពិត ដ៏មិនមាន ក្នុងព្រះនិព្វានណា[២]... ឋាន:នេះ (ពួកសត្វដែលមានកាម-គុណជាទីត្រេកអរ) ឃើញបានដោយក្រ ធម៌ដែលជាគ្រឿងរំងាប់នូវសង្ខារទាំងពួង លះបង់នូវឧបធិក្កិលេសទាំងពួង ឋាន:សូម្បីនេះឃើញបានលំបាក គឺសេចក្តីសូប់សង្ខារទាំងពួង[៣] និងដោយសូត្រសូម្បីនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងព្រះនិព្វានជាអសង្ខតធម៌ផង នូវបដិបទាជាគ្រឿងសម្រេច

១-អភិធម្មបិដក ធម្មសង្គណី លេខ ៧៨ ទំព័រ ៤ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន លេខ ៥២ ទំព័រ ៣២០ ។

៣-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ៧៦ ។

នូវព្រះនិញ្ចានជាអសង្ខតធម៌ផង ដល់អ្នកទាំងឡាយ ព្រោះដូច្នោះ សូម្បីបើវិញ្ញូជន អ្នកធ្វើមិនឱ្យប្រចក្សក្នុងព្រះនិញ្ចាននោះ ក៏រមែងមិនមានសេចក្តីសង្ស័យ ឬ សេចក្តីជឿងធ្ងល់ឡើយ ។ ដើម្បីនឹងបន្ទោបង់សេចក្តីជឿងធ្ងល់របស់ពួកបុគ្គល អ្នកមានសេចក្តីដឹងក្នុងការណែនាំអ្នកដទៃ ក្នុងសេចក្តីនេះមានអធិប្បាយដូចត ទៅនេះ ។ ការរលាស់ចេញ ដែលជាបដិបក្ខចំពោះកាម និងអារម្មណ៍ មានរូប ជាដើម ជាសភាវៈធ្ងេង គឺដែលមានសភាវៈខុសគ្នាពីនោះ រមែងប្រាកដចំពោះ មុខ គឺការដកចេញពីទុក្ខ ឬព្រោះកំណត់ដឹង ដែលមានការពិចារណាដ៏សមរម្យ ព្រះនិញ្ចានដែលជាបដិបក្ខចំពោះសង្ខតធម៌ទាំងអស់ ដែលមានសភាពដូច្នោះ គឺមានសភាវៈខុសគ្នាពីនោះ គប្បីជាគ្រឿងរលាស់ចេញ ។ ក៏ព្រះនិញ្ចាន ដែល មានគ្រឿងរលាស់ចេញចាកទុក្ខនោះ ក៏គឺអសង្ខតធាតុ ។ គប្បីជ្រាបឱ្យក្រៃលែង ឡើងទៅទៀតបន្តិចបន្តួច ។ វិបស្សនាញ្ញាណក្តី អនុលោមញ្ញាណក្តី ដែលមាន សង្ខតធម៌ជាអារម្មណ៍ រមែងមិនអាចនឹងលះកិលេសបានដាច់ ។ ម្យ៉ាងទៀត ញ្ញាណក្នុងបឋមជ្ឈានជាដើម ដែលមានសម្មតិសច្ចៈអារម្មណ៍ រមែងលះ កិលេសបាន ដោយវិក្ខម្ភនបហានប៉ុណ្ណោះ តែមិនអាចលះបានដោយសមុច្ឆេទ-បហានទេ ។ ព្រោះដូច្នោះ អរិយមគ្គញ្ញាណ ដែលធ្វើការលះកិលេសទាំងនោះ បានដាច់ ក៏គប្បីជាអារម្មណ៍ ដែលមានសភាវៈខុសគ្នាពីញ្ញាណទាំងពីរនោះ ព្រោះញ្ញាណដែលមានសង្ខតធម៌ជាអារម្មណ៍ និងមានសម្មតិសច្ចៈជាអារម្មណ៍

*មិនអាចលះកិលេសជាសមុច្ឆេទបានទេ ឈ្មោះថា អសង្ខតធាតុ ។ ម្យ៉ាងទៀត ព្រះតម្រាស់ដែលបំភ្លឺដល់បទនៃព្រះនិព្វាន ដែលមានដោយបរមត្ថ ព្រះដ៏មាន-ព្រះភាគត្រាស់ថា ជាអត្ថដែលមិនខុសប្លែក ដូចបាលីនេះថា ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានមិនកើត មិនមាននូវបច្ច័យអ្វី មិនតាក់តែង មិនសន្សំ មាន មែនពិត ពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុក មានអត្ថមិនខុស ដូចត្រាស់ទុកថា សង្ខារទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ ធម៌ទាំងពួងជាអនត្តា ដូច្នេះ ។ ម្យ៉ាងទៀត និព្វានស័ព្ទ មានបរមត្ថជាអារម្មណ៍ តាមសេចក្តីពិត សូម្បីក្នុងអារម្មណ៍ខ្ទះ ព្រោះកើតមាន ការប្រព្រឹត្តទៅត្រឹមតែជាឧបចារៈ ដូច**សីហ**-ស័ព្ទ ។ ម្យ៉ាងទៀត គប្បីជ្រាបអសង្ខតធាតុមានដោយបរមត្ថ សូម្បីដោយការប្រកបដោយន័យមានជាអាទិ៍យ៉ាងនេះថា ព្រោះព្រះនិព្វាន មានសភាវៈផុតពីវត្ថុដែលមានភាវៈផ្ទុយគ្នានោះ ក្រៅពីនេះ ដូចបឋវីធាតុ ឬវេទនា ។*

តតិយសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៣

៤. ចតុត្ថនិព្វានបដិសំយុត្តសុត្តវណ្ណនា

អដ្ឋកថាចតុត្ថនិព្វានបដិសំយុត្តសូត្រ

ចតុត្ថនិព្វានបដិសំយុត្តសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **អថ ខោ ភគវា ឯតមត្ថំ វិទិត្វា** *សេចក្តីថា បានឮថា ក្នុងកាលនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងព្រះធម្មទេសនា ដែលជាប់ដោយព្រះនិព្វាន ដោយសម្តែងការប្រៀបធ្ងឹមជាដើម ដោយអនេកបរិយាយ ហើយភិក្ខុទាំងនោះ មានការគិតយ៉ាងនេះថា ជាដំបូង ព្រះដ៏មានព្រះភាគកាលនឹងទ្រង់សម្តែងអានិសង្សដែលមានខន្ធ មានអាការជាអនេកនៃអមតមហានិព្វាន-ធាតុ ទើបទ្រង់ប្រកាសអានុភាពនេះ ដែលមិនទូទៅដល់អ្នកដទៃ ។ តែមិនត្រាស់ឧបាយជាគ្រឿងសម្រេចអមតមហានិព្វានធាតុនោះ ពួកយើងកាលបដិបត្តិនឹងគប្បីសម្រេចអមតមហានិព្វាននេះដោយវិធីយ៉ាងណាហ្ន៏ ។ លំដាប់នោះ ព្រះដ៏-មានព្រះភាគទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ត ពោលគឺ ភាវៈដែលភិក្ខុនោះមានបរិវិតក្ក: តាមដែលពោលហើយនេះ ។ បទថា* **ឥមំ ឧទានំ** *សេចក្តីថា ព្រះអង្គទ្រង់បន្ទឺឧទាននេះ ដែលប្រកាសដល់ការសម្រេចព្រះនិព្វាន ដោយការលះតណ្ហាបានដាច់ខាត ដោយអរិយមគ្គ របស់បុគ្គលអ្នកចម្រើនវិបស្សនាដែលប្រព្រឹត្តទៅតាមវិជីចិត្ត មានកាយ និងចិត្តស្ងប់រំងាប់ មិនពឹងអាស្រ័យក្នុងអារម្មណ៍ណា ដោយអំណាចតណ្ហា ។*

បណ្តាបទទាំងនោះ បទថា **និស្សិតស្ស ចលិតំ** សេចក្តីថា បុគ្គលដែលត្រូវតណ្ហា និងទិដ្ឋិចូលអាស្រ័យក្នុងសង្ខារ មានរូបជាដើម រមែងញាប់ញ័រ គឺរមែងក្តៅក្រហាយ ព្រោះតណ្ហា និងទិដ្ឋិថា នោះជារបស់អញ នោះជាខ្លួនរបស់អញ ។ មែនពិត កាលបុគ្គលលះតណ្ហា និងទិដ្ឋិមិនបាន កាលសុខវេទនាជាដើមកើតឡើង មិនអាចនឹងគ្របសង្កត់វេទនា មានសុខវេទនាជាដើមទាំងនោះ មានចិត្តសន្ធានក្តៅក្រហាយ ក្រមើកញាប់ញ័រ ដែលនាំចេញហើយ ព្រោះឱ្យកុសលកើតឡើងដោយអំណាចការប្រកាន់តណ្ហា និងទិដ្ឋិ ដោយន័យមានជាអាទិ៍ថា វេទនារបស់អញ អញសោយវេទនា ។ បទថា **អនិស្សិតស្ស ចលិតំ ឧត្តិ** សេចក្តីថា ក៏បុគ្គលណាដើរទៅតាមវិសុទ្ធិបដិបទា រមែងគ្របសង្កត់តណ្ហា និងទិដ្ឋិបានដោយសមថ: និងវិបស្សនា រមែងពិចារណាឃើញសង្ខារ ដោយលក្ខណ: មានអនិច្ចលក្ខណ:ជាដើម បុគ្គលនោះ គឺអ្នកមិនត្រូវតណ្ហា និងទិដ្ឋិអាស្រ័យ រមែងមិនមានចិត្តញាប់ញ័រ រវើរវាយ ក្តៅក្រហាយ តាមដែលពោលហើយនោះ ព្រោះគ្របសង្កត់ហេតុបានដោយល្អហើយ ។

បទថា **ចលិតេ អសតិ** សេចក្តីថា កាលចិត្តមិនញាប់ញ័រ តាមដែលពោលហើយ ក៏ធ្វើចិត្តនោះ ឱ្យកើតសេចក្តីខ្ជល់ខ្ជាយក្នុងវិបស្សនាដែលប្រព្រឹត្តទៅតាមវិជីចិត្ត ដោយការប្រកាន់តណ្ហា និងទិដ្ឋិកើតឡើងមិនបាន ។ បទថា

បស្សទ្ធិ *សេចក្តីថា បស្សទ្ធិទាំង ២ យ៉ាង ដែលចូលទៅសូប់កិលេស ដែលធ្វើសេចក្តីខ្ជល់ខ្ចាយកាយ និងចិត្ត ដែលកើតរួមនឹងវិបស្សនាចិត្ត ។ បទថា* **បស្សទ្ធិ-យា សតិ រតិ ន ហោតិ**[1] *សេចក្តីថា កាលបស្សទ្ធិ ដែលគួរដល់គុណវិសេសមុន និងក្រោយមាន លោកចម្រើនសមាធិ មានសេចក្តីសុខដែលប្រាសចាកទោសជាទីតាំង ហើយទើបប្រកបសមថ: និងវិបស្សនាឱ្យជាប់គ្នាជាគូ ដោយធ្វើសមាធិនោះ ឱ្យរួមជាមួយវិបស្សនា ហើយធ្វើកិលេសឱ្យអស់ទៅដោយបន្តៗនៃមគ្គ តណ្ហាដែលបានឈ្មោះថា* **រតិ** *ព្រោះបង្ហោនទៅក្នុងកាមភពជាដើម មិនមានក្នុងខណ:នៃអរិយមគ្គ ដោយជាប់ខាត អធិប្បាយថា មិនកើតឡើង ព្រោះឱ្យដល់នូវការមិនកើតឡើងជាធម្មតា ។*

បទថា **រតិយា អសតិ** *សេចក្តីថា កាលមិនមានបរិយុដ្ឋានកិលេស គឺសេចក្តីអាល័យ និងសេចក្តីជាប់ដើម្បីភពជាដើម ព្រោះលះតណ្ហាបានជាប់ដោយអរហត្តមគ្គ ។ បទថា* **អាគតិគតិ ន ហោតិ** *សេចក្តីថា ការមក គឺសេចក្តីមកក្នុងលោកនេះដោយអំណាចបដិសន្ធិ ការទៅ គឺការទៅពីលោកនេះកាន់បរលោក បានដល់ សេចក្តីលះទៅ ដោយអំណាចបដិសន្ធិ រមែងមិនមាន បានដល់ រមែងមិនកើត ។ បទថា* **អាគតិគតិយា អសតិ** *សេចក្តីថា មិនមាន*

១-ក្នុងអដ្ឋកថាច្បាប់ធម្មសង្គាយនាលោកសរសេរថា **បស្សទ្ធិយា សតិ ន តិ ន ហោតិ** *។*

ការមក និងការទៅ ដោយន័យដូចពោលហើយ ។ បទថា **ចុតូបចាតো ន ហោតি** សេចក្តីថា ការចុតិ និងឧប្បត្តិទៅមក រមែងមិនមាន គឺរមែងមិនកើត ។ មែនពិត កាលមិនមានកិលេសវដ្ដ: កម្មវដ្ដ:ក៏ដាច់ទៅឯង និងកាលកម្មវដ្ដ: នោះដាច់ទៅ វិបាកវដ្ដ:នឹងមានមកពីណា ព្រោះហេតុនោះនុ៎ះឯង លោកទើបពោលថា កាលមិនមានចុតិ និងឧប្បត្តិ លោកនេះ និងលោកខាងមុខក៏មិនមានដូច្នេះជាដើម ។ ពាក្យដែលគួរពោលក្នុងសេចក្តីនោះ ខ្ញុំបានពោលទុកហើយ ដោយពិស្តារក្នុងពាហិយសូត្រ ក្នុងកាលមុននុ៎ះឯង ។ ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីដោយន័យដូចពោលហើយក្នុងពាហិយសូត្រនុ៎ះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសអានុភាពនៃអមតមហានិព្វានដែលជាហេតុសូប់ទុក្ខក្នុងវដ្ដ:ដោយមិនឱ្យសេសសល់ ដោយសម្មាបដិបត្តិដល់ភិក្ខុទាំងនោះ ក្នុងព្រះសាសនាសូម្បីនេះដោយប្រការដូច្នេះ ។

ចតុត្ថសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៤

៤.ចុន្ទសុត្តវណ្ណា

អដ្ឋកថាចុន្ទសូត្រ

ចុន្ទសូត្រទី ៤ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **មល្លេសុ** *បានដល់ ក្នុងជនបទ មានឈ្មោះយ៉ាងនោះ ។ បទថា* **មហាតាកិក្ខុសង្ឆេន** *បានដល់ ឈ្មោះថា ធំ ព្រោះធំដោយគុណ និងច្រើនដោយចំនួន ។ មែនពិត ភិក្ខុសង្ឆនោះ ឈ្មោះថា ធំ សូម្បីដោយប្រកបដោយគុណពិសេសមានសីលជាដើម ព្រោះបណ្តាភិក្ខុទាំងនោះ ភិក្ខុអ្នកក្រោយគេទាំងអស់ ក៏ជាព្រះសោតាបន្ន ឈ្មោះថា ធំ ដោយការធំ ដោយចំនួន ព្រោះកំណត់ចំនួនមិនបាន ។ មែនពិត ចាប់ផ្តើមតាំងពីវេលាដាក់អាយុសង្ខារ ភិក្ខុទាំងឡាយអ្នកមកហើយ មិនបានជៀសចេញទៅឡើយ ។*

បទថា **ចុន្ទស្ស** *បានដល់ អ្នកមានឈ្មោះយ៉ាងនោះ ។ បទថា* **កម្មារ-បុត្តស្ស** *បានដល់ បុត្ររបស់ជាងមាស ។ មានសេចក្តីដំណាលមកថា បុត្ររបស់ជាងមាសនោះ ជាអ្នកស្តុកស្តម្ភ ជាមហាកុដុម្ពិក៍ ជាព្រះសោតាបន្ន ដោយការឃើញព្រះដ៏មានព្រះភាគ ជាគ្រាដំបូងនុ៎ះឯង ចាត់ចែងព្រះគន្ធកុដិដែលគួរដល់ការប្រថាប់នៅរបស់ព្រះសាស្តា និងទីសម្រាកក្នុងវេលាយប់ ទីសម្រាកក្នុងវេលាថ្ងៃដល់ភិក្ខុសង្ឆ ឧបដ្ឋានសាលា កុដិ មណ្ឌប និងទីចង្ក្រមដល់ភិក្ខុសង្ឆ ក្នុងសួនអម្ពវ័នរបស់ខ្លួន ហើយសាងវិហារ ដែលប្រកបដោយស៊ុមទ្វារ លោមព័ទ្ធដោយកំពែង ថ្វាយដល់ភិក្ខុសង្ឆ មានព្រះពុទ្ធជាប្រធាន ។ ដែលលោកសំដៅពោលទុកថា បានឮថា ក្នុងទីនោះឯង ព្រះមានព្រះភាគ*

ទ្រង់គង់ក្នុងសួនអម្ពវ័នរបស់ចុន្ទកម្មារបុត្ត (កូនជាងមាស) ទៀបក្រុងបាវា ដូច្នេះ ។

បទថា **ឧជ្ជិយានាបេក្ខា** សេចក្តីថា ឱ្យចាត់ចែង គឺឱ្យដាំស្ង ។ បទថា **សូករមទ្ទវំ** នេះ លោកពោលទុកក្នុងមហាអដ្ឋកថាថា សាច់ជ្រូកដែលទន់ម៉ដ្ត ។ តែអាចារ្យពួកខ្លះពោលថា បទថា **សូករមទ្ទវំ** សេចក្តីថា មិនមែនសាច់ជ្រូក តែជាទំពាំងឫស្សី ដែលសត្វជ្រូកខាំកកេរ ។ អាចារ្យពួកដទៃពោលថា ផ្សិតដែលកើតក្នុងអាវាសដែលសត្វជ្រូកខាំកកេរ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា អណ្តូងកើតនៃរសប្រភេទណាមួយ ដែលមានឈ្មោះថា **សូករមទ្ទវ:** ។ អាចារ្យពួកមួយពោលថា ក៏នាយចុន្ទកម្មារបុត្តរបស់ជាងមាស ស្តាប់ពាក្យនោះថា ថ្ងៃនេះ ព្រះដ៏មានព្រះភាគនឹងបរិនិព្វាន ហើយគិតថា ដូចម្តេចហ្ន៎ ព្រះដ៏-មានព្រះភាគ នឹងគប្បីសោយសាច់ជ្រូកនេះ ហើយគប្បីធរមាននៅរហូតដល់អស់កាលយូរ ដូច្នេះហើយទើបថ្វាយ ដើម្បីប្រាថ្នានឹងឱ្យព្រះសាស្តាតាំងព្រះជន្មាយុរហូតអស់កាលយូរ ។ បទថា **តេន មំ ឧបាវិស** បានដល់ ចូរឱ្យតថាគតសោយសាច់ជ្រូកនោះ ។ ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ ទើបត្រាស់យ៉ាងនោះ ព្រោះទ្រង់អនុគ្រោះដល់សត្វដទៃ ។ ក៏ហេតុនោះ ព្រះអង្គបានត្រាស់ទុកហើយក្នុងព្រះបាលីនុ៎ះឯង ។ ព្រោះហេតុនោះ ព្រះអង្គទ្រង់សម្តែងថា គួរនឹងពោលយ៉ាងនោះ ព្រោះកិច្ចាគេនាំមក កិច្ចដទៃមិនគួរនឹងបរិភោគ ។

បានឮថា ទេវតាក្នុងមហាទ្វីបទាំង ៤ ដែលមាន ២.០០០ ទ្វីប ជាបរិវារ ជាក់ឱ្យជារសចុះក្នុងសាច់ជ្រូកនោះ ។ ព្រោះដូច្នោះ អ្នកណាៗ ដទៃមិនអាចនឹង

ឱ្យសាច់ជ្រូកនោះរលួយបានដោយងាយ ។ ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ដើម្បីនឹងដោះនូវវាទ:របស់ដទៃ ទើបទ្រង់បន្ទឺសីហនាទ ដោយន័យមានជាអាទិ៍ថា ម្នាលចុន្ទកម្មារបុត្ត តថាគតមិនឃើញសាច់ជ្រូកនោះ ។ មែនពិតព្រះមានព្រះភាគ ស្តាប់ពាក្យរបស់ពួកដែលត្រូវការនឹងពោលថា ព្រះមាន-ព្រះភាគមិនប្រទានសួរមទ្ទវ: ដែលព្រះអង្គសោយនៅសល់ ទាំងដល់ភិក្ខុ ទាំងដល់មនុស្សទាំងឡាយ បង្ហាប់ឱ្យកប់ចោលក្នុងរណ្ដា ធ្វើឱ្យវិនាសអស់ដូច្នេះ ទើបទ្រង់បន្ទឺសីហនាទ ដើម្បីដោះពាក្យស្តីបន្ទោសរបស់ជនពួកដទៃ ដោយព្រះបំណងថា នឹងមិនមានឱកាសពោលស្តីបន្ទោសបាន ។

បណ្ដាបទទាំងនោះ ក្នុងបទថា **សទេវកេ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **សទេវក:** ព្រោះប្រព្រឹត្តទៅដោយទេវតាទាំងឡាយ ។ ឈ្មោះថា **សមារក:** ព្រោះប្រព្រឹត្តទៅដោយមារ ។ ឈ្មោះថា **សព្រហ្មក:** ព្រោះប្រព្រឹត្តទៅដោយព្រហ្ម ។ ឈ្មោះថា **សស្សមណាព្រាហ្មណី** ព្រោះប្រព្រឹត្តទៅដោយសមណាព្រាហ្មណ៍ ។ ឈ្មោះថា **បជា** ព្រោះជាសត្វកើត ។ ឈ្មោះថា **សទេវមនុស្សា** ព្រោះប្រព្រឹត្តទៅដោយទេវតា និងមនុស្សទាំងឡាយ ។ ក្នុងលោកនោះ ព្រមដោយទេវលោក ។ល។ ព្រមដោយទេវតា និងមនុស្ស ។ ក្នុងពាក្យទាំងនោះ ដោយពាក្យថា **សទេវក:** សំដៅយកទេវតាជាន់បញ្ចកាមាវចរ ។ ដោយពាក្យថា **សមារក:** សំដៅយកទេវតាជាន់កាមាវចរទី ៦ ។ ដោយពាក្យថា **សព្រហ្មក:** សំដៅយកព្រហ្មជាន់ព្រហ្មកាយិកាជាដើម ។ ដោយពាក្យថា **សស្ស-**

មណាព្រាហ្មណី សំដៅយកសមណាព្រាហ្មណ៍ជាសត្រូវនឹងសមណាព្រាហ្មណ៍ក្នុងព្រះពុទ្ធសាសនា និងសំដៅយកសមណៈអ្នកស្ងប់ចាប និងព្រាហ្មណ៍ដែលមានចាបបន្សាត់បង់ហើយ ។ ដោយពាក្យថា **ឋជា** សំដៅយក សត្វលោក ។ ដោយពាក្យថា **សទេវមនុស្សៈ** សំដៅយក ទេវតាដោយសម្មតិ និងមនុស្សដ៏សេស ។ ដោយបទទាំង ៣ បទនោះ គប្បីជ្រាបថា លោកកាន់យកអាកាសលោក ។ ដោយបទទាំង ២ បទនោះ លោកកាន់យកដោយសត្វលោក ។

គប្បីជ្រាបន័យមួយទៀតដូចតទៅនេះ

ដោយពាក្យថា **សទេវកៈ** លោកសំដៅយកទេវលោកជាន់អរូបាវចរ ។ ដោយពាក្យថា **សមារកៈ** លោកសំដៅយកទេវលោកជាន់ឆកាមាវចរ ។ ដោយពាក្យថា **សព្រហ្មកៈ** លោកសំដៅយកព្រហ្មលោកជាន់រូបាវចរ ដោយពាក្យថា សស្សមណាព្រាហ្មណ៍ជាដើម គប្បីជ្រាបថា លោកសំដៅយកមនុស្សលោកព្រមទាំងទេវតាដោយសម្មតិ ដោយអំណាចបរិស័ទ ៤ ឬគប្បីជ្រាបថា លោកសំដៅយកសត្វលោកដែលនៅសល់ ។

បទថា **ភូតានិ** បានដល់ អ្នកបរិភោគ ។ បទថា **ទ្ធេ** ប្រែថា ត្រាតគ្រាត ។ បទថា **អាពាធេ** បានដល់ ពោគដែលមិនត្រូវចំណែកគ្នា ។ បទថា **បពាឍ្ហា** បានដល់ មានកម្ចាំង ។ បទថា **មរណន្តិកា** បានដល់ កំពុងនឹងស្លាប់ គឺអ្នកជំងឺអាចនឹងជិតស្លាប់ ។ បទថា **សតោ សម្ឆជានោ អធិសេតិ** សេចក្ដីថា តាំងសតិទុកដោយល្អ ហើយអធិដ្ឋានកំណត់ដោយញាណ ។ បទថា **អរិហ-**

ញ្ញមានោ សេចក្ដីថា មិនធ្វើឱ្យផ្ទាស់ប្ដូរត្រឡប់ទៅត្រឡប់មក ដូចធម៌ដែលមិនបានកំណត់ ដោយអនុវត្តតាមវេទនា ដូចមិនត្រូវរុកកួន មិនបានទទួលសេចក្ដីលំបាក ។ មែនពិត វេទនាទាំងនោះ កើតឡើងដល់ព្រះដ៏មានព្រះភាគ ត្រង់ស្រុកវេឡុគ្រាមនុ៎ះឯង តែត្រូវកម្ចាំងនៃសមាបត្តិគ្របសង្កត់ ទើបមិនកើតឡើងដរាបដល់ថ្ងៃបរិនិព្វាន ទើបមិនចូលសមាបត្តិបង្ហោនទៅ ចំពោះរាល់ៗថ្ងៃ ។ តែព្រះអង្គប្រាថ្នានឹងបរិនិព្វាន ទើបមិនចូលសមាបត្តិ ដើម្បីឱ្យសត្វកើតសេចក្ដីសង្វេគថា សូម្បីទ្រង់មានកម្ចាំងស្មើនឹងដំរី ១.០០០ កោដិ មានកាយស្មើដោយផ្ទះពេជ្រ មានបុញ្ញសម្ភារៈដែលសន្សំរហូតអស់កាលប្រមាណមិនបាន កាលកពនៅមាននៅឡើយ វេទនាបែបនេះ ក៏រមែងប្រព្រឹត្តទៅ នឹងចាំបាច់ពោលទៅថ្វីដល់សត្វពួកដទៃហ្ន៎ ព្រោះហេតុនោះ វេទនាទើបប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ។ បទថា **អាយាម** ប្រែថា ចូលមករក្សា ។ ក្នុងកាលជាខាងក្រោយ ព្រះធម្ម-សង្គាហកាចារ្យបានតាំងគាថា ដែលមានជាអាទិ៍ថា **ចុន្ទស្ស ភត្តំ ភុញ្ជិត្វា** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **ភត្តស្ស ច សូការមទ្ទវេន** សេចក្ដីថា កើតព្យាធិយ៉ាងខ្លាំងក្លាដល់ព្រះដ៏មានព្រះភាគ អ្នកសោយ ព្រោះមិនមែនទ្រង់សោយព្រះក្រយាហារជាបច្ច័យទេ ។ ព្រោះបើរោគយ៉ាងខ្លាំងក្លានឹងកើត គឺនឹងបានមានដល់ព្រះដ៏មានព្រះភាគ អ្នកមិនបានសោយ ព្រះក្រយាហារហើយ តែព្រោះព្រះអង្គសោយព្រះក្រយាហារដែលគ្រោតគ្រាតដ៏ក្រៃលែង វេទនាទើបបានស្រាលចុះខ្លះ ព្រោះហេតុនោះនុ៎ះឯង ព្រះអង្គទើបមិនអាចនឹងស្ដេចយាង

ទៅដោយព្រះបាទបាន ។ ព្រះអង្គទើបទ្រង់សម្តែងសីហនាទ ដែលព្រះអង្គទ្រង់បន្ទឹថា ក្រយាហារដែលអ្នកណាបរិភោគហើយ គប្បីដល់សេចក្តីរលួយទៅដោយប្រពៃ ។ល។ រៀរព្រះតថាគត ដូច្នេះ ឱ្យជាប្រយោជន៍ ។ មែនពិត ដែលឈ្មោះថា សំឡេងដែលគ្រហឹមក្នុងឋានៈដែលមិនសមគួរ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ព្រោះហេតុដែលព្រះក្រយាហារ ដែលព្រះអង្គទ្រង់សោយហើយ មិនធ្វើអាការប្ញែកណាមួយ ឱ្យកើតដល់ព្រះដ៏មានព្រះភាគ ព្រះក្រយាហារដែលកើតឡើង គឺកម្មដែលមានឱកាសឱ្យផល ចូលទៅសូប់រំងាប់នូវអាការប្ញែកនោះមានប្រមាណតិច ហើយធ្វើកម្ទាំងឱ្យកើតឡើងក្នុងរាងកាយ ដែលជាហេតុឱ្យប្រយោជន៍ ៣ យ៉ាង តាមដែលនឹងពោលឱ្យសម្រេច ព្រោះដូច្នោះ ព្រះក្រយា-ហារនោះទើបដល់ការរលួយទៅតែម្តង តែវេទនាអាចធ្វើឱ្យស្ងាប់បាន ដែលអ្នកណាៗ មិនដឹង ហើយមិនប្រាកដដូច្នេះឯង ។ បទថា **រិចូមានោ** បានដល់ព្រះអង្គចុះព្រះលោហិតរឿយៗ ។ បទថា **អភេច** សេចក្តីថា ព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះ ដើម្បីប្រយោជន៍ដល់ការបរិនិព្វាន ក្នុងទីដែលព្រះអង្គប្រាថ្នា ។

ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ កាលពោគយ៉ាងនេះកើតឡើងហើយ ព្រះអង្គយាងទៅកាន់ក្រុងកុសិនារា ព្រះអង្គមិនអាចបរិនិព្វានក្នុងទីដទៃឬ ឆ្លើយថា ព្រោះព្រះអង្គមិនអាចនឹងបរិនិព្វានក្នុងទីណាៗមិនមែនទេ តែព្រះអង្គទ្រង់មានព្រះតម្រិះយ៉ាងនេះថា កាលតថាគតទៅកាន់ក្រុងកុសិនារា ការកើតឡើងនៃហេតុក្នុងការសម្តែងមហាសុទស្សនសូត្រ ក៏នឹងមានសម្បត្តិយ៉ាងណា ដូច

នឹងសម្បត្តិដែលតថាគតគប្បីសោយក្នុងទេវលោក ដោយការកើតឡើងនៃហេតុនោះ តថាគតក៏បានសោយហើយក្នុងមនុស្សលោក តថាគតនឹងប្រដាប់សម្បត្តិនោះដោយភាណវារៈទាំង ២ ហើយនឹងសម្តែងធម៌ ជនជាច្រើនបានស្តាប់ដូច្នោះហើយ ក៏នឹងសម្គាល់ដល់កុសល ដែលខ្លួនគប្បីធ្វើ ។ ក្នុងទីនោះ សូម្បីសុភទ្ទៈក៏នឹងមកគាល់តថាគត សួរបញ្ហាក្នុងទីបំផុតនៃការដោះស្រាយបញ្ហា ទើបតាំងនៅក្នុងសរណៈទាំងឡាយបានបព្វជ្ជាឧបសម្បទា ហើយចម្រើនកម្មដ្ឋាន ក្នុងកាលតថាគតមិនទាន់បរិនិព្វាននៅឡើយ សុភទ្ទៈនោះសម្រេចព្រះអរហត្ត នឹងជាអ្នកឈ្មោះថា បច្ឆិមសាវក ។ កាលតថាគត បរិនិព្វានក្នុងទីដទៃ ជម្លោះ ក៏នឹងកើតមាន ព្រោះធាតុជាហេតុ លោហិតនឹងហូរទៅដូចជាស្ទឹង ។ តែកាលតថាគតបរិនិព្វានក្នុងក្រុងកុសិនារា ទោណព្រាហ្មណ៍ ក៏នឹងរំងាប់ជម្លោះនោះចែកព្រះធាតុទាំងឡាយ ។ ព្រះដ៏មានព្រះភាគ កាលទ្រង់ឃើញហេតុ ៣ ប្រការដូចពោលមកនេះ ទើបព្រះអង្គយាងទៅកាន់ក្រុងកុសិនារា ដោយសេចក្តីឧស្សាហ៍ធំ ។

ស័ព្ទថា **ឥង្ឃ** *ជានិបាតប្រើក្នុងចោទនត្ថៈ ។ បទថា* **កិលន្តោស្មិ** *សេចក្តីថា តថាគតជាអ្នកស្គមស្លេកស្លាំង ។ ដោយបទនោះ ទ្រង់សម្តែងចំពោះវេទនាតាមដែលពោលហើយថា មានកម្លាំងខ្លាំង ។ មែនពិត ព្រះដ៏មានព្រះភាគព្រះអង្គបានយាងទៅដោយព្រះបាទក្នុងកាលនោះ ដោយអានុភាពរបស់ព្រះអង្គក៏វេទនាដែលខ្លាំងក្លាក្តៅ ប្រព្រឹត្តទៅដោយប្រការដែលអ្នកពួកដទៃ មិនអាចធ្វើ*

ការលើកជើងឡើងបាន ព្រោះហេតុនោះនុ៎ះឯង ព្រះអង្គទើបត្រាស់ថា តថាគត នឹងអង្គុយដូច្នេះ ។

បទថា **ឥជានិ** ប្រែថា ក្នុងកាលឥឡូវនេះ ។ បទថា **លុជ្ជិតំ** បានដល់ អាកូល:ដូចត្រូវញ្ចាំញ ។ បទថា **អាវិលំ** ប្រែថា កករល្អក់ ។ បទថា **អច្ឆោឧកា** បានដល់ ទឹកដោះថ្ងា ។ បទថា **សាតោឧកា** បានដល់ ទឹកដែលមានរស ធ្ងាញ់ ។ បទថា **សីតោឧកា** បានដល់ ទឹកត្រជាក់ ។ បទថា **សេតោឧកា** បានដល់ ទឹកមិនមានកក់ ។ មែនពិត សូម្បីទឹកនោះ ដោយសការ: មានពណ៌ស តែក្ងាយជាយ៉ាងដទៃ ដោយអំណាចផ្ទៃដី និងកករល្អក់ទៅជាកក់ ។ ទន្ទេ សូម្ប៉ី-ស មានខ្សាច់ស្អាតពាសពេញ មានពណ៌សតែងហូរទៅ ។ ព្រោះហេតុនោះ លោកទើបពោលថា **សេតោឧកា** ទឹកពណ៌ស ។ បទថា **សុបតិដ្ឋា** ប្រែថា កំពង់ល្អ ។ បទថា **រមណីយា** សេចក្ដីថា ជាទីដែលបុគ្គលគប្បីត្រេកអរ ព្រោះជាផែនដី ជាទីនាំមកនូវការរីកភាយចិត្ត និងឈ្មោះថា ទីរីកភាយនៃចិត្ត ព្រោះបរិបូណ៌ដោយទឹកតាមដែលពោលហើយ ។

បទថា **កិលញ្ជោស្មិ ចុន្ទ ជិបច្ឆិស្សាមិ** សេចក្ដីថា បណ្ដាត្រកូលដំរី ១០ ត្រកូល ដែលព្រះតថាគតត្រាស់ទុកយ៉ាងនេះថា ដំរី ១០ ត្រកូលទាំងនេះ គឺត្រកូលដំរីកាឡាវក: ១ ត្រកូលដំរីគង្គេយ្យ: ១ ត្រកូលដំរីបណ្ឌរ: ១ ត្រកូលដំរីតម្ព: ១ ត្រកូលដំរីបិង្គល: ១ ត្រកូលដំរីគន្ធ: ១ ត្រកូលដំរីមង្គល: ១ ត្រកូលដំរីហេម: ១ ត្រកូលដំរីឧបោសថ ១ ត្រកូលដំរីឆទ្ទន្ត ១ ។

*កម្ទាំងនៃដំរីតាមប្រក្រតី ១០ ត្រកូល ពោលគឺ ត្រកូលដំរីកាឡាវក: តាមដែលពោលហើយយ៉ាងនេះ ជាកម្ទាំងរបស់ត្រកូលដំរីគង្គេយ្យ: ១ ត្រកូល រួមសេចក្ដីថា ដោយការគណនាដោយគុណនឹងដប់នៃដំរីតាមប្រក្រតី កម្ទាំងកាយព្រះតថាគតដែលមានប្រមាណកម្ទាំង ១.០០០ កោដិ ត្រកូលទាំងអស់នោះ ដល់នូវការអស់ទៅ ដូចទឹកដែលគេដាក់ក្នុងធម្មក្រក (សំពត់តម្រងទឹក) តាំងពីខាងក្រោយកត្តក្នុងថ្ងៃនោះ ។ ព្រះដ៏មានព្រះភាគស្តេចយាងចេញពីបាវាលចេតិយទៅកាន់ក្រុងកុសិនារាមានប្រវែង ៣ គាវុត ព្រះអង្គឈប់ ២៥ ដងក្នុងចន្លោះផ្លូវនោះ ព្រះអង្គយាងទៅដោយការព្យាយាមយ៉ាងក្រៃលែង ព្រះអង្គបានយាងដល់ក្រុងកុសិនារា ក្នុងវេលាព្រះអាទិត្យអស្តង្គត ។ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងសេចក្ដីនេះថា ដែលឈ្មោះថា **ភោគ** រមែងមកញ៉ាំញ៉ី បុគ្គលដែលមិនមានភោគទាំងអស់បាន ដោយប្រការដូច្នេះ កាលនឹងត្រាស់ព្រះវាចា ដែលធ្វើសេចក្ដីសង្វេគដល់សត្វលោក ព្រមទាំងទេវលោក ទើបត្រាស់ថា ម្នាលចុន្ទ-កម្មារបុត្ត តថាគតនឿយហត់ណាស់ តថាគតនឹងសម្រាក ដូច្នេះ ។ ការដេកក្នុងពាក្យថា **ដំណេក** នេះ មាន ៤ យ៉ាង គឺដំណេកដូចមនុស្សស្លាប់ ១ ដំណេករបស់អ្នកបរិភោគកាម ១ ដំណេកសីហ: ១ ដំណេកព្រះតថាគត ១ ។ បណ្ដាដំណេកទាំងឡាយ ៤ យ៉ាងនោះ ដំណេករបស់អ្នកបរិភោគកាមយ៉ាងនេះ គឺម្នាលកិក្ខុទាំងឡាយ ពួកអ្នកបរិភោគកាមច្រើនតែដេកផ្ងៀងទៅខាងឆ្វេង ។ ដំណេកដូចមនុស្សស្លាប់យ៉ាងនេះ ម្នាលកិក្ខុទាំងឡាយ មនុស្សស្លាប់ច្រើនតែ*

ដេកផ្ទារ ។ ចតុត្ថជ្ឌានជាដំណេករបស់ព្រះតថាគត ។ ដំណេកសីហៈយ៉ាងនេះ គឺម្នាលភិក្ខុទាំងឡាយ សីហមិគរាជ ច្រើនតែដេកផ្ទៀងទៅខាងស្តាំ[1] ។ មែនពិត ដំណេករបស់រាជសីហ៍នេះ ឈ្មោះថា ជាដំណេកយ៉ាងប្រសើរបំផុត ព្រោះ មានឥរិយាបថឧត្តុង្គឧត្តម ព្រោះតេជៈ ។ ព្រោះហេតុនោះ លោកទើបពោលថា រមែងសម្រេចការដេកដូចរាជសីហៈ ដោយផ្ទៀងទៅខាងស្តាំ ដូច្នេះ ។

បទថា **ចាតេ ចាតំ** បានដល់ តម្រួតព្រះបាទធ្វេងលើព្រះបាទស្តាំ ។ បទថា **អច្ចាធាយ** ប្រែថា តម្រួត គឺដាក់ជើងគងលើគ្នា ។ មែនពិត ការដាក់-ក ជើងគងលើ-ក ជើង ជង្គង់គងលើជង្គង់ វេទនារមែងកើតឡើងរឿយៗ ដំណេកមិន ជាសុខសប្បាយ ។ តែកាលដាក់ជើង ឱ្យគងលើគ្នា ដោយមិនបៀតបៀនគ្នា វេទនា រមែងមិនកើត ដំណេកក៏សប្បាយ ។ ព្រោះដូច្នោះ ព្រះអង្គទើបផ្ទំយ៉ាងនេះ ។

គាថាទាំងនេះថា **ឥន្ធ្ការ ពុន្ធោ** ព្រះធម្មសង្គាហកាចារ្យទាំងឡាយ រចនាឡើងខាងក្រោយ ។ បណ្តាបទទាំងនោះ បទថា **ឆនិកំ** បានដល់ ទន្ទេ ។ បទថា **អប្ឍដិមោ ច លោកេ** បានដល់ បុគ្គលមិនមានអ្នកប្រៀបផ្ទឹម ក្នុង លោកនេះ គឺក្នុងលោក ព្រមដោយទេវលោកនេះ ។ បទថា **ឆ្ឍ្ឍ្ការ ឋិត្ការ ឧឧតារ** បានដល់ ទ្រង់ស្រង់ទឹកយូរ ដោយធ្វើព្រះវរកាយឱ្យត្រជាក់ និងទ្រង់ សោយទឹក ហើយស្តេចយាងឡើងពីទឹកវិញ ។ បានឮថា ក្នុងកាលនោះ កាល

---

[1]-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុកនិបាត លេខ ៤៣ ទំព័រ ២៦០ ដល់ ២៦២ ។

ព្រះដ៏មានព្រះភាគ ទ្រង់ស្រង់ទឹកយូរ វត្ថុទាំងអស់ គឺត្រី និងអណ្តើកខាងក្នុងទន្លេ ព្រៃស្រោងត្រង់ច្រាំងទាំងសងខាង និងភូមិភាគទាំងអស់នោះ បានក្លាយដូចជាពណ៌មាសទាំងអស់ ។

បទថា **បុរក្ខ្លោ** សេចក្ដីថា លោក ព្រមទាំងទេវលោក ឈ្មោះថា ធ្វើទុកក្នុងខាងមុខ ដោយការបូជា និងការរាប់អាន ព្រោះព្រះអង្គជាគ្រូដ៏ឧត្ដមរបស់សត្វដោយពិសេស ។ បទថា **ភិក្ខុ**ក**ណ**ាសេ**ឃ** **ម**ជ្ឈ ប្រែថា ត្រង់កណ្ដាលនៃកិក្ខុសង្ឆ ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់បានទទួលវេទនាលើសប្រមាណ ទើបហែហមដោយជុំវិញ ។

បទថា **ស**ត្ថ**ា** សេចក្ដីថា ឈ្មោះថា **ស**ាស្ត**ា** ព្រោះទ្រង់ណែនាំសព្វសត្ត្ដ ដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្ប្ដាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ ។ បទថា **ប**ាវ**ត**ា **ភ**ាគ**ว**ា **ช**ម្ម សេចក្ដីថា ព្រះសាស្ដា ឈ្មោះថា **ภ**ាគ**ว**ា ព្រោះជាអ្នកមានភាគ្យធម៌ជាដើម ទ្រង់ប្រកាសសាសនធម៌ មានសីលជាដើម ក្នុងព្រះសាសនា នេះ គឺទ្រង់ពង្រីកព្រះធម៌ ឬព្រះធម្មក្ខន្ធ ៨៤.០០០ ធម្មក្ខន្ធ ឱ្យបែកច្រើន ។ បទថា **អ**ម្ព**ว**ន**ํ** បានដល់ ព្រៃស្វាយជិតត្រើយទន្លេនុ៎ះឯង ។ បទថា **អ**ាម**ន**្ត**យ**ិ **ช**ุ**ท**្ท**ก**ํ សេចក្ដីថា បានពោលថា ក្នុងខណៈនោះ ព្រះអានន្ទដ៏មានអាយុ រវល់តែពួតសំពត់ងូតទឹក ទើបយឺតយូរ ព្រះចុន្ទកត្ថេរបានទៅជិត ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ហៅព្រះថេរៈមក ។ បទថា **ป**ม**ุ**ข**ว**ิ **ส**ีส**ว**ิ បានដល់ អង្គុយចំពោះព្រះកន្ទ្រេរបស់ព្រះសាស្ដា ដោយលើកវត្ដ្ដ

ជាប្រធាន ដោយពាក្យត្រឹមតែប៉ុណ្ណោះថា ព្រោះហេតុណាហ្ន៎ ព្រះសាស្តាទើបត្រាស់ហៅ ដូច្នេះ ។ ព្រះអានន្ទដ៏មានអាយុជាធម្មកណ្ណគារិក ក៏មកដល់តាមលំដាប់ ។ ត្រាព្រះអានន្ទដ៏មានអាយុ មកដល់តាមលំដាប់យ៉ាងនេះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ហៅមក ។

បទថា **ឧប្ផាឧហេយ្យ** ប្រែថា គប្បីឱ្យកើតឡើង ។ អធិប្បាយថា អ្នកណាៗ អ្នកធ្វើសេចក្តីក្តៅក្រហាយឱ្យកើតឡើង នឹងគប្បីមានខ្ជះ ។ បទថា **អលាភា** សេចក្តីថា បុគ្គលឯណារមែងបានលាភ ពោលគឺ អានិសង្សនៃទាន ដែលបុគ្គលដទៃបានឱ្យហើយ បុគ្គលនោះរមែងមិនបាន ។ បទថា **ឧុល្ទ**ំ សេចក្តីថា បានអត្តភាពជាមនុស្ស បានមកដោយបុណ្យពិសេស ចាត់ថា ជាការបានដោយលំបាក ។ បទថា **យស្ស តេ** កែជា **យស្ស តវ** ប្រែថា របស់អ្នកណា ។ បុគ្គលណានឹងដឹងបិណ្ឌបាតនោះថា បាយធៅ ឬបាយជ្រាយពេក ។ ព្រះតថាគតទ្រង់សោយបិណ្ឌបាតគ្រាចុងក្រោយបង្ហ្ន ស់ មានសភាពយ៉ាងនេះ ទើបព្រះអង្គបរិនិព្វាន នោះជាទានដែលអ្នកមិនបានថ្វាយត្រឹមត្រូវ ។ បទថា **លាភា** បានដល់ លាភ ពោលគឺ អានិសង្សនៃទានដែលមានក្នុងបច្ចុប្បន្ន និងបរលោក ។ បទថា **សុលទ**ំ សេចក្តីថា ភាពជាមនុស្ស លោកបានល្អហើយ ។ បទថា **សម្ម**ុខា ប្រែថា ក្នុងទីចំពោះមុខ មិនមែនដោយបានស្តាប់តគ្នា ឬក៏ពាក្យបម្ប្រាអធិប្បាយថា មិនមែនដោយឮតៗ គ្នាទេ ។ បទថា **មេ**ត**ំ** កាត់ទបជា **មេ ឯ**ត**ំ** ឬ **មយ ឯ**ត**ំ** ប្រែថា ប្រការនោះយើងបានដឹងហើយ ។ បទថា **ទ្វេ**ម**េ** កាត់បទជា

ទ្វេ ឥមេ *ប្រែថា* *បិណ្ឌបាតទាំង ២ យ៉ាងនេះ ។ បទថា* **សមសមफलา** *បានដល់ មានផលស្មើៗគ្នា ដោយអាការទាំងពួង ។ ព្រះតថាគតទ្រង់សោយ បិណ្ឌបាតដែលនាងសុជាតាថ្វាយហើយ ទើបត្រាស់ដឹង អ្នកឱ្យទាននោះ ចាត់ជា ទានក្នុងកាលដែលព្រះអង្គលះកិលេសមិនបាន តែទានរបស់នាយចុន្ទកម្មារបុត្ត នេះ ជាទានក្នុងកាលដែលព្រះអង្គអស់អាសវៈហើយមិនមែនឬ តើព្រោះហេតុ អ្វី បានជាទានទាំង ២ នេះទើបមានផលស្មើគ្នា ។ ព្រោះមានការបរិនិព្វានស្មើ គ្នា ព្រោះមានសមាបត្តិស្មើគ្នា និងព្រោះមានការរពឹកស្មើគ្នា ។ មែនពិត ព្រះដ៏-មានព្រះភាគ ទ្រង់សោយបិណ្ឌបាត ដែលនាងសុជាតាថ្វាយ ហើយបរិនិព្វាន ដោយសឧបាទិសេសនិព្វានធាតុ ទ្រង់សោយបិណ្ឌបាតដែលនាយចុន្ទកម្មារបុត្ត ថ្វាយ ហើយបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ រួមសេចក្ដីថា ទានទាំង នោះ មានផលស្មើគ្នា ព្រោះមានការបរិនិព្វានស្មើគ្នា ។ ក្នុងថ្ងៃត្រាស់ដឹង ព្រះអង្គទ្រង់ចូលសមាបត្តិប្រមាណ ២.៤០០.០០០ កោដិ សូម្បីក្នុងថ្ងៃបរិនិព្វាន ព្រះអង្គក៏ទ្រង់ចូលសមាបត្តិមានប្រមាណប៉ុណ្ណោះទាំងអស់ ទានទាំង ២ យ៉ាង នោះ ទើបឈ្មោះថា មានផលស្មើគ្នា ព្រោះមានការចូលសមាបត្តិស្មើគ្នា ដោយ ប្រការដូច្នេះ ។ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា អ្នក ដែលបរិភោគបិណ្ឌបាតរបស់អ្នកណា ហើយចូលចេតោសមាធិ ជាសមាធិដ៏ ក្រៃលែងរកប្រមាណមិនបាន ការហូរមកនៃបុណ្យ ការហូរមកនៃកុសលរបស់ អ្នកនោះរកប្រមាណមិនបាន ដូច្នេះជាដើម ។ ត្រាតមក នាងសុជាតាបាន*

ឮដំណឹងថា ទេវតានោះ មិនមែនរុក្ខទេវតា ដឹងថា អ្នកនោះជាព្រះពោធិសត្ត្ব បានឮថា ព្រះពោធិសត្ত্বបរិភោគបិណ្ឌបាតនោះ ហើយត្រាស់ដឹងអនុត្តរសម្មា-សម្ពោធិញ្ញាណ បានឮថា ព្រះពោធិសត្ত্বនោះ បានញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយបិណ្ឌបាតនោះអស់ ៧ សប្តាហ៍ ។ កាលនាងសុជាតាបានស្តាប់ពាក្យនេះ ហើយ រឭកថា ជាលាភរបស់យើងហ្ន៎ ទើបកើតបីតិសោមនស្សយ៉ាងខ្លាំងក្លា ។ គ្រាតមក កាលនាយចុន្ទកម្មារបុត្តបានឮមកថា យើងបានថ្វាយបិណ្ឌបាត គ្រាចុងក្រោយបង្អ្ន ់ បានឮមកថា យើងបានទទួល កំពូលធម៌ បានឮមកថា ព្រះសាស្តាទ្រង់សោយបិណ្ឌបាតរបស់យើង ហើយបរិនិព្ធានដោយអនុបាទិ-សេសនិព្ធានធាតុ ដែលព្រះអង្គទ្រង់ប្រាថ្នាយ៉ាងក្រៃលែងរហូតអស់កាលយូរ ទើបរឭកថា ជាលាភរបស់យើងហ្ន៎ ទើបកើតបីតិសោមនស្សយ៉ាងខ្លាំងក្លា ។ គប្បីជ្រាបថា បិណ្ឌបាតទាន ២ យ៉ាងឈ្មោះថា មានផលស្មើគ្នា ព្រោះមានការ រឭកដល់ស្មើគ្នាយ៉ាងនេះ ។

បទថា **អាយុសំវត្តនិកំ** ប្រែថា ជាផ្លូវឱ្យអាយុយឺនយូរ ។ បទថា **ឧបចិត្តំ** ប្រែថា សន្សំហើយ គឺឱ្យកើតហើយ ។ បទថា **យស្ឃសំវត្តនិកំ** ប្រែ ថា ជាផ្លូវដែលប្រព្រឹត្តដើម្បីបរិវារ ។ បទថា **អាធិបតេយ្យសំវត្តនិកំ** ប្រែថា ជាផ្លូវនៃការប្រព្រឹត្តដើម្បីភាពប្រសើរ ។

បទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ព្រះអង្គជ្រាបដោយអាការទាំងពួង ដល់អត្ថទាំង ៣ យ៉ាងនេះ គឺភាពនៃទានមានផលច្រើន ១ ភាពនៃព្រះអង្គទ្រង់ជាអគ្គទក្ខិណេយ្យបុគ្គលដ៏កំពូលដោយគុណ មានសីលជាដើម ១ អនុបាទិ-បរិនិព្វាន ១ ហើយទើបទ្រង់បន្ទឹឧទាននេះ ដែលសម្តែងសេចក្តីនោះ ។*

បណ្តាបទទាំងនោះ បទថា **ឧឧតោ បុញ្ញ បវឌ្ឍតិ** *សេចក្តីថា បុគ្គលដែលឱ្យទាន ឈ្មោះថា រមែងចម្រើនបុណ្យដែលសម្រេចដោយទាន ព្រោះដល់ព្រមដោយចិត្ត និងដល់ព្រមដោយទក្ខិណេយ្យបុគ្គល រមែងមានផលច្រើនជាង មានអានិសង្សច្រើនជាង ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងបទថា* **ឧឧតោ បុញ្ញ បវឌ្ឍតិ** *នេះ យ៉ាងនេះថា ភិក្ខុអ្នកមិនច្រើនទៅដោយអាបត្តិ ក្នុងទីគ្រប់ស្ថាន រមែងអាចដើម្បីនឹងរក្សាសីលឱ្យហ្មត់ចត់ ដោយល្អហើយបំពេញសមថ: និងវិបស្សនាដោយលំដាប់ ព្រោះអ្នកបរិច្ចាគទេយ្យធម៌ រមែងធ្វើឱ្យច្រើន ដោយចេតនាជាគ្រឿងបរិច្ចាគ ព្រោះហេតុនោះ បុណ្យទាំង ៣ យ៉ាងនេះ មានទានជាដើម រមែងចម្រើនដល់បុគ្គលនោះ ។ បទថា* **សញ្ញមតោ** *បានដល់ អ្នកសង្រួម ដោយការសង្រួមក្នុងសីល អធិប្បាយថា អ្នកតាំងនៅក្នុងសំវរ: ។ បទថា* **វេរ ន ចីយតិ** *សេចក្តីថា ពៀរវេរ ៥ យ៉ាង រមែងមិនកើត ។ ម្យ៉ាងទៀត បុគ្គលដែលមានសីលហ្មត់ចត់ដោយសីល អ្នកសង្រួមដោយកាយ វាចា និងចិត្ត ព្រោះអធិសីល មានអទោសៈជាប្រធាន រមែងមិនចម្រើនពៀរដោយអ្នកណាៗ ព្រោះជាអ្នកច្រើនដោយខន្តិ អ្នកនោះនឹងឈ្មោះថា ចម្រើនពៀរមកពីទីណា*

ព្រោះដូច្នោះ អ្នកសង្រួម គឺអ្នកប្រុងប្រយ័ត្ននោះ រមែងមិនចម្រើនពៀរ ព្រោះហេតុមានការសង្រួម ។ បទថា **កុសលោ ច ជហាតិ បាបកំ** សេចក្ដីថា ក៏បុគ្គលដែលឆ្លាត គឺអ្នកដល់ព្រមដោយបញ្ញាតាំងនៅក្នុងសីលដ៏បរិសុទ្ធ កំណត់កម្មដ្ឋាន ដែលសមរម្យដល់ខ្លួន ក្នុងអារម្មណ៍ ៣៨ ប្រការ រមែងញុំាងឈានផ្សេងដោយ ឧបចារៈ និងអប្បនា ឱ្យសម្រេច ឈ្មោះថា លះ គឺលះបង់អកុសល មានកាមច្ឆន្ទៈជាដើម ដ៏ថោកទាបលាមក ដោយវិក្ខម្ភនបហាន ។ បុគ្គលអ្នកឆ្លាតនោះ ធ្វើឈាននោះឯងឱ្យជាបាទ ផ្ដើមតាំងការអស់ទៅ និងការសូន្យទៅក្នុងសង្ខារទាំងឡាយ បំពេញវិបស្សនា ធ្វើវិបស្សនាឱ្យកើត រមែងលះអកុសលដ៏ថោកទាបលាមក បានដោយមិនឱ្យសេសសល់ដោយអរិយមគ្គ ។ បទថា **រាគទោសមោហក្ខយា បរិនិព្វុតោ** សេចក្ដីថា បុគ្គលនោះលះអកុសលដ៏លាមកយ៉ាងនេះ ហើយបរិនិព្វានដោយការរលត់កិលេសមិនសេសសល់ ព្រោះអស់រាគៈជាដើម តអំពីនោះ រមែងបរិនិព្វានដោយការខន្ធបរិនិព្វាន ។ ព្រះដ៏មានព្រះភាគ ទ្រង់អាស្រ័យទក្ខិណេយ្យសម្បត្តិរបស់នាយចុន្ទកម្មារបុត្ត និងទ្រង់អាស្រ័យទក្ខិណេយ្យសម្បត្តិរបស់ព្រះអង្គ ទើបទ្រង់បន្លឺឧទានដែលជ្រួតជ្រាបដោយកម្លាំងនៃបីតិដោយប្រការដូច្នេះ ។

បញ្ចមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៥

៦. ចាដលិគាមិយសុត្តវណ្ណនា

អដ្ឋកថាចាដលិគាមិយសូត្រ

ចាដលិគាមិយសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **មកធេសុ** *ប្រែថា ក្នុងដែនមគធ: ។ បទថា* **មហតា** *សេចក្តីថា ក្នុងទីនេះ បានដល់ ភិក្ខុសង្ឆប្រើន គឺប្រើនដោយគុណខ្ទះ ប្រើនដោយចំនួនខ្ទះ ព្រោះកំណត់មិនបាន ។ បទថា* **ចាដលិគាមោ** *បានដល់ ស្រុកមួយក្នុងដែនមគធ: ដែលមានឈ្មោះយ៉ាងនេះ ។ បានឮថា ក្នុងថ្ងៃកសាងស្រុកនោះ មានកូនដើមអង្ក្រាដ ២-៣ ដើម ត្រង់កន្លែងចាប់ផ្តើមសាងស្រុក បានដុះចេញមកពីផែនដី ។ ព្រោះហេតុនោះ ស្រុកនោះ ជនទាំងឡាយ ទើបនាំគ្នាហៅថា* **ចាដលិគ្រាម** *។ បទថា* **តទវសរិ** *បានដល់ ព្រះដ៏មានព្រះភាគ ព្រះអង្គបានយាងទៅ គឺយាងទៅដល់ចាដលិគ្រាមនោះ ។*

ក៏ព្រះដ៏មានព្រះភាគ ព្រះអង្គបានយាងដល់ចាដលិគ្រាមនោះក្នុងកាលណា ព្រះអង្គទ្រង់បានគេសាងចេតិយ ដើម្បីព្រះធម្មសេនាបតី ក្នុងក្រុងសាវត្ថី ដោយន័យដែលពោលហើយក្នុងកាលមុន ព្រះអង្គចេញចាកក្រុងសាវត្ថីនោះ ប្រថាប់នៅក្នុងក្រុងរាជគ្រឹះ ទើបកសាងចេតិយដើម្បីព្រះមហាមោគ្គល្លានដ៏មានអាយុ ក្នុងក្រុងរាជគ្រឹះនោះ ព្រះអង្គយាងចេញពីក្រុងរាជគ្រឹះនោះ ហើយប្រថាប់នៅត្រង់អម្ពលដ្ឋិវ័ន ហើយព្រះអង្គចារិកទៅក្នុងជនបទ ដោយពុទ្ធដំណើរមិនប្រញាប់ប្រញាល់ ទើបប្រថាប់មួយកន្លែងមួយយប់ៗក្នុងទីនោះ។ កាលនឹងទ្រង់អនុគ្រោះសត្វលោក ទើបព្រះអង្គយាងដល់ចាដលិគ្រាមដោយលំដាប់ ។

បទថា **ចាជលិកាមិយា** បានដល់ ឧបាសក ឧបាសិកាទាំងឡាយ អ្នកស្រុកបាដលិគ្រាម ។ បានឮមកថា ឧបាសក និងឧបាសិកាទាំងនោះ អ្នកខ្ជះ តាំងនៅក្នុងសរណៈ អ្នកខ្ជះតាំងនៅក្នុងសីល អ្នកខ្ជះតាំងនៅក្នុងសរណៈ និងសីល ដោយការជួបព្រះដ៏មានព្រះភាគគ្រាដំបូងប៉ុណ្ណោះ ។ ព្រោះហេតុ នោះ លោកទើបពោលថា ឧបាសក និងឧបាសិកាទាំងឡាយ ចូលទៅគាល់ ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ដូច្នេះ ។

បានឮមកថា ក្នុងបាដលិគ្រាម ពួករាជបម្រើរបស់ព្រះបាទអជាតសត្រូវ និងរបស់ព្រះបាទលិច្ឆវីទាំងឡាយនាំគ្នាទៅតាមកាលសមគួរ បណ្តេញម្ចាស់ ស្រុកចេញពីស្រុក ហើយនៅមួយខែខ្ជះ កន្ទះខែខ្ជះ ។ ព្រោះហេតុនោះ ពួកអ្នក បាដលិគ្រាម ត្រូវរុកគួនជាប្រចាំ ទើបគិតថា ក៏ក្នុងវេលាដែលពួកអ្នកទាំងនេះ ពួកគេនឹងបានកន្លែងនៅ ដូច្នេះហើយ ទើបបាននាំគ្នាសាងសាលាមួយខ្នងធំ ចំកណ្តាលទីក្រុង ដែលត្រឹមតែល្មមដល់ការនៅរបស់អ្នកទាំងអស់នោះ ដោយ មិនឱ្យបៀតបៀនគ្នា និងគ្នា គឺឱ្យមានកន្លែងរក្សាទ្រព្យរបស់ឥស្សរជនមួយ កន្លែង សម្រាប់សម្រាកមួយ កន្លែងសម្រាប់អ្នកធ្វើដំណើរជាអាគន្តុកៈមួយ កន្លែង សម្រាប់មនុស្សកំព្រីកំព្រាមួយ និងកន្លែងសម្រាប់អ្នកជំងឺមួយដូច្នេះ ។ សាលា នោះ មានឈ្មោះថា **អាវសថាគារ** (ទីសម្រាប់សំណាក់) ដូច្នេះឯង ។ ក៏ក្នុងថ្ងៃ នោះ ការកសាងសាលានោះ បានសម្រេចចុះ ។ ក៏អ្នកបាដលិគ្រាមទាំងនោះ

នាំគ្នាទៅក្នុងទីនោះ ត្រួតមើលសាលានោះ តាំងពីស៊ុមទ្វារ ដែលសម្រេចរៀបរយ ចាត់ចែងទុកដោយល្អ ដោយការងារឈើ ការងារកំបោរ និងការងារចិត្តកម្ម ជាដើម ដូចទេវវិមាន ហើយនាំគ្នាគិតថា អាវសថាគារនេះ ជាទីរីករាយនៃចិត្ត ជាទីនាំមកនូវសិរីមង្គលដ៏ក្រៃលែង អ្នកណាហ្ន៎ នឹងបានប្រើប្រាស់មុន នឹងគប្បីប្រព្រឹត្តទៅដើម្បីប្រយោជន៍សុខដល់ពួកយើងអស់កាលយូរ ។ ក៏ក្នុងខណៈនោះឯង អ្នកបាដលិគ្រាមនោះបានឮដំណឹងថា ព្រះដ៏មានព្រះភាគ ព្រះអង្គយាងមកដល់ស្រុកនោះ ។ ព្រោះហេតុនោះ អ្នកបាដលិគ្រាមទើបកើតបីតិសោមនស្ស ធ្វើសេចក្តីព្រមព្រៀងថា ពួកយើងគប្បីនឹងនាំព្រះដ៏មានព្រះភាគមក តែព្រះដ៏មានព្រះភាគព្រះអង្គយាងមកដល់ទីនៅរបស់យើង ដោយព្រះអង្គឯងហើយ ក្នុងថ្ងៃនេះ ពួកយើងទាំងឡាយនឹងឱ្យព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងទីនេះ ហើយនឹងឱ្យព្រះសាស្តា និងភិក្ខុសង្ឆប្រើប្រាស់មុន កាលភិក្ខុសង្ឆមកដល់ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ក៏នឹងមកដល់ដូចគ្នា យើងនឹងអារាធនាព្រះសាស្តាសម្តែងពីមង្គល និងធម៌ ។ ព្រោះដូច្នោះ កាលរតនៈទាំង ៣ ប្រើប្រាស់ហើយនូវអាវសគារ ខាងក្រោយមក ពួកយើង និងអ្នកដទៃ ក៏នឹងប្រើប្រាស់ កាលបើដូច្នេះ ក៏នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍សុខដល់ពួកយើងរហូតអស់កាលយូរ ដូច្នេះហើយ ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍នោះនុ៎ះឯង ។ ព្រោះដូច្នោះ អ្នកបាដលិគ្រាម ទើបក្រាបទូល

យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងអាវសថាគាររបស់ខ្ញុំព្រះអង្គទាំងឡាយចុះ ។

បទថា **យេន អាវសថាការំ តេនុបសង្កមីសុ** សេចក្ដីថា អាវសថាគារនោះ គេចាត់ចែងបដិបត្តិដោយល្អ ដូចទេវវិមាន ព្រោះសម្រេចរៀបរយដោយល្អក្នុងថ្ងៃនោះឯងក៏មែនពិតហើយ តែក៏មិនទាន់បានតាក់តែង ឱ្យគួរដល់ព្រះពុទ្ធ អ្នកបាដលិគ្រាមទាំងនោះនាំគ្នាគិតថា ធម្មតាព្រះពុទ្ធទាំងឡាយ មានអធ្យាស្ស័យនៅក្នុងព្រៃ មានព្រៃជាទីត្រេកអរ គប្បីនៅខាងក្នុងស្រុកក៏ដោយ មិននៅក៏ដោយ ព្រោះដូច្នោះ ពួកយើងគួរដឹងថា ព្រះដ៏មានព្រះភាគទ្រង់ពេញព្រះទ័យ ទើបនឹងតាក់តែង ដូច្នេះហើយ ទើបនាំគ្នាទៅគាល់ព្រះដ៏មានព្រះភាគ ឥឡូវនេះ ដឹងថា ព្រះដ៏មានព្រះភាគទ្រង់ពេញព្រះទ័យ ទើបមានសេចក្ដីប្រាថ្នានឹងតាក់តែង ព្រោះដូច្នោះ ទើបចូលទៅក្នុងអាវសថាគារនោះ ។ បទថា **សព្វសន្ថរឺ អាវសថាការំ សន្ថរិត្វា** សេចក្ដីថា អ្នកបាដលិគ្រាមទាំងនោះ ក្រាលសន្ថរ៉ាតពេញអាវសថាគារនោះដោយល្អ ។ មុននឹងក្រាលសន្ថរ៉ាត អ្នកបាដលិគ្រាមយកអាចម៍គោលាបផែនដី សូម្បីដែលទីនោះលាបដោយកំបោរហើយ ដោយគិតថា ធម្មតាអាចម៍គោ ប្រើប្រាស់បានក្នុងការងារជាមង្គលទាំងអស់ ដឹងថា ស្ងួតហើយ ទើបលាបដោយរបស់ក្រអូបមានជាតិ ៤ យ៉ាង ដោយមិនប្រាកដស្នាមជើងក្នុងទីដែលជាន់ ក្រាលកន្ទេលផែងដែលមានពណ៌ផ្សេងៗខាងលើ ហើយ

ក្រាលសំពត់ពោមសត្វផ្ទាំងធំៗ ជាដើមពីខាងលើ កន្ទេលផែងទាំងនោះ ហើយក្រាលគ្រប់កន្ទែងទាំងអស់ ដែលគួរនឹងគប្បីក្រាល ដោយកម្រាលមានពណ៌ផ្សេងៗ មានកម្រាលដែលគេក្រាលលើខ្នងដំរីជាដើម ។ ព្រោះហេតុនោះ លោកទើបពោលថា **សព្វសន្ថរឺ អាសនបាការំ សន្ថរិត្វា** ជាដើម ។

មែនពិត ត្រង់កណ្ដាលអាសនៈទាំងឡាយ អ្នកបាដលិគ្រាមតាក់តែងពុទ្ធាសនៈមានតម្លៃច្រើន អាស្រ័យសសរជាមង្គល ហើយក្រាលកម្រាលដែលទន់ល្មៃ គួររីករាយចិត្ត ទុកលើពុទ្ធាសនៈនោះ ហើយចាត់ចែងខ្នើយដែលមានពណ៌ក្រហមទាំងសងខាង ឃើញគួរជាទីពេញចិត្ត ហើយចងពិតានដ៏វិចិត្រដោយផ្កាយមាស ផ្ការប្រាក់ទុកខាងលើ ប្រដាប់ដោយកម្រងគ្រឿងក្រអូប និងកម្រងផ្កាឈើជាដើម ឱ្យបាំងដោយសំណាញ់ផ្កាឈើ ក្នុងទី ១២ ហត្ថ ដោយជុំវិញ ហើយឱ្យយកវាំងননព័ទ្ធទីប្រមាណ ៣០ ហត្ថ ឱ្យរៀបគ្រែមានភ្នាក់ដៃសម្រាប់ផ្អែក និងតាំងជាដើម ដើម្បីកិក្ខុសង្ឆសម្រាប់ផ្អែក ឱ្យក្រាលកម្រាលពណ៌-សពីលើ ឱ្យគេធ្វើទីអង្គុយរបស់ខ្លួនត្រង់ទិសខាងកើតនៃសាលា ។ ដូចដែលលោកពោលទុកថា ឱ្យក្រាលអាសនៈជាដើម ។

បទថា **ឧទកមណិកំ** បានដល់ ធ្នាំងទឹក ដែលសម្រេចហើយដោយមាស និងកែវមណីមានតម្លៃច្រើន គឺពាងទឹក ។ ព្រះដ៏មានព្រះភាគ និងកិក្ខុសង្ឆលាងព្រះហស្ត លាងព្រះបាទ និងខ្ពុរព្រះឱស្ថតាមការសព្វព្រះទ័យ ប្រការដូច្នេះ ព្រោះដូច្នោះ ពួកគេទើបដាក់ទឹកដែលមានពណ៌ដូចកែវមណី

ឱ្យពេញក្នុងទីនោះ។ ហើយដាក់ផ្ការណើនានា និងម្សៅម៉ដ្ឋសម្រាប់ទឹក ដើម្បីប្រយោជន៍ដល់ការអប់ ហើយក៏ឱ្យកស្ទឹកចេកគ្របទុក ។ ព្រោះហេតុនោះ លោកទើបពោលថា ឱ្យតាំងធ្នាំងទឹកទុក ។

បទថា **តេលប្ជនីបំ អាហរិត្វា** សេចក្តីថា ឱ្យអុជប្រទីបប្រេង នឹងដង គោមដែលសម្រេចដោយមាស និងប្រាក់ជាដើម និងលើចាន ដែលសម្រេចដោយមាស និងប្រាក់ជាដើម គឺគេតាំងទុកលើដៃរូបទាហាន ដ៏វិចិត្រហើយដោយល្អជាដើម ។ ក៏ក្នុងបទថា **យេន ភគវា តេនុបសង្កមីសុ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ។ ក៏ឧបាសក និងឧបាសិកាអ្នកបាដលិគ្រាមទាំងឡាយ មិនត្រឹមតែរៀបចំអាវសថាគារប៉ុណ្ណោះទេ បើតាមពិតទៅ ពួកគេសម្អាតដងផ្លូវក្នុងស្រុកទាំងមូល ដោតទង់ តម្រៀបដើមចេក និងធ្នាំងទឹកត្រង់ទ្វារផ្ទះទាំងឡាយ ធ្វើស្រុកទាំងមូលឱ្យដូចជាផ្ការយ ដេរដាសដោយប្រទីប និងផ្ការទាំងឡាយ ឱ្យគេវាយស្គរស្រែកប្រកាសថា ក្មេងដែលនៅបៅ ឱ្យបៅទឹកដោះ ក្មេងជំទង់ៗ ឱ្យប្រញាប់បរិភោគ ហើយទៅដេក កុំធ្វើសំឡេងខ្លាំង ក្នុងថ្ងៃនេះ ព្រះសាស្តានឹងប្រថាប់នៅខាងក្នុងស្រុកត្រឹមតែមួយរាត្រី ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មានប្រាជ្ញាដោយសំឡេងតិចៗ ដូច្នេះហើយ កាន់គប់ភ្ជើងដោយខ្លួនឯង ចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ។

បទថា **អថខោ ភគវា (បុព្វណ្ហសមយំ) និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឆេន យេន អាវសថាការ តេនុបសង្ខមិ** *សេចក្តីថា ចានឮ មកថា កាលអ្នកចាដលិគ្រាមទាំងនោះ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្គាល់វេលាដ៏សមគួរក្នុងកាលឥឡូវនេះចុះ ព្រះដ៏មានព្រះភាគទ្រង់ចាត់ចែងសំពត់ដែលជ្រលក់ហើយ ២ ជាន់ មានពណ៌ដូចផ្ការលួសក្រហម ដែលជោគដោយទឹកល័ក្ខ ស្ងៀកដណ្តប់បិទចាំង មណ្ឌល ៣ ដូចយកកន្ត្រៃកាត់ផ្ការណ្ឌក និងដូចយកសង្ហ្ការមាសព័ទ្ធបាច់ផ្ការណ្ឌក ទ្រង់ក្រវាត់កាយព័ន្ធន៍ដ៏ស្រស់ល្អ ស្មើនឹងផ្ទៃកបន្ទោរ ទ្រង់ដណ្តប់សំពត់បង្សុកូលចីវរដ៏ប្រសើរ ដែលគេជ្រលក់ល្អហើយ មានពណ៌ស្មើដោយពន្ធកដើមជ្រៃ គឺព្រះអង្គទ្រង់កាន់យកហើយ ធ្វើចក្រវាឡទាំងមូល ភ្នំសិនេរុ ភ្នំយុគន្ធរ និងមហាប្រថពីទាំងអស់ឱ្យញាប់ញ័រ ដូចជាយកសំពត់កម្ពលក្រហមដណ្តប់ពោងដំរី ដូចជាបោះសំណាញ់កែវប្រវាឡ លើស្ទៀតមាស កម្ពស់ ១០០ ហត្ថ ដូចគ្របអាវកម្ពលក្រហមលើសុវណ្ណចេតិយធំ ដូចពពកក្រហមបិទចាំងព្រះចន្ទ ក្នុងវ្ថៃពេញបូណ៌មីកំពុងគោចរ ដូចក្រាលទឹកល័ក្ត ដែលធ្ងិនល្អលើកំពូលភ្នំមាស និងដូចយកសំណាញ់ក្ងេកបន្ទោរព័ទ្ធជុំវិញកំពូលភ្នំចិត្តកូដ ស្តេចចេញចាកមណ្ឌបដ៏វិចិត្រដែលព្រះអង្គប្រថាប់គង់ ដូចជាព្រះចន្ទពេញវង់ និងដូចជាព្រះសុរិយោ-ទ័យចែងចាំងពន្ធឺស្រទន់ ចេញពីកំពូលភ្នំដោយជុំវិញ ដូចរាជសីហ៍ចេញចាកព្រៃក្រាស់ ។*

លំដាប់នោះ ព្រះរស្មីផ្សាយចេញពីព្រះរកាយរបស់ព្រះអង្គ ដូចផ្ទេក-បន្ទោរ បញ្ចាំងចេញពីពពក ហើយធ្វើដើមឈើទាំងឡាយដោយជុំវិញ ដូចជាផ្ទេកបន្ទោរទាំងឡាយដែលជ្រែកចេញពីចន្ទោះពពក ធ្វើឱ្យរុក្ខជាតិក្នុងអាវាមដូចជាមានស្លឹក ផ្កា ផ្លែ មែក និងគែមទូកអមដោយពពុះទឹកមាសជះស្រោចព្រមគ្នានោះ ។ ភិក្ខុសង្ឆដ៏ច្រើន ក៏កាន់បាត្រ និងចីវររបស់ខ្លួនៗ ហៅហមព្រះមាន-ព្រះភាគ ។ ក៏ភិក្ខុទាំងនោះ ឈរហៅហមព្រះដ៏មានព្រះភាគជាអ្នកមានសភាពដូច្នោះ គឺជាអ្នកប្រាជ្ញាតិច ជាអ្នកសន្ដោស ជាអ្នកស្ងប់ ជាអ្នកមិនច្របូកច្របល់ដោយពួក ជាអ្នកប្រារព្ធសេចក្ដីព្យាយាម ជាអ្នកទូន្មានខ្លួន ជាអ្នកអត់ធន់ចំពោះពាក្យ ជាអ្នកពោលដាស់តឿន ជាអ្នកតិះដៀលអំពើអាក្រក់ ជាអ្នកបរិបូណ៌ដោយសីល សមាធិ បញ្ញា វិមុត្ដិ និងវិមុត្ដញ្ញាណទស្សនៈ ។ ព្រះដ៏មានព្រះភាគ គឺភិក្ខុសង្ឆទាំងឡាយ ហៅហមហើយ រុងរឿងដូចគំនរមាស ដែលព័ទ្ធដោយសំពត់កម្ពលក្រហម ដូចព្រះចន្ទពេញវង់ អមទៅដោយពួកផ្កាយ ដូចនាវាមាសនៅក្នុងព្រៃផ្ការីកក្រហម និងដូចប្រាសាទមាស ដែលឡោមព័ទ្ធទៅដោយប្រាក់កែវប្រាកដ ។ ចំណែកព្រះមហាថេរៈ មានព្រះមហាកស្សបៈជាប្រធាន ជាអ្នកមានរាគៈដែលកាត់ហើយ ជាអ្នកទម្ងាយកិលេស ជាអ្នកមានកិលេសដូចរុក្ខជាតិដែលកាត់ដាច់ហើយ ជាអ្នកមានចំណងកាត់ផ្ដាច់ហើយ ជាអ្នកមិនជាប់ជំពាក់នឹងត្រកូល ឬគណៈ ស្ងៀកដណ្ដប់បង្សុកូលចីវរ មានពណ៌ដូចពណ៌ផ្លែ

មេយ ហៃហមព្រះដ៏មានព្រះភាគ ដូចស្តេចដំរីដណ្តប់អាករណ:កែវមណីដូច្នោះ ។

ដូច្នោះ ព្រះដ៏មានព្រះភាគ ព្រះអង្គជាអ្នកប្រាសចាករាគ: ដែលអ្នកប្រាសចាករាគ:ទាំងឡាយហៃហមហើយ ព្រះអង្គជាអ្នកប្រាសចាកទោស: ដែលអ្នកប្រាសចាកទោស:ទាំងឡាយហៃហមហើយ ព្រះអង្គជាអ្នកប្រាសចាកមោហ: ដែលអ្នកប្រាសចាកមោហ:ទាំងឡាយហៃហមហើយ ព្រះអង្គជាអ្នកប្រាសចាកតណ្ហា ដែលអ្នកប្រាសចាកតណ្ហាទាំងឡាយហៃហមហើយ ព្រះអង្គជាអ្នកប្រាសចាកកិលេស ដែលអ្នកប្រាសចាកកិលេសទាំងឡាយហៃហមហើយ ព្រះអង្គឯងជាអ្នកត្រាស់ដឹង ដែលអ្នកត្រាស់ដឹងតាមទាំងឡាយហៃហមហើយ ដូចជាលម្អងផ្ការ ដែលព័ន្ធព័ទ្ធដោយត្រចក ដូចផ្ការណ៉ាកា ដែលហៃហមដោយកេសរ ដូចស្តេចដំរីឆទ្ទន្ត មានដំរី ៨.០០០ ក្បាល ជាបរិវារ ដូចស្តេចហង្សធតរដ្ឋ មានហង្ស ៩០.០០០ ក្បាល ជាបរិវារ ដូចស្តេចចក្រពត្តិ ហៃហមដោយអង្គសេនា ដូចស្តេចសក្កទេវរាជ ហៃហមដោយទេវតា ដូចហារិតមហាព្រហ្ម ហៃហមដោយពួកព្រហ្ម ដូចព្រះចន្ទពេញវង់ ហៃហមដោយពួកផ្កាយ ព្រះអង្គទ្រង់ពុទ្ធដំណើរតាមផ្លូវ ជាទីទៅកាន់បាដលិគ្រាម ដោយភាពជាព្រះពុទ្ធ រកអ្នកប្រៀបផ្ទឹមមិនបាន ដោយពុទ្ធវិលាស:រកប្រមាណមិនបាន ។

លំដាប់នោះ ព្រះពុទ្ធរស្មីប្រាកដច្បាស់ មានពណ៌ដូចជាពណ៌នៃមាសផ្សាយចេញប្រមាណ ៨០ ហត្ថ ពីព្រះវរកាយខាងមុខរបស់ព្រះដ៏មានព្រះភាគនោះ ម្យ៉ាងទៀត ព្រះពុទ្ធរស្មីប្រាកដច្បាស់ មានពណ៌ដូចជាពណ៌នៃមាស

ផ្សាយប្រមាណ ៨០ ហត្ថ ពីព្រះវរកាយខាងក្រោយ ខាងស្តាំ និងពីខាងឆ្វេង ។ ព្រះពុទ្ធរស្មីប្រាកដច្បាស់ មានពណ៌ដូចជាពណ៌នៃ-កស្តេចក្ងោក ផ្សាយចេញពីផ្ទៃសក់ទាំងអស់ តាំងពីទីបំផុតចុងសក់ប្រមាណ ៨០ ហត្ថ លើផ្ទៃអាកាស ។ ព្រះពុទ្ធរស្មីប្រាកដច្បាស់ មានពណ៌ដូចជាពណ៌នៃកែវប្រាឡ ផ្សាយចេញពីព្រះយុគលបាទ ខាងក្រោមទល់នឹងទីប្រមាណ ៨០ ហត្ថ ទៅកាន់ផែនដី ។ ព្រះពុទ្ធរស្មីប្រាកដច្បាស់ មានពណ៌ស ផ្សាយចេញពីព្រះទន្ត ពីដូងព្រះនេត្រ ពីព្រះនខាដែលផុតពីព្រះមំសៈប្រមាណ ៨០ ហត្ថ ។ ព្រះពុទ្ធរស្មី មានពណ៌ដូចពណ៌ហង្សបាទ ផ្សាយចេញអំពីទីដែលមានពណ៌លាយគ្នា មានពណ៌ក្រហម និងពណ៌លឿង ប្រមាណ ៨០ ហត្ថ ។ ព្រះពុទ្ធរស្មីផ្សាយចេញពីព្រះវរកាយគ្រប់ទិសទាំងអស់ ។ ព្រះពុទ្ធរស្មីមានពណ៌ ៦ ប្រការ ធ្វើស្ថានទីប្រមាណ ៨០ ហត្ថ ដោយជុំវិញយ៉ាងនេះឱ្យរុងរឿង ធ្វៀលធ្វាត់ និងផ្សព្វផ្សាយទៅ ត្រាច់ទៅកាន់ទិសតូច ទិសធំ ដូចជាអណ្តាតនៃមហាប្រទីប ផ្សាយចេញដោយគ្រឿងបំភ្ងឹទាំងឡាយ មានចន្ទុះមាសជាដើម ស្ទុះទៅកាន់អាកាស និងដូចផ្ទេកបន្ទោរ ដែលស្ទុះចេញពីមហាមេឃក្នុងទ្វីបទាំង ៤ ។ គ្រប់ទិសទាំងអស់រុងរឿង ដោយការពោយពាយ បាចសាចដោយផ្កាចម្ប៉ាមាស ដូចយកខ្សែទឹកមាសចេញពីផ្ទាំងមាស ដូចជាការព័ន្ធព័ន្ធដោយផែនមាសដែលផ្សាយចេញទៅ ដូចជាការពោយពាយដ៏ស្មើដោយលម្អិតនៃផ្ការលួសបាយ ផ្ការណាការនិងផ្ការ

រលួសផ្ទុងមាសដែលតាំងឡើងដោយខ្យល់កំបុតត្ស្ងួត និងដូចជ្រលក់ដោយលម្ងិត ម្សៅក្រហម ។

មែនពិត ព្រះធោមរបស់ព្រះដ៏មានព្រះភាគ ដែលរុងរឿង ព័ន្ធព័ទ្ធដោយ អនុព្យញ្ជនៈ ៨០ និងព្រះរស្មីប្រមាណមួយព្យាម ប្រដាប់ដោយមហាបុរិស-លក្ខណៈ ៣២ ប្រការ ដែលប្រាសចាកគ្រឿងសៅហ្មង មានប្រជ្រុយ និងអាចម៍រុយជាដើម រុងរឿងដូចផ្ទៃអាកាស ដែលរុងរឿងដោយពួកផ្កាយ ដែលធ្លាតធាយ ប្រៀបដូចព្រៃផ្ការបទុមដែលរីកស្គុះស្គាយពេញអាកាស ដូចដើម បារិឆត្តកព្រឹក្សកម្ពស់ ១០០ យោជន៍ រីកត្រសុំត្រសាយ មានសីរី ដូចជាសីរីរបស់ព្រះចន្ទ ៣២ ដួង របស់ព្រះអាទិត្យ ៣២ ដួង របស់ស្តេចចក្រពត្តិ ៣២ អង្គ របស់សក្កទេវរាជ ៣២ អង្គ របស់ព្រះមហាព្រហ្ម ៣២ អង្គ តាំងនៅរៀងគ្នាតាមលំដាប់ ដែលប្រដាប់ដោយភាពនៃព្រះអង្គអ្នកមានបារមី ១០ គត់ ដែលទ្រង់បំពេញមកដោយប្រពៃ គឺបារមី ១០ ឧបបារមី ១០ និងបរមត្ថបារមី ១០ កើតឡើងដោយការបំពេញទាន ដោយការរក្សាសីល ដោយការបំពេញកល្យាណធម៌ អស់ ៤ អសង្ខ្យេយ្យ និងក្រៃលែងដោយសែនកប្ប រួមចុះក្នុងអត្តភាពតែមួយ កាលមិនមានឱកាសនឹងឱ្យផល ក៏កើតឡើងក្នុងកាលជាមួយគ្នា ហាក់ដូចជាការលើកឡើងនូវកណ្ហៈប្រមាណ ១០០០ សំពៅ ដាក់លើសំពៅតែមួយ ហាក់ដូចជាការលើកឡើងនូវកណ្ហៈប្រមាណ ១០០០ រទេះ ដាក់លើរទេះតែមួយ និងហាក់ដូចជាទន្ទេគង្គា ២៥ ខ្សែ ចែកចេញពីគ្នា ហើយរួមខ្សែ

តែមួយវិញ ។

គប់ក្ងើងច្រើនពាន់ដើម ផុសឡើងពីខាងមុខព្រះដ៏មានព្រះភាគ ព្រះអង្គ មានពន្ធឹស្វាងស្ងៃដោយពុទ្ធសិរីនេះ ទាំងខាងក្រោយ ខាងធ្វេង ខាងស្តាំ ក៏ដូចគ្នា ។ ផ្ការ៉ាមិ: ផ្ការ៉ាចម្ប៉ា ផ្ការ៉ាមិ:រួត ឧប្បលក្រហម ឧប្បលខៀវ ផ្ការ៉ាពិកុល: ផ្ការ៉ាដើមគន្ធីសជាដើម និងលម្អិតគ្រឿងក្រអូប មានពណ៌ខៀវ និងពណ៌លឿងជាដើម រៀងគ្នាដូចគ្រាប់ភ្ងៀងដែលបង្ករចុះពីមហាមេឃក្នុងទ្វីបទាំង ៤ ទិស ។ សំឡេងគឹកកងនៃតន្ត្រីដែលប្រកបដោយអង្គ ៥ ផង និងសំឡេងគឹកកងការសរសើរដែលជាប់ដោយពុទ្ធគុណ ធម្មគុណ និងសង្ឆគុណផង ហាក់ដូចជាការសន្ធនាគ្នាគ្រប់ទិសទាំងពួង ។ ដួងភ្នែករបស់ទេវតា សុបណ្ណ[1] នាគ យក្ខ គន្ធព្ធ និងមនុស្ស ដូចជាបានផឹកទឹកអម្រឹត ។ ក៏ក្នុងទីនេះ គួរនឹងពោលសរសើរ ការយាង(មករបស់ព្រះដ៏មានព្រះភាគ)ដោយពាន់នៃបទ ។ តែក្នុងទីនេះមានត្រឹមតែមុខបាឋ:ដូចតទៅនេះ

ព្រះដ៏មានព្រះភាគ ព្រះអង្គជាអគ្គមគ្គុទ្ទេសក៏ដ៏ប្រសើរ ព្រះអង្គបរិបូណ៌ដោយសព៌ាង្គកាយយ៉ាងនេះ ព្រះអង្គជាអ្នកធ្វើផែនដីឱ្យញាប់ញ័រ មិនបៀត-

---

១-សុបណ្ណ--ប័ន ជា.; សំ. (ន.) (សុបណ៌ "សត្វមានស្ងាបល្អ") គ្រុឌ ។ សុបណ្ណមាតា (--ប៉ុ:ន-ណ: មាដា) មេគ្រុឌ ។ សុបណ្ណរាជ (--ប៉ុ:ន-ណ:--) ស្តេចគ្រុឌ ។ល។

លៀនពួកសត្វ ព្រះអង្គយាងទៅ ។

ព្រះអង្គជានវាសក: ព្រះអង្គយាងទៅដោយលើកព្រះបាទស្តាំមុន ព្រះអង្គប្រកបព្រមដោយសិរី ព្រះអង្គប្រសើរជាងសត្វជើងពីរ អ្នកមានកាពស្រស់ស្អាត ។

នាកាលព្រះពុទ្ធដ៏ប្រសើរ ស្តេចយាងទៅផ្នែព្រះបាទខាងក្រោម ជាព្រះបាទទន់ណ្ម កាលសម្ផស្សនឹងផែនដីដ៏រៀបស្មើ ក៏មិនប្រឡាក់ដោយធូលី ។

កាលព្រះលោកនាយក ស្តេចដំណើរទៅ កន្ទែងផត ទៅជាប៉ោងឡើង ទាំងកន្ទែងទួល ទៅជាពាបស្មើ ដែលផែនដី ជាធម្មជាតិមិនមានចេតនា ។

កាលព្រះលោកនាថ ទ្រង់យាងទៅ ត្រង់ផ្លូវគ្រប់កន្ទែងមានថ្ម គ្រួស អំបែងក្បឿង ដង្គត់ឈើ និងបន្ទា ក៏ចាត់អស់ ។

ព្រះដ៏មានព្រះភាគ ព្រះអង្គមិនលើកព្រះបាទឈានវែង ក្នុងទីឆ្ងាយ ព្រះអង្គមិនលើកព្រះបាទឈានខ្ជី ក្នុងទីជិត មិនមានភាពលំបាក ក្នុងព្រះជាណុ (ជង្គង់) និង-ក ព្រះបាទទាំងពីរ ។

ព្រះមុនី ព្រះអង្គអ្នកបរិបូណ៌ដោយចរណ: ព្រះអង្គមានព្រះទ័យយ៉ាងមាំ កាលព្រះអង្គយាងទៅ ព្រះអង្គមិនយាងទៅដោយរហ័ស ទាំងមិនយាងទៅដោយយឺតៗ ទេ ។

ព្រះដ៏មានព្រះភាគអង្គនោះ កាលព្រះអង្គយាងទៅ ព្រះអង្គមិនសម្ងឹងមើលលើ មិនមើលក្រោម មិនមើលទទឹង មិនមើលត្រង់ទិសតូច និងទិសធំ តែព្រះអង្គមើលត្រឹមតែមួយជួរនឹមតែប៉ុណ្ណោះ ។

ព្រះជិនស្រីព្រះអង្គនោះ ដូចស្តេចដំរី រមែងស្រស់ល្អក្នុងការយាងទៅ ព្រះអង្គជាអ្នកកំពូលលើសក្នុងលោក ស្តេចដំណើរទៅស្រស់ល្អ ធ្វើលោកព្រមទាំងទេវលោកឱ្យរីករាយ ។

ព្រះអង្គស្រស់ល្អដូចគោឧសភរាជ ដូចស្តេចរាជសីហ៍ មានដំណើរយ៉ាងស្រស់ល្អទ្រង់ញ៉ាំងពួកសត្វដ៏ច្រើនឱ្យត្រេកអរ ព្រះអង្គជាអ្នកប្រសើរយាងទៅកាន់ស្រុក ។

នេះឈ្មោះថា ជាវេលាដល់ការសរសើរ ។ កម្ទាំងរបស់ព្រះធម្មកថិកប៉ុណ្ណោះ ជាប្រមាណក្នុងការសរសើរព្រះធោម និងសរសើរព្រះគុណរបស់ព្រះដ៏មានព្រះភាគ ក្នុងកាលទាំងឡាយដោយប្រការយ៉ាងនេះ ។ ដោយចុណ្ណិយបទចងជាគាថា ដែលលោកនឹងអាចពោលនូវពាក្យណា គប្បីពោលនូវពាក្យនោះ ។ គឺធម្មកថិកមិនគប្បីពោលយ៉ាងថា ពោលបានដោយលំបាក ឬថាត្រាច់មិនខុសកំពង់ ។ មែនពិត សូម្បីព្រះពុទ្ធទាំងឡាយ ជាព្រះដ៏មាន-ព្រះភាគ ព្រះអង្គមានគុណប្រមាណមិនបាន ក៏មិនអាចពោលគុណរបស់ព្រះពុទ្ធទាំងឡាយនេះ ដោយមិនឱ្យមសេសសល់ទេ សូម្បីពណ៌នានូវគុណទាំងឡាយនោះអស់កប្បទាំងមូល ក៏មិនអាចបរិយាយឱ្យអស់បាន ចាំបាច់នឹងពោលទៅថ្វីដល់ជនក្រៅនេះ ។ ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់

ចាដលិគ្រាម ដែលប្រជាប់តាក់តែងដោយព្រះសិរីវិលាស[1]នេះ ដែលជនអ្នកមានចិត្តជ្រះថ្លាបូជាដោយសក្ការៈ មានផ្លាឈើ របស់ក្រអូប ធូប និងម្សៅសម្រាប់អប់ជាដើម ព្រះអង្គយាងចូលទៅកាន់អាវសថាគារ ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រជាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ជាមួយភិក្ខុសង្ឆ យាងទៅកាន់ពោងសំណាក់ ដូច្នេះ ។

បទថា **ចាដេ បក្ខ្លាលេត្វា** *សេចក្ដីថា សូម្បីបើសើម គឺធូលីមិនប្រលាក់ព្រះបាទព្រះដ៏មានព្រះភាគ ក៏ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគ ព្រះអង្គប្រាថ្នាសេចក្ដីចម្រើនដ៏ក្រៃលែងនៃកុសលរបស់ឧបាសក និងឧបាសិកាទាំងនោះ ទើបទ្រង់លាងព្រះបាទ ដើម្បីជាទិដ្ឋានុគតិដល់ជនជំនន់ក្រោយ ។ ម្យ៉ាងទៀត ដែលឈ្មោះថា ព្រះសរីរៈដែលមានចិត្តគ្រប់គ្រង ក៏ត្រូវធ្វើឱ្យត្រជាក់ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ស្រង់ទឹក និងទ្រង់លាងព្រះបាទជាដើម ដើម្បីប្រយោជន៍នេះតែម្យ៉ាង ។*

បទថា **ភតវណ្ដំយេវ បុរក្ខ្លត្វា** *បានដល់ ធ្វើព្រះដ៏មានព្រះភាគ ទុកខាងមុខ ។ ក្នុងសេចក្ដីនោះ ព្រះដ៏មានព្រះភាគទ្រង់ប្រថាប់គង់ត្រង់កណ្ដាលនៃភិក្ខុទាំងឡាយ និងរបស់ឧបាសកនិងឧបាសិកាទាំងឡាយ ទ្រង់ស្រង់ទឹកដោយទឹកក្រអូប ហើយទ្រង់ធ្វើទឹកឱ្យស្ងួតដោយរវៀលសំពត់ ហើយធ្វើឱ្យស្ងួតដោយ*

១-ពិលាស សំ. ជា. (ន.) (វិលាស) លំនាំលីលា, លំនាំក្រៃក្រាយ, ញ៉ែងញ៉ង; លំនាំណ្ដាយណ្ដង ។

ជាតិហិង្គុ រមែងរុងរឿងដ៏ក្រៃលែង ដូចប្រៀបជារូបបដិមាដែលធ្វើដោយដុំមាសពណ៌ក្រហមដែលតម្កល់ទុកលើតាំង ដែលព័ទ្ធដោយសំពត់កម្ពលក្រហម ។

ក៏ក្នុងសេចក្ដីនេះ ជាបទព័ន្ធដែលបោរាណបណ្ឌិត ចងទុកដូចតទៅនេះ

ព្រះលោកនាថជាម្ចាស់ ព្រះអង្គកំពូលលើសសត្វលោក ព្រះអង្គយាងទៅ ដូចស្ដេចដំរី ព្រះអង្គយាងទៅកាន់ពោធិមូលដ៏ស្វាងស្ងៃ ប្រថាប់គង់លើពុទ្ធ-ាសន:ដ៏ប្រសើរ ។

ព្រះអង្គជានាយសារថី អ្នកទូន្មានទូវនរជន ព្រះអង្គ ជាទេវ:ក្រៃលែងជាងទេវ: ព្រះអង្គមានបុញ្ញាធិការកំណត់ដោយរយ ព្រះអង្គប្រថាប់គង់លើពុទ្ធាសន:ប្រសើរនោះ ទ្រង់រុងរឿងនៅត្រង់កណ្ដាលពុទ្ធាសន: ដូចដុំមាសស្រស់ល្អ នៅក្នុងសំពត់កម្ពលពណ៌លឿងដូច្នោះ ។

ព្រះអង្គប្រាសចាកមន្ទិល រមែងរុងរឿង ដូចដុំមាសជម្ពូនុទ ដែលគេដាក់លើសំពត់កម្ពលពណ៌លឿង ដូចកែវមណីស្រស់ល្អដូច្នោះ ព្រះអង្គរុងរឿងល្អ ព្រោងព្រាតជាងវត្ថុទាំងពួង ដូចដើមសាលព្រឹក្សធំ មានផ្ការីកស្ពុះស្ពាយ ដែលប្រដាប់ដោយស្ដេចឈើ ស្រដៀងប្រាសាទមាស ដូចផ្ការីកបទុមកោកនុទ ដូចដើមឈើដែលប្រដាប់ដោយប្រទីបឆេះសន្ធោសន្ធៅ ដូចកូ្ងងលើកំពូលភ្នំ ដូចដើមឈើបារិញ្ឆត្ត:របស់ទេវតាដូច្នោះ ។

បទថា **ចាជលិតាមិយេ ឧចាសកេ អាមន្តេសិ** សេចក្ដីថា ព្រោះ

ហេតុដែលឧបាសក និងឧបាសិកាជាច្រើនទាំងនោះតាំងនៅក្នុងសីល ដូច្នោះ ដើម្បីនឹងប្រកាសទោសនៃសីលវិបត្តិជាដំបូងហើយ ខាងក្រោយទើបសម្តែងអានិសង្សនៃសីលសម្បត្តិ ទើបត្រាស់ហៅមកដើម្បីសម្តែងធម៌ ដោយន័យមានអាទិ៍ថា **បញ្ចិមេ គហបតយោ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុស្សីលោ** បានដល់ អ្នកគ្មានសីល ។ បទថា **សីលវិបន្នោ** បានដល់ អ្នកមានសីលវិបត្តិ គឺបែកទម្ងាយសំវរៈ ។ ក៏ក្នុងបទទាំងនេះដោយបទថា **ទុស្សីលោ** ត្រាស់ដល់បុគ្គលដែលមិនមានសីល ។ ក៏បុគ្គលដែលមិនមានសីលនោះមាន ២ យ៉ាង គឺព្រោះមិនបានសមាទាន ១ ព្រោះទម្ងាយសីលដែលសមាទានហើយ ១ ។ បណ្តាបុគ្គលមិនមានសីលទាំង ២ យ៉ាងនោះ ប្រការទី ១ មិនមានទោសដូចប្រការទី ២ ទេ ព្រោះប្រការទី ២ មានទោសខ្លាំងជាង ។ ដើម្បីនឹងសម្តែងភាពមិនមានសីល ដែលមានទោសតាមដែលប្រាថ្នាជាហេតុ ដោយទេសនាជាបុគ្គលាធិដ្ឋាន ទើបត្រាស់ថា **សីលវិបន្នោ** ដូច្នេះ ។ ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់សម្តែងអត្ថនៃបទថា **ទុស្សីលោ** ដូច្នេះ ។ បទថា **បមាទាធិការណំ** ប្រែថា មានសេចក្តីប្រមាទជាហេតុ ។

ក៏សូត្រនេះមកហើយដោយអំណាចគ្រហស្ថទាំងឡាយ តែបព្វជិតក៏មានន័យដូចគ្នា ។ មែនពិត គ្រហស្ថដែលចិញ្ចឹមជីវិតដោយសិល្បវិជ្ជាណាមួយ ដូចជាកសិកម្មក្តី ពាណិជកម្មក្តី គោរក្ខកម្មក្តី ជាអ្នកប្រមាទដោយបាណាតិបាតជាដើម មិនអាចនឹងញ៉ាំងភាពមាំមួនក្នុងសិល្បៈនោះ ឱ្យសម្រេចបាន តាម

កាលដ៏សមគួរ កាលបើដូច្នេះ ការងាររបស់គេក៏នឹងវិនាសទៅ ។ តែកាលគ្រហស្ថទាំងឡាយនោះ ធ្វើបាណាតិបាតជាដើម ក្នុងវេលាដែលគេអាឃាតរមែងសាបសូន្យចាកកោគៈដ៏ច្រើន ដោយអំណាចអជ្ញា ។ បពូជិតអ្នកទ្រុស្តសីលរមែងសាបសូន្យចាកសីល ចាកព្រះពុទ្ធវចនៈ ចាកឈាន និងចាកអរិយធម៌ ៧ ប្រការ ព្រោះសេចក្តីប្រមាទជាហេតុ ។ បទថា **ចាបកោ កិត្តិសិទ្ធো** សេចក្តីថា កិត្តិស័ព្ទដ៏លាមករបស់គ្រហស្ថ រមែងខ្ចរខ្ចាយទៅត្រង់កណ្តាលបរិស័ទទាំង ៤ ថា គ្រហស្ថឈ្មោះឯណោះ កើតក្នុងត្រកូលឈ្មោះឯណោះ ជាអ្នកទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក ជាអ្នកលះបង់លោកនេះ និងលោកខាងមុខ រមែងមិនឱ្យទាន សូម្បីវត្ថុត្រឹមតែសលាកកត្ត ។ កិត្តិស័ព្ទដ៏លាមករបស់បពូជិត រមែងខ្ចរ-ខ្ចាយទៅយ៉ាងនេះថា បពូជិតឈ្មោះឯណោះ បួសក្នុងព្រះសាសនារបស់ព្រះសាស្តា មិនអាចដើម្បីនឹងរក្សាសីល មិនអាចដើម្បីនឹងរៀនព្រះពុទ្ធវចនៈ ជាអ្នកប្រកបដោយអគារវៈ ៦ ប្រការ ចិញ្ចឹមជីវិតដោយអនេសនកម្ម មានវេជ្ជកម្ម ជាដើម ។ បទថា **អវិសារទো** សេចក្តីថា ជាដំបូង គ្រហស្ថទាំងឡាយអ្នកប្រកបដោយភ័យ បានចូលទៅក្នុងទីប្រជុំនៃជនជាច្រើន ដោយគិតថា អ្នកណាៗ នឹងដឹងទង្វើអាក្រក់របស់យើង នឹងនិន្দা នឹងគ្របសង្កត់យើង ឬនឹងប្រាប់ដល់រាជត្រកូល ជាអ្នកអៀនប្រៀន អង្គុយឱនមុខចុះ ជាអ្នកមិនក្ងៀវក្ងាក្នុងការនិយាយ ។ ចំណែកបពូជិតទាំងឡាយ អ្នកប្រកបដោយភ័យ បានចូលទៅកាន់ទីប្រជុំនៃកិក្ខុសង្ឆដ៏

ច្រើន ដោយគិតថា បព្វជិតមួយរូប នឹងដឹងទង្វើអាក្រក់របស់អញដោយពិត កាលបើដូច្នេះ ភិក្ខុទាំងឡាយ នឹងរៀរឧបោសថកម្មក្តី បវារណាកម្មក្តីរបស់អញ នឹងអូសទាញអញឱ្យចេញចាកភាពជាសមណៈ ជាអ្នកមិនក្បៀវក្លាក្នុងការនិយាយ ។ តែអ្នកខ្វះដល់ភាពជាអ្នកទ្រុស្តសីល ក៏រមែងប្រព្រឹត្តដូចជាអ្នកមានសីល ។ សូម្បីអ្នកទ្រុស្តសីលនោះ ក៏រមែងជាអ្នកអៀនប្រៀនដោយអធ្យាស្រ័យដូចគ្នា ។

បទថា **សម្មូឡ្ហោ កាលំ ករោតិ** សេចក្តីថា មែនពិត កាលបុគ្គលទ្រុស្តសីល ដេកនៅលើគ្រែជាទីស្លាប់ ឋានៈដែលខ្លួនសមាទានកម្ម គឺភាពជាអ្នកទ្រុស្តសីល រមែងមកប្រាកដ គេបើកភ្នែកឃើញលោកនេះ បិទភ្នែកឃើញលោកខាងមុខ ។ អបាយ ៤ រមែងប្រាកដដល់គេតាមសមគួរដល់កម្ម រមែងដូចជាត្រូវរុកចាក់ដោយលំពែង ១០០ និងដូចជាត្រូវឡោមព័ទ្ធដោយអណ្តាតភ្លើង ។ ជននោះរមែងស្រែកទៀបនឹងស្លាប់ថា ចូរកុំមាន ចូរកុំមានដូច្នេះ ដរាបស្លាប់ ។ ព្រោះហេតុនោះ លោកទើបពោលថា វង្វេងធ្វើមរណកាលដូច្នេះជាដើម ។

បទថា **កាយស្ស ភេទា** បានដល់ ព្រោះលះបង់ឧបាទិន្នក្ខន្ធ ។ បទថា **បរម្មរណា** បានដល់ សំដៅយកខន្ធ ដែលនឹងគប្បីកើតក្នុងភពជាលំដាប់នៃឧបាទិន្នក្ខន្ធនោះ ។ ម្យ៉ាងទៀត បទថា **កាយស្ស ភេទា** បានដល់ ព្រោះជីវិតិន្ទ្រិយដាច់ទៅ ។ បទថា **បរម្មរណា** បានដល់ ខាងមុខអំពីចុតិ ។ បទថា **អបាយំ** ជាដើម ជាវេវចនៈរបស់នរកទាំងអស់ ។ មែនពិត នរកឈ្មោះថា **អបាយ** ព្រោះប្រាសចាកសេចក្តីចម្រើន ពោលគឺ បុណ្យដែលជាហេតុនៃ

*សួគ៌ និងព្រះនិព្វាន និងព្រោះមិនមានសេចក្ដីចម្រើន ឬការមកនៃសេចក្ដីសុខ ។ ឈ្មោះថា **ទុគ្គតិ** ព្រោះជាភូមិជាទីទៅ គឺជាទីស្នាក់អាស្រ័យនៃទុក្ខ ។ ម្យ៉ាងទៀត ឈ្មោះថា **ទុគ្គតិ** ព្រោះជាទីកើត ជាទីទៅដោយកម្មអាក្រក់ ពោលគឺ ទោសដ៏ច្រើន ។ ឈ្មោះថា **វិនិបាត** ព្រោះជាទីប្រាសចាកអំណាចធ្លាក់ទៅរបស់បុគ្គលដែលធ្វើកម្មអាក្រក់ ។ ម្យ៉ាងទៀត ឈ្មោះថា **វិនិបាត** ព្រោះជាទីវិនាស ធ្លាក់ទៅរបស់បុគ្គលដែលមានអាយុ:តូចធំបែកទៅ ។ ឈ្មោះថា **និរយៈ** ព្រោះជាទីមិនមានសេចក្ដីចម្រើន ដោយសម្គាល់ថា សេចក្ដីត្រេកអរ ។*

*ម្យ៉ាងទៀត ដោយស័ព្ទថា **អបាយ** ទ្រង់សម្ដែងដល់កំណើតសត្វតិរច្ឆាន ។ មែនពិត កំណើតសត្វតិរច្ឆាន ឈ្មោះថា **អបាយ** ព្រោះប្រាសចាកភូមិជាទីទៅល្អ មិនចាត់ជាទុគ្គតិ ព្រោះជាទីកើតរបស់ស្ដេចនាគជាដើម អ្នកមានសក្ដិធំ ។ ដោយស័ព្ទថា **ទុគ្គតិ** លោកសម្ដែងដល់វិស័យនៃប្រេត ។ មែនពិត បេតវិស័យនោះឈ្មោះថា **អបាយ** ព្រោះប្រាសចាកសុគតិ និងឈ្មោះថា **ទុគ្គតិ** ព្រោះជាភូមិជាទីទៅនៃទុក្ខ តែមិនមែនចាត់ជាវិនិបាត ព្រោះមិនបានធ្លាក់ទៅ ដោយគ្មានអំណាចដូចពួកអសុរ ។ មែនពិត សូម្បីវិមានក៏រមែងកើតដល់ពួកប្រេតអ្នកមានឫទ្ធិច្រើន ។ ដោយស័ព្ទថា **វិនិបាត** ទ្រង់សម្ដែងដល់អសុរកាយ ។ ក៏អសុរកាយនោះ ពោលអំពីអត្ថតាមដែលពោលហើយ លោកហៅថា **អបាយ** និង**ទុគ្គតិ** ហៅថា **វិនិបាត** ព្រោះធ្លាក់ទៅដោយគ្មានអំណាចពីគំនរសម្បត្ដិទាំង-*

អស់ ។ ដោយស័ព្ទថា **និរយ:** *ទ្រង់សម្តែងចំពោះនរក ដែលមាន ប្រការផ្សេងៗ មានអវិចីជាដើម ។ បទថា* **ឧបច្ឆ្ជតិ** *ប្រែថា រមែងកើត ។*

គប្បីជ្រាបអានិសង្សកថា ដោយបរិយាយផ្ទុយគ្នាដូចពោលហើយ ។ ចំណែកសេចក្តីប្លែកគ្នាមានដូចតទៅនេះ

បទថា **សីលវា** *បានដល់ អ្នកមានសីល ដោយការសមាទាន ។ បទថា* **សីលសម្បន្នោ** *បានដល់ អ្នកដល់ព្រមដោយសីល ព្រោះសមាទាននូវសីល ដោយធ្វើឱ្យបរិសុទ្ធបរិបូណ៌ ។ បទថា* **ភោគក្ខន្ធំ** *បានដល់ គំនរនៃភោគ: ។ ដោយសុគតិ-ស័ព្ទ ក្នុងបទថា* **សុគតឺ សក្តំ លោកំ** *នេះ លោករួមយកគតិ របស់មនុស្សចូលផង ។ ដោយស័ព្ទថា* **សក្តំ** *លោកសំដៅដល់គតិរបស់ទេវតា ចូលផង ។ ក្នុងគតិទាំងនោះ ឈ្មោះ* **សុគតិ** *ព្រោះមានគតិល្អ ។ ឈ្មោះថា* **សគ្ត:** *ព្រោះមានអារម្មណ៍ដោយល្អ មានរូបារម្មណ៍ជាដើម ។ ក៏សគ្ត:ទាំងអស់នោះ ឈ្មោះថា* **លោក** *ព្រោះអត្ថថា បែកធ្លាយ ។*

បទថា **ចាដលិគាមិយេ ឧចាសកេ ពហុនេវ រត្តឺ ធម្មិយា កថាយ** *សេចក្តីថា ដោយធម្មកថា និងដោយកថាជាគ្រឿងអនុមោទនាទីដែលសម្រាក អាស្រ័យដែលរួចផុតពីបាលីសូម្បីដទៃ ។*

ក៏ក្នុងគ្រានោះ ព្រោះហេតុដែលព្រះបាទអជាតសត្រូវ កាលនឹងទ្រង់ កសាងនគរបាដលីបុត្រក្នុងទីនោះ ទើបទ្រង់នាំយកកុដុម្ពីក៏ដល់ព្រមដោយសីល និងអាចារ: ពីនិគម ជនបទ និងរាជធានីដទៃៗ ហើយប្រទានទ្រព្យ ធញ្ញាហារ

ផ្ទះ ស្រែជាដើម និងការឃុំគ្រងហើយឱ្យនៅអាស្រ័យដូច្នោះ ព្រះដ៏មានព្រះភាគ គ្រាទ្រង់សម្តែងអានិសង្សនៃសីល មុនដល់ឧបាសក និងឧបាសិកាអ្នកបាដលិគ្រាម អ្នកធ្ងន់ក្នុងសីល ដោយពិសេស ព្រោះជាអ្នកឃើញអានិសង្ស និងព្រោះសីលជាទីតាំងនៃគុណទាំងពួង តអំពីនោះ កាលនឹងសម្តែងបកិណ្ណកកថា ដែលនាំមកនូវប្រយោជន៍សុខដល់ឧបាសក និងឧបាសិកាអ្នកបាដលិគ្រាម ដូចញ្ជាំងអាកាសគង្គាឱ្យធ្លាក់ចុះ ដូចអូសទាញយកឱ្ជ:របស់ដី ដូចចាប់ចុងនៃដើមព្រីងធំឱ្យញ័រ និងដូចយកគ្រឿងយន្តបៀតបៀនសំបុកឃ្មុំប្រមាណមួយយោជន៍ ឱ្យសម្រេចជាទឹកផ្អែមល្អ ទើបទ្រង់សម្តែងធម្មកថាជាច្រើន ដ៏វិចិត្រដោយន័យផ្សេងៗ យ៉ាងនេះថា ម្នាលគហបតីទាំងឡាយ ធម្មតាថា អាវាសទាននេះ មានបុណ្យច្រើន តថាគត និងកិក្ខុសង្ឆបានប្រើអាវាសរបស់ពួកលោក ក៏កាលតថាគត និងកិក្ខុសង្ឆប្រើហើយក៏មាន ឈ្មោះថា ធម្មរតន:ក៏បានប្រើដូចគ្នា កាលរតន:ទាំង ៣ បានប្រើហើយយ៉ាងនេះ រមែងមានវិបាករកប្រមាណមិនបាន ម្យ៉ាងទៀត កាលថ្វាយ អាវាសទាន ក៏ឈ្មោះថា ថ្វាយទានទាំងពួងអ្នកណាៗ មិនអាចនឹងកំណត់អានិសង្សរបស់បណ្ណសាលា ដែលសាងទុកលើផែនដី ឬរបស់សាលាពយរង ដែលសាងឧទ្ទិសថ្វាយសង្ឆ ក៏ដោយអានុភាពនៃអាវាសទានសូម្បីសត្វអ្នក នឹងកើតក្នុងកពនឹងឈ្មោះថា នៅក្នុងគក៌ ដែលត្រូវគេបៀតបៀនមិនបាន ផ្ទៃមាតារបស់សត្វអ្នកកើតក្នុងគក៌នោះ នឹងមិនចង្អៀតឡើយ ដូចបន្ទប់

ប្រមាណ ១២ ហត្ថ ដូច្នេះហើយទើប ត្រាស់កថាពោលអំពីអានិសង្សនៃអាវាសទាន អស់កន្ទុះដ៏ក្រៃលែង ក្នុងរាត្រីជាការច្រើនថា

(វិហារ គឺទីអាវាស ឬសេនាសនៈជាទីនៅនៃសង្ឆទាំងឡាយ) រមែងការពាររដូវផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូច ពស់ទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់នឹងកម្តៅថ្ងៃដ៏ក្ដៅខ្លាំង ដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះៗ ។ វិហារទាន គឺការឱ្យលំនៅ (ដែលបុគ្គលបានឱ្យហើយ) ដល់សង្ឆសម្រាប់ជ្រកកោនផង សម្រាប់នៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចម្រើនវិបស្សនាផង ព្រះពុទ្ធជាម្ចាស់ទាំងឡាយ តែងត្រាស់សរសើរថា ជាអគ្គទាន (ទានដ៏ប្រសើរ) ។ ព្រោះហេតុនោះឯង បុរស (ស្ត្រី) ជាបណ្ឌិត កាលបើបានឃើញចម្រាស់ទូវប្រយោជន៍របស់ខ្លួន ហើយគប្បីកសាងវិហារ គឺអាវាស ឬសេនាសនៈទាំងឡាយដ៏ជាទីគួររីករាយ ហើយគប្បីនិមន្តលោកដែលជា ពហុស្សូត គឺលោកអ្នកចេះដឹងច្រើនទាំងឡាយឱ្យនៅក្នុងទីនោះ ។ គប្បីមានចិត្តជ្រះថ្លា ចំពោះលោកទាំងឡាយដែលមានកាយ នឹងចិត្តត្រង់ ហើយឱ្យម្ហូបចំណីផង ទឹកផង សំពត់នឹងសេនាសនៈទាំងឡាយផង ដល់លោកទាំងនោះចុះ ។ លោកទាំងនោះ រមែងសម្តែងធម៌ជាគ្រឿងបន្ទោបង់សេចក្ដីទុក្ខគ្រប់ប្រការដល់អ្នកនោះ លុះអ្នកនោះ បានដឹងធម៌ណា

ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន[1]។

រួមសេចក្តីថា ទាំងនេះ ជាអានិសង្សនៃអាវាសទាន ដោយប្រការដូច្នេះ ។ តែក្នុងអានិសង្សអាវាសទាននេះ លោកលើកគាថានេះឯងឡើងកាន់សង្គាយនា ចំណែកបកិណ្ណកធម្មទេសនា មិនបានលើកឡើងកាន់សង្គាយនាទេ ។

បទថា **សន្ធសេ្សត្វា** ដូច្នេះជាដើម មានអត្ថដូចពោលហើយនុ៎ះឯង ។ បទថា **អកិញ្ចនា** បានដល់ កន្ធទៅ ២ យាម ។ បទថា **យសិ្ឍានិ កាលំ មញ្ញេ** បានដល់ លោកចូរសម្គាល់កាល ដែលលោកនឹងទៅចុះ អធិប្បាយថា នេះជាវេលាទៅរបស់លោក លោកចូរទៅចុះ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ ទើបបញ្ជូនភិក្ខុទាំងនោះទៅ ធ្វើយថា ដើម្បីអនុគ្រោះ ។ អធិប្បាយថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ជូនទៅ ដោយសេចក្តីអនុគ្រោះ ២ យ៉ាង គឺក៏កាលភិក្ខុទាំងនោះ អង្គុយក្នុងទីនោះ ៣ យាម នៃរាត្រីកន្ធទៅ អាពាធគប្បីកើតឡើងក្នុងរាងកាយរបស់ពួកលោក និងសូម្បីភិក្ខុសង្ឆគួរនឹងបានឱកាសក្នុងការសឹង និងការគង់ដែលប្រាសចាកទីភ្ញ ។

បទថា **សុញ្ញាការំ** បានដល់ ឈ្មោះថា **សុញ្ញាគារ** ដោយចំពោះរមែងមិនមានក្នុងទីនោះ ។ បានឮមកថា គហបតីទាំងនោះ បានឱ្យគេយកសំពត់

១-វិនយបិដក ចុល្លវគ្គ លេខ ១០ ទំព័រ ៣២១ ដល់ ៣២២ ។

រាំងនៅ១ចាំងក្នុងទីមួយរបស់អាវសថាគារ:នោះនុ៎ះឯង ហើយឱ្យចាត់ចែងគ្រែដ៏
សមគួរ ក្រាលកម្រាលដ៏សមគួរក្នុងទីនោះ ចងពិតានដែលប្រដាប់ដោយផ្កាយ
មាស ប្រាក់ របស់ក្រអូប និងកម្រងផ្កាជាដើម ហើយលើកប្រទីបប្រេងក្រអូប
ទុកខាងលើ ដោយគិតថា ដូចម្តេចហ្ន៎ ព្រះសាស្តានឹងគប្បីស្តេចក្រោកពី
ធម្មាសន: ប្រាថ្នានឹងសម្រាកបន្តិច គប្បីផ្ទំក្នុងទីនេះ កាលបើដូច្នេះ ព្រះដ៏មាន-
ព្រះភាគនឹងទ្រង់ប្រើអាវសថាគារនេះរបស់ពួកយើង ដោយឥរិយាបថទាំង ៤
នឹងគប្បីប្រព្រឹត្តទៅដើម្បីប្រយោជន៍សុខរហូតអស់កាលយូរ ។ សូម្បីព្រះសាស្តា
ទ្រង់សំដៅដល់ប្រការនោះនុ៎ះឯង ទើបទ្រង់ឱ្យចាត់ចែងក្រាលសំពត់សង្ឆាដិ
ក្នុងទីនោះហើយ ទើបសម្រេចសីហសេយ្យា ។ ដែលលោកសំដៅពោលទុកថា
ព្រះអង្គយាងចូលទៅកាន់សុញ្ញាគារ ។ ក្នុងសុញ្ញាគារនោះ ចាប់ផ្តើមពីទីដែល
ព្រះសម្មាសម្ពុទ្ធលាងព្រះបាទរហូតដល់ដល់ធម្មាសន: ការស្តេចទៅក្នុងទីប្រមាណ
ប៉ុណ្ណោះ សម្រេចហើយ ស្តេចដល់ធម្មាសន: ហើយប្រថាប់ឈរបន្តិច នេះជា
ឥរិយាបថឈរក្នុងទីនោះ ព្រះអង្គប្រថាប់លើធម្មាសន: រហូតដល់អស់ពីរយាម
ឥរិយាបថគង់ក្នុងទីមានប្រមាណប៉ុណ្ណោះសម្រេច ហើយព្រះអង្គទ្រង់បញ្ជូន
ឧបាសក និងឧបាសិកាទាំងឡាយទៅ ហើយស្តេចចុះពីធម្មាសន:ទ្រង់សម្រេច
សីហសេយ្យាក្នុងទីដូចពោលហើយ ។ ទីនោះបានជាស្ថានទីដែលព្រះដ៏មាន-
ព្រះភាគទ្រង់ប្រើប្រាស់ហើយដោយឥរិយាបថទាំង ៤ ដោយប្រការដូច្នេះឯង ។

បទថា **សុនីធវស្សការ** បានដល់ ព្រាហ្មណ៍ ២ នាក់ គឺសុនីធ-ព្រាហ្មណ៍ និងវស្សការព្រាហ្មណ៍ ។ បទថា **មគធមហាមត្តា** បានដល់ មហាមាត្ររបស់ព្រះបាទមគធ: ឬមហាមាត្រក្នុងដែនមគធ: ។ ឈ្មោះថា **មហា-មាត្រ** ព្រោះប្រកបដោយហេតុត្រឹមតែថា មានឥស្សរយសយ៉ាងធំ ។ បទថា **ចាជលិកាមេ ឧករំ មាបេន្តិ** បានដល់ ឱ្យសាងនគរក្នុងភូមិប្រទេស គឺ បាដលិគ្រាម ។ បទថា **រញ្ញោ ឋានំ បដិពាហាយ** បានដល់ ដើម្បីការពារសេចក្តីចម្រើនរបស់ស្តេចលិច្ឆវី ។ បទថា **សហាស្សេ** បានដល់ បែងចែកជាពួកមួយ ពាន់ៗ ។ បទថា **វត្ថូនិ** បានដល់ កន្ទែងផ្ទៃផ្ទះ ។ បទថា **ចិត្តានិ មនន្តិ និវេសនានិ មាបេតុំ** សេចក្តីថា ចិត្តរបស់បុគ្គលដែលដឹងផ្ទៃដី រមែងបង្អោនទៅដើម្បីនឹងសាងព្រះរាជនិវេសន៍ និងទីនៅអាស្រ័យរបស់រាជអាមាត្រ ។ មានសេចក្តីដំណាលមកថា ពួកទាំងនោះដឹងផ្ទៃដីប្រមាណ ៣០ ហត្ថ ក្នុងខាងក្រោមផែនដី ដោយអានុភាពនៃសិល្ប:របស់ខ្លួនថា ក្នុងទីនេះនាគគ្រប់គ្រង ក្នុងទីនេះយក្ខគ្រប់គ្រង ក្នុងទីនេះភូតគ្រប់គ្រង ក្នុងទីនេះមានផ្ទាំងថ្ម ឬដង្គត់ឈើ ។ ក្នុងកាលនោះ ពួកគេពោលដល់សិល្ប:ហើយ ដូចជាប្រឹក្សានឹងពួកទេវតាទើបសាងឡើង ។

ម្យ៉ាងទៀត ពួកទេវតា សណ្ឋិតនៅក្នុងរាងកាយរបស់ពួកគេ ហើយបង្អោនចិត្តទៅដើម្បីសាងនិវេសន៍ក្នុងទីនោះៗ ។ ទេវតាទាំងនោះត្រឡប់បាត់

ទៅ ក្នុងខណៈដែលពួកគេចោះបង្ហោលត្រង់មុំទាំង ៤ ហើយចាប់ផ្ទៃដី ។ ពួកទេវតា អ្នកមានសទ្ធារបស់ត្រកូលដែលមានសទ្ធា ក៏រមែងធ្វើយ៉ាងនោះ ។ ទេវតាអ្នកមិនមានសទ្ធា របស់ត្រកូលដែលមិនមានសទ្ធា ក៏រមែងធ្វើយ៉ាងនោះ ។ ព្រោះហេតុអ្វី ព្រោះទេវតាអ្នកមានសទ្ធា រមែងគិតយ៉ាងនេះថា ពួកមនុស្ស សាងនិវេសន៍ ក្នុងទីនេះ នឹងនិមន្តកិក្ខុសង្ឆអង្គុយមុនហើយ ទើបពោលមង្គល កាលបើដូច្នេះ ពួកយើងក៏នឹងបានឃើញលោកអ្នកមានសីល ស្តាប់ធម្មកថា ស្តាប់ការដោះស្រាយបញ្ហា និងបានស្តាប់អនុមោទនា ម្យ៉ាងទៀត ពួកមនុស្ស ថ្វាយទានហើយ នឹងឱ្យចំណែកបុណ្យដល់ពួកយើង ។ ចំណែកទេវតាអ្នកមិន មានសទ្ធា រមែងមានការគិតយ៉ាងនេះថា យើងនឹងបានឃើញការបដិបត្តិរបស់ កិក្ខុទាំងនោះ និងបានស្តាប់នូវកថារបស់កិក្ខុទាំងឡាយនោះ តាមសមគួរដល់ សេចក្តីត្រូវការរបស់ខ្លួន ពួកមនុស្សក៏ធ្វើយ៉ាងនោះដូចគ្នា ។

បទថា **តាវតឹសេហិ** សេចក្តីថា ឧទាហរណ៍ថា ព្រោះអាស្រ័យបុគ្គល ជាបណ្ឌិតម្នាក់ក្នុងត្រកូលមួយ កិក្ខុអ្នកជាពហុស្សូត ១ អង្គ ក្នុងវិហារមួយ សំឡេង រមែងខ្ចរខ្ចាយទៅថា ពួកមនុស្សក្នុងត្រកូលឯណោះជាបណ្ឌិត ពួកកិក្ខុក្នុងវិហារ ឯណោះជាពហុស្សូត យ៉ាងណា ព្រោះអាស្រ័យស្តេចសក្កទេវរាជ និងវិស្សកម្ម-ទេវបុត្រ កិត្តិស័ព្ទទើបខ្ចរខ្ចាយទៅថា ពួកទេវតាជាន់តាវត្តឹង្សជាបណ្ឌិត ដូច្នោះ ដែរ ។ ព្រោះហេតុនោះ លោកទើបពោលថា **តាវតឹសេហិ** ដូច្នេះជាដើម ។ ដោយពាក្យថា **សេយ្យថាបិ** ជាដើម ព្រះអង្គទ្រង់សម្តែងថា សុនីធព្រាហ្មណ៍

និងវស្សការព្រាហ្មណ៍ នាំគ្នាសាងនគរ ដូចប្រឹក្សានឹងពួកទេវតាជាន់តាវត្តិង្ស ។

បទថា **យាវតា អានន្ទ អរិយំ អាយតនំ** សេចក្តីថា ឈ្មោះថា ស្ថានទីជាទីប្រជុំនៃពួកមនុស្សអ្នកជាអរិយៈ មានប្រមាណប៉ុណ្ណាមាននៅ ។ បទថា **យាវតា វណិជ្ជប្បថো** បានដល់ ឈ្មោះថា ស្ថានទីទិញ និងលក់ដោយវត្ថុត្រូវពួកឈ្មួញនាំមកមានប្រមាណប៉ុណ្ណាមាននៅ ឬស្ថានទីដែលនៅរបស់ពួកឈ្មួញមានប្រមាណប៉ុណ្ណាមាននៅ ។ បទថា **ឥទំ អក្ខនតរំ** បានដល់ នគរនេះជានគរដ៏ប្រសើរ ជានគរប្រធាន ជានគរប្រមុខនៃជនទាំងឡាយអ្នកជាអរិយៈ និងពួកឈ្មួញទាំងនោះ ។ បទថា **ឫជវកេឧនំ** បានដល់ ជាទីដោះដូរវត្ថុ អធិប្បាយថា ជាទីដោះដូរវត្ថុទាំងឡាយ ។ អធិប្បាយថា ក៏ក្នុងទីនេះឯង ពួកគេនឹងបានសូម្បីវត្ថុដែលនៅមិនបានក្នុងជម្ពូទ្វីបទាំងអស់ សូម្បីនឹងមិនទៅ លក់ក្នុងទីដទៃ ក៏ទៅលក់ក្នុងទីនោះនុ៎ះឯង ព្រោះដូច្នោះ ពួកគេនឹងបែងចែកបង្វិចក្នុងទីនេះឯង ។ ក៏ស្ថានទី ៥០០.០០០ ដែលបានប្រាកដឡើង ដើម្បីសេចក្តីចម្រើន ក្នុងទីនោះ រាល់ៗថ្ងៃ យ៉ាងនេះ គឺត្រង់ទ្វារទាំង ៤ ផ្នែកខាងមាន ២០០.០០០ ត្រង់សកា ១០០.០០០ ត្រង់សការៈទាំងនោះ លោកសម្តែងថា ជាសេចក្តីចម្រើន ។

ភ-ស័ព្ទ ក្នុងបទថា **អក្ខិតោ ភ** ជាដើម ជាសមុច្ចយត្ថៈ ។ អធិប្បាយថា នឹងវិនាសទៅដោយភ្លើង ដោយទឹក និងដោយការបែកមិត្ត ។ ក៏ក្រុងបាដលិគ្រាមនោះ ចំណែកមួយនឹងវិនាសដោយភ្លើង សូម្បីពួកអ្នកក៏មិនអាចនឹងរលត់ភ្លើង

បាន ។ មួយចំណែកទៀត ទន្ទេគង្គានាំទៅ ។ មួយចំណែកទៀត នឹងវិនាសទៅ ដោយការបែងចែកបក្ខពួកគ្នា និងគ្នារបស់ពួកមនុស្ស អ្នកនិយាយដល់រឿង ដែលអ្នកនេះមិនបានពោលដល់អ្នកឯណោះ (និង) និយាយដល់រឿងដែលអ្នក ឯណោះមិនបានពោលដល់អ្នកនេះ បែងចែកគ្នាទៅដោយបិសុណាវាចា (វាចា ស៊ិកសៀត) ។ ព្រះដ៏មានព្រះភាគ គ្រាត្រាស់យ៉ាងនេះហើយ ទើបស្តេចទៅកាន់ ត្រើយទន្ទេគង្គា ជម្រះព្រះកក្ត្រសម្រេចហើយ ប្រថាប់គង់រង់ចាំវេលាកិក្ខាចារ ។

ចំណែកសុនីធព្រាហ្មណ៍ និងវស្សការព្រាហ្មណ៍ នាំគ្នាគិតថា ព្រះរាជ របស់ពួកយើងជាឧបដ្ឋាករបស់ព្រះសមណគោតម ព្រះអង្គត្រាស់សួរពួកយើង អ្នកចូលទៅគាល់ថា បានឮថា ព្រះសាស្តាបានយាងទៅកាន់បាដលិគ្រាម អ្នក ទាំងឡាយបានចូលទៅគាល់ព្រះអង្គឬនៅ ឬថាមិនទាន់បានចូលទៅគាល់ទេ កាលពួកយើងធ្វើយថា បានចូលទៅគាល់ហើយ ក៏នឹងត្រាស់សួរថា ពួកលោក បាននិមន្តព្រះដ៏មានព្រះភាគហើយ ឬក៏មិនបាននិមន្តទេ និងកាលពួកយើង ធ្វើយថា មិនបាននិមន្ត ដូច្នេះ ក៏នឹងលើកទោសគ្របសង្កត់ពួកយើង សូម្បីពួក យើងនឹងសាងនគរនេះ ក្នុងស្ថានទីដែលមិនធ្លាប់សាងក៏ពិត ទោះជាយ៉ាងនោះ ពួកសត្វកាលកណ្ណៀ ក៏នឹងកៀសខ្ជូនទៅក្នុងទីដែលព្រះសមណគោតមស្តេចទៅ ដល់ហើយ។ ពួកយើងនឹងឱ្យព្រះសមណគោតមនោះ ត្រាស់សម្តែងនូវមង្គល ដល់នគរ ដូច្នេះ ទើបនាំគ្នាចូលទៅគាល់ព្រះសាស្តាហើយទូលនិមន្ត ។ ព្រោះ ហេតុនោះ លោកទើបពោលថា **អថ ខោ សុនីធវស្សការា** *ដូច្នេះ ជាដើម ។*

បទថា **បុព្ពណ្ហសមយំ** ប្រែថា ក្នុងវេលាព្រឹក ។ បទថា **និវាសេត្វា** បានដល់ ទ្រង់ស្លៀកស្បង់ ហើយក្រវាត់កាយពន្ធចង្កេះតាមទំនងនៃការយាងទៅកាន់ស្រុក ។ បទថា **បត្តចីវរមាទាយ** បានដល់ ទ្រង់ដណ្តប់ចីវរ ព្រះហស្តកាន់បាត្រ ។

បទថា **សីលវន្តេ** បានដល់ អញ្ជើញអ្នកមានសីលឱ្យបរិភោគ ក្នុងប្រទេសនោះ គឺក្នុងទីនៅរបស់ខ្លួន ។ បទថា **សញ្ញតេ** បានដល់ សង្រួមដោយកាយ វាចា និងចិត្ត ។ បទថា **តាសំ ឧក្ខិណមាទិសេ** សេចក្តីថា គប្បីឧទ្ទិសបច្ច័យ ៤ ដែលថ្វាយដល់សង្ឆ គឺគប្បីឱ្យចំណែកបុណ្យដល់ទេវតា អ្នកស្ថិតនៅក្នុងផ្ទះទាំងនោះ ។ បទថា **ឫជិ ឫជយន្តិ** សេចក្តីថា ធ្វើរក្សាឱ្យការចាត់ចែងដោយល្អ គឺធ្វើការរក្សាដោយល្អ ដោយគិតថា មនុស្សទាំងនេះមិនបានជាញាតិរបស់ពួកយើង សូម្បីយ៉ាងនេះ ក៏ពួកជនទាំងនោះបានឱ្យចំណែកបុណ្យដល់ពួកយើង ។ បទថា **មានិតា មានយន្តិ** សេចក្តីថា ទេវតាអ្នកដែលគេរាប់អាន ដោយការធ្វើពលីកម្មតាមកាលដែលគួរ រមែងរាប់អាន គឺរមែងកម្ចាត់អន្តរាយដែលកើតឡើង ដោយគិតថា មនុស្សទាំងនេះ សូម្បីមិនជាញាតិរបស់ពួកយើងសោះ ក៏នៅធ្វើពលីកម្មដល់ពួកយើងអស់រយៈ ៤ ខែ ៥ ខែ និង ៦ ខែ ។ បទថា **តតោ ឆ** សេចក្តីថា បន្ទាប់អំពីនោះរមែងអនុគ្រោះបុរស អ្នកមានជាតិជាបណ្ឌិតនោះ ។ បទថា **ឱរសំ** បានដល់ ឱ្យជំធាត់ទុកត្រង់ដើមទ្រូង

ដូចមាតាអនុគ្រោះបុត្រអ្នកកើតអំពីទ្រូង ។ អធិប្បាយថា រមែងអនុគ្រោះដោយព្យាយាម ដើម្បីកម្ចាត់អន្តរាយដែលកើតឡើងនុ៎ះឯង ។ បទថា **ភទ្រានិ បស្សតិ** បានដល់ រមែងឃើញថា ល្អ ។

បទថា **អនុមោទិត្វា** សេចក្តីថា ទ្រង់សម្តែងធម្មកថាដល់មហាអាមាត្រឈ្មោះ សុនីធៈ និងវស្សការៈ ដោយអនុមោទនាចំណែកបុណ្យដែលពួកគេនាំគ្នាខ្វល់ខ្វាយក្នុងកាលនោះ ។ ចំណែកមហាអាមាត្រឈ្មោះ សុនីធៈ និងវស្សការៈ បានស្តាប់ព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ គួរឧទ្ទិសទក្ខិណាដល់ទេវតាអ្នកស្ថិតនៅក្នុងទីនោះៗ ទើបបានឱ្យចំណែកបុណ្យដល់ទេវតាទាំងនោះ ។ បទថា **តំ គោតមទ្វារំ នាម អហោសិ** សេចក្តីថា ទ្វាររបស់ព្រះនគរនោះដែលបាននាមថា **គោតមទ្វារ** ព្រោះជាហេតុជាទីយាងចេញរបស់ព្រះដ៏មាន-ព្រះភាគ ម្យ៉ាងទៀត មិនបានឈ្មោះថា **គោតមតិដ្ឋៈ** ព្រោះមិនបានធ្លាក់ចុះកាន់កំពង់ដើម្បីឆ្លងទន្លេគង្គា ។ បទថា **បូរា** ប្រែថា ពេញ ។ បទថា **សមតិត្តិកា** បានដល់ ពេញ គឺប្រៀបដោយទឹក ស្មើច្រាំងស្ទឹង ។ បទថា **កាកបេយ្យា** បានដល់ មានទឹកដែលក្អែកទំត្រង់ច្រាំងអាចផឹកបាន ។ ដោយបទទាំងពីរ លោកសម្តែងចំពោះទឹកដែលពេញប្រៀបទាំងសងខាង ។ បទថា **ឧឡុម្បំ** បានដល់ ក្បូនដែលគេយកឈើផែហើយ-តស្មៀតធ្វើទុកដើម្បីឆ្លងត្រើយ ។ បទថា **កុល្លំ** បានដល់ ក្បូនដែលគេយកវល្លិ៍ចងឫស្សី និងដើមបបុសធ្វើទុក ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួង

ដល់សេចក្តីដែលមហាជន មិនអាចនឹងធ្វង ។ សូម្បីតែទឹកក្នុងទន្ទេគង្គាប៉ុណ្ណោះ តែព្រះអង្គ និងកិក្ខុសង្ឆធ្វងអន្ទង់ទឹក គឺសង្ឆារ ទាំងជម្រៅ ទាំងទទឹង ក្រៃលែងណាស់បានហើយ ទើបទ្រង់បន្ទឺឧទានដែលសម្តែងដល់សេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **អណ្ណវំ** នេះ ជាឈ្មោះរបស់ទឹកដែលជ្រៅ និងទទឹងប្រមាណ ១ យោជន៍ ដោយកំណត់យ៉ាងខ្ពី ។ បទថា **សរំ** លោកប្រាជ្ញដល់ទឹកក្នុងទីនេះ ព្រោះហូរទៅ ។ លោកពោលពាក្យ អធិប្បាយទុកថា ជនទាំងឡាយណាធ្វងទឹក គឺសង្ឆារ និងទន្ទេ គឺតណ្ហាទាំងជម្រៅ ទាំងទទឹង ជនទាំងឡាយនោះសាងស្ពាន គឺអរិយមគ្ត មិនប៉ះត្រូវ គឺមិនចាប់ត្រូវកក់ គឺទីកន្ទុកដែលពេញប្រៀបដោយទឹក ។ ចំណែកជននេះប្រាជ្ញានឹងធ្វងទឹកមានប្រមាណតិចនេះ ទើបចងក្ជួន គឺដល់សេចក្តីលំបាកក្រៃលែងដើម្បីនឹងចងក្ជួន ។ បទថា **តិណ្ណា មេធាវិនោ ជនា** សេចក្តីថា ព្រះពុទ្ធ និងពុទ្ធសាវក ឈ្មោះថា អ្នកមានមេធា[1] ព្រោះប្រកបដោយមេធាពោលគឺ អរិយមគ្តញ្ញាណ រមែងវៀរ គឺធ្វងបានដោយក្ជួន ហើយស្ថិតនៅលើឆ្នេរត្រើយខាងនាយ ។

ឆដ្ឋម សុត្តវណ្ណា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៦

១-មេធា សំ. ជា. (ន.) គំនិត, ប្រាជ្ញា (គំនិត ឬប្រាជ្ញាដែលអាចទម្លុះទម្លាយដំណើរអ្វីនីមួយៗ) ។

៧. ទ្វិធាបថសុត្តវណ្ណនា

អដ្ឋកថាទ្វិធាបថសូត្រ ទី ៧

ទ្វីធាបថសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **អទ្ធានមគ្គបដិបន្នោ** *បានដល់ ជាអ្នកធ្វើដំណើរវែង គឺផ្លូវឆ្ងាយ ។ បទថា* **ជាតសមាលេន** *បានដល់ ព្រះថេរៈមានឈ្មោះយ៉ាងនោះ ។ បទថា* **បច្ឆាសមណេន** *បានដល់ ក្នុងកាលនោះ ព្រះថេរៈអង្គនេះ ជាឧបដ្ឋាករបស់ព្រះដ៏មានព្រះភាគ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់មានពុទ្ធដំណើរ ដោយមានព្រះនាគសមាលៈជាបច្ឆាសមណៈ ។ មែនពិត ក្នុងបឋមពោធិកាល ព្រះដ៏មានព្រះភាគ មិនមានភិក្ខុជាឧបដ្ឋាន អស់ ២០ ឆ្នាំ ។ បន្ទាប់ពីនោះ ដរាបដល់បរិនិព្វាន ព្រះអានន្ទដ៏មានអាយុ បានជាឧបដ្ឋាក ដូចស្រមោលអន្ទោលតាមប្រាណ អស់ ២៥ ឆ្នាំ ។ តែកាលក្នុងនេះ ព្រះអង្គមិនមានឧបដ្ឋាកជាប្រចាំឡើយ ។ ព្រោះហេតុនោះ លោកទើបពោលថា* **អាយស្មតា ជាតសមាលេន បច្ឆាសមណេន** *ដូច្នេះជាដើម ។ បទថា* **ទ្វិធាបថំ** *បានដល់ ផ្លូវបែកជា ២ ។ អាចារ្យពួកខ្លះពោលថា* **ទ្វេធាបថំ** *ដូច្នេះក៏មាន ។ ព្រះនាគសមាលដ៏មានអាយុ ព្រោះធ្លាប់ត្រាច់មកទៅនូវផ្លូវនេះមកពីមុន និងព្រោះសម្គាល់ថា ផ្លូវនោះជាផ្លូវត្រង់ ទើបក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន នេះផ្លូវ ។*

ក៏ក្នុងកាលនោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ផ្លូវនោះមានអន្តរាយ ទើបមានប្រាជ្ញានឹងស្តេចយាងទៅផ្លូវដទៃពីផ្លូវនោះ ទើបត្រាស់ថា ម្នាលនាគ-សមាល: នេះផ្លូវ ។ និងកាលព្រះអង្គត្រាស់ថា ផ្លូវនេះមានអន្តរាយ ទើបមិនជឿ ហើយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ផ្លូវនោះមិនមានអន្តរាយទេ ការដែលព្រះនាគសមាល: មិនជឿហើយទូលយ៉ាងនោះ នឹងគប្បីប្រព្រឹត្តទៅ ដើម្បីមិនមែនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរ ព្រោះហេតុនោះ ព្រះអង្គទើបមិនត្រាស់ថា មានអន្តរាយ ។ ព្រះនាគសមាល:ដ៏មានអាយុ ក្រាបទូលចំពោះព្រះដ៏មានព្រះភាគអស់ ៣ លើកថា នេះផ្លូវ សូមព្រះដ៏មានព្រះភាគយាងទៅផ្លូវនេះចុះ ក្នុងលើកទី ៤ ទើបគិតថា ព្រះដ៏មានព្រះភាគ មិនប្រាជ្ញានឹងស្តេចយាងទៅផ្លូវនេះ និងផ្លូវនេះឯង ជាផ្លូវត្រង់ ណ្ហើយចុះយើងនឹងថ្វាយបាត្រ និងចីវរចំពោះព្រះដ៏មានព្រះភាគ ហើយដើរទៅផ្លូវនេះ កាលមិនអាចនឹងថ្វាយបាត្រ និងចីវរដល់ព្រះហស្តរបស់ព្រះសាស្តា ទើបដាក់ទុកត្រង់ផែនដី នូវកម្មរបស់ខ្លួនដែលជាផ្លូវនៃទុក្ខប្រាកដឡើងជាស់ត្រឿន នៅតែមិនអើពើ នឹងព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគឡើយ ទើបជៀសចេញទៅ ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រានោះឯង ព្រះនាគសមាល:ដ៏មានអាយុ ដាក់បាត្រ និងចីវររបស់ព្រះដ៏មានព្រះភាគលើផែនដី ក្នុងផ្លូវនោះឯង ហើយជៀសទៅ ។

បណ្ដាបទទាំងនោះ បទថា **ភគវតោ បត្តចីវរំ** *បានដល់ បាត្រ និងចីវរ*
របស់ព្រះដ៏មានព្រះភាគ ដែលនៅក្នុងដៃរបស់ខ្លួន ។ បទថា **តត្ថេវ** *សេចក្ដីថា*
ជាក់ទុកត្រង់ផែនដី គឺលើផែនដីត្រង់ផ្លូវនោះឯង ហើយជៀសចេញទៅ ។
អធិប្បាយថា បពិត្រព្រះដ៏មានព្រះភាគ នេះបាត្រ និងចីវររបស់ព្រះអង្គ បើ
ព្រះអង្គប្រាថ្នា ក៏ចូរទទួលទៅចុះ បើព្រះអង្គប្រាថ្នានឹងទៅតាមផ្លូវ ដែលព្រះអង្គ
ប្រាថ្នា ក៏គប្បីយាងទៅចុះ ។ ចំណែកព្រះដ៏មានព្រះភាគទ្រង់កាន់យកបាត្រ និង
ចីវររបស់ព្រះអង្គដោយព្រះអង្គឯង ស្ដេចយាងទៅកាន់ផ្លូវ ដែលព្រះអង្គប្រាថ្នា ។

បទថា **អន្ដរាមគ្គេ ចោរំ ឌិក្ខូមិត្វា** *សេចក្ដីថា បានឮថា ក្នុងកាលនោះ*
បុរស ៥០០ នាក់ ជាអ្នកលេង មានបាតដៃប្រលាក់ដោយឈាម ខុសនឹងព្រះរាជ
ចូលទៅកាន់ព្រៃ ចិញ្ចឹមជីវិតដោយចោរកម្ម គិតថា ពួកយើងនឹងកាត់ផ្លូវចម្រើន
របស់ព្រះរាជា ដោយភាពជាសត្រូវចំពោះគ្នា ដូច្នេះហើយ ទើបពួននៅក្នុងព្រៃ
ជិតផ្លូវ ។ ពួកចោរទាំងនោះ ឃើញព្រះថេរៈកំពុងធ្វើដំណើរទៅ ទើបគិតថា
សមណៈនេះមកផ្លូវនេះ ប្រើផ្លូវដែលមិនសមគួរនឹងប្រើ មិនដឹងថាជារបស់យើង
ណ្ដើយចុះយើងនឹងញ៉ាំងលោកឱ្យដឹង ដូច្នេះហើយប្រញាប់ស្ទុះចេញពីព្រៃ
ស្ទូវ ហើយច្រានព្រះថេរៈឱ្យដួលលើផ្ទៃដីដោយរហ័ស ហើយបោកបាត្រដី
ព្រះថេរៈ ហែកចីវរជាកំណាត់តូចធំ ព្រោះយល់ថា ជាបព្វជិត ទើបបណ្ដេញ

ទៅដោយនិយាយថា ពួកយើងនឹងមិនសម្ងាប់លោក តាំងពីនេះតទៅ លោកចូរដឹងថា ផ្លូវនេះមានអន្តរាយ ។ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ អាយស្មតោ ។បេ។ វិច្ឆាលេសុំ** ដូច្នេះជាដើម ។

ចំណែកព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា ព្រះនាគសមាល: នេះទៅផ្លូវនោះ ត្រូវចោរបៀតបៀន ស្វែងរកតថាគត នឹងមកក្នុងឥឡូវនេះ ដូច្នេះហើយ ព្រះអង្គយាងទៅបន្តិច ធ្វើងចុះពីផ្លូវប្រថាប់គង់ទៀបគល់ឈើមួយកន្លែង ។ ចំណែកព្រះនាគសមាល:ដ៏មានអាយុ ត្រឡប់មកកាន់យកផ្លូវដែលព្រះសាស្តាស្តេចយាងទៅនុ៎ះឯង កំពុងដើរទៅក៏ជួបព្រះដ៏មានព្រះភាគត្រង់គល់ឈើនោះ ទើបចូលទៅគាល់ហើយថ្វាយបង្គំ ក្រាបទូលរឿងនោះចំពោះព្រះសាស្តា ។ ព្រោះហេតុនោះ លោកទើបពោលថា **អថខោ អាយស្មា ជាតសមាលោ ។បេ។ សង្ឆ្យាជិញ្ចិ វិច្ឆាលសុំ** ដូច្នេះជាដើម ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះអង្គជ្រាបថា ព្រះនាគសមាល: ដ៏មានអាយុ មិនអើពើនឹងពាក្យរបស់ព្រះអង្គឡើយ ដើរទៅកាន់ផ្លូវប្រកបដោយភ័យ និងទ្រង់ជ្រាបថា ព្រះអង្គយាងទៅកាន់ផ្លូវមិនមានភ័យនេះ ហើយទើបទ្រង់បន្ទឺឧទានេះ ដែលសម្តែងសេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា **សន្ធឺ ចរំ** ប្រែថា ត្រាច់ទៅរួមគ្នា ។ បទថា

ឯកតោ *វសំ* នេះ ជាវេវចន:របស់បទថា **សន្ធឺ ចរំ** នោះនុ៎ះឯង អធិប្បាយថា នៅរួមគ្នា ។ បទថា **មិសេ្ឆ អញ្ញ**ជនេ**ន** **ឯ**ត្ថ សេចក្តីថា ឈ្មោះថា ដល់ត្រើយនៃវេទ ព្រោះដល់ គឺសម្រេចដោយអរិយមគ្គញ្ញាណ គឺសច្ច: ៤ ពោលគឺ វេទ ព្រោះអត្ថថា ដែលបុគ្គលគប្បីដឹង ឬព្រោះដល់ត្រើយនៃវេទ គឺញ្ញេយ្យធម៌ទាំងអស់ ។ ឈ្មោះថា អ្នកមិនដឹង ព្រោះវត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍របស់ខ្លួន ។ អធិប្បាយថា អ្នកមិនដឹង គឺអ្នកលង់ខ្ចៅ ។ ជាអ្នកច្របូក-ច្របល់លាយឡំដោយអ្នកមិនដឹងនោះ គឺច្របូកច្របល់លាយឡំដោយហេតុត្រឹមតែត្រាច់ទៅរួមគ្នា ។ បទថា **វិ**ជ្ជា **ប**ជ**ហ**ាតិ **ចាបកំ** សេចក្តីថា អ្នកដឹងគឺជ្រាបដោយការ:ដែលដល់វេទនោះ រមែងលះវត្ថុអាក្រក់ គឺវត្ថុមិនចម្រើនបានដល់ វត្ថុដែលនាំទុក្ខមកឱ្យខ្លួន ឬលះអ្នកអាក្រក់ គឺវត្ថុមិនចម្រើន បានដល់ វត្ថុដែលនាំទុក្ខមកឱ្យខ្លួន ឬលះអ្នកអាក្រក់ គឺអ្នកមិនល្អ ប្រៀបផ្ទឹមដូចអ្វី? ប្រៀបផ្ទឹមដូចសត្វក្រៀលផឹកតែទឹកដោះ រៀរចាកទឹក អធិប្បាយថា សត្វក្រៀលកាលគេនាំទឹកដោះ ដែលលាយដោយទឹកចូលទៅ ឈ្មោះថា ផឹកតែទឹកដោះ ព្រោះរៀរចាកទឹក ផឹកតែទឹកដោះប៉ុណ្ណោះ រមែងលះ គឺរៀរចាកទឹក ពោលគឺទន្ទេដែលហូរទៅកាន់ទីកន្ទុកយ៉ាងណា បានឮថា បណ្ឌិតក៏ដូច្នោះ សូម្បីនៅរួមនឹងអ្នកខ្សោយបញ្ញា ក្នុងឥរិយាបថ មានការឈរ និងការអង្គុយជាដើម ក៏លះ

បុគ្គលដែលខ្ជាយបញ្ញានោះ ដោយអើពើ គឺសូម្បីក្នុងកាលវេលាខ្លះ ក៏មិនព្រមលាយជាមួយនឹងពួកគេ ។

សត្តមសុត្តវណ្ណា និដ្ឋិតា

ចប់អដ្ឋកថាសូត្រទី ៧

៨.វិសាខាសុត្តវណ្ណនា

អដ្ឋកថាវិសាខាសូត្រទី ៨

អដ្ឋកថាវិសាខាសូត្រទី ៨ *មានវិនិច្ឆ័យដូចតទៅនេះ*

បទថា **វិសាខាយ មិការមាតុយា ធីតា កាលកតា ហោតិ** *បានដល់ ក្មេងស្រីជាធីតារបស់បុត្រនៃមហាឧបាសិកា ឈ្មោះថា វិសាខា បានស្លាប់ ។ បានឮមកថា ក្មេងស្រីនោះ បរិបូរដោយវត្តប្រតិបត្តិ ជ្រះថ្លាយ៉ាងក្រៃលែង ក្នុងព្រះសាសនា ជាអ្នកមិនប្រមាទ បានធ្វើការខ្ជាប់ខ្ជួយ ដែលខ្លួននឹងគប្បីធ្វើ ដល់ភិក្ខុ និងភិក្ខុនីទាំងឡាយ ដែលនិមន្តចូលទៅកាន់ផ្ទះរបស់ឧបាសិកា ទាំងវេលាមុនអាហារ និងក្រោយអាហារ ។ បដិបត្តិតាមចិត្តរបស់ជីតាខ្លួន ។ ព្រោះហេតុនោះ មហាឧបាសិកា ឈ្មោះថា វិសាខា កាលចេញពីផ្ទះទៅខាងក្រៅ បានប្រគល់នាទីទាំងអស់ដល់ក្មេងស្រីនោះនុ៎ះឯង ហើយទើបទៅ និងក្មេងស្រីក៏មានរូបរាងគួរសរសើរ គួរជ្រះថ្លា ព្រោះដូច្នោះ ក្មេងស្រីនោះ ទើបជាទីស្រឡាញ់ ជាទីពេញចិត្តដោយពិសេសរបស់នាងវិសាខា មហាឧបាសិកា ។ ក្មេងស្រីត្រូវរោគគ្របសង្កត់ទើបធ្វើកាលកិរិយា ។ ព្រោះហេតុនោះ លោកទើបពោលថា ក៏សម័យនោះឯង ចៅស្រីរបស់នាងវិសាខាមិការមាតា ជាទីស្រឡាញ់ ជាទីពេញចិត្ត ធ្វើកាលកិរិយា ។ លំដាប់នោះ មហាឧបាសិកា កាលមិនអាចនឹងអត់ធ្មត់នឹងសេចក្តីសោក ព្រោះការស្លាប់របស់ចៅស្រីបាន ទើបជាទុក្ខ ឱ្យគេយកសាក-សពទៅរក្សាទុក ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ ដោយគិតថា ដូចម្តេចហ្ន៎ ក្នុងវេលាដែលយើងទៅគាល់ព្រះសាស្តា នឹងគប្បីបានរសាយចិត្ត ។ ព្រោះហេតុនោះ លោកទើបពោលថា* **អថ ខោ វិសាខាមិការមាតា** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **ឌិវា ឌិវស្ស** *ប្រែថា ក្នុងវេលាថ្ងៃ អធិប្បាយថា ក្នុងវេលាថ្ងៃត្រង់ ។*

ព្រះដ៏មានព្រះភាគ កាលទ្រង់ជ្រាបថា នាងវិសាខាត្រេកអរក្នុងវដ្ដៈ ដើម្បីនឹងទ្រង់ធ្វើសេចក្ដីសោកសៅរបស់នាងឱ្យស្រាលចុះខ្លះ ដោយឧបាយ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **ឥច្ឆេយ្យាសិ ត្វំ វិសាខេ** ។ បណ្ដាបទទាំងនោះ បទថា **យាវតិកា** ប្រែថា មានប្រមាណប៉ុនណា ។ បានឮមកថា ក្នុងកាលនោះ ជន ៧ កោដិ អាស្រ័យនៅក្នុងក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលវិសាខា អ្នកក្រុងសាវត្ថី ដែលស្លាប់ទៅរាល់ៗ ថ្ងៃ មួយថ្ងៃប៉ុនណា ។ នាងវិសាខាទើបទូលតបថា មួយថ្ងៃ ១០ នាក់ខ្លះ ព្រះអង្គ ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **តីណិ** ស្មើនឹងពាក្យថា **តយោ** ប្រែថា ៣ នាក់ ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះឯង ។ បទថា **អវិត្ដា** ប្រែថា មិនសូន្យ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគកាលនឹងប្រកាសសេចក្ដីប្រាថ្នារបស់ព្រះអង្គ ទើបត្រាស់ថា នាងជាអ្នកមិនមានសំពត់សើម មិនមានសក់សើម ក្នុងគ្រាខ្លះឬ ។ ព្រះអង្គទ្រង់សម្ដែងថា កាលបើដូច្នោះ កាលនាងវិសាខា ត្រូវសេចក្ដីសោកសៅគ្របសង្កត់រហូតអស់កាល នាងគប្បីមានសំពត់សើម មានសក់សើម ដោយការចុះទឹក ដោយជាប់ស្ងួតនឹងវត្ថុមិនជាមង្គលរបស់ចៅជាដើម ដែលស្លាប់ទៅមិនមែនឬ ។

ឧបាសិកាបានស្ដាប់ដូច្នោះហើយ ទើបកើតសេចក្ដីសង្វេគ បដិសេធថា បពិត្រព្រះអង្គដ៏ចម្រើន មិនជាយ៉ាងនោះ ដូច្នេះហើយ ទើបក្រាបទូលថា ចិត្ដរបស់ខ្ញុំនត្រឡប់ពីសេចក្ដីក្ដៅក្រហាយ ក្នុងវត្ថុជាទីស្រឡាញ់ ចំពោះព្រះសាស្ដា

ទើបក្រាបទូលថា ល្មមហើយព្រះអង្គ ដោយពួកបុត្រ និងកូនដែលមានច្រើនដល់ត្រឹមនោះសម្រាប់ខ្ញុំព្រះអង្គម្ចាស់ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់សម្តែងធម៌ដល់នាងថា ឈ្មោះថា ទុក្ខនេះ មានវត្ថុគួរស្រឡាញ់ជាហេតុ វត្ថុគួរស្រឡាញ់មានប្រមាណត្រឹមណា ទុក្ខក៏មានប្រមាណត្រឹមនោះដែរ ព្រោះដូច្នោះ អ្នកស្រឡាញ់សុខដែលប្រាសចាកទុក្ខ គប្បីឱ្យចិត្តកើតសេចក្តីសង្វេគ នឹងវត្ថុជាទីស្រឡាញ់ដោយប្រការទាំងពួង ទើបត្រាស់ពាក្យមានអាទិ៍ថា ម្នាលនាងវិសាខា បុគ្គលពួកណា មានវត្ថុជាទីស្រឡាញ់ ១០០ បុគ្គលទាំងនោះក៏មានទុក្ខ ១០០ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សតំ បិយានិ** បានដល់ វត្ថុដែលជាទីស្រឡាញ់ ១០០ ។ អាចារ្យពួកខ្លះពោលថា **សតំ បិយំ** ដូច្នេះក៏មាន ។ ក៏ក្នុងពាក្យនេះ រាប់តាំងពី ១ ដរាបដល់ ១០ ឈ្មោះថា មានការរាប់ជាប្រធានដូច្នោះ បាលីទើបមកដោយន័យមានជាអាទិ៍ថា អ្នកណាមានវត្ថុដែលជាទីស្រឡាញ់ ១០ អ្នកនោះមានទុក្ខ ១០ ។ តែអាចារ្យពួកខ្លះពោលដោយន័យមានជាអាទិ៍ថា អ្នកណា មានវត្ថុជាទីស្រឡាញ់ ១០ អ្នកនោះក៏មានទុក្ខ ១០ ។ ពាក្យនោះមិនត្រឹមត្រូវ ព្រោះហេតុដែលកាលរាប់តាំងតែ ២០ រហូតដល់ ១០០ ឈ្មោះថា មានការរាប់ជាប្រធានដូចគ្នា ។ ព្រោះដូច្នោះ ព្រោះកាន់យកចំពោះវត្ថុ ជាទីស្រឡាញ់ មានការរាប់ជាប្រធាន សូម្បីក្នុងសេចក្តីនោះ បាលីទើបមកដោយន័យមានអាទិ៍ថា **យេសំ ខោ វិសាខេ សតំ បិយានិ សតំ តេសំ ទុក្ខានិ** ដូច្នេះ ។

បាលីរបស់អាចារ្យទាំងពួងថា ជនពួកណា មានវត្ថុដែលជាទីស្រឡាញ់ មួយ ជនទាំងនោះក៏មានទុក្ខមួយ ដូច្នេះ តែបាលីថា **ទុក្ខស្ស** ដូច្នេះ មិនមាន ។

ក៏ក្នុងចំណែកនេះ ទេសនារបស់ព្រះដ៏មានព្រះភាគ មានរសតែមួយ ព្រោះដូច្នោះ គប្បីជ្រាបបាលី មានន័យតាមដែលពោលមកនោះឯង ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្តីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួងនូវអត្ថនេះថា ទុក្ខផ្លូវចិត្ត និងទុក្ខផ្លូវកាយ មានសោក: និងបរិទេវ:ជាដើម មានវត្ថុជាទីស្រឡាញ់ជាហេតុ រមែងប្រាកដក្នុងកាលមានវត្ថុជាទីស្រឡាញ់ រមែងមិនប្រាកដក្នុងកាលដែលមិនមានវត្ថុជាទីស្រឡាញ់ ទើបទ្រង់បន្ទឹឧទាននេះ ដែលសម្តែងសេចក្តីនោះ ។

ពាក្យនៃឧទាននោះ មានអធិប្បាយដូចតទៅនេះ

ធម៌ពួកណាមួយ មានលក្ខណ:ធ្វើចិត្តរបស់ជនពាល អ្នកពាល់ត្រូវសេចក្តីវិនាសនៃញាតិ ភោគ: រោគ សីល និងទិដ្ឋិ ពាល់ត្រូវហើយ ខ្ជោចផ្សានៅក្នុងខាងក្នុង ឱ្យក្តៅក្រហាយក្តី សេចក្តីសោកសៅប្រកេទណាតិចតួចក្តី និងកណ្តាលជាដើមក្តី ទុក្ខមានការបៀតបៀនកាយរបស់បុគ្គល អ្នកមានកាយត្រូវផោដ្ឋព្វារម្មណ៍ដែលមិនគួរប្រាថ្នាពាល់ត្រូវហើយក្តី ទោមនស្ស និងឧបាយាស: ជាដើម ដែលកាន់យកដោយ **វ**-ស័ព្ទ ដែលជាវិកប្បនត្ថ: ដែលមិនមានអធិប្បាយទុកដូច្នោះ ដែលមានរូបជាអនេក គឺមានផ្សេងគ្នា ដោយសេចក្តីផ្សេងនៃនិស្សរ័យក្តី រមែងប្រាកដ គឺរមែងកើតឡើងក្នុងសត្វលោកនេះ ។ សត្វទាំងនោះ សូម្បីទាំងអស់ រមែងអាស្រ័យ គឺពឹងផ្អែកសត្ត និងសង្ខារជាទីស្រឡាញ់ គឺមានជាតិជាទីស្រឡាញ់ បានដល់ ធ្វើឱ្យជាបច្ច័យកើតឡើង គឺកើតឡើង ។ កាលវត្ថុជាទីស្រឡាញ់តាមដែលពោលហើយនោះ គឺកាលសត្ត និងសង្ខារជាទីស្រឡាញ់

មិនមាន បានដល់ លះធន្ទ្រាគ: ដែលធ្វើសេចក្តីស្រឡាញ់ សេចក្តីសោកសៅ ជាដើមទាំងនោះ ក៏រមែងមិនកើតពេលខ្លះ ។ សមដូចពាក្យដែលព្រះដ៏មាន-ព្រះភាគត្រាស់ទុកថា សេចក្តីសោកកើតពីសេចក្តីស្រឡាញ់... សេចក្តីសោកកើតពីសេចក្តីស្រឡាញ់[1] ជាដើម និងថា ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹក-ខ្សួល ការសោកស្តាយ នឹងសេចក្តីកំណាញ់... កើតមកអំពីរបស់ជាទីស្រឡាញ់[2] ដូច្នេះជាដើម ។ ក៏ក្នុងទីនេះ លោកពោលអំពីលិង្គវិបល្លាសថា **ឧបិ ០ វិតា ០ ឧ ០ ០** *។ ម្យ៉ាងទៀត កាលគួរនឹងពោលថា* **ឧបិ ០ វិតានិ ០ ឧ ០ ០** *ដូច្នេះ គប្បីជ្រាបថា លោកលុបវិភត្តិចេញ ។*

បទថា **តស្មា ហិ តេ សុ ០ ០ ០ ០** *សេចក្តីថា ព្រោះហេតុនៃសេចក្តីសោកជាដើម ដែលកើតពីសត្ត និងសង្ខារជាទីស្រឡាញ់ រមែងមិនមានដល់ជនពួកណា ដូច្នោះ ជនទាំងនោះនុ៎ះឯង ឈ្មោះថា មានសេចក្តីសុខ និងមានសេចក្តីសោកទៅប្រាសហើយ ។ ក៏អ្នកទាំងនោះ គឺអ្នកណា គឺជនអ្នកមិនមានសត្ត និងសង្ខារដែលជាទីស្រឡាញ់ក្នុងលោកណា អធិប្បាយថា ក៏ជនពួកណា គឺព្រះអរិយ:រមែងមិនមានសត្ត និងសង្ខារជាទីស្រឡាញ់ គឺការ:ជាទីស្រឡាញ់ថាបុត្រក្តី ថាបងប្អូនប្រុសក្តី ថាបងប្អូនស្រីក្តី ថាភរិយាក្តី មិនមានក្នុងលោកណាៗ គឺក្នុងសត្តលោក និងសង្ខារលោក ព្រោះប្រាសចាករាគ:ដោយប្រការទាំងពួង គឺសត្ត និងសង្ខារជាទីស្រឡាញ់ បានដល់ សេចក្តីស្រឡាញ់មិនមានក្នុងសង្ខារលោកថា នេះជារបស់យើង យើងរមែងបាន នឹងបាននូវសេចក្តីសុខឈ្មោះនេះ ដោយវត្ថុនេះ ។ បទថា* **តស្មា អសោកំ ០ ០ ០ ០**

១-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគថា លេខ ៥២ ទំព័រ ៦៦ ។

២-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ២៩០ ។

បិយំ ន ការយិរាថ ការហិញ្ចិ លោកេ *សេចក្តីថា ក៏ព្រោះហេតុដែលសត្វអ្នកប្រាសចាកសេចក្តីសោក ឈ្មោះថា មានសេចក្តីសុខ ព្រោះប្រាសចាកសេចក្តីសោកនុ៎ះឯង ទើបឈ្មោះថា មិនមានសេចក្តីស្រឡាញ់ក្នុងអារម្មណ៍ណាៗ ព្រោះដូច្នោះ បុគ្គលកាលប្រាជ្ញានូវសេចក្តីមិនសោក គឺការៈមិនមានសេចក្តីសោក ព្រោះមិនមានសេចក្តីសោកដូចពោលហើយដល់ខ្លួន ឈ្មោះថា មានសេចក្តីសុខ ព្រោះប្រាសចាកសេចក្តីសោកនុ៎ះឯង ទើបឈ្មោះថា មិនមានសេចក្តីស្រឡាញ់ក្នុងអារម្មណ៍ណាៗ ព្រោះដូច្នោះ បុគ្គលកាលប្រាជ្ញាសេចក្តីមិនសោក គឺការៈមិនមានសេចក្តីសោក ព្រោះមិនមានសេចក្តីសោកដូចពោលហើយដល់ខ្លួន ឈ្មោះថា អ្នកប្រាសចាកធូលី គឺការៈដែលមិនមានធូលី ព្រោះប្រាសចាកធូលី គឺរាគៈ បានដល់ ភាពជាព្រះអរហត្ត គឺព្រះនិព្វាន ដែលបាននាមថា **អសោកៈ** និងថា **វិរជៈ** ព្រោះមិនមានសេចក្តីសោក និងព្រោះហេតុនៃការមិនមានធូលី គឺរាគៈជាដើម ទើបកើតឆន្ទៈដោយអំណាចសេចក្តីពេញចិត្តក្នុងកុសល គឺសេចក្តីប្រាជ្ញាដើម្បីនឹងធ្វើ មិនគប្បីធ្វើ គឺមិនគប្បីឱ្យសត្វ និងសង្ខារជាទីស្រឡាញ់ គឺសេចក្តីស្រឡាញ់ឱ្យកើតក្នុងធម៌ មានរូបជាដើម ដោយហោចទៅ សូម្បីក្នុងធម៌ គឺសមថៈ និងវិបស្សនាក្នុងលោកណាៗ ។ សមដូចព្រះតម្រាស់ដែលព្រះដ៏-មានព្រះភាគត្រាស់ទុកថា* **ឩម្ហាបិ ភេ ភិក្ខវេ បហាតព្ពា បតេវ អឩម្ហា** *ម្នាលភិក្ខុទាំងឡាយ សូម្បីធម៌ គឺអ្នកទាំងឡាយ ក៏គួរលះចេញ នឹងចាំបាច់ពោលទៅថ្វីដល់អកុសលធម៌[1] ។*

អដ្ឋមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៨

១-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក: លេខ ២១ ទំព័រ ៤៧ ។

៩-បឋមឧព្ទសុត្តវណ្ណា

អដ្ឋកថាបឋមឧព្ទសូត្រទី ៩

បឋមទព្ទសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **អាយស្មា** *ជាពាក្យគួរទីស្រឡាញ់ ។ បទថា* **ឧព្ទោ** *ជានាមរបស់ព្រះថេរៈអង្គនោះ ។ បទថា* **មល្លបុត្តោ** *បានដល់ ព្រះថេរៈអង្គនោះ ជាព្រះរាជ-បុត្ររបស់មល្លក្សត្រ ។ មែនពិត ព្រះថេរៈដ៏មានអាយុអង្គនោះ បានបំពេញអកិនីហារបារមីទុកមក ទៀបបាទមូលរបស់ព្រះដ៏មានព្រះភាគ ព្រះនាម* **បទុមុត្តរ** *បានធ្វើបុណ្យទុកមករហូតដល់អស់សែនកប្ប ហើយកើតក្នុងព្រះគភ៌របស់ព្រះរាជទេវីនៃស្តេចមល្ល: ក្នុងកាលនៃព្រះដ៏មានព្រះភាគរបស់យើងទាំង-ឡាយ ក្នុងវេលាខ្លួនមានអាយុ ៧ ឆ្នាំ ដោយកំណើត បានចូលទៅរកមាតាបិតាសុំការអនុញ្ញាតដើម្បីបព្វជ្ជ ។ ព្រោះភាពនៃខ្លួនបានកសាងបុណ្យទុកហើយ ។ ចំណែកឯព្រះរាជមាតាបិតា បានអនុញ្ញាតថា នែបា! ចូរកូនបួស សិក្សាក្នុងអាចារ: បើកូនមិនត្រេកអរការសិក្សាក្នុងអាចារ:នោះទេ ចូរត្រឡប់មកក្នុងទីនេះវិញចុះ ។ ទព្ទមល្លបុត្រ បានចូលទៅគាល់ព្រះសាស្តា ទូលសូមបព្វជ្ជ ។ ចំណែកព្រះបរមសាស្តា ព្រះអង្គរំពឹងមើលនូវឧបនិស្សយសម្បត្តិរបស់ទព្ទមល្លបុត្រនោះ ហើយទើបព្រះអង្គទ្រង់អនុញ្ញាតឱ្យបព្វជ្ជ ។ ក្នុងវេលាដែលទព្ទមល្លបុត្របព្វជ្ជ ភពបីប្រាកដដូចជាកៀងនេះសន្ធោសន្ធៅ តាមឱ្យ៉ាងដែលព្រះសាស្តាទ្រង់ប្រទាន ។ ព្រះទព្ទមល្លបុត្រអង្គនេះ ទើបផ្តើមតាំងវិបស្សនា ហើយសម្រេចព្រះអរហត្ត ក្នុងខណ:ដែលចុងកាំបិតកោរលើកដំបូងប៉ុណ្ណោះ ។ ព្រះថេរ: បានសម្រេចធម៌

យ៉ាងណាមួយ ដែលព្រះសាវ័កទាំងឡាយគប្បីសម្រេចទាំងអស់ មានអាទិ៍យ៉ាងនេះ គឺវិជ្ជា ៣ បដិសម្ភិទា ៤ អភិញ្ញា ៦ លោកុត្តរធម៌ ៩ ព្រោះដូច្នោះ ព្រះថេរៈ ទើបត្រូវចាត់ទុកជាព្រះមហាសាវ័ក ក្នុងចំណោម ព្រះមហាសាវ័កទាំង ៨០ ។ សមដូចពាក្យដែលពោលទុកថា អញកើតឡើងបាន ៧ ឆ្នាំ បានសម្រេចអរហត្តផល គុណជាតិឯណានីមួយដែលសាវ័កត្រូវដល់ គុណជាតិ (នោះ) ក៏អញបានដល់ដោយលំដាប់[១] ។

បទថា **យេន ភគវា តេនុបសঙ্কមি** សេចក្ដីថា បានឮមកថា ថ្ងៃមួយ ព្រះទព្វមល្ល បុត្រដ៏មានអាយុអង្គនោះ និមន្តទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ត្រឡប់ពីបិណ្ឌបាតខាងក្រោយភត្ត សម្ដែងវត្តចំពោះព្រះដ៏មានព្រះភាគ ហើយទើបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ កាន់យកទឹកពីឆ្នាំងទឹកប្រើប្រាស់ លាងជើងទាំងពីរ ធ្វើខ្លួនឱ្យត្រជាក់ ក្រាលកំណាត់ស្បែកហើយគង់ កំណត់វេលា ហើយចូលសមាបត្តិ ។ លំដាប់នោះ ព្រះទព្វមល្ល បុត្តត្ថេរដ៏មានអាយុ ចេញចាកសមាបត្តិតាមវេលាដែលកំណត់ទុកហើយ រំពឹងមើលអាយុសង្ខារ របស់ខ្លួន ។ អាយុសង្ខារទាំងនោះ របស់ព្រះថេរៈអស់ទៅហើយ ត្រឹមតែបន្ដិចបន្ដួចប៉ុណ្ណោះ ។ ព្រះថេរៈគិតថា កាលបើយើងមិនក្រាបទូលព្រះសាស្ដា អំពីការបរិនិព្វាន ដើម្បីឱ្យ សព្រហ្មចារីទាំងឡាយជ្រាប ហើយចូលបរិនិព្វានក្នុងទីនេះឯង មិនសមគួរ

១-វិនៃយបិដក មហាវិភង្គ លេខ ២ ទំព័រ ២៩៩ ។

ដល់យើងឡើយ ។ បើដូច្នោះ មានតែយើងនឹងចូលទៅគាល់ព្រះសាស្តា សូមការអនុញ្ញាតដើម្បីបរិនិព្វាន ហើយសម្តែងវត្តចំពោះព្រះសាស្តា ដើម្បីនឹងសម្តែងឥទ្ធានុភាពរបស់ខ្លួន ដើម្បីនឹងសម្តែងថា ព្រះសាសនានេះ ជាសាសនានាំសត្វចេញចាកទុក្ខ ទើបអង្គុយក្នុងអាកាស ចូលតេជោធាតុហើយបរិនិព្វាន ។ កាលបើដូច្នោះ ជនទាំងឡាយណា មិនមានសទ្ធា មិនជ្រះថ្លាក្នុងអាត្មាអញ ក៏នឹងកើតសទ្ធាជ្រះថ្លា ប្រការនោះនឹងគប្បីប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនទាំងឡាយនោះអស់កាលយូរ ។ ក៏កាលដែលព្រះទព្ធមល្ល បុត្ត-ដ៏មានអាយុអង្គនោះ គិតយ៉ាងនេះហើយ ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ បានធ្វើប្រការនោះទាំងអស់នោះឯង ។ ព្រោះហេតុនោះ លោកទើបពោលថា គ្រានោះឯង ព្រះទព្ធមល្ល បុត្រដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ដោយបទថា **បរិនិព្វានកាលោ មេ** សេចក្តីថា ព្រះទព្ធមល្ល បុត្រសម្តែងថា បពិត្រព្រះដ៏មានព្រះភាគ កាលជាទីបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុបានប្រាកដដល់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គប្រាថ្នានឹងក្រាបទូលការបរិនិព្វាននោះ ហើយនឹងបរិនិព្វាន ។ តែអាចារ្យពួកខ្លះពោលថា ព្រះថេរៈមិនទាន់ជរា និងមិនទាន់មានជម្ងឺ លោកទូលលាព្រះសាស្តាដើម្បីបរិនិព្វាន ក្នុងសេចក្តីនោះមានហេតុដូចម្តេច គឺមេត្តិយកិក្ខុ និងភូមជកកិក្ខុ កាលនាំគ្នាចោទព្រះថេរៈ ដោយអាបត្តិបារាជិកមិនមានមូលក្នុងកាលមុន សូម្បី

កាលអធិករណ៍នោះសូប់រំងាប់ទៅហើយ ក៏ភិក្ខុទាំងនោះ នៅតែជេរព្រះថេរៈ ។ ចំណែកបុថុជ្ជនទាំងឡាយដទៃ កាលជឿពាក្យរបស់មេត្តិយភិក្ខុ និងភូមជកភិក្ខុ ទើបមិនគោរព និងការមើលងាយក្នុងយើង (ព្រះទព្ធមល្លបុត្តត្ថេរ) ។ ការនេះ នឹងនាំការៈ គឺទុក្ខនេះ ជាកម្មគ្មានប្រយោជន៍ និងមានប្រយោជន៍អ្វី ព្រោះដូច្នោះ យើងនឹងបរិនិព្វានក្នុងឥឡូវនេះឯង ព្រះថេរៈធ្វើការសន្និដ្ឋាន ទើបទូលលាព្រះសាស្តា ។ ប្រការនោះ មិនមែនជាហេតុ ។ មែនពិត ព្រះខីណាស្រពទាំងឡាយ កាលអាយុសង្ខារមិនទាន់អស់ទៅ រមែងមិនគិត មិនព្យាយាម មិនប្រឹងប្រែង ដើម្បីការបរិនិព្វានឡើយ ព្រោះភ័យអំពីអ្នកដទៃប្រទូស្តជាដើម និងមិនតាំងនៅយូរ ព្រោះហេតុអ្នកដទៃសរសើរជាដើម ។ បើតាមពិតទៅ ព្រះខីណាស្រពទាំងនោះ កាលនឹងអស់អាយុសង្ខាររបស់ខ្លួន ព្រមដោយកិច្ចរបស់ខ្លួនន៏ុះឯង ។ សមដូចពាក្យដែលលោកពោលទុកថា

ជាកិកង្ខ្ជាមិ មរណំ ជាកិកង្ខ្ជាមិ ជីវិតំ

ការាលញ្ជ បដិកង្ខ្ជាមិ និព្ធិសំ ភតកោ យថា ។

អាត្មាមិនត្រេកអរ នឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មារង់ចាំតែនឹងបរិនិព្វាន ដូចអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ[១] ។

ចំណែកព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាមើលអាយុសង្ខាររបស់

១-សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា លេខ ៥៧ ទំព័រ ២៧ ។

ព្រះទព្វមល្លបុត្រដ៏មានអាយុ ទើបដឹងថា អស់ទៅហើយ ទើបត្រាស់ថា ម្នាលទព្វៈ អ្នកចូរសម្គាល់កាលដ៏សមគួរ ក្នុងឥឡូវនេះចុះ ។

បទថា **វេហាសំ អព្ភុគ្គន្ត្វា** បានដល់ ហោះឡើងទៅក្នុងអាកាស អធិប្បាយថា ទៅក្នុងវេហា ។ មែនពិត បទថា **វេហាសំ អព្ភុគ្គន្ត្វា** នេះ ជាទុតិយាវិភត្តិ ព្រោះប្រកបដោយអភិស័ព្ទ គប្បីជ្រាបអត្ថដោយអំណាចសត្តមីវិភត្តិ ។ ដើម្បីនឹងជៀសវាងពាក្យសួរថា ហោះទៅក្នុងអាកាស ហេតុដូចម្តេច ទើបពោលពាក្យមានជាអាទិ៍ថា អង្គុយចម្រើនសមាធិក្នុងអាកាស គឺក្នុងកណ្តាលវេហា ។ បណ្តាបទទាំងនោះ បទថា **តេជោធាតុំ សមាបជ្ជិត្វា** សេចក្តីថា ចូលចតុត្ថជ្ឈានសមាបត្តិ មានតេជោកសិណជាអារម្មណ៍ ។ មែនពិត ក្នុងកាលនោះ ព្រះថេរៈថ្វាយបង្គំព្រះដ៏មានព្រះភាគហើយធ្វើប្រទក្សិណ ៣ ជុំវិញ ហើយឈរក្នុងទីសមគួរមួយ ទើបក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គនៅក្នុងទីនោះៗ នឹងព្រះដ៏មានព្រះភាគ បំពេញបុញ្ញកម្មរហូតអស់សែនកប្ប បានធ្វើប្រយោជន៍នេះមានប្រមាណប៉ុណ្ណេះ ក៏ប្រយោជន៍នេះនោះឯង បានដល់ ទីបំផុតហើយក្នុងថ្ងៃនេះ នេះជាការឃើញគ្រាចុងក្រោយបង្អស់ ។ បណ្តាភិក្ខុជាបុថុជ្ជន ជាសោតាបន្ន និងជាសកទាគាមិក្នុងទីនោះ អង្គខ្លះមានសេចក្តីករុណាយ៉ាងធំក្រៃលែង ។ ពួកខ្លះក៏ស្រែកទ្រហោយំ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបអាចារៈនៃចិត្តរបស់ព្រះថេរៈ ទើបព្រះអង្គត្រាស់ថា ម្នាលទព្វៈ បើដូច្នោះអ្នកចូរសម្តែងឥទ្ធិបាដិហារ្យដល់តថាគត និងភិក្ខុសង្ឃ ។ ក្នុងខណៈនោះឯង

ភិក្ខុសង្ឆទាំងអស់បានមកប្រជុំគ្នាហើយ ។ ក្នុងកាលនោះ ព្រះទព្វមល្ល្ហបុត្ត ដ៏មានអាយុ សម្តែងបាដិហារ្យទាំងអស់ ដែលទូទៅដល់សាវក ដោយន័យមានជាអាទិ៍ថា ធ្វើមនុស្សម្នាក់ ឱ្យក្លាយជាមនុស្សច្រើននាក់ ដូច្នេះហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគម្តងទៀត ហោះទៅក្នុងអាកាស និមិត្តផែនដីក្នុងអាកាស អង្គុយចម្រើនសមាធិក្នុងអាកាសនោះ បរិកម្មដោយតេជោកសិណសមាបត្តិ ចូលសមាបត្តិ ចេញហើយរំពឹងដល់រាងកាយ ចូលសមាបត្តិម្តងទៀត អធិដ្ឋានតេជោធាតុដើម្បីបូជាសរីរៈហើយបរិនិព្វាន ។ ព្រមដោយការអធិដ្ឋាននោះ រាងកាយទាំងអស់ ទើបត្រូវភ្លើងឆេះ ។ ក៏ក្នុងខណៈនោះឯង ភ្លើងនោះ ដូចជាភ្លើងប្រចាំកប្បឆេះសព៌ាង្គកាយ ត្រឹមតែផ្សែង ត្រឹមតែម្រែងភ្លើង មិនមានសេសសល់អ្វីឡើយ ឱ្យឆេះដោយកម្លាំងនៃអធិដ្ឋាន ហើយបរិនិព្វាន ។ ព្រោះហេតុនោះ លោកទើបពោលថា ត្រានោះឯង ព្រះទព្វមល្ល្ហបុត្តដ៏មានអាយុ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **វុដ្ឋហិត្វា បរិនិព្វាយិ** សេចក្តីថា ចេញចាកអំពីចិត្តដែលសម្រេចដោយឫទ្ធិហើយបរិនិព្វាន ដោយកវង្គចិត្ត ។ បទថា **ឈាយមានស្ស** បានដល់ ភ្លើងឆេះសន្ធោសន្ធៅ ។ បទថា **ឌយ្ហមានស្ស** នេះ ជាវេវចនៈនៃបទថា **ឈាយមានស្ស** នោះឯង ។ ម៉្យាងទៀត បទថា **ឈាយមានស្ស** លោកពោលសំដៅយកខណៈដែលភ្លើងឆេះសន្ធោសន្ធៅឡើង ។ បទថា **ឌយ្ហមានស្ស** លោកពោលសំដៅយកខណៈប្រាសចាករងើកភ្លើង ។ បទថា **ឆារិកា** បានដល់ កម្ទេចផេះ ។ បទថា **មសិ** បានដល់ ម្រែងភ្លើង ។ បទ

ថា **ឯ បញ្ញាយិត្ថ** បានដល់ មិនឃើញ ។ អធិប្បាយថា វត្ថុទាំងអស់អន្តរធាន ក្នុងខណៈនោះនុ៎ះឯង ដោយកម្លាំងនៃអធិដ្ឋាន ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះថេរៈទើបសម្ដែងបាដិហារ្យ ជាឧត្តរិមនុស្សធម៌ ព្រោះព្រះដ៏មានព្រះភាគព្រះអង្គត្រាស់ហាមការធ្វើឥទ្ធិបាដិហារ្យ មិនមែនឬ? ឆ្លើយថា ប្រការនេះ មិនគប្បីចោទឡើយ ព្រោះព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់ហាមការធ្វើបាដិហារ្យចំពោះមុខពួកគ្រហស្ថទាំងឡាយ ។ តែប្រការនោះត្រាស់ហាមដោយអំណាចការសម្ដែងឫទ្ធិផ្សេងៗ មិនត្រាស់ហាមដោយអំណាចការអធិដ្ឋានទេ ។ ក៏ព្រះទព្វមល្លបុត្តដ៏មានអាយុអង្គនេះ ដែលព្រះធម្មសាមី ព្រះអង្គត្រាស់បង្គាប់ហើយ ទើបសម្ដែងបាដិហារ្យ ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួងនូវអាការដែលព្រះទព្វមល្លបុត្តដ៏មានអាយុបរិនិព្វាន ដោយអនុបាទិសេសនិព្វាននេះ ទើបទ្រង់បន្លឺនូវឧទាននេះ ដើម្បីសម្ដែងសេចក្ដីនោះ ។

បណ្ដាបទទាំងនោះ បទថា **អភេទិ កាយោ** សេចក្ដីថា រូបកាយ ដែលមានសន្តតិ ៤ មានសេចក្ដីផ្សេងគ្នាដោយភូតរូប និងឧបាទាយរូបទាំងអស់ រមែងបែកធ្លាយ រមែងវិនាស រមែងអន្តរធានទៅ ដោយមិនមានសេសសល់ គឺដល់នូវធម្មជាតិ មិនកើតឡើងទៀត ។ បទថា **និរោធិ សញ្ញា** បានដល់ សញ្ញាទាំងអស់ មានសេចក្ដីផ្សេងគ្នា ដោយរូបសញ្ញាជាដើម ព្រោះមានរូបាយតនៈជាដើម រលត់ទៅហើយដោយការរលត់ ព្រោះមិនមានបដិសន្ធិ ។ បទថា **វេទនា**

សីតិភវីសុ សញ្ញា បានដល់ វេទនាសូម្បីទាំងអស់ គឺវិបាកវេទនា និងកិរិយា-វេទនា ជាធម្មជាតិត្រជាក់ ព្រោះមិនមានសេចក្ដីខ្ជល់ខ្ចាយនៃអារម្មណ៍ សូម្បីមានប្រមាណតិចតួច ព្រោះរលត់ ដោយការរលត់ គឺមិនមានបដិសន្ធិ ។ តែកុសលវេទនា និងអកុសលវេទនា ដល់នូវការរលត់ក្នុងខណៈនៃអរហត្តផលដោយពិត ។ អាចារ្យពួកខ្លះពោលថា **សីតិភវីសុ** ជាការរៀរចាកកាពត្រជាក់ ដូច្នេះក៏មាន អធិប្បាយថា ជាធម្មជាតិរលត់ទៅ ។ បទថា **រូបសមីសុ សង្ខារ** សេចក្ដីថា ធម៌ គឺសង្ខារក្ខន្ធ មានផស្សៈជាដើម សូម្បីទាំងអស់ ផ្សេងដោយវិបាក និងកិរិយា ចូលទៅសូប់ហើយ ដោយលក្ខណៈពិសេស ព្រោះរលត់ហើយដោយការរលត់ គឺមិនមានបដិសន្ធិនុ៎ះឯង ។ បទថា **វិញ្ញាណំ អត្ថមាតមា** សេចក្ដីថា សូម្បីវិញ្ញាណទាំងអស់ផ្សេងដោយវិបាក និងកិរិយា បានដល់ ការតាំងនៅមិនបាន គឺវិនាស បានដល់ ការដាច់សូន្យ ព្រោះរលត់ ដោយមិនមានបដិសន្ធិ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ព្រះអង្គបន្ទឹនូវឧទាន ដោយការសម្ដែងចេញកម្ចាំងនៃបីតិ ព្រោះអាស្រ័យខន្ធទាំង ៥ របស់ព្រះទព្វមល្ល បុត្ត ដ៏មានអាយុ រលត់ ដោយការរលត់ គឺមិនមានការបដិសន្ធិទៀត ដូចភ្លើងដែលអស់គ្រឿងឆេះ ព្រោះដូច្នោះ ព្រោះរលត់ឧបាទាន គឺកិលេស និងអកិសង្ខារ ក្នុងកាលមុនបានដោយមិនឱ្យសេសសល់ ។

ឧរមសុត្តវណ្ណនា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ៩

សម្រាប់ជាធម្មទាន

១០-ឧតិយឧព្ទសុត្តវណ្ណនា

អដ្ឋកថាទុតិយឧព្ទសូត្រទី ១០

ទុតិយទព្ទសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ** *សេចក្តីថា ព្រះដ៏មាន-ព្រះភាគ កាលទ្រង់ប្រថាប់នៅក្នុងក្រុងរាជគ្រឹះតាមអធ្យាស្ស័យ ហើយយាងទៅកាន់ចារិកជនបទ ព្រះអង្គបានដល់ក្រុងសាវត្ថីតាមលំដាប់នោះ ប្រថាប់នៅក្នុងវត្តជេតពន ដើម្បីនឹងសម្តែងការបរិនិព្វានរបស់ព្រះទព្ទមល្លបុត្រដ៏មានអាយុ ដែលមិនទាន់ប្រាកដច្បាស់ដល់ភិក្ខុទាំងឡាយនៅឡើយ ឱ្យប្រាកដច្បាស់ និងដើម្បីឱ្យបុថុជ្ជន អ្នកមិនគោរពក្នុងព្រះថេរ: ដោយការពោលពាក្យមិនពិត គឺមេត្តិយភិក្ខុ និងភូមជកភិក្ខុ បានធ្វើទុកហើយ ឱ្យបែរមកពាប់អានដ៏ច្រើនក្នុងព្រះថេរ: ទើបត្រាស់ហៅ ។*

បណ្តាបទទាំងនោះ បទថា **តត្រ** *នេះ ត្រឹមតែជានិបាត ប្រើក្នុងអត្ថថាសម្គាល់នូវពាក្យ ។ ស័ព្ទថា* **ខោ** *ប្រើក្នុងអត្ថថា អវធារណ: ប្រែថា ហាមសេចក្តីដទៃ ។ បណ្តាបទទាំងនោះ ដោយបទថា* **តត្រ** *នេះ បំភ្ញីអត្ថដែលពោលដល់បទទាំងនេះថា* **ភគវា ភិក្ខូ អាមន្តេសិ** *ព្រះដ៏មានព្រះភាគត្រាស់ហៅចំពោះភិក្ខុ ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងសេចក្តីនេះ ក៏ដោយបទថា* **ខោ** *នេះ ទ្រង់ត្រាស់ហៅដូចគ្នា ក្នុងការត្រាស់ហៅភិក្ខុមិនមានអន្តរាយអ្វីៗ ឡើយ ។ ម្យ៉ាងទៀត បទថា* **តត្រ** *បានដល់ ក្នុងអារាមនោះ ។ ស័ព្ទថា* **ខោ** *ជានិបាត ប្រើក្នុងអត្ថថា* **វចនាលঙ্কার** *(លម្អពាក្យឱ្យមានសេចក្តីពិរោះ) ។ បទថា* **អាមន្តេសិ** *ប្រែថា បានត្រាស់ហៅហើយ ។ សួរថា ក៏ព្រោះហេតុអ្វី បានជាព្រះដ៏មានព្រះភាគទើបត្រាស់ហៅភិក្ខុទាំងឡាយ ឆ្វើយថា ព្រោះជាចម្បង ជាអ្នកចម្រើន ជាអ្នក*

ប្រសើរ ជាអ្នកជិតស្និទ្ធ ជាអ្នកមានចិត្តតាំងមាំ ដោយល្អអស់កាលយូរ និងព្រោះជាអ្នកទទួលព្រះធម្មទេសនាដោយពិសេស ។

បទថា **ភិក្ខវោ** ជាការសម្តែងអាការហៅកិក្ខុទាំងនោះ ។ បទថា **ភគវន្តេ** ជាការធ្វើយតបពុទ្ធតម្រាស់នឹងព្រះសាស្តា ដោយគោរព ។ ព្រះដ៏មានព្រះភាគ កាលនឹងត្រាស់ហៅ ទើបត្រាស់ហៅកិក្ខុទាំងនោះ ដោយពាក្យថា **ភិក្ខវោ** ប្រែថា ម្នាលកិក្ខុទាំងឡាយ ។ កិក្ខុទាំងនោះ កាលនឹងទូល ក៏ទូលធ្វើយតបថា **ភគវន្តេ** ។ ម្យ៉ាងទៀត ដោយពាក្យថា **ភិក្ខវោ** នេះ ជាព្រះតម្រាស់អាស្រ័យនឹងព្រះហ្ឫទ័យដ៏ត្រជាក់ ដែលកើតឡើងដោយករុណាគុណជាប្រធាន ព្រះអង្គទ្រង់ឱ្យកិក្ខុទាំងនោះ ត្រឡប់ចាកការធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន និងពិចារណាធម៌ជាដើម ហើយបែរមុខមករកព្រះអង្គ ។ ដោយពាក្យថា **ភគវន្តេ** នេះ ជាពាក្យសម្តែងដល់សេចក្តីអើពើ សេចក្តីរាប់អាន និងសេចក្តីគោរពដោយច្រើនក្នុងព្រះសាស្តា ទើបកិក្ខុទាំងនោះ ប្រកាសដល់ភាពនៃខ្លួនជាអ្នកស្តាប់ដោយល្អ និងភាពនៃខ្លួនជាអ្នកមានសេចក្តីគោរពក្នុងការទទួលឱ្យ ។ បទថា **ភគវតោ បច្ចុស្សោសុំ** សេចក្តីថា កិក្ខុទាំងនោះធ្វើយតបនឹងពុទ្ធតម្រាស់របស់ព្រះដ៏មាន-ព្រះភាគ គឺដើម្បីឱ្យកើតសេចក្តីត្រូវការក្នុងការស្តាប់ ។ បទថា **ឯតទវោច** សេចក្តីថា ព្រះដ៏មានព្រះភាគ បានត្រាស់ព្រះសូត្រទាំងអស់នេះ ដែលលោកកំពុងពោលក្នុងកាលឥឡូវនេះ ។ បទមានជាអាទិ៍ថា **ឧព្ភស្ស ភិក្ខវេ មល្ល-បុត្តស្ស** ដូច្នេះ មានសេចក្តីដូចពោលក្នុងសូត្រជាលំដាប់គ្នានុ៎ះឯង ។ សូម្បីក្នុងបទថា **ឯតមត្ថំ** ជាដើម មិនមានពាក្យដែលមិនធ្លាប់ពោលទេ គប្បីជ្រាបដោយ

ន័យ ដែលពោលទុកហើយក្នុងព្រះសូត្រជាលំដាប់គ្នានុ៎ះឯង ។

ក្នុងគាថាទាំងឡាយ មានវិគ្រោះដូចតទៅនេះ

បទថា **អយោឃនហតស្ស** *សេចក្ដីថា វត្ថុ ឈ្មោះថា* **អយោឃនំ** *ព្រោះជាគ្រឿងវាយដែក បានដល់ ញញ្ជរ និងកណ្ដាប់ដៃរបស់ពួកជាង ។ ភ្លើងដែលត្រូវញញ្ជរនោះវាយ គឺដំ ។ តែអាចារ្យពួកខ្លះពោលអធិប្បាយថា បទថា* **អយោឃនហតស្ស** *បានដល់ ភ្លើងដែលឆេះ ។* **ឋវំ**-*សទ្ទ ជានិបាត ។ បទថា* **ជលតោ ជាតវេឌេសោ** *បានដល់ ការដុត គឺធ្វើឱ្យឆេះ ។ បទថា* **ជលតោ ជាតេវេឌេសោ** *នេះ ជាធដ្ឋីវិកត្តិ ប្រើក្នុងអត្ថថា អនាទរ: (មិនអើពើ) ។ បទថា* **អនុបុព្ពូបសន្តស្ស** *សេចក្ដីថា ភ្លើងស្ងប់ រលត់ គឺស្ងប់ស្ងាត់ ។ បទថា* **យថា ន ញ្ញាយតេ គតិ** *សេចក្ដីថា ដូចគតិរបស់ភ្លើងនោះ ដែលគេមិនដឹង ។ លោកពោលអធិប្បាយពាក្យនេះទុកថា កាលភ្លើងត្រូវញញ្ជរដង មានកណ្ដាប់ដៃ និងដងដែកជាដើម ប៉ះខ្ទប់ គឹកម្ចាត់ ឬឆេះសន្ធោសន្ធៅជាប់នឹងកាជន:សំរិតជាដើមម្យ៉ាងទៀត កាលសំឡេងដែលកើតឡើងក៏ស្ងប់ គឺចូលទៅស្ងប់ដោយល្អ តាមលំដាប់ គតិរបស់ភ្លើង សំឡេងរមែងមិនប្រាកដ ក្នុងទីណាៗ ក្នុងទិសទាំង ១០ ព្រោះរលត់ដោយមិនមានការបដិសន្ធិ និងគ្មានបច្ច័យ ។*

បទថា **ឋវំ សម្មា វិមុត្តន្តំ** *សេចក្ដីថា គតិរបស់ព្រះខីណាស្រពទាំងឡាយ ឈ្មោះថា រួចផុតដោយប្រពៃ ព្រោះរួចផុតចាកឧបាទាន ៤ និងអាសវ: ៤ ដោយប្រពៃ ដោយហេតុ ដោយញ្ញេយ្យធម៌ ដោយអរិយមគ្គ មានតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិជាប្រធាន លំដាប់នោះ ឈ្មោះថា អ្នកធ្ងងឱឃ: ដែលជាគ្រឿងចង គឺកាម ព្រោះធ្ងងកាមោឃ: ពោលគឺ គ្រឿងចង គឺកាម និងឱឃ: ដែលនៅ*

សល់ ផ្សេងដោយកវោយ:ជាដើម ឈ្មោះថា អ្នកចាស់ គឺសម្រេចសេចក្តីសុខ ដែលចូលទៅសូប់សង្ខារទាំងពួង ពោលគឺ អនុបាទិសេសនិព្វាន ដែលឈ្មោះថា មិនញាប់ញ័រ ព្រោះសូប់រំងាប់កិលេសជាហេតុធ្វើឱ្យក្តៅក្រហាយបានដោយល្អ និងព្រោះមិនញាប់ញ័រដោយខ្យល់ គឺអកិសង្ខារ បានដល់ កិលេស រមែងមិនមាន ដើម្បីនឹងបញ្ញត្ត ដោយមិនមានទីនឹងគប្បីបញ្ញត្តថា នេះឈ្មោះថា គតិ បណ្តាគតិផ្សេងៗ ដោយទេវតា និងមនុស្សជាដើម អធិប្បាយថា ក៏ព្រះទព្វមល្ល្ហបុត្ត នោះ ទៅកាន់ការ:រកបញ្ញត្តមិនបានដូចក្ងើង តាមដែលពោលមកហើយដូច្នោះ។

ឧសមសុត្តវណ្ណា និដ្ឋិតា

ចប់ អដ្ឋកថាសូត្រទី ១០

និដ្ឋិតា ច ចាជលិកាមិយវគ្គវណ្ណា

ចប់ចាជលិកាមិយវគ្គវណ្ណនាទី ៨ ។

រួមព្រះសូត្រដែលមានក្នុងវគ្គនេះ គឺ

១-បឋមនិព្វានបដិសំយុត្តសូត្រ	*២-ទុតិយនិព្វានបដិសំយុត្តសូត្រ*
៣-តតិយនិព្វានបដិសំយុត្តសូត្រ	*៤-ចតុត្ថនិព្វានបដិសំយុត្តសូត្រ*
៥-ពុន្ធសូត្រ	*៦-ជាជលិកាយសូត្រ*
៧-ទ្វិជាបថសូត្រ	*៨-វិសាខាសូត្រ*
៩-បឋមទព្វសុត្រ	*១០-ទុតិយទព្វសូត្រ*

និគមនកថា

ដោយពាក្យមានប្រមាណប៉ុណ្ណោះ

(ព្រះមានដ៏ព្រះភាគ) ព្រះអង្គរួចផុតហើយដោយល្អ ចាកភាពប្រកាន់មាំក្នុងកាម ព្រះអង្គ គឺពួកទេវៈ និងអសុរៈរាប់អានហើយ ព្រះអង្គមានសន្ធានៃតណ្ហាកាត់ផ្តាច់ហើយ ព្រះអង្គជាអ្នកសម្តែងបីតី និងសេចក្តីសង្វេគ ។

(ព្រះអនាវរណញ្ញាណ) ព្រះអង្គជាអ្នកត្រេកអរក្នុងការប្រទានព្រះសទ្ធម្ម ព្រះអង្គជាអ្នកនាំចេញ និងធ្វើឱ្យអស់ទៅនូវឧបាទាន ព្រះអង្គជាមគ្គុទ្ទេសកដ៏ពិសេស ព្រះអង្គបានបន្ទឹនូវព្រះឧទានណាៗ ក្នុងទីនោះ ។

ឧទានទាំងអស់នោះ គឺព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានប្រមូលទុកក្នុងទីជាមួយគ្នា ឡើងកាន់ការសង្គាយនា បាននាមថា **ខុទ្ទានៈ** ។

អត្ថវណ្ណនាឯណា ដែលខ្ញុំ (ធម្មបាលត្ថេរ) ផ្តើមប្រារព្ធឡើង ព្រោះអាស្រ័យន័យនៃអដ្ឋកថាពីបុរាណ ដើម្បីប្រកាសនូវសេចក្តីអត្ថាធិប្បាយនៃគម្ពីរឧទាននោះ ។

អត្ថវណ្ណនានោះ គឺព្រះអដ្ឋកថាចារ្យ បានប្រកាសដោយនាមថា **បរមត្ថទីបនី** តាមសមគួរក្នុងសុត្តន្តបិដកមានអត្ថដ៏សុខុម ។

*អដ្ឋកថា ឈ្មោះ **បរមត្ថទីបនី** មានសេចក្ដីវិនិច្ឆ័យ*
មិនលំបាក សម្រេចហើយដោយភាណវារបាលី
ប្រមាណ ៤៣ ភាណវារៈ ។
ដោយអានុភាពនៃបុញ្ញកម្ម ដែលខ្ញុំបានរចនាគម្ពីរ
***បរមត្ថទីបនី**នេះ* *បរិបូរ និងសម្រេចហើយ* *សូមសាសនា*
នៃព្រះលោកនាថ (តាំងនៅយូរ) ។
សូមសព្វសត្វទាំងឡាយស្វាងសៃ ដោយការប្រតិបត្តិ
ក្នុងត្រ័យសិក្ខា *មានសីលជាដើម* *ឱ្យបរិសុទ្ធ* *ចូរជាអ្នក*
មានចំណែកនៃវិមុត្តិរស ។
សូមសាសនានៃព្រះសម្មាសម្ពុទ្ធ ស្ថិតនៅក្នុងលោក
អស់កាលជានិច្ច *សូមសត្វទាំងឡាយទាំងពួង* *មានការ*
គោរពក្នុងព្រះសាសនាជាដរាប ។
សូមក្ងៀងបង្អុរចុះ *តាមសមគួរដល់កាល* *ដ៏ប្រពៃ*
សូមព្រះមហាក្សត្រ *ត្រេកអរក្នុងព្រះសទ្ធម្ម* *គ្រប់គ្រង*
លោកដោយទសពិធរាជធម៌ *ទៅហោង ។*

ពន្ធរតិត្ថវិហារវាសិនា អាចរិយធម្មចាលត្ថេរេន
កតា ឧទានសារ្ធ អដ្ឋកថា សមត្តា
អដ្ឋកថា បរមត្ថទីបនី នៃគម្ពីរឧទាន
គឺព្រះអាចារ្យ នាមធម្មចាលត្ថេរ អ្នកមានប្រក្រតីគង់នៅពន្ធរតិត្ថវិហារ
បានរចនាហើយ សម្ដែងចាប់ ដោយបរិបូណ៌ហោង ។

រួមវគ្គដែលមានក្នុងឧទានេះ គឺ

ពោធិវគ្គទី ១ មុចលិន្ទវគ្គទី ២ នន្ទវគ្គទី ៣ មេឃិយវគ្គទី ៤ សោណ-ត្ថេរវគ្គទី ៥ ជច្ចន្ធវគ្គទី ៦ ចូឡវគ្គទី ៧ បាដលិគាមិយវគ្គទី ៨ *មានសូត្រ ៨០ សូត្រ វគ្គទាំង ៨ នេះ ព្រះពុទ្ធជាម្ចាស់ ព្រះអង្គមានចក្ខុប្រាសចាកមន្ទិល ទ្រង់ចែកល្អ ហើយ បណ្ឌិតទាំងឡាយអ្នកមានសទ្ធា បានពោលវគ្គនោះថា* ***ឧទាន*** *ដូច្នេះ ។*

ចប់ឧទាន

ឯកសារយោង

១-គម្ពីរ បរមត្ថទីបនី ភាសាបាលី, ច្បាប់ឆដ្ឋសង្គាយនា (Chattha Sangayana Tipitaka 4.0)
២-មហាមកុដរាជវិទ្យាល័យ, គម្ពីរ បរមត្ថទីបនី ភាសាបាលីថៃ, ប្រទេសថៃ ។
៣-មហាមកុដរាជវិទ្យាល័យ, គម្ពីរ បរមត្ថទីបនី, ច្បាប់ប្រែជាភាសាថៃ, ប្រទេសថៃ ។
៤-ពុទ្ធសាសនបណ្ឌិត្យ, សុត្តន្តបិដក ខុទ្ទកនិកាយ លេខ ៥២, ភ្នំពេញ
៥-ព្រះត្រៃបិដកភាសាខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
៦-វិទ្យាស្ថានស្រាវជ្រាវវិបស្សនា, គម្ពីរ អដ្ឋកថា ដីកា, ច្បាប់ឆដ្ឋសង្គាយនា (Chattha Sangayana Tipitaka 4.0, មហាវាស្ត្រ, ឥណ្ឌា ។
៧-ម៉ឹង សៃស, បទានុក្រមបាលី អភិធានប្បទីបិកា, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ព.ស ២៥៣៩ ។
៨-កិម តូរ, បទានុក្រមធម្មបទ(បីភាគ), វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ព.ស ២៥៣៨ ។
៩-អ៊ុម គយ, ធាតុសង្ក្រោះ,ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពឡើងវិញ ២០០៤ ។
១០-វចនានុក្រមខ្មែរអេឡិចត្រូនិចកំណែទី ២,ពុទ្ធសាសនបណ្ឌិត្យ, ២០០៩ ។
១១-វចនានុក្រមបាលី-ថៃ, ច្បាប់ភូមិពលោភិក្ខុ, ព.ស ២៥៣៥ ។
១២-ម៉ាក់ បេន, វចនានុក្រម អង់គ្លេស-ខ្មែរ, ភ្នំពេញ ២០០៤ ។
១៣-យន់ វណ្ណាវង្សនិងរស់ សារ៉ាវុធ, វចនានុក្រម ថៃ-ខ្មែរ,.ភ្នំពេញ ២០០៦ ។
១៤-ស.បុញ្ញអារក្ស, វចនានុក្រមអភិធម្មប្រាំពីរគម្ពីរ, ។
១៥-វចនានុក្រមថៃ, ច្បាប់រាជបណ្ឌិត្យស្ថាន, ព.ស ២៥២៥ ។
១៦-ឆវិន សរៈខាំ, ប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនានៅប្រទេសឥណ្ឌា, ប្រែដោយ អគ្គតេជោ នៅ សាខន, ភ្នំពេញ កម្ពុជា, ២០០៦ ។
១៧-ព្រះនន្ទប្បញ្ញាថេរៈ, ចុល្លគន្ថវំសបាឡি-ប្រែ, ប្រែដោយ បញ្ញិន្ទោ វ៉ាន់ ចាន់សារ៉ែន, ភ្នំពេញ ២០០៥ ។
១៨-វ៉ាន់ ចាន់សារ៉ែន, បាវចនសង្ខេបនៃព្រះពុទ្ធសាសនា, ពុទ្ធិកបណ្ឌិតសភានៃសាកល-វិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, គ.ស ២០០៨ ។
១៩-មហាកច្ចាយនត្ថេរ, នេត្តិប្បករណបាឡি ខុទ្ទកនិកាយ, ឆដ្ឋសង្គាយនា ។
២០-វ៉ាន់ ចាន់សារ៉ែន, សត្ថុសាសនកថា, ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញា-សាស្ត្រកម្ពុជា, ភ្នំពេញ, ព.ស ២៥៥១ ។

២១-THE UDANA, Translated from the Pāli by PETER MASEFIELD, THE PALI TEXT SOCIETY, OXFORD, 1997.
២២- G.M. STRONG., THE UDANA, Republished 2007 by Forgotten Books, www.forgottenbooks.org
២៣-DICTIONARY of PALI PROPER NAMES VoL.1-2,C.P MALALASEKERA,LONDON,1974.
២៤- T.W. Rhys Davids and William Stede., PALI-ENGLISH DICTIONARY, OXFORD, 1999
២៥-THE GUIDE (NETTI-PPAKARANA), Translated from the PALI by BHIKKHU NANAMOLI, The Pali Text society, LONDOM 1977
២៦-A HISTORY OF PALI LITERATURE, BY BIMALA CHUEN LAW, Ph.D., M.A., B.L.,
២៧-www.accesstoinsight.org
២៨-http://www.tipitaka.org/khmr
២៩-ឯកសារផ្សេងៗទៀតៗ

<u>កំណត់សម្គាល់:</u> ឯកសារព្រះពុទ្ធសាសនាទាំងឡាយជាភាសាបាលី អាចរកអានបានក្នុងគេហទំព័រ:<u>http://www.tipitaka.org/khmr</u>

នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពគម្ពីរបរមត្ថទីបនី
អដ្ឋកថា
ខុទ្ទកនិកាយ ១ជាន
ពុទ្ធបរិស័ទពីវត្តភ្នំជញ្ជាំង និងវត្តបឹងត្រាវ
ខេត្តបន្ទាយមានជ័យ

-ពុទ្ធបរិស័ទរួមគ្នា ..... ៥៣០.០០០រ៉ៀល
-ឧបាសិកា ហ៊ុន សារ៉ុម ..... ១០០០ដុល្លារ
-ឧបាសិកា ប៉ាង ស៊ុន និងបុត្រ ..... ៣១.០០០រ៉ៀល
-លោកយាយ រឹម រ៉ាន់ និងក្មួយ ម៉ុម ..... ៣០.០០០រ៉ៀល
-ឧបាសិកា ពុត សារ៉ន្ត ..... ២០.០០០រ៉ៀល
-ឧបាសិកា ចាត យ៉ាន និងឧបាសក សុខ ធាត ..... ១២.០០០រ៉ៀល
-ឧបាសិកា យាយលក់នំដង្កូវ ..... ១២.០០០រ៉ៀល
-ឧបាសិកា យ៉ឹម ពុំ និងឧបាសិកា តាន់ សាមាលា ..... ១២.០០០រ៉ៀល

ពុទ្ធបរិស័ទវត្តឃ្លាងស៊ីសុវត្ថិ

-ឧបាសិកា លឹម រ្ជចណៃ និងបុត្រ ..... ៥០.០០០រ៉ៀល
-លោក ថោង ភិរម្យ និងភរិយា ព្រមទាំងបុត្រ ..... ៣០.០០០រ៉ៀល
-អ្នកស្រី ស៊ីនួន និងបុត្រ ..... ៣០.០០០រ៉ៀល
-អ្នកស្រី សង តាំងអ៊ីម ..... ៣០.០០០រ៉ៀល
-លោកវេជ្ជបណ្ឌិត ស្រី ចាន់រី និងអ្នកស្រី រ៉ែន សុការត្តី ..... ២១.០០០រ៉ៀល
-លោក អ៊ាប សុផាត ..... ២០.០០០រ៉ៀល
-ឧបាសិកា ឡាន់ រ៉ាត់ និងបុត្រ ..... ២០.០០០រ៉ៀល
-ឧបាសិកា ចាន់ ប៊ុនលី និងបុត្រ ..... ២០.០០០រ៉ៀល
-ឧបាសក កែ អាន និងឧបាសិកា លៃ ស៊ាន ព្រមទាំងបុត្រ ..... ១២.៥០០រ៉ៀល
-ឧបាសិកា ប៉ាច ម៉ៅ និងបុត្រ ..... ១២.០០០រ៉ៀល
-ឧបាសិកា ផែ សារ៉ និងបុត្រ ..... ១២.០០០រ៉ៀល
-ឧបាសិកា រ៉ា គិមលាន និងបុត្រ ..... ១២.០០០រ៉ៀល
-ឧបាសិកា ម៉ូវ ជី ..... ១២.០០០រ៉ៀល
-ឧបាសក គាំ និងឧបាសិកា សារ៉ ..... ១២.០០០រ៉ៀល
-ឧបាសិកា គឹម យ៉ុម ..... ១២.០០០រ៉ៀល
-ឧបាសក ចាន់ ធ្លក និងឧបាសិកា ពិន ណាងស៊ីម ..... ១២.០០០រ៉ៀល
-ឧបាសក ចន្ធា និងឧបាសិកា ចន្ធី ព្រមទាំងបុត្រ ..... ១២.០០០រ៉ៀល
-ឧបាសិកា ប៊ុច សារ៉ី និងឧបាសិកា ពៅ ..... ១២.០០០រ៉ៀល
-អ្នកស្រី ខុន នាងមែ និងបុត្រ ..... ១២.០០០រ៉ៀល
-ឧបាសក ខ្ពត ដៀម និងឧបាសិកា ជ្រាង សំបាន ..... ១២.០០០រ៉ៀល
-ឧបាសក ណ្ហុប សុកាទ្ធ និងឧបាសិកា សំពៅ ..... ១២.០០០រ៉ៀល

ពុទ្ធបរិស័ទវត្តសូរិយា ហៅ វត្តគោកធ្ងង់

-ប្រាក់បូជាធម៌ទេសនា (មឿន សាមុត + យឹន យ៉ារ + ណៃប ស៊ីណា) ៣៥៥.០០០រ
-ប្រាក់បូជាព្រះធម៌ទេសនា (ឡុង កុសល + យឹន យ៉ារ) ១៨៥.០០០រ
-ពុទ្ធបរិស័ទចំណុះដើងវត្តគោកធ្ងង់រួមគ្នា ៣២.៥០០រ
-ព្រះតេជគុណ **រក្ខិតធម្មោ** កង យ៉ុន ៣០.០០០រ
-ឧបាសិកា មួយ និងឧបាសិកា ប៉ុន ១៧.០០០រ
-ពេទ្យ ឡាប ១៥.០០០រ
-ព្រះតេជគុណ ផន ស្ងៀន ១២.០០០រ
-ឧបាសិកា ស្ងៀន ណារ៉ា និងបុត្រ ១២.០០០រ
-កុមារ ហុង ឈិងហ្វាង ១២.០០០រ
-កុមារី ហុង លិញអឺ ១២.០០០រ
-ឧបាសក ហាយ ចំណាត និងភរិយា ១២.០០០រ
-ឧបាសិកា គុន សម្ផត្តិ ១២.០០០រ
-ឧបាសក ស្ងួន អាន់ ១២.០០០រ
-ឧបាសិកា រ៉ី កោយ ១២.០០០រ
-ឧបាសក កាក់ លីន និងភរិយា ១២.០០០រ
-ឧបាសិកា សោ ១២.០០០រ

ពុទ្ធបរិស័ទខេត្តបន្ទាយមានជ័យ តាមរយៈឧបាសិកា ភ្ជឿន ម៉ុំ

-ពុទ្ធបរិស័ទវត្តតាហ៊ី (ស្វាយថ្មី) ១០.៩៥០០រ
-ពុទ្ធបរិស័ទជិតធ្វាយ និងពុទ្ធបរិស័ទពង្រ ៩២.៣០០រ
-ពុទ្ធបរិស័ទស្រុកមង្គលបូរី វត្តឫស្សីក្រោក ៨១.០០០រ
-ព្រះតេជគុណ សោម ទូច ជាចៅអធិការវត្តនិវេសន៍ ១៤.០០០រ
-ម៉ា មួន និងបុត្រ ១២.០០០រ
-ឧបាសិកា ស៊ីម៉ុន និងបុត្រ ១២.០០០រ
-ឧបាសិកា ចាន់ ហេង និងកូនចៅ ១២.០០០រ
-ឧបាសិកា យិញ ផាន់ អ៊ីឡាង និងបុត្រ ១២.០០០រ
-ឧបាសក ខាន់ ឈិត និងឧបាសិកា យឿន រ៉ិច្ចិកា ព្រមទាំងបុត្រ ១២.០០០រ
-ឧបាសិកា តាំង គីមមី ១២.០០០រ
-ឧបាសិកា កុល សុវណ្ណ និងបុត្រ ១២.០០០រ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

ពុទ្ធបរិស័ទ ភូមិកោះស្វាយ ស្រុកឃ្លាកាន ខេត្តពោធិ៍សាត់

-ញាន ជន និងកង ដាយ ព្រមទាំងបុត្រ ..... ២៦.០០០រ៉ៀ
-កង ណាង ..... ២៤.០០០រ៉ៀ
-យុង គានី ..... ១៥.០០០រ៉ៀ
-យុង សេត ..... ១៥.០០០រ៉ៀ
-ជិន កង និងញាន កន ..... ១៤.០០០រ៉ៀ
-គំ ឈូក និងយ៉ីប សុខា ..... ១៣.០០០រ៉ៀ
-ខា ហាង និងកង ណាក់ ..... ១៣.០០០រ៉ៀ
-កង សាយ ..... ១៣.០០០រ៉ៀ
-យ៉ាំង យុង ..... ១៣.០០០រ៉ៀ
-អ្នកស្រី យុង សារ៉ឿម ..... ១៣.០០០រ៉ៀ
-អ្នកស្រី ឆែម ឆយ ..... ១៣.០០០រ៉ៀ
-ជួន ឈឿន ..... ១៣.០០០រ៉ៀ
-ស្រឿម សារិត ..... ១៣.០០០រ៉ៀ
-ស៊ិត + សុផាត ..... ១៣.០០០រ៉ៀ
-ផល ភាព ..... ១៣.០០០រ៉ៀ
-ឆែម ឆាម ..... ១៣.០០០រ៉ៀ
-ឧបាសិកា យុង ចន្ធា ..... ១៣.០០០រ៉ៀ
-ឧបាសក ស៊ុំ ស្រឿន ..... ១៣.០០០រ៉ៀ
-ឧបាសក ស៊ុំ ស៊ីម ..... ១៣.០០០រ៉ៀ

ពុទ្ធបរិស័ទភូមិហាណ ឃុំហាណ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

-ឧបាសក ជា ហុង និងឧបាសិកា រ៉ីង ឌី ..... ២៤.០០០រ៉ៀ
-ឧបាសក ស្ងួន ឡាំង និងឧបាសិកា សេង ណារី ..... ២២.០០០រ៉ៀ
-ឧបាសិកា ចក់ ង៉ាន ..... ២០.០០០រ៉ៀ
-លោក ម៉ក់ គឹម និងអ្នកស្រី រ៉ុង សុកេង ..... ២០.០០០រ៉ៀ
-ឧបាសក រ៉ី ឈាន និងឧបាសិកា ស្ងួន បុប្ផា ..... ២០.០០០រ៉ៀ
-កញ្ញា យួម ចរិយា ..... ១៩.០០០រ៉ៀ
-លោក ង ប៊ុនថន និងអ្នកស្រី ឡឹម ភក្តី ..... ១៦.០០០រ៉ៀ
-ឧបាសក អ៊ឿ នុត និងឧបាសិកា ម៉ាន់ ហោ ..... ១៥.០០០រ៉ៀ
-កញ្ញា យួម កល្យាណ ..... ១២.០០០រ៉ៀ
-កំ ឡោះ យួម រ៉ាន់ឆាយ ..... ១២.០០០រ៉ៀ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

-លោកគ្រូពេទ្យ គន និងអ្នកស្រី ចាន់ ភាន់ ១២.០០០រ
-ឧបាសិកា លាំ ឆយ ១២.០០០រ
-ជឿន កញ្ញា ១២.០០០រ
-ឧបាសក សឿន សំណាង និងឧបាសិកា ម៉ា ស៊ីអ៊ី ១២.០០០រ
-លោក ជឿន ហួណា ១២.០០០រ
-លោក សួន ប៉ក់ និងអ្នកស្រី តូ ញ៉ង់ ១២.០០០រ
-ឧបាសក ម៉ក់ សួយ និងឧបាសិកា តូ គឹមហួន (ហៅញោម ម៉ាប់) ១២.០០០រ
-អ្នកស្រី ស៊ិន គឹមគី ១២.០០០រ
-ឧបាសក យ៉ុង និងឧបាសិកា នុត សារី ១២.០០០រ
-ឧបាសក តូ ឈឿន និងឧបាសិកា ផុង ១២.០០០រ
-លោកគ្រូពេទ្យ រៀប និងអ្នកស្រី ចន្ធា ព្រមទាំងបុត្រ ១២.០០០រ
-ឧបាសិកា ប៉ាន ឈាវ និងបុត្រ ១២.០០០រ
-ឧបាសិកា យ៉ិម ១២.០០០រ
-ឧបាសក ហុង និងឧបាសិកា ហ៊ុន ១២.០០០រ
-ឧបាសិកា ថែម ញ៉ែត ១២.០០០រ
-ឧបាសក រ៉ាត់ ធាវ ១២.០០០រ

ពុទ្ធបរិសំទវត្តគីរីវ៉ន្ត ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

-ពុទ្ធបរិស័ទរួមវត្តតាយ៉ែកឯកវង្ស៊ី ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប
តាមរយៈឧបាសិកា ស៊ីម យន់ ៦១៦.០០០រ
-សីអា សីអូន យាយ យ៉ាប ១៧.០០០រ
-លោកតា ម៉ូវ និងកញ្ញា មួង ១៥.០០០រ
-លោកតា ណាំង និងយាយ អ៊ុត ១៥.០០០រ
-លោក ហួន និងអ្នកស្រី សែន ១៤.០០០រ
-លោកតា គឹម និងយាយ ម៉ី ១៣.០០០រ
-លោក ង៉ាន ពុញ និងអ្នកស្រី ភូ ១២.០០០រ
-លោក ង៉ុង និងអ្នកស្រី សួង ១២.០០០រ
-លោក ធី និងអ្នកស្រី ម៉ុក ១២.០០០រ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

-លោក កែវ និងអ្នកស្រី លឿង ១២.០០០រ
-លោក ហ៊ីវ និងនាង ឡេង ,លោក សឿង និងនាង ឡាប ១២.០០០រ
-លោក សូវ៉ៃត និងនាង នីង ,លោក ហ៊ឿត និងនាង នាង ១២.០០០រ
-ឧបាសក កុក និងឧបាសិកា ផែ ព្រមទាំងបុត្រ ១២.០០០រ
-លោកគ្រូ ណារ៉ី និងភរិយា ,សាលី និងភរិយា ១២.០០០រ
-លោកតា ថោយ និងយាយ សឿង ១២.០០០រ
-ឧបាសក ប៉ាវ និងឧបាសិកា ឡៃ ១២.០០០រ
-ឧបាសក ភាព និងឧបាសិកា ដល់ ១២.០០០រ
-ឧបាសក ផុន និងឧបាសិកា ដួន ១២.០០០រ
-ឧបាសក ហួន និងឧបាសិកា ដិន ១២.០០០រ
-ឧបាសក សៅ និងឧបាសិកា ឫ ១២.០០០រ
-ឧបាសក ណម មាល់ និងឧបាសិកា ដូង ១២.០០០រ
-ឧបាសិកា រិន និងបុត្រ ១២.០០០រ
-លោកគ្រូ ណង និងនាង ទាវ ១២.០០០រ
-លោកតា ម៉ាន និងយាយ ដា ១២.០០០រ
-ឧបាសិកា រ៉ិន ១២.០០០រ
-ឧបាសក ហ៊ៀ សំគាត ១២.០០០រ
-ឧបាសក ធំ ម៉ាលី និងបុត្រ ១២.០០០រ

ពុទ្ធបរិស័ទភូមិអូរសទ្ធុក ស្រុកសន្លែ ខេត្តឃ្លាំងជ្រៃ តាមរយៈឧបាសក ធី រ៉ាន់

-លោក ស៊ី និងអ្នកស្រី ហ៊ៃ ព្រមទាំងបុត្រ ៥៥.០០០រ
-ពុទ្ធបរិស័ទវត្តស្វាយចាស់ ក្រុងសិរីសោភ័ណ ៣៨.០០០រ
-ឧបាសក ធី រ៉ាន់ និងភរិយា ព្រមទាំងបុត្រ ២០.០០០រ
-ឧបាសក ប៉ាន និងឧបាសិកា រិន ព្រមទាំងបុត្រ ១២.០០០រ
-ឧបាសក ស ង៉ាន និងឧបាសិកា រ៉ៀង ១២.០០០រ
-ឧបាសក ផ្ងើន និងឧបាសិកា រ៉ី ១២.០០០រ
-ឧបាសក ឃ្យៀម និងឧបាសិកា ណាត សឿន ១២.០០០រ
-ឧបាសិកា រ៉ាន់ ថាង ១២.០០០រ
-ឧបាសិកា ស្ពើង សាម ១២.០០០រ
-ឧបាសក រិន យ៉ាង ១២.០០០រ
-ឧបាសក រ៉ិន និងឧបាសិកា សាង ១២.០០០រ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

ពុទ្ធបរិស័ទវត្តសិម្ពលី ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល

-ព្រះតេជគុណ កិន ផល្លី ៨០.០០០រ
-ឧបាសិកា រឿន ភាព យ៉ាន ណាត់ យាយ រឿន ២២.០០០រ
-ឧបាសិកា ស៊ុន ភិន ១២.០០០រ
-ឧបាសក អ៊ុន ភិម និងឧបាសិកា ម៉ម សុត ១២.០០០រ
-ឧបាសិកា យាយ តេង ១២.០០០រ
-ឧបាសក ឃីម សេង ១២.០០០រ
-ឧបាសិកា វ៉ាន់ ១២.០០០រ
-ឧបាសិកា សម ម៉ែត ១២.០០០រ
-ឧបាសក គឹម រ៉ាជ និងឧបាសិកា ង្វ៉ូ រ៉ាសាល ១២.០០០រ
-ឧបាសក គាត ស៊ាងហេង និងឧបាសិកា ឡេង សុខអូន ១២.០០០រ
-ឧបាសក ចែម គឹមឈុន និងភរិយា ព្រមទាំងបុត្រ ១២.០០០រ
-ឧបាសក ង្វ៉ូ និងឧបាសិកា អាន ១២.០០០រ
-ឧបាសិកា រ៉ែន នៅ និងបុត្រ ១២.០០០រ
-ឧបាសក អ៊ីន ភិន ១២.០០០រ
-ឧបាសក រ៉ន រ្ជប ១២.០០០រ
-ឧបាសិកា រ៉ន រ៉ន ១២.០០០រ
-ឧបាសិកា រ៉ន មិន ១២.០០០រ
-ឧបាសិកា ទេព រ៉ី ១២.០០០រ
-ឧបាសក ញ៉ឹម រ៉ុម និងនួរ សុខន ១២.០០០រ
-ឧបាសិកា ភួង ក្រឹម ១២.០០០រ
-ឧបាសិកា ហ៊ី ទូច ១២.០០០រ
-ឧបាសក យស និងឧបាសិកា សុំ អុច ១២.០០០រ
-ឧបាសក គា និងឧបាសិកា យ៉ន ១២.០០០រ
-ឧបាសិកា គិម ឡាត់ ១២.០០០រ
-ឧបាសក ស៊ុន ស្ងើន និងឧបាសិកា ជុំ ឡូត ១២.០០០រ
-ឧបាសិកា ប៊ូ រស់ និងបុត្រ ១២.០០០រ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

-ឧបាសក ជា សយ និងឧបាសិកា គី សុខន ១២.០០០រ
-ឧបាសក សៅ សឿន និងឧបាសិកា សុន សាត់ ១២.០០០រ
-ឧបាសក សេង សុកា និងឧបាសិកា ម៉ី ចំណាន ១២.០០០រ
-ឧបាសក ចិន សារ៉ន ១២.០០០រ
-ឧបាសិកា ស៊ុន ត្ន ១២.០០០រ
-ឧបាសក សួស ជ័យ និងឧបាសិកា សុខ ហួយ ១២.០០០រ
-ឧបាសក ធេង ណុំ និងឧបាសិកា ទឹក ជា ១២.០០០រ
-ឧបាសក តុន ឃុន ១២.០០០រ
-ឧបាសក ណន និងឧបាសិកា មឿន ១២.០០០រ
-ឧបាសិកា សុក សិម ១២.០០០រ
-ឧបាសក អៀង ចែម និងឧបាសិកា គី សុខនី ១២.០០០រ
-លោកតា ចំរើន និងនាង កីន ១២.០០០រ
-ឧបាសិកា ពុំ ស៊ុំ ១២.០០០រ
-ឧបាសក សាន បុត និងឧបាសិកា យឹម ផ៉ត ១២.០០០រ
-ឧបាសិកា ភីម សារឿន ១២.០០០រ
-ឧបាសិកា សុខ ចាន ១២.០០០រ
-ឧបាសិកា លាស់ យ៉ុម និងកូនចៅ ១២.០០០រ
-ឧបាសក ឡុង ផង់ និងភរិយា ១២.០០០រ
-ឧបាសក ជួប ជឿន និងបុត្រ ១២.០០០រ
-ឧបាសិកា ស៊ូ រាម ១២.០០០រ
-ឧបាសក អ៊ីង ឌន និងឧបាសិកា ខាត់ នាវ ១២.០០០រ
-ឧបាសក ញ៉ែម រ៉ុន្នី ១២.០០០រ
-ឧបាសិកា វណ្ណៈ ស្រឿង ១២.០០០រ
-ឧបាសិកា ឯម រ៉ី ១២.០០០រ
-ឧបាសក អ៊ូរ សោភ័ណ ដា រ៉ា និងហុង ចន្ធី ១២.០០០រ
-ឧបាសិកា ប៉ូវ បុំ ១២.០០០រ
-ឧបាសិកា សុខ ហ៊ុន និងឧបាសិកា ផ៉ត ១២.០០០រ
-ឧបាសិកា អូន លី ១២.០០០រ

ពុទ្ធបរិសំទក្រុងបាត់ដំបង

-ឧបាសក សក់ មី និងឧបាសិកា ឈ្ម ងីមលី ព្រមទាំងបុត្រ ..... ៥ ក្បាល
-ឧបាសក ហម ញង និងឧបាសិកា អ៊ុន ធីន ព្រមទាំងកូន + ក្មួយ ..... ៤ ក្បាល

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

-លោក ហាំង ឡេង និងអ្នកស្រី គឹម គី
-លោក រ៉ូ សេងវ៉ី និងអ្នកស្រី ហាំង គឹមមួយ ..... ៣ ក្បាល
-ព្រមទាំងបុត្រ
-លោកស្រី សំ សំណាង និងបុត្រ ..... ២ ក្បាល
-លោក ឈុន ស្រេង និងអ្នកស្រី ហ៊ុន វិទូ (ស្រីវ៉ី) ..... ២ ក្បាល
-ឧបាសិកា អ៊ាម អ៊ិន និងកូនចៅ ..... ២ ក្បាល
-ឧបាសិកា គុជ ជូ និងស្វាមី ព្រមទាំងកូនចៅ ..... ២ ក្បាល
-កញ្ញា សួន សុកី និងម្តាយ ព្រមទាំងបងប្អូន ..... ២ ក្បាល
-ឧបាសិកា ច័ន្ទ សារ៉ីន មន្ត្រីមន្ទីរវប្បធម៌ និងវិចិត្រសិល្ប:ខេត្ត ..... ១ ក្បាល
-ឧបាសក នូ សុខុន និងឧបាសិកា អ៊ុង គឹមសិន ព្រមទាំងកូនចៅ ..... ១ ក្បាល
-ឧបាសក ញេប រៀន និងឧបាសិកា ឌុក តុមព្រមទាំងកូនចៅ ..... ១ ក្បាល
-ឧបាសក អ៊ុក សំអុន និងឧបាសិកា វណ្ណារ៉ី ព្រមទាំងបុត្រ ..... ១ ក្បាល
-ឧបាសិកា លឹម សុខដ៏ម និងកូនចៅ (អាជីវករផ្សារណាត់) ..... ១ ក្បាល
-លោកស្រី គាំ ចន្ទ ហៅស្រីម៉ៅ ..... ១ ក្បាល
-លោកស្រី រស់ ហ៊ាង និងវ៉ែន ទូច ព្រមទាំងបុត្រ ..... ១ ក្បាល
-ឧបាសិកា តោ និត និងស្វាមី ព្រមទាំងបុត្រ ..... ១ ក្បាល
-លោកស្រី យ៉ាន ហម និងលោក ជួន រ៉ាវុធ ..... ១ ក្បាល
-លោកស្រី គង់ សុគន្ធា និងលោក ចាន់ សារ៉ាយ ..... ១ ក្បាល
-លោកស្រីវេជ្ជបណ្ឌិត ហ៊ីល សុមុន្នី មន្ត្រីមន្ទីរពេទ្យបង្អែកបាត់ដំបង ..... ១ ក្បាល
-ឧបាសិកា ជា វណ្ណ៊ី និងកូនចៅ រាជធានីភ្នំពេញ ..... ១ ក្បាល
-ឧបាសិកា ណុប នារ ព្រមទាំងកូនចៅ ..... ១ ក្បាល
-លោកស្រី លឹម សុខដ៏ម ..... ១ ក្បាល
-លោកស្រី ភោគ ឡាវ៉ិច និងស្វាមី ព្រមទាំងបុត្រ .... ១ ក្បាល
-លោកស្រី ភៅ គឹមធុំ និងស្វាមី+បុត្រ មន្ត្រីការិយាល័យវប្បធម៌ ..... ១ ក្បាល
-លោក ខឹម រ៉ុន្ធី និងអ្នកស្រី ង៉ែន វណ្ណ៊ី ព្រមទាំងកូនចៅ ..... ១ ក្បាល
-លោក សំ សុន និងអ្នកស្រី គឹម ចំ រ៉ាត់ ព្រមទាំងបុត្រ ..... ១ ក្បាល
-ឧបាសិកា ព្រម យួម និងកូនចៅ ..... ១ ក្បាល

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

-អ្នកស្រី នូវ សុកាព និងកូនចៅ ..... ១ ក្បាល
-ឧបាសិកា ង៉ាន់ គ្រី (ហៅលោកយាយ អាន) និងកូនចៅ ..... ១ ក្បាល
-ឧបាសក ចាន់ ឌាយ និងឧបាសិកា រស់ សាគាំ ..... ១ ក្បាល
-លោក ត្រែង រ៉ុទ្ធី និងភរិយា ព្រមទាំងកូនចៅ ..... ១ ក្បាល
-ពុទ្ធបរិស័ទអ្នកដែលចូល ១០.០០០៛ មានចំនួន ៧៥ នាក់ = ... ៧៥០.០០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ៨.០០០៛ មានចំនួន ២ នាក់ = ... ១៦.០០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ៧.០០០៛ មានចំនួន ៧ នាក់ = ... ៥៦៥.០០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ៦.០០០៛ មានចំនួន ១២ នាក់ = ... ៧២.០០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ៥.០០០៛ មានចំនួន ១៥៤ នាក់ = ... ៧៧.០០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ៤.០០០៛ មានចំនួន ១៤ នាក់ = ... ៥៦.០០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ៣.០០០៛ មានចំនួន ៦០ នាក់ = ... ១៨០.០០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ២.៥០០៛ មានចំនួន ១០ នាក់ = ... ២៥.០០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ២.០០០៛ មានចំនួន ១៨៤ នាក់ = ... ៣៦៨.០០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ១.៥០០៛ មានចំនួន ២៣ នាក់ = ... ៣៤.៥០០៛
-ពុទ្ធបរិស័ទអ្នកដែលចូល ១០០០៛ មានចំនួន ៦២ នាក់ = ... ៦២.០០០៛

ពុទ្ធបរិស័ទវត្តធម្មសាមគ្គី ប្រទេសអូស្ត្រាលី
តាមរយៈព្រះតេជគុណ ញាណសរណោ ឃឿ ឫម

-ឧបាសិកា អ៊ិន ម៉ា ..... ១.៣៣០ AUD
-លោក លីចន្ធា សុខ និងភរិយា ព្រមទាំងបុត្រ ..... ៣០០ AUD
-ឧបាសិកា លី មួយហុង និងកូនចៅញាតិមិត្ត ..... ២៣០ AUD
-ព្រះតេជគុណ **ញាណសរណោ** ឃឿ ឫម .... ២០៥ AUD
-ឧបាសក មង្គ ផន និងឧបាសិកា ឃូ គឹមណាប ព្រមទាំងបុត្រ ..... ២០០ USA
-ឧបាសក ស៊ីវ កែវ និងឧបាសិកា ស៊ីវ ឡៃហៀង ព្រមទាំងបុត្រ ..... ១០០ AUD
-ឧបាសក ស៊ីវ មាស និងឧបាសិកា លាង ណាំសួរ ព្រមទាំងបុត្រ ..... ១០០ AUD
-ឧបាសក ស៊ូ ឃីម និងឧបាសិកា ស៊ូ សៀងតិច ព្រមទាំងបុត្រ ..... ១០០ AUD
-ឧបាសក ប៉ុច រឿត និងឧបាសិកា ញ្ជូង សៀងម៉ើង ព្រមទាំងបុត្រ ..... ១០០ AUD
-ឧបាសិកា លី ហៃស៊ីម និងកូនចៅ ..... ១០០ AUD
-ឧបាសក តាំង ហេង និងឧបាសិកា ឈូ អៀ ព្រមទាំងឧបាសិកា តាំង សួយមួយ . ១០០ AUD
-ឧបាសិកា ប៉ែន ឡិ និងបុត្រ ..... . ១០០ AUD
-ឧបាសិកា យឹម សុឃឿន និងគ្រួសារ ..... ៨០ AUD
-ឧបាសិកា ទូ ធុច និងកូនចៅ ..... ៦០ AUD

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

-ឧបាសក អ៊ីង ស្បោង និងឧបាសិកា អ៊ីង ណាំសៀង ព្រមទាំងបុត្រ ..... ៥០ AUD
-ឧបាសក អុន តុង និងគ្រួសារ ..... ៥០ AUD
-ឧបាសិកា អេម និងកូនចៅ ..... ៥០ AUD
-ឧបាសិកា ហុង គឹមហួយ ព្រមទាំងបុត្រ ..... ៥០ AUD
-ឧបាសក ស៊ូ សុផានី និងឧបាសិកា អេង ស្រ៊ុន ព្រមទាំងបុត្រ ..... ៥០ AUD
-លោក ហេង សុផុន និងអ្នកស្រី ប៉ុច រៀលី ព្រមទាំងបុត្រ ..... ៥០ AUD
-លោក ប៉ុច រិទ្ធី និងអ្នកស្រី ម៉ែន ចិន្តា ព្រមទាំងបុត្រ ..... ៥០ AUD
-លោក ផ្ទួន ពិសិដ្ឋ ..... ៥០ AUD
-ឧបាសក ហេង ខេងប៉ាង និងគ្រួសារ ..... ៥០ AUD
-ឧបាសិកា សេង សៀងឈុន និងបុត្រ .... ៥០ AUD
-ឧបាសិកា សុខ លាងស៊ីម និងគ្រួសារ ..... ៥០ AUD
-លោក ហេង គង់ និងអ្នកស្រី លី វណ្ណា ..... ៥០ AUD
-អ្នកស្រី ផល្លា ..... ៥០ AUD
-ឧបាសិកា តាំង ឆេងហួង និងកូនចៅ ..... ៥០ AUD
-ឧបាសិកា លឹម ឈីវយី និងកូនចៅ .... ៥០ AUD
-ឧបាសក លឿង កែម និងឧបាសិកា ប្រាក់ សារិន ព្រមទាំងបុត្រ ..... ៥០ AUD
-ឧបាសិកា ឯម ផាន់យ៉ា និងបុត្រ ..... ៥០ AUD
-ឧបាសិកា ស៊ុក ពេជវ៉ៃ ..... ៥០ AUD
-ឧបាសិកា ម៉ោ បួយ និងកូនចៅ ..... ៥០ AUD
-ឧបាសិកា កែវ សារ៉ុត និងឧបាសិកា មុត សារត ព្រមទាំងស្វាមី និងបុត្រ ..... ៥០ AUD
-លោក គឹម គ្រី និងបុត្រ ..... ៥០ AUD
-អ្នកស្រី ប៉ែន ប៊ុនណា និងបុត្រ ..... ៥០ AUD
-លោក ជី និងអ្នកស្រី ជីណា ព្រមទាំងបុត្រ ..... ៥០ AUD
-ឧបាសិកា បាក់ លី ឡេង ហ៊ាង និងកូនចៅ ..... ៨០ AUD
-ឧបាសិកា ឡុង អ៊ឿ និងបុត្រ ..... ៨០ AUD
-ឧបាសិកា សេង ប៊ុនលី និងកូនចៅ ..... ៣០ AUD

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

-លោក ទ្រី និងអ្នកស្រី មុំ ព្រមទាំងបុត្រ ..... ៣០ AUD
-ឧបាសិកា សៅ ស្រីទូច និងកូនចៅ ..... ៣០ AUD
-ឧបាសិកា ទុយ ហេង និងកូនចៅ ..... ៣០ AUD
-ឧបាសិកា សេង ប៊ុនលីម និងបុត្រ ..... ៣០ AUD
-ឧបាសិកា ហួយ ខេង និងកូនចៅ ..... ៣០ AUD
-លោក ជ័យ ជិន និងភរិយា ព្រមទាំងបុត្រ ..... ៣០ AUD
-លោក គិម ហៀន និងអ្នកស្រី គិម នី ព្រមទាំងកូនៗ ..... ២៥ AUD
-លោក ចាន់ណា សុខខេង ..... ២៥ AUD
-ឧបាសក សរ ប៊ុនធឿង និងកូនចៅ ..... ២០ AUD
-ឧបាសិកា ទា ថោហ៊ាង .... ២០ AUD
-ឧបាសិកា ទូច ឆេង ..... ២០ AUD
-ឧបាសិកា គិម ចាល់ ..... ២០ AUD
-លោក អ៊ុំ ជារិទ្ធ និងអ្នកស្រី រាជ ផល្លា ព្រមទាំងបុត្រ ..... ២០ AUD
-អ្នកស្រី បុប្ផា កិន និងគ្រួសារ ..... ២០ AUD
-លោក ថា រេន និងភរិយា ព្រមទាំងបុត្រ ..... ២០ AUD
-អ្នកស្រី ប៊ុន រី ..... ២០ AUD
-ឧបាសក រាជ ស៊ាង និងឧបាសិកា រង្ស រិទ្ធ ព្រមទាំងបុត្រ ..... ២០ AUD
-លោក លី សៀងថេង និងអ្នកស្រី ឆវី ចន្ទ្ររស្មី ព្រមទាំងបុត្រ ..... ២០ AUD
-ឧបាសិកា ដួង រ៉ុន ..... ២០ USA
-លោក លី គឹមណាល់ និងអ្នកស្រី លេន សុភាព ព្រមទាំងបុត្រ ..... ២០ USA
-កញ្ញា អេលីហ្ស្រាបែត មឿង ..... ២០ AUD
-ឧបាសិកា រ័ត្ន គឹមសាន ..... ២០ AUD
-ឧបាសិកា តាំង ឆេងលន់ និងកូនចៅ ..... ២០ AUD
-ឧបាសិកា លឹម ហ៊ាង និងកូនចៅ ..... ២០ AUD
-លោក ស៊ីវ ស្រេង និងអ្នកស្រី សេង លិនដា ព្រមទាំងបុត្រ ..... ២០ AUD
-លោក គិម គូ និងអ្នកស្រី គិម ផេង ..... ២០ AUD
-លោក គិម ឡេង និងអ្នកស្រី ស៊ីវ ឡាង ..... ២០ AUD
-ឧបាសិកា មោក ម៉ី និងកូនចៅ ..... ២០ AUD
-អ្នកស្រី ឡៅ សុខ៉ាន់ និងកូនចៅ ..... ២០ AUD
-អ្នកស្រី ព្រំ សារឿន និងកូនចៅ ..... ២០ AUD

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

-savugh សុខ និងកូនចៅ ..... ២០ AUD
-កុមារ សោ សទ្ធា ..... ២០ AUD
-ហែម នារី ..... ២០ AUD
-ឧបាសិកា ជ័យ សារិម និងស្វាមី ព្រមទាំងបុត្រ ..... ២០ AUD
-លឹម រួចទៀង ..... ២០ AUD
-ឧបាសិកា ជា ស៊ិន ..... ២០ AUD
-ឧបាសិកា ឈូ គឹមបួយ ..... ២០ AUD
-ឧបាសិកា សុខ ឡាង ..... ២០ AUD
-ឧបាសិកា ម៉ម នាង ..... ២០ AUD
-ជីប វ៉ាន់ឌី ..... ២០ AUD
-លោក ប៊ុនលាក និងភរិយា ព្រមទាំងបុត្រ ..... ២០ AUD
-លោក នន និងអ្នកស្រី អ៊ី សន ..... ២០ AUD
-ឧបាសក ឃិន អ៊ីន ..... ២០ AUD
-ឧបាសិកា ធន់ ជារី ..... ២០ AUD
-ង្វ៉ូ មុយឆែ ..... ២០ AUD
-យ៉ិន មួយឡាង ..... ២០ AUD
-ឧបាសិកា លាង ប៊ុនហុង និងបុត្រ ..... ២០ AUD
-ឧបាសិកា តូច ផល្លា និងកូនចៅ ..... ១៥ AUD
-ឧបាសិកា ក្ងូ ..... ១០ AUD
-ឧបាសិកា គឹម សួរហុន ..... ១០ AUD
-លោក សុផាណា អ៊ីង និងគ្រួសារ ..... ១០ AUD
-ឧបាសិកា ទន់ ហេង ..... ១០ AUD
-ឧបាសិកា តាន់ គឹមហាប់ ..... ១០ AUD
-អ្នកស្រី លី ហុង ..... ១០ AUD
-អ្នកស្រី ឡុង ស៊ីដែត ..... ១០ AUD
-លោក ជា ហុង និងអ្នកស្រី រួច លាង ព្រមទាំងបុត្រ ..... ១០ AUD
-ឧបាសិកា ឌី ឡេង ..... ១០ AUD

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន ឈ្នះអស់ទានទាំងពួង

-ឧបាសិកា តែ ពា ..... ១០ AUD
-ឧបាសិកា ឡាយ មួយហាង ..... ១០ AUD
-អ្នកស្រី ព្រុំ សូកី និងកូនស្រី ..... ១០ AUD
-ឧបាសិកា ដួន ..... ១០ AUD
-អ្នកស្រី សរ ភ្ជង ..... ១០ AUD
-ឧបាសិកា ពុត សុខដ្ឋា ..... ១០ AUD
-ឧបាសក តារា និងឧបាសិកា ឈីវ ប៊ីយ ..... ១០ AUD
-ខ្ជូ ខិលី និងខ្ជូ អិនឡូ ..... ១០ AUD
-ឧបាសិកា អេង ព្រុំ ..... ១០ AUD
-លោក សុខ ទី និងគ្រួសារ ..... ១០ AUD
-ឧបាសិកា សុខ ប៊ុណ្ណា និងគ្រួសារ ..... ១០ AUD
-ឧបាសិកា ង្ហ្ជ មួយធ្ងៃ ..... ១០ AUD
-កញ្ញា សូកា ..... ១០ AUD
-ឧបាសិកា ម៉ា យី ..... ១០ AUD
-អ្នកស្រី ចរិយា និងស្វាមី ព្រមទាំងបុត្រ ..... ១០ AUD
-ជ្ជីប រ៉ាន់ឌ្ឌី ..... ១០ AUD
-លោក ផេក ជាន ..... ៦ AUD
-អ្នកស្រី ជា រ៉ាមី ..... ៥ AUD
-ឧបាសិកា កែម ឃីម ..... ៥ AUD
-ឧបាសិកា ចៅ គុយយិន និងកូន ..... ៥ AUD
-ឧបាសិកា លី អេង និងកូនចៅ ..... ៥ AUD
-ឧបាសិកា ទីម ប៊ុនធី ..... ៥ AUD
-ឧបាសិកា ចាន់ ឋន ..... ៥ AUD
-ឧបាសិកា ចាន់ ឌី ..... ៥ AUD
-អ្នកស្រី ឌ្ជ បុទា ..... ៥ AUD
-ម៉ីង សៀត ..... ៥ AUD
-យាយ ហាយ សេង ហាង ..... ៥ AUD
-អ្នកស្រី ហ្ជូ សូហាង ..... ៥ AUD
-អ៊ីង គារ ..... ៥ AUD
-លោក សុធា សេង ..... ៥ AUD
-ឧបាសិកា សៀង ភ្ជ្ជ និងបុត្រ .....
-ឧបាសក ឈាង ហ៊ីង និងឧបាសិកា សំ នារីពៅ ព្រមទាំងបុត្រ .....
-អ្នកស្រី ជា សុណាលីយ .....
-ឧបាសក សំ យ៉ា .....
-ឧបាសក សំ សុខគុណ និងឧបាសិកា លី សៀមហ្ជៀង ព្រមទាំងបុត្រ .....